# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា



1

សុបិនមួយពីអតីតតកាល និយាយរហូតដល់បច្ចុប្បន្ននេះ


2

ថ្ងៃមួយ អ្នកចេះដឹងជ្រៅជ្រះម្នាក់បានធ្វើដំណើរតាមរទេះភ្លើងមួយខ្សែ ដែលកំពុង ស្លុងអារម្មណ៍ទៅក្នុងការអានសៀវភៅរបស់គាត់។

អ្នកឆែកសំបុត្ររថភ្លើងបានដើរមកជិត គាត់ ហើយបានទារកសំបុត្ររថភ្លើង។ បុរសនោះបានលូកដៃចូលក្នុងហោ ប៉ៅទាំងអស់របស់គាត់ ប៉ុន្តែរកសំបុត្រមិនឃើញសោះ។ គាត់បានចាប់ផ្តើមពិនិត្យម្តងទៀត ជំនួសឱ្យការអន្ទះសារនេះវិញ។

ឃើញដូច្នោះ អ្នកឆែកសំបុត្របាន និយាយ ដោយសុភាពរាបសារថា "មិនអីទេលោក នៅពេលណាដែលលោករកវាឃើញ សូមលោកផ្ញើវាទៅកាន់ ក្រុមហ៊ុនចុះ។ ខ្ញុំជឿថា លោកពិតជាមានសំបុត្រនោះហើយ។

បុរសនោះឆ្លើយផ្ទាញ់ទៅវិញទាំង ភ័យរកគិតមិនទាន់ "ប៉ុន្តែអ្នកមិនយល់ទេ ខ្ញុំត្រូវតែរកវាឱ្យឃើញឥឡូវនេះ! ខ្ញុំត្រូវការ សំបុត្រនោះ ដើម្បីឱ្យដឹងថា តើខ្ញុំនឹងត្រូវទៅកន្លែងណាលើពិភពលោកនេះ!"

មនុស្សរាប់លាននាក់ លើពិភពលោកនេះ កំពុងសួរនៅពេលយប់នេះថា "តើយើង កំពុងធ្វើដំណើរឆ្ពោះទៅទីណា ក្នុងលោកនេះ? អនាគតនឹងកើតឡើងមិនច្បាស់លាស់ឡើយ។

ពួកគេពោរពេញទៅដោយការច្របូក ច្របល់។ ពួកគេមានការងឿងឆ្ងល់ថា តើ ពិភពលោក នេះកំពុងធ្វើដំណើរឆ្ពោះទៅ ឯណា?

យើងមិនត្រូវងឿងឆ្ងល់ទៅទៀតឡើយ។ សុបិននិមិត្តរបស់ស្តេចជំនាន់ដើមមួយអង្គ កាលពី២៥០០ឆ្នាំមុន បានគូសបង្ហាញអំពី ប្រវត្តិរបស់ពិភពលោកយើងនេះ។



3

(វីដេអូ ១០វិនាទី)

អ្នកវិទ្យាសាស្ត្របាននិយាយថា យើង ម្នាក់ៗ តែងតែយល់សប្តិបីបួនដងក្នុងមួយ យប់ៗ។ ភាគច្រើននៃយល់សប្តិរបស់យើងទាំងអស់ នោះ យើងមិនបានចាំឡើយ។


4

សុបិនដ៏គួរឱ្យកត់សំគាល់បំផុត ដែលបានកត់ត្រាអំពីប្រវត្តិសាស្ត្រទាំងអស់ ដែលបានកើតមានឡើងនារាត្រីមួយ កាលពី២៦០០ឆ្នាំកន្លងមក នៅក្នុងព្រះរាជា ណាចក្របាប៊ីឡូនពីបុរាណនោះដែរ។ ប្រវត្តិសាស្ត្រនៃសុបិននេះ ត្រូវបានគេកត់ ត្រាទុកជាឯកសារយ៉ាងត្រឹមត្រូវ ហើយត្រូវ បានសរសេរ និងនិយាយប្រាប់ដោយមនុស្ស ដែលបានយល់សុបិននោះ។

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា



5

ព្រះគម្ពីរដានីយ៉ែលជំពូកទី២ និយាយ អំពីរឿងនេះ។

ទោះជាយ៉ាងនេះក៏ដោយ ក៏ស្តេចដែល បានយល់សុបិននោះ គឺព្រះចៅនេប៊ូក្នេសា ដ៏មានអំណាចមិនអាចនឹកឃើញ នូវអ្វីដែល ទ្រង់បានសុបិនឃើញនោះឡើយ។

ព្រះអង្គទ្រង់ជ្រាបថា សុបិននោះ ជា សុបិនចម្លែក។

ទ្រង់ជ្រាបថា ជាសុបិនដ៏អាថ៌កំបាំង នោះ ពិតប្រាកដជាមានអត្ថន័យយ៉ាងសំខាន់ អស្ចារ្យ។ តាមពិត គឺមានដូច្នោះមែន។


6

ព្រះអម្ចាស់បានប្រទានដល់ទ្រង់នូវសុបិន និមិត្តមួយ ដែលបានគូសបញ្ជាក់នូវចំណុច សំខាន់ៗ សម្រាប់ប្រវត្តិសាស្ត្រ របស់ពិភព លោកយើងនេះ ជាពិសេសចំពោះប្រទេស អឺរ៉ុប និងមជ្ឈិមបូព៌ា ចាប់តាំងពីសម័យ ព្រះចៅនេប៊ូក្នេសា រហូតដល់បំផុតកល្ប។


7

សូមអរគុណព្រះអង្គដែលទ្រង់បានចែក ចាយជាមួយយើងនូវដំណើរនៃអនាគតនេះ។ បាប៊ីឡូនគឺជាចក្រភពដំបូងដែលធំជាងគេ មានស្តុកស្តម្ភជាងគេ និងជាអាណាចក្រ ដែលមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើប្រ ទេសទាំងឡាយដែលល្បីថាជឿនលឿននៅ សម័យនោះ។

វាក៏មានស្តេចដែលមានអំណាចជាងគេបំ ផុតផងដែរ។ អ្នកដឹកនាំរូបនេះបានរៀបចំកងទ័ពដើម្បីផ្តួល រំលំបច្ចាមិត្តរបស់ខ្លួនម្តងមួយៗរហូតដល់នគរ របស់ទ្រង់បានតាំងឡើងជាព្រះរាជនីនៃនគរ ទាំងឡាយ


8

នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលរបស់ទ្រង់ ព្រះចៅនេប៊ូក្នេសាបានយាងចូលកាន់ក្រឡាបន្ទំដោយមានព្រះទ័យខ្វល់ខ្វាយថា តើព្រះរាជា ណាចក្ររបស់ព្រះអង្គ នឹងអាចស្ថិតស្ថេរ បានយូរប៉ុនណា។ ព្រះអង្គក៏ដូចជាអ្នកដឹកនាំ ដទៃទៀតដែរ ដែលតែងតែចង់ដឹងអំពី អនាគតនោះ។

នៅយប់នោះ ព្រះទ្រង់ទតមើលពីស្ថាន សួគ៌មក ហើយបានជ្រើសរើស ផ្ទុកផ្តាក់ លើអ្នកកាន់អំណាចផ្តាច់ការ ដែលមាន ចិត្តមេត្តានេះ នូវការប្រមើលមើលអំពី អនាគតមួយ។

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា


9

នៅពេលដែលស្តេចបានតើនឡើងពីការ ផ្ទំលក់យ៉ាងស្កប់ស្កល់ របស់ទ្រង់ពីព្រលឹម នោះទ្រង់មានព្រះហឫទ័យតក់ក្រហល់ យ៉ាងខ្លាំង។

ព្រះអង្គបានមានសុបិននិមិត្តយ៉ាងធំ ប៉ុន្តែទ្រង់ប្រមើលមើលទៅ មិនអាចនឹក ឃើញថាទ្រង់សុបិនឃើញពីអ្វីនោះឡើយ។

សុបិន គឺជាការសំខាន់យ៉ាងខ្លាំងសម្រាប់ ពួកបាប៊ីឡូន ហើយព្រះរាជាចង់ជ្រាបយ៉ាង ខ្លាំងអំពីសុបិន និងអត្ថន័យរបស់សុបិននោះ


10

ជាការពិតហើយ ស្តេចមានគ្រូគន់គូរ នក្ខត្តឫក្សតាមផ្កាយ គ្រូធ្មប់ គ្រូផ្លិនភ្នែក និងគ្រូមន្តអាគមជាច្រើន ដូច្នេះពួកគេអាច ទូលទ្រង់ថា តើសុបិននោះមានន័យយ៉ាង ណាបាន។

ហេតុនោះហើយ បានជាពួកគេត្រូវបាន ស្តេចកោះហៅឱ្យឡើងកាន់រោងជំនុំពីព្រ ហាម។

នៅពេលដែលពួកគេបានមកដល់ ហើយឈរនៅចំពោះស្តេច ព្រះអង្គទ្រង់មានព្រះបន្ទូលទៅកាន់ពួកគេថា។


11

(ព្រះគម្ពីរ ដានីយ៉ែល ២:៣)

"អញបានយល់សប្តិ ហើយមានវិញ្ញាណ រឹងស៊ុង ដោយចង់ដឹងន័យក្នុងសប្តិនោះ" ដានីយ៉ែល ២:៣


12

បុរសទាំងអស់នោះគឺជាអ្នកដែលតាំង ខ្លួនជាអ្នកដឹង និងអាចប្រាប់ពីអនាគតបាន។ គេអាចថ្វាយយោបល់ដល់ស្តេចក្នុងការកាត់ ស្រាយសុបិននោះ ប៉ុន្តែគេពិតជាមិនអាចដឹងអំពីអត្ថន័យនៃសុបិននោះបានឡើយ។

ពួកគេបានបង្អង់បន្តិច រួចនិយាយថា


13

(ព្រះគម្ពីរ ដានីយ៉ែល ២:៤)

"...បពិត្រព្រះករុណា សូមទ្រង់មាន ព្រះជន្មគង់វង្សទៅ សូមទ្រង់មានបន្ទូលប្រាប់សុបិននោះមកយើងខ្ញុំជាបាវបំរើចុះ នោះយើងខ្ញុំនឹងកាត់ស្រាយថ្វាយទ្រង់ជ្រាប"

ប៉ុន្តែសេចក្តីទុកចិត្តផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវបានក្លាយជាអសារឥតការភ្លាម ក្នុងខណៈពេលដែលព្រះមហាក្សត្រដ៏ មាន អំនួតបានធុញទ្រាន់ ហើយបញ្ឈប់ការពន្យាពេលរបស់គេដោយមានបន្ទូលថា


14

(ព្រះគម្ពីរ ដានីយ៉ែល ២:៥,៦)

"តែព្រះមហាក្សត្រមានព្រះរាជឱង្ការទៅកាន់គ្រូទាយពួកខាល់ដេទាំងនោះវិញថា យើងបានសម្រេចចិត្តដូចតទៅ

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


15

ប្រសិនបើអ្នករាល់គ្នាមិនប្រាប់ឱ្យយើង ដឹងអំពីសុបិន ព្រមទាំងកាត់ស្រាយអត្ថន័យ ទេ នោះយើងនឹងកាត់ចិញ្ច្រាំអ្នករាល់គ្នា។


16

ហើយដុតផ្ទះអ្នករាល់គ្នាឱ្យទៅជាផេះទៀតផង


17

ផ្ទុយទៅវិញ ប្រសិនបើអ្នករាល់គ្នាប្រាប់ឱ្យ យើងដឹងអំពីសុបិន ព្រមទាំងកាត់ស្រាយ ន័យ យើងនឹងឱ្យរង្វាន់ដ៏មានតម្លៃ


18

និងយសស័ក្តិដ៏ខ្ពង់ខ្ពស់ដល់អ្នករាល់គ្នាទៀត ផង។ ដូច្នេះ អ្នករាល់គ្នា ត្រូវតែប្រាប់ឱ្យ យើងដឹងអំពីសុបិននិងអត្ថន័យរបស់វា” (ព្រះគម្ពីរភាសាខ្មែរសម្រាយ ២៤.៦)


19

ម្តងហើយ ម្តងទៀត ពួកគេនៅតែទូល ស្តេចសុំឱ្យប្រាប់ដល់ពួកគេនូវយល់សប្តិនោះ។ ពេលនោះ ស្តេចបានជ្រាបថា ពួកគេជា ហោរាក្លែងក្លាយ ព្រះអង្គបានគំរាមពួកគេ ម្តងទៀត ហើយទីបំផុតពួកគេក៏បាន សារភាព។


20

(ព្រះគម្ពីរ ដានីយ៉ែល ២:១០,១១)

“តែពួកខាល់ដេរគេទូលឆ្លើយនៅចំពោះ

ស្តេចថា គ្មានមនុស្សណាមួយនៅលើផែនដី នេះ ដែលអាចនឹងបង្ហាញ ពីដំណើរនៃព្រះ ករុណាបានទេ


21

ក៏មិនដែលមានស្តេចណា ទោះបើធំហើយ មានអំណាចយ៉ាងណាក៏ដោយ ដែលបាន បង្គាប់ការយ៉ាងនេះដល់ពួកគ្រូមន្តអាគម គ្រូអង្គុយធម៌ ឬដល់ពួកខាល់ដេរណាៗឡើយ។


22

....គ្មានអ្នកណាអាចនឹងបង្ហាញដំណើរ នេះដល់ព្រះករុណាបានទេ មានតែពួកព្រះ ដែលមិនស្ថិតនៅក្នុងសាច់ឈាមវិញប៉ុណ្ណោះ”ដានីយ៉ែល ២:១០,១១

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា



23

ព្រះគម្ពីរបានសំដែងថា ស្តេចទ្រង់បាន មានព្រះទ័យខ្ញាល់ខ្លាយយ៉ាងខ្លាំង ហើយ បានបង្គាប់ដល់ទាហានរបស់ទ្រង់ ឱ្យប្រ ហារជីវិតដល់ពួកគ្រូទាំងអស់នោះ។



24

ជាអកុសល ហោរាដានីយ៉ែល និង កម្លោះជនជាតិហេព្រើរ(អ៊ីស្រាអែល)បីនាក់ ទៀតនោះ ក៏ត្រូវមានឋានៈនៅក្នុងពួក អ្នក ប្រាជ្ញរបស់ស្តេចដែរ ទោះបីជាពួកគេមិន បាននៅក្នុងឱកាសដែលព្រះរាជាបានបង្គាប់ ឱ្យប្រាប់និងកាត់ស្រាយសប្តិរបស់ទ្រង់នោះក៏ ដោយ។

នៅពេលដែលទាហានបានចាប់ហោរា ដានីយ៉ែលយកទៅសម្លាប់ គាត់មានការ ភាន់ភាំង ប៉ុន្តែគាត់បានសុំអនុញ្ញាតឱ្យគេ ពន្យាពេលឱ្យគាត់ ដើម្បីគាត់បានទូលទៅ ព្រះ ដែលបល្ល័ង្ករបស់ទ្រង់មិនមែននៅជា មួយមនុស្ស និងទូលសូមប្រាជ្ញាពីទ្រង់ ដើម្បីទូលយល់សប្តិនោះថ្វាយស្តេចជ្រាប

(២១២-១៥)



25

ព្រះរាជាមានការកោតសរសើរចំពោះការ ស្មោះត្រង់របស់យុវជននេះ ក៏បានប្រទាន ពេលវេលាឱ្យដានីយ៉ែល ទូលទៅដល់ព្រះ របស់គាត់ ជាព្រះដែលបង្កើតលោកីយ៍។ ដានីយ៉ែលមានបន្ទុកយ៉ាងធ្ងន់នៅលើស្មា

មិនមែនគ្រាន់តែអាយុជីវិតរបស់គាត់ ផ្ទាល់ និងមិត្តភ័ក្តិរបស់គាត់ប៉ុណ្ណោះទេ ដែលនឹង ត្រូវជួបប្រទះនូវវាសនាអាក្រក់ ប៉ុន្តែគឺជីវិតរបស់អ្នកប្រាជ្ញទាំងអស់នៅ បាប៊ីឡូន។

ដានីយ៉ែលបានត្រឡប់ទៅផ្ទះរបស់គាត់ វិញ ហើយបានពន្យល់ហេតុការណ៍ទាំង អស់នេះដល់មិត្តរបស់គាត់។



26

ពួកគេបានទូលអង្វរសុំសេចក្តីមេត្តា ករុណាពីព្រះនៃស្ថានសួគ៌ ឱ្យបង្ហាញនូវការ អាថ៌កំបាំងនេះដល់គេ ដើម្បីកុំឱ្យគេត្រូវ ទទួលការប្រហារជីវិតជាមួយនឹងពួកគ្រូ និងអ្នកប្រាជ្ញនៅបាប៊ីឡូនឡើយ។

អូ! ការអធិស្ឋានដ៏ធំមួយបានកើតឡើង!

កម្លោះហេព្រើរបួននាក់ អធិស្ឋានសូមឱ្យ ព្រះបង្ហាញយល់សប្តិរបស់ស្តេចដែលមិនជឿ លើសាសនាមួយអង្គនោះមុនពេលកំណត់ដ៏ ស្លាប់រស់មួយ (២១៦-១៨)



27

ព្រះគម្ពីរសំដែងថា ព្រះរបស់ហោរា ដានីយ៉ែល បានបង្ហាញនូវយល់សប្តិដ៏អាថ៌ កំបាំងនោះដល់ដានីយ៉ែលនៅយប់នោះឯង ក្នុងការនិមិត្តនារាត្រីមួយ។

ព្រះនៃស្ថានសួគ៌ទ្រង់មិនដែលអាក់ខាន និងមិនផ្តល់កិត្តិយសដល់អ្នកដែលអធិស្ឋាន ដល់ទ្រង់ឡើយ!

ដូច្នេះដានីយ៉ែលបានថ្វាយព្រះពរទៅ ព្រះនៃស្ថានសួគ៌ និងនិយាយថា:

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


28

(ព្រះគម្ពីរ ដានីយ៉ែល ២:២៣)

"ឱ ព្រះនៃពួកឰយុកោទូលបង្គំអើយ ទូលបង្គំអរព្រះគុណ ហើយក៏សរសើរដល់ ទ្រង់ ពីព្រោះទ្រង់បានប្រោសឱ្យទូលបង្គំ មានប្រាជ្ញា និងអំណាច


29

ហើយឥឡូវនេះ ទ្រង់បានឱ្យទូលបង្គំដឹង សេចក្តីដែលយើងខ្ញុំបានសូមពីទ្រង់ ដ្បិតទ្រង់បានសំដែងឱ្យយើង ខ្ញុំស្គាល់រឿងរ៉ាវ របស់ស្តេច ។ ដានីយ៉ែល ២:២៣។

ឱ នេះជាការរំភើបដ៏អស្ចារ្យដែលកើត

ឡើងដល់ចិត្តហោរាដានីយ៉ែល និងមិត្ត ហេព្រើរ (អ៊ីស្រាអែល)ទាំងបីនាក់របស់គាត់!

ហោរាដានីយ៉ែលបានរត់ទៅឯនាយពេជ្ឈ ឃាដ អីយ៉ុក ដូចព្រះគម្ពីរបានសំដែងថា:


30

(ព្រះគម្ពីរ ដានីយ៉ែល ២:២៤)

"ដានីយ៉ែលក៏ចូលទៅឯអីយ៉ុក ជាអ្នក ដែលស្តេច បានបង្គាប់ឱ្យបំផ្លាញពួកអ្នកប្រាជ្ញនៅក្រុងបាប៊ីឡូនបង់ នោះគឺបានទៅ និយាយដូច្នេះថា:


31

សូមកុំបំផ្លាញពួកអ្នកប្រាជ្ញនៅក្នុង

បាប៊ីឡូនឡើយ

សូមនាំខ្ញុំចូលទៅគាល់ដល់ស្តេចចុះ នោះខ្ញុំនឹងកាត់ស្រាយសេចក្តីថ្វាយទ្រង់ជ្រាប វិញ" ដានីយ៉ែល ២:២៤


32

នៅពេលដែលហោរាដានីយ៉ែលបានមក នៅចំពោះព្រះភ័ក្ត្រស្តេច ព្រះចៅ នេប៊ូក្នេសា បានសួរទៅគាត់ថា: តើគាត់ អាចទូលសប្តិនោះដល់ទ្រង់ព្រមទាំងកាត់ ស្រាយន័យផងបានមែនឬអី?

ចូរយើងក្រឡេកមើលទៅការដែល ដានីយ៉ែលឆ្លើយតបទៅនឹងស្តេចវិញ:


33

(ព្រះគម្ពីរ ដានីយ៉ែល (២:២៧,២៨)

"សេចក្តីអាថ៌កំបាំងដែលព្រះករុណាបាន បង្គាប់មកនោះ គ្មានពួកអ្នកប្រាជ្ញ ពួកគ្រូ ធ្មប់ ពួកគ្រូអង្គុយធម៌ ឬគ្រូទាយណាដែល អាចនឹងកាត់ស្រាយថ្វាយព្រះករុណាបានទេ


34

មានតែព្រះអង្គដែលគង់នៅស្ថានសួគ៌ ទ្រង់ សំដែងឱ្យយល់សេចក្តីអាថ៌កំបាំងបាន ហើយទ្រង់បានសំដែង ឱ្យព្រះករុណា នេប៊ូក្នេសា បានជ្រាបពីការដែលត្រូវកើត មកនៅថ្ងៃក្រោយ ខ៧,២៧។

(ដានីយ៉ែល ២:២៧,២៨)

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា




35

សូមកត់សំគាល់ថា ហោរាដានីយ៉ែលមិន បានស្វែងរកកេរ្តិ៍ឈ្មោះសម្រាប់ចំណេះវិជ្ជា គាត់ផ្ទាល់ឡើយ គាត់បានដឹងថា មានតែ ព្រះទេដែលអាចបង្ហាញពីអនាគតបាន។


36

(ព្រះគម្ពីរ អេសាយ ៤៦:៩,១០)

គ្មានអ្វីដែលគួរឱ្យសង្ស័យនោះឡើយ គឺគាត់ បានសិក្សាព្រះគម្ពីរអេសាយ ៤៦:៩,១០ យ៉ាងច្បាស់។

"ដ្បិតអញនេះហើយជាព្រះ ឥតមានអ្នក ណាទៀតឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចអញសោះ


37

អញរមែងសំដែង ប្រាប់ពីការដែលត្រូវមក ខាងចុងបំផុត ហើយពីចាស់បុរាណ និងការដែលមិនទាន់មកដល់..."


38

ប្រាជ្ញានេះបានមកពីព្រះ ដែលទ្រង់បានយក ឱកាសនេះ ដើម្បីគូសបង្ហាញអំពីប្រវត្តិសាស្ត្ររបស់ពិភពលោក សម្រាប់រយៈ ពេល២៦០០ឆ្នាំ ដល់ស្តេចនេប៊ូក្នេសា និង យើងរាល់គ្នា។

ជាដំបូង ដានីយ៉ែលបានទូលថ្វាយស្តេច អំពីយល់សប្តិដែលព្រះរាជាទ្រង់បានសុបិន និមិត្តឃើញ:


39

(ព្រះគម្ពីរ ដានីយ៉ែល ២:២៩)

"ឯទ្រង់ ព្រះករុណាអើយ ទ្រង់កើត មានគំនិត កាលទ្រង់កំពុងផ្ទំនៅក្រឡាបន្ទំ ពីការដែលត្រូវកើតមកនៅខាងមុខ


40

ហើយព្រះដែលទ្រង់សំដែងឱ្យបានយល់ការ អាថ៌កំបាំង ទ្រង់បានធ្វើឱ្យព្រះករុណាជ្រាប ពីការដែលត្រូវមកដល់" -នៅថ្ងៃចុងក្រោយ

ដានីយ៉ែល ២:២៩។


41

(ព្រះគម្ពីរ ដានីយ៉ែល ២:៣១)

បន្ទាប់មក ហោរាដានីយ៉ែលទូលថ្វាយ អំពីយល់សប្តិនោះ:

"បពិត្រព្រះករុណា ទ្រង់បានទតឃើញ រូប១យ៉ាងធំ!


42

រូបនោះដែលធំសំបើម ហើយភ្លឺដ៏អស្ចារ្យ ក៏ឈរនៅចំពោះទ្រង់ មានភាពគួរស្ញែង ខ្លាច"

ខ៣១

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា



43

(វីដេអូ ៩វិនាទី)

តើអ្នកមិនឮព្រះរាជាមានព្រះបន្ទូលទាំង រំភើបទេឬអីថា "មែនហើយ មែនហើយ គឺយ៉ាងដូច្នោះហើយ! រូបភាពដ៏គួរឱ្យស្ញែង ខ្លាចមួយ ហើយខ្ពស់ត្រដែតជាងអ្វីៗទាំង អស់!"

ដានីយ៉ែលពិពណ៌នាសុបិននោះយ៉ាង ច្បាស់លាស់ ព្រោះព្រះចៅនេប៊ូក្នេសាទ្រង់ បានព្រះសុបិន ដូចដែលគាត់បានយល់សប្តិ នោះដែរ។



44

(ព្រះគម្ពីរ ដានីយ៉ែល ២:៣២,៣៣)

រួចដានីយ៉ែលក៏បន្តទៀតថា:

"ឯក្បាល របស់រូបនោះ ជាមាសយ៉ាងល្អ ដើមទ្រូង និងដៃជាប្រាក់ ពោះនិងភ្លៅ ជាលង្ហិន



45

ជើងជាដែក ហើយប្រអប់ជើង ជាដែក លាយនឹងដីឥដ្ឋ"



46

(វីដេអូ ១៤វិនាទី)

អស្ចារ្យណាស់ ព្រះចៅនេប៊ូក្នេសាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលព្រះអង្គបានទ្រង់ព្រះសណ្តាប់ អំពីការរៀបរាប់របស់ដានីយ៉ែល ស្តីអំពីធាតុផ្សេងៗគ្នាដែលបាន បង្កើតជារូប ដែលដូចជាសុបិនដែលទ្រង់ បាននិមិត្តឃើញឥតខ្ចោះនោះ។

ក្បាលគឺជាមាសដែលមានពន្លឺភ្លឺចាំង។

ទ្រូងនិងដៃធ្វើពីប្រាក់ដ៏មានពន្លឺភ្លឺថ្លា។

ជើងជាដែក និងបាទជើងល្បាយនៃ ដីឥដ្ឋនិងដែក។



47

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៤,៣៥)

"ទ្រង់បានទតឃើញដរាបដល់មានថ្មមួយ ដាប់ផ្តាច់ចេញឥតដៃអ្នកណាធ្វើ



48

មកទង្គិច

ត្រូវរូបនោះត្រង់ប្រអប់ជើងដែលធ្វើពីដែក

និងដីឥដ្ឋ ក៏បំបាក់បំបែកខ្ទេចខ្ទីទៅ"។

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា



49

រួចទាំងដែក ដីឥដ្ឋ លង្ហិន ប្រាក់ ហើយ និងមាស ក៏ត្រូវបែកបាក់ខ្ទេចខ្ទីទាំងអស់



50

ហើយត្រឡប់ដូចជាអង្កាមនៅលានស្រូវខែ ប្រាំង រួចខ្យល់បក់ផាត់យកទៅបាត់ ឥត ដែលឃើញផង់ណារបស់រូបនោះទៀតឡើយ



51

(វីដេអូ ៩វិនាទី)

បន្ទាប់មក ព្រះរាជាទ្រង់បានភ្ញាក់ផ្អើល ដោយបានទតឃើញថ្មមួយដុំ មិនដឹងជាបោះពួយមកពីកន្លែងណា ដោយមាន ល្បឿនយ៉ាងលឿនមកទង្គិចនឹងរូបនោះចំត្រង់បាទជើង បំបាក់បំបែកខ្ទេចខ្ទី រួចធ្វើឱ្យ បែកខ្ចាត់ខ្ចាយយ៉ាងឃោរឃៅ និងកិនកំទេចរូបនោះទាំងមូលឱ្យទៅជាធូលីដី រួច ខ្យល់បក់មកផាត់យកអស់គ្មានសល់កំទេចណាឡើយ។



52

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៥)

"ឯថ្មដែលទង្គិចនឹងរូបនោះក៏ត្រឡប់ទៅ ជាភ្នំយ៉ាងធំនៅពេញផែនដីទាំងមូល" ដានីយ៉ែល ២:២៩-៣៥។



53

(វីដេអូ ៨វិនាទី)

"មែនហើយដានីយ៉ែលអើយ" ព្រះ រាជាមានព្រះបន្ទូលឆ្លើយតប "ដុំថ្មដែលបានកាត់ផ្តាច់គ្មានដៃមនុស្សធ្វើ បានមកបំ បែករូបនោះ រួចក៏ត្រឡប់ទៅជាភ្នំយ៉ាងធំនៅពេញផែនដីទាំងមូល"

យល់សប្តិទាំងមូលនេះ ដូចគ្នាទៅនឹង យល់សប្តិរបស់ស្តេចគ្មានខុសបន្តិចណាសោះ ឡើយ។ សូមយើងសញ្ជឹងគិតមើល តើ ព្រះចៅនេប៊ូក្នេសាទ្រង់ភ្ញាក់ផ្អើលយ៉ាងណា នៅពេលដែលទ្រង់ត្រូវបានទូលថ្វាយពីកម្លោះដ៏ប្រសើរនេះ នូវការបកស្រាយយ៉ាងល្អិត ល្អន់អំពីយល់សប្តិដែលដូចគ្នាទៅនឹង សុបិន ដែលទ្រង់បាននិមិត្តឃើញនោះ!


54

រឿងមួយ ដែលទ្រង់បានជ្រាបច្បាស់ឥត សង្ស័យនោះ គឺថា គ្មានមនុស្សណាអាចបង្ហាញអំពីយល់សប្តិនេះដល់ ដានីយ៉ែល បានឡើយ គ្មានអ្នកណាម្នាក់ដែលអាចប្រាប់ពីយល់សប្តិដែលអ្នកដទៃបានយល់សប្តិឃើញ នោះឡើយ! វាពិតប្រាកដជាមកពីប្រភពនៃស្ថានសួគ៌(ព្រះ)។

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


55

ឥឡូវនេះ ព្រះរាជាមានការងឿងឆ្ងល់ជា ខ្លាំង ថាតើយល់សប្តិនេះមានន័យយ៉ាងណា ចំពោះទ្រង់។ យើងក៏ប្រហែលជាមាន ចម្ងល់ដូច្នោះដែរ។

មែនហើយ សុបិនរបស់ព្រះចៅ នេប៊ូក្នេសា បានទស្សនទាយអំពីការកើត ឡើង និងធ្លាក់ចុះ នៃជាតិសាសន៍សំខាន់ របស់ពិភពលោកនេះ។

អាណាចក្រដែលបានតំណាងនៅក្នុង សុបិនរបស់ស្តេច មានឥទ្ធិពលទៅលើជាតិសាសន៍នីមួយៗនៅលើពិភពលោកនេះ តាមរបៀបផ្សេងៗ ជាពិសេសនៅក្នុងសម័យទំនើបយើងនេះ។


56

នៅក្នុងព្រះបន្ទូលតែពីរបីម៉ាត់នោះ ព្រះ បានគូសវាសមេរៀនយ៉ាងសំខាន់នៃប្រវត្តិ សាស្ត្រ តាំងពីសម័យបាប៊ីឡូន ៦០០ឆ្នាំមុន ព្រះគ្រីស្ទ រហូតដល់ទីបំផុតនៃប្រវត្តិសាស្ត្រ ផែនដី។

ទីបញ្ចប់ ដានីយ៉ែលបានចូលដល់ ចំណុចចំបងនៃយល់សប្តិនោះ។


57

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៨)

ដានីយ៉ែលបាននិយាយទាំងក្រឡេកមើល ទៅព្រះមហាក្សត្រ "គឺទ្រង់ដែលជាក្បាល មាសនោះ" ខ ៣៨។

បាប៊ីឡូនគឺជាក្បាល គឺជាជាតិមួយនៃ មាសសុទ្ធ!

ភាពញញឹមនៃការគាប់ព្រះហឫទ័យមួយ បានផុសចេញពីព្រះភ័ក្ត្ររបស់ព្រះរាជានៅពេលដែលព្រះអង្គបានឮពាក្យពេចន៍ទាំងអស់នេះ។


58

ចម្បាំងដណ្តើមយកទឹកដី និងស្ថាបត្យកម្ម របស់បាប៊ីឡូនមានការរុងរឿងយ៉ាងលើស លប់។

អ្នកវិទ្យាសាស្ត្របានបញ្ជាក់ថា មាសគឺ ជានិមិត្តរូបយ៉ាងសមរម្យ ដើម្បីតំណាងឱ្យ ទីក្រុងបាប៊ីឡូន។


59

មាសគឺជាវត្ថុយ៉ាងមានតម្លៃសម្រាប់ប្រើ ប្រាស់ ក្នុងការតុបតែងលំអអាគារនានានៃទីក្រុងបាប៊ីឡូន។

នេះគឺជាការកត់សំគាល់អំពីការពិពណ៌នារបស់ប្រវត្តិវិទូម្នាក់នៃទីក្រុងបុរាណដ៏ឧដុង្គឧត្តមនេះ:

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា



60

“ស្ថិតនៅក្នុងសួនច្បារនាទិសខាងកើត លាតសន្ធឹងទៅដោយភាពល្អឥតខ្ចោះ ...ដែលមានស្នាមភ្លោះឬប្រឡាយនៅព័ទ្ធជុំ វិញ...



61

ទ្វារទង់ដែងរបស់ទីក្រុង និងសួនច្បារ របស់វា បានលេចឡើងលាតសន្ធឹងនៅលើផ្ទៃរាបស្មើ...ព្រះរាជវាំងពីរ...



62

ទីក្រុងនោះឈរនៅហាក់បីដូចជាព្រះ
អង្គម្ចាស់ក្សត្រីមួយអង្គដែលពិភពលោកទាំងមូលកំពុងក្រាបនៅចំពោះព្រះបាទាទ្រង់



63

ដែលសមជារាជធានីនៃអាណាចក្រ តំ ណាងឱ្យក្បាលមាសមែន” យូរ៉ៃយ៉ាស្មីត
បទទំនាយនៃដានីយ៉ែល និងវិវរណៈ ទំព័រ ៣៣,៣៤



64

សួនច្បារបណ្តើតបន្តុបលើគ្នា លេចឡើងអស្ចារ្យនៃបាប៊ីឡូន ជាវត្ថុដ៏អស្ចារ្យមួយក្នុងចំណោមវត្ថុបុរាណដ៏អស្ចារ្យទាំងប្រាំពីរលើ ពិភពលោក



65

ប្រសិនបើដានីយ៉ែល ជាអ្នកនយោបាយ ដ៏ឆ្លាតវាងវៃ ដែលប្រឹងប្រែងស្វែងរកកេរ្តិ៍ ឈ្មោះ សម្រាប់ខ្លួនឯងនៅទីក្រុងបាប៊ីឡូន គាត់នឹងបញ្ឈប់ការបកស្រាយយល់សប្តិរបស់ស្តេចនៅត្រង់នោះហើយ
ប៉ុន្តែ ដានីយ៉ែលមានដំណឹងដែលព្រះចង់ឱ្យ គាត់បង្ហាញដល់ពិភពលោក.ដំណឹងនោះ មិនមែនគ្រាន់តែសម្រាប់នៅសម័យគាត់នោះទេ ប៉ុន្តែជាដំណឹងមួយ ដែលបង្ហាញ រហូតដល់ចុងបំផុតនៃប្រវត្តិសាស្ត្រពិភពលោកនេះ



66

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៩)
ដូច្នេះ ដានីយ៉ែលបានប្រកាសយ៉ាង សុភាពរាបសា តែអង់អាចក្លាហានថ្វាយទៅ ស្តេចថា: “តពីទ្រង់ទៅនឹងមាននគរមួយ ទៀតកើតឡើង ដែលថោកជាងទ្រង់”
ដានីយ៉ែល ២:៣៩

១. តើយើងអាចដឹងពីអនាគតដោយវិធីណា

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


67

រំពេចនោះ ភាពញញឹមដ៏គាប់ព្រះហឫទ័យ របស់ព្រះរាជា ក៏អន់ថយបន្តិចម្ដងៗទៅ យ៉ាងរហ័ស នៅពេលដែលទ្រង់បានឮពាក្យ ទាំងនេះពីហោរាដានីយ៉ែល។

ព្រះរាជាដ៏អំនួតនៃទីក្រុងបាប៊ីឡូន ប្រ ហែលជាមិនធ្លាប់មានអ្នកណាទូលថ្វាយថា នឹងមានជាតិសាសន៍ដទៃទៀតណាមួយ នឹង គ្រប់គ្រងលើពិភពលោកនេះឡើយ។

---


68

ជាការពិតណាស់ បុរាណវិទូបានជីក យកបន្ទះដីឥដ្ឋ ដែលបានចារនូវពាក្យពេចន៍ ទាំងនេះដោយស្ដេចនេប៊ូក្នេសា

---


69

"សំណង់ការពារសឹកនៃអេសាគីឡា និង បាប៊ីឡូន អញបានពង្រឹង និងកសាងឡើង នូវឈ្មោះនៃរាជ្យរបស់អញរហូតទៅ

---


70

(ព្រះគម្ពីរ ដានីយ៉ែល ៤:៣០)

ព្រះគម្ពីរបានចែងថា ព្រះរាជាអំនួត នេប៊ូក្នេសា "ទ្រង់មានបន្ទូលថា នេះតើ មិនមែនជាក្រុងបាប៊ីឡូនដ៏ធំ

---


71

ដែលអញបានសាងទុកជាព្រះរាជស្ថាន ដោយអនុភាពនៃអំណាចរបស់អញទេឬអី?" ដានីយ៉ែល ៤:៣០

ទោះជាយ៉ាងនេះក៏ដោយ ព្រះបានមាន ព្រះបន្ទូលថា អំណាចមួយទៀតនឹងកើតឡើង ដែលនឹង បំបែកអាណាចក្រមាសនៃបាប៊ីឡូន។

ហើយដានីយ៉ែលបានរស់នៅឃើញព្រឹត្តិការណ៍នោះ។

---



72

(វីដេអូ ១៣វិនាទី)នៅក្នុងរជ្ជកាលរបស់

ព្រះចៅបេលសាសារ ស្ដេចដ៏ក្រអឺតក្រអោង

មួយអង្គដែលត្រូវជាចៅរបស់ស្ដេចនេប៊ូក្នេសាព្រះចៅស៊ីរូស ជា ស្ដេចមេឌីបានចាប់ឡោមព័ទ្ធបាប៊ីឡូន។

---


73

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំទី ៥៣៩ មុនគ្រិស្តសករាជ អាណាចក្រមាសបាប៊ីឡូន បានដល់ទីបញ្ចប់

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា


74

សូមបញ្ជាក់ថា ព្រះបានទស្សនទាយយ៉ាង ត្រឹមត្រូវថា ទីក្រុងនោះនឹងត្រូវចាប់យក ដោយអ្នកណា និងដោយរបៀបយ៉ាងណា
ជិត២០០ឆ្នាំមុនពេលដែលទីក្រុងបាប៊ីឡូនត្រូវ រលំ។


75

(ព្រះគម្ពីរ អេសាយ ៤៥:១)
ព្រះបានមានព្រះបន្ទូលតាមរយៈហោរា អេសាយថាៈ "ព្រះយេហូវ៉ាទ្រង់មានបន្ទូល ដល់ស៊ីរូស ដែលទ្រង់បានចាក់ប្រេងតាំង ឡើង ហើយជាអ្នកដែលទ្រង់កាន់ដៃស្តាំ ដើម្បីឱ្យបានបង្ក្រាបអស់ទាំងសាសន៍នៅមុខ ខ្លួន


76

ហើយនិងបន្ធូរចង្កេះពួកស្តេច ព្រមទាំង បើកទ្វារនៅមុខខ្លួន រួចទ្វារទាំងនោះមិន ត្រូវបិទវិញឡើយ" អេសាយ ៤៥:១


77

ព្រះថៃមទាំងបានប្រាប់ថា ការនោះនឹងត្រូវ កើតឡើងដោយសារអ្នកណា គឺស្តេចស៊ីរូស ជាជនជាតិមេឌី តាំងពី១៥០ឆ្នាំមុនទ្រង់បាន ប្រសូតមក។



78

(វីដេអូ ៨វិនាទី)
ស្តេចស៊ីរូស មិនអាចបំបាក់បំបែក កំផែងទីក្រុងបានឡើយ ព្រោះកំផែងនោះ ខ្ពស់ និងក្រាសខ្លាំងពេក ដូច្នេះទ្រង់ក៏បាន រកវិធីផ្សេងវិញ ព្រះអង្គបានបង្វែរទន្លេ ដែលហូរកាត់កណ្តាលទីក្រុង ហើយកងទ័ព របស់ទ្រង់អាចដើរក្នុងបាតទន្លេ រហូតដល់ ពួកគេរកផ្លូវឃើញចូលទៅកាន់ទីក្រុង។
អ្នកយាមទ្វារទីក្រុងគ្មានការប្រុងប្រយ័ត្ន ឬ ក្បត់នឹងទីក្រុងនោះ បានទុកទ្វារលង្ហិនដ៏ធំសំ បើមខាងក្នុងទីក្រុងឱ្យនៅចំហ និងគ្មាន អ្នកយាមនៅទីនោះឡើយ!


79

ទាហានរបស់ស្តេចស៊ីរូស បានចូលដល់ ក្នុងទីក្រុង ហើយបានធ្វើគតស្តេច និង មន្ត្រីនៃទីក្រុងបាប៊ីឡូនអស់ នៅក្នុងខណៈ ដែលពួកគេបានស្រវឹងស្រាពីពែងមាស ដែលស្តេចនេប៊ូក្នេសា បានយកមកពីទីក្រុង យេរូសាឡិម កាលពីទ្រង់បានវាយដណ្តើម បានទីក្រុងនោះ។
ទ្រង់បានលួចពែងមាសទាំងនោះពីព្រះវិហារ របស់ស្តេចសាឡូម៉ូនជាច្រើនឆ្នាំកន្លងមក ហើយ។

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


80

ដានីយ៉ែលបានទស្សន្សទាយថា បន្ទាប់ ពីចក្រភពមាសបាប៊ីឡូនទៅ អាណាចក្រ មួយទៀតដែលអន់ជាងបាប៊ីឡូន ដែល តំណាងដោយទ្រូងនិងដៃប្រាក់ នឹងមកកាន់ កាប់បន្ត។


81

រដ្ឋាភិបាលចម្រុះមួយរវាងមេដូ និង ពើរស៊ី ពិតជាមានការអន់ថយជាងចក្រភព ដ៏រុងរឿងរបស់បាប៊ីឡូនមែន ប៉ុន្តែរដ្ឋា ភិបាលនេះបានគ្រប់គ្រងមជ្ឈិមបូព៌ាអស់២ សតវត្សរ៍។

ដានីយ៉ែលក៏បានទាយផងដែរថា អា ណាចក្រប្រាក់នេះ ក៏នឹងមានកាលកំណត់ របស់ខ្លួនដែរៈ


82

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៩)

"...រួចនឹងមាននគរមួយទៀតជានគរ ទី៣ ដែលជាលង្ហិន នគរនោះនឹងគ្រប់ គ្រងលើផែនដីទាំងមូល" ដានីយ៉ែល២:៣៩

តើការនេះបានកើតមានឡើងមែនឬទេ? មែន ពិតប្រាកដមែន!


83

ការទស្សនទាយតាមរូបសំណាកលោហធាតុ នេះ ពោះនិងភ្លៅលង្ហិន បានត្រូវសំរេច នៅ ពេលដែលឧត្តមសេនីយ៍ដ៏ល្បីល្បាញ អាឡិច ហ្សង់ឌឺក្រង់ បានវាយបំបាក់ ស្តេចដារីយុសទី៣ នៃសាសន៍ពែរក្សនៅ ក្នុងសមរភូមិអាប៊ីឡា នៅឆ្នាំ ៣៣១មុន គ្រិស្តសករាជ ហើយ ចក្រភពបន្ទាប់ នោះ គឺអាណាចក្រក្រេក!


84

នៅក្នុងវ័យ២៥ឆ្នាំ មេទ័ពក្មេង អាឡិច ហ្សង់ បានក្លាយជាអ្នកគ្រប់គ្រងម្នាក់នៃចក្រ ភពដ៏ទូលំទូលាយ ដែលល្បីល្បាញ លើ ពិភពលោកនេះ។


85

(អ្នកប្រវត្តិវិទូក្រេក) លោកអារីយ៉ាន បានសរសេរអំពីលោកអាឡិចហ្សង់ថាៈ

"ខ្ញុំត្រូវបានបញ្ចុះបញ្ចូលថា គ្មានជាតិ ណា ទីក្រុងណា ឬប្រជាជនណាមិនបាន ឮអំពីឈ្មោះនោះឡើយ


86

ខ្ញុំហាក់ដូចជាដឹងថា មានដៃដ៏ពិសិដ្ឋធ្វើ ជាអធិបតី ទាំងលើកកំណើតរបស់គាត់ និងសកម្មភាពរបស់គាត់" បណ្ណាល័យ ប្រវត្តិសាស្ត្រសៀវភៅទី១៦ ជំពូក១២។

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


87

គ្រឿងសឹកជាច្រើនដែលកងទ័ពថ្មើរ ជើងរបស់ ក្រេកបានពាក់ ត្រូវបានធ្វើពី ទង់ដែង ដែលជាលោហធាតុទី៣ ក្នុងសុបិនរបស់ស្តេចនេប៊ូក្នេសា។


88

លោកអាឡិចហ្សង់ បានស្លាប់មុនថ្ងៃខួបកំណើត ទី៣៣របស់គាត់ ដោយសារជម្ងឺគ្រុនក្តៅ។ បន្ទាប់ពីមរណភាពរបស់គាត់ទៅ ចក្រភព របស់គាត់ក៏កាន់តែខ្សោយទៅៗ ហើយត្រូវបានបំបែកចេញជាច្រើនផ្នែក រហូតដល់ ទីបញ្ចប់។


89

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៦៨ មុន គ្រិស្តសករាជ នៅសមរភូមិភីតណា ចក្រភពរបស់មហារាជអាឡិចហ្សង់ដឺក្រេង់ ត្រូវ បានសាបសូន្យនៅក្រោយ មរណភាព របស់គាត់១៤៤ឆ្នាំ" ប្រវត្តិសាស្ត្ររ៉ូម

-សៀវភៅទី៣ ជំពូក ១០


90

ឥឡូវនេះវិបត្តិដ៏ធ្ងន់ធ្ងររបស់អាណាចក្រ បុរាណទាំងនោះត្រូវបានមកដល់។ លោកអ្នកចងចាំបានថា ព្រះបានទស្សន ទាយថា នឹងមាននគរបួនកើតឡើងបន្តគ្នា។


91

តាមពិតជើងដែកបានពិពណ៌នាយ៉ាង ច្បាស់អំពីអំណាចដែលអន់ថយឥតឧបមា របស់ចក្រភពទីបួន នៃពិភពលោកនេះ។ ដានីយ៉ែលបានពិពណ៌នាថ្វាយទៅស្តេចយ៉ាងដូច្នេះថា:


92

(ព្រះគម្ពីរ ដានីយ៉ែល ២:៤០)

"ឯនគរទី៤ នឹងមានកម្លាំងខ្លាំងដូច

ដែក..."

ដានីយ៉ែល ២:៤០


93

អធិរាជ្យសេសារបានហៅខ្លួនឯងថា ជាព្រះ ហើយបានបញ្ជាឱ្យគេថ្វាយបង្គំ និងស្តាប់បង្គាប់ទ្រង់គ្រប់ៗគ្នា។

គឺនៅក្នុងកំឡុងពេលនៃការគ្រប់គ្រងរបស់អាណាចក្ររ៉ូមនេះ ដែលព្រឹត្តិការណ៍ធំៗដ៏សំខាន់ពីរបានកើតឡើង នៅក្នុងសាសន៍នេះ។

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


94

១. ព្រះយេស៊ូវបានប្រសូតនៅភូមិ បេថ្លេហិម។

មានអ្នកកាន់អំណាចរ៉ូមម្នាក់ បានចេញ បញ្ជាឱ្យសម្លាប់ក្មេងប្រុស ដែលមានអាយុ ក្រោម២ឆ្នាំទាំងអស់នៅក្នុង ភូមិបេថ្លេ ហិម។ គេសង្ឃឹមថា នឹងអាចធ្វើគតព្រះ យេស៊ូវផងដែរ និង


95

២. ព្រះយេស៊ូវត្រូវបានជាប់ឆ្កាងនៅស្រុក យូដា នៅក្រោមរដ្ឋអំណាចរ៉ូម។

ចៅហ្វាយខេត្តរ៉ូមម្នាក់បានអនុញ្ញាតឱ្យ គេចោទប្រកាន់ព្រះយេស៊ូវ  ព្រះយេស៊ូវ ត្រូវបានទាហានរ៉ូមបោះដែកគោលជាប់នឹង ឈើឆ្កាង ហើយត្រារបស់សាសន៍រ៉ូម ត្រូវ បានគេ យកមកបោះលើផ្នូររបស់ព្រះ យេស៊ូវ ដើម្បីប្រឹងប្រែងដាក់ព្រះសពព្រះ យេស៊ូវឱ្យនៅក្នុងនោះ។

ឥឡូវនេះសញ្ញានៃបទទំនាយនោះបាន ផ្លាស់ប្តូរ។

គ្មានចក្រភព(នគរ)ណាមួយបានដើរ តាមនគររ៉ូមឡើយ។


96

(ព្រះគម្ពីរ ដានីយ៉ែល ២:៤១,៤៣)

ហោរាដានីយ៉ែលបានសរសេរថា "ហើយ ដែលទ្រង់បានឃើញប្រអប់ជើងនិងម្រាមជើង នោះ មាន១ចំណែកជាដីរបស់ជាងស្មូន ហើយ១ចំណែកទៀតជាដែកវិញ


97

នោះគឺថា នគរនោះនឹងញែកបែកគ្នា..."


98

"...នោះគេនឹងលាយខ្លួននឹងអស់ទាំង ពូជមនុស្សផងយ៉ាងនោះដែរ តែគេនឹងមិន នៅជាប់ជិតគ្នានឹងគ្នាទេ


99

ដូចជាដែកដែលមិនលាយជាប់នឹងដីដែរ"

ដានីយ៉ែល ២:៤១:៤៣


100

និយាយម្យ៉ាងទៀតថា ហោរាបានទាយថា នឹងគ្មានចក្រភពទីប្រាំកើតឡើងឡើយ ប៉ុន្តែ ការបែងចែកចក្រភពរ៉ូមបានកើតមានឡើងទៅ វិញ។

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា



101

(វីដេអូ ៣វិនាទី) ចក្រភពរ៉ូមនឹងត្រូវបានបែង ចែកជានគរជាច្រើន


102

ភាពរឹងប៉ឹងដូចដែកនៃចក្រភពដ៏ធំរបស់រ៉ូម ដែលបានគ្រប់គ្រងអស់រយៈពេលជិត ៦០០ ឆ្នាំនោះត្រូវបានបែងចែក។


103

តាមរយៈការសំប៉ូវបែបខាងសម្ភារៈ ការ ពុករលួយខាងនយោបាយ និងការចុះ ខ្សោយខាងសីលធម៌ ចក្រភពរ៉ូមបាន បាត់ បង់លំនឹងរបស់ខ្លួន ហើយបានក្លាយទៅជា
វិពារយ៉ាងងាយស្រួលរបស់កុលសម្ព័ន្ធដ៏ឃោរ ឃៅ ដែលបានចាប់ផ្តើម លុកលុយ ចក្រភពរ៉ូម ក្នុងរវាងគ្រិស្តសករាជ ៣៥១ និង ៤៧៦។


104

ព្រះចៅអូគូស ត្រូវបានគេទំលាក់ ហើយ ចក្រភពរ៉ូមត្រូវបានបែងចែកជាច្រើនចំណែក ដែលតំណាងដោយជើង និងម្រាមជើង ដែលធ្វើពីដែកនិងដីឥដ្ឋរបស់រូបនោះ។


105

(ព្រះគម្ពីរ ដានីយ៉ែល ២:៤៣)
"ហើយដែលទ្រង់បានឃើញដែកលាយជាមួយនឹងដីស្អិតជាយ៉ាងណា នោះគឺគេនឹងលាយ ខ្លួននឹងអស់ទាំងពូជមនុស្សផងយ៉ាងនោះដែរ


106

តែគេនឹងមិននៅជាប់ជិតគ្នានឹងគ្នា ដូចជា ដែកដែលមិនជាប់លាយនឹងដីឥដ្ឋដែរ"
ដានីយ៉ែល ២:៤៣។

ការលុកលុយដ៏ឃោរឃៅរបស់ចក្រភពរ៉ូម បានបែងចែកចក្រភពនេះ។

ការបែងចែកនេះ តំណាងដោយប្រអប់ ជើងដែកនិងដីឥដ្ឋ បានបង្កើតជាមូលដ្ឋាន របស់ជាតិសាសន៍ទាំងឡាយ ដែលមានទី តាំងនៅអឺរ៉ុបសព្វថ្ងៃនេះ។



107

(វីដេអូ ៦វិនាទី) កុលសម្ព័ន្ធឃោរឃៅទាំងដប់នេះ ត្រូវបាន រាយនាមដូចខាងក្រោមនេះ ដោយអ្នកប្រវត្តិសាស្ត្រជាច្រើន:
អាឡាម៉ានី-អាឡាម៉ង់ត៍,ប៊ីហ្គានឌៀន-ស្វីស,ហ្វ្រេងក្ស-បារាំង,ឡំបាឌ្យ-អ៊ីតាលី,ហ្សាក់ហ្សុង-អង់គ្លេស

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា



108

(វីដេអូ ៦វិនាទី)

ស្វីរ៍-ព័រទុយហ្គាល់ វីស៊ីហ្គូថ-អេស្ប៉ាញ

ហ៊ែរវុលី, អូស្ត្រូហ្គូថ, វ៉ែនដាល-បាត់បង់ ឬរលាយចូលជាមួយប្រទេដទៃ


109

ការប្រកាសរបស់ព្រះគឺថា នគរទាំងនេះនឹង

មិនអាចបង្រួបបង្រួមជាចក្រភពនៅលើពិភពលោកនេះវិញបានឡើយ

ដ្បិតមានដែនកំណត់ដែលជាតិសាសន៍ទាំងនោះមិនអាចធ្វើបាន។


110

អឺរុបនៅតែបែងចែកដដែល។ គេនឹង មិននៅជាមួយគ្នាទេ!

ទោះបីជាមានផ្សាររបស់អឺរុប ឬប្រាក់ អឺរុបក៏ដោយ ក៏គេនៅតែជាប្រទេសផ្សេង គ្នាដដែល។


111

ព្រះបានមានព្រះបន្ទូលថា ពួកគេនឹង លាយខ្លួននឹងអស់ទាំងពូជមនុស្ស។ និយាយ ម្យ៉ាងទៀតថា

ពួកគេនឹងរៀបការក្នុងពូជ ស្តេចដទៃ


112

នៅក្នុងព្រះរាជវាំងមួយនៃប្រទេស ដាណឺម៉ាក ពង្សាវតារព្រះរាជវង្សរបស់

អឺរ៉ុប ត្រូវបានគេដាក់បង្ហាញ។

ពួកគេជាញាតិសន្តាននឹងគ្នាទាំងអស់ ពួកគេសង្ឃឹមថា វានឹងអាចការពារនឹង សង្គ្រាមបាន។ ប៉ុន្តែ

វាមិនបានការទេ


113

ពួកគេមិនអាចត្រូវរ៉ូវគ្នាទេ។ ដូច្នេះហើយ បានជាមានសង្គ្រាមជាច្រើនបានកើតឡើងនៅអឺរ៉ុប

ដែលពិតជាគ្រួសារនៃការវាយប្រយុទ្ធ គ្នា!

ព្រះទ្រង់បានទាយថា ពួកគេនឹងមិននៅ ជាប់គ្នាឡើយ។

ពួកគេបានខំប្រឹងប្រែងដាក់ចក្រភពរ៉ូម ឱ្យត្រឡប់ទៅជាអាណាចក្រតែមួយវិញ

ប៉ុន្តែការខំប្រឹងប្រែងនេះមិនបានស្ថិតស្ថេរ ឡើយ ព្រោះថា ដែកនិងដីឥដ្ឋនឹងមិននៅ ជាប់គ្នាឡើយ!


114

សូមយើងគិតមើលអំពីការប៉ុនប៉ងជាច្រើន ដើម្បីផ្សះផ្សាប្រទេសអឺរ៉ុបឱ្យទៅជាមួយឡើង វិញ។

តើនឹងមានអ្វីកើតឡើងដល់អ្នកដែលប៉ុន ប៉ងធ្វើជាអ្នកដឹកនាំពិភពលោកជាច្រើនទាំង នេះ

ដែលបានព្យាយាមបង្រួបបង្រួមប្រ ទេសអឺរុបដែលបាក់បែកនេះឡើងវិញ?

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


115

លោក ឆាឡិម៉េង ត្រូវបានបរាជ័យ ព្រះចៅធាល ទី៥ លីទី១៤ ត្រូវបរាជ័យ ណាប៉ូឡេអុងត្រូវបរាជ័យ កាហ្សេ វីលីយៀម ត្រូវបរាជ័យ អ៊ីត្លែរ ត្រូវបរាជ័យ។

ណាប៉ូឡេអុងបាននិរទេសទៅកាន់កោះ អែលបារី វីរបុរសខាងសង្គ្រាមដ៏អស្ចារ្យនៃ ប្រទេសបារាំងនាទសវត្សរ៍ទី១៨០០ បាន ទទួលស្គាល់ថា ព្រះអស្ចារ្យណាស់សម្រាប់ គាត់ ព្រះទ្រង់អស្ចារ្យណាស់សម្រាប់ពួក អ្នកដឹកនាំទាំងអស់នោះ



116

ព្រះបានមានព្រះបន្ទូលថា "គេនឹងមិន នៅជាប់ជិតគ្នានឹងគ្នាទេ"

អក្សរចារឹកលើផ្ទះដ៏ត្រឹមត្រូវមួយ ជា អ្នកបង្ហាញអំពីហេតុការណ៍នេះ!

ទោះជាយ៉ាងណាក៏ដោយ មនុស្សនៅតែ ខំព្យាយាមបង្រួបបង្រួមប្រទេសអឺរ៉ុបឡើងវិញ ប៉ុន្តែគេហាក់ដូចជាមិនអាចធ្វើបានឡើយ ស្របដូចជាព្រះបានមានព្រះបន្ទូលមកមែន! គេអាចរួបរួមគ្នា ប៉ុន្តែគេមិនអាចរួម បញ្ចូលគ្នាបានឡើយ!



117

(វីដេអូ ១២វិនាទី)

ស្តេចនេប៊ូក្នេសាត្រូវតែមានការភាន់ភាំង ចំពោះបទទំនាយត្រង់នេះ។

ព្រះបានប្រាប់ជាមុន អំពីវាសនាអាក្រក់ របស់ចក្រភពទាំងបួនលើពិភពលោកនេះ។

ទ្រង់បានទស្សនទាយថា នគររ៉ូម នឹង ត្រូវបានបែងចែកទៅជាសាសន៍ជាច្រើន ហើយប្រទេស៧ នៃសាសន៍ទាំងនោះ មាន នៅអឺរ៉ុបខាងលិចសព្វថ្ងៃនេះ ប្រទេសខ្លះ ខ្លាំង ខ្លះខ្សោយ ប៉ុន្តែបានបែងចែកគ្នាយ៉ាង អស់សង្ឃឹមនិងមិនអាចបង្រួបបង្រួមវិញ បានឡើយ។


118

បន្ទាប់មកតើរឿងរ៉ាវនេះនឹងទៅជាយ៉ាង ណា?

ដោយមានអំណរយ៉ាងជាក់ស្តែង និង សេចក្តីទុកចិត្ត ឥឡូវនេះ ដានីយ៉ែលបាន មកដល់កម្រិតខ្ពស់ហួសនិស្ស័យ ក្នុងការបក ស្រាយយល់សប្តិនៃរូបលោហធាតុដ៏ធំនោះ។ គាត់បានសរសេរថា:



119

(ព្រះគម្ពីរ ដានីយ៉ែល ២:៤៤,៤៥)

"រីឯនៅគ្រានៃស្តេចទាំងនោះ ព្រះនៃ ស្ថានសួគ៌ទ្រង់នឹងតាំងនគរ១ឡើង ដែល មិនត្រូវបំផ្លាញឡើយ



120

ហើយអំណាចហ្លួង ក៏មិនត្រូវផ្ទេរដល់ សាសន៍ដទៃណាមួយដែរ គឺនឹងបំបាក់បំ បែក ហើយលេបបំបាត់នគរទាំងនោះវិញ នគរនោះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច"

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


121

គឺដូចជាទ្រង់បានឃើញថ្មនោះដាប់ផ្តាច់ ចេញពីភ្នំឥតមានដៃអ្នកណាធ្វើ


122

ហើយថ្មនោះបានបំបាក់បំបែកទាំងដែក លង្ហិន ដីឥដ្ឋ ប្រាក់ និងមាសហើយ


123

គឺព្រះដ៏ធំ ទ្រង់បានសំដែងឱ្យព្រះ ករុណាជ្រាបពីការដែលត្រូវមកនៅខាងមុខ។
“សុបិននេះជាប្រាកដហើយ ឯសេចក្តី សម្រាយក៏ជាការពិតដែរ”
ដានីយ៉ែល ២:៤៤,៤៥


124

ព្រឹត្តិការណ៍ដ៏ធំបន្ទាប់នៅក្នុងដំណាក់ការ នៃប្រវត្តិសាស្ត្ររបស់មនុស្សគឺ ការយាងមកជាលើកទី២របស់ព្រះគ្រីស្ទ និងការបង្កើត នគររបស់ទ្រង់ដែលតំណាងដោយថ្ម “ដាប់ផ្តាច់ចេញគ្មានដៃមនុស្សធ្វើ”

ព្រះរាជាណាចក្ររបស់ទ្រង់ ដែលបាន សាងឡើង មិនមែនដោយដៃមនុស្សឡើយ គឺដោយសារព្រះហស្តដ៏មានព្រះចេស្តារបស់ ព្រះវិញ គឺជាព្រះរាជាណាចក្រមួយ ដែលបានបំពេញពិភពលោកនេះទាំងមូល។


125

(ព្រះគម្ពី វិវរណៈ ១១:១៥)
ពេលនោះបទទំនាយនឹងត្រូវបានសម្រេច
“នគរទាំងប៉ុន្មាននៅលើលោកីយ៍បានត្រឡប់ ទៅជានគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា...ហើយទ្រង់នឹងសោយរាជនៅ អស់កល្បជានិច្ចរៀងរាបតទៅ”។
វិវរណៈ ១១:១៥


126

សូមពិនិត្យមើលព្រឹត្តិការណ៍ចុងក្រោយ នៅក្នុងព្រះគម្ពីរដានីយ៉ែល ដែលគ្របដណ្តប់ដោយបទទំនាយ គួរឱ្យភ្ញាក់ផ្អើលនេះ:


127

ការយាងមកជាលើកទី២របស់ព្រះយេស៊ូវ

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា


128

នគរទាំងឡាយនៅលើលោកីយ៍នេះនឹងបាន
ដល់ទីបញ្ចប់។


129

ព្រះនឹងបង្កើតព្រះនគរទ្រង់ឡើង


130

នគរនោះនឹងស្ថិតស្ថេរនៅអស់កល្បរៀងរហូតតទៅ


131

ព្រះយេស៊ូវនឹងត្រូវបានតាំងជាស្តេចលើអស់ ទាំងស្តេច និងជាព្រះលើអស់ទាំងព្រះ


132

ទ្រង់បានយាងមកកាន់ផែនដីនេះ ដើម្បី នឹងសោយរាជ្យរៀងរហូត នៅលើនគរដ៏ អស់កល្បមួយ។


133

នៅពេលដែលដានីយ៉ែលបានបញ្ចប់ការ ទូលថ្វាយទៅស្តេច នូវនិមិត្តដ៏អស្ចារ្យ និង
ការបកស្រាយដ៏ច្បាស់ ហួសនិស្ស័យរបស់ ព្រះមក ព្រះចៅនេប៊ូក្នេសាបានក្រោកចេញ ពីបល្ល័ង្ក
ហើយក្រាបនៅចំពោះដានីយ៉ែល ដើម្បីថ្វាយកិត្តិយសដល់ព្រះដ៏ធំរបស់ ដានីយ៉ែល
ដែលទ្រង់បានបង្ហាញប្រាជ្ញា និងអំណាច គួរឱ្យស្ញែងខ្លាច។


134

(ព្រះគម្ពីរ ដានីយ៉ែល ២:៤៧)
ស្តេចទ្រង់មានព្រះបន្ទូលនឹងដានីយ៉ែលថា "ពិតប្រាកដជាព្រះនៃអ្នក ជាព្រះលើអស់ ទាំងព្រះ
ហើយទ្រង់ជាព្រះអម្ចាស់លើអស់ ទាំងស្តេច គឺជាព្រះដែលបានសំដែងឱ្យ យល់សេចក្តីអាថ៌កំបាំង..."
ដានីយ៉ែល ២:៤៧។

ពិតប្រាកដណាស់ ព្រះរបស់ដានីយ៉ែល គឺជាព្រះដែលខ្ញុំចង់បានជាព្រះរបស់ខ្ញុំដែរ

១.តើយើងអាចដឹងពីអនាគតដោយវិធីណា

# ១. តើយើងអាចដឹងពីអនាគតដោយវិធីណា


135

ដោយសាររូបលោហធាតុដ៏ធំ ដែល បានឃើញដោយស្តេចនេប៊ូក្នេសា នៅក្នុង សុបិនរបស់ព្រះអង្គ នៅពេល៦សតវត្សរ៍ មុនកំណើតរបស់ព្រះគ្រីស្ទ ព្រះបានបើក
ស្បៃអាថ៌កំបាំងសម្រាប់រយៈពេលជាច្រើន សតវត្សរ៍ទៅមុខឱ្យបានឃើញ


136

មែនហើយមិត្តអើយ "សុបិននោះ គឺពិតប្រាកដ មែនហើយ ហើយការបកស្រាយក៏ច្បាស់លាស់ដែរ!"
ការធ្វើដំណើរជិតដល់ទីបញ្ចប់ហើយ!
ព្រឹត្តិការណ៍ដ៏ធំបន្ទាប់ គឺការយាងមករបស់ ព្រះគ្រីស្ទនៅលើពពក ដើម្បីបង្កើតនគរអស់កល្បរបស់ទ្រង់។



137

(វីដេអូ ៥វិនាទី) នគរដែលតំណាងដោយ មាស ប្រាក់ លង្ហិន ស្ពាន់ និងដែក បាន កន្លងបាត់ទៅក្លាយជាប្រវត្តិសាស្ត្រទៅ ហើយ ព្រឹត្តិការណ៍ដ៏ធំបន្ទាប់ គឺការយាង មកវិញ
យ៉ាងឆាប់ៗនេះរបស់ព្រះជាម្ចាស់!


138

ទ្រង់បានរៀបចំអនាគតដ៏ស្រស់បំព្រង ដែលអាចកើតឡើងបានដោយសារព្រះលោហិតនៅលើឈើឆ្កាង ត្រង់ភ្នំរលាក្បាល។
វានៅសល់តែបន្តិចទៀតតែប៉ុណ្ណោះ នឹងដល់ពេលដែលការទាំងអស់នេះត្រូវបាន សម្រេចហើយ។
ឥឡូវនេះ ព្រះកំពុងរៀបចំនគររបស់ ទ្រង់ និងអស់អ្នកដែលនឹងនៅក្នុងនគរនោះ។



139

(វីដេអូ ៧វិនាទី) យើងអាចជាសមាជិក យ៉ាងពិតប្រាកដនៃនគររបស់ព្រះ ប្រសិនបើយើងគ្រាន់តែធ្វើដោយជំនឿដូចជាចោរនៅលើឈើឆ្កាង បានធ្វើនៅពេលដែលគេត្រូវបានឆ្កាងនៅកណ្តាលអាកាស និងផែនដី ក្បែរព្រះយេស៊ូវនោះតែប៉ុណ្ណោះ។
គេមិនអាចទៅជិតព្រះយេស៊ូវបានឡើយ ប៉ុន្តែគេបានដឹងថា គេជាមនុស្សមានបាប ហើយគេដឹងថាគេត្រូវការសេចក្តីសង្គ្រោះ ពីបាបទាំងឡាយដែលគេបានប្រព្រឹត្ត។
គេបានសំឡឹងមើលទៅឯព្រះអង្គ សង្គ្រោះ នៃពិភពលោកនេះ ហើយបានឃើញលោហិតទ្រង់ហូរកាត់ព្រះភ័ក្ត្រទ្រង់ ថ្ងាសរបស់ទ្រង់ដែលមុតទម្លុះដោយភ្នួងបន្លា។
ចិត្តរបស់គេត្រូវបានចាប់អង្រួន។ គាត់បាន លន់តួបាបរបស់គាត់ហើយបានស្រែកឡើង

# ១.តើយើងអាចដឹងពីអនាគតដោយវិធីណា




140

(ព្រះគម្ពីរ លូកា ២៣:៤២)

"ព្រះអម្ចាស់ កាលណាចូលទៅក្នុង នគរទ្រង់ សូមនឹកចាំពីទូលបង្គំផង"
លូកា ២៣:៤២។

ហើយព្រះយេស៊ូវប្រទានការធានារ៉ាប់ រងដល់គាត់ថា គាត់នឹងនៅជាមួយនឹងទ្រង់
នៅក្នុងនគរនោះ។



141

លោកអ្នកក៏ដូច្នោះដែរ លោកអ្នកអាច អធិស្ឋានដូចខាងលើ ហើយលោកអ្នកនឹង ទទួលបាននូវសេចក្តីធានារ៉ាប់រងដូចជាចោរ នោះដែរ គឺលោកអ្នកនឹងអាចនៅជាមួយ នឹងព្រះគ្រីស្ទក្នុងនគររបស់ទ្រង់ ដែលទ្រង់ នឹងបង្កើតឡើងនៅពេលឆាប់ៗនៅលើផែនដី នេះ។




142

(ព្រះគម្ពីរ ម៉ាថាយ ២៥:៣៤)

ពេលនោះអ្នកនឹងឮពីព្រះឱស្ឋរបស់ព្រះ គ្រីស្ទ នូវសេចក្តីអញ្ជើញនេះ នៅពេល ដែលព្រះអង្គយាងមកវិញ។

"...ឱពួកអ្នកដែលព្រះវរបិតាយើង បានប្រទានពរអើយ ចូរមកទទួលមរតក ចុះ..." ម៉ាថាយ ២៥:៣៤។



143

ពិភពលោកនេះមិនមែនស្ថិតនៅក្នុង កណ្តាប់ដៃរបស់មនុស្សឡើយ គឺវាស្ថិតនៅ ក្នុងព្រះហស្តរបស់ព្រះ។ យើងអាចប្រ ឈមមុខទល់នឹងថ្ងៃអនាគតដោយសេចក្តីទុកចិត្តយ៉ាងខ្លាំង។ ព្រះគ្រីស្ទនឹងយាងមក ឆាប់ៗនេះ។

ថ្មដែលកាត់ផ្តាច់គ្មានដៃមនុស្សធ្វើនឹង បំបែករូបនេះ។

នគរនៃផែនដីនេះនឹងត្រូវខ្ទេចខ្ទី។

ព្រះនឹងនាំមកនូវនគរដែលស្ថិតស្ថេរអស់ កល្បជានិច្ច។



144

លោកអ្នកអាចមានសេចក្តីទុកចិត្តទៅលើ ព្រះអង្គនេះ។

លោកអ្នកអាចមានជំនឿជឿជាក់ទៅលើ ព្រះអង្គ លោកអ្នកអាចសម្រាកដោយសុខ ស្រួលនៅលើព្រះហស្តរបស់ទ្រង់។

ទ្រង់កំពុងហៅលោកអ្នកនៅថ្ងៃនេះ ទ្រង់កំពុងអញ្ជើញលោកអ្នកឱ្យមកនៅថ្ងៃនេះ ទ្រង់កំពុងអំពាវនាវដល់ចិត្តរបស់លោក អ្នកនៅពេលនេះ។

សូមអញ្ជើញលោកអ្នកនិយាយថា "បពិត្រ ព្រះអម្ចាស់ ទូលបង្គំនឹងទុកចិត្តទ្រង់ទាំង ស្រុង ទូលបង្គំនឹងថ្វាយជីវិតដល់ទ្រង់ឥឡូវ នេះ" នៅពេលដែលយើងអធិស្ឋាន។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!



1

ការប្រឈមមុខនឹងអនាគតដោយគ្មានការភ័យខ្លាច


2

នៅថ្ងៃដ៏ស្រឡះល្អនារដូវក្តៅមួយ ឪពុក ម្នាក់និងកូនស្រីអាយុ៩ឆ្នាំកំពុងបានហែលទឹកលេងនៅក្នុងសមុទ្រ។ ពួកគេបានបាចទឹក ដាក់គ្នានៅក្នុងរលកមួយស្របក់ រំពេចនោះ ខ្យល់ដែលមានកម្លាំងដ៏គួរឱ្យតក់ស្លុតក៏បាន
ចាប់ផ្តើមបក់មក ។

រលកក៏បានបោកទាញយកក្មេងស្រីឱ្យ ឆ្ងាយពីឪពុកបន្តិចម្តងៗ។

ឪពុកមិនអាចឈោងចាប់កូនបានឡើយ។ នាងត្រូវការជំនួយដើម្បីអាចត្រឡប់ មកកាន់ចាំងវិញបាន។

ជាសំណាងល្អ ជំនួសឱ្យការភ័យស្លន់ ស្លោ ឪពុកបានស្រែកប្រាប់កូនថា "ចូរ បណ្តែតខ្លួន ហើយហែលយ៉ាងយឺតៗចុះ កុំភ័យ ប៉ានឹងទៅយកកូន"
បន្ទាប់មកឪពុកក៏បានចេញទៅរកទូក។

នៅពេលដែលឪពុកបានត្រឡប់មក កន្លែងនោះវិញជាមួយនឹងទូក ព្រមទាំងអ្នកជួយសង្គ្រោះខ្លះផងនោះ គាត់បានធ្លាក់ថ្លើម ក្តុក។

កូនស្រីរបស់គាត់មិននៅទីនោះទេ នាង ត្រូវបានរលកបោកបក់ទៅកាន់ទឹកជ្រៅហើយ ប៉ុន្តែទីបំផុត ពេលដែលបានទៅដល់កូន របស់គាត់នោះ នាងកំពុងបានបណ្តែតខ្លួន យ៉ាងថ្នមៗដូចដែល ឪពុកនាងបានស្រែក ប្រាប់។


3

ក្រោយមកនាងត្រូវបានគេសួរថា តើ ធ្វើដូចម្តេចបានជានាងអាចបណ្តែតខ្លួនយ៉ាងថ្នមៗតែឯងនៅក្នុងទឹកសមុទ្រដ៏ជ្រៅយ៉ាងនេះ
បាន។ នាងបានឆ្លើយថា "ខ្ញុំបានធ្វើតាមអ្វី ដែលឪពុកខ្ញុំបានប្រាប់ឱ្យខ្ញុំធ្វើ។ ខ្ញុំដឹងថា គាត់នឹងមកវិញ ហើយខ្ញុំមិនខ្លាចឡើយ"។
សេចក្តីសង្ឃឹមរបស់កុមារីតូចដ៏ក្លាហាន បានជួយនាងឱ្យមានជីវិតដើម្បីរង់ចាំការជួយសង្គ្រោះ។

សេចក្តីសង្ឃឹមដ៏ធំធេងដែលរក្សាសេចក្តី ជំនឿរបស់យើងដែលជាគ្រីស្ទាន គឺការ ជឿថា ឪពុកនៅស្ថានសួគ៌របស់យើង
រៀបចំសង្គ្រោះពិភពលោកដែលស្ទើរតែវិនាសហិនហោចនេះជិតរួចរាល់ហើយ។

២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!



4

(វីដេអូ ១០វិនាទី)
ថ្មីៗនេះអ្នកវិទ្យាសាស្រ្តដ៏ល្បីល្បាញម្នាក់ បានថ្លែងអំពីសេចក្តីព្រួយបារម្ភរបស់គេថា ពិភពលោកនេះប្រហែលជាមិនអាចស្ថិតស្ថេរបានមួយពាន់ឆ្នាំទៀតឡើយ។ គាត់និយាយ ថា ជាតិពុលដែលកើតឡើងដោយមនុស្ស បង្កើតក្នុងបរិយាកាសនៃផែនដីនេះនឹង បណ្តាលឱ្យសីតុណ្ហភាពនៅលើពិភពលោក កើនឡើងខ្លាំង។


5

បង្កើនជាកំដៅរៀងរាល់ថ្ងៃ ហោកបក់នៅ លើផែនដី និងជន់លិចទីបទាំងអស់ នៅពេលដែលទឹកកកនៅតំបន់ប៉ូលរលាយ។
ប៉ុន្តែអ្នកខ្លះទៀតនិយាយថា ផែនដីនេះនឹង បញ្ចប់ទៅដោយរបៀបផ្សេងៗទៀត។



6

(វីដេអូ ៥វិនាទី) អ្នកខ្លះនិយាយថា យើង នឹងត្រូវបំផ្លាញដោយសង្គ្រាមនុយក្លេអ៊ែរ។


7

អ្នកខ្លះទៀតនិយាយថា យើងនឹងខ្វះម្ហូប អាហារ និងប្រភពផ្សេងៗទៀត នៅពេលដែលជាតិពុលនៃពិភពលោកនៅតែបន្តការរីករាលដាល។


8

នោះមានអ្នកខ្លះទៀតនិយាយថា យើង អាចនឹងត្រូវបានបោសសំអាតដោយផ្កាយដុះ កន្ទុយ ឬផ្កាយព្រះគ្រោះជល់គ្នាជាមួយនឹង ផែនដី។


9

ហើយបន្ទាប់មក មានអ្នកខ្លះទៀតគិត ថា ថ្ងៃណាមួយជនចំឡែកមកពីភពផ្សេងៗ នឹងមកបំផ្លាញយើងទាំងអស់គ្នា។
យើងទាំងអស់គ្នាភាគច្រើនពិតជាមាន រឿងជាច្រើនដែលត្រូវខ្វល់ខ្វាយ។


10

យើងខ្វល់ខ្វាយនឹងការប្រកបរបរចិញ្ចឹមជីវិត ឬក៏ការរស់នៅឱ្យត្រូវជាមួយអ្នកដទៃ ឬមួយក៏ខ្វល់ខ្វាយនឹងជម្ងឺ ទុក្ខវេទនា និងសេចក្តី ស្លាប់។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


11

ជីវិតរបស់យើងទាំងអស់គ្នាភាគច្រើន ហើយច្រើនបំផុតដែលមិនមែនជាការងាយ ស្រួល។ វាពិបាកខ្លាំងមែនទែន រហូតដល់ ពេលខ្លះ យើងប្រាថ្នាខ្លួនឯង សូមឱ្យពិភព លោកនេះវិនាសទៅ!

ជាការពិតប្រាកដណាស់ ជីវិតនេះមិន មែនបង្កើតមកសម្រាប់ឱ្យពោរពេញទៅដោយ ការឈឺចាប់ ការអត់ឃ្លាន ការព្រួយបារម្ភ និងកង្វល់ខ្វល់ខ្វាយនោះទេ។ យើងត្រូវការ ជីវិតមួយដែលប្រសើរជាងនេះ!


12

មែនហើយ មិត្តអើយ មានដំណឹងល្អមួយ! ពិភពលោកនេះកំពុងធ្វើដំណើរទៅរកទីបញ្ចប់ហើយ! ហើយនឹងមានពិភពថ្មីមួយទៀតនឹងកើត ឡើងជំនួសវិញ!


13

យើងសឹងតែទាំងអស់គ្នាចង់ដឹងថា តើ នៅពេលណា ហើយដោយរបៀបយ៉ាងណា ដែលលោកីយ៍នេះនឹងត្រូវបញ្ចប់?

តើវានឹងបញ្ចប់ទៅនៅពេលដែលយើង នៅមានជីវិតរស់នៅ ឬក៏មួយពាន់ឆ្នាំទៀត ឬមួយម៉ឺនឆ្នាំទៀត ចាប់ពីឥឡូវនេះទៅ?


14

តើគំនិតអ្នកណាមួយទៅ ដែលត្រឹមត្រូវ អំពីការបញ្ចប់នៃផែនដីនេះ?

មានហោរាជាច្រើនដែលបានទស្សន ទាយអំពីការនេះ។



15

ប៉ុន្តែការទាំងនេះកំពុងត្រូវរកឃើញ ដោយពួកហោរា ដែលការទស្សនទាយ របស់គាត់សុទ្ធតែពិតប្រាកដទាំងអស់ ហោរាដែល ការទស្សនទាយរបស់គាត់បាន កើតឡើងរួចមកហើយយ៉ាងជាក់ច្បាស់!

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!




16

(វីដេអូ ១៥វិនាទី)

ប៉ុន្តែតើលោកអ្នកដឹងទេថា មានហោរា ដែលបទទំនាយរបស់គាត់ទាំងអស់ បាន កើតមានឡើងយ៉ាងពិតប្រាកដនោះ?

ជាអ្នកដែលអាចប្រាប់យើងបានយ៉ាង ច្បាស់លាស់អំពីរបៀបដែលពិភពលោកនេះ នឹងត្រូវបញ្ចប់ និងអំពីពេលវេលាថា តើ ពិភពលោកនេះនឹងត្រូវបញ្ចប់ទៅនៅពេល ឆាប់ៗនេះ ឬមួយក៏មានអាយុ១០០០ឆ្នាំ តទៅទៀត ឬក៏ច្រើនជាងនេះ? វានឹងមិន មានការភ្ញាក់ផ្អើលឡើយ ដើម្បីនឹងដឹងថា អ្នកដែលបានបង្កើតពិភពលោកនេះ ជាអ្នក ដែលនៅទីនោះ នៅពេលដែលពិភពលោក នេះបានចាប់ផ្តើម គឺជាអ្នកដែលដឹងថា វា នឹងត្រូវបញ្ចប់ទៅវិញនៅពេលណា។

មិត្តទាំងឡាយ ព្រះយេស៊ូវគ្រីស្ទ គឺជា អ្នកដែលបង្កើតលោកីយ៍នេះ ដោយសារ ព្រះបន្ទូលរបស់ទ្រង់ ទ្រង់អាចនាំយើងឱ្យ ស្គាល់អំពីអនាគតបាន។ ទ្រង់គឺជាអ្នកដឹក នាំដែលគួរឱ្យទុកចិត្តបាន។ ទ្រង់គឺជាអ្នក ដែលអាចជ្រាបពីការបញ្ចប់នៃពិភពលោកនេះបាន ច្រើនជាងអ្នកណាៗទាំងអស់ ព្រោះ ទ្រង់ជាអ្នកដែលបានចាប់ផ្តើមពិភពលោកនេះដំបូង



17

ព្រះគម្ពីរបានប្រាប់យើងអំពីព្រឹត្តិការណ៍ ដ៏គួរឱ្យចាប់អារម្មណ៍ នៅក្នុងជីវិតរបស់ព្រះ យេស៊ូវ។

ថ្ងៃមួយពួកសិស្សបាននាំទ្រង់ទៅដោយ ឡែក ហើយបានបង្ហាញទ្រង់ទតនូវអាគារ ព្រះវិហារ ដែលទើបនឹងត្រូវបានកសាង ឡើងវិញដោយរដ្ឋាភិបាលរ៉ូម។



18

វាគឺជាអាគារដ៏ល្អមួយក្នុងចំណោមអា គារ ទាំងឡាយនៃចក្រភពរ៉ូមទាំងមូល សម្រាប់ទស្សនាដ៏ល្អមួយ។

ក្រោយពីបានទតមើលអាគារនោះហើយ ព្រះយេស៊ូវទ្រង់បានថ្លែងទៅកាន់ពួកសិស្សនូវ ប្រយោគអាថ៌កំបាំងមួយ



19

(ព្រះគម្ពីរ ម៉ាថាយ ២៤:២)

"...អ្នករាល់គ្នាឃើញវត្ថុទាំងនេះឬទេ? ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា



20

នៅទីនេះនឹងគ្មានថ្មត្រួតលើគ្នាដែលមិនត្រូវទំលាក់ចុះនោះទេ

ម៉ាថាយ ២៤:២

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


21

អាគារនេះជាអាគារដ៏ធំបំផុតនៅក្នុងជាតិ សាសន៍យូដា ហើយដែលព្រះយេស៊ូវបាន ទស្សនទាយ វានឹងត្រូវបានបំផ្លាញទាំងស្រុង។


22

ពួកសាវកមានការស្រឡាំងកាំង! នៅពេល ដែលពួកគេបានធ្វើដំណើរទៅកាន់ភ្នំដើម អូលីវ គេបានសួរនូវសំនួរមួយដែល យើងទាំងអស់គ្នាគួរនឹងសួរដែរនោះ



23

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣)

"...នោះពួកសិស្សមកឯទ្រង់ដោយឡែក ទូលសួរថា សូមប្រាប់យើងខ្ញុំ តើការទាំង នោះកាលណានឹងមកដល់?



24

តើមានទីសំគាល់ណាពីទ្រង់យាងមក ហើយពីបំផុតកល្ប?

ម៉ាថាយ ២៤:៣


25

លោកអ្នកឃើញទេ ពួកសិស្សមាន អារម្មណ៍ថា ប្រសិនបើអាគារនោះនឹងត្រូវ បានបំផ្លាញ វាមានការទាក់ទងទៅនឹងការ យាងមករបស់ព្រះគ្រីស្ទ និងទីបញ្ចប់នៃ ពិភពលោក។


26

ប៉ុន្តែនៅក្នុងព្រះគម្ពីរម៉ាថាយ ជំពូកទី ២៤ យើងរកឃើញ ព្រះយេស៊ូវបានមាន ព្រះបន្ទូលពីព្រឹត្តិការណ៍២ ខុសគ្នា


27

មួយក្នុងចំណោមព្រឹត្តិការណ៍ទាំងពីរនេះ គឺ ការយាងមកវិញរបស់ព្រះយេស៊ូវ ទ្រង់យាង ត្រឡប់មកផែនដីនេះវិញ នៅក្នុងសិរីល្អ និងការកសាងនគរដ៏នៅអស់កល្បមួយនៅលើភពផែនដីនេះ។

២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!

# ២. សញ្ញាដែលត្រូវយកចិត្តទុកដាក់!



28

(វីដេអូ ៦វិនាទី) ព្រឹត្តិការណ៍មួយទៀត គឺ
ជាព្រឹត្តិការណ៍ដែលមនុស្សរស់ក្នុងសម័យនោះជាច្រើនអាចឃើញ។
គឺជាការខូចខាតទីក្រុងយេរូសាឡិម និង ព្រះវិហារ។
ឥឡូវនេះព្រះយេស៊ូវបានបន្តមានព្រះ បន្ទូលប្រាប់ដល់ពួកសាវក នូវហេតុការណ៍
ដែលនឹងកើតមានឡើងដល់ព្រះវិហារ។


29

(ព្រះគម្ពីរ ម៉ាថាយ ២៤:១៥-១៦)
ព្រះអង្គមានព្រះបន្ទូលនៅក្នុងគម្ពីរ
ម៉ាថាយ ២៤:១៥-១៦ថា "ដូច្នេះកាលណា អ្នករាល់គ្នាឃើញសេចក្ដីដែលហោរាដានី
យ៉ែលបានទាយទុក គឺជាសេចក្ដីស្អប់ខ្ពើម ដែលបង្ខូចបំផ្លាញ


30

វាឈរនៅក្នុងទីបរិសុទ្ធ(អ្នកណាដែលអាច
មើលឱ្យយល់ចុះ)។


31

នោះត្រូវឱ្យពួកអ្នកដែលនៅស្រុកយូដារត់ចេញទៅឯភ្នំ"


32

ដានីយ៉ែលបានទាយទុកមកថា ក្រុង យេរូសាឡិមនឹងត្រូវបានបំផ្លាញ។
ប៉ុន្តែ ឥឡូវនេះ ព្រះយេស៊ូវរំលឹកដល់ ពួកសិស្សថា ការប្រកាសរបស់ហោរា
ដានីយ៉ែលជិតបានសម្រេចហើយ។


33

(ព្រះគម្ពីរ ម៉ាថាយ ២៤:១៧-១៨)
ព្រះយេស៊ូវមានព្រះបន្ទូលនៅក្នុងគម្ពីរ ម៉ាថាយ ២៤:១៧-១៨ថា: "កុំឱ្យអ្នកណា
ដែលឈរនៅលើដំបូលផ្ទះចុះមកដើម្បីនឹង យកអ្វីពីផ្ទះឡើយ


34

ហើយកុំឱ្យអ្នកដែលនៅស្រែចំការត្រឡប់មក វិញ ដើម្បីនឹងយកសំលៀកបំពាក់ដែរ"

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


35

ម្យ៉ាងវិញទៀតទ្រង់បានប្រាប់ឱ្យគេរត់ឱ្យ រួចជីវិត ពីព្រោះនៅពេលដែលគេឃើញកង ទ័ពឡោមព័ទ្ធ ទីក្រុងយេរូសាឡិម នោះការ បំផ្លាញទីក្រុងនឹងកើតមានហើយ។


36

(ព្រះគម្ពីរ លូកា ២១:២០)

នៅក្នុងព្រះគម្ពីរលូកា ២១:២០ ព្រះ យេស៊ូវមានព្រះបន្ទូលថា "ប៉ុន្តែកាលណា ឃើញពលទ័ពឡោមព័ទ្ធក្រុងយេរូសាឡិម នោះត្រូវឱ្យដឹងថា សេចក្តីហិនវិនាសនៃក្រុង នោះជិតដល់ហើយ" ហើយទ្រង់បានបន្ត មានព្រះបន្ទូលប្រាប់ពួកគេទៀតថា នៅ ពេលណាដែលពួកគេឃើញកងទ័ពទាំងនោះ ពួកគេត្រូវតែគេចខ្លួន។


37

(ព្រះគម្ពីរ លូកា ២១:២២,២៤)

"ដ្បិតគ្រានោះជាគ្រាសងសឹក ដើម្បីនឹង សម្រេចតាមគ្រប់ទាំងសេចក្តីដែលបានចែង ទុក"


38

"គេនឹងដួលនៅក្រោមមុខដាវ ហើយនិង ត្រូវដឹកនាំទៅជាឈ្លើយដល់អស់ទាំងនគរ


39

ហើយទីក្រុងយេរូសាឡិមនឹងត្រូវសាសន៍ដទៃ ជាន់ឈ្លី ដរាបដល់គ្រារបស់សាសន៍ដទៃ បានសម្រេច"


40

នៅក្នុងគ្រិស្តសករាជ៦៦ ប្រហែល៣៣ឆ្នាំ ក្រោយពីព្រះយេស៊ូវបានទស្សនទាយអំពីការ នេះ កងទ័ពរ៉ូម ក្រោមការដឹកនាំរបស់ សេស្ទុស ជាអភិបាលខេត្តរ៉ូម របស់សេរី បានមកបង្ក្រាប


41

ការបះបោរមួយ ដែលធ្វើឱ្យមានការ បាក់បែកនៅក្នុងទីក្រុងយេរូសាឡិម នៅ ពេលដែលពួកគេបានឡោមព័ទ្ធទីក្រុងនោះ ពេលនោះ ទីក្រុងបានតស៊ូទល់នឹងការ ឡោមព័ទ្ធរបស់កងទ័ពរ៉ូម។

២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!

# ២_សញ្ញាដែលត្រូវយកចិត្តទុកដាក់!


42

ហើយទីបញ្ចប់កងទ័ពរ៉ូមបានដកថយ ដោយអស់សង្ឃឹមនឹងដណ្តើមយកទីក្រុង”

(សូមមើល យូស៊ីប៊ីល ប្រវត្តិក្រុមជំនុំ សាសនាគ្រីស្ទ សៀវភៅទី៣ ជំពូក៥)



43

(វីដេអូ ៦វិនាទី) អស់អ្នកណាដែលបាន ដើរតាមការណែនាំរបស់ព្រះយេស៊ូវនោះបាន

រួចខ្លួនពីការបំផ្លាញទីក្រុងយេរូសាឡិម ហើយនិងមិនត្រូវបានសម្លាប់ឡើយ នៅ

ពេលដែលទីក្រុងនេះត្រូវបានបំផ្លាញ ដោយ ពួករ៉ូមនោះ។


44

មនុស្សប្រហែល១ ១០០ ០០០នាក់ ត្រូវ បានគេសម្លាប់ នៅក្នុងការវាយប្រហារដ៏ធំ នេះ។

ពួកគេបានបរាជ័យដោយមិនបានដើរ តាមការណែនាំរបស់ព្រះយេស៊ូវ ឱ្យភៀស ខ្លួនចេញពីទីក្រុង

នៅពេលដែលឃើញទា ហានរ៉ូមបានដកទ័ពចេញនៅឆ្នាំ៦៦ នៃ

គ្រិស្តសករាជ។

នេះជាមេរៀនដែលគួរឱ្យចាប់អារម្មណ៍ ជាខ្លាំងនៅក្នុងការសិក្សាបទទំនាយ និង

ការយកចិត្តទុកដាក់ទៅ នឹងសញ្ញានៃពេល វេលា។

អស់អ្នកណាដែលជឿដល់ព្រះគ្រីស្ទ និងរង់ចាំសញ្ញាដែលទ្រង់បានប្រាប់នោះ នឹងបានសង្គ្រោះ។

នៅពេលដែលអ្នកមិនជឿត្រូវវិនាស។

ដូច្នេះ វាជាទីបញ្ចប់នៃពិភពលោក អស់អ្នកមានជំនឿដែលបានចាំយាមនឹងត្រូវ បានរំដោះចេញ

នៅពេលដែលអ្នកដែល មិនយកចិត្តទុកដាក់ និងអ្នកមិនជឿត្រូវ

វិនាស។



45

(វីដេអូ ៥វិនាទី) ចុះតើព្រះវិហារដ៏ឆើត ឆាយនោះទៅជាយ៉ាងណា? លោកទីតុស

ដែលជាឧត្តមសេនីយ៍រ៉ូម និងជាអ្នកទទួល ខុសត្រូវនៃការកាន់កាប់ទីក្រុងយេរូសាឡិម

បានបញ្ជាឱ្យរក្សាព្រះវិហារនេះ ប៉ុន្តែទាហាន របស់គាត់ម្នាក់ បានបោះភ្លើងចន្លុះចូល តាមទ្វារ។


46

ហើយព្រះវិហារនោះក៏បានក្លាយទៅជាអណ្តាត

ភ្លើងយ៉ាងសន្ធោសន្ធៅ! គ្មានថ្មណាមួយនៅ ត្រួតលើគ្នាឡើយ

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


47

ការទស្សនទាយរបស់ព្រះយេស៊ូវ ប្រាប់ ពួកសាវករបស់ព្រះអង្គ៤០ ឆ្នាំមុនការបំផ្លាញទីក្រុងយេរូសាឡិម បានកើតមានឡើង យ៉ាងត្រឹមត្រូវ។

តើយើងនឹងធ្វើមិនដឹងមិនឮចំពោះ សញ្ញាទាំងឡាយដែលព្រះយេស៊ូវបានប្រទាន ដល់យើង ដែលទាក់ទងទៅនឹងទីបញ្ចប់នៃ ពិភពលោកនេះដែរឬទេ? ឬមួយក៏យើង ត្រូវតែយកចិត្តទុកដាក់ នឹងការប្រកាសប្រាប់ របស់ទ្រង់ ហើយរៀបចំខ្លួនជាមុន តើ យើងដឹងថា ទីបញ្ចប់នៃពិភពលោកនេះ កាន់តែជិតមកដល់ហើយដែរឬទេ?

ព្រះយេស៊ូវបានប្រទានសញ្ញាមកយើងយ៉ាង ច្បាស់


48

ចូរយើងក្រឡេកមើលទៅសញ្ញាទាំងនេះ ខ្លះៗ នៅសម័យកាលយើងនេះ! នៅក្នុង ព្រះគម្ពីរម៉ាថាយ២៤:៧ ព្រះគ្រីស្ទបានមាន ព្រះបន្ទូលថា


49

(ព្រះគម្ពីរ ម៉ាថាយ ២៤:៧)

"ពីព្រោះសាសន៍១ នឹងលើកគ្នាទាស់នឹង សាសន៍១ នគរ១ ទាស់នឹងនគរ១


50

ហើយនឹងកើតមានអំណត់ ជម្ងឺអាសន្នរោគ និងករញ្ជ្រើកដីនៅកន្លែងផ្សេងៗ" ម៉ាថាយ ២៤:៧

សតវត្សរ៍ទី២០ គឺជាសតវត្សរ៍ដែលមាន ការបង្ហូរឈាមខ្លាំងបំផុតនៅក្នុងប្រវត្តិសាស្រ្ត ពិភពលោក។



51

(វីដេអូ ២០វិនាទី) សង្គ្រាមលោកលើកទី១ គេបានឃើញមនុស្ស២០លាននាក់ បានពលីជីវិតនៅក្នុងភ្លើងសង្គ្រាម។ សង្គ្រាមលោកលើកទី២ បានបង្ហាញថា មានមនុស្ស៥០លាននាក់ត្រូវបានបាត់បង់ជីវិត។

ទោះបីជាអ្នកខ្លះបានគិតថា អំពើហឹង្សា និងសំអប់ត្រូវបានចប់ទៅហើយក៏ដោយ ក៏យើងនៅតែមានសង្គ្រាមដដែល។

ពិភពលោកនេះវាហាក់ដូចជាមានការវឹកវរហើយ។ នេះហើយគឺជាសញ្ញានៃពេល វេលា។


52

ជាតិសាសន៍នានាកំពុងទទួលសន្តិភាព ប៉ុន្តែកំពុងរៀបចំធ្វើសង្គ្រាម។ បទទំនាយក្នុងព្រះគម្ពីរមួយទៀតដែលទាក់ទងនឹងសន្តិ ភាព និងការរៀបចំសង្គ្រាម សូមអានបទ ទំនាយទាំងនេះ

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


53

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៥:៣) ដ្បិតកាលណាគេកំពុងតែនិយាយថា មាន សេចក្តីសុខសាន្ត មានសេចក្តីរៀបរយ ហើយ នោះលោតែមានសេចក្តីហិនវិនាស មកលើគេភ្លាម ដូចជាស្ត្រីមានគភ៌ ឈឺនឹង សំរាល ហើយគេចមិនរួចឡើយ
ថែស្សាឡូនីចទី១ ៥:៣។
 យើងនិយាយអំពីសន្តិភាព ប៉ុន្តែគ្មាន សន្តិភាពឡើយ! មនុស្សគ្រប់គ្នាចង់បាន សន្តិភាព ប៉ុន្តែគេបានត្រឹមតែថាតែប៉ុណ្ណោះ!


54

 ព្រះគម្ពីរបាននិយាយនៅក្នុងសម័យចុង ក្រោយបង្អស់ នៃពិភពលោកនេះថា មនុស្សនឹងមានលទ្ធភាពបំផ្លាញផែនដី។


55

(ព្រះគម្ពីរ វិវរណៈ ១១:១៨)
"អស់ទាំងសាសន៍បានមានសេចក្តីកំហឹង ហើយសេចក្តីខ្ញាល់របស់ទ្រង់ក៏មកដល់... ហើយជាពេលដែលត្រូវ បំផ្លាញពួកអ្នក ដែលបង្ខូចផែនដីផង"
 វិវរណៈ ១១:១៨
 ពីមុនមកមិនដែលមានមនុស្សណាដែល មានលទ្ធភាពនឹងបំផ្លាញធាតុដើម នៃផែន ដីនេះ ត្រូវបានបង្កើតឡើងនោះឡើយ


56

ដោយសារការបង្កើតគ្រាប់បែកនុយក្លេអ៊ែរ
ឥឡូវនេះមនុស្សអាចមានលទ្ធភាពបំផ្លាញផែនដីបានដោយខ្លួនឯង។


57

ឥឡូវនេះ ពួកភេរវជនបានរកឃើញវិធីទិញ ឬលួចអាវុធនុយក្លេអ៊ែរដែលគេបានថែរក្សា យ៉ាងប្រុងប្រយ័ត្ននេះបានម្តង។ ហើយ អាវុធដែលគេលែងប្រើទាំងនោះ បានបាត់ អស់ខ្លះទៅហើយ ហើយបានធ្លាក់ទៅក្នុង កណ្តាប់ដៃរបស់ជនមួយចំនួនដែលកំពុងតែរង់ចាំលក់ ឬប្រើប្រាស់។



58

 ទស្សនាវដ្តីដែលមានគេគោរពយ៉ាង ច្រើនមួយ បានចង្អុលបង្ហាញអំពីរបៀប បង្កើតគ្រាប់បែកនុយក្លេអ៊ែរ ឱ្យមាននៅ ក្នុងបណ្ណាល័យភាគច្រើននៅលើពិភពលោក នេះ។ ការនោះនឹងបង្ហាញឡើងយ៉ាង រហ័ស នៅលើកញ្ចក់កុំព្យូទ័រពេលណា ដែលគេចុចរកវា។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!



59

(វីដេអូ ៥វិនាទី) តើអ្នកណាដែលមាន អាវុធទាំងនេះ? ហើយនៅពេលឆាប់ៗ នៅសម័យយើងនេះ តើគេនឹងធ្វើអ្វីខ្លះទៅ?
មិនធំជាងវ៉ាលិសដាក់ខោអាវឡើយ គេអាចលួចដាក់ វាបាននៅគ្រប់ទីកន្លែង ហើយគ្រាន់តែ អាវុធនោះមួយ វាអាចនឹង បំផ្លាញទីក្រុង នៅលើពិភពលោកនេះបាន ជាច្រើន។


60

ព្រះបានមានព្រះបន្ទូលថា នឹងមានគ្រោះ ធម្មជាតិគ្រប់បែបយ៉ាង នៅសម័យចុង ក្រោយនេះ។


61

(ព្រះគម្ពីរ ម៉ាថាយ ២៤:៧)
“...នឹងមានអំណត់...”
(ម៉ាថាយ ២៤:៧)


62

នឹងមានអំណត់គ្រប់ទីកន្លែងនៅលើពិភព លោកនេះ។


63

មានការប៉ាន់ប្រមាណមួយបានបង្ហាញ ឱ្យឃើញថា មនុស្ស៥៧លាននាក់នឹងត្រូវ អត់អាហារ នៅក្នុងឆ្នាំនេះ គឺចំនួនមនុស្ស ១៥៦ ០០០នាក់ ដែលនឹងត្រូវស្លាប់ក្នុងមួយ ថ្ងៃៗដោយការអត់ឃ្លាន។


64

មនុស្សរាប់កោដិនៅលើពិភពផែនដីនេះ ចំនួន៦០ភាគរយ ត្រូវបានទទួលការចិញ្ចឹម មិនបានត្រឹមត្រូវ ហើយ២០ភាគរយទៀត នឹងត្រូវស្លាប់ដោយការអត់ឃ្លាន។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា នឹងមានអំណត់ដែលជាសញ្ញានៃការបញ្ចប់នៃ ពិភពលោកនេះ។



65

(វីដេអូ ៥វិនាទី) ប្រភពពត៌មានមួយចំនួន បានប្រាប់យើងថា នៅពេលដែលការខ្វះ ស្បៀងអាហារកាន់តែបោះជំហានទៅមុខ ពេលនោះនឹងមានអំណត់ពេញពិភពលោក ការអត់ឃ្លាន និងសង្គ្រាមអាហារនឹងកើត មានឡើង មិនអាចចៀសផុតឡើយ។

តើយើងនឹងចិញ្ចឹមមនុស្សបន្ថែមរាប់ កោដិនេះយ៉ាងណាបាន នៅពេលដែល មនុស្ស២ភាគ៣ នៃពិភពលោក ឥឡូវនេះ កំពុងតែអត់ឃ្លាននោះ?

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!



66

(ព្រះគម្ពីរ លូកា ២១:២៥)

ព្រះយេស៊ូវបានមានព្រះបន្ទូលពិពណ៌នា អំពីការទេវគ្រោះចុងក្រោយបំផុតរបស់ផែនដី នេះ ដោយមានបន្ទូលថា "...ហើយនៅ លើផែនដីនឹងមានសេចក្តីលំបាកនៅគ្រប់ទាំងសាសន៍ និងសេចក្តីទាល់គំនិត..."

លូកា២១:២៥



67

ព្រះយេស៊ូវបានមានព្រះបន្ទូលថា នឹងមាន ជម្ងឺអាសន្នរោគ



68

(ព្រះគម្ពីរ ម៉ាថាយ ២៤:៧)

"...និងមានអំណត់ ជម្ងឺអាសន្នរោគ និង រញ្ជួយផែនដីនៅកន្លែងផ្សេងៗ"

យោងតាមវចនានុក្រម ពាក្យថា ជម្ងឺ អាសន្នរោគ សព្វថ្ងៃនេះមានន័យថា ជម្ងឺ ធន់ហាន់ ឬជម្ងឺចម្លែក។


69

ថ្វីបើវេជ្ជសាស្រ្តទំនើបកំពុងមានដំណើរការ ជឿនលឿនយ៉ាងណាក៏ដោយ


70

អេដស៍ គ្រុនចាញ់ រលាកទងសួត របេង ជម្ងឺអេបូឡា ជម្ងឺកាមរោគ និងអាសន្នរោគ។


71

ឥឡូវនេះអង្គការសុខភាពពិភពលោក បានប៉ាន់ប្រមាណថា មានមនុស្សផ្ទុក មេរោគហ៊ីវចំនួន៤០លាននាក់។

មនុស្សជាតិស្ទើរតែទាំងអស់នឹងត្រូវស្លាប់ បាត់បង់ជីវិត ប្រសិនបើគេពុំមានវិធានការ បញ្ឈប់នឹងជម្ងឺអេដស៍នេះទេ។



72

សញ្ញាមួយទៀតដែលយើងបានរកឃើញ នៅក្នុងភាពក្រខ្វក់នៃបរិយាកាសរបស់យើង។ ព្រះគម្ពីរបានទស្សនទាយទុកមកថា ពិភព លោកយើងនេះនឹងកាន់តែចាស់ទៅៗ។ ព្រះគម្ពីរអេសាយ៥១:៦ ព្រះបានមានព្រះ បន្ទូលថា

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


73

(ព្រះគម្ពីរ អេសាយ ៥១:៦)

"ចូរងើយភ្នែកមើលទៅលើមេឃ ហើយ មើលចុះមកផែនដីខាងក្រោមនេះ ទៀត


74

ដ្បិតផ្ទៃមេឃនឹងសូន្យបាត់ទៅដូចជា ផ្សែង ហើយផែនដីនឹងចាស់ទៅដូចជា សំលៀកបំពាក់" ជាការពណ៌នាដ៏ល្អប្រសើរ ដែលនិយាយអំពីផ្ទៃមេឃនិងផែនដី នៅពេលដែលកំពុងមានភាពឃ្លេងឃ្លោង ឆ្ពោះ ទៅរកទីបញ្ចប់នេះ!


75

ផ្ទៃមេឃដែលគ្របដណ្តប់លើទីក្រុងធំៗ ជាច្រើនរបស់យើងកំពុងមានពេញទៅដោយជាតិគីមីពុល ដែលយើងដកដង្ហើមចូលទៅ ក្នុងសួតរបស់យើង។



76

មានសញ្ញាជាច្រើនដែលបានដាក់នៅ តាមទីក្រុងជាច្រើនសម្រាប់ប្រកាសប្រាប់អំ ពីគ្រោះថ្នាក់ នៃអាកាសធាតុពុលនេះ



77

(វីដេអូ ៥វិនាទី) នៅតាមទឹកទន្លេងជាច្រើន ទឹកពុំមានសុវត្ថិភាពអាចទទួលទានបានតទៅ ទៀតឡើយ ពីព្រោះវាមានសារធាតុ គ្រោះថ្នាក់នៅក្នុងនោះ។



78

កាកសំណល់អាតូមិក បានក្លាយជាបញ្ហា យ៉ាងធំក្នុងការចាក់វាចោល។

អ្នកធ្វើការនៅក្នុងតំបន់រោងចក្រអាតូមិក ដ៏ធំមួយត្រូវបានគេកំពុងទូទាត់សង ដោយសារតែគេត្រូវបានទទួលនូវជាតិពុលអំពីរោងចក្រនោះ។


79

តើយើងនឹងបានថាមពលទឹកបរិសុទ្ធ និងខ្យល់អាកាសបរិសុទ្ធមកពីណា? តើ យើងអាចបានចំណីអាហារមកពីណា?



80

(វីដេអូ ៦វិនាទី) ដោយសារការរីកចំរើន ខាងធាតុអាកាសកខ្វក់យ៉ាងឆាប់រហ័សនៃពិភពលោកនេះ មនុស្សត្រូវប្រឈមមុខយ៉ាងធ្ងន់ ធ្ងរ ក្នុងការរស់នៅលើផែនដីនេះ!

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


81

(ព្រះគម្ពីរ លូកា ២១:២៥)

"...ហើយនៅលើផែនដីនឹងមានសេចក្តីលំ បាកនៅគ្រប់ទាំងសាសន៍ និងសេចក្តីទាល់ គំនិត..."

លូកា ២១:២៥


82

ព្រះគម្ពីរក៏ចែងអំពីការរញ្ជួយផែនដីផងដែរ។


83

(ព្រះគម្ពីរ ម៉ាថាយ ២៤:៧)

"ហើយនឹងមាន...រញ្ជួយផែនដីនៅ កន្លែងផ្សេងៗ"

ម៉ាថាយ២៤:៧

យើងនឹងបានឃើញការរញ្ជួយផែនដី មានចំនួនកាន់តែកើនឡើងក្នុងល្បឿនយ៉ាងសំ បើម។



84

ក្នុងមួយឆ្នាំៗមានការរញ្ជួយផែនដីធំៗ ៦០០០ នៅក្នុងពិភពលោកនេះ។



85

(វីដេអូ ៦វិនាទី) តែក្នុង៩០ឆ្នាំចុងក្រោយ នេះប៉ុណ្ណោះ  យើងមានមនុស្សស្លាប់ដោយ គ្រោះថ្នាក់នេះចំនួន១ ៥០០ ០០០នាក់រួច មកហើយ។


86

នៅក្នុងមួយរយៈពេលខ្លីចុងក្រោយនេះ យើងបានឃើញការរញ្ជួយផែនដីបានយកជីវិតមនុស្សពី ២០ ០០០ ទៅ ៣០ ០០០នាក់ នៅក្នុងសន្ទឹកគ្រាំគ្រែងដ៏ធំមួយ។

បងប្អូនខ្លះប្រហែលជានៅចាំអំពីការ រញ្ជួយផែនដីថ្មីៗ នៅតាមប្រទេសផ្សេងៗ ដែលគេបានជួបប្រទះ។


87

(ព្រះគម្ពីរ លូកា ២១:១១,២៥) ព្រះ គម្ពីរសំដែងថា "ក៏នឹងមានកក្រើកដីជាខ្លាំង អំណត់ ហើយអាសន្នរោគនៅកន្លែងផ្សេងៗ


88

ទាំងមានហេតុនាំឱ្យភ័យ និងទីសំគាល់ យ៉ាងធំពីលើមេឃផង...


89

នឹងមានទីសំគាល់នៅក្នុងព្រះអាទិត្យ ក្នុង ព្រះច័ន្ទ និងក្នុងផ្កាយទាំងអស់


90

នៅលើផែនដីនឹងមានសេចក្តីលំបាកនៅ គ្រប់ទាំងសាសន៍ និងសេចក្តីទាល់គំនិត ដោយព្រោះសូរសន្ធឹក របស់សមុទ្រនិង រលក”

លូកា ២១:១១,២៥



91

(វីដេអូ ១៧វិនាទី) សូមកត់សំគាល់ថា ព្រះគម្ពីរសំដែងថា ដោយព្រោះសូរសន្ធឹក របស់សមុទ្រ និងរលក។

យើងបានឃើញអាកាសធាតុមិនធម្មតា ខ្លះហើយ នៅពាសពេញពិភពលោកយើង នេះ។

ព្យុះសង្ឃរា រលករញ្ជួយព្រះធរណី ខ្យល់គួចធំៗ ភ្នំភ្លើងផ្ទុះ ទាំងអស់នេះ កំពុងបំផ្លាញទ្រព្យសម្បត្តិ និងជីវិតមនុស្ស យ៉ាងគួរឱ្យភ័យខ្លាច។


92

ព្រះគម្ពីរបានផ្តល់ឱ្យយើងនូវសញ្ញាមួយ ទៀត។

ស្ថានភាពសីលធម៌នាចុងបំផុតកល្ប។

ព្រះយេស៊ូវបានប្រៀបធៀបស្ថានភាពនៅ ផែនដីនាសម័យចុងបំផុតនេះ ទៅនឹងទីក្រុង សូដុំម និងកូម៉ូរ៉ា ជាទីក្រុងដែលពោរពេញ ទៅដោយអំពើបាប ដែលមិនធ្លាប់មាននៅ លើពិភពលោកនេះឡើយ។ ទីបំផុត ព្រះ ទ្រង់បានបំផ្លាញទីក្រុងទាំងពីរនោះចោល ដោយភ្លើងនិងស្ពាន់ធ័រ។


93

(ព្រះគម្ពីរ លូកា ១៧:២៨,៣០)

“ក៏ដូចជានៅជំនាន់លោកឡុតដែរ


94

...នៅថ្ងៃដែលកូនមនុស្សលេចមក ក៏នឹងកើតមានដូច្នោះដែរ”

លូកា ១៧:២៨,៣០

# ២_សញ្ញាដែលត្រូវយកចិត្តទុកដាក់!



95

(ព្រះគម្ពីរ យូដាស ១:៧)

លោកយូដាសបានសរសេរថា

"...ក្រុងសូដុំម និងកូម្ម៉ូរ៉ា ហើយអស់ទាំង ទីក្រុងនៅជុំវិញដែរ ដែលគេបានប្រគល់ខ្លួនគេទៅប្រព្រឹត្តសេចក្ដីកំផិតដូចគ្នា ហើយ បណ្ដាលឱ្យទៅតាមសាសន៍ដទៃ"

យូដាស១:៧



96

លោកប៉ុលបាននិយាយអំពីស្ថានភាព សីលធម៌ដែលបង្ហាញពីអតចរិតរបស់ទីក្រុង ទាំងពីរនោះថា



97

(ព្រះគម្ពីរ រ៉ូម ១:២៦,២៧)

"...ដ្បិតទាំងពួកស្រីៗរបស់គេ ក៏បាន ផ្លាស់ប្រែទំនៀមទំលាប់ពីបវេណីចេញឱ្យខុសពីធម្មតា



98

ហើយពួកប្រុសៗក៏បែបដូច្នោះដែរ គេ បានលះបង់ទំនៀមទម្លាប់របស់ស្ត្រីពីបវេណី ចេញ ហើយបង្កើតឱ្យមានសេចក្ដីសំរើប សំរាល ដល់គ្នាទៅវិញទៅមក។



99

គឺប្រុសៗប្រព្រឹត្តនឹងប្រុសៗ....

រ៉ូម ១:២៧,២៨



100

(ព្រះគម្ពីរ ធីម៉ូថេទី២ ៣:២_៥)

"ដ្បិតនៅគ្រានោះមនុស្សនឹងស្រឡាញ់តែ ខ្លួនឯង ទាំងស្រឡាញ់ប្រាក់ អួតអាងគយរ មានឫកខ្ពស់ ប្រមាថ មើលងាយ មិន ស្ដាប់បង្គាប់ឪពុកម្ដាយ រមិលគុណ មាន ចិត្តមិនបរិសុទ្ធ។



101

មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មាន សេចក្ដីអធ្យោគ និយាយបង្កាច់គេ មិនចេះ ទប់ចិត្ត មានចិត្តសាហាវ  មិនចូលចិត្ត ការល្អ។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


102

ក្បត់គេឥតបើគិត មានចិត្តធំ ហើយ ចូលចិត្តនឹងល្បែងលេងជាជាងព្រះ។


103

គេមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែគេបដិសេធអំណាចរបស់ទ្រង់វិញ”
ធីម៉ូថេទី២ ៣:២-៥


104

(ព្រះគម្ពីរ ធីម៉ូថេទី២ ៣:១៣)
តើវាអាចអាក្រក់ជាងនេះទៅទៀតឬទេ? មែនហើយ ខ្ញុំមានការសោកស្តាយណាស់ នឹងនិយាយថា “...ហើយពួកអាក្រក់ និងពួកឆបោក គេនឹងមានជំនឿជឿទៅ ខាងសេចក្តីអាក្រក់កាន់តែខ្លាំងឡើងទាំង នាំមនុស្សឱ្យវង្វេង ហើយត្រូវវង្វេងខ្លួនឯង ផង”។


105

សញ្ញាមួយដែលសំខាន់ជាងគេបង្អស់ ដែលព្រះយេស៊ូវបានប្រទានមកនោះគឺ ការមកដល់របស់ព្រះគ្រីស្ទក្លែងក្លាយ និងហោ រាក្លែងក្លាយ ដែលនឹងលេចមកដើម្បីនឹង បំភាន់លោកីយ៍។


106

(ព្រះគម្ពីរ ម៉ាថាយ ២៤:២៣-២៤)
“គ្រានោះបើមានអ្នកណាប្រាប់អ្នករាល់ គ្នាថា មើលព្រះគ្រីស្ទគង់នៅទីនេះ ឬទីនោះ នោះកុំឱ្យជឿគេឡើយ!


107

ដ្បិតនឹងមានព្រះគ្រីស្ទក្លែង និងហោរា ក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងបញ្ឆោត


108

ទាំងអ្នករើសតាំងឱ្យវង្វេងផង បើសិន ជាបាន”
ម៉ាថាយ ២៤:២៣-២៤

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


109

(ព្រះគម្ពីរ ម៉ាថាយ ២៤:២៦)

"ដូច្នេះបើគេប្រាប់អ្នករាល់គ្នាថា មើលទ្រង់ គង់នៅទីរហោស្ថាន នោះកុំឱ្យចេញទៅ ឡើយ"

ម៉ាថាយ ២៤:២៦

មិនត្រូវទៅកន្លែងណាឡើយ ព្រោះព្រះ យេស៊ូវបានមានបន្ទូលថា


110

(ព្រះគម្ពីរ ម៉ាថាយ ២៤:២៧)

"ព្រោះដំណើរនៃកូនមនុស្សមកនោះនឹង

បានដូចជាផ្លេកបន្ទោរដែលភ្លឺផ្លេក១ពីទិសខាងកើតដល់ទិសខាងលិចដែរ។


111

នោះហើយជាការយាងមកដល់របស់កូន មនុស្ស"


112

(ព្រះគម្ពីរ វិវរណៈ ១:៧)

ទ្រង់បានប្រាប់ម្តងទៀតថា "មើល ទ្រង់យាងមកតាមពពក នោះគ្រប់ភ្នែកនឹង ឃើញទ្រង់

ព្រមទាំងពួកអ្នកដែលចាក់ទ្រង់ ផង..."

វិវរណៈ:១:៧


113

យើងនឹងឃើញទ្រង់នៅពេលដែលទ្រង់ យាងមក មិនចាំបាច់មានអ្នកណាប្រាប់ យើង

នៅពេលដែលព្រះយេស៊ូវយាងមក ជាមួយនឹងទេវតាបរិសុទ្ធរបស់ទ្រង់នោះ ឡើយ។


114

សញ្ញាដែលធំជាងគេ និងក្រោយគេ បង្អស់ ដែលព្រះយេស៊ូវបានប្រទានមក យើងនោះ

គឺដំណឹងល្អពី នគរស្ថានសួគ៌ នឹងឮដល់ចុងផែនដី។

ពីគ្រប់ទាំងសញ្ញាទាំងអស់នេះ មាន សញ្ញាតែមួយគត់ដែលមិនទាន់បានកើតឡើង នៅឡើយ។


115

(ព្រះគម្ពីរ ម៉ាថាយ ២៤:១៤)

ក្នុងព្រះគម្ពីរម៉ាថាយ ២៤:១៤ ព្រះ យេស៊ូវបានមានព្រះបន្ទូលថា "ដំណឹងល្អ

នេះដែលសំដែងពីនគរ នឹងត្រូវប្រកាស ប្រាប់ទូទៅគ្រប់ទាំងសាសន៍ក្នុងលោកីយ៍

ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍ នោះ ទើបនឹងបានដល់ចុងបំផុត"

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


116

នៅក្នុងព្រះគម្ពីរវិវរណៈយើងបានឃើញ ថា ព្រះបានពណ៌នាអំពីសេចក្តីប្រកាសនេះ


117

(ព្រះគម្ពីរ វិវរណៈ១៤:៦)

"ខ្ញុំក៏ឃើញទេវតាមួយទៀតកំពុងហោះ កាត់កណ្តាលមេឃ


118

ទាំងមានដំណឹងល្អនៅអស់កល្បជានិច្ច សម្រាប់នឹងថ្លែងប្រាប់ដល់មនុស្សនៅផែនដី


119

គឺដល់គ្រប់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងត្រកូលដែរ"

វិវរណៈ ១៤:៦

តើអ្នកដឹងថា អ្នកកំពុងឃើញការសំរេច នូវបទទំនាយនេះនៅពេលយប់នេះ ក្នុងការប្រជុំនេះដែរឬទេ?

នេះគឺជាផ្នែកមួយនៃការប្រកាសផ្សាយ ដំណឹងដ៏អស់កល្បទៅកាន់គ្រប់មនុស្សជាតិ។


120

ដំណឹងនេះកំពុងត្រូវបានប្រកាសដោយ ទូរទស្សន៍ វិទ្យុ ការប្រជុំផ្សាយដំណឹង ប្រព័ន្ធអ៊ិនធើណែត ការសិក្សាព្រះគម្ពីរ ម្នាក់ៗ និងមេរៀនទំនាក់ទំនង នៅពាស ពេញពិភពលោកយើងនេះ។


121

លោកដានីយ៉ែលបាននិយាយថា "ចំ ណេះនឹងចម្រើនឡើង "នៅថ្ងៃវិបត្តិចុង ក្រោយបង្អស់នៃប្រវត្តិសាស្ត្រពិភពលោក នេះ ព្រះគម្ពីរដានីយ៉ែលត្រូវបានបកត្រា។ ហើយនិងនាំមកនូវការរីកចំរើននៃចំណេះដឹង ខាងផែនការរបស់ព្រះ ព្រមទាំងការរីកចំ រើននៃចំណេះដឹងខាងវិទ្យាសាស្ត្រលោកីយ៍ផង ដែរ


122

ពេលវេលាកាន់តែខ្លី

អំពើបាបដែលបានបណ្តាលអោយពិភព លោកត្រូវបំផ្លាញនៅសម័យលោកណូអេនោះ នៅតែកើតមានដដែលសព្វថ្ងៃនេះ។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


123

មនុស្សហាក់កំពុងបំផ្លាញខ្លួនឯង ព្រឹត្តិការណ៍ដែលកំពុងតែកើតឡើងនៅពេល បច្ចុប្បន្ននេះជាភស្តុតាងបង្ហាញថា


124

មនុស្សនៅសម័យណូអេ បានរវល់នឹង ការចិញ្ចឹមជីវិត និងធ្វើកិច្ចការប្រចាំថ្ងៃរបស់ គេ ហើយគ្មានពេលច្រើនសម្រាប់កិច្ចការ ខាងវិញ្ញាណឡើយ។


125

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣៧-៣៩)
ព្រះយេស៊ូវមានបន្ទូលនៅក្នុងព្រះគម្ពីរម៉ាថាយ ២៤:៣៧-៣៩ ថា "ដ្បិតកាលណាកូន មនុស្សមក នោះនឹងបានដូចជាជំនាន់លោក ណូអេដែរ ។


126

ដ្បិតនៅគ្រាមុនទឹកជំនន់នោះ គេកំពុង តែស៊ីផឹក


127

ហើយរៀបការប្ដីប្រពន្ធ ដរាបដល់ថ្ងៃ ដែលលោកណូអេចូលទៅក្នុងទូកធំ


128

ហើយគេឥតបានដឹងខ្លួនឡើយ ទាល់តែ ទឹកជន់ឡើងយកគេទាំងអស់គ្នា


129

នោះដល់កាលណាកូនមនុស្សមក ក៏នឹងមាន ដូច្នោះដែរ"


130

ព្រះយេស៊ូវបានមានព្រះបន្ទូលថា ការ យាងមកជាលើកទីពីររបស់ទ្រង់ នឹងបាន ដូចជាសម័យលោកណូអេដែរ។ មនុស្សនឹង មានពេលសប្បាយរបស់គេ តែគ្មានពេល សម្រាប់ព្រះសោះ គេស្រឡាញ់ការសប្បាយ ជាជាងព្រះ។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!




131

គ្រាប់ខ្សាច់បន្តិចចុងក្រោយនៅក្នុង នាឡិកា ដីខ្សាច់ កំពុងធ្លាក់ចុះបន្តិចម្តងៗ ឥឡូវនេះ រំពេចនោះ ព្រះរាជបុត្រារបស់ ព្រះ នឹងទម្លុះផ្ទៃមេឃ និងហ្វូងតារាចុះមក ដោយមានទេវតាហែរហមដ៏ច្រើនឥតគណនា។

ព្រះទ្រង់ទន្ទឹងរង់ចាំថ្ងៃនោះយ៉ាងអន្ទះ អន្ទែង មិនមែនដើម្បីបំផ្លាញពិភពលោក នេះទេ តែដើម្បីនឹងយកភរិយារបស់ទ្រង់ ទៅកាន់ដំណាក់ទ្រង់ ដំណាក់នោះកំពុងរង់ ចាំយើង! ដំណាក់នោះបានរៀបចំរួចស្រេច ហើយ!


132

នៅពេលដែលយើងកំពុងសំឡឹងមើលទៅកាន់សញ្ញាទាំងឡាយ នៅលើពិភពលោកសព្វ ថ្ងៃនេះ យើងអាចឃើញយ៉ាងច្បាស់ថា យើងកាន់តែខិតមកជិតដល់ការយាងមកវិញ របស់ព្រះយេស៊ូវហើយ។

ព្រឹត្តិការណ៍ជាច្រើន នៅពេលបច្ចុប្បន្ន នេះ បានខិតចូលទៅកាន់ការអាក្រក់ ដូច កាលដែលទ្រង់យាងមកកាន់ផែនដីនេះ កាលពីលើកមុនហើយ។

ព្រះបានប្រទានសញ្ញាជាច្រើននៅពេល នោះ ដើម្បីឱ្យមនុស្សដឹងពីពេលវេលាដែល ព្រះអង្គនឹងយាងមកកាន់ផែនដីនេះវិញ។



133

(វីដេអូ ៧វិនាទី) នាឡិកាចោលយោលទៅ មក ៤០០០ឆ្នាំហើយ ហើយព្រះបានបញ្ជូន ទាំងទេវតា និងពួកហោរា មកប្រាប់មនុស្ស ឱ្យដឹងពីការយាងមករបស់ទ្រង់។



134

(ព្រះគម្ពីរ យ៉ូហាន ១:១១)

ប៉ុន្តែគួរឱ្យពិបាកនិយាយណាស់ថា "ទ្រង់បានយាងមកគង់នៅផែនដីរបស់ ទ្រង់ តែរាស្ត្រទ្រង់ មិនបានទទួលទ្រង់សោះ" គេមិនបានរៀបចំខ្លួនសម្រាប់ទ្រង់ឡើយ


135

មិត្តទាំងឡាយ ព្រះទ្រង់បានប្រទាន សញ្ញាទាំងនេះដល់យើង ដែលនិយាយថា ទ្រង់នឹងយាងមកវិញ។ ព្រះយេស៊ូវបាន មានបន្ទូលថា:



136

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣៣_៣៤)

"កាលណាឃើញការទាំងនោះកើតមក ត្រូវដឹងថា លោកជិតមកដល់ហើយ ក៏នៅ មាត់ទ្វារផង!

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!



137

ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្ស តំណនេះនឹងមិនទាន់កន្លងផុតទៅ ទាល់តែគ្រប់ការទាំងនេះបានកើតមកដល់”
ម៉ាថាយ ២៤:៣៣-៣៤


138

តើយើងនឹងទទួលទ្រង់នៅពេលនេះ ឬ ត្រូវអស់សង្ឃឹមម្តងទៀត? ពេលវេលាតិច ទេ តែទុនដែលយើងដាក់មានច្រើន ណាស់។

មិនត្រូវឱ្យខាតបង់ពេលវេលាបន្តិចណា សោះឡើយ។


139

នាវាប្រើចំហាយទឹកឈ្មោះអាមេរិកកណ្តាល បានចេញដំណើរពីដែននាវាក្រុងញូយ៉ក ហើយធ្វើដំណើរ ឆ្ពោះទៅកាន់ទិសខាងត្បូង តាមមហាសមុទ្រអាត្លង់ទិក ឆ្ពោះទៅកាន់ព្រែកជីកប៉ាណាម៉ា នៅពេលដែល កប៉ាល់ នោះជិតលិច  កប៉ាល់មួយទៀតបានឃើញ សញ្ញាអាសន្ន ហើយក៏ចាប់ផ្តើមចេញ ដំណើរទៅជួយ។

ប្រធាននាវិកនៃកប៉ាល់សង្គ្រោះ បាន បញ្ជូនសញ្ញាមួយទៅសួរថា “តើអ្នកមាន បញ្ហាអ្វី?”

ចម្លើយបានត្រឡប់មកវិញ “យើងកំពុង ស្ថិតនៅក្នុងការជួសជុលយ៉ាងអាសន្នមួយ សូមនៅជិតយើងរហូតដល់ព្រឹក” ហើយ អ្នកជួយសង្គ្រោះអាចឃើញកប៉ាល់នោះមាន អាសន្ន ដែលកំពុងគ្រេងឃ្លោងរកលិចនៅ ក្នុងទឹក ក៏ឆ្លើយទៅវិញថា “ឥឡូវ ខ្ញុំសុំយកអ្នកដំណើររបស់អ្នកមកកាន់ទូកខ្ញុំឥឡូវនេះ”

ប៉ុន្តែពេលរាត្រីបានមកដល់ ប្រធាននា វាអាមេរិចកណ្តាល មិនចង់ផ្ទេរអ្នកដំណើរ ដោយប្រថុយប្រថាននៅពេលងងឹតឡើយ ទើបគាត់បានឆ្លើយត្រឡប់ទៅវិញថា “សូមនៅជិតយើងរហូតទល់ភ្លឺ” ប្រធាននាវាមួយ ទៀតបានបញ្ជូនពតឹមានមួយទៀត ដោយសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់ថា ត្រូវតែផ្ទេរអ្នក ដំណើរឥឡូវនេះ។

ប៉ុន្តែគេបដិសេធ។ កប៉ាល់ជំនួយដ៏ធំ មួយបានត្រូវនៅវង់ចាំពីចម្ងាយនៅយប់នោះ ស្បែអន្ធការបានចូលមកដល់។

បុគ្គលិករបស់គេនៅលើដំបូលនាវាអាច ឃើញភ្លើងនៃកប៉ាល់អាមេរិកកណ្តាល មុជងើប១នៅក្នុងរលក ប្រហែលជាមួយ ម៉ោងកន្លះក្រោយមក ពួកគេបានមើល ដោយស្រឡាំងកាំងនៅពេលដែលពន្លឺ នោះបានបាត់ទៅ។

កប៉ាល់នោះបានលិចបាត់ទៅហើយ ហើយអ្នកដំណើរទាំងអស់ដែលជិះលើនោះ ក៏ត្រូវវិនាសទាំងអស់ដែរ។

# ២.សញ្ញាដែលត្រូវយកចិត្តទុកដាក់!


140

ការរង់ចាំអាចទទួលបាននូវលទ្ធផលជា ការបាត់បង់រហូត មានពេលវេលាដែលអ្នកត្រូវធ្វើការសម្រេចចិត្តឥឡូវនេះ។

នាយនាវិករបស់កប៉ាល់អាមេរិកកណ្តាល បានគិតថា មិនជាការអ្វីទេ ក្នុងការរង់ចាំដល់ភ្លឺឡើងនោះ។

គាត់ពិតជាមានកំហុសជាយុទ្ធសាស្ត្រ

ព្រះគម្ពីរបានសំដែងថា "ថ្ងៃនេះ គឺជា ថ្ងៃនៃការសង្គ្រោះ "សូមកុំបង្អែបង្អង់ ឬរង់ ចាំឡើយ។

ចុះតើហេតុអ្វីបានជាមិនធ្វើការសម្រេច ចិត្តទទួលព្រះគ្រីស្ទឥឡូវនេះ ?

តើអ្នកមិនថ្វាយចិត្តរបស់អ្នកទៅព្រះឥឡូវ នេះ ហើយសូមទ្រង់ជួយអ្នក ឱ្យរៀបចំខ្លួន រង់ចាំព្រះគ្រីស្ទយាងមកវិញនៅពេល ឆាប់ៗនេះឬទេ?

តើមានអ្វីក្នុងជីវិតអ្នក ដែលកំពុងរារាំង អ្នកពីការរៀបចំខ្លួន ទទួលការយាងមករបស់ព្រះយេស៊ូវនៅក្នុងពេលឆាប់ៗនេះឬ?

តើលោកអ្នកមិនបោះបង់ចោលនូវបញ្ហានៅចំ ពោះមុខនោះឥឡូវនេះ ដោយអធិស្ឋានទៅទ្រង់ទេឬអី?

ប្រសិនបើលោកអ្នកពិតជាទទួលព្រះ គ្រីស្ទយ៉ាងម៉ឺងម៉ាត់មែននោះ សូមលោក អ្នកលើកដៃឥឡូវនេះដោយនិយាយថា

"បពិត្រ ព្រះអង្គអើយ ទូលបង្គំពិតជាចង់ រៀបចំខ្លួនចាំទទួលទ្រង់ នៅពេលដែលព្រះអង្គយាងមកវិញម្តងទៀត"។

# ៣.ការភៀសខ្លួនដ៏ធំ






1

ថ្ងៃដែលអ្នកឈានចូលទៅក្នុងជីវិតអមតភាព



2

នាងម៉ារីបានអស់កម្លាំងជាខ្លាំង។ វាគឺ ជាថ្ងៃដ៏មមាញឹកមួយ។ ជីវិតរបស់នាងហាក់ដូចជាសកម្មភាពនៃខ្យល់គួច។ នាងបាន បើកឡានពីហាងលក់ទំនិញ ហើយនាងបានបត់ចុះពីផ្លូវធំទៅកាន់ផ្លូវតូចនៃជនបទ ដែលឆ្ពោះទៅផ្ទះនាង។



3

រំពេចនោះនាងបានឃើញផ្កាយធ្លាក់ពីលើ មេឃខ្មៅងងឹតនៅពេលយប់។ ដោយធ្វើឱ្យផ្ទៃមេឃភ្លឺចិញ្ចាច



4

ដោយមិនធ្លាប់ជួបប្រទះយ៉ាងដូច្នេះ នាងក៏បានជាន់បន្ថែមហ្គាឡាន។

រំពេចនោះនាងបានគិតថា "នេះគឺជាទី បញ្ចប់នៃពិភពលោកនេះហើយ!

ព្រះគ្រីស្ទនឹងយាងមកវិញ! ការដែលខ្ញុំចង់ធ្វើនោះ គឺទៅឱ្យដល់ផ្ទះ ហើយនិងនៅជាមួយនឹងកូនប្រុសរបស់ខ្ញុំ"

ដោយការមានយោបល់ទៅលើបទ ពិសោធន៍របស់នាងនោះ ក្រោយមក នាង ម៉ារីបាននិយាយថា "នៅពេលដែលខ្ញុំបាន ឃើញមេឃភ្លឺចិញ្ចាច ខ្ញុំបានគិតថា ព្រះ យេស៊ូវនឹងយាងមកនៅពេលនោះឯង"




5

តើលោកអ្នកធ្លាប់ដែលឆ្ងល់ទេថា តើពិភព លោកនេះនឹងត្រូវបញ្ចប់នៅថ្ងៃណា មួយនោះ? ប្រសិនបើធ្លាប់ ប្រហែលជាលោកអ្នក នឹងឆ្ងល់ទៀតថា តើវានឹងបញ្ចប់ទៅដោយរបៀបណា?

តើនឹងមានពួកឧត្តុនិយម ដ៏មហិមាណា អាចប្រាប់ពីសញ្ញានៃការបញ្ចប់នោះបានឬទេ?




6

(វីដេអូ ៨វិនាទី) មនុស្សខ្លះគិតថា ពិភព លោកនេះនឹងបញ្ចប់នៅក្នុងសង្គ្រាមនុយគ្លេ អ៊ែរ ដែលមនុស្សជាតិនឹងបំផ្លាញខ្លួនឯង ព្រមទាំងជីវិតទាំងឡាយនៅលើផែនដីនេះ។



7

អ្នកខ្លះទៀតគិតថា ចំនួនមនុស្សបាន កើនឡើងជាច្រើននៅលើផែនដីនេះ ជាហេតុធ្វើឱ្យគេមិនអាចរកស្បៀងអាហារ ឧបត្ថម្ភដល់មនុស្សយ៉ាងច្រើនដូច្នេះបាន ហើយអំណត់ដ៏ធំនឹងត្រូវកើតឡើង។

# ៣.ការភៀសខ្លួនដ៏ធំ



8

អ្នកខ្លះទៀតនៅតែព្រួយបារម្ភថា នឹង មានថ្ងៃណាមួយផ្កាយព្រះគ្រោះ ឬផ្កាយដុះកន្ទុយនឹងហោះមកបុកផែនដីនេះ ហើយ និងបំផ្លាញខ្ទេចខ្ទីទៅ។




9

(វីដេអូ ៨វិនាទី) ប៉ុន្តែតើលោកអ្នកជ្រាប ទេថា ជាយូរលង់មកហើយ ព្រះគម្ពីរបានទស្សនទាយយ៉ាងជាក់ច្បាស់ អំពីការដែល ពិភពលោកនេះនឹងត្រូវបានបញ្ចប់នោះ?

មិត្តទាំងឡាយ ដំណឹងល្អនោះគឺថា មនុស្សជាតិនឹងមិនត្រូវស្លាប់ដោយសង្គ្រាម ដោយអំណត់ ឬក៏ដោយសារការប៉ះទង្គិច

ទៅនឹងអ្វីមួយទៀតមកពីអវកាសនោះដែរ។



10

តាមពិត ព្រះគម្ពីរសំដែងថា ពិភពលោក នេះនឹងបញ្ចប់ទៅ ដោយសារការយាងមកវិញដ៏មានជោគជ័យរបស់ព្រះយេស៊ូវគ្រីស្ទ មកកាន់ផែនដីនេះ!

ទ្រង់នឹងយាងមកកាន់ផែនដីដដែលរបស់ ទ្រង់ ដែលទ្រង់បានចាកចេញទៅជាង ២០០០ឆ្នាំមុននេះ ហើយទ្រង់នឹងយាងត្រ ឡប់មក ដើម្បីនឹងបញ្ចប់ពេលវេលា ដែល យើងកំពុងជួបប្រទះនេះ ព្រមទាំងនាំមកនូវ ភាពអស់កល្ប



11

វាជាការសំខាន់មួយដែលមនុស្សគិតថា នឹង កើតមានឡើង នៅពេលដែលពួកគេបាន សួរថា តើគេនឹងគិតយ៉ាងណា នូវការយាង មក វិញរបស់ព្រះយេស៊ូវនោះ តើដោយរបៀបយ៉ាងដូចម្តេចទៅ?



12

មែនហើយ មិត្ត ព្រះយេស៊ូវជាស្តេច ទ្រង់នឹង យាងមកវិញឆាប់ៗនេះ ហើយគ្មានអ្វីដែលគួរឱ្យងឿងឆ្ងល់នោះទេ ថាបញ្ហានៃពិភពលោកនេះ វាលើសពីសមត្ថភាពនៃមនុស្ស ជាតិដែលអាចជួយបាន

ដែលមានតែព្រះគ្រីស្ទ និងព្រះវរបិតា របស់ទ្រង់តែប៉ុណ្ណោះ ដែលអាចនឹងកែតម្រូវបញ្ហាដ៏ធំនៃភពផែនដីនេះបាន គឺជា ព្រះពរដ៏អស្ចារ្យនៅពេលដែលព្រះអង្គយាង ត្រឡប់មកវិញ!



13

នៅពេលដែលសាវកប៉ុលជាអ្នកជាប់គុក ងងឹតនិងត្រជាក់ នៅឯគុកម៉ាមើរទីន រង់ ចាំការកាត់ទោសកាត់ករ នោះគាត់បាន សរសេរថា

# ៣.ការភៀសខ្លួនដ៏ធំ


14

(ព្រះគម្ពីរ ទីតុស ២:១៣)

"ទាំងរង់ចាំសេចក្ដីសង្ឃឹមដ៏មានពរ គឺឱ្យ បានឃើញដំណើរនៃសិរីល្អរបស់ ព្រះដ៏ជាធំ និងព្រះយេស៊ូវគ្រីស្ទជាព្រះអង្គ សង្គ្រោះនៃយើង"

ទីតុស ១:១៣។

លោកប៉ុលបានសរសេរសំបុត្រលើកទឹកចិត្ត

ដល់ទីតុស ជា "កូនពិតប្រាកដក្នុងសេចក្ដី ជំនឿ" របស់គាត់ដើម្បី រំលឹកទីតុសអំពី "ការយាងមកដ៏មានសិរីល្អ" របស់ព្រះ អម្ចាស់របស់យើង។


15

ប្រសិនបើលោកអ្នកឃើញថា ជីវិតលោក អ្នកនៅក្នុងយប់ងងឹត ក្នុងបរិយាកាសនៃ សេចក្ដីអស់សង្ឃឹម សូមសំឡឹងមើលទៅ ខាងលើ ហើយចងចាំថា "សេចក្ដីសង្ឃឹម ដ៏មានពរ" ការយាងមកជាលើទីពីររបស់ ព្រះគ្រីស្ទមកកាន់ផែនដីនេះ ដែលនឹងធ្វើឱ្យ អ្វីៗទាំងអស់បានត្រឹមត្រូវឡើងវិញ!


16

រឿងដែលបាននិយាយច្រើនជាងគេបំផុតនៅ ក្នុងព្រះគម្ពីរសញ្ញាថ្មី គឺការយាងមកជា លើកទីពីររបស់ព្រះគ្រីស្ទ។

ប្រហែលជារាល់២៥ខ មានរឿងទាក់ ទងទៅនឹងព្រឹត្តិការណ៍នេះ១ខ។

ព្រះគ្រីស្ទបានចំណាយពេលជាច្រើន ដើម្បីមានព្រះបន្ទូលអំពីរឿងនេះ ច្រើន ជាងរឿងអ្វីៗដទៃទៀតទាំងអស់ នៅក្នុង  ព្រះគម្ពីរសញ្ញាថ្មី។

មានអត្ថបទពីរនៅក្នុងសញ្ញាថ្មី ដែល អ្នកជឿទៅលើព្រះគម្ពីរគ្រប់គ្នាត្រូវតែដឹង។


17

(ព្រះគម្ពីរ យ៉ូហាន ៣:១៦)

ខព្រះគម្ពីរមួយ ដែលប្រហែលជាគេ ចេះ ច្រើនជាងគេនោះគឺ យ៉ូហាន៣:១៦

"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១


18

ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជ បុត្រានោះមិនត្រូវវិនាសឡើយ គឺឱ្យមាន ជីវិតអស់កល្បជានិច្ចវិញ"

ខទីពីរ គឺជាសេចក្ដីសន្យាដ៏ល្អមួយដែល ព្រះយេស៊ូវបានធ្វើនៅពេលដែលទ្រង់ត្រូវ ជាប់ឆ្កាង និងមុនការយាងឡើងទៅវិញបន្តិច:


19

(ព្រះគម្ពីរ យ៉ូហាន ១៤:១-៣)

"កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ ខ្ញុំដែរ។

# ៣_ការភៀសខ្លួនដ៏ធំ


20

នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំមានទីលំនៅជា ច្រើន ពុំនោះខ្ញុំបានប្រាប់អ្នករាល់គ្នា ហើយ ខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា។


21

បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះ ខ្ញុំនឹងត្រឡប់មកវិញ


22

និងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឱ្យ អ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ" យ៉ូហាន១៤:១_៣។


23

រៀងរាល់ពេលនៅក្នុងសតវត្សរ៍ទាំង ឡាយ នៅពេលណាដែលមានការធ្លាក់ ទឹកចិត្ត ការពិបាក ឬក៏សេចក្តីស្លាប់ បាន មកគំរាមកំហែងដល់សាវករបស់ព្រះយេស៊ូវ


24

ផ្កាយនៃសេចក្តីសង្ឃឹមនេះ គឺការសន្យា នៃការយាងមករបស់ទ្រង់បាន មកនាំពួក គេឱ្យមានសេចក្តីក្លាហាន និងពង្រឹងពួកគេ ឱ្យមានការទ្រាំទ្រ។

អ្នកដែលដើរតាមព្រះយេស៊ូវ តែង រង់ចាំការសម្រេចនូវសេចក្តីសន្យានេះជានិច្ច។


25

(ព្រះគម្ពីរ ធីម៉ូថេទី២ ៤:៧,៨)

ក្រោយមកទៀត នៅក្នុងជីវិតរបស់ លោកប៉ុល នៅពេលដែលគេហៀបនឹង សម្លាប់គាត់ គាត់បានប្រកាសដោយជោគ ជ័យថា

"ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រ ណាំងជាស្រេច ខ្ញុំបានរក្សាសេចក្តីជំនឿទៅ ហើយ


26

ពីនេះទៅមុខ នឹងមានមកុដនៃសេចក្តី សុចរិត ទ្រង់នឹងបំរុងទុកឱ្យខ្ញុំ ដែលព្រះ អម្ចាស់ដ៏ជាចៅក្រមសុចរិត

# ៣.ការភៀសខ្លួនដ៏ធំ


27

ទ្រង់នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ មិន មែនដល់ខ្ញុំតែម្នាក់ប៉ុណ្ណោះ គឺដល់អស់អ្នកណាដែលចូលចិត្តនឹងដំណើរទ្រង់យាងមកវិញនោះដែរ។
ធីម៉ូថេទី២ ៤:៧,៨។


28

លោកប៉ុលអាចប្រឈមមុខយ៉ាងក្លាហាន ទល់នឹងមុខដាវរបស់អ្នកបៀតបៀន នៅថ្ងៃដ៏ស្មោះត្រង់នោះ ពីព្រោះគាត់មានសេចក្តី ជំនឿក្នុងការសន្យានឹងយាងមកវិញរបស់ព្រះ គ្រីស្ទ!


29

មែនហើយ ព្រះយេស៊ូវពិតជានឹងយាងត្រឡប់ មកវិញ! ហើយ មិត្តអើយ សេចក្តីសន្យារបស់ព្រះយេស៊ូវ ចំពោះពួក សាវករបស់ទ្រង់នោះ គឺជា សេចក្តីសន្យារបស់យើងទាំងអស់គ្នាដែរ។
ព្រះយេស៊ូវនឹងយាងមកវិញ!


30

នៅពេលដែលពួកសាវកបានសួរថា តើ អ្វីទៅដែលជាសញ្ញានៃការយាងមកវិញ និង ទីបំផុតកល្បនោះ ព្រះយេស៊ូវបានប្រទាន ការរៀបរាប់យ៉ាងលំអិត អំពីព្រឹត្តិការណ៍ ដែលនឹងកើតឡើងនៅមុនពេលដែលទ្រង់ យាងមកវិញ។


31

(ព្រះគម្ពីរ ម៉ាថាយ ២៤:៤,៥)
សូមយើងទាំងអស់គ្នាអានអំពីរឿងនោះ
ព្រះយេស៊ូវបានមានព្រះបន្ទូលថា "...ចូរ
ប្រយ័ត្ន ក្រែងអ្នកណានាំអ្នករាល់គ្នាឱ្យ វង្វេងចេញផង។


32

ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះ ខ្ញុំមកនិយាយថា ខ្ញុំនេះជាព្រះគ្រីស្ទ ហើយ អ្នកទាំងនោះនឹងនាំមនុស្សជាច្រើនឱ្យវង្វេង ផង" ម៉ាថាយ ២៤:៤,៥។
នៅខទី២៤ ព្រះយេស៊ូវបានបញ្ជាក់យ៉ាង ល្អិតល្អន់អំពីរឿងនោះ។


33

(ព្រះគម្ពីរ ម៉ាថាយ ២៤:២៤)
"ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយ ហោរាក្លែងកើតឡើង គេនឹងធ្វើទីសំគាល់ យ៉ាងធំ ហើយនិងការអស្ចារ្យ

# ៣_ការភៀសខ្លួនដ៏ធំ



34

ដើម្បីនឹងនាំទាំងពួករើសតាំងឱ្យវង្វេងផង បើសិនជាបាន"



35

ប្រសិនបើយើងមិនស្គាល់ការខុសគ្នា
មិនចេះបង្ហាញភាពក្លែងក្លាយ យើងគួរ ភ្ជាប់ខ្លួនយើងទៅនឹងមនុស្សក្លែងក្លាយម្នាក់ ដោយគិតថាគេជាព្រះគ្រីស្ទ។

ព្រះយេស៊ូវបានប្រាប់ឱ្យដឹងថា វាអាច នឹងកើតឡើង! ហើយទ្រង់មិនបានមានព្រះបន្ទូលអំពីការបោកបញ្ឆោតខុសឆ្គងតូចតាចខ្លះនោះទេ។


36

ជាការពិតប្រាកដ ទ្រង់បានមានព្រះបន្ទូល អំពីការក្លែងបន្លំយ៉ាងធំអស្ចារ្យ ដែលបានរៀបចំយ៉ាងប្រុងប្រយ័ត្ន និងបានបៀត បៀន ដែលមនុស្សស្ទើរតែពាសពេញពិភពលោក នេះនឹងត្រូវទទួលការបោកបញ្ឆោតនោះ!

លោកអ្នកឃើញទេ អ្នកបោកបញ្ឆោត នេះនឹងធ្វើការអស្ចារ្យ ព្យាបាលអ្នកឈឺ ហើយនិងធ្វើការយ៉ាងហួសវិស័យមនុស្ស ដើម្បី នឹងគាំទ្រដល់ការប្រកាសអះអាង របស់គេ!


37

យើងនឹងមិនច្រឡំនូវការយាងមកវិញរបស់ព្រះគ្រីស្ទទេ!

គ្មានអ្នកណាមួយអាចធ្វើការនោះបាន ឡើយ ប៉ុន្តែយើងនឹងត្រូវបានបោកបញ្ឆោតដោយព្រះគ្រីស្ទក្លែងក្លាយ ហើយនឹងត្រូវ បានបំភាន់នៅចំពោះការលេចមករបស់ព្រះ គ្រីស្ទ! សូមគិតអំពីរឿងនេះ។


38

អារក្សនឹងប្រើព្រះគ្រីស្ទក្លែងក្លាយ និង ហោរាក្លែង ដើម្បីទាញ និងបំភាន់មនុស្សពីការយាងមកវិញជាលើកទីពីរ។



39

(ព្រះគម្ពីរ កូរិនថូសទី២ ១១:១៣,១៤)

"ដ្បិតមនុស្សទាំងនោះជាសាវកក្លែងក្លាយ ជាអ្នកឆបោកដែលក្លែងខ្លួនធ្វើជាសាវកនៃព្រះ គ្រីស្ទទេ។

# ៣_ការភៀសខ្លួនដ៏ធំ



40

ហើយសេចក្តីនោះមិនជាអស្ចារ្យឡើយ ព្រោះអារក្សសាតាំងក៏ក្លែងខ្លួនធ្វើជាទេវតានៃ ពន្លឺដែរ”

កូរិនថូសទី២ ១១:១៣,១៤។

អារក្សថែមទាំងផ្លាស់ប្តូរខ្លួនវា ហើយនិងថ្លែងបំភាន់ ពីការយាងមកវិញជា លើកទីពីររបស់ព្រះយេស៊ូវ។



41

(វីដេអូ ១៣វិនាទី) យូៗម្តងមានអ្នកខ្លះ បានលេចមកនៅលើឆាកដោយប្រកាសថាខ្លួនជាព្រះគ្រីស្ទ។

គេនឹងស្លៀកសំលៀកបំពាក់ ដូចដែល មនុស្សគិតថា ព្រះគ្រីស្ទអាចនឹងស្លៀក ពាក់យ៉ាងដូច្នោះដែរ។

គេនិយាយដោយសប្បុរស និងមានសំ ឡេងយ៉ាងពិរោះ

គេដកស្រង់ខព្រះគម្ពីរជាច្រើន

គេហាក់ដូចជាមានប្រាជ្ញា ខ្លាំងណាស់។

ពួកគេខ្លះទាក់ទាញមនុស្សឱ្យដើរតាម យ៉ាងច្រើន ដែលបានជឿថា ព្រះគ្រីស្ទបាន យាងមកកាន់ផែនដីម្តងទៀតហើយ។

ប៉ុន្តែ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំង នោះ ជាព្រះគ្រីស្ទឡើយ។

យើងអាចប្រាប់លោកអ្នកថា នោះគឺជា បោកបញ្ឆោតទាំងស្រុង

តើហេតុដូចម្តេចបានជាយើងអាចប្រាប់

ព្រោះហេតុអ្វី?

ពីព្រោះអ្នកទាំងនោះមើលទៅដូចជាព្រះ យេស៊ូវ ដែលអ្នករំពឹងថា ទ្រង់នឹងដូច្នោះ ដែរ។

គេនឹងនិយាយដូចដែលអ្នកគិតថា ព្រះ យេស៊ូវនឹងមានព្រះបន្ទូលដូច្នោះដែរ។


42

គេនឹងអាចព្យាបាលមនុស្ស ហើយនិង ធ្វើការដ៏អស្ចារ្យ ហើយការល្បួងដ៏ធំ និង ធ្វើឱ្យសង្ស័យ អំពីការដែលព្រះគម្ពីរសំដែង។

ប៉ុន្តែយើងមិនខ្លាចនឹងទុកចិត្តវិញ្ញាណរបស់ យើងឡើយ_អ្វីដែលយើងឮ_អ្វីៗដែលយើង ឃើញ និងអ្វីដែលយើងមានអារម្មណ៍!


43

មានអ្នកដឹកនាំដ៏មានសុវត្ថិភាពតែមួយប៉ុណ្ណោះដើម្បីនឹងកំណត់ថា តើអ្នកណាពិតប្រាកដ ឬអ្នកណាក្លែងក្លាយនោះ គឺព្រះគម្ពីរ។

# ៣.ការភៀសខ្លួនដ៏ធំ


44

សូមពិចារណាសញ្ញាខ្លះឬក៏លក្ខណៈ
ពិសេស១ ភ្ជាប់ទៅនឹងការយាងមកជា
លើកទីពីររបស់ព្រះគ្រីស្ទ ដើម្បីកុំឱ្យយើង ចាញ់បោកបញ្ឆោតគេ!


45

ការយាងមកជាលើកទីពីររបស់ព្រះ យេស៊ូវ គឺជាការយាងមកវិញដែលអាច មើលឃើញ


46

(ព្រះគម្ពីរ ម៉ាថាយ ២៤:២៧)
"ព្រោះដំណើរដែលកូនមនុស្សមកនោះ នឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេក១
ពីទិសខាងកើតដល់ទិសខាងលិចដែរ"
ម៉ាថាយ ២៤:២៧។


47

(ព្រះគម្ពីរ វិវរណៈ ១:៧)
"មើលទ្រង់យាងមកតាមពពក នោះគ្រប់ ទាំងភ្នែកនឹងឃើញទ្រង់..."


48

ការក្លែងបន្លំអាចលេចមកនៅទីនេះ ឬទី នោះ ប៉ុន្តែគ្មានអ្នកក្លែងបន្លំណាមួយអាច មកនៅលើពពកនាអាកាស ដើម្បីឱ្យ ភ្នែកគ្រប់គ្នាបានឃើញនោះបានឡើយ


49

បន្ទាប់ពីព្រះយេស៊ូវបានបញ្ចប់ការងារ ទ្រង់នៅលើផែនដីនេះមក ទ្រង់រៀបនឹង
ឡើងទៅកាន់ស្ថានសួគ៌វិញ។


50

ទ្រង់បាននាំយកសាវកដ៏ជិតស្និទ្ធរបស់ ទ្រង់ឡើងទៅភ្នំដើមអូលីវ ហើយបន្ទាប់ពី
ទ្រង់បានណែនាំសាវករបស់ទ្រង់ និងលា ពួកគេមក រំពេចនោះទ្រង់ត្រូវបានយក
ឡើងទៅកាន់ស្ថានសួគ៌។


51

សូមកត់សំគាល់អំពីការដែលព្រះគម្ពីរ បានសំដែងអំពីព្រឹត្តិការណ៍នេះ។

# ៣_ការភៀសខ្លួនដ៏ធំ


52

(ព្រះគម្ពីរ កិច្ចការ ១:៩_១១)
"កាលទ្រង់បានមានបន្ទូលសេចក្តីទាំងនោះ
រួចជាស្រេចហើយ ពួកសាវកកំពុងតែមើល នោះព្រះបានលើកទ្រង់ឡើងទៅ រួចមាន
ពពកមកកំបាំងពីភ្នែកគេ។


53

កំពុងដែលគេងើយសំឡឹងមើលទៅលើ
មេឃ ក្នុងកាលដែលទ្រង់យាងទៅ នោះ ឃើញមានពីរ នាក់ស្លៀកពាក់សនៅជិត


54

និយាយថា ពួកអ្នកស្រុកកាលីឡេអើយ ហេតុអ្វីបានជាឈរងើយមើលទៅលើមេឃ ដូច្នេះ?


55

ព្រះយេស៊ូវនេះឯង ដែលព្រះបានលើក ចេញពីអ្នករាល់គ្នាឡើងទៅលើស្ថានសួគ៌
ទ្រង់នឹងយាងមកវិញ តាមបែបដដែល ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ"
កិច្ចការ ១:៩_១១។


56

ទេវតាពីរអង្គមកពីព្រះ បានយាងមកដើម្បី បញ្ជាក់ដល់ពួកសាវកថា សេចក្តីសន្យា
ដែលព្រះយេស៊ូវបានប្រទានឱ្យពួកគេនោះបានសម្រេចហើយ។
ព្រះយេស៊ូវបានមានព្រះបន្ទូលយ៉ាង ច្បាស់អំពីការដែលពួកគេអាចនឹងឃើញ


57

(ព្រះគម្ពីរ លូកា ២១:២៧)
"នោះគេនឹងឃើញកូនមនុស្សមកលើពពក មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង"


58

មិនចាំបាច់អ្នកណាម្នាក់ប្រាប់អ្នកថា ព្រះយេស៊ូវនឹងយាងមកនៅពេលណានោះទេ។
អ្នកនឹងឃើញទ្រង់យាងមកលើពពក ប៉ុន្តែមានសញ្ញាមួយទៀតដែលអារក្សមិនអាច
ធ្វើតាមបាន។
ព្រះគ្រីស្ទមិនបានលេចមកមួយរំពេចនៅ កន្លែងស្ងាត់ណាមួយ ឬយាងចេញពីយាន
អវកាសនោះទេ។

# ៣.ការភៀសខ្លួនដ៏ធំ


59

ព្រះយេស៊ូវ នឹងមិនយាងមកវិញតែមួយ អង្គឯងឡើយ គឺនឹងមានសិរីរុងរឿង របស់ ទ្រង់ និងទេវតាផង!


60

(ព្រះគម្ពីរ ម៉ាថាយ ២៥:៣១)

ព្រះយេស៊ូវបានមានព្រះបន្ទូលថា "តែ កាលណាកូនមនុស្សនឹងមកក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធ ទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើ បល្ល័ង្កដ៏រុងរឿងឧត្តមរបស់លោក"

ម៉ាថាយ ២៥:៣១។


61

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣១)

តើហេតុអ្វីបានជាព្រះយេស៊ូវនាំយក ទេវតាមកជាមួយនឹងទ្រង់? ទ្រង់ប្រទាន ចម្លើយ "ហើយលោកនឹងចាត់ពួកទេវតារបស់លោក ឱ្យមកដោយសូរផ្លុំត្រែជាខ្លាំង


62

ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់ លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃ ម្ខាង រហូតដល់ជើងមេឃម្ខាង។

ម៉ាថាយ២៤:៣១។


63

មែនហើយ ព្រះយេស៊ូវនឹងត្រូវបានហែរហមដោយ ទេវតាបរិសុទ្ធ ធ្វើឱ្យផ្ទៃមេឃពោរពេញ ដោយសិរីរុងរឿង ដែលមិនអាចពិពណ៌នា បាន។

ឥឡូវនេះលោកអ្នកជ្រាបហើយ នូវ ហេតុដែលអ្នកខ្លះអះអាងថា ជាព្រះគ្រីស្ទ ក្លែងក្លាយមិនមែនជាព្រះគ្រីស្ទពិត។

នឹងមានពេលវេលាមួយ ដែលពួកគេ គ្មានលទ្ធភាព នឹងធ្វើឱ្យដូចទៅនឹងការយាង មកវិញយ៉ាងពិតប្រាកដ របស់ព្រះយេស៊ូវ នោះបានឡើយ!

គ្មានអ្នកណាម្នាក់អាចធ្វើបានឡើយ!

ប៉ុន្តែមានព្រឹត្តិការណ៍ជាច្រើនទៀតដែលទាក់ ទងទៅនឹងការយាងមករបស់ព្រះយេស៊ូវ។


64

វាគឺជាការយាងមកដែលអាចស្តាប់ឮ មួយ ហើយអ្នកដែលស្លាប់ដោយសុចរិត នឹងត្រូវបានប្រោសឱ្យរស់ឡើងវិញ

# ៣.ការភៀសខ្លួនដ៏ធំ


65

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៦)
“ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះ ពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយ ព្រះឱស្ឋ ទាំងមានសំឡេងមហាទេវតា


66

និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះ គ្រីស្ទ នឹងរស់ឡើងវិញជាមុនបង្អស់”
ថែស្សាឡូនីចទី១ ៤:១៦។


67

ដូច្នេះលោកអ្នកឃើញហើយ ការយាង មករបស់ព្រះគ្រីស្ទនឹងមិនមែនគ្រាន់តែអាច មើលឃើញប៉ុណ្ណោះទេ ប៉ុន្តែអាចស្តាប់ឮ ទៀតផង ឮដល់មនុស្សគ្រប់គ្នាទាំងអស់។
សម្លេងត្រាស់ហៅដោយព្រះ ហើយ និងសំឡេងត្រែ ដែលអ្នកស្លាប់ក្នុងព្រះគ្រីស្ទ នឹងត្រូវបានក្រោកឡើង ហើយងើបចេញ ពីផ្នូររបស់គេ។


68

តើលោកអ្នកអាចស្រមៃបានទេ នៅ ពេលដែលផ្នូរទាំងឡាយត្រូវបានបើក ហើយគ្រួសារទាំងឡាយ ត្រូវបានជួបជុំគ្នា វិញនោះ?


69

តើលោកអ្នកឃើញទេ ការដែលអារក្ស មិនអាចធ្វើបាន ដើម្បីនឹងបន្លំការយាងមក វិញពិតប្រាកដរបស់ព្រះគ្រីស្ទ


70

នៅតែមានដំណឹងល្អថែមទៀត!
សូមកត់សំគាល់ថា តើអ្នកសុចរិតដែល រស់នៅនឹងទៅជាយ៉ាងណា នៅគ្រានៃការ យាងមកជាលើកទីពីរនោះ


71

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៧)
“រួចយើងរាល់គ្នាដែលកំពុងតែរស់នៅក៏ នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់


72

យ៉ាងនោះនឹងនៅជាមួយនឹងព្រះអម្ចាស់ជា ដរាបទៅ”
ថែស្សាឡូនីចទី១ ៤:១៧។

# ៣.ការភៀសខ្លួនដ៏ធំ



73

(វីដេអូ ៤វិនាទី) អ្នកដែលដើរតាមព្រះ យេស៊ូវ ដោយស្មោះត្រង់ ត្រូវបានលើក យកទៅជាមួយនឹងអ្នកស្លាប់ដែលបានរស់ឡើងវិញ ដើម្បីនឹងជួបព្រះអម្ចាស់នៅលើអា កាស។

វាគឺជាការរួបរួមគ្នាជាថ្មីឡើងវិញមួយ ដែលនឹងកើតឡើងសម្រាប់គ្រួសារជាច្រើន។


74

លោកប៉ុលបានផ្ដល់ឱ្យយើងនូវការលំ អិតបន្ថែមទៀត អំពីការដែលនឹងកើតមាន ឡើងនៅពេលដែល ព្រះយេស៊ូវយាងត្រ ឡប់មកវិញ


75

(ព្រះគម្ពីរ កូរិនថូសទី១ ១៥:៥១_៥៣)

"នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្ដីអាថ៌ កំបាំង...តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅ


76

ក្នុងមួយរំពេចវិញ គឺក្នុងមួយប៉ព្រិចភ្នែក ប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយ បង្អស់ ដ្បិតត្រែនឹងឮឡើងមែន


77

នោះពួកអ្នកស្លាប់នឹងរស់ឡើងវិញ មិនពុក រលួយឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ ប្រែទៅ


78

ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បាន ប្រដាប់ដោយសេចក្ដីមិនពុករលួយវិញ ហើយ រូបកាយដែលរមែងស្លាប់នេះ ត្រូវតែបាន ប្រដាប់ដោយសេចក្ដីមិនចេះ ស្លាប់វិញដែរ" កូរិនថូសទី១ ១៥:៥១_៥៣


79

ព្រះនឹងប្រទានដល់អ្នកដែលដើរតាម ព្រះយេស៊ូវទាំងអស់នូវអំណោយនៃសេចក្ដី ស្រឡាញ់របស់ទ្រង់ ជីវិតអស់កល្ប។

ប្រសិនបើគ្មានអំណោយទាននៃការមិន ចេះស្លាប់នេះទេ អំណោយទានទាំងអស់នឹង សុទ្ធតែគ្មានន័យ។

# ៣.ការភៀសខ្លួនដ៏ធំ


80

(ព្រះគម្ពីរ ភីលីព ៣:២០,២១)

ហើយរបស់ខ្លះទៀតដែលព្រះនឹងប្រទានដល់ រាស្ត្ររបស់ទ្រង់:

"...ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ


81

ដែលទ្រង់នឹងបំផ្លាស់បំប្រែរូបកាយទាបថោក របស់យើង ឱ្យត្រឡប់ដូចជារូបអង្គឧត្តម របស់ទ្រង់" ភីលីព ៣:២០,២១។

រូបរាងដូចជាអង្គព្រះគ្រីស្ទ។

គ្មានជម្ងឺដំកាត់ ឬការឈឺចុកចាប់ ផ្សេងៗឡើយ:

តើមានដំណឹងអ្វីដែលគួរជាទីស្វាគមន៍ ជាងនេះឬទេ?


82

មានមនុស្សមួយផ្នែកទៀត ដែលមិន បានចាត់ទុក ការយាងមកជាលើកទីពីរនេះ ថាជាដំណឹងដែលគួរឱ្យចង់ទទួលសម្រាប់ ពួកគេឡើយ។ សូមស្តាប់ការដែលព្រះគម្ពីរ ពណ៌នាអំពីព្រឹត្តិការណ៍នៃការរញ្ជួយផែនដីនៃ ប្រវត្តិសាស្ត្រ។


83

(ព្រះគម្ពីរ វិវរណៈ ៦:១៤-១៧)

"ផ្ទៃមេឃក៏បាត់ទៅដូចជាក្រាំងដែលគេមូរ ទៅវិញ


84

ហើយគ្រប់ទាំងភ្នំ និងកោះទាំងប៉ុន្មាន ក៏ ត្រូវរើចេញពីកន្លែងផង


85

អស់ទាំងស្តេចនៅផែនដី និងពួកអ្នកធំ ពួកអ្នកមាន ពួកមេទ័ព ពួកខ្លាំងពូកែ ហើយគ្រប់ទាំងបាវបំរើ និងអ្នកជាទាំងប៉ុន្មាន


86

គេពួននៅក្នុងរអាង ហើយក្នុងក្រហែងភ្នំ ទាំងអស់គ្នា

# ៣.ការភៀសខ្លួនដ៏ធំ


87

គេអង្វរទៅភ្នំ ហើយទៅថ្មថា សូមធ្លាក់មក លើយើង ដើម្បីបំបាំងយើងពីព្រះភ័ក្ត្រព្រះ អង្គ ដែលគង់លើបល្ល័ង្ក...


88

ដ្បិតថ្ងៃធំនៃសេចក្ដីក្រោធរបស់ទ្រង់បានមក ដល់ហើយ តើអ្នកណាអាចនឹងឈរនៅ បាន?”
វិវរណៈ ៦:១៤-១៧។


89

(ព្រះគម្ពីរ វិវរណៈ ១៦:១៨)
“រួចមានផ្លេកបន្ទោរ សូរសំឡេង និងផ្គរ លាន់ ហើយមានកក្រើកដីជាខ្លាំងដែរ


90

ដល់ម៉្លេះ បានជាតាំងពីមានមនុស្សនៅផែន ដីរៀងមក នោះមិនដែលមានកក្រើកដី យ៉ាងខ្លាំង ហើយសំបើមដូច្នេះឡើយ”
វិវរណៈ ១៦:១៨។


91

ការរញ្ជួយផែនដីនេះនឹងបំបែកទីក្រុង ទាំងឡាយនៃផែនដីនេះ។
គ្មានអ្នកណា ម្នាក់អាចគេចផុតពីការ រញ្ជួយផែនដីដូច្នេះ នៅពេលដែលវាកើត ឡើង នៅគ្រានៃការយាងមក របស់ព្រះ គ្រីស្ទនោះឡើយ!


92

ព្រះយេស៊ូវបានប្រកាសឱ្យដឹងថា ការ យាងមករបស់ទ្រង់នឹងកើតឡើងនៅពេល ដែលគ្មានអ្នកណានឹកគិតពីការនោះ។
ទ្រង់ក៏បានមានព្រះបន្ទូលទៀតផងដែរ ថា មនុស្សនឹងរវល់ ខ្ជះខ្ជាយពេលវេលា នៃជីវិតរបស់គេ នៅក្នុងការសប្បាយ ផ្ដេសផ្ដាស។


93

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣០)
គម្ពីរម៉ាថាយ២៤:៣០ចែងថា នៅពេលព្រះ យេស៊ូវយាងមក
“...គ្រប់ទាំងពូជមនុស្សនៅផែន ដីនឹងគក់ទ្រូងយំ...”

# ៣_ការភៀសខ្លួនដ៏ធំ


94

នេះគឺជាការដែលព្រះយេស៊ូវបានមានបន្ទូល អំពីការដែលនឹងកើតឡើងដល់អ្នកដែលមិនបានរៀបចំខ្លួន សម្រាប់ថ្ងៃនោះ!

ពួកគេនឹងត្រូវបាត់បង់ ហើយពួកគេដឹង អំពីការនេះ!

នេះគឺជារូបភាពដ៏គួរឱ្យក្រៀមក្រំ នៅ ពេលដែលវាអាចមានការខុសគ្នាយ៉ាងដូច្នេះ នោះ។

មិត្តអើយ ថ្ងៃនោះវាពិតប្រាកដដូច្នោះ មែន! នឹងមិនមានការភ្ញាក់វិញឡើយ វាមានគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ!


95

គ្មានអ្វីនៅលើផែនដីនេះ ដែលសំខាន់ជាង ការរៀបចំខ្លួនចាំជួបព្រះយេស៊ូវ នៅពេលដែលទ្រង់យាងមកវិញនោះទេ។

ទ្រព្យសម្បត្តិនៅផែនដីនេះដែលយើងឱ្យ តម្លៃធំធេងនោះវាផុយស្រួយអ្វីម្ល៉េះទេ

មានការរញ្ជួយផែនដីមួយ រួចវានឹង បាត់បង់ទៅទាំងអស់!



96

(ព្រះគម្ពីរ លូកា ២១:៣៦)

"ដូច្នេះ ចូរចាំយាមចុះ ហើយអធិដ្ឋាន ជានិច្ច ដើម្បីឱ្យបានរាប់ជាគួរ នឹងរួចពីការ ទាំងនេះដែលត្រូវមក



97

ហើយឱ្យបានឈរនៅមុខកូនមនុស្សផង។

លូកា ២១:៣៦។



98

សូមរំលឹកឡើងវិញបន្តិចនូវអ្វីដែលយើង បានរៀន នៅពេលដែលយើងសិក្សាព្រះ គម្ពីរជាមួយគ្នា។



99

ហោរាក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយ

នឹងខំប្រឹងប្រែងបញ្ឆោតមនុស្សគ្រប់គ្នា។



100

អាក្រក់នឹងលេចមកជាទេវតានៃពន្លឺ។

# ៣.ការភៀសខ្លួនដ៏ធំ


101

ការយាងមកជាលើកទីពីរនឹងមិនមែនជា ការស្ងាត់កំបាំងឡើយ។


102

គ្រប់ភ្នែកនឹងឃើញការយាងមករបស់ ព្រះគ្រីស្ទ។


103

ទេវតាបរិសុទ្ធនឹងយាងមកជាមួយនឹង ព្រះយេស៊ូវ។


104

ទ្រង់នឹងយាងមកជាមួយនឹងស្នូរសំឡេង ត្រែ។


105

ទ្រង់នឹងយាងមកជាមួយនឹងសម្លេង មហាទេវតា


106

អ្នកស្លាប់ដោយបរិសុទ្ធ នឹងត្រូវបាន ប្រោសឱ្យរស់ឡើងវិញ។


107

អ្នកសុចរិតដែលរស់នៅនឹងមិនស្លាប់ ឡើយ។


108

អ្នកសុចរិតទាំងអស់នឹងទទួលបាននូវ ភាពមិនចេះស្លាប់។

# ៣.ការភៀសខ្លួនដ៏ធំ


109

មនុស្សដែលគ្មានព្រះនៅលើផែនដីនេះ នឹងយំទូញនៅពេលដែលគេឃើញព្រះយេស៊ូវ។


110

ការរញ្ជួយផែនដីដ៏ធំមួយនឹងបំផ្លាញ ផែនដីនេះ។


111

អ្នកមិនទទួលសេចក្តីសង្គ្រោះទាំងឡាយ នឹងត្រូវស្លាប់។


112

យើងអាចប្រាប់អំពីការយាងមករបស់ ព្រះយេស៊ូវនោះដល់មនុស្ស មិនទាំងបាន ពាក់កណ្តាលផង ឬស្លាបចាការរបស់ មនុស្ស ក៏មិនអាចសរសេររៀបរាប់បាន ឡើយ ហើយគំនិតរបស់មនុស្ស ក៏មិនអាច គិតដល់អំពីភាពរុងរឿង និងមានសិរីល្អនៃ ការយាងមកវិញដ៏មានព្រះចេស្តារបស់ព្រះគ្រីស្ទនេះបានឡើយ។

ប៉ុន្តែយើងចង់ចែកចាយជាមួយនឹង លោកអ្នក នូវគំនិតដ៏សំខាន់នេះបន្តិច អំពី ការដែលអ្នកនិពន្ធ និងវិចិត្រករ ទាំងឡាយ ដែលបានខំប្រឹងប្រែង ដើម្បីនឹងបកស្រាយ នូវការ យាងមករបស់ព្រះយេស៊ូវនេះ។ តើវាយ៉ាងដូច ម្តេច ហើយនេះជារបៀបដែលគំនិតរបស់ គេបានគិត ដូចជាសេចក្តីពណ៌នា ដែល មានចែងនៅក្នុងព្រះគម្ពីរ។


113

"នៅពេលដែលគ្មានអ្នកណាម្នាក់រំពឹង គិតពីការនោះ ព្រះយេស៊ូវនឹងយាងត្រឡប់ មកវិញ! ព្រះសូរសៀងរបស់ទ្រង់ ដូចជា សំឡេងនៃផ្គរលាន់ បន្លឺពាសពេញផែនដី ប្រកាសអំពីថ្ងៃ និងម៉ោងនៃការយាង មក វិញជាលើកទីពីរ។


114

ផ្ទៃមេឃនឹងរមូរចូលគ្នាដូចជាក្រាំង ផែនដីញ័ររញ្ជួយនៅចំពោះទ្រង់ ហើយភ្នំ និងកោះទាំងឡាយរំកិល ចេញពីកន្លែង របស់ខ្លួន។


115

រំពេចនោះ នៅទិសខាងកើត មានដុំ ពពកខ្មៅតូចមួយ មានទំហំប្រហែលប៉ុន បាទដៃមនុស្ស នឹងលេចមក។

# ៣.ការភៀសខ្លួនដ៏ធំ


116

នៅពេលដែលពពកនោះមកកាន់តែជិត ផែនដីឡើងៗ វាក៏កាន់តែភ្លឺឡើងៗ ហើយពោរពេញទៅដោយ សិរីល្អកាន់តែខ្លាំង ឡើង រហូតទាល់តែបានក្លាយទៅជាដុំពពកដ៏ធំមួយជាមួយនឹងឥន្ទធនូនៅពីលើវា។ ដោយការស្ងៀមស្ងាត់

រាស្ត្ររបស់ព្រះសម្លឹង មើលឥតដាក់ ភ្នែកនូវទស្សនីយភាពនេះដោយរកនិយាយមិនរួចឡើយ។ វាគឺជាទស្សនីយភាពដ៏អស្ចារ្យ!


117

ផ្ទៃមេឃបានបំពេញដោយពន្លឺរស្មីនៃទេវតារាប់សែនលានអង្គហែរហមព្រះយេស៊ូវជុំវិញបល្ល័ង្កទ្រង់!


118

ភាពដ៏រុងរឿងរបស់ព្រឹត្តិការណ៍នេះ បានគ្របដណ្តប់ផ្ទៃមេឃទាំងមូល ហើយនៅពេលដែលទ្រង់យាង មកកាន់តែជិត ផែនដី "គ្រប់ភ្នែក" នឹងឃើញស្តេចដែល យាងមកនោះ!

គ្មានមកុដបន្លានៅលើព្រះសិរទ្រង់ទៀត ឡើយ ប៉ុន្តែមកុដនៃសិរីរុងរឿងបានស្ថិតនៅលើថ្ងាសដ៏បរិសុទ្ធរបស់ទ្រង់ទៅវិញ។ ហើយនៅលើព្រះពស្ត្រ និងភ្លៅរបស់ព្រះអង្គមានសរសេរថា "ស្តេចលើអស់ទាំង ស្តេច ព្រះលើអស់ទាំងព្រះ"


119

ហើយអស់ទាំងស្តេចនៅផែនដី និងពួក អ្នកធំ ពួកអ្នកមាន ពួកមេទ័ព ពួកខ្លាំង ពួកែហើយគ្រប់ទាំងបាវបំរើ និងអ្នកជា ទាំងប៉ុន្មាន បានស្រែកអង្វរទៅថ្ម ឱ្យរលំ លើពួកគេដើម្បីលាក់ពីវត្តមានរបស់កូន ចៀម


120

អ្នកដែលបានបៀតបៀន និងសម្លាប់ រាស្ត្ររបស់ព្រះ ហើយអ្នកដែលចំអក និង បដិសេធព្រះគ្រីស្ទជាព្រះរាជបុត្រារបស់ ព្រះ អ្នកដែលស្រែកថា "ឆ្កាងវាទៅ ឆ្កាង វាទៅ" ត្រូវបានគេនាំមកឱ្យឈរនៅចំពោះ ព្រះភ័ក្ត្រព្រះយេស៊ូវ"

ចិត្តរបស់គេបានខ្ទេចខ្ទាំ ជង្គង់របស់គេ ត្រូវរណ្តំជាមួយគ្នា ជាមួយនឹងការស្រែកទ្រហោយំយ៉ាងអស់សង្ឃឹម។



121

ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ទ្រង់គឺជា ព្រះមែស៊ីពិតប្រាកដ

# ៣_ការរៀសខ្លួនដ៏ធំ


122

ឥឡូវនេះគេឃើញទ្រង់នៅក្នុងសិរីល្អទាំង អស់របស់ទ្រង់ ហើយនៅតែឃើញទ្រង់ កំពុងអង្គុយនៅខាងស្តាំនៃព្រះបារមី។


123

អ្នកដែលចំអកមើលងាយការដែលទ្រង់ បានអះអាងថា ទ្រង់ជាព្រះរាជបុត្រារបស់ ព្រះនោះ នឹងនៅស្ងៀមគ្មានអ្វីនិយាយឡើយ។
មានស្តេចហេរូឌ ដ៏ក្រអឺតក្រទមដែលបាន បដិសេធ នៅក្នុងព្រះរាជវាំងរបស់ទ្រង់ ហើយបានបញ្ជាឱ្យទាហាន ដ៏ចំអករបស់ ទ្រង់ពាក់ភួងបន្លាលើព្រះយេស៊ូវឱ្យធ្វើជា ស្តេច។


124

មានមនុស្សដែលខ្វះការគោរពស្រឡាញ់ ដែលបានដាក់លើព្រះពស្ត្រពណ៌ស្វាយលើ ទ្រង់ និងដាក់ភួងបន្លាលើថ្ងាសដ៏ពិសិដ្ឋ របស់ទ្រង់ ព្រមទាំងដាក់ ដំបងលើព្រះ ហស្ត ដែលមិនរឹងទទឹងរបស់ទ្រង់ ធ្វើ ត្រាប់ជាដំបងរាជ ដោយបានក្រាបចំពោះ ទ្រង់ក្នុងការចំអកដ៏ធំមួយនោះ។


125

"អ្នកដែលធ្វើឱ្យទ្រង់ឈឺចាប់ និងស្តោះ ដាក់ព្រះអម្ចាស់នៃជីវិត ឥឡូវនេះពួកគេបាន បែរចេញពីការសំឡឹងមើលយ៉ាងមុតផ្តះ ដល់ចិត្តគេរបស់ព្រះ និងរកផ្លូវគេចពីសិរី ល្អ ដែលមានអំណាចដ៏ខ្លាំងក្លានៃព្រះវត្ត មានរបស់ទ្រង់វិញ។


126

អ្នកដែលបានបោះដែកគោលទម្លុះព្រះហស្ត និងព្រះបាទរបស់ទ្រង់ ទាហានដែលបាន ចាក់ទម្លុះឆ្អឹងជំនីរទ្រង់ ក៏ឃើញសញ្ញានៃការ ភិតភ័យ និងស្តាយក្រោយ។
ជាមួយនឹងការដ៏គួរឱ្យភ័យខ្លាចយ៉ាងច្បាស់ លាស់ទាំងនេះ ពួកសង្ឃ និងអ្នកដឹកនាំទាំង ឡាយ នឹកឃើញពីព្រឹត្តិការណ៍នៃភ្នំ រលាក្បាល(កាលវ៉ារី) ។ ជាមួយនឹងការភ័យរន្ធត់ គេបាននឹកឃើញ ទង្វើរបស់ពួកគេ ក្នុងភាពរីករាយយ៉ាងក្រៃលែង ដែលពួក គេបានប្រកាសថា " វាអាចជួយអ្នកដទៃ បាន តែវាមិនអាចជួយខ្លួនវាបានទេ"។


127

ប្រសិនបើវាជាស្តេចនៃអ៊ីស្រាអែល ចូរ ឱ្យវាចុះពីលើឈើឆ្កាងមកឥឡូវនេះចុះ នោះ យើងនឹងជឿវា។ វាបានទុកចិត្តលើព្រះ សូមឱ្យទ្រង់រំដោះវាឥឡូវនេះចុះ ប្រសិនបើ វាមានព្រះមែន"

# ៣_ការភៀសខ្លួនដ៏ធំ


128

អ្នកដែលបានបំផ្លាញព្រះគ្រីស្ទនិងរាស្ត្រដ៏ ស្មោះត្រង់របស់ទ្រង់ ឥឡូវនេះបានឃើញ សិរីល្អ ដែលនៅចំពោះពួកគេ។ នៅ កណ្តាលការភ័យខ្លាច គេបានឮសំឡេងពួក បរិសុទ្ធប្រកាសឡើងដោយអំណរ



129

(ព្រះគម្ពីរ អេសាយ ២៥:៩)

"... មើល នេះគឺជាព្រះនៃយើង រាល់គ្នា យើងបានរង់ចាំទ្រង់ ហើយទ្រង់ នឹងជួយសង្គ្រោះយើង"



130

(វីដេអូ ១១វិនាទី) ភាពគ្លេងឃ្លោងនៃផែន ដីរញ្ជួយ ពន្លឺនៃផ្លេកបន្ទោរ និងសម្រែក នៃផ្គរលាន់ សំឡេងរបស់ព្រះរាជបុត្រា នៃព្រះ ហៅពួកបរិសុទ្ធដែលដេកលក់។

ទ្រង់បានទតមើលផ្នូររបស់អ្នកសុចរិត ហើយលើកព្រះហស្តទ្រង់ទៅឯស្ថានសួគ៌ ព្រមទាំងមានបន្ទូលស្រែកថា "ភ្ញាក់ឡើង ភ្ញាក់ឡើង ភ្ញាក់ឡើង អ្នកដែលដេកលក់ នៅក្នុងធូលីដីអើយ ចូរក្រោកឡើង!"


131

ទូទាំងពិភពលោក អ្នកស្លាប់នឹងឮសំឡេង របស់ទ្រង់នេះ។ ហើយផែនដីទាំងមូលនឹង ឮសម្លេងនៃការដាក់ជើងដ៏គួរឱ្យញាប់ញ័ររបស់កងទ័ពដ៏ធំនៃមនុស្សគ្រប់ទាំងសាសន៍ គ្រប់ពូជ អំបូរ និងគ្រប់ភាសា។


132

"ពួកគេបានចេញពីគុកនៃសេចក្តីស្លាប់ ស្លៀកពាក់ដោយសិរីល្អដែលមិនចេះស្លាប់ ទាំងស្រែកថា "ឱ សេចក្តីស្លាប់ តើសេចក្តី របស់ឯងនៅឯណា? ឱ ផ្នូរទាំងឡាយអើយ តើជ័យជំនះរបស់ឯងនៅឯណា?"

ហើយអ្នកសុចរិតដែលរស់នៅ និងអ្នក បរិសុទ្ធដែលបានរស់ពីស្លាប់ឡើងវិញ រួម សំឡេងរបស់គេ នៅក្នុងសម្រែកដ៏វែងនិង រីករាយនៃជ័យជំនះ។ ការសៅហ្មង និង ភាពមិនប្រក្រតីទាំងឡាយ ត្រូវបានបន្សល់ ទុកនៅក្នុងផ្នូរ។

ឱការប្រោសលោះដ៏ល្អអស្ចារ្យអើយ! គេបាននិយាយជាយូរមកហើយ គេមាន សេចក្តីសង្ឃឹមជាយូរមកហើយ គេបាន សំឡឹងមើលដោយយកចិត្តទុកដាក់បំផុត ប៉ុន្តែគេមិនដែលបានយល់ច្បាស់សោះឡើយ។


133

"អ្នកនៅរស់ដែលសុចរិត ត្រូវបានផ្លាស់ ប្តូរ មួយរំពេច នៅក្នុងពេលមួយប៉ព្រិច ភ្នែក។ នៅក្នុងព្រះសូរសៀងរបស់ទ្រង់ ពួកគេបានមានសិរីរុងរឿងយ៉ាងល្អ ឥឡូវ នេះពួកគេបានត្រូវធ្វើឱ្យលែងស្លាប់ទៀត ហើយ ហើយត្រូវបានលើកយកទៅឯស្ថាន សួគ៌ជាមួយនឹងពួកបរិសុទ្ធ ដើម្បីជួបនឹង ព្រះអម្ចាស់នៅឯអាកាស។

# ៣.ការភៀសខ្លួនដ៏ធំ


134

ទេវតាបានប្រមូលពួករើសតាំងពីទិស ទាំងបួន ពីជើងមេឃម្ខាង ដល់ជើងមេឃ ម្ខាង។ ទារកតូចៗត្រូវបានទេវតាបរិសុទ្ធ បី យកទៅប្រគល់ដល់ដៃរបស់ម្តាយគេវិញ។


135

មិត្តទាំងឡាយ ការបែកបាក់គ្នាដោយ សេចក្តីស្លាប់យ៉ាងយូរ ត្រូវបានរួបរួមគ្នា ឡើងវិញ លែងមានការបែកបាក់គ្នាទៀត ហើយ ហើយ ពួកគេឡើងជាមួយគ្នាទៅ ឯទីក្រុងរបស់ព្រះ ជាមួយនឹងចម្រៀង នៃសេចក្តីរីករាយ។


136

“ហើយនៅពេលដែលពួកគេឡើងទៅ ស្ថានសួគ៌ ទេវតាដែលកំពុងហែរហម ស្រែកឡើងថា បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ ព្រះអម្ចាស់ដែលមានគ្រប់ព្រះចេស្តា” ហើយអ្នកដែលបានប្រោសលោះបានស្រែកថា “ហាលេលូយ៉ា នៅពេលដែលពួកគេកំពុង តែរំកិលទៅកាន់ទីក្រុងបរិសុទ្ធ។


137

មុនពេលដែលចូលទៅកាន់ទីក្រុង បរិសុទ្ធ ព្រះអង្គសង្គ្រោះប្រទានអំណោយ ដល់អ្នកដែលដើរតាមទ្រង់ នូវសញ្ញានៃជ័យ ជំនះ ហើយបានដំឡើងឋានៈពួកគេនូវ គ្រឿងសំគាល់នៃរាជវង្សរបស់ទ្រង់។

ក្រសែភ្នែករបស់អ្នកដែលបានប្រោស លោះជាច្រើនរាប់មិនអស់ បានសំឡឹងទៅ ឯទ្រង់ គ្រប់ភ្នែកឃើញសិរីល្អរបស់ទ្រង់ខុស គ្នាស្រឡះពីពេលដែលទ្រង់បានជាប់ឆ្កាង ដែលព្រះភ័ក្ត្រទ្រង់ត្រូវខូច ខុសជាងធម្មតា ហើយរាងកាយទ្រង់ក៏ខុសនឹងរាងកាយរបស់ មនុស្សជាតិទាំងពួងផង។


138

នៅលើក្បាលរបស់អ្នកដែលបានឈ្នះ នោះ ព្រះយេស៊ូវ ទ្រង់កាន់មកុដនៃសិរីរុង រឿងនៅព្រះហស្តស្តាំ។ ម្នាក់ៗមានមកុដ ដែលមាន “ឈ្មោះថ្មី” ផ្ទាល់របស់គេ និងការពិពណ៌នា “ការបរិសុទ្ធរបស់ព្រះ អម្ចាស់”

អំណរដែលមិនអាចពណ៌នាបានដ៏ជាក់ លាក់ បានបំពេញចិត្តគេគ្រប់ៗគ្នា ហើយ សំឡេងរបស់គេម្នាក់ៗ បានបន្លឺឡើងក្នុង ការសរសើរដំកើងដ៏ប្រកបដោយកត្តញ្ញូតា។

# ៣. ការភៀសខ្លួនដ៏ធំ



139

នៅចំពោះហ្វូងមនុស្សដែលបានប្រោស លោះ ព្រះយេស៊ូវបើកទ្វារយ៉ាងធំ ដែលធ្វើ ពីត្បូង ហើយជាតិសាសន៍ដែលបានកាន់ តាមបញ្ញត្តិ និងមានការអត់ធ្មត់របស់ព្រះ យេស៊ូវបានចូលទៅខាងក្នុង។

នៅទីនោះហើយដែលគេឃើញស្ថានសួគ៌ របស់ព្រះ ផ្ទះរបស់អ័ដាម មុនដែលគេបាន ធ្វើបាប។

“បន្ទាប់មកសំឡេង ដែលពិរោះជាង សំឡេងភ្លេង ដែលមិនធ្លាប់ដែលបានឮ ដល់ត្រចៀករបស់មនុស្ស ទាំងមានសម្លេង និយាយថា “ការពិបាកវេទនារបស់អ្នកត្រូវ បានចប់ហើយ”




140

(ព្រះគម្ពីរ ម៉ាថាយ ២៥:៣៤)

“ឱ ពួកអ្នកដែលព្រះវរបិតាបានប្រទាន ពរអើយ ចូរមកទទួលមរតកចុះ គឺជានគរ ដែលបានរៀបចំទុកបំ រុងសម្រាប់អ្នករាល់ គ្នា” ម៉ាថាយ ២៥:៣៤។



141

នេះហើយជាសេចក្តីសង្ឃឹមរបស់យើង។ នេះហើយជាវាសនារបស់យើង។ នេះ ហើយជាអនាគតរបស់យើង។

យើងអាចរស់នៅជាមួយនឹងព្រះគ្រីស្ទ នៅឯស្ថានសួគ៌ជារៀងរហូត។

ប្រសិនបើយើងបាត់បង់ជីវិតអស់កល្ប យើងបានបាត់បង់អ្វីៗទាំងអស់។

ប្រសិនបើយើងបាត់បង់ស្ថានសួគ៌ យើង បានបាត់បង់អ្វីៗទាំងអស់។

ប្រសិនបើយើងមិនបានរៀបចំសម្រាប់ ការយាងមកវិញរបស់ព្រះគ្រីស្ទ យើងនឹង បាត់បង់នូវព្រឹត្តិការណ៍ដ៏ធំ ជាងប្រវត្តិ សាស្ត្រនៃអាយុជីវិតរបស់យើង

ព្រះយេស៊ូវមានព្រះបន្ទូលថា ...ចូរមក ចូរមកដើម្បីទទួលការអត់ឱនទោស។

ចូរមកឯសេចក្តីមេត្តាករុណា។

ចូរមកឯអំណាចលើអំពើបាបរបស់អ្នក។

ចូរមកឯជីវិតអស់កល្ប។

ចូរមក ចូលក្នុងនគររបស់ខ្ញុំ។

តើលោកអ្នកនឹងឆ្លើយតបទៅកាន់ការ អំពាវនាវរបស់ទ្រង់វិញឥឡូវនេះឬទេ? ប្រសិនបើលោកអ្នកប៉ងប្រាថ្នាចង់រស់នៅឯ នគររបស់ទ្រង់ជារៀងរហូត សូមក្រោក ឈរឡើងឥឡូវនេះនៅពេលដែល យើងអធិស្ឋាន។

# ៤. ដោយចៃដន្យ ឬដោយការរៀបចំ



1

ការរកឃើញអាថ៌កំបាំងនៃជីវិត។


2

ចូរឧបមាថា អ្នកបានរស់នៅតាមមាត់ សមុទ្រ។

នៅពេលព្រឹកមួយ អ្នកក្រោកឡើង ហើយបានសម្រេចចិត្តដើរតាមឆ្នេរខ្សាច់។

វាគឺជាទស្សនីយភាពដ៏ត្រកាលមួយដែលមាន កាំរស្មី នៃព្រះអាទិត្យរះរេរាំនៅក្នុងទឹក។ រលកបោកបក់ផ្ទប់ច្រាំង។


3

នៅពេលដែលអ្នកធ្វើដំណើរចុះទៅតាម ឆ្នេរសមុទ្រយ៉ាងស្ងៀមស្ងាត់ អ្នកបានកត់សំ គាល់ឃើញមានដានជើងមួយគូនៅលើ ខ្សាច់ពីខាងមុខអ្នក។

បន្ទាប់មកអ្នកបានឃើញដានជើងគូទីពីរ រួចគូទីបី។

អ្នកសំឡឹងមើលទៅកាន់ទីឆ្ងាយដាច់កន្ទុយភ្នែក នៅតាមឆ្នេរសមុទ្រ ប៉ុន្តែមិនបានឃើញមានអ្នកណាមួយសោះ។

តើដានជើងទាំងអស់នេះប្រាប់អ្នកពីអ្វី? វានិយាយប្រាប់យ៉ាងងាយដូច្នេះថា ទោះបី ជាអ្នកមិនអាចមើលឃើញមានអ្នកណា ម្នាក់ក៏ដោយ ក៏ពិតជាមានអ្នកណាម្នាក់នៅទី នោះដែរ។

មានអ្នកណាម្នាក់បានដើរនៅតាមឆ្នេរ សមុទ្រនៅខាងមុខអ្នក។

ខ្ញុំសូមសួរអ្នកនូវសំណួរមួយទៀត។


4

ប្រសិនបើអ្នកឈរនៅខាងក្រៅ ហើយ ក្រឡេកមើលជុំវិញ តើលោកអ្នកឃើញអ្វីខ្លះ? ស្មៅ ដើមឈើ ទួលឬភ្នំ ទឹកទន្លេ បឹងបួរ ហើយជួនកាលអ្នកឃើញសត្វ ផងទាំងឡាយ។


5

ហើយនៅពេលដែលអ្នកឈរនៅទីនោះ តើអ្នក កំពុងឈរនៅលើអ្វី? ពិតមែនហើយ អ្នកកំពុងឈរនៅលើដី លើផ្ទៃនៃផែនដី។


6

សូមក្រឡេកមើលទៅខាងលើ តើ លោកអ្នកឃើញអ្វីខ្លះ?

# ៤. ដោយចៃដន្យ ឬដោយការរៀបចំ



7

នៅពេលថ្ងៃ លោកអ្នកអាចនឹងឃើញព្រះ អាទិត្យ មេឃ ឬពពក។



8

នៅពេលយប់ លោកអ្នកអាចនឹងឃើញ ផ្កាយរាប់សែនលាន ឬក៏ជួនកាលអ្នកនឹង ឃើញព្រះច័ន្ទ។



9

តើរបស់ទាំងនោះ នៅទីនោះបានដោយ របៀបយ៉ាងណា?

តើលោកអ្នកនៅទីនេះបានដោយរបៀប យ៉ាងណា?

តើអ្នកណាបានបង្កើតលោកអ្នកមក?



10

អ្នកខ្លះនិយាយថា ជីវិតចាប់ផ្តើមឡើង ដោយកោសិកា សមញ្ញនៅក្នុងសមុទ្រ កោសិកាទាំងនោះ បានលូតលាស់ឡើង បង្កើតបានជាសត្វមានជីវិតតូចៗ ដែលផ្គុំ ឡើងដោយកោសិកាជាច្រើន

បន្ទាប់មក សត្វមានជីវិតទាំងនេះបាន ផ្លាស់ប្តូរក្នុងពេលរាប់លានឆ្នាំ ទៅជាសត្វ តូចមួយដែលអាចផ្លាស់ប្តូរទីកន្លែងពីសមុទ្រ មកដីគោកបាន នៅទីនោះហើយ ដែលវា ដុះជើងឡើង។



11

មនុស្សរាប់លាននាក់គ្រប់កាលសម័យ បានជឿលើរឿងរ៉ាវខុសគ្នាអំពីការដែលលោកសន្និវាស ផែនដី និងជីវិតទាំងអស់បាន កើតមានឡើង។

ពួកគេជឿថា ព្រះអាទិករបានបង្កើត របស់ទាំងអស់នេះឡើង។

ប៉ុន្តែតើព្រះអង្គណាមួយ?



12

មនុស្សថ្វាយបង្គំព្រះច្រើនណាស់សព្វថ្ងៃ នេះ ដូចជាព្រះពុទ្ធ ព្រះមហាម៉ាត់ ព្រះស៊ីនតូ ព្រះជាច្រើនរបស់សាសនាហិណ្ឌូ និងព្រះដទៃទៀតជាច្រើន។

អ្នកដែលថ្វាយបង្គំដល់ព្រះទាំងនោះ អះអាងថា ព្រះរបស់ពួកគេគឺជាព្រះពិត



13

ប៉ុន្តែតើលោកអ្នកដឹងទេថា ព្រះទាំង អស់នៅលើពិភពលោកនេះ មានតែព្រះ មួយអង្គទេ ដែលបានអះអាងថា ជាអ្នក បង្កើតអ្វីៗទាំងអស់នៅលើពិភពលោកនេះ?

ហើយព្រះនោះ គឺជាព្រះនៃព្រះគម្ពីរបរិសុទ្ធ។

ដូច្នេះ យើងនឹងរកមើលនូវអ្វីដែល យើងអាចរកឃើញ នៅក្នុងព្រះគម្ពីរ អំពី ព្រះដែលជាអ្នកបង្កបង្កើតរបស់ទាំងអស់នេះ។

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ




14

ប្រសិនបើលោកអ្នកឃើញផ្ទះមួយ តើ លោកអ្នកដែលបានគិតថា ផ្ទះនោះបានកើតមានឡើងដោយខ្លួនវាឬយ៉ាងណា?

ទេ លោកអ្នកដឹងប្រាកដថា ពិតជាមាន អ្នកណាម្នាក់បានសង់ផ្ទះនេះឡើង។


15

ប្រសិនបើលោកអ្នកឃើញផ្លូវមួយ តើលោកអ្នកគិតថា ផ្លូវនេះកើតឡើងដោយ ខ្លួនវា ឬមួយក៏មានអ្នកណាម្នាក់បានធ្វើវា ឡើង? មែនហើយ ផ្លូវថ្នល់ និងផ្ទះ វា ងាយជាងពិភពលោក និងមនុស្សឆ្ងាយ ណាស់។

ដូច្នេះនៅពេលដែលលោកអ្នកសំឡឹង មើលទៅឯមនុស្សនិងសត្វ តើវាមិនធ្វើឱ្យលោកអ្នកសន្និដ្ឋានថា មានអ្នកណាម្នាក់ បង្កើតឡើងទេឬអី?

គឺត្រូវតែមានអ្នកណាម្នាក់បានតាក់តែងវា និងបង្កើតវាឡើង។


16

យើងនឹងរៀនអំពីព្រះដែលអះអាងថា ជាអ្នកដែលរៀបចំ និងបង្កើតរបស់សព្វ សារពើនេះ។

សូមយើងចាប់ផ្ដើមអំពីសៀវភៅរបស់ ទ្រង់ គឺព្រះគម្ពីរនិយាយអំពីការងាររបស់ទ្រង់ក្នុងការបង្កើតផែនដី និងពិភពចក្រ វាលទាំងមូលនេះ។

ដំបូង សូមមើលនូវការដែលកើតឡើង នៅថ្ងៃទីមួយ។


17

(ព្រះគម្ពីរ លោកុប្បត្តិ ១:១)

"កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃនិងផែនដី"

លោកុប្បត្តិ ១:១


18

(ព្រះគម្ពីរ លោកុប្បត្តិ ១:៣)

"នោះព្រះទ្រង់មានបន្ទូលថា ចូរឱ្យមាន ពន្លឺឡើង ដូច្នេះពន្លឺក៏មានឡើង"

លោកុប្បត្តិ ១:៣


19

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ១:៤,៥)

"ព្រះទ្រង់ឃើញពន្លឺនោះក៏យល់ថា ជា ការល្អហើយ រួចទ្រង់ក៏ញែកពន្លឺពីងងឹតចេញ


20

នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃទី១"

លោកុប្បត្តិ ១:៥ នៅថ្ងៃទីមួយនៃសប្ដាហ៍ ព្រះបានបង្កើតផែនដីនេះ។ ទ្រង់បានបង្កើត ពន្លឺ ហើយក៏បានចាប់ផ្ដើមមានវដ្ដនៃ ថ្ងៃនិងយប់។

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


21

(ព្រះគម្ពីរ លោកុប្បត្តិ១:៦) ថ្ងៃទីពីរ

"បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរឲ្យ មានប្រឡោះនៅកណ្តាលទឹក ដើម្បីញែកទឹក ចេញពីគ្នា"

លោកុប្បត្តិ១:៦


22

(ព្រះគម្ពីរ លោកុប្បត្តិ ១:៧)

"...ហើយក៏កើតមានដូច្នោះ"

លោកុប្បត្តិ១:៧


23

(ព្រះគម្ពីរ លោកុប្បត្តិ១:៨)

"ព្រះទ្រង់ហៅប្រឡោះនោះថា ជាមេឃ នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃទី២"

លោកុប្បត្តិ ១:៨

នៅថ្ងៃទីពីរ ព្រះបានបង្កើតផ្ទៃមេឃនៅ ពីលើយើង ហើយនិងបានញែកទឹកលើ ផែនដី ចេញពីទឹកនៅលើពពកនិងនៅលើ មេឃ។


24

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ១:៩)

ថ្ងៃទី៣

"បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរ ឲ្យទឹកនៅក្រោមមេឃប្រមូលគ្នានៅកន្លែងតែ មួយ ហើយឲ្យមានទីគោកដុះលេចឡើង


25

នោះក៏មានដូច្នោះ"

លោកុប្បត្តិ ១:៩


26

(ព្រះគម្ពីរ២រូប លោកុប្បត្តិ ១:១១)

"រួចព្រះទ្រង់មានបន្ទូលថា "ចូរឲ្យដីដុះ តិណជាតិឡើង គឺជាពូជស្មៅដែលមាន គ្រាប់"


27

និងរុក្ខជាតិមានផ្លែតាមពូជ ដែលមានគ្រាប់ ក្នុងផ្លែនោះនៅផែនដី" នោះក៏មានដូច្នោះ"

លោកុប្បត្តិ ១:១១

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


28

(ព្រះគម្ពីរ លោកុប្បត្តិ ១:១៣)

"នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃ

ទី៣"

លោកុប្បត្តិ ១:១៣

ថ្ងៃទីបី ព្រះបានបង្កើតដីគោកឱ្យកើត ឡើង ទ្រង់បានបង្កើតសមុទ្រ ហើយទ្រង់បានគ្របដណ្តប់ផែនដីដោយជីវិតរុក្ខជាតិ។


29

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ១:១៤,១៥)

ថ្ងៃទីបួន

"បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរ ឱ្យមានតួពន្លឺនៅនាផ្ទៃមេឃ ដើម្បីនឹងញែក ថ្ងៃចេញពីយប់


30

សម្រាប់ទុកជាទីសំគាល់ រដូវ ថ្ងៃ និងឆ្នាំ


31

ហើយសម្រាប់ជាពន្លឺនៅផ្ទៃមេឃ ដើម្បីបំភ្លឺ មកផែនដី នោះក៏មានដូច្នោះ"

លោកុប្បត្តិ ១:១៤,១៥


32

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ១:១៨,១៩) "រួចទ្រង់ឃើញថាជាល្អ


33

នោះក៏មានល្ងាចមានព្រឹកឡើង ជាថ្ងៃទី៤"

លោកុប្បត្តិ ១:១៩។

នៅថ្ងៃទីបួន ព្រះបានបង្កើតព្រះអាទិត្យ និងព្រះច័ន្ទឱ្យកើតមានឡើងនៅលើមេឃ។ ទ្រង់ក៏បានបង្កើតផ្កាយទាំងឡាយផងដែរ។


34

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ១:២០) ថ្ងៃទីប្រាំ តើព្រះទ្រង់បានបង្កើតអ្វីនៅថ្ងៃទី ប្រាំ?

"បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរ ឱ្យមានមច្ឆាជាតិរវើកនៅក្នុងទឹកជាបរិបូរ

៤.ដោយចៃដន្យ ឬដោយការរៀបចំ

# ៤. ដោយថៃជន្យ ឬដោយការរៀបចំ


35

និងបក្សីជាតិហើរលើដី នៅនាអាកាស”

លោកុប្បត្តិ១:២០


36

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៣)

“នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃទី៥”

លោកុប្បត្តិ ១:២៣។ នៅថ្ងៃទីប្រាំ ព្រះ គម្ពីរនិយាយថា ព្រះបានបង្កើតបក្សីជាតិ និងមច្ឆាទាំងឡាយ និងជីវិតទាំងឡាយដែល មាននៅក្នុងទឹក។


37

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ១:២៤) ថ្ងៃទី៦...នៅថ្ងៃទីប្រាំមួយ នៃការបង្កបង្កើត គឺជាថ្ងៃដែលសំខាន់ជាងថ្ងៃមុនៗ ដែលកន្លងមកទាំងអស់។

“បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរ ឱ្យមានចតុប្បាទជាតិកើតមកនៅដីគោកតាម ពូជ


38

គឺជាសត្វស្រុក សត្វលូនវារ និងសត្វព្រៃ នៅផែនដីតាមពូជ នោះក៏មានដូច្នោះ”

លោកុប្បត្តិ ១:២៤


39

(ព្រះគម្ពីរ៥រូបលោកុប្បត្តិ១:២៦,២៧)

“រួចទ្រង់មានបន្ទូលថា ចូរយើងធ្វើ

មនុស្ស ឱ្យដូចជារូបយើង ឱ្យមានភាព ដូចយើង


40

ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើងបួន


41

ដែលនៅលើផែនដីទាំងមូល ព្រមទាំង សត្វលូនវារ ដែលវារនៅផែនដីផង

លោកុប្បត្តិ ១:២៦


42

ដូច្នេះព្រះបានបង្កើតមនុស្ស នៅក្នុងរូបអង្គ

ទ្រង់ តាមរូបរបស់ព្រះ ទ្រង់បានបង្កើតគេ ឡើង

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


43

ទ្រង់បានបង្កើតគេជាបុរសជាស្ត្រីឡើង"


44

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ១:៣១)

"រួចព្រះទ្រង់ទតគ្រប់ទាំងរបស់ទាំងអស់

ដែលទ្រង់បានធ្វើនោះ ក៏ឃើញថាទាំងអស់ ជាការល្អប្រពៃ


45

នោះក៏មានល្ងាច មានព្រឹកឡើងជាថ្ងៃទី៦"

លោកុប្បត្តិ ១:៣១

ថ្ងៃទីប្រាំមួយ ជាថ្ងៃដែលព្រះបានបង្កើត សត្វ ហើយបន្ទាប់មក ការបង្កើតដែល ពិសេសលើសលប់

លើអ្វីៗទាំងអស់ដែល ទ្រង់បានបង្កើតនោះ គឺបុរស(មនុស្ស)។


46

លោកអ័ដាម និងនាងអេវ៉ា មិនមែនជាការ វិវត្តន៍ ឬកើតឡើងដោយឯកឯងនោះទេ។

ព្រះគម្ពីរចែងថា ព្រះបានតាក់តែងរូបរាង គេឱ្យដូចជារូបអង្គទ្រង់ដូច្នោះដែរ។


47

ទ្រង់គឺជាវិស្វករដ៏ឧត្តម ទ្រង់គឺជា ស្ថាបត្យករដ៏ចំណាន

ដែលបាននាំយើងរាល់គ្នាឱ្យកើតឡើងមកនេះ!

ថ្ងៃទីប្រាំពីរ

នៅថ្ងៃទីប្រាំពីរ ការងាររបស់ព្រះក្នុងការ បង្កបង្កើត នោះបានចប់សព្វគ្រប់ហើយ

ដូច្នេះទ្រង់ក៏បានសំរាក។ ហើយទ្រង់បាន ញែកថ្ងៃទីប្រាំពីរនោះជាថ្ងៃបរិសុទ្ធនៃការ សម្រាក។


48

(ព្រះគម្ពីរ ៣រូប លោកុប្បត្តិ ២:១,២)

"ដូច្នេះផ្ទៃមេឃនិងផែនដីក៏បានរួចជាស្រេច ព្រមទាំងរបស់សព្វសារពើផង


49

លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើ នោះ បានហើយជាស្រេច

៤.ដោយចៃដន្យ ឬដោយការរៀបចំ

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


50

ទ្រង់ក៏ឈប់ផ្អាកសំរាកនៅថ្ងៃទី៧នោះ ពី គ្រប់ទាំងការដែលទ្រង់បានធ្វើ”
លោកុប្បត្តិ ២:១,២


51

ព្រះទ្រង់ប្រទានពរដល់ថ្ងៃទីប្រាំពីរនោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅ ថ្ងៃនោះ ទ្រង់បានឈប់សំរាកពីគ្រប់ទាំងការ ដែលទ្រង់បានបង្កើតបានធ្វើ”

យើងនឹងនិយាយអំពីថ្ងៃទីប្រាំពីរ ដែល ជាថ្ងៃបរិសុទ្ធនៃការសំរាកដែលព្រះបានបង្កើត នេះឱ្យបានច្រើនទៀត នៅពេលប្រជុំ លើកក្រោយ។


52

ដូច្នេះពេលនេះ យើងក្រឡេកមើលទៅ ឯការដែលព្រះបានបង្កើតពិភពលោកនេះ និងអ្វីៗសព្វសារពើនៅលើនោះ រាប់ទាំង មនុស្សផងដោយសង្ខេបបន្តិច។


53

សូមយើងមើលឱ្យបានជាក់លាក់ថា តើ ស្ថាបត្យករដ៏ចំណាន និងអ្នកដែលបង្ក បង្កើតដ៏អស្ចារ្យនោះ ទ្រង់មានលក្ខណៈ យ៉ាងណា។


54

រាងកាយរបស់មនុស្សផ្តល់ឱ្យយើងនូវភ័ស្តុតាងដ៏អស្ចារ្យ អំពីការតាក់តែង និងអ្នកបង្កើត។


55

សូមពិចារណា ផ្នែកដ៏តូចមួយនៃរាងកាយ យើង គឺភ្នែក



56

(វីដេអូ ១០វិនាទី) អ្នកវិទ្យាសាស្ត្រប្រាប់យើងថា បើយើងធ្វើ ការប្រៀបធៀប នូវប្រស្រី និងកូនក្រមុំភ្នែក ដែលព្រះបានតាក់តែងឡើងយ៉ាង ប្រុងប្រយ័ត្ននោះ វាបានធ្វើឱ្យម៉ាស៊ីនថតរូប ដ៏ទំនើបនៅលើផែនដីនេះ បាន ស្មើត្រឹមតែ ប្រដាប់ក្មេងលេងតែប៉ុណ្ណោះ។

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


57

ភ្នែកផ្លាស់ប្តូរពន្លឺឱ្យទៅជាដំណឹង ខួរ ក្បាលក៏យល់នៅក្នុងវិធីមួយ ដែលសូម្បីតែ មន្ទីរពិសោធន៍ដ៏ទំនើប បំផុតនៅលើពិភព លោកនេះ ក៏មិនអាចធ្វើបានដែរ។

កោសិកាខួរក្បាល ផ្លាស់ប្តូរដំណឹងនេះ ឱ្យទៅជាគំហើញ ដែលជាការមួយ គ្មានអ្វីនៅលើពិភពលោកនេះ អាចនឹងធ្វើ បាន សូម្បីតែស្រដៀងគ្នានោះក៏គ្មានផង


58

ភ្នែករបស់មនុស្សផ្តល់ភ័ស្តុតាងអំពីអ្នកបង្កើតដ៏ជាទីស្រឡាញ់ ដែលចង់ឱ្យយើងឃើញ សម្រស់ដែលទ្រង់បានបង្កើតទាំងអស់នៅលើលោកសន្និវាសនេះ។

គ្មានអ្វីដែលសង្ស័យនោះទេ ដូចគម្ពីរ ទំនុកដំកើងបានសរសេរថា:


59

(ព្រះគម្ពីរ ទំនុកដំកើង ១៣៩:១៤)

"ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិត ទ្រង់បានបង្កើតទូលបង្គំមក យ៉ាងគួរកោត គួរអស្ចារ្យ


60

ឯស្នាដៃទ្រង់ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ" ទំនុកដំកើង ១៣៩:១៤។

រូបរាងរបស់មនុស្ស និងគំនិត មានការ ស្មុគស្មាញជាខ្លាំង ហើយអាចត្រូវបានតាក់ តែងឡើង ដោយសារតែអ្នករៀបចំម្នាក់ដ៏ ចំណានប៉ុណ្ណោះ។


61

ប៉ុន្តែ ចុះតើកន្លែងផ្សេងៗទៀតនៅលើ ពិភពចក្រវាលនេះ នោះតើវាយ៉ាងណា ដែរ? តើអ្វីទៅដែលជាភ័ស្តុតាងថា ព្រះដ៏ ជាស្ថាបត្យករ បានធ្វើការក្នុងការបង្កើតពិ ភពចក្រវាលទាំងមូលនេះ?


62

លោកអេសាយ ដែលជាហោរានៃដំណឹងល្អ ជំរុញទឹកចិត្តយើងទាំងអស់គ្នាឱ្យចោលភ្នែក របស់យើង ក្រឡេកមើលទៅកាន់របស់ តូចៗ នៅជុំវិញខ្លួនយើង ហើយផ្តោត អារម្មណ៍ទៅលើវា ចំពោះអ្វីដែលព្រះបាន ធ្វើនៅលើមេឃ។


63

(ព្រះគម្ពីរ ២រូប អេសាយ ៤០:២៦)

"ចូរងើយភ្នែកឯងឡើងទៅលើ ហើយ ពិចារណាពីអ្នកណាដែលបានបង្កើតរបស់ទាំងនេះ ដែលនាំពួកពល បរិវារចេញមកតាម ចំនួនដូច្នេះ


64

ទ្រង់ក៏ហៅរបស់ទាំងនោះតាមឈ្មោះរៀងរាល់តួ ដោយព្រះចេស្តាដ៏ធំរបស់ទ្រង់

# ៤. ដោយចៃដន្យ ឬដោយការរៀបចំ



65

ហើយគ្មានណាមួយខានឡើយ

អេសាយ ៤០:២៦


66

តើលោកអ្នកធ្លាប់បានសំឡឹងមើលទៅលើ មេឃ ដែលមានផ្កាយរាប់មិនអស់នៅពីលើលោកអ្នកដែរឬទេ? តើលោកអ្នកឆ្ងល់ទេ ថា ផ្កាយទាំងអស់នេះមកពីណា ហើយថាតើវាមានចំនួនប៉ុន្មាននោះ?


67

ព្រះបានប្រើការបកស្រាយ ដើម្បីជួយយើង ឱ្យអាចយល់បានកាន់តែប្រសើរឡើង អំពី ភាពដ៏មហិមាលើសអ្វីៗទាំងអស់នេះបន្តិច។

មានពេលមួយនោះទ្រង់បាននាំលោកអ័ប្រាហាំ ដែលជាឪពុករបស់អារ៉ាប់ និងយូដាចេញទៅខាងក្រៅ ហើយបានជម្រុញគាត់ឱ្យរាប់ ផ្កាយ។



68

(ព្រះគម្ពីរ លោកុប្បត្តិ ១៥:៥)

"រួចទ្រង់នាំគាត់ចេញទៅក្រៅប្រាប់ថា ចូរមើលទៅលើមេឃឥឡូវ ហើយរាប់ផ្កាយ ចុះបើឯងអាចនឹងរាប់ទាំងអស់បាន រួច ទ្រង់មានបន្ទូលប្រាប់ថា ពូជឯងនឹងដូច្នោះ ដែរ"

លោកុប្បត្តិ ១៥:៥។


69

ថ្មីៗនេះតារាវិទូម្នាក់បាននិយាយថា ប្រ សិនបើអ្នកអាចរាប់គ្រាប់ខ្សាច់ នៅមាត់សមុទ្រទាំងអស់នៅលើពិភពលោកនេះអស់ នោះអ្នកអាចនឹងដឹងថា ចំនួនផ្កាយនៅលើមេឃមានស្មើនឹងចំនួនខ្សាច់ទាំងនោះដែរ។


70

នៅពេលក្រោយ ពេលដែលលោកអ្នក នៅឯមាត់សមុទ្រ សូមសាកល្បងរាប់គ្រាប់ខ្សាច់មួយធុងពេញលមើល។ ជាជាងចំ ណាយពេលដ៏ច្រើន!

គ្មានអ្វីគួរឱ្យឆ្ងល់ទេ ការអ្វីដែលស្តេច ដាវីឌបានមានព្រះបន្ទូលថា



71

(ព្រះគម្ពីរ ២រូប ទំនុកដំកើង ៨:៣,៤)

"កាលណាទូលបង្គំពិចារណាមើលផ្ទៃ មេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ គឺទាំងខែ និងផ្កាយ ដែលទ្រង់បាន ប្រតិស្ឋានទុក

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


72

នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករំឭក ដល់គេ ហើយកូនមនុស្សផង ដែលទ្រង់ ប្រោសដូច្នេះ"
ទំនុកដំកើង ៨:៣,៤



73

(វីដេអូ ២០វិនាទី) តើលោកអ្នកដែលឆ្ងល់ ទេថា តើព្រះដ៏មាន អំណាចដែលគ្រប់ គ្រង ជាបន្តនូវពិភព ចក្រវាលដ៏ធំធេង នេះ ពិតប្រាកដជាយក ព្រះទ័យទុកដាក់ ចំពោះបញ្ហាផ្សេងៗរបស់ យើងនៅលើផែន ដីនេះមែនឬទេ?

មែនហើយ ព្រះយេស៊ូវបានមានព្រះបន្ទូលថា គ្មានចាបណា សូម្បីតែមួយដែលធ្លាក់មកដី ដែលព្រះទ្រង់មិនបានយក ព្រះទ័យទុកដាក់ នោះឡើយ។


74

(ព្រះគម្ពីរ ម៉ាថាយ ១០:៣១)
"យ៉ាងនោះមិនត្រូវឱ្យខ្លាចឡើយ អ្នករាល់ គ្នាមានតម្លៃលើសជាងចាបជាច្រើន

ហើយដើម្បីនឹងបញ្ជាក់អំពីសេចក្តីស្រ ឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះ ឱ្យកាន់តែច្បាស់នោះ ព្រះយេស៊ូវបានមាន ព្រះបន្ទូលថា


75

(ព្រះគម្ពីរ ម៉ាថាយ ១០:៣០)
"សូម្បីតែសក់ក្បាលរបស់អ្នករាល់គ្នា ក៏បានរាប់ទាំងអស់ដែរ"
ម៉ាថាយ ១០:៣០។

នេះគឺជាព្រះដ៏អស្ចារ្យ!


76

តើមានសិទ្ធិអ្វីដែលព្រះនៃព្រះគម្ពីរអះ អាងថា មនុស្សគ្រប់គ្នាត្រូវតែថ្វាយបង្គំទ្រង់ ទាំងស្រុងនោះ?

ព្រះនៃព្រះគម្ពីរ និងជាព្រះនៃសាសនា គ្រីស្ទអះអាងថា ទ្រង់មានសិទ្ធិទទួលការ ថ្វាយបង្គំ និងភក្តីភាពរបស់យើង ពីព្រោះ ទ្រង់ជាព្រះដែលបានបង្កើតអ្វីៗទាំងអស់។


77

ប្រសិនបើទ្រង់ពិតដូចជាការដែលទ្រង់ អះអាងមែន ទ្រង់គឺជាអ្នកបង្កើត នោះ ទ្រង់ពិតជាអាចទទួល ការថ្វាយបង្គំរបស់ យើង ហើយតើលោកអ្នកយល់ស្របដូច្នោះ ដែរឬទេ?


78

នៅពេលដែលលោកយ៉ូហាន ដែលជា សាវកម្នាក់របស់ព្រះយេស៊ូវ ហើយដែលជា អ្នកសរសេរសៀវភៅ ចុងក្រោយបង្អស់នៃ ព្រះគម្ពីរ វិវរណៈបានឃើញការជាក់ស្តែង នៅឯកោះផាត់ម៉ូស គាត់ត្រូវបានបង្ហាញនូវ ទស្សនីយភាព របស់បន្ទប់នៃបល្ល័ង្កនៅ ស្ថានសួគ៌

សូមកត់សំគាល់នូវអ្វីដែលគាត់បានឃើញ

# ៤.ដោយថែដន្យ ឬដោយការរៀបចំ



79

(ព្រះគម្ពីរ ៤រូប វិវរណៈ៤:១០,១១)

"នោះពួកចាស់ទុំទាំង២៤នាក់ ក៏ទម្លាក់ ខ្លួន ក្រាបចុះនៅចំពោះព្រះអង្គដែលគង់លើ បល្ល័ង្កទាំងថ្វាយបង្គំដល់ព្រះ



80

ដ៏មានព្រះជន្មរស់នៅអស់កល្បជានិច្ចរៀងរាបតទៅនោះ ហើយក៏ដាក់មកុដខ្លួនចុះ ក្រាប នៅមុខ បល្ល័ង្កដោយទូលថា



81

ឱ ព្រះអម្ចាស់នៃយើងរាល់គ្នាអើយ ទ្រង់ គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា



82

ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើ"

វិវរណៈ ៤:១០,១១



83

ចាស់ទុំនៅមុខបល្ល័ង្ករបស់ព្រះទាំងនេះ កំ ពុងសរសើរដំកើងព្រះ និងថ្វាយបង្គំទ្រង់ ពីព្រោះទ្រង់ គឺជាព្រះដ៏បង្កបង្កើត។ នេះ ហើយជាហេតុដូចគ្នា ដែលយើងត្រូវតែ ថ្វាយបង្គំដល់ព្រះ ដែលគង់នៅស្ថានសួគ៌ ខាងលើ។



84

ទ្រង់គឺជាអ្នកដែលបានបង្កើតពិភពលោក និងយើងទាំងអស់គ្នាមក។

ប៉ុន្តែលោកអ្នកអាចសួរថា តើមានភ័ស្តុ តាងអ្វីខ្លះទៀតដែលយើងមាន ដែល បញ្ជាក់ថា ព្រះគឺជាព្រះដែលបង្កើតអ្វីៗទាំង អស់នេះ? ព្រះអង្គផ្ទាល់ប្រាប់យើងថា មានភ័ស្តុតាងនៅជុំវិញខ្លួនយើង ដែល បញ្ជាក់ថា ទ្រង់គឺជាអ្នកបង្កើតយើង។



85

(ព្រះគម្ពីរ ២រូប រ៉ូម ១:២០)

"ដ្បិតអ្វីៗរបស់ទ្រង់ ដែលរកមើលមិន ឃើញ តាំងពីកំណើតលោកីយ៍មក ទោះ ទាំងព្រះចេស្តាដ៏នៅអស់កល្បជានិច្ច និង និស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់ វិញ

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


86

ដោយពិចារណាយល់របស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក
រ៉ូម ១:២០
តាំងពីការបង្កបង្កើតមក មានភ័ស្តុតាង នៅក្នុងគ្រប់របស់ដែលបានបង្កើតនោះថា
ទ្រង់គឺជាអ្នកបង្កើតនូវរបស់ទាំងអស់នោះ


87

ដូចជាដានជើងនៅលើដីខ្សាច់ដូច្នោះដែរ។
យើងបានដឹងថា មានអ្នកណាម្នាក់បាននៅទី នោះ ទោះបីជាយើងមិនបានឃើញអ្នកនោះ ក៏ដោយ។


88

ហើយនៅពេលដែលលោកអ្នកឃើញ របស់ទាំងអស់នៅជុំវិញអ្នក នោះរបស់ទាំង នោះ
ក៏ត្រូវតែបានបង្កើតដោយសារអ្នកណា ម្នាក់នោះដែរ។ របស់ទាំងអស់នោះហើយ
ដែលដូចជាដានជើងដែលប្រាប់អ្នកថា ត្រូវ តែមានអ្នកណាម្នាក់ ដែលបានបង្កើតរបស់
ទាំងអស់នេះឡើងដែរ។


89

ព្រះវរបិតា.ព្រះនាម ដែលព្រះគម្ពីរហៅ ទ្រង់នោះ ទ្រង់មិនមែននៅតែមួយអង្គឯងទេ នៅក្នុង
ការងារនៃការបង្កបង្កើតរបស់ទ្រង់នេះ។


90

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៦)
នៅក្នុងព្រះគម្ពីរលោកុប្បត្តិនិយាយថា
"ទ្រង់ក៏មានបន្ទូលថា ចូរយើងបង្កើត មនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូច យើង..."
ដំណឹងល្អរបស់លោកយ៉ូហានពង្រីកការ នេះឱ្យកាន់តែច្បាស់ថែមទៀត។


91

(ព្រះគម្ពីរ ពរូប យ៉ូហាន១:១.៣) "កាលដើមដំបូងឡើយមានព្រះបន្ទូល ព្រះ
បន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះ បន្ទូលនោះឯងជាព្រះ


92

ទ្រង់គង់នៅជាមួយនឹងព្រះតាំងពីដើមមក។

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


93

គ្រប់របស់ទាំងអស់បានកើតមកដោយ សារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបាន បង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយ កើតមកក្រៅពីទ្រង់ឡើយ”


94

(ព្រះគម្ពីរ ២រូប យ៉ូហាន ១:១៤) “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយ បានស្នាក់នៅជាមួយនឹង យើងរាល់គ្នាយើង រាល់គ្នាបានឃើញសិរីល្អទ្រង់


95

គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពី ព្រះវរបិតា មានពេញជាព្រះគុណ និង សេចក្ដីពិត” យ៉ូហាន ១:១៤។


96

ព្រះគម្ពីរនិយាយអំពីអ្វីដែលយើងស្គាល់ថា ជាព្រះត្រៃសរណៈគមន៍ (ព្រះដ៏ជាទីពឹង៣ អង្គ រួមគ្នាតែមួយ) ព្រះវរបិតា ព្រះរាជ បុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ត្រៃ សរណៈគមន៍ មានព្រះទាំងបីអង្គនេះ ទោះ បីជាទាំងអស់គិតដូចគ្នាក៏ដោយ ក៏នៅតែ មានបីផ្សេងគ្នាដែរ


97

ព្រះយេស៊ូវបានសហការជាមួយព្រះ វរបិតា ដើម្បីបង្កើតអ្វីៗទាំងអស់។


98

(ព្រះគម្ពីរ អេភេសូរ ៣:៩)

“អាថ៌កំបាំងដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងមក ជាព្រះដែលទ្រង់ បង្កើតរបស់សព្វសារពើ ដោយសារព្រះ យេស៊ូវគ្រីស្ទ”

អំណោយដ៏ល្អ និងពិសេសទាំងឡាយ ដែលមនុស្សធ្លាប់មាន ឬក៏នឹងអាចមាន នៅពេលដែលព្រះអង្គបង្កើតដល់មនុស្សទាំងអស់នោះ គឺជាព្រះពរ ទាំងអស់ដែលគេ មាននោះ។


99

ព្រះមិនមែនគ្រាន់តែបង្កើតមនុស្សមក ឱ្យដូចរូបអង្គទ្រង់ ហើយបានប្រទានដល់ គេនូវពិភពផែនដីនេះ ដើម្បីរស់នៅនោះ ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានបំពេញនូវគ្រប់ ទាំងសេចក្ដីត្រូវការទាំងអស់របស់មនុស្ស ទៀតផង:

# ៤. ដោយចែដន្យ ឬដោយការរៀបចំ


100

(ព្រះគម្ពីរ ទំនុកដំកើង ១៤៥:១៥,១៦)

"ភ្នែករបស់មនុស្សទាំងអស់រង់ចាំតែទ្រង់ ហើយទ្រង់ក៏ប្រទានអាហារដល់គេតាមត្រូវ ពេល


101

ទ្រង់លាព្រះហស្ត ក៏បំពេញចិត្តប្រាថ្នានៃ ជីវិតទាំងឡាយ"

ទំនុកដំកើង ១៤៥:១៥,១៦។


102

សូមក្រឡេកមើលទៅឯការដែលព្រះយកព្រះ

ទ័យទុកដាក់ចំពោះសេចក្តីត្រូវការរបស់មនុស្សដែលទ្រង់បានបង្កើត។

សូមពិចារណាអំពីការដែលលោកអ្នក ពិសា។ វាមានចំណាស់ចាស់ជាងអង្គរវត្ត-

មានចំណាស់ស្មើនឹងភ្នំទាំងឡាយ។


103

ទឹកត្រូវបានធ្វើឱ្យមានជាតិពុលដោយសារជាតិគីមី ឬកាកសំណល់ ប៉ុន្តែចូរឱ្យព្រះអាទិត្យ

រំហួតវាទៅក្នុងលំហអាកាស


104

ហើយវាក៏ត្រឡប់ជាស្អាតអាចប្រើប្រាសបាន ឡើងវិញ ដែលបានចែកចាយដោយភ្លៀង សន្សើម

និងព្រិល។

នេះគឺជាប្រព័ន្ធវដ្តទឹកដ៏ល្អអស្ចារ្យដែល ព្រះបានបង្កើត!


105

ហើយនៅមានរោងចក្រថាមពលដ៏អស្ចារ្យ របស់ព្រះមួយទៀត នៅលើមេឃ គឺព្រះ

អាទិត្យរបស់យើង! សូមគិតបន្តិច:


106

ប្រសិនបើព្រះអាទិត្យធំជាងនេះ

ឬនៅជិតផែនដីជាងនេះតែបន្តិចនោះ

មហាសមុទ្រទាំងឡាយនឹងត្រូវហួតហែងជាមិនខាន

# ៤. ដោយចៃដន្យ ឬដោយការរៀបចំ


107

ប្រសិនបើព្រះអាទិត្យគ្រាន់តែតូចបន្តិច ឬក៏ នៅឆ្ងាយពីផែនដីតែបន្តិចនោះ បរិយាកាស របស់យើងនេះនឹងទៅជាកក។

ម្យ៉ាងវិញទៀតជីវិតមិនអាចមាននៅលើ ពិភពលោកនេះបានឡើយ

ប៉ុន្តែព្រះមិនមែនគ្រាន់ តែបង្កើតរបស់ សព្វសារពើប៉ុណ្ណោះទេ ទ្រង់ធ្វើឱ្យអ្វីៗទាំង អស់នៅមានដំណើរការជាបន្តទៀតផង ខ្យល់ដែលយើងដកដង្ហើម គឺជាអំណោយ របស់ព្រះ ព្រះគម្ពីរនិយាយថា


108

(ព្រះគម្ពីរ យ៉ូប ១២:១០)

"ដែលជីវិតនៃសត្វទាំងឡាយ សុទ្ធតែ នៅក្នុងព្រះហស្តទ្រង់ ព្រមទាំងខ្យល់ដង្ហើម របស់មនុស្សផងដូច្នេះ"

យ៉ូប ១២:១០។


109

ព្រះទ្រង់បានរៀបចំពិភពចក្រវាលនេះ ឡើង ហើយទ្រង់ជ្រាបនូវរូបមន្តដ៏ត្រឹមត្រូវ របស់ខ្យល់ដែល យើងដកដង្ហើម ដើម្បីឱ្យ មានជីវិតជាបន្ត និងដើម្បីដកដង្ហើមនៅលើ ពិភពលោកនេះ។



110

ទ្រង់បានជ្រាបអំពីចំនួន អាហ្សូត អុកស៊ីហ៊្សែន អាកុង និងកាបោន ឌីអុកស៊ីដ ដើម្បីនឹងលាយបញ្ចូលគ្នានៅក្នុង លំហអាកាស។

ការទាំងអស់នេះពិតជាមិនអាចកើត ឡើងដោយខ្លួនឯងបានឡើយ!


111

វាគ្មានទីបញ្ចប់ឡើយ ចំពោះការអស្ចារ្យ ទាំងឡាយនៅក្នុងពិភពលោក នៃធម្មជាតិ របស់យើងនេះ ចំពោះការថែរក្សារបស់ព្រះ ដល់អ្វីៗដែលទ្រង់បានបង្កើតនោះ គ្មានទី បញ្ចប់ឡើយ។

សូមគិតអំពីការផ្លាស់ប្តូរទីលំនៅរបស់ សត្វស្លាប ដែលជាចម្ងល់ដ៏ធំមួយក្នុង ធម្មជាតិ។


112

តើហេតុដូចម្តេចបានជាសត្វស្លាបដែលមាន ទម្ងន់មិនដល់២៨,៣៥ក្រាមផងនោះ អាច ហើរផ្លាស់ប្តូរ ទីកន្លែងរាប់ពាន់គីឡូ ម៉ែត្រមិនឈប់ឈរ ទៅកាន់ទិសដៅមួយ ដែលវាមិនធ្លាប់បានស្គាល់នោះ


113

តើត្រីអាចរកខ្សែទឹក ជាកន្លែងដែលជីវិតវា ចាប់ផ្តើមនេះឃើញយ៉ាងណា នៅក្នុង ជម្រៅទឹក ២០០០គីឡូម៉ែត្រ ក្នុងមហា សមុទ្រដែលគ្មានផែនទីនោះ?

តើវារៀនអំពីទីកន្លែង និងរបៀបទៅ រកទីនោះបានយ៉ាងដូចម្តេច?

# ៤.ដោយថៃដន្យ ឬដោយការរៀបចំ


114

តើអ្នកណាបានបង្រៀនឃ្មុំឱ្យធ្វើសំបុក ដែលមានលក្ខណៈវិស្វកម្មដ៏អស្ចារ្យ ហើយដែលមានខួរក្បាល មិនធំជាងក្បាលម្ជុល ផងនោះ?

តើអ្នកណាដែលជាគំនិតចំបងនៅពី ក្រោយរបស់ទាំងអស់នោះ? លោកយ៉ូប ប្រាប់យើងថា:


115

(ព្រះគម្ពីរ ៣រូប យ៉ូប ១២:៧-៩)

"ចូរអ្នកសួរសត្វតិរច្ឆានឥឡូវចុះ វានឹង បង្រៀនអ្នកហើយសត្វស្លាប ដែលហើរលើ អាកាសផង វានឹងប្រាប់ឱ្យអ្នកដឹង


116

ឬឱ្យនិយាយនឹងដីចុះ នេះនឹងបង្រៀនអ្នក ដែរ ហើយត្រីនៅសមុទ្រនឹងថ្លែងប្រាប់អ្នក


117

ក្នុងពួកទាំងនោះ តើមានអ្នកណាមួយ ដែលមិនដឹងថា ព្រះហស្តនៃព្រះយេហូវ៉ា បានបង្កើតទាំងអស់?"

យ៉ូប ១២:៧-៩។

មែនហើយ ព្រះបានធ្វើទាំងអស់! នៅក្នុងការ ពិត កាតព្វកិច្ច និងសក្ការនុពលរបស់យើង ក្នុងការថ្វាយបង្គំព្រះ មានមូលដ្ឋាននៅលើ ការដែលទ្រង់ ជាព្រះដ៏បង្កបង្កើតរបស់ យើង ហើយដោយសារទ្រង់ គ្រប់របស់ ទាំងអស់បានកើតមានឡើង


118

(ព្រះគម្ពីរ ២រូប ទំនុកដំកើង ១០០:៣)

"ត្រូវឱ្យដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ គឺ ទ្រង់ដែលបានបង្កើតយើងខ្ញុំ


119

យើងខ្ញុំជារបស់ផងទ្រង់ យើងជា រាស្ត្ររបស់ទ្រង់ ហើយជាហ្វូងចៀមនៅ ទីគង្វាលរបស់ទ្រង់"

ទំនុកដំកើង ១០០:៣។

ព្រះទ្រង់ជ្រាបនូវសេចក្តីត្រូវការរបស់ យើង ហើយទ្រង់មានអំណាចនឹងផ្តល់ ឱ្យយើង តាមសេចក្តីត្រូវការទាំងអស់នោះ!


120

(ព្រះគម្ពីរ ២រូប យេរេមា ៣២:១៧)

លោកយេរេមានិយាយថា "ឱព្រះ អម្ចាស់យេហូវ៉ាអើយ មើលទ្រង់បានបង្កើត ផ្ទៃមេឃនិងផែនដី ដោយសារតែព្រះចេស្តា ដ៏ធំរបស់ទ្រង់ និងព្រះពាហុដ៏លើកសម្រេច

# ៤.ដោយចៃដន្យ ឬដោយការរៀបចំ


121

គ្មានអ្វីដែលពិបាកពេកដល់ទ្រង់ទេ


122

តើវាមិនផ្តល់ឱ្យអ្នកនូវសេចក្តីសុខសាន្ត នៅក្នុងចិត្តទេឬអី ដោយដឹងថា ព្រះអាច ដោះស្រាយបាន នូវបញ្ហាទាំងអស់នៅលើ ពិភពចក្រវាលនេះ និងនៅក្នុងជីវិតរបស់ លោកអ្នកផងនោះ?

គ្មានបញ្ហាណាដែលតូចពេកដើម្បីនឹង លើកថ្វាយទៅព្រះដ៏ធំ ដែលអាចបង្កើត ហ្វូងតារាទាំងឡាយបាននោះឡើយ ទ្រង់ ជ្រាបនូវអ្វីៗទាំងអស់ ទ្រង់ថែមទាំងបាន ជ្រាបការទាំងនោះ មុនពេលដែលកើតមាន ឡើងទៅទៀត។


123

(ព្រះគម្ពីរ អេសាយ ៤៦:៩)

ទ្រង់បានមានព្រះបន្ទូលថា "អញជាព្រះ ហើយគ្មានអ្នកណាដូចអញសោះ


124

តាំងតែពីដើមដំបូង អញរមែងសំដែង ប្រាប់ពីការដែលនឹងត្រូវមកនៅខាងចុងបំផុត ហើយតាំងពីចាស់បុរាណ ក៏ប្រាប់ពីការ ដែលមិនទាន់មានមកដែរ"

អេសាយ ៤៦:១០


125

នេះគឺសេចក្តីសុខសាន្ត និងការទុកចិត្ត ដែលយើងអាចមាន ដោយដឹងថា គ្មានអ្វី អាចនឹងកើតមានដល់យើង ដែលពិបាក ពេកសម្រាប់ព្រះ ដើម្បីនឹងដោះស្រាយនោះ ឡើយ។ ប៉ុន្តែពិសេសបំផុត


126

(ព្រះគម្ពីរ យ៉ូហានទី១ ៤:៨)

"ព្រះគឺជាសេចក្តីស្រឡាញ់" ព្រះយេស៊ូវ បានមានព្រះបន្ទូលថា:


127

(ព្រះគម្ពីរ យ៉ូហាន ១៦:២៧)

"ដ្បិតព្រះវរបិតាទ្រង់ក៏ស្រឡាញ់ដល់អ្នក រាល់គ្នាដែរ..."

# ៤.ដោយថែជន្ស ឬដោយការរៀបចំ



128

(វីដេអូ ១០វិនាទី) តើវាធ្វើឱ្យអ្នកភ្ញាក់ ផ្អើលឬទេ ដែលថាព្រះដ៏មានព្រះចេស្ដា ដែលបានបង្កើត
និងដំណើរការ ពិភព ចក្រវាល ដ៏ធំសំបើម និងល្អត្រឹមត្រូវនេះ
បានយកព្រះទ័យទុកដាក់ចំពោះអ្នកផងដែរ
នោះ?

វាគឺជាការហួសវិស័យធម្មជាតិ បើយើង សំឡឹងមើល ដោយយកចិត្តទុកដាក់ ទៅ កាន់អំណាចដ៏ធំបណ្ដាច់របស់ព្រះ ប្រាជ្ញា ដ៏ជ្រាលជ្រៅរបស់ព្រះ និងលទ្ធភាពរបស់ ទ្រង់នៅគ្រប់ទិសទី។

ប៉ុន្តែសេចក្ដីស្រឡាញ់ គឺជារឿងដែល យើងអាចយល់បាន។ ហើយគ្មានអ្វីនៅលើ
ពិភពលោកនេះដែលអាចបំបែកយើងចេញ ពីសេចក្ដីស្រឡាញ់របស់ព្រះឡើយ!


129

(ព្រះគម្ពីរ ៤រូប រ៉ូម ៨:៣៨,៣៩)

"ដ្បិតខ្ញុំជឿជាក់ថា ទោះស្លាប់ឬរស់ ពួកទេវតា ឬអំណាចអ្វី


130

ការអ្វីនៅជាន់នេះឬទៅមុខ ឬឥទ្ធិឫទ្ធិអ្វី


131

ទីមានកំពស់ ទីជម្រៅឬរបស់អ្វីដែលកើត មកទៀតក្ដី នោះពុំអាចពង្រាត់យើងចេញ
ពីសេចក្ដីស្រឡាញ់របស់ព្រះ


132

ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះ អម្ចាស់នៃ យើងរាល់គ្នាទៅបានឡើយ"
រ៉ូម ៨:៣៨,៣៩។


133

ព្រះស្រឡាញ់យើង តាំងពីយើងនៅគួរ ឱ្យស្រឡាញ់ ហើយក៏តាំងពីយើងមិនគួរឱ្យ
ស្រឡាញ់ផងដែរ។ តើលោកអ្នកដឹងដូច្នោះ ដែរឬទេ?

ទ្រង់ស្រឡាញ់យើង ទោះបីជាយើង ខ្មៅឬស ប្រុសឬស្រី ស្អាតឬអាក្រក់ក៏ ដោយ។
គ្មានអ្នកណាម្នាក់ដូចជាទ្រង់ឡើយ!
ហើយសំខាន់បំផុតនោះ គឺទ្រង់ស្រឡាញ់ យើងរៀងរហូត!

# ៤. ដោយថៃ្លដន្យ ឬដោយការរៀបចំ


134

(ព្រះគម្ពីរ យេរេមា ៣១:៣)

"អើ អញបានស្រឡាញ់ឯង ដោយសេចក្តី ស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប"

យេរេមា ៣១:៣


135

(ព្រះគម្ពីរ ទំនុកដំកើង ១០០:៥) ស្តេចដាវីឌបានសរសេរថា "ពីព្រោះព្រះ យេហូវ៉ាទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ ស្ថិតស្ថេរនៅជា និច្ច"

ព្រះមិនដែលបោះបង់យើងឡើយ! ទ្រង់គង់នៅជាមួយយើងគ្រប់ពេលវេលាដែលយើងរស់នៅ

ហើយទ្រង់ក៏មិនដែលចាក ចោលយើងឡើយ!

ហើយប្រសិនបើមានការសង្ស័យនៅក្នុងចិត្ត

យើង អំពីសេចក្តីស្រឡាញ់របស់ទ្រង់ នោះព្រះអង្គបង្រៀនយើងអំពីរឿងនោះ ដោយរបៀបងាយៗ

ដើម្បីឱ្យយើងអាច យល់បាន


136

(ព្រះគម្ពីរ ៣រូប អេសាយ ៤៩:១៥,១៦)

"ចុះតើស្ត្រីនឹងបំភ្លេចកូនដែលកំពុងបៅ

ដោះឥតមានអាណិតដល់កូនដែលចេញពីផ្ទៃ ខ្លួនមកបានដែរឬ?


137

អើ គេនឹងភ្លេចបាន ប៉ុន្តែអញមិនដែល បំភ្លេចឯងឡើយ


138

មើលអញបានចារឹកឯងទុកនៅផ្ទៃបាទដៃរបស់អញហើយ"

អេសាយ ៤៩:១៥,១៦។


139

ព្រះប្រឹងប្រែងស្រាយបញ្ជាក់នូវសេចក្តីស្រ ឡាញ់របស់ទ្រង់ដល់មនុស្ស ប៉ុន្តែព្រះបន្ទូល

និងដំណឹងដែលបញ្ជូនដោយពួកហោរានោះ មិនគ្រប់គ្រាន់ទេ។ យើងមិនបានទទួលដំ ណឹងឡើយ។


140

ដូច្នេះ ព្រះបានចាត់ព្រះរាជបុត្រារបស់ ទ្រង់ គឺព្រះយេស៊ូវ ដែលជាទំនាក់ទំនង

ដ៏ល្អឥតខ្ចោះនៃបុគ្គលិកលក្ខណៈ និងអត្តច រិតរបស់ព្រះវរបិតាទ្រង់។

# ៤.ដោយថែជន្ស ឬដោយការរៀបចំ


141

(ព្រះគម្ពីរ យ៉ូហាន ១៤:៩)
ទ្រង់បានមានព្រះបន្ទូលថា "អ្នកណាដែល ឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ"


142

ប្រសិនបើលោកអ្នកពិតជាចង់ដឹងថា ព្រះអង្គយ៉ាងណា ហើយថា តើទ្រង់មាន ព្រះទ័យយ៉ាងណាចំពោះយើងនោះ យើង ត្រូវតែសិក្សាជីវិតរបស់ព្រះយេស៊ូវ។ ទ្រង់បានយកជម្មជាតិជាមនុស្សដូចយើង ដើម្បី ទ្រង់អាចជ្រាបអំពីសេចក្តីត្រូវការរបស់យើង។ ទ្រង់បានប្រកាសដំណឹងល្អនៃសេចក្តីសង្គ្រោះ ដល់អ្នកក្រីក្រ។

ទ្រង់បានព្យាបាលអ្នកអស់សង្ឃឹម និង ឱ្យអ្នកខ្វាក់អាចមើលឃើញវិញ។


143

ទ្រង់បានចំអែតអ្នកឃ្លាន ហើយសោយអា ហារជាមួយនឹងប្រជាជននៅក្នុងផ្ទះរបស់គេ។
ទ្រង់បានអត់ឱនទោសដល់អំពើបាប របស់គេ ហើយប្រទានសេចក្តីសង្ឃឹមពី អនាគតដល់ពួកគេ។


144

ព្រះភ័ក្ត្ររបស់ទ្រង់ គឺជាព្រះភ័ក្ត្រដែល មនុស្សខ្វាក់ជាច្រើនបានឃើញជាលើកទីមួយ ព្រះសូរសៀងរបស់ទ្រង់ គឺជាព្រះសូរសៀង លើកទីមួយ ដែលមនុស្សថ្លង់ជាច្រើនមិនដែលធ្លាប់បានឮ។

ទ្រង់បានផ្សព្វផ្សាយជីវិត និងអំណរ ពាសពេញទាំងភូមិស្រុកដែលទ្រង់បានយាង កាត់។

ជីវិតរបស់ទ្រង់ គឺជាជីវិតដែលពោរ ពេញទៅដោយការលះបង់ផ្ទាល់ខ្លួន និង គិតគូរពីអ្នកដទៃវិញ។


145

នៅពេលដែលយើងឃើញភាពគួរឱ្យ ខ្មាស ការអាម៉ាស់ និងការបន្ទាបខ្លួនដែល ទ្រង់បានទ្រាំទ្រ ការសុគតរបស់ទ្រង់នៅ ភ្នំលលាក្បាល និងការបាក់ទឹកព្រះទ័យ របស់ទ្រង់ យើងចាប់ផ្តើមយល់ អំពីសេចក្តីស្រឡាញ់ របស់ទ្រង់ចំពោះព្រះ រាជបុត្ររបស់ទ្រង់បាន តែបន្តិចបន្តួច ប៉ុណ្ណោះ។


146

(ព្រះគម្ពីរ យ៉ូហាន ៣:១៦)
"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់
ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១


147

ដើម្បីឱ្យអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ"
យ៉ូហាន ៣:១៦។

៤.ដោយថែជន្ស ឬដោយការរៀបចំ

# ៤. ដោយចៃដន្យ ឬដោយការរៀបចំ



148

តើព្រះនៃលោកសន្និវាសនេះគឺជាព្រះ អង្គណា?

ទ្រង់គឺជាព្រះដ៏បង្កបង្កើត និងជាព្រះដ៏ មានអំណាច។

ទ្រង់គឺជាអ្នកផ្គត់ផ្គង់ដ៏អស្ចារ្យ។

ទ្រង់គឺជាស្ថាបត្យករដ៏ចំណាន។

ទ្រង់គឺជាព្រះវរបិតាដ៏ជាទីស្រឡាញ់។




149

ជាច្រើនឆ្នាំកន្លងមកហើយ ក្មេងតូច ម្នាក់បានមានគ្រោះថ្នាក់មួយដ៏គួរឱ្យខ្លោចផ្សា។ វាបានប្រញាប់រត់ទៅកាន់មន្ទីរពេទ្យ ដោយស្ថានភាពយ៉ាងយ៉ាប់យ៉ឺន។

ក្មេងប្រុសនោះ ត្រូវការការបញ្ចូល ឈាមជាបន្ទាន់។ គេមិនអាចរកអ្នកបរិច្ចាគ ឈាមណាម្នាក់ ដើម្បីនឹងជួយវាបានឡើយ។

ឪពុករបស់វាមានឈាមប្រភេទដូចគ្នា ហើយគាត់សុខចិត្តផ្តល់ឈាមទៅឱ្យកូន។ វេជ្ជបណ្ឌិតបានចាប់ផ្តើមបង្ហូរឈាមចេញពីដៃរបស់គាត់តាមបំពង់ទុយោផ្លាស្ទិក ទៅកាន់ កូនរបស់គាត់ដែលនៅដេកស្តូកស្តឹង គាត់ បានសំឡឹងមើលទៅគ្រូពេទ្យទាំងទឹកភ្នែក ហើយសំឡេងរបស់គាត់និយាយថា

លោកវេជ្ជបណ្ឌិត ប្រសិនបើលោកត្រូវ ការ សូមលោកយកឈាមខ្ញុំទាំងអស់ចុះ។ លោកគ្រូពេទ្យ ខ្ញុំសុខចិត្តប្រគល់ឈាមខ្ញុំ ទាំងអស់ដើម្បីកូនខ្ញុំ"។



150

ព្រះវរបិតារបស់យើងដែលទ្រង់គង់នៅ ស្ថានសួគ៌ បានទតមកមើលពិភពលោក ដែលទ្រង់បានបង្កើត ហើយបានឃើញថា បានបាត់បង់ទៅក្នុងអំពើបាប។

ទ្រង់បានប្រទានស្ថានសួគ៌ទាំងមូលដែល ទ្រង់អាចប្រទាននៅក្នុងព្រះរាជបុត្រារបស់ ទ្រង់។

ព្រះយេស៊ូវបានមានព្រះបន្ទូលថា "ព្រះ វរបិតា ប្រសិនបើទ្រង់ត្រូវការ សូមយកវា ទាំងអស់ចុះ។ យកឈាមរបស់ខ្ញុំគ្រប់តំ ណក់ ដើម្បីនឹងជួយកូនប្រុស កូនស្រីរបស់ ខ្ញុំ និងមិត្តសំឡាញ់របស់ខ្ញុំ"



151

តើអ្នកអាចបែរចេញពីសេចក្តីស្រឡាញ់ បែបនេះបានយ៉ាងណា?

ព្រះដ៏ជាទីស្រឡាញ់និងមានអំណាច ដែលបានបង្កើតអ្នក។

នៅពេលដែលមនុស្សលោកបានធ្វើបាប ទ្រង់បានប្រទាននូវអ្វីដែលទ្រង់មាន ដល់ អ្នកទាំងអស់។

លោកអ្នកមានតម្លៃដល់ទ្រង់។ ទ្រង់ស្រ ឡាញ់លោកអ្នក ដោយសេចក្តីស្រឡាញ់ យ៉ាងអស្ចារ្យ។

នៅពេលដែលយើងឱនក្បាលដើម្បីនឹង អធិស្ឋាននៅយប់នេះ សូមលោកអ្នក លើកដៃឡើង ហើយនិយាយថា "ព្រះ អម្ចាស់អើយ ទូលបង្គំបើកចិត្តរបស់ទូល បង្គំថ្វាយ ដល់សេចក្តីស្រឡាញ់របស់ទ្រង់ ឥឡូវនេះ។ អរព្រះគុណទ្រង់ ចំពោះការ បង្កើតទូលបង្គំ និងការប្រោសលោះ ដល់ទូលបង្គំរបស់ទ្រង់។ ទូលបង្គំសូម ថ្វាយជីវិតដល់ទ្រង់ឥឡូវនេះ"

# ៥.អាថិកំបាំងនៃក្រាំងពីបុរាណ



1

តើវាមានន័យយ៉ាងដូចម្ដេចសំរាប់លោកអ្នកបច្ចុប្បន្ននេះ?


2

ប៉ុន្មានឆ្នាំកន្លងមកនេះលោកម៉ារស៍ បាន ដឹងថាម្ដាយមីងរបស់គាត់បានស្លាប់ ហើយ
បានបញ្ចូលគាត់ក្នុងបណ្ដាំមរតករបស់នាង។
បណ្ដាំមរតកបានសរសេរថា "ចំពោះអ្នក ដែលជាទីស្រឡាញ់របស់ខ្ញុំម៉ារស៍ ខ្ញុំទុក
អោយនូវព្រះគម្ពីរប្រចាំគ្រួសារ និងអ្វីៗ ដែលនៅក្នុងនេះ ជាមួយនឹងមរតកទាំង ឡាយរបស់ខ្ញុំ
ដែលនៅសល់ទាំងអស់។
បាទ បន្ទាប់ពីបានទូទាត់សងបំណុល គេរួចរាល់មក ទ្រព្យសម្បត្តិទាំងនោះនៅ
សល់តែពីរបីរយដុល្លាប៉ុណ្ណោះ។
មិនយូរប៉ុន្មាន ប្រាក់ទាំងនោះក៏ត្រូវបាន ចាយវាយអស់ទៅ ហើយអ្វីដែលលោក ម៉ារស៍សល់នោះ
គឺមានតែព្រះគម្ពីរប្រចាំ គ្រួសារតែប៉ុណ្ណោះ ដែលគាត់បានដាក់នៅ ក្នុងហិបលើធ្នើរបស់គាត់។
លោកស្ដេវេន ម៉ារស៍ត្រូវបានចូល និវត្ត ដោយបានទទួលប្រាក់រ៉ឺត្រែតយ៉ាង តិចតួចជាទីបំផុត។
គាត់បានរស់នៅក្នុងភាពក្រខ្សត់អស់រយៈ ពេលជាង៣០ឆ្នាំ។

# ៥_អាថ៌កំបាំងនៃក្រាំងពីបុរាណ



3

(វីដេអូ ៩វិនាទី) ទីបំផុត នៅក្នុងអាយុ ៩០ឆ្នាំរបស់គាត់ គាត់បានសម្រេចចិត្តផ្លាស់ ប្តូរទីលំនៅ ទៅនៅជាមួយកូនប្រុសរបស់ គាត់។

នៅពេលដែលគាត់រៀបចំឥវ៉ាន់របស់ គាត់ គាត់បានប្រទះឃើញព្រះគម្ពីររបស់ ម្តាយមីងគាត់ ហើយគាត់ក៏ចាប់ផ្តើមបើក មើលម្តងមួយសន្លឹក ម្តងមួយសន្លឹក។

លោកម៉ារ៉ស៍ មានការភ្ញាក់ផ្អើលជាខ្លាំង ដោយបានឃើញលិខិតធនាគារ ដាក់រាយប៉ាយនៅនឹងទំព័រព្រះគម្ពីរជាច្រើន គាត់ បានរាប់ឃើញមានទឹកប្រាក់ចំនួន ជាងប្រាំ ពាន់ដុល្លា ដែលជាចំនួនទឹកប្រាក់យ៉ាង ច្រើននៅសម័យនោះ។

បុរសនោះបានចំណាយពេលសឹងតែមួយ ជីវិតរបស់គាត់ជាអ្នកក្រ នៅក្នុងខណៈដែលគាត់អាចក្លាយជាអ្នកមានបាន។

មានទ្រព្យសម្បត្តិនៅនឹងម្រាមដៃរបស់ គាត់ នៅក្នុងព្រះបន្ទូលរបស់ព្រះ។

យើងក៏អាចមានសៀវភៅមរតកនៅនឹង ចុងម្រាមដៃរបស់យើងយ៉ាងដូច្នោះដែរ។ មានមនុស្សរាប់លាននាក់ដែលបានជឿថា ព្រះគម្ពីរគឺជាសៀវភៅដ៏អស្ចារ្យ ដែលមិនដែលមានអ្នកណាធ្លាប់បានសរសេរឡើយ។

ពួកគេមានជំនឿជឿជាក់ថា ព្រះគម្ពីរ បានបណ្តាលដោយព្រះ និងមានការណែនាំយ៉ាងច្បាស់លាស់ជាច្រើន ដើម្បីអោយបាន ទទួលជីវិតអស់កល្ប។

មនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសា និងគ្រប់ពូជអំបូរ បានទទួលព្រះបន្ទូលរបស់ព្រះជាការផ្លាស់ប្តូរជីវិត និងជាមរតក ដ៏ពិសេស។

មានមនុស្សជាច្រើនទៀតមានការងឿង ឆ្ងល់ជាខ្លាំង។ ពួកគេមានសំនួរជាច្រើន។


4

ចុះតើសៀវភៅដែលលក់បានច្រើនជាង គេលើពិភពលោកនេះ_គឺព្រះគម្ពីរ នោះ យ៉ាងណាដែរ? តើសៀវភៅនេះបានប្រាប់ ការពិតឬទេ?

តើព្រះគម្ពីរបានកត់ត្រាត្រឹមត្រូវឬទេ?

អ្នកខ្លះនិយាយថា អ្នកអាចទុកចិត្តលើ ព្រះគម្ពីរដោយគ្មានសង្ស័យ។ អ្នកខ្លះទៀត និយាយថា មិនអាចទុកចិត្តបានទេ។

តើអ្នកណាមួយត្រូវ?

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



5

ហើយចម្លើយនោះសំខាន់ណាស់ ព្រោះថា ប្រសិនជាព្រះគម្ពីរពិត ទោះជាអ្នកទុកចិត្ត ឬមិនទុកចិត្តក៏ដោយ ក៏វាជាបញ្ហាសំខាន់ ស្លាប់រស់មួយដែរ។

ប្រសិនបើព្រះគម្ពីរពិត វាសនាដ៏អស់ កល្បរបស់អ្នកទាំងស្រុង នឹងពឹងទៅលើ ការដែលអ្នកជឿនិងទទួលព្រះគម្ពីរនោះ។

អ្វីដែលអ្នកជឿទៅលើព្រះគម្ពីរ មាន ឥទ្ធិពលទៅលើអ្វីដែលអ្នកជឿអំពីព្រះ។

មានតែកន្លែងមួយគត់ដែលអ្នកអាច ទទួល បាននូវរូបភាពពិតរបស់ព្រះ ហើយ ការនោះគឺនៅក្នុងព្រះគម្ពីរនោះឯង។ នោះ ហើយជាហេតុផលដែលព្រះគម្ពីរត្រូវបានផ្តល់មកអោយយើងទាំងអស់គ្នា។


6

ព្រះគម្ពីរនោះបានប្រាប់យើងអំពីព្រះ ដែលយើងមើលមិនឃើញ ហើយដែលយើងអាចស្គាល់ទ្រង់បាន ដោយសារតែការ អានដំណឹងរបស់ទ្រង់ ដែលទ្រង់បានផ្ញើមកអោយយើងតាមរយៈហោរា និងព្រះរាជ បុត្រារបស់ទ្រង់ ដើម្បីនឹងឱ្យយើងបាន ឃើញព្រះអង្គ។


7

ចូរយើងក្រឡេកមើលទៅសៀវភៅដ៏ ឧត្តមនេះ គឺព្រះគម្ពីរដែលហៅថា ព្រះ បន្ទូលរបស់ព្រះ ហើយរកមើលថា តើនឹង មានភស្តុតាង ដែលបង្ហាញថាពិតឬមិនពិត ឬទេ ហើយថា តើគួរទុកចិត្តឬមិនគួរ។



8

(វីដេអូ ៦វិនាទី) ព្រះគម្ពីរមិនមែនគ្រាន់ តែជាសៀវភៅតែមួយប៉ុណ្ណោះទេ ប៉ុន្តែគឺជាបណ្ណាល័យនៃសៀវភៅទាំងអស់ នៅក្នុង ក្របតែមួយនោះ។

ព្រះគម្ពីរមាន៦៦កណ្ឌ ដែលសរ សេរនៅពេលខុសគ្នា ដោយអ្នកនិពន្ធផ្សេងៗគ្នានៅក្នុងកំឡុងពេល១៦០០ឆ្នាំ។

មាន៣៦កណ្ឌនៅក្នុងសញ្ញាចាស់ និង ២៧កណ្ឌនៅក្នុងសញ្ញាថ្មី។


9

មនុស្ស៤៥នាក់ផ្សេងគ្នាបានសរសេរសៀវភៅ (កណ្ឌ)ទាំងនេះ ហើយគេរកឃើញថា ក្នុង ចំណោមពួកគេទាំងនោះ មានការត្រូវគ្នា យ៉ាងអស្ចារ្យ ដែលអាចត្រូវបានពន្យល់ ដោយហេតុផលដែលចេញពីប្រភពរួមតែមួយ ប៉ុណ្ណោះ។

ការយល់ស្របគ្នាទាំងស្រុងនេះបានកើតឡើងយ៉ាងត្រឹមត្រូវ ទោះបីជាអ្នកសរសេរសៀវភៅទាំងនេះភាគច្រើនមិន ដែលបានស្គាល់ គ្នាក៏ដោយ។


10

ពួកគេទាំងអស់គ្នាមានអាជីពផ្សេងៗគ្នា។
ខ្លះជាអ្នកនេសាទត្រី ខ្លះជាអ្នកឃ្វាលចៀម ខ្លះជាស្តេច ខ្លះជាអ្នកដឹកនាំរដ្ឋាភិបាល ខ្លះ ជាកសិករ ខ្លះជាអ្នកអធិប្បាយ ខ្លះជាចៅ ហ្វាយខេត្ត ជាគ្រូពេទ្យ និងមនុស្សទាំងចាស់ទាំងក្មេង។

# ៥. អាថ៌កំបាំងនៃក្រាំងពីបុរាណ



11

(វីដេអូ ១៣វិនាទី) មែនហើយ មានឯកភាពនិង ការចុះសំរុងគ្នាឥតខ្ចោះ រវាងគម្ពីរទាំងទាំងឡាយដែលគេបានសរសេរនោះ ពិត ជាការអស្ចារ្យមែន!

ការស៊ីសង្វាក់គ្នានេះអាចពន្យល់ទៅបាន ដោយសារការទទួលយល់ព្រមថា ព្រះបានប្រទានព្រះគម្ពីរនេះ មកយើងរាល់ គ្នា ដើម្បីអោយទ្រង់អាច ទាក់ទងនូវព្រះហឫទ័យទ្រង់ជាមួយយើង។


12

(ព្រះគម្ពីរ ពេត្រុសទី២ ១:២១)

លោកពេត្រុសបានសរសេរថា "ដ្បិត សេចក្តីទំនាយមិនដែលមកដោយបំណងចិត្ត មនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បណ្តាលវិញ" ពេត្រុសទី២ ១:២១។


13

(ព្រះគម្ពីរ ធីម៉ូថេទី២ ៣:១៦-១៧)

លោកសាវកប៉ុលបានសរសេរថា "គ្រប់ ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលអោយតែងទេ ក៏មានប្រ យោជន៍ សំរាប់ការបង្រៀន


14

ការរំលឹកអោយដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត។


15

"ដើម្បីអោយអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ"
ធីម៉ូថេទី២ ៣:១៦-១៧

ហេតុផលដែលព្រះជ្រើសរើសរបៀប ទាក់ទងបែបនេះ និយាយមកកាន់យើង ដោយសារទ្រង់ទ្រាយនៃការសរសេរ ដោយ ព្រោះថា ខ្សែទំនាក់ទំនងរវាងមនុស្សនិងព្រះ ត្រូវបានកាត់ផ្តាច់ដោយសារអំពើបាប។


16

នៅពេលដែលព្រះបានយាងជាមួយនឹង មនុស្ស ជាមួយគ្នានៅក្នុងសួនច្បារអេដែន នោះទ្រង់មិនចាំបាច់ត្រូវការសរសេរ នូវអ្វី ដែលព្រះចង់ អោយមនុស្សដឹងនោះទេ។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


17

នៅពេលដែលអ័ដាមមានបាប គេបាន លាក់ខ្លួនពីព្រះ ពីព្រោះគេមានការភ័យខ្លាច និងមានទោស ចំពោះអ្វីដែលគេបានធ្វើ។

នៅពេលដែលព្រះបានសួរអ័ដាមថា តើ គាត់នៅឯណា គាត់បានឆ្លើយថា



18

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១០)

"...ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួន ច្បារ ទូលបង្គំនឹកភ័យខ្លាច...ទូលបង្គំក៏រត់ ទៅពួន"

លោកុប្បត្តិ៣:១០


19

ព្រះមិនអាចបន្តមានព្រះបន្ទូលដោយព្រះភ័ក្ត្រ ផ្ទាល់បានទៀតឡើយ។

ទ្រង់ជ្រើសរើសប្រាប់នូវអ្វីដែលទ្រង់ចង់ អោយយើងដឹងតាមរយៈពួកហោរា និង សំបុត្រ តាមរយៈព្រះរាជបុត្រារបស់ទ្រង់។



20

(ព្រះគម្ពីរ អេម៉ុស ៣:៧)

"ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិនធ្វើអ្វី ដូច្នោះឡើយ លើកតែទ្រង់សំដែង អោយពួក ហោរាជាអ្នកបំរើទ្រង់ ឃើញគំ និតលាក់កំបាំងរបស់ទ្រង់ផង"

អេម៉ុស៣:៧។


21

ព្រះបានបណ្តាលអោយលោកម៉ូសេ សរសេរសៀវភៅយ៉ូប និងសៀវភៅប្រាំដំបូងទៀតនៃព្រះគម្ពីរសញ្ញាចាស់ ដែលទាំង អស់នេះហៅថា "ច្បាប់"។

ការនេះកើតឡើងនៅក្នុងពេលម៉្ភៃឆ្នាំ ១៥០០ មុនគ្រិស្តសករាជ។


22

នៅពេលនោះ អ៊ីស្រាអែលបានរីកចំរើន ជាជាតិសាសន៍ដ៏ខ្លាំងពូកែមួយដែលមានមនុស្សរាប់លាននាក់ ហើយព្រះត្រូវការទាក់ទងជាមួយពួកគេ ដោយទ្រង់ទ្រាយនៃ ការសរសេរ។

ការនោះគឺវាចំពេលដែលការសរសេរជាតួអក្សរ ប្រសើរជាងការសរសេរ ដោយប្រើសញ្ញា ។


23

ឥឡូវនេះមនុស្សអាចអានក្រិត្យវិន័យ ដែលព្រះទ្រង់បានសរសេរដោយចុងព្រះ អង្គុលី (ម្រាម) របស់ទ្រង់ និងសៀវភៅ ច្បាប់ដែលលោកម៉ូសេបានសរសេរដើម្បី ព្រះ។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


24

ប៉ុន្តែនៅតែមានសំនួរថា តើព្រះគម្ពីរនៅ តែពិតប្រាកដ និងអាចទុកចិត្តបានដូចដែលព្រះទ្រង់បានប្រទានមកមែនឬទេ?

រហូតដល់ឆ្នាំ១៩៤៧ក្រាំង ដែលមិនទាន់ បោះពុម្ពដំបូងនៃសញ្ញាចាស់បានចម្លងចេញនៅម្តុំឆ្នាំ៩០០នៃ គ្រិស្តសករាជ។


25

ក្រាំងអេសាយ ដែលបានរកឃើញ នៅទីនោះ បានត្រឡប់ទៅខាងក្រោយរហូត ដល់ឆ្នាំ១២៥មុនគ្រិស្តសករាជ។

ក្រាំងនេះត្រូវបានគេចំឡងជាងមួយពាន់ ឆ្នាំមុនក្រាំងចាស់បំផុត ដែលបានរករឃើញនៅជំនាន់នោះ។

ក្រាំងនោះមានសៀវភៅអេសាយទាំងមូល។


26

លោក ហ្វ្រេដេរិក ខិនយ៉ុន ជាអ្នកជំនាញការដែលមានសមត្ថភាពគ្រប់គ្រាន់ខាងបុរាណវិទ្យាម្នាក់ និងជាប្រធាន សាលាបុរាណវិទ្យា នៃចក្រភពអង់គ្លេសបានថ្លែងថាយ៉ាងដូច្នេះថា។

"នៅក្នុងមួយជំពូកដែលមានពាក្យ១៦៦ មានពាក្យតែមួយម៉ាត់គត់ (បីអក្សរ) ដែលនៅក្នុងការសង្ស័យ បន្ទាប់ពីការ
ចម្លងតៗគ្នាមួយពាន់ឆ្នាំមក


27

ហើយពាក្យនោះមិនបានផ្លាស់ប្តូរអត្ថន័យជាដុំកំភួននៃសេចក្តីនោះឡើយ!"



28

លោក ហ្វ្រេដេរិក ខិនយ៉ុនបានថ្លែងថា យ៉ាងដូច្នេះ


29

គ្រីស្ទានអាចកាន់ព្រះគម្ពីរនៅនឹងដៃរបស់គេ ហើយនិយាយដោយគ្មានការភ័យខ្លាច ឬ រុញរាថា គេបានកាន់នៅនឹងដៃគេនូវព្រះ បន្ទូលពិតរបស់ព្រះ

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


30

ដែលបានទទួលជាបន្តបន្ទាប់ដោយគ្មានបាត់ បង់សារសំខាន់ឡើយ ពីជំនាន់មួយទៅជំនាន់មួយរាប់សតវត្សរ៍"



31

លោកខិនយ៉ុន បានធ្វើសេចក្តីថ្លែង ការណ៍នេះ បន្ទាប់ពីបានចំណាយពេលវេ លា នៃជីវិតរបស់គាត់ដើម្បីសាកល្បងរក ភស្តុតាង នៃការចម្លងបន្តរបស់ព្រះគម្ពីរ និងផលប៉ះពាល់នៃការចម្លងបន្តនោះទៅលើដំណឹងនៃព្រះគម្ពីរ។


32

អ្នករិះគន់ព្រះគម្ពីរ កាលពីមួយសតវត្សរ៍ មុន បានរកឃើញហេតុផលជា ច្រើនដែលសង្ស័យអំពីព្រះគម្ពីរ "ប៉ុន្តែអ្នក រិះគន់ទាំង នោះបានត្រូវស្ងៀមស្ងាត់ទៅវិញ ដោយសារតែផ្លែប៉ែលរបស់អ្នកបុរាណវិទ្យា។


33

រហូតដល់សតវត្សរ៍ទីដប់ប្រាំបួន មាន មនុស្សតិចតួចណាស់ដែលឥតបានដឹងអំពីអតីតកាលជំនាន់ដើម លើកលែងតែព្រះគម្ពីរបានប្រាប់ប៉ុណ្ណោះ។



34

ប្រវត្តិសាស្ត្របុរាណហាក់ដូចជាបាន សំឡឹងមើលរហូត ពីក្រោយការសរសេរនៃ រូបភាពដ៏ចំឡែក ការសរសេរដោយប្រើ សញ្ញារបស់អេស៊ីព្ទ។ ដែលគ្មានអ្នកណាម្នាក់នៅអេស៊ីព្ទឬនៅលើពិភពលោកនេះអាចនឹងបកស្រាយបាន។



35

បន្ទាប់មកនៅឆ្នាំ១៧៩៨ ណាប៉ូឡេអុង បាន ដឹកនាំកងទ័ពធ្វើប្រតិបត្តិការ ចូលទៅកាន់ស្រុកអេស៊ីព្ទ។

ដោយមានទាហានចំនួន ៣៨ ០០០នាក់ របស់គាត់ ណាប៉ូឡេអុងបានចាប់យក វិចិត្រករ អ្នកជំនាញភាសា និងអ្នក វិទ្យាសាស្ត្រជាច្រើន ដើម្បីជួយគាត់ឱ្យ បានយល់អំពីប្រវត្តិសាស្ត្រ នៃដែនដីដែលគួរអោយចាប់អារម្មណ៍នេះ ឱ្យកាន់តែ ប្រសើរឡើង។


36

នៅគ្រប់ទីកន្លែងគេបានឃើញវត្ថុបុរាណ ដែលមានការពិពណ៌នាដែលគេមិនអាចអាន បាន ដែលបានតុបតែងជញ្ជាំងវិមាន និងព្រះវិហារផ្សេងៗ។

លោកណាប៉ូឡេអុងនិងអ្នកប្រាជ្ញរបស់គាត់ មានការងឿងឆ្ងល់ អំពីដំណឹងដ៏អាថ៌កំបាំងដែលមាននៅក្នុងរូបភាពទាំងនេះ។

# ៥_អាថ៌កំបាំងនៃក្រាំងពីបុរាណ


37

មួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៧៩៩
សារសំខាន់ដ៏ធំជាងគេបំផុតនៃការរកឃើញ
ខាងបុរាណវិទ្យាបាន កើតឡើងនៅសម័យ នោះ។


38

ទាហានម្នាក់របស់ណាប៉ូឡេអុង បាន គាស់យកចេញពីក្នុងដី នូវរបស់មួយដែល
គេស្គាល់យ៉ាងល្បីល្បាញ ថាថ្មរ៉ូសេត្តាជាថ្ម ខ្មៅមួយដុំ ដែលមានប្រវែង១២២សង់ទី ម៉ែត្រ
និងទទឹង៧៦សង់ទីម៉ែត្រដែលបាន បើកសោ អាថ៌កំបាំងនៃការសរសេរដោយ ប្រើសញ្ញា
និងបង្ហាញពីការសម្ងាត់ដែល បានលាក់ទុករាប់សតវត្សរ៍មកហើយនោះ។


39

ថ្មរ៉ូសេត្តានោះ ឥឡូវនេះ បានតាំងនៅឯ សារមន្ទីរនៃប្រទេសអង់គ្លេស។


40

សិលាចារឹកនេះ កប់នៅជិតទីក្រុងដែនដី សណ្តរនៃរ៉ូសេត្តា ក្រិត្យបុរាណមួយក្នុងអក្សរ ខុសគ្នាបីៈ


41

ការសរសេរដោយប្រើសញ្ញា ការ
សរសេដោយប្រើរូបភាព ការទាក់ទងទៅនឹង អក្សរអេស៊ីព្ទសាមញ្ញ និងអក្សរក្រេក។
ជាការពិតណាស់ អ្នកប្រាជ្ញអាចបកប្រែ ភាសាក្រេកបានយ៉ាងងាយ ប៉ុន្តែអក្សរ
ដោយរូបភាពជារឿងម្យ៉ាងផ្សេងទៀត។


42

ទោះជាយ៉ាងណាក៏ដោយ ២០ឆ្នាំក្រោយ មក គឺនៅឆ្នាំ១៨២២ កម្លោះជនជាតិបារាំង
ដ៏ចំណានម្នាក់ដែលមានឈ្មោះថា ហ្សង់ហ្វ្រង់ស្វ័រ សង់ប៉ូលីយ៉ុងបានធ្វើអោយពិភព
លោកនេះភ្ញាក់ផ្អើលដោយបានបកស្រាយ
សារសម្ងាត់ជាការសរសេរដោយរូបភាពនៅ
លើថ្មរ៉ូសេត្តា។


43

ពេលនោះ មរតកដ៏ទូលំទូលាយរបស់ អេស៊ីព្ទបុរាណបានត្រូវបើកចំហ ទៅកាន់
អ្នកប្រាជ្ញទាំងឡាយនៅលើពិភពលោកនេះ។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


44

ប៉ុន្តែការដែលសំខាន់បំផុតនោះ គឺប្រ វត្តិសាស្ត្រដ៏យូរអង្វែង ដែលគេស្ទើរតែភ្លេច
អស់ទៅហើយរបស់អេស៊ីព្ទនោះ ឥឡូវនេះ បានបញ្ជាក់បន្ថែមអំពីខព្រះគម្ពីរ។
ផ្ទាំងថ្មទាំងឡាយបានស្រែកប្រាប់ថា អ្វីៗដែលព្រះគម្ពីរបានចែងនោះ ពិតប្រាកដ ទាំងអស់មែន។


45

ពួកបុរាណវិទូបន្តជីកកាន់តែច្រើនឡើង មានភ័ស្តុតាងកាន់តែច្រើនឡើង ដែលគេ
បានរកឃើញយកមក បញ្ជាក់អំពីប្រវត្តិ សាស្ត្ររបស់ព្រះគម្ពីរជាមួយនឹងកំណត់ត្រា ប្រវត្តិសាស្ត្រ
នៃការស៊ីវិល័យ នាសម័យ អតីតកាល។


46

ការរកឃើញថ្មីៗនៅតែលម៉ាដុក បាន ធ្វើឱ្យរំភើបដល់ពិភពបុរាណវិទ្យា។
ទីក្រុងនេះត្រូវបានគេហៅថា អេប្លា នៅប្រទេសសេរី និងធ្លាប់ជាសង្គមដ៏មាន ស្តុកស្តម្ភ
និងជឿនលឿនមួយ ដែលមាន មនុស្សជិត៣០០ ០០០០នាក់។


47

តាំងពីការរកឃើញក្រាំងនៅសមុទ្រ
មរណៈមក មិនដែលមានអ្នកប្រាជ្ញដែល បានសិក្សាខាងបុរាណវិជ្ជាណា មានការភ្ញាក់
'ផ្អើលចំពោះការរកឃើញទាំងនោះទេ។ ប៉ុន្តែ ចំពោះអ្នកសិក្សាព្រះគម្ពីរ គេមានការ រំភើប
យ៉ាងខ្លាំងជាងពួកអ្នកប្រាជ្ញទាំងនោះ


48

នៅក្នុងសាលាច្បាប់មួយដែលនៅជាប់
ព្រះរាជវាំង ក្នុងទីក្រុងមានបន្ទះដីឥដ្ឋ ដែលមានអក្សរចារិកចំនួន ១៤០០០
និងបំណែកត្រូវបានគេរកឃើញ ដែលមាន កាលបរិច្ឆេទ យ៉ាងហោចណាស់ ក៏តាំងពី ឆ្នាំ២៣០០
មុនគ្រិស្តសករាជដែរ។
បណ្ណសារដ្ឋានរដ្ឋាភិបាល ដែលផ្ទុកទៅ
ដោយកំណត់ត្រាផ្លូវការរបស់អាណាចក្រអេប្លាក្នុងពេលជាងមួយសតវត្សរ៍ ដែលគេបាន រកឃើញនោះ
បញ្ជាក់ថា ទីក្រុងនោះមាន ចំណាស់ជាងគេបំផុតនៅលើពិភពលោក នេះ។


49

អ្នកប្រវត្តិវិទូខ្លះបានសួរថា តើពួកហេ ព្រើរ អាចមានការលូតលាស់ខាងសិល្បៈ
នៃការសរសេរបានដែរឬទេ នៅជំនាន់ លោក ម៉ូសេនោះ។
រហូតមកដល់សតវត្សរ៍ទីដប់ប្រាំបួន គ្មានភ័ស្តុតាងខាងប្រវត្តិសាស្ត្រណា ដែល បានរកឃើញ
ដើម្បីបញ្ជាក់អំពីការនោះ ឡើយ។

# ៥.អាចឹកំបាំងនៃក្រាំងពីបុរាណ



50

ទោះបីជាយ៉ាងណាក៏ដោយបន្ទះថ្មអេប្លា និងការរកឃើញដទៃទៀតមានកាលបរិច្ឆេទ
មុនជំនាន់លោកម៉ូសេរស់នៅយ៉ាងយូរ។
តាមពិត ពួកបុរាណវិទូបានរកឃើញបណ្ណា ល័យទាំងមូលដែលមានកាលបរិច្ឆេទរាប់សតវត្សរ៍
មុនលោកម៉ូសេ។



51

បន្ទះថ្មនៅអេប្លា បានបង្ហាញអំពីប្រវត្តិ នៃការបង្កបង្កើតលោកីយ៍ និងប្រវត្តិសាស្ត្រ នៃទឹកជំនន់។
ក៏បានរ៉ាយរ៉ាប់ផងដែរ នូវ ឈ្មោះ និងទីកន្លែងដែលកើតឡើងជាមួយ គ្នានេះ
ដែលជារឿងរ៉ាវក្នុងព្រះគម្ពីរ ដូច ជាអេសាវ អ័ប្រាហាំ អ៊ីស្រាអែល ស៊ី ណាយ
សូម្បីតែទីក្រុងយេរូសាឡិមក៏មាន ផងដែរ។



52

ប៉ុន្តែរឿងដែលគួរអោយភ្ញាក់ផ្អើលមែន ទែននោះ គឺការរៀបរាប់អំពីទីក្រុងដែល "មានបាបពីរ"
សូដុំម និងកូម៉ូរ៉ា។
មុនពេលដែលគេរកឃើញបន្ទះថ្មនេះ គ្មានឯកសារប្រវត្តិសាស្ត្រណា ដែលទាក់
ទងទៅនឹងទីក្រុងទាំងពីរនេះ ត្រូវបានគេ ដឹងឮឡើយ លើកលែងតែព្រះគម្ពីរប៉ុណ្ណោះ។
ហេតុដូច្នោះហើយបានជាគេចាត់ទុកទី នោះថា ជាកន្លែងខាងទេវកថា (រឿងព្រេង)។



53

ទោះជាយ៉ាងណាក៏ដោយ មានសៀវភៅ ជាច្រើនត្រូវបានសរសេរឡើងវិញ សំរាប់
ការរកឃើញទាំងអស់នេះ ដែលបានបញ្ជាក់ យ៉ាងពិតប្រាកដ នូវឈ្មោះបុរាណវិទ្យាជា
ច្រើននៅសម័យនោះ។



54

អ្នកនិពន្ធខ្លះបានទទូលស្គាល់ថា គម្ពីរ លោកុប្បត្តិ មិនមែនគ្រាន់តែជាចម្រៀង
អ្នកគង្វាលចៀមបុរាណ និងរឿងព្រេង បុរាណនោះទេ។
ការរកឃើញនៅអេប្លា និងទីកន្លែង ផ្សេងៗទៀត បានបញ្ជាក់អំពីភាពពិត
ប្រាកដរបស់ព្រះគម្ពីរ។




55

(ព្រះគម្ពីរ ទំនុកដំកើង ១១៩:១៦០)
ស្តេចដាវីឌបានមានព្រះបន្ទូលថា "បូករួម នៃព្រះបន្ទូលរបស់ទ្រង់ទៅឃើញថា ពិត ត្រង់ទាំងអស់
ទំនុកដំកើង១១៩:១៦០




56

(ព្រះគម្ពីរ អេសាយ ៤៥:១៩)
ព្រះបានមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ អេសាយថា "...គឺអញ ព្រះយេហូវ៉ានេះ
អញនិយាយតាមសុចរិត អញថ្លែងប្រាប់ សេចក្តីដែលត្រឹមត្រូវ"។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


57

មនុស្សជាច្រើននិយាយថា មនុស្សស្លាប់ មិននិយាយរឿងទេ ប៉ុន្តែតាមពិត មនុស្សស្លាប់បាននិយាយ។
គេនិយាយរឿងដែលគួរឱ្យចាប់ចិត្ត ជាងរឿងប្រលោមលោក។
អ្នកដែលបានស្លាប់ក្នុងសម័យស៊ីវិល័យ ជាយូរមកហើយនោះ កំពុងបាននិយាយពីផ្នូរនៃធូលីដីរបស់គេ ដោយបញ្ជាក់អំពី ភាពត្រឹមត្រូវនិងភាពដែលគួរអោយជឿបាននៃព្រះបន្ទូលរបស់ព្រះ។


58

រហូតមកដល់សតវត្សរ៍ទីដប់ប្រាំបួន មានពួកអ្នកប្រាជ្ញជាច្រើនបានជឿថា ព្រះមហាក្សត្រីសេមីរ៉ាមីស បានសាងទីក្រុង បាប៊ីឡូន។
ប៉ុន្តែនៅក្នុងព្រះគម្ពីរ ដានីយ៉ែលបាន លើកយកព្រះបន្ទូលរបស់ស្តេចនេប៊ូក្នេសាមកនិយាយថា



59

(ព្រះគម្ពីរ ដានីយ៉ែល ៤:៣០)
"...នេះតើមិនមែនជាក្រុងបាប៊ីឡូនដែលអញបានស្អាងទេឬអី?"
ដានីយ៉ែល ៤:៣០
តើអ្នកណាត្រូវ?



60

នៅក្នុងឆ្នាំ១៨៩៩ លោករ៉ូបើរត កុលឌីវី បានចាប់ផ្តើមជីកសំណង់បាក់បែកចាស់ៗនៃទីក្រុងបាប៊ីឡូន ដោយបានគាស់យកបាន នូវឥដ្ឋដុតរាប់ពាន់ដុំដែលមានស្នាមត្រារបស់ស្តេចនេប៊ូក្នេសាទាំងអស់ ហើយដែលទាំង អស់នោះត្រូវបានគេយកមកពីជញ្ជាំងទីក្រុង និងជញ្ជាំងព្រះវិហារ។


61

ផ្ទាំងសិលាចារឹកមួយផ្ទាំង បានរៀបរាប់ ពីស្នាព្រះហស្តរបស់ស្តេចនេប៊ូក្នេសានោះ ត្រូវបានគេរកឃើញ ដោយពួកបុរាណវិទូ នៃទីក្រុងបាប៊ីឡូន។


62

នៅលើបន្ទះសិលាចារឹកនោះ ស្តេចបានមានបន្ទូលថា "សំណង់ការពារត្រូវរបស់អេសាគីឡា និង បាប៊ីឡូន អញបានពង្រឹង និងសង់ឡើង ដើម្បីកេរ្តិ៍ឈ្មោះនៃរាជ្យរបស់យើងរៀងរហូត"។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



63

(ព្រះគម្ពីរ ដានីយ៉ែល ៤:៣០)

ព្រះគម្ពីរបានថ្លែងថា ស្តេចដ៏មានអំនួត នេប៊ូក្នេសា "បានមានបន្ទូលថា នេះតើមិន
មែនជាក្រុងបាប៊ីឡូនដ៏ជាធំ



64

ដែលអញបានសាងទុកជាព្រះរាជស្ថាន ដោយអានុភាពនៃអំណាចរបស់អញ ហើយ សំរាប់ជាសិរីល្អ
នៃឥទ្ធានុភាពរបស់អញទេ ឬ?" ដានីយ៉ែល ៤:៣០



65

អក្សរចារឹកនៃផ្ទះឥណ្ឌាខាងកើត សព្វថ្ងៃ នេះនៅក្នុងទីក្រុងឡុង ទុកសសរ៦ នៃ
សំណេររបស់បាប៊ីឡូន សំរាប់ការពិពណ៌នា អំពីគំរោងសំណង់ដ៏ធំរបស់ស្តេចនេប៊ូក្នេសា។
ប៉ែលបានឈរនៅចំពោះព្រះបន្ទូលរបស់ព្រះ
ម្តងទៀតហើយ។



66

អាថ៌កំបាំងមួយទៀតដែលមិនទាក់ទង ទៅនឹងសាសនានោះ គឺការបាត់ព្រះចៅ បេលសាសារ
ជាអ្នកដឹកនាំនៃទីក្រុង បាប៊ីឡូន។

ព្រះគម្ពីរបានដាក់ឈ្មោះស្តេច បេល សាសារថា ជាអ្នកដឹកនាំនៃទីក្រុង បាប៊ីឡូន
ដែលបានធ្វើទីបន្ទាល់អំពី ដៃសរសេរលើ ជញ្ជាំងបន្ទប់ជប់លៀងមួយ។

តើទ្រង់គ្រាន់តែជាការប្រឌិតនៃគំនិតដ៏
ប៉ិន ប្រសប់របស់ស្តេចដានីយ៉ែលប៉ុណ្ណោះ ទេឬយ៉ាងណា? ទេមិនមែនដូច្នោះទាល់តែសោះ។



67

ណាបូនីដាស ដែលជារាជទាយាទរបស់ ស្តេចនេប៊ូក្នេសាដ៏ឧត្តម បានបន្ទុកបណ្តាក់
ជាបន្តអោយព្រះរាជបុត្រាទ្រង់ព្រះនាមបេលសាសារ នៅពេលដែលទ្រង់តែងតែគង់ នៅធីម៉ា
ក្នុងប្រទេសអារ៉ាប់ អស់រយៈ ពេលដប់ឆ្នាំ។



68

បន្ទះសិលាចារឹកនៃការរកឃើញរបស់បុរាណ
វិទូថ្លែងថា ព្រះរាជាណាចក្រនោះ ពិតជាត្រូវបាន ថ្វាយទៅបេលសាសារ



69

"ជាព្រះរាជបុត្រាទ្រង់ នោះគឺជាការ ដែលបានសរសេរមកបេលសាសារ បុត្រាដែលត្រូវបានលើក
ដំកើងរបស់អញ អើយ ចូរអ្នកដាក់សេចក្តីសរសើរនៃទេវតាដ៏ ធំនៅក្នុងចិត្ត សូមកុំឱ្យឯងធ្វើបាបឡើយ

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


70

សូមអោយទ្រង់បានស្តប់ព្រះហឫទ័យនឹងជីវិត
ដ៏រីកចំរើនយ៉ាងបរិបូរ និងឫទ្ធានុភាពនៃព្រះ អាទិទេពគង់ក្នុងព្រះទ័យរបស់ព្រះចៅ
បេលសាសារ ដែលជាកូនច្បងជាទី
ស្រឡាញ់របស់អញ"
ព្រះមានបន្ទូលទៅកាន់មនុស្សសម័យថ្មី ទំព័រ១៥៤។


71

(ព្រះគម្ពីរ ដានីយ៉ែល ១២:៤)
តើវាមិនមែនជាការគួរអោយចាប់ អារម្មណ៍ទេឬអី ដែលនៅក្នុងជំពូកបញ្ចប់
នៃគម្ពីរដានីយ៉ែលយើងបាន អាននោះ និយាយថា: "តែចំណែកអ្នក ឱដានីយ៉ែល អើយ
ចូរបិទបាំងពាក្យទាំងនេះ ហើយបិទ ត្រាសៀវភៅនេះទុកដរាបដល់គ្រាចុងបំផុត ចុះ:


72

មនុស្សជាច្រើននឹងខំរកយល់ ហើយចំណេះ នឹងបានចំរើនឡើង"
ដានីយ៉ែល១២:៤
ចំណេះនឹងបានចំរើនឡើងមិនមែនគ្រាន់តែ
នៅខាងពិភពវិទ្យាសាស្ត្រនេះប៉ុណ្ណោះទេ។
តែនឹងបានចំរើនឡើងខាងភាពត្រឹមត្រូវនៃ
ព្រះបន្ទូលរបស់ព្រះផងដែរ។


73

ថ្មឥដ្ឋនិងស៊ីឡាំង បន្ទះថ្ម និងចម្លាក់ ដែលបានជីករកឃើញដោយបុរាណវិទូបាន បញ្ជាក់ថា
អ្វីៗដែលព្រះគម្ពីរបាននិយាយ នោះ គឺជាការពិត!


74

ទោះបីជាយ៉ាងណាក៏ដោយ ភ័ស្តុតាង មួយទៀតដែលជំរុញអោយឃើញថា ព្រះគម្ពីរគឺជាព្រះបន្ទូល
ដែលបណ្តាល ដោយព្រះនោះ គឺជាលទ្ធភាពនៃការទាយ ទុកពីអនាគតយ៉ាងត្រឹមត្រូវ


75

(ព្រះគម្ពីរ អេសាយ ៤៦:៩-១០)
"ដ្បិតអញនេះហើយជាព្រះ ហើយក៏ឥត មានអ្នកណាទៀតដូចអញឡើយ

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


76

អញរមែងសំដែងប្រាប់ពីការដែលត្រូវមកខាងចុងបំផុត ហើយតាំងពីចាស់បុរាណក៏ប្រាប់ពីការដែលមិនទាន់មានមកដែរ” អេសាយ ៤៦:៩-១០។


77

មែនហើយ ព្រះទ្រង់បានរូតបើកវាំងននៃ ពេលវេលា ដោយផ្តល់មកឱ្យយើងនូវ គំហើញនៃអនាគតទ្រង់បានបញ្ជាក់ដល់ពិភព លោកថា ព្រះគម្ពីរ-សៀវភៅរបស់ទ្រង់។


78

តាំងពីមុនពេលទីក្រុងបាប៊ីឡូនបានចំរើន រុងរឿង និងមានអំណាចមកម្ល៉េះ សៀវភៅរបស់ព្រះបានប្រាប់ ពីការដួលរលំនៃទី ក្រុងនេះរួចស្រេចទៅហើយ។


79

(ព្រះគម្ពីរ អេសាយ ១៣:១៩)
“នោះក្រុងបាប៊ីឡូនដែលជាសិរីល្អនៃអស់ទាំងនគរ ហើយជាទីអំនួតរបស់សាសន៍ខាល់ដេរ


80

នឹងត្រូវដូចជាកាលដែលព្រះបានរំលំក្រុងសូ ដុំម និងក្រុងកូម៉ូរាបង់”
អេសាយ១៣:៩។ ព្រះគម្ពីរថែមទាំងបាន ប្រាប់អោយដឹងជាមុន នូវអំណាចដែលព្រះ នឹងរំលំនគរដ៏មានចេស្តានេះផងដែរ។


81

(ព្រះគម្ពីរ យេរេមា ៥១:១១)
“ព្រះយេហូវ៉ាទ្រង់បានដាក់វិញ្ញាណរបស់
ពួកស្តេចសាសន៍មេឌីឡើង ពីព្រោះទ្រង់ មាន គំនិតទាស់នឹងបាប៊ីឡូន ដើម្បីនឹង បំផ្លាញចេញ”
យេរេមា ៥១:១១


82

ឈ្មោះមនុស្សដែលនឹងដឹកនាំកងទ័ពប្រ ឆាំងនឹងទីក្រុងបាប៊ីឡូន និងវិធីដែលគេប្រើដើម្បីដណ្តើមយកទីក្រុងនោះ ត្រូវបាន ទស្សនទាយ១៥០ឆ្នាំ មុនពេលអ្នកនោះ បានកើតមក។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



83

(ព្រះគម្ពីរ អេសាយ៤៥:១)

“ព្រះយេហូវ៉ាទ្រង់មានបន្ទូលដល់ស៊ីរូស... អញនឹង... បើកទ្វារនៅមុខវា ហើយទ្វារ ទាំងនោះនឹងមិនត្រូវបិទវិញឡើយ...”

អេសាយ ៤៥:១។

តើបទទំនាយនៅក្នុងព្រះគម្ពីរបានសំរេច ហើយឬនៅ ចំពោះសេចក្ដីត្រង់នេះ?។




84

នៅក្នុងបន្ទប់ពែរស៍ នៃសារមន្ទីរអង់គ្លេស ស៊ីឡាំងរបស់ស្ដេចស៊ីរូសឈរនៅទីដែលគេរកឃើញនៅក្នុងសំណង់បាក់បែកនៅទីក្រុង បាប៊ីឡូន។

នៅលើស៊ីឡាំងដីឥដ្ឋនេះ ស្ដេចស៊ីរូសបានប្រាប់ពីនគរចំណុះរបស់ទ្រង់ ។

ហើយសេចក្ដីលំអិតនោះមានយ៉ាងពិតប្រាកដមែន។




85

ព្រះគម្ពីរមិនមែនគ្រាន់តែបានប្រាប់មុនពី ការវិនាសនៃទីក្រុងបាប៊ីឡូន ប៉ុណ្ណោះទេ តែថែមទាំងបានបង្ហាញអំពី រដ្ឋាភិបាល របស់នគរនោះតទៅមុខទៀតផង:



86

(ព្រះគម្ពីរ យេរេមា ៥១:៣៧)

“ឯក្រុងបាប៊ីឡូននឹងត្រឡប់ទៅជាគងគំនរ...” យេរេមា ៥១:៣៧។



87

(ព្រះគម្ពីរ អេសាយ ១៣:២០-២១)

លោកអេសាយបានសរសេរថា:

“ក្រុងនោះនឹងគ្មានអ្នកណានៅតទៅទៀត ឡើយ...”



88

គឺនឹងមានតែសត្វនៅទីរហោស្ថានបានដេកនៅទីនោះវិញ... សត្វអូទ្រីសនឹងអាស្រ័យនៅ ហើយពពែព្រៃ នឹងលោតកញ្ឆេងនៅទី នោះ...”

អេសាយ១៣:២០-២១




89

មានតែព្រះទេដែលអាចទ្រង់ជ្រាបជាមុន នូវអនាគត និងទស្សនទាយបានយ៉ាងពិត ប្រាកដជាទីបំផុតអំពីវាសនានៃទីក្រុងដ៏មាន ចេស្ដានេះ។

អ្នករុករកម្នាក់ឈ្មោះអុស្ទាន អេចធ៍ ឡាយ៉ាដ៍ពិពណ៌នាអំពីទីតាំងនៃទីក្រុងបាប៊ីឡូនបុរាណ:

៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ

# ៥_អាថ៌កំបាំងនៃក្រាំងពីបុរាណ


90

គំនរសម្រាមដែលគ្មានរូបរាង បានគ្រប ដណ្តប់ដីជាច្រើនហិចតា ជាទីកន្លែងមួយ ដែលអាក្រក់មើលជាទីបំផុត


91

ទីទុយចាប់ផ្តើមតាំងពីព្រៃគុម្ពោធតូចៗ ហើយលលាដ៍ក្បាលឆ្កែព្រៃ ដែលមានក្លិន អាសោចន៍ ពាសពេញគន្លងនង្គ័ល។

ការរកឃើញនៅក្នុងសំណង់បាក់បែកនៅ ទីក្រុងនីនីវេ និងបាប៊ីឡូន ទំព័រ៤១៣។



92

បាប៊ីឡូនដែលជាទីក្រុងដ៏មានសិរីល្អគ្មាន អ្វីសេសសល់ឡើយ មានតែឈ្មោះនៅតាម ផ្ទាំងសញ្ញានៅតាម ចិញ្ចើមថ្នល់តែប៉ុណ្ណោះ។

គំនរសំរាមជាច្រើន បានខ្ចាត់ខ្ចាយពាស ពេញ សំណង់បាក់បែកនៃបាប៊ីឡូនបុរាណ ពិតជាភស្តុតាង នៃការពិតនិងភាពសុចរិត នៃព្រះគម្ពីរ។


93

(ព្រះគម្ពីរ អេសាយ ៤០:៨)

យើងអាចយល់ស្របជាមួយនឹងហោរា

"ស្មៅក៏ស្វិតក្រៀម ហើយផ្ការោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប"

អេសាយៈ៤០:៨


94

មិត្តទាំងឡាយ ប្រសិនបើព្រះអាចប្រាប់ ពីអនាគតនៃនគរបុរាណបានយ៉ាងច្បាស់រាប់ សតវត្សរ៍មុនមកដូច្នេះ តើឥឡូវនេះគួរឱ្យ សង្ស័យ អំពីលទ្ធភាពរបស់ទ្រង់ ដែលអាចនឹង ទស្សនទាយពីអនាគត របស់យើងដែរឬទេ? មិនត្រូវសង្ស័យឡើយ។


95

តាមពិតការទស្សនទាយនៃព្រះគម្ពីរបាន ផ្តល់មកយើងនូវសក្តានុពល នៃការបើក វាំងនន ដើម្បីសំឡឹងមើលទៅឯអនាគត តាមរយៈព្រះនេត្ររបស់ព្រះ និងក្រឡេក មើលទៅដំណោះស្រាយរបស់ទ្រង់ ចំពោះ បញ្ហា ដែលនឹងគំរាមកំហែងការរស់នៅ របស់មនុស្សនៅលើពិភពផែនដីនេះ។


96

ព្រះគម្ពីរប្រសើរជាងប្រវត្តិសាស្ត្រ ដែល គួរអោយទុកចិត្តបាន ប្រសើរជាង រឿងពិត ក្នុងប្រវត្តិសាស្ត្រ ប្រសើរជាងបទទំនាយ បានសម្រេចហើយ ទៅទៀត។

ប្រសិនបើមិនដូច្នោះទេនោះ វាគ្មានអ្វី សំខាន់ឡើយក្នុងការជឿទៅលើព្រះគម្ពីរនោះ

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


97

ប្រធានបទនោះជាបេះដូងនៃសៀវភៅ នោះទាំងមូល គឺដំណើររឿងដែលបានកើតឡើងនៅលើវាល ដ៏រដិបរដុបមួយនៅខាង ក្រៅទីក្រុងយេរូសាឡិម ជាង១៩សតវត្សរ៍កន្លងមកហើយ។

ហើយរឿងនោះវាជារឿងដ៏សំខាន់ដែល យើងត្រូវតែជឿទៅលើរឿងនោះ។


98

ទោះបីជាព្រះរាជបុត្រារបស់ព្រះ ដែល មានព្រះជន្មរស់ បានសុគតនៅលើឈើឆ្កាង ឬមិនបានសុគតក៏ដោយ

ទោះបីទ្រង់ជាព្រះដែលបាន ចែងនៅ ក្នុងព្រះគម្ពីរឬមិនមែនក៏ដោយ តើភ្នំរលា ក្បាល(កាលវ៉ារី) គឺជាការរវើរវាយ ឬជា ការពិត?

នេះជាការសំខាន់ដែលយើងត្រូវតែដឹង!


99

ប្រហែលជាភ័ស្តុតាងដ៏ធំបំផុតដែលថា ព្រះគម្ពីរ គឺជាសៀវភៅ ដែលបានអះអាងថាជាអំណាចនៅក្នុងសៀវភៅដែលអាចផ្លាស់ប្តូរជីវិតមនុស្សបាន។

អំណាចនោះត្រូវបានរុំព័ទ្ធមនុស្សម្នាក់ គឺ ព្រះយេស៊ូវគ្រីស្ទ! ព្រះយេស៊ូវបានមានព្រះ បន្ទូលថា


100

(ព្រះគម្ពីរ យ៉ូហាន ៥:៣៩)

"អ្នករាល់គ្នាស្ទង់មើលគម្ពីរដោយស្មានថា បានជីវិតនៅអស់កល្បជានិច្ចអំពីគម្ពីរនោះមកគឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ" យ៉ូហាន ៥:៣៩


101

ព្រះយេស៊ូវកំពុងបានមានព្រះបន្ទូលអំពី សញ្ញាចាស់ ព្រោះសញ្ញាថ្មីមិនទាន់ត្រូវបាន គេសរសេរទេ ហើយនៅពេលដែលអ្នក បើកទំព័រសញ្ញាចាស់ អ្នកនឹងរកឃើញថា ទំព័រទាំងនោះទស្សន៍ទាយអំពីការយាងមក របស់ព្រះមែស៊ី និងប្រាប់អំពីបេសកកម្មនៃ សេចក្តីស្រឡាញ់ និងសេចក្តីសង្គ្រោះរបស់ទ្រង់។


102

(ព្រះគម្ពីរ លូកា ២៤:៤៤)

ព្រះយេស៊ូវបានប្រាប់សាវកទ្រង់ថា:

"...នេះហើយជាសេចក្តីដែលខ្ញុំបាន ប្រាប់អ្នករាល់គ្នា កាលនៅជាមួយគ្នានៅ ឡើយ គឺថាត្រូវតែបានសម្រេច គ្រប់ទាំង សេចក្តីដែលបានចែកទុកពីខ្ញុំ


103

ទោះក្នុងក្រិត្យវិន័យលោកម៉ូសេ ក្នុងទំ នាយពួកហោរា ឬក្នុងបទទំនុកដំកើងផង" លូកា ២៤:៤៤

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



104

សញ្ញាចាស់បានទស្សនទាយអំពីព្រះគ្រីស្ទ ហើយសញ្ញាថ្មីអំពីប្រវត្តិនៃជីវិតរបស់ទ្រង់។
ដូច្នេះយើងឃើញថា នៅក្នុងព្រះគម្ពីរ ទាំងមូល គឺជាការបើកសំដែងឱ្យឃើញពី ព្រះយេស៊ូវគ្រីស្ទ
ដែលបានយាងមកបង្ហាញ
ដល់ពិភពលោកមួយដែលបះបោរប្រឆាំងទៅនឹងអ្វីដែលព្រះវរបិតាទ្រង់ប្រាថ្នាចង់បាន នោះ។




105

ហេតុនោះហើយបានជាព្រះគម្ពីរត្រូវបាន គេហៅថា "ព្រះបន្ទូលដ៏រស់"
ព្រះគម្ពីរបានផ្ទុកនូវអំណាចដ៏អស្ចារ្យជា មួយខ្លួន ទោះបីព្រះគម្ពីរទៅទីណាក៏ដោយ
អំណាចដែលផ្លាស់ប្តូរជីវិតបំផ្លាស់បំប្រែ អត្តចរិតរបស់មនុស្ស ផ្តល់កម្លាំងដល់អ្នក ខ្សោយ
លើកទឹកចិត្តដល់អ្នកអស់សង្ឃឹម ហើយនិងផ្តល់សេចក្តីសង្ឃឹមដល់អ្នកស្លាប់។
គ្រប់កាលៈទេសៈនៃប្រវត្តិសាស្ត្រ អំណាចនៃព្រះគម្ពីរ ផ្លាស់ប្តូរមនុស្ស
ត្រូវបានបញ្ជាក់ម្តងហើយម្តងទៀត
មនុស្សច្រឡោតខឹងបានផ្លាស់ទៅជាមនុស្សស្លូតបូត និងមានសេចក្តីសុខសាន្ត
ដោយសារអំណាចនៃព្រះគម្ពីរ។



106

មនុស្សសំបូរកាមតណ្ហា គ្មានសីលធម៌ ត្រូវបានក្លាយទៅជាបរិសុទ្ធ និងស្អាតស្អំ។
អ្នកប្រមឹកត្រូវបានរំដោះពីជីវិតនៃការស៊ីផឹក របស់គេ
ពួកចោរ ត្រូវបានផ្លាស់ប្រែចិត្តពីការ លួចរបស់គេ
អ្នកកេងប្រវ័ញ្ចក្លាយជាឈប់កេងប្រ វ័ញ្ច។
អ្នកមិនចាំបាច់សំឡឹងរកមើលឃាតករ ចិត្តរឹងនៅក្នុងគុកដែលបានផ្លាស់ប្តូរទៅជា
គ្រីស្ទានដ៏មានអំណរ តាមរយៈអំណាច របស់ព្រះគម្ពីរទៀតទេ។



107

អ្នកមិនចាំបាច់រកមើលគ្រួសារដែលប្រុង នឹងលែងលះគ្នា ដែលត្រូវបានសង្គ្រោះ
និងបានបំពេញដោយសេចក្តីស្រឡាញ់ថ្មី តាមរយៈអំណាចរបស់ព្រះគម្ពីរនោះទេ
គ្មានអ្នកណាម្នាក់អាចអានព្រះគម្ពីរ ដោយការទុកចិត្តរៀងរាល់ថ្ងៃដោយសៀវ
ភៅរបស់ព្រះនេះមិនបានផ្លាស់ប្តូរគេនោះទេ។
ហើយប្រសិនបើអ្នកចំណាយពេលរាល់ថ្ងៃ
្អានព្រះគម្ពីរនេះ
មិត្តទាំងឡាយ ព្រះគម្ពីរនោះក៏នឹងផ្លាស់ ប្តូរជីវិតលោកអ្នកដែរ។



108

ព្រះយេស៊ូវបានចំណាយពេលវេលា របស់ទ្រង់ដើម្បីបំផ្លាស់បំប្រែមនុស្ស។ នោះ
ហើយដែលជាបេះដូងនៃគ្រីស្ទសាសនា។
ហើយក៏ជាបេះដូងនៃព្រះគម្ពីរ ហើយនិងជា អាថ៌កំបាំងនៃអំណាច។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ


109

(ព្រះគម្ពីរ យ៉ូហាន ៨:៣២)
ព្រះយេស៊ូវទ្រង់បានជ្រាបអំពីអំណាច ដែលបានផ្លាស់ប្ដូរមនុស្ស:
"អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនោះនឹងប្រោសអ្នករាល់ គ្នាបានរួច" យ៉ូហាន ៨:៣២។


110

វាជាការពិត ដែលថាដោះលែង មនុស្សឱ្យមានសេរីភាពនោះ គឺជាការ ផ្លាស់ប្ដូរមនុស្ស!
វាជាការពិតដែលថា ធ្វើឱ្យអ្នក ប្រមឹកក្លាយទៅជាអ្នកមិនផឹកស្រា ហើយ ក្លាយទៅជាឪពុកដ៏ជាទីស្រឡាញ់នោះ។
វាជាការពិតដែលថា រំដោះអ្នកញៀន គ្រឿងញៀនឱ្យលែងញៀនទៀតនោះ
មានភស្តុតាងជាច្រើន ដែលគេកំពុងតែ អនុវត្ត នៅលើពិភពលោកយើងសព្វថ្ងៃនេះ យើងសួរថា "តើអ្វីទៅជាការពិត?"


111

(ព្រះគម្ពីរ យ៉ូហាន ១៧:១៧)
ព្រះយេស៊ូវបានផ្ដល់ចម្លើយ:
"ឯសេចក្ដីពិតគឺជាព្រះបន្ទូលរបស់ ទ្រង់" យ៉ូហាន១៧:១៧។
ព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះ គឺ ជាការពិត!
អំណាចនៃព្រះបន្ទូលនោះអាចផ្លាស់ប្ដូរ ចិត្តរបស់បុរស និងស្ត្រីទាំងឡាយបាន។


112

ប៉ុន្តែព្រះបន្ទូលរបស់ព្រះអាចផ្លាស់ប្ដូរ បានតែចំពោះអ្នកណាដែលចង់ផ្លាស់ប្ដូរ ប៉ុណ្ណោះ
អ្នកដែលចង់ទទួលបុរស និង ស្ត្រីទាំងឡាយនៅក្នុងសៀវភៅនោះ គឺព្រះ យេស៊ូវគ្រីស្ទ។
ហើយជីវិតមនុស្សរាប់លាននាក់ត្រូវបាន ផ្លាស់ប្ដូរ នៅពេលដែលគេបានសិក្សាព្រះ គម្ពីរ។
គ្មានអំណាចដែលធំជាងនេះនៅលើ ពិភពលោកនេះ ដែលអាចប៉ះពាល់ចិត្ត និងបំផ្លាស់បំប្រែជីវិតបាននោះឡើយ។
លោកអ្នកឃើញទេ វាធ្វើឱ្យមានការខុសគ្នា ពីអ្វីដែលយើងធ្វើនៅក្នុងសៀវភៅនេះ។
ព្រះគម្ពីរមិនមែនគ្រាន់តែជាសៀវភៅដែល
សម្រាប់ កាន់ទៅព្រះវិហារ ឬទុកនៅឯផ្ទះប៉ុណ្ណោះទេ!
លើសពីនេះទៅទៀតគឺជាពតិមានដ៏មានប្រ យោជន៍ ឬក៏ជាដំបូន្មានដ៏មានសារសំខាន់។
គឺជាការដែលព្រះទ្រង់មានព្រះបន្ទូលមក កាន់ចិត្តយើង។
គឺជាលិខិត នៃសេចក្ដីស្រឡាញ់របស់ ព្រះមកកាន់កូនចៅរបស់ទ្រង់នៅលើភពផែនដីនេះ។
នៅក្នុងសៀវភៅនោះមានអាថ៌កំបាំងជា ច្រើននៃអំណររីករាយដ៏នៅអស់កល្ប និង សន្តិភាពនៅក្នុងចិត្ត។

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



113

(វីដេអូ ១២វិនាទី) ខ្ញុំសូមប្រាប់រឿងមួយ ស្ដីអំពីព្រះបន្ទូលបានផ្លាស់ប្ដូរជីវិតនេះជា
ច្រើនឆ្នាំកន្លងមកហើយ មាននាវាមួយ ឈ្មោះបូនធី។

នៅក្នុងឆ្នាំ១៧៩០ ប្រធាននាវិក ប្លៃត៍
និងនាវិករបស់គាត់បានចេញដំណើរពីប្រទេសអង់គ្លេសទៅដឹកយក ដើមខ្នុរយកមកដាំនៅ
ឥណ្ឌាខាងលិច ដើម្បីធ្វើជាអាហារដែល មានតម្លៃ ថោកសម្រាប់ពួកទាសករ។



114

(វីដេអូ ៧វិនាទី) ដោយសារតែការដឹកនាំ ដ៏ឃោរឃៅរបស់លោកប្លៃត៍ និងការថែ
រក្សាមិនល្អពីនាវិករបស់គាត់ មានការបះ បោរនៅលើនាវាមួយប្លៃត៍ឈើរ គ្រីស្ទាន
គឺជាអ្នកដឹកនាំការបះបោរនោះ បានធ្វើឱ្យ លោកប្លៃត៍ និងនាវិក១៨នាក់ទៀតបាន
រសាត់ក្នុងកូនទូកតូចមួយ។

ពួកគេអាចចាត់ចែងរកផ្លូវទៅកាន់ប្រ ទេសអង់គ្លេសវិញបានយ៉ាងងាយ ព្រោះ
តែជំនាញរបស់នាយនាវិកប្លៃត៍ ទៅកាន់ ច្រកផ្លូវនៃនាវា



115

(វីដេអូ ៨វិនាទី) ពួកនាវិកនៅលើកប៉ាល់បូនធី មិនបាន ជោគជ័យល្អប្រសើរទេ ប៉ុន្តែគេក៏បាន
បញ្ចប់ដំណើរ របស់គេនៅលើកោះដែល គ្មានមនុស្សនៅមួយឈ្មោះ កោះភីណកាអ៊ីន



116

ពួកគេបានដុតកប៉ាល់បូនធីចោល ដើម្បីបំ បាត់ដាន។ កាលពួកគេបាននៅលើកោះ ថាហ៊ីធី
ពួកគេបាននាំមនុស្សជនជាតិ ដើមមួយចំនួន មានស្ត្រី និងក្មេងៗខ្លះ
និងបុរសពីរបីនាក់ចូលទៅក្នុងនាវា។

បញ្ហាបានមកដល់ពួកបះបោរនៅពេល ដែលពួកគេរៀនបិតស្រា គឺមានអំពើ ឃាតកម្ម
និងឧក្រិដ្ឋកម្មបានកើតឡើង។

ដំបូងឡើយ គឺមានមនុស្សប្រុសតែម្នាក់ ឈ្មោះយ៉ូហាន អ័ដាម ហើយនិងស្ត្រីហើយ
និងក្មេងៗមួយចំនួនប៉ុណ្ណោះ

# ៥.អាថ៌កំបាំងនៃក្រាំងពីបុរាណ



117

(វីដេអូ ៨វិនាទ) ហ្វូនអ័ដាមបានរកទាល់ តែឃើញនូវព្រះគម្ពីររបស់នាវាបូនធី ដែលបានដាក់នៅក្នុងហឹប។

គាត់បានចាប់ផ្ដើមអានព្រះគម្ពីរនោះ ហើយនៅ ពេលដែលគាត់បានអានព្រះ គម្ពីរនេះមានការផ្លាស់ប្ដូរយ៉ាងអស្ចារ្យ បានកើតឡើង ដល់គាត់។

គាត់បានដឹងថា ការទទួលខុសត្រូវយ៉ាង ធំសំបើមមួយបានធ្លាក់មកលើគាត់ក្នុងការស្វែងរកអនាគតឱ្យក្មេង១ទាំងអស់នោះ។ គាត់ក៏បានចាប់ផ្ដើមអប់រំពួកគេឱ្យចេះអាន និងចេះសរសេរ ព្រមទាំងឱ្យចេះរបៀបរស់ នៅទៀតផង។

ការផ្លាស់ប្ដូរដ៏អស្ចារ្យនៅក្នុងចំណោមប្រជាជនទាំងអស់ដែលរស់នៅលើកោះនោះបានទាក់ទាញអារម្មណ៍អ្នក ដែលបានធ្វើដំណើរតាមទូកកាត់កោះនោះ។

ក្រោយមក ដល់រដ្ឋាភិបាលអង់គ្លេស ហើយទីបំផុតដល់ពិភពលោកទាំងមូល។


118

ព្រះគម្ពីរនេះក៏អាចផ្លាស់ប្ដូរចិត្តរបស់ លោកអ្នកផងដែរ។

នៅពេលដែលយើងអានព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធដដែលដែលបានបណ្ដាល ចិត្តដល់អ្នក ដែលបានសរសេរព្រះគម្ពីរឱ្យសរសេរនូវព្រះបន្ទូលរបស់ព្រះរាប់សតវត្សរ៍មកហើយនោះ នឹងផ្លាស់ប្ដូរជីវិតយើង នៅពេលដែលយើងសិក្សាព្រះគម្ពីរនេះ។

សូមចូលមកឯព្រះបន្ទូលរបស់ព្រះដោយ ចិត្តបើកចំហ ព្រមទាំងនិយាយដោយ សេចក្ដីជំនឿថា:

"ឱ ព្រះអម្ចាស់អើយ សូមបង្ហាញ សេចក្ដីពិតរបស់ទ្រង់ដល់ទូលបង្គំ ហើយ ទូលបង្គំនឹងដើរតាម"

"ឱ ព្រះអម្ចាស់អើយ សូមបង្ហាញការ ផ្លាស់ប្ដូរ ដែលទូលបង្គំត្រូវការក្នុងជីវិត ទូលបង្គំ

"ឱ ព្រះអម្ចាស់អើយ ទូលបង្គំចង់ជួប ព្រះអង្គ ដែលជាព្រះនៃសេចក្ដីស្រឡាញ់ ព្រះនៃការអត់ឱនទោស ជាព្រះអង្គសង្គ្រោះ នៃការផ្លាស់ប្ដូរជីវិត នៅក្នុងទំព័រនៃព្រះបន្ទូលទ្រង់ជាខ្លាំង"


119

មែនហើយ សម្លាញ់ទាំងឡាយអើយ ព្រះគម្ពីរមិនមែន គ្រាន់តែជាសៀវភៅ ប៉ុណ្ណោះទេ តែគឺជាអ្នកនិពន្ធ នៃសៀវភៅ នោះដែលបានបង្កើតការ សំខាន់អស្ចារ្យ នោះ

នៅពេលដែលយើងក្រឡេកមើលទៅ អ្នកនិពន្ធនោះ សេចក្ដីជំនឿរបស់យើងនឹង ហោះឡើង។

ដើម្បីស្គាល់ទ្រង់គឺស្រឡាញ់ និងទុកចិត្ត លើទ្រង់។

# ៦.តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?



1

តើព្រះនៃសេចក្តីស្រឡាញ់ បណ្តោយឱ្យការយ៉ាងនោះកើតឡើងដូចម្តេចបាន?


2

ក្លារ៉ាស៊ីន ឌើរសាន់ គឺជាស្រីបំរើម្នាក់ នៅរដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ ហើយនាងក្លារ៉ាស៊ីន ជានារីដ៏សុភាព និងមានមនសិការជាទី បំផុត។

ថ្ងៃមួយ បន្ទាប់ពីបានធ្វើការឱ្យចៅ ហ្វាយដដែលមួយអស់រយៈពេល១៥ឆ្នាំមក នាងក៏បានបាត់ខ្លួនទៅ។

ចៅហ្វាយរបស់នាងមិនបានដឹងថានាង បាត់ទៅទីណាឡើយ។

នាងហាក់ដូចជាបានបាត់សូន្យឈឹងទៅ តែម្តង។

ក្រោយមកបន្ទាប់ពីបានស្វែងរកអស់ ពេលជាច្រើនថ្ងៃ នាយកដ្ឋានសង្គមកិច្ច ប្រចាំទីក្រុងក៏បានរកនាងឃើញ ដោយ ការអស្ចារ្យ។

នាងក្លារ៉ាស៊ីន បាននៅក្នុងដំណើរការ នៃការអត់អាហារសម្លាប់ខ្លួនឯង នៅលើភ្នំ មួយ ជាកន្លែងលាក់ខ្លួននៅខាងក្រៅទីក្រុង សាន់ហ្វ្រាន់ស៊ីស្កូ។

នាងបាននិយាយថា "ខ្ញុំចង់ស្លាប់ សូម ទុកឱ្យខ្ញុំនៅម្នាក់ឯងចុះ"

នៅពេលដែលអ្នកសារពត៌មាន ដែល បានរកនាងឃើញ និងធ្វើសម្ភាសន៍នាងជា គ្រាចុងក្រោយ នាងក្លារ៉ាស៊ីន បាននិយាយ ថា "មើល គ្មានអ្នកណាយកចិត្តទុកដាក់ ចំពោះខ្ញុំឡើយ។ ខ្ញុំគ្រាន់តែជាស្រីបំរើម្នាក់ ប៉ុណ្ណោះ-គឺជាស្រីម្នាក់ក្នុងចំណោមស្រីរាប់ ពាន់នាក់ នៅក្នុងសង្គមដែលធ្វើការងារ យ៉ាងថោកទាបប៉ុណ្ណោះ។ ជីវិតខ្ញុំគ្មានតម្លៃអ្វី ឡើយ។ ខ្ញុំគ្មានបងប្អូនជិតស្និទ្ធ គ្មានគ្រួ សារ គ្មានមិត្តភ័ក្តិ។ ខ្ញុំឯកកោជាខ្លាំង ទើបខ្ញុំ ចង់ស្លាប់។

គ្មានអ្នកណាម្នាក់ដែលខ្ញុំគិតថា ជិតដិត នឹងខ្ញុំឡើយ-គ្មានអ្នកណាម្នាក់ដែលខ្ញុំអាច និយាយជាមួយបានទេ-គ្មានអ្នកណាម្នាក់ ដែលខ្ញុំអាចបើកចិត្តចំហឱ្យបានសោះឡើយ។ ដូច្នេះ សូមទុកឱ្យខ្ញុំស្លាប់ទៅ ព្រោះគ្មាន អ្នកណាគេរវល់នឹងខ្ញុំឡើយ"

៦.តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


3

"គ្មានអ្នកណាយកចិត្តទុកដាក់ គឺជាការ យំសោកយ៉ាងខ្លាំងរបស់បុរស និងស្ត្រីទាំងឡាយនៅលើពិភពលោកដ៏ឯកកោនេះ។

ថ្មីៗនេះ នៅក្នុងការស្ទង់មតិមួយ ទាក់ ទងនឹងព្រះ មនុស្សត្រូវបានគេសួរថា "ប្រសិនបើអាចសួរសំនួរមួយទៅកាន់ព្រះ តើ អ្នកនឹងសួរសំនួរអ្វី?

ចុះអ្នកវិញ? ប្រសិន បើអ្នកអាចសួរ ព្រះនូវសំនួរមួយ តើអ្នកនឹងសួរនូវសំនួរ អ្វីដែរ?

នេះគឺជាសំនួរដែលមនុស្សរាប់លាន នាក់នឹងសួរៈ

"ព្រះអង្គ តើព្រះអង្គយកព្រះទ័យទុក ដាក់នឹងទូលបង្គំមែនឬទេ? ប្រសិនបើទ្រង់ ល្អ ហើយយកព្រះទ័យទុកដាក់នឹងទូលបង្គំ ចុះតើហេតុអ្វីបានជាព្រះអង្គឱ្យទូលបង្គំមាន ការឈឺចាប់ និងសេចក្តីស្លាប់នៅលើពិភព លោកនេះ?"

"តើហេតុអ្វីបានជាមានការឈឺចាប់ និង ទុក្ខព្រួយច្រើនម្ល៉េះ?

"តើហេតុអ្វីបានជាមានអំណត់ ទឹកជំ នន់ គ្រោះធម្មជាតិ និងសង្គ្រាមយ៉ាង ដូច្នេះ?"


4

យើងក្រឡេកមើលជុំវិញយើង ហើយ យើងបានដឹងថា មានកម្លាំងអាក្រក់មួយនៅលើពិភពលោកយើងនេះ។

នៅគ្រប់ទីកន្លែងមានសោកនាដកម្មយ៉ាង អាក្រក់អាក្រីបានកើតឡើងរៀងរាល់ថ្ងៃ។



5

(វីដេអូ ១៥វិនាទី) តើអ្នកណាជាអ្នកទទួល ខុសត្រូវចំពោះសោកនាដកម្ម ទុក្ខព្រួយ និងការឈឺចាប់នៅលើពិភពលោកនេះ?

មានមនុស្សជាច្រើននាក់បានបន្ទោសព្រះ ចំពោះការពិបាកវេទនា ដែលគេបានជួបប្រ ទះក្នុងការរស់នៅរបស់គេ!

តើអ្នកធ្លាប់បានឮគេ សួរសំនួរនេះ ញឹកញាប់ប៉ុនណា?

"តើហេតុអ្វីបានជាព្រះធ្វើយ៉ាងនេះដល់ ខ្ញុំ?"


6

សូមយើងក្រឡេកមើលនូវការដែលព្រះ គម្ពីរបានសំដែងអំពីសមរភូមិដ៏ធំ ដែលកំ ពុងតែបន្តដំណើររវាងអំណាចនៃអំពើល្អ និងអំពើអាក្រក់។

អ្នកអាចសួរថា "ប្រសិនបើព្រះមិនបាន នាំមកនូវបញ្ហា និងទុក្ខព្រួយទាំងឡាយមកកាន់ផែនដីនេះទេ ចុះតើអ្នកណាទៅ ដែល ជាអ្នកទទួលខុសត្រូវចំពោះសោកនាដកម្មដែលយើងឃើញរៀងរាល់ថ្ងៃនេះ?"


7

ព្រះគម្ពីរបានចង្អុលទៅលើភាគីមាន ទោស!

ព្រះយេស៊ូវបានមានព្រះបន្ទូលប្រាប់អំពី រឿងមួយស្តីពីកសិករម្នាក់ ដែលបានព្រោះពូជល្អនៅក្នុងស្រែរបស់ខ្លួន ប៉ុន្តែនៅពេល ដែលគ្រាប់ពូជនោះបានដុះឡើង

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


8

មានរុក្ខជាតិមិនល្អនៅក្នុងស្រែដែរ។


9

(ព្រះគម្ពីរ ម៉ាថាយ ១៣:២៧)

"ពួកបាវរបស់ថៅកែនោះ គេមកជំរាប ថា លោកម្ចាស់ តើលោកមិនបានព្រោះ ពូជល្អនៅស្រែរបស់លោកទេឬអី?


10

ដូច្នេះ តើស្រងែនេះកើតពីណាមក"

ពួកគេចង់ដឹងថា តើស្រងែមកពីណា?


11

(ព្រះគម្ពីរ ៣រូប ម៉ាថាយ ១៣:៣៧_៣៩)

"ទ្រង់មានបន្ទូលឆ្លើយថា អ្នកដែល ព្រោះពូជល្អ គឺជាកូនមនុស្ស


12

ចំណែកស្រែនោះ គឺជាតួលោកីយ៍ ឯពូជ ល្អ គឺអស់ទាំងមនុស្សរបស់នគរស្ថានសួគ៌ ចំណែកឯស្រងែ គឺជាអស់ទាំងមនុស្សរបស់ អាកំណាចវិញ"


13

ខ្មាំងសត្រូវដែលលបព្រោះស្រងែនោះ គឺជាអារក្ស"

ម៉ាថាយ ១៣:៣៧_៣៩


14

លោកអ្នកឃើញទេ នៅពេលដែលព្រះ ខំប្រឹងប្រែងសាបព្រោះសេចក្ដីស្រឡាញ់ សេចក្ដីសប្បុរសដល់មនុស្សគ្រប់គ្នា ក៏មាន អំណាចមួយទៀត មកធ្វើការនៅលើពិភព លោកនេះ ដោយនាំមកនូវគ្រោះមហន្តរាយ សោកនាដកម្ម សេចក្ដីស្លាប់ និងជម្ងឺដំកាត់ មកដល់ជីវិតនៃកូនរបស់ព្រះដែរ។

៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


15

សៀវភៅចុងក្រោយនៃព្រះគម្ពីរ-វិវរណៈ ប្រាប់យើងអំពីការចាប់ផ្តើមនៃហេតុនោះ ដើម្បីឱ្យយើងមានការពិតច្បាស់លាស់អំពីការ ដែលបានកើតមានឡើងនៅស្ថានសួគ៌ ដែលបានបណ្តាលឱ្យមានបញ្ហាជាច្រើន
យ៉ាងនេះនៅលើពិភពផែនដីនេះ។

យើងនឹងរកឃើញនូវប្រភពដើមនៃការ អាក្រក់។ វានឹងធ្វើឱ្យអ្នកភ្ញាក់ផ្អើល ប៉ុន្តែ មានសង្គ្រាមម្តងនៅលើស្ថានសួគ៌!


16

(ព្រះគម្ពីរ ៤រូប វិវរណៈ:១២:៧-៩)
"នោះមានចម្បាំងនៅលើមេឃ គឺមីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគនិងទេវតា វាក៏ច្បាំងនឹងលោកដែរ


17

តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែង ណាឱ្យវានៅលើមេឃទៀតផង


18

នោះនាគធំត្រូវបោះទម្លាក់ទៅ គឺជាពស់ ពីបុរាណដែលឈ្មោះហៅថា អារក្ស ហើយ សាតាំងផង ដែលបាននាំលោកីយ៍ ទាំងមូលឱ្យវង្វេងចេញ


19

វាត្រូវបានទម្លាក់ទៅផែនដីវិញ ព្រមទាំង ពួកទេវតារបស់វាផង"
វិវរណៈ ១២:៧-៩។


20

ឥឡូវនេះ សូមពិនិត្យមើលអំពីការដែល
ព្រះគម្ពីរ បានបង្ហាញអំពីនាគ ឬអារក្ស នោះ
វិវរណៈ ១២:៣,៤:


21

(ព្រះគម្ពីរ ២រូប វិវរណៈ ១២:៣,៤)
"ឃើញមានទីសំគាល់មួយទៀតនៅលើ មេឃ គឺនាគដ៏ធំមានសម្បុរក្រហម ដែល មានក្បាល៧ និងស្នែង១០

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


22

នៅលើក្បាលវា មានមកុដ៧


23

កន្ទុយវាក៏ទាញផ្កាយនៅលើមេឃ១ភាគ ក្នុង៣ គ្រវាត់ចោលទៅផែនដី..."


24

ជាការជាក់ស្តែង ១ភាគ៣នៃទេវតានៅ ស្ថានសួគ៌ បានតាមការបោកបញ្ឆោតរបស់ទេវតានេះនៅក្នុង ការបះបោរប្រឆាំងនឹង ព្រះ។

ប៉ុន្តែ ចូរយើងស្វែងយល់ថែមទៀតអំពី ទេវតា ដែលបានធ្លាក់ចុះឈ្មោះលុយស៊ី ហ្វ៊ែរនេះ។

នៅក្នុងសញ្ញាចាស់ វាត្រូវបានគេហៅ ថា ជាស្តេចនៃទីក្រុងទីរ៉ុស ហើយបាននិយាយអំពីវាយ៉ាងដូច្នេះ:


25

(ព្រះគម្ពីរ ៤រូប អេសេគាល ២៨:១២-១៤)

"ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល ដូច្នេះ ឯងជាអ្នកបំពេញខ្នាតដ៏មានប្រាជ្ញា ពោរពេញ ហើយលំអគ្រប់លក្ខណ៍"

អេសេគាល ២៨:១២


26

ពីដើមឯងបាននៅក្នុងច្បារអេដែន ជា សួនរបស់ព្រះ ឯងបានប្រដាប់កាយដោយត្បូងដ៏មានតម្លៃគ្រប់មុខ

អេសេគាល ២៨:១៣


27

ឯងជាចេរូប៊ីនដែលបានចាក់ប្រេងតាំង ឡើង ជាអ្នកគ្របបាំង...ឯងបាននៅលើភ្នំ បរិសុទ្ធរបស់ព្រះ


28

ឯងក៏បានដើរទៅមកនៅកណ្តាលថ្មភ្លឺចាំង" អេសេគាល ២៨:១៤

៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


29

លុយស៊ីហ្វ៊ែរជាទេវតាល្អ ដែលព្រះបាន បង្កើតវាមកយ៉ាងល្អ នូវគ្រប់ទាំងផ្លូវរបស់ វាទាំងអស់។ វាជាទេវតា ដែលបានឈរនៅបន្ទាប់ពី ព្រះ ជាចេរូប៊ីនដែលគ្របបាំង។


30

លុយស៊ីហ្វ៊ែរមានតួនាទីយ៉ាងខ្ពង់ខ្ពស់នៅឯ ស្ថានសួគ៌។

នៅសងខាងនៃកន្លែងមេត្តាករុណា ឬ បល្ល័ង្ករបស់ព្រះ មានទេវតាពីរអង្គ មួយ នៅខាងស្តាំ មួយនៅខាងឆ្វេង។ មួយអង្គ នៃទេវតាទាំងពីរអង្គនេះគឺលុយស៊ីហ្វ៊ែរ។


31

វាមិនសប្បាយចិត្តនឹងនៅបន្ទាប់ពីព្រះទេ។

វាចង់ក្លាយជាព្រះ!

មានរឿងខ្លះបានកើតឡើងដល់លុយ ស៊ីហ្វ៊ែរ និងដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធ របស់វាជាមួយនឹងព្រះ ព្រះបានមានព្រះ បន្ទូលទៅកាន់លុយស៊ីហ្វ៊ែរថា


32

(ព្រះគម្ពីរ អេសេគាល ២៨:១៥)

"ចាប់តាំងពីឯងបានកើតមក នោះឯង បានគ្រប់លក្ខណ៍ក្នុងគ្រប់ទាំងផ្លូវរបស់ឯង ដរាបដល់វេលាដែលឃើញមានសេចក្តីទុច្ចរិត នៅក្នុងឯង"

អេសេគាល ២៨:១៥


33

(ព្រះគម្ពីរ អេសេគាល ២៨:១៧)

"ចិត្តឯងបានសប្បាយឡើងដោយព្រោះសេចក្តីលំអរបស់ឯង ឯងបានបង្ខូចប្រាជ្ញាឯង ដោយពន្លឺរស្មីរបស់ឯង

អេសេគាល ២៨:១៧


34

ទេវតាល្អ និងខ្ពង់ខ្ពស់នេះមានគំនិត អាត្មានិយម វាចង់បានសិរីល្អ និងតំណែង ដែលគួរឱ្យគោរព និងវន្ទនារបស់ព្រះមកលើ វាតែឯង។

វាជាអ្នកស្រេកឃ្លានអំណាច វាគ្មាន កោតញញើត នឹងជណ្តើមពីអ្នកដែលបាន បង្កើតវា នូវភាពជាអ្នកគ្រប់គ្រង នៅលើ លោកសន្និវាសនេះទេ! សូមស្តាប់ដោយ ប្រុងប្រយ័ត្ន:


35

(ព្រះគម្ពីរ ៣រូប អេសាយ ១៤:១២-១៤)

"ឱតារាប្រចាំថ្ងៃ ជាផ្កាយព្រឹកអើយ ន៎ ឯងបានធ្លាក់ចុះពីលើមេឃហើយ ឯងបាន ផ្តេកអស់ទាំងនគរឱ្យរាប ឯងបានត្រូវកាប់ រំលំដល់ដី ហ្ន៎

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?



36

ឯងបានគិតក្នុងចិត្តថា អញនឹងឡើងទៅ ស្ថានសួគ៌ អញនឹងដំកើងបល្ល័ង្កអញឱ្យខ្ពស់ជាងផ្កាយរបស់ព្រះ



37

ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ”
អេសាយ ១៤:១២-១៤


38

ដោយសារពាក្យច្រឡោងខាមដែលចេញ ពីបបូរមាត់របស់លុយស៊ីហ្វ័រទាំងនេះ ធ្វើឱ្យសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះ និងការចុះ សម្រុងគ្នានៅស្ថានសួគ៌ បានបែកខ្ញែកទៅជាភាពអាត្មានិយមរាប់លានចំណែក។


39

មិនយូរប៉ុន្មានពេលដែលលុយស៊ីហ្វ័រ
ចាប់ផ្តើមប្រកាសអំពីវិញ្ញាណនៃការមិនពេញចិត្តគ្នាទៅក្នុងចំណោមពួកទេវតាទាំងឡាយ។ វាបានធ្វើឱ្យអន្តរាយដល់សេចក្តីស្រឡាញ់ និងសេចក្តីយុត្តិធម៌របស់ព្រះ យ៉ាងយឺត១ និងពិតប្រាកដ។


40

ដូចជាផ្លែឈើរលួយនៅក្នុងប្រអប់មួយ ការបះបោររបស់វាបានរាលដាល ដល់ទេវតាទាំងឡាយនៅស្ថានសួគ៌។

ព្រះអាចបំបាត់លុយស៊ីហ្វ័រ និងទេវតា ដែលបានចូលរួមក្នុងបដិវត្តន៍របស់វាតែក្នុងពេលមួយរំពេចប៉ុណ្ណោះ ប៉ុន្តែបើទ្រង់ធ្វើ ដូច្នោះ នោះអ្នកដែលទ្រង់បានបង្កើតទាំងអស់នឹងបំរើទ្រង់ដោយភ័យខ្លាច។


41

ចូរយើងឧបមាថា ព្រះបានដកយកចេញ នូវសេរីភាពនៃការសំរេចចិត្តរបស់យើង ហើយធ្វើអោយយើងទាំងអស់ គ្នាទៅជា មនុស្សយន្តវិញ។

(យោងតាមអ្នកស្តាប់) តើបងប្អូនប៉ុន្មាន នាក់ដែលមានកូន? គឺតិចតួចណាស់ដែល មានកូន។

តើលោកអ្នកចង់បានកូនជាមនុស្សយន្ត ឬទេ?

តើអ្នកចង់បានកូនដែលអ្នកដាក់កម្មវិធី ដើម្បីឱ្យស្តាប់បង្គាប់នូវគ្រប់អ្វី១ទាំងអស់ដែលអ្នកបាននិយាយនោះឬយ៉ាងណា?

កូនរបស់អ្នកនឹងក្រោកឡើងពីព្រលឹម ហើយនិយាយថា “បាទ(ចាស) ម៉ាក់ ខ្ញុំនឹងញ៉ាំ បាយរបស់ខ្ញុំ” “បាទប៉ា ខ្ញុំនឹងសំអាតផ្ទះ” អ្នកមាន មនុស្សយន្តមួយ-ជាមនុស្សយន្តដែលធ្វើពី ដែកដ៏សោះកក្រោះ។

អ្នកមិនមានកូនទៀតឡើយ តើអ្នកចង់ បានកូនរបៀបនេះឬទេ? ពិតប្រាកដជាមិន ចង់ឡើយ ហើយព្រះក៏ដូច្នោះដែរ។

៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?



42

ព្រះគឺជាព្រះនៃសេចក្តីស្រឡាញ់។ ទ្រង់ អាចមានព្រះទ័យរីករាយ ក្នុងទំនាក់ទំនងនៃសេចក្តីស្រឡាញ់ ជាមួយនឹងរបស់ដែល ទ្រង់បានបង្កើត កាលណាពួកគេថ្វាយ បង្គំទ្រង់ ព្រោះគេស្រឡាញ់និងទុកចិត្តទ្រង់ ប៉ុណ្ណោះ។



43

សាតាំងបានផ្លាស់ប្រែច្បាប់របស់ព្រះ និងសេចក្តីយុត្តិធម៌របស់ព្រះ ប៉ុន្តែព្រះមិនបានដាក់ច្បាប់ទាំងនេះមកជាធរមាន ដើម្បី បង្ហាញថា អ្នកណាជាចៅហ្វាយនោះទេ! ទ្រង់បានធ្វើច្បាប់ទាំងនេះឡើងដើម្បីការពារ អ្នកដែលទ្រង់បានបង្កើត ដើម្បីបញ្ជាក់ពីសេចក្តីសុខនិងសេចក្តីសប្បាយរីករាយរបស់ ពួកគេតែប៉ុណ្ណោះ។




44

ព្រះបញ្ញត្តិរបស់ទ្រង់ដូចជាភ្លើងស្តុប និងសញ្ញាកំណត់ល្បឿន ដែលទាំងអស់នេះបានរៀបចំឡើងដើម្បីសុវត្ថិភាព និងភាព ល្អប្រសើររបស់យើងដូច្នោះដែរ។

ប៉ុន្តែទេវតាដែលបានផ្តល់កិត្តិយសឱ្យ ច្រើនជាងគេនោះបានគិតថា គេអាចគ្រប់គ្រងលោកសន្និវាសនេះ បានល្អជាងព្រះ ដែលជាអ្នកបង្កើតគេ!



45

សាតាំង "សត្រូវរបស់ព្រះ" បាន បង្កើតអារក្សដោយខ្លួនវា




46

(វីដេអូ ១០វិនាទី) ព្រះប្រទានឱ្យមនុស្ស គ្រប់គ្នានូវអំណាចនៃការសំរេចចិត្ត និង ស្តាប់បង្គាប់ ឬមិនស្តាប់បង្គាប់។

ចេញពីការគោរពខ្លាច និងសេចក្តីស្រ ឡាញ់របស់ព្រះ បានអនុញ្ញាតឱ្យសាតាំងបង្ហាញទៅកាន់លោកីយ៍ នូវរបៀបដែលវា នឹងគ្រប់គ្រងពិភពលោកនេះ។

យើងមិនយល់ថា ការទាំងនេះបានកើត ឡើងយ៉ាងណាទេ នៅពេលដែលព្រះស្រ ឡាញ់ និងល្អយ៉ាងខ្លាំងដល់មនុស្សនេះ។



47

សមរភូមិបានចាប់ផ្តើមនៅស្ថានសួគ៌ មិនទាន់ចប់ទេ វាគ្រាន់តែជាការផ្លាស់ប្តូរទី កន្លែងតែប៉ុណ្ណោះ ផែនដីជាកន្លែងដែល មានមហាវិវាទ រវាងការល្អ និងអាក្រក់ កំ ពុងតែប្រយុទ្ធគ្នានៅទីនេះ។

ជាកន្លែងដែលសាតាំងនឹងបង្ហាញការគ្រប់គ្រងរបស់វា នូវរបៀបដែលវាកាន់កាប់ពិ ភពលោកនេះ



48

ប៉ុន្តែតើហេតុអ្វីបានជាការនេះកើតឡើង នៅផែនដីនេះ? តើហេតុអ្វីបានជាពិភពរបស់យើងបានក្លាយជាសមរភូមិយ៉ាងដូច្នេះ?

# ៦.តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្លេះ?


49

(ព្រះគម្ពីរ កូរិនថូសទី១ ៤:៩)
"...ពីព្រោះយើងខ្ញុំបានត្រឡប់ជាទី ដែលសម្រាប់ឱ្យលោកីយ៍បានមើលលេង គឺដល់ទាំងពួកទេវតា និងពួកមនុស្សផង"
កូរិនថូសទី១ ៤:៩


50

ផែនដីទើបនឹងបានចេញពីព្រះហស្ត របស់ព្រះអាទិករ ក្នុងភាពដ៏រុងរឿង និង ល្អឥតខ្ចោះ ដែលទ្រង់បានតាក់តែងឡើង យ៉ាងល្អស្រស់មិនអាចពណ៌នាបាន។

តាមពិតសាតាំងក៏បានគិតយ៉ាងដូច្នោះ ដែរ ព្រោះវាបានឃើញពិភពលោកនេះថា ជារង្វាន់ដ៏មានតម្លៃដែលគួរឱ្យចង់បាន វា បានប៉ុនប៉ងចាប់យកភពដ៏ស្រស់ត្រកាលនេះ ជាពិភពលោកថ្មី ដែលទើបនឹងបង្កើតឡើង។


51

ទោះបីជាអ័ដាម និងអេវ៉ា ជាឪពុក ម្តាយរបស់មនុស្សលោក ត្រូវបានបង្កើតមក ល្អឥតខ្ចោះក៏ដោយ ក៏ពួកគេមិនត្រូវបាន ដាក់ឱ្យផុតពីលទ្ធភាពនៃការប្រព្រឹត្តិខុស ឡើយ។

ពួកគេមានសេរីភាពដើម្បីនឹងស្រឡាញ់ និងដើរតាមព្រះ ឬមិនទទួលការណែនាំ របស់ទ្រង់។

ប៉ុន្តែភាពស្មោះត្រង់របស់ពួកគេនឹងត្រូវ បានសាកល្បងលមើល ហើយការសាក ល្បងនោះ នឹងផ្តោតទៅលើដើមឈើមួយ ដើម។ ព្រះបានហាមថា


52

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៦,១៧) "ឯងនឹងស៊ីផ្លែឈើទាំងអស់នៅក្នុងសួនច្បារ នេះបានតាមចិត្ត


53

តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឱ្យ ឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯង ស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន"
លោកុប្បត្តិ ២:១៦,១៧

ការនេះវាហាក់ដូចជាសំណូមពរមួយដ៏ សមហេតុផល ពួកគេត្រូវតែដឹងថា គេ គ្មានគ្រោះថ្នាក់ឡើយ គឺរួចពីគ្រោះថ្នាក់។

ប៉ុន្តែមនុស្សកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ជាទីបំផុត នៅពេលដែលគេគ្មានការប្រុងប្រយ័ត្ន ទាល់តែសោះ ព្រោះគេគិតថា គេមាន សេចក្តីសុខសាន្តហើយ


54

នេះគឺរឿងរ៉ាវដែលបានកើតឡើងដល់ នាងអេវ៉ា។

សាតាំងបានប្រើអំណាចហួសនិស្ស័យ របស់វាដើម្បីបញ្ឆោតនាង។

សាតាំងពិតជាមិនបានធ្វើការនេះដោយ បើកចំហទេ។

វាពោរពេញទៅដោយការបោកបញ្ឆោត វាប្រើអង្គការផ្សេងៗ មនុស្ស ថែមទាំង ពស់ផង!

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


55

ការនោះហើយ ដែលលោកប៉ុលបាន និយាយថា:


56

(ព្រះគម្ពីរ ៣រូប អេភេសូរ ៦:១១-១២)

"ចូរពាក់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាច នឹងឈរមាំមួនទាស់នឹងឧបាយកលទាំងប៉ុន្មាន របស់អារក្ស


57

ដ្បិតយើងរាល់គ្នាមិនតយុទ្ធនឹងសាច់ ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមាន អំណាច


58

និងពួកងងឹតនៅលោកីយ៍នេះវិញ ហើយ ទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅផែនដីដែរ"

អេភេសូរ ៦:១១-១២


59

នាងអេវ៉ា ត្រូវបានល្បួង

នាងមិនបានសង្ស័យថា ពាក្យពេចន៍ ដែលចេញពីមាត់របស់សត្វពស់នោះមក ពី សាតាំងនោះឡើយ។

អារក្សបាននិយាយតាមរយៈសត្វពស់ ដោយសួរនាងថា


60

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១)

"...តើព្រះមានបន្ទូលហាមមិនឲ្យអ្នក បរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?"

លោកុប្បត្តិ ៣:១


61

(ព្រះគម្ពីរ ៤រូប លោកុប្បត្តិ ៣:២-៤)

អេវ៉ាឆ្លើយថា "យើងអាចបរិភោគអស់ ទាំងផ្លែឈើនៅក្នុងសួនច្បារបាន


62

តែត្រង់ដើមឈើមួយដែលនៅកណ្តាលសួន ច្បារនោះ

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


63

ព្រះទ្រង់មានបន្ទូលថា កុំឱ្យបរិភោគផ្លែ នោះឡើយ ព្រមទាំងកុំឱ្យពាល់ប៉ះផង ក្រែងលោស្លាប់


64

រួចពស់ក៏និយាយទៅស្ត្រីថា អ្នកមិន ស្លាប់ជាពិតប្រាកដមែន"

លោកុប្បត្តិ ៣:២-៤


65

នៅពេលដែលនាងអេវ៉ាបានស្តាប់សត្វ ពស់ នាងប្រាកដជាបានគិតថា វាបាន និយាយខុសគ្នាស្រឡះ អំពីអ្វីដែលព្រះបាន ប្រាប់ដល់ពួកគេនោះ។

ប្រហែលជាវិញ្ញាណនាងមានការភាន់ ច្រឡំហើយ ពស់បានបន្ថែមយ៉ាងប្រញាប់ថា


66

(ព្រះគម្ពីរ លោកុប្បត្តិ ៣:៥) "ដ្បិតព្រះ ទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹង បានដូចជាព្រះដែរ ព្រមទាំងដឹងការខុស ត្រូវផង"

លោកុប្បត្តិ ៣:៥


67

អារក្សបានឱ្យយោបល់ថា ព្រះមិនត្រឹម ត្រូវទេ ដែលទ្រង់បានលាក់អ្វីមួយដ៏ល្អ ដូច្នេះនោះ។

ភាពដូចជាព្រះ គឺជាការប៉ងប្រាថ្នា និងជាការដែលធ្វើឱ្យវាត្រូវបានធ្លាក់ចុះមក ក្រោម។ ឥឡូវរឿងនោះវាក៏ជាការល្អដល់ អេវ៉ាដែរ ហើយនៅក្នុងឱកាសដែលមិនបាន ពិចារណាមួយភ្លែតនោះ នាងបានលះ ចោលនូវការស្តាប់បង្គាប់ព្រះ


68

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ៣:៦)

"កាលស្ត្រីបានឃើញថា ផ្លែឈើនោះ បរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក


69

ហើយជាដើមឈើដែលល្មមគួរនឹងចង់បាន ដើម្បីឱ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមក បរិភោគ..."

លោកុប្បត្តិ ៣:៦


70

ហើយនាងអេវ៉ាបានឱ្យផ្លែឈើនោះទៅ អ័រដាម ហើយគាត់ក៏បានបរិភោគទៅ។

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


71

អ័ដាម និងនាងអេវ៉ាបានធ្លាក់ពីការ សាកល្បងនៃសេចក្តីស្រឡាញ់ និងស្មោះ ត្រង់របស់ព្រះ ហើយមិនយូរប៉ុន្មាន ពួកគេ ក៏បានដឹងថា មានរឿងរ៉ាវខុសឆ្គង។


72

សាតាំងបានប្លន់យកផែនដីដ៏ថ្មី! ចាប់ពី ពេលនោះមក វាបានប្រកាសអះអាងថា "វាជាព្រះអម្ចាស់នៃពិភពលោក" ជាថៅ ហ្វាយលើពិភពនៃការប្រឆាំងបះបោរនេះ លោកអ័រដាមនិងនាងអេវ៉ាបានស្តាប់តាម សំឡេងរបស់អារក្ស។


73

កាលថ្ងៃដ៏គួរឱ្យខ្លាចផ្សាបំផុតនោះបាន ខិតជិតដល់ទីបញ្ចប់ហើយ ព្រះបានយាង មកនៅពេលរសៀលដ៏ត្រជាក់មួយដូចធម្មតា ដោយមានបន្ទូលរកអ័ដាមនិងនាងអេវ៉ា។ តាំងពីដើមរហូតមកទល់នឹងពេលនេះ ពេលថ្ងៃរនេះ គឺជាពេលមួយដ៏ល្អបំផុតសំ រាប់ពួកគេ-ជាឱកាសដែលគេបានដើរជា មួយនឹងព្រះ និងនិយាយដោយផ្ទាល់ទៅ កាន់ព្រះដែលបានបង្កើតគេមក។

ប៉ុន្តែថ្ងៃនេះ ពួកគេបានរត់ពួននៅក្នុងព្រៃ!


74

ទីបំផុត អ័ដាមបានចេញសន្សឹមៗ ពីក្រោយព្រៃគុម្ពោត នៅក្នុងសួនច្បារ និងបានសារភាព


75

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១០)

"...ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួន ច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច ពី ព្រោះនៅខ្លួនទទេ"

លោកុប្បត្តិ ៣:១០


76

ពីមុនមក អ័ដាមមិនធ្លាប់មានការភ័យ ខ្លាចសោះឡើយ

ប៉ុន្តែនេះគឺជាការដែលបាបបានធ្វើ។

វាធ្វើឱ្យមនុស្សខ្លាចតាំងពីព្រះឡើងទៅ។


77

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១១)

ព្រះទ្រង់មានបន្ទូលសួរថា "...តើឯង បានស៊ីផ្លែឈើដែលអញបានហាមមិនឱ្យ ស៊ីឬអី?" ខ ១១ អ័ដាមឆ្លើយថា

# ៦.តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


78

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១២)

"...ស្ត្រីដែលទ្រង់បានប្រទានឱ្យនៅ ជាមួយនឹងទូលបង្គំ វាឱ្យផ្លែឈើនេះមក ទូលបង្គំ ទូលបង្គំក៏ទទួលទានទៅ"

លោកុប្បត្តិ ៣:១២

ពីរបីម៉ោងមុននេះ អ័ដាមសុខចិត្តស្លាប់ជា មួយនឹងអេវ៉ា ឥឡូវនេះគេបានបន្ទោសនាង និងបន្ទោសដល់ព្រះដែលទ្រង់បានបង្កើតនាងមក ។ ឱ អំពើបាបបានបំផ្លាញសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍មែន!


79

ប៉ុន្តែនាងអេវ៉ាក៏មានការចោទប្រកាន់ទៅ លើគេមិនអន់ដែរ។ នៅពេលដែលព្រះ បានសួរនាងថា នាងបានធ្វើអ្វី នាងបាន ឆ្លើយថា


80

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១៣)

"...ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទាន"

លោកុប្បត្តិ ៣:១៣

អេវ៉ាក៏បានដាក់ការបន្ទោសទៅព្រះដែរ! នៅក្នុងពាក្យម្យ៉ាងទៀតនាងបាននិយាយថា "គឺជាពស់ដែលទ្រង់បានបង្កើត ដែលធ្វើឱ្យ ខ្ញុំម្ចាស់មានបញ្ហា"


81

នៅថ្ងៃនេះឯងដែលអ័ដាមនិងអេវ៉ាត្រូវ បានទទួលវាសនាអាក្រក់ដល់ស្លាប់!

ដើម្បីរក្សាអ័ដាមនិងអេវ៉ា ពីការស៊ីផ្លែ នៃដើមជីវិតនេះ ព្រះបានបណ្តេញគេចេញ ពីសួនច្បារដែលជាផ្ទះរបស់ពួកគេ។

អារក្សបាននិយាយថា ពួកគេនឹងមិន ស្លាប់ទេ ប៉ុន្តែព្រះគម្ពីរនិយាយថា


82

(ព្រះគម្ពីរ លោកុប្បត្តិ ៥:៥)

"អាយុអ័ដាមទាំងអស់បាន៩៣០ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ" លោកុប្បត្តិ ៥:៥

យឺតពេលទៅហើយនៅពេលដែលគេដឹងថាអារក្ស


83

(ព្រះគម្ពីរ យ៉ូហាន ៨:៤៤)

"...ដ្បិតវាជាអ្នកកំភូត ហើយជាឪពុក

នៃសេចក្តីនោះឯង"

យ៉ូហាន ៨:៤៤

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្លេះ?


84

វាជាការងាយនឹងបន្ទោសព្រះ ចំពោះ ការខូចចិត្ត និងការហិនហោចខ្ទេចខ្ទី ផ្សេងៗនៅលើលោកនេះ ប៉ុន្តែសាតាំងទេ ដែលជាអ្នកទទួលខុសត្រូវចំពោះការបំផ្លិចបំផ្លាញដ៏ខ្ទេចខ្ទីទាំងនេះ។



85

(វីដេអូ ១០វិនាទី) វាគឺជាអ្នកដែលនាំនូវ ការពិបាកទាំងឡាយមកកាន់ពិភពលោកនេះ ហើយវាគឺជាអ្នកដែលបណ្តាលឱ្យមានអំពើ បាប និងការឈឺចាប់តាំងពីពេលនោះមក។ ព្រះយេស៊ូវមិនបានបិទបាំងមុខអារក្ស និង របៀបដែលវាធ្វើឱ្យមនុស្សមានទុក្ខវេទនានោះឡើយ។


86

នៅពេលដែលទ្រង់កំពុងតែបង្រៀននៅ ក្នុងព្រះវិហារ នាថ្ងៃបរិសុទ្ធមួយ ទ្រង់បានទតឃើញស្ត្រីម្នាក់ដែលមានខ្នងកោង ដែលមានរូបរាងពិការ។

ទ្រង់មានព្រះទ័យរំជួលដោយស្ថានភាព ដ៏គួរឱ្យអាណិតអាសូររបស់នាង ព្រះអង្គក៏បានព្យាបាលនាង។


87

ពួកមេដឹកនាំបានរិះគន់ទ្រង់ភ្លាមៗ ពី ព្រោះការព្យាបាលរបស់ទ្រង់បានធ្វើឡើងនៅ ថ្ងៃបរិសុទ្ធ-ជាថ្ងៃបរិសុទ្ធរបស់ព្រះសំរាប់ ថ្វាយបង្គំ

ប៉ុន្តែសូមយើងពិនិត្យមើលថា តើទ្រង់ បានការពារសកម្មភាពរបស់ទ្រង់នេះយ៉ាង ណា:



88

(ព្រះគម្ពីរ ២រូប លូកា ១៣:១៦)

"ឯស្ត្រីនោះជាពូជលោកអ័ប្រាហាំ ដែលអារក្សសាតាំងបានចងគាត់១៨ឆ្នាំមក ហើយ ដូច្នេះតើមិនគួរនឹងស្រាយឱ្យរួចពី ចំណងនេះ



89

នៅថ្ងៃឈប់សម្រាកទេឬអី?"

លូកា ១៣:១៦


90

ព្រះយេស៊ូវបានមានព្រះបន្ទូលថា សា តាំងបានចងនាងអស់១៨ឆ្នាំមកហើយ។ សាតាំង គឺជាអ្នកដែលមានកំហុស! តាម ពិតសាតាំងគឺជាកំឡាំងដែលគួរឱ្យខ្លាចនៅពី ក្រោយជម្ងឺដំកាត់ ការឈឺចាប់ ការពិបាក ចិត្ត និងសេចក្តីស្លាប់ទាំងឡាយ!

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


91

ប្រហែលជាគ្មានកន្លែងណានៅក្នុងព្រះ គម្ពីរ ដែលយើងនឹងឃើញយុទ្ធសាស្ត្ររបស់សាតាំងច្បាស់ជាង

ជំពូកទី១ នៃគម្ពីរយ៉ូប នៅក្នុងការ សន្ទនារវាងអារក្ស និងព្រះនោះទេ។


92

បន្ទាប់ពីការធ្លាក់ចុះរបស់សាតាំងមក មានពេលខ្លះ ដែលកូនព្រះបានចូលទៅគាល់នៅចំពោះព្រះភ័ក្ត្រ របស់ព្រះអម្ចាស់

សាតាំងក៏បានមកផងដែរ

សូមគិតអំពីរឿងនេះ! ការប្រជុំមួយ របស់ "កូនព្រះ" និងសាតាំង ដែលបានមកដោយគ្មានការអញ្ជើញនោះ!


93

(ព្រះគម្ពីរ ២រូប យ៉ូប ១:៧)

"នោះព្រះយេហូវ៉ា ទ្រង់មានបន្ទូលសួរ សាតាំងថា ឯងមកពីណា?"

ម្យ៉ាងទៀត តើអ្នកណាបានហៅឯង មក? តើអ្នកមានសិទ្ធិអ្វីដែលមកកាន់ទីនេះ? សាតាំងបានឆ្លើយទៅព្រះថា


94

"មកពីដើរចុះឡើងទៅមកនៅផែនដី"

យ៉ូប ១:៧

សាតាំងបានទាមទារនូវអំណាចគ្រប់គ្រង នៅលើភពផែនដី។ វាបានយកដំណែង នេះពីអ័ដាមមក!


95

អ័ដាមត្រូវបានហៅថា កូនព្រះ មើល (លូកា ៣:៣៨) ដូចជាអ្នកដទៃទៀតបានមកនៅក្នុងថ្ងៃប្រជុំជាមួយព្រះនោះដែរ។


96

តើវាអាចទៅរួចឬទេ ដែលថា ពួកគេ ជាអ្នកដឹកនាំនៃភពផ្សេងៗទៀត ដូចជា អ័ដាមជាអ្នកដឹកនាំនៃពិភពផែនដីយើង នេះដែរនោះ?

ទោះជាយ៉ាងណាក៏ដោយ ក៏ការអះអាង របស់សាតាំងថា វាជាតំណាងឱ្យផែនដីនេះ នោះមិនមានដំណើរការទៅដោយគ្មាន ការប្រកួតប្រជែងនោះឡើយ។

ព្រះមានព្រះបន្ទូលទៅកាន់សាតាំងថា:


97

(ព្រះគម្ពីរ ៤រូប យ៉ូប ១:៨,៩,១១)

"....ឯងបានសង្កេតមើលយ៉ូបជាអ្នក បំរើអញឬទេ ដ្បិតគ្មានអ្នកណាមួយនៅផែន ដីដូចគាត់ឡើយ

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


98

ជាអ្នកដែលគ្រប់លក្ខណ៍ ហើយទៀងត្រង់ ក៏កោតខ្លាចដល់ព្រះ ហើយចៀសចេញពី សេចក្ដីអាក្រក់?


99

សាតាំងទូលឆ្លើយដល់ព្រះយេហូវ៉ាថា ដែលយ៉ូបកោតខ្លាចដល់ព្រះអង្គ តើឥត
មានប្រយោជន៍ទេឬ?


100

ដូច្នេះ ចូរទ្រង់គ្រាន់តែលូកព្រះហស្ដ ទៅពាល់របស់ផងគាត់ទាំងប៉ុន្មាន នោះ
គាត់នឹងប្រមាថដល់ទ្រង់ នៅចំពោះព្រះ ភក្ត្រ!"
យ៉ូប ១:៨,៩,១០


101

ការប្រកួតប្រជែងដ៏ធំ! សាតាំងបានអះ អាងថា ហេតុផលតែមួយគត់ដែលយ៉ូប មាន
គឺការស្មោះត្រង់ចំពោះព្រះ នោះគឺ ព្រោះតែអ្វីៗដែលព្រះធ្វើទៅកាន់គាត់ មិន
មែនដោយសារគាត់ស្រឡាញ់ និងទុកចិត្ត លើទ្រង់ទេ។


102

(ព្រះគម្ពីរ ២របូ យ៉ូប ១:១២)
"ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញប្រគល់របស់ដែលគាត់មានទាំងប៉ុន្មាន
ទៅក្នុងអំណាចឯងហើយ កុំឲ្យតែដាក់ដៃ លើខ្លួនគាត់ឡើយ


103

ដូច្នេះ សាតាំងក៏ចេញពីព្រះយេហូវ៉ាទៅ"
យ៉ូប ១:១២
សាតាំងបានចាកចេញជាប្រញាប់ ដើម្បី ដាក់ដៃលើទ្រព្យសម្បត្តិរបស់យ៉ូប។


104

ការវាយសង្កត់ក៏ចាប់ផ្ដើមធ្លាក់មកភ្លាមៈ
ទីមួយៈ ពួកសេបា បានលួចគោ និង សម្លាប់អ្នកបំរើរបស់យ៉ូប


105

ទីពីរៈ រន្ទះបាញ់សម្លាប់ចៀម និងអ្នក គង្វាលចៀមរបស់គាត់

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


106

ទីបី: ពួកខាល់ដេរ បានមកនិងប្លន់ យកអូដ្ឋរបស់យ៉ូបអស់


107

ទីបួន: ជាដំណឹងដែលធ្វើឱ្យមានការ រន្ធត់ចិត្តជាទីបំផុត គឺខ្យល់កួចមួយបានបំ ផ្លាញផ្ទះកូនច្បងបង្អស់របស់យ៉ូប។ ការ ជប់លៀងមួយត្រូវបានចប់ ហើយកូនទាំងដប់នាក់របស់យ៉ូបត្រូវបានស្លាប់ទាំងអស់!


108

យ៉ូបដ៏កំសត់ គាត់បានគិតថា ព្រះបាន ដកយកទ្រព្យសម្បត្តិរបស់គាត់ចេញវិញ និងបានបណ្តាលឱ្យមានការឈឺចាប់ ទាំងអស់នេះកើតឡើង។

គាត់មិនបានយល់ថា អារក្សបានធ្វើការ ទាំងអស់នេះទេ!

ទោះបីជាមានការទុកព្រួយយ៉ាងណាក៏ ដោយ ក៏ភាពស្មោះត្រង់របស់យ៉ូបមិនបាន ផ្លាស់ប្តូរដែ។


109

(ព្រះគម្ពីរ យ៉ូប ១:២១)

ហើយគាត់និយាយថា "...ព្រះយេហូវ៉ា ទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដក យកទៅវិញ សូមឱ្យព្រះនាមព្រះយេហូវ៉ា បានព្រះពរចុះ"

ទោះបីជាគាត់មិនអាចយល់ពីសោកនាដ កម្មដែលបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងកូនរបស់គាត់ក៏ដោយ ក៏គាត់នៅតែទុកចិត្ត ចំពោះសេចក្តីល្អរបស់ព្រះដូចមុនដដែល។

ប៉ុន្តែសាតាំងមិនបានឈប់ទេ វាបាន បញ្ចេញយោបល់ប្រឆាំងជាមួយនឹងព្រះ ដោយនិយាយថា


110

(ខព្រះគម្ពីរ ៣រូប យ៉ូប ២:៤-៦)

"...មនុស្សនឹងសុខចិត្តលះបង់ ទាំងអស់ចោល ដើម្បីឱ្យបានជីវិតគង់នៅ


111

ចូរទ្រង់គ្រាន់តែលូកព្រះហស្តទៅពាល់ ដល់ឆ្អឹងនិងសាច់គាត់ចុះ នោះគាត់នឹងប្រ មាថដល់ទ្រង់នៅចំពោះព្រះភ័ក្ត្រ។


112

ព្រះយេហូវ៉ាមានបន្ទូលថា មើលអញ ប្រគល់គាត់ទៅក្នុងអំណាចឯងទៀត ចូរប្រណីដល់តែជីវិតគាត់ប៉ុណ្ណោះ"

យ៉ូប ២:៤-៦

៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


113

ការសាកល្បងបានបន្តទៅទៀត! តើ យ៉ូបនៅតែមានការស្មោះត្រង់ជាមួយនឹងព្រះ នៅពេលដែលមានការពិបាកកាន់តែខ្លាំងឡើងនោះ ឬមួយក៏គាត់បែរខ្នងដាក់ព្រះវិញ?


114

(ព្រះគម្ពីរ ២របូ យ៉ូប ២:៧)
"ដូច្នេះសាតាំងក៏ចេញពីព្រះយេហូវ៉ា


115

ទៅវាយយ៉ូបឱ្យកើតដំបៅដ៏អាក្រក់ ចាប់ តាំងពីបាទជើងរហូតដល់ក្រយៅក្បាល"
យ៉ូប ២:៧


116

តើអ្នកធ្លាប់កើតបូសឬទេ? អ្នកដឹងទេ គ្រាន់តែបូសមួយ តើវាឈឺប៉ុណ្ណាទៅហើយ សូមអ្នកសញ្ជឹងគិតមើលថា ចុះទំរាំបូស តាំងពីក្បាលដល់ចុងជើងនោះ តើវាឈឺ យ៉ាងណាទៅ!


117

ទោះបីជាសាតាំងបានដកយកទ្រព្យ សម្បត្តិ កូន និងសុខភាពរបស់យ៉ូបក៏ ដោយ ក៏គាត់នៅតែរក្សាសេចក្ដីស្មោះត្រង់ ជាមួយនឹងព្រះដដែល។ នេះគឺជាបុរសដ៏ អស្ចារ្យ! ព្រះគម្ពីរនិយាយថា


118

ក្នុងគ្រប់សេចក្ដីទាំងនោះ យ៉ូបមិនបានធ្វើ បាបឡើយ ក៏មិនបានប្រកាន់ទោសដល់ព្រះ ដែរ
យ៉ូប ១:២២


119

តើអ្នកណាធ្វើឱ្យយ៉ូបឈឺចាប់?
តើអ្នកណាបានដាក់ការវេទនាដល់យ៉ូប?
គឺសាតាំង!


120

តើអ្នកណាដែលបានលួចសត្វនិងសម្លាប់ អ្នកបំរើរបស់គាត់?
គឺ សាតាំង!

# ៦.តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្លេះ?


121

តើអ្នកណាដែលបាននាំមកនូវខ្យល់ព្យុះ ដែលបានបំផ្លាញកូនស្រីកូនប្រុសរបស់គាត់? គឺ សាតាំង!


122

ព្រះអាចបណ្ដោយឱ្យការពិបាកកើតឡើង ដើម្បីសាកល្បងរកភក្ដីភាព និងសេចក្ដីស្រឡាញ់របស់យើង។


123

ប៉ុន្តែសាតាំងគឺជាអ្នកមានទោស ដែល
មានកំហុសចំពោះហេតុការណ៍ទាំង ឡាយ នៅលើភពផែនដីនេះ!


124

លោកអ្នកនិងខ្ញុំកំពុងស្ថិតនៅកណ្ដាល ឆាកល្ខោនអាថ៌កំបាំងដ៏ធំមួយ ទំនាស់មួយ នៃអំណាច និងភាពគ្មានច្បាប់ រវាងព្រះនៃ ការបង្កបង្កើត និងសាតាំង ដែលជាអ្នក បះបោរដំបូង។

យើងមិនមែនជាអ្នកទស្សនាទេ គឺយើង ជាអ្នកចូលរួមសំដែងផ្ទាល់ ទោះបីជាយើង ចង់ឬមិនចង់ក៏ដោយ។


125

ប្រសិនបើយើងមានគំនិតថា សាតាំងគឺ ជារឿងមិនពិតទេ ឬក៏គ្រាន់តែជាឥទ្ធិពល មួយប៉ុណ្ណោះ យើងពិតជាមិនបានរៀបចំ ដើម្បីទប់ទល់នឹងពួកឆ្លាតវាងវៃ ដែល មានយ៉ាងពិតប្រាកដនោះឡើយ


126

ព្រះគម្ពីរវិវរណៈនិយាយថាៈ


127

(ព្រះគម្ពីរ ២រូប វិវរណៈ ១២:១២)
"ហេតុនោះឱ ស្ថានសួគ៌ និងពួកអ្នកដែល នៅស្ថាននោះអើយ ចូរអរសប្បាយឡើង តែវេទនាដល់ផែនដីនិងសមុទ្រវិញ!

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


128

ពីព្រោះអារក្សបានចុះមកឯអ្នករាល់គ្នា ទាំងមានសេចក្ដីឃោរឃៅជាខ្លាំង ដោយ វាដឹងថា ពេលវេលាវាខ្លីណាស់ហើយ”

វិវរណៈ ១២:១២

ពេត្រុសបានសរសេរការប្រកាសឱ្យដឹង ជាមុននេះ


129

(ព្រះគម្ពីរ ២រូប ពេត្រុសទី១ ៥:៨)

“ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ


130

ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេប បាន

ពេត្រុសទី១ ៥:៨


131

ប៉ុន្តែទោះជាសាតាំងធ្វើរការយ៉ាងអាក្រក់ របស់វាយ៉ាងណាក៏ដោយ ព្រះដ៏ជាអាទិករ មានផែនការមួយដើម្បីនឹងបង្កើតឡើងជាថ្មីវិញ រាប់បញ្ចូលទាំងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវផង-ព្រះរាជបុត្រាតែមួយគត់ របស់ទ្រង់ ដែលសុខចិត្តសុគតដើម្បីចេញ ថ្លៃលោះរបស់យើងទាំងអស់គ្នា ដើម្បីឱ្យយើងមានជីវិតអស់កល្បជានិច្ចវិញ។


132

ព្រះគម្ពីរនិយាយថា សាតាំងបានមក ទាំងគ្រហឹម។


133

សាតាំងបានធ្វើការតាមរយៈស្ដេចហេរ៉ូឌ ដើម្បីបំផ្លាញទារកព្រះគ្រីស្ទ(វាបានបរាជ័យ)



134

(វីដេអូ ១០វិនាទី) សាតាំងបានមកឯព្រះ យេស៊ូវនៅឯវាលរហោស្ថាន ដោយបាន ក្លែងធ្វើជាទេវតាមកពីស្ថានសួគ៌ ជាមួយ នឹងការល្បួងបីយ៉ាងធំ (វាត្រូវបរាជ័យ)

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


135

សាតាំងបានធ្វើឱ្យហ្វូងមនុស្សបំផ្លាញ ព្រះយេស៊ូវនៅភ្នំរលាក្បាល(កាលវ៉ារី) វាជាសត្រូវដែរបានបរាជ័យអស់កល្ប


136

ទោះបីជាមានភ្នំរលាក្បាល(កាលវ៉ារី) ក៏ដោយ ក៏មានការរស់ឡើងវិញដែរ! សូមសរសើរដំកើងដល់ព្រះអម្ចាស់ចុះ!

ដូច្នេះ គឺព្រះដែលបានប្រទានព្រះរាជ បុត្រារបស់ទ្រង់ ហើយព្រះរាជបុត្រានោះបានប្រទានអង្គទ្រង់ ដើម្បីប្តូរជាមួយនឹង វាសនាអាក្រក់របស់អ្នកនិងខ្ញុំ។

ពេលនោះ គឺជារយៈពេលមួយម៉ោង នៃជ័យជំនះ មួយថ្ងៃនៃការរំដោះអ្នកជាប់គុករបស់អារក្សទាំងអស់ នៅលើពិភព លោកនេះ។


137

នៅថ្ងៃនោះ សាតាំងបានក្លាយជាសត្រូវ ដែលត្រូវបរាជ័យ! ដោយសារការសុគត របស់ទ្រង់ ព្រះគ្រីស្ទបានទទួលសិទ្ធិដើម្បី បំផ្លាញអារក្សចេញពីការពិបាកវេទនាទាំង អស់។

លោក ប៉ុលបានសរសេរនៅក្នុងព្រះ គម្ពីរហេព្រើរ ២:១៤ថា



138

(ព្រះគម្ពីរ ២រូប ហេព្រើរ ២:១៤)

"ដូច្នេះ ដែលកូនចៅបានប្រកបដោយ សាច់ឈាម ព្រមគ្នានោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ



139

ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ ដែល មានអំណាចលើសេចក្តីស្លាប់ គឺជាអារក្សដោយសារទ្រង់សុគត"


140

សាតាំងបានបង្ហាញចំពោះអ្នកមានប្រាជ្ញា ទាំងឡាយនៅលើពិភពចក្រវាលនេះ នូវលក្ខណៈពិតប្រាកដរបស់វា ហើយវានៅ តែបង្ហាញ នូវរបៀបដែលវានឹងគ្រប់គ្រង ពិភពលោកនេះ។

ខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ ឧក្រិដ្ឋកម្ម ជម្ងឺ និងការឈឺចាប់ទាំងឡាយទាំងអស់នេះយើងបានឃើញ។



141

ប៉ុន្តែការដែលយើងមិនអាចមើលឃើញ នៅពីក្រោយការទាំងអស់នោះ គឺការងារដ៏ធំហួសវិស័យធ្មមជាតិរបស់សាតាំង។

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


142

សោកនាដកម្មទាំងនេះមិនមែនជា "កិច្ច ការរបស់ព្រះទេ"
វាគឺជា "កិច្ចការរបស់សាតាំង"


143

លោកអ្នកប្រហែលជាមានចម្ងល់អំពី ទុក្ខព្រួយ ការគ្រាំគ្រាចិត្ត និងការពិបាក នៅក្នុងជីវិតរបស់លោកអ្នកផ្ទាល់។ លោក អ្នកប្រហែលជាធ្លើងឆ្ងល់អំពីការបាត់បង់កូន ចៅ ឬអ្នកដែលជាទីស្រឡាញ់ណាម្នាក់ ហើយលោកអ្នកសួរថា "តើព្រះនៅឯណា?"


144

ព្រះគម្ពីរបង្រៀនថា ព្រះគង់នៅទីនេះ ព្រះអង្គគង់នៅកណ្តាលការទុក្ខព្រួយ និង ការពិបាក គ្រាំគ្រាចិត្តរបស់លោកអ្នក
ហើយទ្រង់នឹងយាងចូលមកថែរក្សាអ្នក និងដោះស្រាយនូវបញ្ហានៃអំពើបាប និង ការឈឺចាប់ទាំងឡាយនោះ។


145

ដំណឹងល្អនោះគឺថា ភពផែនដីដែល សាតាំងបានប្លន់យកនោះ នឹងត្រូវបាន សង្គ្រោះក្នុងពេលឆាប់ៗនេះ។
ចំណេះដឹងនេះ នឹងបញ្ឈប់នូវការភ័យ ខ្លាចរបស់អ្នកដំណើរដ៏ញ័ររន្ធត់ នៅលើ យានអវកាសនៃផែនដី ដែលកំពុងបើកខុស ទិសដៅនេះ ព្រះមានផែនការបំផ្លាញ សាតាំង ជាអ្នកអាក្រក់ ដែលពោរពេញ ទៅដោយការឆបោកនេះ ហើយយើងនឹង សិក្សាអោយបានហ្មត់ចត់អំពីអ្វីដែលជាផែន ការនេះ នៅពេលប្រជុំលើកក្រោយទៀត។
សូមយើងពិនិត្យមើលថា តើព្រះគម្ពីរ និយាយយ៉ាងម៉េចអំពីសាតាំងនេះ:


146

(ព្រះគម្ពីរ ៣រូប អេសេគាល ២៨:១៦, ១៨)
"....ឱ ចេរូប៊ីនដែលគ្របបាំង អើយ អញនឹងបំផ្លាញឯង..."


147

ហេតុនោះអញបានធ្វើឱ្យមានភ្លើងចេញ ពីកណ្តាលឯងមក


148

ភ្លើងនោះបានឆេះបំផ្លាញឯង អញបានឱ្យ ឯងទៅជាផេះនៅលើផែនដី..."
អេសេគាល ២៨:១៨
អំពើបាបនិងការឈឺចាប់នឹងសូន្យបាត់ទៅ

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


149

មែនហើយ មិត្តទាំងឡាយអើយ ព្រះយេស៊ូវ នឹងយាងមកវិញឆាប់ៗនេះ!

មិនមែនមកជាអ្នកកាលីឡេដ៏ទន់ទាបទេ មិនមែនឱ្យគេចំអកទេ មិនមែនឱ្យគេស្តោះ ដាក់ និងបដិសេធទេ។ មិនមកឱ្យគេឆ្កាង នៅលើឈើឆ្កាងទៀតនោះទេ។


150

ប៉ុន្តែក្នុងឋានៈជាស្តេចលើអស់ទាំងស្តេច ជាព្រះលើអស់ទាំងព្រះ ដែលមានអំណាច សោយរាជ្យ!

យើងត្រូវតែរៀបចំខ្លួនចាំជួបទ្រង់ ព្រោះថា បើយើងបាត់បង់ឱកាសនេះ យើងនឹងបាត់បង់អ្វីៗទាំងអស់។



151

(វីដេអូ ១២វិនាទី) រឿងនៅសព្វថ្ងៃនេះ គឺ

តើយើងនឹងជឿអ្នកណា?

តើយើងនឹងដើរតាមអ្នកណា?

ព្រះជាទីស្រឡាញ់ ឬទេវតាដែលធ្លាក់ចុះ?

ខ្សែបន្ទាត់ត្រូវបានគេគូសខណ្ឌ

លោកីយ៍ទាំងមូលនេះបានត្រូវបែងចែក ជាពីរផ្នែក។ តើភក្តីភាពរបស់លោកអ្នកនៅ ខាងណា?

តើអ្នកនឹងនៅខាងណា?


152

ចំពោះអ្នកនឿយហត់ទាំងឡាយ អ្នក មានចិត្តឯកោទាំងឡាយ ចំពោះអ្នកមានការ ឈឺចាប់និងព្រលឹងមានទោសទាំងឡាយ ចំពោះកូនរបស់ទ្រង់ទាំងអស់ នៅលើពិភព លោកបះបោរនេះ ព្រះយេស៊ូវបានប្រទាន សេចក្តីអញ្ជើញនៃសេចក្តីស្រឡាញ់មួយៈ


153

(ព្រះគម្ពីរ ម៉ាថាយ ១១:២៨)

"អស់អ្នកដែលនឿយព្រួយហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាសម្រាក"

ម៉ាថាយ ១១:២៨


154

(ព្រះគម្ពីរ យ៉ូហាន ៦:៣៧)

"...ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏ មិនដែលចោលទៅក្រៅដែរ"

យ៉ូហាន ៦:៣៧

តើនេះមិនមែនជាដំណឹងដ៏ល្អអស្ចារ្យទេ ឬអី?

# ៦. តើហេតុអ្វីបានជាមានការឈឺចាប់ច្រើនម្ល៉េះ?


155

នៅកណ្តាលសោកនាដកម្មនៃជីវិត ការទុក្ខ ព្រួយ ចិត្តគ្រាំគ្រា និងការអស់សង្ឃឹម ព្រះយេស៊ូវគង់នៅទីនោះ។

ទ្រង់យល់នូវការទុក្ខព្រួយ ដែលអ្នកកំ ពុងជួបប្រទះឥឡូវនេះ។

ព្រះយេស៊ូវទ្រង់ជ្រាបថា រូបកាយអ្នក ដែលបានរាតត្បាតដោយជម្ងឺនោះយ៉ាងណា ទ្រង់ជ្រាបការឈឺចាប់

ទ្រង់បានជួបការឈឺចាប់នេះ នៅពេល ដែលមនុស្សអាក្រក់បានបោះដែកគោលចូល ក្នុងព្រះហស្តទ្រង់

ទ្រង់ជ្រាបពីភាពឯកកោ

ទ្រង់បានជួបការនេះ នៅពេលដែល ទ្រង់ត្រូវបានគេឆ្កាង នៅក្នុងភាពងងឹតនៅ លើឈើឆ្កាង។

ទ្រង់ជ្រាបពីការក្រខ្សត់។

ទ្រង់បានជួបប្រទះការនេះ នៅពេល ដែលទ្រង់បានយាងកាត់ផ្លូវដែលពោរពេញ ដោយធូលីដីមួយនៃប្រទេសប៉ាឡេស្ទីន ដែលមានអាហារយ៉ាងតិចតួច និងគ្មានផ្ទះ សំបែង។ សូមចូលមកឯទ្រង់នៅថ្ងៃនេះ ចុះ។ ទ្រង់នឹងប្រទានដល់លោកអ្នក នូវ សេចក្តីសង្ឃឹមថ្មី និងការកំសាន្តចិត្ត។

នេះគឺជាដំណឹងដ៏ល្អលើសពីដំណឹង ណាៗទាំងអស់។

ថ្ងៃណាមួយនៅពេលឆាប់ៗនេះ ព្រះ យេស៊ូវនេះនឹងយាងមកម្តងទៀត ដាក់ ហើយនិងដាក់ឱ្យដល់ទីបញ្ចប់នូវការឈឺចាប់ របស់ជីវិតមនុស្សទាំងអស់។

ទ្រង់នឹងយាងមកម្តងទៀត ដើម្បីនឹងនាំ មកនូវផែនដីថ្មីមួយ។

អំពើបាបនិងអ្នកមានបាបនឹងត្រូវបានបំ ផ្លាញ។

សាតាំងនឹងត្រូវបរាជ័យ។ ព្រះយេស៊ូវ ចង់ស្ដាបនាអ្នកមកជាគ្រួសាររបស់ទ្រង់ឡើង វិញជាខ្លាំង ទ្រង់ចង់ប្រទានជីវិតអស់កល្ប ដល់លោកអ្នក នៅលើផែនដីដែលបានធ្វើ ជាថ្មីឡើងវិញនេះ។

ប៉ុន្តែសេចក្តីសម្រេចចិត្តមួយត្រូវតែបាន ធ្វើ-ថាតើអ្នកណាជាព្រះអម្ចាស់ និងជា ម្ចាស់របស់លោកអ្នក?

មិត្តទាំងឡាយ ការសម្រេចចិត្តនេះ គឺ ជាបញ្ហាស្លាប់រស់!

តើអ្នកមិនជ្រើសរើសយកព្រះយេស៊ូវធ្វើ ជាស្តេចរបស់លោកអ្នកឥឡូវនេះទេឬអី?

ទ្រង់កំពុងរង់ចាំលោកអ្នក ព្រះពាហុ ទ្រង់ កំពុងបានលាតយ៉ាងវែង។

ទ្រង់មានព្រះបន្ទូលថា "ចូរមក! ចូរមក! ចូរមក!"

សូមអញ្ជើញលោកអ្នកឱនក្បាលចុះ ហើយនិយាយថា "ក្រាបទូលព្រះយេស៊ូវ ទូលបង្គំកំពុងមក" នៅពេលដែលយើងអធិស្ឋាននេះ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


1

ទ្រង់នោះក៏អាចបំផ្លាស់ប្រែជីវិតលោកអ្នកដែរ


2

បុរសពីរនាក់បានធ្វើដំណើររាប់រយគីឡូ ម៉ែត្រ កាត់សហរដ្ឋអាមេរិកដោយរទេះ ភ្លើង។
ដោយដំណើររបស់គាត់ វែងឆ្ងាយ ពេក
គេបានចំណាយពេលជជែកគ្នាអំពីអ្វីៗដែលបានកើតឡើងក្នុងគំនិតគេ។

ពួកគេបាននិយាយអំពីធាតុអាកាស។
ពួកគេបាននិយាយអំពីនយោបាយ។
ពួកគេបាននិយាយអំពីបទពិសោធន៍នៃកុមារភាព គ្រួសារ និងអាពាហ៍ពិពាហ៍របស់គេ។
ទីបំផុតការសន្ទនានោះបានធ្លាក់ដល់រឿងសាសនា។

បុរសម្នាក់ជឿថា គ្មានព្រះទេ។ ម្នាក់ទៀតគឺជាគ្រីស្ទាន។
បុរសម្នាក់មិនបានជឿដល់ព្រះទាល់តែសោះ។ ម្នាក់ទៀតមានជំនឿលើព្រះយ៉ាងមុតមាំជាទីបំផុត
បុរសម្នាក់មិនដែលបានអានព្រះគម្ពីរទេ។ ម្នាក់ទៀតអានគម្ពីរជាប្រចាំ។


3

ចំណងជើងនៃការជជែកគ្នារបស់គេនៅ ល្ងាចដ៏ស្រឡះនៃរដូវក្តៅនោះ គឺព្រះយេស៊ូវ គ្រីស្ទ។
អ្នកដែលមិនជឿថាមានព្រះ បានសួរ ទៅសំឡាញ់គ្រីស្ទានរបស់ខ្លួននូវសំនួរដ៏សំខាន់
និងមានអំណាចខ្លះៗ ដូចជាសំនួរថាៈ
តើហេតុដូចម្តេចបានជាអ្នកក្លាយជា គ្រីស្ទាន? តើវាមិនមែនជារឿងចៃដន្យនៃ ភូមិវិទ្យាទេឬអី?
តើអ្នកគ្រាន់តែជឿ ដោយ សារអ្នកកើតឡើងនៅក្នុងប្រទេសគ្រីស្ទានមួយប៉ុណ្ណោះមែនទេ?
តើព្រះយេស៊ូវខុសពីមនុស្សឧត្តមៗដទៃ ទៀតយ៉ាងណា? តើព្រះអង្គប្រសើរជាងគ្រូ
ដែលមានសីលធម៌ត្រឹមត្រូវ ឬទស្សនវិទូ ដែលមានសីលធម៌ល្អឬទេ?
តើហេតុដូចម្តេចបានជាអ្នកប្រាកដក្នុង ចិត្តថា ព្រះយេស៊ូវ ទ្រង់ពិតប្រាកដ
ដូចដែលទ្រង់បានអះអាងទាំងអស់មែន នោះ?
តើហេតុដូចម្តេចបានជាអ្នកជឿជាក់ថា ព្រះយេស៊ូវពិតជាព្រះមែន ហើយទ្រង់អាច
ប្រទានជីវិតអស់កល្បមែននោះ?
សំនួររបស់អ្នកមិនជឿព្រះនៅល្ងាចនៃ រដូវក្តៅនៅលើរទេះភ្លើងនោះ សុទ្ធតែជាសំ នួរល្អៗ។
សំឡាញ់ដែលជាគ្រីស្ទានរបស់ គាត់បានចែកចាយចម្លើយខ្លះៗជាមួយគាត់។
ខ្ញុំដឹងច្បាស់ថា ចម្លើយដ៏ល្អទៅនឹងសំនួរ ទាំងនេះ គឺនៅពេលណាដែលយើងយល់ ពីចម្លើយទាំងនោះ
យើងបានជាជីវិតអស់ កល្បនោះ។

# ៧. ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល




4

ពិភពលោករបស់យើងត្រូវតែមាន មនុស្សល្បីៗជាចំណែករបស់ខ្លួន។ ជា
មនុស្សដែលបានធ្វើវិភាគទាន ដើម្បី ធ្វើអោយពិភពលោកនេះកាន់តែប្រសើរ ឡើង។



5

ស្តេច ប្រធានាធិបតី អ្នកកាន់សាសនា អ្នកដឹកនាំកងទ័ព អ្នកវិទ្យាសាស្ត្រ និង វិចិត្រករ
បានបន្សល់ស្នាដៃរបស់គេនៅលើ ពិភពលោកនេះ។
ពួកគេមានកេរ្តិ៍ឈ្មោះល្បីពាសពេញពិ
ភពលោក។



6

មានឈ្មោះមួយដែលល្បីជាងគេបង្អស់។
សូម្បីតែជាប្រវត្តិសាស្ត្រក៏បានបែងចែកនៅក្នុងឆ្នាំមុននិងក្រោយអ្នកនោះបានកើតដែរ។
អ្នកនោះឈ្មោះ យេស៊ូវ។
ព្រះយេស៊ូវគឺជា ឈ្មោះដែលល្បីល្បាញ ជាងគេនៅក្នុងប្រវត្តិសាស្ត្រ។
វាមានការខុសគ្នារវាងការស្គាល់ព្រះនាម ទ្រង់ និងការដឹងថា ទ្រង់ជានរណា



7

យប់នេះខ្ញុំចង់ណែនាំលោកអ្នកបន្ថែម ទៅលើព្រះយេស៊ូវនៃប្រវត្តិសាស្ត្រ-ព្រះ យេស៊ូវនៃព្រះគម្ពីរ-
ចូរយើងចាប់ផ្តើមពី ដើមដំបូង។
អ្នកប្រហែលជាងឿងឆ្ងល់ថា-តើព្រះ យេស៊ូវនេះជាអ្នកណា? តើទ្រង់ខុសពីគេ យ៉ាងណា?
តើទ្រង់គ្រាន់តែជាមនុស្សល្អ ម្នាក់ គ្រូបង្រៀនល្អម្នាក់ ឬទស្សនវិទូដែល
មានសីលធម៌ល្អម្នាក់ប៉ុណ្ណោះទេឬ?
សាវកពីរនាក់ក៏មានចម្ងល់ពីបញ្ហាទាំង នេះដែរ។



8

នៅពេលដែលព្រះយេស៊ូវបានជួបសិស្ស ពីរនាក់នៅតាមផ្លូវទៅអេម្មូស នៅថ្ងៃអា ទិត្យ
នៃការរស់ឡើងវិញ។



9

ទ្រង់បានប្រាប់ពួកគេនូវបទទំនាយដែល បានសំរេចកាលពីពីរបីថ្ងៃមុន។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


10

(ព្រះគម្ពីរ ៣រូប លូកា ២៤:២៥-២៧)

"ឱមនុស្សឥតពិចារណា ហើយក្រនឹង ជឿអស់ទាំងសេចក្តី ដែលពួកហោរាបាន ទាយទុកមកអើយ!...


11

ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរ ពួកហោរារៀងមក


12

រួចទ្រង់ក៏ស្រាយន័យសេចក្តីដែលតម្រូវ ដល់ទ្រង់។

លូកា ២៤:២៥-២៧


13

សូមមើលទៅភ័ស្តុតាងទាំងឡាយដែល បញ្ជាក់ថា ព្រះយេស៊ូវជាព្រះមែស៊ី។


14

ការប្រសូតដ៏អស្ចារ្យរបស់ទ្រង់។

តាំងពីយូរយារ មុនព្រះយេស៊ូវប្រសូតពី នាងព្រហ្មចារីមក ហោរាអេសាយបាន ទស្សន៍ទាយថា:


15

(ព្រះគម្ពីរ ២រូប អេសាយ ៧:១៤)

ដូច្នេះទ្រង់នឹងប្រទានទីសំគាល់១មកអ្នក រាល់គ្នា ដោយព្រះអង្គទ្រង់


16

មើល នាងព្រហ្មចារីនឹងមានគភ៌ ប្រ សូតបានបុត្រា១ ហើយនឹងឱ្យព្រះនាមថា អេម៉ាញូអែល

អេសាយ៧:១៤

៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល

# ៧. ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល



17

(វីដេអូ ៥វិនាទី) ព្រះយេស៊ូវមានព្រះនាម ជាច្រើនៈ អេម៉ាញូអែល ព្រះយេស៊ូវ ព្រះ អង្គសង្គ្រោះ ព្រះគ្រីស្ទ និងព្រះមែស៊ី។

បទទំនាយរបស់ហោរាអេសាយ ទាក់ ទងទៅនឹងកំណើតរបស់ព្រះយេស៊ូវពីស្ត្រីព្រហ្មចារី បានសរសេរតាំងពី៦០០ឆ្នាំមុនព្រះ អង្គប្រសូត។

ទេវតាមួយអង្គបានលើកយករឿងនេះ មកអះអាងធ្វើជាភ័ស្តុតាង ថាព្រះយេស៊ូវ ជាព្រះមែស៊ី។ ចូរយើងពិនិត្យមើល ការ ដែលទេវតាបានពិពណ៌នាអំពីកំណើតរបស់ ព្រះយេស៊ូវ ពីនាងព្រហ្មចារីម៉ារា


18

(ព្រះគម្ពីរ ម៉ាថាយ ១:១៨)

"រីឯកំណើតព្រះយេស៊ូវ នោះបានកើតមក យ៉ាងដូច្នេះ គឺនាងម៉ារាមាតាទ្រង់ កាលដែលយ៉ូសែបបានដណ្តឹងនាងហើយ


19

នាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ មុន ដែលបាននៅជាមួយគ្នា"

ម៉ាថាយ ១:១៨


20

ទីកន្លែងកំណើតរបស់ទ្រង់


21

(ព្រះគម្ពីរ មីកា ៥:២)

"...ឱបេថ្លេហិម...នឹងមាន ម្នាក់កើតចេញពីឯងមកឱ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល..."

មីកា: ៥:២

វាជាការដែលគួរអោយកត់សំគាល់ ដែលថា ព្រះយេស៊ូវបានប្រសូតនៅបេថ្លេ ហិម គឺជាទីក្រុងដែលបទទំនាយបានទស្សន ទាយ៧០០ឆ្នាំ តាំងពីមុនការប្រសូតនេះ យ៉ាងត្រឹមត្រូវ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល





22

(ព្រះគម្ពីរ ម៉ាថាយ ២:១)

"...កាលព្រះយេស៊ូវប្រសូតមក នៅភូមិ បេថ្លេហឹមស្រុកយូដា..."

ម៉ាថាយ ២:១

ព្រះគម្ពីរសញ្ញាថ្មីបានបញ្ជាក់អំពីការសំ រេចនៃបទទំនាយក្នុងគម្ពីរមីកា។ ព្រះយេស៊ូវទ្រង់លើសពីមនុស្សល្អ លើសពីគ្រូ បង្រៀន ដែលមានសីលធម៌ល្អ លើសពីទស្សនវិទូដែលមានសីលធម៌ល្អ។

ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះនៃស្ថាន

សួគ៌។ ទ្រង់បានប្រសូតពីស្រីព្រហ្មចារី ដូចហោរាអេសាយបានទស្សនទាយមែន។

ទ្រង់បានប្រសូតនៅបេថ្លេហឹមដូច ហោរាមីកាបានទស្សនទាយមែន។



23

បទទំនាយនៃព្រះគម្ពីរបានបង្ហាញយ៉ាង ច្បាស់លាស់ អំពីការលំអិតដ៏សំខាន់ៗទាំងឡាយនៅក្នុងជីវិត របស់ព្រះគ្រីស្ទរាប់រយ

ឆ្នាំជាមុន។

បទទំនាយទាំងនេះបានសំរេចយ៉ាងត្រឹម ត្រូវរួចហើយ នៅពេលដែលអ័ដាម និង អេវ៉ាមានអំពើបាប ព្រះបានមានគំរោងការ មួយ។

សេចក្តីស្រឡាញ់របស់ទ្រង់បានត្រាស់ ហៅព្រះយេស៊ូវ-ព្រះរាជបុត្រាទ្រង់-អោយយាងមកកាន់ផែនដី រស់នៅក្នុងជីវិតដ៏ល្អ គ្រប់លក្ខណ៍មួយ និងសុគតសំរាប់បាបរបស់ យើង។ ទ្រង់បានធ្វើជាថ្នូរជំនួសយើង ដើម្បីឱ្យ យើងអាចមានជីវិតអស់កល្ប ប្រសិនបើយើងបានទទួលផែនការរបស់ទ្រង់ ជាព្រះ អង្គសង្គ្រោះរបស់យើង។ ការនេះត្រូវ បានហៅថាផែនការនៃសេចក្តីសង្គ្រោះ។



24

ប្រហែលជា២០០០ឆ្នាំមុន អ្នក ប្រាជ្ញមកពីទិសខាងកើតបានសិក្សាព្រះគម្ពីរ។ គេបានអានអំពីស្តេចដ៏ឧត្តុង្គឧត្តមមួយ អង្គ និងបានដឹងអំពីពេលវេលាដែលទ្រង់ នឹងយាងមក។



25

គេបានដឹងថា កាលណាពេលនោះមក ដល់ និងមានផ្កាយជាសញ្ញានៃការប្រសូតរបស់ព្រះរាជឱរសនោះ។ នៅបេថ្លេហឹម ពួកគេបានរកទ្រង់ឃើញ ហើយក្រាបចុះថ្វាយបង្គំព្រះយេស៊ូវ។



26

(ព្រះគម្ពីរ ២រូប លូកា ២:៧)

ហើយនាង(ម៉ារី)ប្រសូតបានបុត្រាជាចំ បងមក រួចរុំនឹងសំពត់

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


27

ផ្ដេកក្នុងស្នូក ពីព្រោះក្នុងផ្ទះសំណាក់
គ្មានកន្លែងណានៅទេ” លូកា ២:៧


28

គ្មានបន្ទប់ឡើយនៅក្នុងផ្ទះសំណាក់ ដូច្នេះ ព្រះយេស៊ូវត្រូវបានគេផ្ដេកនៅក្នុងស្នូកសត្វ។
ទ្រង់បានប្រសូតដោយគ្មានអ្នកណាជួយ ឡើយ។


29

មាតារបស់ទ្រង់មានចិត្តសប្បុរសណាស់ នាងនៅក្មេងនៅឡើយ នៅពេលដែល
ទេវតាបានមកប្រាប់នាងថា នាងនឹងប្រសូត បានបុត្រជាព្រះរាជបុត្ររបស់ព្រះ។



30

ទោះបីទ្រង់ជា “ព្រះរាជបុត្រារបស់ ព្រះ” ទ្រង់ក៏ជាព្រះដូចជាព្រះវរបិតាទ្រង់ ដែរ។
សាវកប៉ុលបាននិយាយថា ទ្រង់ស្មើនឹង ព្រះ ហើយបានមកយកទ្រង់ទ្រាយជាអ្នក
បំរើក្នុងភាពជាមនុស្ស។


31

(ព្រះគម្ពីរ ៣រូប ភីលីព ២:៦)
“...មានរូបអង្គជាព្រះក៏ដោយ គង់តែ មិនបានរាប់សេចក្ដីដែលស្មើនឹងព្រះនោះ ទុក
ជាសេចក្ដីដែលគួរកាន់ខ្ជាប់ឡើយ


32

គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូប ភាពជាបាវបំរើវិញ


33

ព្រមទាំងប្រសូតមកមានរូបជាមនុស្ស”
ភីលីព ២:៦_៧

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


34

ព្រះយេស៊ូវបានយាងមករស់នៅលើផែន ដីនេះដូចយើងរាល់គ្នាដែរ។ ប៉ុន្តែទ្រង់ បរិសុទ្ធ ស្អាតស្អំ និងគ្មានសៅហ្មង ដើម្បី អោយទ្រង់អាចលះបង់ព្រះជន្មរបស់ទ្រង់ ប្រយោជន៍អោយយើងអាចមានជីវិតអស់ កល្ប។

ក្នុងពេល២៤ម៉ោងចុងក្រោយនៃជីវិត របស់ព្រះយេស៊ូវ បទទំនាយជាច្រើន ដែលមានអាយុរាប់សតវត្សរ៍មកហើយ ត្រូវ បានសម្រេចយ៉ាងល្អិតល្អន់។


35

សូមយើងលើកយកការក្បត់ព្រះយេស៊ូវ របស់យូដាសមកធ្វើជាឧទាហរណ៍។


36

(ព្រះគម្ពីរ ទំនុកដំកើង ៤១:៩)

"អើ ទាំងមិត្តសំឡាញ់ស្និទ្ធស្នាលរបស់ ទូលបង្គំ ជាអ្នកដែលទូលបង្គំបានទុកចិត្ត ហើយក៏បានបរិភោគបាយរបស់ទូលបង្គំផង នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំ ដែរ"

លោកពេត្រុសបានសួរទៅព្រះយេស៊ូវ ថា តើអ្នកណាដែលនឹងក្បត់ទ្រង់ ហើយ ព្រះយេស៊ូវបានឆ្លើយថា


37

"...ជាអ្នកដែលខ្ញុំជ្រលក់នំបុ័ងហុចទៅ ឱ្យ... "

យ៉ូហាន ១៣:២៦


38

តម្លៃដែលបានចំណាយអោយអ្នកក្បត់


39

រួចគេសម្រេចនឹងឱ្យប្រាក់៣០រៀល ដល់គាត់"

សាការី ១១:១២


40

(ព្រះគម្ពីរ ២របា ម៉ាថាយ ២៦:១៤-១៥)

"នៅគ្រានោះមានម្នាក់ក្នុងពពួក១២នាក់ ឈ្មោះយូដាស-អ៊ីស្ការីយុត វាក៏ទៅឯពួក សង្គ្រាជ

# ៧. ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


41

សួរថា បើខ្ញុំបញ្ជូនអ្នកនោះមកលោក តើ លោកនឹងធ្វើអ្វីដល់ខ្ញុំ? រួចគេសម្រេចនឹងឱ្យប្រាក់៣០រៀលដល់គាត់"


42

ការវាយ និងការធ្វើទុក្ខទោសទ្រង់


43

(ព្រះគម្ពីរ ២រូប អេសាយ ៥០:៦)
"ខ្ញុំបានប្រគល់ខ្នងទៅឱ្យពួកអ្នកដែល
វាយហើយថ្ពាល់ខ្ញុំទៅឱ្យពួកដែលបោច
ពុកចង្កា


44

ខ្ញុំមិនបានគេចមុខពីសេចក្តីអាម៉ាស់ខ្មាស ឬ ពីការស្តោះទឹកមាត់ទេ
អេសាយ ៥០:៦


45

(ព្រះគម្ពីរ ម៉ាថាយ ២៦:៦៧)
"គេក៏ស្តោះដាក់ព្រះភ័ក្ត្រ ហើយដាល់តប់ ទ្រង់ មានអ្នកខ្លះទះទ្រង់"
ម៉ាថាយ ២៦:៦៧


46

គេទម្លុះព្រះហស្ត និងព្រះបាទរបស់ទ្រង់


47

(ព្រះគម្ពីរ ទំនុកដំកើង ២២:១៦)
"គេបានចាក់ទម្លុះដៃជើងនៃទូលបង្គំ"
ទំនុកដំកើង ២២:១៦

បន្ទាប់ពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ថូម៉ាស់ជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំង អស់ដែលបានសង្ស័យថា ទ្រង់បានរស់ ឡើងវិញ បានបញ្ជាក់ទៅលើ ហេតុការណ៍ នៃព្រះហស្ត និងព្រះបាទរបស់ទ្រង់ត្រូវបាន ទម្លុះយ៉ាងពិតប្រាកដ។ គាត់បាននិយាយថា:

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


48

(ព្រះគម្ពីរ ២រូប យ៉ូហាន ២០:២៥)

"បើខ្ញុំមិនបានឃើញស្នាមដែកគោលនៅ

ព្រះហស្តទ្រង់


49

...នោះខ្ញុំមិនព្រមជឿទេ"

យ៉ូហាន ២០:២៥


50

ទ្រង់ត្រូវបានគេរាប់ថា ជាអ្នកទទឹងច្បាប់

សូមយើងពិនិត្យមើលថា តើបទទំនាយ នៃព្រះគ្រីស្ទនេះបានសំរេច ហើយពិតប្រា កដយ៉ាងណាខ្លះ?


51

(ព្រះគម្ពីរ អេសាយ ៥២:១២)

"...គេបានរាប់ទ្រង់ទុកជាអ្នកទទឹង

ច្បាប់"

អេសាយ ៥៣:១២


52

(ព្រះគម្ពីរ ២រូប ម៉ាកុស ១៥:២៧-២៨)

"ហើយក៏ឆ្កាងចោរពីរនាក់ ជាមួយនឹងទ្រង់ ម្នាក់ខាងស្តាំ ម្នាក់ខាងឆ្វេង


53

នោះបានសម្រេចតាមបទគម្ពីរដែលថា គេបានរាប់ទ្រង់ជាពួកអ្នកដែលទទឹងច្បាប់"

ម៉ាកុស ១៥:២៧-២៨


54

ពួកគេបានចាប់ឆ្នោតយកព្រះពស្ត្រទ្រង់

ស្តេចដាវីឌបានប្រាប់អំពីហេតុការណ៍ ដែលនឹងកើតមានឡើង ដល់ព្រះពស្ត្រទ្រង់

មួយពាន់ឆ្នាំមុនព្រះយេស៊ូវសុគត:

# ៧. ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


55

(ព្រះគម្ពីរ ទំនុកដំកើង ២២:១៨)

"គេយកសំលៀកបំពាក់ទូលបង្គំចែកគ្នា ឯអាវវែងរបស់ទូលបង្គំ គេក៏ធ្វើឆ្នោតចាប់ យក"

ទំនុកដំកើង ២២:១៨


56

(ព្រះគម្ពីរ ៣រូប យ៉ូហាន ១៩:២៣-២៤)

"ឯពួកទាហានកាលបានឆ្កាងព្រះយេស៊ូវ រួច ...នោះគេបានយកព្រះពស្ត្រទ្រង់ចែក ជាបួនចំណែក...


57

តែអាវនោះបានត្បាញពីលើ ជាសំពត់ តែ១ គ្មានថ្នេរសោះ


58

ដូច្នេះគេនិយាយគ្នាថា កុំហែកអាវនេះ ឡើយ ចូរយើងចាប់ឆ្នោតវិញ ឱ្យបានដឹង ថា អាវនេះនឹងទៅជារបស់អ្នកណា"

យ៉ូហាន ១៩: ២៣-២៤


59

ព្រះបន្ទូលរបស់ទ្រង់នៅលើឈើឆ្កាង


60

(ព្រះគម្ពីរ ទំនុកដំកើង ២២:១)

"ឱ ព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ?"

ទំនុកដំកើង ២២:១ ប្រៀបធៀបខ នេះជាមួយនឹងម៉ាថាយ ២៧:៤៦


61

(ព្រះគម្ពីរ ម៉ាថាយ ២៧:៤៦)

"ព្រះអង្គ ព្រះអង្គនៃទូលបង្គំអើយ ហេតុអ្វី បានជាទ្រង់ចោលទូលបង្គំ"

ព្រះយេស៊ូវបានបន្ទឺព្រះបន្ទូលនេះមុន ពេលព្រះអង្គសុគតបន្តិច នៅម៉ោងទី៩។


62

បទទំនាយជាច្រើន ដែល លើសពីការគ្រប់គ្រងនៃភាពជាមនុស្សរបស់ ព្រះយេស៊ូវ ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


63

ទ្រង់មិនអាចរៀបចំកន្លែងប្រសូតរបស់ ទ្រង់ទេ


64

របៀបនៃការប្រសូតរបស់ទ្រង់


65

ការរត់ទ្រង់


66

ឫក៏ហេតុការណ៍ដែលកើតឡើងជុំវិញការ សុគតរបស់ទ្រង់។


67

ព្រះយេស៊ូវពិតជាអ្នកដែលគេបានអះ អាងថា ជាព្រះមែស៊ី។ នៅពេលទ្រង់បានជាប់នៅលើឈើឆ្កាង ដ៏ ឃោរឃៅ បានដាច់ស្នាមហូរឈាមដោយ ការវាយដំ គេបោះដែកគោលលើព្រះហស្ត និងព្រះបាទទ្រង់ ជាមួយនឹងភួងបន្លានៅលើ ព្រះសិរ ព្រមទាំងត្រូវ បានគេចំអកនិង ផ្លែផ្កាដាក់។


68

ទ្រង់អាចហៅទេវតាមួយម៉ឺនអង្គមកបំ ផ្លាញផែនដី ហើយរំដោះទ្រង់ចេញ”

បើធ្វើដូច្នោះ ទ្រង់មិនអាចជួយព្រះអង្គ ឯង និងយើងទាំងអស់គ្នាផងបានទេ!


69

ជួនកាលអ្នកឆ្ងល់ទេថា តើមានអ្នកណា ពិតជាយកចិត្តទុកដាក់ចំពោះអ្នកឬទេ? ព្រះ យេស៊ូវ ព្រះអង្គយកព្រះទ័យទុកដាក់នឹងអ្នក ទ្រង់បានបង្ហាញការនេះជាយូរយារណាស់មក ហើយ នៅភ្នំក្រៅទីក្រុង យេរូសាឡិម!

នេះគឺជាសេចក្តីស្រឡាញ់យ៉ាងអស្ចារ្យ!

វាបានបំបែកចិត្តមោទនះរបស់យើង ទ្រង់អាចហៅទេវតាមួយម៉ឺនអង្គ ប៉ុន្តែអរ ព្រះគុណដល់ព្រះដែលទ្រង់មិនបានធ្វើដូច្នោះ ផ្ទុយទៅវិញទ្រង់បានសុគតជំនួសអ្នក ហើយនិងខ្ញុំ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល



70

សំនួរដែលសំខាន់ជាងគេនោះគឺ “តើ ព្រះយេស៊ូវជាអ្នកណាសំរាប់អ្នក?”


71

ព្រះយេស៊ូវបានយាងមកកាន់ភពយើង នេះ ដើម្បីរស់ក្នុងជីវិតដ៏គ្រប់លក្ខណ៍ សម្រាប់ជំនួសអោយជីវិតដ៏ ពោរពេញ ដោយ អំពើបាបរបស់យើង។ ព្រះអង្គក៏បានសុគត ជំនួសសេចក្ដីស្លាប់ ដែលយើងត្រូវទទួល ផងដែរ ដើម្បីអោយយើងអាចរស់នៅជា រៀងរហូត! ព្រះគម្ពីរបាននិយាយអំពីព្រះ ពលិកម្ម (ការលះបង់) នេះ។


72

(ព្រះគម្ពីរ ៤រូប អេសាយ ៥៣:៣_៧)

“ទ្រង់ត្រូវគេមើលងាយ ហើយត្រូវ មនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្ដីឈឺចាប់...


73

តែទ្រង់ត្រូវរងរបួសដោយព្រោះអំពើ រំលងរបស់យើង ក៏ត្រូវវាយជជាំ ដោយ ព្រោះអំពើទុច្ចរិតរបស់យើង ឯការវាយ ផ្ចាលដែល នាំឱ្យយើងបានជាមេត្រីនោះ បានធ្លាក់មក លើទ្រង់  ហើយយើងរាល់ គ្នាបានប្រោស ឱ្យជា ដោយសារស្នាម រំពាត់របស់ទ្រង់។


74

យើងទាំងអស់គ្នាបានទាសចេញដូចជា ចៀម...”


75

ទ្រង់ត្រូវគេសង្កត់សង្កិន... តែទ្រង់មិន បានហើបព្រះឱស្ឋសោះ គឺដូចជាកូនចៀម ដែលគេដឹកទៅសម្លាប់”

អេសាយ ៥៣:៣_៧


76

ត្រង់នេះយើងបានរកឃើញថា ព្រះ យេស៊ូវត្រូវបានហៅថាកូនចៀមនោះ។ ទ្រង់បានត្រូវគេហៅថា “កូនចៀម” ជា ច្រើនកន្លែងទៀតនៅក្នុងព្រះគម្ពីរ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


77

(ព្រះគម្ពីរ វិវរណៈ ១៣:៨)

វិវរណៈ១៣:៨ និយាយអំពី "បញ្ជីជីវិត របស់កូនចៀម ដែលត្រូវគេសម្លាប់តាំងពីកំណើតលោកីយ៍មក"


78

(ព្រះគម្ពីរ ២រូប វិវរណៈ ៥:៨-១២)

"ពួកចាស់ទុំ២៤នាក់ក៏ទម្លាក់ខ្លួនក្រាបចុះនៅចំពោះកូនចៀម...


79

(គ្រប់គ្នាក៏បន្លឺសំឡេងថា)

កូនចៀមដែលបានសម្លាប់នោះគួរនឹងបានទទួលព្រះចេស្តា"


80

(ព្រះគម្ពីរ ២រូប រ៉ូម ៦:២៣)

"ដ្បិតឈ្នួលនៃអំពើបាបគឺសេចក្តីស្លាប់"


81

តែអំណោយទាននៃព្រះវិញ គឺជាជីវិត នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទ យេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា"

រ៉ូម ៦២:៣


82

អ័ដាមនិងអេវ៉ាបានធ្វើបាប ហើយបាន បំបែកចេញអំពីព្រះ។

ព្រះត្រូវតែដេញពួកគេចេញពីសួនច្បារអេដែន ជាផ្ទះរបស់ពួកគេ ដើម្បីកុំឱ្យគេ បរិភោគផ្លែឈើដឹងខុសត្រូវទៀត។

ថាមពលនៃជីវិតរបស់គេបានត្រូវចុះ ថយ រហូតដល់ពួកគេត្រូវស្លាប់។


83

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ៣:២៤)

"ទ្រង់បណ្តេញមនុស្សចេញ ហើយដាក់ ចេរូប៊ីននៅខាងកើតសួនច្បារអេដែន


84

និងដាវដែលជាអណ្តាតភ្លើងបែរទៅគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត"

លោកុប្បត្តិ ៣:២៤

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


85

ព្រះទ្រង់បានប្រាប់គេពីគំរោងការរបស់ ទ្រង់ដើម្បីសង្គ្រោះដល់ពួកគេ។


86

(ព្រះគម្ពីរ ២រូប លោកុប្បត្តិ ៣:១៥)

"អញនឹងធ្វើឱ្យឯងហើយនិងស្ត្រី គឺទាំង ពូជឯង(អ្នកដែលដើរតាមសាតាំង)និងពូជ នាង (អ្នកដែលដើរតាមព្រះគ្រីស្ទ)


87

មានសេចក្តីខ្មាំងនឹងគ្នា ពូជនាង (ព្រះ យេស៊ូវ)នឹងកិនក្បាលរបស់ឯង(សាតាំង) ហើយឯង(សាតាំង) នឹងចឹកកែងជើងរបស់ (ព្រះយេស៊ូវ) គេ"

លោកុប្បត្តិ ៣:១៥


88

តើកិនក្បាលមានន័យថាយ៉ាងដូចម្តេច?


89

ភាសាហេព្រើរ ពាក្យ "កិន" មានន័យថា "កំទេច"

កិនកំទេចក្បាលអ្នកណាម្នាក់ វាខ្លាំង ជាងចឹកកែងជើងអ្នកណាម្នាក់ ព្រះគ្រីស្ទ គឺជាអ្នកមានជ័យជំនះលើសាតាំង។

ព្រះបានធ្វើការជ្រេងទៀត ដើម្បីរំលឹក មនុស្សនៃផែនការ និងស្តាបនាពួកគេ ឡើងវិញ របស់ទ្រង់។


90

ទ្រង់បានបង្កើតប្រព័ន្ធនៃការបូជាយញ្ញ ពួកគេត្រូវតែបង្ហាញសេចក្តីជំនឿរបស់គេ ចំពោះ "កូនចៀម" នៃព្រះ "ព្រះយេស៊ូវ ដែលថ្ងៃណាមួយទ្រង់នឹងត្រូវសុគតដើម្បី ផ្តល់ជីវិតអស់កល្បដល់ពួកគេ។


91

ព្រះគម្ពីរមិនបានប្រាប់យើងឱ្យបាន ច្បាស់អំពីប្រព័ន្ធនៃការបូជាយញ្ញនេះថា បានចាប់ផ្តើមពីពេលណាមកនោះទេ។

អ័ដាមនិងអេវ៉ាត្រូវបាននៅអាក្រាត ហើយ ព្រះទ្រង់បានធ្វើសំលៀកបំពាក់ឱ្យគេ ពី ស្បែកសត្វ។

នៅក្នុងជំពូកបន្ទាប់ជាប់ពី នោះមក កាអ៊ីននិងអេបិលបានថ្វាយយញ្ញបូជា។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


92

(ព្រះគម្ពីរ ២ រូប លោកុប្បត្តិ ៤:៤,៥)
ហើយអេបិលក៏ធ្វើដូចគ្នា គឺគាត់យក កូនដំបូងពីហ្វូងសត្វមកថ្វាយ ព្រមទាំង ខ្លាញ់ផង


93

រួចព្រះយេហូវ៉ាទ្រង់សព្វព្រះទ័យចំពោះ អេបិល និងដង្វាយរបស់គាត់"
លោកុប្បត្តិ ៤:៤


94

"...មិនសព្វព្រះទ័យចំពោះដង្វាយរបស់ កាអ៊ីនទេ នោះកាអ៊ីនក៏ក្តៅក្រហាយ ហើយ ឡើងទឹកមុខក្រញូវ
លោកុប្បត្តិ ៤:៥
អេបិលបានយកចៀមជាតំណាងឱ្យកូន ចៀមនៃព្រះ ប៉ុន្តែកាអ៊ីនបានយកផ្លែឈើ ពីដើមឈើវិញ។ ដង្វាយរបស់កាអ៊ីនមិនបានបង្ហាញ សេចក្តីជំនឿទៅលើកូនចៀមនៃព្រះទេ។


95

(ព្រះគម្ពីរ ហេព្រើរ ៩:២២)
"...បើគ្មានខ្វាយឈាមទេ នោះគ្មានផ្លូវណា ឱ្យបានរួចពីបាបឡើយ"
ហេព្រើរ ៩:២២


96

នៅពេលដែលព្រះបាននាំយកពួកអ៊ីស្រា អែលចេញពីស្រុកអេស៊ីព្ទ ទ្រង់បាន បង្រៀនគេនូវមេរៀនជាច្រើន ស្តីពីពិធី បុណ្យនៃទីបរិសុទ្ធ ដែលទ្រង់បានឱ្យលោក ម៉ូសេសង់ទីបរិសុទ្ធ ឬរោងឧបោសថដែល បានចម្លង ពីទីបរិសុទ្ធដែលបានដំឡើងនៅ ស្ថានសួគ៌។


97

បុណ្យមួយក្នុងចំណោមបុណ្យទាំងនេះ គឺបុណ្យរំលង


98

នៅថ្ងៃទី១៤ ខែទីមួយ មនុស្សទាំង ឡាយ ត្រូវបានគេបង្គាប់ឱ្យសំឡាប់កូន ចៀម ហើយដាក់ឈាមនៃកូនចៀមនោះ នៅលើក្របទ្វាររបស់គេ នេះគឺជាសញ្ញាមួយ ថា ពួកគេត្រូវបានគ្របបាំងដោយសារ ឈាមនៃកូនចៀម។

៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល



99

យប់ដែលទេវតានៃការបំផ្លាញ បាន ហោះរំលងផ្ទះដែលបានគ្របដោយឈាម ហើយមិនបានធ្វើឱ្យអ្នកណាម្នាក់នៅក្នុងផ្ទះ នោះមានការឈឺចាប់ឡើយ។



100

បុណ្យរំលងគឺជាការរំលឹកដល់ពួកគេថា មានតែឈាមរបស់កូនចៀមទេ ដែលអាចរំដោះគេពីការវិនាសអន្តរាយបាន។

សត្វដែលពួកគេបានបូជាយញ្ញនោះ មិនអាចសំអាតអំពើបាបរបស់គេបានទេ។ ប៉ុន្តែសេចក្តីជំនឿរបស់មនុស្សទៅលើការលះបង់របស់ព្រះ ទើបអាចសង្គ្រោះគេពីបាប បាន។




101

(ព្រះគម្ពីរ ហេព្រើរ ៩:២៦)

"...នោះទ្រង់បានលេចមក១ដង ដើម្បីនឹង លើកអំពើបាបចោល ដោយថ្វាយព្រះអង្គ ទ្រង់វិញ ទុកជាយញ្ញបូជា..."

ហេព្រើរ ៩:២៦




102

(ព្រះគម្ពីរ ហេព្រើរ ១០:៤)

"ដ្បិតឈាមគោឈ្មោល និងពពែឈ្មោល នោះពុំអាចនឹងដោះបាបបានឡើយ"

(ហេព្រើរ ១០:៤)



103

លោកយ៉ូហានបាទីស្ទបានប្រកាសថា ព្រះមែស៊ី ហើយបានចង្អុលទៅព្រះយេស៊ូវ និងនិយាយថា




104

(ព្រះគម្ពីរ យ៉ូហាន ១:២៩)

"...នុះន៏កូនចៀមនៃព្រះដែលដោះបាប មនុស្សលោក"

យ៉ូហាន ១:២៩



105

ប្រព័ន្ធនៃបុណ្យថ្វាយយញ្ញបូជា បាន ចង្អុលបង្ហាញឆ្ពោះទៅរកព្រះមែស៊ី-កូន ចៀមរបស់ព្រះ។

ការបង្ហូរឈាមកូនចៀមដែលស្លាប់ទាំង អស់នៅក្នុងគម្ពីរសញ្ញាចាស់ ដែលមានរាប់សតវត្សរ៍មកហើយនោះ តំណាងឱ្យការបង្ហូរ ព្រះលោហិតរបស់ព្រះយេស៊ូវសម្រាប់ពួក យើង។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


106

ព្រះយេស៊ូវ គឺជាព្រះអង្គសង្គ្រោះនៃ ពិភពលោក។

ព្រះយេស៊ូវអត់ឱនទោស ព្រះយេស៊ូវ រំដោះយើងពីពិរុទ្ធភាព(ភាពមានទោស)

ព្រះយេស៊ូវបង្រៀនយើងអំពីរបៀបរស់ នៅ

ជីវិតរបស់ព្រះយេស៊ូវគឺជាគំរូសម្រាប់ យើង

ព្រះយេស៊ូវប្រទានអំណាចដល់ជីវិតយើង

ព្រះយេស៊ូវបំផ្លាស់បំប្រែយើងពីខាងក្នុង

ព្រះយេស៊ូវប្រទានជីវិតថ្មីដល់យើង


107

នៅក្នុងការប៉ុនប៉ងឆ្លងកាត់មហាសមុទ្រ អង់តាក់ទិករបស់លោកអើរណេស សាក់ ក្លឹតុន នៅឆ្នាំ១៩១៤ កប៉ាល់របស់គាត់ ឈ្មោះអង់ឌូរ៉ង់ បានត្រូវបែកបាក់ដោយ ផ្ទាំងទឹកកក។ ពួកនាវិកបានរសាត់ជាច្រើន ថ្ងៃ ទម្រាំបានចូលមកចតនៅលើកោះដំរី។

សាក់ក្លឹតុន បានឱ្យពួកគាត់បោះតង់នៅ កន្លែងដែលពួកគេអាចថែរក្សាសម្ភារៈរបស់គេបាន ហើយខំប្រឹងប្រែងរស់នៅក្នុងរដូវរងា ដែលនឹងចូលមកដល់។

ប៉ុន្តែគាត់បានដឹងភ្លាមថា គ្មានអ្នកណា អាចនឹងមកជួយសង្គ្រោះគាត់បានទេ។

គ្មានអ្នកណាម្នាក់ដឹងថា ពួកគាត់នៅ ទីណាឡើយ។

ពួកគេត្រូវបានកាត់ផ្តាច់ពីពិភពលោក ដោយព្យុះទឹកកកនៃមហាសមុទ្រអង់តាក់ទិក។

មានសេចក្តីសង្ឃឹមតែមួយគត់ ដើម្បីឱ្យ រួចពីគ្រោះថ្នាក់នោះបានគឺៈ ត្រូវតែមានអ្នក ណាម្នាក់ឆ្លងកាត់ មហាសមុទ្រដែលជា សត្រូវនោះ ហើយជួយពួកគាត់តែប៉ុណ្ណោះ។

លោកសាក់ក្លឹតុន ចាប់ផ្តើមចងក្តោង ទូកក្តោង ដែលមានប្រវែងប្រាំមួយម៉ែត្រ មួយ ដើម្បីបន្តដំណើរទៅទៀត។ ដោយ មានការស្ម័គ្រចិត្ត គាត់បានយកនាវិកស្ម័គ្រ ចិត្ត៦នាក់។

ពួកគេត្រូវធ្វើដំណើរឆ្លងកាត់ឱ្យបាន ១០០០គីឡូម៉ែត្រ លើសមុទ្រដែលមាន ព្យុះសង្ឃរាដ៏ខ្លាំងក្លា ដើម្បីទៅដល់ស្ថានីយ៍ ទូកក្តោងនៃប្រទេសន័រវ៉េ នៅលើកោះ ទឹកកកនៃភាគខាងត្បូងនៃរដ្ឋ ហ្វូចចៀរ។

# ៧.ជីវិតមួយដែលបានបំផ្លាស់ប្រែពិភពលោកទាំងមូល


108

វាហាក់ដូចជាការងារមួយដែលមិនអាច ធ្វើទៅបានឡើយ នៅក្នុងទូកចំហមួយ នា កណ្តាលព្យុះប្រចាំឆ្នាំដ៏ធំបំផុតនេះ។ ប៉ុន្តែ លោកសាក់ឃ្លីតុនបានតាំងចិត្តជាមួយសមាជិក របស់គាត់។

ជាច្រើនថ្ងៃក្រោយមក ពួកគេបានជ្រក នៅក្រោមដំបូលតង់ក្រណាត់បណ្តោះអាសន្ន ដើម្បីទប់ទល់នឹង ក្បាលទូកដែលបែរទៅ រករលកដ៏ខ្លាំងក្លា ដោយអធិស្ឋានសុំកុំឱ្យខ្យល់បំបែកទូកតូចរបស់គេឡើយ។

ពួកគេបានតស៊ូទ្រាំនឹងភាព ត្រជាក់រងា ញាក់ដល់ឆ្អឹងខ្នង ភួយរបស់គេបាន កករឹង ទឹកត្រជាក់ដូចជាទឹកកកបានធ្លាក់ លើខ្នង របស់គេ ក្នុងខណៈដែលគេកំពុង មានការ ស្រេកឃ្លាន។

ដប់បួនថ្ងៃបន្ទាប់ពីការធ្វើដំណើររបស់គេ បានចាប់ផ្តើមមក គេស្ទើរតែស្លាប់ ដោយនៅក្នុងភាពត្រជាក់ និងការស្រេកឃ្លាន។

ពួកគេបានឃើញច្រាំងថ្មចោទពណ៌ខ្មៅនៃហ្សូចចៀរខាងត្បូង!

សាក់ឃ្លីតុន មិនស្លាប់ឡើយ រំពេចនោះ មានកប៉ាល់មួយ កំពុងបានធ្វើដំណើរនៅ លើផ្លូវរបស់វា ដើម្បីទៅជួយសង្គ្រោះអ្នក ដែលជាប់គៀងដែលសេសសល់ដទៃទៀត។

នៅពេលដែលព្រះទតមកមើលស្ថាន ភាពដ៏យ៉ាប់យឺនរបស់យើង ហើយទ្រង់បាន ឃើញថា យើងនៅឯកោ លើកោះរបស់ យើង។ ទ្រង់យាងបោះពួយទៅកាន់សមុទ្រ ដ៏គ្រោះថ្នាក់នោះ ដោយព្រះអង្គឯង។ ទ្រង់បានទទួលរងដោយផ្ទាល់ព្រះអង្គ នូវការពិបាកនឹងទ្រាំក្នុងទឹកកកដ៏ល្វឹងល្វើយនៃអំពើអាក្រក់របស់មនុស្សលោក។


109

គ្មានអ្នកណាម្នាក់ នៅលើលោកសន្និ វាសនេះ ដែលដូចជាព្រះយេស៊ូវនោះ ឡើយ។ ទ្រង់គឺជាព្រះតែមួយអង្គគត់ដែល សង្គ្រោះយើង។ ទ្រង់គឺជាព្រះតែមួយអង្គ គត់ដែលអាចដកចេញនូវកំហុសរបស់ យើង និងផ្លាស់ប្តូរជីវិតយើងបាន។ ទ្រង់គឺជាព្រះតែមួយអង្គគត់ដែលអាចប្រទានជីវិតអស់កល្បដល់យើងបាន។

សូមអញ្ជើញលោកអ្នកលើកដៃឥឡូវនេះ ហើយនិយាយថា "បពិត្រព្រះយេស៊ូវ ទូលបង្គំទទួលទ្រង់ថា ជាព្រះអម្ចាស់ និងជា ព្រះអង្គសង្គ្រោះរបស់ទូលបង្គំនៅពេលយប់ នេះ។ បពិត្រព្រះអង្គ ទូលបង្គំជឿថា ទ្រង់សុគតដើម្បីទូលបង្គំ។ ពពិត្រព្រះអង្គ ទូលបង្គំសូមថ្វាយជីវិតដល់ព្រះអង្គ"

សូមគ្រាន់តែលើកដៃនៅពេលដែលខ្ញុំ អធិស្ឋានជូនលោកអ្នកនេះ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



1

អាថ៌កំបាំងនៃជីវិតអស់កល្ប



2

(វីដេអូ ១៩វិនាទី)ផែនដីបានរញ្ជួយ។ ភាព កក្រើកដ៏មានអំណាចយ៉ាងខ្លាំងក្លា បាន បញ្ជូនរលករញ្ជួយពាសពេញទីក្រុងទាំង មូល។ អាគារការិយាល័យជាច្រើនបាន ត្រូវរលំ និងផ្ទះជាច្រើនខ្ទងបានត្រូវបាក់បែកខ្ទេចខ្ទី។ មន្ទីរពេទ្យ សាលារៀន និង ព្រះវិហារទាំងអស់ត្រូវបានបំផ្លាញ។

ការរញ្ជួយផែនដីក្នុងខែកុម្ភៈ ឆ្នាំ២០០១ នៅអាល់សាវ៉ាឌ័រ បានសម្លាប់មនុស្ស ៣០០០នាក់ភ្លាមៗ។ មនុស្សរាប់ពាន់នាក់ គ្មានផ្ទះសំបែង។ អ្នកធ្វើការផ្តល់ជំនួយ បន្ទាន់ បានធ្វើការដោយគ្មានខ្លាចនឿយហត់ ទាំងយប់ទាំងថ្ងៃ ដើម្បីស្វែងរកជន រងគ្រោះ។ ពួកគេបានរកឃើញមនុស្ស ដែលបានរស់នៅតែពីរបីនាក់ប៉ុណ្ណោះ។

បន្ទាប់ពីការបន្តជីករកអស់រយៈពេលបួន ថ្ងៃមក គេបានរៀបចំបញ្ឈប់ការរុករករបស់ពួកគេទៅហើយ នៅពេលដែលពួកគេម្នាក់ បានកត់សំគាល់ឃើញមានដៃ ពាក់កណ្តាលមួយបានលេចឡើង ពិក្នុងស្នូរសំឡេងយ៉ាង អឺងកង។

ផែនដីរញ្ជួយកាន់តែខ្លាំងឡើង នៅ ពេលដែលដៃនោះបានកំរើកឡើងយ៉ាង យឺតៗ។ អ្នកជួយសង្គ្រោះបានជីកយ៉ាងអស់ ទំហឹង។

ពួកគេត្រូវចំណាយពេលជិតមួយម៉ោង ដើម្បីស្តារយកបុរសវ័យកណ្តាលម្នាក់ពីក្រោមកំទេចកំទីនោះ។

បុរសនោះមានជីវិតនៅឡើយ។ គាត់ បានរស់នៅដោយគ្មានអាហារនិងទឹកអស់រយៈពេលបួនថ្ងៃ។ ក្រោយមកនៅមន្ទីរពេទ្យ គាត់ត្រូវបានគេសួរថា តើគាត់អាចរស់នៅក្រោមស្ថានភាពដ៏សែនពិបាកអស្ចារ្យនេះបានយ៉ាងដូចម្តេច?

គាត់បានឆ្លើយថា "ខ្ញុំចង់រស់"។ ខ្ញុំបាន ដង្ហក់រកខ្យល់។ ខ្ញុំមិនចង់ស្លាប់ទេ ខ្ញុំបាន ជឿជាក់ថានឹងមានជំនួយមកដល់"


3

យើងបានកើតមកជាមួយនឹងសេចក្តីប៉ង ប្រាថ្នាឱ្យបានរស់នៅ។

អ្នកនិងខ្ញុំមានសេចក្តីប៉ងប្រាថ្នានេះ នៅ ពេលដែលយើងបានចូលមកក្នុងលោកីយ៍ នេះ។

មនុស្សគ្រប់ៗគ្នា ដែលរស់នៅលើផែន ដី ត្រូវតែមានសេចក្តីប៉ងប្រាថ្នានេះ។

វាប្រហែលជាសេចក្តីប៉ងប្រាថ្នាដ៏ខ្លាំង បំផុតដែលយើងមិនធ្លាប់មាន។

យើងជាមនុស្សជាតិ ត្រូវបានចងភ្ជាប់ ជាមួយគ្នា ដោយសេចក្តីប៉ងប្រាថ្នារួមមួយ នេះ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



4

ហើយនៅពេលដែលជីវិតមនុស្សត្រូវ បានជួបប្រទះនឹងគ្រោះថ្នាក់ដល់ជីវិត អ្នកដទៃតែងតែធ្វើកិច្ចការធំហួសវិស័យផ្សេងៗ ដើម្បីជួយសង្គ្រោះអ្នកនោះ។ វាហាក់ដូចជាក្មេងម្នាក់ដែលបានធ្លាក់ចូលទៅក្នុងអណ្តូង។ ឬមួយក៏មនុស្សនៅក្នុងនាវាដ៏បាក់បែកមួយដែលបានជាប់គៀងនៅកណ្តាលសមុទ្រ។



5

ឬមួយក៏ដូចអ្នកឡើងភ្នំម្នាក់បានគាំងដំណើរ នៅច្រមុះភ្នំដ៏មានគ្រោះថ្នាក់។
ឬដូចជាអ្នករងគ្រោះដែលបានជាប់អន្ទាក់ នៅក្នុងគំនរបាក់បែកនៃការរញ្ជួយផែនដី។
ប៉ុន្តែនៅពេលដែលជីវិតរបស់អ្នកណាម្នាក់នៅក្នុងភាពស្ទើររស់ស្ទើរស្លាប់ មនុស្សប្រណាំងប្រជែងគ្នាទៅជួយដល់អ្នកនោះ។



6

នៅមានសេចក្តីពិតមួយ ដែលគ្មានអ្នក ណាម្នាក់ក្នុងចំណោមពួកយើង ចង់គិតគូរ ដល់នោះទេ. ប៉ុន្តែវាគឺជាការពិត ដែលជីវិត ចុងក្រោយបង្អស់របស់យើងម្នាក់ៗស្ថិតនៅក្នុងភាពគ្រោះថ្នាក់នេះ។
មិនមែនត្រឹមតែគ្រោះថ្នាក់ធម្មតាទេ ប៉ុន្តែយើងម្នាក់ៗត្រូវបានផ្តន្ទាទោសដល់ ស្លាប់។




7

(ព្រះគម្ពីរ រ៉ូម ៦:២៣)
"ដ្បិតឈ្នួលនៃអំពើបាប គឺសេចក្តីស្លាប់ តែឯអំណោយទាននៃព្រះវិញ គឺជាជីវិតអស់ កល្បដោយសារព្រះគ្រីស្ទយេស៊ូវ ជាព្រះ អម្ចាស់នៃយើងរាល់គ្នា"
រ៉ូម ៦:២៣



8

អំពើបាបគឺជាសារជាតិពុល.វាធ្វើឱ្យ ស្លាប់។ វាបណ្តាលឱ្យស្លាប់។
តើហេតុអ្វី? ពីព្រោះវាបានបំបែកយើង ពីប្រភពនៃជីវិតទាំងស្រុង.គឺព្រះដែលបាន បង្កើតយើង។
ហើយយើងម្នាក់ៗបានធ្វើបាប




9

(ព្រះគម្ពីរ រ៉ូម ៣:២៣)
"ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិន ដល់សិរីល្អនៃព្រះ"
រ៉ូម ៣:២៣




10

(ព្រះគម្ពីរ រ៉ូម: ៣:១០.១២)
"...គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ ក៏គ្មានផង

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


11

គ្មានអ្នកណាដែលយល់ គ្មានអ្នកណា ដែលស្វែងរកព្រះ


12

គ្រប់គ្នាបានបែរចេញ... គ្មានអ្នកណាដែល ប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ តែម្នាក់ ក៏គ្មានផង"
រ៉ូម ៣:១០_១២


13

លោកអ័ដាមនិងនាងអេវ៉ា ជាឪពុកនិង ម្ដាយដើមរបស់យើង ដែល ពូជមនុស្ស ទាំងអស់បានកើតពីគាត់មកនោះ បានជ្រើស រើសកាត់ ផ្ដាច់ខ្លួនឯងចេញ ពីព្រះ ដោយមិនស្ដាប់បង្គាប់ទ្រង់ ហើយបានដើរ តាមផ្លូវរបស់ខ្លួនឯងវិញ។


14

(ព្រះគម្ពីរ រ៉ូម ៥:១២)
"ដូច្នេះដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មាន សេចក្ដីស្លាប់ចូលមកដែរ


15

ដោយសារអំពើបាបនោះជាយ៉ាងណា នោះ សេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្ស គ្រប់គ្នាយ៉ាងនោះដែរ"
រ៉ូម ៥:១២


16

លទ្ធផលធម្មជាតិនៃអំពើបាបគឺ សេចក្ដី ស្លាប់។
តម្លៃនៃសេចក្ដីស្លាប់កើតមកពីអំពើបាប ១០០ភាគរយ
លោកអ័ដាមត្រូវស្លាប់ដោយសារតែអំ ពើបាបរបស់គាត់។
យើងទាំងអស់គ្នា ដែលជាខ្សែស្រឡាយ របស់គាត់ក៏ដូចគ្នាដែរ គឺរាប់បញ្ចូលទាំង យើងម្នាក់ៗគ្រប់គ្នាផង។


17

ដូច្នេះយើងទាំងអស់គ្នាចូលទៅក្នុងរណ្ដៅ
ជាប់អន្ទាក់ និងអស់សង្ឃឹម។
ត្រូវផ្ដន្ទាទោសដល់ស្លាប់ ទាល់តែមាន អ្នកណាម្នាក់មកជួយយើង។
ដំណឹងដ៏អាក្រក់នោះគឺថា យើងត្រូវប្រ ឈមមុខរហូត លុះត្រាតែមានអ្នកណាម្នាក់ មកជួយសង្គ្រោះយើង។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


18

(ព្រះគម្ពីរ អេភេសូរ ២:៨,៩)

ដ្បិតគឺដោយសារព្រះគុណ ដែលអ្នក រាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដី ជំនឿ ហើយសេចក្ដីនោះក៏មិនមែន កើតពី អ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ ព្រះវិញ


19

ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នក រាល់គ្នាអួតខ្លួន

អេភេសូរ ២:៨,៩

មែនហើយ យើងទាំងអស់គ្នាមានបាប។

គ្មានអ្វីដែលត្រូវសង្ស័យពីរឿងនេះឡើយ។

យើងមានបាប ដោយសារគ្រប់សកម្មភាព គ្រប់ពាក្យសំដី ឬសូម្បីតែគំនិតផងដែរ។



20

សូមពិចារណាមើល យើងបានធ្វើបាប ជាច្រើនដងរាប់មិនអស់ ក្នុងមួយថ្ងៃៗ!

បញ្ហារបស់យើងនោះ មិនមែនគ្រាន់ តែជាអំពើបាបដែលយើងបានប្រព្រឹត្តនោះទេ-

វាគឺជាការពិតដែលថា យើងជាមនុស្ស មានបាប!


21

មនុស្សដែលមានជម្ងឺជិតស្លាប់ ហើយ មិនបានដឹងអំពីបញ្ហានៃជម្ងឺរបស់ខ្លួន ឬក៏ ស្វែងរកថ្នាំសង្កូវមកព្យាបាលទេនោះ មុខ តែនឹងត្រូវស្លាប់ជាមិនខាន។

ហើយចំណែកឯសេចក្ដីស្លាប់របស់អ្នក មានបាប ដែលមិនព្រមទទួលស្គាល់ លក្ខណ:ខាងព្រលឹងវិញ្ញាណរបស់ខ្លួន និង ស្វែងរកជំនួយវិញនោះ ក៏បែបដូច្នោះដែរ។


22

(ព្រះគម្ពីរ អេសាយ ៥៩:២)

"គឺជាអំពើទុច្ចរិត(បាប)របស់ឯងរាល់គ្នា ដែលបានខណ្ឌជាកណ្ដាលឯង ហើយនិង ព្រះនៃឯងទេតើ"

អេសាយ ៥៩:២។

ព្រះគឺជាប្រភពនៃជីវិតទាំងអស់ ហើយ នៅពេលដែលលោកអ័ដាមមានបាប គាត់ ក៏ចាប់ផ្ដើមទទួលនូវសេចក្ដីស្លាប់។

ប៉ុន្តែព្រះនៃសេចក្ដីស្រឡាញ់ មិនគ្រាន់ តែបានប្រាប់យើង អំពីលទ្ធផលនៃអំពើ បាប ដែលធ្វើឱ្យយើងបាត់បង់នូវសេចក្ដី សង្ឃឹមប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានប្រាប់ យើងអំពីសេចក្ដីសង្គ្រោះផងដែរ!

នេះគឺជាដំណឹងល្អ!

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



23

(ព្រះគម្ពីរ រ៉ូម ៦:២៣)
"ដ្បិតឈ្នួលនៃអំពើបាបគឺជាសេចក្ដីស្លាប់ តែឯអំណោយទាននៃព្រះវិញ គឺជាជីវិតអស់ កល្ប ដោយសារព្រះគ្រីស្ទយេស៊ូវ ជាព្រះ អម្ចាស់នៃយើងរាល់គ្នា"
រ៉ូម ៦:២៣



24

(វីដេអូ ៣វិនាទី) សេចក្ដីសង្គ្រោះគឺជាអំ ណោយទាន ដែលយើងមិនសមនឹងទទួល ឡើយ។
ឬមួយក៏យើងអាចរកបានដោយអំពើល្អ របស់យើងនោះឡើយ។
ហើយយើងក៏មិនអាចទិញជូរវាបានដែរ ទោះជាឱ្យថ្លៃប៉ុន្មានក៏ដោយ។


25

មនុស្សភាគច្រើនជឿថា មនុស្សលោក ទាំងអស់ ទទួលការអត់ឱនទោស និងជីវិតអស់កល្បដោយបានធ្វើការល្អច្រើន។
មនុស្សអង្គុយនៅលើគ្រែដែកគោល ដោយជឿថា ការធ្វើទារុណកម្មលើរាង កាយរបស់គេបែបនេះ អាចធ្វើឱ្យគាប់ព្រះ ហឫទ័យរបស់ព្រះបាន។


26

មនុស្សខ្លះវាយ និងធ្វើឱ្យមានស្នាមរបួស ខ្លួនឯងដោយរំពាត់ និងច្រវាក់ អ្នកខ្លះទៀតចាក់ខ្លួនឯងដោយទំពក់ស្រួចៗ និង


27

អ្នកខ្លះទៀតធ្វើដំណើរដោយជើងទទេនៅលើ រងើកភ្លើងដ៏ក្ដៅ ដើម្បីស្វែងរកការគាប់ព្រះហឫទ័យដល់ព្រះអាទិទេព ដោយ សកម្មភាពនៃការធ្វើទារុណកម្មលើរាងកាយរបស់គេខុសពីធម្មតា។


28

អ្នកខ្លះទៀតជឿថា គេអាចទទួលបុណ្យ កុសលសម្រាប់អនាគត ដោយសាងសង់ ព្រះវិហារ ឬជូនអាហារដល់អ្នកបរិសុទ្ធ


29

ហើយអ្នកខ្លះទៀត មិនអាចស្វែងរកការ គាប់ ព្រះហឫទ័យព្រះណា ដែលធំជាង ឬប្រសើរជាងការធ្វើធម្មយាត្រាទៅកាន់ មេកា ឬក៏ស្លាប់នៅក្នុងការការពារសាសនា នោះឡើយ

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


30

គ្រីស្ទានជាច្រើនបានធ្វើកិច្ចការទាំងនេះ ដោយមិនដឹងខ្លួន។

ពួកគេបានចូលមកព្រះវិហារ ដាក់ ដង្វាយ និងដើរតាមច្បាប់មាសក្នុងព្រះគម្ពីរ ដោយគិតថា គេអាចស្វែងរកការគាប់ព្រះ ទ័យដល់ព្រះបាន ហើយនិងត្រូវបានទទួល ជីវិតអស់កល្ប។

ប៉ុន្តែតើការនេះអាចកើតមានឡើងបាន មែនឬទេ?


31

តើមនុស្សអាចសូកព្រះ ដើម្បីឱ្យទ្រង់ប្រ ទានការអត់ឱនទោស និងជីវិតអស់កល្ប ដោយធ្វើទណ្ឌកម្មខ្លួនឯង ការសង្រួមចិត្ត ឬក៏អំពើសប្បុរសណាមួយនោះបានដែរឬទេ?


32

តើយើងអាចរកសេចក្ដីសង្គ្រោះបាន ដូចអ្នកកីឡាដែលឈ្នះ ហើយបានទទួល ជ័យលាភីឬ មេដាយបានដែរឬទេ?


33

(ព្រះគម្ពីរ អេភេសូរ ២:៨,៩)

ព្រះគម្ពីរនិយាយថា "ដ្បិតគឺដោយសារ ព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះ មិនមែនកើតមកពីអ្នករាល់គ្នាទេ គឺជាអំ ណោយទានរបស់ព្រះវិញ


34

ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នក រាល់គ្នាអួតខ្លួន"

អេភេសូរ ២:៨,៩។


35

យើងមិនអាចសង្គ្រោះខ្លួនឯង ដោយ ការងាររបស់យើងបានទេ

យើងត្រូវតែពឹងទៅលើព្រះគុណរបស់ ព្រះ និងសេចក្ដីស្រឡាញ់ ព្រមទាំងការ គាប់ព្រះទ័យរបស់ទ្រង់ ដែលទ្រង់ពិតជា នឹងដោះលែងយើងឱ្យមានសេរីភាព។

ប្រសិនបើយើងអាចរកសេចក្ដីសង្គ្រោះដោយខ្លួនឯងបាននោះ វាមិនមែនជាអំណោយទេ។


36

ឧបមាថា នយោជករបស់អ្នក ឱ្យ ស្រោមសំបុត្រមួយមកអ្នក ហើយបាន និយាយថា គាត់មានអំណោយសម្រាប់អ្នក។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


37

ប្រសិនបើអ្នកឃើញថា នេះជាប្រាក់ ឈ្នួលរបស់អ្នកសម្រាប់ការងារពីរអាទិត្យមុន នៅក្នុងស្រោមសំបុត្រនោះ តើនោះវាជា អំណោយដល់អ្នកឬទេ?

ទេមិនមែនជាអំណោយទេ ពីព្រោះវាគឺ ជាប្រាក់ដែលអ្នករកបានទេតើ!


38

ប៉ុន្តែតើហេតុអ្វីបានជាព្រះដ៏មានព្រះ ចេស្ដា ដែលគ្រប់គ្រងលោកសន្និវាសនេះ



39

(វីដេអូ ១២វិនាទី) បានយកព្រះទ័យទុក ដាក់ដល់មនុស្ស នៅលើភពមួយនា ឮដ៏ចុងអវកាសនេះខ្លាំងម្ល៉េះ?

តើហេតុអ្វីបានជាទ្រង់បោះបង់ មនុស្ស ដែលអាត្មានិយម និងបះបោរ ហើយទុក គេឱ្យទទួលរងនូវលទ្ធផលរបស់អំពើបាបដូ

ច្នេះ?


40

(ព្រះគម្ពីរ យ៉ូហានទី១ ៤:៨)

ចម្លើយត្រូវបានរកឃើញនៅក្នុងសំបុត្រ ទី១របស់លោកយ៉ូហាន:

"ព្រះគឺជាសេចក្ដីស្រឡាញ់"

យ៉ូហានទី១ ៤:៨


41

លោកអ្នកខ្លះជាឪពុកម្ដាយ

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


42

ហើយលោកអ្នកខ្លះដឹងថា តើវាមាន អារម្មណ៍យ៉ាងណា នៅពេលដែលមាន កូនតូចម្នាក់មានជម្ងឺ ហើយចាប់ផ្តើមយំ ទាំងយប់ទាំងថ្ងៃនោះ។

លោកអ្នកនឹងខំប្រឹងប្រែងរកគ្រប់វិធី ដើម្បីធ្វើឱ្យជម្ងឺនេះគ្រាន់បើឡើង ប៉ុន្តែ ហាក់ដូចជាគ្មានអ្វីដែលអាចជួយលោកអ្នក បានសោះ។

អ្នកគោះកម្រាលក្តារ ឬឥដ្ឋ អ្នកច្រៀង បំពេរ និងសាកល្បងនូវគ្រប់មធ្យោបាយ ទាំងឡាយ ដែលមិត្តភ័ក្តិរបស់លោកអ្នក ផ្តល់ឱ្យ ប៉ុន្តែគ្មានអ្វីមួយបានការសោះ។

ប៉ុន្តែខ្ញុំសូមសួរលោកអ្នកអំពីរឿងមួយ។

មិនថា អ្នកបានប្រឹងប្រែងយ៉ាងណាទេ មិនថា ទារកនោះឈឺយូរប៉ុនណាទេ តើ លោកអ្នកដែលគិតថា ទុកឱ្យទារកនោះនៅ ឆ្ងាយពីលោកអ្នក ឬក៏ទុកវាឱ្យនៅរងទុក្ខ វេទនាតែម្នាក់ឯងឬទេ?


43

ទេ! ព្រោះអ្វី? ពីព្រោះលោកអ្នកស្រ ឡាញ់ទារកតូច ដែលមិនអាចជួយបាន សោះនោះ លើសពីនេះទៅទៀត ដោយ សារការឈឺចាប់ និងការរងគ្រោះដែលទារក នោះត្រូវរងទ្រាំ។

ចំណែកព្រះ ក៏បែបដូច្នោះដែរ!


44

កូនរបស់ទ្រង់នៅលើភពផែនដីនេះ បានក្លាយទៅជាឈឺ ដោយសារជម្ងឺនៃអំពើ បាប។


45

ហើយពីព្រោះតែការឈឺចាប់ និងការរងទុក្ខ ទោសដែលពួកគេត្រូវរងទ្រាំ ធ្វើឱ្យសេចក្តី ស្រឡាញ់របស់ព្រះចំពោះពួកគេ មានកាន់ តែខ្លាំងថែមទៀត


46

ព្រះមិនដែលគិតថា គ្រាន់តែយាងចេញ ឱ្យឆ្ងាយពីយើងទៅប៉ុណ្ណោះទេ!

ព្រះអង្គមិនដែលគិតថា ទុកយើង ចោលឱ្យស្លាប់ និងរងទុក្ខទោស ដែលជា លទ្ធផលនៃការបះបោររបស់យើងនោះទេ។


47

(ព្រះគម្ពីរ ពេត្រុសទី២ ៣:៩)

ព្រះគម្ពីរនិយាយថា "ព្រះអម្ចាស់ មិន... គឺទ្រង់មានព្រះហឫទ័យអត់ធ្មត់នឹង យើងរាល់គ្នាវិញ ដោយមិនចង់ឱ្យអ្នកណា មួយវិនាសឡើយ គឺចង់ឱ្យមនុស្សទាំងអស់ ប្រែចិត្តវិញ" ពេត្រុសទី២ ៣:៩

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


48

មិនទាក់ទងទៅនឹងអ្នកល្អឬអាក្រក់នោះទេ
ព្រះស្រឡាញ់អ្នក និងចង់សង្គ្រោះអ្នក។
ព្រះអង្គមិនដែលមានបំណងចង់ទុកអ្នក ឱ្យស្លាប់នោះទេ។


49

ទោះបីជាយើងទាំងអស់គ្នាមានបាប។
យើងទាំងអស់គ្នាបានបះបោរប្រឆាំងនឹង ទ្រង់ ហើយបានធ្វើខុសនឹងបញ្ញត្តិរបស់ទ្រង់ ក៏ដោយ


50

រដ្ឋាភិបាលលោកីយ៍ មិនអាចនឹង សម្របសម្រួលភាពគ្មានច្បាប់បានទេ ព្រម
ទាំងមិនអាចមានជីវិតទៅ បានយូរអង្វែង ដែរ។


51

អ្នកដែលប្រព្រឹត្តល្មើសនឹងច្បាប់ ត្រូវ តែបានគេផ្តន្ទាទោស។
ប៉ុន្តែការល្មើសទៅនឹងច្បាប់របស់ព្រះ នោះ វាធ្ងន់ធ្ងរជាងនោះទៅទៀត ព្រោះ
អំពើបាបបែងចែកយើងចេញពីព្រះ តែ មួយអង្គគត់ ដែលអាចជួយយើង និង សង្គ្រោះយើងបាន!


52

ទោះជាទ្រង់ជាព្រះនៃសេចក្តីស្រឡាញ់ ដ៏អស់កល្បក៏ដោយ ក៏ទ្រង់ជាព្រះនៃសេចក្តី យុត្តិធម៌ដែរ។
នៅលើភ្នំស៊ីណាយ ទ្រង់បានពិពណ៌នា ដោយព្រះអង្គផ្ទាល់ថា:


53

(ព្រះគម្ពីរ និក្ខមនំ ៣៤:៦,៧)
"...យេហូវ៉ាដ៏ជាព្រះ ទ្រង់មានព្រះ ហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់
ហើយមានសេចក្តី សប្បុរស និងសេចក្តីទៀងត្រង់ជាបរិបូរ


54

ទ្រង់មានសេចក្តីមេត្តាករុណាដល់មនុស្សទាំងពាន់ ក៏អត់ទោសចំពោះសេចក្តីទុច្ចរិត សេចក្តីរំលង
និងអំពើបាប ប៉ុន្តែទ្រង់មិន រាប់មនុស្សមានទោស ទុកជាឥតទោស ឡើយ"
និក្ខមនំ ៣៤:៦,៧

៨. បង្កើតមកដើម្បីរស់នៅរៀងរហូត

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


55

តើគ្មានដំណោះស្រាយណាទេឬ? គ្មាន ច្រកចេញទេឬ?

មែនហើយ ពិតជាមានច្រកចេញ!

ព្រះនៃសេចក្តីស្រឡាញ់មួយអង្គ ទ្រង់ បានរកឃើញផ្លូវដើម្បីជួយសង្គ្រោះយើង ហើយនៅតែយុត្តិធម៌ដដែល។


56

ទ្រង់បានរកឃើញការជំនួសដ៏ល្អឥតខ្ចោះ ដោយសុគតជំនួសយើង បង់ថ្លៃលោះ សម្រាប់អំពើបាបរបស់យើង ដើម្បីឱ្យយើង អាចនៅរស់បាន។

លោកយ៉ូហាន សិស្សជាទីស្រឡាញ់ របស់ទ្រង់ បានពន្យល់យ៉ាងដូច្នេះ:


57

(ព្រះគម្ពីរ យ៉ូហាន ៣:១៦)

“ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១


58

ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ”

យ៉ូហាន ៣:១៦


59

ព្រះយេស៊ូវបានយាងមករស់នៅជា មនុស្សនៅលើផែនដីនេះ ដោយប្រឈម មុខនឹងបញ្ហា និងសេចក្តីល្បួង ដូចមនុស្ស គ្រប់គ្នាបានជួបប្រទះដែរ។

ទ្រង់បានរស់នៅជាជីវិតមួយដែលស្តាប់ បង្គាប់ឥតខ្ចោះ។

ពេលនោះ ក្នុងខណៈដែលអ្នកគ្មានបាប ម្នាក់ ជាតំណាងឱ្យពូជមនុស្ស គឺព្រះគ្រីស្ទ បានទទួលបាបរបស់មនុស្សគ្រប់គ្នាយកមក

ដាក់លើ អង្គទ្រង់ដោយស្ម័គ្រព្រះទ័យ ដែល រស់នៅលើផែនដីនេះ ហើយសុគតជំនួស ពួកគេ។


60

(ព្រះគម្ពីរ រ៉ូម ៥:១៩)

លោកប៉ុលបានសរសេរថា “ដ្បិតដូចជា មនុស្សជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់ មិនបានស្តាប់ បង្គាប់ជាយ៉ាងណា


61

នោះមនុស្សជាច្រើនក៏បានត្រឡប់ជាសុចរិត ដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះ ដែរ”

រ៉ូម ៥:១៩

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


62

ការសុគតរបស់ព្រះយេស៊ូវ មិនមែន បានបំរុងទុកដើម្បីឱ្យស្កប់ព្រះទ័យដល់ព្រះ
ដែលមានសេចក្តីក្រោធនោះទេ។
ព្រះយេស៊ូវសុខចិត្តសុគត ដើម្បី សង្គ្រោះយើងពីអំពើបាបរបស់យើង
ហើយព្រះបានស្រឡាញ់យើងជាខ្លាំង បាន ជាព្រះអង្គសព្វព្រះហឫទ័យលះបង់ព្រះរាជ
បុត្រាទ្រង់តែមួយ ដើម្បីយើងទាំងអស់គ្នា។
ព្រះយេស៊ូវ គឺជាកូនចៀមរបស់ព្រះ ជា កូនចៀមសម្រាប់បូជាយញ្ញ!



63

(វីដេអូ ២៥វិនាទី) នៅពេលពួកអ្នកដែល ព្រះបានជ្រើសរើស គឺពួកអ៊ីស្រាអែលបាន
ដើរដោយគ្មានទីកំណត់ នៅក្នុងវាលរហោ ស្ថានជិតភ្នំស៊ីណាយ បន្ទាប់ពីបានរំដោះ
ចេញពីស្រុកអេស៊ីព្ទ ដោយលោកម៉ូសេមក នោះ ពួកគេបានឃើញជារៀងរាល់ថ្ងៃ នូវ និមិត្តរូប
ពិធីផ្សេងៗនៃការបកស្រាយមួយ អំពីផែនការរបស់ព្រះ ដើម្បីប្រោសលោះ មនុស្ស
ដែលបានធ្លាក់ចុះ។ ទីបរិសុទ្ធនៅ វាលរហោស្ថាន ត្រូវបានសង់ឡើងដើម្បី
បង្ហាញការណែនាំយ៉ាងជាក់លាក់របស់ព្រះ អំពីការងារដែលព្រះបានចាត់តាំងឡើង
ដើម្បីទាក់ទាញមនុស្ស អោយយកចិត្តទុក ដាក់ជាបន្ត ឆ្ពោះទៅរកអនាគតនៃភ្នំ
រលាក្បាល(កាលវ៉ារី)ជាកំពូល ភ្នំដែលព្រះ យេស៊ូវបានសុគតនៅទីនោះ ជាទីកន្លែង
ដែលកូនចៀមពិតប្រាកដត្រូវបានគេបូជាយញ្ញ ព្រោះតែអំពើបាបរបស់មនុស្សគ្រប់ៗគ្នា
ដោយផ្តល់នូវសេចក្តីសង្ឃឹមទាំងអស់  និង ការធានារ៉ាប់រងនូវការអត់ឱនទោស និង
សេចក្តីសង្គ្រោះ។


64

អ្នកមានបាបបានចូលមកដោយបាននាំ យកសត្វសម្រាប់បូជាយញ្ញមក ជាមួយផង។
ពួកគេបានដាក់ដៃលើសត្វនោះ ហើយ លន់តួបាបរបស់គេ។
រួចយកកាំបិតមកសម្លាប់សត្វនោះទៅ ជានិមិត្តរូបថា បាបរបស់គេបានធ្វើឱ្យស្លាប់
ដល់កូនចៀមសម្រាប់បូជាយញ្ញ ដែលបាន តំណាងដោយព្រះយេស៊ូវនោះ ។


65

មិនគួរឱ្យចូលចិត្តឡើយ បាទ ប៉ុន្តែឈើ ឆ្កាងនៅភ្នំរលាក្បាល(កាលវ៉ារី) ដែលបាននាំមកនូវសេចក្តី
សន្យានៃជីវិតអស់កល្ប ដល់ចិត្តមនុស្ស នោះ មិនគួរឱ្យចូលចិត្តជាងនោះទៅទៀត
ទោះបីជាយ៉ាងនេះក៏ដោយ ដោយសារ សកម្មភាពនេះ ព្រះបានបង្ហាញឱ្យឃើញថា
អំពើបាបបាននាំមកនូវសេចក្តីស្លាប់ ដល់ ទាំងអ្នកមានបាប និងដល់សត្វដែលឥត មានកំហុស
ដែលគេយកមកបូជាយញ្ញនោះ។


66

រាស្ត្ររបស់ព្រះ នៅសម័យព្រះគម្ពីរ បានថ្វាយយញ្ញបូជា ដើម្បីបង្ហាញសេចក្តីជំ នឿរបស់ពួកគេ
ទៅលើការសុគតនៅពេល អនាគតខាងមុខរបស់ព្រះរាជបុត្រានៃព្រះ
ជាអ្នកដែលត្រូវសុគតជំនួសមនុស្ស ដើម្បី ជាថ្លៃរបស់ពួកគេ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



67

(ព្រះគម្ពីរ យ៉ូហាន ១:២៩)

ព្រះយេស៊ូវគឺជាយញ្ញបូជាពិត។ នៅ ពេលដែលព្រះយេស៊ូវបានមកទទួលបុណ្យ ជ្រមុជទឹក លោកយ៉ូហានបាននិយាយថា "...នុះន៎ កូនចៀមនៃព្រះ ដែលដោះបាប មនុស្សលោក" យ៉ូហាន១:២៩

ចម្លែកណាស់ដោយមានមនុស្សខ្លះដែលទ្រង់បានយាងមកសង្គ្រោះ រៀបគម្រោងការ ដើម្បីយកព្រះជន្មទ្រង់ ទៅវិញ!

ព្រះយេស៊ូវបានត្រូវគេវាយដំ គេសើចចំអក ហើយត្រូវបានកាត់ទោសឱ្យជាប់ឆ្កាង ជារបៀបសម្លាប់មនុស្សមួយ ដ៏កាចសាហាវជាទីបំផុត។



68

(ព្រះគម្ពីរ ពេត្រុសទី១ ២:២២)

ដូចដែលព្រះគម្ពីរនិយាយថា ទ្រង់ "មិនបានធ្វើបាបអ្វីសោះ ក៏មិនឃើញមាន កិច្ចកលអ្វី នៅព្រះឱស្ឋទ្រង់ឡើយ" ក៏ទ្រង់នៅ តែសុគតនៅលើឈើឆ្កាង!

ពេត្រុសទី១ ២:២២



69

ព្រះគ្រីស្ទត្រូវបានជាប់ឆ្កាងនៅរដូវបុណ្យ រំលង។ ជាទម្លាប់របស់អ្នកដឹកនាំប្រទេស រ៉ូម នៅរដូវនោះ គេតែងលែងអ្នកទោស ឧក្រិដ្ឋម្នាក់ ជាការបង្ហាញអំពីសេចក្ដីជំនឿ។ ហ្វូងមនុស្សបានជ្រើសយកបារ៉ាបាស ហើយទុកឱ្យព្រះយេស៊ូវសុគតជំនួសវិញ



70

ព្រះយេស៊ូវបានសុគតជំនួសអ្នកមានបាប

ទ្រង់បានត្រូវជាប់ឆ្កាងនៅកណ្ដាលចោរពីរ នាក់!

ហើយនៅពេលនោះព្រះបានដាក់អំពើ បាបរបស់មនុស្សក្នុងលោកីយ៍ទាំងមូលលើ ទ្រង់។



71

(ព្រះគម្ពីរ ម៉ាថាយ ២៧:៤៦)

ទ្រង់បានស្រែកថា "ព្រះអង្គ ព្រះអង្គ នៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោល ទូលបង្គំ?" ម៉ាថាយ ២៧:៤៦

ទ្រង់បានជ្រាបអំពីការបំបែក ដ៏អាក្រក់ អាក្រី ដែលបាបបាននាំមក។ ព្រះយេស៊ូវ មិនអាចបញ្ចេញនូវការឈឺចាប់យ៉ាងខ្លាំងនៃ ការបំបែកពីព្រះវរបិតាបានឡើយ។ វាបានធ្វើឱ្យទ្រង់ឈឺចុកចាប់ក្នុងព្រះទ័យយ៉ាងខ្លាំង។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


72

(ព្រះគម្ពីរ ម៉ាកុស ១៥:៣១)

ហ្វូងមនុស្សបានស្រែកថា "...វាជួយ សង្គ្រោះដល់មនុស្សឯទៀតបាន តែពុំអាច នឹងសង្គ្រោះចំពោះខ្លួនឯងបានទេ"
ម៉ាកុស ១៥:៣១


73

ហើយនោះគឺជាការពិត!

ទ្រង់មិនអាចជួយព្រះអង្គឯងបានទេ តែអាចជួយអ្នកដទៃបាន។

ទ្រង់គឺជាអ្នកចេញថ្លៃលោះរបស់ព្រះ សម្រាប់មនុស្សបាត់បង់ អ្នករំលោភច្បាប់ គឺជាឈ្នួលនៃអំពើបាប។

ដូច្នេះព្រះអង្គដែលពោរពេញទៅដោយ សេចក្តីស្រឡាញ់ ដែលមិនអាចស្លាប់ ព្រះ ទ័យរហូតទាល់តែមនុស្សត្រូវ បានកសាង ជាថ្មីឡើងវិញនោះ បានប្រទាន ព្រះរាជបុត្រាទ្រង់ផ្ទាល់មកសុគតជំនួស មនុស្ស ដើម្បីជាថ្នូររបស់គេវិញ។


74

អ្វីៗដែលគួរតែបានប្រព្រឹត្តមកលើយើង ព្រះគ្រីស្ទបានទទួលរងជួសវិញ ដើម្បីឱ្យយើងអាចទទួលតាមបែបដែលទ្រង់គួរ ទទួល។ ទ្រង់ត្រូវបានគេផ្តន្ទាទោស ដោយសារតែអំពើបាបរបស់យើង។ ទ្រង់ទទួល សេចក្តីស្លាប់ ដែលជារបស់យើង ដើម្បីឱ្យយើងទទួលជីវិតអស់កល្ប។

ក្នុងរបៀបនេះ ព្រះអាចប្រទានមកឱ្យ យើងនូវជីវិតអស់កល្បបាន ហើយនៅតែ យុត្តិធម៌ដដែល។

មិនមែនដោយសារអំពើល្អដែលយើង បានធ្វើនោះឡើយ ប៉ុន្តែពីព្រោះព្រះអាចប្រទានឱ្យយើងនូវកិត្តិយស ដែលព្រះគ្រីស្ទ បានធ្វើ-សម្រាប់ជីវិតដ៏គ្រប់លក្ខណ៍របស់ទ្រង់ដែលទ្រង់បានរស់នៅ។


75

(ព្រះគម្ពីរ អេភេសូរ ២:៨)

ពីសាវកទៅអ្នកក្រៅសាសន៍ លោកប៉ុល បាននិយាយថា "ដ្បិតគឺដោយសារព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារ សេចក្តីជំនឿ"
អេភេសូរ ២:៨

សេចក្តីជំនឿនេះគឺជាបេះដូងនៃសេចក្តី សង្គ្រោះ។


76

នៅពេលដែលអ្នកថ្នាំគុក ក្រុងភីលីព បាន សួរលោកប៉ុលថា តើគេត្រូវធ្វើយ៉ាងណាដើម្បីបានសង្គ្រោះ នោះប៉ុលបានឆ្លើយថា

៨. បង្កើតមកដើម្បីរស់នៅរៀងរហូត

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


77

(ព្រះគម្ពីរ កិច្ចការ ១៦:៣១)

"ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ"

កិច្ចការ ១៦:៣១


78

ទោះជាយ៉ាងណាក៏ដោយ ក៏ការដែល គ្រាន់តែយល់ព្រមក្នុងគំនិតអ្នកថា ព្រះគ្រីស្ទបានរស់នៅលើផែនដីនេះ មិនគ្រប់គ្រាន់ ទេ។ នោះមិនមែនជាសេចក្តីជំនឿដែលនាំឱ្យបានសង្គ្រោះនោះទេ។

នៅមានលើសពីនេះទៅទៀត។


79

(ព្រះគម្ពីរ យ៉ាកុប ២:១៩)

ព្រះគម្ពីរនិយាយថា "ទោះទាំងពួក អារក្សក៏ជឿដូច្នោះដែរ ព្រមទាំងព្រឺខ្លាចដែរ"

យ៉ាកុប ២:១៩


80

ការជឿលើព្រះយេស៊ូវមានន័យលើសពី ការទទួលស្គាល់ថា ទ្រង់បានសុគតនៅលើផែនដីនេះកាលពីជាង២០០០ឆ្នាំមុន។

ព្រះគម្ពីរចែងថា


81

(ព្រះគម្ពីរ សុភាសិត ៣:៥,៦)

"ចូរទីពឹងដល់ព្រះយេហូវ៉ាឱ្យអស់ពីចិត្ត កុំឱ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ


82

ត្រូវឱ្យទទួលស្គាល់ទ្រង់នូវគ្រប់ទាំងផ្លូវឯងចុះ"

សុភាសិត ៣:៥,៦

តើលោកអ្នកទុកចិត្តលើទ្រង់ឬទេ? តើ លោកអ្នកពិតប្រាកដជាទុកចិត្តលើទ្រង់មែន ទែនឬទេ? តើលោកអ្នកមានសេចក្តីជំនឿ គ្រប់គ្រាន់ល្មមនឹងឱ្យទ្រង់ឃុំគ្រងជីវិតលោក អ្នកឬទេ?


83

សេចក្តីជំនឿដែលបានសង្គ្រោះ គឺជា ការទុកចិត្តទៅលើព្រះពលិកម្មរបស់ព្រះគ្រីស្ទថាជាការបង់ថ្លៃលោះ យ៉ាងពេញលេញ និងគ្រប់គ្រាន់ សម្រាប់រាល់អំពើបាបដែល យើងបានប្រព្រឹត្ត ។

មានន័យថា យើងជឿថា យើងមិន អាចធ្វើអ្វី ដើម្បីជួយសង្គ្រោះខ្លួនយើងបាន ឡើយ ប៉ុន្តែមានតែការដែលព្រះគ្រីស្ទបាន ធ្វើនៅលើភ្នំរលាក្បាល(កាលវ៉ារី) នោះទេ ដែលអាចជួយសង្គ្រោះយើងបាន។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



84

ការទទួលសេចក្ដីសង្គ្រោះគឺជាការងាយ បំផុត ប៉ុន្តែនៅមានអ្នកខ្លះហាក់ដូចជានៅ តែពិបាកនិងស្មុគស្មាញ។

សំនួរដែលយើងត្រូវឆ្លើយនោះ ដូចគ្នា នឹងសំនួរដែលចេញពីឆ្មាំគុក នៅក្រុង ភីលីព នៅពេលដែលគេស្រែកទៅរកប៉ុល និងស៊ីឡាសនៅពេលយប់ដ៏រន្ធត់មួយ ដែល មានការរញ្ជួយផែនដី បានបើកទ្វារគុកទាំង អស់នោះដែរ។



85

ការទទួលសេចក្ដីសង្គ្រោះគឺជាការងាយ បំផុត ប៉ុន្តែនៅមានអ្នកខ្លះហាក់ដូចជានៅ តែមានការពិបាកនិង ស្មុគស្មាញដដែល។

សំនួរដែលយើងត្រូវឆ្លើយនោះ ដូចគ្នា នឹងសំនួរដែលចេញពីឆ្មាំគុក នៅក្រុង ភីលីព នៅពេលដែលគេស្រែកទៅរកប៉ុល និងស៊ីឡាសនៅពេលយប់ដ៏រន្ធត់មួយ ដែល មានការរញ្ជួយផែនដី បានបើកទ្វារគុកទាំង អស់នោះដែរ។



86

(ព្រះគម្ពីរ កិច្ចការ ១៦:៣០)

"តើខ្ញុំត្រូវធ្វើដូចម្ដេចឱ្យបាន សង្គ្រោះផង?"



87

មានសេចក្ដីពិតតែបួនគត់ អំពីសេចក្ដី សង្គ្រោះដែលអ្នកត្រូវដឹង ដើម្បីឱ្យបាន សង្គ្រោះ។ តែបួនគត់



88

(ព្រះគម្ពីរ អេភេសូរ ២:៨,៩)

សេចក្ដីពិតទី១: សេចក្ដីសង្គ្រោះ គឺជា អំណោយទានដែលឥតគិតថ្លៃ។

"ដ្បិតគឺដោយសារព្រះគុណ ដែលអ្នក រាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតមកពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយសារការប្រព្រឹត្តិដែរ ក្រែង អ្នកអួតខ្លួន"

ឥឡូវនេះសំនួរគឺ "តើហេតុដូចម្ដេចបាន ជាសេចក្ដីសង្គ្រោះគឺជាអំណោយទានដែលឥតគិតថ្លៃយ៉ាងដូច្នេះ?"

សេចក្ដីពិតដែលថា តើហេតុអ្វីបានជា សេចក្ដីសង្គ្រោះជាអំណោយទានដែលឥតគិត ថ្លៃនោះ ចង្អុលបង្ហាញយើងឱ្យឃើញនូវ សេចក្ដីពិតទី ២។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



89

(ព្រះគម្ពីរ រ៉ូម ៣:២៣)

សេចក្តីពិតទី២: យើងទាំងអស់គ្នាមាន បាប។

គម្ពីររ៉ូម ៣:២៣និយាយថា "ដ្បិតគ្រប់ គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អ របស់ព្រះ"



90

ត្រង់នេះមានន័យថា ខ្ញុំមិនគួរនឹងទទួល អំណោយទាននោះឡើយ។

ខ្ញុំមិនគួរនឹងទទួលសេចក្តីសង្គ្រោះនោះ ឡើយ។

លោកអ្នកឃើញទេ ខ្ញុំមានបាប ខ្ញុំខ្វះ មិនដល់សិរីល្អរបស់ព្រះឡើយ។

ប្រសិនបើសេចក្តីសង្គ្រោះពឹងផ្អែកលើ អំពើល្អរបស់ខ្ញុំនោះ ខ្ញុំមិនអាចរកវាបាន សោះឡើយ ពីព្រោះខ្ញុំមានបាប ខ្ញុំមិនអាច បានល្អគ្រប់គ្រាន់ឡើយ។

នោះហើយ គឺជាសេចក្តីពិតយ៉ាងត្រឹម ត្រូវថា សេចក្តីសង្គ្រោះពិតជាអំណោយទាន ដែលឥតគិតថ្លៃ ដែលព្រះបានប្រទានឱ្យ ដោយឥតគិតថ្លៃមែន ពីព្រោះខ្ញុំមិនអាចរក វាបានឡើយ ខ្ញុំមិនគួរនឹងទទួលអំណោយ នេះឡើយ។

យើងទាំងអស់គ្នាមានបាប ហើយខ្វះ មិនដល់សិរីល្អរបស់ព្រះឡើយ។



91

(ព្រះគម្ពីរ រ៉ូម ៦:២៣)

សេចក្តីពិតទី៣: បញ្ហា: អំពើបាបមាន ន័យថាស្លាប់

រ៉ូម៦:២៣ "ដ្បិតឈ្នួលនៃអំពើបាបគឺ សេចក្តីស្លាប់"

នោះគឺជាបញ្ហាដ៏ធំ ដែលយើងទាំងអស់ គ្នាប្រឈមមុខ។

ខ្ញុំជាអ្នកមានបាប ហេតុនោះហើយខ្ញុំ ត្រូវតែទទួលនូវសេចក្តីស្លាប់។

ខ្ញុំមិនគួរនឹងទទួលអំណោយទាននៃ សេចក្តីសង្គ្រោះឡើយ។

ខ្ញុំមិនគួរនឹងទទួលអំណោយទានដែល ឥតគិតថ្លៃនេះទេ។

ហេតុដូច្នេះហើយបានជាថា អំណោយ ទាននោះ ជាអំណោយទានដែលឥតគិតថ្លៃ លោកអ្នកឃើញទេ ពីព្រោះយើងទាំងអស់ គ្នាបានធ្វើបាប ហើយយើងទាំងអស់គ្នាបាន ខ្វះមិនដល់សិរីល្អរបស់ព្រះឡើយ។

បញ្ហានោះគឺថា អ្នកត្រូវតែទទួលសេចក្តី ស្លាប់។

ប៉ុន្តែព្រះមានដំណោះស្រាយចំពោះបញ្ហា នោះវិញ

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


92

(ព្រះគម្ពីរ រ៉ូម ៥:៨)

សេចក្ដីពិតទី៤: ដំណោះស្រាយ: ព្រះ យេស៊ូវបានសុគតជំនួសយើង

រ៉ូម ៥:៨ និយាយថា "តែឯព្រះទ្រង់សំ ដែងសេចក្ដីស្រឡាញ់របស់ទ្រង់ ដល់យើង រាល់គ្នា ឱ្យយើងរាល់គ្នាឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាប នៅឡើយផង"

តើការនេះមិនមែនជាការដ៏ល្អមួយទេ ឬអី? ព្រះយេស៊ូវបានសុគតជំនួសមនុស្ស មានបាប។ មិត្តអើយ ទ្រង់សុគតជំនួសអ្នកដែរ!


93

មានសេចក្ដីពិតបួនយ៉ាងងាយ។ ចូរ យើងរំលឹកអំពីសេចក្ដីពិតទាំងបួននោះឡើង វិញ:


94

១. សេចក្ដីសង្គ្រោះ គឺជាអំណោយទាន ដែលឥតគិតថ្លៃ


95

២. យើងទាំងអស់គ្នាបានធ្វើបាប


96

៣. បញ្ហា: អំពើបាបមានន័យថា សេចក្ដី ស្លាប់របស់យើង។


97

៤. ដំណោះស្រាយ: ព្រះយេស៊ូវបានសុគត ដើម្បីយើង ដែលមានន័យថា ជាជីវិត សម្រាប់យើង ប្រសិនបើយើងទទួលទ្រង់ជាព្រះអង្គ សង្គ្រោះរបស់យើង។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



98

នៅពេលដែលយើងនៅជាអ្នកមានបាប នៅឡើយ ព្រះយេស៊ូវបានសុគតជំនួស យើង។

មិត្តទាំងឡាយអើយ តើលោកអ្នកមិន ស្រឡាញ់ទ្រង់ទេឬ?

តើលោកអ្នកមិនស្រឡាញ់ទ្រង់ ដោយ ទ្រង់បានសុគតជំនួសបាបរបស់អ្នកនិងខ្ញុំទេឬអី?

តើលោកអ្នកមិនស្រឡាញ់ទ្រង់ ដោយ ទ្រង់បានប្រទានសេចក្តីសង្គ្រោះនេះ ដោយ ឥតគិតថ្លៃទេឬអី?



99

ឥឡូវនេះអ្នកគួរសួរថា "តើខ្ញុំអាចទទួល អំណោយទានដែលឥតគិតថ្លៃនេះរបៀបយ៉ាងណា?"



100

(ព្រះគម្ពីរ វិវរណៈ ៣:២០)

ព្រះគម្ពីរផ្តល់ចម្លើយនេះដល់យើងនៅ ក្នុងព្រះគម្ពីរ វិវរណៈ៣:២០

"មើល ខ្ញុំឈរនៅមាត់ទ្វារទាំងគោះ"

ប្រសិនបើមានអ្នកណាម្នាក់ដែលមានជីវិតអស់កល្ប គោះទ្វារផ្ទះលោកអ្នក តើលោកអ្នក ទុកគាត់ ឱ្យនៅក្រៅផ្ទះ-ឬក៏លោកអ្នកអញ្ជើញ គាត់ឱ្យចូលមកខាងក្នុង?



101

ពិតប្រាកដណាស់ លោកអ្នកនឹងបើកទ្វារ ហើយអញ្ជើញគាត់ចូលខាងក្នុង! លោក អ្នកឃើញទេ

ដោយសារការទទួលព្រះយេស៊ូវ យើង ទទួលអំណោយទាននៃជីវិតអស់កល្ប ដែលទ្រង់បាននាំយកមក។

តើនោះមិនមែនជាការល្អប្រសើរឬទេ?

ព្រះយេស៊ូវយាងចូលកាន់ក្នុងចិត្តរបស់ យើង។

សូមយើងយាងទ្រង់ចូលចុះ។



102

នេះហើយជារបៀបដែលយើងទទួលអំ ណោយទានដែលឥតគិតថ្លៃនោះ។

យើងគ្រាន់តែស្វែងរកដោយនិយាយ យ៉ាងងាយថា "អរគុណព្រះយេស៊ូវ!

សូមយាងចូលក្នុងជីវិតទូលបង្គំចុះ។

សូមយាងចូលក្នុងចិត្តទូលបង្គំ

សូមទ្រង់គ្រប់គ្រងជីវិតទូលបង្គំ-សូម ទ្រង់គ្រប់គ្រងចិត្តទូលបង្គំ"

ហើយនៅពេលដែលព្រះយេស៊ូវយាង ចូលក្នុងចិត្តយើងហើយ យើងទទួលទ្រង់ ជាមិត្តរបស់យើង ជាព្រះអង្គសង្គ្រោះ

ជាព្រះអម្ចាស់ និងជាចៅហ្វាយដ៏ធំរបស់ យើង។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


103

រឿងសំខាន់ពីរនឹងកើតឡើង នៅពេល ដែលយើងសុំយាងព្រះយេស៊ូវឱ្យចូលគង់ក្នុងចិត្តរបស់យើង. នៅពេលដែលយើងសុំយាង ព្រះអង្គឱ្យចូលគង់ក្នុងជីវិតយើង។


104

(ព្រះគម្ពីរ យ៉ូហានទី១ ១:៩)

ជាដំបូងយើងលន់តួបាបរបស់យើង ហើយទទួលការអត់ឱនទោស "បើយើង លន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យ ស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹង អត់ទោសបាបឱ្យយើង


105

ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិត ទាំងអស់ផង" យ៉ូហានទី១ ១:៩

មិត្តទាំងឡាយ ទាំងអស់នេះគឺជាសេចក្តី សន្យាដ៏ល្អ។


106

មិនថាយើងធ្វើការអ្វីក៏ដោយ ឬយើង នៅទីណាក៏ដោយ មិនថាយើងបានរស់នៅ ក្នុងជីវិតបែបណា ឬមួយជាមនុស្សមានបាប ដ៏អាក្រក់អាក្រីយ៉ាងណាទេ យើងអាចទៅឯ ព្រះយេស៊ូវ ហើយទទួលអំណោយទាន ដែលឥតគិតថ្លៃនៃសេចក្តីសង្គ្រោះនោះ។

យើងអាចលន់តួបាបរបស់យើង ហើយ ទទួលការអត់ឱនទោសទាំងស្រុង និងពេញ លេញ។


107

ព្រះគម្ពីរប្រាប់យើងថា ព្រះយេស៊ូវ បណ្តេញអំពើបាបរបស់យើងទៅក្នុងបាត សមុទ្រ ដែលមិនអាចនឹកឃើញវិញបាន ឡើយ។


108

មិត្តទាំងឡាយ នៅពេលដែលព្រះ យេស៊ូវអត់ទោស ទ្រង់នឹងបំភ្លេចចោលនូវ អំពើបាបទាំងអស់របស់អ្នក។

តើមានបាបណាដែលលោកអ្នកបានលន់ តួទៅព្រះហើយ ហើយលោកអ្នកនៅតែបាន ចោទប្រកាន់ និងរងនូវកំហុសទៀតនោះ ឬទេ? ប្រហែលជាលោកអ្នកមាន អារម្មណ៍ថា មានបាបខ្លះដែលធំសម្រាប់ ព្រះ អត់ឱនទោសឱ្យហើយ។

យើងត្រូវតែជឿនូវអ្វីដែលព្រះបានមាន ព្រះបន្ទូល

នៅក្នុងព្រះគម្ពីរយ៉ូហានទី១ ៥:១០ ពាក្យនោះបានធ្វើឱ្យយើងឃើញយ៉ាងច្បាស់ថា បើយើងមិនជឿព្រះនោះ យើងបានធ្វើឱ្យ ព្រះក្លាយជាអ្នកកុហកហើយ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


109

(ព្រះគម្ពីរ យ៉ូហានទី១ ៥:១០)

"អ្នកណាដែលជឿដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្តីបន្ទាល់នៅក្នុងខ្លួនហើយ


110

តែអ្នកណាដែលមិនជឿដល់ព្រះសោះ នោះ ឈ្មោះថា បានធ្វើឱ្យទ្រង់ទៅជាអ្នកកុហកវិញ


111

ពីព្រោះមិនបានជឿដល់សេចក្តីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរនៃព្រះរាជបុត្រានៃ ទ្រង់"

យ៉ូហានទី១ ៥:១០

នៅពេលដែលព្រះយេស៊ូវសន្យាថា ទ្រង់នឹងអត់ទោសបាបរបស់យើង ដោយ នាំទៅអោយឆ្ងាយនូវកំហុសរបស់យើងនោះ ទ្រង់នឹងធ្វើអោយបានត្រឹមត្រូវទៅតាមអ្វីដែលទ្រង់មានបន្ទូលសន្យាថានឹងធ្វើ។


112

នៅពេលដែលព្រះយេស៊ូវអត់ទោស ទ្រង់ក៏បំភ្លេចអំពើបាបយើង ហើយយើង ក៏ត្រូវតែបំភ្លេចដែរ!


113

(ព្រះគម្ពីរ កិច្ចការ ៣:១៩)

នៅក្នុងពាក្យពេចន៍របស់លោកពេត្រុសក្នុង គម្ពីរកិច្ចការ ៣:១៩: "ដូច្នេះចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឱ្យបាបរបស់អ្នក រាល់គ្នាបានលុបចេញ..."


114

លោកអ្នកឃើញទេ យើងមកឯព្រះ យេស៊ូវ យើងទទួលអំណោយដែលឥតគិត ថ្លៃនៃសេចក្តីសង្គ្រោះ យើងយាងទ្រង់ឱ្យ ចូលគង់ក្នុងចិត្តយើង ហើយការដំបូងដែល កើតឡើងនោះគឺ ទ្រង់អត់ទោសនិងសំអាត យើង ទ្រង់ដេញអំពើបាបរបស់យើងចូល ទៅក្នុងបាតសមុទ្រ។

តើនេះមិនមែនជាការដ៏ល្អទេឬមិត្ត?

តើលោកអ្នកមិនស្រឡាញ់ព្រះអង្គសង្គ្រោះ របស់លោកអ្នកនិងរបស់ខ្ញុំទេឬអី?

ប៉ុន្តែមានរឿងខ្លះទៀតដែលកើតឡើង នៅពេលដែលលោកអ្នកយាងព្រះយេស៊ូវចូលគង់ក្នុងចិត្តរបស់លោកអ្នក។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត




115

ទ្រង់ប្រទានអំណាចឱ្យឈ្នះលើអំពើបាប របស់យើង ហើយធ្វើឱ្យយើងកាន់តែដូច ទ្រង់ខ្លាំងឡើង១ ដើម្បីដើរតាមស្នាមព្រះ បាទរបស់ទ្រង់។

ចោរលែងលួចតទៅទៀត។

អ្នកកុហកលែងកុហកតទៅទៀត។

អ្នកប្រមឹកលែងផឹកស្រាតទៅទៀត។



116

(ព្រះគម្ពីរ យ៉ូហាន ១:១២)

សូមកត់សំគាល់នូវខព្រះគម្ពីរ យ៉ូហាន ១:១២ "ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកណាដែលជឿដល់ទ្រង់



117

នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ ជាកូនព្រះ"

ទ្រង់នឹងប្រទានដល់យើងនូវអំណាចជា កូនរបស់ទ្រង់

កូនប្រុស កូនស្រីរបស់ទ្រង់។ យើង លែងគ្រប់គ្រងដោយសាតាំងទៀតហើយ។

ហើយក៏លែងជាកូននៃភាពងងឹតទៀតហើយ។


118

ទ្រង់នឹងប្រទានអំណាចឱ្យយើងដើរតាម ដានព្រះបាទរបស់ព្រះអង្គ នៅពេលដែល យើងជឿលើទ្រង់ ពេលដែលយើងទទួលអំ ណោយទាននៃសេចក្តីសង្គ្រោះនោះ ទ្រង់ នឹងប្រទានដល់យើងនូវ អំណាចជាអ្នកឈ្នះ។


119

ប្រសិនបើយើងជំពប់ដួល ក្រោយពី យើងបានទទួលអំណោយទាននោះ ទ្រង់ នឹងអត់ទោសឱ្យយើងម្តងហើយម្តងទៀត។

រួចទ្រង់នឹងប្រទានដល់យើងនូវអំណាចជាអ្នកឈ្នះ-រីកធំធាត់ឡើង១ដូចជាព្រះយេស៊ូវ ដូច្នោះដែរ។

សេចក្តីជំនឿ ការទុកចិត្តទៅលើព្រះ យេស៊ូវថា ជាព្រះអង្គសង្គ្រោះ គឺដំណើរ ការនៃការរីកចំរើនខ្លាំងឡើង១ សាតាំង លែងជាព្រះរបស់យើងទៀតហើយ។

ព្រះយេស៊ូវជាព្រះអង្គម្ចាស់របស់យើងវិញ។


120

លោកអ្នកឃើញទេ ការជឿ មានន័យ ថា ការជឿ និងទុកចិត្ត ហើយនិងការ ទទួលអំណោយទាននៃសេចក្តីសង្គ្រោះ។

ទ្រង់អត់ទោសចំពោះអំពើបាបរបស់ យើង ហើយទ្រង់ក៏ប្រទាននូវអំណាចឱ្យដើរ តាមដានព្រះបាទរបស់ទ្រង់ដែរ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត


121

នៅពេលដែលយើងឆ្លើយតបទៅនឹងការ គោះទ្វារចិត្តរបស់យើង ហើយយាងព្រះយេស៊ូវឱ្យចូលគង់ខាងក្នុង ទ្រង់នឹងសំអាត ចិត្តដែលពោរពេញដោយអំពើបាបរបស់យើង ហើយអត់ទោសឱ្យយើង។

ទ្រង់ក៏ប្រទានអំណាចនៃការផ្លាស់ប្រែ ហើយនិងឈ្នះលើអំពើបាបដល់យើង ដើម្បីឱ្យយើងកាន់តែដូចទ្រង់ខ្លាំងឡើងៗដែរ។


122

ហើយនៅពេលដែលព្រះយេស៊ូវគង់ក្នុង យើង យើងអាចដឹងបានយ៉ាងប្រាកដជាក់ ច្បាស់ថាយើងមានជីវិតអស់កល្ប។

តើលោកអ្នកបានដឹងដូច្នោះហើយឬនៅ?

យើងមិនត្រូវខ្វល់ខ្វាយអំពីថា តើយើងនឹង បានសង្គ្រោះ និងរស់នៅជាមួយនឹងព្រះយេស៊ូវយ៉ាងណានោះទេ។


123

(ព្រះគម្ពីរ យ៉ូហានទី១ ៥:១២,១៣)

"អ្នកណាដែលមានព្រះរាជបុត្រា នោះ ក៏មានជីវិតដែរ


124

ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមក អ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជ បុត្រានៃព្រះ


125

ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នា មានជីវិតអស់កល្បជានិច្ចហើយ" យ៉ូហានទី១ ៥:១២,១៣


126

ព្រះយេស៊ូវចង់ឱ្យយើងដឹងនៅទីនេះ-ឥឡូវនេះ-ថាយើងមានជីវិតអស់កល្ប។

យើងបានដឹងនៅទីនេះ និងឥឡូវនេះថា នៅពេលណាដែលយើងយាងព្រះយេស៊ូវចូលគង់ក្នុងចិត្តយើង យើងបានទទួល ការធានា រ៉ាប់រងនៃសេចក្តីសង្គ្រោះ។

ព្រះយេស៊ូវបានប្រទានសេចក្តីអញ្ជើញ ដល់មនុស្សគ្រប់ៗគ្នា នៅគ្រប់ទីកន្លែង ដើម្បីឱ្យ

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



127

(ព្រះគម្ពីរ យ៉ូហាន ៣:១៦)

"អ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះ មិនត្រូវវិនាសឡើយ គឺមានជីវិតរស់ កល្បជានិច្ចវិញ" យ៉ូហាន ៣:១៦

ប្រហែលជាលោកអ្នកមានអារម្មណ៍ថា លោកអ្នកជាអ្នកមានបាបដ៏អស់សង្ឃឹមម្នាក់ តែការនោះមិនពិតទេ! ព្រះអាចកែប្រែស្ថាន ភាពដែលមិនអាចមានលទ្ធភាពសោះនោះ មកជាជ័យជំនះវិញបាន។

គ្មានជីវិតណាដែលអាក្រក់ហួសហេតុ គ្មានអំពើបាបណាដែលធំធេងហួយហេតុ ដែលព្រះយេស៊ូវមិនអាចអត់ឱនទោសឱ្យនោះ ឡើយ!

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



128

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៥ លោក ហូន ក្លិនស៊ី ជាអ្នកពន្លត់ភ្លើងជើងចាស់ ម្នាក់នៅទីក្រុង ញូយ៉ក បានដឹកនាំក្រុម របស់គាត់ទៅកាន់អាគារទំនេរ ដែលមាន ភ្លើងឆេះមួយនៅតំបន់គ្រឿងញៀន ម៉ាន់ហាតាន់ខាងក្រោម។ នៅពេលដែលភ្លើង បានឆេះពេញទំហឹងមិនអាចគ្រប់គ្រងបាន អ្នកពន្លត់ភ្លើងមានការព្រួយបារម្ភជាខ្លាំង ព្រោះគេដឹងថា មានមនុស្សខ្លះអាចនៅក្នុង អាគារនោះនៅឡើយ។

ទោះបីជាមនុស្សដែលប្រើប្រាស់អាគារ នោះជាមនុស្សខ្វាត់ភ្លាត់គ្មានទីលំនៅ អ្នកញៀនគ្រឿងញៀន អ្នកញៀនសុរា និង ស្រីពេស្យាក៏ដោយ។ ទោះជាយ៉ាងនេះក៏ ដោយក៏លោកក្លិនស៊ី និងសហការីរបស់ គាត់ បានសំរេចចិត្តចូលទៅក្នុងគំនរភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅ ដើម្បីដឹកនាំ ប្រតិបត្តិការរុករក និងជួយសង្គ្រោះមួយ។ អាគារនោះមានផ្សែងពាសពេញងងឹតឈឹង ធ្វើឱ្យមើលអ្វីមិនឃើញសោះឡើយ។

អ្នកពន្លត់ភ្លើងបានប្រថុយប្រថានជីវិត របស់គេ ដើម្បីស្វែងរកជនរសាត់អណ្តែតដែលបានប្រើប្រាស់អាគារនោះជាទីលំនៅ បណ្តោះអាសន្ន។

រំពេចនោះ ពិដាននៃជាន់ទីពីរបានរលំ គ្របលើលោកហូន គ្លិនស៊ី។ សហការីរបស់គាត់បានធ្វើការក្រោមកំដៅភ្លើងយ៉ាងក្តៅដើម្បីរំដោះគាត់ចេញពីភយន្តរាយនៃអគ្គីភ័យ នេះ ប៉ុន្តែនៅពេលដែលពួកគេបានទាញ គាត់ចេញមក នៅគ្រាចុងក្រោយបង្អស់នោះវាយឺតពេលណាស់ទៅហើយ...

រាងកាយរបស់គាត់បានឆេះរកមើលមិន យល់។ ថ្ងៃចុងក្រោយបង្អស់នៃឆ្នាំ ១៩៩៥ គឺជាថ្ងៃចុងក្រោយបង្អស់ នៃជីវិតរបស់អ្នក ពន្លត់ភ្លើងដ៏អង់អាចក្លាហាននេះ។ គាត់បានបន្សល់ទុកនូវភរិយាដែលមានទម្ងន់ប្រាំមួយខែនិងផែនការអនាគតទាំងឡាយដែលគាត់បានរៀបចំជាមួយប្រពន្ធរបស់គាត់។ លោក ហ្វូន គ្លិនស៊ី បានជឿថា ជីវិតទាំងអស់ សុទ្ធតែមានតម្លៃ។

ហេតុដូច្នោះហើយ បានជាគាត់សុខចិត្ត ប្រថុយជីវិតរបស់គាត់ទៅសង្គ្រោះដល់អ្នកដែលនៅក្នុងអាគារនោះ។ គាត់បានចាក ចោលសេចក្តីសុខសាន្ត នៃផ្ទះសំបែងរបស់ គាត់ ដោយសុខចិត្តរងគ្រោះក្នុងភ្លើងដ៏សន្ធោ
សន្ធៅ។

គាត់បានចូលទៅក្នុងអណ្តាតភ្លើងដើម្បី ជួយសង្គ្រោះជីវិតមនុស្ស ហើយត្រូវបានបាត់បង់ជីវិតរបស់គាត់។ ភក្តីភាពចំពោះ ការងាររបស់គាត់ មានតម្លៃស្មើនឹងជីវិត ផ្ទាល់របស់គាត់។

គាត់មិនអាចឈរស្ងៀមបានឡើយ នៅ ពេលដែលគាត់បានដឹងថា អ្នកដទៃត្រូវ ស្លាប់នោះ។

រឿងនេះត្រូវបានគេដឹងច្បាស់ ដោយ អ្នកសង្កេតការណ៍បានរកឃើញថា អគ្គីភ័យនោះបណ្តាលមកពីការលួចដុត។  អេដវិន ស្មីត ជាមនុស្សគ្មានទីពឹងម្នាក់ នៅក្នុងអា គារនោះត្រូវបានគេរាយការណ៍ប្រាប់ថា ជាអ្នកដុតអាគារនោះ។

រឿងដ៏គួរឱ្យឆ្ងល់នោះគឺថា លោកហូន គ្លិនស៊ី បានប៉ុនប៉ងសង្គ្រោះអ្នកដែលបានដុតបំផ្លាញអាគារនោះ។

គាត់បានលះបង់ជីវិតរបស់គាត់។

នេះគឺជាឧទាហរណ៍មួយអំពីព្រះយេស៊ូវ គ្រីស្ទ។

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត





129

ព្រះយេស៊ូវបានលះចោលសេចក្ដីសុខ សាន្តនៃដំណាក់ស្ថានសួគ៌របស់ទ្រង់ ហើយ យាងចុះមកកាន់គំនរភ្លើងយ៉ាងសន្ធៅ សន្ធៅនៃភ្លើងលោកីយ៍នេះ។

ព្រះអង្គសង្គ្រោះនៃយើង បានជាប់នៅ លើឈើឆ្កាង ហើយភ្លើងនៃអំពើបាបបានដុតបញ្ឆេះលើទ្រង់ទាំងស្រុង ដោយការ ជ្រើសរើសដែលបានគិតទុកជាមុនរបស់យើង យើងបានធ្វើបាប។

យើងបានធ្វើឱ្យពិភពលោកនេះឆេះ ដោយសារចិត្តខឹងរបស់យើង ការមិនស្មោះ ត្រង់របស់យើង តណ្ហារបស់យើង ការ លោភលន់របស់យើង ការកំផិត និងការ កុហករបស់យើង។

ព្រះគ្រីស្ទបានសុគត ដើម្បីឱ្យយើងបាន រស់នៅវិញ។

ទ្រង់បានទទួលអណ្ដាតភ្លើងនៃអំពើបាប នៅលើឈើឆ្កាង ដើម្បីកុំឱ្យយើងត្រូវទទួលភ្លើងនរកនៅពេលដែលព្រះយេស៊ូវ នឹង យាងមកដុតអំពើបាបជារៀងរហូតនោះ ឡើយ។



130

ទ្រង់កំពុងរង់ចាំ និងចាំស្ដាប់។

តើហេតុដូចម្ដេចបានជាមិនបើកទ្វារចិត្ត របស់លោកអ្នក ហើយយាងទ្រង់ឱ្យចូល គង់ក្នុងចិត្ត និងធ្វើជាព្រះអង្គសង្គ្រោះ និង ជាព្រះអម្ចាស់នៃជីវិតលោកអ្នក?

ទ្រង់កំពុងរង់ចាំ! ទ្រង់កំពុងចាំស្ដាប់!

មានការមួយដែលព្រះយេស៊ូវមិនអាចធ្វើ បាន គឺការបង្ខិតបង្ខំលោកអ្នកឱ្យបើកទ្វារចិត្តទទួលទ្រង់។

ទ្រង់បានព្រទានដល់យើងម្នាក់ៗនូវអំ ណាចនៃការជ្រើសរើស

យើងត្រូវតែជាអ្នកបើកទ្វារចិត្តថ្វាយទ្រង់!

ទ្រង់នឹងយាងចូលដោយរីករាយ ប្រសិន បើលោកអ្នកបើកទ្វារថ្វាយទ្រង់។

មិត្តអើយ តើអ្នកគួរធ្វើដូច្នោះឥឡូវនេះ ឬទេ?

តើលោកអ្នកនឹងយាងព្រះយេស៊ូវឱ្យគង់ ក្នុងចិត្តលោកអ្នក ដោយគ្មានការបង្អែបង្អង់ ឬទេ?




131

បើដូច្នេះ សូមលោកអ្នកអធិស្ឋាននូវ សេចក្ដីនេះជាមួយនឹងខ្ញុំ




132

ឱ ព្រះអង្គជាទីស្រឡាញ់ ទូលបង្គំដឹង ថា ទូលបង្គំជាអ្នកមានបាប ហើយទូល បង្គំត្រូវការជំនួយ

# ៨. បង្កើតមកដើម្បីរស់នៅរៀងរហូត



133

ទូលបង្គំចង់ទទួលទ្រង់ជាព្រះអង្គ សង្គ្រោះ និងជាព្រះអម្ចាស់នៃទូលបង្គំ



134

ទូលបង្គំចង់ឆ្លើយតបទៅនឹងការកោះ ហៅរបស់ទ្រង់ និងយាងទ្រង់មកគង់ក្នុង ចិត្តឥឡូវនេះ។



135

សូមទ្រង់អត់ទោសនូវរាល់អំពើបាបទាំង ឡាយ ដែលទូលបង្គំធ្លាប់បានប្រព្រឹត្ត។

សូមទ្រង់គ្រប់គ្រងជីវិតទូលបង្គំទាំង ស្រុងចុះ។



136

ទូលបង្គំចង់ឱ្យព្រះយេស៊ូវយាងគង់ក្នុង ចិត្តទូលបង្គំ និងលាងសំអាតទូលបង្គំឱ្យ ស្អាត ហើយជួយឱ្យទូលបង្គំរស់នៅដើម្បី ទ្រង់។

សូមអរព្រះគុណទ្រង់ ដែលបានឮនិង ឆ្លើយតបនូវសេចក្តីអធិស្ឋានរបស់ទូលបង្គំ នៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន”

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



1

ចៅក្រមនៅខាងអ្នក


2

ព្រះចៅហ្ស៊េមទី១ ជាក្សត្រមួយអង្គនៃប្រ ទេសអង់គ្លេស ដែលត្រូវបានគេនិយាយថា បានសាកល្បងធ្វើជាចៅក្រម។ ទ្រង់បាន ព្រះសណ្តាប់ដោយយកព្រះទ័យទុកដាក់បំផុត ទៅលើករណីម្ខាង។ ទ្រង់រៀបតែធ្វើការ សំរេចព្រះទ័យទៅហើយ នៅមុនពេល ដែលទ្រង់បានទ្រង់ព្រះសណ្តាប់ ទៅលើ ករណីរបស់ភាគីម្ខាងទៀត។

ក្រោយមក ទ្រង់មានការស្ទាក់ស្ទើរទាំង ស្រុង ដោយទ្រង់មិនដឹងជាធ្វើយ៉ាងណា អ្នកដែលទ្រង់គិតថាគ្មានទោសសោះ ឥឡូវ នេះបែរជាមានកំហុសទៅវិញ។

ទ្រង់បានបោះបង់ចោលតំណែងជាចៅ ក្រមរបស់ទ្រង់ក្នុងការអស់សង្ឃឹមជាយថា ហេតុ។

ព្រះចៅហ្ស៊េមទី១បានមានបន្ទូលរបៀប យ៉ាងនេះ "ខ្ញុំមិនអាចខំធ្វើឱ្យបានល្អតទៅ ទៀតដោយស្តាប់តែម្ខាងនោះទេ ប៉ុន្តែនៅ ពេលណាដែលខ្ញុំបានឮពីអ្នកទាំងសងខាង ខ្ញុំមិនដឹងថាខាងណាមួយត្រឹមត្រូវឡើយ"។

ចៅក្រមដែលភាន់ច្រឡំ នឹងមានការ ពិបាកក្នុងការធ្វើការសំរេចចិត្តអោយបានត្រឹមត្រូវមួយមិនខាន។

ព្រះគឺជាចៅក្រមដែលមិនប្រកាន់បក្ស ពួក យុត្តិធម៌ និងត្រឹមត្រូវជាទីបំផុត។ ទ្រង់នឹងមិនភាន់ច្រឡំឡើយ នៅពេលដែល ទ្រង់ជំនុំជំរះយើង។



3

(វីដេអូ ៨វិនាទី) ព្រះគម្ពីរបង្រៀនយើង ថា យើងម្នាក់ៗមានករណីមួយរង់ចាំសេចក្តី សំរេចនៅចំពោះព្រះ។



4

(វីដេអូ ១២វិនាទី) សូម្បីតែឥឡូវនេះ យើងត្រូវបានប្រទានមកអោយនូវជីការកោះ មួយ អោយចូលមកបង្ហាញខ្លួនក្នុងការជំនុំជំ រះនោះ ដើម្បីផ្តល់នូវដំណើររឿងនៃរបៀប ដែលយើងបានរស់នៅ និងអ្វីៗដែលយើង បានធ្វើ។

រាល់បុរសស្ត្រីទាំងឡាយដែលរស់នៅ មាន ករណីព្យួរនៅខាងមុខស្នាក្តីនៃការជំនុំជំរះរបស់ព្រះ ជាតុលាការដ៏ខ្ពស់បំផុតនៅលើលោក សន្និវាសនេះ។

លោកសាវកប៉ុលបានប្រាប់អំពីការណាត់ ដែលមនុស្សទាំងអស់នៅលើពិភពលោកនេះ ត្រូវតែរក្សាទុក។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



5

កិច្ចការ ១៧:៣១

គ្មានអ្នកណាម្នាក់អាចប្រកែកដោះសារបាន ឡើយ។ គ្មានអ្នកណាម្នាក់អាចគេចចេញពី

ដីការកោះនោះបានទេ។

ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា មនុស្ស រាល់គ្នាត្រូវតែបង្ហាញមុខ។



6

(ព្រះគម្ពីរ កូរិនថូសទី២ ៥:១០)

"ដ្បិតយើងទាំងអស់គ្នាត្រូវតែទៅនៅមុខ

ទីជំនុំជំរះរបស់ព្រះគ្រីស្ទ..."

កូរិនថូសទី២ ៥:១០



7

ទោះយើងជឿឬមិនជឿលើរឿងនោះក៏ដោយ ទោះបីជាយើងចូលចិត្តឬមិនចូលចិត្តរឿងនេះក៏ដោយ

ទោះបីយើងជាគ្រីស្ទានឬមិនមែន ក៏ដោយ។

ទោះបីជាយ៉ាងណាក៏ដោយ យើងទាំង

អស់គ្នាត្រូវតែបង្ហាញខ្លួន។ ព្រះគ្មានពេញចិត្តអ្នក ណាជាងអ្នកណា ឡើយ។

នៅពេលដែលយើងត្រូវកោះហៅដោយ

តុលាការស្ថានសួគ៌ យើងត្រូវបង្ហាញខ្លួន។ តើហេតុអ្វី?

លោកប៉ុលផ្តល់ចម្លើយនេះ:



8

(ព្រះគម្ពីរ រ៉ូម ១៤:១២)

"ដូច្នេះយើងទាំងអស់គ្នានឹងត្រូវរៀបរាប់

ទូលថ្វាយព្រះ ពីដំណើររបស់ខ្លួនយើងជា

មិនខាន"

រ៉ូម ១៤:១២



9

សេចក្តីសំរេចចិត្តរបស់តុលាការស្ថានសួគ៌ នឹងបោះត្រាលើអនាគតរបស់មនុស្សគ្រប់រូប រៀងរហូត។

ហើយសេចក្តីសំរេចនោះនឹង មិនអាចកែប្រែបានឡើយ ព្រោះថា នឹង

គ្មានតុលាការណាទៀតនឹងត្រូវឡើងទៅតវ៉ា

បន្តឡើយ!។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



10

(វីដេអូ ១៥វិនាទី)

ប៉ុន្តែមុននឹងចេញសាលក្រម ឬការ

វិនិច្ឆ័យទោសនោះ ត្រូវតែមានការកាត់ សេចក្តី ឬការស៊ើបអង្កេតសិន។ សូមបើកទៅព្រះគម្ពីរ

ហើយកត់សំគាល់ អំពីរូបភាពនៃសាលាក្តី ឬការប្រជុំតុលាការ ស្ថានសួគ៌នេះ។

ហោរាដានីយ៉ែលបានសរសេរថា:


11

ដានីយ៉ែល ៧:៩,១០

ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្កមក តាំង ហើយព្រះដ៏មានព្រះជន្មពីចាស់ បុរាណ ទ្រង់ក៏គង់លើ


12

ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយ ព្រះកេសនៅព្រះសិរទ្រង់ ក៏សដូចរោម ចៀមយ៉ាងស្អាត


13

ឯបល្ល័ង្កទ្រង់ នោះសុទ្ធតែជាអណ្តាតភ្លើង

ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ


14

មានដូចជាភ្លើងហូរចេញ

ពីចំពោះទ្រង់មក


15

មានទាំងពាន់ទាំងពាន់ ដែលគោរពដល់ទ្រង់


16

ហើយទាំងម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់

នោះការវិនិច័យបានរៀបចំជាស្រេច ឯបញ្ជី ទាំងប៉ុន្មានបានបើកឡើងហើយ"។

ដានីយ៉ែល ៧:៩, ១០។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


17

នេះដានីយ៉ែលបានបង្ហាញរូបភាពរបស់ព្រះ វរបិតាឬក៏ព្រះពីបុរាណ បានគង់នៅលើ បល្ល័ង្កដ៏អស់កល្បរបស់ទ្រង់ ហើយហ៊ុំព័ទ្ធ ដោយទេវតាជាច្រើនរាប់មិនអស់។ ឥឡូវនេះ ចូរកត់សំគាល់ថា តើដានីយ៉ែល បានឃើញអ្វីទៀត នៅក្នុងការជាក់ស្តែង បន្ទាប់របស់គាត់:


18

ដានីយ៉ែល ៧:១៣

"ខ្ញុំក៏ឃើញក្នុងការជាក់ស្តែងពេលយប់នោះ


19

មាន១អង្គដូចជាមនុស្សជាតិ ទ្រង់យាងមក ក្នុងពពកឰដ៏អាកាស!


20

ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីចាស់ បុរាណនោះ ហើយមានគេនាំចូលទៅ ចំពោះព្រះអង្គ" ដានីយ៉ែល ៧:១៣


21

ទីនេះកូនមនុស្សត្រូវបានបង្ហាញ ដោយឈរ ពីមុខព្រះពីចាស់បុរាណ។ ពិតដូចជា បន្ទប់តុលាការនៅផែន ដីនេះយ៉ាងប្រាកដ!

មានប្រធានចៅក្រមម្នាក់: ព្រះពីចាស់ បុរាណ មានសាក្សី: ទេវតាបរិសុទ្ធដែល បានឃើញនិងកត់ត្រាអ្វីៗទាំងអស់ ហើយ ឈរនៅពីមុខបល្ល័ង្គ គឺព្រះយេស៊ូវជា មេធាវី ដូចដែលលោកយ៉ូហានបាន សរសេរថា:


22

(ព្រះគម្ពីរ យ៉ូហានទី១ ២:១)

"នោះយើងមានព្រះដ៏ជាជំនួយ១អង្គ ហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជា ព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត..." យ៉ូហានទី១ ២:១



23

(វីដេអូ ៥វិនាទី) "មែនហើយ" លោកអ្នក និយាយថា: " គ្រប់ៗគ្នាហាក់បីដូចជា នៅទីនោះ ប៉ុន្តែមានម្នាក់ដែលជាចុង ចោទ!"

នោះជាការពិត ប៉ុន្តែចូរយើងពិនិត្យ មើលនូវការដែលព្រះគម្ពីរបាននិយាយ:

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


24

(ព្រះគម្ពីរ ដានីយ៉ែល៧:១០)

"នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯ បញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ"

ដានីយ៉ែល ៧:១០

ជាការជាក់ស្តែងសៀវភៅទាំងនេះមានកំណត់ ត្រានៃទង្វើរបស់អ្នកទាំងឡាយ ដែលឈរ
នៅចំពោះមុខការជំនុំជំរះដូចស្តេចសាឡូម៉ូន បានមានព្រះបន្ទូលថា:


25

(ព្រះគម្ពីរ សាស្តា ១២:១៤)

"ពីព្រោះព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មក ដើម្បីជំនុំជំរះ ព្រមទាំងអ្វីៗដែលលាក់កំ បាំងផង
ទោះល្អឬអាក្រក់ក្តី" សាស្តា១២:១៤


26

(ព្រះគម្ពីរ ម៉ាឡាគី ៣:១៦)

"គ្រានោះពួកអ្នកដែលកោតខ្លាចដល់ព្រះ
យេហូវ៉ា ក៏និយាយគ្នាទៅវិញទៅមក ហើយ ព្រះយេហូវ៉ាក៏ទ្រង់ប្រុងស្តាប់ ក៏បានឮ


27

រួចមានសៀវភៅរំលឹកបានកត់ទុកនៅ
ចំពោះព្រះយេហូវ៉ា សម្រាប់ដល់ពួកអ្នកដែល
កោតខ្លាចដល់ទ្រង់ និងពួកអ្នកដែលនឹក ដល់ព្រះនាមទ្រង់"

ម៉ាឡាគី ៣:១៦

ព្រះទ្រង់ពិនិត្យរាល់ពេលវេលាដែលចិត្ត
យើងត្រូវបានទាញទៅឯទ្រង់។ ទ្រង់បាន កត់ត្រា នូវគ្រប់ពាក្យពេចន៍ លើកទឹកចិត្ត ដែល
យើងពោលទៅកាន់ អ្នកដទៃផ្សេង ទៀតនិងរាល់អំពើសប្បុរសទាំងឡាយ។

ស្តេចដាវីឌក៏បានជ្រាប អំពីកំណត់ត្រា
នេះ ទើបបានជាទ្រង់បានមានបន្ទូលថា:


28

(ព្រះគម្ពីរ ទំនុកដំកើង ៥៦:៨)

"សូមទ្រង់ដាក់អស់ទាំងទឹកភ្នែករបស់
ទូលបង្គំទុកនៅក្នុងដបនៃទ្រង់ ទឹកភ្នែក ទាំងនោះ តើមិនកត់ទុកក្នុងបញ្ជីទ្រង់ទេឬអី?

ទំនុកដំកើង ៥៦:៨

ព្រះអង្គក៏ជ្រាបអំពីកង្វល់ដ៏ជ្រៅបំផុត នៃ
ជីវិតរបស់អ្នកដែរ។ ពិតប្រាកដណាស់ ទ្រង់ជ្រាបអំពីយើងទាំងអស់ ដូចជាស្តេច
ដាវីឌបានចារទុកមកថា:

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


29

(ព្រះគម្ពីរ ទំនុកដំកើង ១៣៩:១,៣,១៦)

"ព្រះអម្ចាស់អើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង


30

...ក៏ស្គាល់អស់ទាំងផ្លូវប្រព្រឹត្តិរបស់ទូល បង្គំដែរ


31

ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់ គឺ អស់ទាំងថ្ងៃអាយុដែលបានដំរូវឱ្យទូលបង្គំរស់

នៅក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយ នោះនៅឡើយ"

ទំនុកដំកើង ១៣៩:១,៣,៦


32

នៅពេលដែលព្រះទ្រង់ជ្រាបទាំងអស់អំពី យើង វាគ្មានប្រយោជន៍អ្វីដែលទ្រង់ត្រូវកត់ ត្រានោះទេ។

កំណត់ត្រាទាំងនោះ ត្រូវបាន រក្សាសំរាប់ជាប្រយោជន៍ដល់ពិភពចក្រវាល ទាំងមូល

ទុកជាភស្តុតាងអំពីសេចក្តី

ស្រឡាញ់ និងយុត្តិធម៌របស់ព្រះយ៉ាងច្បាស់ បំផុតនៅគ្រប់ករណីទាំងអស់។

ការទទួលខុសត្រូវរបស់យើងចំពោះព្រះ គឺ ជាគំនិតដ៏មុតមាំមួយ


33

គ្រប់ៗគ្នាត្រូវតែទទួលនូវអំណោយទានដ៏មានតម្លៃលើសអ្វីៗទាំងអស់ គឺជីវិត! នេះគឺជា

អ្វីដែលស្តេចសាឡូម៉ូនបានមានព្រះបន្ទូល នៅពេលដែលទ្រង់បានសរសេរ


34

(ព្រះគម្ពីរ សាស្តា ១១:៩)

"ឱមនុស្សកំឡោះអើយ ចូរមានចិត្តរីករាយ ក្នុងវ័យកំឡោះរបស់ឯងចុះ ហើយចិត្តឯង បានអរសប្បាយ

ក្នុងជំនាន់ដែលឯងនៅ ក្មេងផង


35

ចូរដើរតាមផ្លូវនៃចិត្តឯង ហើយតាមតែភ្នែក ឯងមើលឃើញដែរ

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត




36

ប៉ុន្តែត្រូវឱ្យឯងដឹងថា ព្រះនឹងហៅឯងមក ជំនុំជំរះ ដោយព្រោះអំពើទាំងនេះជាមិន ខាន"
សាស្តា ១១:៩


37

(ពះគម្ពីរ ម៉ាថាយ ១២:៣៦,៣៧)
"នៅថ្ងៃជំនុំជំរះ នោះមនុស្សលោកនឹង
ត្រូវរៀបរាប់ប្រាប់ពីអស់ទាំងហេតុនៃពាក្យឥត
ប្រយោជន៍ ដែលគេបាននិយាយ


38

ដ្បិតអ្នកនឹងបានរាប់ជាសុចរិត ដោយសារ ពាក្យសំដីរបស់ខ្លួន ឬនឹងត្រូវទោសដោយ
សារតែពាក្យសំដីនោះដែរ"
ម៉ាថាយ១២:៣៦,៣៧


39

អ្នកខ្លះបានប៉ាន់ប្រមាណថា មនុស្សជា
មធ្យមនិយាយក្នុងមួយសប្តាហ៍បានពាក្យដែលអាចសរសេរបានជាសៀវភៅមួយក្បាលដែល
មាន៣២០ទំព័រ! ក្នុងរយៈពេល៦០ឆ្នាំនោះ មានន័យថាអាច លើសពីសៀវភៅបែប នោះ
៣០០០ក្បាល!


40

តើសៀវភៅច្រើនយ៉ាងណាទៅ ដែលអ្នក នឹងត្រូវនិយាយនៅគ្រាជំនុំជំរះ?
ហើយលើសពីនោះទៅទៀត សូម្បីតែមូល
ហេតុនិងសកម្មភាពដែលនៅពីក្រោយ ពាក្យទាំងនោះ ក៏នឹងត្រូវបើកបង្ហាញឱ្យបាន ឃើញដែរ។


41

(ព្រះគម្ពីរ កូរិនថូសទី១ ៤:៥)
"ដែលទ្រង់នឹងយកអស់ទាំងអំពើលាក់
កំបាំង ដែលធ្វើនៅទីងងឹតមកដាក់ នៅទីភ្លឺ វិញ ហើយនិងបើកសំដែង ឱ្យឃើញអស់ ទាំងគំនិត
ក្នុងចិត្តរបស់មនុស្សផង..."
កូរិនថូសទី១ ៤:៥


42

នឹងគ្មានទីកលប់ឬក្រដាសបិទឡើយ នៅថ្ងៃ នោះ! មនុស្សអាចបំភាន់មិត្តភក្តិខ្លួន ឬគ្រូ សារខ្លួនបាន
តែមិនអាចបំភាន់ព្រះបាន ឡើយ។ ទ្រង់ជ្រាបអាថ៌កំបាំងនៃចិត្ត!។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



43

លោកអ្នកឃើញទេ នៅពេលដែលសេចក្តី ជំនុំជំរះរបស់យើងមកដល់ យើងនឹងឃើញ ថា ខ្លួនយើងផ្ទាល់ ស្ថិតនៅក្នុងស្ថានភាព មួយនៃស្ថានភាពពីរៈ
កំណត់ត្រាទាំងអស់អំពីអតីតកាលដែល
បរាជ័យរបស់យើង នឹងត្រូវបានលប់ចោល ដោយលោហិតព្រះយេស៊ូវ ឬមួយក៏កំណត់ ត្រារបស់យើងនឹងត្រូវឈរដើម្បីកាត់ទោស យើង។
ហើយជាការពិត មិនមែនអ្វីដែលយើងអះ អាងនោះទេ ប៉ុន្តែគឺជាអ្វីដែលរស់នៅ និង អ្វីដែលយើងធ្វើទេ ដែលធ្វើអោយយើង មានការខុសគ្នា។




44

(ព្រះគម្ពីរ ម៉ាថាយ ១៦:២៧)
យើងត្រូវបានប្រាប់ថា នៅពេលដែល ព្រះ យេស៊ូវយាងមក "...គ្រានោះលោក នឹង សងដល់គេគ្រប់គ្នា តាមការដែល បានធ្វើរៀងខ្លួន" ម៉ាថាយ ១៦:២៧

អំពើល្អរបស់យើងមិនមែនជាមូលដ្ឋាននៃ សេចក្តីសង្គ្រោះរបស់យើងទេ គឺជាព្រះ គុណរបស់ព្រះឯណោះទេ។
ប៉ុន្តែអំពើល្អរបស់យើងបង្ហាញថា ចិត្តរបស់ យើងបានថ្វាយទៅព្រះ។




45

ឥឡូវនេះប្រហែលជាអ្នកកំពុងនិយាយថា "ប្រសិនបើយើងត្រូវបានសង្គ្រោះដោយសារ ព្រះគុណ តើហេតុដូចម្តេចបានជាយើងត្រូវ បានជំនុំជំរះដោយសារអំពើរបស់យើង?" នោះគឺជាសំនួរដ៏ល្អមួយ! ថ្មីៗនេះ បណ្ឌិតសាកាគួបូបានសរសេរថាៈ



46

"ចូរយើងពិចាណាមើលថា តើវាមាន
ន័យ យ៉ាងណា ប្រសិនបើការជំនុំជំរះមិន សំអាងលើការប្រព្រឹត្តិទាំងឡាយដែលមនុស្ស ធ្វើនោះទេ



47

តើព្រះនឹងជំនុំជំរះយើងដោយសារអ្វី? ស្បែករបស់យើង ពូជអំបូររបស់យើង ឋានៈក្នុងសង្គមរបស់យើង ការសិក្សារបស់ យើង ភិនភាគរបស់យើង ទេពកោសល្យ របស់យើង កម្លាំងរបស់យើង។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


48

សមាជិកភាពក្នុងក្រុមជំនុំរបស់យើង ឬ មួយក៏គ្រាន់តែនិយាយពីព្រះគ្រីស្ទរបស់យើង?
ព្រះអាចជំនុំជំរះយើងដោយសារតែការងារ របស់យើងតែប៉ុណ្ណោះ អាក្រក់ឬល្អ?
ដីការកោះរបស់អ្នកទៅកាន់តុលាការ ទំព័រ២០
សេចក្ដីសង្គ្រោះមិនមែនបានមកពីការប្រព្រឹត្តិល្អនោះទេ។



49

(វីដេអូ ៨វិនាទី) តែការប្រព្រឹត្តិល្អទាំង នោះ គឺជាលទ្ធផលដែលពោរពេញដោយ សេចក្ដីស្រឡាញ់ដ៏សុទ្ធចិត្តរបស់យើងចំ ពោះព្រះ និងមនុស្ស។
ទំនាក់ទំនងនៃសេចក្ដីស្រឡាញ់ជាមួយ
ព្រះយេស៊ូវ ជំរុញទឹកចិត្តពួកសិស្សរបស់ ទ្រង់អោយធ្វើល្អ។
សេចក្ដីសរុបនៃសៀវភៅសាស្ដា ស្ដេចសា ឡូម៉ូនបានមានបន្ទូលថា:


50

(ព្រះគម្ពីរ សាស្ដា ១២:១៣,១៤)
"...យើងអាចទាញជាសេចក្ដីសន្និដ្ឋានថា


51

ត្រូវគោរពកោតខ្លាចព្រះជាម្ចាស់ ហើយកាន់តាមបទបញ្ញារបស់ព្រះអង្គ។
នេះហើយជាការដែលមនុស្សគ្រប់ៗគ្នាត្រូវធ្វើ


52

ព្រះជាម្ចាស់នឹងវិនិច្ឆ័យកិច្ចការទាំងប៉ុន្មានដែលមនុស្សធ្វើ"
(សាស្ដា ១២:១៣,១៤ ព្រះគម្ពីរភាសា ខ្មែរសម្រាយ)
ពីព្រោះទំនាក់ទំនងរបស់មនុស្សទៅកាន់ព្រះ គ្រីស្ទ នឹងត្រូវវិនិច្ឆ័យដោយអំពើ(ការប្រ ព្រឹត្តិ)
របស់គេដូច្នេះ ត្រូវតែមានម្នាក់ជា គំរូយ៉ាងត្រឹមត្រូវ ដើម្បីវាស់វែងនូវអំពើ ទាំងឡាយនោះ។


53

នៅក្នុងកិច្ចដំណើរការនៃការជំនុំជំរះនៅលើ លោកីយ៍នេះ គោលបំណងធម្មតារបស់ការកាត់សេចក្ដីនៃតុលាការ គឺដើម្បីរកឱ្យឃើញ ថា តើបទល្មើសត្រូវបានគេប្រព្រឹត្តឬអត់
តើច្បាប់ត្រូវបានគេបំពានឬទេ។
មានតែនៅពេលដែលច្បាប់ត្រូវបានគេបំពាន នោះទេ ទើបគេអាចរកឃើញមនុស្សមាន ទោសបាន ។


54

នៅក្នុងការជំនុំជំរះរបស់ព្រះមានច្បាប់ឬគំរូ មួយ ហើយលោកយ៉ាកុបបានបញ្ជាក់នូវ
ច្បាប់ដែលនឹងត្រូវប្រព្រឹត្តតាមនោះ។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



55

(ព្រះគម្ពីរ យ៉ាកុប ២:១២)

"ចូរឱ្យអ្នករាល់គ្នានិយាយ ព្រមទាំងប្រ ព្រឹត្តបែបដូចជាក្រិត្យវិន័យ នៃសេចក្តីសេរី ភាព រៀបនឹងជំនុំជំរះអ្នកហើយចុះ"

យ៉ាកុប ២:១២


56

(ព្រះគម្ពីរ យ៉ាកុប ២:១១)

នៅក្នុងខមុននេះ យ៉ាកុបបានពិពណ៌នា អំពីក្រិត្យវិន័យពីរ "កុំអោយផិតក្បត់" និង "កុំអោយសម្លាប់" ដូច្នោះក្រិត្យវិន័យ១០ប្រការរបស់ព្រះ ត្រូវបានគេឃើញយ៉ាងប្រត្យក្សថា ជា "ច្បាប់នៃសេរីភាព" ដែលដោយសារច្បាប់ នោះ ជីវិតមនុស្សនឹងត្រូវបានជំនុំជំរះ។



57

(វីដេអូ ៤វិនាទី) ការជំនុំជំរះនឹងកំណត់ យ៉ាងច្បាស់ថា តើយើងនឹងឈរនៅ ខាងណា នៅក្នុងមហាវិវាទរវាងព្រះ និងសាតាំងនោះ។

តើយើងនៅខាងព្រះគ្រីស្ទឬ? តើយើងបាន អនុញ្ញាតអោយទ្រង់ដាក់ជីវិតទ្រង់នៅក្នុងយើង ហើយឬនៅ?


58

តើយើងមានសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ សំរាប់ទ្រង់ និងព្រះហឫទ័យទ្រង់ដែលបាន បញ្ជាក់នៅក្នុងក្រិត្យវិន័យ១០ប្រការហើយ ឬនៅ? តើវា ជាសេចក្តីប៉ងប្រាថ្នារបស់ យើងឬទេ ដែលនឹងដើរតាម ព្រះហឫទ័យនិងកម្លាំងរបស់ទ្រង់នោះ?

តើទ្រង់បានសរសេរបញ្ញត្តិនេះនៅ ក្នុងចិត្តរបស់យើងហើយឬនៅ?


59

លោកអ្នកឃើញទេ នៅពេលដែលជន អន្តោប្រវេសន៍ប្រាថ្នា អោយមានសញ្ជាតិនៃ ប្រទេសណាមួយនោះ ពួកគេនឹងត្រូវគេ តម្រូវអោយសូត្រពាក្យសច្ចាប្រណិធាន ចំពោះប្រទេសនោះ ដោយសន្យាថា នឹង ធ្វើជាពលរដ្ឋដ៏ស្មោះត្រង់និងគោរពច្បាប់នៃ ទឹកដីនោះ។



60

(វីដេអូ១០វិនាទី)ដូចជាគ្រីស្ទានក៏ដូច្នេះដែរ នៅពេលដែលពួកគេបានទទួល ព្រះគ្រីស្ទ និងសំរេចក្លាយខ្លួនជាពលរដ្ឋនៃ នគររបស់ព្រះ ទ្រង់សូមអោយពួកគេសូត្រ នូវសេចក្តីស្រឡាញ់ និងពាក្យសច្ចា ប្រណិធាន របស់ពួកគេថ្វាយទ្រង់ និង គោរពច្បាប់នៃរដ្ឋាភិបាលរបស់ទ្រង់។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


61

ទោះជាយ៉ាងនេះក៏ដោយ ក៏ជនអន្តោប្រវេសន៍ទាំងអស់មិនបាននៅស្មោះត្រង់ទៅនឹងការសច្ចាប្រណិធានរបស់គេដែរ។ ខ្លះពីខាងក្រៅ គេហាក់ដូចជាពលរដ្ឋស្មោះត្រង់នៃដែនដីនោះ ប៉ុន្តែក្រោយមកបាន រកឃើញថា ជាជនវិទ្ធង្សនាវិញ។ នៅពេលដែលការនោះត្រូវបានបង្ហាញឡើងពី សញ្ជាតិរបស់ពលរដ្ឋនោះនឹងត្រូវបានគេដក ហូតវិញ ហើយគេត្រូវបាននិរទេសចេញ។


62

ដូចគ្នានេះដែរ មិនមែនគ្រីស្ទានទាំងអស់ នៅស្មោះត្រង់ចំពោះពាក្យសច្ចារបស់ពួកគេ ទេ។ វាមិនទាន់គ្រប់គ្រាន់ទេ ដែលអះអាង ថា សុចរិត នៅពេលនេះយើងត្រូវតែស្មោះត្រង់ជាមួយនឹងទ្រង់រហូតដល់ទ្រង់យាងមក។

វាមិនទាន់គ្រប់គ្រាន់ទេដែលអះអាងថា ជាអ្នកដើរតាមព្រះគ្រីស្ទនោះ គឺយើងត្រូវ តែអនុញ្ញាត អោយជីវិតដែលស្តាប់បង្គាប់ និងស្មោះត្រង់ដ៏គ្រប់លក្ខណ៍របស់ព្រះ យេស៊ូវគង់នៅក្នុង យើង។


63

(ព្រះគម្ពីរ ម៉ាថាយ ៧:២១)

"មិនមែនអស់អ្នកណាដែលគ្រាន់តែ និយាយមកខ្ញុំថា ព្រះអម្ចាស់អើយៗ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ


64

គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះ វរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ" ម៉ាថាយ ៧:២១

វិវាទទាំងមូលរវាងការល្អនិងការអាក្រក់ រវាងព្រះគ្រីស្ទនិងសាតាំង គឺអំពីអត្តចរិតនៃសេចក្តីស្រឡាញ់របស់ព្រះ។


65

ហើយបញ្ញត្តិគឺជាគំរូមួយដែលបាន សរសេរអំពីអត្តចរិតនោះ។ ដូច្នេះបញ្ញត្តិនោះគឺជាចំណុចដ៏សំខាន់បំផុត ក្នុងការជំនុំ ជំរះចុងក្រោយ។


66

ប៉ុន្តែហេតុការណ៍ដ៏ធំហួសនិស្ស័យ ហើយដែលគ្រីស្ទានភាគតិចបានដឹងនោះ គឺថា តុលាការនៃនគរស្ថានសួគ៌កំពុងមាន ដំណើរការឥឡូវនេះហើយ! តាមពិតព្រះ គម្ពីរចុងក្រោយ វិវរណៈបង្ហាញថា ការ ជំនុំជំរះរបស់ព្រះកំពុងដំណើរការឥឡូវនេះ។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


67

ហេតុដូច្នោះហើយបានជានៅក្នុងជំពូកបញ្ចប់
នៃព្រះគម្ពីរវិវរណៈ លោកយ៉ូហានបានដៅ បង្ហាញការប្រកាសចុងក្រោយដល់ពិភព
លោកនិងសេចក្តីអញ្ជើញនៅក្នុងពាក្យពេចន៍ ទាំងនេះ។


68

(ព្រះគម្ពីរ វិវរណៈ ១៤:៦,៧)
"ខ្ញុំឃើញទេវតា១ទៀតកំពុងហោះកាត់ កណ្តាលមេឃ


69

ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សំរាប់នឹងថ្លែងប្រាប់ដល់អស់មនុស្សនៅផែនដី-


70

គឺដល់គ្រប់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ


71

ទេវតានោះបន្លឺសំឡេងយ៉ាងខ្លាំងថា "ចូរ កោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អ របស់ទ្រង់ចុះ
ដ្បិតពេលដែលទ្រង់ត្រូវជំ នុំជំរះនោះបានមកដល់ហើយ


72

ចូរក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ
វិវរណៈ ១៤:៦,៧


73

លោកអ្នកនឹងកត់សំគាល់ឃើញថា ដំណឹង នេះមិនបាននិយាយថា "ការជំនុំជំរះនឹងមក ដល់"
ទេតែបាននិយាយថា "ពេលវេលា នៃការជំនុំជំរះបានមកដល់ហើយ"

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


74

ផ្នែកទីពីរនៃសារទាំងបីត្រាស់ហៅរាស្ត្ររបស់ ព្រះ អោយចេញពីប្រពន្ធ័សាសនាក្លែង ក្លាយដែលនឹងមាននៅសម័យចុងក្រោយ នេះ។
ផ្នែកបញ្ចប់នៃដំណឹងចុងក្រោយទៅកាន់ ពិភពលោកនេះ ប្រកាសដល់រាស្ត្ររបស់ព្រះអោយប្រយ័ត្នចំពោះការថ្វាយបង្គំអំណាច របស់សត្វនៃគម្ពីរវិវរណៈជំពូកទី១៣។


75

(ព្រះគម្ពីរ វិវរណៈ ១៤:៩,១០)
"បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វានៅលើ ថ្ងាស ឬនៅដៃ


76

អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅ របស់ព្រះ ជាស្រាឥតលាយ ដែលចាក់ទៅក្នុងពែងនៃសេចក្តីក្រោធរបស់ទ្រង់"
វិវរណៈ ១៤:៩,១០
ឥឡូវនេះសូមកត់សំគាល់ខ១៤និង១៥ ដែលមានការប្រកាសរបស់ទេវតាបីអង្គ:


77

(ព្រះ វិវរណៈ ១៤:១៤,១៥)
"ខ្ញុំក្រឡេកទៅឃើញពពកស១ ហើយ មាន ១អង្គដូចជាកូនមនុស្ស គង់នៅលើ ពពកនោះ


78

ទាំងពាក់មកុដមាស ហើយកាន់កណ្តៀវដ៏មុត


79

រួចមានទេវតា១ទៀតចេញពីព្រះវិហារមក បន្លឺដោយសំឡេងយ៉ាងខ្លាំងដល់ព្រះអង្គដែលគង់លើពពកថា


80

សូមលូកកណ្តៀវទ្រង់ទៅច្រូតចុះ ដ្បិតជាវេលាត្រូវច្រូតហើយ

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


81

ពីព្រោះនៅផែនដីបានទុំជាស្រេច"

វិវរណៈ ១៤:១៤,១៥


82

តើអ្វីទៅជាចំរូតនៃផែនដី? វាគឺជាចុង បញ្ចប់នៃពិភពលោក។ ចំរូតសំដៅទៅលើ ការយាងមកវិញជាលើកទីពីររបស់ព្រះ គ្រីស្ទ។ តើមានអ្វីកើតឡើងមុនពេលព្រះ យេស៊ូវយាងមកវិញ? គឺមានការជំនុំជំរះ របស់ព្រះ។

ការជំនុំជំរះរបស់ទ្រង់បង្ហាញអោយឃើញថា តើអ្នកណាដែលបានរៀបចំខ្លួនសំរាប់ ការយាងមករបស់ទ្រង់។ ប៉ុន្តែយើងត្រូវតែ ឈប់បង្អង់ដើម្បីពិនិត្យអង្កេតអំពីប្រធាន បទនៅក្នុងជំរៅដ៏ធំធេងនេះ។ ប្រហែលជា អ្នកកំពុងងឿងឆ្ងល់ថា តើការជំនុំជំរះ នេះនឹងចាប់ផ្តើមនៅពេលណា?


83

គន្លឹះនៃសំនួរនោះ ត្រូវបានគេរកឃើញនៅ

ក្នុងបទទំនាយ ដែលគួរអោយកត់សំគាល់ មួយ នៅក្នុងព្រះគម្ពីរដានីយ៉ែល


84

(ព្រះគម្ពីរ ដានីយ៉ែល ៨:១៤)

"អ្នកនោះក៏ប្រាប់មកខ្ញុំថា ដរាបដល់បាន កន្លង២៣០០ ព្រឹកនិងល្ងាចទៅ នោះទើប ទីបរិសុទ្ធនឹងបានស្អាតឡើងវិញ"

ដានីយ៉ែល៨:១៤។

នេះគឺជាបទទំនាយដែលទស្សនទាយអំពី រយៈពេលយូរជាងគេបំផុតនៅក្នុងព្រះគម្ពីរ។


85

(ព្រះគម្ពីរ អេសេគាល ៤:៦)

នៅក្នុងបទទំនាយយើងកត់សំគាល់ថា១ថ្ងៃស្មើនឹង១ឆ្នាំ។ "អញបានកំណត់១ថ្ងៃ ទុកជា១ ឆ្នាំដល់ឯង" "អេសេគាល៤:៦។ ដូច្នេះ២៣០០ថ្ងៃតំណាងអោយ២៣០០ឆ្នាំ។



86

២៣០០ឆ្នាំ គឺជាផ្នែកនៃបទទំនាយដ៏ទូលំទូ លាយមួយ ដែលបានរកឃើញនៅក្នុងព្រះ គម្ពីរដានីយ៉ែលជំពូក៧,៨ និង៩។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



87

បទទំនាយនេះបង្ហាញយ៉ាងជាក់លាក់អំពីថ្ងៃ ខែដ៏ត្រឹមត្រូវនៃការជ្រមុជទឹក និងការឆ្កាង របស់ព្រះអង្គម្ចាស់នៃយើង។ វាក៏បង្ហាញ យ៉ាងច្បាស់អំពីពេលដែល ការជំនុំជំរះចាប់ ផ្តើម។



88

២៣០០ថ្ងៃនៃបទទំនាយឬរយៈពេល២៣០០ឆ្នាំនេះ ចាប់ផ្តើមនៅពេលដែលស្តេច អើថា សើកសេស ចេញបញ្ជាអោយកសាងទីក្រុង យេរូសាឡិមឡើងវិញ និងស្ថាបនាសេដ្ឋកិច្ច នៃទីក្រុងនេះផង។ ពួកអ៊ីស្រាអែលត្រូវបានគេចាប់ជាឈ្លើយទៅ បាប៊ីឡូនអស់រយៈពេល៧០ឆ្នាំ ហើយគេ ចង់ត្រឡប់ទៅផ្ទះនិងកសាងទីក្រុងរបស់គេ ឡើងវិញ។


89

ទីបំផុត នៅក្នុងឆ្នាំ៤៥៧មុនគ.ស ស្តេច បានចេញនូវព្រះរាជក្រិត្យដែលគេបានរង់ចាំ ជាយូរមកហើយនោះ។ ២៣០០ឆ្នាំចាប់ពី ថ្ងៃនោះមកចប់នៅក្នុងគ.ស១៨៤៤។ ឥឡូវនេះចូរមើលទៅខព្រះគម្ពីររបស់ យើងវិញ។ លុះដល់ពីរពាន់បីរយថ្ងៃនៃ បទ ទំនាយ ឬពីរពាន់បីរយឆ្នាំ ឆ្នាំពិតប្រាកដនោះទើប ទីបរិសុទ្ធនឹងត្រូវ បានសំអាត។ យើងបានរកឃើញថា បទទំនាយនេះបានបញ្ចប់នៅគ.ស១៨៤៤ តើអ្វីទៅជាការសំអាតទីបរិសុទ្ធ?



90

ក្នុងឆ្នាំ១៨៤៤ ជាការដែលព្រះគម្ពីរបាន ពិពណ៌នាថា ពេលវេលានៃការជំនុំជំរះបាន ចាប់ផ្តើម។ នាឡិកាចោលបន្លឺសំឡេង។ លោក អ្នកអាចសួរថា "តើការជំនុំជំរះ ទាក់ទង យ៉ាងណាទៅនឹងការសំអាត ទីបរិសុទ្ធ ដែលដានីយ៉ែលបានទាយទុក មកនេះនឹងកើតឡើង នៅចុងនៃ២៣០០ថ្ងៃ?"


91

តើអ្វីទៅជាការសំអាតទីបរិសុទ្ធ? តើវា ត្រូវធ្វើអ្វីជាមួយនឹងការជំនុំជំរះ? ព្រះគម្ពីរ ពណ៌នាអំពីទីបរិសុទ្ធពីរ.មួយនៅផែនដី មួយទៀតនៅស្ថានសួគ៌។


92

ក្នុងសម័យអ៊ីស្រាអែលបុរាណ មនុស្ស តែងនាំយកដង្វាយដុតទៅកាន់ទីបរិសុទ្ធរៀង រាល់ថ្ងៃ។


93

នៅទីនោះពួកគេលន់តួបាបរបស់ពួកគេ ហើយយកជីវិតកូនចៀម ដើម្បីបង្ហាញ សេចក្តីជំនឿរបស់គេក្នុងការសុគតរបស់ ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះនៅពេលអនាគត។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


94

សព្វថ្ងៃនេះប្រសិនបើយើងធ្វើបាប


95

ទោះបីជាយ៉ាងណាក៏ដោយ មុនភ្នំកាល់វ៉ារី (កាល់វ៉ារី) មនុស្សគ្មាន យញ្ញបូជាដើម្បីសំឡឹងមើលទៅខាងក្រោយឡើយ ដូច្នេះដោយសេចក្តីជំនឿ ពួកគេសំឡឹងមើលទៅខាងមុខ ជំនួស អោយពេលដែល "កូនចៀម" នៃព្រះ នឹងត្រូវសុគតដើម្បីពួកគេ។

តាមសកម្មភាពនៃការថ្វាយសត្វ ដែល គ្មានកំហុសជាយញ្ញបូជានេះ ពួកគេបាន ប្រកាស សេចក្តីជំនឿរបស់ ពួកគេទៅលើ ព្រះអង្គ សង្គ្រោះមួយអង្គ ដែលនឹងយាង មក និង សុគតដើម្បីធ្វើអោយពួកគេបាន ទទួលការអត់អោនទោស។


96

បន្ទាប់មកបាបរបស់គេបានត្រូវផ្ទេរទៅ កាន់ទីបរិសុទ្ធ ដោយសង្ឃបានរលាស់ឈាមពីសត្វនៅពីមុខវាំងននៃទីបរិសុទ្ធបំផុតក្នុងទីបរិសុទ្ធជានិមិត្តរូប។



97

បន្ទាប់មកទៀតនៅក្នុងមួយថ្ងៃនៃឆ្នាំ

នីមួយៗ ពួកកូនចៅអ៊ីស្រាអែលបានប្រារព្ធ ធ្វើពិធីដ៏ធំ និងពិសិដ្ឋបំផុតមួយហៅថា ថ្ងៃធួននិងបាប ឬក៏ការសំអាតទីបរិសុទ្ធ។ សំរាប់ពួកអ៊ីស្រា អែលគឺជា ថ្ងៃជំនុំជំរះ។


98

ដប់ថ្ងៃមុនថ្ងៃធួននឹងអំពើបាប ត្រែត្រូវបាន បន្លឺឡើង ដើម្បីរំលឹកដល់ពួកអ៊ីស្រាអែល ថា ដល់ពេលវេលាដែលពួកគេត្រូវធ្វើ បញ្ជីសារពើភ័ណ្ឌនៃជីវិតរបស់គេ-ជាការកែប្រែចិត្តនិងលន់តួបាប។

អ្នកណាដែលមិនបានធ្វើដូច្នោះ នឹងត្រូវបំបរ បង់ចេញពីជំរំ។



99

"ដ្បិតនៅថ្ងៃនោះនឹងបានធ្វើឱ្យធួននឹងឯងរាល់គ្នា ដើម្បីនឹងញែកចេញជាស្អាត



100

នោះឯងរាល់គ្នានឹងបានស្អាតអំពីអំពើបាបទាំងប៉ុន្មាននៅចំពោះព្រះយេហូវ៉ា" (លេវីវិន័យ ១៦:៣០)

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


101

ឥឡូវនេះព្រះគម្ពីរហេព្រើរ បញ្ជាក់ យ៉ាងច្បាស់ថា ទីបរិសុទ្ធនៅផែនដី និងការងាររបស់ខ្លួនគឺជាការបកស្រាយអំពីទីបរិសុទ្ធ នៅស្ថានសួគ៌ ដែលព្រះគ្រីស្ទជាសម្តេចសង្ឃដ៏ខ្ពស់របស់យើង បានអត់ទោសបាប របស់យើងរាល់គ្នា។


102

(ព្រះគម្ពីរ ហេព្រើរ ៨:១,២)
ប៉ុលនិយាយថា "យើងរាល់គ្នាមានសម្តេច សង្ឃ១អង្គយ៉ាងនោះ ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្គនៃឫទ្ធានុភាពនៅស្ថានសួគ៌


103

ជាអ្នកមានការងារក្នុងទីបរិសុទ្ធ ហើយក្នុង រោងឧបោសថដ៏ពិត ដែលព្រះអម្ចាស់បាន ដំឡើង មិនមែនជាមនុស្សទេ"
ហេព្រើរ ៨:១,២


104

(ព្រះគម្ពីរ ហេព្រើរ ៩:១១,១២,២៤)
ម្តងទៀត "ប៉ុន្តែកាលព្រះគ្រីស្ទបានយាងមកធ្វើជាសម្តេចសង្ឃ...


105

គឺដោយសារព្រះលោហិតនៃព្រះ នោះទ្រង់ បានយាងចូលក្នុងទីបរិសុទ្ធបំផុត១ដងជាសំ រេច


106

ទាំងបានសេចក្តីប្រោសលោះ នៅអស់កល្ប ជានិច្ច


107

ដ្បិតព្រះគ្រីស្ទទ្រង់មិនបានយាងចូលទៅក្នុងទីបរិសុទ្ធ ធ្វើដោយដៃ


108

ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបាន ចូលទៅក្នុងស្ថានសួគ៌នោះឯង

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត



109

ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំ ពោះព្រះភ័ក្ត្រនៃព្រះ តំណាងយើងរាល់គ្នា"

ហេព្រើរ ៩:១១,១២,២៤

ការសុគតរបស់ព្រះគ្រីស្ទនៅភ្នំរលាក្បាល

(កាល់វ៉ារី) បាន ផ្ដល់យញ្ញបូជាអោយធួន នឹងបាបយ៉ាងគ្រប់គ្រាន់ ដល់អំពើបាប

របស់យើងទាំងអស់គ្នា។



110

(ព្រះគម្ពីរ ហេព្រើរ ៧:២៥)

"...ទ្រង់អាចនឹងជួយសង្គ្រោះសព្វគ្រប់

បានដល់មនុស្សទាំងអស់ ដែលចូលទៅឯ ព្រះ ដោយសារទ្រង់



111

ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បី នឹងជួយអង្វរជំនួសគេ"

ហេព្រើរ ៧:២៥

រោងឧបោសថ ឬទីបរិសុទ្ធពិតប្រាកដនៅស្ថានសួគ៌។

អ្វីៗទាំងឡាយដែលកើតមាននៅផែនដីជាគំរូនៃអ្វីៗដែល

កើតឡើងក្នុងផែនការនៃការសង្គ្រោះ។ ព្រះយេស៊ូវជាកូនចៀមដែលគេសម្លាប់។

ព្រះយេស៊ូវជាសម្ដេចសង្ឃដែលមានព្រះជន្មរស់។ ព្រះយេស៊ូវគឺជាសម្ដេចសង្ឃដ៏ធំរបស់យើង។

ព្រះយេស៊ូវគឺជាសង្ឃជាន់ខ្ពស់របស់ពួកអ៊ីស្រា អែល ដែលចូលទៅក្នុងទីបរិសុទ្ធបំផុតមួយឆ្នាំម្ដង

ដូច្នេះនៅទីចុងបំផុត ព្រះយេស៊ូវបានយាងចូលក្នុងទីបរិសុទ្ធបំផុត

ដើម្បីធ្វើការនៃការជំនុំជំរះរបស់ទ្រង់។



112

(ព្រះគម្ពីរ ម៉ាថាយ ១០:៣២,៣៣)

ក្នុងការជំនុំជំរះ គឺជាទំនាក់ទំនងនិង អាកប្បកិរិយារបស់យើងឆ្ពោះទៅរកព្រះគ្រីស្ទ

ដែលនឹងបញ្ចប់វាសនាដ៏អស់កល្បរបស់ យើង។ ព្រះគ្រីស្ទវង់ចាំសង្គ្រោះយើង។

ទ្រង់កំពុងតែធ្វើអ្វីៗគ្រប់បែបយ៉ាង ដែល ទ្រង់អាចធ្វើបាន ដើម្បីសង្គ្រោះយើងទាំង អស់គ្នា។

ទ្រង់មានបន្ទូលថា "ដូច្នេះអស់ អ្នកណាដែលទទួលថ្លែងប្រាប់ពីខ្ញុំ នៅ ចំពោះមនុស្សលោក



113

នោះខ្ញុំនឹងទទួលថ្លែងប្រាប់ពីអ្នកនោះ

នៅចំពោះព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថាន សួគ៌ដែរ

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


114

តែអ្នកដែលមិនព្រមទទួលស្គាល់ខ្ញុំ នៅមុខ មនុស្សលោក នោះខ្ញុំក៏មិនព្រមទទួលស្គាល់ អ្នកនោះ នៅចំពោះព្រះវរបិតាខ្ញុំ ដែលគង់ នៅស្ថានសួគ៌ដែរ”
ម៉ាថាយ១០:៣២,៣៣


115

លោកអ្នកឃើញទេ អ្នកមិនមែនឈរនៅ តែម្នាក់ឯងនៅក្នុងការជំនុំជំរះនោះទេ! ប្រសិនបើយើងបានលន់តួទៅព្រះគ្រីស្ទ ទ្រង់ នឹងលន់តួចំពោះព្រះវរបិតាទ្រង់ជំនួសយើង។ ប្រសិនបើយើងជារបស់ព្រះគ្រីស្ទ ទ្រង់ ជាមេធាវីរបស់យើង។ ដោយសារព្រះ យេស៊ូវ យើងនឹងឈរនៅចំពោះព្រះភ័ក្ត្រ ព្រះ ដូចជាមិនដែលបានធ្វើបាបសោះ។


116

បញ្ជីកត់ត្រារបស់យើងនឹងបង្ហាញតែជីវិត
ដែលពោរពេញដោយសេចក្តីស្រឡាញ់នៃព្រះអង្គសង្គ្រោះរបស់យើង។ ដូច្នេះ សំឡាញ់ទាំងឡាយអើយ គ្មានអ្វីដែលគួរអោយភ័យ ខ្លាចនៅថ្ងៃជំនុំជំរះនោះទេ ចំពោះអ្នកដែលស្រឡាញ់និងដើរតាមព្រះយេស៊ូវដោយអស់ពីចិត្ត និងអស់អំពីព្រលឹង។
ព្រោះព្រះយេស៊ូវនឹងបង្ហាញអំពីគុណ
សម្បត្តិនៃការបង្ហូរលោហិតរបស់ទ្រង់ ដើម្បីគ្រប លើបាបដែលបានលន់តួ ដូចលោកយ៉ូហាន បានសរសេរថា:


117

(ព្រះគម្ពីរ យ៉ូហានទី១ ១:៧)
“ហើយព្រះលោហិតព្រះយេស៊ូវគ្រីស្ទ ជា ព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់”
យ៉ូហានទី១ ១:៧



118

(វីដេអូ ១៣វិនាទី) យើងកំពុងរស់នៅក្នុង ពេលចុងក្រោយបង្អស់នៃផែនដី។ ការមក ដល់ដំបូងនៃការជំនុំជំរះបានមកប្រជុំគ្នានៅ តុលាការនៃស្ថានសួគ៌តាំងពីឆ្នាំ១៨៤៤។



119

(វីដេអូ ជាបន្ត)មិនបាច់សង្ស័យឡើយ ការ ជំនុំជំរះបានចាប់ផ្តើមពីអេបិល អ្នក សប្បុរសដំបូង ដែលបានស្លាប់នៅលើផែនដី
នេះ។

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


120

(ព្រះគម្ពីរ ពេត្រុសទី១ ៤:១៧)
"ដ្បិតពេលវេលាដែលសេចក្ដីជំនុំជំរះ ត្រូវ ចាប់ផ្តើមពីដំណាក់នៃព្រះទៅនោះ បានមកដល់ហើយ"
ពេត្រុសទី១ ៤:១៧
ម្យ៉ាងវិញទៀតការជំនុំជំរះចាប់ផ្ដើមជាមួយអ្នកដែលអះអាងថាជារាស្ត្ររបស់ព្រះ។


121

យើងអាចស្រមៃឃើញនៅក្នុងគំនិតរបស់ យើង អំពីថ្ងៃរបស់អេបិលនៅក្នុងតុលាការ របស់អេបិល។ នៅពេលដែលករណីរបស់គាត់បានមកដល់ តុលាការ ព្រះឃើញជីវិតរបស់អេបិល ហើយបានឃើញកំណត់ត្រា នៃការទទួល ការសុគតរបស់កូនចៀមនៃព្រះរបស់គាត់។


122

សកម្មភាពចុងក្រោយបង្អស់មួយនៃកំណត់ត្រា របស់អេបិលនៅក្នុងព្រះគម្ពីរ គឺយញ្ញបូជា (ដង្វាយដុត)ដែលគាត់បានថ្វាយ បង្ហាញពី សេចក្ដីជំនឿ លើការយាងមករបស់ព្រះដ៏ប្រោសលោះមួយអង្គ។ ជីវិតរបស់ព្រះគ្រីស្ទត្រូវបានកត់ចូល ទៅក្នុងបញ្ជីជីវិតរបស់គាត់។ អំពើបាប របស់គាត់ត្រូវបានគ្របដណ្ដប់ដោយ លោហិតរបស់ព្រះគ្រីស្ទ។


123

លោកអ្នកអាចជឿជាក់ថា ព្រះយេស៊ូវ ជាអាវ៉ូការបស់អេបិល បានលាត ព្រះហស្ត ដែលបានបោះដែកគោលរបស់ទ្រង់ ហើយ មានបន្ទូលថា: "ព្រះវរបិតាអើយ ឈាមរបស់ខ្ញុំបានចេញថ្លៃលោះអេបិលហើយ" ហើយតើលោកអ្នកមិនអាចឮទេវតាដ៏ច្រើនរាប់មិនអស់បន្លឺឡើងដោយអំណរ នៅ ពេលដែលព្រះយេស៊ូវមានបន្ទូលថា "ដាក់ឈ្មោះអេបិលក្នុងបញ្ជីជីវិតទេឬអី!" ហើយ ឈ្មោះរបស់គាត់នៅទីនោះដដែល! ដូចនេះ ព្រះគ្រីស្ទបានសន្យាថា:


124

(ព្រះគម្ពីរ វិវរណៈ ៣:៥)
"អ្នកណាដែលឈ្នះនោះនឹងបានស្លៀក
ពាក់ស


125

ហើយអញមិនដែលលុបឈ្មោះអ្នកនោះចេញ
ពីបញ្ជីជីវិតឡើយ

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


126

អញនឹងថ្លែងប្រាប់ពីឈ្មោះអ្នកនោះ នៅ ចំពោះព្រះវរបិតាអញ និងចំពោះពួកទេវតា ផងដែរ”
វិវរណៈ៣:៥


127

ហើយគ្មានអ្វីត្រូវសង្ស័យឡើយ ឈ្មោះ
យូដាស ក៏ត្រូវបានលើកយកទៅតុលាការ នៅស្ថានសួគ៌ដែរ។
យូដាសគឺជាអ្នកដើរតាមព្រះគ្រីស្ទ-ជាម្នាក់ក្នុងចំណោមសាវករបស់ទ្រង់។
គាត់មិនមែនអាក្រក់ទាំងអស់ទេ ប៉ុន្តែ
ជីវិត របស់គាត់មិនបានស្មើនឹងអ្វីៗដែលគាត់បាន
អះអាងនោះទេ គាត់មិនបានស្រឡាញ់ព្រះ គ្រីស្ទឱ្យបានខ្លាំងជាងអ្វីៗទាំងអស់នៅក្នុងជីវិត
របស់គាត់នោះទេ!


128

មានពេលដែលគាត់ត្រូវបានទាញទៅឯព្រះ គ្រីស្ទ ប៉ុន្តែកំសោយមួយបាននាំគាត់ទៅកាន់ ផ្លូវមួយទៀត
រហូតគាត់បានលក់ព្រះរបស់ គាត់ក្នុងតំលៃប្រាក់៣០ដួង បន្ទាប់មកដោយ ការទង្គឹះចិត្ត
គាត់ក៏បានចងកខ្លួនឯង!


129

ព្រះយេស៊ូវបានស្រឡាញ់យូដាស។ ទ្រង់ ថែមទាំងបានឱនលាងធូលីដីពីជើងយូដាស
នៅយប់នៃបុណ្យលៀងព្រះ អម្ចាស់ចុង ក្រោយបង្អស់! ព្រះយេស៊ូវបាន សង្ឃឹមថា
នឹងអង្រួនចិត្តដ៏មានអំនួតនោះ។ ទ្រង់បានចង់ធ្វើជាមេធាវីរបស់គាត់ក្នុងថ្ងៃជំ
នុំជំរះនោះ។


130

ប៉ុន្តែយូដាសបានបែរចេញ។ ព្រះយេស៊ូវ មានការក្រៀមក្រំជាខ្លាំង នៅពេលដែល
ទ្រង់រំលឹកឈ្មោះយូដាសឡើងវិញ។ សេចក្តីសុចរិតរបស់យើងនឹងមិនមាន
ប្រសិទ្ធភាពឡើយនៅក្នុងការជំនុំជំរះ។
សូមស្តាប់:


131

(ព្រះគម្ពីរ អេសាយ ៦៤:៦)
“ដ្បិតយើងទាំងអស់គ្នាបានត្រឡប់ទៅ ដូចជាមនុស្សដែលមិនស្អាត ហើយអស់ ទាំងអំពើ
សុចរិតរបស់យើងខ្ញុំ ក៏ដូចជា អាវកខ្វក់ហើយ...”
អេសាយ ៦៤:៦

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


132

មានតែអ្នកដែលបន្តយកព្រះគ្រីស្ទជាទីមួយនៃ
ជីវិតគេទេ ដែលពាក់អាវផាយនៃសេចក្តី សុចរិតរបស់ព្រះគ្រីស្ទបាន។ បើមិនដូច្នេះទេ
គ្មានអ្នកណាអាចនឹង បង្ហាញអោយឃើញថា គ្មានទោសក្នុងការ ជំនុំជំរះនោះឡើយ។
ដូច្នេះឈ្មោះរបស់ យូដាសត្រូវបានលប់ចោលពីបញ្ជីជីវិត។


133

វាគឺជាពេលដ៏ឱឡារិកមួយក្នុងជីវិតរបស់ អ្នក ដូចជាពួកអ៊ីស្រាអែល ដែលយើងត្រូវ តែ
ធ្វើបញ្ជីសារពើភ័ណ្ឌនៃជីវិតរបស់ យើង។
យើងត្រូវតែថែរក្សាការប្តេជ្ញាចិត្តរបស់ យើង ចំពោះព្រះយេស៊ូវ ដែលជាការរៀប ចំតែមួយគត់
ដែលអាចធ្វើទៅបានសំរាប់ ដីការកោះរបស់យើងឡើងកាន់តុលាការ។
ពេលឆាប់ៗនេះ ពេលសាកល្បងចិត្ត មនុស្ស នឹងត្រូវបញ្ចប់ ហើយក្រឹត្យនឹងត្រូវ ចេញៈ


134

(ព្រះគម្ពីរ វិវរណៈ ២២:១១)
"អ្នកណាដែលទុច្ចរិត ឱ្យអ្នកនោះនៅតែ ទុច្ចរិត... អ្នកណាដែលបរិសុទ្ធ ឱ្យអ្នក
នោះនៅតែបរិសុទ្ធដដែល"
វិវរណៈ ២២:១១
នៅពេលនោះ សេចក្តីមេត្តាករុណានិង ការអភ័យទោសដែលព្រះបានប្រទានដល់
មនុស្សយ៉ាងយូរនឹងត្រូវបានដកចេញ។ ពាក្យដ៏ក្រៀមក្រំបំផុតក្នុងភាសាមនុស្ស គឺ
ជាពាក្យរបស់អ្នកដែលបោះបង់សេចក្តី សង្គ្រោះ-អ្នកដែលមិនទទួលព្រះគ្រីស្ទជា ព្រះអង្គម្ចាស់
និងជាមេធាវីរបស់គេ។


135

(ព្រះគម្ពីរ យេរេមា ៨:២០)
ពួកគេនឹងនិយាយថា "រដូវច្រូតកាត់ បានកន្លងហើយ រដូវក្តៅក៏ផុតទៅ តែយើង រាល់គ្នា
មិនទាន់បានសង្គ្រោះ នៅឡើយ"
យេរេមា ៨:២០
ហើយព្រះយេស៊ូវបានយាងត្រឡប់មក កាន់ផែនដីដូចដែលយើងបានអាន


136

(ព្រះគម្ពីរ វិវរណៈ ២២:១២)
"មើលអញមកជាឆាប់ ក៏នាំយករង្វាន់ មកជាមួយ ដើម្បីនឹងចែកឱ្យគ្រប់គ្នា តាម
ការដែលខ្លួនបានធ្វើ"
វិវរណៈ ២២:១២

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត




137

មិត្តអើយព្រះយេស៊ូវចង់ធ្វើជាមេធាវី របស់លោកអ្នក ក្នុងពេលជំនុំជំរះនោះ មែនទែន!

ទ្រង់ចង់អោយលោកអ្នកទទួលយញ្ញបូជា របស់ទ្រង់នៅភ្នំរលាក្បាល(កាល់វ៉ារី) ទ្រង់ចង់ឱ្យលោកអ្នកលន់តួបាបរបស់លោក អ្នក ដើម្បីអោយទ្រង់អាចបំបាត់វាចេញ។ ទ្រង់ចង់អោយមានជីវិតរបស់អ្នកត្រូវបានកត់ ក្នុងបញ្ជីជីវិត។ លោកយ៉ូហានពណ៌នាអំពីអ្នកដែលបានចូល ក្នុងទីក្រុងបរិសុទ្ធនិងអ្នកដែលមិនបានចូលថា:


138

វិវរណៈ ២១:២៧

"ក៏គ្មានអ្វីស្មោកគ្រោក ឬអ្នកណាដែលប្រ ព្រឹត្តបែបគួរខ្ពើម ឬសេចក្តីកំភូតណាចូល ទៅក្នុងទីក្រុងនោះបានឡើយ


139

ចូលបានតែអ្នកណាដែលមានឈ្មោះកត់ទុក ក្នុងបញ្ជីជីវិតរបស់កូនចៀមប៉ុណ្ណោះ"

# ៩. ការប្រឈមមុខនឹងការជំនុំជំរះដោយមានការទុកចិត្ត


140

តើលោកអ្នកចង់បើកចិត្តថ្វាយ
ព្រះយេស៊ូវ ឥឡូវនេះឬទេ?
តើលោកអ្នកចង់សុំអោយ ទ្រង់យក ចេញពីជីវិតលោកអ្នក នូវអ្វីដែលធ្វើឱ្យ
លោកអ្នកមិនអាចនៅក្នុងនគរទ្រង់បាន
ឬទេ? ក្នុងថ្ងៃជំនុំជំរះ ព្រះបង្ហាញអ្វីៗទាំង អស់អំពីយើង។
អ្វីៗទាំងអស់នឹងត្រូវប្រកាសអោយដឹងឮ
ពាសពេញលោកសន្និវាសនេះ។
អំពើបាបរបស់យើងនឹងត្រូវបានកត់ត្រាទុក
ហើយ។
តើលោកអ្នកចង់អោយអំពើបាបរបស់អ្នក
ត្រូវបានគ្របបាំងឬទេ?
គ្របបាំងដោយព្រះលោហិតព្រះយេស៊ូវ តើលោកអ្នកចង់អោយព្រះយេស៊ូវបោះជំហាន
ទៅមុខហើយមានបន្ទូលថា "អើ បុរសនេះ ស្ត្រីនេះជារបស់ខ្ញុំ។
ខ្ញុំបានអត់ឱនទោសដល់អំពើបាបរបស់
គេហើយ ខ្ញុំបានលុបបំណុលគេចោល ហើយ ខ្ញុំបានអភ័យទោសដល់កំហុសរបស់ គេហើយ។
អំពើបាបរបស់គេត្រូវបានគ្រប ដណ្តប់ដោយលោហិតរបស់ខ្ញុំ។ ខ្ញុំបានបំបាត់វាចោល
ពីបញ្ជីរៀងរហូតហើយ" ដែរឬទេ?
ព្រះយេស៊ូវឈរនៅឯបល្ល័ង្ក នៃស្ថានសួគ៌។ ទ្រង់ឈរនៅថ្ងៃជំនុំជំរះ ជាព្រះអង្គសង្គ្រោះរបស់អ្នក។
ឥឡូវនេះ! នៅពេលនេះ! តើលោកអ្នក អញ្ជើញមកឯទ្រង់ឬទេ? តើលោកអ្នក
នឹងថ្វាយជីវិតលោកអ្នកទាំងស្រុងដល់ទ្រង
់ឬទេ?
សូមលើកដៃអ្នកឡើងទៅស្ថានសួគ៌ ឥឡូវនេះ នៅពេលដែលលោកអ្នក អធិស្ឋាន និងសូមនិយាយថា
"បពិត្រព្រះ អម្ចាស់អើយ សូមទ្រង់ទទួលជីវិតទូល បង្គំផង ដ្បិតទូលបង្គំ ចង់ក្លាយទៅជា
របស់ផងទ្រង់"។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?



1

តើវាធ្វើអោយមានការខុសគ្នាយ៉ាងពិតប្រាកដមែនឬទេ?



2

តើលោកអ្នកបានកត់សំគាល់ទេថា មានអំ ពើឧក្រិដ្ឋកម្មកើតមានឡើងជាច្រើន នៅ តាមទីក្រុងនានាពាសពេញពិភពលោកនេះ?
វាកំពុងបានបង្ហាញក្នុងរបៀបដ៏គួរអោយភ្ញាក់ ផ្អើលមួយ។


3

ថ្ងៃមួយ មានមនុស្សម្នាក់បានវាយ
សន្ធាប់ចូលទៅក្នុងទីបញ្ជាការដ្ឋានប៉ូលីសមួយដោយមានការខឹងសំបាយ៉ាងខ្លាំង។
មានគេបានទម្លុះចូលទៅក្នុងផ្ទះគាត់ ហើយយកបានរបស់មានតម្លៃខ្លះ។ គាត់បាន
ក្រឡេកឃើញចោរមួយភ្លែត ហើយបាន ទាមទារអោយប៉ូលីសចាត់វិធានការ អំពី បញ្ហានោះ។
ដូច្នេះ នាយតម្រួត ដែលទទួលខុសត្រូវ បាននាំគាត់ទៅកាន់គំនរសៀវភៅរូបថតនៃពួកចោរប្លន់។
គាត់បាននាំបុរសនោះអោយ មើលរូបថតរបស់មនុស្ស ដែលមានការ
កត់ត្រាពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋកម្ម ដើម្បី រកមើលក្រែងលោគាត់អាចស្គាល់ចោរនោះ បាន។


4

រំពេចនោះ នាយតម្រួតបាននិយាយថា "ចាំមួយភ្លែត" គាត់បានចង្អុលទៅលើទំព័រ មួយ
ហើយមើលដោយយកចិត្តទុកដាក់_ពី រូបថតនៃសៀវភៅរូបថត ទៅកាន់មុខបុរស នោះ
រួចមើលម្តងទៀត។
"គឺអ្នកឯងហ្នឹងហើយ" ប៉ូលីសឧទាន ឡើង "ហើយគាត់បាននិយាយថា មានដី
ការដ៏ត្រឹមត្រូវដើម្បីចាប់ខ្លួនអ្នក!"
នៅពេលដែលគាត់បានងាកចេញទៅ ម្ចាស់ផ្ទះដែលមានកំហឹងយ៉ាងខ្លាំង ដែល
បានដើរទន្ទ្រាំជើងចូលទៅកាន់ស្ថានីយ៍ប៉ូលីស ដោយទាមទាររកយុត្តិធម៌នោះ បានបញ្ចប់
ដោយការបង្ហាញថា គាត់ខ្លួនឯងនេះជា ឧក្រិដ្ឋជន!



5

ឧក្រិដ្ឋកម្ម និងអំពើហឹង្សាមានគ្រប់ទី កន្លែង ទោះបីនៅកន្លែងដែលអ្នកគិតថាមិន មានក៏ដោយ។
វាមាននៅកន្លែងធ្វើការ នៅក្នុងរោង ចក្រ នៅក្នុងភូមិរបស់យើង ក្នុងស្រុក
និងក្នុងទីក្រុងរបស់យើង។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


6

នៅប្រទេសខ្លះ អំពើកុបកម្ម ការធ្វើ បដិវត្តន៍ និងចោរកម្ម ជារឿងធម្មតាទៅ ហើយ។

តាមផ្លូវនានា បានក្លាយជាកន្លែងដែល គ្មានសុវត្ថិភាព។

ឃាតកម្ម ការប្លន់យន្តហោះ ការទម្លាក់ គ្រាប់បែកដណ្តើមទឹកដី ប្លន់ រំលោភ លួច ការលួចបន្លំ និងអំពើពុករលួយក្នុង រដ្ឋាភិបាល ត្រូវបានគេរាយការណ៍ជារៀង រាល់ថ្ងៃ នៅក្នុងប្រទេសជាច្រើននៅលើ សាកលលោកនេះ។

តើហេតុអ្វីបានជាអំពើឧក្រិដ្ឋកម្មកំពុង កើនឡើងយ៉ាងដូច្នេះ?

តើមានអ្វីនៅពីក្រោយខ្នង ការគ្មាន ច្បាប់ទម្លាប់ ដែលមិនធ្លាប់កើតមានឡើង ពីមុនមកនេះ?

តើពិភពលោកយើងនេះនឹងទៅជាយ៉ាង ណា?

---



7

នៅក្នុងប្រទេសលោកខាងលិច និងប្រ ទេសអ្នកមានជាច្រើននៅលើពិភពលោកនេះយុវជនជំនាន់ថ្មីមួយ ត្រូវបានចាប់ផ្តើមកើត ឡើង-យុវជនដែលកំពុងងឿងឆ្ងល់សង្ស័យ និងប្រឆាំង

ព្រះបានត្រាស់ហៅមនុស្សចាស់អោយធ្វើ ជាគំរូដល់កូនចៅរបស់គេ។

ក្មេងៗ គ្រាប់តាមទម្លាប់របស់សង្គម ដែលនៅជុំវិញពួកគេ។

តើអ្នកណានឹងធ្វើជាគំរូខាងព្រលឹងវិញ្ញាណ ដល់ពួកគេឬទេ?

---


8

ឪពុកកេងប្រវ័ញ្ចចំពោះការងារ ឬពន្ធ ដារ ម្តាយស្វែងរកការរំលូតកូន ហើយឪ ពុកម្តាយកេងគ្នាទៅវិញទៅមក។

---


9

កូនៗឃើញការនេះទាំងអស់!

ហើយគ្រួសារបាក់បែកកំពុងរស់នៅ ដោយមានស្លាកស្នាមយ៉ាងកខ្វក់!

តើអ្នកណានឹងបំពាក់បំប៉នទួងការដឹង ខុសនិងត្រូវនេះ ប្រសិនបើឪពុកម្តាយមិន អាច ឬនឹងមិនធ្វើនោះ?

ជាការពិតប្រាកដណាស់ ឪពុកម្តាយមិន អាចទុកការទទួលខុសត្រូវដ៏ធំនេះ អោយ ទៅសាលាទេ!

សាលាជាច្រើនមិនបានបង្រៀន ឬក៏គាំ ទ្រសីលធម៌នៃការរស់នៅនោះទេ។

ហាក់ដូចជាមានគំនិតជាទូទៅថា យើង មានគំរូសីលធម៌នៃព្រះគម្ពីរដ៏ធំធេង!

---


10

សូម្បីតែនៅក្នុងព្រះវិហារខ្លះ សព្វថ្ងៃនេះ ក៏កំពុងបង្រៀនថា ខ្នាតគំរូរបស់ព្រះអំពីការ ខុសនិងត្រូវនោះ លែងត្រូវបានគេប្រើទៀត ហើយ។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


11

ពួកគេនិយាយថា បញ្ញត្តិរបស់ទ្រង់ត្រូវ បានលុបចោលហើយ។


12

ឬក៏ថា បញ្ញត្តិទាំងនោះលែងទាក់ទងអ្វី ទៀតហើយ


13

ឬក៏ថា វាមិនអាចកាន់បានទេ។


14

ហើយជាលទ្ធផលនៃការទាំងនេះ មនុស្សជាច្រើនកំពុងប្រព្រឹត្តតាមផ្លូវរបស់គេ‑ ហើយសង្គមកំពុងប្រមូលផលបានជាចំរូត យ៉ាងធំធេងនូវ គ្រួសារបាក់បែក កូនដែលមិនអាចគ្រប់គ្រងបាន និងអំពើឧក្រិដ្ឋកម្ម យ៉ាងឃោរឃៅ។



15

(ព្រះគម្ពីរ ហូសេ ៨:៧)

នៅក្នុងពាក្យពេចន៍របស់ហោរាហូសេ និយាយថា "ពួកគេបានសាបព្រោះជាខ្យល់ ហើយនិងច្រូតកាត់បានជាខ្យល់គួចវិញ"


16

ប៉ុន្តែសំនួរត្រូវបានសួរថា: តើអ្នកណា នឹងវិនិច្ឆ័យនូវស្ថានភាពខុសឬត្រូវនេះ? តើមិនមែនជួនកាលសូម្បីតែការជំនុំជំរះ របស់ មនុស្សល្អ ក៏មិនបានត្រឹមត្រូវផងទេឬអី?

ប្រសិនបើគ្មានខ្នាតគំរូនៃការខុសនិងត្រូវ នៅខាងក្រៅយើងនោះទេ យើងសឹងតែមិនអាចកែតម្រូវអ្វីបានសោះឡើយ។



17

(ព្រះគម្ពីរ សុភាសិត ១៦:២៥)

ប៉ុន្តែព្រះគម្ពីរបានរំលឹកយើងថា យើង មិនមែនជាចៅក្រមដ៏ល្អសម្រាប់នឹងវិនិច្ឆ័យ អំពីអ្វីដែលខុសនិងអ្វីដែលត្រូវនោះឡើយ

"មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវ
ល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជា សេចក្ដីស្លាប់"
សុភាសិត ១៦:២៥

១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


18

(ព្រះគម្ពីរ ធីម៉ូថេទី២ ៤:៣,៤)

លោកសាវកប៉ុលបានទស្សនទាយថា "ដ្បិតនឹងមានគ្រាមកដែលគេមិនទ្រាំទ្រនឹង សេចក្តីបង្រៀនដ៏ត្រឹមត្រូវទេ


19

គឺគេនឹងមានត្រចៀករមាស់ ហើយនិងហៅ គ្រូកាន់តែច្រើនឡើងមកបង្រៀនឱ្យត្រូវចិត្ត


20

គេនឹងងាកត្រចៀកចេញពីសេចក្តីពិត បែរ ទៅតាមរឿងព្រេងវិញ
ធីម៉ូថេទី២ ៤:៣,៤


21

បាទ វាពិបាកនឹងនិយាយណាស់ យើង កំពុងដឹងថា យើងមិនមានសេរីភាពដោយ បោះបង់ចោលច្បាប់ទាំងអស់នោះទេ!
ការដកយកខ្នាតគំរូនៃការខុសនិងត្រូវចេញ នោះនឹងមានការច្របូកច្របល់កើតឡើង។



22

ប្រសិនបើអ្នកយកចេញនូវសញ្ញានៃច្បាប់ ចរាចរ នោះនឹងមានការរឹករវរនៅតាមផ្លូវ តូចផ្លូវធំទាំងឡាយ។



23

តើអ្វីទៅជាច្បាប់?
តើយើងអាចដឹងពីការខុសនិងត្រូវឬទេ?


24

ជាយូរយារណាស់មកហើយ ព្រះបានប្រ ទានមកអោយយើងនូវសង្គមដែលគ្មានឧក្រិដ្ឋកម្មមួយ។
ហើយច្បាប់នោះត្រូវបានគេអនុវត្តតាម យ៉ាងត្រឹមត្រូវ ឧក្រិដ្ឋកម្មមិនដែលមានឡើយ!
គ្រប់ៗគ្នានឹងបានសុខសាន្តនិងសប្បាយរីករាយនៅគ្រប់ទីកន្លែងនៅលើផែនដីនេះ។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?



25

(ព្រះគម្ពីរ និក្ខមនំ ២០:២)

នៅពេលពួកកូនចៅអ៊ីស្រាអែលបាន បោះជំរំនៅភ្នំស៊ីណាយ ព្រះទ្រង់បានយាង មកជួបពួកគេ ហើយមានបន្ទូលថា "អញ នេះគឺជាយេហូវ៉ា ជាព្រះនៃឯង ដែលបាន នាំឯងចេញពីផ្ទះពួកបាវបំរើនៅស្រុកអេស៊ីព្ទ មក"

និក្ខមនំ ២០:២




26

(វីដេអូ ៦វិនាទី) ដំបូងព្រះបានបញ្ជាក់អង្គ ទ្រង់ថា ជាអ្នករំដោះពួកគេពីទាសភាព។ ទ្រង់គឺជាព្រះដែលបានបើកសមុទ្រក្រហមពី មុខពួកគេ ទ្រង់គឺជាអ្នកការពារពួកគេ។ ម្យ៉ាងវិញទៀត ទ្រង់បានមានព្រះមន្ទូលថា "អញថែរក្សាឯង ឯងអាចទុកចិត្ត អញបាន"



27

បន្ទាប់មកទ្រង់បានមានបន្ទូលពីបញ្ញត្តិ របស់ព្រះអង្គ ដើម្បីអោយមនុស្សអាចដឹង អំពីការរស់នៅក្នុងសន្តិភាពនិងសុវត្ថិភាព.ដើម្បីអោយគេដឹងថា អ្វីខុស អ្វីត្រូវ។



28

សូមយើងក្រឡេកមើលមួយភ្លែតទៅឯ បញ្ជីក្រិត្យវិន័យដប់ប្រការ ដែលទ្រង់បាន មានបន្ទូលនៅលើកំពូលភ្នំស៊ីណាយ:

ក្រិត្យវិន័យដប់ប្រការពីព្រះគម្ពីរ

(និក្ខមនំ ជំពូក២០)

"មិនត្រូវអោយមានព្រះឯណាទៀតនៅ ចំពោះអញអោយសោះ...



29

"មិនត្រូវឆ្លាក់រូបណាសំរាប់ឯងថ្វាយបង្គំ ឡើយ...



30

"មិនត្រូវចេញព្រះនាមព្រះយេហូវ៉ាជា ព្រះនៃឯងជាអសារឥតការឡើយ...



31

"ចូរនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែក ថ្ងៃនោះចេញជាបរិសុទ្ធ។ ក្នុងរវាង៦ថ្ងៃ នោះត្រូវឱ្យឯងធ្វើការ... តែឯថ្ងៃទី៧ នោះ គឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ...

១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?



32

"ចូរគោរពប្រតិបត្តិដល់ឪពុកម្តាយឯង...



33

"កុំឱ្យសម្លាប់មនុស្សអោយសោះ។



34

"កុំអោយផិតក្បត់អោយសោះ។



35

"កុំអោយលួចប្លន់អោយសោះ។



36

កុំអោយធ្វើទីបន្ទាល់ក្លែងទាស់នឹងអ្នកជិត ខាងខ្លួនអោយសោះ។



37

"កុំឱ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួន ប្រពន្ធកូនគេ អ្នកបំរើប្រុស



38

ឬអ្នកបំរើស្រី ឬគោ លា ឬរបស់អ្វីផង អ្នកជិតខាងខ្លួនឡើយ" និក្ខមនំ ២០:៣-១៧។



39

(វីដេអូ ១០ វិនាទី) នៅពេលដែលជន ជាតិអ៊ីស្រាអែលបានស្តាប់ហើយ គេបាន យល់ព្រមដោយរីករាយ។

ប្រសិនបើនេះជាព្រះហឫទ័យរបស់ព្រះ ពួកគេត្រូវតែប្តេជ្ញាចិត្តគោរពតាមបញ្ញត្តិទាំង អស់នោះ!

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?




40

ប៉ុន្តែក្រោយមក យើងដឹងហើយថា យើងជាមនុស្សមានការភ្លេចភ្លាំងជាច្រើន ព្រះបានសរសេរក្រិត្យ វិន័យដប់ប្រការនៅ លើបន្ទះថ្ម ដោយចុងព្រះអង្គុលី(ចុងម្រាម) របស់ព្រះអង្គផ្ទាល់:



41

(ព្រះគម្ពីរ និក្ខមនំ ៣១:១៨)

"កាលព្រះបានមានបន្ទូលនឹងម៉ូសេ នៅ លើភ្នំស៊ីណាយរួចសព្វគ្រប់ហើយ



42

នោះទ្រង់ក៏ប្រទានសេចក្ដីបន្ទាល់ដល់ លោក ជាសេចក្ដីដែលទ្រង់បានសរសេរចុះ នឹងបន្ទះថ្មពីរផ្ទាំង



43

ដោយអង្គុលីព្រះហស្ត

និក្ខមនំ ៣១:១៨


44

នោះបីនេះជាលើកទីមួយដែលព្រះបាន ប្រទានបញ្ញត្តិរបស់ទ្រង់ទៅពួកគេ ដោយ សរសេរក៏ដោយ ក៏ច្បាប់នោះ មានតាំងពី ដើមអស់កល្បរៀងរហូតមកហើយដែរ។

ជាយូរលង់មុនភ្នំស៊ីណាយ ឬក៏តាំងពី មុនអ័ដាម និងអេវ៉ាទៅទៀត ខ្នាតគំរូ ដែលមិនអាចផ្លាស់ប្តូរបាននេះ បានក្លាយជា មូលដ្ឋាននៃរាជរដ្ឋាភិបាលស្ថានសួគ៌របស់ព្រះ។


45

តាមពិត សូម្បីតែពួកទេវតា ក៏ត្រូវបាន គ្រប់គ្រងដោយច្បាប់ទាំងនេះដែរ។

ពួកទេវតាទាំងនោះត្រូវបានផ្តល់ជម្រើស អោយថា តើត្រូវដើរតាមច្បាប់របស់ព្រះ ឬបដិសេធ និងបះបោរប្រឆាំងនឹងច្បាប់នោះ។


46

សាតាំងនិងទេវតារបស់វា ជ្រើសរើស "ធ្វើតាមចិត្តវាផ្ទាល់" ធ្វើច្បាប់របស់គេ ផ្ទាល់។

ហើយការប្រឆាំងបះបោរនេះ បានដឹក នាំទៅរកការបណ្តេញពួកគេចេញពីស្ថាន សួគ៌។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


47

(ព្រះគម្ពីរ វិវរណៈ ១២:៧-៩)

ព្រះគម្ពីរនិយាយថា "នោះមានចម្បាំង នៅលើមេឃ គឺមីកែលនិងពួកទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគនិងទេវតា វាក៏ច្បាំងនឹងលោកដែរ


48

តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែង ណាឱ្យវានៅលើមេឃទៀតផង


49

នោះនាគធំត្រូវបានបោះទម្លាក់ទៅ គឺជា ពស់ពីបុរាណដែលឈ្មោះហៅថាអារក្ស ហើយសាតាំង ដែលបាននាំលោកីយ៍ទាំង មូលឱ្យវង្វេងចេញ


50

វាត្រូវបានបោះទម្លាក់ទៅផែនដីវិញ ព្រម ទាំងពួកទេវតារបស់វាផង"

វិវរណៈ ១២:៧-៩

ប៉ុន្តែមានទេវតាដែលបានជ្រើសរើសដើរ តាមព្រះ និងនៅតែស្មោះត្រង់ចំពោះច្បាប់ របស់ទ្រង់។


51

(ព្រះគម្ពីរ ទំនុកដំកើង ១០៣:២០)

ចូរសរសើរដល់ព្រះយេហូវ៉ា អស់ពួក ទេវតារបស់ទ្រង់អើយ ជាអ្នកដែលមានឥទ្ធ ឫទ្ធិខ្លាំង ហើយក៏ប្រតិបត្តិតាមបង្គាប់ទ្រង់"

ទំនុកដំកើង ១០៣:២០


52

លោកអ័ដាមនិងនាងអេវ៉ាមានចំណេះ ដឹងខាងបញ្ញត្តិរបស់ព្រះនេះ នៅសួនច្បារអេ ដែន ព្រោះគេមានអារម្មណ៍ខ្មាសអៀននៅ ពេលដែលគេបានធ្វើបាប។


53

ហើយនៅពេលដែលកាអ៊ីនខឹង ពីព្រោះ ព្រះទទួលដង្វាយរបស់អេបិល ហើយមិន ទទួលដង្វាយរបស់គាត់ ព្រះបានសួរគាត់ថា


54

(ព្រះគម្ពីរ លោកុប្បត្តិ ៤:៦,៧)

"ឯងខឹងធ្វើអ្វី? ហេតុអ្វីបានជាឯងធ្វើ ទឹកមុខក្រញូវដូច្នេះ?

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


55

បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយ វិញទេឬអី? បើឯងធ្វើមិនល្អនោះ មាន ដង្វាយលោះបាប ដេកនៅមាត់ទ្វារស្រាប់ ហើយ"

"លោកុប្បត្តិ ៤:៦,៧

ច្បាប់របស់ព្រះបានចូលជាធរមានតាំង ពីពេលនោះមក ព្រោះយើងត្រូវបានគេ ប្រាប់ថា


56

(ព្រះគម្ពីរ រ៉ូម ៤:១៥)

"...ដ្បិតកន្លែងណាដែលគ្មានក្រិត្យវិន័យ នោះក៏ឥតមានសេចក្ដីរំលងដែរ"

រ៉ូម ៤:១៥


57

វចនានុក្រមសាកលវិទ្យាល័យ

វេបស្ទើរ ញូ វើលដ៍ និយាយថា

"...ការប្រព្រឹត្តិរំលងច្បាប់ មានន័យថា ការល្មើសនឹងច្បាប់ ការល្មើសនឹងករណីយកិច្ច និងបាប។ល។"


58

លោកអ័ប្រាហាំបានដឹង និងគោរពអំពី បញ្ញត្តិរបស់ព្រះជាយូវយារ មុនបញ្ញត្តិនេះ ត្រូវបានព្រះមានព្រះបន្ទូល នៅភ្នំស៊ីណាយ ទៅទៀត។


59

(ព្រះគម្ពីរ លោកុប្បត្តិ ២៦:៥)

ព្រះបានមានព្រះបន្ទូលថា ទ្រង់នឹងប្រ ទានព្រះពរអោយលោកអ័ប្រាហាម និងពូជ របស់គាត់

"ពីព្រោះអ័ប្រាហាំបានស្ដាប់តាម

ពាក្យអញព្រមទាំងរក្សាបញ្ញើនិងបញ្ញត្តិ ហើយ ច្បាប់ និងក្រិត្យវិន័យរបស់អញ"

លោកុប្បត្តិ ២៦:៥


60

ពិតប្រាកដណាស់ តាំពីយូរមុនភ្នំ ស៊ី ណាយ សតិសម្បជញ្ញៈ និងវិញ្ញាណរបស់ លោកយ៉ូសែប បាននាំគាត់ទៅជួបនឹងការ ល្បួងមួយពីប្រពន្ធលោកប៉ូទីផា ដោយ និយាយថា


61

(ព្រះគម្ពីរ លោកុប្បត្តិ ៣៩:៩)

"ហើយលោកក៏មិនបានហួងទុករបស់ ណាមួយនឹងខ្ញុំដែរ លើកតែលោកស្រី ប៉ុណ្ណោះ ពីព្រោះលោកស្រីជាប្រពន្ធ របស់ លោក

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


62

ដូច្នេះ ធ្វើដូចម្ដេចឱ្យខ្ញុំប្រព្រឹត្តការដែល អាក្រក់យ៉ាងធំនេះទៅបាន ធ្វើយ៉ាងនោះនឹងមានបាបនៅចំពោះព្រះផង?”

លោកុប្បត្តិ ៣៩:៩


63

លោកយ៉ូសែបបានដឹងថា ការកំផិតជាអំ ពើបាប គាត់បានដឹងអំពីខ្នាតគំរូនៃការខុស និងត្រូវ។

គាត់បានធ្វើការប្ដេជ្ញាចិត្តយ៉ាងមុតមាំថា គាត់នឹងមិនប្រព្រឹត្តល្មើសនឹងច្បាប់ដ៏បរិសុទ្ធរបស់ព្រះឡើយ!



64

(វីដេអូ ៤វិនាទី) កូនចៅអ៊ីស្រាអែល ត្រូវ បានណែនាំអោយគោរពនិងធ្វើតាមព្រះ ប៉ុន្តែនៅពេលដែលពួកគេរស់នៅក្រោមអំពើ ឃោរឃៅជាទាសករនៅស្រុកអេស៊ីព្ទ ពួកគេបានបំភ្លេចច្បាប់របស់ព្រះ។


65

បន្ទាប់ពីការរំដោះខ្លួនមក គ្រាន់តែពីរបី សប្ដាហ៍មុនទៅដល់ភ្នំស៊ីណាយ ព្រះទ្រង់បានតំរាមដល់លោកម៉ូសេ ព្រោះពួកអ៊ីស្រា អែលបានប្រព្រឹត្តល្មើសនឹងបញ្ញត្តិរបស់ទ្រង់ ដោយប៉ុនប៉ងរើសនំម៉ានានៅថ្ងៃបរិសុទ្ធ:


66

(ព្រះគម្ពីរ និក្ខមនំ ១៦:២៨,៣០)

“នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹង ម៉ូសេថា តើឯងរាល់គ្នាមិនព្រមធ្វើតាម បញ្ញត្តិ ហើយនិងច្បាប់របស់អញដល់កាល ណាទៀត?


67

ហេតុនោះបណ្ដាជនគ្រប់គ្នាក៏សំរាកនៅថ្ងៃ ទី៧នោះ”

និក្ខមនំ ១៦:២៨,៣០

ដូច្នេះតើលោកអ្នកឃើញទេ ក្រិត្យវិន័យ ទីបួនត្រូវបានគេទទួលស្គាល់មុនភ្នំស៊ីណាយ ទៅទៀត។


68

មែនហើយ បញ្ញត្តិរបស់ព្រះ គឺជាខ្នាតគំរូនៃ ការត្រូវដ៏នៅអស់កល្ប សម្រាប់លោកសន្និវាសទាំងមូលនេះ។

ហើយជាការពិតប្រាកដ តើគួរអោយ យើងភ្ញាក់ផ្អើលឬទេដែលថា ព្រះមានច្បាប់សម្រាប់គ្រប់គ្រងនគររបស់ទ្រង់នោះ?


69

(ព្រះគម្ពីរ កូរិនថូសទី១ ១៤:៣៣,៤០)

លោកសាវកប៉ុលបានសរសេរថា “ដ្បិត ព្រះមិនមែនជាព្រះនៃសេចក្ដីវឹកវរទេ”

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


70

ត្រូវតែធ្វើការទាំងអស់តាមបែបគួរសម ហើយដោយលំដាប់លំដោយផង”
កូរិនថូសទី១ ១៤:៣៣,៤០


71

គ្មានរដ្ឋាភិបាលណា ដែលមានសណ្តាប់ ធ្នាប់ទៅបាន ដោយគ្មានច្បាប់នោះឡើយ។
គ្មានសង្គមដែលគ្មានការខ្វែងគំនិត មានការ រីករាយ និងមានសុវត្ថិភាពណា អាចដំ ណើរការទៅបាន ដោយគ្មានច្បាប់ទម្លាប់ នោះឡើយ។
ធម្មជាតិខ្លួនឯងក៏មានច្បាប់ដែរ សូម្បី តែកូនក្មេងក៏មិនអាចលេងល្បែងដោយគ្មាន ច្បាប់បានដែរ!


72

(ព្រះគម្ពីរ រ៉ូម ២:១៣)
ព្រះគម្ពីរ និយាយថា “ដ្បិតពួកអ្នក ដែលគ្រាន់តែស្តាប់ក្រិត្យវិន័យ នោះមិនមែន ឈ្មោះថាសុចរិត នៅចំពោះព្រះឡើយ


73

គឺបានរាប់ជាសុចរិត តែពួកអ្នកដែលប្រ ព្រឹត្តតាមក្រិត្យវិន័យប៉ុណ្ណោះទេ”
រ៉ូម ២:១៣។
លោកអ្នកឃើញទេ មិនគ្រាន់តែជាការ សំខាន់ ដែលដឹងអំពីបញ្ញត្តិរបស់ព្រះ ប៉ុណ្ណោះទេ យើងត្រូវតែឆ្លើយតបថែមទៀត។


74

(ព្រះគម្ពីរ យ៉ូហាន ១៤:១៥)
ព្រះយេស៊ូវបានមានបន្ទូលថា “បើអ្នក រាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ ខ្ញុំចុះ” យ៉ូហាន១៤:១៤
តាមពិត ដកស្រង់ចេញពីព្រះគម្ពីរ សញ្ញាថ្មី ព្រះយេស៊ូវបានចង្អុលបង្ហាញថា សេចក្តីស្រឡាញ់គឺជាមូលដ្ឋាន សំរាប់ការ កាន់ក្រិត្យវិន័យទាំងអស់។


75

(ព្រះគម្ពីរ ម៉ាថាយ ២២:៣៧-៤០)
“...ត្រូវឱ្យស្រឡាញ់ព្រះអម្ចាស់នៃឯង ឱ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ ពីគំនិត


76

នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១”

១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


77

បន្ទាប់មក ព្រះយេស៊ូវបានមានព្រះ បន្ទូលថា "ហើយបញ្ញត្តិទី២ ក៏បែបដូចគ្នា គឺថា ត្រូវឱ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង


78

បណ្តាក្រិត្យវិន័យ និងអស់ទាំងទំនាយ ហោរាទាំងប៉ុន្មានក៏សំរេចទៅនៅបញ្ញត្តិទាំងពីរប្រការនេះឯង"

ម៉ាថាយ ២២:៣៧-៤០


79

ប្រសិនបើយើងពិតជាស្រឡាញ់ព្រះ អស់អំពីចិត្ត អស់អំពីគំនិត អស់អំពីព្រលឹង


80

យើងពិតជាបង្ហាញសេចក្តីស្រឡាញ់នោះដោយកាន់តាមបញ្ញត្តិបួនដំបូង:


81

ព្រះនឹងក្លាយជាលេខមួយក្នុងជីវិតរបស់យើង


82

ការថ្វាយបង្គំរបស់យើងនឹងត្រូវបាន លើកថ្វាយទៅទ្រង់តែមួយអង្គគត់


83

យើងនឹងគោរព និងកោតខ្លាចព្រះនាម ដ៏បរិសុទ្ធរបស់ទ្រង់


84

យើងនឹងខ្វាយខ្វល់រក្សាការណាត់របស់ យើងជាមួយទ្រង់រៀងរាល់ថ្ងៃបរិសុទ្ធ

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


85

ហើយប្រសិនបើយើងពិតជាស្រឡាញ់ មនុស្សដទៃ ដូចដែលយើងស្រឡាញ់ខ្លួន ឯងនោះ យើងប្រាកដជា:


86

គោរពនិងប្រតិបត្តិដល់
ឪពុកម្តាយយើង


87

អោយតម្លៃដល់ជីវិត


88

រក្សាសីលធម៌


89

គោរពទ្រព្យសម្បត្តិអ្នកដទៃ


90

ស្មោះត្រង់ក្នុងទំនាក់ទំនងរបស់យើងជា មួយអ្នកដទៃ


91

មិនលោភលន់ចង់បានរបស់អ្នកដទៃ


92

ការប៉ាន់ប្រមាណបានចង្អុលបង្ហាញថា មានច្បាប់ជាង៣៥លាន ដែលត្រូវបានរៀបចំឡើងដោយមនុស្ស ដើម្បីគ្រប់គ្រងចរិយា របស់មនុស្ស។

១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


93

ប៉ុន្តែនៅក្នុងក្រិត្យវិន័យដប់ប្រការ ព្រះ ទ្រង់បានព្រៀងច្បាប់មួយ ដែលពិតប្រាកដ ជាអាចគ្រប់គ្រង ចរិយារបស់មនុស្សគ្រប់ គ្នាបានទាំងអស់។

មានតែព្រះទេ ដែលអាចសរសេរច្បាប់ ដ៏ល្អឥតខ្ចោះនេះបាន។ ព្រះគម្ពីរនិយាយថា:


94

(ព្រះគម្ពីរ ទំនុកដំកើង ១៩:៧)

"ឯក្រិត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់ លក្ខណ៍ ក៏តែព្រលឹងឡើងវិញ"

ទំនុកដំកើង ១៩:៧


95

(ព្រះគម្ពីរ ទំនុកដំកើង ១៩:១១)

"ហើយដែលកាន់តាមនោះក៏មានរង្វាន់ យ៉ាងធំ"

ទំនុកដំកើង ១៩:១១


96

អ្នកប្រាជ្ញព្រះគម្ពីរម្នាក់ឈ្មោះ អូហ្គាស ស្ត្រុងបានសរសេរថា:

"បញ្ញត្តិគឺជាការចម្លងយ៉ាងត្រឹមត្រូវអំពី ធម្មជាតិរបស់ព្រះ"


97

សព្វថ្ងៃនេះ យើងអាចនិយាយបានថា ក្រិត្យវិន័យដប់ប្រការ គឺជាទម្រង់នៃអត្តច រិតរបស់ព្រះ-អត្តចរិតដែលមិនអាចផ្លាស់ ប្តូរបាន!"


98

លោកអ្នកឃើញទេ ប្រសិនបើមានការ ផ្លាស់ប្តូរណានៅក្នុងបញ្ញត្តិរបស់ព្រះ បញ្ញត្តិ នោះនឹងលែងគ្រប់លក្ខណ៍ហើយ បញ្ញត្តិ ដ៏ល្អគ្រប់លក្ខណ៍ គឺជាបញ្ញត្តិដែលមិនត្រូវ បានគេកែប្រែ។


99

(ព្រះគម្ពីរ លូកា ១៦:១៧)

នេះគឺជាការពិតដែលចេញពីព្រះឱស្ឋ ព្រះយេស៊ូវ នៅពេលដែលទ្រង់បានមាន ព្រះបន្ទូល:

"ប៉ុន្តែដែលផ្ទៃមេឃនិងផែនដី បាត់ទៅនោះ ងាយជាជាងបាត់ក្បៀស១ ក្នុង ក្រិត្យវិន័យទៅទៀត"

លូកា ១៦:១៧

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


100

ប៉ុន្តែអ្នកនិយាយថា "ខ្ញុំតែងតែមាន អារម្មណ៍ថា ក្រិត្យវិន័យដប់ប្រការ បាន ហ៊ុំព័ទ្ធការសប្បាយរបស់ខ្ញុំ-ជាច្បាប់ម្យ៉ាង ដែលហាក់បីដូចជារបងព័ទ្ធជុំវិញខ្ញុំ"

ព្រះមិនដែលមានបំណងថា ក្រិត្យវិន័យ របស់ទ្រង់ជាបន្ទុកដល់មនុស្ស ឬជាការ កំណត់ព្រំដែននៃការសប្បាយរបស់មនុស្សនោះទេ។


101

ផ្ទុយទៅវិញ ព្រះបានបម្រុងវាទុកដើម្បី ធ្វើជាជញ្ជាំងសំរាប់គ្របបាំងការពារយើង អំពីកង្វល់និង កំហុសផ្សេងៗទៅវិញ។

ទ្រង់បានរៀបចំបញ្ញត្តិរបស់ទ្រង់នេះ ឡើង ដើម្បីបញ្ជាក់អំពីសេរីភាព និងសុវត្ថិ ភាពរបស់មនុស្ស គ្រប់គ្នានៅគ្រប់ទីកន្លែង។


102

(ព្រះគម្ពីរ ចោទិយកថា ៥:២៩)

ព្រះអម្ចាស់បានមានព្រះបន្ទូលថា "ឱ បើសិនជាគេមានចិត្តយ៉ាងនោះជាដរាបទៅ អេះ ដើម្បីឱ្យគេបានកោតខ្លាចដល់អញ ហើយកាន់តាមគ្រប់ទាំងបញ្ញត្តិរបស់អញ


103

ប្រយោជន៍ឱ្យគេ និងកូនចៅគេ បាន សប្បាយនូវជារៀងរាបដរាបទៅ!" ចោទិយកថា ៥:២៩


104

ដើម្បីការពារយើងពីគ្រោះថ្នាក់ ព្រះបាន ប្រទានច្បាប់របស់ទ្រង់ដល់យើង ដើម្បីការ ពារ និងថែរក្សាយើង នៅតាមផ្លូវនៃជីវិត ដូចជាយើងសង់បង្កាន់ដៃនៅលើស្ពាន និង លើផ្លូវនៅលើភ្នំដូច្នោះដែរ។


105

(ព្រះគម្ពីរ រ៉ូម ៣:២០)

ប៉ុន្តែមានហេតុផលមួយទៀត ដែលព្រះ បានប្រទានក្រិត្យវិន័យរបស់ទ្រង់មកដល់ មនុស្សនេះ "ដ្បិតក្រិត្យវិន័យគ្រាន់តែសំដែង ឱ្យស្គាល់អំពើបាបប៉ុណ្ណោះ" រ៉ូម ៣:២០


106

(ព្រះគម្ពីរ រ៉ូម ៧:៧)

ដូចលោកប៉ុលបាននិយាយថា "...ខ្ញុំ មិនបានទាំងស្គាល់បាបផង លើកតែដោយ សារក្រិត្យវិន័យចេញ

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


107

ដ្បិតបើសិនជាក្រិត្យវិន័យមិនបានថា "កុំ ឱ្យលោភ" នោះខ្ញុំឥតបានដឹងថា មាន
សេចក្ដីលោភផងឡើយ"
រ៉ូម៧:៧


108

មានរឿងមួយដែលត្រូវបានគេនិយាយអំ ពីព្រះរាជនីមួយអង្គ ដែលត្រូវបានគេ បញ្ជើចបញ្ចើថា
សម្រស់របស់ព្រះនាងល្អ ហួសវិស័យ។
ទោះបីជាយ៉ាងណាក៏ដោយ ថ្ងៃមួយ
មានអ្នកជំនួញម្នាក់បានធ្វើដំណើរទៅឯព្រះរាជវាំងរបស់ព្រះនាង ហើយបានលក់កញ្ចក់
មួយថ្វាយព្រះនាង។
នៅពេលដែលព្រះនាងទតមើលទៅក្នុង
កញ្ចក់ទ្រង់មានការភ្ញាក់ក្រញាង ដោយទត ឃើញរូបអង្គរបស់ព្រះនាងនៅក្នុងកញ្ចក់
ហើយព្រះនាងក៏បានបំបែកកញ្ចក់នោះចោល
ទៅ។


109

ច្បាប់របស់ព្រះដូចជាកញ្ចក់មួយ ហើយ នៅពេលដែលយើងមើលទៅក្នុងវានោះ
ដូចជាព្រះរាជនីអង្គនោះ ដូច្នោះដែរ យើង អាចនឹងមិនពេញចិត្តនូវអ្វីដែលយើងឃើញ នោះឡើយ


110

ប៉ុន្តែការបំបែកឬបដិសេធបញ្ញត្តិរបស់ព្រះ មិនបានផ្លាស់ប្តូរលក្ខណៈរបស់យើងបានទេ។


111

ច្បាប់ចង្អុលបង្ហាញអំពើបាបរបស់យើង!
វាគឺជាអ្នកនាំដើម្បីជួយយើង ឱ្យមានការរីក រាយ ធ្វើឱ្យជីវិតរួចពីទោស ប្រសិនបើ
យើងដើរតាមការណែនាំរបស់ទ្រង់នៅក្នុង បញ្ញត្តិរបស់ទ្រង់។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


112

ច្បាប់មិនអាចឱ្យអំណាចដល់យើង ឱ្យ ឈ្នះលើអំពើបាប ឬក៏ដកយកទោសកំហុសពីយើងនោះទេ។

គ្មានជំនួយនៃអំពើល្អណា ដែលយើង អាចធ្វើទៅអនាគត ដើម្បីនឹងលប់បំបាត់ អំពើបាបរបស់យើងដែលយើងបានប្រ ព្រឹត្តកន្លងមកនេះបានទេ។

ពេលនោះតើធ្វើដូចម្តេច ដើម្បីឱ្យយើង បានទទួលការអត់ឱនទោស

តើធ្វើដូចម្តេចដើម្បីឱ្យយើងបានសង្គ្រោះ អំពីទោស នៃការល្មើសនឹងបញ្ញត្តិ ដែលជាសេចក្តីស្លាប់នេះ?


113

នៅនឹងក្លោងទ្វារនៃសួនច្បារអេដែន ព្រះបានដាក់សញ្ញាយ៉ាងច្បាស់លាស់ ដើម្បី រំលឹកថាការមិនស្តាប់ បង្គាប់នាំមកនូវ សេចក្តីស្លាប់-ទោះជាអ្នកមិនស្តាប់បង្គាប់ ឬអ្នកដែលគ្មានកំហុសដែលយកមកជំនួសក៏ ដោយ។

កូនចៀម ត្រូវបានគេយកមកធ្វើយញ្ញ បូជា ដើម្បីបង្ហាញអំពីសេចក្តីជំនឿរបស់អ្នកមានបាបក្នុងផែនការរបស់ព្រះ ដើម្បី សង្គ្រោះមនុស្ស។


114

នេះគឺជាវិធីរបស់ព្រះ ក្នុងការជួយ លោកអ័ដាមឱ្យយល់អំពីការដែលព្រះរាជ បុត្រារបស់ព្រះដែលគ្មានកំហុសសោះ ត្រូវតែ សុគត ដើម្បីឱ្យធួននឹងការទាមទារ នៃការបំពានទៅនឹងបញ្ញត្តិព្រះរបស់ពួកគេ។

ព្រះគ្រីស្ទជាកូនចៀមនៃព្រះ និងទទួល ទណ្ឌកម្មរបស់មនុស្ស ព្រមទាំងទទួលរងនូវការសុគតរបស់ទ្រង់។


115

លោកអ្នកឃើញទេ បញ្ញត្តិមិនអាចជួយ សង្គ្រោះអ្នកណាម្នាក់ ពីអំពើបាបបានទេ។



116

(ព្រះគម្ពីរ កាឡាទី ៣:២១)

លោកសាវកប៉ុលបាននិយាយថា "ដ្បិត បើសិនជាមានក្រិត្យវិន័យណាប្រទានមកដែលអាចនឹងធ្វើឱ្យរស់បាន

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


117

នោះប្រាកដជាសេចក្តីសុចរិតនឹងមក ដោយ សារក្រិត្យវិន័យនោះហើយ"
កាឡាទី ៣:២១

វាមិនមែនជាច្បាប់ទេ ដែលនាំមកនូវ ការអត់ឱនទោស និងការសង្គ្រោះ-គឺជាព្រះគុណរបស់ព្រះឯណោះទេ! មានតែតាមរយៈ ការលះបង់របស់ព្រះគ្រីស្ទប៉ុណ្ណោះទេ ដែលយើងអាចមានជីវិតអស់កល្បបាន។


118

(ព្រះគម្ពីរ រ៉ូម ៦:២៣)

"ដ្បិតឈ្នួលរបស់អំពើបាប នោះជា សេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយសារ ព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់ គ្នា"
រ៉ូម ៦:២៣

សេចក្តីសង្គ្រោះមិនមែនអាចរកបាន ដោយសារការគោរពច្បាប់នោះទេ:


119

(ព្រះគម្ពីរ អេភេសូរ ២:៨,៩)

"ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់ គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែន កើតពីអ្នក រាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ


120

ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នក ណាអួតខ្លួន"
អេភេសូរ ២:៨,៩


121

ប្រសិនបើយើងបានសង្គ្រោះដោយសារ ព្រះគុណ តើយើងមានសេរីភាពនឹងរស់នៅក្នុងជីវិតដែលមិនស្តាប់បង្គាប់ឬទេ? មិនមែនទាល់តែសោះ!


122

(ព្រះគម្ពីរ រ៉ូម ៦:១,២)

លោកប៉ុលបានសរសេរថា "ដូច្នេះ យើងនឹងដូចម្តេច តើត្រូវឱ្យយើងចេះតែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឱ្យព្រះគុណបានចំរើនឡើងឬអី?"

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?





123

ទេ មិនត្រូវឡើយ ធ្វើដូចម្ដេចឱ្យយើង ដែលស្លាប់ខាងឯអំពើបាបហើយ បានរស់នៅក្នុងអំពើបាបទៀតបាន?”

រ៉ូម ៦:១,២។

សេចក្ដីសង្គ្រោះត្រូវបានប្រគល់ទៅឱ្យអ្នក ណាដែលចង់បានសេចក្ដីសង្គ្រោះពីអំពើបាប និងចង់ចូលជាចំណែកនៃនគរព្រះ។




124

មានមនុស្សខ្លះជឿថា បញ្ញត្តិរបស់ព្រះ ត្រូវបានគេបោះបង់ចោលហើយ។ សូមគិតអំពីរឿងនោះបន្តិច។




125

ប្រសិនបើគ្មានបញ្ញត្តិទេ ក៏គ្មានអំពើ បាបដែរ

ពីព្រោះអំពើបាបគឺជា “ការប្រព្រឹត្តិរំ លងក្រិត្យវិន័យ”។




126

ប្រសិនបើគ្មានបញ្ញត្តិទេ យើងមិនចាំ បាច់ត្រូវការព្រះគុណទេ ព្រោះថាព្រះគុណ គឺជាសេចក្ដីមេត្តាករុណា ដោយស្រឡាញ់ របស់ព្រះ តាំងពីយើងបានរំលងបញ្ញត្តិ របស់ព្រះមក។




127

ប្រសិនបើយើងមិនត្រូវការព្រះគុណទេ យើងអាចបោះបង់ឈើឆ្កាងចោល។




128

ប្រសិនបើមិនត្រូវការឈើឆ្កាងទេ យើង ក៏ពិតប្រាកដជាមិនត្រូវការព្រះអង្គសង្គ្រោះ ដែរ។

ប្រសិនបើយើងបោះបង់បញ្ញត្តិចោល យើងក៏បោះបង់...អំពើបាប ព្រះគុណ ឈើឆ្កាង និងព្រះអង្គសង្គ្រោះ មួយអង្គ ចោលដែរ

តើយើងត្រូវការព្រះអង្គសង្គ្រោះដែល បានសុគតជំនួសយើងនៅលើឈើឆ្កាង ដោយសារព្រះគុណប្រយោជន៍ឱ្យថ្លៃនៃ អំពើបាបរបស់យើងត្រូវបានបង់ ដោយ សារយើងបានរំលោភច្បាប់របស់ទ្រង់នោះ ឬទេ?។ នេះគឺជាដំណឹងល្អ។ ព្រះគុណមិនបានបោះបង់ចោលបញ្ញត្តិរបស់ ព្រះទេ។

ដោយសារព្រះគុណរបស់ព្រះ យើងត្រូវ ការគោរពបញ្ញត្តិរបស់ព្រះ។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


129

ប្រសិនបើអ្នកជាប់គុក កំពុងរង់ចាំ សេចក្តីស្លាប់ម្នាក់


130

ទទួលការអត់ឱនទោស ហើយបានរួចខ្លួន តើមានន័យថាឥឡូវនេះ គេមានសេរីភាព នឹងរស់នៅ ក្នុងជីវិតដែលគ្មានច្បាប់ឬទេ?

ហើយធ្វើតាមចិត្តគេឬទេ? មិនមែន ទាល់តែសោះ!


131

ដោយសារគាត់ត្រូវបានអត់ទោស គាត់ ត្រូវតែដឹងឱ្យបានខ្លាំងជាងពីមុន នូវកាតព្វ កិច្ចរបស់គាត់ ក្នុងការប្រកាន់ច្បាប់នៃ ប្រទេសជាតិ។



132

សំខាន់បំផុត គឺបញ្ញត្តិរបស់ព្រះ ចង្អុល បង្ហាញនូវអំពើបាបរបស់យើង និងជួយ យើងឱ្យមានអារម្មណ៍ថា យើងត្រូវការព្រះ អង្គសង្គ្រោះមួយអង្គ។

នៅពេលដែលយើងទទួលព្រះគ្រីស្ទជា ព្រះអង្គសង្គ្រោះ ទ្រង់ប្រទានការអត់ឱន ទោស ព្រមទាំងអំណាច ដើម្បីរក្សាបញ្ញត្តិ របស់ទ្រង់ផង ដ្បិតទ្រង់បានសន្យាថា:



133

(ព្រះគម្ពីរ ហេព្រើរ ៨:១០)

"...អញនឹងដាក់ក្រិត្យវិន័យអញនៅក្នុងគំនិត គេ ហើយនិងកត់ទុកនៅក្នុងចិត្តគេផង"

ហេព្រើរ ៨:១០


134

វាជាការងាយស្រួលណាស់ ក្នុងការធ្វើ អ្វីដែលយើងចង់ធ្វើមែនទេ?

ហើយការនោះហើយដែលព្រះអម្ចាស់ បានសន្យា ចំពោះអស់អ្នកដែលដើរតាម ទ្រង់។

ទ្រង់នឹងសរសេរបញ្ញត្តិរបស់ទ្រង់នៅក្នុង ចិត្តគេ ដើម្បីឱ្យពួកគេចង់កាន់តាមបញ្ញត្តិ នោះ។



135

(វីដេអូ ៨វិនាទី) នោះហើយ គឺជាវិធីតែ មួយគត់ ដែលមនុស្សអាចនឹងគោរពតាម បញ្ញត្តិរបស់ព្រះបាន។

គឺពីព្រោះតែសេចក្តីស្រឡាញ់របស់ ព្រះវរបិតាទ្រង់ ទើបព្រះគ្រីស្ទអាចកាន់ តាមបញ្ញត្តិរបស់ទ្រង់បាន

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


136

(ព្រះគម្ពីរ យ៉ូហាន ១៥:១០)
ដោយទ្រង់បានមានព្រះនបន្ទូលថា "ដូចជាខ្ញុំ បានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ដែរ"
យ៉ូហាន ១៥:១០


137

(ព្រះគម្ពីរ យ៉ូហាន ១៤:១៥)
ហើយព្រះយេស៊ូវសូមឱ្យយើងបង្ហាញ សេចក្តីស្រឡាញ់របស់យើងដល់ទ្រង់ ដោយកាន់តាមបញ្ញត្តិរបស់ទ្រង់: "បើអ្នករាល់គ្នា ស្រឡាញ់ខ្ញុំចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ"
យ៉ូហាន១៤:១៥


138

ការបកស្រាយអំពីសេចក្តីស្រឡាញ់ និង ការស្តាប់បង្គាប់ដ៏ធំជាងគេ ចំពោះព្រះហឫទ័យព្រះគឺជារាត្រី ដ៏ងងឹតយ៉ាងត្រជាក់ និងរស់រវើក នៅក្រោមដើមអូលីវមួយនៅក្នុងសួនច្បារ។
ដោយមានតំណក់ឈាមហូរចេញពីព្រះ ភ័ក្ត្រទ្រង់ ព្រះរាជបុត្រានៃព្រះបានអធិស្ឋាន


139

(ព្រះគម្ពីរ ម៉ាថាយ ២៦:៣៩)
"...ឱព្រះវរបិតានៃទូលបង្គំអើយ បើ សិនជាបាន នោះសូមឱ្យពែងនេះកន្លងហួសពីទូលបង្គំទៅ..."
ម៉ាថាយ ២៦:៣៩
វាសនារបស់មនុស្សជាតិព្យួរនៅលើ ជញ្ជីង-លោកីយ៍ដែលមានកំហុសនេះ នឹងត្រូវបានសង្គ្រោះឬបាត់បង់។


140

តើយុវជនកាលីឡេនេះបានទុកសេចក្តី ប៉ងប្រាថ្នានៃជីវិត និងសេចក្តីត្រូវការរបស់ មនុស្សមួយឡែក ហើយស្លាប់នៅភ្នំវលា ក្បាល(កាល់វ៉ារី)ឬទេ?
ទ្រង់អាចជួតញើសពីថ្ងាសចេញ ហើយ មានបន្ទូលថា "ចូរឱ្យអ្នកមានបាបទាំងឡាយទទួលលទ្ធផលនៃអំពើបាបរបស់ខ្លួន គេចុះ"


141

ឬមួយក៏ទ្រង់លីឈើឆ្កាងដើម្បីយើង។
ទ្រង់បានធ្វើការសម្រេចព្រះទ័យសុគត ជំនួសយើង។ ទ្រង់បានខ្ចាយព្រះលោហិត ទ្រង់ដើម្បីឱ្យយើងបានទទួលការអត់ ទោស។ ទ្រង់សុគតដោយទទួលនូវសេចក្តីស្លាប់ របស់យើង ដើម្បីឱ្យយើងអាចរស់នៅ រៀងរហូតជាមួយទ្រង់

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


142

ដោយសារព្រះគ្រីស្ទបានបង់ថ្លៃលោះ សំរាប់ អំពើបាបរបស់យើងហើយនោះ យើងអាចទទួលការអត់ ឱនទោសដោយ សារការលះបង់របស់ទ្រង់ឥឡូវនេះ។


143

ឈើឆ្កាងកញ្ចាស់យ៉ាងមាំ នៅលើទួល មួយហៅថា ភ្នំរលាក្បាល គឺជាការរំលកដ៏ នៅអស់កល្ប អំពីតម្លៃដែលព្រះសុខចិត្ត បង់ ដើម្បីឱ្យធួននឹងការទាមទាររបស់ការប្រ ព្រឹត្តិរំលងនឹងបញ្ញត្តិ និងការសង្គ្រោះ មនុស្សមានទោស។


144

ប្រសិនបើបញ្ញត្តិរបស់ព្រះ ត្រូវបានលុប ចោល ឬផ្លាស់ប្តូរនោះ ព្រះយេស៊ូវមិនចាំ បាច់សុគតទេ។ ភ្នំរលាក្បាល(កាល់វ៉ារី)ក៏គ្មានសារសំខាន់អ្វី ដែរ។


145

ប៉ុន្តែព្រះមិនអាចធ្វើព្រងើយកន្តើយនឹងអំពើ បាបរបស់មនុស្សបានទេ!


146

ទ្រង់មិនអាចផ្លាស់ប្តូរបញ្ញត្តិរបស់ទ្រង់ បានទេ។


147

ដូច្នេះមនុស្សមានបាបត្រូវការព្រះអង្គ សង្គ្រោះមួយអង្គ។
ហើយសូមអរព្រះគុណដល់ព្រះ ចំពោះ សេចក្តីស្រឡាញ់របស់ទ្រង់ ក្នុងការយល់ ព្រមប្រគល់ព្រះរាជបុត្រាទ្រង់តែមួយគត់ ឱ្យមកសុគតជំនួសយើងរាល់គ្នា!"


148

(ព្រះគម្ពីរ យ៉ូហាន ៣:១៦)
"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រា ទ្រង់តែមួយ


149

ដើម្បីឱ្យអស់អ្នកណាដែលជឿលើព្រះរាជ បុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមាន ជីវិតអស់កល្ប ជានិច្ចវិញ"
យ៉ូហាន ៣:១៦

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


150

ព្រះគម្ពីរវិវរណៈពណ៌នាអំពីមនុស្ស ដែលរៀបចំជួបព្រះយេស៊ូវ នៅពេលដែលទ្រង់យាងមកជាលើក ទីពីរ ហើយយក យើងទៅកាន់លំនៅជាមួយទ្រង់ ដើម្បីរស់នៅអស់កល្បនៅក្នុងទីក្រុងនៃស្ថានសួគ៌។


151

(ព្រះគម្ពីរ វិវរណៈ ១៤:១២)

ព្រះមានបន្ទូលដូច្នេះចំពោះពួកគេ: "នេះហើយជាសេចក្ដីអត់ធ្មត់របស់ពួកបរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយ មានសេចក្ដីជំនឿដល់ព្រះយេស៊ូវ" វិវរណៈ:១៤:១២


152

(ព្រះគម្ពីរ វិវរណៈ ១៤:១៤)

នៅក្នុង១១៤ ព្រះមានព្រះបន្ទូលថា "នោះខ្ញុំក្រឡេកទៅឃើញពពកស១ ហើយមាន១អង្គដូចជាកូនមនុស្ស គង់នៅលើ ពពកនោះ


153

ទាំងពាក់មកុដមាស ហើយកាន់កណ្ដៀវ ដ៏មុត"

នេះគឺជាការពណ៌នាអំពីការយាងមក របស់ព្រះជាម្ចាស់ដើម្បីច្រូតនៅផែនដី។


154

នៅក្នុងបទទំនាយដ៏ធំ ដែលព្រះយេស៊ូវ បានប្រទានដល់លោកយ៉ូហាន នៅក្នុងគម្ពីរ វិវរណៈ អំពីប្រវត្តិសាស្ត្រនៃក្រុមជំនុំ ទ្រង់ មានបន្ទូលថា ក្រុមរើសតាំង នៃក្រុមជំនុំដ៏ពិតប្រាកដចុងក្រោយបង្អស់របស់ព្រះ នៅ លើពិភពលោកនេះ បានពណ៌នាថា យ៉ាងដូច្នេះ:


155

(ព្រះគម្ពីរ វិវរណៈ ១២:១៧)

"នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញ ទៅច្បាំងនឹងសំណល់ពូជនាងទាំងប៉ុន្មាន


156

ជាពួកអ្នកដែលកាន់តាមបញ្ញត្តិព្រះ ហើយ មានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវ" វិវរណៈ: ១២:១៧


157

អ្នកនឹងមានដំណឹងនោះនៅក្នុងព្រះគម្ពីរ ចុងក្រោយបង្អស់!

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


158

វាស្ត្ររបស់ព្រះ ស្រឡាញ់ព្រះដែល បង្កើតគេ និងលោះបាបគេខ្លាំងណាស់ ទើបបានជាពួកគេចង់ធ្វើតាមទាំងអស់នូវ អ្វីដែលទ្រង់ទាមទា ឬក៏ទ្រង់ចង់បាន។

ពួកគេចង់បង្ហាញសេចក្តីស្រឡាញ់របស់ គេដល់ទ្រង់ ដោយធ្វើតាមព្រះហឫទ័យ ទ្រង់។

ពួកគេដឹងថា ព្រះហឫទ័យទ្រង់មាននៅ ក្នុងក្រិត្យវិន័យរបស់ទ្រង់។

ពួកគេបានឆ្លើយតប ដោយការគោរព ដល់អ្នកដែលបានសុគតដើម្បីសង្គ្រោះគេចេញពីអំពើបាបយ៉ាងខ្លាំង។

ដោយព្រះហស្តដែលលាតសន្ធឹងរបស់ ទ្រង់ ព្រះយេស៊ូវកំពុងស្រែកហៅថា "ចូរមក!"

ទ្រង់កំពុងនៅតែហៅយើង!

ទ្រង់ចង់ប្រទានអំណាចដល់យើង ដើម្បីរស់នៅសំរាប់ទ្រង់។

---


159

(ព្រះគម្ពីរ វិវរណៈ ២២:១៧)

ទ្រង់ចង់លាងសំអាតបាបរបស់យើង សំឡេងអង្វររបស់ទ្រង់នៅដង្ហោយហៅថា "អញ្ជើញមក ហើយអ្នកណាដែលឮ អ្នក ណាដែលស្រេក នោះមានតែមក ហើយ អ្នកណាដែលចង់បាន មានតែយកទឹកជីវិត នោះចុះឥតចេញថ្លៃទេ" វិវរណៈ:២២:១៧។

---


160

លោកគ្រូអធិប្បាយព្រះគម្ពីរម្នាក់ បាន ទៅសួរសុខទុក្ខផ្ទះមួយ នៅជាយទីក្រុងដ៏ធំ មួយ។

ស្ត្រីនៅក្នុងផ្ទះនេះសុភាពរាបសាណាស់ ប៉ុន្តែម៉ឺងម៉ាត់ នាងបាននិយាយថា "ខ្ញុំមិនចាប់អារម្មណ៍អំពីព្រះគម្ពីរ ឬក៏គ្រីស្ទានអ្វីទេ-គឺមិនទាល់តែសោះ"

"ប៉ុន្តែបើអ្នកយកចិត្តទុកដាក់នឹងត្រឡប់ មកវិញល្ងាចនេះ អ្នកនឹងឃើញថា ប្តីខ្ញុំចូលចិត្តរៀនពីរឿងនេះណាស់។ ខ្ញុំពិតជា ចង់ឱ្យលោកត្រឡប់មកជួបគាត់ខ្លាំងណាស់"

អ្នកអធិប្បាយរូបនេះ បានត្រឡប់មកនៅ ល្ងាចថ្ងៃសៅរ៍មួយ។ ដោយពេលនោះមិនមែនជាថ្ងៃធ្វើការ ប្តីរបស់ស្ត្រីនោះបានធ្វើ តាមទំលាប់ ដោយចំណាយពេលល្ងាច របស់គាត់លេងបៀជាមួយមិត្តភ័ក្តិគាត់ នៅឯសណ្ឋាគារ។

បុរសនោះស្ថិតនៅក្នុងស្ថានភាពនៃការ និយាយប៉ប៉ាច់ប៉ប៉ោចជាខ្លាំង ប៉ុន្តែដោយឥទ្ធិពលនៃការស្រវឹងស្រាស្រៀង១ ទើប បានជាគាត់និយាយប៉ប៉ាច់ប៉ប៉ោចដូចសត្វសេក "ខ្ញុំមានព្រះគម្ពីរ" គាត់និយាយ "លោកអាចឃើញព្រះគម្ពីររបស់ខ្ញុំ។ ម្តាយខ្ញុំបានដាក់វានៅក្នុងវ៉ាលីសរបស់ខ្ញុំ នៅ ពេលខ្ញុំបានចេញពីផ្ទះមករៀបការ។ តើព្រះគម្ពីរបងនៅឯណាអូន?" ការរកព្រះ គម្ពីរយ៉ាងយូរបានឃើញត្រឹមតែសៀវភៅធម្មតាមួយក្បាលប៉ុណ្ណោះ។ គាត់មិនបានរក ព្រះគម្ពីរឃើញទេ។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


161

ប៉ុន្តែស្រាគឺជាបញ្ហាមួយរបស់គាត់។ ល្បែងក៏ជាការបំផ្លាញស្មើគ្នា ហើយគាត់ គឺជាអ្នកជក់ចារីដ៏ចំណាប់ម្នាក់ទៀតដែរ។ ទាំងអស់នេះ បូកបញ្ចូលនឹងទម្លាប់អាក្រក់ ផ្សេងៗរបស់គាត់ទៀតផង បានធ្វើឱ្យ គម្លាតរវាងគាត់និងប្រពន្ធរបស់គាត់កាន់តែធំ ទៅៗ។ នាងបានរៀបចំឥវ៉ាន់ ប្រុងនឹងចាកចេញពីផ្ទះទៅហើយ។

គេទាំងពីរនាក់ប្រុងនឹងលែងលះគ្នា។ ការងារទាំងឡាយកំពុងស្ថិតនៅក្នុងសភាពទន់ជ្រាយជាទីបំផុត។

ប៉ុន្តែសេចក្តីប្រាថ្នាមួយបានមាននៅក្នុង ចិត្តបុរសនោះ។ ទោះបីជាការផឹកស្រាយ៉ាង ខ្លាំងក៏មិនអាចធ្វើអោយការនេះលិចលង់ បានដែរ។

អ្នកអធិប្បាយបានណាត់ជួបគាត់ម្តង ទៀតនៅល្ងាចថ្ងៃច័ន្ទ ហើយនៅពេលនេះការសិក្សាព្រះគម្ពីរប្រចាំ សប្តាហ៍ក៏បាន ចាប់ផ្តើមឡើង។


162

ពីមួយសប្តាហ៍ ទៅមួយសប្តាហ៍ នៅ ពេលដែលចំណងជើងនៃព្រះបន្ទូលរបស់ព្រះបានត្រូវបង្ហាញការអំពាវនាវរបស់ឈើឆ្កាង បានចាប់ផ្តើមធ្វើការ។ ដោយសារព្រះ វិញ្ញាណរបស់ទ្រង់ព្រះគ្រីស្ទបានយាងចូល កាន់ផ្ទះដែលមានសេចក្តីត្រូវការមួយនេះ។

ជាការអស្ចារ្យ នៅពេលល្ងាចមួយបុរស នោះបាននិយាយថា “លោកត្រូវតែនៅឱ្យបានយូរបន្តិចយប់នេះ។ ប្រពន្ធរបស់ខ្ញុំនឹង ចូលគេងឥឡូវនេះហើយ។ បានទេព្រោះខ្ញុំមានការចង់ជជែកគ្នាជាមួយនឹងលោក មួយទល់នឹងមួយ?”

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?


163

បន្ទាប់មក គាត់បានលាតត្រដាង ប្រាប់ ដល់អ្នកអធិប្បាយនោះដោយឥតលាក់លៀម អំពីរឿងរ៉ាវដ៏ក្រៀមក្រំនៃជីវិតរបស់គាត់ ដែលបានចាប់ផ្ដើមឡើងយ៉ាងល្អ។ គាត់បានកើតនៅក្នុងគ្រួសារគ្រីស្ទានយ៉ាងល្អមួយ ប៉ុន្តែបានបណ្ដោយឱ្យចំណង់នៃយុវភាពអូសទាញឱ្យបាត់ភាពម្ចាស់ការ។ ជនវង្វេងម្នាក់ ទៀតបានធ្លាក់ទៅក្នុងផ្លូវអបាយមុខយ៉ាងជ្រៅ និងបានរសាត់ទៅកាន់ទីជនបទឆ្ងាយមួយ។

មិនយូប៉ុន្មានគេក៏បានបំភ្លេចព្រះវិហារ ព្រះគម្ពីរក៏ត្រូវបានគេបដិសេធ ហើយគេបានប្រើព្រះនាមព្រះគ្រីស្ទ សម្រាប់តែប្រ ទេចផ្ដាសាតែប៉ុណ្ណោះ។

"ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងនោះ លោកគ្រូ គឺ តើលោកបានធ្វើអ្វីដល់ខ្ញុំ? ខ្ញុំលែងផឹក ស្រាលែងធ្វើអ្វីដែលអាក្រក់បួនអាទិត្យមក ហើយមកទល់នឹងពេលនេះ។

ឬមួយក៏ពោលពាក្យប្រមាថ ឬប្រើព្រះ នាមរបស់ព្រះជាអសាឥតការទៀតឡើយ" ហើយនៅពេលដែលគាត់បានយកចារីពាក់ កណ្ដាលដើម ដុតទៅក្នុងឡភ្លើង គាត់បាន បន្តថា "ចារីរបស់ខ្ញុំបានក្លាយជាការស្អប់ ខ្ពើមដល់ខ្ញុំ។ ខ្ញុំដឹងថា ខ្ញុំហៀបនឹងឈប់ ជក់ហើយ។

ប៉ុន្តែមានការមួយដែលអស្ចារ្យជាងនេះ ទៅទៀតនោះគឺថា ប្រពន្ធរបស់ខ្ញុំបានស្រាយបង្ហិចឥវ៉ាន់វិញហើយ។ នាងបានធ្វើ ដូច្នេះបីសប្ដាហ៍កន្លងមកហើយ។

ព្រឹកមិញនេះ នាងបានដើរតាមខ្ញុំទៅ កាន់ក្លោងទ្វារ នេះជាលើកទីមួយហើយតាំងពីច្រើនឆ្នាំកន្លងមក ដែលនាងបាន ។

មែនហើយ នាងបានធ្វើមែន! ខ្ញុំបានស្រឡាំង កាំងលោកគ្រូ ហើយលែងមានការអៀន ខ្មាសនៅពេលដែលនាងញញឹមដាក់ខ្ញុំ ហើយនិយាយថា "ខ្ញុំចូលចិត្តហ្វាកថ្មី ណាស់"។

"ឥឡូវតើមានអ្វីកើតឡើងដល់ខ្ញុំ? ខ្ញុំ ជឿជាក់ថា វាប្រាកដជាទាក់ទងទៅនឹងការ សិក្សាព្រះគម្ពីរនៅល្ងាចថ្ងៃច័ន្ទរបស់យើង"។

# ១០. តើការខុសនិងត្រូវនឹងទៅជាយ៉ាងណា?



164

អ្នកអធិប្បាយនោះនិយាយថា "ខ្ញុំមិន បានធ្វើអ្វីទាំងអស់ ទោះបីជាខ្លួនខ្ញុំផ្ទាល់ក៏ ដោយ ប៉ុន្តែខ្ញុំជឿជាក់ថា ព្រះគម្ពីរអាច ពន្យល់អំពីការនេះបានទាំងអស់"។ ហើយ ក៏បើកទៅព្រះគម្ពីរកូរិនថូសទី២ ៥:១៧ រួចចាប់ផ្តើមអាន "បានជាបើអ្នកណានៅ ក្នុងព្រះគ្រីស្ទ នោះឈ្មោះថា បានកើតជាថ្មី ហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ ទៅមើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ" លោកហ្វាកបានក្លាយជាមនុស្សថ្មីហើយ ហើយគាត់បានអានខព្រះគម្ពីរនោះឡើងវិញ សម្រាប់ខ្លួនគាត់យ៉ាងយឺត១ថា "ការបង្កើត ថ្មីនោះគឺហ្វាក ជាមនុស្សថ្មីយ៉ាងពិតប្រាក ដមែន"។ លោកគ្រូ! បើសិនជាលោកគ្រូ បានស្គាល់ខ្ញុំច្បាស់ពីមុនមក ឥឡូវនេះ ខ្ញុំគឺ ជាមនុស្សថ្មីហើយ។

មែនហើយ មិត្តអើយ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះ រាជបុត្រារបស់ព្រះនៃស្ថានសួគ៌ ហើយមាន តែទ្រង់ទេ ដែលមានអំណាចអាចផ្លាស់ប្រែ បុរស និងស្ត្រីទាំងឡាយបាន។

ព្រះយេស៊ូវនេះក៏ចង់ផ្លាស់ប្តូរជីវិតអ្នក ផងដែរ។ ទ្រង់ចង់ប្រទានដល់អ្នកនូវព្រះ គុណ និងអំណាចដើម្បី នឹងអាចកាន់តាម បញ្ញត្តិរបស់ទ្រង់បាន។ អ្នកអាចខ្សោយ ប៉ុន្តែព្រះយេស៊ូវទ្រង់ខ្លាំង។ ទោះជាអ្នកបាន ធ្វើអ្វីកន្លងមក ហើយក៏ដោយ ក៏ព្រះ យេស៊ូវនឹងអត់ទោសឱ្យអ្នកនិងសំអាតអ្នកបាន។ ទ្រង់នឹងប្រទានកម្លាំងរបស់ទ្រង់ដល់អ្នកឱ្យ រស់នៅក្នុងជីវិតថ្មីមួយ។ សូមកុំឱ្យមានអ្វី មួយទាញអ្នកត្រឡប់ថយក្រោយវិញឡើយ។

ព្រះយេស៊ូវកំពុងត្រាស់ហៅ។ ទ្រង់កំ ពុងហៅលោកអ្នកឱ្យមកកាន់លំនៅស្ថាន តើលោកអ្នកគួរលុតជង្គង់ដោយស្ងៀមស្ងាត់ ហើយនិយាយថា "បពិត្រព្រះអង្គ ទូលបង្គំ កំពុងតែមកហើយ" ឬទេ ឥឡូវនេះ?

ខ្ញុំសូមអញ្ជើញលោកអ្នកទម្លាក់ខ្លួនលុត ជង្គង់ចុះ ដោយស្ងៀមស្ងាត់ តាមការ សម្រេចចិត្តរបស់លោកអ្នកផ្ទាល់ ដោយកុំ គិតអំពីអ្នកស្តាប់ដែលនៅជុំវិញលោកអ្នក ឡើយ។

សូមគិតតែពីព្រះយេស៊ូវប៉ុណ្ណោះ នៅ ពេលដែលលោកអ្នកលុតជង្គង់។ សូម និយាយថា" បពិត្រព្រះយេស៊ូ ទូលបង្គំ មកហើយ  ទូលបង្គំមកហើយ ឥឡូវនេះ"។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



1

តើធ្វើយ៉ាងឱ្យស្កប់ចិត្តនឹងបំណងប្រាថ្នាដ៏ធំបំផុតរបស់លោកអ្នក


2

មានរឿងមួយត្រូវបានគេនិយាយអំពីអ្នក ជីវវិទ្យាម្នាក់ ឈ្មោះ ថូម៉ាស ហ៊ុកស្លី ដែលបានចេញដំណើរទៅបង្រៀនឃីត នៅក្នុងទីក្រុងមួយ។ គាត់លោតឡើងទៅលើតាក់ ស៊ីមួយ ដែលនៅជំនាន់នោះគេប្រើសេះ

អូសរទេះកង់បួន ហើយគាត់បានស្រែកទៅ កាន់អ្នកបររទេះសេះនោះថា

"ឱ្យលឿនឡើង!"


3

អ្នកបររទេះសេះក៏ធ្វើតាម ដោយបាន លើករំពាត់វាយសេះឮខ្ទាប់ៗ ហើយរទេះ សេះនោះកំពុងធ្វើដំណើររលិរលាក់យ៉ាង លឿនទៅតាមបណ្តោយផងផ្លូវ ហ៊ុកស្លី ដ៏ប្រញាប់ប្រញាល់

នៅស្ងៀមលើកៅអីនៃ រទេះសេះរបស់គាត់ សម្រាកមួយស្របក់ បន្ទាប់មក

ស្ទុះឡើងអង្គុយដោយរន្ធត់។

គាត់បានស្រែកឡើងថា "ឮឬទេ ឮឬ ទេ តើអ្នកដឹងថា ខ្ញុំកំពុងទៅទីណាឬទេ?"

"ទេលោកម្ចាស់" អ្នកបររទេះសេះបាន ឆ្លើយតប "ប៉ុន្តែខ្ញុំកំពុងបរយ៉ាងលឿនអស់ លទ្ធភាពហើយ"


4

មនុស្សដ៏គួរឱ្យភ័យខ្លាចជាច្រើនកំពុង ធ្វើដំណើរពពាក់ពពូនសព្វថ្ងៃនេះ។ មានបញ្ហាជាច្រើនកំពុងកើតឡើង នៅក្នុងជីវិត របស់ពួកគេ។ ពួកគេតែងតែទៅណាមកណាយ៉ាងលឿនដូច្នេះ។ ប៉ុន្តែការពិត មាន មនុស្សច្រើនណាស់ដែលមិនដឹងថា គេកំពុងធ្វើដំណើរទៅកាន់ទីណា គេមិនបានដឹង ថា ជីវិតរបស់ពួកគេកំពុងមាន ដំណើរទៅខាងណាឡើយ។


5

ដោយសារហេតុដ៏ជាក់លាក់នេះហើយ ទើបព្រះទ្រង់ប្រទានការអំពាវនាវរបស់ទ្រង់នៅក្នុងព្រះគម្ពីរ ចុងក្រោយបង្អស់ វិវរណៈ នៅក្នុងជំពូក១៤ ខ៧ លោកសាវក

យ៉ូហានអំពាវនាវទៅកាន់ពិភពលោកឱ្យរង់ចាំការយាងមករបស់ព្រះយេស៊ូវដោយពាក្យយ៉ាងដូច្នេះ...



6

(ព្រះគម្ពីរ វិវរណៈ ១៤:៧)

"...ចូរកោតខ្លាចដល់ព្រះ ហើយ សរសើរ សិរីល្អរបស់ទ្រង់ចុះ ដ្បិតពេល ដែលទ្រង់ត្រូវជំនុំជំរះនោះបាន មកដល់ ហើយ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



7

ចូរក្រាបថ្វាយបង្គំដល់ព្រះដែលបង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ" វិវរណៈ:១៤:៧

ប៉ុន្តែប្រសិនបើអ្នកមានផែនទីនៃទីក្រុង របស់អ្នក ហើយអ្នកកំពុងតែមើលវាដើម្បី រកកន្លែងមួយ តែផែនទីនោះខុស វាពិតជា ធ្វើឱ្យមានការខុសទិសដៅជាពិតប្រាកដ!


8

ថ្វាយបង្គំអ្នកណា? ថ្វាយបង្គំដល់ព្រះ ដែលបានបង្កើតផ្ទៃមេឃនិងផែនដី។

ថ្វាយបង្គំព្រះដែលបង្កើតរបស់សព្វសារ ពើ។

ព្រះបានសូមឱ្យយើងបង្អង់សិន ហើយ ផ្ចង់គំនិតដើម្បីអោយដឹងថា យើងកំពុងធ្វើ ដំណើរទៅកាន់ទីណា

នៅពេលដែលយើងយល់ថា យើងត្រូវ បានបង្កើតឡើងដោយព្រះ វាធ្វើឱ្យយើង គិតថា តើហេតុអ្វីបានជាយើង នៅទីនេះ និងតើយើងកំពុងទៅទីណា។


9

សព្វថ្ងៃនេះមនុស្សបានភ្លេចថា ព្រះជា អ្នកបង្កើតលោកសន្និវាសយើងទាំងមូល បង្កើតពិភពលោកយើងនេះ បង្កើតរបស់ សព្វសារពើ បង្កើតមនុស្សគ្រប់គ្នា នៅក្នុង ពិភពលោកនេះ។

អ្នកខ្លះនិយាយថា អ្នកអាចទុកចិត្តលើ ព្រះគម្ពីរទាំងស្រុង ដោយគ្មានសង្ស័យ។ ខ្លះទៀតនិយាយថា ទេ មិនអាចទេ។

តើអ្នកណាមួយជាអ្នកត្រូវទៅ?



10

(វីដេអូ ៦វិនាទី) សព្វថ្ងៃនេះមនុស្សរាប់ លាននាក់គិតថា គេគ្រាន់តែជាការវិវត្តន៍ តែប៉ុណ្ណោះ។

រាប់កោដិឆ្នាំ យើងបានកើតឡើងពីកោ សិកាតូចមួយ ជាសត្វសមុទ្រ ជាសត្វលើដី រួចជាមនុស្ស។

គេគិតថា អ្វីៗទាំងអស់បានកើតឡើង ដោយឯកឯង ឬដោយចៃដន្យ ដែលយើង មិនអាចយល់បានប៉ុណ្ណោះ។


11

ប៉ុន្តែ តើលោកអ្នកដឹងទេថា ព្រះបាន ប្រទានឱ្យយើងនូវនិមិត្តសញ្ញាមួយ នៃការ ងាររបស់ទ្រង់ ថាទ្រង់ជាអ្នកបង្កើតយើង មក?

ទ្រង់បានប្រទានការមួយដើម្បីរំលឹក យើងរៀងរាល់សប្តាហ៍ ថាទ្រង់បានបង្កើត យើង ពិភពលោកយើង និងពិភពចក្រ វាលរបស់យើនេះមក?

ប្រសិនបើព្រះគម្ពីរពិត វាសនារបស់អ្នក ទាំងស្រុងត្រូវពឹងផ្អែកទៅលើការដែលអ្នកជឿនិងទទួលព្រះគម្ពីរនោះ។

ការដែលអ្នកជឿទៅលើព្រះគម្ពីរនោះ មានសារសំខាន់ លើសេចក្ដីជំនឿរបស់ អ្នកចំពោះព្រះ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



12

តាមពិតទ្រង់បានប្រទានការរំលឹកដល់ យើងរៀងរាល់សប្តាហ៍នេះ តាំងពីថ្ងៃចុង ក្រោយបង្អស់នៃសប្តាហ៍នៃការបង្កបង្កើតមក ម្ល៉េះ

ប៉ុន្តែ ស្ទើរតែពេញពិភពលោកទាំង មូល បានបំភ្លេចនូវការរំលឹកនេះ។



13

(វីដេអូ ១៥វិនាទី) ហើយបើគ្មានការរំលឹក នោះទេ មនុស្សស្ទើរតែទាំងអស់បានភ្លេច ថា ព្រះគឺជាអ្នកបង្កើតពិភពលោក។

ដូចនៅសម័យយើងនេះ យើងបាន បញ្ជូនមនុស្សទៅកាន់ស្ថានព្រះច័ន្ទ ដើម្បីរក មើលនូវសញ្ញាថា តើពិភពលោកយើងនេះ បានកើតឡើងរបៀបយ៉ាងណា


14

យើងមើលទៅលំហអាកាសដោយកែវ យឹតដ៏មានកម្លាំងខ្លាំង ដើម្បីរកមើលសញ្ញា ថា តើលោកសន្និវាស យើងនេះបានចាប់ ផ្តើមឡើងដោយរបៀបណា។

ឥឡូវសូមយើងមើលទៅកាន់សៀវភៅ ដ៏ធំនេះ_គឺព្រះគម្ពីរ_ដែលត្រូវបានគេហៅ ថា ព្រះបន្ទូលរបស់ព្រះផងដែរ_ហើយរក មើលក្រែងលោអាចឃើញមានភ័ស្តុតាងអំពី ការនេះ ទោះបីជាពិតឬមិនពិតក៏ដោយ_ទោះបីជាគួរឱ្យទុកចិត្តបានឬមិនបានក៏ដោយ


15

តើហេតុអ្វីបានជាមានការខំប្រឹងប្រែង និងចំណាយជាច្រើនទាំងនេះ? ពីព្រោះ យើងចង់ឆ្លើយទៅនឹងសំនួរដ៏ធំរបស់យើង។ តើយើងនៅតែឯងនៅលើលោកសន្និវាសនេះឬអី? ហេតុអ្វីបានជាយើងមកដល់ទីនេះ? ហេតុអ្វីបានជាយើងនៅទីនេះ? ហើយ តើ យើងកំពុងធ្វើដំណើរទៅកាន់ទីណា?

ដូច្នេះការស្រាវជ្រាវបានធ្វើឡើងជាបន្ត។ តាំងពីដើមមក ចម្លើយនៅចំពោះមុខយើង ប៉ុន្តែយើងបានបំភ្លេចចោល យើងលែងនឹក ចាំតទៅទៀតថា តើយើងមកពីណា!



16

ទៅកាន់ពិភពលោកដែលបានភ្លេចនោះ ព្រះបានមានបន្ទូលថា "ចូរឱ្យនឹកចាំ ចូរឱ្យនឹកចាំថា ខ្ញុំជាអ្នកបង្កើតអ្នក។ និងដើម្បីជួយឱ្យអ្នកនឹកចាំថា ខ្ញុំបានផ្តល់ឱ្យ អ្នកនូវសញ្ញាមួយ_និមិត្តសញ្ញាមួយ!"



17

(វីដេអូ ៥ វិនាទី) សព្វថ្ងៃនេះនៅក្នុង ប្រវត្តិសាស្ត្រ នៅពេលដែលការវិវត្តន៍បាន បង្រៀនថា យើងជាលទ្ធផលនៃភ័ព្វវាសនា ព្រះមានបន្ទូលថា "អ្នកមិនមែនជាការ វិវត្តន៍ទេ អញបានបង្កើតឯងមក!"

១១. បានបង្កើតសម្រាប់ការប្រសើរឡើង

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


18

ប៉ុន្តែមានអ្នកខ្លះអាចសួរថា "តើអ្វីទៅ ដែលជាសញ្ញា ឬនិមិត្តសញ្ញាដែលរំលឹក យើងថា ព្រះបានបង្កើតយើងនោះ?"
តើលោកអ្នកចាំទេ នៅពេលដែលយើង បានសិក្សាអំពីការដែលព្រះបានបង្កើត នៅថ្ងៃនីមួយៗក្នុងសប្តាហ៍ នៃការបង្កបង្កើតនោះ


19

(ព្រះគម្ពីរ ទំនុកដំកើង ៣៣:៨,៩)
ការបង្កបង្កើតគឺជាការសំបើមអស្ចារ្យ! តើព្រះទ្រង់បានធ្វើយ៉ាងណា ហើយលឿន យ៉ាងណា?
ព្រះគម្ពីរផ្តល់ចម្លើយ "ចូរឱ្យគ្រប់ផែន ដីខ្លាចចំពោះព្រះយេហូវ៉ា ហើយឱ្យគ្រប់ មនុស្សនៅលោកីយ៍កោតក្រែងដល់ទ្រង់ចុះ


20

ដ្បិតទ្រង់គ្រាន់តែមានបន្ទូល នោះក៏កើត មានដូច្នោះ ទ្រង់បានបង្គាប់នោះក៏មាននៅ"
ទំនុកដំកើង ៣៣:៨,៩


21

យើងមិនអាចយល់បានថាយ៉ាងណានោះ ទេ ប៉ុន្តែព្រះអាចនាំយករបស់ទាំងឡាយឱ្យកើតមានឡើងបាន ដោយសារព្រះបន្ទូល របស់ទ្រង់ ទោះបីជាមានបន្ទូល ឬសរសេរ នៅក្នុងព្រះគម្ពីរក៏ដោយ ក៏ព្រះបន្ទូលនោះ មានអំណាចអាចនឹងបង្កបង្កើតឡើងបានដែរ។
ការយល់ស្របនេះអាចត្រូវពន្យល់បាន ដោយការទទួលស្គាល់ថា ព្រះបានប្រទាន សៀវភៅនេះមកឱ្យយើង ដើម្បីឱ្យយើង អាចទាក់ទងជាមួយនឹងព្រះហឫទ័យទ្រង់បាន។


22

(ព្រះគម្ពីរ លោកុប្បត្តិ ២:១)
"ដូច្នេះផ្ទៃមេឃ និងផែនដីក៏បានរួចជា ស្រេច ព្រមទាំងរបស់សព្វសារពើផង"
លោកុប្បត្តិ ២:១


23

ក្នុងរវាងប្រាំមួយថ្ងៃ ព្រះអាទិករបាននាំ ព្រះបន្ទូលឱ្យកើតជាជីវិត ដែលរុំព័ទ្ធដោយ រុក្ខជាតិនានា ដើមឈើតូចធំ ផ្កា និងផ្លូវ ទឹកទាំងឡាយ។


24

ទ្រង់បាននាំមកនូវអរុណោទ័យ និង អស្តង្គតកាលដ៏មានរស្មីចាំងចែង ហើយ និងដាក់ព្រះច័ន្ទដ៏ល្អគ្មានអ្វីប្រៀបបាន ដើម្បី ឱ្យមានអំណរនៅពេលយប់!

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



25

ប៉ុន្តែពិសេសបំផុត ទ្រង់បានបង្កើត មនុស្សគ្រប់លក្ខណ៍ពីរនាក់។

ជាការដែលគួរឱ្យសរសើរណាស់ គេ ត្រូវបានបង្កើតតាមរូបរបស់អ្នកបង្កើតគេ!

ពួកគេត្រូវបានបង្កើតឱ្យធ្វើជាអ្នកត្រួតត្រាលើ ផែនដី និងអ្វីៗទាំងអស់ដែលនៅលើផែន ដីនោះ!



26

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៧)

"ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់

គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះ ឯង"

លោកុប្បត្តិ ១:២៧



27

ប៉ុន្តែព្រះទ្រង់មិនទាន់បានបញ្ចប់ទេ!

ទ្រង់នៅមានការមួយទៀតដែលទ្រង់ចង់ ធ្វើ។

សូមកត់សំគាល់ដោយប្រុងប្រយ័ត្ន នូវអ្វី ដែលព្រះគម្ពីរនិយាយថា នឹងកើតឡើងនៅថ្ងៃ បន្ទាប់ថ្ងៃទីប្រាំពីរនៃការបង្កបង្កើតៈ



28

(ព្រះគម្ពីរ លោកុប្បត្តិ ២:២-៤)

"លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើ នោះបានហើយជាស្រេច



29

ទ្រង់ក៏ឈប់ផ្អាកសំរាកនៅថ្ងៃទី៧នោះ ពី គ្រប់ទាំងការដែលទ្រង់ធ្វើ



30

ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះថ្ងៃ នោះទ្រង់បានឈប់សំរាកពីគ្រប់ទាំងការ ដែលទ្រង់បានបង្កើតបានធ្វើ



31

នេះហើយជាដើមកំណើតនៃផ្ទៃមេឃ និងផែនដីក្នុងកាលដែលបានកើតមក គឺនៅ

ពេលដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានធ្វើ

ផែនដី និងផ្ទៃមេឃនោះឯង"

លោកុប្បត្តិ ២:២-៤

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


32

មានតែព្រះទេដែលអាចធ្វើអ្វីៗឱ្យបរិសុទ្ធ បាន ហើយព្រះគម្ពីរនិយាយថា ទ្រង់បាន ញែកជាបរិសុទ្ធនូវថ្ងៃទីប្រាំពីរនោះ។


33

ញែកអ្វីមួយ គឺជាការដកចេញដើម្បីប្រើ ជាបរិសុទ្ធ។ ព្រះបានញែកថ្ងៃបរិសុទ្ធចេញ ពីថ្ងៃដទៃទៀតទាំងអស់។

ថ្ងៃនោះត្រូវបានញែកចេញជាបរិសុទ្ធ បានថ្វាយដាច់ទាំងស្រុងដល់ទ្រង់។

មានមនុស្សដែលងឿងឆ្ងល់ថា តើថ្ងៃ នោះត្រូវបានបង្កើតឡើងខុសពីថ្ងៃដទៃទៀត យ៉ាងណា? ប្រហែលជាការបកស្រាយនេះ អាចនឹងជួយបាន


34

អាពាហ៍ពិពាហ៍មួយ នារីម្នាក់ត្រូវបាន ញែកចេញសម្រាប់បុរសម្នាក់។

ចូរឧបមាថា វាជាថ្ងៃអាពាហ៍ពិពាហ៍ របស់អ្នក។

អ្នកនឹងរំភើបជាខ្លាំង។ អ្នកបានទន្ទឹងរង់ ចាំថ្ងៃនោះជាយូរមកហើយ។


35

ចូរឧបមាទៀតថា ប្រពន្ធរបស់អ្នកមាន បងប្អូនស្រីប្រាំមួយនាក់។ នៅក្នុងឱកាស អាពាហ៍ពិពាហ៍ ស្ត្រីម្នាក់ត្រូវបានរួបរួមជា មួយបុរសម្នាក់។ នាងត្រូវបានញែកចេញ។ នាងលែងជាស្ត្រីម្នាក់ក្នុងចំណោមទាំងប្រាំពីរ នាក់ទៀតហើយ។

នាងជាអ្នកដែលត្រូវបានញែកចេញជា បរិសុទ្ធ។

សម្រាប់ប្តីរបស់នាងក្នុងអាពាហ៍ពិពាហ៍ នោះ!


36

តើវាយ៉ាងណាទៅបើសិនជាបងប្អូនស្រី ម្នាក់របស់ប្រពន្ធអ្នកបាននិយាយថា "តើ មួយក្នុងប្រាំពីរនេះ វាខុសគ្នាយ៉ាងណា ទៅ?។ អ្នកទាំងអស់គ្នាក្នុងចំណោមទាំង ប្រាំពីរនាក់នេះសុទ្ធតែល្អដូចតែគ្នាទេតើ"

តើអ្នកនឹងនិយាយថាយ៉ាងណា តើវាមាន ការខុសគ្នាឬទេ?

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


37

ចុះលោកស្រីទាំងឡាយវិញ តើយ៉ាង ណាដែរ តើវាធ្វើឱ្យខុសគ្នាយ៉ាងណាដែរឬ ទេ ចំពោះកូនក្រមុំ?

ពិតប្រាកដជាមានការខុសគ្នា!

ក្នុងនាមជាប្ដី អ្នកនឹងនិយាយថា "កូន ក្រមុំរបស់ខ្ញុំត្រូវតែបានជ្រើសរើស បាន ញែកចេញ បានរៀបចំជាបរិសុទ្ធ សម្រាប់ ខ្ញុំ"

ដូច្នេះ ព្រះបានយកថ្ងៃធម្មតាមួយដែល មាន២៤ម៉ោង-ថ្ងៃទីប្រាំពីរ-ហើយជ្រើស រើសថ្ងៃនោះធ្វើវាឱ្យបរិសុទ្ធញែកវាចេញ ហើយថ្វាយដាច់ដល់ទ្រង់ផ្ទាល់។

ថ្ងៃបរិសុទ្ធត្រូវបានប្រទានពរ ជាថ្ងៃ ដែលបានញែកចេញ។ យោងតាមព្រះ បន្ទូលរបស់ព្រះ វាមិនមែនជាថ្ងៃណាផ្សេង នោះទេ គឺថ្ងៃទីប្រាំពីរ។



38

(ព្រះគម្ពីរ ម៉ាកុស ២:២៧-២៨)

នេះគឺជាការដែលព្រះគ្រីស្ទបានមានព្រះ បន្ទូល "ថ្ងៃឈប់សំរាកបានតាំងឱ្យសម្រាប់ មនុស្ស មិនមែនជាមនុស្ស សម្រាប់ថ្ងៃ ឈប់សំរាកទេ



39

ដូច្នេះកូនមនុស្សជាម្ចាស់នៃថ្ងៃឈប់សំ រាកដែរ"

ម៉ាកុស ២:២៧,២៨


40

ព្រះបានប្រទានថ្ងៃបរិសុទ្ធ ដើម្បីឱ្យយើង ចំណាយពេលចងចាំ ថាយើងមិនមែនជា ការវិវត្តន៍ទេ។

ព្រះទ្រង់បានបង្កើតមនុស្ស និងរបស់ ទាំងឡាយដទៃទៀត នៃពិភពលោកដ៏ស្រស់ ប្រិមប្រិយនេះ ក្នុងរវាងប្រាំមួយថ្ងៃ!

នេះគឺជាពេលដ៏បរិសុទ្ធ នៅពេលដែលមនុស្សនិងអ្នកដែលបង្កើតគេ អាចនឹងរំលឹកឡើងវិញ ជាថ្មីនូវពាក្យសច្ចា នៃសេចក្ដីស្រឡាញ់ ព្រមទាំងមនុស្ស ថ្វាយបង្គំព្រះ ហើយទ្រង់ទទួលការថ្វាយ បង្គំពីគេ ជាមួយគ្នារៀងរាល់ សប្ដាហ៍។

រៀងរាល់សប្ដាហ៍មនុស្សត្រូវតែ "នឹកចាំ" ថាព្រះបានបង្កើតផ្ទៃមេឃ និងផែនដី នៅក្នុងពេលប្រាំមួយថ្ងៃ ហើយបានសម្រាក នៅថ្ងៃទីប្រាំពីរ។


41

ព្រះបានសុំឱ្យមនុស្សចងចាំ បានជាទ្រង់ បានសរសេរបញ្ញត្តិ ដោយព្រះអង្គុលីរបស់ ព្រះអង្គផ្ទាល់។

បញ្ញត្តិទីបួននៅចំកណ្ដាល នៃច្បាប់ដ៏ ពិសិដ្ឋរបស់ព្រះ។

ទ្រង់បានប្រាប់ដល់មនុស្សថា "ចូរនឹក ចាំ" ថ្ងៃនោះ ពីព្រោះក្នុងរវាងប្រាំមួយថ្ងៃ ទ្រង់បានបង្កើតផែនដី សមុទ្រ និងវន្ទទឹក ទាំងឡាយ។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



42

ប្រសិនបើថ្ងៃបរិសុទ្ធត្រូវបានគេគោរព ដើម្បីទុកជាការរំលឹកអំពីការបង្កបង្កើតនោះ នឹងមិនមាន អ្នកប្រាជ្ញនៃការវិវត្តន៍ទេ មិន មានអ្នកមិនជឿសាសនា និងមិនមានអ្នក សង្ស័យឡើយ។

ពួកគេត្រូវបានរំលឹកជារៀងរាល់សប្តាហ៍ អំពីដើមកំណើត និងទំនាក់ទំនងរបស់គេ ទៅនឹងព្រះដែល បានបង្កើតគេមក!

នៅពេលដែលអំពើបាបកាន់តែកើន ឡើងនៅលើផែនដីនេះ មនុស្សបានភ្លេច ថា គេកើតមកពីណា ថា ហេតុអ្វីបាន ជាគេនៅទីនេះ និងថា តើគេកំពុងធ្វើ ដំណើរទៅឯណា។

នៅពេលដែលការទាំងអស់នេះកើត ឡើង ពួកគេបានភ្លេចផងដែរ អំពីរបៀប ដែលពួកគេត្រូវរស់នៅ។



43

(វីដេអូ ១០វិនាទី)នៅជំនាន់លោកម៉ូសេ ជនជាតិអ៊ីស្រាអែលបានបំភ្លេចសឹងតែអស់ រលីងអំពីព្រះរបស់គេ។

ពួកគេត្រូវបានងប់ងុលទៅក្នុងការថ្វាយ បង្គំ ដល់រូបសំណាកដែលមនុស្សបានធ្វើ!



44

(វីដេអូ ៧វិនាទី) ព្រះបានរំដោះគេចេញពី ពួកសត្រូវរបស់គេមកដោយការអស្ចារ្យ ហើយបានដឹកនាំគេឆ្លងវាលរហោស្ថាន តាមផ្លូវទៅកាន់ "ដែនដីសន្យា"។

នៅក្នុងទីរហោស្ថាននេះ ទ្រង់បានធ្វើ ការពីរ ដើម្បីបង្ហាញដល់ពួកគេនូវអ្វីដែល ទ្រង់ចង់ឱ្យពួកគេធ្វើ ដែលទាក់ទងទៅនឹង ថ្ងៃបរិសុទ្ធ ជាថ្ងៃទីប្រាំពីរ ដែលទ្រង់បាន តាំងសម្រាប់ពួកគេ នៅក្នុងសប្តាហ៍ទីមួយ នៃប្រវត្តិសាស្ត្រពិភពលោកនេះ។



45

(វីដេអូ ១០វិនាទី) ដំបូងព្រះបានបង្ហាញ ពួកគេថា ទ្រង់យកព្រះទ័យទុកដាក់ចំពោះ ពួកគេបានជាទ្រង់ បាននាំពួកគេចេញ ពីស្រុកអេស៊ីព្ទ។

ពួកគេមិនអាចយកចំណីអាហារបាន គ្រប់គ្រាន់ទេ។

មិនយូរប៉ុន្មាន ពួកគេបាន ត្អូញត្អែ ដោយគេអស់ម្ហូបអាហារ។

ពួកគេហាក់ដូចជាគ្មានការកោតសរសើរ អំពីការអស្ចារ្យ និងសេចក្តីសប្បុរសដែល ព្រះបានបង្ហាញដល់ពួកគេ សោះ ប៉ុន្តែព្រះ ដ៏ជាទីស្រឡាញ់បានប្រទានចំណីអាហារដល់ ពួកគេ!


46

(ព្រះគម្ពីរ និក្ខមនំ ១៦:៤,៥)

"បន្ទាប់មក ព្រះយេហូវ៉ាទ្រង់មាន បន្ទូលនឹងម៉ូសេថា មើលអញនឹងបង្អុរ ភ្លៀងជានំបុ័ង ពីលើមេឃមកឱ្យឯងរាល់គ្នា។


47

ត្រូវឱ្យបណ្តាជនចេញទៅរើសឱ្យល្មមតែ ១ថ្ងៃ រាល់ៗថ្ងៃ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


48

ដើម្បីឱ្យអញបានល្បងលគេមើល តើគេ នឹងដើរតាមច្បាប់របស់អញឬទេ”

និក្ខមនំ ១៦:៤

“នំបុ័ង” នោះត្រូវបានគេហៅថា “ម៉ាន៉ា”


49

ដល់ថ្ងៃទី៦ នោះត្រូវឱ្យគេរើស


50

លើសជាងធម្មតា១ជា២ យកទៅរៀបចំទុក”

និក្ខមនំ ១៦:៥


51

(ព្រះគម្ពីរ និក្ខមនំ ១៦:៦)

“ម៉ូសេនិងអឺរ៉ុនក៏ប្រកាសប្រាប់ដល់កូន ចៅអ៊ីស្រាអែលទាំងអស់ថា


52

នៅល្ងាចនេះអ្នករាល់គ្នានឹងដឹងថា គឺជា ព្រះយេហូវ៉ាហើយ ដែលបាននាំអ្នករាល់គ្នា ចេញពីស្រុកអេស៊ីព្ទមក

និក្ខមនំ ១៦:៦



53

(វីដេអូ ១៦វិនាទី) ម៉ាន៉ាធ្លាក់មកនាពេល យប់ នៅពេលដែលទឹកសន្សើមធ្លាក់។ នៅ ពេលព្រឹកឡើង ក្រោយពីទឹកសន្សើមបាន ហួតអស់ទៅ នំម៉ាន៉ាបានក្រាលពាសពេញដី។

មនុស្សបានចេញទៅរើសតាំងពីព្រលឹម ហើយនៅពេលថ្ងៃត្រង់ នំម៉ាន៉ានោះក៏ រលាយអស់ទៅ ប៉ុន្តែចាំបន្តិច។ សូមពិនិត្យមើលថា តើ នឹងមានអ្វីកើតឡើងនៅថ្ងៃទីប្រាំមួយនៃសប្តាហ៍


54

(ព្រះគម្ពីរ និក្ខមនំ ១៦:២១,២២)

“គេតែងតែរើសល្មមរាល់តែព្រឹកឱ្យល្មម បរិភោគឆ្អែតគ្រប់ៗគ្នា


55

លុះដល់ថ្ងៃក្តៅនំនោះក៏រលាយទៅ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


56

លុះដល់ថ្ងៃទី៦ គេក៏រើសនំនោះបាន ចំនួន២ភាគ គឺ២ខ្ទឹងគ្រប់គ្នា


57

រួចអស់ទាំងមេលើពួកជំនុំក៏មកប្តឹងដល់ ម៉ូសេ។


58

(ព្រះគម្ពីរ និក្ខមនំ ១៦:២៣)

“តែលោកឆ្លើយថា នោះគឺជាសេចក្តី ដែលព្រះយេហូវ៉ាបានបង្គាប់មកទេ ដ្បិតថ្ងៃស្អែកជាថ្ងៃសម្រាក គឺជាថ្ងៃឈប់សម្រាក បរិសុទ្ធ ថ្វាយព្រះយេហូវ៉ា។


59

អាហារណាដែលត្រូវដុតនោះឱ្យដុតចុះ ហើយអាហារណាដែលត្រូវស្ងោរឱ្យស្ងោរទៅ ឯអាហារណាដែលសល់ នោះត្រូវទុកដល់ ព្រឹកឡើងសម្រាប់អ្នករាល់គ្នា”

និក្ខមនំ ១៦:២១-២៣


60

(ព្រះគម្ពីរ និក្ខមនំ ១៦:២៥,២៦)

ទាក់ទងទៅនឹងថ្ងៃទីប្រាំពីរៈ “រួចម៉ូសេ ប្រាប់ថា ត្រូវបរិភោគសំណល់នោះនៅថ្ងៃ នេះ ដ្បិតជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ា” ថ្ងៃនេះអ្នករាល់គ្នានឹងរកនៅឯវាលទៀតគ្មាន ទេ


61

អ្នករាល់គ្នានឹងរើសនំនោះបានតែក្នុង រវាង៦ថ្ងៃ លុះដល់ថ្ងៃទី៧ នោះគ្មានទេ ព្រោះជាថ្ងៃឈប់សំរាក”

ខ ២៥,២៦


62

មនុស្សភាគច្រើនបានធ្វើតាមការដែល ព្រះបានបញ្ជា ប៉ុន្តែខ្លះបានមករើសនំម៉ាន៉ា នៅថ្ងៃបរិសុទ្ធ សូមកត់សំគាល់នូវអ្វីដែល ព្រះបានមានព្រះបន្ទូលអំពីការនោះ!


63

(ព្រះគម្ពីរ និក្ខមនំ ១៦:២៨-៣០)

“នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹង ម៉ូសេថា តើឯងរាល់គ្នាមិនព្រមធ្វើតាម បញ្ញត្តិ ហើយនិងច្បាប់អញដល់កាលណា ទៀត?

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


64

មើល ដោយព្រោះព្រះយេហូវ៉ាបានប្រ ទានឱ្យមានថ្ងៃឈប់សំរាក នោះបានជាក្នុង ថ្ងៃទី៦ ទ្រង់ក៏ប្រទាននំឱ្យលួមគ្រប់គ្រាន់ ដល់២ថ្ងៃ


65

ដូច្នេះចូរឱ្យឯងរាល់គ្នានៅតែក្នុង កន្លែងឯងចុះ កុំឱ្យអ្នកណាចេញទៅក្រៅ នៅថ្ងៃទី៧ឡើយ


66

ហេតុនោះ បណ្តាជនគ្រប់គ្នាក៏សំរាក នៅថ្ងៃទី៧នោះ" និក្ខមនំ១៦:២៨-៣០


67

ថ្ងៃបរិសុទ្ធត្រូវតាំងឡើងនៅពេលបង្ក បង្កើតផែនដី ហើយត្រូវបានប្រតិបត្តិដោយ រាស្ត្ររបស់ព្រះ មុនដែលគេបានមកដល់ភ្នំ ស៊ីណាយ ជាកន្លែងដែលបានប្រទានក្រិត្យ វិន័យដប់ប្រការឱ្យគេ។


68

ក្នុងខែទីបីនៃដំណើរភៀសខ្លួន ព្រះបាននាំ មនុស្សទៅកាន់ភ្នំស៊ីណាយ ហើយនៅទីនោះ ទ្រង់បានលេចមកឯលោកម៉ូសេ ហើយបាន ផ្តល់ដំណឹងឱ្យយកទៅចែកចាយដល់ ប្រជា នុរាស្ត្រ:


69

(ព្រះគម្ពីរ និក្ខមនំ ១៩:៥,៦)
"ដូច្នេះឯងរាល់គ្នានឹងស្តាប់តាមបញ្ញត្តិអញ ឥឡូវ ហើយកាន់តាមសេចក្តីសញ្ញារបស់អញ


70

នោះឯងរាល់គ្នានឹងបានជាច់ជារបស់ផងអញ លើសជាងអស់ទាំងសាសន៍ ដ្បិតផែនដី ទាំងមូល ជារបស់ផងអញ


71

ឯងរាល់គ្នានឹងបានធ្វើជានគរដល់អញ ដែលសុទ្ធតែជាសង្ឃ ហើយជាសាសន៍ បរិសុទ្ធឱ្យអញដែរ។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


72

គឺពាក្យទាំងនេះហើយ ដែលឯងត្រូវ ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល"


73

ព្រះអម្ចាស់បានបង្កើតលោកីយ៍យ៉ាងល្អប្រ
សើរដើម្បីផ្តល់ដល់រាស្ត្ររបស់ទ្រង់! ប្រសិន បើគេគោ រពច្បាប់និងបញ្ញត្តិរបស់ទ្រង់ ពួកគេនឹង
ក្លាយជារាស្ត្រដ៏ពិសេស និង សាសន៍ដ៏ បរិសុទ្ធរបស់ទ្រង់! បញ្ញត្តិមួយ ក្នុងចំ
ណោមបញ្ញត្តិទាំងអស់នោះ ដែលទ្រង់បាន ប្រទាន គឺដើម្បីធ្វើឱ្យគេ ក្លាយជារាស្ត្ររបស់ ទ្រង់ផ្ទាល់
និងមិនឱ្យបំភ្លេចនូវទំនាក់ទំនង ជាមួយនឹង ព្រះដ៏ជាអាទិកររបស់គេទេ។
ជាការពិតណាស់ ទ្រង់បានចាប់ផ្តើមជា មួយនឹងពាក្យថា "ចូរនឹកចាំ"។


74

(ព្រះគម្ពីរ និក្ខមនំ ២០:៨-១១)
(វីដេអូ ៥វិនាទី) "ចូរនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ។ ក្នុង រវាង៦ថ្ងៃនោះ
ត្រូវឱ្យឯងធ្វើអស់ទាំងការ របស់ឯងចុះ


75

តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយ ព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះ
មិនត្រូវធ្វើអ្វីឱ្យសោះ


76

ទោះខ្លួនឯង ឬកូនប្រុសកូនស្រីឯងក្តី ទោះ បាវប្រុសឬបាវស្រីឯងក្តី ទោះ


77

សត្វរបស់ឯង ឬអ្នកដទៃដែលនៅផ្ទះឯងក្តី។ ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានបង្កើត


78

ផ្ទៃមេឃ ផែនដី ហើយនិងសមុទ្រ ព្រម ទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧
ទ្រង់ឈប់សំរាក។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


79

ហេតុនោះបានជាព្រះយេហូវ៉ាបានប្រទាន ពរដល់ថ្ងៃឈប់សំរាក ហើយញែកចេញជាបរិសុទ្ធ”

និក្ខមនំ ២០:៨-១១



80

ថ្ងៃបរិសុទ្ធជាមជ្ឈមណ្ឌល ឬជាបេះដូង នៃគំនិតនេះ។

ថ្ងៃបរិសុទ្ធ គឺជាការរំលឹកដល់ការបង្ក បង្កើត។

វាមានចំណាស់ស្មើនឹងផែនដីនោះឯង!

ព្រះសន្យាជាមួយរាស្ត្រទ្រង់នូវព្រះពរជាច្រើន ប្រសិនបើគេស្តាប់តាមទ្រង់ ហើយចងចាំអំពីអនុស្សាវរីយ៍នៃការបង្កបង្កើតរបស់ទ្រង់។


81

(ព្រះគម្ពីរ អេសាយ ៥៨:១៣,១៤)

“បើឯងឃាត់ជើងឯង មិនឱ្យបែរចេញ ពីថ្ងៃឈប់សំរាក ក៏មិនឱ្យធ្វើតាមអំពើចិត្តនៅថ្ងៃបរិសុទ្ធរបស់អញ បើឯងរាល់គ្នា ឈប់សំរាកទុកជាទីរីករាយចិត្ត


82

ហើយលើកថ្ងៃបរិសុទ្ធរបស់ព្រះយេហូវ៉ា ទុកជាថ្ងៃគួរគោរព ព្រមទាំងប្រតិបត្តិតាម ផងឥតធ្វើតាមអំពើចិត្តរបស់ខ្លួន


83

ឬស្វែងរកសេចក្តីអំណរដល់ខ្លួនឯង ឬ ពោលតែពាក្យរបស់ផងខ្លួនឡើយ


84

គ្រានោះឯងនឹងបានចិត្តរីករាយក្នុងព្រះ យេហូវ៉ា”

អេសាយ ៥៨:១៣,១៤)

ប្រសិនបើមនុស្សនឹកចាំពីអនុស្សាវរីយ៍ នោះ បញ្ហាទាំងឡាយដែលគេជួបប្រទះ មានការភ្លេចព្រះ ជីវិតគ្មានន័យ ការខ្វល់ ខ្វាយនៃជីវិត នឹងត្រូវបានដោះស្រាយទាំង អស់។

នឹងគ្មានអ្នកវិវត្តន៍ទៀតឡើយ!



85

(វីដេអូ ៨វិនាទី) ប៉ុន្តែវាមានការពិបាកនឹង និយាយណាស់ថា រាស្ត្ររបស់ព្រះបាន បំភ្លេចរឿងនោះ។ ពួកគេបានភ្លេចថ្វាយបង្គំទ្រង់នៅថ្ងៃ បរិសុទ្ធ របស់ទ្រង់និង

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


86

មិនយូរប៉ុន្មាន គេក៏ចាប់ផ្តើមថ្វាយបង្គំព្រះ ដែលធ្វើពីឈើនិងថ្ម។ គេបានភ្លេចប្រភព ដើមរបស់គេ!


87

ការប្រតិបត្តិថ្ងៃបរិសុទ្ធ ត្រូវបានគេនិយម ឡើងវិញនៅក្នុងកំឡុងពេលរាប់សតវត្សរ៍មក ហើយពីព្រោះ ហោរារបស់ព្រះបានអំពាវ នាវអោយត្រឡប់ទៅរកការដែលព្រះបានបង្ក បង្កើតលោកីយ៍នេះវិញ។

លោកអេសាយបានទស្សនទាយថា ព្រះ មិនដែលបានគ្រោងទុកថា នឹងកំណត់ព្រំដែនថ្ងៃបរិសុទ្ធសំរាប់ជនជាតិយូដាទេ


88

ថ្ងៃបរិសុទ្ធត្រូវបានបង្កើតមុនពួកយូដា កើតមានទៅទៀត។

ព្រះមិនបានកំណត់ព្រំដែនចំពោះព្រះពរ ដ៏ធំនេះ ដល់ជាតិសាសន៍ណាមួយឡើយ។


89

(ព្រះគម្ពីរ អេសាយ ៥៦:៦,៧)

ទ្រង់បានអញ្ជើញមនុស្សគ្រប់គ្នា គ្រប់ ទីកន្លែងឱ្យនឹកចាំ និងគោរពថ្ងៃបរិសុទ្ធជា មួយទ្រង់។

"គឺគ្រប់អស់អ្នក ណាដែល រក្សាថ្ងៃឈប់សំរាកឥតបង្អាប់ឡើយ...


90

នោះអញនឹងនាំគេមកឯភ្នំបរិសុទ្ធរបស់ អញ ហើយឱ្យគេបានអរសប្បាយ នៅក្នុង ដំណាក់របស់អញដែលសំរាប់ជាទីអធិស្ឋាន


91

...ដ្បិតដំណាក់អញនឹងបានហៅជាទី អធិស្ឋានសំរាប់គ្រប់ទាំងសាសន៍"

អេសាយ ៥៦:៦,៧


92

គ្មានកន្លែងណានៅក្នុងព្រះគម្ពីរដែល ថ្ងៃទីប្រាំពីរត្រូវបានហៅថា "ថ្ងៃបរិសុទ្ធ របស់ពួកយូដាទេ"

ព្រះយេស៊ូវបានមានព្រះបន្ទូលយ៉ាង ច្បាស់ថា ថ្ងៃបរិសុទ្ធសម្រាប់មនុស្សគ្រប់គ្នា ទាំងអស់នៅពេលដែលព្រះអង្គមានព្រះ បន្ទូលថា

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


93

(ព្រះគម្ពីរ ម៉ាកុស ២:២៧)

"...ថ្ងៃឈប់សំរាកបានតាំងសំរាប់ឱ្យ មនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់ សំរាកទេ"

ម៉ាកុស ២:២៧


94

(ព្រះគម្ពីរ និក្ខមនំ ២០:១០)

ហើយព្រះទ្រង់មានព្រះបន្ទូលថា

"...ជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជា ព្រះនៃឯងវិញ..."

និក្ខមនំ ២០:១០


95

(ព្រះគម្ពីរ ម៉ាថាយ ១២:៨)

ព្រះយេស៊ូវថែមទាំងបានមានព្រះ បន្ទូលថា "ដ្បិតកូនមនុស្សជាម្ចាស់នៃថ្ងៃ ឈប់សំរាក" (ម៉ាថាយ ១២:៨) ពីព្រោះ ទ្រង់បានបង្កើតថ្ងៃនេះ


96

(ព្រះគម្ពីរ វិវរណៈ ១:១០)

ហេតុនេះហើយបានជាលោកយ៉ូហាន ដែលជាអ្នកបានឃើញការជាក់ស្តែង នោះ បានហៅថា "ថ្ងៃនៃព្រះអម្ចាស់"

វិវរណៈ ១:១០

ថ្ងៃបរិសុទ្ធ លើសពីការនឹកចាំនូវការ បង្កបង្កើត និងព្រះដែលបានបង្កបង្កើតទៅ ទៀត។

ថ្ងៃនោះគឺជាសញ្ញារវាងមនុស្សនិងព្រះ។


97

(ព្រះគម្ពីរ អេសេគាល ២០:២០)

"ចូរញែកថ្ងៃឈប់សំរាករបស់អញចេញ ជាបរិសុទ្ធ នោះនឹងបានជាទីសំគាល់ដល់ អញ ហើយនឹងឯងរាល់គ្នា


98

ដើម្បីឱ្យឯងបានដឹងថា អញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា

អេសេគាល ២០:២០។

អ្នកដែលបានបង្កើតថ្ងៃបរិសុទ្ធ ជា បរិសុទ្ធ នៅសប្តាហ៍ទីមួយនៃការបង្កបង្កើត គឺជាអ្នកដែលបានធ្វើឱ្យមនុស្សមានបាប បានបរិសុទ្ធឡើងវិញ។

ព្រះដែលជាអ្នកបង្កបង្កើតយើង គឺជា ព្រះអង្គសង្គ្រោះរបស់យើងដែរ!

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



99

(ព្រះគម្ពីរ អេសេគាល ២០:១២)

"អញក៏តាំងថ្ងៃឈប់សំរាកឱ្យគេដែរ ទុកសំរាប់ជាទីសំគាល់ដល់អញ ហើយនិងគេ



100

ប្រយោជន៍ឱ្យគេបានដឹងថា អញជាព្រះ យេហូវ៉ាដែលញែកគេចេញជាបរិសុទ្ធ"

អេសេគាល ២០:១២




101

(វីដេអូ ១២វិនាទី) ថ្ងៃបរិសុទ្ធត្រូវបាន បង្កើតមុនពេលដែលអំពើបាបបានចូលមក កាន់ផែនដីនេះ ហើយនិងត្រូវបានគេប្រារព្ធ ក្រោយពេលអំពើបាបត្រូវបានបំបរបង់ចេញ ពីផែនដីជារៀងរហូត។



102

(ព្រះគម្ពីរ អេសាយ ៦៦:២២,២៣)

"ដ្បិតដែលផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលអញនឹងបង្កើតឡើងនោះ នឹងស្ថិតស្ថេរនៅចំពោះអញជាយ៉ាងណា ព្រះ យេហូវ៉ាទ្រង់មានបន្ទូលថា



103

ពូជពង្សរបស់ឯង និងឈ្មោះឯងរាល់គ្នា ក៏នឹងស្ថិតស្ថេរនៅយ៉ាងនោះដែរ



104

គ្រានោះនឹងកើតមានដូច្នេះថា ចាប់តាំងពី ថ្ងៃចូលខែ១ ដរាបដល់ថ្ងៃឈប់សំរាក១ទៀត



105

នោះគ្រប់មនុស្សទាំងអស់នឹងមកក្រាប ថ្វាយបង្គំនៅចំពោះអញ នេះជាព្រះបន្ទូល នៃព្រះយេហូវ៉ា"

អេសាយ ៦៦:២២,២៣

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង




106

(វីដេអូ ៦វិនាទី) ជារឿងរាបដរាបអស់ កល្ប រាស្ត្ររបស់ព្រះ និងគោរពថ្ងៃបរិសុទ្ធ ដើម្បីសរសើរដំកើងព្រះថា ជាអ្នកបង្កើត និងអ្នកប្រោសលោះរបស់គេ។

ប្រសិនបើថ្ងៃនោះត្រូវបានគេប្រារព្ធមុន អំពើបាបបានចូលមកកាន់ផែនដីនេះ ហើយនឹងត្រូវបានគេប្រារព្ធនៅ ពេលដែល ផែនដីនេះត្រូវបានបង្កើតឡើងជាថ្មីវិញដែរ នោះ តើវាមិនមានន័យថា រាស្ត្ររបស់ព្រះ ត្រូវ ប្រារព្ធធ្វើ ពិធីនេះនៅពេលឥឡូវនេះ ដែរទេអី?



107

ប្រសិនជាអ្នកមានសំនួរអំពីព្រះ និងថ្ងៃ បរិសុទ្ធ យើងត្រូវមើលទៅការដែលព្រះ យេស៊ូវប្រកាន់ថ្ងៃនោះការ។



108

លោកលូការប្រាប់យើង ពីអ្វីដែលព្រះ យេស៊ូវបានធ្វើនៅថ្ងៃបរិសុទ្ធ:




109

(ព្រះគម្ពីរ លូកា ៤:១៦)

"រួចទ្រង់យាងមកដល់ណាសារ៉ែត ជាស្រុក ដែលទ្រង់គង់នៅពីកុមារ




110

ក៏ចូលទៅក្នុងសាលាប្រជុំនៅថ្ងៃឈប់សំរាក តាមទម្លាប់ទ្រង់ ហើយឈរឡើងដើម្បីអាន មើលគម្ពីរ" លូកា ៤:១៦។

ព្រះគម្ពីរបានប្រាប់ថា គឺជាទំនៀមទំលាប់ របស់ព្រះយេស៊ូវ!



111

វចនានុក្រមខ្មែរនិយាយថា "ថ្ងៃសៅរ៍



112

ជាថ្ងៃទីប្រាំពីរនៃសប្ដាហ៍

ដូចជាវចនានុក្រមខ្មែរ សម្ដេចជួនណាត ដែលបញ្ជាក់ថា ថ្ងៃសៅរ៍ គឺជាថ្ងៃទី៧នៃ សប្ដាហ៍ដែរ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



113

(វីដេអូ ៩វិនាទី) បើថ្ងៃនោះបានត្រូវផ្លាស់ ប្តូរឬត្រូវ បានគេបំភ្លេចនៅចន្លោះពេល លោកអ័ដាម និងលោកម៉ូសេ ព្រះនឹងបាន កែលំអវា នៅពេលដែលទ្រង់បានសរសេរ ក្រិត្យវិន័យជប់ប្រការ នៅលើភ្នំស៊ីណាយ ហើយ។



114

(វីដេអូ ១១វិនាទី) ប្រសិនបើថ្ងៃនោះត្រូវ បានបាត់បង់ ក្នុងរយៈពេលពីលោកម៉ូសេ ដល់ព្រះយេស៊ូវ នោះព្រះគ្រីស្ទបានធ្វើឱ្យ ត្រឹមត្រូវឡើងវិញទៅហើយ។



115

(វីដេអូ ៩វិនាទី) ប្រសិនបើថ្ងៃនោះត្រូវបាន ផ្លាស់ប្តូរនៅជំនាន់ពួកសាវ័ក ពួកគេពិត ប្រាកដជាបានកត់ត្រារឿងនោះហើយ។



116

(វីដេអូ ៩វិនាទី) ហើយជាពិសេសពួកយូដា ដែលបានកត់ត្រាពេលវេលាយ៉ាងតឹងរឹង នៅតែថ្វាយបង្គំនៅថ្ងៃទីប្រាំពីរនោះដដែល។



117

(វីដេអូ ១៩វិនាទី) ការបញ្ជាក់របស់ថ្ងៃនៃ ការសំរាកមិនដែលត្រូវបានគេសង្ស័យឡើយ នៅជំនាន់ព្រះយេស៊ូវមានព្រះជន្មរស់នៅលើ ផែនដីនេះ។

ទំនាស់តែមួយគត់ គឺការដែលទ្រង់ អនុវត្តថ្ងៃនោះ។

ពួកគ្រូយូដា បានធ្វើឱ្យថ្ងៃបរិសុទ្ធខុសពី ភាពដើម ដោយបង្កើតឱ្យមានការពិបាក នឹងប្រតិបត្តិ ជាបទបញ្ជាដែលពិបាកនឹង អនុវត្ត ព្រះយេស៊ូវព្យាយាមបំបាត់តម្រូវការរបស់ មនុស្ស និងបង្ហាញពីអត្ថន័យនៃការគោរព ថ្ងៃបរិសុទ្ធ


118

នៅពេលដែលពួកគេចោទប្រកាន់ព្រះ យេស៊ូវ អំពីការបង្ខូចថ្ងៃបរិសុទ្ធ ព្រោះទ្រង់ ព្យាបាលមនុស្សនៅថ្ងៃនោះ



119

(ព្រះគម្ពីរ ម៉ាថាយ ១២:១២)

"...មានច្បាប់ឱ្យធ្វើការល្អនៅថ្ងៃឈប់ សម្រាកដែរ"

ម៉ាថាយ ១២:១២

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



120

(វីដេអូ ១៨វិនាទី) ព្រះគម្ពីរនិយាយថា ព្រះយេស៊ូវបានព្យាបាលនិងផ្សាយដំណឹង។ ថ្ងៃបរិសុទ្ធធ្វើឱ្យយើងបានពេញលេញ ដោះ លែងយើងឱ្យរួចពីទោស រួចពីការប្រកាន់ពូជ សាសន៍ និងភាពអាត្មានិយម និងផ្តល់នូវ សេចក្តីសុខសាន្តដល់ព្រលឹង

វាគឺជាការបង្កើតយើងឡើងវិញទៅនឹង រូបអង្គរបស់ព្រះ និងចង្អុលបង្ហាញយើងឱ្យត្រឡប់ទៅកាន់ព្រះដែលបានបង្កើតយើង!

នេះគឺជាការងារដែលព្រះយេស៊ូវបានយាងមកធ្វើ និងជាការងារដែលពួកសាវកបានធ្វើក្រោយពេលដែលព្រះ យេស៊ូវបានចាក ចេញពីពួកគេទៅ។



121

(វីដេអូ ១១វិនាទី) ការគោរពថ្ងៃបរិសុទ្ធ ត្រូវបានបង្ហាញ ដោយពួកអ្នកដែលដើរតាមព្រះយេស៊ូវនៅឯការសុគតរបស់ទ្រង់។

នៅក្នុងវិបត្តិនេះ មិត្តរបស់ព្រះយេស៊ូវ បានសំរាកទៅតាមបញ្ញត្តិរបស់ព្រះ ដោយ ទុកការចាក់ប្រេងលើព្រះសពរបស់ព្រះយេស៊ូវចោល រហូតដល់ម៉ោងនៃថ្ងៃបរិសុទ្ធបានចប់។



122

(ព្រះគម្ពីរ លូកា ២៣:៥៤-៥៦)

"ថ្ងៃនោះជាថ្ងៃរៀបចំ រៀបនឹងចូលថ្ងៃ ឈប់សំរាកហើយ។



123

ឯពួកស្រីៗ ដែលមកពីស្រុកកាលីឡេ ជាមួយនឹងទ្រង់ គេក៏តាមទៅឃើញផ្នូរ និងសណ្ឋានដែលគេបញ្ចុះព្រះសពទ្រង់



124

រួចគេវិលទៅវិញ រៀបគ្រឿងក្រអូប និងប្រេងអប់ តែគេឈប់នៅថ្ងៃឈប់សំរាក តាមបញ្ញត្តិសិន" លូកា ២៣:៥៤-៥៦



125

(វីដេអូ ៨វិនាទី) ថ្ងៃមុន ថ្ងៃបរិសុទ្ធ

សេចក្តី សង្ឃឹមទៅលើព្រះយេស៊ូវត្រូវ បានកំទេច ពួកគេបានឃើញ ទ្រង់សុគត យ៉ាងវេទនានៅលើឈើឆ្កាង។ ការសុបិន និងសេចក្តី សង្ឃឹមរបស់ពួកគេនៅក្នុងផ្នូរដ៏ងងឹត។

ពួកគេចង់ចាក់ប្រេងថ្វាយព្រះសពទ្រង់។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


126

(ព្រះគម្ពីរ លូកា ២៤:១)

"...លុះដល់ថ្ងៃទី១ក្នុងអាទិត្យ កាលភ្លឺ ស្រាងៗ នោះគេយកគ្រឿងក្រអូប ដែល រៀបចំនោះ នាំគ្នាទៅឯផ្នូរ..."

លូកា ២៤:១


127

សូមយើងមើលទៅព្រឹត្តិការណ៍នៃថ្ងៃ ដែលគួរឱ្យចងចាំមួយទៀត។


128

១. ថ្ងៃសុក្រៈព្រះយេស៊ូវសុគត ពួកស្រីៗ បានរៀបប្រេងអប់ និងគ្រឿងក្រអូប


129

២. ថ្ងៃសៅរ៍(ថ្ងៃបរិសុទ្ធ) ព្រះយេស៊ូវបាន

សម្រាកនៅក្នុងផ្នូរ អ្នកដែលដើរតាមទ្រង់ បាន សម្រាកដែរ។


130

៣. ថ្ងៃអាទិត្យ(ថ្ងៃទីមួយនៃសប្តាហ៍): ព្រះ យេស៊ូវរស់ពីការសុគតឡើងវិញ! ពួកស្រីៗ បានមកដើម្បី ចាក់គ្រឿងក្រអូបថ្វាយព្រះ យេស៊ូវ។

នៅឯការសុគតរបស់ព្រះយេស៊ូវនោះ

គ្មានអ្វីដែលគួរឱ្យសង្ស័យ ថាថ្ងៃ ណាជា ថ្ងៃបរិសុទ្ធឡើយ។


131

(ព្រះគម្ពីរ យ៉ូហាន ១៩:៣០)

ព្រះយេស៊ូវជាប់នៅលើឈើឆ្កាងនៅថ្ងៃ រៀបចំ ហើយបានស្រែកថា "...ការ សម្រេចហើយ!..."

យ៉ូហាន ១៩:៣០


132

ការងារនៃការប្រោសលោះរបស់ទ្រង់ត្រូវ បានចប់ដោយបរិបូរ!

ទ្រង់បានសំរាកនៅក្នុងផ្នូរនៅថ្ងៃបរិសុទ្ធ

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



133

(វីដេអូ ៦វិនាទី) ហើយរស់ឡើងវិញនៅថ្ងៃ អាទិត្យ ជាថ្ងៃទីមួយនៃសប្តាហ៍។
សូម្បីតែនៅក្នុងការសុគតក៏ដោយ ក៏ព្រះ យេស៊ូវប្រកាន់ថ្ងៃបរិសុទ្ធដែរ។
ទ្រង់បានសំរាកនៅក្នុងផ្នូរនៅថ្ងៃបរិសុទ្ធ។
នៅពេលដែលយើងឈរក្បែរឈើឆ្កាង យើងមានអារម្មណ៍ថា ថ្ងៃបរិសុទ្ធមិនមែន ថ្ងៃណាមួយក៏បាននៅក្នុងថ្ងៃទាំងប្រាំពីរ នោះឡើយ ព្រោះថាការបង្ខូចថ្ងៃបរិសុទ្ធ
អាចចាត់ទុកជាការបង្ខូចការបង្កបង្កើត លោកីយ៍ បង្ខូចភ្នំស៊ីណាយ និងបង្ខូចចំពោះភ្នំរលាក្បាល(កាល់វ៉ារី) នោះឯង!


134

មែនហើយ រឿងនេះសំខាន់ណាស់ ទាក់ទង ទៅនឹងថ្ងៃណាមួយ ក្នុងថ្ងៃទាំងប្រាំពីរដែលយើងប្រតិបត្តិ។
អ្នកនិពន្ធគ្រីស្ទានម្នាក់ឈ្មោះហ្គេច វ៉ាន ឌីម៉ែន បានសរសេរថា
"បើយើងអាចឃើញពួកអ្នកដើរតាម ទ្រង់ បដិសេធមិនព្រមធ្វើឱ្យអាប់ឱនពេល វេលាដ៏ពិសិដ្ឋនោះ ទោះបើធ្វើការងារនៃ សេចក្តីស្រឡាញ់ក៏ដោយ


135

បើយើងអាចឃើញពួកសិស្សរបស់ព្រះ អង្គបដិសេធមិនប្រមាថដល់ពេលដ៏ពិសិដ្ឋ នោះ ទោះបីជាការងារនៃសេចក្តីស្រឡាញ់ របស់គេក៏ដោយ។


136

បើយើងឃើញទ្រង់សុគតនៅលើឈើឆ្កាង
ព្រោះតែបញ្ញត្តិមិនអាចសម្របសម្រួលបាន សូម្បីតែ ដើម្បីសង្គ្រោះជីវិតទ្រង់ផ្ទាល់ក៏ ដោយ


137

តើយើងឈរនៅក្នុងអណ្តាតភ្លើងនៃភ្នំ រលាក្បាល(កាល់វ៉ារី) ហើយនិយាយថា មិនជាបញ្ហា អ្វីទេបានឬទេ?"
ថ្ងៃដែលគួរឱ្យចងចាំមួយ ទំព័រ៤០



138

ព្រះដ៏ជាអាទិករបានមានព្រះបន្ទូលថា "ចូរឱ្យនឹកចាំ" មានមនុស្សជាច្រើននៅតែ ភ្លេច ប៉ុន្តែនោះមិនមែនជាព្រះរាជបំណង របស់ទ្រង់ទេ។
ព្រះយេស៊ូវបានរំពឹងថា គ្រីស្ទានទាំង អស់ ត្រូវតែរក្សាថ្ងៃបរិសុទ្ធគ្រប់ពេលវេលា។

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


139

(ព្រះគម្ពីរ ម៉ាថាយ ២៤:២០)

“ចូរឱ្យអធិស្ឋានសូមកុំឱ្យត្រូវរត់នៅរដូវ រងា ឬនៅថ្ងៃឈប់សំរាកឡើយ”

ម៉ាថាយ ២៤:២០។



140

(វីដេអូ ៦វិនាទី) ព្រះយេស៊ូវបានរំពឹងថា

គ្រីស្ទាននៅឆ្នាំ៧០ នៃគ្រិស្តសករាជនឹងនៅ តែគោរពថ្ងៃបរិសុទ្ធ នៅពេលដែលទីក្រុង

យេរូសាឡិមត្រូវបានបំផ្លាញ!


141

(ព្រះគម្ពីរ កិច្ចការ ១៧:១,២) ព្រះគម្ពីរ សញ្ញាថ្មីបានកត់ត្រាថា ពួកសិស្សរបស់ព្រះ

យេស៊ូវបានគោរពថ្ងៃបរិសុទ្ធ បន្ទាប់ពីការ មានព្រះជន្មរស់ឡើងវិញ:

“នោះគេទៅដល់ក្រុងថែស្សាឡូនីច ជា កន្លែងដែលមានសាលាប្រជុំរបស់សាសន៍យូដា


142

ប៉ុលក៏ចូលទៅឯគេតាមទម្លាប់គាត់ ហើយជជែកពន្យល់ដល់គេតាមគម្ពីរក្នុង៣ថ្ងៃ ឈប់សំរាក”

កិច្ចការ ១៧:១,២។

នៅថ្ងៃបរិសុទ្ធមួយទៀត នៅពេលដែល លោកប៉ុលកំពុងអធិប្បាយ មានពួកក្រៅ សាសន៍ខ្លះ

បានមកដោយសួរថា


143

(ព្រះគម្ពីរ កិច្ចការ ១៣:៤២,៤៤)

“នោះពួកសាសន៍ដទៃក៏សូមឱ្យប៉ុល

អធិប្បាយតាមសេចក្តីទាំងនោះ នៅថ្ងៃឈប់ សំរាកមួយក្រោយទៀត


144

“ដល់ថ្ងៃឈប់សំរាកក្រោយ នោះពួក អ្នកក្រុងស្ទើរតែទាំងអស់ ក៏មកប្រជុំគ្នា

ដើម្បីនឹងស្តាប់ព្រះបន្ទូល”

កិច្ចការ ១៣:៤២,៤៤


145

ជាការពិត ព្រះគម្ពីរកិច្ចការបានកត់ត្រាការ ប្រជុំ៨៤ដងដែលលោកប៉ុលធ្វើនៅថ្ងៃ បរិសុទ្ធ។


146

ថ្ងៃបរិសុទ្ធបានដំណើរការដូចជាខ្សែមាស ដែលបានបន្តតាំងពីព្រះគម្ពីរលោកុប្បត្តិ រហូតដល់វិវរណៈ

ដែលពិពណ៌នាអំពីអ្នក ដែលត្រូវបានរៀបចំខ្លួនចាំជួបនឹងព្រះយេស៊ូវ នៅគ្រាយាងមកជាលើកទីពីរ!

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង


147

(ព្រះគម្ពីរ វិវរណៈ ១៤:១២)
"នេះហើយជាសេចក្ដីអត់ធ្មត់របស់ពួក បរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្ដីជំនឿដល់ព្រះយេស៊ូវ"
វិវរណៈ:១៤:១២


148

(ព្រះគម្ពីរ យ៉ូហាន ១៤:១៥)
ព្រះយេស៊ូវបានមានបន្ទូលថា "បើអ្នក រាល់លគ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបពាត្តិ របស់ខ្ញុំចុះ" យ៉ូហាន ១៤:១៥)
ហើយបញ្ញត្តិមួយក្នុងចំណោមបញ្ញត្តិទាំងនោះ ប្រាប់យើងឱ្យ "នឹកចាំពីថ្ងៃបរិសុទ្ធ"


149

ប្រសិនបើយើងថ្វាយបង្គំព្រះដែលជា ព្រះអាទិកររបស់យើងរៀងរាល់សប្ដាហ៍នៅថ្ងៃទីប្រាំពីរ យើងនឹងមិនដែលភ្លេចទេថា យើងមកពីណា ឬក៏អ្នកណាបានបង្កើត យើង និងថា ពិភពលោកជុំវិញយើងនេះ មកពីណា។


150

ប្រសិនបើយើងគោរពថ្ងៃបរិសុទ្ធរៀង រាល់សប្ដាហ៍ យើងនឹងមិនត្រូវសង្ស័យ ឡើយថា យើងជាអ្នកណា ជាកូនប្រុស កូនស្រីរបស់ព្រះ ដែលជាស្ដេចនៃចក្រវាល នេះ!


151

យើងមិនត្រូវសង្ស័យឡើយថា យើងមក ដល់ទីនេះដោយរបៀបណា។ យើងនៅទី នេះ ពីព្រោះព្រះចង់ឱ្យយើងនៅ ព្រោះ ទ្រង់បានបង្កើតយើង។


152

ព្រះយេស៊ូវដដែល ដែលបានសុំឱ្យអ្នក "នឹកចាំ" លាតព្រះហស្តរបស់ទ្រង់ ទៅរក លោកអ្នកនៅយប់នេះ-ជាព្រះហស្តដែលគេ បានបោះដែកគោលភ្ជាប់ទៅនឹងឈើឆ្កាង ដើម្បីអំពើបាបរបស់យើងនៅភ្នំរលាក្បាល (កាល់វ៉ារី)ម្ដង ហើយហៅដោយសុភាពថា "សូមមកតាមខ្ញុំ"

# ១១. បានបង្កើតសម្រាប់ការប្រសើរឡើង



153

តើលោកអ្នកនឹងដើរតាមព្រះដែលបាន បង្កើតលោកអ្នកឥឡូវនេះឬទេ?

តើលោកអ្នកនឹងគោរពថ្ងៃបរិសុទ្ធដែល ទ្រង់បានបង្កើតសម្រាប់លោកអ្នកឬទេ?

តើលោកអ្នកនឹងថ្វាយបង្គំទ្រង់រៀងរាល់ សប្តាហ៍ ចាប់ពីឥឡូវនេះទៅ នៅពេលដែលថ្ងៃបរិសុទ្ធរបស់ទ្រង់ ចូលមករៀង រាល់ថ្ងៃទីប្រាំពីរឬទេ?

តើលោកអ្នកនឹងធ្វើតាមគំរូរបស់ព្រះ យេស៊ូវ និងសិស្សរបស់ទ្រង់ លើការថ្វាយបង្គំព្រះជាម្ចាស់របស់អ្នក រៀងរាល់ថ្ងៃទី ប្រាំពីរ ជាថ្ងៃបរិសុទ្ធឬទេ?


154

មិត្តទាំងឡាយ សារសំខាន់នៃថ្ងៃបរិសុទ្ធ មិនមែនគ្រាន់តែស្ថិតនៅលើការដែលថ្វាយបង្គំព្រះនៅថ្ងៃណាមួយនោះទេ វាជាសារសំខាន់នៃការដើរតាមព្រះយេស៊ូវរៀងរហូត។ វាជា សារសំខាន់ នៃការឈរនៅជាមួយអ័ដាម និងអេវ៉ា នៅពេលដែលគេថ្វាយបង្គំនៅ ក្នុងសួនច្បារអេដែននៅថ្ងៃបរិសុទ្ធដំបូង។

វាគឺជាសារសំខាន់នៃការគោរពប្រតិបត្តិ ដល់ព្រះជាមួយលោកម៉ូសេ នៅពេលដែលព្រះបានមានព្រះបន្ទូលថា "ចូរឱ្យនឹកចាំ ពីថ្ងៃឈប់សម្រាក ហើយញែកថ្ងៃនោះចេញជាបរិសុទ្ធ។

គឺជាសារសំខាន់ នៃការថ្វាយបង្គំ ដូច ដែលលោកអេសាយ យេរេមា ដានីយ៉ែល និងអ្នកដែលមានជំនឿរឹងមាំងទៀត ដែល មានជំនឿមុតមាំនៅសម័យសញ្ញាចាស់។

គឺជាសារសំខាន់នៃការសរសើរដំកើងព្រះ រៀងរាល់ថ្ងៃបរិសុទ្ធជាព្រះដ៏បង្កបង្កើតរបស់យើងទាំងអស់គ្នា ជាមួយលោកពេត្រុស យ៉ាកុប និងយ៉ូហាន។

វាជាសារសំខាន់ នៃការចូលរួមចំណែក ជាមួយរាស្ត្រចុងក្រោយបង្អស់របស់ព្រះដែលរក្សាបញ្ញត្តិរបស់ទ្រង់ តាមព្រះគម្ពីរ វិវរណៈ។

តើលោកអ្នកចង់និយាយថា "បពិត្រ ព្រះយេស៊ូវ ទូលបង្គំនឹងឈរនៅជាមួយ ទ្រង់។ ទូលបង្គំនឹងយកទ្រង់ជាទីមួយ។ ទូលបង្គំនឹងដើរតាមទ្រង់ឱ្យអស់ពីចិត្ត" ប្រសិនបើនេះគឺជាបំណងប្រាថ្នារបស់លោក អ្នក សូមលើកដៃឡើង នៅពេលដែល យើងអធិស្ឋាន។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត



1

សូមកុំឱ្យវាកើតមានដល់លោកអ្នកឡើយ


2

រឿងប្រឌិតវាងាយនឹងទទួលជឿជាង រឿងពិតណាស់ ប្រសិនបើវាកើតមានជា យូរយារមកហើយ។ យកករណីនៃសត្វពីង ពាងជាឧទាហរណ៍។ ប្រហែលជា៣៥០ឆ្នាំ មុនគ្រិស្តសករាជ ទស្សនវិទូក្រេកដ៏ធំម្នាក់ ឈ្មោះអារីស្តូដ  បានចាត់ទុកពីងពាងជា សត្វមានជើងប្រាំមួយ។

ហើយរយៈពេល២០សតវត្សរ៍មក មនុស្សគ្រប់គ្នាបានជឿថា ពីងពាងមាន ជើងប្រាំមួយមែន។ គ្មានអ្នកណាម្នាក់រវល់ នឹងរាប់ឡើយ។ ហើយម្យ៉ាងវិញទៀត តើ អ្នកណានឹងហ៊ានប្រឆាំងនឹងលោកអារីស្តូដ ដ៏មានប្រាជ្ញានោះ? ក្រោយមកមានលោកឡាម៉ារ៉ាក្វ ជាជីវវិទូ និងធម្មជាតិវិទូយ៉ាងចំណាន។ គាត់បានរាប់ជើងពីងពាងយ៉ាង យកចិត្តទុកដាក់។ ហើយសូមសាកល្បងទាយមើលថា តើគាត់រាប់ឃើញមានប៉ុន្មាន? មានប្រាំបីយ៉ាងត្រឹមត្រូវ! ប្រពៃណីដែលត្រូវបានបង្រៀនថា ជាការពិតរាប់សតវត្សរ៍មកហើយនោះ ត្រូវបានបំបាត់ចោលយ៉ាងយកចិត្តទុកដាក់បំផុតដោយលោក ឡាមារ៉ាក្វ ។


3

តើប្រពៃណីភាន់ច្រឡំបែបនោះ អាច វរអិលចូលក្នុងក្រុមជំនុំគ្រីស្ទានបានដែរឬទេ? តើអាចមានរឿងដែលទាក់ទងនឹងក្រុមជំនុំ គ្រីស្ទានដែលសំខាន់ជាងពីងពាងមានជើង ប្រាំមួយឬប្រាំបី នៅទីនេះដែរឬទេ?

មនុស្សរាប់លាននាក់ថ្វាយបង្គំព្រះនៅ ថ្ងៃទីមួយនៃសប្តាហ៍ ដោយជឿថា នេះគឺជាថ្ងៃបរិសុទ្ធនៃព្រះគម្ពីរ។ នៅការប្រជុំ លើកមុនរបស់យើង យើងបានឃើញថា ថ្ងៃទីប្រាំពីរនៃសប្តាហ៍-ថ្ងៃនៃសប្តហ៍-ថ្ងៃ សៅរ៍ គឺជាថ្ងៃបរិសុទ្ធដ៏ពិតរបស់ព្រះ។

ដូចជាសៀវភៅសិក្សាដែលបានបង្រៀន ទាំងខុសអស់រយៈពេល២០០០ឆ្នាំមកហើយ ថា ពីងពាងមានជើងប្រាំមួយដូច្នោះដែរ មនុស្សរាប់លាននាក់បានទទួលការយល់ខុស ទាក់ទងទៅនឹងថ្ងៃបរិសុទ្ធនេះ។

មូលហេតុដែលលោកអ្នកកំពុងចូលរួម ការសិក្សាព្រះគម្ពីរតាមលំដាប់នេះ ពីព្រោះចិត្តលោកអ្នកចង់ដឹងពីការពិត។

លោកអ្នកចង់ដឹងថា ព្រះបន្ទូលរបស់ ព្រះថាយ៉ាងដូចម្តេច។ លោកអ្នកមិនចាប់អារម្មណ៍អំពីការដែលអ្នកដឹកនាំសាសនា បង្រៀននោះទេ។ លោកអ្នកចង់ដឹងនូវអ្វីដែលព្រះបានមានព្រះបន្ទូល។

សូមយើងរំលឹកអំពីអ្វីដែលយើងបានដឹង ពីការប្រជុំលើកមុន។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត



4

(វីដេអូ ៨វិនាទី) យើងបានរៀនមកថា ព្រះ បានប្រទានដល់យើងនូវថ្ងៃពិសេសមួយរៀង រាល់សប្តាហ៍-គឺថ្ងៃបរិសុទ្ធ-ជាថ្ងៃដែលយើង ថ្វាយបង្គំទ្រង់ ហើយនឹកចាំពីកិច្ចការរបស់ទ្រង់ដែលជាអ្នកបង្កបង្កើតយើង។

យើងបានរៀនថា ថ្ងៃបរិសុទ្ធមិនមែនថ្ងៃ ណាក៏បាននោះទេ ប៉ុន្តែគឺជាថ្ងៃទីប្រាំពីរនៃ សប្តាហ៍។

ហើយយើងបានរៀនទៀតថា ថ្ងៃ បរិសុទ្ធនេះ នឹងនៅតែត្រូវបានគេថែរក្សារហូតដល់ពិភពលោកនេះត្រូវបានបញ្ចប់ ហើយយើងនឹងនៅឯស្ថានសួគ៌ជាមួយព្រះដែលជាអ្នកបង្កើតយើង។


5

ប៉ុន្តែនៅពេលដែលយើងមើលជុំវិញ ពិភពលោកយើងនេះ យើងឃើញថា មនុស្សជាច្រើន-មនុស្សច្រើនបំផុត ជា ប្រាកដ-មិនថ្វាយបង្គំព្រះនៅថ្ងៃទីប្រាំពីរទេ។


6

អ្នកខ្លះទៀត មិនទាំងថ្វាយបង្គំព្រះនៃ ព្រះគម្ពីរយ៉ាងពិតប្រាកដផង ហើយបែរជាទៅថ្វាយបង្គំព្រះដទៃទៅវិញ។



7

ប៉ុន្តែអ្នកដែលថ្វាយបង្គំព្រះនៃព្រះគម្ពីរ ភាគច្រើននៃអ្នកទាំងនោះ ថ្វាយបង្គំនៅថ្ងៃមួយផ្សេងពីថ្ងៃដែល ព្រះបានញែកចេញជា បរិសុទ្ធទៅវិញ។

ហេតុអ្វីបានជាយ៉ាងដូច្នេះ?

តើព្រះបានប្តូរថ្ងៃនោះឬទេ?

តើមានអ្នកណាផ្សេងបានផ្លាស់ប្តូរវាឬទេ?

តើហេតុអ្វីបានជាមានមនុស្សជាច្រើន បានរក្សាថ្ងៃផ្សេងទៀត ដូចជាថ្ងៃអាទិត្យ ជាដើមនោះថាជាថ្ងៃរបស់ព្រះ ជាជាងថ្ងៃ ទីប្រាំពីរទៅវិញ?


8

យើងបានរៀនរួចមកហើយថា ព្រះ គម្ពីរប្រាប់យើងថា នៅក្នុងបញ្ញត្តិរបស់ទ្រង់ព្រះបានប្រទានដល់យើង ទាំងអស់គ្នានៅ លើពិភពលោកនេះ នូវសញ្ញាមួយ-សញ្ញា ដ៏ពិសេសៈ


9

(ព្រះគម្ពីរ អេសេគាល ២០:១២,២០)

"អញក៏តាំងថ្ងៃឈប់សំរាករបស់អញឱ្យគេដែរ ទុកសំរាប់ជាទីសំគាល់ដល់អញហើយនិងគេ

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


10

ប្រយោជន៍ឱ្យគេបានដឹងថា អញជាព្រះ យេហូវ៉ាដែលញែកគេចេញជាបរិសុទ្ធ...”


11

ចូរញែកថ្ងៃឈប់សំរាករបស់អញចេញជា បរិសុទ្ធ នោះនឹងបានជាទីសំគាល់ដល់អញ ហើយនិងឯងរាល់គ្នា


12

ដើម្បីឱ្យបានដឹងថា អញនេះគឺយេហូវ៉ា ជា ព្រះនៃឯងរាល់គ្នា” អេសេគាល ២០:១២,២០



13

(វីដេអូ ៨វិនាទី) តាំងពីដើមដល់ចប់ ព្រះ គម្ពីរបានបញ្ជាក់អំពីហេតុការណ៍ថា ព្រះ បានបង្កើតថ្ងៃបរិសុទ្ធ ហើយថ្ងៃបរិសុទ្ធនោះ គឺជាថ្ងៃទីប្រាំពីរនៃសប្តាហ៍។

ហើយគ្មានកន្លែងណានៅក្នុងព្រះគម្ពីរ ដែលព្រះបានប្រាប់ថា ទ្រង់បានផ្លាស់ប្តូរថ្ងៃ បរិសុទ្ធឬថ្ងៃឈប់សម្រាកនោះឡើយ-សញ្ញា នេះគឺជាសញ្ញារវាងព្រះអម្ចាស់ផ្ទាល់និងរាស្ត្ររបស់ទ្រង់។



14

(វីដេអូ ១០វិនាទី) សូមយើងរំលឹកឡើង វិញបន្តិចអំពី អ្វីដែលយើងបានរកឃើញ អំពីដំណឹងនេះ ដោយកាសិក្សាព្រះបន្ទូល របស់ព្រះមួយ។

នៅពេលដែលព្រះបញ្ចប់ការបង្កើតភព ផែនដីនេះ និងមនុស្សទ្រង់បានបង្កើតថ្ងៃ បរិសុទ្ធ


15

ជាការរំលឹកដល់ការបង្កបង្កើតរបស់ទ្រង់នៅ ថ្ងៃទីប្រាំពីរនៃសប្តាហ៍ទីមួយ ហើយរៀង រហូតនៃប្រវត្តិសាស្ត្រផែនដី។


16

នៅពេលដែលព្រះបានសរសេរបញ្ញត្តិ របស់ទ្រង់នៅលើភ្នំស៊ីណាយ ទ្រង់បានដាក់ ថ្ងៃបរិសុទ្ធជាបេះដូងនៃបញ្ញត្តិទាំងអស់។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត



17

(វីដេអូ ៥វិនាទី) បញ្ញត្តិនេះមានរឿងរហូត ដើម្បីរំលឹកដល់មនុស្សថា គេមិនមែនកើត មានឡើង ដោយឯងៗនោះឡើយ។


18

មូលហេតុដែលទ្រង់បានប្រទានមកនោះ គឺដើម្បីឱ្យមនុស្សរក្សាថ្ងៃទីប្រាំពីរ ជាថ្ងៃរំ លឹកថា ទ្រង់បានបង្កើតផែនដីក្នុងរវាង ប្រាំមួយថ្ងៃ។


19

ហើយឈប់សម្រាកនៅថ្ងៃទី៧។

ទាក់ទងទៅនឹងបញ្ញត្តិរបស់ទ្រង់ តាម រយៈលោកម៉ូសេ ព្រះបានប្រាប់ប្រជារាស្ត្រ ថា ពួកគេមិនត្រូវដកចេញ ឬបន្ថែមទៅ លើបញ្ញត្តិទាំងនោះឡើយ។


20

(ព្រះគម្ពីរ ចោទិយកថា ៤:២)

"មិនត្រូវឱ្យឯងរាល់គ្នាបន្ថែម ឬបញ្ចូល អ្វីៗក្នុងសេចក្តីទាំងប៉ុន្មាន ដែលអញបង្គាប់ ដល់ឯង ឬកាត់ចោលអ្វីណាមួយឡើយ


21

ដើម្បីឱ្យឯងរាល់គ្នាបានកាន់តាមអស់ទាំង បញ្ញត្តិផងព្រះយេហូវ៉ា ជាព្រះនៃឯង ដែលអញបង្គាប់មកនេះ"

ព្រះអម្ចាស់បានប្រាប់គេផងដែរ នៅ ក្នុងគម្ពីរចោទិយកថា៤:២


22

(ព្រះគម្ពីរ ទំនុកដំកើង ៨៩:៣៤)

"អញនឹងមិនក្បត់សេចក្តីសញ្ញារបស់ អញ ឬបំផ្លាស់បំប្រែសេចក្តីដែលបានចេញ ពីបបូរមាត់អញឡើយ"

ទំនុកដំកើង ៩:៣៤


23

ព្រះយេស៊ូវផ្ទាល់ព្រះអង្គបានបង្ហាញការ កំណត់ដដែលនេះ ដើម្បីលើកដំកើងច្បាប់ ដែលទ្រង់បានប្រទាននៅលើភ្នំស៊ីណាយ។

ទ្រង់បានប្រាប់ដល់មនុស្សនៅក្នុងសេចក្តី អធិប្បាយនៅលើភ្នំថា ទ្រង់យាងមកមិន មែនដើម្បីដកយកបញ្ញត្តិ របស់ព្រះចេញទេ ប៉ុន្តែទ្រង់យាងមកដើម្បីធ្វើឱ្យបានសម្រេច វិញ!

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


24

(ព្រះគម្ពីរ ម៉ាថាយ ៥:១៧-១៩)

សូមកត់សំគាល់ព្រះបន្ទូលរបស់ទ្រង់ "កុំឱ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យ វិន័យ ឬទំនាយពួកហោរាចោលឡើយ។ ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹង ធ្វើឱ្យសម្រេចវិញ


25

ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹង គ្មានចាំងឈើ ឬក្បៀស១ នៅក្នុងក្រិត្យ វិន័យត្រូវបាត់ឡើយ ដរាបដល់កាលណាផ្ទៃ មេឃនិងផែនដីបានកន្លងបាត់ទៅ


26

គឺទាល់តែសេចក្ដីទាំងអស់បានសម្រេច ដោយសព្វគ្រប់


27

ដូច្នេះអ្នកណាដែលនឹងរំលងបទណា មួយ សូម្បីយ៉ាងតូចបំផុត ក្នុងបញ្ញត្តិទាំង នេះ ហើយបង្រៀនមនុស្សឱ្យធ្វើដូច្នោះដែរ


28

នោះនឹងត្រូវហៅជាអ្នកតូចបំផុតក្នុងនគរស្ថានសួគ៌..."

ម៉ាថាយ ៥:១៧-១៩

នៅពេលដែលព្រះប្រទានបញ្ញត្តិដប់ប្រ ការដល់រាស្ត្ររបស់ទ្រង់ ទ្រង់ថែមទាំងបាន បញ្ជាក់យ៉ាងច្បាស់ថា គ្មានមនុស្សណាអាច ធ្វើឡើងវិញ ឬផ្លាស់ប្ដូរនូវការបង្រៀនដែល ចេញពីព្រះឱស្ឋទ្រង់បានឡើយ។


29

ព្រះយេស៊ូវផ្ទាល់ ទ្រង់បានបង្ហាញ ដោយឧទាហរណ៍ថា ទ្រង់បានចង់ផ្ដល់កិត្តិ យសដល់ថ្ងៃដែលទ្រង់ និងព្រះវរបិតាបាន បង្កើតជាបរិសុទ្ធ នៅសប្ដាហ៍ទីមួយនៃប្រវត្តិ សាស្ត្រពិភពលោកនេះ។


30

(ព្រះគម្ពីរ លូកា ៤:១៦)

"រួចទ្រង់ក៏យាងមកដល់ណាសារ៉ែត ជា ស្រុកដែលទ្រង់គង់នៅពីកុមារ ក៏ចូលទៅ ក្នុងសាលាប្រជុំ

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


31

តាមទម្លាប់ទ្រង់ដើម្បីអានមើលគម្ពីរ
លូកា ៤:១៦


32

នៅពេលដែលមេដឹកនាំសាសនាបាន ចោទប្រកាន់ សិស្សព្រះយេស៊ូវអំពីការប្រព្រឹត្តិល្មើសនឹងថ្ងៃបរិសុទ្ធ ព្រះយេស៊ូវបាន មានព្រះបន្ទូលថា ទ្រង់ជាព្រះអម្ចាស់នៃថ្ងៃ នោះ។


33

(ព្រះគម្ពីរ ម៉ាកុស ២:២៧,២៨)
"ថ្ងៃឈប់សំរាក បានតាំងសម្រាប់ឱ្យ មនុស្ស មិនមែនជាមនុស្សសម្រាប់ថ្ងៃឈប់ សំរាកទេ


34

ដូច្នេះកូនមនុស្សជាម្ចាស់នៃថ្ងៃឈប់សំរាក"
ម៉ាកុស ២:២៧,២៨


35

ព្រះយេស៊ូវមិនគ្រាន់តែលើកដំកើងថ្ងៃ បរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានសុំឱ្យពួក សាវករបស់ទ្រង់អធិស្ឋានដើម្បីឱ្យគេបាន រក្សាថ្ងៃបរិសុទ្ធនោះរៀងរៀបដរាបតទៅ អនាគត។


36

(ព្រះគម្ពីរ ម៉ាថាយ ២៤:២០)
យើងរកឃើញសំណូមពរនេះនៅក្នុង គម្ពីរម៉ាថាយ ២៤:២០ "ចូរអធិស្ឋានសូមកុំឱ្យត្រូវរត់នៅរដូវរងា ឬនៅថ្ងៃឈប់សំរាក ឡើយ"


37

ទីនេះព្រះយេស៊ូវបានមានព្រះបន្ទូលអំពី ការភៀសខ្លួនចេញពីទីក្រុងយេរូសាឡិម ដោយសិស្សរបស់ទ្រង់នៅមុន


38

ការហិនវិនាសនោះ នៅគ្រិស្តសករាជទី ៧០ ដោយពួករ៉ូម

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


39

នៅពេលដែលទ្រង់ជាប់ឆ្កាង ទ្រង់បាន រំពឹងថា គេនឹងបន្តលើកដំកើងថ្ងៃនោះ។


40

ពួកយូដា អ៊័រតូដុក បានថ្វាយបង្គំនៅថ្ងៃ ទីប្រាំពីរ តាំងពីការភៀសខ្លួនជាង៣៥០០ ឆ្នាំមុន។
កន្លែងណាដែលពួកគេរស់នៅ លើ ពិភពលោកនេះ គេនៅតែទទួលស្គាល់ថ្ងៃ
សៅរ៍ជាថ្ងៃទីប្រាំពីរនៃសប្តាហ៍ ជាថ្ងៃដែល ព្រះបានញែកចេញសម្រាប់ថ្វាយបង្គំ។


41

ទោះបីជាព្រះគម្ពីរជាប្រភពតែមួយគត់ របស់យើងក៏ដោយ ក៏យើងនៅតែអាច កំណត់ថា
ថ្ងៃណាជាថ្ងៃទីប្រាំពីរ ឬជាថ្ងៃ បរិសុទ្ធបានដែរ។
នៅពេលណាដែលយើងបើកទៅបញ្ជី នៃការជាប់ឆ្កាង ព្រះគម្ពីរលូកាសង្ខេបអំពី
ព្រឹត្តិការណ៍នាចុងសប្តាហ៍នោះ។
បន្ទាប់ពីព្រះគ្រីស្ទសុគតនៅលើឈើឆ្កាង នៅថ្ងៃសុក្រ ព្រះគម្ពីរបានពណ៌នាថា:


42

(ព្រះគម្ពីរ លូកា ២៣:៥៤-៥៦ , ២៤:១)
"ថ្ងៃនោះជាថ្ងៃរៀបចំ ហៀបនឹងចូលថ្ងៃ
ឈប់សំរាកហើយ"


43

លុះដល់ថ្ងៃទី១ ក្នុងអាទិត្យនោះ កាល ភ្លឺស្រាង១ នោះគេយកគ្រឿងក្រអូបដែល រៀបចំនោះ


44

រួចគេវិលទៅវិញ រៀបគ្រឿងក្រអូប និងប្រេងអប់ តែគេឈប់នៅថ្ងៃឈប់សំរាក តាមបញ្ញត្តិសិន


45

លុះដល់ថ្ងៃទី១ ក្នុងអាទិត្យនោះ កាល ភ្លឺស្រាង១ នោះគេយកគ្រឿងក្រអូបដែល រៀបចំនោះ

១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


46

នាំគ្នាទៅឯផ្នូរ មានអ្នកខ្លះទៀតទៅជាមួយ ដែរ”

លូកា ២៣:៥៤-៥៦ , ២៤:១


47

ត្រីស្ទានភាគច្រើននៅលើសាកលលោក នេះ ប្រារព្ធធ្វើពិធីបុណ្យមួយហៅថា ថ្ងៃ សុក្រដ៏ល្អ ក្នុងការរំលឹកអំពីការសុគតរបស់ ព្រះគ្រីស្ទ។

គេធ្វើបុណ្យថ្ងៃអាទិត្យនៃការមានព្រះជន្ម រស់ឡើងវិញ ក្នុងការរំលឹកអំពីការមានព្រះជន្មរស់ឡើងវិញ។


48

ព្រះគម្ពីរបានប្រាប់យើងថា ថ្ងៃដែល នៅចន្លោះថ្ងៃទាំងពីរនោះ គឺថ្ងៃបរិសុទ្ធ “យោងទៅតាមព្រះបញ្ញត្តិ”


49

(វីដេអូ ៤វិនាទី) ទោះបីជាលោកលូកា សរសេរពាក្យទាំងនេះ ជាច្រើនឆ្នាំក្រោយ ឈើឆ្កាងក៏ដោយ គាត់នៅតែបានអះអាងថា ថ្ងៃអាទិត្យជា “ថ្ងៃទីមួយនៃសប្តាហ៍”

ហើយនៅតែហៅថ្ងៃសៅរ៍ថាជា “ថ្ងៃ បរិសុទ្ធ”

កំណត់ត្រាព្រះគម្ពីរបានញែកពីគ្នាយ៉ាង ច្បាស់នូវថ្ងៃទាំងពីរនេះ។


50

តាមពិតពួកសាវកនៅតែបន្តថ្វាយបង្គំ និង អធិប្បាយនៅថ្ងៃទីប្រាំពីរជាថ្ងៃបរិសុទ្ធអស់ពេលជាច្រើនឆ្នាំ ក្រោយឈើឆ្កាង។


51

(ព្រះគម្ពីរ កិច្ចការ ១៣:១៤,៤២,៤៤)

ព្រះគម្ពីរនិយាយអំពីលោកប៉ុល និង គូកនរបស់គាត់ នៅពេលដែលពួកគេបានទៅកាន់ទីក្រុងអាន់ទីយ៉ូក

“...ក៏ចូលទៅអង្គុយក្នុងសាលាប្រជុំ នៅថ្ងៃឈប់សំរាក”


52

កិច្ចការ ១៣:១៤ “កាលពួកយូដាបាន ចេញពីសាលាប្រជុំទៅហើយ

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


53

នោះពួកសាសន៍ដទៃ ក៏សូមឱ្យប៉ុល អធិប្បាយតាមសេចក្តីទាំងនោះ នៅថ្ងៃឈប់ សំរាកក្រោយទៀត”


54

“ដល់ថ្ងៃឈប់សំរាកក្រោយ នោះពួក អ្នកក្រុងស្ទើរតែទាំងអស់ក៏មកប្រជុំគ្នា ដើម្បីនឹងស្តាប់ព្រះបន្ទូល”

កិច្ចការ ១៣:៤២,៤៤

វាគឺជាទម្លាប់របស់លោកប៉ុលដែលថ្វាយ បង្គំនៅក្នុងទីបរិសុទ្ធរៀងរាល់ថ្ងៃបរិសុទ្ធ:


55

(ព្រះគម្ពីរ កិច្ចការ ១៨:៤)

“គាត់ក៏អធិប្បាយនៅក្នុងសាលាប្រជុំ រាល់តែថ្ងៃឈប់សំរាក ព្រមទាំងបញ្ចុះ បញ្ចូលពួកសាសន៍យូដា និងសាសន៍ក្រេក ឱ្យជឿផង” កិច្ចការ ១៨:៤

តាំងពីព្រឹត្តិការណ៍នៃព្រះគម្ពីរមក គ្មាន អ្នកណាម្នាក់រកឃើញដោយងាយនោះទេ ថាមានភ័ស្តុតាងដែលបញ្ជាក់ថា ព្រះ យេស៊ូវឬសាវករបស់ទ្រង់ បានផ្លាស់ប្តូរថ្ងៃ ថ្វាយបង្គំនោះឡើយ។

គ្មានកំណត់ត្រានៅក្នុងព្រះគម្ពីរណា ដែលបង្គាប់ឱ្យមានការផ្លាស់ប្តូរដូច្នេះឡើយ!


56

គ្មានអ្នកសរសេរព្រះគម្ពីរសញ្ញាថ្មីណា មួយបាន ប្រាប់អំពីការផ្លាស់ប្តូរថ្ងៃបរិសុទ្ធ នេះឡើយ!

ព្រះគម្ពីរសញ្ញាថ្មី មិនបានបន្ថែមការ ផ្លាស់ប្តូរដ៏សំខាន់នេះ នៅកន្លែងណាមួយ ឡើយ។


57

(ព្រះគម្ពីរ ទំនុកដំកើង ៨៩:៣៤)

ព្រះបានមានព្រះបន្ទូលថា “អញនឹង មិនក្បត់សេចក្តីសញ្ញារបស់អញ ឬបំផ្លាស់ បំប្រែសេចក្តីដែលបានចេញ ពីបបូរមាត់ អញឡើយ

ទំនុកដំកើង ៨៩:៣៤

ព្រះមិនបានផ្លាស់ប្តូរច្បាប់របស់ទ្រង់ ឡើយ ហើយក៏គ្មានអ្នកណាមានសិទ្ធិនឹងកែ ប្រែបញ្ញត្តិរបស់ព្រះដែរ!

អ្នកប្រាជ្ញមកពីក្រុម អ្នកកាន់ថ្ងៃអាទិត្យ ផ្សេងៗបានទទួលស្គាល់ការនេះ


58

មានម្តងសង្ឃកាតូលិកដ៏សំខាន់មួយអង្គ ព្រះនាម ហ្គេមគីបូន បានសរសេរថា: “អ្នកអាចអានព្រះគម្ពីរតាំងពីលោកុប្បត្តិដល់ វិវរណៈ ហើយអ្នកនឹងមិនអាចរកឃើញ ប្រយោគណាមួយដែល អាចផ្តល់អំណាច ឱ្យញែកថ្ងៃអាទិត្យជាថ្ងៃបរិសុទ្ធឡើយ។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


59

ព្រះគម្ពីរបង្គាប់ឱ្យការប្រតិបត្តិរបស់ សាសនាធ្វើឡើងនៅថ្ងៃសៅរ៍”
សេចក្ដីជំនឿនៃព្រះវរបិតារបស់យើង ទំព័រ ១១១,១១២។


60

លោកគ្រូមេតូឌីសម្នាក់ឈ្មោះ កូស្ស៊ីស៍ ឆាមផែល បានចង្អុលបង្ហាញដូចគ្នានេះ
នៅពេលដែលគាត់និយាយ
“ហេតុផលដែលយើងប្រតិបត្តិថ្ងៃទីមួយ ជំនួសថ្ងៃទីប្រាំពីរ គ្មានការបង្គាប់បញ្ញាជា
មូលដ្ឋានវិជ្ជមានណាមួយ នោះទេ!


61

អ្នកនឹងស្រាវជ្រាវព្រះគម្ពីរជាការឥតប្រ យោជន៍ ដើម្បីរកអំណាចនៃការផ្លាស់ប្តូរពី ថ្ងៃទីប្រាំពីរ
ទៅថ្ងៃទីមួយវិញ”
ច្បាប់ដប់យ៉ាងដើម្បីរស់នៅ ទំព័រ៦១។


62

កំណត់ត្រាណាក្នុងព្រះគម្ពីរដែលថា ព្រះគ្រីស្ទឬសាវករបស់ទ្រង់ គោរពថ្ងៃដទៃ
ឬបង្រៀនគេឱ្យធ្វើដូច្នោះដែរនោះឡើយ!
“ចុះតើការគោរពថ្ងៃអាទិត្យចាប់ផ្ដើមឡើង យ៉ាងណា?”
អ្នកអាចសួរដូច្នេះ។


63

យើងរៀនពីសូក្រាត ស្កូឡាស្ទីកឹស ប្រវត្តិ វិទូនាសតវត្សរ៍ទីប្រាំ:
“សឹងតែគ្រប់ព្រះវិហារទូទាំងពិភព លោកប្រារព្ធធ្វើពិធីអាថ៌កំបាំងដ៏ពិសិដ្ឋរបស់ ព្រះ
“បុណ្យលៀងព្រះអម្ចាស់” នៅថ្ងៃ បរិសុទ្ធរៀងរាល់សប្ដាហ៍


64

ប៉ុន្តែគ្រីស្ទាននៃអាឡិចសង់ដ្រា និងរ៉ូម ដោយសារប្រពៃណីបុរាណបានឈប់ធ្វើការ ខាងលើនេះ”
ប្រវត្តិសាស្ត្រនៃសាស្តាដែលដកស្រង់ ដោយ ស៊ីប៊ី ហាយណេស ថ្ងៃបរិសុទ្ធទៅ ថ្ងៃអាទិត្យ
ទំព័រ៣៥។


65

ប្រវត្តិវិទូជាច្រើនទៀតបានកត់ត្រាថា ក្រុមជំនុំជាច្រើនប្រតិបត្តិថ្ងៃបរិសុទ្ធទីប្រាំពីរ នៅមជ្ឈិមសម័យ
ហើយការអនុវត្តន៍បានល្អ ដោយបានចងក្រងជាឯកសារក្នុងសម័យថ្មី
ដោយគ្រីស្ទានជុំវិញពិភពលោក។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


66

អ្នកប្រវត្តិវិទូគ្រីស្ទសាសនាជាច្រើន បានឱ្យដឹងថា ថ្ងៃបរិសុទ្ធចាប់ផ្តើមផ្លាស់ប្តូរ បន្តិចម្តងៗ នៅម្តុំឆ្នាំ៧០ និង ១៣៥ នៃគ្រិស្តសករាជ ជាសម័យនៃការបះបោរ ពីរដ៏ជូរចត់ និងបង្ហូរឈាម ដោយពួក យូដា ដែលត្រូវបានកំទេចដោយចក្រភពរ៉ូម។


67

អរិយភាពរបស់ពួកយូដាប្រឆាំងនឹងពួក រ៉ូម កាន់តែរីកធំឡើងៗ រួមបញ្ចូលទាំងទំនាស់រវាងពួកយូដា ជាមួយនឹងពួក គ្រីស្ទានផង បង្កើតឱ្យមានសំណេរនៃការប្រឆាំងជាមួយនឹងពួកយូដាឡើង ដែល បណ្តាលឱ្យគុំកួននិងការប្រឆាំងនឹងពួកយូដានេះបានចាប់ផ្តើមឡើងពាសពេញចក្រភព រ៉ូមទាំងមូល។

ដោយហេតុនោះបានជាពួកគ្រីស្ទានបាន ផ្តាច់ខ្លួនចេញពីពួកយូដាកាន់តែឆ្ងាយទៅៗ។ ដោយការគោរពថ្ងៃបរិសុទ្ធ ជាសញ្ញាមួយ បញ្ជាក់ថា ពួកគេនៅជាមួយពួកយូដា ពួកគ្រីស្ទានជាច្រើនក៏ចាប់ ផ្តើមបន្ថយ កាតព្វកិច្ចរបស់គេចំពោះថ្ងៃបរិសុទ្ធ។


68

"ការដាក់ស្នើដ៏ធំមួយថា ការគោរពថ្ងៃ អាទិត្យ ត្រូវបាននាំមកនៅពេលនោះ ក្នុងការភ្ជាប់ទៅនឹងបុណ្យព្រះ គ្រីស្ទមានព្រះ ជន្មរស់ឡើងវិញនៅថ្ងៃអាទិត្យ។


69

ជាការប៉ុនប៉ងបញ្ជាក់ឱ្យអ្នកកាន់អំណាចរ៉ូមដឹងច្បាស់ថា ពួកគ្រីស្ទានបានបែងចែកដាច់ស្រឡះពីពួកយូដា"

ថ្ងៃបរិសុទ្ធទៅថ្ងៃអាទិត្យទំព័រ២៣៧


70

ដោយមានរឿងនេះនៅក្នុងគំនិត វាជា ការងាយនឹងឃើញរបៀបគ្រីស្ទានរស់នៅក្នុងរាជធានីរបស់ចក្រភពរ៉ូម បានដឹកនាំផ្លូវ របស់ខ្លួន ទៅក្នុងការផ្តាច់ទំនាក់ទំនងពីការគោរពថ្ងៃបរិសុទ្ធ។

ពួកគេបានរស់នៅកណ្តាលកន្លែងនៃការ បង្ក្រាបយ៉ាងធំបំផុត!



71

(វីដេអូ ៧វិនាទី) វាជាការដែលអាចឱ្យយល់បានយ៉ាងពិសេស ថា ពួកគេអាចផ្ញើលចេញពីការគោរពថ្ងៃបរិសុទ្ធ ដែលត្រូវបានមើលងាយដោយពួក រ៉ូម ក្នុងគំនិតថា ក្រុមជំនុំ គ្រីស្តសាសនា នៅទីក្រុងរ៉ូម ភាគច្រើនលើសលប់ជាពួក ក្រៅសាសន៍ ហើយដែលបានប្តូរជំនឿមក ពីពួកកាន់សាសនាដទៃ។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


72

(ព្រះគម្ពីរ រ៉ូម ១១:១៣)
វាជាការសំខាន់ណាស់ក្នុងការកត់សំគាល់
នូវការដែលលោកប៉ុលបានបញ្ជាក់ទៅ
កាន់ក្រុមជំនុំនៅទីក្រុងរ៉ូម "ខ្ញុំនិយាយ នឹងអ្នករាល់គ្នាដែលជាសាសន៍ដទៃ..."
រ៉ូម ១:១៣។


73

គ្រីស្ទានទាំងអស់នេះបានក្លាយមកពីពួក អ្នកដែលមិនជឿ ដែលមិនមែនបានត្រូវ
បង្កើតឡើងពីអ្នកគោរពថ្ងៃបរិសុទ្ធត្រឹម ត្រូវ ដូចពួកគ្រីស្ទានយូដា ដែលបានអនុវត្ត
ថ្ងៃបរិសុទ្ធជាប្រចាំមកហើយនោះទេ។


74

ប៉ុន្តែតើហេតុអ្វីបានជាថ្ងៃអាទិត្យបានត្រូវ គេជ្រើសរើសច្រើនជាងថ្ងៃដទៃទៀត?
នោះគឺជាសំនួរមួយដ៏ល្អ!
អ្នកមិនជឿនៅទីក្រុង រ៉ូមជាអ្នកថ្វាយ បង្គំព្រះអាទិត្យ ជាច្រើនឆ្នាំមកហើយ គេ
បានធ្វើបុណ្យនៅថ្ងៃអាទិត្យ ជាថ្ងៃនៃព្រះ អាទិត្យ។


75

ព្រះចៅអធិរាជរ៉ូម បានបង្ហាញអង្គទ្រង់ ថា ជាព្រះនៃព្រះអាទិត្យ បានបោះត្រា
សញ្ញាព្រះអាទិត្យនៅលើ កាក់របស់ព្រះអង្គ និងអាគារនានា ព្រមទាំងទាមទារឱ្យរបស់
ទាំងនោះថ្វាយបង្គំដល់ទ្រង់ថែមទៀតផង។
អ្នកប្រវត្តិសាស្ត្រគ្រីស្ទសាសនាខ្លះជឿថា ក្រុមជំនុំនៅសម័យនោះ បានឃើញអត្ថ
ប្រយោជន៍ក្នុងការសម្រប សម្រួលជាមួយ នឹងអ្នកកាន់សាសនាដទៃ។
ដោយគេនៅតែអាចរក្សាទំនៀមទម្លាប់ ចាស់ខ្លះរបស់ពួកគេបាន អ្នកកាន់សាសនាដ ទៃទាំងនោះ
ក៏បានត្រឡប់ ជាអ្នកជឿលើ គ្រីស្ទសាសនា ដោយមានអារម្មណ៍ដូច
កាលដែលគេនៅក្នុងសាសនាដើមរបស់គេ ដដែលដែរ។ វាក៏មានប្រយោជន៍ផងដែរ
ដល់ប្រទេសជាតិក្នុងការរួបរួមប្រជារាស្ត្រទាំងឡាយទៅក្នុងសាសនាដ៏ធំតែមួយ។


76

អស់ជាច្រើនសតវត្សរ៍  គេមិនបាន ប្រារព្ធថ្ងៃអាទិត្យ ជាថ្ងៃបរិសុទ្ធទេ
ប៉ុន្តែជាថ្ងៃឈប់សម្រាកវិញ។
បន្ទាប់មកថ្ងៃទាំងពីរនោះក៏ត្រូវបានគេគោ
រពជាថ្ងៃបរិសុទ្ធ។


77

យើងអាននូវសៀវភៅ អាផូស្តូលិក ខុនស៊ីធូសឺននេះ នៅទំព័រ២៣។
"មិនមែនតែពួកគ្រីស្ទានទេ ដែលបាន ធ្វេសប្រហែស និងបានសម្របសម្រួល
សេចក្តីជំនឿរបស់គេបន្តិចម្តងៗ"។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


78

ភាពបរិសុទ្ធរបស់ពួកជំនុំអាផូស្តូលិក បានឈរនៅយ៉ាងរឹងមាំនិងបរិសុទ្ធ
ប៉ុន្តែនៅពេលដែលគ្រីស្ទានជំនាន់ទី២ និងទី៣បានមកដល់


79

យើងឃើញភ័ស្តុតាងនៃការសម្រុះសម្រួលនិង
ការបោះបង់ជំនឿ"


80

ការរអិលចូលទៅក្នុងការសម្រុះសម្រួល នេះ ត្រូវបានកើតឡើងដោយសារការបង្ខំឱ្យ
អនុវត្តច្បាប់ថ្ងៃអាទិត្យមួយ ដោយព្រះចៅ អធិរាជរ៉ូម កុងស្តង់ទីន នៅថ្ងៃទី៧ខែមិនា គ.ស.៣២១។


81

ពេលដែលព្រះអង្គនៅជាអ្នកជឿលើ
សាសនាដទៃនៅឡើយ និងមុនពេលដែល ទ្រង់បានក្លាយមកជាគ្រីស្ទាន ទ្រង់បានធ្វើ ច្បាប់នេះ:
"នៅថ្ងៃសក្ការៈដល់ព្រះអាទិត្យ សូមឱ្យរាជវង្សានុវង្ស និងប្រជានុរាស្ត្រ នៅក្នុង ទីក្រុងសម្រាក
ហើយត្រូវឱ្យហាង ទំនិញ ទាំងឡាយបិទទ្វារ


82

នៅតាមជនបទ ទោះជាអ្នកណាក៏ដោយ មនុស្សដែលកំពុងជាប់រវល់នឹងកសិកម្មអាច មានសេរីភាព
នឹងបន្តសកម្មភាពរបស់ គេបាន"
ប្រវត្តិសាស្ត្ររបស់ក្រុមជំនុំគ្រីស្ទាន បោះពុម្ពនៅឆ្នាំ១៩០២ វ៉ុលទី៣ ទំព័រ ៣៨០


83

ជំហ៊ានបន្ទាប់ក្នុងការធ្វើឱ្យការគោរព ថ្ងៃអាទិត្យនៅក្នុងចំណោមគ្រីស្ទានទាំងមូល
កើតឡើងដោយក្រុមជំនុំនៃទីក្រុងរ៉ូម ក្នុង ក្រុមប្រឹក្សាឡៅឌីសេ។
ក្រុមប្រឹក្សានេះបានបង្កើតច្បាប់មួយទាក់ ទងទៅនឹងការគោរពថ្ងៃអាទិត្យ។


84

"នៅឆ្នាំ៣២៥ បូជាចារ្យស៊ីលវេស្ទើរ នៃទីក្រុងរ៉ូមបានផ្លាស់ប្តូរឈ្មោះថ្ងៃទីមួយនៃ សប្តាហ៍ទៅជា
"ថ្ងៃនៃព្រះអម្ចាស់វិញ"
ប្រវត្តិសាស្ត្រសាស្នា ទំព័រ៧៣៩។
នាក្រុមប្រឹក្សាមួយទៀតរបស់ឡៅឌីសេ បានប្រជុំនៅឆ្នាំ៣៦៤ បានបង្កើតច្បាប់ដូច ខាងក្រោមនេះ

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


85

"គ្រីស្ទានមិនត្រូវអនុវត្តតាមពួកយូដា( ដោយ
គោរពថ្ងៃបរិសុទ្ធ) និងឈប់សំរាក នៅថ្ងៃ សៅរ៍នោះទេ...ប៉ុន្តែត្រូវធ្វើការនៅថ្ងៃនោះ វិញ


86

ប៉ុន្តែក្នុងនាមជាគ្រីស្ទាន ត្រូវតែលើកដំកើង ដល់ថ្ងៃនៃព្រះអម្ចាស់ជាពិសេសវិញ ហើយ
បើអាចធ្វើបាន


87

មិនត្រូវធ្វើការនៅថ្ងៃនោះឡើយ"
ប្រវត្តិសាស្ត្រនៃក្រុមប្រឹក្សានៃពួកជំនុំ វ៉ុលទី២ ទំព័រ ៣១៦


88

ថ្វីបើដូច្នោះក៏ដោយ គ្រីស្ទាននៅតែ គោរពថ្ងៃ បរិសុទ្ធដដែលនៅក្នុងសតវត្សរ៍ ទីប្រាំមួយ
ដូចសម្តេចប៉ាបគ្រីហ្គ័របានប្រ កាសមិនយល់ព្រមជាឧឡារិកថា


89

"អ្នកណាដែលនៅតែរក្សាការឈប់សំ រាកនៅថ្ងៃបរិសុទ្ធ នោះគឺជារហោរាដែល
ប្រឆាំងនឹងព្រះគ្រីស្ទ។
ច្បាប់ថ្ងៃអាទិត្យដែលបានដកស្រង់នៅ ស៊ីប៊ី ហាយណេស ពីថ្ងៃបរិសុទ្ធទៅថ្ងៃ អាទិត្យទំព័រ ៤៣។



90

(វីដេអូ ៧វិនាទី) សូមជ្រាបថា មនុស្ស គ្រប់គ្នា មិនអាចរកព្រះគម្ពីរបាន ដូច សម័យសព្វថ្ងៃនេះទេ។
គោលលទ្ធិត្រូវបាន ប្រាប់បន្តគ្នាផ្ទាល់មាត់ រហូតដល់មនុស្ស ធម្មតាមិនអាចដឹងបាន
អំពីការខុសគ្នារវាង បទព្រះគម្ពីរនិងប្រពៃណីឡើយ។


91

ជាច្រើនសតវត្សរ៍បានកន្លងផុតទៅ មុន
ពេលដែលមនុស្សជាច្រើនបានដឹងយ៉ាងច្បាស់លាស់អំពីសេចក្តីពិត ដូចដែលបាន
បង្រៀនដោយព្រះយេស៊ូវ និងពួកសាវក របស់ទ្រង់។


92

ហើយការកែប្រែឡើងវិញរបស់ពួកប្រូតេស្តង់
បានមកដល់ មនុស្សមួយចំនួនចាប់ផ្តើមចោទ
សួរអំពីចារិត និងប្រពៃណីជាច្រើន ដែល ត្រូវបានគេយកមកជំនួសការបង្រៀនរបស់ ព្រះបន្ទូល។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត



93

ការអំពាវនាវរបស់ការកែទម្រង់ គឺ "ព្រះគម្ពីរ ហើយព្រះគម្ពីរតែមួយគត់ ដែលជាសេចក្ដីជំនឿរបស់យើង"



94

មនុស្សជាច្រើនដូចជា ហាស និងហ្សេរ៉ូ ជាដើមបានចំណាយពេល ដើម្បីសេចក្ដីស្មោះត្រង់របស់ពួកគេ ចំពោះព្រះគម្ពីរ ដោយត្រូវបានគេដុតភ្ជាប់នឹងបង្គោលសរសេរ!



95

ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពី សតវត្សរ៍ទីប្រាំមួយមក សេចក្ដីពិតនៃថ្ងៃបរិសុទ្ធសឹងតែបានបាត់បង់ បានលាក់នៅ ក្រោមសតវត្សរ៍នៃប្រពៃណី។ មនុស្សសុចរិតបានសិក្សាយ៉ាងដិតដល់ ដើម្បីស្វែងរកនូវការដែលបទគម្ពីរបាន បង្រៀន។ មានមនុស្សជាច្រើនបានទទួល នូវអ្វីៗដែលគេបានចែកចាយតៗគ្នាពីជំនាន់ មួយទៅជំនាន់មួយទៀត ដោយមិនដែល បានសួរថា តើវាពិតឬប្រឌិតនោះឡើយ។



96

ជួនកាលមនុស្សទទួលយកនូវរឿងរ៉ាវ ផ្សេងៗដោយមិនបានពិចារណា។
ជាច្រើនសតវត្សរ៍មកហើយ មនុស្សបាន ជឿថា ផែនដីជាមជ្ឈមណ្ឌលនៃចក្រវាល។ ពួកគេបានជឿថា ព្រះអាទិត្យនិងភពឯទៀត ទៀតទាំងអស់វិលជុំវិញផែនដី។
ជាការពិតណាស់ ដោយគំនិតដ៏ទូលំ ទូលាយរបស់គាត់ លោក កូពែរនីគីសបាន បញ្ចេញយោបល់ប្រឆាំងនឹងរឿងបប្រឌិតនេះ គាត់បានប្រកាសថា "ព្រះអាទិត្យ គឺជាមជ្ឈមណ្ឌលនៃពិភពចក្រវាល មិនមែនផែនដីទេ" តើលោកអ្នកដឹងទេ តើអ្នកណាដែលប្រឆាំងនឹងគាត់ខ្លាំងជាងគេ? គឺអ្នកដឹកនាំពួកជំនុំ-អ្នកដឹកនាំសាសនា។ ពួកគេបានស្រែកថា "អ្នកមិនអាចផ្លាស់ ប្ដូរវិថីគោចររបស់ភពទាំងឡាយដែលព្រះបានបង្កើតនោះទេ" ជាការពិតណាស់ លោកកូពែរនីគីសមិន បានផ្លាស់ប្ដូរវិថីគោចររបស់ភពទាំងឡាយ ដែលព្រះបានបង្កើតនោះមែន គាត់គ្រាន់តែបានវែកមុខឱ្យឃើញច្បាស់ នូវប្រពៃណី ដែលគ្មានមូលដ្ឋានសំអាង ច្បាស់លាស់ ដែលគេបានជឿតៗគ្នាជា ច្រើនតំណមកហើយនោះ។ គាត់មិនបាន ផ្លាស់ប្ដូរវិថីគោចរនៃ ចក្រវាលនេះឡើយ។ លោកកូពែរនីគីស បានបង្ហាញការពិត។
ដូច្នេះការដែលជឿទៅលើអ្វីៗដែលកើត មានជាយូរមកហើយនោះ មិនមែនសុទ្ធតែ ជាការពិតទាំងអស់នោះឡើយ។
តើថ្ងៃបរិសុទ្ធ ត្រូវបានផ្លាស់ប្ដូរយ៉ាង ណា? សូមស្ដាប់នូវទស្សនាវដ្ដីខាងក្រោម នេះ ដែលសរសេរដោយអ្នកនិពន្ធ ជាអ្នក កាតូលិក ដែលអ្នកដឹកនាំក្រុមជំនុំរបស់គេ បាននាំទៅកាន់ការផ្លាស់ប្ដូរថ្ងៃបរិសុទ្ធទៅ ថ្ងៃអាទិត្យនេះ។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


97

"ក្រុមជំនុំកាតូលិក មានតាំងពីជាងមួយ ពាន់ឆ្នាំមុនក្រុមជំនុំប្រឆាំង(ប្រូតេស្តង់) បានកើតឡើង ដោយសារអំណាចរបស់ខ្លួន។


98

បានផ្លាស់ប្តូរពីថ្ងៃសៅរ៍ ទៅថ្ងៃអាទិត្យ"
ថ្ងៃបរិសុទ្ធរបស់គ្រីស្ទាន ទំព័រ១៦


99

ពីសំនួរចម្លើយរបស់កាតូលិក យើងមាន


100

សំនួរៈ "តើថ្ងៃណាជាថ្ងៃបរិសុទ្ធ?


101

ចម្លើយៈ ថ្ងៃសៅរ៍ គឺជាថ្ងៃបរិសុទ្ធ


102

សំនួរៈ តើហេតុអ្វីបានជាយើងប្រតិបត្តិ នៅថ្ងៃអាទិត្យជំនួសថ្ងៃសៅរ៍វិញ?


103

ចម្លើយៈ...ពីព្រោះក្រុមជំនុំកាតូលិកបាន ផ្លាស់ប្តូរឧឡារភាពនេះ ពីថ្ងៃសៅរ៍ទៅថ្ងៃ អាទិត្យ"
ការផ្លាស់ប្តូរនេះ ត្រូវបានធ្វើឡើងដោយ ក្រុមប្រឹក្សាឡៅឌីសេក្នុងឆ្នាំ៣៣៦ នៃ គ្រិស្តសករាជ។


104

អ្នកអាចសួរថា តើហេតុអ្វីបានជាក្រុម ជំនុំកាតូលិកយល់ព្រមទទួលស្គាល់ការផ្លាស់ប្តូររបស់ខ្លួននេះ ដោយសុធន្ទៈ និងចំហ យ៉ាងដូច្នេះ? ចម្លើយមួយភាគមាននៅក្នុង ត្រង់ការដែលក្រុមជំនុំកាតូលិកបានផ្តល់ អំណាចទៅប្រពៃណី។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត




105

ចំណុចមួយដែលសំខាន់ក្នុងចំណុចទាំង ឡាយនៃការខុសគ្នារវាងប្រូតេស្តង់ និង កាតូលិកនៅដើមសម័យ នៃការកែទម្រង់ គឺការដាក់អំណាច នៃប្រពៃណីក្នុងសាសនា របស់គេ។

នៅពេលដែលលោកម៉ាធីនលុយធើរ បានប្រកាសថា គាត់ត្រូវដើរតាមព្រះគម្ពីរ តែមួយគត់ នោះគាត់បានប្រឆាំងនឹងវិទ្យា ស្ថាននៃក្រុមជំនុំកាតូលិកទាំងឡាយដែលបានឈរនៅលើមូលដ្ឋាននៃប្រពៃណី តែម្នាក់ ឯងប៉ុណ្ណោះ។


106

តាមពិត ក្រុមប្រឹក្សាត្រេនត៍បានមកប្រ ជុំគ្នា ដើម្បីសម្រេចយ៉ាងត្រឹមត្រូវ អំពី ស្ថានភាពនៃក្រុមជំនុំកាតូលិក ដើម្បីទទួល យកអំណាចរបស់ខ្លួនថា តើត្រូវដាក់អំ ណាចប្រពៃណីនៅលើអំណាចរបស់ព្រះគម្ពីរ ឬក៏ដាក់អំណាចព្រះគម្ពីរលើអំណាចប្រ ពៃណី។

ជាទីបញ្ចប់សំនួរនេះត្រូវបានគេសំរេច ដោយសេចក្តីព្រមព្រៀងមួយ

សូមកត់សំគាល់នូវសេចក្តីសង្ខេបដែល បានផ្តល់ ដែលសង្កថាមួយ ដោយបាន ជម្រុញឱ្យមានសេចក្តីសម្រេចនេះឡើង ហើយដែលបានកត់ត្រាដោយ អេច្ឆ អេច្ឆ ហូលស្ទែន


107

ទីបញ្ចប់នៅការបើកប្រជុំចុងក្រោយ បង្អស់នៅថ្ងៃទីដប់ប្រាំបី ខែមករា ឆ្នាំ ១៥៦២ ការស្ទាក់ស្ទើរទាំងឡាយត្រូវបាន ញែកចេញៈ


108

លោកបូជាចារ្យ រីជីអូ បានថ្លែងសង្កថា មួយនៅក្នុងការប្រកាសបើកថា ប្រពៃណី ត្រូវបានឈរលើបទព្រះគម្ពីរ"

ព្រះគម្ពីរនិងប្រពៃណី ទំព័រ២៦៣។

ព្រះគម្ពីរមិនបានគាំទ្រគំនិតដែលថា ប្រ ពៃណីជាមូលដ្ឋាននៃគោលលទ្ធិនោះទេ។


109

តើលោកអ្នកចាំទេ នូវសំនួរដែលព្រះ យេស៊ូវបានសួរ ដល់អ្នកដឹកនាំសាសនាអំពី ថ្ងៃរបស់ទ្រង់?


110

(ព្រះគម្ពីរ ម៉ាថាយ ១៥:៣,៩)

ទ្រង់បានសួរថា "ឯអ្នករាល់គ្នាវិញ តើហេតុអ្វីបានជាធ្វើខុសនឹងបញ្ញត្តិព្រះ ដោយកាន់តាមទំនៀមទំលាប់បុរាណ របស់ អ្នករាល់គ្នាដូច្នេះដែរ?"

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


111

ហើយទ្រង់បានបន្ថែមថា "គេថ្វាយបង្គំ អញជាឥតប្រយោជន៍ទេ ព្រោះគេបង្រៀន សេចក្តីដែលជាបញ្ញត្តិរបស់មនុស្សវិញ" ម៉ាថាយ ១៥:៣,៩



112

តើលោកអ្នកឃើញសារសំខាន់ឬទេ?

តើលោកអ្នកដើរតាមព្រះគ្រីស្ទនិងព្រះ គម្ពីរ ឬដើរតាមប្រពៃណីរបស់មនុស្ស?

សារសំខាន់មិនស្ថិតនៅលើថ្ងៃណាឬ ចំ នួននៃថ្ងៃនោះទេ

ប៉ុន្តែវាជាសារសំខាន់នៃម្ចាស់

(ចៅហ្វាយ)

នេះគឺជារឿងពិត!

តើព្រះយេស៊ូវជាម្ចាស់របស់អ្នក ឬ មួយក៏ប្រពៃណីរបស់អង្គការផ្សេងៗ?


113

យើងបានសរសើរការងាររបស់អ្នកប្រាជ្ញ និងអ្នកប្រវត្តិសាស្ត្រមួយចំនួនដោយស្មោះ។ ប៉ុន្តែនេះគឺជាប្រយោគទំនើបលើការ ផ្លាស់ប្តូរថ្ងៃបរិសុទ្ធ


114

សូមយើងកត់សំគាល់នូវប្រយោគនេះ "គឺជាក្រុមជំនុំកាតូលិក ដែលបានសម្រេច ថា ថ្ងៃអាទិត្យជាថ្ងៃថ្វាយបង្គំរបស់គ្រីស្ទាន ក្នុងការសរសើរដំកើង ការមានព្រះជន្មរស់ ឡើងវិញ" ការរៀន កៀផិង កាតូលិក និងគោលលទ្ធិគ្រឹះ ១៩៨៨ ទំព័រ៣៨ ។


115

ប្រយោគមួយទៀតដែលនឹងធ្វើឱ្យអ្នក ឈប់និងសញ្ជឹងគិត គឺមកពីសន្តបុគ្គល កាតឺរីន ក្នុងទស្សនាវដ្តី ក្រុមជំនុំកាតូលិក សង់ទីណែល ថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៩៥ បាននិយាយថា

"ប្រហែលជាការដែលមុះមុតបំផុត ការ ផ្លាស់ប្តូរដែលខុសប្លែកពីធម្មតាបំផុត ដែល ក្រុមជំនុំមិនដែលបានធ្វើ បានកើតឡើងនៅ សតវត្សរ៍ទីមួយ នោះគឺការផ្លាស់ប្តូរថ្ងៃ បរិសុទ្ធ។


116

ថ្ងៃបរិសុទ្ធបានត្រូវផ្លាស់ប្តូរពីថ្ងៃសៅរ៍ទៅថ្ងៃ អាទិត្យ...

មិនមែនមកពីទិសដៅណាមួយដែលបាន កត់សំគាល់នៅក្នុងបទព្រះគម្ពីរទេ គឺមក ពីអំណាចរបស់ខ្លួនឯង...


117

មនុស្សដែលគិតថា អំណាចព្រះគម្ពីរ ជាអំណាចតែមួយ បានក្លាយជាអ្នក សេវេនដេយ អាត់វេនទីស្ទ ដ៏ពិតប្រាកដ ហើយគោរពថ្ងៃសៅរ៍ជាថ្ងៃបរិសុទ្ធ"

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


118

នៅក្នុងបទទំនាយនៃគម្ពីរដានីយ៉ែល ព្រះបានបង្ហាញដល់ដានីយ៉ែលថា "ស្នែងតូច" នៅក្នុងដានីយ៉ែល ៧:២១,២៥ ព្រមទាំង



119

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)

"គិតបំផ្លាស់ពេលកំណត់"

បទទំនាយដ៏អស្ចារ្យ!

នេះគឺជាការទស្សនទាយថា អំណាច សាសនានៅផែនដី នឹងប៉ុនប៉ងផ្លាស់ប្តូរ អំណាចរបស់ព្រះ។

មានតែមួយគត់នៅក្នុងក្រិត្យវិន័យទាំង ដប់ដែលនិយាយអំពីពេលវេលា-បញ្ញត្តិ ថ្ងៃបរិសុទ្ធ។


120

ក្រុមជំនុំរ៉ូមបានគិតថាធ្វើដូច្នេះ ប៉ុន្តែ ព្រះនៅតែដដែលសព្វថ្ងៃនេះ ដូចពេលដែលទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី ដែរ ហើយក៏មិនបានផ្លាស់ប្តូរអ្វីដែលទ្រង់បានប្រាប់នៅស្ទួនច្បាប់នៅដែននោះដែរ។

ជាការពិត បទទំនាយអំពាវនាវឱ្យ មនុស្សគ្រប់ទីកន្លែងថ្វាយបង្គំដល់ព្រះអាទិករ ពីព្រោះទ្រង់គឺជាព្រះដែលនឹងជំនុំជំរះ មនុស្សលោក។


121

បទទំនាយនេះ នឹងផ្តល់មកដើម្បីហៅ ដល់អស់អ្នកណាដែលនឹងរៀបចំខ្លួន ចាំជួបព្រះយេស៊ូវនៅពេលដែលទ្រង់យាងមក វិញនៅក្នុងពពកនៃសិរីល្អ។

អ្នកដែលឆ្លើយតប និងបានរៀបចំខ្លួន ត្រូវបានពណ៌នាថាយ៉ាងដូច្នេះ



122

(ព្រះគម្ពីរ វិវរណៈ ១៤:១២)

"នេះហើយជាសេចក្តីអត់ធ្មត់របស់ពួកបរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្តីជំនឿដល់ព្រះយេស៊ូវ"

វិវរណៈ ១៤:១២


123

យើងទាំងអស់គ្នាបានដឹងអស់ហើយ អស់អ្នកដែលមានជំនឿលើព្រះយេស៊ូវ ចេញពីចិត្តនៃសេចក្តីស្រឡាញ់របស់ព្រះ និងកំពុងតែត្រូវបានកាន់តាមបញ្ញត្តិរបស់ ទ្រង់។

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


124

មែនហើយ ព្រះយេស៊ូវ សុំឱ្យយើងនឹកចាំពី ទ្រង់ ជាអ្នកបង្កើតយើង ដោយគោរពថ្ងៃបរិសុទ្ធរបស់ទ្រង់។

នៅពេលដែលមនុស្សគោរពថ្ងៃបរិសុទ្ធ

ដែលមនុស្សបង្កើត គេបានគោរពប្រពៃណី របស់មនុស្សហើយ។

នៅពេលដែលយើងបានស្គាល់

ព្រះហឫទ័យរបស់ព្រះ វាជាអំណររបស់យើង ដើម្បីដើរតាម

ព្រះហឫទ័យនោះ។

ព្រះមានរឿងដើម្បីមានព្រះបន្ទូលមកកាន់យើងអំពីប្រពៃណីរបស់មនុស្ស:

---


125

(ព្រះគម្ពីរ ម៉ាកុស ៧:៦,៧)

"...ជនជាតិនេះគេគោរពប្រតិបត្តិអញ

តែបបូរមាត់ទេ តែចិត្តគេនៅឆ្ងាយពីអញ

ណាស់

---


126

ដែលគេថ្វាយបង្គំអញដោយបង្រៀន បញ្ញត្តិជារបស់មនុស្ស នោះជាឥត

ប្រយោជន៍

ទេ"

ម៉ាកុស ៧:៦,៧

---


127

(ព្រះគម្ពីរ ម៉ាកុស ៧:៨)

ហើយម្តងទៀត "...អ្នករាល់គ្នា លះបង់ចោលបញ្ញត្តិព្រះមែន ដើម្បីនឹង

កាន់តាមសណ្តាប់របស់ខ្លួនវិញ!"

ម៉ាកុស ៧:៨

---


128

(ព្រះគម្ពីរ ម៉ាកុស ៧:៦)

ព្រះយេស៊ូវមានព្រះបន្ទូលថា "ឯចិត្តគេ នៅឆ្ងាយពីអញណាស់"

លោកអ្នកឃើញទេ វាគឺជាសារសំខាន់ នៃចិត្តមួយ សារសំខាន់នៃសេចក្តីស្រឡាញ់ មួយ។

---


129

(ព្រះគម្ពីរ យ៉ូហានទី១ ៥:៣)

ព្រះគម្ពីរនិយាយថា "ដ្បិតនេះហើយ ជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឱ្យយើងរាល់

គ្នាកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ បញ្ញត្តិទ្រង់នោះមិនមែនជាបន្ទុកដ៏ធ្ងន់ទេ"

យ៉ូហានទី១ ៥:៣

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


130

នៅពេលដែលព្រះយេស៊ូវកំពុងបង្រៀន នៅថ្ងៃមួយ ទ្រង់បានប្រាប់ទៅអ្នកស្តាប់ថា មិនមែនមនុស្សគ្រប់គ្នាដែលបានទៅនគរស្ថានសួគ៌នោះទេ។

ទ្រង់បានមានព្រះបន្ទូលថា អ្នកអាច ស្គាល់ដើមឈើបានដោយសារផ្លែរបស់វា ទោះបីជាផ្លែល្អឬអាក្រក់ក្តី។


131

(ព្រះគម្ពីរ ម៉ាថាយ ៧:២១)

"មិនមែនអស់អ្នកណាដែលនិយាយមក ខ្ញុំថា ឱព្រះអម្ចាស់អើយៗ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ


132

គឺអស់ទាំងអ្នកណាដែលធ្វើតាមព្រះហឫទ័យ នៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញ ទេតើ ម៉ាថាយ ៧:២១


133

នោះគឺជាការពិតត្រង់ណាស់ ព្រះស្គាល់ ថាជារបស់ទ្រង់បាន ដោយទ្រង់ទតមើលផ្លែផ្កានៃជីវិតរបស់អ្នកនោះ។

វាមិនមែនអ្នកណាដែលគ្រាន់តែនិយាយ ថា គេជារបស់ព្រះនោះទេ ប៉ុន្តែអស់អ្នកណាដែលបានធ្វើតាមការ ដែលទ្រង់ចង់ឱ្យ គេធ្វើ។

គឺជាអ្នកទាំងនោះហើយដែលនឹងត្រូវ បានស្វាគមន៍ចូលទៅក្នុងនគររបស់ព្រះ។


134

ប្រសិនបើអ្នកស្រឡាញ់ទ្រង់នោះ សូមលោកអ្នកអនុញ្ញាតឱ្យទ្រង់រៀបចំជីវិតអ្នកចុះ ដើម្បីឱ្យអ្នកអាចធ្វើអ្វីៗទៅតាមព្រះ ហឫទ័យទ្រង់

នៅពេលដែលយើងរក្សាថ្ងៃបរិសុទ្ធនោះ យើងមិនមែនគ្រាន់តែរក្សាក្រិត្យវិន័យរបស់ទ្រង់ប៉ុណ្ណោះទេ តែយើងថែមទាំងបាន បើកទ្វារចិត្តរបស់យើង ដើម្បីទទួលព្រះពរដ៏អស្ចារ្យពីទ្រង់ផងដែរ។


135

នៅពេលដែលយើងចំណាយ ថ្ងៃដ៏ ពិសេសនោះរៀងរាល់សប្តាហ៍ ក្នុងការរំលឹកពីព្រះអទិកររបស់យើង និងឈាន ទៅរកទ្រង់នោះ យើងកាន់តែស្គាល់ទ្រង់ ខ្លាំងឡើងៗ។

សព្វថ្ងៃនេះជីវិតយើងរវល់ណាស់

គ្រប់ៗគ្នាហាក់បីដូចជាកំពុងតែប្រញាប់ ប្រញាល់ជាខ្លាំង មានការងារជាច្រើន ហើយមានពេលវេលាយ៉ាងតិចដើម្បីនឹង បង្អើយ!

# ១២. មនុស្សរាប់លាននាក់ត្រូវបានបំភាន់ ដោយរឿងប្រឌិត


136

នៅកណ្តាលការប្រញាប់ញាល់កង្វល់ និង ការស្ទុះស្ទានេះ ព្រះអញ្ជើញយើងឱ្យចេញ ឆ្ងាយពីវាមួយថ្ងៃដើម្បីសំរាក។

ទ្រង់អញ្ជើញយើងឱ្យចំណាយថ្ងៃជាមួយ ទ្រង់-ថ្វាយបង្គំទ្រង់ និយាយជាមួយទ្រង់ ស្តាប់ទ្រង់នៅពេលដែលទ្រង់មានព្រះបន្ទូល មកកាន់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះគម្ពីរ។

គឺជាបុព្វសិទ្ធដ៏អស្ចារ្យ-ដើម្បីចំណាយ ពេលមួយថ្ងៃពេញជាមួយព្រះរៀងរាល់ សប្តាហ៍ និងទាក់ទងជាមួយនឹងអ្នកដែល បានបង្កើតយើង!


137

មិត្តអើយ ខ្ញុំសូមបញ្ជាក់រឿងនេះឱ្យកាន់ តែច្បាស់ដល់អ្នក។

នៅម្ខាងយើងមានសេចក្តីពិត ហើយ ម្ខាងទៀតប្រពៃណី។

នៅម្ខាងយើងមានព្រះគម្ពីរ ម្ខាងទៀតយើងមាន ការបង្រៀនរបស់ មនុស្ស

នៅខាងម្ខាងយើងមានបញ្ញត្តិរបស់ព្រះ ម្ខាងទៀតគោលលទ្ធិមកពីមនុស្ស

នៅខាងម្ខាងយើងមានថ្ងៃបរិសុទ្ធ (សាបាថ) ម្ខាងទៀតថ្ងៃអាទិត្យ។

សារសំខាន់មិនមែនស្ថិតនៅលើថ្ងៃណា នោះទេ-វាស្ថិតនៅលើការដែលថា តើអ្នក ណាជាម្ចាស់របស់យើង ជាសារសំខាន់នៃ ការស្តាប់បង្គាប់ព្រះអម្ចាស់ និងដើរតាម ព្រះយេស៊ូវ

តើលោកអ្នកចង់ធ្វើការសម្រេចចិត្ត ដើម្បីថ្វាយជីវិតរបស់អ្នក ដើរតាមសេចក្តី ពិតរបស់ព្រះជាជាងការទទួល ប្រពៃណី ដែលមនុស្សបង្កើតឬទេ? ហេតុអ្វីបានជា មិនទូលទៅព្រះយេស៊ូវថា អ្នកនឹងដើរតាម ទ្រង់នូវគ្រប់ផ្លូវ ទាំងអស់នៅពេលដែល យើងអធិស្ឋាននៅពេលនេះ?។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?



1

ស្ថានសួគ៌ នរក ឬក៏គ្មានអ្វីទាំងអស់?


2

នៅឆ្នាំ១៩៥៦ កុងហ្គោបែលស៊ិក ត្រូវ បានញាំញីដោយសង្គ្រាមស៊ីវិលដ៏ធំមួយ! មន្ទីរពេទ្យរបស់លោកវេជ្ជបណ្ឌិត ប៉ូលកាលសិន ត្រូវបានរឹបអូសដោយកង កម្លាំងពួកឧទាម។ បុគ្គលិកមន្ទីរពេទ្យជា ច្រើនត្រូវបានគេសម្លាប់។

ជាអកុសលវេជ្ជបណ្ឌិតកាលស៊ិន ក៏បាន នៅជាមួយពួកគេដែរ។

នៅពេលដែលសាកសពគាត់ត្រូវបានគេ រកឃើញ ពីបីថ្ងៃបន្ទាប់ពីការធ្វើឃាតដ៏គ្មានសម្បជញ្ញៈទៅលើរូបលោកមក គេឃើញមានព្រះ គម្ពីរសញ្ញាថ្មីមួយនៅក្នុងហោប៉ៅអាវធំរបស់គាត់។ នៅក្នុងទំព័រនៃព្រះគម្ពីរនោះ លោក វេជ្ជបណ្ឌិតបានសរសេរកាលបរិច្ឆេទមួយ។

វាគឺជាថ្ងៃមុនពេលដែលគាត់ត្រូវបានគេ បាញ់ ហើយគាត់បានសរសេរពាក្យមួយ ម៉ាត់ "សេចក្តីសុខសាន្ត" សេចក្តីសុខសាន្ត នៅចំពោះមុខនៃបរិយាកាសដ៏អាក្រក់បំផុត។ សេចក្តីសុខសាន្តនៅនឹងមុខនៃសេចក្តីស្លាប់។ តើអ្វីទៅដែលផ្តល់ឱ្យលោកវេជ្ជបណ្ឌិត កាលសិន នូវសេចក្តីសុខសាន្តបែបនេះ?


3

តើវាជាការដែលអាចកើតមានឡើងបាន ដល់យើងទេដែលមានសេចក្តីសុខដ៏មហិមា ដូច្នេះ នៅពេលដែលយើងប្រឈមមុខទល់ នឹងសេចក្តីស្លាប់នោះ?

មានចម្លើយនៃសំនួរជាច្រើន ទាក់ទង ទៅនឹងសំនួរនៃសេចក្តីស្លាប់នេះ។

តើនឹងមានរឿងអ្វីកើតឡើងនៅពេល ដែលមនុស្សម្នាក់ស្លាប់?

ទៅស្ថានសួគ៌? ស្ថាននរក? ឬក៏គ្មានអ្វី ទាំងអស់?

តើលោកអ្នកដឹងទេថា មានរឿងអ្វីកើត ឡើងដល់រូបរាងកាយ ហើយតើមនុស្សនោះ បានទៅទីណាហើយ?

នៅពេលដែលមនុស្សស្លាប់ តើគេពិត ជាបានរលត់សូន្យសុងឬទេ? ឬមួយក៏ពួកគេ រស់នៅកន្លែងណាមួយទៀត?


4

ការឈឺចាប់នៃសេចក្តីស្លាប់របស់យើង គួរឱ្យភ័យខ្លាច ដែលយើងចង់ដឹងយ៉ាង ខ្លាំងថានឹងប្រាកដជា មានអ្នកដែលជា ទីស្រឡាញ់របស់យើងពិតជាមិនទាន់ទៅទីណា ទេ ហើយប្រសិនបើយើងអាចស្រាវជ្រាវ យើងអាចនឹងរកផ្លូវនិយាយជាមួយពួកគេ បាន។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


5

មានមនុស្សខ្លះកំពុងនិយាយប្រាប់យើង យ៉ាងច្បាស់លាស់ថា ការនោះនឹងអាចកើត ឡើងទៅបាន។ សូមគិតមើលបន្តិចអំពី លោកហ្វេម វ៉ាន ប្រាហ្គ ដែលជាគ្រូខាប ព្រលឹងខ្មោចនៅប្រទេសអាមេរិក ដែល យើងនឹងលើកយកមកធ្វើជាឧទាហរណ៍។

សៀវភៅរបស់គាត់ឈ្មោះ ការនិយាយ ទៅកាន់ស្ថានសួគ៌ ដំណឹងអំពីជីវិត ក្រោយ ពេលស្លាប់ទៅរបស់គ្រូខាបព្រលឹងខ្មោច។

បានក្លាយជាសៀវភៅដែលលក់ដាច់ច្រើនជាងគេបំផុតបន្ទាប់ពីបានបង្ហាញខ្លួននៅលើកញ្ចក់ ទូរទស្សន៍ឡារិឃិងមក។


6

ចិត្តរបស់យើងស្រែកទាមទាចង់ដឹងការ ពិតអំពីសេចក្តីស្លាប់ និងមានសេចក្តីសុខ សាន្តនៅពេលដែលយើង ប្រឈមមុខនៅ ក្នុងផ្នូរ។



7

(វីដេអូ ៥វិនាទី) តើព្រះមានអ្វីមានព្រះ បន្ទូលទាក់ទងនឹងប្រធាននេះឬទេ?

តើព្រះគម្ពីរមានអ្វីនិយាយឬទេ នៅ ពេលដែលយើងស្លាប់ទៅ? ចម្លើយគឺពិត ប្រាកដជាបាន


8

ហើយចម្លើយនោះត្រូវបានរកឃើញនៅ ក្នុងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ


9

បន្ទាប់ពីព្រះយេស៊ូវសុគត នៅលើឈើ ឆ្កាង ព្រះគម្ពីរនិយាយថា មិត្តរបស់ទ្រង់ បានដាក់ព្រះសពទ្រង់ក្នុង "ផ្នូរថ្មីរបស់ យ៉ូសែប"


10

ចៅហ្វាយខេត្តរ៉ូម លោកពីឡាត់ បាន ចាត់អ្នកយាមម្នាក់ និងទាហានឱ្យបោះត្រា នៅលើមាត់ផ្នូរដោយត្រារបស់ប្រទេសរ៉ូម។ ឥឡូវនេះគ្មានអ្នកណាអាចយកព្រះសព ទ្រង់បានឡើយ។ គ្មានអ្នកណាអាចយកបាន ឡើយ មានតែព្រះវរបិតារបស់ព្រះគ្រីស្ទប៉ុណ្ណោះ។


11

នៅពេលព្រឹកថ្ងៃអាទិត្យ នៅពេលដែល នៅងងឹតនៅឡើយ ទេវតាដ៏ភ្លឺចិញ្ចាចបាន ចុះពីស្ថានសួគ៌មក ប្រមៀលថ្មដែលគ្រប ទ្វារផ្នូរនោះចេញ ហើយបានហៅព្រះគ្រីស្ទ ឡើង។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


12

ព្រះអង្គសង្គ្រោះ ដែលមានព្រះជន្មរស់ ហើយយាងចេញពីផ្នូរឡើងវិញ គឺជា
ភ័ស្តុតាងយ៉ាងពេញលេញ និងគ្រប់គ្រាន់ ថា ទ្រង់មានជ័យជំនះលើសេចក្តីស្លាប់-
ជាជ័យជំនះមួយដ៏ពោរពេញដោយព្រះ ចេស្តា
ហើយពួកទាហានបានដួលចុះដូចជា
មនុស្សស្លាប់ ដោយសារសិរីល្អរបស់ទេវតា។


13

រឿងរ៉ាវនៃការរស់ឡើងវិញរបស់ព្រះ គ្រីស្ទបានជំរុញអំណាចដល់ក្រុមជំនុំគ្រីស្ទានដំបូង
នៅពេលដែលជនជាតិរ៉ូមគ្មានសេចក្តី សង្ឃឹមលើសពីនៅក្នុងផ្នូរនោះឡើយ។
រឿងតែមួយគត់ដែលពួកគេបានដឹងនោះ គឺថា ផ្នូរគឺជារណ្តៅមួយយ៉ាងជ្រៅ ធំ និងងងឹត
ដែលគ្មានអ្នកណាម្នាក់អាច សង្ឃឹមថា អាចរស់ចេញបានវិញនោះ
ឡើយ។
ឥឡូវនេះពួកគ្រីស្ទានមានដំណឹងនៃសេចក្តី សង្ឃឹមដ៏ពិតបំផុតមួយ។ ផ្នូរមិនមែនជាទី
បញ្ចប់ចុងក្រោយនោះទេ។
អស់អ្នកណាដែលបានស្លាប់ "ក្នុងព្រះ គ្រីស្ទ" ថ្ងៃណាមួយអាចនឹងរស់ឡើងវិញ!


14

ផ្នូរក្រោមដីនៅខាងក្រោមទីក្រុងរ៉ូម បង្ហាញអំពីការខុសគ្នារវាងសេចក្តីស្លាប់របស់អ្នកដែលជឿព្រះ
និងអ្នកមិនមែនគ្រីស្ទាន។
សូមកត់សំគាល់អក្សរចារឹក នៅផ្នូរ ខ្មោចរបស់អ្នកដែលស្លាប់នៅក្នុងការអស់
សង្ឃឹមរបស់អ្នកដែលមិនជឿព្រះ។


15

ម្តងហើយម្តងទៀតពាក្យពេចន៍នៃទុក្ខ សោកទាំងនោះត្រូវបានចារទុកថា លា ហើយរហូតតទៅ
ឬលាហើយរហូតដល់ អស់កល្ប។
បន្ទាប់មកសូមយើងមើលទៅផ្នូររបស់ គ្រីស្ទានវិញ:


16

លាហើយរហូតដល់យើងបានជួបគ្នាម្តង ទៀត ឬលាហើយរហូតដល់ព្រឹក។
ផ្នូររបស់ពួកគេត្រូវបានចារដោយសេចក្តី សង្ឃឹមនិងសេចក្តីក្លាហាន ទន្ទឹងរង់ចាំថ្ងៃនៃ
ការរស់ឡើងវិញ។


17

(ព្រះគម្ពីរ វិវរណៈ១:១៨)
"អញជាព្រះដែលរស់នៅ អញបាន ស្លាប់ តែមើលអញរស់នៅអស់កល្បជានិច្ច រៀងរាបតទៅវិញ។

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


18

អញក៏មានកូនសោនៃសេចក្តីស្លាប់ និងស្ថាន ឃុំព្រលឹងមនុស្សស្លាប់ដែរ" វិវរណៈ ១:១៨ នឹងគ្មានសេចក្តីសង្ឃឹមសម្រាប់អនាគត លើសពីសេចក្តីស្លាប់នោះឡើយ លើក លែង តែពួកគ្រីស្ទានតែប៉ុណ្ណោះ ដែល ដឹងថា ព្រះមានអនាគតនោះសម្រាប់ពួក គេ។


19

ជំពូកទីដប់ប្រាំនៃព្រះគម្ពីរ កូរិនថូសទី១ គឺជាការអធិប្រាយដ៏ធំរបស់លោកប៉ុល ស្តី អំពីការស្លាប់និងរស់ឡើងវិញនេះ។

គាត់បានមានប្រសាសន៍យ៉ាងច្បាស់ថា ប្រ សិនបើគ្មានការរស់ឡើងវិញទេ នោះនឹង គ្មានអនាគតសម្រាប់គ្រីស្ទានដែរ។


20

(ព្រះគម្ពីរ កូរិនថូសទី១ ១៥:១៦-១៨)

សូមកត់សំគាល់នូវអ្វីដែលព្រះគម្ពីរបាន និយាយ "ដ្បិតបើសិនជាពួកស្លាប់មិនរស់ ឡើងវិញទេ នោះព្រះគ្រីស្ទក៏មិនបានរស់ ឡើងវិញដែរ


21

ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ មែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នាក៏ ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាប នៅឡើយ!


22

ហើយអស់អ្នកដែលបានដេកលក់ក្នុង ព្រះគ្រីស្ទគេបានត្រូវវិនាសហើយ" កូរិនថូសទី១ ១៥:១៦-១៨


23

ប៉ុន្តែដើម្បីឱ្យយល់នូវអ្វីដែលគាត់បានធ្វើ យើងត្រូវយល់នូវអ្វីដែលព្រះគម្ពីរបង្រៀន អំពីសេចក្តីស្លាប់ខ្លួនឯងសិន។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?




24

នៅពេលដែលព្រះបានបង្កើតមនុស្ស វាមិនមែនជាគោលបំណងរបស់ទ្រង់ថា នឹងមានអ្នកណាម្នាក់នឹងត្រូវស្លាប់នោះឡើយ។
បន្ទាប់ពីព្រះបានបង្កើតអ័ដាម ទ្រង់បានទត មើលនូវរបស់ដែលទ្រង់បានបង្កើត ហើយ ព្រះគម្ពីរប្រាប់យើង នៅក្នុងលោកុប្បត្តិ ១:១៣ថា អក្សរទាំងអស់បានល្អប្រសើរ ហើយ!
គ្មានសេចក្ដីស្លាប់ទេ គ្មានជម្ងឺ និងការ ទុក្ខព្រួយទេ នៅលើពិភពផែនដីនេះ មុន ពេលដែលអ័ដាមនិងនាងអេវ៉ា
ធ្លាក់ចុះ(មានបាប)។
ប្រហែលជានឹងនឹកឃើញឡើងវិញនូវ ការដែលព្រះបានប្រាប់ដល់មនុស្ស



25

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៦,១៧)
"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បង្គាប់ទៅ អ័ដាមថា ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុង សួនច្បារនេះបានតាមចិត្ត



26

តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឱ្យ ឯងស៊ីផលឡើយ



27

ដ្បិតនៅថ្ងៃណាដែលឯងស៊ីនោះ ឯងនឹងត្រូវ ស្លាប់ជាមិនខាន"
លោកុប្បត្តិ ២:១៦-១៧


28

ជំពូកចុងក្រោយនៃរឿងនេះមិនសូវ
រីករាយប៉ុន្មានទេ។ រឿងដ៏គួរឱ្យខ្លោចផ្សានេះ បានកត់ត្រាទុកសម្រាប់យើងនៅក្នុងព្រះគម្ពីរ លោកុប្បត្តិជំពូក៣។


29

អារក្សបានប្រើសត្វពស់ជាមេអណ្ដើក លេចមកឯនាងអេវ៉ា ហើយបានល្បួងនាង ឱ្យមិនស្ដាប់បង្គាប់ព្រះ ហើយបរិភោគផ្លែ ឈើដែលព្រះបានហាមឃាត់។ នៅពេល ដែលនាងអេវ៉ាបានត្រូវពន្យល់ថា ព្រះបាន ហាមនាងមិនឱ្យបរិភោគផ្លែឈើនោះ បើពុំនោះទេ នាងនឹងត្រូវស្លាប់

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


30

(ព្រះគម្ពីរ លោកុប្បត្តិ ៣:៤)

ពស់បាននិយាយថា "អ្នកនឹងមិនស្លាប់ ជាពិតមែន" (ខ៤)។

នេះគឺជាការកុហកទីមួយដែលបានកត់ ត្រានៅក្នុងព្រះគម្ពីរ ស្តីអំពីសេចក្តីស្លាប់!

នាងអេវ៉ា ជ្រើសរើសជឿអារក្ស ហើយ បានបរិភោគផ្លែដឹងខុសត្រូវ


31

ព្រះបានបង្ខំបំបែកអ័ដាមនិងនាងអេវ៉ា ចេញពីដើមជីវិតព្រោះ


32

(ព្រះគម្ពីរ លោកុប្បត្តិ ៣:២២,២៣)

"...មើលមនុស្សបានត្រឡប់ដូចជាយើង

១ដែរ ទាំងដឹងខុសត្រូវផង


33

ឥឡូវខ្លាចក្រែងវាលូកដៃទៅបេះផ្លែជីវិត ស៊ីទៀតហើយរស់ជារៀងរាបដរាបទៅ


34

ដូច្នេះព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់ក៏ បណ្តេញគាត់ពីសួនច្បារអេដែនចេញ


35

ឲ្យទៅភ្ជួររាស់ដីដែលទ្រង់បានយកមកបង្កើត គាត់នោះវិញ" លោកុប្បត្តិ៣:២២,២៣។


36

សេចក្តីស្លាប់បានមកដល់មនុស្សជាតិ ពី ព្រោះវាត្រូវបានបំបែកចេញពីព្រះ ដែលជា ប្រភពនៃជីវិត និងពីដើមជីវិត។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


37

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១៨,១៩)

ព្រះបានប្រាប់ដល់អ័ដាមនៅពេលនោះ

ថា

"...ឯងត្រូវស៊ីអស់ទាំងតិណជាតិដែលដុះ នៅស្រែចំការ


38

ឯងនឹងបានអាហារស៊ីដោយការបែក ញើស ដរាបដល់ឯងត្រឡប់ទៅជាដីវិញ


39

ពីព្រោះអញបានយកឯងពីដីមក ដ្បិត ឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលី ដីវិញ" លោកុប្បត្តិ ៣:១៨,១៩


40

នេះគឺជាគន្លឹះដើម្បីផ្តល់អំពីសេចក្តីស្លាប់ និងបំណងព្រះហឫទ័យរបស់ព្រះដែលត្រូវធ្វើ ដើម្បីសង្គ្រោះយើងពីការបំបែកជាអមតៈ ចេញពីទ្រង់។


41

ព្រះគម្ពីរនិយាយថា មនុស្សត្រឡប់ទៅ ជាធូលីដី ដែលគេត្រូវបានយកមកនោះវិញ។ សូមកត់សំគាល់ការដែលព្រះបានបង្កើតអ័ដាម


42

(ព្រះគម្ពីរ លោកុប្បត្តិ ២:៧)

"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដី មកសូនធ្វើជាមនុស្ស


43

ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង" លោកុប្បត្តិ ២:៧។

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?



44

ព្រះទ្រង់បានយកធាតុនៃផែនដី ហើយ បានធ្វើជារូបរាងរបស់មនុស្ស នៅពេលដែលទ្រង់បានសូនរូបមនុស្សរួចហើយ ទ្រង់មានតែរូបបុគ្គលប៉ុណ្ណោះ មានតែរូប កាយប៉ុណ្ណោះ។

ទ្រង់បានយកអ្វីម្យ៉ាងប្រសើរជាងនេះទៅ ទៀត ដើម្បីធ្វើឲ្យមនុស្សមានជីវិតរស់ឡើង។ ព្រះគម្ពីរនិយាយ នៅត្រង់នោះថា ព្រះ បានផ្លុំខ្យល់បង្ហើមរស់ចូលក្នុងរន្ធច្រមុះអ័ដាម ហើយមនុស្សក៏បានក្លាយជាមានព្រលឹង រស់ឡើង។




45

(វីដេអូ ៣វិនាទី) យើងអាចសរសេរជា សមីការបានដូច្នេះ:

រាងកាយ

+ ខ្យល់ដង្ហើម

= ព្រលឹងរស់មួយ




46

(វីដេអូ ៣វិនាទី) ឬសម្រាប់សេចក្តីស្លាប់ យើងអាចសរសេរ

មនុស្សរស់-ខ្យល់ដង្ហើម=បុគ្គល(ខ្មោច)



47

(ព្រះគម្ពីរ សាស្តា ១២:៧)

នោះគឺជាការដែលហោរាបាននិយាយ នៅក្នុងគម្ពីរសាស្តាថា "ហើយធូលីត្រឡប់ ជាដីដូចដើមវិញ និងវិញ្ញាណ ត្រឡប់ទៅឯ ព្រះដែលទ្រង់បានប្រទានមកនោះ"

សាស្តា ១២:៧។



48

នេះគឺជាសារសំខាន់ដូចគ្នាទៅនឹងសៀវ ភៅយ៉ូប ជាសៀវភៅដែលបានសរសេរមុនគេបង្អស់នៅក្នុងគម្ពីរ-ត្រូវបាននិយាយអំពី សេចក្តីស្លាប់នោះដែរ។



49

(ព្រះគម្ពីរ យ៉ូប ២៧:៣)

"កាលខ្ញុំនៅមានដង្ហើមចេញចូល ហើយមានខ្យល់វិញ្ញាណនៃព្រះ នៅក្នុងរន្ធ ច្រមុះខ្ញុំនៅឡើយ"

យ៉ូប ២៧:៣

សូមកត់សំគាល់ថា ព្រះគម្ពីរនិយាយ ថា "ហើយមានខ្យល់វិញ្ញាណនៃព្រះនៅក្នុងរន្ធច្រមុះខ្ញុំនៅឡើយ"



50

នោះហើយជាអ្វីដែលព្រះបានដាក់នៅ ក្នុងរន្ធច្រមុះរបស់មនុស្សនៅពេលដែលទ្រង់បានបង្កើតគេមក។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


51

(ព្រះគម្ពីរ ទំនុកដំកើង ១៤៦:៣,៤)
សូមមើលទៅខមួយទៀត
"សូមកត់សំគាល់ថា ព្រះគម្ពីរនិយាយ ថា កុំឱ្យទុកចិត្តនឹងអ្នកធំ ឬនឹងពូជពង្សនៃ មនុស្សណាឡើយ គេនឹងជួយឯងមិនបានទេ


52

គេផុតដង្ហើមទៅ ហើយត្រឡប់ទៅជាដី វិញនៅថ្ងៃនោះឯង អស់ទាំងគំនិតរបស់គេក៏សូន្យបាត់ទៅ"
ទំនុកដំកើង ១៤៦:៣,៤


53

ស្តេចដាវីឌបង្ហាញសេចក្តីពិតអំពី សេចក្តីស្លាប់ នៅពេលដែលទ្រង់មានព្រះ បន្ទូលថា ការស្លាប់ខ្យល់ដង្ហើមបាន ចេញរូបកាយ ហើយរូបកាយត្រឡប់ទៅជា ធូលីដីវិញ។ មនុស្សស្លាប់។


54

(ព្រះគម្ពីរ សាស្តា ៩:៥,៦)
រឿងនេះស្របទៅនឹងស្តេចសាឡូម៉ូនបាន មានព្រះបន្ទូលថា:
"ដ្បិតមនុស្សដែលរស់គេដឹងថា ខ្លួននឹង ស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹងអ្វី ឡើយ គេក៏គ្មានរង្វាន់អ្វីទៀតដែរ


55

ពីព្រោះសេចក្តីនឹកចាំពីគេបានសូន្យបាត់ហើយ។


56

ទោះទាំងសេចក្តីស្រឡាញ់ សេចក្តី សំអប់ និងសេចក្តីឈ្នានិះរបស់គេក៏វិនាសសូន្យបាត់ជាយូរមកហើយ
សាស្តា ៩:៥,៦


57

(វីដេអូ ៥វិនាទី) គេមិនដឹងអ្វីទាំងអស់!
គ្មានអ្វីទាំងអស់! មិនជាអ្វីទាំងអស់!
រឿងនេះក៏ដូចគ្នាទៅនឹងកវីដែលបាន សរសេរថា អ្នកដែលស្លាប់មិនមែននៅ ឯស្ថានសួគ៌ ហើយសរសើរដំកើងព្រះទេ។
ដូច្នេះតើពួកគេនៅទីណា? លោកអ្នក អាចសួរ។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


58

(ព្រះគម្ពីរ ទំនុកដំកើង ១១៥:១៧) ស្តេចដាវីឌបានបញ្ជាក់យ៉ាងច្បាស់ក្រឡែត "មនុស្សស្លាប់រមែងមិនសរសើរដល់ ព្រះយេហូវ៉ាទេ ព្រមទាំងមនុស្សដែលចុះទៅឯស្ថានស្ងាត់ឈឹងផង"

ទំនុកដំកើង ១១៥:១៧។


59

(ព្រះគម្ពីរ យ៉ូប ១៤:១០,១២,១៣)

"ឯមនុស្សវិញគេស្លាប់ក៏ពុករលួយទៅ អើមនុស្សប្រគល់វិញ្ញាណទៅ នោះតើគេ នៅឯណា?


60

នោះមនុស្សក៏ដេកទៅឥតក្រោកឡើង ទៀតយ៉ាងនោះដែរ គេនឹងមិនភ្ញាក់ឡើង វិញឬអ្នកណាដាស់ ឱ្យគេភ្ញាក់ពីដេកឡើង ឡើយ។


61

គេនឹងមិនភ្ញាក់ឡើងវិញឬអ្នកណាដាស់ ឱ្យ គេភ្ញាក់ពីដេកឡើងឡើយ។


62

ឱ បើទ្រង់នឹងលាក់ទូលបង្គំ នៅស្ថានឃុំ ព្រលឹងមនុស្សស្លាប់ទៅអេះ ហើយទូលបង្គំ នៅទីស្ងាត់កំបាំង ដរាបដល់សេចក្តីក្រោធ របស់ទ្រង់កន្លងបាត់ទៅ


63

ហើយដំរូវឱ្យមានពេលកំណត់ដល់ទូលបង្គំ រួចនឹកចាំពីទូលបង្គំផង!"

យ៉ូប ១៤:១០,១២,១៣។


64

នេះយើងមានដំណឹងនេះមកពីព្រះបន្ទូល របស់ព្រះផ្ទាល់ថា មនុស្សស្លាប់និងដេកនៅ ក្នុងផ្នូរ ហើយមិនងើបឡើងវិញទេ រហូត ដល់ថ្ងៃនៃការរស់ឡើងវិញ។

សូមកត់សំគាល់ការដែលទ្រង់ពណ៌នាអំ ពីការនេះ។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


65

(ព្រះគម្ពីរ យ៉ូប ១៤:១៤,១៥)

"បើមនុស្សស្លាប់ទៅ គេនឹងមានជីវិត រស់ឡើងទៀតឬ? បើមាន នោះទូលបង្គំ នឹងរង់ចាំអស់រវាងសង្គ្រាមវេទនារបស់ទូល បង្គំ ដរាបដល់កំណត់ដែលទូលបង្គំបាន រអិលចេញទៅ


66

នោះទ្រង់នឹងហៅ ហើយទូលបង្គំ នឹងទូលតប"
យ៉ូប ១៤:១៤,១៥


67

(ព្រះគម្ពីរ យ៉ូប ១៧:១៣)

សូមកត់សំគាល់ថាយ៉ូបបានប្រាប់យើង ថា "បើកាលណាខ្ញុំសង្ឃឹមនឹងឱ្យបានស្ថាន យុំព្រលឹងមនុស្សស្លាប់ទុកជាទីលំនៅខ្ញុំ បើ ខ្ញុំក្រាលកន្ទេលដេករបស់ខ្ញុំនៅស្ថានងងឹត"
យ៉ូប ១៧:១៣


68

សូមកត់សំគាល់ផងដែរថា លោកយ៉ូប បានប្រើពាក្យថា "ដេកលក់" ក្នុងការ និយាយអំពីការស្លាប់។ នោះក៏ដូចជាអ្នកសរសេរព្រះគម្ពីរម្នាក់ ទៀតនិយាយថា។


69

(ព្រះគម្ពីរ ទំនុកដំកើង ១៣:៣)

ស្តេចដាវីឌបានសរសេរថា "សូមពិចារ ណាមើល ហើយឆ្លើយតបទូលបង្គំផង សូមបំភ្លឺភ្នែកទូលបង្គំ ក្រែងទូលបង្គំដេក លក់ទៅក្នុងសេចក្តីស្លាប់"
ទំនុកដំកើង ១៣:៣

ស្តេចដាវីឌបានខ្លាចការផ្ទំ(ដេក)លក់ ជាការផ្ទំលក់នៃសេចក្តីសុគត(ស្លាប់)!


70

(ព្រះគម្ពីរ ដានីយ៉ែល ១២:២)

ដានីយ៉ែលប្រាប់ពីអ្នកស្លាប់ដែលនឹងត្រូវ បានលើកឡើងវិញ "ហើយពួកអ្នកដែល ដេកលក់នៅក្នុងធូលីដី នឹងភ្ញាក់ឡើងវិញ ជាច្រើន គឺខ្លះឱ្យបានជីវិតរស់នៅអស់កល្ប ជានិច្ច និងខ្លះឱ្យបានសេចក្តីអាម៉ាស់ខ្មាស ហើយឱ្យបានជាទីខ្ពើមឆ្អើម នៅអស់កល្ប ជានិច្ចវិញ"
ដានីយ៉ែល ១២:២

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


71

ការទុកចិត្តទៅយ៉ាងស្រួលបំផុតទៅលើ ព្រះបន្ទូលរបស់ព្រះគឺថា នៅពេលមនុស្ស ម្នាក់ស្លាប់ គាត់ឬនាងសម្រាកយ៉ាងស្ងៀម ស្ងាត់ ដោយគ្មានការរំខានពីបញ្ហាជីវិតអ្វី ឡើយ រហូតដល់មានការត្រាស់ហៅរបស់ អ្នកដែលប្រគល់ជីវិតឱ្យគេ។

តើនេះមិនមែនជាការអស្ចារ្យទេឬ ដែល ព្រះគម្ពីរប្រដូចការស្លាប់ទៅនឹងការដេកលក់ នោះ?


72

ហោរាណាថានបានទូលស្ដេចដាវីឌនូវ ការដែលនឹងកើតឡើងដល់ទ្រង់ នៅពេល ដែលទ្រង់សុគត។


73

(ព្រះគម្ពីរ សាំយូអែលទី២ ៧:១២)

"កាលណាឯងបានរស់នៅគ្រប់កំណត់ អាយុហើយ...រួចបានដេកលក់ជា មួយពួកឰយុកោឯង..." សាំយូអែលទី២ ៧:១២។


74

ព្រះយេស៊ូវផ្ទាល់ទ្រង់បានហៅសេចក្ដី ស្លាប់ថា ជាការដេកលក់។

ទ្រង់បានប្រើពាក្យដូចគ្នានេះដើម្បី ពិពណ៌នាអំពីការស្លាប់របស់ឡាសារសម្លាញ់ ទ្រង់។

សូមយើងពិនិត្យមើលការដែលព្រះ យេស៊ូវ និងអ្នកដែលទាក់ទងនឹងទ្រង់យ៉ាង ជិតស្និទ្ធ បាននិយាយអំពីការស្លាប់នេះ។

មានផ្ទះមួយនៅភូមិបេថ្ថេហ៊ឹមដែលព្រះ យេស៊ូវតែងតែយាងទៅលេង_ផ្ទះរបស់ ឡាសារ ម៉ារី និងម៉ាថា។


75

(ព្រះគម្ពីរ យ៉ូហាន១១:៥)

ព្រះគម្ពីរនិយាយថា "រីឯព្រះយេស៊ូវ ទ្រង់ស្រឡាញ់នាងម៉ាថា និងប្អូនស្រីនាង ហើយនិងឡាសារផង"

យ៉ូហាន១១:៥


76

ថ្ងៃមួយនៅពេលដែលព្រះយេស៊ូវនឹងពួក សិស្សបានចេញទៅខាងក្រៅ ក្បែរទន្លេយ័រ ដាន់ ទ្រង់បានទទួលដំណឹងយ៉ាងបន្ទាន់ពី មិត្តទាំងបីនាក់របស់ទ្រង់ ពីបេថានីមកថា ឡាសារបានឈឺធ្ងន់ណាស់ ប៉ុន្តែព្រះយេស៊ូវ ទ្រង់បាននៅកន្លែងដែលទ្រង់គង់នៅនោះពីរ ថ្ងៃទៀត។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


77

(ព្រះគម្ពីរ យ៉ូហាន ១១:១១,១២,១៤, ១៥)

បន្ទាប់មកព្រះយេស៊ូវបានមានព្រះបន្ទូល ថា "ឡាសារសំឡាញ់យើងគាត់បានដេក លក់ហើយ ខ្ញុំទៅដើម្បីនឹងដាស់គាត់ឡើង


78

ដូច្នេះពួកសិស្សទូលថា ព្រះអម្ចាស់ អើយ បើគាត់ដេកលក់ នោះគាត់នឹងបាន ជាវិញ"


79

"នោះព្រះយេស៊ូវមានបន្ទូលទៅគេយ៉ាង ច្បាស់ថា ឡាសារស្លាប់ហើយ


80

ខ្ញុំអរណាស់ ដោយយល់ដល់អ្នករាល់គ្នា ព្រោះខ្ញុំមិនបាននៅឯណោះ ដើម្បីឱ្យអ្នក រាល់គ្នាបានជឿ ឥឡូវចូរយើងទៅឯគាត់ចុះ"

យ៉ូហាន ១១:១១-១៥


81

ពួកគេបានធ្វើដំណើរទៅកាន់ភូមិបេថានី ជាកន្លែងដែលគ្រួសារនោះរស់នៅ។

នៅពេលដែលពួកគេបានទៅដល់ទីក្រុង នាងម៉ាថា បានរត់មកជួបទ្រង់។


82

(ព្រះគម្ពីរ យ៉ូហាន ១១:២១,២៣,២៤)

នៅពេលជួបព្រះយេស៊ូវនាងបាននិយាយ ថា "ព្រះអម្ចាស់អើយ បើសិនជាទ្រង់បាន គង់នៅទីនេះ នោះប្អូនខ្ញុំម្ចាស់មិនស្លាប់ទេ"

យ៉ូហាន១១:២១

គ្មានការសង្ស័យទេ នាងនិយាយនោះ ត្រឹមត្រូវហើយ!


83

ព្រះយេស៊ូវមានបន្ទូលទៅនាងថា "ប្អូនរបស់ នាងនឹងរស់ឡើងវិញ"

ឥឡូវនេះសូមពិនិត្យដោយយកចិត្ត

ទុកដាក់ នូវការដែលនាងម៉ាថាឆ្លើយតប

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


84

ខ្ញុំដឹងថា នៅថ្ងៃចុងបំផុត កាលណា មនុស្សត្រូវរស់ពីស្លាប់ឡើងវិញ  នោះប្អូនខ្ញុំម្ចាស់នឹងរស់ឡើងដែរ”

យ៉ូហាន ១១:២៣-២៤។

នាងម៉ាថាបានបញ្ជាក់ប្រាប់ព្រះយេស៊ូវ ថា នាងសង្ឃឹមថានឹងបានជួបឡាសារវិញ នៅគ្រារស់ឡើងវិញ នៅទីចុងបញ្ចប់នៃ ពិភពលោក។


85

ទោះបីជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវ ហៀបនឹងបង្ហាញអំពីព្រឹត្តិការណ៍ដែលធ្វើឱ្យរំភើបយ៉ាងខ្លាំងនោះ។


86

(ព្រះគម្ពីរ យ៉ូហាន ១១:២៥)

បន្ទាប់មកព្រះយេស៊ូវបានមានព្រះបន្ទូល ដោយត្រង់ថា “ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ ឡើងវិញដែរ”

យ៉ូហាន១១:២៥។

នៅពេលដែលព្រះយេស៊ូវយាងទៅកាន់ ផ្ទះរបស់ឡាសារ លោកយ៉ូហានប្រាប់យើង


87

នៅពេលដែលព្រះយេស៊ូវយាងទៅកាន់ ផ្ទះរបស់ឡាសារ លោកយ៉ូហានប្រាប់យើង


88

(ព្រះគម្ពីរ យ៉ូហាន ១១:៣៥)

ព្រះយេស៊ូវក៏ទ្រង់ព្រះកន្សែង!

ទ្រង់មិនបានយំព្រោះតែឡាសារសម្លាញ់ ទ្រង់ទេ

ទ្រង់បានជ្រាបថា ទ្រង់នឹងលើក ឡាសារឱ្យរស់ឡើងវិញ។


89

ទ្រង់បានដោយសារការទុក្ខព្រួយ របស់ គ្រួសារនិងមិត្តភក្ដិដែលកំពុងជួបប្រទះ និងដល់អស់មនុស្សគ្រប់រូបដែលនឹងត្រូវរង ទុក្ខវេទនា និងមានការរងទុក្ខសោកនៅពេលដែលពួកគេបាត់បង់អ្នកដែលជាទី ស្រឡាញ់របស់គេ។


90

ព្រះយេស៊ូវបានសុំឱ្យគេយកដុំថ្មដែល គ្របផ្នូរនោះ

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


91

ត្រូវយកចេញ



92

(ព្រះគម្ពីរ យ៉ូហាន ១១:៣៩)

ដោយពិចារណាចំពោះសំណើនេះ នាង ម៉ាថាប្រកែក "...ព្រះអម្ចាស់អើយ...
ខ្មោចនេះធំក្លិនហើយ ព្រោះស្លាប់កន្លងបាន បួនថ្ងៃ"

យ៉ូហាន ១១:៣៩

មែនហើយ ព្រះយេស៊ូវបានពន្យាការយាងទៅ បេថានីបួនថ្ងៃ។ ការពន្យាពេលនេះនឹងបាន ដាក់ឱ្យនៅឆ្ងាយនូវការសង្ស័យទាំងឡាយអំពី ហេតុផលថា ឡាសារពិតជាបានស្លាប់ពិត ប្រាកដមែន។


93

ប៉ុន្តែដុំថ្មត្រូវគេប្រមៀលចេញពីផ្នូរ ហើយព្រះយេស៊ូវទ្រង់ស្រែកឡើង ដោយ សំឡេងយ៉ាងខ្លាំងថា "ឡាសារអើយ ចូរក្រោកឡើង!"


94

អ្នកខ្លះបាននិយាយថា វាជាការល្អ ដែលព្រះយេស៊ូវបានបញ្ជាក់ដោយបានមានព្រះបន្ទូលហៅ តែឡាសារមួយប៉ុណ្ណោះ

បើពុំនោះទេ ផ្នូរទាំងអស់នៅលើពិភពផែនដី នេះនឹងត្រូវបានរបើកឡើងទាំងអស់!


95

នោះគឺជាថ្ងៃដ៏អស្ចារ្យរបស់មិត្តទាំងបី នាក់នៅបេថានី!

ជាអំណរនិងការរីករាយយ៉ាងខ្លាំង!

មិត្តទាំងឡាយ នេះគឺជាថ្ងៃមួយយ៉ាង រំភើបនៅបេថានី។


96

ប៉ុន្តែវាគ្រាន់តែជាការបង្ហាញឱ្យឃើញជាមុនដ៏តូចមួយ អំពីសិរីល្អ និងការរំភើប ដែល នឹងកើតឡើង នៅពេលដែលព្រះយេស៊ូវ យាងមកវិញម្តងទៀត ហើយគ្រប់ទាំងផ្នូរ របស់មិត្តទ្រង់ដទៃទៀតដែលបានទទួលទ្រង់ ជាព្រះអង្គសង្គ្រោះត្រូវបានបើក ហើយពួក គេងើបឡើងទៅជួបទ្រង់នៅលើអាកាស!

នេះគឺជាដំណឹងនៃការកំសាន្តចិត្ត ដែល លោកសាវកប៉ុលបានចែកចាយដល់ក្រុមជុំនុំ ដំបូង



97

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៣,១៦)

"បងប្អូនអើយ ខ្ញុំមិនចង់ឱ្យអ្នកឥតដឹង ពីពួកអ្នកដែលដេកលក់ទៅហើយទេ

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


98

ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយដូចជាអ្នកឯ ទៀតដែលគ្មានសង្ឃឹម”
ថែស្សាឡូនីច ៤:១៣
 លោកប៉ុលប្រាប់យើងអំពីការដែលព្រះ
យេស៊ូវនឹងធ្វើនៅពេលដែលទ្រង់នឹងយាងមក
ជាលើកទីពីរ


99

 “ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថាន
សួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំង មានឮសំឡេងមហាទេវតា


100

និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះ គ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់
ថែស្សាឡូនីចទី១ ៤:១៦


101

 លោកប៉ុលពណ៌នាដោយលំអិត នូវ ព្រឹត្តិការណ៍ដែលនឹងកើតមានឡើងនៅពេល
ដែលព្រះយេស៊ូវយាងមកវិញ


102

(ព្រះគម្ពីរ កូរិនថូសទី១  ១៥:៥១-៥៥)
 “នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តី
អាថ៌កំបាំង គឺថាយើងរាល់គ្នានឹងមិនដេក លក់ទេ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែ


103

ក្នុង១រំពេចវិញ គឺក្នុង១ប៉ព្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮស្នូរត្រែក្រោយបង្អស់


104

 ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់ នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ
រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ”
កូរិនថូសទី១ ១៥:៥១,៥២
 ហើយលោកប៉ុលប្រាប់ពីរបៀបដែលយើង
នឹងផ្លាស់ប្តូរ

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


105

“ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវ តែបានប្រដាប់ដោយសេចក្តីមិនចេះស្លាប់វិញ ដែរ


106

កាលណារូបកាយពុករលួយនេះ បាន ប្រដាប់ដោយសេចក្តីមិនពុករលួយ ហើយ រូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ ដោយសេចក្តីមិនស្លាប់វិញ


107

នោះទើបនឹងបានសំរេចតាមពាក្យដែលចែង ទុកមកថា “សេចក្តីជ័យជំនះបានលេប សេចក្តីស្លាប់បាត់ហើយ”


108

“ឱ សេចក្តីស្លាប់អើយ ទ្រនិចឯងនៅ ឯណា?”
កូរិនថូសទី១ ១៥:៥៣-៥៥។


109

ព្រះយេស៊ូវបានប្រាប់ដល់ពួកសាវកថា មនុស្សទាំងអស់នឹងត្រូវបានលើកឡើងពីផ្នូរ។


110

(ព្រះគម្ពីរ យ៉ូហាន ៥:២៨,២៩)
“កុំឱ្យឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមាន ពេលវេលាមក ដែលអស់ទាំងខ្មោចនៅ ក្នុងផ្នូរ នឹងឮសំឡេងទ្រង់


111

ហើយនិងចេញមក គឺពួកអ្នកដែលបាន ប្រព្រឹត្តល្អ គេនឹងរស់ឡើងវិញឱ្យបានជីវិត


112

ឯពួកអ្នកដែលបានប្រព្រឹត្តអាក្រក់វិញ គេ នឹងរស់ឡើង ឱ្យជាប់មានទោស”
យ៉ូហាន ៥:២៨,២៩។

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


113

សូមគិតមើលបន្តិច ទោះបីជាមនុស្ស បានទៅកាន់ស្ថានសួគ៌ឬនរកក៏ដោយនៅពេល គេស្លាប់ទៅ តើនឹងត្រូវមានការរស់ឡើង វិញរបស់អ្នកសុចរិត និងអ្នកទុច្ចរិតដែរ ឬទេ?

តើហេតុអ្វីបានជាព្រះយេស៊ូវមានព្រះ បន្ទូលថ្លែងយ៉ាងដូច្នេះ?


114

(ព្រះគម្ពីរ វិវរណៈ ២២:២១)

"មើលអញមកជាឆាប់ ទាំងនាំយក រង្វាន់មកជាមួយ ដើម្បីនឹងចែកឱ្យគ្រប់គ្នា តាមការដែលខ្លួនបានធ្វើ"

វិវរណៈ:២២:២១


115

វាចំៗមែនទែន!

នៅពេលដែលមនុស្សស្លាប់ ពួកគេ កំពុងដេកលក់ ពួកគេសំរាកពីការងារ និង ទុក្ខព្រួយទាំងឡាយរបស់ពួកគេ ទម្រាំព្រះ យេស៊ូវយាងមកវិញ


116

តើទ្រង់យាងមកធ្វើអ្វី?

ទ្រង់នឹងយាងមកប្រោសឱ្យរស់ឡើងវិញ និងធ្វើឱ្យជួបគ្នាឡើងវិញនូវអស់អ្នកណាដែល បានទទួលការលះបង់របស់ទ្រង់ ជំនួសពួក គេ។

ព្រះយេស៊ូវក៏បានយាងមកដើម្បីនឹង ស្វាគមន៍ដល់អ្នកដែលដើរតាមទ្រង់ដោយ ស្មោះត្រង់នៅពេលនោះផងដែរ។

សូមស្តាប់នូវដំណឹងល្អនេះ!


117

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៧)

"រួចយើងរាល់គ្នាដែលកំពុងតែរស់ នៅ ក៏នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នា ទាំងអស់ ដើម្បីឱ្យ បានជួបជុំនឹងព្រះ អម្ចាស់ នៅនាអាកាស


118

យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះ អម្ចាស់ជាដរាបទៅ"

ថែស្សាឡូនីចទី១ ៤:១៧


119

យើងបានឃើញថា អ្នកដែលបាន សង្គ្រោះ ទាំងអស់នឹងមានរូបកាយដែល ពោរពេញ ដោយសិរីល្អដូចព្រះយេស៊ូវដែរ ហើយពួក គេទទួលជីវិតដ៏អស់កល្ប ដើម្បីឱ្យពួកគេ នឹងនៅជាមួយព្រះជា អម្ចាស់ជារៀងរហូត។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?



120

អ្នកខ្លះប្រហែលសួរថា “ចុះចោរដែល នៅលើឈើឆ្កាងនោះនឹងទៅជាយ៉ាងណា ដែរ?”



121

សូមមើល តើព្រះគម្ពីរបង្រៀនយ៉ាង ណា អំពីចោរនោះ និងសេចក្តីសន្យាដែល ព្រះយេស៊ូវប្រទានដល់វា។

ព្រះយេស៊ូវត្រូវបានគេឆ្កាងនៅកណ្តាល ចោរពីរនាក់ ដើម្បីឱ្យអ្នកដែលបានឆ្កាង ទ្រង់ អាចបញ្ជាក់ថា ទ្រង់ជាឧក្រិដ្ឋជន។



122

ព្រះគម្ពីរម៉ាកុសនិយាយថា ដំបូង ចោរ ទាំងពីរនាក់និយាយឡកឡឺយឱ្យព្រះយេស៊ូវ ហើយនិយាយថា បើសិនជាទ្រង់ពិតជាមាន អំណាចមែន សូមឱ្យព្រះអង្គរំដោះខ្លួនឯង និងពួកគេផងទៅ។

ហើយចោរមួយបានក្លាយជាអ្នកកែ ប្រែចិត្ត ហើយស្រែកសុំសេចក្តីសង្គ្រោះ។



123

(ព្រះគម្ពីរ លូកា ២៣:៤២,៤៣)

វានិយាយថា “ព្រះអម្ចាស់អើយ កាល ណាចូលទៅក្នុងនគរទ្រង់ សូមនឹកចាំពីទូល បង្គំផង។



124

ព្រះយេស៊ូវមានបន្ទូលទៅថា ខ្ញុំប្រាប់ អ្នកជាប្រាកដថា ថ្ងៃនេះ អ្នកនឹងនៅក្នុង ស្ថានបរមសុខជាមួយនឹងខ្ញុំដែរ”

លូកា ២៣:៤២,៤៣



125

សូមមើលទៅឯសេចក្តីសន្យាម្តងទៀត។ មែនហើយ មិត្តហើយ! ថ្ងៃនេះ ឥឡូវនេះ លោក អ្នកក៏អាចមានការធានារ៉ាប់រងនេះដែរ។ នៅក្នុងព្រះគ្រីស្ទមានការធានារ៉ាប់រង។



126

ទោះបីជាព្រះគ្រីស្ទបានសុគតនៅថ្ងៃនោះ ក៏ដោយ ហើយបានត្រូវដាក់នៅក្នុងផ្នូររហូត ដល់ព្រឹកថ្ងៃអាទិត្យក៏ដោយ ក៏ព្រះយេស៊ូវ បានធានាអះអាងថា ទ្រង់នឹងអាចរស់ចេញ ពីផ្នូរឡើងវិញ។

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?



127

(ព្រះគម្ពីរ លូកា ២៣:៤៣)

(វីដេអូ ៥វិនាទី) ជាការធានារ៉ាប់រងយ៉ាង អស្ចារ្យដល់ចោរដែលបានស្លាប់!

នៅពេលដែលគ្មានសេចក្តីសង្ឃឹម សម្រាប់វា។ នៅពេលដែលអ្វីៗដែលវាបាន ឃើញនោះគឺមានតែភាពងងឹត ដែលធ្វើ ឱ្យព្រលឹងវាមានការភ័យខ្លាចនោះ ព្រះយេស៊ូវអាចសន្យាដល់វានូវសេចក្តីសង្ឃឹមមួយហួសពីផ្នូរ (ហួសពីសេចក្តីស្លាប់)។

ព្រះយេស៊ូវបានសន្យាទៅកាន់ចោរ នៅ ម៉ោងនោះថា "ថ្ងៃនេះខ្ញុំប្រាប់អ្នក ឬឥឡូវនេះខ្ញុំប្រាប់អ្នកថា អ្នកនឹងនៅស្ថានបរមសុខ ជាមួយនឹងខ្ញុំដែរ"។



128

អ្នកខ្លះបានគិតថា ព្រះយេស៊ូវបានសន្យា ទៅកាន់ចោរ ដែលវាអាចទៅស្ថានសួគ៌ ភ្លាម។ ប៉ុន្តែព្រះយេស៊ូវព្រះអង្គឯងមិនបាន យាងទៅកាន់ស្ថានសួគ៌ភ្លាមទេ នៅពេល ដែលទ្រង់សុគតនោះ។



129

ព្រះគម្ពីរប្រាប់យើងថា ទ្រង់សុគតនៅ ថ្ងៃនោះ ថ្ងៃសុក្រ ហើយត្រូវបានបញ្ចុះនៅក្នុងផ្នូររបស់អ្នកដទៃម្នាក់។



130

នៅព្រឹកថ្ងៃអាទិត្យព្រះយេស៊ូវបានលេច មកឯនាងម៉ារា ហើយនាងចង់ថ្វាយបង្គំ ទ្រង់ ប៉ុន្តែទ្រង់បានទប់ចិត្តនាង ពីព្រោះ ទ្រង់មិនទាន់បានយាងឡើងទៅកាន់ស្ថានសួគ៌ នៅឡើយ។ សូមស្តាប់នូវការដែលទ្រង់ បានមានព្រះបន្ទូល



131

(ព្រះគម្ពីរ យ៉ូហាន២០:១៧)

"...កុំពាល់ខ្ញុំ ព្រោះខ្ញុំមិនទាន់ឡើងទៅ ឯព្រះវរបិតាខ្ញុំនៅឡើយ..."

ពេលនោះគឺជាព្រឹកថ្ងៃអាទិត្យ ហើយទ្រង់បានមានបន្ទូលថា ទ្រង់មិនទាន់ បានយាងឡើងទៅឯព្រះវរបិតានៅឡើយ! យ៉ូហាន ២០:១៧។

ព្រះយេស៊ូវមិនអាចទៅឯស្ថានសួគ៌នៅ ថ្ងៃសុក្រនោះទេ!



132

ព្រះគម្ពីរបានប្រាប់យើងថា រឿងរ៉ាវ ដែលកើតឡើងដល់ព្រះយេស៊ូវ គឺត្រឹមត្រូវតាមបទទំនាយទាំងឡាយ ដែលបានទាយ ទុករាប់សតវត្សរ៍មកហើយទាំងអស់។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


133

(ព្រះគម្ពីរ យ៉ូហាន ១៩:៣១-៣៣)

"ពួកយូដាក៏សូមលោកពីឡាត់ឱ្យបានបំបាក់
ជើងពួកជាប់ឆ្កាង ហើយយកចេញទៅ ដើម្បីកុំ ឱ្យខ្មោចជាប់នៅលើឈើឆ្កាង ក្នុងថ្ងៃឈប់ សម្រាក។


134

ពីព្រោះជាថ្ងៃរៀបចំ ឯថ្ងៃឈប់សំរាក (នោះគឺជាថ្ងៃបុណ្យធំ)
យ៉ូហាន ១៩:៣១ ដោយបំបាក់ជើង ចោរទាំងពីរនោះនឹងអាចស្លាប់យ៉ាងរហ័ស


135

ដូច្នេះពួកទាហានក៏មកបំបាក់អ្នក១ រួច អ្នក១ទៀត ដែលជាប់ឆ្កាងជាមួយនឹងទ្រង់
ចោរទាំងពីរនោះមិនទាន់ស្លាប់ទេ ទើបបាន ជាទាហានបំបាក់ជើងគេ


136

"តែកាលគេមកដល់ ព្រះយេស៊ូវក៏ ឃើញថា ទ្រង់សុគតផុតហើយ បានជាគេ
មិនបានបំបាក់ព្រះបាទទ្រង់ទេ" យ៉ូហាន១៩:៣១-៣៣


137

ដូច្នេះពួកទាហានក៏មកបំបាក់អ្នក១ រួចអ្នក១ទៀត ដែលជាប់ឆ្កាងជាមួយនឹង ទ្រង់
ចោរទាំងពីនោះមិនទាន់ស្លាប់ទេ ទើបបានជាទាហានបំបាក់ជើងគេ


138

"តែកាលគេមកដល់ ព្រះយេស៊ូវក៏ឃើញថា ទ្រង់សុគតផុតហើយ បានជាគេមិនបានបំ
បាក់ព្រះបាទទ្រង់ទេ"
យ៉ូហាន១៩:៣១-៣៣។ រួចទាហានម្នាក់ បានចាក់ចំហៀងទ្រង់ រួចមានឈាមនិង ទឹកហូរចេញមក
ជាហេតុបញ្ជាក់ថា ទ្រង់បាន សុគត់ហើយ។


139

ព្រះយេស៊ូវបានបង់ថ្លៃសម្រាប់ការ ប្រោសលោះ និងការស្លាបនាយើងឡើង វិញ។
ពិតប្រាកដដូចបទទំនាយបានទាយជា ច្រើនសតវត្សន៍កន្លងមកមែន

១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


140

អំណោយទានដ៏ធំបំផុត ដែលព្រះអាច ប្រទានដល់មនុស្សគឺជីវិតអស់កល្ប ជ័យជំនះលើសេចក្តីស្លាប់!

អំណោយទាំងឡាយនឹងទៅជាគ្មានន័យបើ គ្មានអំណោយទាននោះទេ!

ហើយនេះជារបស់អ្នកដែលលោកអ្នក ត្រូវតែសូម!


141

សេចក្តីសម្រេចចិត្តរបស់លោកអ្នកគឺជា សេចក្តីសម្រេចចិត្តដ៏ធំ ដែលលោកអ្នកមិន ដែលបានធ្វើ អនាគតដ៏អស់កល្បរបស់ លោកអ្នក លោកអ្នកពឹងផ្អែកទៅលើអំ ណោយទាននោះ!


142

តម្លៃដ៏មិនអាចកាត់ថ្លៃបាននៃជីវិតអស់ កល្ប ត្រូវបានសន្យាដល់មនុស្សគ្រប់ៗគ្នា ដែលបានទទួលព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះ និងព្រះជាអម្ចាស់របស់គេ។ ហើយចុះតើតម្លៃប៉ុន្មានទៅ? គ្រាន់តែចិត្ត ដែលថ្វាយដាច់មួយប៉ុណ្ណោះ។

ជាចិត្តដែលស្អាត និងបានផ្លាស់ប្រែមួយ។ ចិត្តដែលមានអំនួត និងអាត្មានិយម ត្រូវ បានធ្វើឱ្យថ្មីឡើងវិញនៅជើងឈើឆ្កាង។ ព្រះគ្រីស្ទធ្វើឱ្យការទាំងនេះមានលទ្ធភាពទៅ បាននៅឯភ្នំរលាក្បាល(កាល់វ៉ារី)។

តើទ្រង់អាចធ្វើអ្វីបានថែមទៀត?


143

ជីវិតអស់កល្បអាចជារបស់អ្នក ប្រសិន បើលោកអ្នកពិតជាចង់បានវាមែន។


144

ដោយព្រោះទ្រង់រស់ យើងមានសេចក្តី សង្ឃឹមដែលពោរពេញទៅដោយសិរីល្អ សេចក្តីសង្ឃឹមដែលហួសពីផ្នូរ(សេចក្តីស្លាប់)!


145

នៅពេលព្រឹកមួយការប្រជុំជាបន្តបន្ទាប់ មួយ ត្រូវបានប្រារព្ធឡើងនៅក្នុងទីក្រុងតូចមួយនៅសហរដ្ឋអាមេរិក ប៉ែកខាងកើត។ ក្មេងប្រុសម្នាក់ចង់ចូលរួមក្នុងអង្គប្រជុំនោះ ដោយការក្រៀមក្រំយ៉ាងក្រៃលែង។

# ១៣. ពេលអ្នកស្លាប់ទៅ តើវានឹងទៅជាយ៉ាងណា?


146

អាគារប្រជុំនោះនៅជាប់កន្លែងកប់ខ្មោច មួយ។ មុនពេលចូលទៅកាន់កន្លែងដែល គេរៀបចំប្រជុំនោះ ក្មេងប្រុសនោះបានដើរ ថ្នមៗតាមកន្លែងកប់ខ្មោច។ វាបានសួរ សំនួរអំពីអត្ថន័យនៃជីវិត។

វាចង់បានការអត់ឱនទោសនិងសេចក្តី សុខសាន្តនៅក្នុងចិត្ត។

នៅពេលដែលវាបានគិតអំពីសេចក្តី ស្លាប់ វាចង់បានសេចក្តីធានារ៉ាប់រងនៃជីវិត អស់កល្បជាងអ្វីៗទាំងអស់។


147

ចំណងជើងនៃព្រះគម្ពីរដែលគេនឹង លើកយកមកបង្ហាញនៅពេលល្ងាចនោះ គឺ "សេចក្តីសង្ឃឹមហួសពីផ្នូរ" ក្មេងប្រុសនោះ បានអង្គុយស្តាប់ដោយយកចិត្តទុកដាក់។

នៅយប់នោះឯងវាបានថ្វាយជីវិតវាទៅ ព្រះគ្រីស្ទ នៅយប់នោះឯងវាទទួលព្រះ គ្រីស្ទ ដែលសុគតជំនួសវា ហើយរស់ឡើង វិញ ដើម្បីផ្តល់ជីវិតអស់កល្បដល់វា។

នៅយប់នោះឯងដែលជីវិតរបស់វាត្រូវ បានផ្លាស់ប្តូរទាំងស្រុង ដោយសារព្រះ គ្រីស្ទដ៏មានព្រះជន្មរស់នេះ។

នៅយប់នោះឯងដែលសេចក្តីសុខសាន្ត បានជនឡើងហូរហៀនៅក្នុងព្រលឹងរបស់វា។

នៅយប់នោះឯងដែលសេចក្តីសង្ឃឹមបានពុះ កញ្ជ្រោលឡើងពីក្នុងចិត្តរបស់វា។


148

លោកអ្នកអាចមានសេចក្តីសុខសាន្តនេះ មានសេចក្តីសង្ឃឹមនេះ សេចក្តីធានារ៉ាប់រង នៃជីវិតអស់កល្បនេះ ជាជីវិតហួសពីផ្នូរ។ ប្រសិនបើលោកអ្នកចង់បានសេចក្តីធានារ៉ាប់ រងនេះ សូមលោកអ្នកក្រោកឈរឡើង ឥឡូវនេះនៅពេលដែលយើងអធិស្ឋាន?

# ១៤. សម្លេងឯនាយផ្ទះ



1

តើអ្នករស់អាចនិយាយទៅកាន់អ្នកស្លាប់បានដែរឬទេ?


2

នៅពេលដែលមនុស្សស្លាប់ តើពួកគេ ត្រឡប់មកវិញជាវិញ្ញាណ ដើម្បីទៅលេងជាមួយអ្នកនៅរស់បានឬទេ?

តើវិញ្ញាណរបស់អ្នកស្លាប់ទៅហើយ អាចត្រឡប់មកនិយាយទៅកាន់អ្នកនៅរស់បានឬទេ?

នៅពេលដែលមនុស្សស្លាប់ទៅ តើ ស្លាប់តែរូបកាយ ហើយវិញ្ញាណរស់នៅ ឬយ៉ាងណា?


3

តើគ្រូខាងវិញ្ញាណនិងគ្រូស្ទឹងស្មាធ គ្រូខាបព្រលឹងខ្មោចនិងរូបអារក្ស ត្រឹម ត្រូវឬទេ នៅពេលដែលគេនិយាយថា ពួកគេអាចឱ្យយើងទាក់ទងជាមួយនឹងព្រលឹងនៃអ្នកដែលជាទីស្រឡាញ់របស់យើង ដែលបានស្លាប់ទៅហើយនោះបាន?


4

ហើយតើវិញ្ញាណរបស់អ្នកដែលស្លាប់ ទៅ អាចចូលមនុស្សរស់ ដោយប្រើប្រាស់ រូបកាយរបស់មនុស្ស សម្លេងរបស់មនុស្ស គំនិត របស់មនុស្ស ដើម្បីឱ្យធ្វើសកម្មភាព និងនិយាយបានដែរឬទេ?


5

អ្វីដែលយើងម្នាក់ៗកំពុងនិយាយនៅពេលនេះ គឺជារឿងដែលយើងធ្លាប់ជួបប្រទះដ៏មានសារសំខាន់មួយ


6

ហើយវាសំខាន់មែនទែន រហូតដល់អ្នក ខ្លះហៅថា ជាបញ្ហាស្លាប់រស់។

សេចក្តីសង្គ្រោះរបស់យើង គឺជា ផុត(ដាក់ផុត)ដ៏ធំបំផុត

ដូច្នេះយើងត្រូវតែដឹងឱ្យបានច្បាស់អំពី រឿងនេះ

ហើយតើយើងអាចដឹងបានយ៉ាងជាក់ ច្បាស់ពិតប្រាកដយ៉ាងណាបានថា បទពិសោធន៍ដែលយើងមាននោះ វាជាការពិត ឥតក្លែងក្លាយ ឬមួយជាការមិនពិត និង បណ្តោយឱ្យមានគ្រោះថ្នាក់?


7

ចម្លើយគឺថា មាននៅក្នុងព្រះគម្ពីរ ព្រះ យេស៊ូវបានប្រទានសេចក្តីពិតដល់យើង!

# ១៤. សម្លេងឯនាយផ្នូរ


8

ព្រះយេស៊ូវជាមិត្តសំឡាញ់របស់យើង។
ទ្រង់យល់នូវអ្វីដែលយើងកំពុងតែជួបប្រទះ
នៅពេលដែលយើងបាត់បង់អ្នកដែលជាទីស្រឡាញ់ណាម្នាក់ នៅក្នុងជ្រោះនៃសេចក្តីស្លាប់
ទ្រង់ត្រូវបានទទួលរងនូវទុក្ខសោករបស់យើង។ ទ្រង់បាននៅទីនោះ។
ដូច្នេះ យើងនឹងត្រឡប់ទៅឯព្រះយេស៊ូវ ដើម្បីឱ្យដឹងថា តើទ្រង់បានមានព្រះបន្ទូល
ថាយ៉ាងដូចម្តេចអំពីសេចក្តីស្លាប់ ការរស់ ឡើងវិញ និងជីវិតអស់កល្ប។
ប្រសិនបើព្រះយេស៊ូវមានព្រះបន្ទូលពី ការនោះ ជីវិតរបស់ខ្ញុំអាចទុកចិត្តទៅលើ ការនោះបាន។
នោះនឹងចប់សព្វគ្រប់ហើយ។ តើលោក អ្នកអាចយល់ដែរឬទេ?


9

តើលោកអ្នកអរគុណដល់ព្រះយេស៊ូវ
ឬទេ?
ទ្រង់ត្រូវបានរងនូវទុក្ខព្រួយរបស់យើង។


10

(ព្រះគម្ពីរ យ៉ូហាន ១១:៣៥)
នៅឯការបញ្ចុះសពមិត្តរបស់ទ្រង់ ព្រះគម្ពីរនិយាយថា "ព្រះយេស៊ូវ ក៏ទ្រង់ ព្រះកន្សែង"
យ៉ូហាន ១១:៣៥។
ទ្រង់បាននៅឯជ្រោះនៃស្រមោលរបស់ សេចក្តីស្លាប់ ដោយព្រះអង្គឯង។


11

(ព្រះគម្ពីរ វិវរណៈ ១:១៧,១៨)
"...កុំខ្លាចអ្វីឡើយ អញជាដើម ហើយ ជាចុង


12

ជាព្រះដ៏រស់នៅ អញបានស្លាប់ តែ មើល អញរស់នៅអស់កល្បជានិច្ចរៀងរាប តទៅ។ អាម៉ែន


13

អញក៏មានកូនសោនៃសេចក្តីស្លាប់ និង ស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ"
វិវរណៈ:១:១៧,១៨។
ការដែលលើសពីនេះទៅទៀតនោះ គឺ ព្រះយេស៊ូវជាអ្នកផ្តល់ជីវិត។
ទ្រង់បានយាងមកដើម្បីឱ្យយើងមានជីវិត ថ្មីយ៉ាងពិតប្រាកដនៅពេលឥឡូវនេះ។

# ១៤. សម្លេងឯនាយផ្នូរ


14

(ព្រះគម្ពីរ យ៉ូហាន ១០:១០)

"...តែឯខ្ញុំវិញ ខ្ញុំបានមក ដើម្បីឱ្យវា រាល់គ្នាមានជីវិត ហើយឱ្យមានជីវិតនោះ ពេញបរិបូរផង"
យ៉ូហាន ១០:១០

ទ្រង់សន្យានូវជីវិតដែលបានស្លាបនា ឡើងវិញយ៉ាងបរិបូរដ៏អស់កល្បជានិច្ច


15

(ព្រះគម្ពីរ យ៉ូហាន ១១:២៥)

"ព្រះយេស៊ូវបានមានបន្ទូលទៅនាងថា "ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត
អ្នកណាដែលជឿដល់ខ្ញុំ ទោះជាបានស្លាប់ ហើយ គង់តែនឹងរស់ឡើងវិញដែរ"
យ៉ូហាន ១១:២៥

ព្រះយេស៊ូវគឺជាអ្នកឯកទេសខាងជីវិត។
ទ្រង់ជ្រាបពីជីវិតនេះជាងអ្នកណាទាំងអស់នៅ
លើលោកសន្និវាសនេះ ពីព្រោះទ្រង់បានបង្កើត ជីវិតនៅលើភពនេះ។


16

(ព្រះគម្ពីរ យ៉ូហាន១:១,៣)

"កាលដើមដំបូងឡើយមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយ
ព្រះបន្ទូលនោះឯងជាព្រះ"


17

គ្រប់របស់ទាំងអស់បានកើតមកដោយ សារទ្រង់ ហើយក្នុងបណ្តារបស់ដែលបាន
កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយ កើតមកក្រៅពីទ្រង់ឡើយ"
យ៉ូហាន១:១,៣


18

(ព្រះគម្ពីរ កូល៉ុស ១:១៦)

"ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ ទាំងអស់នោះសុទ្ធតែកើតមកដោយសារទ្រង់
ហើយសំរាប់ទ្រង់ទាំងអស់ផង"
កូល៉ុស ១:១៦


19

វាជាការសំខាន់នៅលើចំណុចនេះ ដើម្បីរំលឹកនូវអ្វីដែលយើងបានរៀន ជា ច្រើនមកហើយនៅក្នុង
ខ្សែមេរៀននេះ។
ព្រះយេស៊ូវបានបញ្ជាក់យ៉ាងច្បាស់ថា ការ ស្លាប់មិនមែនជាជីវិតទេ ឬមួយក៏វាជាការ
បន្តជីវិតនៅក្នុងទម្រង់ ណាមួយទៀតនោះ ក៏ទេដែរ។

# ១៤. សម្លេងឯនាយផ្នូរ


20

(ខព្រះគម្ពីរ យ៉ូហាន ១១:១១)

ព្រះយេស៊ូវបានមានព្រះបន្ទូលអំពី សម្លាញ់ទ្រង់ដែលបានស្លាប់នោះថា "ឡាសារសំឡាញ់ខ្ញុំដេកលក់ហើយ..."

យ៉ូហាន ១១:១១។

ទ្រង់បានមានព្រះបន្ទូលអំពីបុរសម្នាក់ ដែលបានស្លាប់ហើយ។

សូមកត់សំគាល់អំពីការដែលព្រះយេស៊ូវ ពណ៌នាអំពីសេចក្តីស្លាប់ "ដេកលក់" វាជាការប្រៀបប្រដូចយ៉ាងត្រឹមត្រូវបំផុតនៅក្នុងព្រះគម្ពីរអំពីសេចក្តីស្លាប់។


21

(ព្រះគម្ពីរ យ៉ូហាន ១១:១៤)

ដោយសិស្សរបស់ទ្រង់នៅតែមិនយល់ ព្រះយេស៊ូវបានមានព្រះបន្ទូលបញ្ជាក់យ៉ាង ច្បាស់ថា "ឡាសារស្លាប់ ហើយ"

យ៉ូហាន ១១:១៤។

ឡាសារមិននៅរស់ជាទ្រង់ទ្រាយណា មួយទៀតនៅកន្លែងណាមួយឡើយ។


22

គាត់បានស្លាប់ទៅហើយ ហើយសព គាត់ត្រូវបានបញ្ចុះនៅក្នុងផ្នូរ ព្រះយេស៊ូវបានបង្រៀនបន្តទៀតយ៉ាងច្បាស់ថា នឹង គ្មានជីវិតទេ ក្រោយពីស្លាប់ទៅ រហូតដល់ ការរស់ឡើងវិញ ហើយទ្រង់បានបញ្ជាក់ ឱ្យកាន់តែច្បាស់ថែមទៀត អំពីការរស់ឡើងវិញនៅពេលអនាគតខាងមុខនោះថា


23

(ព្រះគម្ពីរ យ៉ូហាន ៦:៤០)

"នេះហើយជាបំណងព្រះហឫទ័យនៃ ព្រះវរបិតាខ្ញុំ គឺឱ្យអ្នកណាដែលបានឃើញ ព្រះរាជបុត្រា


24

ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់ កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញនៅថ្ងៃចុងបំផុត"

យ៉ូហាន ៦:៤០


25

ចិត្តរបស់យើងត្រូវបានពុះកញ្ច្រោល នៅពេលដែលយើងរៀនអំពីការយាងមកវិញ របស់ព្រះយេស៊ូវ នៅក្នុងការយាងមកជា លើកទីពីររបស់ទ្រង់។

គោលបំណងរបស់ទ្រង់ច្បាស់លាស់ ហើយបញ្ចាំងពន្លឺជាខ្លាំងក្រៃលែង ទៅលើប្រធានបទនៃការរស់និងស្លាប់នេះ។

តើហេតុអ្វីបានជាទ្រង់យាងមកវិញ?

# ១៤. សម្លេងឯនាយផ្ទូរ


26

(ព្រះគម្ពីរ យ៉ូហាន ១៤:១-៣)

"កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ ខ្ញុំដែរ"


27

"នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំមានទី លំនៅជាច្រើន ពុំនោះខ្ញុំបានប្រាប់អ្នករាល់ គ្នាហើយ ខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា"


28

បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះ ខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នា ទៅឯខ្ញុំ


29

ប្រយោជន៍ឱ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ"

យ៉ូហាន១៤:១-៣


30

ព្រះយេស៊ូវបានពិពណ៌នាអំពី

ព្រឹត្តិការណ៍ដ៏ធំសំបើមនេះដោយផ្ទាល់ព្រះអង្គ


31

(ព្រះគម្ពីរ ម៉ាថាយ ២៤:៣០,៣១)

"នោះទីសំគាល់របស់កូនមនុស្សនឹង លេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្ស នៅផែនដីនឹងគក់ទ្រូងយំ


32

ក៏នឹងឃើញកូនមនុស្សមកលើពពកនៅលើ មេឃ មានទាំងព្រះចេស្តា និងសិរីល្អជា ខ្លាំង"


33

ហើយលោកនឹងចាត់ពួកទេវតារបស់ លោក ឱ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូល ពួករើសតាំង របស់លោក ពីទិសទាំងបួន

# ១៤. សម្លេងឯនាយផ្ទរ


34

ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើង មេឃម្ខាង
ម៉ាថាយ ២៤:៣០,៣១


35

តើហេតុអ្វីបានជាមានសម្លេងត្រែ? ហេតុអ្វីបានជាមានទេវតា?


36

ដើម្បីដាស់អ្នកដែលបានរើសតាំងពីការ ដេកលក់នៃសេចក្តីស្លាប់ ហើយដើម្បីប្រ មូលពួកគេ
នឹងយកឡើងទៅនគរស្ថានសួគ៌ ជាកន្លែងដែលព្រះយេស៊ូវបានរៀបចំទុក
សម្រាប់អស់អ្នកណាដែលស្រឡាញ់ទ្រង់។
ការយាងមករបស់ព្រះអម្ចាស់ត្រូវបានពិពណ៌ នាលំអិតយ៉ាងជាក់លាក់ ។


37

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៣-១៨)
"បងប្អូនអើយ ខ្ញុំមិនចង់ឱ្យអ្នករាល់គ្នា ឥតដឹងពីពួកអ្នកដែលដេកលក់ទៅហើយទេ


38

ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯ ទៀតដែលគ្មានសង្ឃឹម


39

ដ្បិតបើយើងជឿថា ព្រះយេស៊ូវបាន សុគត ព្រមទាំងរស់ឡើងវិញហើយ នោះ ត្រូវជឿថា
ព្រះទ្រង់នឹងនាំអស់អ្នក ដែល ដេកលក់នៅក្នុងព្រះយេស៊ូវ ឱ្យបានមកជា មួយនឹងទ្រង់ដែរ


40

ដ្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នា តាម ព្រះបន្ទូលនៃព្រះអម្ចាស់ដូច្នេះ ថាយើង ដែលរស់នៅជាប់


41

ដរាបដល់ព្រះអម្ចាស់យាងមក នោះយើង មិនទៅមុនពួកអ្នក ដែលបានដេកលក់ទៅ ហើយនោះទេ

# ១៤. សម្លេងឯនាយផ្ទូរ


42

ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពី ស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា


43

និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះ គ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់


44

រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏ នឹងបានលើកឡើងនៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់នៃ យើងនៅនាអាកាស។


45

យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះ អម្ចាស់ជាដរាបតទៅ


46

ដូច្នេះចូរកំសាន្តចិត្តគ្នាទៅវិញទៅមក ដោយដំណើរនេះចុះ”
ថែស្សាឡូនីចទី១ ៤:១៣_១៨


47

សូមកត់សំគាល់នូវសេចក្តីពិតដ៏សំខាន់ បី ដែលបានបញ្ជាក់នៅទីនេះ


48

១. ការនេះយោងទៅតាម “ព្រះបន្ទូល របស់ព្រះជាម្ចាស់ផ្ទាល់” នេះគឺជាការដែល ព្រះយេស៊ូវបានបង្រៀនដោយព្រះអង្គផ្ទាល់ ហើយទុកជារឿងសំខាន់ដល់យើង។

# ១៤. សម្លេងឯនាយផ្នូរ


49

២. គ្រីស្ទានទាំងឡាយណាដែលនៅមាន ជីវិតរស់នៅ នៅពេលដែលព្រះយេស៊ូវ យាងមកវិញ ត្រូវបានយកទៅជាមួយគ្នា នឹងអ្នកដែលបានលើកពីសេចក្តីស្លាប់ នាគ្រាយាងមកជាលើកទីពីររបស់ព្រះ យេស៊ូវ។

អ្នកដែលរស់នៅនឹងមិនបានទៅស្ថាន សួគ៌មុនអ្នកដែលបានដេកលក់ក្នុងព្រះ យេស៊ូវទេ ឬក៏អ្នកដែលស្លាប់ទៅហើយបាន ទៅស្ថានសួគ៌ម្តងមួយៗ នៅពេលដែល គេស្លាប់នោះឡើយ។


50

៣. "ដេកលក់" គឺជាពាក្យដែលបានប្រើ ដោយព្រះយេស៊ូវនិងលោកប៉ុល ដើម្បីនឹង ពណ៌នាអំពីសេចក្តីស្លាប់ មុនពេលការ រស់ឡើងវិញ "ការដេកលក់ក្នុងទ្រង់ (ព្រះយេស៊ូវ)"។

ព្រះយេស៊ូវបញ្ជាក់យ៉ាងច្បាស់លាស់ខ្លាំង មែនទែនថា ការស្លាប់មិនមែនជាជីវិតដែល ដឹងខុសត្រូវនោះទេ។

គ្មានការដឹងអ្វីទាំងអស់នៅក្នុងការស្លាប់។ ការដឹងខុសត្រូវ គឺជាដំណើរការនៃគំនិត ហើយនៅពេលស្លាប់ ដំណើរការនេះនឹង ត្រូវចប់។


51

(ព្រះគម្ពីរ សាស្តា ៩:៥)

ត្រង់នេះព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ "ដ្បិតមនុស្សដែលរស់ គេនឹងដឹងថា ខ្លួន នឹងស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹង អ្វីឡើយ"

សាស្តា ៩:៥


52

តើអ្នកដែលស្លាប់ទៅនោះដឹងបាន ប៉ុនណា? "ឥតដឹងអ្វីទាំងអស់"

ហេតុនេះហើយបានជាមនុស្សស្លាប់ មិនអាចទាក់ទងជាមួយមនុស្សរស់បាន។ តើជំនឿដែលថា មនុស្សនៅរស់ក្រោយពី សេចក្តីស្លាប់នោះមកពីណា?


53

(ព្រះគម្ពីរ យ៉ូប ៧:៩,១០)

ព្រះគម្ពីរបង្រៀនយ៉ាងណា ពីលក្ខណៈ ឥតដឹងអ្វី របស់មនុស្សស្លាប់ លោកយ៉ូប បានបញ្ជាក់យ៉ាងច្បាស់លាស់ថា "អ្នកណា ដែលចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះមិនដែល ឡើងមកវិញឡើយ ឧបមា ដូចជាពពកដែលរលាយទៅ ហើយមើល មិនឃើញទៀត។

យ៉ូប៧:៩


54

"អ្នកនោះនឹងមិនដែលត្រឡប់មកឯផ្ទះ ខ្លួនទៀតឡើយ ទីកន្លែងរបស់គេក៏នឹងលែង ស្គាល់គេផង"

យ៉ូប ៧:១០

# ១៤. សម្លេងឯនាយផ្នូរ


55

សេចក្តីជំនឿបែបនោះមកតែពីអារក្សខ្លួន ឯងប៉ុណ្ណោះ"។

នៅក្នុងសួនច្បារអេដែន វាបានបញ្ឆោត នាងអេវ៉ានិងប្តីរបស់នាង ឱ្យបាត់បង់លំនៅក្នុងសួនច្បារនិងជីវិតអស់កល្បរបស់គេ។

សាតាំងបានប្រើវិធីហៅខ្មោចដើម្បីទាក់ទងជាមួយនឹងនាងអេវ៉ា ដោយប្រើសត្វពស់ជាមេរូប(ចូលរូប)ក្នុងការនិយាយ។ វាជាមេនៃ អ្នកល្បួង។


56

(ព្រះគម្ពីរ លោកុប្បត្តិ ៣:៤)

នាងបានជឿការកុហករបស់សាតាំងថា "នាងនឹងមិនស្លាប់ជាប្រាកដ" លោកុប្បត្តិ៣:៤។


57

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៧)

ការកុហកនេះគឺជាការនិយាយប្រឆាំង ដោយត្រង់ទៅនឹងសេចក្តីពិតរបស់ព្រះថា "...នោះនឹងត្រូវស្លាប់ជាមិនខាន"។

លោកុប្បត្តិ ២:១៧។

នេះគឺជាបញ្ហាសំខាន់ តើយើងត្រូវជឿលើអ្នក ណា?


58

គ្រូស្ទីងស្មាធម្នាក់ និយាយថា "វាមានលទ្ធភាពអាច និយាយជាមួយនឹង អ្នកដែលជាទីស្រឡាញ់ ដែលបានបាត់បង់ ទៅហើយនោះបាន" (ហើយពាក្យនេះ ក៏ត្រូវបានគ្រូមន្តអាគម ជាច្រើននៅលើពិភពលោកនេះនិយាយ ដូច្នោះដែរ)

តើវាត្រឹមត្រូវឬទេ? តើវាអាចទៅរួច ឬទេ? ទេ។


59

ពីការបង្រៀនរបស់ព្រះយេស៊ូវ យើង ដឹង យ៉ាងប្រាកដប្រជាថា អ្នករស់នៅមិន អាចទាក់ទងជាមួយនឹងអ្នកដែលស្លាប់ទៅ បានទេ។

ហេតុអ្វីបានជាមិនបាន? "ព្រោះអ្នក ស្លាប់មិនដឹងអ្វីទាំងអស់"

ពួកគេកំពុងដេកលក់ក្នុងការស្លាប់ដោយ ឥតដឹងអ្វីសោះឡើយ។

ប្រសិនបើលោកអ្នកកំពុងទាក់ទងជា មួយវិញ្ញាណនោះ លោកអ្នកប្រហែលជានឹងសួរដោយថប់បារម្ភថា


60

ប្រសិនបើអ្នកស្លាប់មិនដឹងអ្វីទាំងអស់ តើអ្នកណាជាវិញ្ញាណដែលនិយាយជាមួយ មនុស្សរស់"

# ១៤. សម្លេងឯនាយផ្ទះ


61

ព្រះគម្ពីរប្រាប់យ៉ាងច្បាស់ថាវាជានរណា។


62

(ព្រះគម្ពីរ វិវរណៈ ១៦:១៣,១៤)
"រួចខ្ញុំឃើញវិញ្ញាណអាសោចិ៍៣ដូចជា
កង្កែបចេញពីមាត់នាគ(សាតាំង)


63

មាត់សត្វ និងពីមាត់ ហោរាក្លែងក្លាយមក


64

ដ្បិតវិញ្ញាណទាំងនោះជាវិញ្ញាណនៃពួក អារក្ស(ទេវតាដែលធ្លាក់ចុះ) ដែលចេញ
ទៅឯអស់ទាំងស្តេច នៅផែនដីទាំងមូល ទាំងធ្វើទីសំគាល់


65

ដើម្បីនឹងប្រមូលស្តេចទាំងនោះមកក្នុងចម្បាំង
នៅថ្ងៃដ៏ធំរបស់ព្រះដ៏មានព្រះចេស្តាបំផុត"
វិវរណៈ ១៦:១៣,១៤


66

ព្រះគម្ពីរមិនគ្រាន់តែបង្ហាញឱ្យដឹងថា វាជានរណានោះទេ ប៉ុន្តែថែមទាំងបាន ប្រាប់ថា
វាមកពីណាទៀតផង:


67

(ព្រះគម្ពីរ វិវរណៈ ១២:៧-៨)
"នោះមានចំបាំងនៅលើមេឃ គឺ មីកែល និងពួកទេវតារបស់លោកច្បាំង នឹងនាគ
ហើយនាគនិងទេវតា វាក៏ច្បាំង នឹងលោកដែរ


68

តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែង ណាឱ្យវានៅលើមេឃទៀតផង

# ១៤. សម្លេងឯនាយផ្នូរ



69

នោះនាគធំត្រូវបោះទម្លាក់ទៅ គឺជាពស់ ពីបុរាណ ដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកីយ៍ ទាំងមូលឱ្យវង្វេងចេញ



70

វាត្រូវបានទំលាក់ទៅផែនដីវិញ ព្រមទាំង ពួកទេវតារបស់វាផង"
វិវរណៈ ១២:៧-៩


71

ពួកវាជាទេវតាដែលបានធ្លាក់មក! មិត្ត ទាំងឡាយអើយ សូមប្រុងប្រយ័ត្ន! វាគឺជាការមួយដែលមានគ្រោះថ្នាក់ជាទីបំផុត ប្រសិនបើអ្នកធ្លាប់ធ្វើអ្វីដែលទាក់ទងនឹង "វិញ្ញាណ"នេះ។

បំណងតែមួយគត់របស់ពួកវា ខ្ញុំនិយាយ ម្តងទៀត បំណងតែមួយគត់របស់ពួកវា គឺដើម្បីបញ្ឆោតលោកអ្នក ហើយនិងបង្វែរ អ្នកឱ្យឆ្ងាយពីព្រះយេស៊ូវ និងបណ្តាលឱ្យអ្នកបាត់បង់នូវសេចក្តីសង្គ្រោះដ៏អស់កល្បតែ ប៉ុណ្ណោះ។


72

វាអាចធ្វើឱ្យអ្នកបះសក់ និងព្រឺខ្នង ហើយធ្វើឱ្យអ្នកកាន់តែខិតឆ្ងាយពី "វិញ្ញាណ" នោះខ្លាំងឡើង

ប្រសិនបើអ្នកជឿថាវិញ្ញាណរបស់អ្នកស្លាប់ ទៅនៅរស់ លោកអ្នកបានបើកចិត្តយ៉ាងធំ ទទួលការបោកបញ្ឆោត និងត្រូវបាត់បង់ ហើយពីព្រោះអ្នក នឹងត្រូវទទួលការបោក បញ្ឆោតធំជាងនេះទៅទៀត!


73

នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ព្រះបាន ចោទប្រកាន់យ៉ាងច្បាស់ដល់អ្នកជឿលើវិញ្ញាណខ្មោច ហើយទ្រង់បានហាមប្រាមការប៉ុន ប៉ងទាំងឡាយរបស់មនុស្ស ក្នុងការទាក់ទង ជាមួយនឹងមនុស្សស្លាប់។

សូមកត់សំគាល់នូវការព្រមានដែលព្រះ បានធ្វើដល់រាស្ត្ររបស់ទ្រង់ អំពីការទូន្មានមនុស្សម្នាក់ដែលខំព្យាយាម និយាយទៅ កាន់ "គ្រូខាប"។


74

(ព្រះគម្ពីរ លេវីវិន័យ ១៩:៣១)
លេវីវិន័យ ១៩:៣១ "កុំឱ្យឯងរាល់គ្នាបែរ ទៅតាមគ្រូខាប ឬគ្រូមន្តគាថាឡើយ កុំឱ្យពឹងរកគេឱ្យសោះ ក្រែងឯងទៅជាស្មោក គ្រោកដោយសារគេដែរ

# ១៤. សម្លេងឯនាយផ្ទះ


75

អញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា”


76

(ព្រះគម្ពីរ ចោទិយកថា ១៨:១០-១២)

មុនពួកអ៊ីស្រាអែលបានទៅស្រុក កាណាន ពួកគេត្រូវបានប្រាប់យ៉ាងតឹងរឹង ថា “នៅក្នុងពួកឯង មិនត្រូវឱ្យមានអ្នក ណាមួយដែល...


77

ឆ្លងកាត់ភ្លើង ឬគ្រូទាយ គ្រូគន់គុនក្ខត្ត

ឬក្ស គ្រូអង្គុយធម៌ គ្រូអាបធ្មប់ គ្រូ សន្ទាប់ គ្រូខាប គ្រូគាថា ឬគ្រូអន្ទង ខ្មោច ណាឡើយ


78

ដ្បិតអ្នកណាដែលប្រព្រឹត្តការទាំងនោះ ជាការស្អប់ខ្ពើមដល់ព្រះណាស់...”

ចោទិយកថា ១៨:១០-១២

ព្រះទ្រង់ជ្រាបថា មនុស្សដែលឱ្យ យោបល់ដោយគ្រូខាប នឹងនាំរាស្ត្រទ្រង់

ទៅកាន់ភាពគ្មានអ្នកដឹកនាំ ដូច្នោះទើបទ្រង់ បានប្រាប់ពួកគេយ៉ាងដូច្នេះថា


79

(ព្រះគម្ពីរ និក្ខមនំ ២២:១៨)

“កុំឱ្យទុកស្ត្រីដែលជាគ្រូអាបធ្មប់នៅរស់ ឡើយ” និក្ខមនំ ២២:១៨


80

ការពិសោធន៍របស់ស្តេចសូលក្នុងការ សួរយោបល់ពីការបង្ហាញរបស់អ្នកខាប វិញ្ញាណ

ជាការខំប្រឹងប្រែង និយាយទៅ កាន់អ្នកស្លាប់ទាំងងងើល។


81

(ព្រះគម្ពីរ របាក្សត្រទី១ ១០:១៣)

“ដូច្នេះសូលបានសុគត ដោយព្រោះ អំពើដែលទ្រង់បានប្រព្រឹត្តរំលងទាស់នឹងព្រះយេហូវ៉ា...


82

ហើយដោយព្រោះទ្រង់បានសួរសំនួរពីស្រី គ្រូខាប” របាក្សត្រទី១ ១០:១៣

# ១៤. សម្លេងឯនាយផ្នូរ


83

សាតាំងខ្លួនឯងនឹងប៉ុនប៉ងក្លែងធ្វើជាព្រះ យេស៊ូវផ្ទាល់។


84

(ព្រះគម្ពីរ កូរិនថូសទី២ ១១:១៤)

"ហើយសេចក្តីនោះមិនជាអស្ចារ្យឡើយ ព្រោះអារក្សសាតាំង ក៏ក្លែងខ្លួនធ្វើជាទេវតា នៃពន្លឺដែរ" កូរិនថូសទី២ ១១:១៤។


85

តើលោកអ្នកឆ្ងល់ទេថា តើហេតុអ្វីបាន ជាមនុស្សម្នាក់ អាចនិយាយជាមួយម្នាក់ ទៀតដែល ជាអ្នកដែលគេធ្លាប់ស្គាល់មុន ពេលគេស្លាប់ទៅនោះ ទាំងសំឡេង ពាក្យ សំដី និងកាយវិការបាន?

ព្រះគម្ពីរប្រាប់ថា ព្រោះសាតាំង "និង ទេវតារបស់វាក្លែងបន្លំ"


86

វាអាចក្លែងបន្លំធ្វើជាអ្នកដែលធ្លាប់មាន ជីវិតរស់នៅណាមួយក៏បាន ។

វាគឺជាការដ៏គួរឱ្យភ័យខ្លាចមួយយ៉ាងពិត ប្រាកដ នៅពេលដែលយើងគិតថា មនុស្សល្អក៏អាចត្រូវបានបញ្ឆោត និងទាញ ឱ្យចូលទៅក្នុងកណ្តាប់ដៃរបស់សាតាំងនៅ ពេលដែលគេគិតថា គេកំពុងនិយាយជា មួយមនុស្សជាទីស្រឡាញ់ម្នាក់ដែលបានស្លាប់ ទៅនោះ!


87

ប៉ុន្តែបទព្រះគម្ពីរនេះបង្ហាញឱ្យឃើញ កាន់ តែគួរឱ្យខ្លាចជាងនេះទៅទៀត សាតាំងខ្លួនឯងនឹងខំរិះរកវិធីធ្វើការក្លែងបន្លំ ឱ្យដូចជាព្រះយេស៊ូវ។

តើលោកអ្នកអាចស្រមៃមើលបានទេថា តើមានមនុស្សច្រើនប៉ុណ្ណាដែលនឹងត្រូវបាន បោកបញ្ឆោត ដោយពួកគេមិនដឹងអំពីការ ពិតនៃការយាងមករបស់ព្រះយេស៊ូវនោះ?

តើវាមានការអស្ចារ្យឬទេ ដែលព្រះយេស៊ូវ បានប្រទានការប្រកាសឱ្យដឹងដ៏សំខាន់អំពី ការនេះ?


88

(ព្រះគម្ពីរ ម៉ាថាយ ២៤:៤,៥)

"ព្រះយេស៊ូវទ្រង់មានបន្ទូលឆ្លើយថា ចូរប្រយ័ត្នក្រែងអ្នកណានាំអ្នករាល់គ្នាឱ្យ វង្វេង"


89

ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះ ខ្ញុំមកនិយាយថា ខ្ញុំនេះជាព្រះគ្រីស្ទ ហើយ អ្នកទាំងនោះនឹងនាំមនុស្សជាច្រើនឱ្យវង្វេង ចេញផង"

ម៉ាថាយ ២៤:៤,៥

រឿងនេះសំខាន់ខ្លាំងមែនទែន បានជា

# ១៤. សម្លេងឯនាយផ្នូរ



90

ព្រះយេស៊ូវបានរំលឹកដំណឹងនេះម្តង ទៀត នៅក្នុងសេចក្តីអធិប្បាយដដែល




91

(ពះគម្ពីរ ម៉ាថាយ ២៤:២៣-២៥)

"គ្រានោះ បើអ្នកណាប្រាប់អ្នករាល់ គ្នាថា មើលព្រះគ្រីស្ទគង់នៅទីនេះ ឬនៅទីនោះ នោះកុំឱ្យជឿគេឡើយ




92

ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយហោរា ក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងនាំទាំង




93

អ្នករើសតាំងឱ្យវង្វេងផង បើសិនជាបាន




94

មើលខ្ញុំបានប្រាប់អ្នករាល់គ្នាជាមុន"

ម៉ាថាយ ២៤:២៣-២៥



95

ប៉ុន្តែប្រហែលមានអ្នកខ្លះនិយាយថា ឬ ក៏អ្នកប្រហែលជាស្គាល់មនុស្សខ្លះដែល និយាយថា "ខ្ញុំបានឃើញអ្នកជាទីស្រឡាញ់ ម្នាក់នៅរស់"



96

អ្នកខ្លះទៀតអាចនឹងនៅតែចចេសថា "ខ្ញុំបាននិយាយជាមួយប្តីខ្ញុំដែលបានស្លាប់ទៅ"

# ១៤. សម្លេងឯនាយផ្ទះ


97

ហើយនៅតែមានអ្នកខ្លះទៀតនិយាយថា "ខ្ញុំបានបាត់កូនខ្ញុំក្នុងការប្រយុទ្ធនៃអំពើភារវកម្មមួយ ប៉ុន្តែខ្ញុំបានជួបវា និយាយទៅកាន់វា ហើយវាធ្វើឱ្យខ្ញុំរីករាយជាខ្លាំង"

តើព្រះយេស៊ូវបានមានព្រះបន្ទូលថាយ៉ាងដូច ម្តេច?

ថាអ្នកស្លាប់គឺដេកលក់ ហើយថា "វិញ្ញាណ" នោះនឹងបញ្ឆោត ទាំងអ្នករើស តាំងឱ្យវង្វេងផងបើសិនជាបាន។

មនុស្សរាប់លាននាក់នឹងត្រូវបានបញ្ឆោត។

តើហេតុអ្វី? ពីព្រោះពួកគេទុកចិត្តលើ អារម្មណ៍របស់គេ វិញ្ញាណរបស់គេ និង ការពិសោធន៍របស់គេជាងព្រះបន្ទូលរបស់ ព្រះ។


98

តើហេតុអ្វីបានជាអ្នករើសតាំងមិនត្រូវ បានបញ្ឆោត?

ពីព្រោះគេជឿលើព្រះយេស៊ូវ។

ពួកគេទុកចិត្តលើព្រះបន្ទូលដ៏ពិតរបស់ ព្រះជាងវិញ្ញាណ អារម្មណ៍ និងការ ពិសោធន៍របស់ពួកគេ។



99

នេះគឺជាបញ្ហាសំខាន់


100

តើយើងទទួលការពិតរបស់ព្រះ


101

ឬក៏យើងជឿការកុហករបស់សាតាំង?


102

មានតែអ្នកដែលបានការពារគំនិតរបស់ ខ្លួនដោយព្រះបន្ទូលនៃព្រះគម្ពីរទេ ដែល អាចឈរប្រឆាំងនឹង ជមនោរនៃការ បោកបញ្ឆោត ដែលកំពុងជោរជន់លើផែន ដីនេះរួចមកហើយនោះបាន។

យើងត្រូវតែដឹង និងជឿលើការទាំង អស់នេះ ដោយការតាំងចិត្តយ៉ាងមាំទាំជា ស្រេច និងមិនអនុញ្ញាតឱ្យការពិសោធន៍ ណា អារម្មណ៍ណា ឬការលេចឡើងណា មករារាំងយើងពីសេចក្តីពិតឡើយ។

# ១៤. សម្លេងឯនាយផ្នូរ


103

ប្រហែលជាអ្នកបានឮលំអំពីបទ ពិសោធន៍នៃការ "ភ្ញឹក" ដែលមនុស្សត្រូវ បានគេថ្លែងប្រាប់ថា បានស្លាប់ ពិតប្រាកដ ហើយត្រូវបានដឹងខ្លួនវិញនោះ!


104

ហើយរាយការណ៍មកថា គេបានឃើញខ្លួន គេ សំកាំងនៅក្នុងបន្ទប់នៃមន្ទីរពេទ្យ សំឡឹងមើលទៅក្រោមទៅរករូបកាយរបស់គេ


105

ឬក៏គេបានឃើញពន្លឺដ៏ភ្លឺចាំង និងព្រះ យេស៊ូវ ឬទេវតាបោយដៃហៅគេឱ្យមក។

ខ្លះទៀតបានរាយការណ៍មកថា បាន ឃើញអ្នកដែលជាទីស្រឡាញ់ ហើយដែល បានស្លាប់ទៅហើយនោះ

មានតែដោយសារព្រះបន្ទូលរបស់ព្រះទេ ដែលអាចរកឱ្យដឹងនូវការកុហក និងការ ពារយើងពីការបោកបញ្ឆោតនេះ។



106

ការនិយាយថា "ឃើញ ទើបជឿ "ខ្ញុំនឹងជឿរឿងនោះ នៅពេលដែលខ្ញុំ ឃើញវាផ្ទាល់នឹងភ្នែកខ្ញុំ"។ នោះពិតជាផ្លូវ មួយដែលនាំទៅរកការចាញ់ការបោក បញ្ឆោតហើយ។


107

យើងអាចធ្វើការសម្រេចចិត្តដ៏ស្លាប់រស់ មួយ នៅពេលដែលយើងពឹងផ្អែកលើ វិញ្ញាណរបស់យើង អារម្មណ៍របស់យើង និងការពិសោធន៍របស់យើង ជាជាងពឹង លើព្រះបន្ទូលរបស់ព្រះ ព្រះគម្ពីរនោះ។

មានជំនឿខុសឆ្គងជាច្រើនដែលបញ្ចុះ បញ្ចូលអ្នកស្លាប់ទាំងឡាយនៅទូទាំងពិភព លោកនេះ។



108

ឧទាហរណ៍ដូចជាការចាប់ជាតិ។

មនុស្សរាប់លាននាក់ជឿថា នៅពេល ដែលមនុស្សស្លាប់ គេនឹងកើតឡើងវិញក្នុង រូបរាងថ្មីមួយទៀត ដែលគេមិនដែលបាន ដឹងថា ជារូបកាយយ៉ាងណានោះ។

គេជឿថា វាអាចកើតមានជាពិតប្រាកដ ជាសត្វ ដូចជាគោ កណ្ដុរ ឬពស់ជាដើម។


109

ឬមួយក៏កើតជាមនុស្សម្នាក់ទៀត ដែល អាចក្លាយទៅជាអ្នកមាន ជាស្ដេច ឬជា អ្នកក្រ ឬជាអ្នកសុំទាន ឬមួយក៏ ថ្លង់ ខ្វាក់ភ្នែក ឬពិកា ឬមួយក៏មានជម្ងឺ ឈឺ ចាប់ ឬជម្ងឺដែលធ្វើឱ្យពិកា។

# ១៤. សម្លេងឯនាយផ្ទះ


110

សាសនាហិណ្ឌូបង្រៀនថា មាន "កង់ជីវិត" ដែលវិលចុះវិលឡើងជានិច្ច ហើយនៅពេលដែលមនុស្សម្នាក់ស្លាប់ គេនឹងរស់ឡើងវិញ ហើយនឹង គ្មានការបញ្ចប់នៃការដដែលៗនេះពីពិភពលោកនេះ ឡើយ។

មនុស្សជាច្រើនត្រូវបាននាំឱ្យចង់ដឹងចង់ ឮ ដោយមិនបានដឹងច្បាស់អំពីគំនិតដែលអាចនៅពីក្រោយការទាំងនោះឡើយ។

នៅក្នុងជំនឿនេះ មនុស្សម្នាក់ៗមិន មានការគ្រប់គ្រងវាសនាខ្លួនឯងឡើយ គ្មានការជ្រើសរើសឡើយ និងក៏គ្មាន ការសម្រេចចិត្តដែរ។



111

គោលដៅនោះ មិនមែនជាជីវិត ដែលមានមនសិការ ដែលមាន បុគ្គលិកលក្ខណៈ មានការជ្រើសរើស មានអំណរ និងមានមិត្តភាពនោះឡើយ។

ជំនួសឱ្យ ទៅដល់និព្វាន្តជាយថាហេតុ



112

ជាដំណាក់ការសុខសាន្ត ដែលគ្មានអ្វី ទាំងអស់ ដែលគ្មានបុគ្គលិកលក្ខណៈ គ្មាន ប្រាជ្ញា គ្មានការចងចាំ



113

គ្មាន "អ្នក" ជាមនុស្ស គ្មានលទ្ធភាពនៃ ការគិត និងស្រឡាញ់ និងអារម្មណ៍ ដឹង ពីអំណរឡើយ។


114

អាត្មាន់នឹងត្រូវស្រូបចូលទៅក្នុងពិភពចក្រ វាល ដូចជាដំណក់ទឹកដែលត្រូវស្រូបចូលទៅក្នុងមហាសមុទ្រ ដែលបាត់បង់នូវអត្ត សញ្ញាណទាំងស្រុង។


115

សាសនាព្រះពុទ្ធក៏ស្រដៀងគ្នានេះដែរ។
ទោះជាយ៉ាងណាក៏ដោយ ព្រះពុទ្ធបាន បង្រៀនថា អ្នកអាចចាកចេញពី "វាលវដ្តសំសារ" នៅចុងបញ្ចប់នៃជីវិតនេះ ដោយអ្នកនឹងមិនត្រូវ វិលកើត វិលស្លាប់ ដោយគ្មានទីបញ្ចប់នោះទេ ប្រសិនបើអ្នក មានកម្មផលល្អ។

# ១៤. សម្លេងឯនាយផ្ទូរ


116

ការបង្រៀនបន្តទៀតថា តាមរយៈការ គ្រប់គ្រងឆន្ទៈដោយអសម្បជ្ជញ្ញៈ (ដែល ឥតគិត) មនុស្សអាចមកដល់ចំណុចនៃជីវិត ដែលមានការលះបង់យ៉ាងពេញលេញនូវសេចក្តីប៉ងប្រាថ្នា(កិលេស)។



117

នៅពេលដែលគំនិតនិងរាងកាយស្លាប់ ទៅ គេអាចទៅកាន់និព្វាន្តតែម្តង ដែលជាកន្លែងអាចទទួលបាននៅលើចក្រវាល ដូចជាអាត្មមមួយ នៅក្នុងចំណោមអាត្មម ដទៃទៀតដែរ។


118

ជាមួយនឹងសាសនាដ៏ធំទាំងពីរនេះក៏មានសេចក្តីជំនឿថា ការល្អនិងការអាក្រក់មានអំណាចស្មើគ្នានិងមានតាំងពីអស់កល្បមកផងដែរ។



119

នៅលើកោះបាលី នៅប្រទេសឥណ្ឌូណេស៊ី អ្នកណាក៏ដោយអាចទស្សនារបាំ បារុងបាន។


120

របាំបារុង មានសំលៀកបំពាក់ ដែលមើល ទៅដូចជាស៊ុតស្មោរដ៏ធំមួយ ទល់មុខនឹង បុរសប្រាំមួយនាក់ ដែលប្រដាប់ដោយ គ្រីស (អាវុធជាកាំបិត)ស្រួចហើយមុត មានរាងក្ងិកក្ងក់របស់គេ ដែលអាចសំលាប់មនុស្សបានយ៉ាងងាយ។

ពួកគេទាំងនោះស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀនដែលគេប្រើនៅក្នុងស្រុកគេ (ស្រវឹង)


121

បារុងរាំសំដៅទៅមនុស្សទាំងនោះ ហើយពួកគេក៏ថយក្រោយ។

វាបញ្ចេញសំឡេងដូចចង្រិត ហើយ មនុស្សទាំងអស់នោះរត់ពីក្រោយវា លើកដៃវាយទៅលើខ្យល់និងខំប្រឹងកាប់ វាសម្លាប់។

# ១៤. សម្លេងឯនាយផ្ទះ


122

បារុងឈប់ ហើយបែរទៅរកបុរសទាំងនោះ។

ពួកគេក៏ឈប់ដែរ ។ វាឈានទៅមុខមួយជំហាន ហើយថយមកវិញមួយជំហាន។

គេធ្វើដូច្នេះម្តងហើយម្តងទៀត រហូតដល់បុរសទាំងប្រាំមួយត្រូវបានធ្លាក់ទៅ

ក្នុងស្ថានភាពដ៏ឃោរឃៅនៃការរឹករវជា

ប្រញាប់ ហើយពួកគេបាត់បង់ភាពម្ចាស់ការ វាមិនមែនជារឿងធម្មតាទេ ដែលមនុស្ស

ម្នាក់ឬច្រើននាក់ គ្រវែងកាំបិតគ្រីស និងចាក់មនុស្ស ដែលកំពុងឈរមើល ដោយភាន់ច្រឡំនោះ។

នៅពេលនោះ មនុស្សដែលមកពីភូមិ ក៏ចេញមកពីក្រោយ

មនុស្សទាំងនោះ ហើយបោកចំបាប់ពួកគេ ទៅនឹងដី ហើយចាក់ទឹកលើពួកគេ នៅ ពេលដែលពួកគេ

កំពុងរងទុក្ខវេទនានោះ។

ទីបញ្ចប់គេគ្រវីក្បាលរបស់គេ នៅពេល ដែលគេមានអារម្មណ៍ដ៏អណ្តែតអណ្តូង គេក្រោកឡើង

ហើយដើរទៅខ្ទមរបស់គេ នៅពេលដែលបារុងដើរចេញទៅទិសផ្ទុយគ្នា

នោះ។

តើវាមានន័យថាយ៉ាងម៉េច?

វាគឺជាបុណ្យប្រចាំឆ្នាំខាងសាសនា ដែលមនុស្សសំដែងអំពីសេចក្តីជំនឿរបស់គេ។

បារុងតំណាងឱ្យព្រះ ហើយមនុស្ស ប្រាំមួយនាក់តំណាងឱ្យអារក្ស។

យោងតាមជំនឿរបស់ពួកហិណ្ឌូ គឺ មានទំនាស់ជាអមតៈរវាងការល្អនិងការអា

ក្រក់។

មិនចាញ់មិនឈ្នះឡើយ ស្មើរហូត។


123

វាមានមូលដ្ឋានទៅលើជំនឿថា ប្រវត្តិសាស្ត្រវិលចុះវិលឡើង ដែលមានការច្រំដែលខ្លួនឯងដដែលៗ

មិនចេះចប់ មិនចេះហើយ ជីវិតនេះមិនបានទៅកន្លែងណាឡើយ។

គ្មានព្រះដ៏អស់កល្ប នៃសេចក្តីស្រឡាញ់ ដែលនឹងឈ្នះជាយថាហេតុ ហើយនាំមកនូវសេចក្តីសុចរិត

និងសេចក្តីសុខសាន្តមកក្នុងពិភពលោកទាំងមូលនេះបានទេ។


124

ខ្ញុំអរគុណដល់ព្រះយេស៊ូវយ៉ាងខ្លាំង ចំពោះការរស់ឡើងវិញរបស់ទ្រង់

ចុះលោកអ្នកវិញ?

គឺជាសេចក្តីសង្ឃឹមដ៏ល្អអស្ចារ្យដែលទ្រង់នាំមក!

អារក្សនឹងមិនមានជ័យជំនះរហូតឡើយ។

ប្រវត្តិសាស្ត្រមិនមែនវិលចុះវិលឡើងនោះទេ វានឹងទៅកាន់ទីកន្លែងណាមួយ។

គ្រប់ប្រវត្តិសាស្ត្រទាំងអស់កំពុងរំកិលទៅ

រកពេលវេលាដែលព្រះនឹងបង្កើតផែនដីថ្មី សម្រាប់រាស្ត្រពិតប្រាកដ ដែលគ្មានបាប គ្មានជម្ងឺ

គ្មានសង្គ្រាមគ្មានការខ្វះចំណី អាហារ គ្មានការឈឺចាប់ និងស្លាប់ឡើយ។

# ១៤. សម្លេងឯនាយផ្ទៃ


125

(ព្រះគម្ពីរ វិវរណៈ ២១:១-៤)

"រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុន បានកន្លង បាត់ទៅហើយ


126

ក៏គ្មានសមុទ្រទៀតឡើយ


127

ហើយយ៉ូហានខ្ញុំក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌ មកពីព្រះ


128

គាត់តែងដូចជាប្រពន្ធថ្មោងថ្មីទទួលប្ដី"


129

ខ្ញុំមានឮសំឡេងមួយយ៉ាងខ្លាំង ចេញពី ស្ថានសួគ៌មកថា មើលរោងឧបោសថរបស់ ព្រះ
បាននៅជាមួយនឹងមនុស្សហើយ


130

ទ្រង់ក៏គង់នៅជាមួយនឹងគេ គេនឹងធ្វើជា រាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹង ធ្វើជាព្រះដល់គេ


131

ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពី ភ្នែកគេចេញ នឹងគ្មានសេចក្ដីស្លាប់ ឬ សេចក្ដីសោកសង្រេង
ឬសេចក្ដីយំទួញ


132

ឬទុក្ខលំបាកណាទៀតឡើយ ដ្បិត សេចក្ដីមុនទាំងប៉ុន្មានបានកន្លងបាត់ហើយ"
វិវរណៈ ២១:១-៤

# ១៤. សម្លេងឯនាយផ្ទូរ


133

តើលោកអ្នកមិនជ្រើសយកព្រះយេស៊ូវ ឥឡូវនេះហើយ "កើតឡើងវិញ " ឬទេ?

មិនមែនចាំដល់បន្ទាប់ពីស្លាប់នោះទេ នោះនឹងយឺតពេលហើយ។

មិនមែនតាមរយៈនៃការវិលចុះវិលឡើង នៃការចាប់ជាតិក្នុងជីវិតដ៏ធំរាប់លានឆ្នាំ នោះទេ។

ប៉ុន្តែឥឡូវនេះ! ថ្ងៃនេះ!


134

(ព្រះគម្ពីរ ពេត្រុសទី១ ១:៣,៤)

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃ ព្រះយេស៊ូវគ្រីស្ទ


135

ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់ បានបង្កើតយើងឡើងជាថ្មី តាមសេចក្តី

មេត្តាករុណារបស់ទ្រង់ ដើម្បីឱ្យយើងរាល់ គ្នាបានសេចក្តីសង្ឃឹមដ៏រស់


136

ដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់រស់ឡើងវិញ


137

ហើយឱ្យយើងបានមរតក ដែលមិនចេះពុក រលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រ ពោនឡើយ


138

ជាមរតកដែលបំរុងទុកឱ្យយើងរាល់គ្នា នៅ ស្ថានសួគ៌"

ពេត្រុសទី១ ១:៣,៤


139

លោកអ្នកអាចមានជីវិតអស់កល្បជានិច្ច រហូតទៅ។

នោះគឺជាការធានារ៉ាប់រងដែលព្រះចង់ ឱ្យលោកអ្នកមានថ្ងៃនេះ។

# ១៤. សម្លេងឯនាយផ្ទះ


140

(ព្រះគម្ពីរ យ៉ូហានទី១ ៥:១១,១២)

"នេះហើយជាសេចក្ដីបន្ទាល់នោះ គឺថា
ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅ
ក្នុងព្រះរាជបុត្រានៃទ្រង់


141

ឯអ្នកណាដែលមានព្រះរាជបុត្រា នោះ នឹងមានជីវិតដែរ តែអ្នកណាដែលគ្មានព្រះ
រាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ"
យ៉ូហានទី១ ៥:១១,១២
តើយើងដឹងដោយរបៀបណា? តើធ្វើ ដូចម្ដេចឱ្យយើងអាចទុកចិត្តបាន? ព្រះបន្ទូល
របស់ព្រះធ្វើឱ្យយើងដឹងយ៉ាងច្បាស់ក្រឡែត


142

(ព្រះគម្ពីរ យ៉ូហានទី១ ៥:១៣)

"ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមក អ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជ បុត្រានៃព្រះ


143

ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នា មានជីវិតអស់កល្បជានិច្ចហើយ"
យ៉ូហានទី១ ៥:១៣
សំនួរដែលមនុស្សម្នាក់ៗត្រូវតែឆ្លើយនោះ គឺ "តើខ្ញុំបានទទួលព្រះយេស៊ូវហើយឬនៅ?"
លោកអ្នកអាចទទួលព្រះអង្គនៅពេលឥឡូវ នេះ


144

(ព្រះគម្ពីរ វិវរណៈ៣:២០)

ទ្រង់មានបន្ទូលថា "មើលអញឈរនៅ មាត់ទ្វារនៃចិត្ត(របស់អ្នក)


145

ទាំងគោះ បើអ្នកណាឮសំឡេងអញ ហើយបើកទ្វារឱ្យ


146

នោះអញនឹងចូលទៅឯអ្នកនោះ អញ នឹងបរិភោគជាមួយនឹងអ្នកនោះ ហើយអ្នក
នោះជាមួយនឹងអញដែរ"
វិវរណៈ៣:២០

# ១៤. សម្លេងឯនាយផ្ទះ


147

គ្រាន់តែបើកចិត្តលោកអ្នកឥឡូវនេះ ហើយយាងទ្រង់ចូលគង់ចុះ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



1

តើអាចឈានទៅដល់សុខភាពល្អបំផុតដោយរបៀបណា


2

នៅលើកំពូលនៃជ្រោះភ្នំមួយ ដែល មើល ទៅឃើញតែទឹកពណ៌ខៀវស្រងាត់នៃសមុទ្រមេឌីទែរ៉ាណេ មានវត្តបុរាណរបស់ ព័រទុយ ហ្គេមួយ។ ទស្សនីយភាពនៅទី នោះល្អឆើតឆាយអស្ចារ្យណាស់ គេមិន ដែលឃើញមាន ទេសភាពណាល្អ ដូចនៅ ទីនោះឡើយ។

ប៉ុន្តែមានបញ្ហាមួយ។

វិធីតែមួយគត់ដើម្បីឡើងទៅកាន់កំពូល ភ្នំនោះបានគឺ មានកន្ត្រកកញ្ជាស់មួយ ចងភ្ជាប់ទៅនឹងខ្សែពួរ ហើយសំរូតឡើងទៅ លើ ដោយលោកសង្ឃ(កាតូលិក)ចំណាស់ មួយអង្គ


3

ថ្ងៃមួយអ្នកនាំផ្លូវ និងអ្នកទេសចរម្នាក់ បានចាកចេញពីវត្តនោះ។

នៅពេលដែលគេឈានជើងចូលទៅក្នុង កន្ត្រក ដែលត្រូវយោងឡើងដោយលោកសង្ឃមួយអង្គនោះ ខ្សែពួរនោះក៏យោលចុះ ឡើងពីលើថ្មស្រួចៗនៅពីក្រោម។

អ្នកទេសចរនោះបានសួរដោយស្លន់ ស្លោថា "តើគេផ្លាស់ខ្សែនេះញឹកញាប់ប៉ុនណា?"


4

"កុំភ័យ" អ្នកនាំផ្លូវឆ្លើយតប ដោយ សំឡេងលើកទឹកចិត្ត រៀងរាល់ពេល ដែលវាដាច់ យើងប្តូរវាហើយ"


5

ដូចជារឿងនេះដូច្នោះដែរ មនុស្សរាប់ ពាន់នាក់ ដាក់ខ្លួនគេក្នុងស្ថានភាពមួយ ដែលមិនអាចទាយទុកជាមុនបាន ទាក់ទង ទៅនឹងសុខភាពរបស់គេ។

ពួកគេរង់ចាំទាល់តែសុខភាពរបស់គេ ទ្រុឌទ្រោម ដូចជាខ្សែពួរ នោះទើបប្រញាប់ប្រញាល់ព្យាបាល តាមការនិយមនៃ សុខភាពសម័យទំនើបវិញ។

ការខូចសុខភាពមិនអាចស្រួលនឹងផ្លាស់ ប្តូរដូចជាខ្សែពួរដែលខូចនោះទេ!

សុខភាពវាមិនមែនជាជោគវាសនានោះ ទេ ប៉ុន្តែវាជាសារសំខាន់នៃការជ្រើសរើសនៃការធ្វើតាមច្បាប់ធម្មជាតិ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


6

មិត្តអើយ តើអ្នកមានប្រាក់គ្រប់គ្រាន់ សម្រាប់ចំណាយលើសុខភាពមិនល្អឬទេ
មនុស្សចំណាយប្រាក់រាប់លានក្នុងមួយឆ្នាំៗ ដើម្បីរក្សាសុខភាព។
ជម្ងឺ គឺជាការចំណាយយ៉ាងថ្លៃជាងគេ
បំផុតនៅលើពិភពលោកនេះ ដែលមនុស្ស បានចំណាយប្រាក់ដើម្បីព្យាបាលវា!
ចុះពេលនោះតើការជាពីជម្ងឺនោះ មានតម្លៃប៉ុន្មានដែរ?
ចូរសួរអ្នកដែលស្លាប់ដោយជម្ងឺមហារីក ឬដោយជម្ងឺអេដស៍មើល។


7

ចូរសួរឪពុកម្តាយកុមារដែលស្លាប់ដោយ ជម្ងឺមហារីកឈាម ឬមួយក៏មនុស្សចាស់ ម្នាក់
ដែលមានការទ្រុឌទ្រោម ដោយជម្ងឺ រលាកសន្លាក់ដៃជើងមើល ពួកគេនឹងប្រាប់ អ្នកថា
សុខភាពល្អមានតម្លៃមិនអាចកាត់ ថ្លៃបាន នោះគឺជាព្រះពរដ៏គួរឱ្យកោត
សរសើរមិន ចេះចប់រហូតដល់វាបាត់ទៅវិញ!


8

តើជីវិតមួយឆ្នាំ ឬក៏សូម្បីតែមួយថ្ងៃ...
មានតម្លៃប៉ុន្មាន?
ម្ចាស់ក្សត្រីយ៍ អេលីសាបែត បានមាន ព្រះបន្ទូលទាំងទឹកនេត្រា នៅលើព្រះទែន របស់ព្រះនាងថា
"ខ្ញុំអាចប្តូរទ្រព្យសម្បត្តិ របស់ខ្ញុំទាំងអស់ ជាមួយនឹងអាយុជីវិតតែ មួយនាទីប៉ុណ្ណោះ"
ប៉ុន្តែលុយមិនអាចទិញអាយុជីវិតបានទេ។
ទោះជាយ៉ាងនេះក៏ដោយ តើលោកអ្នក ដឹងទេថា លោកអ្នកអាចទទួលអាយុជីវិត បានច្រើនឆ្នាំ
និងកាន់តែប្រសើរឡើងទៀត ដោយសារតែការអនុវត្តន៍តាមការណែនាំអំពី
សុខភាពយ៉ាងងាយ និងប្រកបដោយ សុភវិនិច្ឆ័យ


9

លោកវេជ្ជបណ្ឌិត ប្រេស្លូវ សាកលវិទ្យាល័យខាងច្បាប់សុខភាព នៅកាលីហ្វ័រញ៉ា
រដ្ឋឡូសអ៊ិនហ្គឺឡឺស បាន ធ្វើការសិក្សាស្រាវជ្រាវមួយក្នុងរយៈពេលប្រាំ បួនឆ្នាំ។
គាត់បានសួរដល់មនុស្ស៧០០០នាក់ នូវ សំនួរប្រាំពីរដែលទាក់ទងទៅនឹងទម្លាប់សុខ ភាព
ហើយបានសង្កេតមើលចំពោះអ្នក
ជម្ងឺទាំងនោះ ដោយប្រៀបធៀបអ្នក ដែលបានដើរតាម ទម្លាប់ល្អសម្រាប់ សុខភាពល្អ ជាមួយអ្នក
ដែលមានទម្លាប់ អាក្រក់។


10

នេះគឺជាសំនួរទាំង៧ដែលគាត់បានសួរ:

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


11

១. តើអ្នកពិសាបារីឬទេ?

២. តើអ្នកពិសាស្រាឬទេ បើពិសា តើ ច្រើនប៉ុន្មាន ហើយញឹកញាប់ប៉ុនណា?

៣. តើអ្នកបានហាត់ប្រាណទៀងទាត់ឬទេ?


12

៤. តើអ្នកសម្រាន្តប៉ុន្មានម៉ោងរៀងរាល់យប់?

៥. តើអ្នកមានទម្ងន់ប៉ុន្មាន?

៦. តើអ្នកបានទទួលទានអាហារពេលព្រឹក ទៀងទាត់ឬទេ?

៧. តើអ្នកមានទទួលទានអាហារនៅចន្លោះ ពេលបាយជារៀងរាល់ពេលឬទេ?

អស់អ្នកដែលបានដើរតាមទម្លាប់ល្អនៃ សុខភាពយ៉ាងទៀងទាត់ ទៅតាមសំនួរទាំងប្រាំពីរនេះរស់នៅបាន១១ ឆ្នាំកន្លះយូរជាង អ្នកដែលមិនបានកាន់តាមទម្លាប់ទាំងអស់ នេះ។


13

តើអ្នកនឹងធ្វើអ្វីដើម្បីបន្ថែមជីវិត១១ឆ្នាំកន្លះនេះ ?

តើអ្វីទៅដែលយើងកំពុងចែកចាយជាមួយលោកអ្នកនៅពេលនេះ ក្នុងដំណឹងនេះដើម្បីនឹងបន្ថែម អាយុយ៉ាងប្រសើរដល់ជីវិតលោកអ្នក អាយុដែល រីករាយនិងមាន សុខភាពល្អ។

តើអ្នកគិតថា វាមានតម្លៃ ដែលគួរឱ្យ លោកអ្នកស្តាប់ដោយយកចិត្តទុកដាក់ដែរឬទេ?

វាលេចឡើងគួរឱ្យភ្ញាក់ផ្អើលដល់មនុស្ស ជាច្រើន ដែលថាព្រះយកព្រះទ័យទុកដាក់ អំពីសុខភាពនិងសេចក្តីសុខ សាន្ត របស់យើងនៅទីនេះ និងនៅពេលនេះ ។


14

(ព្រះគម្ពីរ យ៉ូហានទី៣ ១:២)

"កូនស្ងួនភ្ងាអើយ ខ្ញុំប្រាថ្នាចង់ឱ្យអ្នក បានចំរើនឡើងគ្រប់ជំពូក ហើយឱ្យបានសុខសប្បាយខាងរូបសាច់ ដូចជាព្រលឹង អ្នកបានចំរើនឡើងដែរ"

យ៉ូហានទី៣ ២


15

(ព្រះគម្ពីរ យ៉ូហាន ១០:១០)

ព្រះយេស៊ូវបានមានបន្ទូលថា "តែឯខ្ញុំ វិញ ខ្ញុំបានមកដើម្បីឱ្យវារាល់គ្នាមានជីវិតហើយឱ្យមានជីវិតនោះពេញបរិបូរផង"

យ៉ូហាន ១០:១០

១៥. ចូរបង្វិលនាឡិកាថយក្រោយ

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


16

ព្រះយេស៊ូវចង់ឱ្យយើងមានជីវិត ដែល មានសុខភាពដ៏ពោរពេញដោយភាពរីករាយ និងអំណរ។ ព្រះអង្គចង់ឱ្យយើងរស់នៅក្នុងជីវិតដ៏ ពេញបរិបូរ!


17

តើមានលទ្ធភាពដែលអាចដឹងបានអំពី ថា តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យមានសុខ ភាពល្អឬទេ? វាពិតជាមាន!

មនុស្សច្រើនណាស់មិនបានដឹងថា នៅ ក្នុងព្រះគម្ពីរ ព្រះបានប្រទានច្បាប់ដ៏សំខាន់ និងការណែនាំដែលទាក់ទងទៅនឹងការរស់ នៅដែលមានសុខភាពល្អទេ។


18

ជាច្រើនទសវត្សរ៍មកហើយ ដែលជីវិត គំរូរបស់ពួកយូដាអ៊ុរត្វដុកបុរាណ គឺជាការ ចាប់អារម្មណ៍យ៉ាងគួរឱ្យពិចារណា របស់ អ្នកស្រាវជ្រាវខាងវិជ្ជាពេទ្យ។

អត្រាអ្នកមានជម្ងឺមហារីកមានតិចជាង ជនជាតិដទៃ ហើយពួកគេហាក់ដូចជាមាន ការភ័យខ្លាចចំពោះជម្ងឺដ៏សាហាវ១តិចជាង ជនជាតិដទៃទៀត។

តើពួកយូដាមានកត្តាពីកំណើត ដែល ផ្ដល់ឱ្យគេនូវភាពស៊ាំទៅនឹងការនាំទៅរក សេចក្ដីស្លាប់ដែលអ្នកដទៃកំពុងត្រូវបាន យាយីនេះឬយ៉ាងណា?


19

វាជាការដែលគួរឱ្យចាប់អារម្មណ៍ដែល នៅពេលពួកយូដា ចាប់ផ្ដើមទទួលទាន អាហារដូចអ្នកដែលនៅជុំវិញគេបានទទួល ទានដែរ ហើយក៏មានជម្ងឺមហារីក និងជម្ងឺ ផ្សេង១ដូចមនុស្សដទៃ។

វាត្រូវបានគេរកឃើញថា សណ្ឋានអាថ៌ កំបាំងនៃសុខភាពរបស់គេ ស្ថិតនៅលើការ អនុវត្តន៍គោលការណ៍សុខភាព ចំណី អាហារនិងរបៀបនៃការរស់នៅរបស់គេ។



20

(វីដេអូ ១០វិនាទី) នៅពេលដែលព្រះបាន នាំពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ ទ្រង់បានរំលឹកពួកគេអំពីច្បាប់និងគោល ការដ៏សំខាន់១ខ្លះ ទាក់ទងទៅនឹងការរស់ នៅដោយមានសុខភាពល្អ។

បន្ទាប់ពី បានរៀបចំផែនការសម្រាប់ សុខភាពល្អរបស់ទ្រង់រួចមក ទ្រង់បានប្រ ទាននូវសេចក្ដីសន្យាដែលគួរឱ្យចាប់អារម្មណ៍ ជាទីបំផុត ទៅដល់អស់អ្នកណាដែលនឹង ដើរតាមការណែនាំរបស់ទ្រង់។


21

(ព្រះគម្ពីរ និក្ខមនំ ១៥:២៦)

ទ្រង់បានមានព្រះបន្ទូលថា "បើឯង រាល់គ្នាប្រុងនឹងស្ដាប់តាមព្រះយេហូវ៉ា ជា ព្រះនៃឯង ហើយធ្វើតាមត្រឹមត្រូវនៅព្រះ នេត្រទ្រង់

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


22

ព្រមទាំងផ្ទៀងត្រចៀកស្តាប់តាមបញ្ញត្តិទ្រង់ ហើយកាន់តាមច្បាប់ទ្រង់ទាំងប៉ុន្មាន


23

នោះអញនឹងមិនធ្វើឱ្យឯងរាល់គ្នាកើត មានជម្ងឺ រោគាណាមួយ ដូចជាអញបាន ធ្វើឱ្យកើតឡើងដល់ពួកសាសន៍អេស៊ីព្ទ នោះឡើយ ដ្បិតអញនេះជាយេហូវ៉ា គឺជាព្រះដែលប្រោសឯងរាល់គ្នាឱ្យជា"

និក្ខមនំ ១៥:២៦

ទ្រង់ក៏បានមានបន្ទូលផងដែរថា


24

(ព្រះគម្ពីរ និក្ខមនំ ២៣:២៥)

"ត្រូវឱ្យឯងរាល់គ្នាគោរពប្រតិបត្តិដល់ ព្រះយេហូវ៉ា ជាព្រះនៃឯងវិញ នោះទ្រង់នឹងប្រទានពរដល់អាហារ និងទឹករបស់ឯង


25

ហើយអញនឹងដកជម្ងឺរោគាពីពួកឯង រាល់គ្នាចេញ"

និក្ខមនំ ២៣:២៥

តើលោកអ្នកចាប់សញ្ញាសំគាល់នេះបាន ហើយឬនៅ?

ប្រសិនបើយើងដើរតាមការបង្រៀន របស់ព្រះ ឥទ្ធិពលនៃជម្ងឺអាចនឹងត្រូវបាន ចុះថយ!

នោះគឺជាដំណឹងដ៏ល្អដែលមិនអាចកាត់ ថ្លៃបាន!

នេះគឺជាសេចក្តីសន្យាដ៏អស្ចារ្យ!


26

ការពណ៌នាទៅលើការសម្រេចនៃសេចក្តី សន្យានេះ អ្នកសរសេរគម្ពីរទំនុកដំកើង ប្រាប់យើងថា


27

(ព្រះគម្ពីរ ទំនុកដំកើង ១០៥:៣៧)

"ឯក្នុងអស់ទាំងពូជអំបូរនោះគ្មានអ្នក ណាមួយគ្រាកចិត្តឡើយ"

ទំនុកដំកើង ១០៥:៣៧

"មែនហើយ" លោកអ្នកនិយាយថា "ប្រ ហែលជាប្រជាជនអេស៊ីព្ទមិនមានជម្ងឺដូចដែលយើងមានសព្វថ្ងៃនោះទេ" ខុសហើយ!

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


28

ក្រុមជំនាញការ ទូទាំងពិភពលោកនេះ បានមកជួបជុំគ្នា នៅក្នុងឆ្នាំ១៩៧៥ ដើម្បីគោលបំណងតែមួយគត់ នៃការវះកាត់វត្ថិត សព (សពដែលគេរក្សាទុកមិនឱ្យរលួយ) ជនជាតិអេស៊ីព្ទ នៅឯសារមន្ទីរសាលាពេទ្យ ម៉ាន់ឆេស្ទើរ(ប្រទេសអង់គ្លេស)។ សាកសពទាំងនេះមានកាលបរិច្ឆេទតាំងពី ឆ្នាំ ១៩០០ មុនគ្រិស្តសករាជ។



29

(វីដេអូ ១វិនាទី) ការរកឃើញត្រូវបានគេ កត់សំគាល់ថា ជនជាតិអេស៊ីព្ទបុរាណ បានទទួលរងនូវជម្ងឺដូចគ្នានឹងមនុស្សសម័យទំនើបដែរ



30

(វីដេអូ ៦វិនាទី)ជម្ងឺបេះដូង

មហារីក

ជម្ងឺសរសៃឈាម

ជម្ងឺសន្លាក់ដៃជើង



31

(វីដេអូ ៦វិនាទី) រលាកថ្លើម

តេតាណូស

ជម្ងឺដែលបណ្តាលមកពីបរិភោគសាច់ជ្រូកមានរោគ

ជម្ងឺរឹងថ្គាម និងជម្ងឺផ្សេងៗទៀត។


32

ទោះបីជាប្រទេសអេស៊ីព្ទគឺជាមជ្ឈមណ្ឌលនៃការអប់រំ និងវប្បធម៌នៅ ជំនាន់លោកម៉ូសេក៏ដោយ ក៏ចំណេះដឹងខាង វិជ្ជាពេទ្យ និងការព្យាបាលរបស់គេប្រហាក់ ប្រហែលគ្នា ទៅនឹងពួកអាហ្វ្រិកដែលមាន វេជ្ជបណ្ឌិតសព្វថ្ងៃនេះដែរ!


33

នៅឆ្នាំ១៥៥២ មុនគ្រិស្តសករាជ មុន កំណើតលោកម៉ូសេបន្តិចនោះ សៀវភៅពេទ្យដ៏ល្បីល្បាញមួយត្រូវបានគេសរសេរ ឡើង នៅប្រទេសអេស៊ីព្ទ ហៅថា ប៉ាពីរុស អេបើរស៍។

សៀវភៅនេះរៀបរាប់ពីការព្យាបាលជម្ងឺ ជាច្រើនយ៉ាង ដូចជាការរលាក និងគ្រោះ ថ្នាក់ផ្សេងៗ ហើយមានតិចណាស់ដែល លោកអ្នកប្រហែលជានឹងចង់យកមកប្រើ!


34

សៀវភៅនេះណែនាំថា ចំពោះការមុត ចម្រាស់ជាប់ក្នុងសាច់ ឱ្យយកឈាមរបស់ ដង្កូវ និងអាចម៍សេះ យកមកជូតត្រង់ កន្លែងរបួសនោះ។ មិនត្រូវឱ្យងឿងឆ្ងល់ ឡើយ ជម្ងឺរឹងថ្គាមបានសម្លាប់មនុស្សជា ច្រើននាក់ នៅសម័យនោះ

ចំពោះពស់ចឹក ចូរផឹកទឹកដែលចាក់ពី លើរូបសំណាកមួយ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


35

ចុះក្បាលទំពែក? រុំលលាដ៍ក្បាលដោយ ថ្នាំម្យ៉ាងធ្វើពីក្រចកសេះ និងកែងជើងឆ្កែ ដាំក្នុងខ្លាញ់។


36

ព្រះគម្ពីរប្រាប់យើងថា ម៉ូសេត្រូវបាន បង្រៀនអំពីគតិបណ្ឌិតទាំងអស់របស់ជនជាតិ អេស៊ីព្ទ (កិច្ចការ ៧:២២)។

ការសរសេរ របស់គាត់បានត្រូវបំពេញ ដោយការណែនាំ ទាក់ទងទៅនឹងអនាម័យ ការដាក់ឱ្យនៅដាច់ពីគេ អនាម័យផ្ទាល់ខ្លួន និងចំណីអាហារ ប៉ុន្តែមិនមានម្តងណាមួយ ដែលគាត់បានដាក់ឱ្យកាន់តាមការព្យាបាល ដែលមាននៅក្នុងសៀវភៅ ប៉ាពីរូស អេបើរស៍នោះទេ។

តើលោកម៉ូសេបានសៀវភៅ គោលការណ៍សុខភាពទាំងនេះពីណាមក?

បានពីព្រះ!


37

ជម្ងឺប៉េសនិង ឃ្លង់ គឺជាគ្រោះវេទនា យ៉ាងធំបំផុតនៅមជ្ឈិមសម័យ។


38

គោលការណ៍នៃសុខភាពសាធារណៈ ដែលព្រះបានប្រទានឱ្យ ហើយដែលបានបង្រៀន ដោយលោកម៉ូសេ បន្ទាប់ពីការជន្លៀស ខ្លួនមក បាននាំឱ្យ សេចក្តីវេទនាស្ថិត នៅក្រោមការគ្រប់គ្រង ដ៏មានប្រសិទ្ធភាពមួយ!

ជីវិតមនុស្សរាប់លាននាក់ត្រូវបាន សង្គ្រោះ នៅពេលដែល វេជ្ជបណ្ឌិតបាន ងាកទៅរកអ្នកដឹកនាំក្រុមជំនុំគ្រីស្ទ សាសនា នៅពេលដែលមានការវេទនាទាំងនោះ។


39

លោកហ្សច្ស៍សេន បានសរសេរថា "ដោយសារពួកគ្រូពេទ្យវេជ្ជសាស្ត្រ ពុំមាន លទ្ធភាពនឹងដោះស្រាយបាន ការដឹកនាំខាង សុខភាព ត្រូវបានគេប្រគល់ទៅឱ្យអ្នកដឹកនាំក្រុមជំនុំគ្រីស្ទសាសនា។


40

ក្រុមជំនុំចាប់ផ្តើមប្រើបានគោលការណ៍ ណែនាំ អំពីគំនិតនៃជម្ងឺឆ្លងរាលដាល ដែលមានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


41

គំនិតនេះនិងផលវិបាកនៃការអនុវត្តន៍
របស់វា បានបញ្ជាក់យ៉ាងច្បាស់លាស់នៅ ក្នុងព្រះគម្ពីរលេវីវិន័យ”
វេជ្ជបណ្ឌិតហ្គេច រ៉ូសេន ប្រវត្តិសាស្ត្រ នៃសាធារណៈសុខាភិបាល ទំព័រ ៦៣-៦៥។


42

គួរឱ្យមានការអៀនខ្មាសណាស់ ដែលមនុស្ស៦០លាននាក់បានស្លាប់ ដោយសារតែ
សេចក្ដីវេទនាទាំងនោះ នៅពេលដែលគោលការណ៍នៃសុខភាពជាសាធារណៈ របស់ ព្រះគម្ពីរ
នៅទីនោះគ្រប់ពេលវេលានោះ!


43

ព្រះបានរៀបចំរូបកាយយើង
ទ្រង់ជ្រាបថា យើងអាចជៀសវាងពី ជម្ងឺបានដោយរបៀបណា ហើយរក្សារូប
កាយយើងឱ្យនៅតែមាន ដំណើរការប្រសើរ បំផុតដដែល!
ព្រះបានប្រទានមកឱ្យមនុស្សនូវ រូប កាយដែលគួរឱ្យកត់សំគាល់ ដែលមិនអាច កំណត់ព្រំដែនបាន។
មានផ្នែកដ៏ប្រណិតជាច្រើន។


44

ព្រះទ្រង់បានបង្កើតយើង ហើយទ្រង់ ជ្រាបយ៉ាងច្បាស់នូវអ្វីដែលសំខាន់ ដើម្បីធ្វើ
ឱ្យយើងមានសុខភាពល្អ និងមានផល ប្រយោជន៍ដ៏ខ្ពស់បំផុត។


45

បុរសក្មេងម្នាក់បានទិញឡានថ្មីដ៏ភ្លឺ
រលោងមួយ ដោយប្រាក់ដែលគាត់បាន សន្សំជាច្រើនឆ្នាំមកហើយ។


46

គេបានជូនទៅគាត់នូវសៀវភៅក្បួនខ្នាត របស់រោងចក្រ ដែលប្រាប់យ៉ាងច្បាស់នូវ
របៀបថែរក្សាឡានថ្មីនោះ នៅក្នុងវិធីមួយ ដ៏ល្អបំផុត ដើម្បីឱ្យប្រើបានយូរ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



47

ឡាននោះជាឡានថ្លៃណាស់ ហើយ លោកអ្នកគិតថា ម្ចាស់ឡានថ្មីនេះ យ៉ាង ហោចណាស់ក៏មើលការណែនាំអំពីការ ថែរក្សាឡាន នេះដោយប្រុងប្រយ័ត្នមិន ខានដែរ។

ប៉ុន្តែតាមពិតគាត់មិនបានមើលសោះ។

រឿងមួយដែលគាត់គិតនោះ គឺថា តើវា លឿនប៉ុនណា ដើម្បីបើកនូវ១០០គីឡូ ម៉ែត្រ ក្នុងមួយម៉ោងឱ្យបានក្នុង រយៈពេល ត្រឹមតែមួយវិនាទីប៉ុណ្ណោះវិញ។

គាត់ចង់ឱ្យឡាននោះលឿនយ៉ាងអស់ លទ្ធភាពដែលគាត់អាចបើកបាន ហើយ ចាប់ហ្វ្រាំង ដើម្បីមើលឱ្យឃើញថា តើ វាឈប់បានរហ័សប៉ុនណា។

គាត់ចង់ឮសម្លេងញ៉េច១នៃកង់របស់វា។



48

គាត់មិនបានផែកមើល ប្រេងម៉ាស៊ីន មើលទឹក ឬខ្យល់របស់កង់ឡើយ ព្រោះ ថា ការនោះវាអំពល់ដល់គាត់ណាស់ ហើយ ខាតពេលវេលាច្រើនទៀតផង។ គាត់មិនអាចខ្ជះខ្ជាយពេលវេលាដើម្បីធ្វើការដ៏ងាយៗបែបនេះបានទេ។

គាត់ចង់កាន់ចង្កូត បើកបរទៅកាន់ទី ណាដែលគាត់ចង់ទៅ ហើយជាពិសេស កន្លែងណាដែលមានមនុស្សច្រើន ឃើញ គាត់បញ្ជាឡានដ៏លឿននោះ។



49

លោកអ្នកអាចចាន់ស្មានបាន នៅផ្នែក បញ្ចប់នៃសាច់រឿងនេះ។

មែនហើយ ឡាននេះមិនអាចប្រើបានយូរទេ មិនយូរប៉ុន្មាន គាត់នឹងត្រូវចំណាយប្រាក់ អស់ជាច្រើន ដើម្បីជួសជុល។

តើយើងធ្វើដូចគ្នានេះទៅនឹងរូបរាងដ៏ល្អ របស់យើង ដែលព្រះបានប្រទានដល់យើង ឬយ៉ាងណា?

យើងពិតប្រាកដជាចង់ធ្វើតាមការណែនាំ របស់ទ្រង់មិនខាន!



50

ជូនកាលដំណើរទៅកាន់មន្ទីរពេទ្យមួយ ជើង អាចបោសសំអាតទ្រព្យសម្បត្តិដែល បានសន្សំមួយជីវិតបាន។



51

វាពិតជានឹងមានតម្លៃសម្រាប់ជីវិតរបស់ យើង ដើម្បីវិលត្រឡប់ទៅកាន់សួនច្បារ អេដែនវិញ ទៅកាន់ការបង្កបង្កើត ហើយ កត់សំគាល់នូវរឿងរ៉ាវខ្លះដែលព្រះបានប្រាប់ ដល់អ័ដាមនិងនាងអេវ៉ា ដើម្បីបង្កើនសុខ ភាព។

ការទទួលទានអាហារដែលនាំឱ្យមាន សុខភាពល្អ មុនពេលអំពើបាបបានចូល មកដល់ ព្រះបានប្រទានឱ្យអ័ដាម និងនាង អេវ៉ានូវការបរិភោគអាហារយ៉ាងត្រឹមត្រូវ ដើម្បីថែរក្សា និងបង្កើនសុខភាពរបស់ ពួកគេ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



52

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៩)

"មើលអញឱ្យគ្រប់ទាំងតិណជាតិមាន គ្រាប់ពូជ ដែលដុះនៅផែនដី



53

និងគ្រប់ទាំងរុក្ខជាតិទាំងឡាយ ដែលកើត ផ្លែមានគ្រាប់ពូជ ទុកជាអាហារដល់ឯង

លោកុប្បត្តិ ១:២៩



54

នៅក្នុងភាសាទំនើបយើងអាចនិយាយថា ទ្រង់បានប្រទានឱ្យនូវផ្លែឈើ គ្រាប់ធញ្ញ ជាតិ និងគ្រាប់រុក្ខជាតិ



55

នេះហើយជាចំណីអាហាររបស់ពួកគេ។ ព្រះក៏ទ្រង់បានប្រទាន ដើមជីវិតដល់ពួកគេ ដែលបានបំពេញការបរិភោគរបស់គេ នៅ ក្នុងរបៀបមួយដែលធ្វើឱ្យគេមានការកក់ក្តៅចំពោះយុវភាព និងសុខភាពរបស់គេ។

បន្ទាប់ពីអ័ដាមនិងនាងអេវ៉ា មានបាប មក ព្រះទ្រង់បានញែកដើមជីវិតចេញពីពួក គេ ហើយប្រទានបន្លែជាអាហារជំនួសវិញ។



56

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១៨)

"ឯងត្រូវស៊ីអស់ទាំងតិណជាតិដែល ដុះនៅស្រែចំការ"

លោកុប្បត្តិ ៣:១៨

អាហារនេះ ជាមួយនឹងផ្លែឈើ គ្រាប់ ធញ្ញជាតិ និងគ្រាប់ឈើ ជាអាហារយ៉ាង ពេញលេញរបស់មនុស្សរហូតដល់ទឹកជំនន់។

តើវាល្អមគ្រប់គ្រាន់ឬទេ? មែនហើយ វាពិតជា គ្រប់គ្រាន់ណាស់!

សូមយើងពិចារណាថា មនុស្សនៅ សម័យដែលគេទទួលទានអាហារដើមរបស់ព្រះរស់នៅបានរាប់រយឆ្នាំ។



57

(ព្រះគម្ពីរ លោកុប្បត្តិ ៥:២៧)

"អាយុរបស់មធូសាឡាទាំងអស់បាន ៩៦៩ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ"

មនុស្សដែលចាស់ជាងគេដែលធ្លាប់បាន រស់នៅលើផែនដីនេះ គឺ ម៉ាធូសាឡា"

លោកុប្បត្តិ ៥:២៧

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


58

បន្ទាប់ពីទឹកជំនន់ រយៈពេលនៃអាយុ របស់មនុស្ស បានចុះថយយ៉ាងជាក់ស្ដែង។ កូនរបស់ណូអេ សឹម រស់បានតែ៦០០ឆ្នាំ ប៉ុណ្ណោះ ចៅរបស់គាត់បាន២៣៩ឆ្នាំ ចៅទួតរបស់គាត់រស់បាន ១៥៧ឆ្នាំ

នៅសម័យស្ដេចដាវីឌ អាយុរបស់ មនុស្សបានចុះថយរហូតទៅដល់នៅត្រឹមតែ ៧០ឆ្នាំប៉ុណ្ណោះ!

នេះគឺជាការធ្លាក់ចុះយ៉ាងធំមួយ មិនថាអញ្ចឹងឬ?


59

ជីវិតរុក្ខជាតិនៅលើផែនដី ត្រូវបាន កំណត់យ៉ាងតឹងរឹង (ពិបាករក) ដោយសារ ទឹកជំនន់ដ៏ធំ។

គ្រឿងបរិភោគរបស់លោកណូអេត្រូវ បានអស់ បន្ទាប់ពីគាត់និងគ្រួសារបានរស់ នៅក្នុងទូកអស់រយៈពេល ជាងមួយឆ្នាំមក។

នៅពេលនោះព្រះអនុញ្ញាតឱ្យលោកណូអេ និងគ្រួសារគាត់បរិភោគសាច់សត្វ ជាវិធានការបន្ទាន់ និងបណ្ដោះអាសន្ន។

មិនមែនសត្វទាំងអស់ និងរុក្ខជាតិទាំង អស់សុទ្ធតែល្អសម្រាប់ជាចំណីអាហារនោះ ទេ។

ព្រះបានប្រទានការណែនាំអំពីចំណីអា ហារដែលបានពិចារណាថាល្អ ដល់មនុស្ស ដើម្បីបរិភោគ។


60

ភាពខុសគ្នាមួយ ដែលត្រូវបានញែក រវាងសត្វ "ស្អាត" និង "សត្វមិនស្អាត"។ ព្រះថែមទាំងបានប្រាប់លោកណូអេថា សត្វ ណាដែលត្រូវយកទៅជាមួយគាត់ ហើយ ត្រូវយកទៅមួយមុខប៉ុន្មានទៀតផង


61

(ព្រះគម្ពីរ លោកុប្បត្តិ ៧:២)

"ខាងឯសត្វជើងបួនដែលស្អាតនោះ ឯងត្រូវយក៧គូ


62

ហើយសត្វជើងបួនដែលមិនស្អាត នោះឱ្យ យកតែ១គូវិញ គឺទាំងឈ្មោលទាំងញីផង" លោកុប្បត្តិ ៧:២


63

វាបានបង្ហាញឱ្យឃើញថា លោកណូអេ បានដឹងថា សត្វណាស្អាត និងសត្វណាមិន ស្អាត។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


64

បន្ទាប់មកនៅពេលដែលព្រះបាននាំពួក អ៊ីស្រាអែលចេញពីទាសភាពនៃស្រុកអេស៊ីព្ទ ទ្រង់បានប្រទានដល់ពួកអ៊ីស្រាអែល នូវ គោលការណ៍នៃចំណីអាហារ ដើម្បីការពារ អាយុជីវិត និងនិរន្តភាពរបស់ពួកគេ។

ព្រះបានបញ្ជាក់អំពីសត្វណាដែលស្អាត និងសត្វណាដែលមិនស្អាត សម្រាប់ធ្វើជា ចំណីអាហារ


65

(ព្រះគម្ពីរ ចោទិយកថា ១៤:៦)

"ហើយគ្រប់ទាំងសត្វដែលមានក្រចក ផែក គឺក្រចកផែកដាច់ជា២


66

ហើយដែលទំពាអៀងផង ក្នុងអស់ទាំងពួក សត្វទាំងនោះនឹងបរិភោគបាន"

ចោទិយកថា ៤:៦

សូមកត់សំគាល់អំពីការណែនាំនោះ វា ជាការងាយស្រួលចាំជាទីបំផុត គឺមាន តែពីរប៉ុណ្ណោះ ១. ក្រចកផែក និង

២.ទំពាអៀង។



67

(វីដេអូ ១៤វិនាទី) សត្វស្អាតធម្មតាខ្លះ យោងទៅតាមខ ៤.៦ គោ ចៀម ឈ្លូស ពពែ ប្រើស ក្តាន់ រមាំង



68

(វីដេអូ ១០វិនាទី)សត្វមិនស្អាតសព្វថ្ងៃនេះ ត្រូវបានគេយកមកប្រើជាអាហារជាធម្មតា យោងទៅតាមខ៧ និង៨ នឹងរាប់បញ្ចូល នូវ អូដ្ឋ ទន្សាយ ជ្រូក និងស្កាថ្មុ។

សូមចងចាំពីច្បាប់ទាំងពីរនោះ

ប្រសិនជាសត្វណាដែលមានក្រចកផែក និងទំពាអៀង នោះអាចយកមកធ្វើជា អាហារបាន មិនមានគ្រោះថ្នាក់អ្វីទេ

វាជាការសំខាន់ដែលត្រូវចងចាំថា សត្វ ខ្លះទំពាអៀង តែគ្មានក្រចកផែកទេ។


69

ឧទាហរណ៍ជ្រូក មានក្រចកផែក តែ មិនទំពាអៀងទេ វាជាសត្វមិនស្អាត។

ព្រះគម្ពីរមានការណែនាំខ្លះចំពោះសត្វ ជ្រូកនេះ:

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


70

(ព្រះគម្ពីរ លេវីវិន័យ ១១:៧,៨)

"ហើយជ្រូក១ ដ្បិតវាក៏មានក្រចកឆែកជា២ តែមិនទំពាអៀងទេ ជាសត្វដែលរាប់ជាមិន ស្អាតដល់ឯងរាល់គ្នាដែរ


71

មិនត្រូវឱ្យបរិភោគសាច់នៃសត្វទាំងនោះ ឡើយ ក៏មិនត្រូវទាំងប៉ះពាល់ខ្មោចវាផង ដ្បិតជាសត្វដែលរាប់ជាមិនស្អាតដល់ឯងរាល់

គ្នាហើយ

លេវីវិន័យ១១:៧,៨

សត្វភាគច្រើនដែលព្រះបានរាប់ជាមិន ស្អាត ត្រូវបានចាត់ជាសត្វដែលដើររក អាហារខ្លួនឯង និងស៊ីអាហារគ្រប់យ៉ាង។

ព្រះមិនបានដកយកអ្វីដែលល្អចេញទេ នៅ ពេលដែលទ្រង់ប្រទានច្បាប់នេះ។

ទ្រង់ជ្រាបថា សត្វណាមួយដែលផ្តល់ សុខភាពល្អ និងសត្វណាមួយដែលធ្វើឱ្យ មានជម្ងឺនិង ការឈឺថ្កាត់ផ្សេងៗ


72

(ព្រះគម្ពីរ ទំនុកដំកើង ៨៤:១១)

"...ព្រះយេហូវ៉ាទ្រង់នឹងផ្តល់ព្រះគុណ ព្រមទាំងកិត្តិយសទ្រង់និងមិនសំចៃទុករបស់ល្អអ្វី ដល់ពួកអ្នកដែលដើរ ដោយទៀងត្រង់ ឡើយ"

ទំនុកដំកើង ៨៤:១១


73

ជ្រូកជាសត្វដែលស៊ីអ្វីៗគ្រប់ទាំងអស់ ចំណីអាហារដែលជ្រូកស៊ី ដែលមានទាំង សំរាមផងនោះ ត្រូវបានកិនរំលាយជាសាច់ ឈាម នៅក្នុងរយៈពេលបីបួនម៉ោង ប៉ុណ្ណោះ។ រីឯ គោវិញមានប្រព័ន្ធ រំលាយអាហារសាំញ៉ាំ។

វាត្រូវការពេលវេលា ៤៨ម៉ោងដើម្បីឱ្យ អាហារវាបានកែប្រែត្រឡប់ទៅជាសាច់ ឈាម។

ហើយវាក៏មានប្រព័ន្ធនៃការបញ្ចេញ ចោលយ៉ាងសាំញ៉ាំច្រើន ទៀតដែល សម្រាប់បញ្ចេញជាតិមិនបរិសុទ្ធ ចេញពីប្រ ព័ន្ធនោះដែរ។


74

ជ្រូកតែងតែត្រូវបានចម្លងមកនូវកូនព្រូន

ឬព្រូន។

នៅពេលដែលមនុស្សបរិភោគសាច់ជ្រូកដែលបានឆ្លងនេះ ពងរឹងដែលនៅព័ទ្ធជុំវិញពង

ញាស់នោះត្រូវបានរលាយ។

ពេលនោះទ្រីកូមីណាស ក៏រុលចូលទៅ ក្នុងជញ្ជាំងពោះវៀន ហើយបង្កើតកូនជា ច្រើននៅទីនោះ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


75

ព្រូននេះចូលទៅក្នុងចរន្តឈាមហូរ ហើយត្រូវបានពាំនាំទៅចែកចាយគ្រប់ ផ្នែកទាំងអស់នៃសពាំង្គកាយយើងទាំងអស់។

ជម្ងឺដែលបណ្ដាលមកពីការទទួលទានសាច់ ជ្រូក អាចក្លាយទៅជាជម្ងឺដែលបណ្ដាលឱ្យ ស្លាប់យោងទៅតាមចំនួនព្រូនដែលបាន បរិភោគ។

ជាទូទៅ ជម្ងឺនេះ តែងតែត្រូវបានគេ ឱ្យរោគវិនិច្ឆ័យខុស ទៅជាជម្ងឺសន្លាក់ដៃ ជើង ឬពុលអាហារទៅវិញ។


76

ការវះកាត់សព បង្ហាញឱ្យឃើញថា សាកសពដែលគេទុកមិនឱ្យរលួយជាច្រើន ដែលរស់នៅជំនាន់លោកម៉ូសេ ត្រូវបានឆ្លង ដោយព្រូន ទ្រីកូមីណាសនេះដែរ!

ព្រះទ្រង់ជ្រាបយ៉ាងច្បាស់  ទុកវាឱ្យនៅ តែឯងទៅ!

ព្រះទ្រង់ក៏បានប្រទានការណែនាំអំពីត្រីដែរ


77

(ព្រះគម្ពីរ ចោទិយកថា ១៤:៩,១០)

"ឯបណ្ដាសត្វទាំងប៉ុន្មានដែលនៅក្នុងទឹក នោះឯងនឹងបរិភោគសត្វទាំងនេះបាន គឺសត្វណាដែលមានព្រុយ ហើយមានស្រ កាផង។


78

តែមិនត្រូវឱ្យបរិភោគសត្វណាដែល គ្មានព្រុយនិងស្រកាទេ ដ្បិតជាសត្វដែលមិនស្អាតទាំងអស់ដល់ឯងរាល់គ្នា"

ចោទិយកថា ១៤:៩,១០



79

នោះច្បាស់លាស់ណាស់ ហើយសូមកត់ សំគាល់ម្ដងទៀតថា មានគោលការណ៍ ណែនាំពីរ ដែលធ្វើឱ្យវាងាយស្រួលចងចាំ។



80

១) មានព្រុយ និង



81

២) មានស្រកា។

តើលោកអ្នកអាចគិតអំពីអាហារសមុទ្រ ដែលគ្មានព្រុយ និងគ្មានស្រកាដែលគេកំពុងបរិភោគជាទូទៅ នៅលើពិភព លោកនេះដែរឬទេ?

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


82

វេជ្ជបណ្ឌិត ប្រ៊ូស ហាលស្ដេដ នៃ សាកលវិទ្យាល័យ ឡូម៉ាលិនដា ត្រូវបាន រដ្ឋាភិបាលសុំឱ្យធ្វើការស្រាវជ្រាវសម្រាប់ កងទ័ព ដើម្បីបញ្ជាក់ថា តើត្រីណាដែល
មានសុវត្ថិភាពដល់ការប្រើប្រាស់របស់មនុស្ស
និងត្រីណាដែលមានជាតិពុល។


83

ពួកនាវិក ដែលត្រូវបានទូកលិចឬគៀង នៅកណ្ដាលសមុទ្រត្រូវការដឹងថា ត្រីណា ពុល និងត្រីណាដែលពួកគេអាចបរិភោគ បាន ដើម្បីឱ្យមានជីវិតរស់នៅ។

នៅពេលដែលការងារនេះត្រូវបានចប់ សព្វគ្រប់ហើយ វេជ្ជបណ្ឌិត ហាលស្ដេដ
បានសរុបសេចក្ដីមកជា ច្បាប់មេដៃ សម្រាប់កងទ័ព និងមនុស្សជាច្រើនទៀត ដើម្បីអនុវត្តតាម
ដូចជាគោលការណ៍ ណែនាំមួយ ដែលព្រះបានប្រទានដល់ពួក អ៊ីស្រាអែលតាំងពី
៣៥០០ឆ្នាំមុនមកហើយ នោះដែរ:


84

(ព្រះគម្ពីរ ចោទិយកថា ១៤:៩)

"ឯបណ្ដាសត្វទាំងប៉ុន្មានដែលនៅក្នុងទឹក នោះឯងនឹងបរិភោគសត្វទាំងនេះបាន គឺ
សត្វណាដែលមានព្រុយ ហើយមានស្រកា ផង"។ ព្រះទ្រង់បានជ្រាបនូវអ្វីដែលទ្រង់ បានបង្កើត
ហើយនិងមូលហេតុដែលយើង គួរបរិភោគ និងមិនគួរបរិភោគ នូវចំណី ណាខ្លះ។


85

"ចុះសត្វស្លាបវិញ" លោកអ្នកប្រហែលជា នឹងសួរ។

ព្រះគម្ពីរផ្ដល់នូវការបង្រៀនដ៏សំខាន់នេះ


86

(ព្រះគម្ពីរ ចោទិយកថា ១៤:១១,១២)

"ឯបណ្ដាសត្វហើរដែលស្អាត នោះឯង រាល់គ្នានឹងបរិភោគបានគ្រប់យ៉ាង


87

តែសត្វហើរទាំងនេះមិនត្រូវឱ្យបរិភោគ ឡើយ..."

ខ ១១,១២



88

(វីដេអូ ១៨វិនាទី) ព្រះបន្ទរាយឈ្មោះសត្វ ស្លាបមិនស្អាតទាំងនោះ:

គឺ ត្មាត ស្ទាំង ខ្លែង ក្អែក មៀម ទុង ក្រៀល កុក ក្រសារ តាមពូជវា។

# ១៥. ចូរបង្ហូរលនាឡិកាថយក្រោយ


89

(ព្រះគម្ពីរ ចោទិយកថា ១៤:១៩)

រួចព្រះទ្រង់បានមានព្រះបន្ទូលថា "និង អស់ទាំងសត្វដែលវាហើរផង នោះជាសត្វ មិនស្អាតដល់ឯង មិនត្រូវបរិភោគឡើយ" ខ ១៩។


90

(ព្រះគម្ពីរ លេវីវិន័យ ៣:១៧)

ព្រះបានប្រទានការណែនាំបន្តទៅទៀត ថា "នេះជាច្បាប់នៅអស់កល្បជានិច្ច ដល់អស់ទាំងតំណឯងរាល់គ្នាតទៅ នៅគ្រប់ទី កន្លែងណាដែលឯងរាល់គ្នាតាំងទីលំនៅ


91

គឺថាមិនត្រូវឱ្យឯងរាល់គ្នាបរិភោគខ្លាញ់ឬ ឈាមឡើយ"

លេវីវិន័យ ៣:១៧


92

ពួកយូដាអ៊ុរតូដុក នៅតែបន្តអនុវត្តការ ណែនាំនេះរហូតមកទល់សព្វថ្ងៃនេះ។

នៅពេលដែលគេសម្លាប់សត្វ គេដាក់ ក្បាលចុះក្រោម ដើម្បីឱ្យឈាមហូរចេញ អស់។

បន្ទាប់មកសត្វនោះត្រូវបានសម្លាប់ដោយ ត្រាំក្នុងទឹកអំបិល ដើម្បីយកឈាមដែលសេសសល់ចេញ។


93

ខ្លាញ់ត្រូវបានគេកាត់ចេញមិនបរិភោគ ឡើយ។

អស់ពេលជាច្រើនឆ្នាំ មនុស្សបានគិតថា ការហាមមិនឱ្យបរិភោគខ្លាញ់និងឈាម គ្រាន់តែជាច្បាប់ដែលធ្វើឱ្យទើសទែងមួយ ដែលព្រះបានប្រទានមកតែប៉ុណ្ណោះ។


94

ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវ ទំនើប បញ្ជាក់បន្ថែមអំពីការត្រាស់បង្គាប់ ដែលប្រកបដោយគតិបណ្ឌិតរបស់ព្រះទាំងនេះ។


95

ឥឡូវនេះយើងដឹងថា ឈាមនេះ នាំ សារធាតុកខ្វក់ មេរោគ វីរុស និងកាកសំណល់នៃសពាង្គកាយ។

ជម្ងឺជាច្រើនត្រូវបានឆ្លងតាមឈាមនេះ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



96

យើងក៏បានដឹងផងដែរថា ខ្លាញ់សើម ដោកជាំច្រើន ដូចជាគេបានរកឃើញនៅ ក្នុងកន្លែងធ្វើម្ហូប និងសាច់ក៏បណ្ដាលឱ្យ មានកំណើនកំរិតអង្គធាតុខ្លាញ់នៅក្នុងឈាម ដែលជាកត្តាសំខាន់មួយបណ្ដាលឱ្យ កើតជម្ងឺសាច់ដុំ និងជម្ងឺបេះដូងដែរ។

ជម្ងឺជាច្រើននឹងត្រូវបានចៀសវាង ប្រ សិនបើមនុស្សទុកចិត្តថា អ្វីគួរបរិភោគ និងអ្វីដែលមិនគួរបរិភោគ!



97

ការហាត់ប្រាណដើម្បីសុខភាព

ព្រះគម្ពីរបានប្រាប់ថា បន្ទាប់ពីព្រះបាន បង្កើត អ័ដាម និងនាងអេវ៉ាមក ទ្រង់បាន ប្រទានការងារឱ្យពួកគេធ្វើសកម្មភាពដែល មានប្រយោជន៍ និងការហាត់ប្រាណខ្លះ



98

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៥)

"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកអ័ដាមទៅដាក់ក្នុងសួនច្បារអេដែន ឱ្យគាត់ធ្វើការ ហើយ ថែរក្សា" លោកុប្បត្តិ ២:១៥



99

ការហាត់ប្រាណ ការពារខ្លួនប្រាណ យើងពីជម្ងឺជាច្រើន! រាងកាយដែលគ្មាន សកម្មភាពនឹងកាន់តែយ៉ាប់យ៉ឺនឡើង១។



100

ការហាត់ប្រាណបង្កើននូវចលនាសាច់ដុំ និងសរសៃឈាម



101

សួតក្លាយជាមានកម្លាំងខ្លាំង ដែលអាច ធ្វើឱ្យខ្យល់មានដំណើរការបានច្រើនជាងធម្មតា ដោយប្រើកម្លាំងតិច។



102

បេះដូងមានសមត្ថភាពខ្លាំងឡើង បាញ់ ឈាមបានច្រើនដោយចង្វាក់បេះដូងនី មួយៗ ផលិតអុកស៊ីហ្សែនដែលត្រូវបាននាំ ទៅចែកចាយដល់ជាលិកាទាំងឡាយនៃរាង កាយ។

ក្រោយពេលដែលអ័ដាមនិងនាងអេវ៉ា មានបាប ព្រះបានបង្កើនការងារ និងតម្រូវការងារខាងរាងកាយបន្ថែមទៀត។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


103

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១៩)

ព្រះបានមានព្រះបន្ទូលថា "ឯងនឹងបាន អាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ជាធូលីដីវិញ"

លោកុប្បត្តិ ៣:១៩

ទ្រង់ក៏បានមានព្រះបន្ទូលផងដែរថា ផែនដីនឹងត្រូវបណ្តាសារ ហើយបន្លា និង អញ្ចាញនឹងដុះឡើង ហើយថា "ឯងត្រូវរក ស៊ីដោយនឿយហត់អស់មួយជីវិត" ខ ១៧,១៨។


104

ព្រះទ្រង់បានជ្រាបថា មនុស្សត្រូវការ ហាត់ប្រាណ ហើយគេមិនមែនត្រូវការ ការហាត់ប្រាណ ដើម្បីគ្រាន់តែសម្រាប់រាង កាយគេតែប៉ុណ្ណោះទេ ប៉ុន្តែដើម្បីរក្សា សុខភាពពួកគេ អោយជៀសផុតពីជម្ងឺ ផ្សេងៗ។

អ្នកខ្លះនិយាយថា "ភាពឥតការងារធ្វើ គឺជាការថ្វាយបង្គំដល់អារក្ស"


105

(ព្រះគម្ពីរ និក្ខមនំ ២០:៩)

ព្រះបានមានព្រះបន្ទូលថា "ក្នុងរវាង៦ថ្ងៃនោះត្រូវឱ្យឯងធ្វើអស់ទាំងការ របស់ឯងចុះ" និក្ខមនំ ២០:៩។

ប្រសិនបើមនុស្សបានធ្វើការ ៦ថ្ងៃក្នុង មួយសប្តាហ៍ពួកគេនឹងមានការនឿយហត់ យ៉ាងខ្លាំង នឹងធ្លាក់ចូលទៅក្នុងបញ្ហា!


106

រាងកាយរបស់យើងគឺជាព្រះវិហាររបស់ ព្រះវិញ្ញាណបរិសុទ្ធ

ការសំខាន់នៃការថែរក្សា រាងកាយរបស់ យើងអាចត្រូវបានយល់ កាលណាយើង ដឹងថាតើវាសំខាន់យ៉ាងណា ចំពោះព្រះ តែប៉ុណ្ណោះ។


107

(ព្រះគម្ពីរ កូរិនថូសទី១ ៦:១៩,២០)

លោកសាវកប៉ុលបាននិយាយថា "តើ មិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ


108

ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


109

ដ្បិតព្រះទ្រង់បានចេញថ្លៃលោះអ្នករាល់ គ្នាហើយ ដូច្នេះចូរដំកើងព្រះនៅក្នុងរូប កាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា ដែលជារបស់ផងទ្រង់ចុះ"
កូរិនថូសទី១ ៦:១៩,២០


110

មនុស្សជារបស់ព្រះដោយការបង្កើតមក និងដោយការចេញថ្លៃលោះ។
តម្លៃដែលព្រះបានចេញលោះយើង គឺ ការលះបង់ព្រះរាជបុត្រារបស់ទ្រង់នៅភ្នំ វលាក្បាល។
ដោយសារតែមនុស្សត្រូវបានលោះដោយ តម្លៃដែលមិនអាចកំណត់បានដូច្នេះ គេត្រូវ តែសរសើរដំកើងព្រះនូវគ្រប់ទាំងការដែលគេ ធ្វើ។


111

(ព្រះគម្ពីរ កូរិនថូសទី១ ១០:៣១)
"ដូច្នេះទោះបើស៊ីឬផឹក ឬធ្វើការអ្វីក៏ ដោយ នោះចូរធ្វើទាំងអស់សម្រាប់ចំរើន សិរីល្អដល់ព្រះចុះ"
កូរិនថូសទី១ ១០:៣១
មនុស្សរាល់គ្នាដែលពិតជាស្រឡាញ់ព្រះ និងប្រុងប្រយ័ត្នដើម្បីចៀសវាងពីអ្វីដែលនឹងបំផ្លាញឬធ្វើឱ្យខូចដល់រាងកាយរបស់គេ។


112

(ព្រះគម្ពីរ កូរិនថូសទី១ ៣:១៧)
"បើអ្នកណាបង្ខូចព្រះវិហារនៃព្រះ នោះ ព្រះនឹងធ្វើឱ្យអ្នកនោះត្រូវខូចដែរ


113

ដ្បិតព្រះវិហារនៃព្រះជាវត្ថុដ៏បរិសុទ្ធ គឺ ជាខ្លួនអ្នករាល់គ្នានេះឯង"
កូរិនថូសទី១ ៣:១៧។
ប្រហែលជាលោកអ្នកឆ្ងល់ថា តើ មនុស្សគេធ្វើឱ្យរាងកាយគេខូចដោយរបៀបណា។
លោកប៉ុលរៀបរាប់រឿងរ៉ាវមួយចំនួន ដែលយើងត្រូវចៀសវាង:


114

(ព្រះគម្ពីរ កូរិនថូសទី១ ៦:៩,១០)
"...កុំឱ្យច្រឡំឡើយ ដ្បិតពួកមនុស្ស កំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសាហាយ ស្មន់ ពួកអ្នកសំរេចកិច្ច ដោយខ្លួនឯង ពួក លេងកូនជឹង

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


115

ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល និងពួកប្លន់កំហែង នោះ មិនដែលគ្រងនគរព្រះទុកជាមរតកឡើយ”

កូរិនថូសទី១ ៦:៩,១០

ព្រះគម្ពីររៀបរាប់ពីអំពើអសីលធម៌ និងការនាំទៅរកផ្លូវអាក្រក់ ថាជាការ អនុវត្តន៍ នៃការបំផ្លាញរូបរាងកាយដែរ។

ព្រះគម្ពីរក៏បានរៀបរាប់ពីការទទួលទាន ស្រាផងដែរ។


116

(ព្រះគម្ពីរ សុភាសិត ២០:១)

ស្ដេចសាឡូម៉ូនបានសរសេរថា “ឯស្រា ទំពាំងបាយជូរជារបស់បញ្ឆោតមើលងាយ ហើយគ្រឿងស្រវឹងបង្កើតការឡូឡា អ្នក ណាដែលវង្វេងដោយគ្រឿងទាំង២ នោះ ឈ្មោះថាគ្មានប្រាជ្ញា”

សុភាសិត ២០:១


117

(ព្រះគម្ពីរ សុភាសិត ២៣:៣១-៣៣)

“កុំឱ្យមើលស្រាទំពាំងបាយជូរ ក្នុង កាលដែលមានពណ៌ក្រហម គឺនៅក្នុងកាល ដែលព្រួចពពុះនៅក្នុងកែវ ហើយហូរចុះ ទៅដោយស្រួលនោះឡើយ


118

ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ ហើយអុចដូចជាពស់ហនុមានផង


119

ភ្នែកឯងនឹងឃើញស្រីដទៃ ហើយចិត្ត នឹងពោលសេចក្ដីខូចអាក្រក់ដែរ”

សុភាសិត ២៣:៣១-៣៣


120

ការនិយមសុរាជាបញ្ហាដ៏ធំបំផុតសម្រាប់ សុខភាពនៅលើពិភពលោកនេះ។

ជាងពាក់កណ្ដាលនៃគ្រោះថ្នាក់ចរាចរ ត្រូវបានគេដៅយ៉ាងចំៗទៅលើអ្នកបើកបរ ឬអ្នកថ្មើរជើង ដែល“នៅក្រោមឥទ្ធិពល” “នៃសុរា”

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


121

នៅក្នុងជាងពាក់កណ្តាលនៃអំពើឃាត កម្ម ជូនកាលអ្នកសម្លាប់ ជូនកាលអ្នក ស្លាប់ ជូនកាលទាំងពីរនាក់បានផឹកស្រា!


122

ស្រាធ្វើឱ្យរាងកាយទ្រុឌទោម ហើយ គ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ វីតាមីន ហើយជាតិស្ករដែលមាននៅក្នុង ស្រា(ភេសជ្ជៈដទៃទៀត) បន្ថយលទ្ធភាព របស់រាងកាយក្នុងការប្រយុទ្ធ តទល់ជាមួយ នឹងជំងឺក្តៅខ្លួន


123

ស្រាធ្វើឱ្យថ្លើមមានជាតិខ្លាញ់។ អ្នក ទទួលទានស្រា មានវាសនានៃការស្លាប់ ដោយជម្ងឺ ក្រិនថ្លើម ច្រើនជាងអ្នក មិនទទួលទានស្រា។

ការកាត់បន្ថយអាយុដោយការទទួល ទានសុរា យ៉ាងហោចណាស់ក៏១២ឆ្នាំដែរ។ ហើយយោងទៅតាមស្ថិតិចុងក្រោយនេះ មនុស្សម្នាក់ក្នុងចំណោមដប់នាក់ ដែលចាប់ផ្តើមទទួលទានស្រា នឹងក្លាយទៅជាអ្នក ញៀនស្រា។


124

ការស្រាវជ្រាវថ្មីៗបង្ហាញថា កោសិកា ខួរក្បាលជាច្រើនត្រូវស្លាប់ នៅរៀងរាល់ពេលទាំងឡាយណា ដែលស្រាបានចូលទៅ ក្នុងសរសៃឈាម ហើយថា ឪពុក


125

និងម្តាយដែលទទួលទានស្រានោះ មាន ឥទ្ធិពលយ៉ាងខ្លាំងក្លា ធ្វើឱ្យកូន របស់គេ កើតមកមាន រូបរាងកាយ មិនប្រក្រតី ច្រើនជាងកូនអ្នកដែលមិនទទួលទានស្រា។

ប៉ុន្តែសម្រាប់គ្រីស្ទាន ការប្រើប្រាស់ស្រា ជាភេសជ្ជៈ មានផលវិបាកធំជាងនោះ ទៅទៀត។


126

គ្រីស្ទានត្រូវប្រើគំនិតរបស់ខ្លួនយ៉ាងពេញ លេញ ដើម្បីទប់ទល់នឹងការល្បួងរបស់ សាតាំង។

គេមិនអាចទទួលយកនូវការអន់ថយក្នុង ការវិនិច្ឆ័យ ឬបាត់បង់ភាពជាម្ចាស់ការ ក្នុង ការញែកឱ្យដាច់ពីគ្នា នូវការល្អនិងការ អាក្រក់នេះទេ!


127

ព្រះយេស៊ូវបានបដិសេធ ទឹកខ្មេះដែល ទាហានបានផ្តល់ឱ្យទ្រង់នៅលើឈើឆ្កាង ក្នុងន័យ ដើម្បីបំបាត់ការឈឺចាប់របស់ទ្រង់។

១៥. ចូរបង្វិលនាឡិកាថយក្រោយ

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


128

ទោះបីជាព្រះយេស៊ូវបានរងទទួលនូវការ ឈឺចាប់យ៉ាងខ្លាំងក្លាក៏ដោយ ក៏ទ្រង់មិន ព្រមទទួលអ្វីដែលធ្វើឱ្យវង្វេង សូម្បីតែ បន្តិចនោះទេ រហូតដល់ពេលដែលទ្រង់ បានសុគតទៅ


129

ការអនុវត្តន៍ ធម្មតាជាច្រើនទៀតធ្វើឱ្យ សុខភាពមានការចុះថយ ដ៏គួរឱ្យមានគ្រោះ ថ្នាក់។

អ្នកជក់បារី មានជោគវាសនាអាក្រក់ ដល់ស្លាប់ ដោយជម្ងឺមហារីកសួត ១ពាន់ភាគរយច្រើនជាងអ្នកមិនជក់។

ហើយមហារីកមិនមែនជាឃាតកររបស់ ថ្នាំជក់តែម្នាក់ឯងប៉ុណ្ណោះទេ។

ជោគវាសនានៃការស្លាប់របស់អ្នកជក់ បារីដែលបណ្តាលមកពីជម្ងឺបេះដូង មាន ១០៣ភាគរយច្រើនជាងអ្នកដែលមិនធ្លាប់ ជក់បារីជាទៀងទាត់។


130

ជម្ងឺសួតកំពុងបំផ្លាញជីវិត មនុស្សច្រើនជាង៥៥ ០០០នាក់ ក្នុងមួយ ឆ្នាំៗ!

ជាតិនីកូទីនក៏បណ្តាលឱ្យសរសៃឈាមរួម តូចដែរ


131

ការផ្សំជាតិខ្លាញ់នេះបានកើតឡើង និង ការរួមតូចនៃសរសៃអាទែរ បង្អាក់គ្រាប់ ឈាមពីការចែកចាយឈាមឱ្យបានគ្រប់ គ្រាន់ទៅកាន់សរសៃឈាម បេះដូង ចុងដៃ ចុងជើង និងសរីរាង្គផ្សេងៗទៀត។

នៅពេលនោះ វាយកបានតែដុំឈាមដ៏ តូចមក សរសៃឈាមរួមតូចបណ្តាលឱ្យមានការគាំងបេះដូងឬ ជម្ងឺស្លាប់ដៃជើង។


132

អ្នកជក់បារី ក៏ជាទិសដៅដ៏សំខាន់នៃការ វង្វេងវង្វាន់ដែរ ពីព្រោះតែការថយចុះ នៃអុកស៊ីហ្សែនទៅកាន់ខួរក្បាល


133

ស្រីដែលជក់បារីនៅពេលមានផ្ទៃពោះ នោះ កំពុងបំផ្លាញគ្រាប់ឈាមរបស់កូនខ្លួន ឯងហើយ។

ការស្លាប់របស់ទារកដែលទើបនឹងកើត មានចំនួន២៧ភាគរយ ខ្ពស់ជាងទារកដែលមានម្តាយជាអ្នកពិសាបារី។


134

ការជក់បារីបានបណ្តាលឱ្យមនុស្សស្លាប់ ជាង ៥០០ ០០០នាក់ស្លាប់ គ្រាន់តែនៅប្រ ទេស អាមេរិកមួយប៉ុណ្ណោះកាលពីឆ្នាំទៅ មិញនេះ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


135

(ព្រះគម្ពីរ និក្ខមនំ ២០:១៣)

ព្រះបានមានព្រះបន្ទូលថា "កុំឱ្យសម្លាប់ មនុស្សឱ្យសោះ" និក្ខមនំ ២០:១៣

តើមានមនុស្សប៉ុន្មាននាក់ដែលសម្លាប់ ខ្លួនឯងដោយរបស់ដែលគេបរិភោគ ផឹក និងជក់នេះ?


136

អ្នកខ្លះបាននិយាយថា អាវុធដ៏សាមញ្ញ បំផុត ក្នុងការធ្វើអត្តឃាតគឺ កាំបិត សម និងស្លាបព្រា។ ប្រហែលយើងត្រូវបន្ថែមកែវ និងដប ផងដែរ!


137

"កាហ្វេអ៊ីន គឺជាគ្រឿងញៀនដែល មាននៅក្នុងកាហ្វេ ត្រូវបានគេចាត់ថ្នាក់នៅ ក្នុងសៀវភៅថា ជាគ្រឿងលើកកម្លាំងឬ លើកទឹកចិត្តផង និងជាថ្នាំពុលផង"

លោក ហ្វេរ៉ូល ស្រើយ៉ូក វេជ្ជបណ្ឌិត នៅ ក្នុងសៀវភៅ អ្នកនិងសុខភាពរបស់អ្នក វ៉ុលទី១ ទំព័រ៤១៣។



138

តែ និងភេសជ្ជៈកូឡា ក៏មានជាតិ កាហ្វេអ៊ីនដែរ។

ភេសជ្ជៈទាំងនេះ ឥឡូវនេះត្រូវបានគេ ភ្ជាប់ទៅនឹងជម្ងឺបេះដូង ការមិនធម្មតានៃ ប្រព័ន្ធសរសៃប្រសាទ និងមហារីកប្លោក នោម។


139

ប្រសិនបើអ្នកបានស្គាល់អ្នកណាម្នាក់ ដែលប្រញាប់ប្រញាល់ចូលទៅក្នុងបន្ទប់មួយ ទៀត ដើម្បីចាក់កាហ្វេអ៊ីនពីរបីគ្រាប់ចូល ទៅក្នុងសរសៃឈាមរបស់គេ នៅក្នុង ពេលពីរបីម៉ោងម្តងនោះ អ្នកនឹងហៅគេថា អ្នកញៀន។

នៅតែមានមនុស្សជាច្រើនដែលកំពុងធ្វើ ការដូចគ្នានេះជាមួយនឹងកាហ្វេ និងភេសជ្ជៈ កូឡា។



140

ការចេះចាំប្រមាណមានន័យថា ការ ចៀសវាងមិនប្រើប្រាសនូវអ្វីៗដែលមិនធ្វើឱ្យ មានការ ឈឺចាប់និងមិនប្រើអ្វីៗដែលល្អ នោះច្រើនហួសហេតុ។


141

មនុស្សជាច្រើន ប្រើប្រាស់ច្រើនពេក នូវអ្វីដែលល្អ!

ការនេះនាំទៅរកបញ្ហាសុខភាពមួយដ៏ ធំទៀតសម្រាប់មនុស្សនៅក្នុងផ្នែកជាច្រើន លើពិភពលោកនេះ។


142

"មានអ្នកខ្លះបានចាំប្រមាណថា រាល់ ទម្ងន់ខ្លាញ់ក្នុងរាងកាយ៤ខាំកន្លះ ត្រូវការ សរសៃឈាមបន្ថែមក្នុងរាងកាយនោះជិត១គីឡូម៉ែត្រ។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



143

ហើយបេះដូងត្រូវបាញ់ឈាមតាមប្រព័ន្ធ បន្ថែមនៃសរសៃឈាមនេះ" វេជ្ជបណ្ឌិត ហារ៉ូល ស្រ៊ិយ៉ុក អ្នកនិងសុខភាពរបស់ អ្នក វ៉ុលទី១ ទំព័រ ៣៩៥។



144

បេះដូង តម្រងនោម ថ្លើម និងសួត របស់អ្នកលើសទម្ងន់ ត្រូវធ្វើការហួស កម្លាំង។

អ្នកដែលលើសទម្ងន់ទទួលរងគ្រោះ ដោយជម្ងឺ ដប់ប្រាំមួយយ៉ាងច្រើនជាងមិត្ត របស់គេដែលស្គម១។



145

ព្រះចង់ឱ្យយើងថែរក្សារូបកាយយើងឱ្យ បានល្អ ដើម្បីឱ្យយើងមានអំណរនៅក្នុង ជីវិតដ៏ល្អបំផុតរបស់ខ្លួននៅពេលឥឡូវនេះ។

ទ្រង់ចង់ឱ្យយើងជាមនុស្សមានការទទួលខុស ត្រូវមានសីលធម៌ និងរីករាយ។

ទ្រង់ចង់ឱ្យយើងមានជីវិតដ៏ល្អប្រសើរ។

រស់នៅបានយូរប៉ុនណា និងមានសុខភាពល្អ ប៉ុនណានោះ វាអាស្រ័យទៅលើការដែល យើងគោរពការណែនាំ របស់ព្រះបាន ប៉ុនណាដែរ



146

ការសម្រាក និងការលំហែ

ព្រះយេស៊ូវបានជឿទៅលើការសម្រាក និងការចេញឱ្យឆ្ងាយអំពីភាពតានតឹង។

បន្ទាប់ពីថ្ងៃដ៏ហត់នឿយជាមួយមនុស្ស ជាច្រើនកុះករមក ព្រះយេស៊ូវបានមានព្រះ បន្ទូលទៅកាន់ពួកសាវកទ្រង់ថា




147

(ព្រះគម្ពីរ ម៉ាកុស ៦:៣១)

"អ្នករាល់គ្នាមកឯទីស្ងាត់ដោយឡែក នឹងឈប់សំរាកបន្តិចសិន"

ម៉ាកុស ៦:៣១

ព្រះយេស៊ូវចង់ឱ្យយើងមានតុល្យភាព រវាងការងារ និងការសម្រាកឬការបន្ធូរ បន្ថយ។



148

ហេតុនោះហើយបានជាទ្រង់ប្រទានថ្ងៃ បរិសុទ្ធដល់យើង។

ព្រះទ្រង់ជ្រាបថា យើងត្រូវការបំភ្លេច បញ្ហា និងការងាររបស់យើង ហើយ ចំណាយពេលជាមួយទ្រង់។

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


149

ពេលវេលារបស់អ្នក នៅឆ្ងាយពីកម្មវិធី ដ៏មមាញឹកនោះ ប្រហែលជាមិនមែននៅទីរហោស្ថាននោះទេ

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ទីរហោ ស្ថានជាកន្លែងសម្រាកដ៏ល្អម្តងម្កាល នៅពេលវិសម្សកាលដែរ។

អ្នកអាចចូលចិត្តតំបន់ដ៏ស្ងៀមស្ងាត់ នៅ តាមភ្នំដែលមានដើមឈើខ្ពស់ៗ និងទឹកបឹងយ៉ាងជ្រៅដែលអាចរំងាប់ ចិត្តរសាប់រសល់ របស់អ្នកបាន។


150

ទោះជាទីណាក៏ដោយ អ្នកត្រូវតែរក កន្លែងដែលឆ្ងាយពីទីក្រុង ដែលមានហ្វូង មនុស្សម្នា និងសម្លេងខ្ទៀវខ្ទារ និងផ្លូវថ្នល់។

ប្រសិនបើអ្នកមានការលេងសប្បាយបន្តិច បន្តួចផងនោះ វារឹតតែប្រសើរណាស់ទៅ ទៀត!។


151

មែនហើយ ព្រះចង់ឱ្យលោកអ្នកមានស្ថានសួគ៌ តូចមួយនៅទីនេះ ហើយដើម្បីរៀបចំខ្លួន នឹងរស់នៅក្នុងផែនដីថ្មី ជាកន្លែងដែល ជម្ងឺតម្កាត់ទាំងឡាយដែលធ្វើឱ្យ ផែនដីនេះមានការឈឺចាប់ នោះនឹងត្រូវរលាយបាត់ទៅ។


152

“ការនោះស្តាប់ទៅគួរឱ្យល្អណាស់ សម្រាប់ខ្ញុំ” អ្នកនិយាយ “ខ្ញុំចង់នៅទីនោះ ប៉ុន្តែខ្ញុំមានទម្លាប់ខ្លះដែលខ្ញុំមិនអាចយកឈ្នះ លើវាបាន”

មានដំណឹងល្អនៅថ្ងៃនេះ។

ព្រះមិនបានរំពឹងឱ្យលោកអ្នកធ្វើការនេះ ដោយខ្លួនឯងនោះទេ។



153

(ព្រះគម្ពីរ យ៉ូហាន ១៥:៥)

ជាការពិតណាស់ព្រះយេស៊ូវបានមាន បន្ទូលថា “ដ្បិតបើដាច់ពីខ្ញុំចេញនោះអ្នករាល់គ្នាមិនអាចនឹងធ្វើអ្វីបានទេ”

យ៉ូហាន ១៥:៥

យើងមិនអាចយកឈ្នះលើទម្លាប់អាក្រក់ ដោយសារកម្លាំងរបស់យើងឡើយ។

ព្រះអង្គសង្គ្រោះរបស់យើងទ្រង់គង់នៅ ទីនេះ រង់ចាំជួយយើង!



154

(ព្រះគម្ពីរ ភីលីព ៤:១៣)

ទ្រង់បានមានព្រះបន្ទូលថា “ខ្ញុំអាចនឹង ធ្វើ គ្រប់ទាំងអស់បានដោយសារព្រះគ្រីស្ទទ្រង់ចំរើនកម្លាំងដល់ខ្ញុំ”

ភីលីព ៤:១៣

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ



155

ស្ត្រីម្នាក់បានចូលរួមក្នុងការប្រជុំបែប នេះនៅល្ងាចមួយ។

នៅពេលដែលលោកគ្រូគង្វាលបានទៅ លេងជាមួយនាង គាត់បាននិយាយជាមួយ នាង អំពីការត្រឡប់មកកាន់គ្រួសាររបស់ ព្រះវិញ។

មានទឹកភ្នែករលីងរលោងហូរចេញពីភ្នែក របស់នាង នៅពេលដែលនាងបានឆ្លើយ "ខ្ញុំចង់ដែរ តែខ្ញុំមិនអាចធ្វើបានទេ ព្រោះខ្ញុំ ជក់បារី" គាត់បានហៅនាងចំឈ្មោះ ហើយនិយាយថា "តើនាងជឿថា ព្រះ យេស៊ូវចង់ឱ្យនាង មានជ័យជំនះលើទម្លាប់អាក្រក់នេះឬទេ?"

"អូ ចាំ ខ្ញុំជឿ ប៉ុន្តែខ្ញុំមិនអាចឈ្នះ បានទេ ព្រោះខ្ញុំខ្សោយណាស់" គាត់ឆ្លើយ "សូមឱ្យខ្ញុំអានខ ព្រះគម្ពីរមួយជូននាង?"

គាត់បានបើកព្រះគម្ពីររបស់គាត់ទៅ យ៉ូហានទី១ ៥:១៤ "យើងមានសេចក្តី ក្លាហានដល់ទ្រង់ យ៉ាងដូច្នេះដែរ គឺថា បើយើងនឹងសូមអ្វីដែលតម្រូវតាមព្រះ ហឫទ័យទ្រង់ នោះទ្រង់នឹងទទួលព្រម"

"ឥឡូវនេះ ម៉ារី តើនាងមានការទុកចិត្តថា នាងអាចឈប់ជក់បារីបានឬទេ? "គាត់បាន សួរទៅនាង។

"ទេ" នាងបានឆ្លើយ។

"ល្អ" គាត់បាននិយាយថា "ដោយ សារព្រះគម្ពីរបាននិយាយ នេះគឺជាការទុក ចិត្តទៅលើទ្រង់" ដូច្នេះតើឯណាទៅជា សេចក្តីក្លាហាននោះ?

នាងបានឆ្លើយ" នៅក្នុងទ្រង់"

# ១៥. ចូរបង្វិលនាឡិកាថយក្រោយ


156

គាត់បានអានព្រះគម្ពីរបន្ថែមទៀត "បើ យើងនឹងសូមអ្វីដែលត្រូវតាមព្រះហឫទ័យទ្រង់ លើកលែងតែការឈប់ជក់បារី នោះទ្រង់ នឹងទទួលព្រម

ដោយបែរទៅរកនាងមារី គាត់បានសួរ នាងថា តើខ្ញុំអាចសរសេរដូច្នោះនៅក្នុងព្រះ គម្ពីររបស់នាងបានឬទេ? តើខ្ញុំអាចយកព្រះ គម្ពីររបស់នាងមកសរសេរខនេះបានឬទេ?"

"ទេ ទេ"នាងនិយាយថា "ខ្ញុំមិនចង់ ផ្លាស់ប្តូរព្រះគម្ពីរទេ"

គាត់បាននិយាយថា "តើនេះមិនមែន ទៅតាមព្រះហឫទ័យរបស់ព្រះទេឬ សម្រាប់អ្នកក្នុងការឈប់ជក់បារីនេះ?"

"ចាំ វាពិតជាដូច្នោះមែន" នាងបាន ឆ្លើយតប។

ដូច្នេះតើអ្នកអាចសូមព្រះគ្រីស្ទចំពោះ ការទុកចិត្តទៅលើអំណាចរបស់ទ្រង់ ដែល ទ្រង់បានសន្យានោះឬទេ?"

អូ ចាំ នាងបានឆ្លើយតបវិញ"ខ្ញុំជឿថា ខ្ញុំអាច"

"ខ្ញុំមានសំណួរមួយទៀត"

នៅពេលណាដែលនាងទទួលអំណាច ដើម្បីឈប់ជក់បារីនេះ? តើមួយអាទិត្យ មួយខែ បីខែ ទើបនាងនឹងទទួលអំណាច នេះ?"

បន្ទាប់មកគាត់ យកព្រះគម្ពីររបស់គាត់ ហើយបើកនៅ យ៉ូហាន ១:១២ រួចអាន "ប៉ុន្តែអស់អ្នកណាដែល...នោះទ្រង់ បានប្រទានអំណាចឱ្យត្រឡប់ជាកូនព្រះ" គាត់បានបន្តទៀតថា។

"ឥឡូវ យប់នេះយើងបានឃើញថា អ្នកមានទំនុកចិត្តក្នុងព្រះយេស៊ូវ។ យើង បានឃើញថា អ្វីក៏ដោយដែល យើងសុំពី ទ្រង់ទៅតាមព្រះហឫទ័យរបស់ទ្រង់ ទ្រង់ នឹងប្រទានដល់យើង។

ហើយយើងដឹងថា ជាព្រះហឫទ័យ របស់ទ្រង់ ដើម្បីឱ្យអ្នកឈប់ជក់បារី។ យើងក៏បានឃើញផងដែរថា នៅពេល ដែលអ្នកទទួលទ្រង់ អ្នកនឹងបានទទួល អំណាចនេះ"


157

ជាមួយនឹងជំនួយពីទ្រង់ លោកអ្នកអាច មានជីវិតដែលប្រកបដោយសុខភាពល្អ អំណរ ដ៏ធំធេង នៅពេលឥឡូវនេះ ហើយនិងរីករាយនឹងទទួលជីវិតអស់កល្ប នៅផែនដីដែលបង្កើតថ្មី។

សូមឈោងដៃទៅរកព្រះយេស៊ូវ ទ្រង់ ក៏កំពុងតែឈោងព្រះហស្តទៅរកលោកអ្នក ដែរ!

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ




1

លោកអ្នកអាចចាប់ផ្ដើមម្ដងទៀត។




2

(វីដេអូ ១០វិនាទី)នៅក្នុងខែមិនា ឆ្នាំ ១៩៩២ អ្នកផ្សាយដំណឹងល្អរបស់គ្រីស្ទាន ម្នាក់ បានដឹកនាំការប្រជុំ ផ្សាយដំណឹងល្អ ជាបន្តបន្ទាប់មួយនៅក្នុងសាលប្រជុំ ក្រឹម ឡាំងនៃទីក្រុងម៉ូស្គូ។

បន្ទាប់ពីការប្រជុំមួយនៃកម្មវិធីនោះមក គាត់បានអង្គុយនៅក្នុងការិយាល័យរបស់គាត់ រំពេចនោះ ទ្វារត្រូវបានគេរុញបើកយ៉ាងខ្លាំង។



3

ក្មេងប្រុសដែលមានទឹកមុខមាំម្នាក់ ដែលមានពុកមាត់ស្រមូម ហើយអាក្រក់ មើលផង បានលេចមកផ្លោនៅក្នុងបន្ទប់។

ក្នុងជំនឿមួយថា គេនឹងប្រយុទ្ធជាមួយ នឹងគាត់។ អ្នកផ្សាយដំណឹងថយក្រោយ។ អ្នកបកប្រែភាសារុស្ស៊ីរបស់គាត់បោះជំហាន ទៅឈរនៅចន្លោះអ្នកទាំងពីរ។

រំពេចនោះ បុរសនោះចាប់ផ្ដើមនិយាយ ផ្ទាដៃផ្ទាជើងជាភាសារុស្ស៊ី។ អ្នកបកប្រែ ភាសាពន្យល់ថា មនុស្សនេះជាមនុស្សម្នាក់ ក្នុងចំណោម ឧក្រិដ្ឋជនដ៏ល្បីល្បាញនៅ ទីក្រុងម៉ូស្គូ។

គេបានជាប់គុក និងរួចចេញពីគុក ២៨ដងរួចមកហើយ។

ពោរពេញទៅដោយភាពជាអ្នកមាន ទោស និងអស់សង្ឃឹមរបស់គេ គេបាន ស្វែងរកសេចក្ដីសុខសាន្ត។

អ្នកផ្សាយដំណឹងបានអានព្រះគម្ពីរ យ៉ូហានទី១ ១:៩ យ៉ាងស្ងៀមស្ងាត់ "បើយើងលន់តួបាបវិញ នោះទ្រង់មាន ព្រះទ័យ ស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបរបស់យើង"

គាត់បានប្រាប់ជនដែលមានបញ្ហានោះ អំពីរឿងចោរនៅលើឈើឆ្កាង ដែលបាន រកឃើញការអត់ឱនទោស។

គាត់បានបញ្ជាក់ទៅកាន់អ្នកទោសនោះ ថា ព្រះសេស៊ូវគឺជាព្រះអង្គសង្គ្រោះ ដដែលនោះ នៅសព្វថ្ងៃនេះ។

ទ្រង់ប្រទានការអត់ឱនទោស។ ទ្រង់ប្រ ទានការរំដោះឱ្យចេញផុត។

ទ្រង់ប្រទានសេចក្ដីសង្គ្រោះ។ សូមអ្នក ទទួលចុះ! មានអំណរនៅក្នុងនោះ! សូម សរសើរដំកើងព្រះចំពោះការនោះ!"

ដោយមានទឹកភ្នែកហូរកាត់ផ្ទៃមុខរបស់ គាត់ ពិរុទ្ធជនរុស្ស៊ីម្នាក់នេះ បានលុត ជង្គង់និងទទួលការអត់ឱនទោសពីព្រះ។

១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ


4

ប្រហែលជាមួយឆ្នាំក្រោយមក អ្នក ផ្សាយដំណឹងនោះ បានទៅលេងទីក្រុងមូស្គូ។ ពេលដែលគាត់បានសរសើរដំកើងព្រះ ជា មួយក្រុមជំនុំនៅក្នុងព្រះវិហារដែលទើបនឹង បង្កើតថ្មីមួយនោះ គាត់បានឃើញឧក្រិដ្ឋជន ដែលបានផ្លាស់ប្រែនោះ កំពុងច្រៀងនៅ ក្នុងក្រុមចម្រៀងពិសេស។


5

មុខរបស់អតីតឧក្រិដ្ឋជនបានបង្ហាញនូវ សេចក្ដីសុខសាន្តថ្មីក្នុងចិត្តមួយ។

បុរសនោះបានបញ្ចេញនូវភាពរីករាយ។ គាត់បានទទួលព្រះគ្រីស្ទ។ ការបង្រៀននៅ ក្នុងព្រះគម្ពីរបានផ្លាស់ប្ដូរជីវិតគាត់ ហើយ គាត់បានដើរតាមព្រះយេស៊ូវដោយធ្វើការជ្រ មុជទឹកដូចព្រះគម្ពីរបានចែង។

ការជ្រមុជទឹកក្នុងព្រះគម្ពីរ គឺជានិមិត្ត រូបនៃជីវិតមួយ ដែលបានផ្លាស់ប្ដូរដោយ សារព្រះគុណរបស់ព្រះ។

ការជ្រមុជទឹកបង្ហាញដល់អ្នកដែលទើ បនឹងចាប់ផ្ដើមជីវិតថ្មីមួយក្នុងព្រះយេស៊ូវ គ្រីស្ទ។

ការជ្រមុជទឹកនិយាយពីជីវិតដែលបាន ផ្លាស់ប្ដូរមួយ។

ឧទាហរណ៍ដ៏មានអំណាចបំផុតមួយនៃ ការផ្លាស់ប្ដូរដ៏រំភើបក្រៃលែងនោះ គឺការ ដែលព្រះគ្រីស្ទបានធ្វើ នៅក្នុងជីវិតជា ប្រវត្តិសាស្រ្តរបស់លោកសុល ដែលក្រោយ មកបានក្លាយជាសាវកប៉ុល។


6

ទោះបីសុលមានសញ្ជាតិជាជនជាតិរ៉ូម តាំងពីកំណើត ហើយត្រូវបានអប់រំដោយ គ្រូដ៏ល្អៗ នៅទីក្រុងយេរូសឡិមក៏ដោយ។

សុលមានកាច្រណែនចំពោះសាសនាយូដា ហើយត្រូវបានគេស្គាល់ថា ជាអ្នកមានការ ប្រឆាំងយ៉ាងខ្លាំងក្លា ដើម្បីសេចក្ដីជំនឿ របស់គាត់។


7

សុល ដែលឈ្មោះរបស់គាត់ក្រោយមក បានក្លាយទៅជាប៉ុល ក្រោយពីបានផ្លាស់ប្រែ នោះ ពិពណ៌នាដោយខ្លួនឯង នូវអ្វីដែល គាត់បានធ្វើដើម្បីដាក់ពួកគ្រីស្ទានឱ្យដល់ទី បញ្ចប់ថា។


8

(ព្រះគម្ពីរ កិច្ចការ ២២:៤,៥)

"ពីដើមខ្ញុំជាអ្នកធ្វើទុក្ខបៀតបៀនដល់ មនុស្ស ...ឱ្យដល់ស្លាប់ក៏មាន ព្រមទាំង ចាប់ចង គេទាំងប្រុសទាំងស្រី បញ្ជូន ទៅដាក់គុក ដែរ...

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ



9

ហើយខ្ញុំបានទទួលយកសំបុត្រពីលោក ទៅ ឱ្យពួកសាសន៍យើងនៅក្រុងដាម៉ាស រួចខ្ញុំក៏ចេញទៅ ដើម្បីនឹងនាំអស់អ្នកក្នុង ពួកនេះទាំងប៉ុន្មាន ដែលនៅស្រុកនោះ ទាំងជាប់ចំណង មកឯក្រុងយេរូសាឡិមវិញ ឱ្យគេជាប់ទោស”

កិច្ចការ ២២:៤,៥


10

នៅពេលដែលគាត់កំពុងធ្វើដំណើរទៅ កាន់ទីក្រុងដាម៉ាស ពន្លឺដ៏ភ្លឺចាំង បានចាំង ពីលើមេឃ ហើយបានផ្តួលគាត់ទៅនឹងដី។



11

(ព្រះគម្ពីរ កិច្ចការ ២២:៧,៨)

គាត់បានឮសម្លេងមួយនិយាយថា “... សុល នែសុល ហេតុអ្វីបានជាធ្វើទុក្ខដល់ ខ្ញុំ?”



12

ហើយគាត់បានឆ្លើយថា “ឱ ព្រះអម្ចាស់ អើយ តើព្រះអង្គណាទ៎ុះ” រួចសំឡេងនោះ ឆ្លើយមកវិញថា



13

“ខ្ញុំជាព្រះយេស៊ូវពីភូមិណាសារ៉ែតដែល អ្នកបៀតបៀន”

កិច្ចការ ២២:៧,៨។



14

(ព្រះគម្ពីរ កិច្ចការ ២២:១០)

ជនជាតិផារិស៊ីដ៏អំនួតនេះ បានសួរទៅ ព្រះដោយបន្ទាបខ្លួនថា “ព្រះអម្ចាស់អើយ តើត្រូវឱ្យទូលបង្គំធ្វើដូចម្តេច? រួចព្រះអម្ចាស់មានបន្ទូលមកខ្ញុំថា...ចូរក្រោក ឡើងចូលទៅក្នុងក្រុងដាម៉ាស



15

នៅទីនោះនឹងមានគេប្រាប់អ្នក ពីអស់ទាំង ការដែលបានតម្រូវឱ្យអ្នកត្រូវធ្វើ”

កិច្ចការ ២២:១០

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


16

សុលត្រូវបានខ្វាក់ភ្នែកដោយសារពន្លឺដ៏ភ្លឺ ចាំងនោះ ហើយត្រូវបានគេនាំទៅកាន់ ផ្ទះមួយ នៅទីក្រុងដាម៉ាស។


17

រយៈពេលបីថ្ងៃដែលសុលបានគិតអំពី ការរងទុក្ខវេទនា និងការឈឺចាប់នៃរាស្ត្រ របស់ព្រះ ដែលបណ្តាលឡើងដោយសារ គាត់ និងពីការដែលគាត់ប្តេជ្ញាថាព្រះ យេស៊ូវ មិនមែនជាព្រះមែស៊ីទេ ហើយពួក សិស្សរបស់ព្រះយេស៊ូវមានជំនឿមាំទៅលើ ព្រះអង្គទាំងងងឹតងងល់នោះ

ក្នុងការធ្វើជាសាក្សីប្រឆាំងនឹងរាស្ត្រ របស់ព្រះ និងការចោទប្រកាន់ខុសទៅ លើពួកគេ គាត់បានចោទប្រកាន់និង ធ្វើ ជាសាក្សីប្រឆាំងនឹងព្រះអង្គសង្គ្រោះនៃពិភព លោកនេះដែរ!

តើលោកសុលមានការទង្គឹះ ចិត្តយ៉ាង ណាទៅ នៅពេលដែលគាត់ បានដឹងខ្លួននោះ។

សុលមានពេលនឹងធ្វើឱ្យដំណើរការបាន ត្រឹមត្រូវឡើងវិញជាមួយនឹងព្រះអម្ចាស់របស់ គាត់។


18

គាត់បានអង្គុយក្នុងភាពងងឹតសូន្យអស់ ពេលបីថ្ងៃ ហើយពេលនោះព្រះបានបញ្ជូន ហោរាម្នាក់ឱ្យទៅជួបគាត់ដែលមានឈ្មោះថា អាន្នានាស។

ហើយ អាន្នានាសបាននិយាយទៅកាន់ សុលថា



19

„(ព្រះគម្ពីរ កិច្ចការ ២២:១៣-១៥)

"អ្នកសុលអើយ សូមឱ្យភ្នែកអ្នកបានភ្លឺ ឡើង ខ្ញុំក៏ងើបភ្នែកឡើងឃើញគាត់"



20

រួចគាត់និយាយមកខ្ញុំថា "ព្រះនៃពួក ឰយុកោយើងបានដំរូវអ្នកឱ្យស្គាល់ចំណង់ព្រះហឫទ័យទ្រង់



21

ហើយឱ្យឃើញព្រះដ៏សុចរិត ព្រមទាំងឮ សំឡេងពីព្រះឱស្ឋទ្រង់

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


22

ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់ពីទ្រង់ ដល់ មនុស្សទាំងអស់ ពីគ្រប់ការដែលអ្នកបាន ឃើញបានឮ" កិច្ចការ ២២:១៣-១៥។

បន្ទាប់មក ដើម្បីឱ្យសុលបន្តដំណើរការ នៃជីវិតរបស់គាត់ទៅមុខទៀត ហើយបិទ ទំព័រអតីតកាល


23

(ព្រះគម្ពីរ កិច្ចការ ២២:១៦)

អាន្នាទាសបាននិយាយទៅកាន់សុលថា "ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត? ចូរ ក្រោកឡើង ទទួលបុណ្យជ្រមុជទឹក ហើយ លាងបាបអ្នកចេញចុះ


24

ដោយការអំពាវនាវដល់ព្រះនាមជាព្រះ

អម្ចាស់

កិច្ចការ ២២:១៦។


25

នេះគឺជារបៀបដែលសុលបានចូលរួម ជាមួយនឹងព្រះអម្ចាស់រហូតមក។

ការជ្រមុជទឹក គឺជាមាត់ទ្វារសម្រាប់ ជីវិតថ្មីរបស់សុល។

សុលត្រូវការលាងសំអាតពីការអាក្រក់ ទាំងឡាយដែលគាត់បានធ្វើនៅក្នុងនាមនៃសាសនា(ចាស់)របស់គាត់។

គាត់ត្រូវការការសំអាត។ គាត់បានដឹង ថា គាត់ត្រូវការព្រះគុណអស្ចារ្យរបស់ព្រះ ដើម្បីនឹងអត់ឱនទោស។


26

នៅពេលដែលគាត់បានជ្រមុជទឹក គាត់ បានដឹងថាព្រះបានអត់ទោសឱ្យគាត់។

ហើយសុលដែលជាអ្នកបៀតបៀនបាន ប្រែជាប៉ុលវិញ អ្នកដែលមានជំនឿស៊ប់លើព្រះយេស៊ូវអស់មួយជីវិតរបស់គាត់!


27

តើអ្នកធ្លាប់បានប៉ងប្រាថ្នាឱ្យអ្នកអាច ចាប់ផ្តើមឡើងវិញម្តងទៀត ហើយនិង ថា កំហុសទាំងអស់របស់អ្នក ដែលអ្នកបាន ប្រព្រឹត្តកន្លងមកត្រូវបានលាងសំអាតឱ្យស្អាតឬទេ?

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ



28

(វីដេអូ ៨ វិនាទី) ព្រះទ្រង់ប្រាបថា យើង ត្រូវការ ការពិសោធន៍ដូចគ្នានេះ ដូច្នេះទ្រង់បានដាក់ការជ្រមុជទឹកដើម្បីជាសញ្ញាថា យើងអាចចូលរួមជាមួយនឹងទ្រង់ចាប់ពីពេលនោះមក: គឺជាការចាប់ផ្ដើមថ្មីមួយ-ជីវិតថ្មី ក្នុងព្រះយេស៊ូវ។

តើមានអ្វីដែលជានិមិត្តរូបដ៏ល្អនៃការ ស្លាប់របស់អំពើបាប និងការចាប់ផ្ដើមជីវិត ថ្មីជាងការជ្រមុជទឹក ដោយការជ្រមុជ-ដោយមុជចុះ លិចទៅក្នុងទឹកនេះឬទេ?


29

ការជ្រមុជទឹករបស់គ្រីស្ទានមានដើម កំណើតដោយលោកយ៉ូហានបាបទីស្ទ ជា ហោរាដ៏ខ្លាំងក្លាដែលបានលេចចេញពី ស្រុកយូដា ប្រកាសពីការប្រែចិត្តយ៉ាងអង់ អាចក្លាហាន។

តាមផ្លូវទៅកាន់ទន្លេយ័រដាន់ពោរពេញ ទៅដោយហ្វូងមនុស្សម្នា ដែលធ្វើដំណើរ ទៅស្ដាប់ទ្រង់។


30

(ព្រះគម្ពីរ ម៉ាថាយ ៣:៥,៦)

ព្រះគម្ពីរនិយាយថា "នោះពួកក្រុង យេរូសាឡិម និងពួកស្រុកយូដាទាំងអស់ព្រមទាំងមនុស្សដែលនៅជុំវិញ ក្រវល់ទន្លេ យ័រដាន់ គេចេញមកឯគាត់


31

ក៏លន់តួបាបហើយទទួលបុណ្យជ្រមុជពីគាត់

ម៉ាថាយ ៣:៥,៦


32

ដោយបានបិទទ្វាររោងជាងរបស់ទ្រង់

រួចមានព្រះបន្ទូល លាមាតាទ្រង់ ព្រះ យេស៊ូវក៏បានយាងទៅកាន់ទន្លេយ័រដាន់ដែរ។

នៅពេលដែលលោកយ៉ូហានបានក្រឡេក ឃើញព្រះយេស៊ូវ គាត់បានស្គាល់ទ្រង់ហើយឈប់អធិប្បាយ។


33

(ព្រះគម្ពីរ យ៉ូហាន ១:២៩)

ដោយចង្អុលទៅព្រះយេស៊ូវ លោក យ៉ូហាន បាននិយាយថា "...នុះ ន់ កូន ចៀមនៃព្រះដែលដោះបាបមនុស្សលោក"

យ៉ូហាន ១:២៩។


34

លោកយ៉ូហានបានស្គាល់កូនចៀមដែលជា យញ្ញបូជា ដែលនឹងត្រូវស្លាប់ជំនួសអំពើបាបរបស់អស់អ្នកណា ដែលនឹងទទួល យញ្ញបូជារបស់ទ្រង់។

នៅពេលដែលព្រះយេស៊ូវសុំឱ្យគាត់ ជ្រមុជទឹកថ្វាយទ្រង់ លោកយ៉ូហានមាន ការស្ទាក់ស្ទើរ។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


35

(ព្រះគម្ពីរ ម៉ាថាយ ៣:១៤)

គាត់បាននិយាយថា "គឺទូលបង្គំដែល ត្រូវទទួលបុណ្យជ្រមុជពីទ្រង់វិញទេតើ" ម៉ាថាយ ៣:១៤


36

(ព្រះគម្ពីរ ម៉ាថាយ ៣:១៥)

ប៉ុន្តែព្រះយេស៊ូវបានទទូចថា "...ចូរធ្វើ ម្តងនេះចុះ ដ្បិតគួរឱ្យយើងធ្វើសម្រេចតាម គ្រប់ទាំងសេចក្តីសុចរិត" ខ១៥។

លោកយ៉ូហានបានដឹងថាព្រះយេស៊ូវគ្មាន បាបដើម្បីនឹងលន់តួឡើយ។

ហើយព្រះយេស៊ូវក៏មិនចាំបាច់ត្រូវ បង្ហាញ សេចក្តីជំនឿរបស់ទ្រង់ ដោយការ កើតជាថ្មីផ្ទាល់របស់ទ្រង់ដែរ!


37

ព្រះយេស៊ូវបានសូមឱ្យគេធ្វើបុណ្យជ្រ មុជទឹកពីព្រោះទ្រង់បានចង់បញ្ជាក់ជាមួយ មនុស្ស។

ទ្រង់ទុកឧទាហរណ៍ដ៏ល្អឥតខ្ចោះឱ្យយើង ទាំងអស់គ្នាធ្វើតាម។

ដូច្នោះលោកយ៉ូហានក៏បានជ្រមុជព្រះ យេស៊ូវចូលទៅក្នុងទឹកទន្លេយ័រដាន់ ហេតុ នោះហើយទើបពាក្យថា ជ្រមុជទឹក មាន អត្ថន័យយ៉ាងដូច្នោះ។


38

(ព្រះគម្ពីរ ម៉ាថាយ ៣:១៦, ១៧)

ព្រះគម្ពីរនិយាយថា "កាលព្រះយេស៊ូវ បានទទួលបុណ្យជ្រមុជហើយ នោះទ្រង់ យាងឡើងពីទឹកភ្លាម ស្រាប់តែ មេឃក៏ បើកឡើង


39

ឱ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះ យាងចុះ មកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់


40

នោះមានឮសំឡេងចេញពីមេឃថា "នេះគឺជាកូនស្ងួនភ្ងាររបស់អញ ជាទីពេញ ចិត្តអញណាស់" ម៉ាថាយ ៣:១៦,១៧។

ព្រះបានបញ្ជូនសេចក្តីស្រឡាញ់ និងព្រះ បន្ទូលរបស់ទ្រង់ ដើម្បីលើកទឹកចិត្តដល់ ព្រះយេស៊ូវ ជាសណ្ឋាននៃសត្វព្រាប ប៉ុន្តែ ទ្រង់បានធ្វើការម្យ៉ាងទៀត។

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ


41

នៅពេលដែលព្រះយេស៊ូវបានយាង ឡើងចេញពីទឹក ហើយកំពុងឈរដោយសំលៀកបំពាក់ទទឹកជោក នៅលើច្រាំងភក់ នៃទន្លេយ័រដាន់ ព្រះបានប្រកាសថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះអង្គ-ដែលទ្រង់បាន ចាក់ប្រេងតាំងឡើង។

ការជ្រមុជទឹករបស់ព្រះគ្រីស្ទជាសញ្ញា នៃការចាប់ផ្ដើមបេសកកម្មរបស់ទ្រង់ ដូចលោកពេត្រុសបាននិយាយថា


42

(ព្រះគម្ពីរ កិច្ចការ ១០:៣៨)

"គឺព្រះយេស៊ូវពីស្រុកណាសារ៉ែត ដែល ព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ និងព្រះចេស្ដាមកសណ្ឋិតលើទ្រង់..."


43

ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឱ្យអស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ ជាមួយនឹងទ្រង់"

កិច្ចការ ១០:៣៨

ព្រះយេស៊ូវមិនបានធ្វើបុណ្យ ជ្រមុជឱ្យ គេដោយផ្ទាល់ព្រះអង្គទេ ប៉ុន្តែព្រះគម្ពីរបាន និយាយថា សាវករបស់ទ្រង់បានធ្វើ:


44

(ព្រះគម្ពីរ យ៉ូហាន ៤:១,២)

ដូច្នេះកាលព្រះអម្ចាស់ទ្រង់ជ្រាបពីពួក ផារិស៊ី ដែលគេបានឮនិយាយថា ទ្រង់បាន សិស្ស ហើយក៏ធ្វើបុណ្យជ្រមុជទឹកឱ្យជា ច្រើន លើសជាងលោកយ៉ូហានទៅទៀត


45

តែមិនមែនព្រះយេស៊ូវដែលធ្វើបុណ្យជ្រមុជ ព្រះអង្គទ្រង់ទេ គឺជាសិស្សទ្រង់វិញ"

យ៉ូហាន៤:១,២។

ហើយសូមកត់សំគាល់ការកត់ត្រាចុង ក្រោយបង្អស់របស់ព្រះគ្រីស្ទ មុនពេលដែលទ្រង់យាងឡើងទៅកាន់ស្ថានសួគ៌:


46

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៩,២០)

"ដូច្នេះចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្ស នៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ:


47

ហើយបង្រៀន ឱ្យគេកាន់តាមគ្រប់ទាំង សេចក្ដីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នា ហើយមើលខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នា ជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប"

ម៉ាថាយ ២៨:១៩,២០

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


48

ប្រហែលជាលោកអ្នកឆ្ងល់អំពីរបៀបនៃ ការជ្រមុជទឹកដែលសាវកព្រះយេស៊ូវបានធ្វើ
ក្រោយពេលដែល ទ្រង់បានយាងទៅកាន់ ស្ថានសួគ៌។
មិនបាច់ឆ្ងល់ទេ ពួកគេបានធ្វើតាមគំរូ របស់ព្រះយេស៊ូវ តាំងតែពីពួកគេនៅជា
សាវករបស់ទ្រង់មកម្ល៉េះ។


49

(ព្រះគម្ពីរ អេភេសូរ ៤:៥)
លោកប៉ុលដែលជាសាវកដ៏ឆ្នើមម្នាក់ របស់ព្រះយេស៊ូវបាននិយាយថា "មានព្រះអម្ចាស់តែមួយ
មានសេចក្តី
ជំនឿតែមួយ មានបុណ្យជ្រមុជតែមួយ"
អេភេសូរ ៤:៥។


50

ប្រវត្តិលំអិតនៃការជ្រមុជទឹកតែមួយគត់ បន្ទាប់ពីឈើឆ្កាងដែលបានធ្វើឡើងដោយ លោកភីលីព
ដែលជាអ្នកផ្សាយដំណឹងល្អ ត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរកិច្ចការ។


51

នៅពេលដែលលោកភីលីពកំពុងបាន ធ្វើដំណើរនៅតាមផ្លូវ ដែលមានដីហុយទ្រ
លោមទៅកាន់ទីក្រុង កាហ្សា គាត់ បានឃើញហោរញ្ញិករបស់ម្ចាស់ក្សត្រី ខិនដាស
ដែលជាអ្នកទទួលខុសត្រូវលើ
ទ្រព្យសម្បត្តិទាំងអស់របស់ព្រះនាង។
គាត់បានមកកាន់ទីក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំ។


52

ឥឡូវនេះគាត់កំពុងធ្វើដំណើរត្រឡប់ទៅផ្ទះ វិញ ដោយជិះលើរទេះចម្បាំងរបស់គាត់
និងកំពុងអានអំពីក្រាំងផង។
លោកភីលីពបានរត់ទៅកាន់បុរសនោះ ហើយសួរគាត់ថា


53

(ព្រះគម្ពីរ កិច្ចការ ៨:៣០,៣១)
តើលោកបានយល់ពីអ្វីដែលលោកកំពុង អាននេះទេ? លោកហោរញ្ញិកនោះក៏ឆ្លើយ
ឡើងជាប្រញាប់ថា


54

"បើគ្មានអ្នកណាដឹកនាំខ្ញុំនោះ ធ្វើដូច ម្តេចឱ្យខ្ញុំយល់បាន?"

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


55

គាត់ក៏បានអញ្ជើញលោកភីលីពឱ្យឡើង ជិះរទេះជាមួយគាត់។

លោកភីលីពបានមើលទៅឃើញបុរស នោះកំពុងអានគម្ពីរអេសាយជំពូក៥៣

អ្នកអេធ្យូពីនោះបានសុំឱ្យភីលីពពន្យល់គាត់។

ជំពូកនោះបានប្រាប់អំពីជីវិត និងការលំអិត នៃការជាប់ឆ្កាងរបស់ព្រះមែស៊ី។


56

(ព្រះគម្ពីរ កិច្ចការ ៨:៣៥)

ព្រះគម្ពីរនិយាយថា "នោះភីលីពបើក មាត់សំដែងប្រាប់ដំណឹងល្អពីព្រះយេស៊ូវ

ចាប់តាំងពីបទគម្ពីរនោះរៀងទៅ"

កិច្ចការ ៨:៣៥។


57

នោះគឺជាការសិក្សាព្រះគម្ពីរមួយដែល បានលោតចុះលោតឡើងនៅលើរទេះសេះ!

លោកភីលីពមិនគ្រាន់តែប្រាប់អំពីព្រះ យេស៊ូវប៉ុណ្ណោះទេ គាត់ថែមទាំងបាន

ពន្យល់ភ្លាមអំពីសញ្ញានៃការជ្រមុជទឹក ដូច ដែលព្រះគម្ពីរបានចែង នៅពេលដែលពួក

គេបានមកដល់កន្លែងដែលមានស្រះទឹក ជនជាតិអេធ្យូពីនោះបាននិយាយទៅកាន់

ភីលីពថា


58

(ព្រះគម្ពីរ កិច្ចការ ៨:៣៦,៣៧)

"...នោះឃើញមានទឹក ហើយអ្នកកំរៀវ និយាយថា មើលនុ៎ះន៎ តើមានអ្វីឃាត់មិន

ឱ្យខ្ញុំទទួលបុណ្យជ្រមុជទឹកបាន?"

កិច្ចការ ៨:៣៦


59

ភីលីពឆ្លើយឡើងថា "បើលោកជឿអស់ ពីចិត្តនោះទទួលបាន"


60

ជនជាតិអេធ្យូពីនោះឆ្លើយឡើងថា "ខ្ញុំ ជឿហើយថាព្រះយេស៊ូវគ្រីស្ទព្រះរាជបុត្រា របស់ព្រះ"

ខ៣៧

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ


61

(ព្រះគម្ពីរ កិច្ចការ ៨:៣៨)

"នោះលោកបង្គាប់ឱ្យឈប់រថ រួច ភីលីពនិងអ្នកកំរៀវ ក៏ចុះទៅក្នុងទឹកទាំង ពីរនាក់ ហើយភីលីពគាត់ធ្វើបុណ្យ ជ្រមុជ ទឹកឱ្យ"

កិច្ចការ ៨:៣៨

លោកភីលីពបានជ្រមុជជនជាតិអេធ្យូពី នោះទៅក្នុងទឹក ដូចជាលោកយ៉ូហានបាន ជ្រមុជព្រះយេស៊ូវនៅពេលដែលគាត់បាន ធ្វើបុណ្យជ្រមុជថ្វាយទ្រង់យ៉ាងដូច្នោះដែរ។


62

(ព្រះគម្ពីរ កិច្ចការ ៨:៣៩)

លុះឡើងពីទឹកមក នោះព្រះវិញ្ញាណនៃព្រះ អម្ចាស់ ទ្រង់ឆក់យកភីលីពបាត់ទៅ


63

...ក៏ទៅតាមផ្លូវដោយអរសប្បាយ"

កិច្ចការ ៨:៣៩


64

នោះហើយគឺជាការដែលកើតឡើង នៅ ពេលដែលយើងបានកប់ជីវិតនៃអំពើបាប របស់យើង ហើយចាប់ផ្ដើមជីវិតថ្មីមួយនៅ ក្នុងព្រះគ្រីស្ទ។

ពិតប្រាកដណាស់ ការជ្រមុជទៅក្នុងទឹក គឺជារបៀបនៃការជ្រមុជទឹករបស់ក្រុមជំនុំដំបូង។


65

ជាការពិតណាស់ថា គ្មានភស្តុតាងណានៅក្នុងសញ្ញាថ្មី អំពីរបៀបផ្សេងទៀតនៃការជ្រមុជទឹកទេ។ នេះគឺជារូបភាពនៃអាងជ្រមុជទឹកមួយ របស់ព្រះវិហារ ក្នុងសតវត្សរ៍ទីមួយ នៅទីក្រុងភីលីព។

អ្នកប្រវត្តិសាស្ត្ររបស់ក្រុមជំនុំគ្រីស្ទានដំបូង និងការរកឃើញដោយបុរាណវិទ្យា។


66

ទាំងពីរនេះបង្ហាញថា ការជ្រមុជចូល ទៅក្នុងទឹក គឺជារបៀបនៃការជ្រមុជទឹក ដែលមានរហូតដល់សតវត្សរ៍ទីដប់ពីរ និង សតវស្សទីដប់បី


67

លោកកាឌីណាល់ ហ្គេមគីបូន បានសរសេរថា "ជាច្រើនសតវត្សរ៍ក្រោយ ពីគ្រិស្ទានបានកើតមក ការជ្រមុជទឹក តែងតែធ្វើដោយការជ្រមុជចូលទៅក្នុងទឹក

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


68

ប៉ុន្តែ នៅក្នុងសតវត្សរ៍ទីដប់ពីរ ការ អនុវត្តន៍ការជ្រមុជទឹក ដោយការប្រោះទឹក ពីលើ បានត្រូវកើតឡើង នៅក្នុងពួកជំនុំ កាតូលិក


69

ព្រោះរបៀបនេះ ងាយស្រួលជាងការ ជ្រមុជដោយមុជលិចទៅក្នុងទឹក...


70

អ្នកដឹកនាំក្រុមជំនុំក៏បានជ្រើសរើសការ ទទួលយកការអនុវត្តន៍ នូវរបៀបណាមួយ ដែលស្រួលជាងគេបំផុត យោងទៅតាម កាលៈទេសៈ នៃពេលវេលានិង ទីកន្លែង។

សេចក្តីជំនឿទៅលើព្រះវរបិតារបស់ យើង ការបោះពុម្ពសារថ្មីលើកទី៩៤ ទំព័រ ២៧៧។


71

សព្វថ្ងៃនេះ ទេសចរជាច្រើនបាន ទៅលេងព្រះវិហារមួយឈ្មោះសន្តបុគ្គល យ៉ូហាន ដែលមានទីតាំងនៅក្នុងរូងក្រោមដី នៃទីក្រុងនៃព្រះគម្ពីរ អេភេសូរ ក្នុងប្រ ទេសទួរគី។

ព្រះវិហារនេះត្រូវបានសាងឡើងដើម្បី ជាអនុស្សាវរីយ៍របស់សាវកយ៉ូហាន។

ការចាប់អារម្មណ៍ជាពិសេសគឺ អាងជ្រ មុជទឹក ដែលមានរាងមូល មានបន្ទាត់ផ្ចិត ប្រវែងជិតបួនម៉ែត្រ និងជម្រៅមួយម៉ែត្រ ពីរតឹក ដែលមានជណ្តើរចុះទៅរហូតដល់ អាងទឹកនោះ ទាំងសងខាង។



72

មនុស្សជាច្រើនបានឮអំពីប៉មកណ្តឹង ចាស់បុរាណមួយនៅពីមុខមហាវិហារនៃទីក្រុងពិសា ក្នុងប្រទេសអ៊ីតាលី ដែលត្រូវបាន គេដឹងឮជាទូទៅថា ជាកំពូលទ្រេតនៃប៉ម ពិសា។


73

តាមបណ្តោយនៃមហាវិហារ និងកំពូល ទ្រេត មានអាងជ្រមុជទឹក នៅជុំវិញអាគារ ចាំងជំវិញ


74

ស្រះមួយដែលមានប្រវែងពីម្ខាងទៅម្ខាងជាង៦ម៉ែត្រ និងជម្រៅ១.២ម៉ែត្រ ដែលត្រូវ បានសាងឡើងនៅក្នុងសតវត្សរ៍ទីដប់បួន។ ដែលត្រូវបានសាងឡើងនៅក្នុងសតវត្សរ៍ទី ដប់បួន។ មួយពាន់បីរយឆ្នាំក្រោយពេលព្រះគ្រីស្ទបាន យាងឡើងទៅកាន់ស្ថានសួគ៌ របៀបនៃការ ជ្រមុជទឹកនេះនៅតែ ធ្វើដោយការជ្រមុជ ចូលទៅក្នុងទឹកដដែល!។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


75

មានមហាវិហារដូច្នេះរាប់ឡូត៍ នៅអឺរ៉ុប ដែលមានស្រះជ្រមុជទឹកធំៗ។
មហាវិហារហុកសិបប្រាំមួយត្រូវបានគេរក
ឃើញ នៅក្នុងប្រទេសអ៊ីតាលីតែមួយ ប៉ុណ្ណោះ ដែលមានកាលបរិច្ឆេទសាងសង់ នៅចន្លោះ
សតវត្សរ៍ទីបួន និងទីដប់បួន។


76

ប៉ុន្តែតើចរិតនៃការជ្រមុជទឹកនេះសំខាន់ យ៉ាងណា?


77

តើវាពិតជាមានសារសំខាន់ឬទេក្នុងការ ទទួលបុណ្យជ្រមុជទឹកនោះ?


78

(ព្រះគម្ពីរ យ៉ូហាន ៣:៥)
"ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដ មែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើ
មិនបានកើតអំពីទឹក ហើយពីព្រះវិញ្ញាណ


79

នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ"
យ៉ូហាន ៣:៥


80

ព្រះយេស៊ូវបានបញ្ជាក់នៅទីនេះអំពីការ កើតពីទឹក ជាការយោងទៅនឹងការជ្រមុជ ទឹក
ដែលយើងនឹងឃើញនៅពេលខាងមុខ នេះថា ជាការសំខាន់ដើម្បីចូលទៅនគរ ស្ថានសួគ៌។


81

ព្រះយេស៊ូវមិនបានធ្វើការថ្លែងដ៏សំខាន់ នេះតែម្តងនោះទេ។
សូមកត់សំគាល់ថា ទ្រង់បានមានព្រះ បន្ទូល ដោយសង្កត់ធ្ងន់ដែលៗនៅក្នុងព្រះ គម្ពីរ ម៉ាកុស
១៦:១៦:

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ


82

(ព្រះគម្ពីរ ម៉ាកុស ១៦:១៦)

"អ្នកណាដែលជឿ ហើយទទួលបុណ្យ ជ្រមុជទឹក នោះនឹងបានសង្គ្រោះ"

ម៉ាកុស ១៦:១៦។

ជំហានទីមួយក្នុងការរៀបចំសម្រាប់ការ ជ្រមុជទឹកនៅក្នុងព្រះគម្ពីរ គឺជឿថា ព្រះ គ្រីស្ទបានសុគត ដើម្បីអំពើបាបរបស់អ្នក ហើយថាទ្រង់គឺជាព្រះអង្គសង្គ្រោះនិងជាព្រះអម្ចាស់។


83

លោកភីលីពបានបញ្ជាក់អំពី សេចក្ដី ត្រូវការ នៃជំនឿទាំងស្រុងទៅលើព្រះ យេស៊ូវ ដល់ជនជាតិអេត្យូពី។

នៅពេលដែលជនជាតិអេត្យូពីបានសួរ លោកភីលីពថា តើគាត់អាចជ្រមុជទឹកបាន ឬទេ ភីលីពឆ្លើយថា


84

(ព្រះគម្ពីរ កិច្ចការ ៨:៣៧)

"បើលោកជឿអស់ពីចិត្តនោះលោក ទទួលបាន"

កិច្ចការ៨:៣៧


85

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៩)

ព្រះយេស៊ូវបានប្រទានដល់ពួកសាវកនូវ ជំហានទីពីរ

"ដូច្នេះ ចូរចេញទៅបញ្ចុះបញ្ចូលឱ្យមាន សិស្សនៅគ្រប់ទាំងសាសន៍ ហើយធ្វើបុណ្យ ជ្រមុជទឹកឱ្យគេ..."

ម៉ាថាយ ២៨:១៩។

បញ្ចុះបញ្ចូលឱ្យមានសិស្សមានន័យថា ការបង្រៀន ដូច្នេះការបង្រៀនមានមុន ការជ្រមុជទឹក។


86

(ព្រះគម្ពីរ ម៉ាថាយ ២៨:២០)

ព្រះយេស៊ូវបានបង្រៀនថា បេក្ខជន ជ្រមុជទឹកត្រូវតែបានបង្រៀន "...ឱ្យគេ កាន់តាមគ្រប់ទាំងការដែលខ្ញុំបានបង្រៀន ដល់អ្នករាល់គ្នា..."?

ម៉ាថាយ ២៨:២០។


87

ម្យ៉ាងវិញទៀត ការរៀបចំផ្ទាល់ខ្លួន របស់បុគ្គលម្នាក់ៗ សម្រាប់តម្លៃដ៏ពិសិដ្ឋនៃ ការជ្រមុជទឹកនោះ គឺយល់អំពីការបង្រៀន របស់ព្រះយេស៊ូវ ហើយនិងទទួលនូវការ បង្រៀនទាំងនោះ។

ប៉ុន្តែលើសពីចំណេះដឹងខាងគោលលទ្ធិ ទៅទៀតនោះគឺ។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


88

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៩)

"ដូច្នេះ ចូរចេញទៅនាំមនុស្ស គ្រប់ ជាតិសាសន៍ឱ្យធ្វើជាសាវក ហើយធ្វើពិធី ជ្រមុជទឹកឱ្យគេ ដោយនូវព្រះនាមព្រះ វរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ បរិសុទ្ធ" (ព្រះគម្ពីរភាសាខ្មែរសម្រាយ) ម៉ាថាយ ២៨:១៩

ត្រូវតែមានការប្តេជ្ញាចិត្តគ្រប់ទាំងអស់ក្នុង ជីវិតរបស់អ្នកថ្វាយទៅព្រះគ្រីស្ទ។

នៅពេលដែលមនុស្សរួបរួមជាមួយព្រះ យេស៊ូវ គេចាប់ផ្តើមរស់នៅតាមរបៀប ដែលព្រះយេស៊ូវរស់នៅ ដោយធម្មជាតិ (ដោយខ្លួនឯង)។

គេនឹងលែងចង់ធ្វើនូវអ្វីៗដែលព្រះ យេស៊ូវមិនសព្វព្រះហឫទ័យទៀតហើយ!


89

ជំហានទីបីគឺការកែប្រែ។ លោក ពេត្រុសបាននិយាយថា


90

(ព្រះគម្ពីរ កិច្ចការ ៣:១៩)

"ដូច្នេះចូរប្រែចិត្តហើយវិលមកចុះ ដើម្បីឱ្យបាបរបស់អ្នករាល់គ្នាបានលប់ចេញ" កិច្ចការ ៣:១៩។ ការកែប្រែចិត្តមាន ន័យថា មានការសោកស្តាយយ៉ាងខ្លាំង ចំពោះអំពើបាប ហើយបែរចេញអំពីបាប នោះ។


91

ការនេះអាចកើតមកបានតែពីចិត្តដែល មាននៅភ្នំរលាក្បាល(កាល់វ៉ារី)ប៉ុណ្ណោះ-ជាចិត្តដែលត្រូវ បានចាប់អង្រួន និងបន្ទន់ដោយពលិកម្ម ដែលបានធ្វើនៅលើឈើឆ្កាង ដើម្បី សង្គ្រោះយើងចេញពីអំពើបាបរបស់យើង។


92

សូមយើងសង្ខេបជំហាន ក្នុងការរៀប ចំធ្វើបុណ្យជ្រមុជទឹកទាំងនេះ


93

១. មុនជ្រមុជទឹក មនុស្សត្រូវតែទទួលព្រះ យេស៊ូវជាព្រះអង្គសង្គ្រោះនិងជាព្រះអម្ចាស់។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


94

២. មុនជ្រមុជទឹក មនុស្សត្រូវតែយល់អំពី ការបង្រៀនរបស់ព្រះយេស៊ូវ ហើយសុខ ចិត្តធ្វើតាមទ្រង់។


95

៣. គេត្រូវតែលន់តួរាល់អំពើ បាបទាំង អស់របស់គេ និងកែប្រែចិត្ត។


96

ប្រហែលជាលោកអ្នកបានប្រាថ្នាចង់បាន ពេលវេលា ដែលលោកអ្នកអាចផ្លាស់ ប្តូរជីវិតលោកអ្នកឱ្យកាន់តែប្រសើរឡើង ប៉ុន្តែលោកអ្នកមិនបានដឹងថាធ្វើយ៉ាងណា។ ដោយអនុវត្តតាមជំហានទាំងបីយ៉ាង ក្នុង ការរៀបចំធ្វើការជ្រមុជទឹកនេះ លោកអ្នកពិតប្រាកដជាអាចក្លាយទៅជាមនុស្សថ្មីមួយ បាន-ពីខាងក្នុងចេញមកក្រៅ។

ដោយសារអំណាចរបស់ព្រះ លោកអ្នក អាចត្រូវបានផ្លាស់ប្តូរ កើតជាថ្មី និងបាន ផ្លាស់ប្តូរជំនឿ ។


97

ជួនកាលមនុស្សសួរថា "នៅពេលដែល ខ្ញុំជ្រមុជទឹក តើខ្ញុំក្លាយជាចំណែកនៃក្រុម ជំនុំឬទេ? ឬក៏ថាខ្ញុំគ្រាន់តែជ្រមុជទឹកក្នុង ព្រះយេស៊ូវទេឬ?"

ព្រះគម្ពីរបង្រៀនថា ជ្រមុជទឹកក្នុងព្រះ យេស៊ូវ គឺជ្រមុជទឹកចូលទៅក្នុងរាងកាយរបស់ព្រះគ្រីស្ទក្រុមជំនុំ។ នៅពេលដែល មនុស្សជាច្រើនត្រូវបានទទួលជ្រមុជទឹកនៅថ្ងៃប៉ង់ តាកូស ព្រះគម្ពីរបញ្ជាក់ថា


98

(ព្រះគម្ពីរ កិច្ចការ ២:៤១,៤២)

"នោះពួកអ្នកដែលទទួលពាក្យរបស់គាត់ ដោយអំណរក៏បានទទួលបុណ្យជ្រមុជទឹក ហើយនៅថ្ងៃដដែលនោះ មានប្រហែលជា ៣ពាន់នាក់ ថែមកើនឡើងទៀត


99

អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្តី បង្រៀនរបស់ពួកសាវក ហើយក្នុងសេចក្តី ប្រកបគ្នា

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


100

ព្រមទាំងកាច់នំបុ័ង និងសេចក្តី អធិស្ឋានផង

(កិច្ចការ ២:៤១,៤២)

ខនេះច្បាស់លាស់ណាស់។ នៅពេល ដែលយើងបានជ្រមុជទឹក យើងមិនមែន

នៅកំព្រាខាងព្រលឹងវិញ្ញាណនោះទេ។ យើងមិនមែននៅឯកោទេ។

មនុស្សបានជ្រមុជទឹកនៅក្នុងព្រះគម្ពីរ កិច្ចការ "បានប្តេជ្ញាក្នុងគោលលទ្ធិនិងការ

ចូលរួមជាមួយពួកសាវក"

ពួកគេបានចូលរួមចំណែកជាមួយនឹង

ពួកជំនុំ ដែលមានជំនឿលើព្រះគម្ពីររបស់ ព្រះ។


101

(ព្រះគម្ពីរ កូរិនថូសទី១ ១២:១៣)

គម្ពីរកូរិនថូសទី១ ១២:១៣ ថ្លែងថា: "យើងបានទទួលបុណ្យជ្រមុជចូលក្នុងរូប កាយតែ១

ដោយសារព្រះវិញ្ញាណតែ១" ខទី២៨ បានចង្អុលបង្ហាញ យ៉ាងច្បាស់ថា រាងកាយគឺក្រុមជំនុំ។

នៅពេលដែលបុរស និងនារីទាំងឡាយ បានថ្វាយជីវិតរបស់គេដើរតាមព្រះយេស៊ូវ

ពួកគេចង់ថ្វាយបង្គំទ្រង់ដូចជាពួកសិស្សទ្រង់ ដែរ។ ចិត្តរបស់គេបានឆេះឆួលឡើងឱ្យចង់

ចូលរួមចំណែកក្នុងពួកជំនុំ ដែលកាន់តាម បញ្ញត្តិរបស់ព្រះគ្រីស្ទ។


102

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៩:២០)

នេះហើយជាហេតុដែលព្រះយេស៊ូវបាន មានព្រះបន្ទូលទៅកាន់លោកម៉ាថាយថា

"ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ អស់ទាំងសាសន៍ ហើយធ្វើបុណ្យជ្រមុជឱ្យ

គេដោយនូវព្រះនាមព្រះវរបិតា ព្រះរាជ បុត្រា និងព្រះវិញ្ញាណបរិសុទ្ធ


103

ព្រមទាំងបង្រៀនគេឱ្យកាន់តាមគ្រប់ទាំងការ ដែលខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា..."


104

យប់នេះព្រះយេស៊ូវកំពុងអំពាវនាវដល់ លោកអ្នកឱ្យថ្វាយចិត្តទៅដល់ទ្រង់។

ទ្រង់កំពុងអំពាវនាវដល់អ្នកឱ្យចូលរួមចំ ណែកនៃការជឿលើព្រះគម្ពីររបស់ទ្រង់ ជា

មនុស្សដែលមានការប្តេជ្ញាចិត្ត និងប្រកាន់ ខ្ជាប់។ ទ្រង់ប្រទានដល់លោកអ្នកដូចដែល

ទ្រង់បានប្រទានដល់សាវកប៉ុលដែរ:

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


105

(ព្រះគម្ពីរ កិច្ចការ ២២:១៦)

 "ឥឡូវនេះតើអ្នកបង្អង់ចាំអ្វីទៀត? ចូរ ក្រោកឡើងទទួលបុណ្យជ្រមុជទឹក ហើយ លាងបាបអ្នកចុះ "

កិច្ចការ ២២:១៦


106

 យប់មួយអ្នកដឹកនាំ យូដាម្នាក់ដែលមាន ឈ្មោះថា នីកូដេមបានមកឯព្រះយេស៊ូវ។ គាត់មិនចង់ឱ្យមិត្តរបស់គាត់ដឹងថា គាត់ មានការចាប់អារម្មណ៍ទៅលើព្រះយេស៊ូវទេ។


107

(ព្រះគម្ពីរ យ៉ូហាន ៣:២)

 គាត់បានសរសើរព្រះយេស៊ូវដោយទូលទៅ

ទ្រង់ថា "...លោកគ្រូ យើងខ្ញុំដឹងថា លោកជាគ្រូមកពីព្រះពិត។


108

 ដ្បិតគ្មានអ្នក ណាអាចនឹងធ្វើទីសំគាល់ ដែលលោកធ្វើ ទាំងនោះបានទេ លើកតែព្រះគង់នៅជាមួយប៉ុណ្ណោះ"។

 ព្រះយេស៊ូវទ្រង់ជ្រាបចិត្តរបស់មនុស្ស

នេះ ដូច្នេះទ្រង់បានមានព្រះបន្ទូលចំៗ

ចំណុចតែម្តង និងបង្ហាញដល់លោក នីកូដេមនូវអ្វីដែលគាត់បានត្រូវការ។


109

(ព្រះគម្ពីរ យ៉ូហាន ៣:៣)

 "ព្រះយេស៊ូវមានបន្ទូលឆ្លើយថា

ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា


110

 បើមិនបានកើតជាថ្មី នោះគ្មានអ្នកណា អាចនឹងឃើញនគរព្រះបានទេ"

យ៉ូហាន ៣:៣


111

(ព្រះគម្ពីរ យ៉ូហាន ៣:៤)

 លោកនីកូដេមបានមានការងឿងឆ្ងល់ជា ខ្លាំង ក៏បានសួរទៅព្រះយេស៊ូវថា "ធ្វើដូចម្តេចនឹងកើតឡើងបានក្នុងកាល ដែលចាស់ ហើយ?

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


112

តើអាចនឹងចូលទៅក្នុងពោះម្តាយទៀត ហើយកើតឡើងវិញបានឬ?” យ៉ូហាន ៣:៤


113

(ព្រះគម្ពីរ យ៉ូហាន ៣:៥)

ពេលនោះព្រះយេស៊ូវបានចង្អុលបង្ហាញ អំពីការកើតខាងឯវិញ្ញាណ នៅពេលដែលទ្រង់បានមានព្រះបន្ទូលថា

“ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជា ប្រាកដថា បើមិនបានកើតពីទឹក ហើយអំពី ព្រះវិញ្ញាណ


114

នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ”

យ៉ូហាន ៣:៥

នៅទីនោះព្រះយេស៊ូវបានមានព្រះបន្ទូល អំពីការកើតជាថ្មីខាងឯវិញ្ញាណ ដែលបង្ហាញដោយការជ្រមុជទឹកនេះ។

សេចក្តីនេះ សំដៅទៅរកហេតុការណ៍ ដែលមនុស្សនឹងត្រូវលាងសំអាតនៅក្នុងទឹកនៃការជ្រមុជទឹក។


115

គ្មានអ្វីដែលគួរឱ្យសង្ស័យសោះឡើយ លោកនីកូដេមជាជនជាតិផារិសីដ៏អំនួតម្នាក់ នេះបានឃើញទ្វារចូលទៅកាន់នគររបស់ ព្រះ ដោយសារសញ្ជាតិយូដា ដែលកាន់តាមបញ្ញត្តិសាសនាដ៏តឹងរឹងរបស់គាត់។


116

ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវ បានបញ្ជាក់យ៉ាងច្បាស់ថា អ្វីដែលតូចជាងការដែលផ្លាស់ប្តូរជីវិតយ៉ាងបរិបូរ ដោយ សារអំណាចនៃព្រះវិញ្ញាណបរិសុទ្ធនោះ មិន គ្រប់គ្រាន់ទេ.


117

នេះគឺជាវិធីដែលមនុស្សបោះត្រា

(មិនផ្លាស់ប្តូរ)ការ ទទួលយញ្ញបូជារបស់គេ ដែលផ្តល់ឱ្យ ដោយព្រះ វរបិតា និងដែលធ្វើឡើងដោយព្រះរាជបុត្រា។


118

នេះគឺជាការចាប់ផ្តើមជីវិតថ្មីនៅក្នុងព្រះ គ្រីស្ទ។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


119

(ព្រះគម្ពីរ ម៉ាថាយ ៣:១៧)

នៅឯការជ្រមុជទឹករបស់ព្រះគ្រីស្ទ ព្រះ បន្ទូលរបស់ព្រះត្រូវបានបន្លឺឡើងថា "នេះគឺជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្ត អញណាស់" ម៉ាថាយ ៣:១៧។


120

នៅពេលនោះឯងដែលព្រះវិញ្ញាណ បរិសុទ្ធ នៅក្នុងសណ្ឋានជាសត្វព្រាប បាន ចាក់ប្រេងតាំងថ្វាយព្រះយេស៊ូវ ដែលទ្រង់ បានក្លាយជាអ្នកដែលបានចាក់ប្រេងតាំង ឬព្រះមែស៊ី ព្រះគ្រីស្ទ។


121

ព្រឹត្តិការណ៍នេះ ជាសញ្ញានៃបេសកកម្ម ជាសាធារណៈរបស់ព្រះយេស៊ូវគ្រីស្ទ។

ដូច្នេះហើយបានជាការជ្រមុជទឹករបស់ អ្នកដែលដើរតាមទ្រង់ ជាសញ្ញានៃការចាប់ ផ្តើមជីវិតថ្មី ជាមួយនឹងព្រះគ្រីស្ទជាព្រះអង្គ សង្គ្រោះ។

ព្រឹត្តិការណ៍នេះក៏ជាសញ្ញានៃការធ្វើទី បន្ទាល់ជាសាធារណៈនៃអ្នកដែលជឿទ្រង់ ដោយការជ្រមុជទឹករបស់គេ ដែលគេបាន ចូលរួមក្នុងព្រះគ្រីស្ទ ដែលគេបានប្រដាប់ ខ្លួនដោយព្រះគ្រីស្ទមែន។


122

(ព្រះគម្ពីរ កាឡាទី ៣:២៧)

កាឡាទី ៣:២៧ និយាយថា "ព្រោះ អស់អ្នកដែលបានទទួលបុណ្យជ្រមុជក្នុងព្រះ គ្រីស្ទ នោះឈ្មោះថា បានប្រដាប់កាយ ដោយព្រះគ្រីស្ទហើយ"



123

(វីដេអូ ១០វិនាទី) ចំពោះអ្នកដែលបាន ទទួលព្រះគ្រីស្ទជាយញ្ញបូជារបស់គេ ការ ជ្រមុជទឹក បង្ហាញសេចក្តីជំនឿរបស់គេ នៅក្នុងហេតុការណ៍ដ៏ធំបី នៃការលះបង់ របស់ព្រះគ្រីស្ទ។


124

(ព្រះគម្ពីរ រ៉ូម ៦:៣,៤)

លោកប៉ុលបាននិយាយថា "តើអ្នករាល់ គ្នាមិនដឹងទេឬអីថា យើងទាំងប៉ុន្មានដែល បានទទួលបុណ្យជ្រមុជក្នុង ព្រះយេស៊ូវ គ្រីស្ទ នោះក៏បានទទួលក្នុងសេចក្តីសុគតនៃ ទ្រង់ដែរ" រ៉ូម ៦:៣


125

រួចគាត់បានបន្តចង្អុលបង្ហាញជំហាន បន្ទាប់ ដែលគ្រីស្ទានទទួលយកជាតម្លៃ របស់គេ "ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ ហើយ ដោយទទួលបុណ្យជ្រមុជក្នុងសេចក្តី ស្លាប់" ខ៤។ ប៉ុន្តែមានចំណែកទីបីនៃសកម្មភាពនៃ សេចក្តីជំនឿនេះ។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


126

(ព្រះគម្ពីរ រ៉ូម ៦:៤)

"ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មី


127

ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតា" ខ៤។

ឥឡូវនេះ លោកអ្នកឮហើយ។ មនុស្ស ដែលបានទទួលបុណ្យជ្រមុជទឹក បានត្រូវកើត ពីព្រះវិញ្ញាណ និងពីទឹក!


128

យើងបង្ហាញសេចក្តីជំនឿរបស់យើងជា សាធារណៈ នៅក្នុងការសុគត ការបញ្ចុះ និងមានព្រះជន្មរស់ ឡើងវិញរបស់ព្រះ យេស៊ូវគ្រីស្ទ។


129

(ព្រះគម្ពីរ រ៉ូម ៦:១១)

ពេលនោះលោកប៉ុលបានប្រាប់យើងថា "ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ ខាងបាបដែរ តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃ យើងរាល់គ្នា"

ឥឡូវនេះតើលោកអ្នកឃើញថា ហេតុអ្វី បានជាវាជាផ្នែកដ៏អស្ចារ្យម្ល៉េះ សម្រាប់ជីវិត គ្រីស្ទាន?


130

វាដូចជាពិធីអាពាហ៍ពិពាហ៍ របស់គូរ ដណ្តឹងមួយគូដូច្នោះដែរ។

នេះគឺជាឱកាសមួយរបស់គេ ដើម្បី បង្ហាញជាសាធារណៈថា គេបានចូលរួមជា មួយគ្នារហូតដល់អស់ជីវិត។


131

(ព្រះគម្ពីរ អេភេសូរ ៤:៥)

ព្រះគម្ពីរប្រាប់យើងថា មាន "ព្រះ អម្ចាស់តែ១ សេចក្តីជំនឿតែ១ បុណ្យជ្រ មុជតែ១" អេភេសូរ ៤:៥។

នៅក្នុងព្រះវិហារ ហាក់ដូចជានៅតែ មានការអនុវត្តន៍នៃការជ្រមុជទឹកនេះផ្សេងៗគ្នាជាច្រើន។


132

ខ្លះប្រោះទឹក ខ្លះចាក់ទឹក ហើយខ្លះទៀត ជ្រមុជលិចទៅក្នុងទឹក។

តើធ្វើដូចម្តេចឱ្យមានការជ្រមុជតែមួយ នៅពេលដែលមានការភាន់ច្រឡំទៅលើថា តើរបៀបណាមួយដែល ត្រឹមត្រូវនោះ?

# ១៦. បង្កើតការចាប់ផ្ដើមថ្មីមួយ


133

យើងត្រូវសួរតែម្យ៉ាងគត់ថា "តើព្រះ យេស៊ូវបានធ្វើយ៉ាងណា?"


134

យើងបានរកឃើញថា លោកយ៉ូហាន កំពុងធ្វើបុណ្យជ្រមុជទឹកឱ្យគេនៅឯទន្លេយ័រ ដាន់។
នៅពេលដែលព្រះយេស៊ូវបានទទួល បុណ្យជ្រមុជទឹក ទ្រង់ "បានយាងចុះទៅ ក្នុងទឹក"
ទ្រង់បានធ្វើបុណ្យជ្រមុជទឹកដោយការ ជ្រមុជលិចទៅក្នុងទឹក។


135

នេះហើយដែលជាអត្ថន័យនៃពាក្យថា បាបទីហ្ស៊ូ ជាភាសាក្រេក។
មានន័យថា ជ្រមុជចុះទៅក្នុងទឹក ឬ គ្របដោយទឹក។
នេះហើយដែលជារបៀបនៃការជ្រមុជ ទឹកតែមួយគត់ដែលតំណាងឱ្យការសុគត ការបញ្ចុះ និងការមានព្រះជន្មរស់ឡើងវិញ របស់ព្រះគ្រីស្ទ។


136

មានពេលមួយលោកប៉ុលនិងអ្នកធ្វើការ ជិតស្និទ្ធជាមួយគាត់ គឺលោកស៊ីឡាស បាន ធ្វើដំណើរទៅកាន់ទីក្រុង ភីលីព តាមការ អញ្ជើញរបស់បុរសម៉ាសេដូនម្នាក់ ដែល លោកប៉ុលបានឃើញនៅក្នុងយល់សប្តិ។


137

ដោយសារការអធិប្បាយរបស់គាត់ លោកប៉ុលនិងស៊ីឡាស បានធ្វើឱ្យពួកអ្នក ដែលនៅក្រុងភីលីព មានការពុះកញ្ជ្រោល យ៉ាងខ្លាំង។


138

ខ្លាំងក្លារហូតដល់ហ្វូងមនុស្សវាយតប់ ដល់ពួកគាត់ ហើយជីវិតគាត់ក៏ជួបប្រទះ នូវការគ្រោះថ្នាក់។ ហ្វូងមនុស្សបានហែក អាវរបស់គាត់ទាំងពីរនាក់ ហើយអ្នកកាន់រដ្ឋ អំណាចបានវាយគាត់។


139

គាត់ទាំងពីរនាក់ត្រូវបានគេយកទៅកាន់ ពន្ធនាគារ ដែលគេបានបញ្ជាឱ្យឆ្មាំគុក ដាក់គាត់ទាំងពីរ ក្នុងការឃុំឃាំងជាទម្ងន់ ហើយប្រយ័ត្នប្រយែងកុំឱ្យគាត់ចេញរួច។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ



140

នាពេលកណ្តាលអាធ្រាត្រ ប៉ុលនិងស៊ី ឡាសកំពុងអធិស្ឋាន និងច្រៀង ពេល នោះមានការរញ្ជួយផែនដីមួយ បានធ្វើឱ្យ រញ្ជួយដល់ជញ្ជាំងគុក ហើយរំពេចនោះទ្វារ គុកក៏ត្រូវបានរបើក ហើយច្រវាក់របស់អ្នក ទោសគ្រប់គ្នាត្រូវបានរបូតអស់។

ឆ្មាំគុកបានរត់មក ហើយបានឃើញទ្វារ គុករបើក បានគិតថា អ្នកទោសបានរត់រួច អស់ហើយ។



141

គាត់កំពុងតែដកដាវរបស់គាត់ដើម្បីធ្វើ អត្តឃាត ព្រោះគាត់ដឹងច្បាស់ថា គាត់នឹង ត្រូវស្លាប់ដោយបានអនុញ្ញាតឱ្យអ្នកទោស រត់រួចអស់។



142

(ព្រះគម្ពីរ កិច្ចការ ១៦:២៨)

ប៉ុន្តែប៉ុលបានស្រែកទៅកាន់គាត់ដោយ សំឡេងយ៉ាងខ្លាំងថា "កុំធ្វើបាបខ្លួនឡើយ ដ្បិតយើងនៅឯណេះទាំងអស់គ្នាទេ" (កិច្ចការ ១៦:១៨)



143

អ្នកយាមគុកបានស្ញើចសរសើរ! បុរស ទាំងពីរនេះ ប៉ុលនិងស៊ីឡាស ដែលបានរង ទុក្ខឈឺចាប់ដោយសារស្នាដៃរបស់អ្នកយាម គុកនោះ តែគេនៅតែគ្មានការខឹងសំបារ និងចង់សងសឹកឡើយ។

អ្នកយាមគុកដឹងថា គាត់ទាំងពីរនាក់ជា មនុស្សគ្មានទោសទេ។

គាត់បានរត់ទៅយកពិល ហើយបានធ្វើ ដំណើរទៅកាន់បន្ទប់ឃុំឃាំងរបស់គាត់ លុតជង្គង់នៅទៀបជើងគាត់ទាំងពីរនាក់ ហើយក៏ចាប់ផ្តើមលន់តួទោស។



144

(ព្រះគម្ពីរ កិច្ចការ ១៦:៣០,៣១)

"គាត់នាំគេចេញទៅក្រៅសួរថា លោកម្ចាស់អើយ តើត្រូវឱ្យខ្ញុំធ្វើដូចម្តេច ឱ្យបានសង្គ្រោះផង?"



145

ដូច្នោះអ្នកបំរើព្រះទាំងពីរនោះបានឆ្លើយ ថា "ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទៅនោះនឹងបានសង្គ្រោះហើយ ព្រមទាំង គ្រួសារលោកផង"



146

អ្នកយាមគុកបានយកប៉ុល និងស៊ីឡាស ទៅកាន់ផ្ទះរបស់គាត់ ហើយលាងឈាម ចេញពីជើង និងខ្នងរបស់គាត់។

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ



147

(ព្រះគម្ពីរ កិច្ចការ ១៦:៣៣)

នៅវេលាយប់នោះឯង គាត់យកគេទៅ លាងស្នាមរំពាត់ចេញ



148

រួចខ្លួនគាត់ និងពួកគាត់ទាំងអស់ ក៏ ទទួលបុណ្យជ្រមុជទឹកភ្លាម"

កិច្ចការ ១៦:៣៣


149

មិត្តទាំងឡាយ បើលោកអ្នកមិនទាន់ បានយល់ អំពីអត្ថន័យនិងសារសំខាន់នៃការជ្រមុជទឹកពីមុនមកទេ ឬមួយក៏អ្នកមិន ដែលមានឱកាស ដើរតាមព្រះយេស៊ូវនៅ ក្នុងពិធីដ៏ពិសិដ្ឋនៃការជ្រមុជទឹក ដោយជ្រ មុជលិចចូលទៅក្នុងទឹកនេះទេ សំនួរ និង សេចក្តីអញ្ជើញដដែលដូចដែលលោកអាន្នានាស បានសួរទៅលោកប៉ុល យ៉ាងដូច្នោះដែរ:



150

(ព្រះគម្ពីរ កិច្ចការ ២២:១៦)

"ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចុះ..."

កិច្ចការ ២២:១៦

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ


151

នៅពេលដែលព្រះយេស៊ូវបានទទួល បុណ្យជ្រមុជទឹក មានសំឡេងពីស្ថានសួគ៌ មកថា "នេះជាកូនស្ងួនភ្ងាអញ ជាទីពេញ ចិត្តអញណាស់" លោកអ្នកក៏ដូច្នោះដែរ នៅពេលដែលលោកអ្នកចូលទៅក្នុងទឹកដើម្បី ធ្វើបុណ្យជ្រមុជទឹក ព្រះជាអម្ចាស់របស់ យើងនឹងមានព្រះបន្ទូលទៅកាន់ចិត្តរបស់អ្នក ថា "ឯងជាកូនប្រុសជាទីពេញចិត្តរបស់ អញ ឯងជាកូនស្រីជាទីពេញចិត្តរបស់អញ អញពេញចិត្តនឹងឯងណាស់"

អំណរដ៏ធំបំផុតរបស់ជីវិត គឺការដែល លោកអ្នកកំពុងធ្វើឱ្យព្រះសព្វព្រះហឫទ័យ។

នៅពេលដែលលោកអ្នកទទួល បុណ្យជ្រមុជទឹក លោកអ្នកនឹងមានវិញ្ញាណ ដ៏ល្អឆើតឆាយថា អ្នកជារបស់ព្រះ។ លោក អ្នកជាកូនរបស់ព្រះ។ នៅក្នុងអារម្មណ៍ មួយដែលគិតថា ការជ្រមុជទឹក ប្រៀបដូច ជាអាពាហ៍ពិពាហ៍។ មុនពេលរៀប អាពាហ៍ពិពាហ៍ កូនកម្លោះនិងកូនក្រមុំស្រ ឡាញ់គ្នា។ អាពាហ៍ពិពាហ៍‗មិនមែនបង្កើត សេចក្តីស្រឡាញ់នៅក្នុងចិត្តបុរស សម្រាប់ ស្ត្រី ឬស្ត្រីសម្រាប់បុរសនោះទេ។

អាពាហ៍ពិពាហ៍គឺជាសាក្សីនៃសេចក្តី ស្រឡាញ់។ អាពាហ៍ពិពាហ៍ គឺជាការប្តេជ្ញា ចិត្តជាសាធារណៈ នៅចំពោះមុខ គ្រួសារ និងមិត្តភ័ក្តិ។

ការជ្រមុជទឹកក៏ដូច្នោះដែរ។ អាពាហ៍ពិពាហ៍ មិនមែនបង្កើតសេចក្តីស្រ ឡាញ់នៅក្នុងចិត្តសម្រាប់ព្រះនោះទេ។

ហេតុដែលយើងចង់ទទួលការជ្រមុជទឹក នោះគឺ ពីព្រោះយើងពិតជាស្រឡាញ់ទ្រង់។

ការជ្រមុជទឹកគឺជាសាក្សី ជាសាធារណៈ នៅចំពោះគ្រួសារ និងមិត្តភ័ក្តិ និងក្រុមជុំនុំ របស់យើងថា យើងស្រឡាញ់ព្រះយ៉ាងខ្លាំង និងប្តេជ្ញាចិត្តចំពោះព្រះយេស៊ូវគ្រីស្ទ។

អតីតកាលបានកន្លងបាត់ទៅហើយ‗បាន កប់បាត់‗មិនអាចត្រឡប់មកវិញបានឡើយ។ ព្រះសន្យាថា ទ្រង់នឹងប្រទាននូវព្រះវិញ្ញាណ បរិសុទ្ធរបស់ទ្រង់ ដើម្បីឱ្យយើងមានអំ ណាចរស់នៅក្នុងជីវិតគ្រីស្ទាន។

អ្នកខ្លះមានការស្ទាក់ស្ទើរ។ គេនៅរារែក គេមិនជឿថា គេបានរៀបចំខ្លួនរួចហើយ នោះទេ។

ការជ្រមុជទឹកមិនមែនមានន័យថា លោកអ្នកល្អឥតទាស់នោះទេ។ វាមានន័យ ថា លោកអ្នកបានថ្វាយចិត្តទៅព្រះ។

ព្រះយេស៊ូវបានអំពាវនាវដល់លោកអ្នក ថ្ងៃនេះ ដើម្បីឱ្យដើរតាមដានព្រះបាទរបស់ ទ្រង់នៅក្នុងផ្លូវនៃទឹក ដោយការជ្រមុជ ទឹកនេះ។ ទ្រង់ប្រទានការ អត់ឱនទោស ឱ្យអ្នកនិងសិរី ភាពអំពីទោសកំហុសពី អតីតកាលរបស់អ្នកហើយ និងប្រទាន អំណាចឱ្យអាចរស់នៅជាជីវិតថ្មីមួយ តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។

តើលោកអ្នកនឹងឆ្លើយថា បាទ ឬ ចាស ទៅកាន់ព្រះយេស៊ូវឥឡូវនេះឬទេ?

ប្រសិនបើលោកអ្នកចង់ដើរតាមព្រះ

# ១៦. បង្កើតការចាប់ផ្តើមថ្មីមួយ

យេស៊ូវ តាមការជ្រមុជទឹងក្នុងព្រះគម្ពីរទាំង ស្រុង ខ្ញុំចង់ឱ្យលោកអ្នកដើរឡើងមកខាង មុខនៃសាលប្រជុំនេះ ដើម្បីឱ្យខ្ញុំអាច អធិស្ឋាន ជាពិសេសជូនលោកអ្នក។

ខ្ញុំសូមអញ្ជើញលោកអ្នកទាំងអស់គ្រោក ឈរឡើងឥឡូវនេះ ដើម្បីធ្វើការអធិស្ឋាន ឥឡូវនេះ។ មុននឹងខ្ញុំអធិស្ឋាន ប្រសិនបើ លោកអ្នកចង់និយាយថា "បពិត្រ ព្រះ យេស៊ូវ ទូលបង្គំចង់ទទួលបុណ្យជ្រមុជ ទឹក" សូមដើរចូលមកកាន់ច្រកដើរមកកាន់ វេទិកាឥឡូវនេះ ហើយឈរនៅអាសនានេះ ដោយឱនក្បាល ដើម្បីឱ្យខ្ញុំអាចអធិស្ឋាន ជូនលោកអ្នក។ សូមកុំរារែក សូមអញ្ជើញ មក សូមអញ្ជីញមកឥឡូវនេះ ខ្ញុំនឹង អថិស្ឋានជូន។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ



1

ការក្លែងបន្លំដ៏ធំបំផុតនៅលើពិភពលោក



2

(វីដេអូ ១៩វិនាទី)មានការបោកបញ្ឆោត មួយដ៏ធំបំផុត ដែលគេបានកត់ត្រាទុក បានកើតឡើងនៅចុងទសវត្សរ៍ទី ១៩៦០។ លោកដេវីឌ ស្ទេន បុរសវ័យក្មេងជាតិ បារាំងម្នាក់ បានគូររូបតាមស្តេចគំនូរ ដ៏ល្បីៗ ជាង៤០០សន្លឹក:

រូបពីកាហ្សូក្លែងក្លាយ រូបឆាហាហ្គាល ក្លែងក្លាយ រ៉េនហ្វ័រក្លែងក្លាយ រូបវ៉ាន់ហ្គ័ត ក្លែងក្លាយ និងរូបក្លែងក្លាយផ្សេងៗទៀត ជាច្រើន ។

គាត់បានចុះហត្ថលេខាឈ្មោះពិតប្រាកដ របស់វិចិត្រករដែលជាម្ចាស់រូបនោះ នៅលើស្នាដៃរបស់គាត់ទាំងអស់ ហើយលក់រូប ទាំងនោះដូចជារូបពិតដូច្នោះដែរ។

ទាំងអស់នោះ គឺសុទ្ធតែជាស្នាដៃក្លែង ក្លាយទាំងអស់។

មនុស្សជាច្រើនបានធ្វើការសាកល្បង មើល ហើយបានសន្និដ្ឋានថា ជាគំនូរពិត ប្រាកដទាំងអស់!



3

(វីដេអូ ៩វិនាទី)មានគំនូរក្លែងក្លាយតែ១១០ ប៉ុណ្ណោះ ដែលត្រូវបានគេដឹង និងរក ឃើញ។ លោកស្ទេន ត្រូវគេចាប់ខ្លួនបាន នៅក្នុងឆ្នាំ១៩៧២ ហើយបានជាប់នៅក្នុង ពន្ធនាគារ ស៊ីង ស៊ីង និងពន្ធនាគារ នៅ ទីក្រុងប៉ារីសនៃប្រទេសបារាំង។

គាត់បានត្រូវគេដោះលែងនៅឆ្នាំ១៩៨០។ ក្នុងកំឡុងពេលដែលគាត់ជាប់នៅក្នុង ពន្ធនាគារ ស្ទេន បានផ្លាស់ប្តូរចិត្ត និង សម្រេចចិត្តថា នឹងគូរដោយប្រើតែហត្ថ លេខា របស់ខ្លួនគាត់ផ្ទាល់តែប៉ុណ្ណោះ។



4

(វីដេអូ ១២វិនាទី)សព្វថ្ងៃនេះគាត់ត្រូវបាន គេកត់សំគាល់ថាជាវិចិត្រករ និងអ្នក បង្រៀនអំពីការគូររូបដ៏ល្បីល្បាញម្នាក់ នៅលើពិភពលោកនេះ។ ហើយតើគាត់ បង្រៀនពីអ្វីទៅ? អ្វីដែលគាត់ចេះច្បាស់ជាងគេនោះគឺ "ការស្គាល់ភាពក្លែងក្លាយ"

លោកអ្នកនឹងត្រូវតែយល់ស្រប ដូច លោកស្ទេនបានបង្ហាញយ៉ាងពិតប្រាកដដែរថា វាមិនមែនងាយស្រួលជានិច្ចនោះទេ ក្នុង ការក្លែងបន្លំនោះ-ទោះបីជាអ្នកជំនាញយ៉ាង ណាដ៏ដោយ!

ប៉ុន្តែទោះបីគាត់ជា "អ្នកឆបោក" ដ៏ ឆ្លាតវៃយ៉ាងណាក៏ដោយ គាត់ប្រៀបបាន ត្រឹមតែក្មេងបៀមដៃម្នាក់ប៉ុណ្ណោះ បើ ប្រៀបធៀបទៅនឹង

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ



5

(វីដេអូ ៧វិនាទី) អារក្សសាតាំង ដែល ជាបិតានៃការបោកបញ្ឆោតលើសគេឯងនោះ!
នៅពេលដែលវាលេចមកដើម្បីនឹងធ្វើការបំ ភាន់ និងក្លែងបន្លំនោះ គ្មានអ្នកណាអាច
ប្រៀបផ្ទឹមនឹងវាបានឡើយ។ ជាការពិត ណាស់ សាតាំងមិនបានធ្វើការបោក បញ្ឆោតដោយចំហទេ។
វាធ្វើការតាមមនុស្សដទៃ អំណាចដទៃ និងភ្នាក់ងារដទៃទៀត។
ប្រសិនបើវាជាសត្រូវរបស់ព្រះ និង សេចក្តីពិតដោយចំហនោះ វាពិតជានឹង
មានគ្រោះតិចតួចណាស់ ដល់ពួកគ្រីស្ទាន ដែលនឹងត្រូវចាញ់បញ្ឆោតវា។
ដូច្នេះវាធ្វើការជាសម្ងាត់បំផុត ជួនកាល លាក់មុខនៅក្នុងរូបរាងរបស់សាសនាតែម្តង


6

ដោយបញ្ចូលគ្នាយ៉ាងប៉ិនប្រសប់នូវការពិត និងក្លែងក្លាយ ដើម្បីទាញមនុស្សឱ្យឆ្ងាយពី
ការថ្វាយបង្គំពិតរបស់ព្រះ។ ទាំងអស់នេះ
ហើយដែលជាសេចក្តីត្រូវការរបស់វារាប់ពាន់ឆ្នាំមកហើយ។


7

ព្រះមិនបានទុកយើងឱ្យនៅក្នុងសេចក្តី មេត្តារបស់ការបោកបញ្ឆោតនោះឡើយ
ប៉ុន្តែទ្រង់បានប្រាប់យើងតាមរយៈព្រះគម្ពីរ អំពីការបោកប្រាសដ៏ធំបំផុតនៅ សម័យចុងបញ្ចប់។


8

ព្រះគម្ពីរ និយាយថា ដានីយ៉ែលខ្លួន ឯងបានយល់សប្តិឃើញសត្វតិរច្ឆានមួយលេចឡើងពីសមុទ្រ។


9

(ព្រះគម្ពីរ ដានីយ៉ែល ៧:២,៣)
"...ខ្ញុំបានឃើញការជាក់ស្តែងនៅពេល
យប់ ដូច្នេះ ខ្យល់ទាំងបួននៅលើអាកាស ធ្លាក់ ចុះមកលើមហាសមុទ្រ


10

រួចមានសត្វធំបួន ឡើងចេញពីសមុទ្រ មក មានសណ្ឋានផ្សេងៗគ្នា" ដានីយ៉ែល ៧:២,៣


11

សត្វតិរច្ឆានចេញមកពីសមុទ្រ?
តើមានន័យថាយ៉ាងណា?

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


12

សូមឱ្យព្រះគម្ពីរផ្ដល់កូនសោឱ្យយើង ដើម្បីចាក់បើកនិមិត្តសញ្ញានៃបទទំនាយនេះ។ ដំបូង នៅក្នុងយល់សប្ដិនេះមានទឹក។


13

(ព្រះគម្ពីរ វិវរណៈ ១៧:១៥)

ព្រះគម្ពីរវិវរណៈ ១៧:១៥និយាយថា "...ឯទឹកដែលអ្នកបានឃើញគឺជាប្រជាជន និងមនុស្សផងទាំងឡាយគ្រប់សាសន៍ គ្រប់ភាសា"។

នៅក្នុងជំពូកដដែលនោះ ព្រះបានប្រាប់ ដានីយ៉ែលអំពី អ្វីដែលតំណាងឱ្យសត្វនោះ:


14

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៧,២៣)

"ឯសត្វធំទាំងបួននោះ គឺជាស្ដេច៤អង្គ ដែលនឹងកើតមានឡើងនៅផែនដី។


15

...អ្នកនោះក៏ប្រាប់ថា សត្វទី៤នោះ គឺជា នគរទី៤ នៅលើផែនដី" ដានីយ៉ែល ៧:១៧,២៣

ព្រះបន្ទូលរបស់ព្រះបានបញ្ជាក់យ៉ាង ច្បាស់ថា សត្វនោះតំណាងឱ្យស្ដេចមួយអង្គ ឬនគរមួយ។


16

សត្វនោះបានចេញមកពីតំបន់ដែលមាន មនុស្សច្រើននៃផែនដី ដែលតំណាងឱ្យជាតិសាសន៍មួយយ៉ាងជាក់លាក់ ដែលនឹងកើត មានឡើង។

សូមកត់សំគាល់ការដែលទ្រង់បាន ពណ៌នាការទាំងអស់នេះ នៅក្នុងព្រះគម្ពីរ ដានីយ៉ែល ៧:៣


17

(ព្រះគម្ពីរ ដានីយ៉ែល ៧:៣)

"រួចមានសត្វធំ៤ឡើងចេញពីសមុទ្រ មកមានសណ្ឋានផ្សេងៗគ្នា"


18

(ព្រះគម្ពីរ ដានីយ៉ែល ៧:៤)

"សត្វទី១ដូចជាសិង្ហ ហើយមានស្លាប ជាឥន្ទ្រីយ៍..." ដានីយ៉ែល ៧:៤

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


19

(ព្រះគម្ពីរ ដានីយ៉ែល ៧:៥)

"រួចឃើញសត្វ១ទៀតជាសត្វទី២ មាន សណ្ឋានជាខ្លាឃ្មុំ ក៏ឈរចំហៀង


20

ពាំឆ្អឹងនៅក្នុងមាត់ ខាំដោយធ្មេញ ហើយ មានគេប្រាប់ដល់វាថា ចូរក្រោកឡើង..."
ដានីយ៉ែល ៧:៥


21

(ព្រះគម្ពីរ ដានីយ៉ែល ៧:៦)

ក្រោយមកខ្ញុំគន់មើលទៅឃើញសត្វ១ ទៀត មានសណ្ឋានជាខ្លារខិន ឯនៅលើ ខ្នងវា មានស្លាប៤ នៃសត្វហើរ..." ដានីយ៉ែល ៧:៦


22

(ព្រះគម្ពីរ ដានីយ៉ែល ៧:៧)

"លំដាប់នោះក្នុងការជាក់ស្តែងពេល យប់ ខ្ញុំក៏ឃើញសត្វទី៤ ដែលគួរស្ញើម គួរស្ញែងខ្លាច ហើយមានកម្លាំងយ៉ាងក្រៃ លែង"


23

មានធ្មេញដែកធំៗ វាត្របាក់លេប លំ អិតកំទេច ហើយជាន់ឈ្លីសំណល់ដោយ ជើង.


24

សត្វនោះផ្សេងពីអស់ទាំងសត្វដែលមាន មកជាន់មុននោះ ក៏មានស្នែង១០"
ដានីយ៉ែល ៧:៧


25

នេះគឺជាសួនសត្វដ៏ពពាក់ពពូន! លោក អ្នកនឹងកត់សំគាល់បានថា សត្វនីមួយៗមិន មែនជាសត្វធម្មតាទេ។

វាទាំងអស់មានលក្ខណៈពិសេសរៀងៗ ខ្លួន ដែលជួយឱ្យយើងយល់អំពីការជាក់ ស្តែងនេះ។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ



26

នៅពេលដែលដានីយ៉ែលផ្ទះបញ្ចាំងការ ជាក់ស្តែងនៃសត្វទាំងបួននេះ គាត់ត្រូវតែ នឹកឃើញពីសុបិនរបស់ព្រះមហារាជា នេប៊ូក្នេសា_យល់សប្តិអំពីរូបលោហធាតុ ដ៏ធំ។ នៅក្នុងយល់សប្តិទាំងពីរនេះ គឺជា និមិត្តសញ្ញាសម្គាត់ នៃអាណាចក្រទាំងបួន របស់ពិភពលោកពីបុរាណ




27

(វីដេអូ ៦វិនាទី) ចាប់ផ្តើមពីចក្រភព បាប៊ីឡូន មេដូ និងពើរស៊ី អាណាចក្រ ក្រេក និងរ៉ូម



28

ហើយបញ្ចប់ដោយការយាងមករបស់ព្រះ យេស៊ូវ ហើយនិងការបង្កើតនគរដ៏អស់ កល្បរបស់ទ្រង់ឡើង។



29

សូមយើងត្រឡប់មក និងមើលសត្វ ឬ ជាតិសាសន៍នីមួយៗនេះ នៅពេលដែលវា លេចឡើងពីកន្លែងដែល មានមនុស្សនៅ លើពិភពលោកនេះ:



30

(ព្រះគម្ពីរ ដានីយ៉ែល ៧:៤)

“សត្វទី១ ដូចជាសិង្ហ ហើយមានស្លាប ជាស្លាបឥន្ទ្រីយ៍ ខ្ញុំបានគន់មើល ដរាបដល់ ចំអេងស្លាបវាត្រូវដកចេញ



31

ហើយវាត្រូវលើកឡើងផុតពីដី ក៏ដាក់ឱ្យ ឈរជើង២ដូចជាមនុស្ស ហើយបានឱ្យវា មានចិត្តរបស់មនុស្សដែរ” ដានីយ៉ែល ៧:៤



32

តើមានអ្វីទៅដែលអាចជាតំណាងឱ្យ បាប៊ីឡូន ដែលជាចក្រភពទីមួយនៅលើ សាកលលោកនេះ ឱ្យបានប្រសើរ ជាងសត្វសិង្ហ ដែលជាស្តេចនៃសត្វ និង ក្បាលមាស (នៅក្នុងរូបដ៏ខ្ពស់)ដែរឬទេ?

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


33

បាប៊ីឡូនបុរាណខ្លួនឯងបាន ប្រើរូបសិង្ហ នេះជាតំណាងឱ្យចក្រភពរបស់ខ្លួន។
បុរាណវិទូបានរកឃើញនៅក្នុងសំណង់ បាក់បែកនៃទីក្រុងបាប៊ីឡូន នូវរូបសំណាក
សត្វសិង្ហដែលមាន ស្លាបឥន្ទ្រីយ៍នេះ។


34

ដូចដែលសត្វសិង្ហត្រូវបានគេកត់សំគាល់ នូវកម្លាំង និងសន្ទុះខ្លាំងក្លារបស់វា ភាព
ខ្លាំងក្លាក្នុងការធ្វើសឹក សង្គ្រាមនៃកងទ័ព របស់ស្តេចនេប៊ូក្នេសា ក៏មានសន្ទុះខ្លាំងក្លាដ៏
លើសលប់ដូច្នោះដែរ។
ភាពលឿនស្លេវដែលនគរបាប៊ីឡូន យកអំណាចពីនគរនានា និងពង្រីកអាណា
ចក្ររបស់ខ្លួនវាសមរម្យ ទៅនឹងនិមិត្តសញ្ញា នៃស្លាបឥន្ទ្រីយ៍នេះណាស់។
សូមកត់សំគាល់ថា ព្រះបានប្រើនិមិត្ត សញ្ញានេះ ដើម្បីតំណាងឱ្យនគរបាប៊ីឡូនៈ


35

(ព្រះគម្ពីរ យេរេមា ៤:៧)
"មានសត្វសិង្ហ១ បានឡើងចេញពីព្រៃ ស្តុករបស់វាមក ជាមេបំផ្លាញនគរផ្សេងៗ
វាកំពុងតែមកតាមផ្លូវ


36

វាបានចេញពីកន្លែងរបស់វាមកហើយ ដើម្បីនឹងបំផ្លាញស្រុកឯង..."
យេរេមា ៤:៧


37

ស្តេចអំនួតដ៏ក្រអឺតក្រទមនៃនគរ បាប៊ីឡូន បានប្រាថ្នាចង់ឱ្យនគរទ្រង់ស្ថិត នៅរៀងរហូត។
ទ្រង់បានព្រះតម្រិះ ឃើញថា មិនដែលមានជាតិសាសន៍ណា ដែលនឹង
ត្រូវគ្រប់គ្រងលើពិភពលោកនេះឡើយ។
ទ្រង់បានចារនៅនឹងថ្មនៃអាគាររបស់ទ្រង់ថា "សូមឱ្យវាគង់វង់នៅជាដរាប"



38

(វីដេអូ ៤វិនាទី) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ៥៣៩ មុនគ្រិស្តសករាជ នគរបាប៊ីឡូន
តំណាងដោយក្បាលមាស នៅក្នុងរូប លោហធាតុ ហើយនិងដោយស្លាបឥន្ទ្រីយ៍
(នៅក្នុងសុបិនរបស់ដានីយ៉ែល) បានដល់ទី បញ្ចប់ដ៏អាម៉ាស់មួយ។



39

(វីដេអូ ៣វិនាទី) នគរ ឬអាណាចក្រ ដែលតំណាងដោយសត្វទីពីរ-ខ្លាឃ្មុំនោះ គឺជានគរមេដូពើរស៊ី
ដែលកាន់កាប់បន្ត ជានគរដែលតំណាងដោយ ដៃនិងដើមទ្រូង ប្រាក់នៅក្នុងរូបសំណាកដ៏ធំនោះ
នៅពេល ដែលដានីយ៉ែលមើលទៅខ្លាឃ្មុំ នៅក្នុង យល់សប្តិរបស់គាត់ គាត់បាននិយាយថា

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


40

(ព្រះគម្ពីរ ដានីយ៉ែល ៧:៥)

"...វាឈរលើជើងម្ខាង ព្រមទាំងពាំ ឆ្អឹងជំនីរបីក្នុងមាត់ផង" (ព្រះគម្ពីរភាសារ ខ្មែរសម្រាយ)
ដានីយ៉ែល ៧:៥


41

ដានីយ៉ែលបាននិយាយថា ខ្លាឃ្មុំមាន ពាំឆ្អឹងបីនៅនឹងមាត់ ចន្លោះធ្មេញរបស់វា ប៉ុន្តែព្រះគម្ពីរមិនបាន បញ្ជាក់អំពីអត្ថន័យ របស់វាទេ។


42

ទោះជាយ៉ាងណាក៏ដោយ អ្នកប្រាជ្ញព្រះ គម្ពីរជាច្រើនជឿថា ឆ្អឹងទាំងបីនោះតំណាង ឱ្យ


43

លីដា បាប៊ីឡូន និងអេស៊ីព្ទ ដែនដីបី ដែលត្រូវបានទំពារលេបដោយ កងទ័ព មេ៉ដូ និងពើរស៊ី។


44

ចក្រភពពើរស៊ី បានគ្រប់គ្រងអំណាច អស់រយៈពេលពីរសតវត្សរ៍ ប៉ុន្តែ ដូចដែលព្រះបានបង្ហាញឱ្យដានីយ៉ែលបានឃើញ នៅក្នុងយល់សប្តិថា នឹងមានសត្វឬនគរមួយទៀតនឹងកើតឡើង ដែលសាហាវ និង ខ្លាំងក្លា:


45

(ព្រះគម្ពីរ ដានីយ៉ែល ៧:៦)

"ក្រោយមកខ្ញុំក៏គន់មើលទៅឃើញសត្វ ១ទៀត មានសណ្ឋានជាខ្លារខិន មាន ស្លាប៤នៃសត្វហើរ


46

ក៏មានក្បាល៤ដែរ ហើយមានអំណាចគ្រប់ គ្រងប្រគល់ឱ្យវា"
ដានីយ៉ែល ៧:៦


47

ដូចជាខ្លាឃ្មុំដែលរត់យ៉ាងយឺតៗ បង្ហាញ ថា មិនអាចប្រៀបធៀបទៅ នឹងខ្លារខិនដែលរត់យ៉ាងលឿនបានឡើយ ដូច្នេះ កងទ័ព ពើរស៊ីមិនអាចការពារខ្លួនគេ ប្រឆាំងនឹងការរុលទៅមុខយ៉ាងលឿន ស្លេវរបស់ អាឡិចហ្សង់ បានឡើយ។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ



48

(វីដេអូ ៨វិនាទី) នៅក្នុងសុបិននៃបទ ទំនាយរបស់ស្តេចនេប៊ូក្នេសា ពោះនិងភ្លៅ លង្ហិននៃរូបសំណាក
នោះតំណាងឱ្យចក្រ ភពទីបី នៅលើសាកលលោកនេះ គឺនគរ ក្រេក
ហើយក៏ដូចជាខ្លារខិននៅក្នុងយល់ សប្តិ របស់ដានីយ៉ែលដែរ។


49

ស្លាបទាំងបួនពិពណ៌នាអំពីសន្ទុះនៃការ វាយលុកយ៉ាងខ្លាំងក្លារបស់អាឡិចហ្សង់។
លោកបានវាយបំបាក់ស្តេចដារីយុសទី៣ នៃនគរពើរស៊ីនៅសមរភូមិ អាបេឡានៅ ក្នុងឆ្នាំ៣១១
មុនគ្រិស្តសករាជ ដូច្នេះ នៅក្នុងកំឡុងពេលតិចជាងដប់ពីរឆ្នាំ អ្នក គ្រប់គ្រងនៃចក្រភពដ៏ទូលំទូលាយ
ដែល មិនដែលមាននៅលើលោកនេះក៏បានកាន់កាប់អំណាចឡើង។
ខ្លារខិនក្បាលបួនតំណាងឱ្យភូមិភាគទាំង បួននៃនគរក្រេក។



50

(ព្រះគម្ពីរ ដានីយ៉ែល ៨:២២)
"នោះគឺជានគរ៤ ដែលនឹងកើតឡើង ពីសាសន៍នោះ" ដានីយ៉ែល៨:២២


51

ប្រវត្តិសាស្ត្រប្រាប់យើងថា ចក្រភព ក្រេក បានបែងចែកជាបួនផ្នែកបន្ត១ពិត ប្រាកដមែន។
លោកអាឡិចហ្សង់បានស្លាប់នៅក្នុងអាយុ សាមសិបពីរឆ្នាំ បានតែប្រាំពីរឆ្នាំក្រោយពី
ជោគជ័យដ៏ធំរបស់គាត់ នៅអារបេឡា តែប៉ុណ្ណោះ។
គាត់មិនទាន់ទាំងបានត្រូវគេយកទៅ បញ្ចុះផង អំណាចរបស់គាត់ត្រូវចាប់ផ្តើម
មានបញ្ហារង្គោះរង្គើ នៅក្នុងចំណោមបង ប្អូនរបស់គាត់ ហើយក្រោយមកទៀតក្នុង ចំណោម
អ្នកដឹកនាំកងទ័ពរបស់គាត់។
ទីបញ្ចប់ឧត្តមសេនីយ៍បួននាក់របស់ អាឡិចហ្សង់ ក៏បានទទួលគ្រប់គ្រងចក្រ ភពទាំងមូល។



52

(វីដេអូ ៩វិនាទី)ឥឡូវនេះ សត្វខ្លារខិន ឬ ក្រេកមានក្បាលបួន!
កាសិនឌើរ លីស៊ីម៉ាឈឹស ផាតូឡេមី និងសេលូសឹស។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


53

មនុស្សជាច្រើនមានបញ្ហា ក្នុងការធ្វើ ដំណើរឱ្យចំទិសដៅ នៅពេលដែលគេមាន ត្រឹមតែក្បាលមួយប៉ុណ្ណោះ ចុះទំរាំបើមាន ក្បាលដល់ទៅបួនឯណោះនោះ តើវាពិបាក យ៉ាងណាទៅ?។

ឧបមាថា លោកអ្នកមានក្បាលបួន តើ វានឹងទៅជាយ៉ាងណា? ច្បាស់ជាវង្វេង ហើយ!

ក្បាលនីមួយៗចង់ "បានជាលេខមួយ" ទាំងអស់!

នោះហើយជាហេតុដែលបានកើតមាន ឡើងយ៉ាងត្រឹមត្រូវដល់ចក្រភពក្រេក។ ឧត្តមសេនីយ៍ទាំងបួនរបស់អាឡិចហ្សង់ មានការប្រណែនគ្នា និងមានមហិច្ឆិតាដ៏លើសលប់រៀងៗខ្លួន ចង់គ្រប់គ្រងចក្រ ភពទាំងមូលតែរៀងខ្លួន។


54

"ម្នាក់សំលៀងដាវប្រឆាំងនឹងម្នាក់ទៀត ហើយចក្រភពទាំងមូលក៏បានរលំដួល" អាឡិចហ្សង់ ទំព័រ៤៩៤។


55

ភាពគ្មានលំនឹង និងការទាស់ទែងគ្នា បានបន្តនៅក្នុងចំណោមផ្នែកទាំងបួន នៃចក្រភពនោះ រហូតដល់ទីបំផុត "ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៦៨ មុន
គ្រិស្តសករាជ នៅឯសមរភូមិ ភីដណា ចក្រភពរបស់អាឡិចហ្សង់ ត្រូវបានបាត់ បង់
បន្ទាប់ពីមរណភាព
របស់គាត់១៤៤ឆ្នាំ" ប្រវត្តិសាស្ត្ររបស់ ប្រទេសរ៉ូម សៀវភៅទី៣ ជំពូក១០។


56

ប៉ុន្តែ ចុះអំពីសត្វសាហាវទីបួនដែល ដានីយ៉ែលបាននិយាយថា នឹងកើតឡើង ដែលនឹងមានអំណាចបន្ទាប់ ពីក្រេកនោះ តើយ៉ាងណាដែរ?


57

ទេវតាបានប្រាប់ដានីយ៉ែលថា នគរទី បួននេះ នឹងខុសពីនគរដទៃទៀត។

សត្វដែលតំណាងឱ្យនគរនោះមាន អំណាចខ្លាំងមែនទែន ហើយវាមានធ្មេញ ដែកយ៉ាងធំសំបើម ដែលបានបំផ្លាញរំពារ របស់វាទៀតផង។

នេះគឺជារូបភាពនៃអំណាចដ៏ឃោរឃៅ និងប្រកបដោយជោគជ័យមួយ។


58

គ្មានការពិពណ៌នាណាឱ្យបានត្រឹមត្រូវជាង ការវាយលុកដ៏ធំរបស់ចក្រភពរ៉ូម ឱ្យបានច្បាស់ជាងនេះទៀតឡើយ

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


59

រ៉ូមគឺជាចក្រភពមួយដែលគ្មានមេត្តា និងសាហាវឃោរឃៅជាងចក្រភពមុនៗទាំងអស់។
គេថែមទាំងបានបំផ្លាញជាតិរបស់គេ ផ្ទាល់ ហើយបានដាក់ជនជាតិគេ ឱ្យទៅជា ទាសករទៀតផង។



60

(វីដេអូ ៤វិនាទី) សត្វដ៏គួរឱ្យភ័យខ្លាច នេះ មានធ្មេញដែក នៅពេលដែលនគរ ទីបួនក្នុងរូប
សំណាកលោហធាតុ ដែល តំណាងដោយជើងដែក។
ដានីយ៉ែលត្រូវបានចាប់អារម្មណ៍ទៅលើ សត្វដ៏អាក្រក់នេះ ហើយជាពិសេសដោយ
សារស្នែងទាំងដប់របស់វា។



61

(ព្រះគម្ពីរ ដានីយ៉ែល ៧:៨)
គាត់បាន និយាយថា "ខ្ញុំបានពិចារណា មើលស្នែង ទាំងនោះ ក៏ឃើញមានស្នែង ១ទៀត ជាស្នែងតូច
ដុះឡើងនៅជាកណ្តាល



62

នៅមុខវា ស្នែងចាស់៣ត្រូវដកចេញទាំង
ឫស..." ដានីយ៉ែល ៧:៨



63

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៤)
ទេវតាបានប្រាប់ដានីយ៉ែលថា "ឯស្នែង ទាំង១០នោះ គឺនឹងមានស្តេច១០អង្គកើត ឡើង"
ដានីយ៉ែល៧:២៤



64

(វីដេអូ ៤វិនាទី) មិនចាំបាច់ឆ្ងល់ទេ គំនិត
របស់ដានីយ៉ែលបានថយក្រោយទៅរករូបសំណាកលោហធាតុដ៏ធំ ដែលមានជើងជា ដែកនិងដីឥដ្ឋ
ដែលជាតំណាងឱ្យការបែង ចែកនៃចក្រភពរ៉ូម។



65

(វីដេអូ ៤វិនាទី) នៅឆ្នាំ ៤៧៦ នៃ
គ្រិស្តសករាជ កុលសម្ព័ន្ធដ៏ឃោរឃៅនៃ
អឺរ៉ុបខាងជើង បានបំផ្លាញចក្រភពរ៉ូម ជាដំណាំ។ នគរប្រាំពីរនៃនគរ(ជាតិ)ទាំង នោះ
នៅតែមាននៅឯអឺរ៉ុបរហូតសព្វថ្ងៃនេះ។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


66

ប៉ុន្តែអ្វីដែលធ្វើឱ្យដានីយ៉ែលចាប់ អារម្មណ៍ ជាងគេនោះគឺ ស្នែងតូច ដែល លើកខ្លួនឯងចេញ ពីក្នុងចំណោមស្នែងដប់ ដោយដកទាំងឫសរបស់ស្នែងបីទៀត នៅ ក្នុងការខំប្រឹងប្រែងឱ្យបានបរមានុភាព (ភាពដាច់គេ) របស់ខ្លួន ។


67

(ព្រះគម្ពីរ ដានីយ៉ែល ៧:៨)

ដានីយ៉ែបានបញ្ជាក់ថា "ស្នែងតូចនោះ មានភ្នែក ដូចជាភ្នែកមនុស្ស ក៏មានមាត់ កំពុងពោលពាក្យយ៉ាងធំ" ដានីយ៉ែល ៧:៨


68

ស្នែងតូចនេះបានធ្វើឱ្យដានីយ៉ែលមាន បញ្ហា។


69

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៥)

គាត់បានសរសេរថា "ឯខ្ញុំដានីយ៉ែល ចិត្ត ខ្ញុំកើតមានសេចក្តីតប់ប្រមល់នៅក្នុងខ្លួន ហើយជាការជាក់ស្តែងក្នុងខួរខ្ញុំ"

ដានីយ៉ែល ៧១៥


70

តើហេតុអ្វីបានជាការពិពណ៌នានៃស្នែង តូចនេះ បានធ្វើឱ្យដានីយ៉ែលមានការចាប់ អារម្មណ៍ខ្លាំងម្ល៉េះ?


71

(ព្រះគម្ពីរ ដានីយ៉ែល ៧:២១,២៥)

ពីព្រោះ "ឃើញស្នែងនោះឯងបាន ច្បាំងនឹង ពួកបរិសុទ្ធ ហើយក៏ឈ្នះផង"


72

ស្តេចនោះនឹងពោលពាក្យទាស់នឹងព្រះ ដ៏ខ្ពស់បំផុត


73

ហើយនិងធ្វើទុកបៀតបៀនដល់ពួកបរិសុទ្ធនៃ ព្រះដ៏ខ្ពស់បំផុតដែរ ព្រមទាំងគិតបំផ្លាស់ ពេល កំណត់ និងច្បាប់ផង

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


74

ហើយគេនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃ ស្តេចនោះ  នៅ១ខួប២ខួប ហើយកន្លះ ខួប"
ដានីយ៉ែល ៧:២១,២៥។


75

ដានីយ៉ែលបានដឹងថា ទំនាយនេះ មិន គ្រាន់តែទាក់ទងទៅនឹងប្រវត្តិសាស្ត្រធម្មតា ប៉ុណ្ណោះទេ ប៉ុន្តែវាទាក់ទងទៅនឹងរាស្ត្រ របស់ព្រះអម្ចាស់ទៀតផង។


76

ស្នែងតូចនេះបានធ្វើសង្គ្រាមប្រឆាំងនឹង ពួកបរិសុទ្ធរបស់ព្រះ ហើយបានឈ្នះជា យថាហេតុ អស់ពេលមួយរយៈ ជាការជាក់ ស្នែង វាគឺជាអំណាច ដែលជាសត្រូវបៀត បៀន-
ជាអំណាចឬជាភ្នាក់ងារដែលប្រើ ដោយសាតាំង ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹង រាស្ត្ររបស់ទ្រង់ និងសេចក្តីពិតរបស់ ទ្រង់។


77

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៨)
ដានីយ៉ែលបាននិយាយថា
"ចំណែកខ្ញុំ... គំនិតខ្ញុំបាននាំឱ្យខ្ញុំវិតក្ក ព្រួយជាខ្លាំង


78

ភាពខ្ញុំក៏ផ្លាស់ប្រែទៅ តែខ្ញុំបានទុកដំណើរ នេះនៅតែក្នុងចិត្តទេ"
ដានីយ៉ែល ៧:២៨


79

តើស្នែងតូចនេះជាអ្នកណា?


80

សូមយើងពិនិត្យមើលការពិពណ៌នា នៃ ព្រះគម្ពីរ អំពីស្នែងតូចនេះ ហើយនិង មើលអំពីកំណត់ត្រា នៃប្រវត្តិសាស្ត្រ ដែលបានកត់ត្រាពីការដែលវានឹងកើតមាន ឡើង។

ដានីយ៉ែលបានពិពណ៌នាអំពីសត្វទីបួន ឬក៏ចក្រភពទីបួននៃពិភពលោកយ៉ាងដូច្នេះ

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


81

(ព្រះគម្ពីរ ដានីយ៉ែល ៧:៧)

"...ដែលគួរស្ញើម គួរស្ញែងខ្លាច ហើយ មានកម្លាំងយ៉ាងក្រៃលែង... ក៏មានស្នែង១០" ដានីយ៉ែល ៧:៧


82

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៤)

ដានីយ៉ែល ៧:២៤ ប្រាប់យើងថា ស្នែងដប់តំណាងឱ្យ "ស្តេចដប់អង្គដែល នឹងកើតឡើង"


83

ជំនួសឱ្យចក្រភពមួយទៀតដែលនឹងកើត មានឡើងនៅលើពិភពលោកនេះ ដែលនឹងបង្ហាញខ្លួននៅលើ ឆាកប្រវត្តិសាស្ត្រ នៅ ពេលដែលចក្រភពទីបួនត្រូវដួលរលំនោះ បទទំនាយបានទស្សនទាយថា នឹងមានការ បែងចែកនៃចក្រភពរ៉ូម ដែលជាលទ្ធផលក្នុងនគរតូច១ទាំងដប់។

ប្រវត្តិសាស្ត្របានបញ្ជាក់បន្ថែមអំពីចំ ណែកនៃបទទំនាយរបស់ដានីយ៉ែលនេះ។


84

អ្នកប្រវត្តិសាស្ត្រប្រាប់យើងយ៉ាងច្បាស់ ថា ការបែងចែកនៃចក្រភពរ៉ូមបានកើត ឡើងយ៉ាងត្រឹមត្រូវស្រេចបាច់នៅ គ្រិស្តសករាជ៤៧៦។

យោងតាមអ្នកប្រវត្តិសាស្ត្រជាតិអង់ គ្លេសឈ្មោះ អេដវ៉ាដ អេលីយ៉ូត នៅក្នុងសៀវភៅរបស់គាត់មួយឈ្មោះ ហូរ៉ា អាប៉ូកាលីពទីកា បានបញ្ជាក់ថា កុលសម្ព័ន្ធដ៏ឃោរឃៅខាងក្រោមនេះបានយកជ័យជំនះ លើចក្រភពរ៉ូមនៅឆ្នាំ៣៥១-៤៧៦ នៃ គ្រិស្តសករាជ។


85

(វីដេអូ ២០វិនាទី) បញ្ជីខាងក្រោមនេះ រាយឈ្មោះកុលសម្ព័ន្ធអាឡឺម៉ង់ត៍ ហើយ និងឈ្មោះថ្មីរបស់គេនៅសព្វថ្ងៃនេះ

អាឡាម៉ានី - អាឡឺម៉ង់ត៍

ប៊ឺហ្គានឌៀន - ស្វីស

ហ្រ្វេង្ស - បារាំង

ឡុំបាឌ្ស - អ៊ីតាលី

ហ្សាក់ហ្សុង - អង់គ្លេស

ស៊្វីវ - ព័រទុយហ្គាល់

វីស៊ីហ្គូថ - អេស្ប៉ាញ

ហ៊ែរុលី - បាត់បង់

អូសស្ត្រូហ្គូថ - បាត់បង់

វេនដាល - បាត់បង់

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


86

ទាំងនេះគឺជាស្នែងទាំងដប់ ដែល ដានីយ៉ែល បានឃើញនៅក្នុងការជាក់ ស្តែង។

ហើយយោងទៅតាមបទទំនាយ ស្នែង តូចត្រូវបានកើតឡើង ហើយមានអំណាច ជាខ្លាំង បន្ទាប់ពីស្នែងទាំងដប់នោះ

បន្ទាប់ពីការបែងចែងនៃចក្រភពរ៉ូមមក។


87

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៤)

"ឯស្នែងទាំង១០នោះ គឺនឹងមានស្តេច ១០អង្គកើតឡើងពីនគរនោះ


88

ហើយក្រោយមកនឹងមាន១ទៀតកើតឡើង ...ក៏នឹងទំលាក់ស្តេច៣អង្គនោះចុះ"

ដានីយ៉ែល ៧:២៤


89

នៅក្នុងឆ្នាំ ៤៩៣ នៃគ្រិស្តសករាជ ប្រទេសហ៊ែរុលី បានជួបនឹងវាសនាអាក្រក់ របស់ខ្លួន ដែលមានជំនួយពីព្រះចៅអធិរាជ ហ្សេណូ។


90

ព្រះចៅអធិរាជមួយអង្គទៀត ព្រះនាម ហ្សាស្ទីនៀន បានធ្វើឱ្យសាបសូន្យប្រទេស វេនដាល នៅក្នុងឆ្នាំ៥៣៤ ហើយបន្ទាប់មក បានបំបែកអំណាចរបស់ អូស្ត្រូហ្គូថនៅ ក្នុងឆ្នាំ៥៣៨។


91

ដូច្នេះស្នែងបីនៃយល់សប្តិរបស់ ដានីយ៉ែល "ត្រូវបានដកទាំងឫស" ធ្វើឱ្យ ការកើតឡើងនៃសាសនារ៉ូម បានក្លាយជា ការពិតប្រាកដ។


92

នៅគ្រានោះហើយដែលព្រះ ចៅហ្សាស្ទី នៀន បានចេញច្បាប់ឱ្យបង្កើត ប៊ូជាចារ្យ ប៉ាបនៃនគររ៉ូម ជាអ្នកដឹកនាំសាសនាគ្រីស្ទ នៃនគររ៉ូមខាងលិច។

ដានីយ៉ែលក៏បានទស្សនទាយផងដែរថា ស្នែងតូចនេះ នឹងខុសពីនគរដទៃផ្សេងៗ ទៀត:

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


93

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៤)

"...ដែលនឹងប្លែកពីស្តេចមុនៗ"

ដានីយ៉ែល ៧:២៤។ តើសត្វនេះមានការ ខុសពីគេមែនទេ? ពិតប្រាកដណាស់ វា ខុសពីគេមែន!


94

នគរផ្សេងៗទៀតជាអំណាចនយោបាយ ប៉ុន្តែស្នែងតូច ជាសាសនាដែលកាន់ អំណាចនយោបាយ។


95

ការចង្អុលបង្ហាញនៃបទទំនាយ ហាក់បី ដូចជាបានចង្អុលបង្ហាញយ៉ាងចំៗ ទៅលើ សាសនារ៉ូម៉ាំង នៅមជ្ឈិមសម័យ ថាជា ស្នែងតូចនៃព្រះគម្ពីរដានីយ៉ែល៧ ដូចដែល ពួកអ្នកកែទម្រង់ប្រូតេសស្តង់បានអះអាង មែន។

ដានីយ៉ែលបានផ្តល់លក្ខណៈសំគាល់ មួយទៀតរបស់អំណាចនៃស្នែងតូចនេះ:


96

(ព្រះគម្ពីរ ដានីយ៉ែល ៧:២១)

"ខ្ញុំក៏គន់មើលទៅ ឃើញស្នែងនោះឯង បានច្បាំងនឹងពួកបរិសុទ្ធ ហើយក៏ឈ្នះផង"

ដានីយ៉ែល ៧:២១។


97

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)

គាត់ថែមទាំងនិយាយទៀតថា អំណាច នេះនឹង "...ធ្វើទុក្ខបៀតបៀនដល់ពួក បរិសុទ្ធ..." ខ២៥។


98

តើក្រុមជុំនុំនៅមជ្ឈិមសម័យនោះ បាន ជួបប្រទះនឹងការបៀតបៀនមែនឬទេ?

ជាអកុសល គឺពិតជាមានដូច្នោះមែន!

សង្គ្រាមសាសនាពីរបានកើតមានឡើង

១ប្រឆាំងនឹងពួកមូស្លីម ១ទៀតប្រឆាំង នឹងពួកជំនុំគ្រីស្ទសាសនា ដែលបង្រៀន គោលលទ្ធិផ្សេងពិសាសនារ៉ូមនៅមជ្ឈិម

សម័យនោះ មានក្រុមហាក់គីណូ ក្រុមវ៉ាលដិនស៊ី និង ក្រុមអាល់បើគិននីស។ ពួកគ្រីស្ទានត្រូវបាន ទទួលការបៀតបៀន ពីក្រុមជំនុំនៅសម័យនោះអស់ពេលជាយូរឆ្នាំ។ ការបៀតបៀនទាំងនោះមាន ការធ្វើ ទារុណកម្មដោយទាញខ្លួនផ្តាច់ពីគ្នា ដាក់គុក ងងឹត និង

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


99

ចងភ្ជាប់ទៅនឹងបង្គោលសសរ ហើយដុត ភ្លើងយ៉ាងសន្ធោសន្ធៅ ទៅលើទុក្ករបុគ្គល ទាំងឡាយ (អ្នកដែលសុខចិត្តស្លាប់ដើម្បី សេចក្ដីជំនឿរបស់គេ)-ទាំងអស់នេះហើយ ដែលជាប្រវត្តិសាស្ត្រ ទាក់ទងទៅនឹងអ្នក ដឹកនាំក្រុមជំនុំ នៅសតវត្សរ៍ដ៏ខ្មៅងងឹតនៅ ពេលដែល ខ្លួនមានអំណាច ដ៏កំពូល ដាច់គេនោះ

ប៉ុន្តែយើងនៅតែរកឃើញមានលក្ខណៈ

សំខាន់ដ៏ល្បីល្បាញមួយទៀត របស់អំណាច នៃស្នែងតូចនេះ។


100

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)

បទទំនាយបានទស្សនទាយថាវានឹង "...គិតបំផ្លាស់ពេលកំណត់និងច្បាប់ផង..." ដានីយ៉ែល ៧:២៥។

តើអំណាចរបស់ប៉ាបនៅមជ្ឈិមសម័យប៉ុនប៉ងផ្លាស់ប្ដូរច្បាប់ពីស្ថានសួគ៌របស់ព្រះមែនឬទេ?


101

មែនហើយ គេបានទាមទារផ្លាស់ប្ដូរ

ថ្ងៃបរិសុទ្ធ ដោយអំណាចនៃប្រពៃណី ពីថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យវិញ។


102

លក្ខណៈចុងក្រោយដែលយើងនឹងសិក្សាយ៉ាងជាក់លាក់អំពីថា តើ នៅពេលណាដែល អំណាចនេះនឹង បានឡើងខ្ពស់បំផុត និងថា តើរយៈពេលប៉ុន្មាន ដែលវានឹងបៀតបៀន ដល់ពួកបរិសុទ្ធរបស់ព្រះ៖


103

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)

"ហើយគេនឹងត្រូវប្រគល់ទៅក្នុង កណ្ដាប់ដៃនៃស្ដេចនោះ នៅ១ខួប ២ខួប ហើយកន្លះខួប" ដានីយ៉ែល ៧:២៥។

ទីនេះយើងឃើញសញ្ញាច្រើនទៀតនៃ ព្រះគម្ពីរ។


104

(វីដេអូ ១០វិនាទី)ពាក្យថាមួយខួប មាន ន័យថា មួយឆ្នាំ ឬ៣៦០ថ្ងៃ ដូច្នេះពីរខួប ត្រូវជាពីរឆ្នាំ ឬ៧២០ថ្ងៃ នៅក្នុងបទ ទំនាយ។

"កន្លះខួប" គឺកន្លះឆ្នាំ ឬ១៨០ថ្ងៃ។

នៅពេលដែលយើងបូកមួយខួប (៣៦០ថ្ងៃ) ពីរខួប(៧២០ថ្ងៃ) និងកន្លះខួប (១៨០ថ្ងៃ) យើងបានចំនួនសរុបមួយគឺ ១២៦០ថ្ងៃ នៃបទទំនាយ ឬ១២៦០ឆ្នាំ។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


105

(ព្រះគម្ពីរ អេសេគាល ៤:៦)

យោងតាមហោរាអេសេគាល មួយថ្ងៃ នៃបទទំនាយស្មើនឹងមួយឆ្នាំ "អញបានកំណត់១ថ្ងៃស្មើនឹង១ឆ្នាំ"

អេសេគាល ៤:៦។

ស្នែងតូចបានត្រូវខ្ពស់ដាច់គេអស់រយៈ ពេល១២៦០ឆ្នាំ!

ប្រវត្តិសាស្ត្របានបញ្ជាក់បន្ថែមការពិត ត្រឹមត្រូវនៃរយៈពេលនេះ។


106

អូស្ត្រូហ្គូថដែលជាកុលសម្ព័ន្ធក្រោយ បង្អស់ដែលប្រឆាំងនឹងពួកជំនុំរ៉ូម៉ាំងត្រូវបានផ្តួលរំលំនៅឆ្នាំ៥៣៨ នៃគ្រិស្តសករាជ។

ដែលធ្វើឱ្យអ្នកដឹកនាំក្រុមជំនុំរ៉ូម៉ាំង

មានសេរីភាពគ្រប់គ្រាន់ដើម្បីពង្រីក អំណាចនយោបាយ និងអំណាចសាសនា របស់ខ្លួន។



107

១២៦០ឆ្នាំយ៉ាងត្រឹមត្រូវក្រោយមក គឺ នៅក្នុងឆ្នាំ ១៧៩៨ អំណាចនយោបាយ របស់ក្រុមជំនុំរ៉ូម៉ាំងត្រូវបានផ្តួលរំលំ ដោយឧត្តម សេនីយ៍របស់ណាប៉ូឡេអុងឈ្មោះ បើរធៀ។


108

នៅពេលដែលយើងបានសិក្សាបទ ទំនាយដានីយ៉ែល៧ និងស្នែងតូចដែលបានចេញពីក្បាលនៃសត្វទីបួន យើងបានរក ឃើញចំណុចសំគាល់ដែលបញ្ជាក់ថា តើ អំណាចនោះជាអ្វី។

សូមក្រឡេកមើលទៅ ចំណុចទាំងនេះ។


109

១. ស្នែងតូចនឹងកើតឡើងនៅអឺរ៉ុបខាង លិច ក្នុងចំណោមនគរទាំងដប់ ដែលបានកើតឡើងពីចក្រភពរ៉ូម ដែលបាក់បែក។

ដានីយ៉ែល ៧:៨។


110

២. នៅពេលឡើងកាន់អំណាចរបស់ខ្លួន ស្នែងតូចបានដកទាំងឫស នគរដើមបី។ នគរទាំងបីនោះគឺ ហេរុលី អូស្ត្រូហ្គូថ និងវេនដាល។ ជាតិសាសន៍ទាំងបីនេះមិនយល់ព្រមទទួលគោលទ្ធិរបស់ក្រុមជំនុំរ៉ូម នៅក្នុងសេចក្តីជំនឿរបស់ពួកគេ ហើយនិងមិនព្រមទទួលយកប៉ាប ធ្វើជាអ្នកដឹកនាំ ក្រុមជំនុំរបស់គេឡើយ។ សូមអាន (ដានីយ៉ែល ៧:៨)


111

៣. បទទំនាយនិយាយថា ស្នែងតូចនេះ នឹងលេចចេញមកពីក្នុងចំណោមស្នែងដទៃ ទៀតក្រោយពេល ដែលស្នែងទាំងនោះ បានកើតឡើងរួចមកហើយសូមមើល (ដានីយ៉ែល៧:២០)។

ត្រង់នេះមានន័យថា នគរនេះ នឹងត្រូវបានកើតឡើងនៅក្រោយ ឆ្នាំ៤៧៦ នៃគ្រិស្តសករាជ។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


112

៤. អំណាចនេះនឹងខុសប្លែកពីនគរដទៃ ទៀត។ វាជានគរដែលមានទាំងអំណាច នយោបាយ និងអំណាចសាសនា។ ដានីយ៉ែល ៧:២៤។


113

(ព្រះគម្ពីរ ដានីយ៉ែល ៧:២១,២៥)
៥. ស្នែងតូចនេះនឹងបៀតបៀន ឬ "ខ្ញុំ បានគន់មើលឃើញស្នែងនោះច្បាំងនឹងពួក បរិសុទ្ធ ហើយក៏បានឈ្នះផង"
ដានីយ៉ែល ៧:២១,២៥។


114

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)
៦. អំណាចនេះនឹង "គិតបំផ្លាស់ពេល
កំណត់ និងច្បាប់ផង" ម្យ៉ាងវិញទៀត ពួកជំនុំនេះបានគិតថា គេអាចនឹងផ្លាស់ប្តូរ
ពេលកំណត់របស់ព្រះនិងក្រិត្យវិន័យ
របស់ទ្រង់បានដោយខ្លួនឯង។
ដានីយ៉ែល ៧:២៥



115

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)
៧. បទទំនាយចង្អុលបង្ហាញថា អំណាច នេះនឹងគ្រប់គ្រងតែម្នាក់ឯងក្នុងកំឡុងពេល១២៦០ឆ្នាំ។ ដូចដែលព្រះគម្ពីរបានចែងថា "ហើយគេនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចនោះ នៅ១ខួប ២ខួប ហើយកន្លះ ខួប" ដានីយ៉ែល ៧:២៥។


116

លោកអ្នកឃើញដោយសារបទទំនាយ នេះថា មានតែអំណាចមួយប៉ុណ្ណោះនៅលើ ពិភពលោកនេះ ដែលបានងើបឡើងនៅចំ ពេលនោះ និងចំកន្លែងនោះ ដើម្បីនឹង សម្រេចនូវចំណុចទាំងឡាយនេះ។ អំណាច នោះគឺសាសនារ៉ូម៉ាំង។


117

ឥឡូវនេះសូមក្រឡេកមើល ទៅកាន់បទ ទំនាយដ៏ខ្ពស់បំផុតរបស់ដានីយ៉ែល ដែល បានបញ្ចប់ដោយរីករាយសម្រាប់រាស្ត្រ របស់ព្រះ។


118

នៅក្នុងការជាក់ស្តែង នៅពេលយប់ នោះ ដានីយ៉ែលសំឡឹងមើលទៅអំណាច ដែលនៅលើផែនដី កំពុងប្រកួតប្រជែង ដើម្បីគ្រប់គ្រង និងគ្របសង្កត់អំណាច នយោបាយ និងអំណាចសាសនាដាច់តែម្នាក់ឯង

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ





119

រំពេចនោះ អារម្មណ៍របស់គាត់ប្តូរកន្លែង ពីផែនដីទៅស្ថានសួគ៌។



120

(ព្រះគម្ពីរ ដានីយ៉ែល ៧:៩,១០)

"ខ្ញុំក៏គន់មើលទាល់តែមានបល្ល័ង្កមក

តាំង ហើយព្រះដែលមានព្រះជន្មពីចាស់ បុរាណក៏គង់នៅលើ



121

ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយ ព្រះកេស នៅព្រះសិរទ្រង់ ក៏សដូចរោម ចៀមយ៉ាងស្អាត



122

ឯបល្ល័ង្កទ្រង់នោះសុទ្ធតែជាអណ្តាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ



123

មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក



124

មានទាំងពាន់ ទាំងពាន់ ដែលគោរព ដល់ទ្រង់



125

ហើយទាំងម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់

នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯ បញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ" ដានីយ៉ែល ៧:៩,១០



126

ដានីយ៉ែលបានឃើញព្រះវរបិតាដែល ហៅថា ព្រះពីចាស់បុរាណ បានយាងមក

ហើយគង់លើបល្ល័ង្ក។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


127

(ព្រះគម្ពីរ ដានីយ៉ែល ៧:២២)

សូមពិនិត្យមើល ការដែលដានីយ៉ែល ពណ៌នាអំពីព្រឹត្តិការណ៍នេះ "ដរាបដល់ព្រះដ៏មានព្រះជន្មពីបុរាណបានយាងមក..."ដានីយ៉ែល ៧:២២។

ឥឡូវនេះ តុលាការបានរៀបចំរួចរាល់ ហើយដើម្បីចាប់ផ្តើមជំនុំជំរះ។


128

(ព្រះគម្ពីរ ដានីយ៉ែល ៧:១០)

"...នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ" ដានីយ៉ែល ៧:១០។

ដានីយ៉ែលត្រូវបានបង្ហាញអំពីការជំនុំជំរះ
នៅស្ថានសួគ៌ ដោយការជំនុំជំរះរបស់ព្រះ ទៅលើអំណាចស្នែងតូច ដែលបានធ្វើសង្គ្រាមប្រឆាំងនឹងពួកបរិសុទ្ធរបស់ទ្រង់។
ដានីយ៉ែលក៏បានឃើញលទ្ធផលនៃការជំនុំជំរះនេះដែរ:


129

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៦)

"ប៉ុន្តែការវិនិច្ឆ័យ នឹងបានរៀបចំ ហើយ គេនឹងដកអំណាចវាចេញ


130

ឱ្យត្រូវបំផ្លាញ ហើយសាបសូន្យទៅដរាប ដល់ចុងបំផុត" ដានីយ៉ែល ៧:២៦។


131

រួចដានីយ៉ែលបានឃើញការពិសេស យ៉ាងល្អប្រសើរមួយទៀត កើតឡើង បន្ទាប់ពីព្រះវរបិតាបានយាងគង់ និង ជំនុំជំរះ ដែលរៀបចំនឹងចាប់ផ្តើមនោះ


132

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៣)

"ខ្ញុំក៏ឃើញក្នុងការជាក់ស្តែងពេលយប់ នោះ មាន១អង្គដូចជាមនុស្សជាតិ ទ្រង់យាងមកក្នុងពពកឰដ៏អាកាស


133

ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីបុរាណ នោះ ហើយមានគេនាំចូលទៅចំពោះព្រះ អង្គ" ដានីយ៉ែល ៧:១៣។

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


134

តើអ្នកណាដែលជាមនុស្សដ៏ប្រសើរដាច់ គេដែលហៅថា "កូនមនុស្ស" ដែលលេច មកនៅចំពោះមុខ ការជំនុំជំរះដ៏អស់កល្ប នេះ?


135

ព្រះយេស៊ូវបានឆ្លើយទៅនឹងសំនួរនេះ ដោយផ្ទាល់ព្រះអង្គ ជាងសែសិបដងនៅ ក្នុងព្រះគម្ពីរសញ្ញាថ្មី។

ទៅកាន់សិស្សដ៏ស្រឡាំងកាំងរបស់ទ្រង់។


136

(ព្រះគម្ពីរ ម៉ាថាយ ១៧:២២,២៣)

ទ្រង់បានមានព្រះបន្ទូលថា "កូនមនុស្ស នឹងត្រូវបញ្ជូនទៅក្នុងកណ្តាប់ដៃនៃមនុស្ស:


137

គេនឹងសម្លាប់លោក ហើយ៣ថ្ងៃក្រោយ មក លោកនឹងរស់ឡើងវិញ"

ម៉ាថាយ ១៧:២២,២៣។

ព្រះយេស៊ូវបានសួរទៅយូដាស ដែល ជាអ្នកក្បត់ទ្រង់ថា


138

(ព្រះគម្ពីរ លូកា ២២:៤៨)

"...យូដាសអើយ អ្នកបញ្ជូនកូនមនុស្ស ដោយថើប១ខ្សឺតឬអី?" លូកា ២២:៤៨។

ប៉ុន្តែប្រយោគដ៏សំខាន់លើសពីនេះទៅ ទៀត ដែលព្រះយេស៊ូវបានមានបន្ទូលសំ ដៅទៅកាន់ សម្តេចសង្ឃដ៏ខ្ពស់ បំផុត ដែលគង់នៅក្នុងការជំនុំជំរះ នាការវិនិច្ឆ័យ របស់ព្រះយេស៊ូវនោះគឺ:


139

(ព្រះគម្ពីរ ម៉ាថាយ ២៦:៦៤)

"អំណើះទៅមុខ អ្នករាល់គ្នានឹងឃើញ កូនមនុស្សអង្គុយនៅខាងស្តាំនៃព្រះដ៏មានព្រះ ចេស្តា


140

ហើយទាំងមកលើពពកនៅលើមេឃផង"

ម៉ាថាយ ២៦:៦៤។

ទីនោះ ព្រះយេស៊ូវ បានបញ្ជាក់ដោយ គ្មានការភាន់ច្រឡំ អំពីអង្គទ្រង់ថា ជាកូន មនុស្ស ដែលដានីយ៉ែលបានឃើញ នៅ ក្នុងការជាក់ស្តែងរបស់គាត់-ជាអ្នកដែល "យាងក្នុងពពកនាអាកាស"

១៧. វិធីស្គាល់ភាពក្លែងក្លាយ

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


141

ព្រះគ្រីស្ទយាងមកកាន់ការជំនុំជំរះ ដើម្បីតំណាងឱ្យអ្នកមានបាបទាំងអស់ ដែលបានទទួលទ្រង់ជាមេធាវី ជាអ្នក សម្រុះសម្រួល ជាអាវ៉្វការ របស់យើងនៅ ក្នុងតុលាការនោះ ទ្រង់មិនដែលចាញ់ក្តីណា មួយឡើយ!

ព្រះគម្ពីរនិយាយថា បញ្ជីត្រូវបានបើក ឡើង។


142

(ព្រះគម្ពីរ ដានីយ៉ែល ៧:១០)

"ការវិនិច្ឆ័យ បានរៀបចំជាស្រេច ឯ បញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ"

ដានីយ៉ែល ៧:១០ខាងចុង។


143

នៅក្នុងបញ្ជីនោះនឹងមានរាល់សកម្មភាព ក្នុងជីវិតយើងទាំងអស់ ទោះជាអាក្រក់ឬល្អ ក្តី។

សៀវភៅនោះក៏បានកត់ត្រាពី ឱកាស ដែលព្រះបានប្រទានដល់យើង និងអំពី របៀបដែលយើងឆ្លើយតប ទៅនឹងឱកាស ទាំងនោះដែរ។


144

ប្រសិនបើយើងបានទទួលព្រះគ្រីស្ទជា ព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ នោះ នៅពេលដែលរឿងក្តី របស់យើងបានមក ចំពោះព្រះ ព្រះយាងមកខាងមុខ ហើយ អះអាងថា ទ្រង់ជាព្រះអង្គសង្គ្រោះរបស់ យើង ហើយថា ការសុគតរបស់ទ្រង់ បានទទួលខុសត្រូវចំពោះអំពើបាបទាំងអស់ ដែលយើងបានប្រព្រឹត្តហើយ!


145

នៅថ្ងៃនេះ ក្នុងបញ្ជីនៃស្ថានសួគ៌ ជីវិត ដែលគ្មានបាបរបស់ទ្រង់ បានមកជំនួស ជីវិត ដែលមានបាបរបស់យើងទាំងអស់គ្នា ហើយរឿងតែមួយដែលព្រះវរបិតាអាចឃើញ នៅពេលដែលទ្រង់បានយកកំណត់ត្រារបស់ យើងទតមើលនោះ គឺជីវិតគ្មានបាបរបស់ ព្រះគ្រីស្ទដែល ត្រូវបានកត់ចូលទៅក្នុង បញ្ជីរបស់យើងរាល់គ្នា។


146

យើងនឹងមានជីវិតអស់កល្ប មិនមែន ដោយសារអ្វីដែលយើងបានធ្វើនោះទេ ប៉ុន្តែដោយសារព្រះគ្រីស្ទ បានធ្វើជំនួស យើងនៅលើឈើឆ្កាង។

ប្រហែលជាដានីយ៉ែលចាប់អារម្មណ៍ យ៉ាងខ្លាំងចំពោះស្នែងតូច និងគំនិតរបស់ គាត់អំពីពេលខាងមុខ ហើយបានផ្តល់នូវ ប្រវត្តិសាស្ត្រយ៉ាងពេញលេញអំពីអាជីពរបស់វា ដែលនឹងកើតឡើងជាយថាហេតុ បន្ទាប់ពីការជំនុំជំរះដំបូងមក


147

នៅពេលដែលការងារនៅលើផែនដីនេះ ត្រូវបានពិនិត្យពិច្ច័យ និងសេចក្តីសម្រេច បានធ្វើឡើងថា តើអ្នកណាអាចនឹងឡើង ទៅកាន់នគរដ៏អស់កល្បរបស់ព្រះបាន។ នគរនោះ នឹងត្រូវបានប្រទានឱ្យព្រះគ្រីស្ទ និងអំណាចគ្រប់គ្រងរបស់ទ្រង់ផង:

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


148

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៤)

"នោះបានប្រទានឱ្យទ្រង់មានអំណាច គ្រប់ គ្រង និងសិរីល្អ ព្រមទាំងឱ្យមានរាជ្យ


149

ផង ដើម្បីឱ្យបណ្តាជនទាំងឡាយ សាសន៍ដទៃ និងមនុស្សគ្រប់ភាសា បានគោរពដល់ទ្រង់


150

ឯអំណាចគ្រប់គ្រងរបស់ទ្រង់នោះ ក៏ ស្ថិតស្ថេរនៅអស់កល្ប ឥតដែលកន្លងបាត់ ឡើយ


151

ហើយរាជ្យរបស់ទ្រង់ក៏នឹងបំផ្លាញមិនបាន ផង"

ដានីយ៉ែល ៧:១៤។

ដានីយ៉ែលបន្តទៅទៀតជាមួយនឹង ដំណឹងល្អអំពីនគរនេះថា:


152

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៧)

"...នោះរាជ្យ និងអំណាចគ្រប់គ្រង របស់ទ្រង់... នឹងបានប្រគល់ដល់បណ្តា ជន ជាពួកបរិសុទ្ធនៃព្រះដ៏ខ្ពស់បំផុត"

ដានីយ៉ែល ៧:២៧។

រាស្ត្ររបស់ព្រះ អ្នកបរិសុទ្ធរបស់ទ្រង់ នឹងចូលរួមទទួលមរតកជាមួយព្រះគ្រីស្ទ ក្នុងការទទួលទ្រព្យសម្បត្តិរបស់ នគរដ៏នៅ អស់កល្បនោះ:


153

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៨)

"តែពួកបរិសុទ្ធរបស់ព្រះដ៏ខ្ពស់បំផុត គេនឹងទទួលរាជ្យ ហើយនិងបានរាជ្យនោះ ជារបស់ផងខ្លួននៅជានិច្ច គឺអស់កល្ប តទៅ" ដានីយ៉ែល ៧:១៨


154

ចំណែកនៃបទទំនាយត្រង់នេះ ស្របទៅ នឹងថ្ម នៅក្នុងយល់សប្តិ របស់ស្តេច នេប៊ូក្នេសា ថាបានកាត់ផ្តាច់ ដោយគ្មាន ដៃមនុស្សធ្វើ ហើយបានកំទេចរូបនោះនៅ ត្រង់ជើង ហើយបានក្លាយទៅជា

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ



155

(ព្រះគម្ពីរ ដានីយ៉ែល ២:៣៥)

"...ឯថ្ម...ក៏ត្រឡប់ទៅជាភ្នំយ៉ាងធំ នៅពេញផែនដីទាំងមូល"

ដានីយ៉ែល ២:៣៥។

នៅក្នុងបទទំនាយស្របគ្នាទាំងពីរនេះ_សុបិនរបស់ស្តេចនេប៊ូក្នេសា អំពីរូប លោហធាតុដ៏ធំ និង


156

យល់សប្តិអំពីសត្វរបស់ដានីយ៉ែល_ព្រះ បានសង្ខេបប្រវត្តិសាស្ត្រផែនដីនេះតាំងពី ពេលបាប៊ីឡូនបុរាណ ដល់ថ្ងៃដ៏ធំ នៅ ពេលដែលព្រះយេស៊ូវយាងមកនៅលើពពក នៃសិរីល្អ ដើម្បីនឹងតាំងនគរដ៏អស់កល្ប នៃ សេចក្តីស្រឡាញ់ និងសុចរិត របស់ទ្រង់ ឡើង។


157

សព្វថ្ងៃនេះយើងរស់នៅ ចុងនៃសម័យ ជើងដែកនិងដីឥដ្ឋហើយ។

ពេលវេលាអស់ហើយ សម្រាប់ផែនដី និងអ្នកដែលរស់នៅលើនោះ!

នេះហើយគឺជាដំណឹងដែលព្រះខំប្រឹង ប្រែងចែកចាយជាមួយយើងម្នាក់ៗ ដោយ បទទំនាយដ៏ធំរបស់ទ្រង់នេះ។


158

នេះគឺជារបៀបដ៏គួរឱ្យកត់សំគាល់ជាទី បំផុត ក្នុងការទស្សនទាយពីប្រវត្តិសាស្ត្រ ពិភពលោករាប់សតវត្សរ៍ នៅក្នុងជំពូកដ៏ខ្លី ទាំងពីរនៃព្រះគម្ពីរនេះ!

ហើយសូមអញ្ជើញមក និងគិតអំពីរឿង នេះ តើយល់សប្តិដែលព្រះបានប្រទានឱ្យ ដានីយ៉ែលនៅយប់នោះនាទី ក្រុងបាប៊ីឡូន ជាយូរយារមកហើយនោះ មិនបង្ហាញអំពី សេចក្តីស្រឡាញ់និងការយកព្រះទ័យទុកដាក់ របស់ ព្រះដ៏ធំធេងបំផុតចំពោះរាស្ត្រ ទ្រង់ នៅលើផែនដីនេះទេឬអី?


159

លោកអ្នកឃើញទេ ទីក្រុងយេរូសាឡិម បានស្ថិតនៅក្នុងគ្រោះមហន្តរាយ។

រាស្ត្ររបស់ព្រះ អ៊ីស្រាអែល បានក្លាយ ជាឈ្លើយនៅបាប៊ីឡូន។

ស្ថានការណ៍មើលទៅអាក្រក់អាក្រីមែន ទែន។

ប៉ុន្តែព្រះមានវិធីដ៏អស្ចារ្យ ទ្រង់បានមាន ព្រះបន្ទូលទៅកាន់ដានីយ៉ែលថា "ខ្ញុំនៅតែ គ្រប់គ្រងដដែល"

# ១៧. វិធីស្គាល់ភាពក្លែងក្លាយ


160

ស្តេចអាចតាំងឡើង ហើយស្តេចអាច ធ្លាក់ចុះ។

ចក្រភពទាំងឡាយអាចកើតឡើង ហើយក៏អាចរលំចុះដែរ ប៉ុន្តែខ្ញុំមិនបានភ្លេច រាស្ត្ររបស់ខ្ញុំនៅលើផែនដី និងផែនការ របស់ខ្ញុំសម្រាប់ពួកគេឡើយ។

ថ្ងៃណាមួយ អ្វីៗទាំងអស់នឹងត្រឡប់ជា ល្អឡើងវិញ។

មិត្តទាំងឡាយ នគរនិងស្តេចទាំងឡាយ បានកើតឡើងហើយក៏បាត់ទៅវិញ។

បទទំនាយទាំងពីរ នៃរូបសំណាក និង សត្វតិរច្ឆាននេះ បានជិតដល់ការសំរេចសព្វ គ្រប់ហើយ។

ព្រះយេស៊ូវនឹងយាងមកវិញឆាប់ៗនេះ ដើម្បីនឹងចេញសាលក្រមនៃការជំនុំជំរះ និងរៀបចំស្ថាបនាឡើងវិញ នូវអំណាច ដែលបានបាត់បង់ ជាយូរយារមកហើយ តាំងពីសម័យអ័ដាមនិងអេវ៉ាមកនោះ


161

ព្រះអង្គចង់ឱ្យរាស្ត្ររបស់ទ្រង់នៅលើ ភពផែនដីនេះ ជាសមាជិកនៃនគរនោះ ដើម្បីរៀបចំខ្លួនរួចជាស្រេច សម្រាប់ពេល វេលាដ៏មានសិរីល្អនោះ នៅពេលដែលព្រះ អង្គសង្គ្រោះរបស់យើងយាងមកវិញ!

នៅក្នុងថ្ងៃនៃសិរីល្អនោះ យើងនឹង ឃើញទ្រង់-ជាព្រះអង្គសង្គ្រោះ និងជាព្រះ អម្ចាស់!

# ១៨. សញ្ញាដ៏នៅអស់កល្ប



1

របៀបជៀសវាងពីការទទួល
សញ្ញារបស់សត្វនោះ


2

មានថ្ងៃដ៏ខ្ពង់ខ្ពស់ ថ្ងៃដ៏ឧត្តុង្គឧត្តមមួយ ជាថ្ងៃដែលតម្រូវឱ្យមានពិធីបុណ្យដ៏ពិសេស មួយដែលមានក្បួន ព្យុហយាត្រា និងការ ប្រគំក្រុមតន្ត្រីព្រះរាជវាំងផង។
ស្តេចនេប៊ូក្នេសាមានការរំភើបយ៉ាងខ្លាំង។


3

ទ្រង់បានអញ្ជើញអ្នកមុខអ្នកការទាំង ឡាយ មកពីទូទាំងចក្រភពបាប៊ីឡូនដ៏ធំ ធេងឱ្យមកចូលរួម។
ជាថ្ងៃដែលទ្រង់បានទតមើលទៅកាន់ការ រង់ចាំយ៉ាងរំភើបដ៏មុះមុតរបស់ទ្រង់ និងជាថ្ងៃមួយដែលទ្រង់ មិនអាចបំភ្លេចបានក្នុង មួយជីវិតរបស់ព្រះអង្គ។


4

មានពេលមួយកាលកន្លងមក ព្រះអង្គបានមានសុបិននិមិត្តដ៏ចម្លែកមួយ។
ទ្រង់បានទតឃើញរូបលោហធាតុដ៏ធំមួយ។


5

ទ្រង់មិនអាចនឹកចាំពីយល់សប្តិនោះថា ជាយ៉ាងណានោះទេ ដូច្នេះដានីយ៉ែលត្រូវតែបើកសំដែងរឿងនោះថ្វាយទ្រង់ មិនមែន គ្រាន់តែអត្ថន័យ នៃសុបិននោះប៉ុណ្ណោះទេ តែគឺជាសុបិននោះទាំងស្រុងតែម្តង។
ស្តេចនេប៊ូក្នេសាមិនអាចគិតឃើញអ្វី ទាំងអស់!



6

ទោះបីជាទ្រង់ជាក្បាលមាស!
នគររបស់ទ្រង់បានឈរនៅដោយគ្មាន គូប្រជែងឡើយ នៅលើលោកនេះក៏ដោយ។ ហើយឥឡូវនេះមនុស្សគ្រប់គ្នា នឹងឃើញ ការបកស្រាយបញ្ហាក់ដ៏ផ្អើមមួយ អំពីថា តើបាប៊ីឡូនដ៏ជាធំនោះនឹងទៅជាជាយ៉ាងណា? តើទ្រង់ពិតជាធំឧត្តមយ៉ាងណាន់!


7

ទ្រង់បែរជាមានការរឹងទទឹង ហើយបាន បញ្ជាឱ្យអ្នកបំរើរបស់ទ្រង់ធ្វើជារូបសំណាក មួយអំពីមាស។

# ១៨. សញ្ញាដ៏នៅអស់កល្ប


8

រូបសំណាកនេះធ្វើពីមាសទាំងអស់ មិន មែនគ្រាន់តែក្បាលប៉ុណ្ណោះទេ ប៉ុន្តែរហូតដល់ខ្លួនប្រាណទាំងមូល។

គ្រប់គ្នាមានការរំភើបយ៉ាងខ្លាំង ចំពោះ ភាពដ៏ភ្លឺចាំងយ៉ាងអស្ចារ្យនៃរូបសំណាកនោះ។ វាគឺជារបៀបនៃការបញ្ជាក់ប្រាប់ពិភព លោកថា នគររបស់ទ្រង់នឹងស្ថិតស្ថេររៀង រហូតតទៅ។


9

នៅថ្ងៃនោះអ្នកមុខអ្នកការសំខាន់ៗ រាប់ ពាន់នាក់ នៅក្នុងនគរបានមកជួបជុំគ្នា ដើម្បីធ្វើជាសាក្សីចំពោះ ការប្រកាស នៃ រូបមាសរបស់ស្តេចនេប៊ូក្នេសានេះ។


10

រំពេចនោះ ភាពស្ងៀមស្ងាត់បានធ្លាក់ មកគ្របសង្កត់លើហ្វូងមនុស្សដ៏ច្រើនកុះករ។

ត្រែក៏បានបន្លឺឡើង ហើយអ្នកនាំពាក្យ របស់ស្តេចបានប្រកាសឡើងយ៉ាងខ្លាំងៗថា


11

(ព្រះគម្ពីរ ដានីយ៉ែល ៣:៤-៦)

ដានីយ៉ែល ៣:៤-៦

"...ម្នាលជនទាំងឡាយ ព្រមទាំង សាសន៍ដទៃ និងមនុស្សគ្រប់ភាសាអើយ មានសេចក្តីបង្គាប់ដល់អ្នករាល់គ្នាថា


12

វេលាណាដែលអ្នករាល់គ្នា ឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងប៉ី


13

ហើយតន្ត្រីគ្រប់យ៉ាង នោះត្រូវ ក្រាបថ្វាយ បង្គំដល់រូបមាស


14

ដែលព្រះករុណាទ្រង់បានតាំងឡើងទៅ

# ១៨. សញ្ញាដ៏នៅអស់កល្ប



15

បើអ្នកណាមិនក្រាបថ្វាយបង្គំទេ



16

នោះនឹងត្រូវបោះទៅកណ្ដាលគុកភ្លើង" ដានីយ៉ែល ៣:៤-៦


17

ភ្លេងក៏បានបន្លឺឡើង។

មនុស្សទាំងអស់ក្រាបចុះគោរពរូបសំ ណាកនោះ។

មែនហើយ មនុស្សសឹងតែគ្រប់គ្នា។


18

នៅក្នុងចំណោមមនុស្សដែលកំពុងប្រជុំដោយលុតជង្គង់ជាច្រើន មានសាដ្រាក់ មែសាក់ និង អ័បេឌ-

នេកោនៅឈរដដែល-ជន ជាតិហេព្រើរទាំងបីនាក់នេះ មិនបានបោះ បង់ការមិនគោរពព្រះ

ដោយថ្វាយបង្គំរូប សំណាកឡើយ។

មិនយូរប៉ុន្មានដំណឹងនោះក៏បានឮទៅ ដល់ស្ដេច។



19

(វីដេអូ ៣វិនាទី) ស្ដេចខ្ញាល់ខ្លាំងណាស់

ដែលមានមនុស្សហ៊ានប្រឆាំងនឹងបញ្ជាដោយ

ផ្ទាល់របស់ព្រះអង្គនេះ ស្ដេចនេប៊ូក្នេសា បានបញ្ជាទាហានឱ្យនាំអ្នកប្រឆាំងទាំងនោះមកគាល់ទ្រង់។



20

(វីដេអូ ៣វិនាទី) នៅពេលស្ដេចទតមើល ទៅកាន់ជនជាតិហេព្រើរទាំងបីនាក់ ទ្រង់

បានស្គាល់គេភ្លាម។

ពួកគេគឺជាបុរសវ័យ ក្មេងមិនធម្មតា ដែលមានប្រាជ្ញាឆ្លាតវាងវៃ និងមានទេព កោសល្យជាច្រើន។



21

(វីដេអូ ២វិនាទី) ទ្រង់បានតែងតាំងពួកគេឱ្យ ទទួលខុសត្រូវជាច្រើនកន្លងមក ដែលគេ

បានបំពេញយ៉ាងស្មោះត្រង់ និងមាន

ប្រសិទ្ធភាពជាទីបំផុត។

ដោយមានព្រះទ័យអាណិតអាសូរដល់ ពួកគេទាំងបីនាក់ ទ្រង់បានសម្រេចព្រះ ទ័យ

ផ្ដល់ឱកាសឱ្យគេម្ដងទៀត។

ស្ដេចបានមានព្រះបន្ទូល ដោយហៅ ពួកគេចំៗឈ្មោះថា

# ១៨. សញ្ញាដ៏នៅអស់កល្ប


22

(ព្រះគម្ពីរ ដានីយ៉ែល ៣:១៥)

"ឥឡូវនេះ បើឯងរាល់គ្នាប្រុងប្រៀប ក្នុងវេលាដែលឯងឮសូរ...និងតន្ត្រី គ្រប់យ៉ាង"


23

បានក្រាបថ្វាយបង្គំដល់រូបមាសដែល យើងបានធ្វើនេះ នោះបានហើយ តែបើ មិនថ្វាយបង្គំទេ


24

នោះនឹងត្រូវបោះឯងទៅក្នុងគុកភ្លើង" ដានីយ៉ែល ៣:១៥។

នៅពេលដែលស្តេចបានប្រកាសហើយ ទ្រង់ត្រូវតែអនុវត្តនូវសេចក្តីប្រកាសនោះ បើពុំនោះទេ នឹងត្រូវអាប់ ព្រះភ័ក្ត្រនៅ ចំពោះមុខប្រជានុរាស្ត្រទាំងអស់។


25

សាដ្រាក់ មែសាក់ និងអ័បេឌនេកោ អាចឃើញអណ្តាតភ្លើងពីគុកភ្លើង។

មិនបាច់សង្ស័យឡើយ ចំពោះបំណងព្រះ ហឫទ័យរបស់ស្តេច។


26

តើពួកគេធ្វើយ៉ាងណា? តើអ្នកនឹងត្រូវ ធ្វើយ៉ាងណា?

តើគេនឹងមិនស្តាប់បង្គាប់តាមបញ្ញត្តិ របស់ព្រះទេឬ?

ឬវាមិនជាបញ្ហាអីទេ ដែលគ្រាន់តែធ្វើ ឱ្យឃើញថា សមដូចគេឯងដែរ ដោយ គ្រាន់តែក្រាបចំពោះរូបបដិមាករ នៅក្នុង កាលៈទេសៈនោះ។

ហើយម្យ៉ាងទៀត ជីវិតរបស់ពួកគេស្ថិត នៅក្នុងសភាពគ្រោះថ្នាក់ហើយ

តើវាមិនជាការសំខាន់ទេឬអ្វី ដែល បង្ហាញការគោរពចំពោះស្តេចនោះ?


27

ជាការជាក់ស្តែង គំនិតនេះ មិនដែល កើតមាននៅក្នុងថ្នក់គំនិតរបស់ពួកគេទាល់តែ សោះ ព្រោះពួកគេត្រូវបានបង្រៀនអំពី បញ្ញត្តិរបស់ព្រះនេះ តាំងពីវ័យកុមារមក ម្ល៉េះ ហើយបញ្ញត្តិមួយក្នុងចំណោមបញ្ញត្តិ ទាំងនោះនិយាយថា


28

(ព្រះគម្ពីរ និក្ខមនំ ២០:៤,៥)

"កុំឱ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឱ្យសោះ ក៏កុំឱ្យធ្វើរូបណាឱ្យដូចជាអ្វី...

# ១៨- សញ្ញាដ៏នៅអស់កល្ប



29

កុំឱ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមនោះឡើយ...” និក្ខមនំ ២០:៤,៥

ដោយស្មៀមស្ងាត់និងគ្មានការស្ទាក់ស្ទើរ ពួកគេបានឆ្លើយថា:



30

(ព្រះគម្ពីរ ដានីយ៉ែល ៣:១៦-១៨)

“...បពិត្រព្រះរាជា នេប៊ូក្នេសា យើងខ្ញុំ មិនចាំបាច់ទូលឆ្លើយដល់ទ្រង់ពីដំណើរនេះទេ



31

បើជាយ៉ាងនោះមែន នោះព្រះនៃយើង ខ្ញុំដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាច នឹងជួយឱ្យយើងខ្ញុំរួចពីគុកភ្លើង ដែលឆេះ យ៉ាងសន្ធោសន្ធៅបានហើយ



32

បពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយឱ្យ យើងខ្ញុំរួចពីព្រះហស្តទ្រង់



33

តែបើមិនជួយទេ នោះសូមឱ្យទ្រង់ព្រះ ករុណាជ្រាបថា យើងខ្ញុំមិនព្រមគោរពតាម ព្រះរបស់ទ្រង់ឡើយ



34

ក៏មិនព្រមថ្វាយបង្គំដល់រូបមាស ដែលទ្រង់ បានតាំងឡើងនោះដែរ”

ដានីយ៉ែល ៣:១៦-១៨។

រឿងបន្តទៅទៀតមានការរំភើបខ្លាំង ណាស់។

ស្តេចទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយ បានបញ្ជាឱ្យគេដុតគុកភ្លើងឱ្យក្តៅជាង ធម្មតាប្រាំពីរដង។



35

រួចស្តេចទ្រង់បានបញ្ជាថា ត្រូវចាប់ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ចង ហើយបោះចូលទៅក្នុងគុកភ្លើង។

ភ្លើងនោះក្តៅខ្លាំងណាស់ ដែលធ្វើឱ្យ ទាហានដែលចាប់បោះកំឡោះទាំងបីនាក់ទៅ ក្នុងគុកភ្លើងនោះ បានដួលស្លាប់ទាំងអស់។

# ១៨. សញ្ញាដ៏នៅអស់កល្ប


36

រំពេចនោះ ស្តេចបានយាងរត់ដោយព្រះ បាទផ្ទាល់ សំដៅទៅកាន់គុកភ្លើងជិតនោះ មានបន្ទូលស្រែកទៅកាន់មន្ត្រីរបស់ទ្រង់ថា ទ្រង់បានឃើញមនុស្សបួននាក់ដើរជុំវិញក្នុង ភ្លើង ហើយថាមានម្នាក់ មានសណ្ឋានដូច ជាកូនព្រះ!


37

ព្រះអម្ចាស់បានយាងចូលទៅក្នុងគុក ភ្លើង។ ទ្រង់បាននៅជាមួយកំឡោះហេព្រើរទាំងបីក្នុងគុកភ្លើង។ ទ្រង់គឺជាអ្នករំដោះពួក គេដ៏មានព្រះចេស្តា។


38

ស្តេចនេប៊ូក្នេសាបានបញ្ជាឱ្យជនជាតិ ហេព្រើរទាំងបីនាក់នេះចេញពីគុកភ្លើង ហើយនៅចំពោះការអស្ចារ្យដ៏ធំនេះ មនុស្ស ទាំងបីនាក់បានចេញមកដោយគ្មានសក់មួយ សរសៃ ឬក្បាលមានស្នាមអណ្តាតភ្លើង ឡើយ ហើយសូម្បីតែក្លិនផ្សែងដែលជាប់ នឹងសំលៀកបំពាក់ក៏គ្មានដែរ!

រូបមាសដ៏ធំនោះត្រូវបានគេបំភ្លេចចោល។
ទំព័រទី១នៃរឿងដ៏ធំបំផុតនៅថ្ងៃនោះ ហើយ និងសម្រាប់ពេលវេលាជាច្រើនឆ្នាំទៅមុខ ទៀត គឺជាការអនុវត្តន៍ដ៏ម៉ឺងមាត់ របស់ អ្នកកំឡោះទាំងបីនាក់នោះ។


39

ព្រះរបស់គាត់បានជួយសង្គ្រោះគាត់ ចេញពីគុកភ្លើង!

នេះគឺជាទីបន្ទាល់ដ៏អស្ចារ្យមួយអំពី សេចក្តីស្រឡាញ់ និងការថែរក្សារបស់ព្រះ ចំពោះអ្នកដែលស្មោះត្រង់ដល់ទ្រង់!

វាអាចកើតមានទៅបាន នៅថ្ងៃណាមួយ
នាពេលអនាគត យើងក៏នឹងមានគេបង្ខំ យើងអំពីរបៀបថ្វាយបង្គំនេះដែរ។

វាអាចកើតឡើងបានដូចជាជនជាតិ ហេព្រើរទាំងបីនាក់នេះ ដែលយើងនឹងអាច ប្រឈមមុខទល់នឹង សេចក្តីស្លាប់ដោយ ត្រង់ៗ ចំពោះបញ្ហានៃការថ្វាយបង្គំនេះ។


40

"មែនហើយ" អ្នកនិយាយថា "ខ្ញុំសប្បាយ ដោយគ្មានអ្នកណាបង្ខិតបង្ខំខ្ញុំ អំពីរបៀប ថ្វាយបង្គំនោះទេ!"

រឿងនោះវាអាក្រក់ខ្លាំងណាស់ ដែលប្រ ឈមមុខនឹងសេចក្តីស្លាប់ ប្រសិនបើអ្នកមិន ព្រមថ្វាយបង្គំតាម របៀបដែលអ្នកដទៃគេ បានបញ្ជាដល់អ្នកនោះ។


41

តើលោកអ្នកដឹងទេ យោងតាមបទ ទំនាយនៃព្រះគម្ពីរ វិបត្តិដ៏ធំបំផុតនៃប្រវត្តិ សាស្ត្រ នៅចំពីមុខយើង ហើយថា មជ្ឈមណ្ឌលនៃវិបត្តិនោះ គឺការថ្វាយបង្គំ នោះឯង?

# ១៨. សញ្ញាដ៏នៅអស់កល្ប



42

ដូចជាជនជាតិហេព្រើរទាំងបីនាក់នោះ ដែរ យើងរាល់គ្នាដែលកំពុងរស់នៅសម័យ ចុងក្រោយនេះ នឹងត្រូវជួបប្រទះនូវជម្រើស ដូចគ្នានេះដែរ

ជាជម្រើសដែលនឹងបោះត្រាលើវាសនា នៃជីវិតរៀងរហូត!


43

នេប៊ូក្នេសា ដែលជាអ្នកដឹកនាំដ៏មាន អំណាចនៅទីក្រុងបាប៊ីឡូន បានធ្វើរូប សំណាកដ៏ធំសំបើម ដែលមនុស្សគ្រប់គ្នា ត្រូវថ្វាយបង្គំ។

បញ្ញត្តិទីពីរ ហាមថ្វាយបង្គំរូប បដិមាករ គឺជាការសាកល្បងទៅលើការ ស្មោះត្រង់ រវាងការថ្វាយបង្គំព្រះដ៏ពិត និង ថ្វាយបង្គំព្រះក្លែងក្លាយ។

គុកភ្លើងបានក្តៅជាងធម្មតាប្រាំពីរដង។

ពេលនោះ ជាគ្រាពិបាកជាងការពិបាក លើកណា១ទាំងអស់។

លទ្ធផលនៃការមិនស្តាប់បង្គាប់ដល់ សាសនារដ្ឋនោះ នឹងត្រូវទទួលទោសដល់ ស្លាប់។

ម្តងទៀត នៅសម័យចុងក្រោយ

ព្រះបន្ទូលរបស់ព្រះនៅក្នុងព្រះគម្ពីរវិវរណៈ បើកសំដែងឱ្យឃើញថា អ្នកដឹកនាំដ៏មាន អំណាច នៅលើពិភពលោកនេះ នឹង បង្រួបបង្រួមសាសនា និងរដ្ឋាភិបាល បញ្ចូលគ្នា។

បញ្ហាចំបងនោះ នឹងទាក់ទងទៅនឹងការ ថ្វាយបង្គំ។ ក្រិត្យវិន័យនឹងត្រូវបានសាក ល្បង អំពីការស្មោះត្រង់ នៅពេលចុង បំផុតនៃផែនដី នៃការពិបាកវេទនា នៅ ពេលដែលច្បាប់នៃសេចក្តីស្លាប់នៅក្នុង លោកីយ៍នេះ ត្រូវបានគេអនុមតិ។


44

ការដ៏មុះមុតបំផុត ដែលមិនដែលធ្លាប់ បានផ្តល់មកដល់មនុស្សលោកនៅលើផែនដី នេះ ត្រូវបានកត់ត្រានៅក្នុងគម្ពីរវិវរណៈ។

ជាការជាក់ស្តែង ព្រះពិចារណាឃើញ ថា ដំណឹងនេះមានសារសំខាន់ស្លាប់រស់ ដល់រាស្ត្ររបស់ទ្រង់ បានជាទ្រង់បានមាន ព្រះបន្ទូលថាៈ


45

(ព្រះគម្ពីរ វិវរណៈ ១៣:៩)

"បើអ្នកណាមានត្រចៀក ឱ្យអ្នកនោះ ស្តាប់ចុះ"

វិវរណៈ ១៣:៩។

យើងត្រូវស្តាប់នូវដំណឹងដ៏បន្ទាន់ បំផុតនេះ!


46

(ព្រះគម្ពីរ វិវរណៈ ១៤:៩,១០)

"...បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វានៅលើ ថ្ងាសឬនៅដៃ

# ១៨. សញ្ញាដ៏នៅអស់កល្ប


47

អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តី ឃោរឃៅរបស់ព្រះ


48

ជាស្រាឥតលាយ ដែលចាក់ទៅក្នុងពែងនៃ សេចក្តីក្រោធរបស់ទ្រង់


49

ព្រមទាំងត្រូវរងទុក្ខវេទនា នៅក្នុងភ្លើង និងស្ពាន់ធ័រ ចំពោះមុខនៃទេវតាបរិសុទ្ធ និងកូនចៀមផង"
វិវរណៈ ១៤:៩,១០


50

មនុស្សគ្រប់រូបត្រូវតែសិក្សាបទទំនាយ នេះ ហើយដឹងឱ្យច្បាស់ថា គាត់ឬនាងគ្មាន
អ្វីទាក់ទងទៅនឹងសត្វនេះ ឬសញ្ញារបស់វា ទេ។


51

យោងទៅតាមបទទំនាយនៅក្នុងព្រះ គម្ពីរ នៅគ្រាចុងក្រោយបង្អស់ មនុស្ស
ដែលរស់នៅលើផែនដីនេះ នឹងត្រូវចែក ចេញជាពីរក្រុម:
អ្នកដែលមានស្វាមីភក្តិចំពោះព្រះ និង គោរពតាមបញ្ញត្តិរបស់ទ្រង់ និងអ្នកដែល ថ្វាយបង្គំសត្វ
និងទទួលសញ្ញារបស់វា។



52

សម្ពាធយ៉ាងតឹងរឹង នឹងត្រូវធ្លាក់ទៅលើ អស់អ្នកណាដែលបដិសេធមិនព្រមថ្វាយបង្គំសត្វនោះ
និងទទួលសញ្ញារបស់វា។
វានឹងមានបញ្ហាធ្ងន់ធ្ងរដូចជាជនជាតិ ហេព្រើរទាំងបីនាក់ បានប្រឈមនៅពេល
ដែលគេបានឈរនៅចំពោះស្តេចនេប៊ូក្នេសា នោះដែរ។



53

(ព្រះគម្ពីរ វិវរណៈ ១៣:១៦,១៧)
"វាក៏បង្ខំមនុស្សទាំងអស់ ទាំងធំ ទាំង តូច ទាំងមាន ទាំងក្រ ហើយទាំងអ្នកជា និងបាវគេ
ឱ្យទទួលទីសំគាល់នៅដៃស្តាំ ឬ នៅថ្ងាសរៀងខ្លួន

# ១៨. សញ្ញាដ៏នៅអស់កល្ប


54

ហើយមិនបើកឱ្យអ្នកណាមានច្បាប់នឹងទិញ ឬលក់អ្វីបានឡើយ លើកតែអ្នកដែលមាន ទីសំគាល់នោះចេញ គឺជាឈ្មោះរបស់សត្វ នោះឬជាលេខរបស់វា"
វិវរណៈ ១៣:១៦,១៧។


55

ជាការពិតណាស់ ច្បាប់មួយនឹងត្រូវបាន អនុមតិ ដាក់ទោសប្រហារជីវិត ចំពោះអស់អ្នកណាដែលប្រកែក មិនព្រមថ្វាយ បង្គំសត្វ នោះនិងរូបរបស់វា។


56

(ព្រះគម្ពីរ វិវរណៈ ១៣:១៥)
សត្វទីពីរនៃព្រះគម្ពីរវិវរណៈ ព្រះគម្ពីរ និយាយថា "ក៏មានអំណាចបានប្រគល់ឱ្យវា និងធ្វើឱ្យរូបសត្វនោះមានខ្យល់ដង្ហើម ដើម្បីឱ្យបានចេះនិយាយ


57

ហើយអំណាចនឹងធ្វើឱ្យពួកអ្នកដែលមិន ព្រមក្រាបថ្វាយបង្គំរូបសត្វនោះត្រូវស្លាប់ ផង"
វិវរណៈ:១៣:១៥


58

មនុស្សនិយាយថា "ប្រសិនបើអ្នកមិន ថ្វាយបង្គំសត្វនោះទេ យើងនឹងមិនទិញ អ្វីពីអ្នក ឬលក់អ្វីឱ្យអ្នកដែរ ហើយយើងនឹង សម្លាប់អ្នកយ៉ាងពិតប្រាកដ"


59

ព្រះមានព្រះបន្ទូលថា "ប្រសិនបើអ្នកថ្វាយ បង្គំសត្វនោះ អ្នកនឹងទទួលផឹកស្រានៃ សេចក្តីក្រោធរបស់ព្រះ"


60

មនុស្សទាំងអស់នៅលើផែនដីនេះ នឹង ប្រឈមមុខជាមួយនឹងការសម្រេចចិត្តយ៉ាង ពិបាកបំផុត ដែលគេមិនដែលធ្លាប់បានជួប ប្រទះសោះឡើយ។
តើអ្វីទៅដែលជាការជំនុំជំរះរបស់ព្រះ ដែលនឹងទម្លាក់មកលើមនុស្សអាក្រក់នោះ? គម្ពីរវិវរណៈកាន់ចម្លើយនេះ:


61

(ព្រះគម្ពីរ វិវរណៈ ១៥:១)
"ខ្ញុំក៏ឃើញទីសំគាល់១ទៀត ដែលធំ ហើយអស្ចារ្យនៅលើមេឃ

# ១៨. សញ្ញាដ៏នៅអស់កល្ប



62

គឺមានទេវតា៧ ដែលកាន់សេចក្ដីវេទនា ទាំង៧ក្រោយបង្អស់ ដ្បិតសេចក្ដីឃោរឃៅ
របស់ព្រះបានសម្រេច ដោយសេចក្ដីវេទនា ទាំងនោះ” វិវរណៈ១៥:១


63

ការវេទនាបី ក្នុងចំណោមទាំងប្រាំពីរ មានទិសដៅច្បាស់លាស់តម្រង់ចំពោះសត្វ នោះ
និងអស់អ្នកដែលថ្វាយបង្គំដល់វា។
ជាការពិតប្រាកដណាស់ ព្រះមិនដែល អនុញ្ញាតឱ្យការជំនុំជំរះ ធ្លាក់មកលើរាស្ត្រ របស់ទ្រង់
ដោយទ្រង់មិនបានប្រាប់ឱ្យដឹង ជាមុននោះឡើយ។


64

នេះហើយដែលជាការដែលអស្ចារ្យបំផុត អំពីព្រះ!
ទ្រង់នឹងមិនចាក់ការវេទនាទាំងប្រាំពីរ ចុងក្រោយបង្អស់ មកលើមនុស្សជាតិដោយ
មិនបានផ្ដល់ឱកាសលើកទីមួយឱ្យមនុស្ស គ្រប់ៗគ្នាដឹងថា តើសញ្ញារបស់សត្វនោះ គឺជាអ្វី
ហើយតើធ្វើយ៉ាងណា ដើម្បី នឹងចៀសវាង ការថ្វាយបង្គំដល់វានោះទេ។


65

ជាមួយនឹងដំណឹងនៃការប្រកាសឱ្យដឹង ចុងក្រោយបង្អស់របស់ទ្រង់នេះ ព្រះបាន
ប្រទានកូនសោសម្រាប់បើកបទទំនាយ ដើម្បីឱ្យយើងអាចយល់បានថា វានិយាយ អំពីអ្វី។
គ្មានអ្នកណាម្នាក់ដែលនឹងប្រឈម មុខទល់នឹងវិបត្តិ ដែលនឹងមកដល់នោះ
ដោយមិនបានរៀបចំជាមុនបានទេ។
វាជាការសំខាន់ចាំបាច់ណាស់ សម្រាប់ យើងដែលត្រូវដឹងថា តើអ្នកណាមួយដែល
ជាអំណាចរបស់សត្វនោះ ហើយថា តើ យើងត្រូវធ្វើយ៉ាងណាដើម្បីចៀសវាងការ
ទទួលសញ្ញារបស់វា។


66

សូមបើកទៅឯបទទំនាយដែលរកឃើញ នៅក្នុងព្រះគម្ពីរវិវរណៈ ហើយអានអំពីអំ
ណាចរបស់សត្វនោះ



67

(ព្រះគម្ពីរ វិវរណៈ ១៣:១-៨)
លោកសាវកយ៉ូហានបានសរសេរថា “ខ្ញុំក៏ឈរលើខ្សាច់នៅមាត់សមុទ្រ ហើយខ្ញុំ ឃើញសត្វសាហាវ
១ឡើងចេញពីសមុទ្រមក

# ១៨. សញ្ញាដ៏នៅអស់កល្ប


68

ដែលមានស្នែង១០ និងក្បាល៧ រីឯនៅ លើស្នែងវា មានមកុដ១០


69

ហើយនៅលើក្បាលទាំងប៉ុន្មាននោះ មានឈ្មោះជាពាក្យប្រមាថ


70

សត្វដែលឃើញនោះ មើលទៅដូចជា ខ្លារខិន ជើងវាដូចជាជើងនៃខ្លាឃ្មុំ


71

ហើយមាត់វាដូចជាមាត់សិង្ហ


72

នាគក៏ឱ្យឫទ្ធិ និងបល្ល័ង្ករបស់វាដល់សត្វ នោះ ព្រមទាំងអំណាចយ៉ាងធំដែរ" វិវរណៈ ១៣:១,២


73

ខ្ញុំឃើញក្បាលវា១ដូចជាបានកាប់សម្លាប់ ហើយ


74

តែរបួសដល់ស្លាប់នោះបានសះជាឡើងវិញ ហើយផែនដីក៏អស្ចារ្យនឹងសត្វនោះ


75

គេក៏ក្រាបថ្វាយបង្គំដល់នាគ ដែលឱ្យ សត្វនោះមានអំណាច

១៨. សញ្ញាដ៏នៅអស់កល្ប

# ១៨. សញ្ញាជំនៅអស់កល្ប



76

ព្រមទាំងក្រាបថ្វាយបង្គំដល់សត្វនោះដែរ ដោយនិយាយថា តើមានអ្នកណាដូចសត្វ នេះ?



77

មានអ្នកណាដែលអាចច្បាំងនឹងវាបាន?”



78

នាគក៏ឱ្យវាមានមាត់ចេះនិយាយជាពាក្យសំដីធំ និងពាក្យប្រមាថ



79

ក៏ឱ្យមានអំណាចនឹងធ្វើការវាក្នុងរវាង៤២ខែ”
វិវរណៈ១៣:៣-៥។



80

“វាបើកមាត់ប្រមាថដល់ទាំងព្រះ និង ព្រះនាម



81

ហើយព្រះវិហារនៃទ្រង់ដែរ ព្រមទាំង ដល់ពួកអ្នកនៅស្ថានសួគ៌ផង



82

ក៏មានអំណាចបានប្រគល់ដល់វា ឱ្យ ច្បាំងឈ្នះពួកបរិសុទ្ធបាន



83

ហើយនិងអំណាចលើគ្រប់ទាំងពូជ មនុស្ស គឺអស់ទាំងគ្រួសារ និងភាសា
ហើយនិងអស់ទាំងសាសន៍ផង

# ១៨. សញ្ញាដ៏នៅអស់កល្ប



84

ឯអស់មនុស្សទាំងប៉ុន្មាន នៅលើផែនដី ដែលគ្មានឈ្មោះកត់ទុក



85

នៅក្នុងបញ្ជីជីវិតរបស់កូនចៀមដែលត្រូវគេ សម្លាប់តាំងពីកំណើត លោកីយ៍មកនោះ នឹងក្រាបថ្វាយបង្គំចំពោះ សត្វនោះ”
វិវរណៈ ១៣:៨


86

យើងត្រូវតែមើលបទទំនាយនេះមួយចំ ណុចម្តងៗ។
ទីនេះព្រះប្រើនិមិត្តសញ្ញាបទទំនាយម្តង ទៀត ដើម្បីនឹងគូសបញ្ជាក់ការប្រកាសរបស់ទ្រង់ដល់លោកីយ៍។


87

ហើយតើសត្វនោះតំណាងឱ្យអ្វីទៅ?
ដានីយ៉ែល៧ បានបង្រៀនយើងថា សត្វ តំណាងឱ្យនគរ ឬអំណាចគ្រប់គ្រង។
ទីនេះ នៅក្នុងវិវរណៈ យើងរកឃើញ រូបភាពដ៏អស្ចារ្យពិតប្រាកដ-ដែលមានសត្វ ចម្រុះទាំងបួន ដែលបានឃើញនៅក្នុងការ ជាក់ស្តែងរបស់ដានីយ៉ែល!
លោកអ្នកមិនដែលឃើញសត្វដូច្នោះ ឡើយ!
ការរំលឹកនៃសត្វទាំងបួនរបស់ដានីយ៉ែល បានបង្រៀន និងជួយយើងឱ្យយល់អំពីអំណាចរបស់សត្វដែលយើងកំពុងរៀននៅ ពេលនេះ



88

តើសិង្ហតំណាងឱ្យអ្វី? មែនហើយ គឺបាប៊ីឡូន!



89

ចុះខ្លាឃ្មុំ? ត្រឹមត្រូវ គឺមេដូ-ពើរស៊ី។



90

ហើយចុះតើខ្លារខិនវិញ? ក្រេក បាទ(ចាស)។

# ១៨. សញ្ញាដ៏នៅអស់កល្ប


91

ហើយចុះស្ទេងដ៏អាក្រក់ទាំងដប់វិញ នោះ? តើលោកអ្នកចាំបានច្បាស់លាស់ ឬទេ! មែនហើយ វាតំណាងឱ្យចក្រភពរ៉ូម។


92

សត្វនៃវិវរណៈជំពូក១៣ គឺជាអំណាច ដែល កើតឡើងបន្ទាប់ពីចក្រភពដ៏មានអំ ណាចទាំងបួន។

ឥឡូវនេះយើងរកឃើញរឿងដ៏គួរឱ្យចាប់ អារម្មណ៍មួយៈ អំណាចតែមួយគត់នៅលើ ផែនដីនេះ ដែលមានលក្ខណៈទាំងអស់ ដែលបានប្រើនៅក្នុងបទទំនាយនេះ។

បទព្រះគម្ពីរ និងអ្នកប្រាជ្ញប្រវត្តិសាស្រ្ត ធ្វើការបញ្ជាក់យ៉ាងច្បាស់។

និយាយអំពីសត្វនេះ លោកយ៉ូហានបាន សរសេរថា


93

(ព្រះគម្ពីរ វិវរណៈ ១៣:២)

"...នាគក៏ឱ្យឫទ្ធិ និងបល្ល័ង្ករបស់វាទៅ ដល់សត្វនោះ ព្រមទាំងអំណាចយ៉ាងធំដែរ" វិវរណៈ:១៣:២។

យើងរកឃើញថា នាគតំណាងឱ្យ សាតាំង ដូចដែលព្រះគម្ពីរនិយាយថា


94

(ព្រះគម្ពីរ វិវរណៈ ១២:៧-៩)

"នោះមានចម្បាំងនៅលើមេឃ...


95

នោះនាគធំក៏បានទម្លាក់ទៅ គឺជាពស់ពី បុរាណ ដែលឈ្មោះហៅថា អារក្សហើយ សាតាំងផង ដែលបាននាំលោកីយ៍ទាំងមូល ឱ្យវង្វេងចេញ..." វិវរណៈ ១២:៧-៩។


96

ជាការពិតណាស់ សាតាំងមិនដែល ឈានចូលទៅក្នុងសមរភូមិក្នុងទ្រង់ទ្រាយ ដែលគេមើលឃើញវានោះឡើយ។

វាធ្វើការក្លែងបន្លំពីក្រោយវិញ តាមរយៈ ភ្នាក់ងារ អំណាច និងមនុស្សដទៃ។

ព្រះគម្ពីរវិវរណៈផ្តល់រូបភាពមួយនៃ ទំនាស់ដ៏ធំសំបើម រវាងសាតាំងនិងក្រុម ជំនុំរបស់ព្រះ:

# ១៨. សញ្ញាដ៏នៅអស់កល្ប


97

(ព្រះគម្ពីរ វិវរណៈ ១២:៣-៥)

"ឃើញមានទីសំគាល់១ទៀតនៅលើ មេឃ គឺនាគដ៏ធំមានសម្បុរក្រហម


98

ដែលមានក្បាល៧ និងស្នែង១០ ឯនៅលើ ក្បាលវាមានមកុដ៧...


99

នាគនោះក៏ស្ថិតនៅត្រង់មុខស្ត្រី ដែល រៀបនឹងសំរាលកូននោះ


100

ដើម្បីនឹងលេបកូននាងក្នុងកាលដែលសំរាល ចេញមក


101

នាងសំរាលបានកូនប្រុសដែលត្រូវឃ្វាល គ្រប់អស់ទាំងសាសន៍ដោយដំបងដែក:


102

តែព្រះទ្រង់លើកកូននាងទៅឯទ្រង់ និង ដល់បល្ល័ង្កទ្រង់វិញ" វិវរណៈ ១២:៣-៥


103

តើអ្នកណាទៅ ដែលជាកូនរបស់មនុស្ស នោះ?

ចម្លើយគឺ ព្រះយេស៊ូវគ្រីស្ទ!

ពីក្រោយវិញ្ញាណរបស់នាគ ឬសាតាំង ត្រូវបានឃើញថា កំពុងធ្វើការយ៉ាងខ្លាំង តាមរយៈអំណាចរបស់លោកីយ៍នេះ ដើម្បី បំផ្លាញព្រះយេស៊ូវ។

រឿងនោះពិតប្រាកដ ដូចដែលបានកើត ឡើងមែន។

តើតាមរយៈជាតិសាសន៍អ្វីទៅ ដែល អារក្សបានធ្វើការ នៅពេលកំណើតព្រះ យេស៊ូវ?

# ១៨. សញ្ញាដ៏នៅអស់កល្ប


104

នៅពេលដែលយើងបើកទំព័រនៃអ្នក ប្រាជ្ញប្រវត្តិសាស្ត្រ យើងបានរកឃើញថា អ្នកមិនជឿសាសនារ៉ូម ក្រោមការគ្រប់គ្រង របស់ព្រះចៅសេសារ បានគ្រប់គ្រងអំណាចនៅពេលដែលព្រះគ្រីស្ទប្រសូត។


105

ច្បាប់ដ៏ធំរបស់ស្តេចហេរូឌ ដែលប្រ  កាសថា កុមារទាំងអស់នៅភូមិ បេថ្លេហិម ចាប់ពីអាយុពីរឆ្នាំចុះក្រោម ត្រូវសម្លាប់ចោល នៅក្នុងការប៉ុនប៉ងធ្វើគត ព្រះយេស៊ូវ នាពេលដែលទ្រង់ប្រសូតមក។


106

លោកចៅហ្វាយខេត្តរ៉ូម ប៉ុនទាស ពីឡាត់ បានបញ្ជាឱ្យគេយកព្រះគ្រីស្ទទៅ សម្លាប់។


107

ទាហានរ៉ូម បោះដែកគោលទ្រង់ជាប់ ទៅនឹងឈើឆ្កាង ហើយត្រារបស់ប្រទេស រ៉ូម បានបោះការពារ មាត់ទ្វារផ្នូររបស់ ទ្រង់។ សាតាំងបានធ្វើការតាមរយៈនគរ ដែលគ្មានសាសនារ៉ូម ដើម្បីបំផ្លាញព្រះ គ្រីស្ទ។


108

ហើយព្រះយេស៊ូវ បានមានព្រះជន្មរស់ ឡើងវិញ រួចបានយាងឡើងទៅកាន់ ស្ថានសួគ៌ យ៉ាងពិតប្រាកដដូចដែលព្រះ គម្ពីរបានទស្សនទាយមកមែន។

តើការនេះបានផ្តល់ឱ្យអ្នកមានការទុក ចិត្តទៅលើបទទំនាយក្នុងព្រះគម្ពីរឬទេ?


109

បទទំនាយនេះ ទស្សនទាយបន្តទៅទៀត ថា អំណាចរ៉ូមដែលគ្មានសាសនានេះនឹង



110

(ព្រះគម្ពីរ វិវរណៈ ១៣:២)

ឱ្យ "ឫទ្ធិ" របស់វា "បល្ល័ង្ក" របស់វា និង "អំណាចយ៉ាងធំ" របស់វាដល់សត្វនោះ

តើអ្នកកាន់អំណាចរ៉ូមគ្មានសាសានានេះ បានសម្រេចតាម បទទំនាយនេះហើយឬនៅ?

ហើយបើដូច្នោះមែននោះ តើវាបានឱ្យ ទៅអ្នកណា?

# ១៨. សញ្ញាដ៏នៅអស់កល្ប


111

អស់រយៈពេលជាច្រើនទសវត្សរ៍
ពួកជំនុំរ៉ូម៉ាំងកាតូលិក បានប្រើប្រាស់ ឯកសារដែលមានចំណងជើងថា
"អំណោយរបស់ព្រះចៅកុងស្តង់ទីន" ដើម្បី បញ្ជាក់ អំណាចទៅឱ្យទីក្រុងរ៉ូម។ ក្រោយ មកទៀត
ឯកសារនេះត្រូវបាន គេទទួល ស្គាល់ថាជាច្បាប់ក្លែងក្លាយ ដែលផ្តល់អំ
ណាចឱ្យក្រុមជំនុំមានសិទ្ធិគ្រប់គ្រង ប្រទេសរ៉ូមខាងជើង ទាំងនយោបាយ និងសាសនា។
ឯកសារនេះជាច្បាប់មូលដ្ឋាន ដើម្បីធ្វើឱ្យ អំណាចរបស់ពួកគេបានត្រឹមត្រូវ ជានគរ
ដែលមានសម្តេចប៉ាប ជាព្រះមហាក្សត្រ។


112

នៅក្នុងឆ្នាំ ៣០០នៃគ្រិស្តសករាជ ស្តេចកុងស្តង់ទីន បានលើករាជធានីទៅ កាន់ប៊ីហ្សាន់ធីយ៉ូម
ហើយបានផ្លាស់ប្តូរ ឈ្មោះទីក្រុងទៅជាកុងស្តង់ទីណូប ដើម្បី លើកកិត្តិយសដល់ព្រះអង្គផ្ទាល់។


113

នៅពេលដែលស្តេចកុងស្តង់ទីននេះចាក ចេញទៅ ទ្រង់បានប្រគល់បល្ល័ង្ករបស់ទ្រង់
ដល់បូជាចារ្យរបស់ទីក្រុងរ៉ូម។
អភិបាលពួកជំនុំរ៉ូមបានក្លាយជាអ្នកដឹកនាំ
ពួកជំនុំ ព្រមទាំងជាព្រះមហាក្សត្រនៅលើ បល្ល័ង្កផង។
ការរួបរួមគ្នារបស់ព្រះវិហារ និង
រដ្ឋាភិបាលបានផ្តល់លទ្ធផលឱ្យពួក
ជំនុំគ្រប់ គ្រងលើរដ្ឋាភិបាល។


114

វិមានវ៉ាទីហ្គង់ លាតសន្ធឹងនៅកណ្តាល ទីក្រុងរ៉ូម ជាទីក្រុងដែលមានបល្ល័ង្ករបស់ ព្រះចៅអធិរាជ
រ៉ូមពីបុរាណ។


115

ពួកជំនុំនោះបន្តរហូតមកដល់សព្វថ្ងៃ នេះ មិនមែនគ្រាន់តែអំណាចខាងសាសនា ប៉ុណ្ណោះទេ
ប៉ុន្តែថែមទាំងអំណាច
នយោបាយទៀតផង។ ស្ទើរតែគ្រប់ សាសន៍ទាំងអស់នៅលើពិភពលោកនេះ បញ្ជូនអង្គទូតរបស់ខ្លួន
ទៅកាន់វិមាន វ៉ាទីហ្គង់។


116

វាជាការសំខាន់ណាស់ដែលត្រូវដឹងនៅក្នុងគំ និតថា បទទំនាយកំពុងនិយាយអំពីអង្គការ
និងធម៌របស់គេ។ មិនមែននិយាយអំពី បុគ្គលណាម្នាក់នោះទេ

# ១៨. សញ្ញាដ៏នៅអស់កល្ប


117

មានមនុស្សស្មោះត្រង់ជាច្រើនដែល ថ្វាយបង្គំព្រះ ប៉ុន្តែមិនទាន់បានដឹងអំពីអ្វី ដែលលោកអ្នកកំពុងរៀននៅថ្ងៃនេះ អំពី បទទំនាយនៃព្រះគម្ពីរ ស្តីពីអំណាចនោះទេ។


118

ការសិក្សាយ៉ាងជិតដិតអំពីការបញ្ជាក់ របស់អំណាចនៃសត្វនោះ នៅក្នុងគម្ពីរ វិវរណៈជំពូកទី១៣ ធ្វើឱ្យកាន់តែច្បាស់ថា វាគឺ ជាអំណាចដដែលនោះ ដែលមាន និមិត្តរូប ដោយស្នែងតូចនៅក្នុងព្រះគម្ពីរ ដានីយ៉ែល  ជំពូក៧ដែលយើងបានចាប់អារម្មណ៍ពីមុននោះ។



119

ហោរាយ៉ូហានបាននិយាយថា អំណាច សត្វនោះ នឹងមានសញ្ញាខុសប្លែក ហើយ ថាវានឹងខំប្រឹងប្រែង បង្ខំដល់មនុស្សទាំង អស់នៅលើពិភពលោកនេះ!


120

(ព្រះគម្ពីរ វិវរណៈ ១៣:១៦,១៧)

"វាក៏បង្ខំមនុស្សទាំងអស់ ទាំងធំ ទាំងតូច ទាំងមាន ទាំងក្រ ហើយទាំង អ្នកជា និងបាវគេ ឱ្យទទួលទីសំគាល់ នៅដៃស្តាំ ឬនៅ ថ្ងាសគេរៀងខ្លួន:


121

ហើយមិនបើកឱ្យអ្នកណាមានច្បាប់នឹងទិញ ឬលក់អ្វីបានឡើយ លើកដែលអ្នកដែល មានទីសំគាល់នោះចេញ គឺជាឈ្មោះរបស់ សត្វនោះ ឬជាលេខរបស់ឈ្មោះវា" វិវរណៈ ១៣:១៦, ១៧។


122

យោងទៅតាមព្រះបន្ទូលរបស់ព្រះ សញ្ញានេះ ពិតជានិមិត្តរូបនៃការប្រឆាំង បះបោរ ឬការមិនស្មោះត្រង់ទៅនឹងរដ្ឋា ភិបាលរបស់ព្រះ។

ព្រះគម្ពីរពណ៌នាយ៉ាងច្បាស់អំពីមនុស្ស មួយក្រុមទៀត ដែលមិនទទួលសញ្ញារបស់ សត្វនោះ


123

(ព្រះគម្ពីរ វិវរណៈ ១៤:១២)

"នេះហើយជាសេចក្តីអត់ធ្មត់របស់ពួកបរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្តីជំនឿដល់ព្រះយេស៊ូវ"

វិវរណៈ ១៤:១២។

# ១៨. សញ្ញាដ៏នៅអស់កល្ប


124

គ្មានអ្វីខុសឡើយ ចំណុចដ៏ចំបងនៃបញ្ហាដ៏ធំ នៃពិភពលោកនេះគឺស្ថិតនៅត្រង់ការគោរព បញ្ញត្តិរបស់ព្រះ!

មនុស្សមួយក្រុមទទួលសញ្ញារបស់សត្វ នៅពេលដែលមនុស្សមួយក្រុមទៀតស្រឡាញ់ និងស្មោះត្រង់ចំពោះព្រះ ដោយគោរពគ្រប់ទាំងបញ្ញត្តិរបស់ទ្រង់ទាំងអស់. ហើយរក្សាសេចក្តីជំនឿទៅលើព្រះយេស៊ូវ។


125

រាស្ត្ររបស់ព្រះ នឹងទទួលសញ្ញាមួយដែរ ប៉ុន្តែវាជាសញ្ញារបស់ព្រះ ត្រារបស់ព្រះ។


126

ត្រានោះនឹងបោះនៅលើថ្ងាសរបស់អ្នកដែលដើរតាមទ្រង់។



127

(ព្រះគម្ពីរ វិវរណៈ ៧:២,៣)

រួចខ្ញុំឃើញទេវតា១ទៀតដែលឡើងមក ពីទិសថ្ងៃរះ មានទាំងត្រារបស់ព្រះដ៏មាន ព្រះជន្មរស់



128

ទេវតានេះក៏បន្លឺសំឡេងទៅទេវតាទាំង៤ នោះ ដែលមានអំណាចនឹងធ្វើទុក្ខផែនដី ហើយនិងសមុទ្រ



129

ថា កុំឱ្យធ្វើទុក្ខផែនដីឬសមុទ្រ ឬដើម ឈើណាក្តី



130

ទាល់តែបោះត្រានៅគ្រប់ថ្ងាស នៃពួក បាវបំរើរបស់ព្រះនៃយើងសិន”
វិវរណៈ ៧:២,៣។

# ១៨. សញ្ញាដ៏នៅអស់កល្ប



131

ខ្ញុំចង់បានត្រានោះ ចុះតើលោកអ្នកវិញ?

គ្មានអ្វីដែលសំខាន់ជាងនោះទេ។

វិវាទចុងក្រោយនៃប្រវត្តិសាស្ត្រពិភព លោកនេះ គឺស្ថិតនៅលើត្រារបស់ព្រះ ឬ សញ្ញារបស់សត្វ។ គឺជាវិវាទរវាងសញ្ញា របស់ព្រះ និងសញ្ញាក្លែងក្លាយ។

នៅពេលដែលយើងរកឃើញត្រា ឬ សញ្ញារបស់ព្រះ វាជាការងាយស្រួលនឹង ស្គាល់សញ្ញាក្លែងក្លាយ ដែលអំណាចរបស់ សត្វនោះនឹងបង្ខំឱ្យទទួល។

ព្រះប្រាប់យើងថា សញ្ញាឬត្រារបស់ព្រះ នោះគឺ:



132

(ព្រះគម្ពីរ អេសេគាល ២០:១២)

"អញក៏តាំងថ្ងៃឈប់សំរាករបស់អញឱ្យ គេដែរ ទុកសំរាប់ជាទីសំគាល់ដល់អញ ហើយនិងគេ..." អេសេគាល ២០:១២



133

(ព្រះគម្ពីរ និក្ខមនំ ៣១:១៣)

"ឱ្យប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ត្រូវឱ្យឯងរាល់គ្នាកាន់អស់ទាំងថ្ងៃឈប់សំរាក របស់អញកុំខាន



134

ដ្បិតនោះជាទីសំគាល់ដល់អញ ហើយនិង ឯងរាល់គ្នា នៅអស់ទាំងតំណតទៅ



135

ដើម្បីឱ្យបានដឹងថា អញនេះជាព្រះយេហូវ៉ា ដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ" និក្ខមនំ ៣១:១៣។



136

ព្រះបានមានព្រះបន្ទូលថា ថ្ងៃបរិសុទ្ធគឺ ជាសញ្ញា ឬការគូសចំណាំ នៃអំណាច របស់ទ្រង់។

តើអំណាចរបស់សត្វនិយាយថា អ្វីទៅ ដែលជាអំណាចរបស់វា?

# ១៨. សញ្ញាដ៏នៅអស់កល្ប



137

ការដកស្រង់ខាងក្រោមនេះ បានមកពី
សៀវភៅសំនួរចម្លើយរបស់ពួកជំនុំកាតូលិក។
សំនួរៈ តើអ្វីទៅដែលជាភស្តុតាង បញ្ជាក់ថា ពួកជំនុំមានអំណាចអាចបង្គាប់ បញ្ជាឱ្យមានពិធីបុណ្យ និងថ្ងៃបរិសុទ្ធបាន?



138

"ចម្លើយៈ ដោយសារសកម្មភាពនៃការផ្លាស់
ប្តូរថ្ងៃបរិសុទ្ធទៅជាថ្ងៃអាទិត្យវិញ។
ពួកប្រូតេសស្តង់ បានអនុញ្ញាតឱ្យ
មានការផ្លាស់ប្តូរនោះ



139

ប៉ុន្តែពួកគេបានអនុវត្តផ្ទុយទៅវិញ ដោយ បានគោរពថ្ងៃអាទិត្យយ៉ាងតឹងរឹង តែបាន ប្រព្រឹត្ត ល្មើសទៅនឹងថ្ងៃបុណ្យផ្សេងៗ ដែលបានបង្គាប់បញ្ជាពួកជំនុំនោះ។



140

"សំនួរៈ តើអ្នកមានវិធីផ្សេងណាទៀត ដែលបញ្ជាក់ថា សាសនាកាតូលិកមាន អំណាចតាំងបុណ្យ នៃសិក្ខាបទឬទេ?



141

"ចម្លើយៈ ពួកជំនុំគ្មានអំណាចនោះ ឡើយ គឺគ្មានអំណាចនឹងជំនួសការប្រតិបត្តិ ថ្ងៃអាទិត្យ ជាថ្ងៃទីមួយនៃសប្តាហ៍



142

ជាមួយនឹងការប្រតិបត្តិថ្ងៃសៅរ៍ ជាថ្ងៃទីប្រាំពីរ ពីព្រោះការផ្លាស់ប្តូរបែបនេះ
មិនមានចែងនៅក្នុងព្រះគម្ពីរទេ"
សេចក្តីសង្ខេបនៃគោលលទ្ធិគ្រីស្ទាន ហេនរី ទូបើវីល ទំព័រ៥៨។




143

ថ្ងៃអាទិត្យ គឺជាសញ្ញារបស់អំណាចនៃ សាសនារ៉ូម៉ាំងកាតូលិក យោងទៅតាមការ
ធ្វើទីបន្ទាល់ផ្ទាល់របស់ពួកគេ។
គេបានទទួលស្គាល់យ៉ាងពិតប្រាកដថា គេពិតជាបានផ្លាស់ប្តូរថ្ងៃថ្វាយបង្គំ ពីថ្ងៃ
សៅរ៍ទៅថ្ងៃអាទិត្យវិញ ហើយលើសពីនេះ ទៅទៀត

# ១៨. សញ្ញាដ៏នៅអស់កល្ប


144

ពួកជំនុំកាតូលិកនិយាយថា សកម្មភាពនេះ គឺជា "សញ្ញានៃអំណាចសាសនា និង នយោបាយ" (សំបុត្រពីអធិការបតី
ស៊ីអេហ្វ ថូម៉ាស ទៅកាន់កាឌីណាល់ គីបូន ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៨៩៥)
ពួកជំនុំរ៉ូម៉ាំងកាតូលិក បានជម្រុញ
ប្រូតេសស្តង់ ឱ្យបង្ហាញពីការដែលគេបាន ប្រមាថថ្ងៃរបស់ព្រះ និងបានបែរចេញពី



145

(វីដេអូ ២វិនាទី) ថ្ងៃបរិសុទ្ធនៃព្រះគម្ពីរ ដែលដើរតាមថ្ងៃដែលត្រូវបានតាំងឡើងដោយ



146

(វីដេអូ ៥វិនាទី) ទំនៀមទម្លាប់
ប្រពៃណី
និងពួកជំនុំរ៉ូម៉ាំងកាតូលិក


147

(ព្រះគម្ពីរ ដានីយ៉ែល ៧:២៥)
ដានីយ៉ែលបានទស្សនទាយថា អំណាច នៃសត្វនោះនឹង "...គិតបំផ្លាស់ពេល
កំណត់ និងច្បាប់..."
ដានីយ៉ែល ៧:២៥។


148

(ព្រះគម្ពីរ ដានីយ៉ែល ៨:១២)
គាត់បានទស្សនទាយផងដែរថា អំ ណាចនោះនឹងត្រូវបោះ "បោះចោលសេចក្ដីពិត ចុះដល់
ដី ក៏ធ្វើតាមតែអំពើចិត្ត ហើយបាន ចម្រើនផង"
ដានីយ៉ែល ៨:១២


149

លោកយ៉ូហានបានទស្សនទាយថា សាតាំងនឹងខំប្រឹងប្រែងដើម្បីបង្ខំមនុស្សឱ្យ
ទទួលសញ្ញារបស់សត្វនោះ:



150

(ព្រះគម្ពីរ វិវរណៈ ១៣:១៦,១៧)
"វាក៏បង្ខំមនុស្សទាំងអស់ ទាំងធំ ទាំង តូច ទាំងមាន ទាំងក្រ ហើយទាំងអ្នកជា និងបាវគេ
ឱ្យទទួលទីសំគាល់ នៅដៃស្ដាំ ឬនៅថ្ងាសគេរៀងខ្លួន

# ១៨. សញ្ញាដ៏នៅអស់កល្ប





151

ហើយមិនបើកឱ្យអ្នកណាមានច្បាប់នឹងទិញ ឬលក់អ្វីបានឡើយ លើកតែអ្នកដែលមានទីសំគាល់នោះចេញ គឺជាឈ្មោះរបស់សត្វ នោះ ឬជាលេខឈ្មោះរបស់វា”
វិវរណ: ១៣:១៦,១៧។


152

ដើម្បីឱ្យអំណាចនេះបានសម្រេចទៅតាមបទទំនាយទាំងអស់នោះ វានឹងខំប្រឹងប្រែងដោយប្រើអំណាចរបស់រដ្ឋាភិបាលស៊ីវិល ដើម្បី បង្ខំទៅដល់មនុស្ស គ្រប់ៗគ្នានៅចុងសម័យនេះឱ្យទទួលនូវសញ្ញារបស់ខ្លួន។

សូមកត់សំគាល់នូវការដែលព្រះបាន បញ្ជាក់យ៉ាងច្បាស់លាស់អំពីអំណាចនេះ:


153

(ព្រះគម្ពីរ វិវរណ: ១៣:១៨

“នេះហើយជាប្រាជ្ញា អ្នកណាដែលមាន យោបល់ ឱ្យអ្នកនោះរាប់លេខនៃសត្វនោះ ចុះដ្បិតលេខនោះជាលេខរបស់មនុស្ស


154

គឺ ៦៦៦
វិវរណ: ១៣:១៨


155

តើ “លេខ” របស់សត្វនោះមានន័យ យ៉ាងដូចម្ដេច? លោកអ្នកប្រហែលជាត្រូវបានគេសួរយ៉ាងដូច្នេះ។ មនុស្សជាច្រើន បានសួរនូវសំនួរនេះ។


156

យើងគួរទុកឱ្យសាសនាកាតូលិកឆ្លើយ ចុះ។ ភាសាឡាតាំង ជាភាសាផ្លូវច្បាប់របស់ពួកជំនុំកាតូលិក។

នៅក្នុងទេវវិទ្យារបស់កាតូលិក ប៉ាប តំណាង ឱ្យសាសនាកាតូលិកទាំងមូល។



157

បរមងាររមួយទៀតរបស់សម្ដេចប៉ាបគឺ វីកការីយូស ដែលមានន័យថា “ជំនួសកូនព្រះ”


158

ក្រុមជំនុំសាសនាកាតូលិកជឿថា ក្រុម ជំនុំគឺជាសង្គមដែលគេអាចមើលឃើញ ដូច្នេះត្រូវតែមានសិរសារនៃក្រុមជំនុំដែលគេ អាចមើលឃើញ។

# ១៨. សញ្ញាដ៏នៅអស់កល្ប



159

(វីដេអូ ៩វិនាទី) លោកអ្នកនឹងឃើញថា តម្លៃលេខនៃអក្សរឡាតាំងងាយនឹងបូកណាស់

៥,១,១០០,០,០,១,៥,០=១១២

០,១,៥០,១,១=៥៣

៥០០,០,១=៥០១

=៦៦៦

នេះគឺជាសញ្ញាយ៉ាងច្បាស់មួយទៀត ដែលបញ្ជាក់ថា សាសនារ៉ូម៉ាំងកាតូលិកនោះ គឺជាអំណាចរបស់សត្វ នៃព្រះគម្ពីរ វិវរណៈជំពូក១៣នោះ។


160

តើយើងអាចសន្និដ្ឋានបានថាយ៉ាង ដូចម្តេច អំពីការសិក្សានៃបទទំនាយ នៅក្នុងព្រះបន្ទូលរបស់ព្រះនេះ?

យើងអាចឃើញថា ពេលវេលាកំពុង មកដល់ហើយ នៅពេល ដែលមនុស្សរាល់រូបត្រូវបានតម្រូវឱ្យគោ រពថ្ងៃទីមួយនៃសប្តាហ៍ នៅក្នុងការរំលោភ បំពានដោយចំពោះ ទៅនឹងបញ្ញត្តិរបស់ព្រះនោះនៅមិនឆ្ងាយទេ!


161

សេចក្តីបង្គាប់ថ្មីៗមួយក្រោមចំណងជើង ថា "សំបុត្រអាប៉ូស្តូលិក ឌីណូមីនី នៃព្រះ វរបិតាបរិសុទ្ធ ហ្គនប៉ូលទី២ ទៅកាន់អភិបាល បុព្វជិត និងអ្នកដែល ស្មោះត្រង់របស់ពួកជំនុំ ឱ្យគោរពថ្ងៃនៃព្រះអម្ចាស់ ឱ្យបានបរិសុទ្ធ"

ត្រូវបានផ្ញើទៅជូនអ្នកដឹកនាំព្រះវិហារ ក្នុងការក្រើនរំលឹកពួកគេ ឱ្យជំរុញអ្នកដទៃ ឱ្យកាន់ថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាក និង ថ្វាយបង្គំ។

តើលិខិតដែលមានចេតនាដ៏មុះមុតនេះ មិនមែនជាការរៀបចំ ធ្វើច្បាប់ឱ្យគេគោរព ថ្ងៃអាទិត្យជំនួសថ្ងៃបរិសុទ្ធនៅក្នុងព្រះគម្ពីរ ទេឬអី?


162

លិខិតនោះ បានបន្ថែមទៀតថា ត្រូវដាក់ស្នើឱ្យទៅជាច្បាប់ ស៊ីវិលមួយដើម្បីឱ្យបានក្លាយទៅជាច្បាប់រដ្ឋ យ៉ាងពិត ប្រាកដ។

តើស្តាប់ទៅស្រដៀងគ្នាឬទេ?

គឺដូចជាបទទំនាយបាននិយាយមែន!


163

សំនួរមួយដែលមនុស្សជាច្រើនសួរនោះ គឺ "តើមានអ្នកណាម្នាក់មានសញ្ញារបស់ សត្វនោះឥឡូវនេះឬទេ?"

ទេ មិនទាន់មានអ្នកណាមានសញ្ញា របស់សត្វនោះនៅឡើយទេ។

ព្រះមានអ្នកដើរតាមដ៏ស្មោះត្រង់នៅគ្រប់ ទាំងពួកជំនុំ។

# ១៨. សញ្ញាដ៏នៅអស់កល្ប



164

នៅពេលដែលសញ្ញារបស់សត្វនោះត្រូវ បានបង្ខំឱ្យអនុវត្ត-តាមច្បាប់រដ្ឋ ពេល នោះមនុស្សម្នាក់ៗ ត្រូវតែជ្រើសរើស រវាងការស្មោះចំពោះព្រះ ដោយគោរពថ្ងៃ បរិសុទ្ធ ដែលយោងទៅតាមបញ្ញត្តិរបស់ព្រះ

ឬក៏ស្មោះត្រង់ទៅនឹងសត្វនោះ ដោយ គោរពថ្ងៃដែលបានជំនួសដោយអំណាច របស់មនុស្ស។

ពេលនោះហើយ ដែលមនុស្សម្នាក់ៗនឹងទទួលសញ្ញានោះ

វាមិនមែនគ្រាន់តែជាសារសំខាន់នៃថ្ងៃ ប៉ុណ្ណោះទេ។

វាគឺជាសារសំខាន់នៃម្ចាស់



165

(ព្រះគម្ពីរ រ៉ូម ៦:១៦)

លោកប៉ុលបានសរសេរថា “តើអ្នក រាល់គ្នាមិនដឹងទេឬអី ថាអ្នករាល់គ្នា ប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្ដាប់ តាមចៅហ្វាយណា



166

នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះឯង ដែលអ្នកស្ដាប់តាម ទោះជារបស់ផងអំពើ បាបឱ្យបានសេចក្ដីស្លាប់



167

ឬជារបស់ផងសេចក្ដីស្ដាប់បង្គាប់ឱ្យបាន សុចរិត?”

រ៉ូម ៦:១៦




168

ពេលវេលាដ៏ធំធេងបំផុតមួយនឹងត្រូវប្រ ឈមចំពោះមនុស្សគ្រប់គ្នា នៅលើផែនដី នេះ នៅពេលឆាប់ៗនេះ។

គ្មានអ្នកណាម្នាក់អាចទិញឬលក់អ្វីឡើយ ចំពោះអ្នកដែលមិនមានសញ្ញារបស់សត្វនោះ។



169

ដំបូងការមិនព្រមទិញយក ឬលក់ឱ្យ បន្ទាប់មកមានច្បាប់នៃការស្លាប់។

ហើយចំពោះអ្នកដែលទទួលសញ្ញារបស់ សត្វនោះ គឺការវេទនាចុងក្រោយទាំងប្រាំពីរ។

តើលោកអ្នកឃើញទេ ថាតើហេតុអ្វី បានជាវាជារឿងសំខាន់ស្លាប់រស់ដូច្នេះ?

តើហេតុអ្វីបានជាវាសំខាន់ស្មើនឹងអាយុជីវិត ដែលយើងត្រូវតែជ្រើសរើសយកព្រះនៅពេលឥឡូវនេះ?

# ១៨. សញ្ញាដ៏នៅអស់កល្ប


170

មានដំណឹងល្អចំពោះអ្នកដែលជ្រើស រើស សរសើរដំកើងព្រះ និងទទួលត្រា របស់ទ្រង់។


171

(ព្រះគម្ពីរ អេសាយ ៣៣:១៦)

ពួកគេមិនអាចទិញ ឬលក់របស់អ្វី បានឡើយ តែព្រះមានបន្ទូលថា

"ឯអាហារនឹងបានប្រទានមកអ្នកនោះ ហើយទឹករបស់អ្នកនោះនឹងចេះតែមាននៅ"

អេសាយ ៣៣:១៦។


172

(ព្រះគម្ពីរ ទំនុកដំកើង ៩១:៥_៨)

ហើយទាក់ទងទៅនឹងការវេទនាដែល នឹងត្រូវចាក់មកលើផែនដី ព្រះទ្រង់សន្យាថា

"ឯងនឹងមិនភ័យខ្លាចអ្វីឡើយ ទោះជា សេចក្តីស្ញែងខ្លាចនៅពេលយប់ ឬព្រួញ ដែលហើរនៅពេលថ្ងៃ


173

ឬសេចក្តីវេទនា ដែលមាននៅក្នុងទីងងឹត ឬសេចក្តីវិនាសដែលបំផ្លាញនៅពេលថ្ងៃត្រង់ផង


174

នឹងមានមនុស្ស១ពាន់នាក់ដួលស្លាប់នៅ ក្បែរឯង ហើយ១ម៉ឺននាក់នៅខាងដៃស្តាំឯង ដែរ តែសេចក្តីនោះនឹងមិនមកជិតឯងឡើយ


175

ឯងនឹងបានក្រឡេក

ឃើញការតបស្នង

ដល់ពួកមនុស្សអាក្រក់ ដោយភ្នែកតែប៉ុណ្ណោះទេ"

ទំនុកដំកើង ៩១:៥_៨

ហើយប្រសិនបើលោក

អ្នកនៅតែឆ្ងល់ថា តើនឹងមានអ្វីកើតឡើងនោះ ព្រះគម្ពីរនិយាយថា


176

(ព្រះគម្ពីរ ទំនុកដំកើង ៩១:៩_១១)

"ពីព្រោះឯងបានថា ព្រះយេហូវ៉ាជា ទីពឹងជ្រកដល់ឯង គឺបានយកព្រះដ៏ខ្ពស់

បំផុតជាទីលំនៅដល់ឯង

# ១៨. សញ្ញាដ៏នៅអស់កល្ប


177

យ៉ាងនោះនឹងគ្មានសេចក្តីអាក្រក់ណាកើតមានដល់ឯងឡើយ ក៏គ្មានវេទនាណាមកជិតលំនៅរបស់ឯងដែរ


178

ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ពីដំណើររបស់ឯង ឱ្យបានថែរក្សាឯង ក្នុងគ្រប់ទាំងផ្លូវរបស់ឯង"
ទំនុកដំកើង ៩១:៩-១១។
ប៉ុន្តែព្រះបានប្រទានសេចក្តីសន្យាដ៏ល្អ ដល់អ្នកដែលជ្រើសរើសដើរតាមទ្រង់:


179

(ព្រះគម្ពីរ ដានីយ៉ែល ១២:១)
"នៅគ្រាចុងក្រោយ មហាទេវតា មីកែល ដែលជាមេដឹកនាំសំខាន់របស់ពួក ទេវតា ហើយជាអ្នកថែរក្សាប្រជាជនរបស់ លោកនឹងក្រោកឈរឡើង


180

គ្រានោះ នឹងមានទុក្ខលំបាកយ៉ាងខ្លាំង គឺតាំងពីពេលកើតមានប្រជាជាតិ រហូត ដល់សព្វថ្ងៃនេះ


181

មនុស្សលោកមិនដែលរងទុក្ខលំបាក ដូច្នេះទេ ប៉ុន្តែនៅគ្រានោះ ក្នុងចំណោម ប្រជាជនរបស់លោក អ្នកដែលមានឈ្មោះ កត់ទុកក្នុងបញ្ជីជីវិត នឹងត្រូវរួចខ្លួន" ដានីយ៉ែល ១២:១ (ព្រះគម្ពីរភាសាខ្មែរសម្រាយ)។
លោកយ៉ូហានត្រូវបានបង្ហាញនូវការ ជាក់ស្តែងមួយ អំពីអ្នកដែលបានជ័យជំនះ លើសត្វនោះ:


182

(ព្រះគម្ពីរ វិវរណៈ ១៥:២)
"រួចខ្ញុំមើលទៅឃើញដូចជាសមុទ្រកែវ លាយនឹងភ្លើង ហើយពួកអ្នកដែលបានឈ្នះ សត្វនោះ


183

និងរូបវា ហើយលេខ ឈ្មោះវាផង

# ១៨. សញ្ញាដ៏នៅអស់កល្ប



184

គេឈរលើសមុទ្រនោះ ទាំងកាន់ស៊ុងរបស់ ព្រះគ្រប់គ្នា”

វិវរណៈ ១៥:២

សូម្បីតែឥឡូវនេះក៏ដោយ ព្រះកំពុង

អង្វរដល់អ្នកដែលដើរតាមទ្រង់ដោយស្មោះ ឱ្យងាកចេញពីប្រព័ន្ធ សាសនាក្លែង ក្លាយ

មកដើរតាមទ្រង់ឱ្យបានពេញលេញ វិញ។



185

(ព្រះគម្ពីរ វិវរណៈ ១៨:៤)

“រាស្ត្រអញអើយ ចូរចេញពីទីក្រុងនោះ មក ដើម្បីកុំឱ្យមានចំណែកក្នុងអំពើបាប វាឡើយ



186

ក្រែងត្រូវវេទនាដូចជាវាដែរ”

វិវរណៈ ១៨:៤។



187

វាមានតម្លៃក្នុងការជ្រើសរើសដើរតាម

ព្រះ។ លោកអ្នកចាំទេជនជាតិហេព្រើរ បីនាក់ ដែលបានឈរយ៉ាងមាំនៅខាងព្រះ ដោយក្លាហាន

ទោះបីជាត្រូវប្រឈមមុខ ទល់នឹងសេចក្តីស្លាប់ក៏ដោយ ក៏មិនបានបង្អែ បង្អង់ បន្តិចជាមួយអ្នកដទៃដែរ

គេឈរនៅ យ៉ាងមាំនៅខាងព្រះ។

តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ព្រះកំពុងបានមានព្រះបន្ទូលទៅកាន់លោកអ្នក

ដោយការប្រជុំនេះ។ ទ្រង់កំពុងតែធ្វើការ អំពាវនាវចុងក្រោយបង្អស់ ទៅកាន់ពិភព

លោកដែលនឹងត្រូវស្លាប់នេះ ដើម្បីរៀបចំខ្លួន សម្រាប់ការយាងមកជា

លើកទីពីរនៃព្រះរាជបុត្រារបស់ទ្រង់។

ទ្រង់នឹងយាងមកយកទៅឯតំណាក់ជា មួយទ្រង់ នូវអស់អ្នកណាដែលកែប្រែចិត្ត

ជ្រើសរើសដើរតាមទ្រង់អស់ពីចិត្ត។ តើ

លោកអ្នកមិនចង់ធ្វើដូចជនជាតិហេព្រើរទាំងបីនាក់ដោយក្រោកឈរឡើងដើម្បីព្រះ និង សេចក្តី

ពិតរបស់ទ្រង់នៅយប់នេះទេឬអី?

# ១៨. សញ្ញាដ៏នៅអស់កល្ប


188

វាមានតម្លៃក្នុងការជ្រើសរើសដើរតាម ព្រះ។ លោកអ្នកចាំទេ ជនជាតិហេព្រើរ បីនាក់ ដែលបានឈរយ៉ាងមាំនៅខាងព្រះ ដោយក្លាហាន ទោះបីជាត្រូវប្រឈមមុខ ទល់នឹងសេចក្ដីស្លាប់ក៏ដោយក៏មិនបាន បង្អែបង្អង់ ធ្វើឱ្យសមជាមួយអ្នកដទៃដែរ។

តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ព្រះកំពុងបានមានព្រះបន្ទូលទៅកាន់លោកអ្នក ដោយអង្គប្រជុំនេះ។ ទ្រង់កំពុងតែធ្វើការ អំពាវនាវចុងក្រោយបង្អស់ ទៅកាន់ពិភពលោកដែលនឹងត្រូវស្លាប់ ដើម្បីរៀបចំខ្លួន សម្រាប់ការយាងមកជាលើកទីពីរនៃព្រះរាជបុត្រារបស់ទ្រង់។

ទ្រង់នឹងយាងមកយកទៅឯតំណាក់ជា មួយទ្រង់ នូវអស់អ្នកណាដែលកែប្រែចិត្ត ជ្រើសរើសដើរតាមទ្រង់អស់ពីចិត្ត។ តើ លោកអ្នកមិនចង់ធ្វើដូចជនជាតិហេព្រើរទាំងបីនាក់ ដោយក្រោកឈរឡើងដើម្បីព្រះ និងសេចក្ដី ពិតរបស់ទ្រង់នៅយប់នេះទេឬអី?

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត



1

របៀបដឹងច្បាស់ថាប្រាក់កាសរបស់អ្នកមានសុវត្ថិភាពហើយ


2

ព្រះយេស៊ូវបានមានព្រះបន្ទូលអំពីរឿងដ៏ធំមួយទាក់ទងទៅនឹងប្រាក់កាស។

ការប្រៀបធៀបរបស់ព្រះអង្គ ៣៨ ដែលទាក់ទងទៅនឹងការគ្រប់គ្រងប្រាក់កាស និងទ្រព្យសម្បត្តិ។

នៅក្នុងដំណឹងល្អទាំងបួននៃ គម្ពីរ ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន មានរឿងដ៏អស្ចារ្យដែលរាល់ដប់ ១០ ភាគរយនៃព្រះគម្ពីរនោះ ឬទាំងអស់២៨៨ខ ទាក់ទងយ៉ាងចំទៅនឹងប្រធានបទនៃប្រាក់ កាស និងទ្រព្យសម្បត្តិនេះ។

មានប្រហែល ៥០០ខ នៅក្នុងព្រះគម្ពីរ ស្តីអំពីការអធិស្ឋាន ៥០០ទៀត អំពីសេចក្តី ជំនឿ ប៉ុន្តែមានច្រើនរហូតដល់២០០០ខ ស្តីអំពីប្រាក់កាស និងទ្រព្យសម្បត្តិ។

ប្រាក់កាស គឺជាប្រធានបទដ៏ធំរបស់ព្រះ។

ទ្រង់មិនចង់ឱ្យយើងខ្វាយខ្វល់អំពីវាទេ។

ទ្រង់ចង់ឱ្យយើងទុកចិត្តដល់ទ្រង់ ដើម្បីឱ្យទ្រង់ផ្តល់ដល់យើងនូវអ្វីៗដែលយើងត្រូវការ។


3

មនុស្សជាច្រើននាក់ ចំណាយពេលជាច្រើនព្រួយបារម្ភអំពីបញ្ហាប្រាក់កាសនេះ-

អំពីការចំណាយទៅលើរបស់ ដែលគេចង់បាន និងត្រូវការ។

គេក៏ខ្វាយខ្វល់អំពីអនាគតដែរ។


4

តើពួកគេមានគ្រប់គ្រាន់ដើម្បីរស់នៅ នៅពេលគេចូលនិវត្តឬទេ?

តើនឹងទៅជាយ៉ាងណា នៅពេលដែលគេកាន់តែចាស់ទៅ ឬឈឺធ្ងន់ មិនអាចធ្វើការទៀតកើតនោះ?

មនុស្សកំពុងស្វែងរកនូវអ្វីដែលនឹងធន់ ឬស្ថិតស្ថេរ។

ប៉ុន្តែ តើយើងអាចរកបាននូវសុវត្ថិភាព សម្រាប់ពេលបច្ចុប្បន្ន និងអនាគតនេះបាននៅឯណា?


5

ព្រះមិនដែលមានព្រះទ័យចង់ឱ្យយើងខ្វល់ខ្វាយអំពីបច្ចុប្បន្ន និងអនាគតនេះឡើយ។

ប្រសិនបើយើងទុកចិត្តលើទ្រង់

យើងនឹងមិនត្រូវខ្វល់ខ្វាយអំពីអ្វីដែលនឹងកើតឡើងដល់យើងនោះឡើយ។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


6

(ព្រះគម្ពីរ ម៉ាថាយ ៦:៣១,៣២)

“ដូច្នេះកុំឱ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ


7

“...ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ
ថាអ្នកអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះ ដែរ”
ម៉ាថាយ ៦:៣១,៣២។
សូមយើងពិនិត្យមើលផែនការដ៏អស់កល្បរបស់ព្រះសម្រាប់យើង។


8

វាបានចាប់ផ្តើមតាំងពីសួនច្បារអេដែនមក។


9

ពិភពផែនដីទើបតែចេញពីស្នាព្រះហស្ត
របស់ព្រះ ដែលជាអ្នកបង្កើតលោកីយ៍មក ក្នុងភាពរុងរឿង គ្រប់លក្ខណ៍ និងមានសិរី ល្អរបស់ខ្លួន
ដែលមិនអាចពណ៌នាបាន។


10

ស្នាមជក់របស់វិចិត្រករដ៏ចំណានម្នាក់ បានទាក់ទាញ ក្រសែភ្នែករបស់មនុស្ស ឱ្យចាប់ចិត្តគ្រប់
ជ្រុងជ្រោយ។
ភាពស្រស់ឆើតឆាយដ៏សំបើមអស្ចារ្យ នៃអរុណោទ័យ ដែលគ្មានអ្វីផ្ទឹមស្មើបាន
មានតែអស្តង្គតកាលប៉ុណ្ណោះ ដែលអាចមានសម្រស់ប្រហាក់ប្រហែលគ្នា។


11

ទន្លេដ៏ស្ងាត់ជ្រងំយ៉ាងស្ងប់ស្ងួល ដូចសត្វក្នុងសំបុក នៅចន្លោះទួលទាំងឡាយ។


12

ផ្កាដ៏ល្អអស្ចារ្យដែលមានពណ៌ចម្រុះគ្នា រីកស្គុសស្គាយ គួរជាទីរីករាយក្រៃលែង
ដល់វិញ្ញាណទាំងអស់របស់មនុស្សគ្រប់គ្នា។

# ១៩_វិនិយោគទុនមួយដែលមិនចេះខាត



13

ដើមឈើទាំងឡាយជ្រុះគ្រាប់ ដែលមានផ្លែយ៉ាងឆ្ងាញ់ពិសាគ្រប់មុខ។



14

បក្សាបក្សីអឹងកង ពាសពេញអាកាស ជាមួយនឹងសំឡេងច្រៀងភ្លៀវភ្លាដ៏ពិរោះរណ្ដំរបស់វា។

សត្វចតុប្បាទទាំងឡាយកំពុងលេងនៅក្នុងវាលស្មៅដ៏ត្រសុំត្រសាយ

ហើយដើរចំប្រប់ដោយគ្មានខ្លាចអ្វីឡើយ។

ទន្លេបឹងបួរទាំងឡាយពោរពេញទៅដោយ

មច្ឆជាតិចម្រុះពណ៌។

គឺជាពិភពលោកដ៏អស្ចារ្យ លាតសន្ធឹងពីប៉ូលម្ខាងទៅប៉ូលម្ខាង!



15

អ័ដាមនិងនាងអេវ៉ា បានរីករាយនឹងពិភពលោកដ៏ល្អឥតខ្ចោះ ដែលព្រះបានបង្កើតឱ្យពួកគេ។



16

(ព្រះគម្ពីរ លោកុប្បត្តិ ២:៨)

ប៉ុន្តែមានលើសពីនេះទៅទៀត រួចព្រះយេហូវ៉ា ដ៏ជាព្រះ ទ្រង់ធ្វើសួន ច្បារ១... ក៏ដាក់មនុស្សដែលទ្រង់សូនធ្វើ ឱ្យនៅទីនោះ” លោកុប្បត្តិ ២:៨។



17

សូមគិតមើលបន្តិច នៅត្រង់កន្លែងមួយនៃ ពិភពលោកថ្មីដ៏អស្ចារ្យ និងស្រស់ប្រិមប្រិយ៍ នេះ ព្រះបានរៀបចំសួនច្បារពិសេសមួយ ជាលំនៅសម្រាប់អ័ដាមនិងនាងអេវ៉ា។



18

គេហដ្ឋាននៅលើផែនដីនេះ ទោះជាល្អ

ប្រណិតបំផុតយ៉ាងណាក៏ដោយ ក៏មិនអាច

ផ្ដើមប្រៀបផ្ទឹម បានទៅនឹងគេហដ្ឋានដើម ដំបូងរបស់ពិភពលោកនេះ នៅក្នុងសួនច្បារនោះឡើយ។

ព្រះមិនមែនគ្រាន់តែបានប្រទានលំនៅដ៏ជាទី

ស្រឡាញ់ដល់ពួកគេទេ ទ្រង់ក៏បានពន្យល់ អំពីចំណីអាហារដ៏ល្អ ដែលទ្រង់បាន ប្រទានឱ្យគេផងដែរ។

# ១៩. វិនិយោគទុនមួយដែលមិនចេះខាត



19

ព្រះគម្ពីរ លោកុប្បត្តិ ១:២៩)

"...មើលអញឱ្យគ្រប់ទាំងតិណជាតិ មានគ្រាប់ពូជដែលដុះនៅផែនដី



20

និងគ្រប់ទាំងរុក្ខជាតិទាំងឡាយ ដែលកើតផ្លែមានគ្រាប់ពូជ ទុកជាអាហារដល់ឯង

លោកុប្បត្តិ ១:១៩។



21

អ័ដាមនិងអេវ៉ា មិនចាំបាច់បង់ថ្លៃឈ្នួល ផ្ទះឡើយ មិនបាច់ខ្វល់ខ្វាយពីការបង់ពន្ធ ឡើយ

មិនចាំបាច់មានសោឡើយ គ្មានអ្នកបំផ្លាញ ឬចោរចូលលួចឡើយ គ្មានមន្ទីរពេទ្យ

ឬកន្លែងលក់ថ្នាំពេទ្យឡើយ។



22

គេមានការរីករាយនឹងសុខភាពដ៏ល្អឥតទាស់ និងយុវវ័យដែលមិនចេះចប់របស់គេ

ការប្តេជ្ញាចិត្តជាមួយ គ្នាទៅវិញទៅមក ដែលមិនចេះរលប់បាត់បង់មួយ និង

ចំណងនៃសេចក្តីស្រឡាញ់ដ៏គ្មាន ព្រំដែន របស់គេចំពោះព្រះ។

ព្រះចង់ឱ្យពួកគេចែកចាយព្រះពរនេះ ទើបទ្រង់បានមានព្រះបន្ទូលថា



23

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៨)

"ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យមានពេញពាសលើផែនដីចុះ..."

លោកុប្បត្តិ ១:២៨



24

យើងជាអ្នកថែរក្សានូវទ្រព្យសម្បត្តិរបស់ព្រះ



25

វាគឺជាការរៀបចំរបស់ព្រះ ដើម្បីឱ្យ គ្រួសារដ៏ធំនិងរីករាយមួយ រស់នៅលើភព ផែនដីនេះ។

ព្រះក៏ទ្រង់ជ្រាបផងដែរថា មនុស្សត្រូវ ការធ្វើការងារ ដែលគេនឹងរីករាយ ក្នុងការ

បំពេញការងារទាំងនោះ។

# ១៩. វិនិយោគទុនមួយដែលមិនចេះខាត


26

(ព្រះគម្ពីរ លោកុប្បត្តិ ១:២៨)

ដូច្នោះទ្រង់ក៏មានព្រះបន្ទូលប្រាប់ដល់

អ័ដាមនិងអេវ៉ាថា "...ហើយមានអំណាច លើត្រីសមុទ្រ សត្វហើរ លើអាកាស


27

និងជីវិតផងទាំងឡាយដែលកំរើកនៅផែន

ដីផង...


28

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៥)

"ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់យកអ័ដាម ទៅដាក់នៅក្នុងសួនច្បារអេដែន ឱ្យគាត់ធ្វើការ

ហើយថែរក្សា"

លោកុប្បត្តិ ២:១៥


29

នៅពេលដែលអ្វីៗទាំងអស់នៅលើពិភពលោកនេះជារបស់ព្រះនោះ ទ្រង់បានបន្ទុក

បណ្តាក់ដល់មនុស្ស នូវការថែរក្សាផែនដីនេះ។

ព្រះគឺជាម្ចាស់ យើងទាំងអស់គ្នាជាអ្នកថែរក្សា គ្រប់គ្រងទ្រព្យសម្បត្តិរបស់ព្រះ។


30

(ព្រះគម្ពីរ ទំនុកដំកើង ២៤:១)

ព្រះគម្ពីរនិយាយថា "ផែនដី និងសារពើ នៅផែនដី ជារបស់ផងព្រះយេហូវ៉ា ព្រម ទាំងលោកីយ៍

និងបណ្តាអ្នកដែលនៅ លោកីយ៍ផង"

ទំនុកដំកើង ២៤:១។


31

(ព្រះគម្ពីរ ទំនុកដំកើង ៥០:១០,១១)

ព្រះបានមានព្រះបន្ទូលម្តងទៀតថា "ដ្បិតអស់ទាំងសត្វនៅព្រៃ សុទ្ធ តែរបស់ អញ

ព្រមទាំងហ្វូងសត្វទាំងប៉ុន្មាន នៅលើ ភ្នំទាំងពាន់ផង


32

អញស្គាល់អស់ទាំងសត្វស្លាបនៅលើភ្នំ ហើយសត្វព្រៃទាំងឡាយជារបស់ផងអញដែរ"

ទំនុកដំកើង ៥០:១០,១១

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត



33

គឺជាព្រះដែលប្រទានលទ្ធភាពដល់យើងដើម្បីរកប្រាក់កាស។

យើងពិតជាមិនមែនជាម្ចាស់លើអ្វីទាំងអស់

ឡើយ!

ក្នុងនាមជាអ្នកបង្កើតយើង ព្រះបានទាម ទារទ្រព្យសម្បត្តិទាំងអស់របស់យើង និង

ជីវិតរបស់យើងផង



34

(ព្រះគម្ពីរ ចោទិយកថា ៨:១៨)

"ត្រូវឱ្យនឹកពីព្រះយេហូវ៉ា ជាព្រះនៃឯង វិញ ដ្បិតគឺទ្រង់ហើយ ដែលប្រទានឱ្យ ឯងមានឥទ្ធិឫទ្ធិឱ្យ

បានទ្រព្យសម្បត្តិ



35

ដើម្បីនឹងបញ្ជាក់សេចក្តីសញ្ញា ដែលទ្រង់ បានស្បថនឹងពួកឰយុកោឯង ដូចជាមាន សព្វថ្ងៃនេះ"

ចោទិយកថា ៨:១៨។



36

វចនានុក្រមខ្មែរ បានបញ្ជាក់ន័យរបស់ ពាក្យថែរក្សាថា

"ថែ = គ្រប់គ្រង"

"រក្សា= កាន់កាប់"

ដូច្នេះ "អ្នកថែរក្សា" មានន័យថា "អ្នកគ្រប់គ្រង កាន់កាប់" ថវិកា

និងទ្រព្យសម្បត្តិរបស់អ្នកណាម្នាក់ទៀត។

សព្វថ្ងៃនេះ នៅពេលដែលមនុស្សម្នាក់ចូល ទៅក្នុងទំនាក់ទំនងនៃភាពជាអ្នកថែរក្សា គេ ចង់ដឹងថា

តើម្ចាស់នោះ ចង់ឱ្យគេធ្វើអ្វី។

នេះហើយគឺជាព្រះដ៏ទ្រង់ជ្រាប បាន ប្រទានឱ្យអ័ដាម ដូចដែលព្រះគម្ពីរបាន ចែងថា



37

(ព្រះគម្ពីរ លោកុប្បត្តិ ២:១៦,១៧)

"ឯងនឹងស៊ីផ្លែឈើទាំងអស់នៅក្នុងសួន

ច្បារនេះបានតាមចិត្ត



38

តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឱ្យ

ឯងស៊ីផលឡើយ

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត



39

ដ្បិតនៅថ្ងៃណាដែលឯងស៊ីនោះនឹងត្រូវស្លាប់ ជាមិនខាន”
លោកុប្បត្តិ ២:១៦,១៧



40

(វីដេអូ ២០វិនាទី)ព្រះបានសាកល្បង សេចក្តីស្រឡាញ់ និងការស្មោះត្រង់របស់ មនុស្ស។
អ័ដាមនិងអេវ៉ាអាចបរិភោគផ្លែឈើគ្រប់
ទាំងអស់នៅក្នុងសួនច្បារបាន ប៉ុន្តែ
ពួកគេមិនត្រូវបរិភោគផ្លែនៃដើមឈើមួយ។
លើសពីការស្តាប់បង្គាប់ព្រះ ពួកគេបាន បង្ហាញពីភាពជាម្ចាស់របស់ទ្រង់។
ប្រសិនបើគេជាអ្នកថែរក្សាដ៏ស្មោះត្រង់
របស់ព្រះ ពួកគេនឹងត្រូវបានរស់នៅក្នុង ពិភពលោកដែលជាស្ថានសួគ៌រៀងរហូត។
អ័ដាមនិងអេវ៉ាបានធ្លាក់ពីការសាកល្បង
យ៉ាងងាយមួយ ដែលបានដាក់ឱ្យ ដល់ ពួកគេ។
ពួកគេជាអ្នកថែរក្សាមិនស្មោះត្រង់ ហើយពួកគេបានត្រូវបាត់បង់នូវអ្វីៗទាំងអស់
លំនៅនៅក្នុងសួនច្បារ ភាពមិនចេះស្លាប់ សេចក្តីស្រឡាញ់ ការសប្បាយរីករាយ សន្តិសុខ សម្បជ្ជញ្ញៈ
ហើយការដើរ ជា មួយនឹងព្រះ និងការនិយាយទល់មុខ
ជាមួយទ្រង់!


41

ពួកគេបានធ្លាក់ពីត្រកូលក្សត្រ ទៅទាសករ។
ហើយមូលហេតុនោះបណ្តាលមកពី
សាតាំង ទេវតាអាក្រក់ ដែលបានសង្ឃឹមថា នឹងបានគ្រប់គ្រងលើផែនដីនេះ រៀងរហូត។


42

ទោះបីជាយ៉ាងណាក៏ដោយ ការគ្រប់គ្រង របស់សាតាំង ត្រូវបានខ្ទាត់ខ្ទាយ ដោយសារ ការយាងមក
របស់ព្រះគ្រីស្ទ មកកាន់ផែន ដីនេះ នៅរាប់សតវត្សរ៍ក្រោយមក។


43

ផែនការរបស់សាតាំង គឺបញ្ឆោតព្រះរាជ បុត្រាពីស្ថានសួគ៌របស់ព្រះ ឱ្យងាយដូចដែល
វាបានបញ្ឆោតដល់ អ័ដាមនិងអេវ៉ា ដូច្នោះដែរ។
សាតាំងបានចាំរហូតដល់ព្រះយេស៊ូវបាន
តមអាហារអស់ពេល៤០ថ្ងៃ។

# ១៩_វិនិយោគទុនមួយដែលមិនចេះខាត



44

(ព្រះគម្ពីរ ម៉ាថាយ ៤:៨,៩)

(វីដេអូ ៨វិនាទី) ហើយវាបាននាំទ្រង់ឡើងទៅ

លើកំពូលភ្នំយ៉ាងខ្ពស់



45

ក៏បង្ហាញអស់ទាំងនគរក្នុងលោកីយ៍...



46

រួចទូលថា "បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះខ្ញុំនឹងឱ្យរបស់ទាំងនេះដល់អ្នក"

ម៉ាថាយ ៤:៨,៩។



47

សាតាំងបានសង្ឃឹមថា នឹងល្បួងព្រះ យេស៊ូវ ដោយសារនគរនៅលើផែនដីនេះ

ប៉ុន្តែវាមិនបានជោគជ័យឡើយ។ "របស់" ដែលសាតាំងបានសន្យាថា នឹងឱ្យដល់ព្រះ យេស៊ូវនោះ

មិនមែនជារបស់ដែលវាត្រូវ ថ្វាយទៅទ្រង់នោះឡើយ!

វាបានលួចយកភពមួយនេះដោយការ បន្លំនិងបោកបញ្ឆោត។

ហើយព្រះយេស៊ូវមិនបានប្តូរទំនាក់ទំនង របស់ទ្រង់ជាមួយនឹងព្រះវរបិតាជាមួយនឹង

ទ្រព្យសម្បត្តិទាំងអស់នៅ លើពិភពលោក នេះ និងរបស់ដែលគ្រាន់តែគ្មានតម្លៃនោះ ឡើយ។



48

ទីបំផុត វាសនារបស់សាតាំងត្រូវបញ្ចប់ ជារៀងរហូតនៅភ្នំរលាក្បាល(កាល់វ៉ារី)។

ដោយសារការសុគត របស់ព្រះគ្រីស្ទ នៅលើឈើឆ្កាង សាតាំងត្រូវបានបរាជ័យ!

ការសុគតរបស់ព្រះគ្រីស្ទ បានធ្វើឱ្យ ផែនដីនេះ មានលទ្ធភាព អាចនឹងស្តាបនា ជាថ្មីឡើងវិញបាន។



49

របស់សព្វសារពើដែលយើងនៅ និង យើងមាន ត្រូវបានធ្វើឱ្យមានលទ្ធភាព

ដោយសារអំណោយទាន ដ៏អស់កល្បរបស់ ព្រះគ្រីស្ទ ដល់គ្រួសាររបស់មនុស្ស។

ទោះបីជាយើងស្រឡាញ់ទ្រង់ឬអត់

ក៏ដោយ ជីវិតទាំងស្រុង និងទ្រព្យសម្បត្តិ ទាំងអស់ របស់យើង គឺជារបស់ទ្រង់។



50

ព្រះអង្គមិនមែនគ្រាន់តែជាព្រះដែលបាន

បង្កើតយើងមកប៉ុណ្ណោះទេ តែទ្រង់គឺជាអ្នក ប្រោសលោះយើងទៀតផង!

ហើយដូចជាអ័ដាមនិងអេវ៉ាដូច្នោះដែរ យើងជាអ្នកថែរក្សារបស់ព្រះទាំងអស់ ដែល

ទ្រង់បានប្រទានដល់យើង។ ដូច្នេះតើទ្រង់ តម្រូវអ្វីពីយើងវិញ?

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


51

(ព្រះគម្ពីរ កូរិនថូសទី១ ៤:២)

"រីឯអ្នករ៉ាប់រង ត្រូវឱ្យគេបានស្មោះត្រង់"

កូរិនថូសទី១ ៤:២


52

យើងជាអ្នកថែរក្សាជីវិត ដែលជាអំណោយទានរបស់ព្រះ

អំណោយទានដ៏ធំបំផុត របស់ព្រះនោះ គឺជាជីវិតនោះឯង។

លោកសាវកប៉ុលអះអាងថា:


53

(ព្រះគម្ពីរ កិច្ចការ ១៧:២៤,២៥)

"ដ្បិតព្រះដែលបង្កើតលោកីយ៍ និងរបស់ សព្វសារពើ...


54

ឱ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ ជំពូក"

កិច្ចការ ១៧:២៤,២៥។


55

ជីវិតរបស់យើងមានប្រភពដើមជាមួយនឹងព្រះ ហើយទ្រង់ទ្រទ្រង់វា។

រាល់ចង្វាក់បេះដូង រាល់ដង្ហើមចេញចូល រាល់ចលនាជីពចរ នៃរាងកាយយើង

គឺជាអំណោយទានរបស់ព្រះ ទាំងអស់។


56

(ព្រះគម្ពីរ រ៉ូម ១២:១)

លោកប៉ុលបានសរសេរថា "ដូច្នេះបង ប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយ

សេចក្ដីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូប កាយទុកជាយញ្ញបូជារស់


57

ហើយបរិសុទ្ធដែលគាប់ព្រះហឫទ័យដល់ព្រះជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង"

រ៉ូម ១២:១។

"យញ្ញបូជារស់" មានន័យថា ការ ប្ដេជ្ញា ចិត្តដែលមិនសំចៃទុក ឬការចុះចូល

ទាំងស្រុងចំពោះព្រះគ្រីស្ទ និងការរបស់ ទ្រង់ក្នុងជីវិតរបស់យើង។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


58

(ព្រះគម្ពីរ កិច្ចការ ១០:៣៨)

ព្រះគ្រីស្ទ "បានយាងចុះឡើងធ្វើការល្អ"

កិច្ចការ ១០:៣៨


59

ទ្រង់គឺជាគំរូដល់យើងទាំងអស់គ្នា យើងត្រូវតែដើរតាមគំរូរបស់ទ្រង់ គឺការ បំរើដោយមិនកំណាញ់។


60

យើងគឺជាអ្នកថែរក្សាលើពេលវេលា ដែលព្រះបានប្រទានដល់យើង យើងមិន មែនគ្រាន់តែជាអ្នកថែរក្សាលើប្រាក់កាស ប៉ុណ្ណោះទេ យើងក៏ជាអ្នកថែរក្សាលើពេល វេលារបស់យើងដែរ។

អ្នកខ្លះបាននិយាថា "ជីវិត គឺជាពេល វេលា"

អ្នកនិពន្ធទំនុកដំកើងបានសំសូមដល់ព្រះ


61

(ព្រះគម្ពីរ ទំនុកដំកើង ៩០:១២)

"ដូច្នេះសូមបង្រៀនឱ្យយើងខ្ញុំចេះកំណត់ រាប់ថ្ងៃអាយុនៃយើងខ្ញុំ ដើម្បីឱ្យយើងខ្ញុំមាន ចិត្តខ្មីឃ្មាតឱ្យបានសតិបញ្ញា"

ទំនុកដំកើង ៩០:១២



62

(វីដេអូ ៦វិនាទី) ការខ្ជះខ្ជាយពេលវេលា គឺខ្ជះខ្ជាយជីវិត-ជាការចាយវាយខ្ជះខ្ជាយនូវ ទេពកោសល្យដែលព្រះទ្រង់បានប្រទាន មកដោយព្រះអង្គផ្ទាល់ ដល់មនុស្សប្រុស ស្រីគ្រប់គ្នានោះ។

មនុស្សគ្រប់ៗគ្នាមានពេលវេលាដូចៗគ្នា ក្នុងមួយថ្ងៃៗ ចំនួននាទីដូចគ្នានៅក្នុងម៉ោង នីមួយៗ ហើយនិងការទទួលខុសត្រូវ ក្នុង ការប្រើប្រាសពេលវេលាទាំងនោះ។



63

ព្រះរំពឹងថា យើងនឹងប្រើពេលវេលា របស់យើងយ៉ាងវាងវៃ ដោយការត្រិះរិះពិចារណាឱ្យបានម៉ត់ចត់។ ហើយទ្រង់ក៏បាន រំពឹងឱ្យយើងញែកពេលវេលាជាក់លាក់មួយ គឺថ្ងៃបរិសុទ្ធ ថ្ងៃទីប្រាំពីរនៃសប្តាហ៍ ក្នុង ន័យនៃការបញ្ចេញសេចក្តីជំនឿរបស់យើង ចំពោះទ្រង់ជាព្រះដែលបានបង្កើតយើង មក។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


64

កាលណាពេលវេលារបស់យើងជារបស់ ព្រះនោះ ទ្រង់សូមឱ្យយើងបូជា ថ្ងៃបរិសុទ្ធ ថ្ងៃទី ប្រាំពីរ ដើម្បីប្រកបជាមួយ នឹងទ្រង់ សម្រាកនៅក្នុងព្រះបន្ទូលទ្រង់ ហើយនិង ទាញយកនូវការសម្រាកពីសេចក្តី សន្យា របស់ទ្រង់។

ទ្រង់អញ្ជើញយើងឱ្យញែកចេញនូវ សកម្មភាពការងារប្រចាំសប្តាហ៍ លក់ដូរ ឥវ៉ាន់ និងសកម្មភាពលោកីយ៍ ហើយនឹក ចាំពីទ្រង់ជាព្រះអង្គសង្គ្រោះ និងជាព្រះ ដ៏ប្រោសលោះរបស់យើង។


65

យើងជាអ្នកថែរក្សា ទេពកោសល្យ ដែលព្រះប្រទានឱ្យយើង

"មែនហើយ" លោកអ្នកសួរ "តើអ្វីទៅដែល ជាទេពកោសល្យជាក់លាក់ ដែលយើង ទទួលខុសត្រូវជាអ្នកថែរក្សារបស់ ព្រះ នោះ? ខ្ញុំគិតថា ខ្ញុំគ្មានទេពកោសល្យអ្វី ទាំងអស់"


66

សព្វថ្ងៃនេះពាក្យថា ទេពកោសល្យមាន ន័យថា ច្រៀងបានពិរោះ លេងតន្ត្រី គូរគំនូរ កាត់ដេរសំលៀកបំពាក់ សរសេរ រៀបចំ បានល្អ


67

ទាំងនេះហើយគឺជាទេពកោសល្យដែល យើងអាចប្រើ ប៉ុន្តែទេពកោសល្យដែលព្រះ មាននៅក្នុងព្រះទ័យ មិនបានកំណត់ចំពោះ តែទេព កោសល្យទាំងប៉ុន្មានខាងលើនេះ ប៉ុណ្ណោះទេ។

ជាអ្នកថែរក្សារបស់ព្រះ យើងទទួល ខុសត្រូវចំពោះអ្វីៗទាំងអស់ ដែលទ្រង់បាន ប្រទានដល់យើង រាប់បញ្ចូលទាំងជីវិត ពេលវេលា លទ្ធភាពនិងទ្រព្យសម្បត្តិផង។

ថ្ងៃណាមួយព្រះនឹងសួរយើងថា តើ យើងនឹងខំស្វែងរកតែទ្រព្យសម្បត្តិផ្ទាល់ខ្លួន ស្វែងរកឱ្យបានស្កប់ស្កល់នូវ អ្វីៗដែលយើង ចង់បាន និងសេចក្តីសប្បាយផ្ទាល់ខ្លួន ផ្ទុក ជួយដល់អ្នកដទៃវិញ!

ព្រះយេស៊ូវបានមានព្រះបន្ទូលថា "ចូរមកតាមខ្ញុំ" ទ្រង់បានរស់នៅគ្មានភាព អាត្មានិយមឡើយ។


68

(ព្រះគម្ពីរ កិច្ចការ ១០:៣៨)

ព្រះគម្ពីរនិយាយថា ព្រះយេស៊ូវគឺជា ព្រះមួយអង្គដែល "...បានយាងចុះឡើង ធ្វើការល្អ..." កិច្ចការ ១០:៣៨។ យើង ភាគច្រើនគ្រាន់តែពេញចិត្តតែនឹង" ដើរចុះ ឡើង" តែប៉ុណ្ណោះ


69

អំណោយទានរបស់យើងមិនមែនត្រូវ ប្រើដើម្បីនឹងទទួលការសរសើរពីមនុស្ស ឬ ក៏ដើម្បីសន្សំការល្អជាមួយនឹងព្រះនោះទេ។ របស់ទាំងអស់ត្រូវបានព្រះឱ្យខ្ចីដើម្បីឱ្យពរដល់អ្នកដទៃ។

# ១៩. វិនិយោគទុនមួយដែលមិនចេះខាត


70

(ព្រះគម្ពីរ កូរិនថូសទី១ ៤:៧)

លោកប៉ុលបានសរសេរថា "...តើអ្នក មានអ្វីខ្លះដែលអ្នកមិនបានទទួល?


71

ចុះបើបានទទួលមែន ហេតុអ្វីបានជា អួតខ្លួនដូចជាមិនបានទទួលវិញ" កូរិនថូស ៤:៧។


72

យើងជាអ្នកប្រគល់ប្រាក់កាស ដែលព្រះ ប្រទានមកឱ្យយើង


73

(ព្រះគម្ពីរ ម៉ាថាយ ៦:៣៣)

ពេលដែលយើង "...ស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុន" (ម៉ាថាយ ៦:៣៣) យើងរកឃើញព្រះពរ របស់ព្រះ ដែលបានបង្ហូរមកដល់យើង។ កិច្ចការ ១០:៣៨។ មនុស្សយើងភាគច្រើន គ្រាន់តែពេញចិត្តនិង "អ្វីដែលមាន" ប៉ុណ្ណោះ


74

ក្នុងការបន្ថែមទៅលើការប្រទានពេល វេលាដល់យើង យើងរកឃើញនៅក្នុងព្រះ គម្ពីរថា ការថ្វាយទៅព្រះ រាប់ទាំងការ បង្វិលថ្វាយទ្រង់នូវចំណែក នៃព្រះពរខាង សម្ភារៈរបស់ទ្រង់ផង។



75

(វីដេអូ ១១វិនាទី)

ថ្ងៃមួយ ក្មួយរបស់អ័ប្រាហាំ ឡុតនិង គ្រួសាររបស់គាត់ ត្រូវបានចាប់ជាឈ្លើយពីផ្ទះរបស់គេនៅទីក្រុងសូដុំម ដោយពួកកុល សម្ព័ន្ធរបស់សត្រូវ។

នៅពេលដែលដំណឹងនោះបានឮទៅ ដល់លោកអ័ប្រាហាំ គាត់ក៏បានតាំងចិត្តថា នឹងរំដោះឡុត និងអ្នកដទៃទៀតមកវិញ។ គាត់បានអធិស្ឋានឱ្យព្រះគង់នៅជាមួយគាត់ ហើយប្រទានជោគជ័យដល់គាត់ ព្រះក៏បាន គង់នៅជាមួយគាត់។

ឡុត និងគ្រួសារត្រូវបានរំដោះ ហើយ ទ្រព្យសម្បត្តិជាច្រើន ត្រូវបាននាំមកជាមួយ។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


76

នៅពេលដែលអ័ប្រាហាំ មកដល់ទីក្រុង សូដុំម ស្តេចទ្រង់បានយាងមកជួបគាត់ ជំរុញឱ្យគាត់រក្សាទ្រព្យសម្បត្តិ ដែលគាត់រឹប អូសយកបាន ហើយគ្រាន់តែលែងប្រជារាស្ត្រដែលត្រូវគេចាប់ជាឈ្លើយ ឱ្យត្រឡប់ ទៅវិញប៉ុណ្ណោះ

ប៉ុន្តែអ័ប្រាហាំបដិសេធមិនព្រមយកអ្វី សម្រាប់គាត់វឡើយ។

លោកម៉ិលគីហ្សាដែក ជាសម្តេចសង្ឃ របស់ព្រះ បាននាំអាហារមកជូនអ័ប្រាហាំ មួយពេល ហើយបានឱ្យពរគាត់។



77

(ព្រះគម្ពីរ លោកុប្បត្តិ ១៤:២០)

រួចអ័ប្រាហាំ "...ក៏ថ្វាយ១ភាគក្នុង១០ ពីគ្រប់របស់ទាំងអស់ដល់ទ្រង់" លោកុប្បត្តិ ១៤:២០។


78

លោកអ័ប្រាហាំចង់បញ្ចេញការសរសើរ របស់គាត់ចំពោះព្រះដែលបានជួយគាត់ ក្នុងការការពារគាត់ ក្នុងការរំដោះឡុត ដោយការប្រកាសភាពជាម្ចាស់របស់ព្រះ និងព្រះពររបស់ទ្រង់។


79

មួយរយហាសិបឆ្នាំក្រោយមក ចៅរបស់លោកអ័ប្រាហាំបានបញ្ចេញអាកប្បកិរិយាបែបនេះរបស់គាត់ថ្វាយព្រះ។

នៅពេលដែលរត់គេចខ្លួនពីបងប្រុស ដែលមានកំហឹងរបស់គាត់ យ៉ាកុបបានចាកចេញមកដោយភ័យខ្លាច និងភ័យខ្លាចខ្លាំង មែនទែន។

គាត់ចង់បានការការពាររបស់ព្រះយ៉ាង ខ្លាំង ប៉ុន្តែគាត់ដឹងកំហុសដោយការលួច ពររបស់អេសាវបងប្រុសរបស់គាត់ គាត់ បានភ័យខ្លាចក្រែង ព្រះនឹងបោះបង់គាត់ ហើយនិងមិនអត់ទោសឱ្យគាត់។


80

ជាមួយសម្បជ្ជញ្ញៈនៃសេចក្តីស្តាយ ក្រោយ ជាខ្លាំងនោះ យ៉ាកុបបានលន់តួកំហុសរបស់គាត់ចំពោះព្រះ រួចក៏បានទ ម្រេតថ្មមៗទៅលើដី ហើយក៏លង់លក់ទៅ។



81

(ព្រះគម្ពីរ លោកុប្បត្តិ ២៨:១២,២២)

"គាត់យល់សប្តិឃើញថា មានជណ្តើរ មួយបញ្ឈរនៅលើដី មានចុងទល់នឹងមេឃ

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


82

ក៏ឃើញមានពួកទេវតារបស់ព្រះឡើងចុះតាម
ជណ្ដើរនោះ
លោកុប្បត្តិ ២៨:១២។

នៅពេលដែលយ៉ាកុបភ្ញាក់ឡើង គាត់ បានដឹងថា ព្រះបានមានបន្ទូលអំពីសេចក្ដី សន្យានៃការដឹកនាំ និងការការពារ។

នៅពេលដែលយ៉ាកុបភ្ញាក់ឡើង គាត់ បានដឹងថា ព្រះបានមានព្រះបន្ទូលសន្យាថា នឹងដឹកនាំ និងការពារគាត់។


83

ដោយការរំជួលចិត្តយ៉ាងជ្រាលជ្រៅ គាត់បានសន្យាដោយកតញ្ញូថា "...ហើយ ទូលបង្គំនឹងថ្វាយទ្រង់១ក្នុង១០ ពីគ្រប់ទាំង របស់ដែលទ្រង់ប្រទានមកទូលបង្គំ" ខ២២។


84

ស្ដេចដាវីឌមានព្រះទ័យដូចគ្នានេះដែរ នៅពេលដែលទ្រង់បានសួរសំនួរនេះ


85

(ព្រះគម្ពីរ ទំនុកដំកើង ១១៦:១២)

"តើត្រូវឱ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា ចំពោះព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំទាំង ប៉ុន្មាន?"
ទំនុកដំកើង ១១៦:១២។

តើលោកអ្នកដែលឆ្ងល់ទេថា តើត្រូវអរ ព្រះគុណដល់ព្រះយ៉ាងណា ចំពោះសេចក្ដី ល្អដែលទ្រង់បានធ្វើដល់លោកអ្នក-ចំពោះ អំណោយទាននៃជីវិត ចំពោះគ្រួសារ ចំពោះសុខភាព និងចំពោះព្រះពរខាង សម្ភារៈនេះ?

តើជូនកាលលោកអ្នកដែលឆ្ងល់ទេថា
ពាក្យថា "អរគុណ" នោះវាគ្រប់គ្រាន់ឬទេ

គោលការណ៍ព្រះគម្ពីរនៃភាពជាអ្នក ថែរក្សា ផ្តល់របៀបជាក់ស្តែងនៃការ បញ្ចេញនូវការសរសើររបស់យើង ថ្វាយ ព្រះ ចំពោះអំណោយរបស់ទ្រង់ទាំងអស់ នេះ។


86

យ៉ាកុបបាននិយាយថា គាត់នឹងថ្វាយទៅ ព្រះមួយភាគដប់ ដប់ហូតមួយ នូវអ្វី១ទាំង អស់ដែលគាត់បានទទួល ដូចជីតារបស់ គាត់ លោកអ័ប្រាហាំបានធ្វើដែរ។

# ១៩_វិនិយោគទុនមួយដែលមិនចេះខាត


87

ការសរសេរការណែនាំលើកទីមួយ ទាក់ ទងទៅនឹងការថ្វាយដង្វាយដប់ហូតមួយ ឬ ក៏បង្ហិលមួយភាគដប់ថ្វាយទៅព្រះ ត្រូវបាន កត់ត្រានៅក្នុងព្រះគម្ពីរលេវីវិន័យ។


88

(ព្រះគម្ពីរ លេវីវិន័យ ២៧:៣០)
"ហើយផលពីដី១ភាគក្នុង១០ ទោះបី ជាផលដែលកើតពីដី ឬជាផ្លែឈើ នោះ ជារបស់ផងព្រះយេហូវ៉ា


89

ហើយត្រូវតែបាន ទុកជាបរិសុទ្ធសំរាប់ទ្រង់"
លេវីវិន័យ ២៧:៣០។


90

នៅពេលដែលយើងបង្ហិលដង្វាយមួយ ភាគដប់ យើងបានស្ញើចសរសើរជាបន្ត នូវសេចក្តីពិតថា ព្រះគឺជាអ្នកបង្កើតរបស់ សព្វសារពើ និងជាប្រភពនៃអ្វីៗទាំងអស់។
ហើយតើដង្វាយដប់ហូតមួយនេះនឹងត្រូវប្រើ ប្រាស់យ៉ាងណា?


91

(ព្រះគម្ពីរ ជនគណនា ១៨:២១)
ព្រះគម្ពីរជនគណនាផ្តល់នូវការពន្យល់ យ៉ាងច្បាស់លាស់ "ឯពួកកូនចៅលេវី (អ្នកបំរើការងាររបស់ព្រះ) នោះអញបានឱ្យ អស់ទាំងដង្វាយ ដែលពួកកូនចៅអ៊ីស្រាអែលថ្វាយ១ភាគក្នុង១០ ទុកជាមរតកដល់ គេហើយ


92

ដើម្បីឱ្យបានជាកំរៃនៃការងារដែលគេ ធ្វើ គឺជាក្រសួងការរបស់ត្រសាលជំនុំ"
ជនគណនា ១៨:២១។


93

ក្នុងព្រះគម្ពីរទាំងមូល យើងតែងតែ ឃើញថា ដង្វាយដប់ហូតមួយនេះ តែងតែ ប្រើដើម្បីឧបត្ថម្ភការងាររបស់ព្រះ។

១៩_វិនិយោគទុនមួយដែលមិនចេះខាត

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


94

(ព្រះគម្ពីរ កូរិនថូសទី១ ៩:១៣,១៤)

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោកប៉ុល បានពន្យល់ថា "តើមិនដឹងទេឬអីថា ពួកអ្នកដែលធ្វើការព្រះគេបរិភោគ ដោយសារ ព្រះវិហារ


95

ហើយពួកអ្នកដែលបំរើអាសនា ក៏បាន ចំណែកពីអាសនាដែរ


96

ព្រះអម្ចាស់ទ្រង់ក៏បង្គាប់ ឱ្យពួកអ្នក ដែលផ្សាយដំណឹងល្អ បានរស់ដោយសារ ដំណឹងល្អដូច្នោះដែរ" កូរិនថូសទី១ ៩:១៣,១៤។


97

ព្រះគ្រីស្ទបានតម្រូវប្រព័ន្ធដង្វាយដប់ហូត មួយនេះ នៅដំណាលគ្នានឹងទ្រង់បានបន្ទោសដល់ពួកអាចារ្យ និងពួកផារិសី
ចំពោះគំនិតដ៏ចង្អៀតចង្អល់របស់គេដល់ សាសនា:


98

(ព្រះគម្ពីរ ម៉ាថាយ ២៣:២៣)

"...ដ្បិតអ្នករាល់គ្នាថ្វាយ១ ភាគក្នុង១០ ទាំងជីរអង្កាម ជីរលីងលាក់ និងល្ងផង តែបានចោលសេចក្តីសំខាន់ជាង ដែលនៅក្នុង ក្រិត្យវិន័យវិញ:


99

ដូចជាសេចក្តីយុត្តិធម៌ សេចក្តីមេត្តា
ករុណា និងសេចក្តីជំនឿ គួរតែឱ្យអ្នករាល់ គ្នាបានប្រព្រឹត្តការទាំងនេះ ហើយការឯទៀតនោះក៏មិនត្រូវចោលផង"
ម៉ាថាយ ២៣:២៣។


100

ប្រហែលជាលោកអ្នកកំពុងឆ្ងល់ថា តើលោកអ្នកអាចថ្វាយមួយភាគដប់ទៅព្រះពីចំណូលរបស់លោកអ្នកយ៉ាងណា។

មនុស្សជាច្រើនបានឆ្ងល់របៀបនេះ!

ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ក៏គេបានធ្វើ ការសម្រេចចិត្ត ទុកចិត្តលើការណែនាំនិងតម្រិះរបស់ព្រះ ហើយបង្វិល ដង្វាយថ្វាយ ដល់ទ្រង់វិញ។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


101

ជាច្រើនសប្តាហ៍ក្រោយមក មនុស្ស ដដែលនេះ បានធ្វើជាសាក្សីយ៉ាងរីករាយថា ការអស្ចារ្យបានកើតឡើង ចំពោះជីវិតពួកគេ!

មិនដឹងជាយ៉ាងណា ប្រាំបួនភាគដប់នៃ ចំណូលរបស់គេ បានចម្រើនលើសពីដប់ភាគដប់ដែលគេបានទុកកាលពីមុន!

នេះគឺជាអាថ៌កំបាំងនៃសុវត្ថិភាពនៃប្រាក់កាស


102

អ្នកខ្លះសួរថា “តើការថ្វាយដង្វាយដប់ ហូតមួយនេះសម្រាប់តែពួកយូដាទេឬអី?

“ចំពោះសំនួរនេះ យើងសួរត្រឡប់ទៅ វិញថា “តើព្រះពរពីស្ថានសួគ៌សម្រាប់តែ ពួកយូដាទេឬអី?”


103

មានបុរសម្នាក់ឈ្មោះជីម ដែលមាន បញ្ហាក្នុងការដាក់ដង្វាយដប់ហូតមួយនេះ ដោយគាត់មានប្រាក់ខែតែបន្តិចបន្តួចតែប៉ុណ្ណោះ។

វាហាក់ដូចជាពិបាកណាស់នៅពេលដំបូង ប៉ុន្តែក្រោយមកគាត់បានទទួលព្រះពរចំពោះមុខជំនួញរបស់គាត់ ដែលបាន រីកចម្រើនយ៉ាងល្អ ធ្វើឱ្យគាត់លែងមានការខ្វល់ខ្វាយអំពីប្រាក់កាសទៀតហើយ


104

ឥឡូវនេះ គាត់បានថ្វាយព្រះលើសពី ប្រាក់ដែលបានជោគជ័យរបស់គាត់ ហើយ រីករាយនឹងថ្វាយដើម្បីនឹងជម្រុញការងារ របស់ព្រះ។



105

ឬក៏យកលោកអ៊ីដ ជាឧទាហរណ៍ ដែលគាត់បានលោតផ្លោះនូវសេចក្តីជំនឿរបស់គាត់ដោយបិទហាងរបស់គាត់នៅថ្ងៃបរិសុទ្ធ ជាថ្ងៃមួយដ៏មមាញឹកនៅរដូវនោះ.គាត់ត្រូវបាន ទទួលព្រះពរ ដោយមុខជំនួញរបស់គាត់បានកើនឡើងជាច្រើននៅថ្ងៃទាំងប្រាំមួយនៃ សប្តាហ៍! ព្រះទ្រង់ជាអ្នករក្សាព្រះបន្ទូល សន្យា!


106

គ្រីស្ទានបែបនោះ ត្រូវបានទទួលព្រះពរ ដូចមានចែងនៅក្នុងព្រះបន្ទូលសន្យា ដែលមាននៅក្នុងគម្ពីរ ម៉ាឡាគី:

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


107

(ព្រះគម្ពីរ ម៉ាឡាគី ៣:១០)

"ចូរនាំយកដង្វាយ១ភាគក្នុង១០ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ ដើម្បីឱ្យមានស្បៀង
អាហារនៅក្នុងដំណាក់នៃអញ ហើយល្បង លអញឥឡូវ


108

បើអញមិនបើកទ្វារស្ថានសួគ៌ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹង គ្មានកន្លែងល្មមទុក បានទេ


109

នេះហើយជា ព្រះបន្ទូលនៃព្រះ យេហូវ៉ានៃពួកពលបរិវារ"
ម៉ាឡាគី ៣:១០។


110

ព្រះមានព្រះបន្ទូលថា មួយពីក្នុងដប់នៃ អ្វីៗទាំងអស់ ជារបស់បរិសុទ្ធថ្វាយទ្រង់។
ទ្រង់បានប្រទានសក្តានុភាពដល់យើង ក្នុង ការបង្វិលថ្វាយទៅទ្រង់វិញ ដើម្បីឱ្យយើង
បានសាកល្បងភាពជា អ្នកថែរក្សារបស់ យើង ដើម្បីឱ្យឃើញថា តើយើងនឹងសរ សើរដំកើងទ្រង់
ហើយនិងប្រកាសភាព ជាម្ចាស់របស់ទ្រង់ឬទេ។


111

ប្រសិនបើយើងបដិសេធមិនធ្វើដូច្នោះ យើងពិតជាកំពុងប្លន់ព្រះយ៉ាងពិតប្រាកដ
ហើយយោងទៅតាមព្រះគម្ពីរ។


112

(ព្រះគម្ពីរ ម៉ាឡាគី ៣:៨)

"...រួចបែរជាសួរថា តើយើងបានកោង យករបស់ទ្រង់ឯណា? គឺក្នុងដង្វាយ១ភាគ ក្នុង១០
ហើយក្នុងដង្វាយលើកចុះឡើង នោះឯង"
ម៉ាឡាគី ៣:៨។


113

នៅពេលដែលដង្វាយដប់ហូតមួយ ឬក៏ មួយភាគដប់នៃចំណូលរបស់យើង ជា របស់ព្រះហើយនោះ
យើងកំពុងត្រូវបាន អញ្ជើញ ឱ្យមកថ្វាយលើសពីដង្វាយដប់ ហូតមួយ ដែលជាចំណែករបស់ព្រះនោះ
ទៅទៀត។ ចំណែកដង្វាយសទ្ធាវិញ វាអា ស្រ័យទៅលើយើងម្នាក់ៗ ដែលសម្រេចថា នឹងដាក់ប៉ុន្មាន
ទៅតាមសទ្ធារបស់យើង។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត



114

(ព្រះគម្ពីរ លូកា ៦:៣៨)

នោះជាយ៉ាងនេះក៏ដោយ ក៏មានការណែ នាំខ្លះនៅក្នុងព្រះគម្ពីរដែរ។

ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលថា "ចូរឱ្យទៅគេ នោះនឹងបានឱ្យមកអ្នកដែរ គេនឹងវាល់ឱ្យអ្នកយ៉ាងល្អទាំងញាត់ ទាំង រលាក់ហើយដាក់ឱ្យហៀរ និងយកមកដាក់បំពេញចិត្តអ្នកផង..."

លូកា ៦:៣៨។



115

ព្រះហឫទ័យរបស់ព្រះខាងថវិការសម្រាប់ទ្រទ្រង់កិច្ចការរបស់ព្រះអង្គនៅលើផែនដីនេះងាយស្រួលនិង ល្អប្រសើរជាទីបំផុត។ ទ្រង់បានសុំឱ្យរាស្ត្ររបស់ទ្រង់ថ្វាយដោយអស់ពីចិត្តរបស់ពួកគេ ហើយមិនត្រូវខ្វល់ខ្វាយអំពីសេចក្តីត្រូវការផ្ទាល់របស់គេ ដែលនឹង ត្រូវបានជួបប្រទះនោះឡើយ នៅទីបំផុតរបស់ទាំងឡាយនោះនឹងត្រូវផ្តល់ឱ្យលើសពី ការរំពឹងទុករបស់គេយ៉ាងឆ្ងាយ។



116

ប្រហែលលោកអ្នកកំពុងតែគិតថា ប្រ សិនបើព្រះជាម្ចាស់លើអ្វីៗទាំងអស់ មាស ប្រាក់ គោ ក្របី ដីធ្លី និងមនុស្សយើង ទៀតនោះ តើហេតុអ្វីបានជាទ្រង់ត្រូវការ ប្រាក់របស់ខ្ញុំ?

ប្រព័ន្ធដង្វាយដប់ហូតមួយ គឺជាផែន ការរបស់ទ្រង់ ខាងហិរញ្ញវត្ថុ ដើម្បីផ្គត់ផ្គង់ការងាររបស់ទ្រង់នៅលើផែនដីនេះ។



117

ទ្រង់មិនដែលមានបំណងចង់ឱ្យក្រុមជំនុំ ផ្គត់ផ្គង់ថវិកាព្រះវិហារដោយ លេងឆ្នោត ល្បែងឡូតូ ឬក៏ឆ្នោតវត្ថុនោះទេ!

ហើយតើការថ្វាយដង្វាយដប់ហូតមួយ មិនមែនជារបៀបដ៏ប្រសើរ ដើម្បីផ្គត់ផ្គង់ថវិកាសម្រាប់កិច្ចការព្រះវិហារ ចំពោះការ ដោះស្រាយនូវសេចក្តីត្រូវការរបស់មនុស្សទេឬអី?



118

មនុស្សម្នាក់ៗថ្វាយទៅតាមអ្វីដែលគេបាន ទទួល។



119

ប្រសិនបើអ្នករកបានមួយពាន់រៀល

# ១៩. វិនិយោគទុនមួយដែលមិនចេះខាត


120

លោកអ្នកបង្វិលមួយរយរៀលថ្វាយទៅព្រះ។


121

ប្រសិនបើលោកអ្នករកបានមួយរយ


122

លោកអ្នកថ្វាយដប់រៀល។ តើមានអ្វី ត្រឹមត្រូវជាងនេះឬទេ?


123

អ្វីដែលយើងថ្វាយទៅព្រះ ទ្រង់ប្រទាន មកយើងលើសពីនោះទៅទៀត។ យើងតែងទទួលច្រើនជាងយើងថ្វាយជានិច្ច។

នៅពេលដែលយើងថ្វាយដង្វាយទៅព្រះ យើងបញ្ចេញការសរសើររបស់យើង ចំពោះអ្វីដែលទ្រង់បានធ្វើចំពោះយើង ហើយភាពអាត្មានិយម និងលោភលន់មាន កាន់តែតិចទៅៗ។


124

យើងក្លាយជាអ្នកដែលយកចិត្តទុកដាក់ពី អ្នកដទៃកាន់តែខ្លាំងឡើងៗ ហើយនៅពេលដែលយើងចែក ចាយព្រះពរជាមួយនឹង ពួកគេ យើងលូតលាស់ខាងសេចក្តីស្រ ឡាញ់ និងការអាណិតអាសូរ ហើយកាន់ តែដូចព្រះយេស៊ូវខ្លាំងឡើងៗ។

នោះហើយ គឺជាផែនការរបស់ព្រះ សម្រាប់ការលូតលាស់របស់យើងក្នុងព្រះ គ្រីស្ទ។

ព្រះយេស៊ូវបាននិទានរឿងដ៏ល្អមួយ ដើម្បីបកស្រាយអំពីការបង្រៀននេះ។


125

នេះគឺជាកសិករដ៏សំខាន់ យកចិត្តទុក ដាក់ និងឧស្សាហ៍ព្យាយាមម្នាក់ បានខំធ្វើ ការយ៉ាងខ្លាំង ហើយបានផលយ៉ាងហូរ ហៀរនៅពេលប្រមូលផល។

ការប្រមូលផលរបស់គាត់បានច្រើន មែនទែន រហូតដល់ជង្រុករបស់គាត់មិន អាចដាក់អស់។

ជង្រុកបានពេញប្រៀបទៅហើយ ហើយការប្រមូលផលមិនទាន់រួចរាល់នៅ ឡើយ។

តើគាត់ត្រូវធ្វើយ៉ាងណា? នេះគឺជាបញ្ហា

គាត់មានបញ្ហាក្នុងការធ្វើការសម្រេចចិត្ត។

តើគាត់គួរឱ្យផលដែលសល់ទៅអ្នកក្របូយ៉ាងណា?

ប៉ុន្តែផលទាំងនោះជារបស់គាត់។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


126

តើគាត់មិនមែនជាអ្នកដែលបានដាំ ដុះ ដោយប្រុងប្រយ័ត្ន និងប្រើប្រាជ្ញា និងបទ ពិសោធន៍ខាងកសិកម្មរបស់គាត់ ដើម្បីនឹង បង្កើនផលកសិកម្មនេះទេឬអី?

គាត់សម្រេចចិត្តយ៉ាងដូច្នេះ


127

(ព្រះគម្ពីរ លូកា ១២:១៨-២១)

"...អញត្រូវធ្វើយ៉ាងនេះ គឺអញនឹងរុះ ជង្រុកអញ ពង្រីកឱ្យធំជាងទៅទៀត រួចប្រមូលផលនិងទ្រព្យសម្បត្តិ ទៅផ្ទុកនៅ ទីនោះ


128

នោះអញនឹងប្រាប់ដល់ចិត្តថា ចិត្តអើយ ឯងមានទ្រព្យសម្បត្តិជាច្រើន ល្មមទុក សំរាប់ជាយូរឆ្នាំទៅមុខទៀតបានហើយ ចូរឯងឈប់សំរាកទៅ ហើយស៊ីផឹក សប្បាយចុះ"

លូកា ១២:១៨,១៩។


129

"ប៉ុន្តែព្រះទ្រង់មានបន្ទូលទៅអ្នកនោះថា ឱមនុស្សល្ងីល្ងើអើយ នៅវេលាយប់នេះឯង អញនឹងដកយកព្រលឹងឯងទៅវិញ


130

ដូច្នេះ តើទ្រព្យសម្បត្តិទាំងប៉ុន្មានដែលឯង បានប្រមូលទុកនោះ នឹងទៅជារបស់អ្នក ណាវិញ?


131

អ្នកណាដែលប្រមូលទ្រព្យសម្បត្តិទុក បំរុងតែខ្លួនឯង តែឥតមានខាងព្រះសោះ នោះក៏ដូច្នោះដែរ"

លូកា ១២:២១:២១។


132

កសិករដ៏មាននេះមិនបានដឹងថា តើព្រះ ពររបស់គាត់នេះមកពីណាទេ។

គាត់មិនបានទទួលស្គាល់ព្រះដែលបង្កើត គេមក ឬក៏ទទួលករណីយកិច្ចរបស់គាត់ជាអ្នកថែរក្សាឡើយ។

គាត់បានបំភ្លេចភាពក្រីក្រ ភាពជាអ្នក កំព្រា ភាពជាមនុស្សមេម៉ាយ ឬគ្មានផ្ទះសំ បែងទាំងស្រុង ។

គាត់គិតតែ ខាងមានតែម្នាក់ឯងប៉ុណ្ណោះ។

មនុស្សនេះមានបញ្ហាផ្លូវចិត្ត។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


133

(ព្រះគម្ពីរ ម៉ាថាយ ៦:២១)

ព្រះយេស៊ូវបានមានព្រះបន្ទូលថា "ពី ព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណានោះចិត្តអ្នកនឹងនៅកន្លែងនោះដែរ" ម៉ាថាយ ៦:២១

ព្រះយេស៊ូវទ្រង់ម៉ឺងម៉ាត់ចំពោះ អាកប្បកិរិយារបស់យើងទៅលើទ្រព្យសម្បត្តិ នេះ ព្រោះថា បើយើងមិនថ្វាយ ទៅព្រះ យេស៊ូវទេ វានឹងអាចដឹកនាំយើងឱ្យឆ្ងាយ ពីព្រះ ហើយវាថែមទាំងបណ្តាលឱ្យយើង បាត់បង់ជីវិតអស់កល្បទៀតផង។


134

(ព្រះគម្ពីរ ម៉ាថាយ ១៦:២៦)

ទ្រង់បានមានព្រះបន្ទូលថា "ដ្បិតបើ មនុស្សណានឹងបានលោកីយ៍ទាំងមូល តែ បាត់ព្រលឹងទៅ នោះតើមានប្រយោជន៍ អ្វីដល់អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរ ឱ្យបានព្រលឹងខ្លួនវិញ?..." ម៉ាថាយ ១៦:២៦


135

បញ្ហារបស់មនុស្សសម័យទំនើបនេះគឺថា ជីវិតរបស់គេបានក្លាយទៅជាស្មុគស្មាញ ហើយកម្មវិធីរបស់គេមមាញឹកខ្លាំងណាស់ រហូតដល់គេភ្លេច ឬក៏មិនបានចំណាយ ពេលដើម្បីរំលឹកថា តើព្រះពរទាំងអស់ របស់គេនេះមកពីណា។



136

(វីដេអូ ៦វិនាទី) គេបរាជ័យ មិនបាន ពិចារណានូវតម្លៃដែលត្រូវបានបង់ ដើម្បី លោះគេអំពីអំពើបាបឡើយ។

ជាលទ្ធផល គេបានបដិសេធការ សរសើរដំកើងព្រះដោយពេលវេលា ទេពកោសល្យ និងទ្រព្យសម្បត្តិរបស់គេ។

យើងម្នាក់ៗត្រូវតែបានរំលឹករៀងរាល់ថ្ងៃថា


137

របស់ដែលយើងស្រឡាញ់ ហើយពេញចិត្ត យ៉ាងខ្លាំងនោះ


138

គ្រាន់តែជារបស់ដែលត្រូវបានខ្ចីមកតែប៉ុណ្ណោះ វាមិនមែនជារបស់យើងសោះឡើយ។

# ១៩.វិនិយោគទុនមួយដែលមិនចេះខាត


139

ព្រះយេស៊ូវអនុញ្ញាតឱ្យយើងប្រើ ដើម្បី នឹងធ្វើឱ្យជីវិតយើងបានសប្បាយតែប៉ុណ្ណោះ


140

ដូច្នេះសូមរំលឹកយើងខ្ញុំឡើង សូមរំលឹក យើងឡើង ព្រះអម្ចាស់ជាទីស្រឡាញ់អើយ។

ដកស្រង់ពី សៀវភៅរបស់អ្នកស្រី

ដូធី រ៉ាំបូ

"សូមរំលឹកទូលបង្គំ ឱព្រះអម្ចាស់អើយ"


141

អ្វីៗដែលយើងមាន គឺជាអំណោយទាន របស់ព្រះ។

ជីវិតរបស់យើង គឺជាអំណោយមកពី ព្រះ។

សុខភាពរបស់យើង គឺជាអំណោយ មកពីព្រះ។

រាល់ដង្ហើមចេញចូលរបស់យើង គឺ ជាអំណោយមកពីព្រះ។

ចំណីអាហារដែលយើងបរិភោគ សំ លៀកបំពាក់ដែលយើងស្លៀកពាក់ ផ្ទះ ដែលយើងរស់នៅ គឺជាអំណោយរបស់ព្រះ។

នៅពេលដែលយើងថ្វាយត្រឡប់ទៅព្រះវិញ យើងកំពុងនិយាយថា "អរគុណព្រះអម្ចាស់ ចំពោះអ្វីៗដែល ទ្រង់បានប្រទានមកឱ្យទូល បង្គំ"

តើលោកអ្នកចង់និយាយថា "ព្រះអម្ចាស់អើយ ទូលបង្គំចង់ទុកទ្រង់ ជាទីមួយនៅក្នុងថវិការបស់ទូលបង្គំ និងគ្រប់ទាំងផ្នែកទាំង អស់នៃជីវិតទូលបង្គំឬទេ?"

ប្រសិនបើលោកអ្នកចង់ សូមលោកអ្នក លើកដៃឡើង នៅពេលដែលយើងអធិស្ឋាន

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព



1

តើយើងអាចរកសេចក្តីពិតនោះឃើញនៅឯណាសព្វថ្ងៃនេះ?


2

រឿងមួយត្រូវបានគេនិទានមកថា មាន កម្លោះជនជាតិក្រេកបុរាណម្នាក់ក្រេកបុរាណ ដែលចង់ស្វែងរកសេចក្តីពិត។

គាត់ក៏បានទៅជួបលោកតាម្នាក់ដែលត្រូវ បានគេទទួលស្គាល់ថា ជាអ្នកមានប្រាជ្ញា ជាងគេនៅក្នុងទីក្រុង។

អ្នកកម្លោះនោះបានសួរទៅតាថា "លោកតាដ៏មានប្រាជ្ញា សូមប្រាប់មកមើល តើខ្ញុំអាចរកសេចក្តីពិតឃើញ ដោយរបៀប ណា? តើលោកតាអាចដឹកនាំខ្ញុំទៅរកវាបាន ទេ?"

អ្នកប្រាជ្ញចំណាស់ក្រោកឡើង ហើយ ចាប់ផ្តើមដើរចេញទៅ។

ជនកម្លោះនោះក៏បានដើរតាម។ គេដើរ តាមផ្លូវនៃទីក្រុងសំដៅទៅឆ្នេរសមុទ្រ។

លោកតានៅតែបន្តដើរចូលទៅក្នុងទឹក ទៀត។

នៅពេលដែលពួកគេចូលទៅក្នុងទឹក ជម្រៅប្រហែលត្រឹមចង្កេះ លោកតាបាន ប្រាប់អ្នកកម្លោះនោះ ឱ្យដាក់ដៃលើក្បាល របស់គាត់។

លោកតាបានជ្រមុជអ្នកកម្លោះនោះទៅ ក្នុងទឹក។

បីដង ជនកម្លោះងើបឡើង ដង្ហក់រក ខ្យល់។ គម្រប់បីដង នៅលើកទីបីនោះ ជនកម្លោះបានស្រែកឡើងថា "អ្វីដែលខ្ញុំចង់បាន នោះគឺស្វែងរក សេចក្តីពិត!"

តាបានឆ្លើយថា "នៅពេលដែលអ្នកចង់ ដឹងពីសេចក្តីពិតខ្លាំង ដូចអ្នកចង់បានខ្យល់ ដកដង្ហើមដូច្នេះ នោះ អ្នកនឹងអាចរកវាឃើញហើយ"

ព្រះមិនបានលាក់សេចក្តីពិតនេះពីយើង ឡើយ។ ហោរាយេរេមានិយាយថា



3

(ព្រះគម្ពីរ យេរេមា ២៩:១៣)

"ឯងរាល់គ្នានឹងស្វែងរកអញ ហើយ នឹងឃើញផង គឺកាលណាឯងស្វែងរកអញ ឱ្យអស់ពីចិត្ត" យេរេមា ២៩:១៣។

ប៉ុន្តែមនុស្សខ្លះកំពុងរកនៅកន្លែងខុសទៅ វិញ។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព


4

មានអ្នកខ្លះនិយាយថា យើងម្នាក់ៗ បានកើតមកជាមួយនឹង "ចិត្តទទេ ដែល មានតែព្រះទេ ដែលអាចបំពេញបាន"

តាំងពីកំណើតមក យើងហាក់ដូចជាមាន សេចក្ដីប៉ងប្រាថ្នានូវអ្វីៗដែលយើងគ្មានជាខ្លាំង មិនអាចពណ៌នាបានឡើយ។

ដោយមិនបានគិត យើងហាក់ដូចជា កំពុងស្វែងរកអ្វីដែលយើងមិនអាចពណ៌នា បាន ប៉ុន្តែជារបស់ដែលយើងចង់បាន និង យើងត្រូវការ!


5

នៅក្នុងការធុញទ្រាន់ដែលនៅមិនសុខ មិនសាប់ យើងតែងតែខំស្វែងរក ដើម្បី បំពេញភាពទទេ នៅក្នុងជីវិតយើងនេះ ដោយកិត្តិនាម សុភមង្គល គ្រឿងញៀន ស្រា ទ្រព្យសម្បត្តិ និងពេលវេលាសប្បាយ ទោះបីជាយើងបានសម្រេចនូវសេចក្ដីត្រូវការ ទាំងអស់នោះហើយក៏ដោយ ក៏វាគ្រាន់តែ ជារង្វាន់ ដែលយើងពេញចិត្តតែមួយភ្លែត ប៉ុណ្ណោះ។


6

ហើយមិនយូរមិនឆាប់ នាឱកាសនៃរាត្រី ឯកោ យ៉ាងស្ងាត់ជ្រងំដ៏រសាប់រសល់ សម្រាន្តមិនលក់មួយ នោះក៏មានសំឡេង សំនួររបស់ហោរាពីបុរាណ នឹងបំពងឡើង អំពីអតីតកាលនៅក្នុងចិត្តយើង



7

(ព្រះគម្ពីរ អេសាយ ៥៥:២)

"ហេតុអ្វីបានជាចាយប្រាក់ឱ្យបានរបស់ ដែលមិនមែនជាអាហារ ហើយបង់កំលាំង ឱ្យបានតែរបស់ដែលមិនស្កប់ចិត្តដូច្នេះ? អេសាយ ៥៥:២

ព្រះយេស៊ូវទ្រង់បានជ្រាបនូវការស្អប់ ស្អល់ជាបណ្ដោះអាសន្ននៃទ្រព្យសម្បត្តិ "របស់"



8

(ព្រះគម្ពីរ លូកា ១២:១៥)

ទ្រង់បានមានព្រះបន្ទូលថា "ដ្បិតជីវិត នៃមនុស្សមិនស្រេចនឹងបានទ្រព្យសម្បត្តិជា បរិបូរទេ" លូកា ១២:១៥។


9

មនុស្សសព្វថ្ងៃមានអារម្មណ៍ត្រូវការអំ ណាចខាងក្រៅពីខ្លួនគេ។

នេះគឺគ្មានអ្វីថ្មីទេ។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


10

ចាប់ពីមនុស្សជ្រើសរើសដើរតាមផ្លូវ របស់គេផ្ទាល់ តាំងពីជំនាន់សួនច្បារ អេដែនមក គេបានមានភាពទទេ ដ៏ ចម្លែក ដែលមានតែព្រះទេដែលអាច បំពេញបាន។


11

ព្រះបានអនុញ្ញាតឱ្យពួកអ៊ីស្រាអែលនៅ ក្នុងវាលរហោស្ថានដោយការវង្វេង និង ស្រេកឃ្លាន ដើម្បីឱ្យគេអាចទទួលស្គាល់ សេចក្តីត្រូវការរបស់គេ ពីទ្រង់។

ព្រះបានមានព្រះបន្ទូលទៅកាន់ពួក អ៊ីស្រាអែលតាមរយៈលោកម៉ូសេថា


12

(ព្រះគម្ពីរ ចោទិយកថា ៨:៣)

"ទ្រង់ក៏បានបន្ទាបចិត្តឯងមែន ព្រម ទាំងឱ្យឃ្លានផង


13

...ដើម្បីឱ្យឯងបានដឹងថា មនុស្សមិនមែន រស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ


14

គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែល ចេញពីព្រះឱស្ឋនៃព្រះយេហូវ៉ាមកដែរ"

ចោទិយកថា ៨:៣


15

ជាការជាក់ស្តែង ព្រះអនុញ្ញាត ឱ្យ យើងដឹងអំពីមហិច្ឆតា និងការមិនស្កប់ចិត្ត ដើម្បីឱ្យយើងស្វែងរកព្រះ ហើយអនុញ្ញាត ឱ្យទ្រង់បំពេញសេចក្តីត្រូវការរបស់យើង


16

សព្វថ្ងៃនេះ យើងហាក់ដូចជាមានការ ចាប់អារម្មណ៍នឹងសាសនាខ្លាំងណាស់។

ជាមួយនឹងការបញ្ជាក់យ៉ាងអស្ចារ្យសព្វថ្ងៃនេះ

ទៅលើការរួមបញ្ចូលគ្នានូវសាសនាទាំងឡាយ

ហើយនិងការ ជម្រុញបំបែកជញ្ជាំងនៃ គណៈរបស់សាសនាទាំងឡាយ

មានការសិក្សានិងគំនិតជាច្រើន អំពីទម្រង់ ផ្សេងៗនៃសាសនានិងពួកជំនុំសាសនាគ្រីស្ទ។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


17

ពួកជំនុំថ្មីៗជាច្រើន បានកើតឡើង យ៉ាងរហ័សនៅលើពិភពលោកនេះ។
ម្នាក់ៗអះអាងថា ខ្លួនជារាស្រ្តពិសេស របស់ព្រះ ដែលមានដំណឹងពីសេចក្តីពិត
ដល់មនុស្សទាំងអស់នៅលើផែនដីនេះ។
ដោយពិចារណាទៅលើការអះអាងទាំងនោះ បានធ្វើឱ្យឃើញជាក់ស្តែងថា មិនមែនការ
អះអាងទាំងអស់ អាចជាការពិតនោះទេ។


18

ពួកគេម្នាក់ៗអះអាងថា ព្រះគម្ពីរគឺជា គ្រឹះនៃសេចក្តីជំនឿរបស់គេរៀងៗខ្លួន
ប៉ុន្តែការបង្រៀនរបស់ពួកគេខុសគ្នាយ៉ាងឆ្ងាយទៅវិញ។


19

តើមនុស្សស្មោះត្រង់មិនអាចដឹងច្បាស់
អំពីការអះអាងរបស់សាសនាទាំងអស់នេះនិងដឹងច្បាស់នូវអ្វីៗ ដែលជាសេចក្តីពិតនោះ បានទេឬអី?
តើព្រះពិតជាមានពួកពិសេស នៅក្នុង
ចំណោមគ្រីស្ទានដែលទ្រង់ស្គាល់ថាជាក្រុមជំនុំរបស់ទ្រង់នៅសព្វថ្ងៃនេះឬទេ?
ពិតប្រាកដណាស់ ដូចលោកសាវកប៉ុល បានសរសេរថា:


20

(ព្រះគម្ពីរ អេភេសូរ ៤:៤)
"មានរូបកាយតែ១ ហើយព្រះវិញ្ញាណ តែ១ ដូចជាទ្រង់បានហៅអ្នករាល់គ្នាមក
ក្នុងសេចក្តីសង្ឃឹមតែ១ របស់ការងារអ្នក រាល់គ្នាដែរ


21

មានព្រះអម្ចាស់តែ១ សេចក្តីជំនឿតែ១ បុណ្យជ្រមុជតែ១


22

មានព្រះតែ១ គឺជាព្រះវរបិតានៃទាំងអស់"
អេភេសូរ ៤:៤-៦


23

(ព្រះគម្ពីរ ធីម៉ូថេទី១ ៣:១៥)
លោកប៉ុលបានសរសេរទៅកាន់មិត្តដ៏ ក្មេងរបស់គាត់ លោកធីម៉ូថេ ហើយ និយាយថា
"ដើម្បីក្រែងខ្ញុំក្រមក នោះឱ្យ អ្នកបានដឹងពីរបៀបយ៉ាងណាដែលគួរប្រព្រឹត្តក្នុងដំណាក់នៃព្រះ

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


24

គឺក្នុងពួកជំនុំនៃព្រះ ដ៏មានព្រះជន្មរស់ ដែលជាសរសរ ហើយជាជើងថ្កល់(គ្រឹះ) របស់សេចក្តីពិត”
ធីម៉ូថេទី១ ៣:១៥។
លោកប៉ុលថ្លែងយ៉ាងច្បាស់ថា ពួកជំនុំ របស់ព្រះសព្វថ្ងៃនេះ គឺជាសសរ និងគ្រឹះ (ជើងថ្កល់) របស់សេចក្តីពិត ប៉ុន្តែ
តើយើងរកឱ្យឃើញថា ក្រុមជំនុំណាមួយ ដែលមាន សេចក្តីពិតនោះជាយ៉ាងណា។


25

មានគណៈជាច្រើន មានវិវាទជាច្រើន មានការភាន់ច្រឡំជាច្រើន នៅក្នុង សហគមន៍សាសនានេះ។


26

មិត្តទាំងឡាយអើយ យោងតាមព្រះ គម្ពីរ ព្រះយេស៊ូវមិនដែលមានបំណងចង់ ឱ្យមានការភាន់ច្រឡំណាមួយឡើយ ហើយ ទ្រង់ពិតជាមិនចង់ឱ្យមានគណៈច្រើនដូច្នេះ ឡើយ។
មុនពេលដែលទ្រង់ត្រូវបានជាប់ឆ្កាង ព្រះយេស៊ូវបានអធិស្ឋាន:


27

(ព្រះគម្ពីរ យ៉ូហាន ១៧:២១)
“ដើម្បីឱ្យទាំងអស់បានរួមមកតែ១ ឱ ព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ ហើយទូលបង្គំ នៅក្នុងទ្រង់ដែរ


28

គឺឱ្យអ្នកទាំងនោះបានរួមគ្នាតែមួយក្នុងយើង ប្រយោជន៍ឱ្យលោកីយ៍បានជឿថា ទ្រង់ចាត់ ឱ្យទូលបង្គំមកពិត”
យ៉ូហាន ១៧:២១។
ព្រះយេស៊ូវបានចង់ឱ្យពិភពលោកនេះ ស្គាល់សិស្សរបស់ទ្រង់ដោយការរួបរួម និង សេចក្តីស្រឡាញ់របស់ពួកគេ។
ព្រះគ្រីស្ទមិនចង់បានការបែកខ្ញែកគ្នា ណាមួយ នៅក្នុងពួកជំនុំរបស់ទ្រង់ឡើយ។


29

(ព្រះគម្ពីរ កូរិនថូសទី១ ១២:២៥)
ជាការពិតណាស់លោកប៉ុលបានសរសេរ ថា “ដើម្បីមិនឱ្យមានសេចក្តីបែកខ្ញែកគ្នា ក្នុងរូបកាយឡើយ”
កូរិនថូសទី១ ១២:២៥។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


30

ប៉ុន្តែលោកប៉ុលបាននិយាយថា ការបោះ បង់ជំនឿនឹងមកដល់ ហើយដោយសារការនោះនឹងមានការបែកខ្ញែកគ្នា!



31

(ព្រះគម្ពីរ កិច្ចការ ២០:២៨-៣០)

យើងបានអានថា "ដូច្នេះ ចូរអ្នករាល់ គ្នាប្រយ័ត្នខ្លួន ហើយនិងថែរក្សាហ្វូងសិស្ស... ឱ្យធ្វើជាអ្នកគង្វាលដល់គេ ដើម្បីឱ្យបាន ឃ្វាលពួកជំនុំរបស់ព្រះអម្ចាស់...



32

ដ្បិតខ្ញុំដឹងថា ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ ដែលមិនចេះប្រណីដល់ហ្វូងចៀម វានឹងចូលមកក្នុងពួក អ្នករាល់គ្នា



33

ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹង កើតមានមនុស្សដែលនឹងអធិប្បាយសេចក្តីទទាស់ខុសដែរ



34

ដើម្បីនឹងទាញនាំពួកសិស្សទៅតាមគេវិញ"

កិច្ចការ ២០:២៨-៣០។


35

នៅពេលដែលយើងបើកទំព័រនៃប្រវត្តិ សាស្ត្រពួកជំនុំ យើងរកឃើញថា ការនេះពិតដូចជាអ្វីដែលបានកើតឡើងមែន។

គ្រូក្លែងក្លាយបានលេចឡើងហើយ មនុស្សខ្លះក៏បានទទួលយកការខុសឆ្គងរបស់គេហើយចាកចេញពីពួកជំនុំ។

អ្នកខ្លះទៀតបានមានការភាន់ច្រឡំ។ ពួកសិស្សត្រូវ បានទាញចេញឱ្យឆ្ងាយ ហើយពួកគេត្រូវបានធ្លាក់ចុះបន្តិចម្តងៗ ពីការបង្រៀនរបស់ព្រះយេស៊ូវ។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ព្រះនៅតែមានពួកជំនុំមួយដែលនៅតែស្មោះត្រង់ដដែល។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព


36

ប៉ុន្តែមនុស្សខ្លះនិយាយថា "វានឹងត្រូវ ចំណាយពេលអស់មួយជីវិត ដើម្បីនឹង សិក្សានូវការបង្រៀនរបស់សាសនាទាំងអស់ ដើម្បីរកឱ្យឃើញថា មួយណាជាពួកជំនុំពិតរបស់ព្រះនោះ"

ប៉ុន្តែមានរបៀបយ៉ាងងាយមួយ។
គឺជារបៀបរបស់ព្រះ!


37

អ្នកកាន់អំណាចរដ្ឋាភិបាលប្រាប់យើង យ៉ាងច្បាស់ថា វាជាការងាយស្រួលណាស់ ក្នុងការញែកឱ្យដាច់ពីគ្នាក្រដាសប្រាក់ពិតប្រាកដ និងក្រដាសប្រាក់ក្លែងក្លាយនោះ

លោកអ្នកឃើញទេ គេសិក្សាលក្ខណៈ របស់ក្រដាសប្រាក់ពិតប្រាកដយ៉ាងជាក់លាក់។


38

គេស្គាល់សរសៃវាយភាព (ខ្សែនៅលើក្រដាសប្រាក់) របស់ក្រដាសពណ៌យ៉ាង ជាប់របស់ទឹកខ្មៅ និមិត្តសញ្ញានិង លំដាប់ត្រឹមត្រូវនៃលេខរៀងតៗគ្នារបស់ ក្រដាសប្រាក់ពិត។

នៅពេលដែលគេមើលទៅក្រដាសប្រាក់ គេអាចប្រៀបធៀបវាបានយ៉ាងរហ័សអំពីក្រដាសប្រាក់ក្លែងក្លាយ ទៅនឹងក្រដាស ប្រាក់ពិតប្រាកដ។

ប្រសិនបើវាខ្វះលក្ខណៈណាមួយ វាគឺជា ក្រដាសក្លែងក្លាយហើយ។


39

ហើយវាក៏ដូចគ្នាជាមួយនឹងសេចក្ដីពិតដែរ។


40

យើងមិនចាំបាច់សិក្សានូវការបង្រៀន របស់គណៈដទៃទៀតយូរនោះទេ ប្រសិនបើយើងស្គាល់លក្ខណៈពួកជំនុំពិតរបស់ព្រះ ដូចដែលបានផ្ដល់នៅក្នុងព្រះគម្ពីរនោះ។

ព្រះមិនបានទុកឱ្យមនុស្សស្មានថា មួយ ណាជាក្រុមជំនុំពិតនោះទេ ព្រោះព្រះបានប្រទានមកឱ្យយើងនូវការពិតនេះ នៅក្នុង ព្រះបន្ទូលរបស់ទ្រង់:


41

(ព្រះគម្ពីរ អេម៉ូស ៣:៧)

"ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិន
ធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់សំដែងឱ្យ
ពួកហោរា ជាអ្នកបំរើទ្រង់ឃើញគំនិត
លាក់កំបាំងរបស់ទ្រង់ផង"
អេម៉ុស ៣:៧

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព



42

ព្រះគម្ពីរវិវរណៈ គឺជាការសង្ខេបនៃ បទទំនាយទាំងអស់នៅក្នុងព្រះគម្ពីរ។
ព្រះគម្ពីរនេះ ផ្ដល់ឱ្យមនុស្សទាំងអស់នូវការ
យល់ធ្លុះជ្រៅទៅក្នុងសម័យចុងក្រោយនេះ។
នៅក្នុងព្រះគម្ពីរវិវរណៈ ការបោះបង់ ជំនឿ និងសាសនាច្របូកច្របល់ ដែលមាននៅ
ក្នុងសម័យចុងក្រោយ នៃប្រវត្តិសាស្ត្ររបស់ ផែនដីនេះ ត្រូវបាន បើកសំដែងឱ្យដឹង។
ព្រះគម្ពីរវិវរណៈទស្សនទាយអំពីទំនាស់ រវាងពួកជំនុំរបស់ព្រះ និងពួកជំនុំរបស់ សាតាំង។
ជំពូកទី១២ ផ្ដល់នូវគំនិតដ៏ទូលំទូលាយនៃ ប្រវត្តិសាស្ត្រពិភពលោក តាំងពីសម័យព្រះ
គ្រីស្ទរហូតដល់ចុងបញ្ចប់នៃពិភពលោកនេះ:


43

(ព្រះគម្ពីរ វិវរណៈ ១២:១,២)
"រួចមានទីសំគាល់១យ៉ាងធំនៅលើ មេឃ គឺជាស្ត្រីម្នាក់ប្រដាប់ខ្លួនដោយព្រះ អាទិត្យ


44

មានព្រះច័ន្ទនៅក្រោមជើង ក៏មានមកុដធ្វើ ពីផ្កាយ១២នៅលើក្បាលដែរ


45

នាងមានគភ៌ ក៏ស្រែកដោយរៀបនឹង សំរាលចេញ ទាំងឈឺចាប់នឹងបង្កើតកូនមក"
វិវរណៈ ១២:១,២


46

ទីនេះព្រះបានផ្ដល់រូបភាពរបស់ស្ត្រីម្នាក់ ដែលមានសំលៀកបំពាក់ស ដែលគ្រប
ដណ្ដប់ដោយព្រះអាទិត្យ ឈរនៅលើព្រះ ច័ន្ទ ជាមួយនឹងមកុដនៃផ្កាយ១២ នៅលើ
ក្បាលរបស់នាង។ តើទាំងអស់នេះមានន័យ យ៉ាងណា?
នៅក្នុងបទទំនាយនៃព្រះគម្ពីរ ស្ត្រី បរិសុទ្ធតំណាងឱ្យរាស្ត្ររបស់ព្រះ-ពួកជំនុំ របស់ទ្រង់។
ហោរាយេរេមាបានសរសេរថា:


47

(ព្រះគម្ពីរ យេរេមា ៦:២)
"ឯកូនស្រីស៊ីយ៉ូនដ៏ល្អ ហើយរុងរឿង នោះអញនឹងបំផ្លាញបង់"
យេរេមា ៦:២
ហើយតើអ្នកណាទៅដែលជា "ស៊ីយ៉ូន" នោះ? តាមរយៈលោកអេសាយ ព្រះបាន មានព្រះបន្ទូលថា

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


48

(ព្រះគម្ពីរ អេសាយ ៥១:១៦)

"...រួចនិយាយដល់ពួកក្រុងស៊ីយ៉ូនថា ឯងជារាស្ត្ររបស់អញ"

អេសាយ ៥១:១៦។

នៅពេលដែលយើងគិតពីខទាំងពីរនេះ យើងឃើញថា ព្រះបានប្រើស្ត្រីដែល ប្រកបដោយគុណធម៌ ដើម្បីតំណាងឱ្យពួក ជំនុំពិតរបស់ទ្រង់។

លោកសាវកប៉ុលបានប្រើពាក្យ បច្ចេកទេសដូចគ្នានេះ ដើម្បីពិពណ៌នា អំពីពួកជំនុំកូរិនថូស។


49

(ព្រះគម្ពីរ កូរិនថូសទី២ ១១:២)

"ពីព្រោះខ្ញុំប្រច័ណ្ឌចំពោះអ្នករាល់គ្នា ដោយសេចក្តីប្រច័ណ្ឌនៃព្រះ ដ្បិតខ្ញុំបាន បំរុងអ្នករាល់គ្នាទុក ឱ្យមានប្តីតែ១ ទុកដូច ជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅព្រះ គ្រីស្ទតែ១ប៉ុណ្ណោះ"

កូរិនថូសទី២ ១១:២។


50

(ព្រះគម្ពីរ វិវរណៈ ១៧:៣-៥)

ទោះជាយ៉ាងនេះក៏ដោយ លោកយ៉ូហាន ត្រូវបានបង្ហាញនូវស្ត្រីម្នាក់ទៀត ដែលគាត់ បានពណ៌នានៅក្នុងព្រះ គម្ពីរវិវរណៈ:១៧:

"នោះខ្ញុំឃើញមានស្ត្រីម្នាក់ ជិះនៅលើសត្វ សម្បុរក្រហម ដែលពេញជាឈ្មោះ ប្រមាថ...


51

សំលៀកបំពាក់របស់ស្ត្រីនោះ មានពណ៌ ស្វាយ ហើយក្រហម ក៏តែងដោយមាស ត្បូងមានតម្លៃ ហើយនិងកែវមុក្តា


52

ព្រមទាំងកាន់ពែងមាស ដែលពេញដោយ សេចក្តីស្មោកគ្រោក របស់ការកំផិតដ៏គួរ ខ្ពើមរបស់វាផង"


53

ហើយនៅថ្ងាសវាមានកត់ឈ្មោះថា:

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព


54

សេចក្ដីអាថ៌កំបាំង ក្រុងបាប៊ីឡូនដ៏ជាធំ ជាម្ដាយនៃពួកស្រីសំផឹង និងអស់ទាំង
សេចក្ដីគួរខ្ពើមនៅផែនដី”
វិវរណៈ ១៧:៣-៥។


55

ភាសានិមិត្តរូបនេះពណ៌នាអំពីស្ត្រីមិន បរិសុទ្ធ-ពួកជំនុំក្លែងក្លាយ។ ពួកជំនុំធ្លាក់
ចុះមិនបានស្មោះត្រង់ចំពោះព្រះគ្រីស្ទ ហើយបានសម្របសម្រួលការពិតរបស់ព្រះ គម្ពីរ។
លោកយ៉ាកុបបានប្រើពាក្យពេចន៍ដូចគ្នា នេះ ដើម្បីនឹងពិពណ៌នាអំពីអ្នកដែលបាន បោះបង់ចោល
ការបង្រៀន របស់ព្រះ និងចូលរួមជាមួយនឹងលោកីយ៍:


56

(ព្រះគម្ពីរ យ៉ាកុប ៤:៤)
“ឱពួកកំផិតទាំងប្រុសទាំងស្រីអើយ តើ មិនដឹងទេឬអីថាដែលស្រឡាញ់ដល់
លោកីយ៍នោះ គឺជាស្អប់ដល់ព្រះហើយ”
យ៉ាកុប ៤:៤។


57

ស្ត្រីអាក្រក់ តំណាងឱ្យក្រុមជំនុំក្លែងក្លាយ ហើយស្ត្រីបរិសុទ្ធ តំណាងឱ្យក្រុមជំនុំបរិសុទ្ធ។
សូមមើលម្ដងទៀតទៅបទទំនាយអំពីស្ត្រី បរិសុទ្ធនេះ។
ស្ត្រីបរិសុទ្ធ = ក្រុមជំនុំបរិសុទ្ធ
ស្ត្រីក្លែងក្លាយ = ក្រុមជំនុំក្លែងក្លាយ


58

(ព្រះគម្ពីរ វិវរណៈ ១២:២,៤)
“នាងមានគភ៌ ក៏ស្រែកដោយរៀបនឹង សំរាលចេញ ទាំងឈឺចាប់នឹងបង្កើតកូន មក...


59

នាគនោះក៏ស្ថិតនៅត្រង់មុខស្ត្រី ដែល រៀបនឹងសំរាលកូននោះ ដើម្បីនឹងលេបកូន នាង


60

ក្នុងកាលដែលសំរាលចេញមក”
វិវរណៈ ១២:២,៤។
តើនាគដែលឈរនៅពីមុខស្ត្រី ដើម្បី នឹងចាំលេបកូនរបស់នាងភ្លាម នៅពេល
ដែលកើតមកនោះជានរណា?

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


61

(ព្រះគម្ពីរ វិវរណៈ ១២:៧-៩)

"នោះមានចម្បាំងនៅលើមេឃ គឺ មីកែល និងពួកទេវតារបស់លោកក៏ច្បាំង នឹងនាគ ហើយនាគនិងទេវតាវាក៏ច្បាំង នឹងលោកដែរ


62

តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែង ណាឱ្យវានៅលើមេឃទៀតផង


63

នោះនាគធំត្រូវបោះទម្លាក់ទៅ គឺជាពស់ ពីបុរាណ ដែលឈ្មោះហៅថាអារក្ស ហើយសាតាំងផង ដែលបាននាំលោកីយ៍ ទាំងមូលឱ្យវង្វេងចេញ


64

វាត្រូវបានបោះទំលាក់ទៅផែនដីវិញ ព្រម ទាំងពួកទេវតារបស់វាផង"

វិវរណៈ ១២:៧-៩។


65

(ព្រះគម្ពីរ វិវរណៈ ១២:៥)

គម្ពីរវិវរណៈក៏បានពណ៌នាអំពីកូននោះ ដែរ "នាងសំរាលបានកូនប្រុស ដែលត្រូវ ឃ្វាលគ្រប់អស់ទាំងសាសន៍ ដោយដំបងដែក


66

តែព្រះទ្រង់លើកកូននាងទៅឯទ្រង់ និង ដល់បល្ល័ង្កទ្រង់វិញ"

វិវរណៈ ១២:៥។


67

មានតែកូនម្នាក់ទេនៅក្នុងប្រវត្តិសាស្ត្រ ពិភពលោកនេះ ដែលនឹង "គ្រប់គ្រងលើ អស់ទាំងសាសន៍ដោយដំបងដែក" ហើយ ត្រូវបាន "លើកយកទៅឯព្រះ និងបល្ល័ង្ក របស់ទ្រង់" ហើយកូននោះឯងគឺជាព្រះ យេស៊ូវ។

អំពីការយាងមកជាលើកទីពីររបស់ព្រះ គ្រីស្ទ

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


68

(វិវរណៈ ១៩:១៥)

លោកយ៉ូហានបាននិយាយថា "មានដាវ យ៉ាងមុតចេញពីព្រះឱស្ឋទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍


69

ហើយទ្រង់នឹងឃ្វាលគេ ដោយដំបង ដែក..."

វិវរណៈ ១៩:៥។

លោកប៉ុលប្រាប់ពីការដែលព្រះយេស៊ូវ ត្រូវបាន "យកទៅកាន់បល្ល័ង្ករបស់ព្រះ"


70

(ព្រះគម្ពីរ អេភេសូរ ១:២០)

នៅពេលដែលព្រះ "ប្រោសព្រះគ្រីស្ទ ឱ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រមទាំងតាំងឱ្យគង់ខាងស្តាំ ទ្រង់នៅស្ថានដ៏ខ្ពស់"

អេភេសូរ ១:២០។


71

សង្គ្រាមដែលបានចាប់ផ្តើមនៅស្ថានសួគ៌ នោះ បានធ្លាក់មកផែនដីយើងនេះ។

ដែលបានធ្វើការតាមរយៈពួករ៉ូមដែល គ្មានសាសនា សាតាំងប្រឹងប្រែង ដើម្បីយកព្រះជន្មរបស់ព្រះយេស៊ូវ តាំងពីព្រះអង្គ ប្រសូតមកភ្លាម។

ស្តេចហេរ៉ូឌដែលជាអ្នកគ្រប់គ្រង
ប្រទេសរ៉ូមបានចេញច្បាប់មួយថាក្មេងប្រុស
ចាប់ពីអាយុពីរឆ្នាំចុះ ត្រូវតែសម្លាប់ចោល ប៉ុន្តែ ទេវតាបានប្រាប់ម៉ារី និងយ៉ូសេប ឱ្យបានដឹងជាមុន ដើម្បីគេចខ្លួនជាមួយនឹង ព្រះយេស៊ូវ ទៅកាន់ស្រុកអេស៊ីព្ទ។


72

អារក្សបានល្បួងព្រះយេស៊ូវគ្រប់ទាំង បេសកកម្មរបស់ទ្រង់ទាំងអស់ ដោយ សង្ឃឹមថានឹងអាចទប់ស្កាត់ ផែនការ របស់ព្រះ ដើម្បីនឹងសង្គ្រោះពិភពលោក ដែលធ្លាក់ចុះរបស់យើងនេះ។

រូបរាងកាយរបស់ព្រះគ្រីស្ទ ត្រូវបានព្យួរ លើឈើឆ្កាង ហើយសាតាំងបានគិតថា វាបានឈ្នះសមរភូមិនេះហើយ។

ប៉ុន្តែនៅក្នុងផ្នូរទទេនោះ គឺជាបរាជ័យ ដ៏ពិតប្រាកដរបស់សាតាំងទៅវិញ។


73

ព្រះគ្រីស្ទបានរស់ឡើងវិញ ហើយយាង ទៅកាន់បល្ល័ង្ករបស់ព្រះវរបិតាទ្រង់។

បទទំនាយបានសម្រេចត្រឹមត្រូវតាម ពេលកំណត់ ដូចដែលបានទាយទុកមកមែន! ដោយការបរាជ័យក្នុងការបំផ្លាញព្រះរាជបុត្រារបស់ព្រះនោះមក សាតាំងបានបែរកំហឹងរបស់វាទៅរកស្ត្រីនោះ ឬពួកជំនុំគ្រីស្ទាន។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព



74

សិស្សរបស់ព្រះគ្រីស្ទទាំងអស់ លើក លែងតែម្នាក់ចេញ បានស្លាប់ក្នុងនាម ជាទុក្ករបុគ្គល សុខចិត្តទទួលទារុណកម្ម ព្រោះតែគេរក្សាសេចក្ដីជំនឿលើព្រះ( យេស៊ូវ)

សាតាំងមិនអាចប៉ះពាល់ព្រះយេស៊ូវបានទៀតឡើយ។

ទ្រង់ពិតប្រាកដជាបានយាងទៅកាន់ ស្ថានសួគ៌ទៅហើយ។

ដូច្នេះវាបានប្រយុទ្ធជាមួយអ្នកដែលដើរ តាមព្រះយេស៊ូវយ៉ាងកាចសាហាវ។



75

ហើយលោកសាវកប៉ុលត្រូវបានគេកាត់ក នៅខាងក្រៅទីក្រុងរ៉ូម។

គ្រីស្ទានត្រូវបានគេធ្វើទារុណកម្មដាក់ក្នុង គុកងងឹត ជាច្រើននាក់ទៀតត្រូវបោះត្រា ដោយឈាមលើទីបន្ទាល់របស់គេ។



76

ដរាបណាដែលពួកសាវកនៅមានជីវិត រស់នៅ ក្រុមជំនុំឈរយ៉ាងរឹងមាំចំពោះ សេចក្ដីពិត។

បន្ទាប់ពីពួកសាវកបានស្លាប់អស់ទៅ ជា មួយនឹងការកន្លងផុតនៃពេលវេលា គ្រីស្ទានខ្លះបានសម្របសម្រួលសេចក្ដីជំនឿរបស់គេ ជាមួយនឹងការបង្រៀនខុស ដែលចូលមក ក្នុងពួកជំនុំ។



77

“ក្រោយមកនៅចុងសតវត្សរ៍ទីពីរ ក្រុម ជំនុំភាគច្រើន បានក្លាយទៅជាទម្រង់ថ្មីមួយ



78

បន្ទាប់ពីពួកសាវកចាស់ៗ បានស្លាប់អស់ ទៅ ភាពស្មោះត្រង់ពិតប្រាកដរបស់ពួកជំនុំដំបូងក៏បានបាត់បង់ទៅ”

ការស្រាវជ្រាវសាស្ដា ទំព័រ៥១។



79

នៅសតវត្សរ៍ទីបួន ព្រះចៅអធិរាជ កុងស្តង់ទីន បានប្រឹងប្រែងបង្រួបបង្រួម ចក្រភពរ៉ូមឡើងវិញ ដោយបង្រួបបង្រួមអ្នក ជឿសាសនាដែលមានព្រះច្រើន ជាមួយនឹង គ្រីស្ទានទៅក្នុងប្រព័ន្ធនៃសាសនាដ៏ធំមួយ។

ជាលទ្ធផលនៃការបង្រួបបង្រួមនេះ សាសនាគ្រីស្ទបានក្លាយជា មានប្រជាប្រិយ៍ ភាពយ៉ាងខ្លាំង។

អ្នកកាន់សាសនាដទៃត្រូវបានជ្រមុជទឹក ចូលជាពួកជំនុំ ហើយបាននាំមកនូវសេចក្ដី ជំនឿ និងការអនុវត្តន៍របស់គេ ជាច្រើន មកជាមួយគេ។

នៅពេលដែលពួកជំនុំអោបក្រសោប ការខុសឆ្គងទាំងនេះ គេបានបាត់បង់នូវគោលបំណងរបស់ខ្លួន។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព



80

ប្រវត្តិវិទូម្នាក់បានសរសេរថា "ដោយ សារគំនិត និងទម្លាប់បានកន្លងទៅ គ្រីស្ទានថ្មី ក៏ដូចជាពួកអ្នកដែលកាន់ សាសនាដទៃដែរ...ពួកគេនាំគ្នាពពាក់ពពូន ចូលទៅក្នុងពួកជំនុំ ដោយមិនបានជម្រុះ
ចោលនូវជំនឿលើសាសនាដើមរបស់គេឡើយ។



81

ផ្ទុយទៅវិញ ការជ្រមុជទឹកទាំងហ្វូងៗ របស់ពួកកាន់សាសនាដទៃ មានន័យថា ជំនឿលើសាសនាដើមរបស់ពួកនោះ បានកាត់បន្ថយកម្លាំងខាងសីលធម៌របស់ ពួកជំនុំគ្រីស្ទានដើម រហូតដល់ បាត់បង់ កម្លាំងខាងសីលធម៌នេះអស់រលីងទៅ។

សតវត្សរ៍នៃគ្រីស្ទសាសនា ការសង្ខេប នៃប្រវត្តិសាស្ត្រ ទំព័រ៥៨។



82

ទោះជាយ៉ាងនេះក៏ដោយ ក៏មានអ្នក គ្រីស្ទានជាច្រើន នៅតែស្មោះត្រង់ចំពោះ សេចក្ដីពិតរបស់ព្រះដដែល ហើយបាន ប្រឆាំងនឹងការផ្លាស់ប្ដូរដែលបានលួនចូល សន្សឹមៗទៅក្នុងក្រុមជំនុំ។

ពួកគេបានបដិសេធការសម្របសម្រួល
សេចក្ដីជំនឿរបស់ពួកគេ ហើយពួកគេជា ច្រើននាក់ត្រូវបានទទួល ការបៀតបៀន ដោយសារការឈរនៅយ៉ាងម៉ឺងម៉ាត់បែប
ដូច្នេះ។

មិនយូរប៉ុន្មាន អធិរាជប្រទេសរ៉ូមបាន អនុមតិដាក់ទណ្ឌកម្មដល់ស្លាប់ចំពោះអ្នកណា ដែលមិនគោរពសាសនារដ្ឋ



83

(ព្រះគម្ពីរ វិវរណៈ ១២:១៣)

ដោយការប្រមើលមើលទៅអនាគត លោកយ៉ូហានបានសរសេរថា "នោះវា(នាគ)... ក៏ធ្វើទុក្ខដល់ស្ត្រីដែល សំរាលកូនប្រុសនោះ" វិវរណៈ ១២:១៣

តើមានអ្វីកើតឡើងដល់ពួកគ្រីស្ទាន?



84

(ព្រះគម្ពីរ វិវរណៈ ១២:៦)

"រួចស្ត្រីនោះក៏រត់ទៅឯទីរហោស្ថាន នៅទី នោះព្រះបានរៀបកន្លែងឱ្យនាង

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព



85

ដើម្បីនឹងចិញ្ចឹមនាងនៅទីនោះ អស់រវាង ១២៦០ថ្ងៃ”

វិវរណៈ ១២:៦។

សូមកត់សំគាល់ថា ព្រះបានសំដែងឱ្យឃើញ ថាភស្ត្រីរបស់ទ្រង់ត្រូវបានទទួលការបៀត

បៀន អស់រយៈពេល១២៦០ថ្ងៃ។

យើងក៏បានរកឃើញផងដែរថា មួយថ្ងៃៗនៅក្នុងបទទំនាយនៃព្រះគម្ពីរ ស្មើនឹងមួយឆ្នាំក្នុងន័យត្រង់។



86

(ព្រះគម្ពីរ អេសេគាល ៤:៦)

លោកអេសេគាលបានសរសេរថា “អញបានកំណត់១ថ្ងៃ ទុកជា១ឆ្នាំដល់ឯង”

អេសេគាល ៤:៦។



87

ដូច្នេះ ការបៀតបៀនសង្កត់លើភស្ត្រីស្មោះ ត្រង់របស់ព្រះ ដូចដែលបានទស្សនទាយ នៅក្នុងព្រះគម្ពីរ

វិវរណៈ បានត្រូវបន្តរហូត ដល់១២៦០ឆ្នាំ។



88

ប្រវត្តិសាស្ត្របញ្ជាក់បន្ថែមយ៉ាងត្រឹមត្រូវ នូវបទទំនាយនៃព្រះគម្ពីរនេះ។

ព្រះចៅចក្រភពរ៉ូម ហ្សាស្ទីនៀន បាន បញ្ជាឱ្យឧត្តមសេនីយ៍រ៉ូម បេលីសារីយុស

ឱ្យបំបាត់អំណាចចុងក្រោយពីរ ដែលប្រ ឆាំងនឹងពួកជំនុំរ៉ូម។



89

កុលសម្ព័ន្ធចុងក្រោយបំផុតមួយ ក្នុង ចំណោមកុលសម្ព័ន្ធទាំងនោះ ត្រូវ បាន

លុបបំបាត់នៅឆ្នាំ៥៣៨នៃគ្រិស្តសករាជ ហើយព្រះចៅ ហ្សាស្ទីនៀនបានប្រកាស

អភិបាលរបស់ពួកជំនុំ

រ៉ូមជា “អ្នកដឹកនាំរបស់ពួកជំនុំ

គ្រីស្ទសាសនានិងជាអ្នកដែលមានសិទ្ធិត្រឹមត្រូវដើម្បីតម្រង់អ្នកដែលមិនគោរពតាម

គោលទ្ធិរបស់ពួកជំនុំរ៉ូម”

សម័យកាលនៃការមិនសម្របសម្រួល

មួយហៅថា “ការប្រឆាំងជាមួយនឹង គោលទ្ធិរបស់ពួកជំនុំរ៉ូម” បានចាប់ផ្តើមឡើង



90

ហើយពួកគ្រីស្ទានស្មោះត្រង់ ដែលបន្ត ការស្រឡាញ់ស្មោះត្រង់នឹងសេចក្តីពិត

ដែលបានបង្ហាញនៅក្នុង ព្រះបន្ទូលរបស់ ព្រះ បានរកឃើញថា វិធីតែមួយគត់

ដើម្បីរក្សាសេចក្តីជំនឿរបស់ពួកគេបាន គឺ ការគេចខ្លួនចេញ ដូចព្រះគម្ពីរវិវរណៈបាន

ទស្សនទាយទុកមកថា ស្ត្រីនោះបានគេចខ្លួន ទៅឯទីវាលរហោស្ថាន។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


91

ក្រុមវ៉លឌិនស៊ី ក្រុមអាល់បើរគិននីស និងអ្នកគ្រីស្ទានស្មោះត្រង់ដទៃទៀត បានគេចខ្លួនទៅកាន់ជួរភ្នំ អាលភ្ស៍ នៅក្នុង ប្រទេសអ៊ីតាលីខាងជើង ហើយនិង ប្រទេសបារាំងខាងត្បូង ហើយក្រុមហ៊ូកាណូ បានខ្ចាត់ខ្ចាយ ពាសពេញប្រទេសបារាំង។

ពួកគេបានបោះជំរកនៅឯរូងភ្នំដាច់ស្រយាលជា រូងភ្នំឆ្ងាយដាច់សង្វែងនិងនៅ លើភ្នំខ្ពស់។

ពួកគេត្រូវបានគេស្វែងរកចាប់ខ្លួន ដូច ជាឧក្រិដ្ឋជនដ៏ធ្ងន់ធ្ងរ ហើយត្រូវបានគេសម្លាប់អស់ជាច្រើននាក់។

តើអ្វីទៅជាឧក្រិដ្ឋកម្មរបស់ពួកគេ? ពួក គេមិនបានបោះបង់ការដែលព្រះយេស៊ូវបានបង្រៀនដល់ពួកគេឡើយ។


92

គ្រីស្ទានជាច្រើនសុខចិត្តស្លាប់ ប្រសើរ ជាងសម្រុះសម្រួលសេចក្តីជំនឿរបស់ពួកគេ។

អ្នកប្រវត្តិវិទ្យាខ្លះប៉ានបាន់ប្រមាណថា មានចំនួនមនុស្សស្លាប់រហូតដល់ទៅ៥០លាន នាក់។

ហើយអ្នកស្លាប់ដោយសារតែសេចក្តី ស្មោះត្រង់ទៅលើជំនឿរបស់គេជាច្រើនត្រូវបានសម្លាប់ដោយពួកអ្នក ដែលអះអាង ថា គេជាអ្នកគ្រីស្ទានដែលបានធ្វើតាមព្រះហឫទ័យរបស់ព្រះ!


93

ទីបំផុតសេចក្តីពិតរបស់ព្រះ បានទទួល ជោគជ័យ។

ព្រះគម្ពីរត្រូវបានគេបកប្រែជាភាសា របស់មនុស្ស ហើយឥឡូវនេះតាមរយៈការ បោះពុម្ពទំនើប ព្រះគម្ពីរ បានត្រូវ រីករាលដាលពាស ពេញពិភពលោក។

សេចក្តីពិតរបស់ព្រះលែងបានត្រូវលាក់ កំបាំងទៀតហើយ។ ឥឡូវនេះ ការនេះត្រូវបានបើកសំដែងហើយ!


94

អ្នកកែទម្រង់ដ៏ក្លាហានបានប្រកាសអះ អាងយ៉ាងមុះមុតនូវព្រះបន្ទូលរបស់ព្រះ។ មានដូចជាលោកហាស និងហ្សេរ៉ូន ត្រូវ បានដុតនៅលើបង្គោលសសរ។


95

អ្នកដទៃខ្លះទៀតដូចជា លូធើរ វីគ្លីហ្វ និងធីនដាល ត្រូវបានគេតាមចាប់និងទទួល ការបៀតបៀន។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


96

នោះបីជាយ៉ាងនេះក៏ដោយ ការរក ឃើញសហរដ្ឋអាមេរិករបស់អឺរ៉ុប នៅពេល ដែលពួកគ្រីស្ទានត្រូវបានគេ បៀតបៀននៅ អឺរ៉ុប ពួកនោះមានសេរីភាពថ្មីខាងសាសនា ហើយ បានភៀសខ្លួនទៅកាន់ទីនោះ។


97

នៅតាមឆ្នេរនៃជាតិសាសន៍ដែលទើបនឹង កើតថ្មីមួយ ត្រូវបានពង្រាយនូវគ្រឹះនៃ សេរីភាពខាងសាសនា។



98

(វីដេអូ ១០វិនាទី) សករាជនៃការសម្រប សម្រួល និងការបៀតបៀន បានទស្សន ទាយនៅក្នុងព្រះគម្ពីរ វិវរណៈជំពូកទី១២ នោះ ទីបំផុត បានមកដល់ទីបញ្ចប់នៅ ឆ្នាំ១៧៩៨។

វាបានចប់នៅពេលដែលលោកណា ប៉ូឡេអុងបានចាត់ឧត្តមសេនីយ៍ បើរធៀ ទៅចាប់ចាបជាឈ្លើយ. ១២៦០ឆ្នាំយ៉ាង ត្រឹមត្រូវ បន្ទាប់ពីពេលដែលការបៀតបៀន បានកើតឡើងនៅក្នុងឆ្នាំ៥៣៨។


99

នៅគ្រាដែលបានទស្សនទាយនេះ ត្រូវបានមកដល់ទីបញ្ចប់ ព្រះនៅតែ មានក្រុមនៃអ្នកមានជំនឿស្មោះត្រង់មួយ ដែលប្រកាន់ខ្ជាប់នូវព្រះគម្ពីរ និងការ បង្រៀនរបស់ព្រះគម្ពីរ។

បទទំនាយបានប្រាប់ថា សាតាំងនឹង បង្វិលកំហឹងដ៏ខ្លាំងរបស់វាទៅលើក្រុមជំនុំ របស់ព្រះ ដែលនៅគង់វង់បន្ទាប់ពីពេល វេលា ដែលបានទស្សនទាយនេះ:


100

(ព្រះគម្ពីរ វិវរណៈ ១២:១៧)

"នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញទៅ ច្បាំងនឹងសំណល់ពូជនាងទាំងប៉ុន្មាន


101

ជាពួកអ្នកដែលកាន់តាមបញ្ញត្តិព្រះ ហើយ មានសេចក្តីបន្ទាល់ពីព្រះយេស៊ូវ" វិវរណៈ ១២:១៧។


102

សំណល់គឺជាផ្នែកចុងក្រោយបង្អស់នៃ ក្រណាត់ដែលសល់ពីដុំក្រណាត់ធំមួយ។ ដូចគ្នានេះ "សំណល់" នៃក្រុមជំនុំរបស់ ព្រះ គឺជាផ្នែកចុងក្រោយបង្អស់របស់ក្រុម ជំនុំនោះ. ក្រុមជំនុំដែលនៅសល់ នៅពេល ចុងក្រោយបង្អស់នោះ នាពេលដែលព្រះ យេស៊ូវយាងត្រឡប់មកកាន់ផែនដីនេះវិញ។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


103

ដូច្នេះការបកប្រែជាទូទៅនៃពាក្យនេះ យើងគួរនិយាយថា "សាតាំងបានខឹង...
ហើយបានទៅបង្កើតសង្គ្រាមជាមួយ នឹង ក្រុមជំនុំនាសម័យចុងក្រោយ "សាតាំងខឹង យ៉ាងខ្លាំង
ដោយវាស្គាល់របស់ព្រះនៅតែដើរ តាមសេចក្តីពិតរបស់ព្រះ នៅសម័យចុង ក្រោយនេះ។


104

លោកយ៉ូហានបានពិពណ៌នាអំពី
លក្ខណៈពីរយ៉ាងដែលយើងអាចសំគាល់បានដល់ក្រុមជំនុំចុងក្រោយនេះ:
"នាគបានខឹងនឹងស្ត្រីនោះយ៉ាងខ្លាំង ហើយបានទៅច្បាំងជាមួយនឹងសំណល់ពូជ របស់នាង


105

ដែលគោរពនូវបញ្ញត្តិរបស់ព្រះ ហើយនិង មានទីបន្ទាល់ពីព្រះយេស៊ូវ"
វិវរណៈ ១២:១៧។
អ្នកសំណល់នេះ គឺជាអ្នកដែលគោរព នូវគ្រប់ទាំងបញ្ញត្តិរបស់ព្រះ។


106

មានទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ


107

ប៉ុន្តែតើមិនមែនគ្រប់ពួកជំនុំសាសនាគ្រីស្ទ
ទាំងនោះបាន បង្រៀនថា គ្រីស្ទានទាំង អស់ ត្រូវតែគោរពបញ្ញត្តិរបស់ព្រះទេឬអី?
មិនត្រឹមត្រូវទេ! ប៉ុន្តែ ពួកជំនុំសាសនា ជាច្រើនសព្វថ្ងៃនេះបង្រៀន សមាជិក
របស់គេតាមរបៀបមួយ ផ្សេងទៀត មិនឱ្យគោរពការណែនាំរបស់ព្រះទេ។
ឧទាហរណ៍ ពួកជំនុំខ្លះត្រូវបានបង្រៀន ឱ្យឱនគោរពចំពោះរូបសំណាក។
ខ្លះទៀតបដិសេធភាពបរិសុទ្ធនៃព្រះនាម របស់ព្រះ។


108

(ព្រះគម្ពីរ និក្ខមនំ ២០:៨-១០)
ហើយមនុស្សជាច្រើននៅក្នុងពិភព សាសនា ភ្លេចនូវការរំលឹកពីការបង្កបង្កើត
ដែលបានពណ៌នានៅក្នុងបញ្ញត្តិទីបួន:
"ចូរនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែក ថ្ងៃនោះចេញជាបរិសុទ្ធ


109

ក្នុងរវាង៦ថ្ងៃ នោះត្រូវឱ្យឯងធ្វើអស់ ទាំងការរបស់ឯងចុះ

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


110

តែងថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយ ព្រះយេហូវ៉ាជាព្រះនៃឯងវិញ”
និក្ខមនំ ២០:៨-១០


111

(ព្រះគម្ពីរ វិវរណៈ ១២:១៧)
ក្រុមសំណល់របស់ព្រះ មិនមែនគ្រាន់ តែគោរពបញ្ញត្តិរបស់ព្រះប៉ុណ្ណោះទេ
ប៉ុន្តែ បទទំនាយ ថែមទាំងបាននិយាយ ទៀតថា នឹងមាន “សេចក្តីបន្ទាល់ពីព្រះ យេស៊ូវគ្រីស្ទ”
វិវរណៈ ១២:១៧)


112

(ព្រះគម្ពីរ វិវរណៈ ១៩:១០)
វិវរណៈ ១៩:១០ និយាយថា “ដ្បិតការ ធ្វើបន្ទាល់ពីព្រះយេស៊ូវ នោះហើយជា
វិញ្ញាណនៃសេចក្តីទំនាយ”


113

ពួកជំនុំចុងក្រោយបង្អស់របស់ព្រះនឹង មានអំណោយទានខាងវិញ្ញាណ រាប់បញ្ចូល ទាំងវិញ្ញាណ
នៃបទទំនាយផង។
យើងនឹងសិក្សាអំពីអំណោយទានដ៏ ពិសេសនេះ ឱ្យបានជាក់លាក់នៅពេល ក្រោយទៀត។
ព្រះប្រទានលក្ខណៈដទៃជាច្រើនទៀត សម្រាប់ជួយយើងដើម្បីស្រាវជ្រាវរកនូវពួក
ជំនុំចុងក្រោយរបស់ទ្រង់នេះ។
រាស្ត្ររបស់ទ្រង់នឹងត្រូវបំពេញការងារ
នាំដំណឹងល្អចូលទៅកាន់ពិភពលោកទាំងមូលព្រោះព្រះយេស៊ូវបាន ទាមទារពីពួកជំនុំ របស់ទ្រង់


114

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៩-២០)
“ដូច្នេះចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្ស នៅគ្រប់ទាំងសាសន៍


115

ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវ ព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ


116

ហើយបង្រៀនគេឱ្យកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


117

ហើយមើលខ្ញុំក៏នៅជាមួយនឹងអ្នករាល់ គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន”
ម៉ាថាយ ២៨:១៩-២០។


118

ការត្រាស់បង្គាប់ឱ្យប្រកាសដំណឹងដ៏នៅ
អស់កល្បនៅលើពិភពលោកនេះ ត្រូវបាន បង្ហាញជានិមិត្តរូបនៅក្នុងព្រះគម្ពីរ វិវរណៈ១៤
ដោយទេវតាបីអង្គហោះនៅ លើមេឃ។

ផ្នែកទីមួយនៃសាររបស់ទេវតាបីអង្គនេះ បញ្ជាក់សេចក្តីពិតធំៗពីរ សម្រាប់ចែក
ចាយជាមួយនឹងមនុស្សទាំងអស់:


119

(ព្រះគម្ពីរ វិវរណៈ ១៤:៦,៧)
“ខ្ញុំក៏ឃើញទេវតា១ទៀតកំពុងហោះកាត់ កណ្តាលមេឃ


120

ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សំរាប់នឹងថ្លែងប្រាប់ដល់មនុស្សនៅផែនដី


121

គឺដល់គ្រប់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ


122

ទេវតានោះបន្លឺសំឡេងយ៉ាងខ្លាំងថា “ចូរ កោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អ របស់ទ្រង់ចុះ
ដ្បិតពេលដែលទ្រង់ត្រូវ ជំនុំជំរះ នោះបានមកដល់ហើយ


123

ចូរក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ”
វិវរណៈ ១៤:៦,៧។

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


124

នេះគឺជាការប្រកាសឱ្យដឹងចំពោះអ្នក ដែលរស់នៅ នាម៉ោងចុងក្រោយបង្អស់លើ ពិភពលោកនេះ ដើម្បីឱ្យនឹកចាំថា ថ្ងៃនៃ ការជំនុំជំរះបានមកដល់ហើយ។

វាក៏ជាការរំលឹកអំពីការចងចាំដ៏ធំ អំពី អំណាចនៃការបង្កបង្កើតរបស់ព្រះ គឺថ្ងៃទី ប្រាំពីរ ជាថ្ងៃសម្រាក។

ផ្នែកទីពីរនៃសាររបស់ទេវតាបីអង្គនេះគឺ បានរកឃើញនៅក្នុងខទី៨:


125

(ព្រះគម្ពីរ វិវរណៈ ១៤:៨)

"មានទេវតា១ទៀតមកតាមក្រោយប្រាប់ ថា ក្រុងបាប៊ីឡូនដ៏ជាធំបានរលំហើយ បានរលំហើយ


126

ដ្បិតវាបានឱ្យគ្រប់ទាំងសាសន៍ផឹកស្រានៃ សេចក្តីឃោរឃៅ របស់ការកំផិតរបស់វា" វិវរណៈ ១៤:៨។

ដំណឹងនេះហៅរាស្ត្រស្មោះត្រង់របស់ព្រះ "ឱ្យញែកខ្លួនចេញ" ពីសាសនាច្របូកច្របល់នៅលើពិភពលោកនេះ។

ដំណឹងនេះប្រាប់ពួកគេឱ្យដឹងអំពីការបង្រៀន ខុសពីព្រះគម្ពីរ ដែលមាននៅក្នុងសាសនា សព្វថ្ងៃនេះ

ការអំពាវនាវចុងក្រោយ និងសំខាន់ បំផុត ត្រូវបានផ្តល់ជូននៅក្នុងផ្នែកទីបីនៃ បទទំនាយនេះ:


127

(ព្រះគម្ពីរ វិវរណៈ:១៤:៩-១០)

"រួចមានទេវតាទី៣ មកតាមក្រោយ ទៀត ទាំងបន្លឺដោយសំឡេងយ៉ាងខ្លាំងថា


128

បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វានៅលើ ថ្ងាស ឬនៅដៃ


129

អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅ របស់ព្រះ..."

វិវរណៈ ១៤:៩,១០


130

ពិភពលោកទាំងមូលត្រូវបានប្រកាស ប្រឆាំងនឹងការថ្វាយបង្គំសត្វនិងរូបវា ឬក៏ ទទួលសញ្ញារបស់វា។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព


131

(ព្រះគម្ពីរ យ៉ូហាន ១០:១៦)

ព្រះយេស៊ូវបានមានព្រះបន្ទូលថា "ខ្ញុំ ក៏មានចៀមឯទៀតដែលមិនទាន់នៅក្នុង ក្រោលនេះនៅឡើយ ត្រូវតែខ្ញុំនាំចៀមទាំង នោះមកដែរ


132

វានឹងស្ដាប់តាមសំឡេងខ្ញុំ នោះនឹងមានហ្វូង តែ១ និងអ្នកគង្វាលតែ១វិញ"
យ៉ូហាន ១០:១៦។


133

ព្រះមានអ្នកដើរតាមដ៏ស្មោះត្រង់នៅគ្រប់
ពួកជំនុំ ប៉ុន្តែនឹងមានពេលមកដល់ ដែល នឹងមានក្រុមពិតប្រាកដ ឬក៏ពួកជំនុំពិត មួយ។

ព្រះយេស៊ូវបានមានព្រះបន្ទូលថា ចៀម របស់ទ្រង់នឹងត្រូវបានហៅចេញពីហ្វូងមួយ ទៀត ដែលមិនបានដើរតាមដោយប្រុង ប្រយ័ត្ន នូវការបង្រៀននៃព្រះបន្ទូលរបស់ ទ្រង់!


134

(ព្រះគម្ពីរ វិវរណៈ ១៨_៤)

លោកយ៉ូហានដែលបានទទួលការបើក សំដែងបានទស្សនទាយថា

"ខ្ញុំឮសំឡេង១ទៀតពីលើមេឃ ពោល ថា រាស្ត្រអញអើយ ចូរចេញពីទីក្រុង នោះមក


135

ដើម្បីកុំឱ្យត្រូវមានចំណែក ក្នុងអំពើ បាបវាឡើយ ក្រែងត្រូវវេទនាដូចជាវាដែរ"
វិវរណៈ ១៨:៤។

អ្នកដើរតាមព្រះដ៏ស្មោះត្រង់ នឹងត្រូវ បានហៅឱ្យចេញពីសាសនាខុសឆ្គង និង ច្របូកច្របល់ដែលមាននៅគ្រាចុងបំផុត។
លោកអ្នកនឹងចង់ដឹងអំពីការដែលព្រះគម្ពីរ ពណ៌នា ពីមនុស្សដែលនឹងត្រូវបានហៅ ចេញពីសាសនាច្របូកច្របល់ ដែលនឹង កើតមានឡើងនៅមុនពេលដែលព្រះយេស៊ូវ យាងមកវិញនោះ។


136

(ព្រះគម្ពីរ វិវរណៈ ១៤:១២,១៤)

"នេះហើយជាសេចក្ដីអត់ធ្មត់របស់ពួក បរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្ដីជំនឿ ដល់ព្រះយេស៊ូវ...


137

"នេះខ្ញុំក្រឡេកទៅឃើញពពកស១ ហើយមាន១អង្គដូចជាកូនមនុស្សគង់នៅលើពពកនោះ

# ២០. សេចក្តីពិតដោះអ្នកឱ្យមានសេរីភាព


138

ទាំងពាក់មកុដមាស
ហើយកាន់កណ្តៀវដ៏មុត"
វិវរណៈ ១៤:១២,១៤


139

សូមយើងសង្ខេបសាឡើងវិញអំពីចរិត លក្ខណៈខ្លះរបស់ក្រុមជំនុំសម័យចុងក្រោយ ដ៏ប្រសើ ដូចបានចែងនៅក្នុងព្រះគម្ពីរ


140

ក្រុមជំនុំសំណល់របស់ព្រះត្រូវបានកើត ឡើងបន្ទាប់ពីពេលនៃការបៀតបៀនយ៉ាង ឃោរឃៅមួយ ដែលបានបញ្ចប់នៅឆ្នាំ ១៧៩៨។


141

ពួកគេនឹងមានការទុកចិត្តលើព្រះ
យេស៊ូវ ដែលនឹងដឹកនាំគេឱ្យគោរព បញ្ញត្តិទាំងអស់របស់ព្រះ។


142

ពួកនោះនឹងប្រកាសអំពី ដំណឹងនៃ ការប្រកាសអោយដឹងរបស់ព្រះគម្ពីរវិវរណៈ ទៅកាន់មនុស្សទាំងអស់ ឱ្យរៀបចំសម្រាប់ ការយាងមកវិញរបស់ព្រះយេស៊ូវ។


143

ពួកគេនឹងមានអំណោយទាននៃវិញ្ញាណ រាប់បញ្ចូលទាំងវិញ្ញាណនៃបទទំនាយផង។


144

នៅពេលដែលយើងមើលទៅកាន់ក្រុម ជំនុំគ្រីស្ទាន វាហាក់បីដូចជាក្រុមទាំងឡាយ នោះដូចគ្នាទាំងអស់

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព


145

ប៉ុន្តែនៅពេលដែលអ្នកសិក្សាអំពីការពណ៌នា របស់សេចក្ដីពិត អ្នកដែលស្មោះត្រង់ក្នុង ព្រះបន្ទូលដ៏បរិសុទ្ធរបស់ទ្រង់ វាជាការ ងាយបំផុតដើម្បីបញ្ជាក់ថា មួយណាដែល មិនមានលក្ខណៈដូចព្រះគម្ពីរបានចែង។

ប្រហែលលោកអ្នកកំពុងស្រាវជ្រាវ ប្រឹងប្រែងញែករកនូវក្នុងសាសនាច្របូក ច្របល់ នៅលើពិភពលោកសព្វថ្ងៃ ដើម្បី ស្វែងរកពួកជំនុំចុងក្រោយរបស់ព្រះនេះ។

ខ្ញុំជឿថា មានពួកជំនុំពិតតែមួយគត់។ គឺជាក្រុមជំនុំដែលជឿលើព្រះគម្ពីរ មាន ព្រះគ្រីស្ទជាមូលដ្ឋាន គោរពថ្ងៃបរិសុទ្ធ ចលនារង់ចាំ(អាត់វេនម្ទីម៉េន)ទូទាំងពិភព លោក។

ហេតុដូច្នេះហើយបានជាខ្ញុំជាអ្នក សេវេនដេយអាត់វេនទីស្ទ ខ្ញុំជឿថា ក្រុម ជំនុំនេះនឹងមានគ្រប់លក្ខណៈទាំងអស់នោះ។


146

នៅពេលដែលយើងបានសិក្សាអំពីបទ ទំនាយដ៏គួរឱ្យចាប់អារម្មណ៍នេះ លោកអ្នក អាចឃើញយ៉ាងច្បាស់ថា ព្រះពិតជាមាន ដំណឹងពិសេស ហើយនិងមនុស្សពិសេស ដែលនឹងពាំនាំដំណឹងនេះទៅកាន់ពិភពលោកទាំងមូល។

ប៉ុន្តែ ប៉ុណ្ណេះមិនទាន់គ្រប់គ្រាន់ នឹង ដឹងអំពីហេតុការណ៍ពិតរបស់ព្រះគម្ពីរនេះទេ។


147

ដើម្បីឱ្យមានសេចក្ដីសុខសាន្ត និង សេចក្ដីរីករាយ ដែលចេញមកពីការងារ ដ៏ពេញ លេញជាមួយនឹងព្រះយេស៊ូវគ្រីស្ទ វាជាការ ចាំបាច់សម្រាប់លោកអ្នកបោះជំហាន ហើយដើរតាមសេចក្ដីពិតដែលបានបើក សំដែងនៅក្នុងព្រះបន្ទូលរបស់ព្រះ ដូចព្រះ យេស៊ូវបានមានព្រះបន្ទូលថា


148

(ព្រះគម្ពីរ យ៉ូហាន ១៣:១៧)

"បើអ្នករាល់គ្នាដឹងសេចក្ដីទាំងនេះ ហើយប្រព្រឹត្តតាមនោះ មានពរហើយ"
យ៉ូហាន ១៣:១៧។

# ២០. សេចក្ដីពិតដោះអ្នកឱ្យមានសេរីភាព



149

ព្រះអញ្ជើញលោកអ្នកឱ្យធ្វើការសម្រេច ចិត្តដ៏សំខាន់មួយសម្រាប់ជីវិតលោកអ្នក។

តើលោកអ្នកជឿថា លោកអ្នកបានឮ ព្រះបន្ទូលរបស់ព្រះ បានប្រកាសដល់លោក អ្នក នៅក្នុងការរៀនមេរៀននេះឬទេ?

តើលោកអ្នកជឿថា លោកអ្នកបានឮ សេចក្ដីពិត បានប្រកាសនៅក្នុងមេរៀននេះ ឬទេ?

តើលោកអ្នកជឿថា ព្រះវិញ្ញាណបរិសុទ្ធ កំពុងអង្រួនចិត្តលោកអ្នក នៅក្នុងមេរៀន នេះឬទេ?

នៅពេលដែលយើងឮព្រះបន្ទូលរបស់ ព្រះ នៅពេលដែលយើងស្ដាប់សេចក្ដីពិត របស់ព្រះ ព្រះវិញ្ញាណបរិសុទ្ធញុំាងឱ្យយើង ធ្វើការសម្រេចចិត្តមួយ។

ឥឡូវនេះដល់ពេលធ្វើការសម្រេចចិត្ត ហើយ។

សូមលោកអ្នកនិយាយថា "បពិត្រព្រះ អម្ចាស់ ទូលបង្គំសូមទទួលព្រះបន្ទូលរបស់ ទ្រង់។ បពិត្រព្រះយេស៊ូវ ទូលបង្គំចង់ដើរ តាមសេចក្ដីពិតរបស់ទ្រង់។ បពិត្រ ព្រះ យេស៊ូវ ទូលបង្គំសូមទទួលការណែនាំរបស់ ព្រះវិញ្ញាណបរិសុទ្ធទាំងស្រុង។ ទូលបង្គំ សម្រេចចិត្តដើរតាមផ្លូវនៃសេចក្ដីពិត"

ប្រសិនបើនេះជាសេចក្ដីសម្រេចចិត្ត របស់លោកអ្នក សូមលោកអ្នកអញ្ជើញ ក្រោកឈរឡើង នៅពេលដែលយើង អធិស្ឋានឥឡូវនេះ?

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



1

ព្រះនៅតែមានព្រះបន្ទូលតាមរយៈហោរារបស់ទ្រង់


2

នៅផ្នែកផ្សេងៗគ្នានៃពិភពលោកនេះ  អ្នកវិទ្យាសាស្ត្រ បានប្រើវិទ្យុស្រូបសំឡេងពីភពផ្សេងៗនៅខាងក្រៅផែនដី ដើម្បីនឹង ស្តាប់សំឡេងពីភពដទៃទាំងនោះ។


3

ពួកគេសង្ឃឹមថា ប្រហែលជាមានថ្ងៃ ណាមួយ ពួកគេនឹងឮដំណឹងពីមនុស្សដែលមានប្រាជ្ញាពីភពដទៃទៀត។


4

មានភស្តុតាងថា មានដំណឹងមកកាន់ ផែនដីនេះរាប់ពាន់ឆ្នាំមកហើយ តែមនុស្សតិចណាស់ដែលកំពុងស្តាប់ដំណឹងនេះ។

វាគឺជាដំណឹងរបស់ព្រះដែលបង្កើតភព នេះ ជាដំណឹងនៃសេចក្តីស្រឡាញ់ពីព្រះ មួយអង្គកំពុងខំប្រឹងប្រែងនាំកូនចៅរបស់ ទ្រង់ដែលប្រឆាំងបះបោរឱ្យត្រឡប់មកវិញ។


5

ការបំបែករវាងព្រះនិងមនុស្សជាតិ មិន មែនមាននៅជាអចិន្ត្រៃយ៍នោះទេ។ អ្វីៗទាំងអស់ចាប់ផ្តើមឡើងយ៉ាងល្អ នៅលើ ភពផែនដីនេះ-ពិភពលោកដ៏ល្អសម្រាប់ មនុស្សពីរនាក់-ដែលត្រូវបានបង្កើតតាមរូប អង្គរបស់ព្រះ!



6

(វីដេអូ ៧វិនាទី) ហើយនៅក្នុងសួនច្បារ ដែលជាលំនៅរបស់គេ ព្រះបានយាងមក រកពួកគេ ហើយមាន ព្រះបន្ទូលជាមួយ ពួកគេមុខទល់នឹងព្រះភ័ក្ត្រ។ សូមស្រមៃ គិតមើល ពួកគេកំពុងដើរលំហែជាមួយ ព្រះនៅ ពេលល្ងាចត្រជាក់មួយ!


7

នេះហើយជាផែនការ ដែលព្រះបាន រៀបចំ វាជាទំនាក់ទំនងដ៏អស្ចារ្យនៃការជួប ជុំគ្នាមួយ! គ្មានអ្វីដែលធ្វើឱ្យពួកគេបែក ចេញពីព្រះឡើយ! នេះពិតជាការមកលេង ដ៏សប្បាយជាមួយគ្នា។


8

ប៉ុន្តែវាគួរឱ្យពិបាកនិយាយណាស់ ទំនាក់ ទំនងនៃសេចក្តីស្រឡាញ់និង ភាពជួបជុំគ្នានេះមានអាយុបានត្រឹមតែពីរជំពូក នៅក្នុង ព្រះគម្ពីរប៉ុណ្ណោះ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


9

ព្រះគម្ពីរលោកុប្បត្តិជំពូក៣ ប្រាប់អំពី រឿងដ៏គួរឱ្យសោកស្តាយនេះ។ អ័ដាម និង នាងអេវ៉ាបានធ្វើបាប។


10

ពួកគេបានប្រឆាំងទៅនឹងច្បាប់នៃ សេចក្តីស្រឡាញ់របស់ព្រះ-អំពើបាបបានបំ បែកពួកគេ។ អំពើបាបនិងព្រះ មិនត្រូវគ្នា សោះឡើយ។ អ័ដាមនិងនាងអេវ៉ា មិន អាចទាក់ទងដោយផ្ទាល់ និងប្រកបជាមួយ ព្រះបានទៀតឡើយ។


11

ពួកគេបានស្តាប់ពស់លុយស៊ីហ្វ័រ ហើយបានស្តាប់បង្គាប់វាជំនួសព្រះវិញ-នោះ ហើយគឺជាអំពើបាប។


12

(ព្រះគម្ពីរ លោកុប្បត្តិ ៣:៨)

ព្រះគម្ពីរនិយាយថា "រួចមកបានឮសំ ឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់បាន យាងក្នុងសួនច្បារ នៅពេលថ្ងៃល្ហើយ:


13

នោះអ័ដាម និងប្រពន្ធគាត់ ក៏ពួននឹងព្រះ យេហូវ៉ាដ៏ជាព្រះ


14

នៅកណ្តាលដើមឈើក្នុងសួនច្បារ"

លោកុប្បត្តិ ៣:៨។

អ័ដាមនិងអេវ៉ាបានពួន! ពួកគេមិនចង់ ជួបនឹងព្រះឡើយ។ គេចង់តែរត់ពួន។ នោះហើយជាការដែលអំពើបាបធ្វើ។ វា បានបំបែក និងកំចាត់កំចាយទំនាក់ទំនងនៃ សេចក្តីស្រឡាញ់រវាងព្រះ និងមនុស្ស ហើយរវាងមនុស្ស និងមនុស្សដទៃដូចគ្នា។


15

វាបានបំបែក និងកំចាត់កំចាយទំនាក់ ទំនងនៃសេចក្តីស្រឡាញ់រវាងព្រះនិងមនុស្ស ហើយរវាងមនុស្ស និងមនុស្សដទៃដូចគ្នា។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


16

(ព្រះគម្ពីរ អេសាយ ៥៩:២)

ហោរាអេសាយបានសរសេរថា "គឺជា អំពើទុច្ចរិតរបស់ឯងរាល់គ្នា ដែលបាន ខណ្ឌជាកណ្តាលឯង ហើយនិងព្រះ នៃឯង ទេតើ


17

ហើយអំពើបាបរបស់ឯងរាល់គ្នា បានបាំងព្រះ ភក្ត្រទ្រង់មិនឱ្យឯងឃើញ..." អេសាយ ៥៩:២។

មែនហើយ អំពើបាបបានបំបែកយើងចេញពី ព្រះ ប៉ុន្តែវាមិនបានបំបែកយើងចេញពី សេចក្តីស្រឡាញ់របស់ទ្រង់ឡើយ។ ព្រះ បានរកឃើញវិធី ដើម្បីទាក់ទងជាមួយនឹង មនុស្សមានបាប។ សេចក្តីស្រឡាញ់ តែង តែរកឃើញនូវវិធីទាក់ទងជានិច្ច!


18

ព្រះអង្គបានបង្កើតវិធីមួយទៀត នៃទំ នាក់ទំនងជាមួយនឹងកូនរបស់ទ្រង់នៅលើ ភពផែនដីនេះ- វិធីនៃការដឹកនាំនិងបង្រៀន ព្រមទាំងបើកសំដែងឱ្យឃើញនូវផែនការ របស់ទ្រង់។

ទ្រង់បានជ្រើសរើសយកបុរស និងស្ត្រី ដែលទ្រង់អាចទុកចិត្តឱ្យធ្វើជាផ្នែកនៃព្រះឱស្ឋរបស់ទ្រង់ ដើម្បីទាក់ទងសេចក្តីស្រឡាញ់ និងផែនការរបស់ទ្រង់ទៅកាន់មនុស្សលោក។


19

ក្នុងចំណោមអ្នកដែលទ្រង់បានជ្រើសរើស នោះមាន លោកម៉ូសេ មីរីយ៉ាម សាំយ៉ូអែល អេលីយ៉ា ហ៊ុលដា ដេបូរ៉ា អេសាយ យេរេមា និងហោរាជាច្រើន នាក់ផ្សេងទៀត។


20

ហោរាប្រុស ស្រី ទាំងនោះគឺជាអ្នកនាំ ពាក្យរបស់ព្រះ!


21

នេះគឺជាវិធីនៃការមានព្រះបន្ទូលរបស់ ទ្រង់ថា "ខ្ញុំស្រឡាញ់អ្នក ខ្ញុំយកចិត្តទុក ដាក់ចំពោះអ្នក និងខ្ញុំមានផែនការសម្រាប់ អ្នក"


22

ព្រះគម្ពីរកត់ត្រានូវការសន្ទនាជាច្រើន រវាងព្រះអម្ចាស់ និងតួអង្គនៅក្នុងព្រះគម្ពីរ ផ្សេងៗជាច្រើននាក់ ប៉ុន្តែមិនមែនដូចជា ការសន្ទនា និងការប្រកបគ្នាដែលអ័ដាម និងអេវ៉ាមាន នៅក្នុងសួនច្បារអេដែននោះ ទេ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


23

ជួនកាលព្រះមានព្រះបន្ទូលតាមរយៈ ព្រះវិញ្ញាណបរិសុទ្ធ ជួនកាលតាមរយៈ ទេវតាបរិសុទ្ធ ហើយជួនកាលទៀត តាម រយៈមនុស្សដែលទ្រង់ជ្រើសរើសជាអ្នកនាំដំណឹងរបស់ទ្រង់។

នៅក្នុងកំឡុងពេល ២៥០០ឆ្នាំនៃប្រវត្តិ សាស្ត្រមនុស្សលោក គ្មានការបើកសំដែង ជាលាយល័ក្ខអក្សរមកពីព្រះ ដូចដែល យើងបានរកឃើញនោះទេ។

អ្នកដែលត្រូវបានបង្រៀនដោយព្រះនោះ បានចែកចាយផ្ទាល់មាត់ត១គ្នា នូវអ្វីដែល ព្រះបានមានព្រះបន្ទូល ប្រាប់ដល់ពួកគេ។

ប៉ុន្តែប្រឡាយដែលព្រះគ្រីស្ទជ្រើសរើស យកមកប្រើជាញឹកញាប់ជាងគេបំផុត ដើម្បីបង្ហូរទំនាក់ទំនងពីទ្រង់ ទៅកាន់រាស្ត្រ របស់ព្រះអង្គនោះគឺ


24

(ព្រះគម្ពីរ អេម៉ុស ៣:៧)

គឺតាមរយៈហោរាប្រុស ហោរាស្រី បុរស និងស្ត្រី ដែលនិយាយជំនួសព្រះវិញ្ញាណ បរិសុទ្ធវិញ។

ការនេះគ្មានអ្វីដែលគួរឱ្យភ្ញាក់ផ្អើលខ្លាំង នោះទេ ព្រោះព្រះគម្ពីរបានចែងយ៉ាង ច្បាស់ថា "ពិតប្រាកដជាព្រះយេហូវ៉ា ទ្រង់ នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់ សំដែងឱ្យពួកហោរា ជាអ្នកបំរើទ្រង់ឃើញ គំនិតលាក់កំបាំងរបស់ទ្រង់ផង"

អេម៉ូស ៣:៧។


25

ចូរយើងកត់សំគាល់នូវការដែលហោរា ទាំងនោះទទួលដំណឹងរបស់ពួកគេ:


26

(ព្រះគម្ពីរ ពេត្រុសទី២ ១:២១)

"ដ្បិតសេចក្ដីទំនាយមិនដែលមក ដោយ បំណងចិត្តមនុស្សទេ


27

គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបាន ទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់ បណ្ដាលវិញ"

ពេត្រុសទី២ ១:២១

ព្រះមានហោរាពិតប្រាកដណាស់ តាំង តែពីមុនជំនាន់ទឹកជំនន់ សម័យលោក ណូអេទៅទៀត។


28

(ព្រះគម្ពីរ យូដាស១៤)

លោកហេណុក បានប្រកាសពីការយាង មករបស់ព្រះគ្រីស្ទ "ឯហេណុក ជាដំណទី ៧ពីលោកអ័ដាមមក គាត់បានទាយពី មនុស្សទាំងនោះថា

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


29

មើលព្រះអម្ចាស់ទ្រង់យាងមកនៅ កណ្តាលពួកបរិសុទ្ធទ្រង់ ទាំងសល់សែន"
យូដាស ១៤។
លោកហេណុក គឺជាមនុស្សទីមួយដែល បានពណ៌នានៅក្នុងព្រះគម្ពីរថា ជាអ្នកមាន
អំណោយទានខាងបទទំនាយ។
ប៉ុន្តែនៅមានអ្នកដទៃជាច្រើនទៀត!


30

(ព្រះគម្ពីរ កិច្ចការ ៣:២១)
ព្រះគម្ពីរនិយាយថា "ដែលព្រះបាន មានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់
នៃពួកហោរាបរិសុទ្ធរបស់ទ្រង់ តាំងពី បុរាណមក"
កិច្ចការ ៣:២១។
លោកណូអេគឺជាហោរាម្នាក់ទៀត ដែលបានប្រាប់ឱ្យដឹងជាមុន អំពីការវេទនា
របស់ពិភពលោកដោយសារ ទឹកជំនន់១២០ ឆ្នាំ មុនការនោះបានកើតឡើង។


31

ក្រោយទឹកជំនន់ យើងបានរកឃើញ ហោរាប្រុស ស្រីជាច្រើនទៀត រួមមាន
ម៉ារាម ដេបូរ៉ា យេរេមា អេសាយ អេសេគាល និងហោរាផ្សេងៗជាច្រើន ទៀត។
ពួកគេគឺជាគ្រូបង្រៀនអំពីសេចក្តី សុចរិត។ ពួកគេជាអ្នកដឹកនាំសីលធម៌ និង ខាងព្រលឹងវិញ្ញាណ។
ជាអ្នកនិយាយជំនួសព្រះ។


32

ជួនកាលព្រះបើកសំដែងព្រះហឫទ័យ របស់ទ្រង់តាមរយៈហោរា ប្រុស ស្រី ដោយការជាក់ស្តែង
ជួនកាល ដោយសារ ការយល់សប្តិ ហើយជួនកាលទៀត ដោយ សារព្រះបន្ទូលផ្ទាល់របស់ព្រះ។
ប៉ុន្តែតែងតែតាមរយៈព្រះវិញ្ញាណបរិសុទ្ធ
ជានិច្ច។


33

(ព្រះគម្ពីរ ជនគណនា ១២:៦)
ព្រះអម្ចាស់បានមានព្រះបន្ទូលថា "...បើមានហោរាណានៅក្នុងពួកឯងរាល់គ្នា
នោះអញដ៏ជាព្រះយេហូវ៉ា អញនឹងឱ្យអ្នក នោះស្គាល់អញក្នុងការជាក់ស្តែង


34

ហើយអញនឹងនិយាយនឹងអ្នកនោះ ដោយ ការពន្យល់សប្តិ"
ជនគណនា ១២:៦។
ជួនកាលអ្នកនាំពាក្យរបស់ព្រះ ត្រូវបាន ណែនាំឱ្យនិយាយជំនួសព្រះ ជួនកាលពួក គេត្រូវសរសេរ
ឬកត់ត្រាដំណឹងអំពីទ្រង់។
ជាការជាក់ស្តែងព្រះគម្ពីរ គឺជាស្នាដៃនៃ ការងាររបស់ពួកហោរា។
អ្នកនិពន្ធនីមួយៗគឺជាចំណែកនៃផែនការ របស់ព្រះ។

២១. ព្រះរាជសារពីនគរស្ថានសួគ៌

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


35

ពួកគេទាំងអស់បាននិយាយ ឬសរសេរ ជំនួសទ្រង់ ដែលបានបណ្ដាលដោយព្រះ វិញ្ញាណបរិសុទ្ធ”
តាមរយៈពួកគេ ព្រះបានបញ្ជូនលិខិត នៃសេចក្ដីស្រឡាញ់ ទៅកាន់កូនរបស់ព្រះ
អង្គនៅលើផែនដីនេះ។


36

នេះគឺជារបៀបដែលទ្រង់មានព្រះបន្ទូល
៉ថា “ខ្ញុំស្រឡាញ់អ្នក ហើយខ្ញុំចង់ទាក់ ទងជាមួយនឹងអ្នក”
ហើយជាពិសេស ទ្រង់ចង់ឱ្យយើងដឹង ថា ទ្រង់រង់ចាំពេលវេលាដែលអាចប្រកប
ជាមួយយើងមុខទល់នឹងព្រះភ័ក្ត្រ!


37

អ្នកនិពន្ធទាំងអស់នៅក្នុងព្រះគម្ពីរសញ្ញា ថ្មី-ម៉ាថាយ ម៉ាកុស លូកា យ៉ូហាន ប៉ុល យ៉ាកុប ពេត្រុស
និងយូដាស-គឺជាចំ ណែកនៃផែនការនេះ។
ទាំងអស់គ្នាសុទ្ធតែមានអំណោយនៃបទ
ទំនាយ។
ជាការពិតណាស់ មានហោរាជាច្រើន ទៀត ដែលនិយាយជំនួសព្រះនៅពេល នោះ: ស៊ីម៉ូន
អ័ក្កាបុស បាណាបាស និងអាណ


38

(ព្រះគម្ពីរ កិច្ចការ ២១:៩)
ហើយនិងកូនស្រីទាំងបួនរបស់ភីលីព “ដែលចេះទាយទំនាយ”
ទាំងអស់គ្នាគឺជាឧបករណ៍ ដែលព្រះ បានប្រើ ដើម្បីបើកសំដែងបំណងព្រះ ហឫទ័យរបស់ទ្រង់
ហើយនិង ដើម្បីលើក ទឹកចិត្តដល់ពួកជំនុំដំបូង។


39

ហើយបន្ទាប់មក ព្រះយេស៊ូវបានយាង មកស្រាយបញ្ជាក់ដោយព្រះអង្គឯង ដោយ ព្រះបន្ទូល
និងសកម្មភាព អំពីលក្ខណៈ របស់ព្រះ។
ពិភពលោកមិនដែលឃើញមានអ្នកនាំ ពាក្យណា ដែលមានវោហារវថី នៃសេចក្ដី ស្រឡាញ់
និងយកចិត្តទុកដាក់ខ្លាំងដូច្នេះ ឡើយ។


40

ជិតម្ភៃសតវត្សរ៍មកហើយ ដែល ទស្សនីយភាពនៅភ្នំរលាក្បាល(កាល់វ៉ារី)
បានកន្ទងផុតទៅ តែមនុស្សប្រុស ស្រី ក្មេង ចាស់ នៅតែលុតជង្គង់នៅជើង ឈើឆ្កាង
ដើម្បីនឹងសូត្រពាក្យសច្ចា ប្រណិធាន និងភក្ដីភាព ដែល មិនចេះ រលប់បាត់បង់របស់គេ
ទៅកាន់ព្រះអង្គ សង្គ្រោះនៃពិភពលោកនេះ!
នៅពេលដែលព្រះយេស៊ូវយាងទៅកាន់ ស្ថានសួគ៌ ព្រះគម្ពីរនិយាយថា ទ្រង់បាន
ប្រទានអំណោយទានទៅមនុស្ស-អំណោយ ទានដែលអាចនឹងពង្រឹងកម្លាំង និងលើក
ទឹកចិត្តដល់អ្នកដែលដើរតាមទ្រង់:

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


41

(ព្រះគម្ពីរ អេភេសូរ ៤:៨)

"បានជាទ្រង់មានបន្ទូលថា ដែលបាន យាងឡើងទៅស្ថានខ្ពស់ នោះទ្រង់បានចាប់ពួកឈ្លើយនាំទៅជាឈ្លើយ ហើយបានប្រ ទានអំណោយទានដល់មនុស្ស"

អេភេសូរ ៤:៨

តើអ្វីទៅដែលជាអំណោយទានទាំងនេះ


42

(ព្រះគម្ពីរ អេភេសូរ ៤:១១-១៥)

ព្រះគម្ពីរនិយាយថា "ហើយទ្រង់បាន ប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវក ខ្លះជាគ្រូ អធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ហើយខ្លះជាគ្រូបង្រៀន"

អេភេសូរ ៤:១១។


43

តើហេតុអ្វីបានជាព្រះយេស៊ូវជ្រើសរើស ប្រគល់អំណោយទាននេះដល់ក្រុមជំនុំ?

ខទី១២ និយាយថា "ប្រយោជន៍នឹងនាំឱ្យ ពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ ធ្វើការជំនួយ ហើយនិងស្អាងរូបកាយព្រះ គ្រីស្ទឡើង"


44

តើអំណោយទាននេះមាននៅក្នុងពួកជំនុំ យូរប៉ុនណាទៅ? "ទាល់តែយើងរាល់គ្នា បានរួបរួមខាងសេចក្តីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូច គ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស


45

ហើយដល់ខ្នាតកំពស់នៃសេចក្តីពោរពេញផង ព្រះគ្រីស្ទ"

ខទី១៣។

ព្រះគម្ពីរនិយាយថា អំណោយទានទាំង នេះ អាចនឹងផ្តល់នូវលំនឹងដល់ពួកជំនុំ និងពង្រឹងកម្លាំងដល់មនុស្ស


46

"ដើម្បីកុំឱ្យយើងនៅជាកូនតូចទៀត ទាំងត្រូវរអស់គ្រប់ទាំងខ្យល់នៃសេចក្តីបង្រៀនបោក ហើយផាត់យើងចុះឡើង


47

ដោយសេចក្តីឆបោករបស់ផងមនុស្ស ហើយឧបាយកល ដែលគេប្រើនឹងនាំឱ្យ វង្វេងទៀតឡើយ"

ខទី១៤។

សូមកត់សំគាល់ថា អំណោយទានខាង បទទំនាយដែលមានរាយក្នុងបញ្ជីនៃ "អំណោយទានខាងវិញ្ញាណ" ដូចលោកប៉ុល បានហៅ អំណោយទានទាំងនោះថា:

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


48

(ព្រះគម្ពីរ កូរិនថូសទី១ ១២:២៨)
"ព្រះទ្រង់បានតាំងអ្នកខ្លះក្នុងពួកជំនុំ
ឡើង មុនដំបូងគឺជាសាវក ទី២គ្រូអធិប្បាយ(ឬ ហោរា សូមមើល រ៉ូម១:២)..."


49

អំណោយទានខាងបទទំនាយ ឈរនៅ លំដាប់ថ្នាក់ទី២ បន្ទាប់ពីពួកសាវកតែ ប៉ុណ្ណោះ ប៉ុន្តែវាជាអំណោយទានដ៏សំខាន់ និងចាំបាច់ជាទីបំផុត ដើម្បីជួយដល់ពួកជំនុំឱ្យមានដំណើរការបានល្អ។


50

លោកប៉ុលបានប្រៀបធៀបអំណោយទាន
ខាងវិញ្ញាណ ទៅនឹងផ្នែកផ្សេងៗនៃរាង កាយ។
គាត់បានបង្ហាញថា ភ្នែក ក្បាល មាត់ និងផ្នែកផ្សេងៗទៀតនៃរាងកាយ សុទ្ធតែសំខាន់សម្រាប់រាងកាយ ទាំងអស់ ដើម្បី ដំណើរការអោយស្របគ្នា និងមានប្រសិទ្ធ ភាព។
ដូចជាពួកជំនុំយ៉ាងដូច្នោះដែរ។
ឧទាហរណ៍ បើគ្មានការបើកសំដែងទេ ពួកជំនុំនឹងទៅជាខ្វាក់!


51

(ព្រះគម្ពីរ សុភាសិត ២៩:១៨)
"គ្រាណាឥតមានការបើកសំដែង នោះ បណ្តាជនរមែងលែងទប់ចិត្ត តែអ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់ នោះ សប្បាយហើយ"
សុភាសិត ២៩:១៨។


52

ប៉ុន្តែលោកអ្នកនិយាយថា "តើ អំណោយទានខាងបទទំនាយនោះនឹងទៅជា យ៉ាងណា បន្ទាប់ពីព្រះយេស៊ូវយាងឡើង ទៅកាន់ស្ថានសួគ៌ ហើយសាវករបស់ទ្រង់ បានស្លាប់អស់ទៅនោះ?"


53

កន្លងផុតទៅមិនទាំងបានប៉ុន្មានជំនាន់ផង
ពួកជំនុំបានក្លាយទៅជាគ្មានការយកចិត្ត ទុកដាក់ សម្របសម្រួលសេចក្តីជំនឿ ព្រមទាំងមិនស្មោះត្រង់ជាមួយនឹងព្រះ និង បញ្ញត្តិរបស់ទ្រង់។
លោកយេរេមា បានកត់ត្រានូវអ្វីដែល បានកើតឡើង នៅពេលដែលពួកអ៊ីស្រាអែលបានបោះបង់ជំនឿមួយរយៈពេលនោះ:

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


54

(ព្រះគម្ពីរ បរិទេវ ២:៩)
"ឃ្លាតផុតពីក្រិត្យវិន័យ អើទាំងពួក ហោរា ក៏លែងឃើញការជាក់ស្តែងពីព្រះ យេហូវ៉ាទៀតដែរ" បរិទេវ ២:៩។


55

នៅពេលដែលក្រុមជំនុំដំបូងទទួលយក ចរិត និងការអនុវត្តន៍របស់ពួកមិនជឿព្រះ និងបោះបង់ចោល នូវគ្រឹះនៃសេចក្តីពិតនៃ ព្រះគម្ពីរនោះ អំណោយទានខាងវិញ្ញាណ នោះក៏ត្រូវបានដកយកចេញម្តងមួយៗដែរ។


56

នៅសម័យដែលគេបង្រៀនខុសពីព្រះ គម្ពីររបស់ពួកជំនុំ ឬយុគសម័យខ្មៅងងឹត ព្រះគម្ពីរ ត្រូវបានគេដាក់ច្រវាក់ភ្ជាប់ទៅ នឹងអាសនារបស់បុព្វជិតតែប៉ុណ្ណោះ។
ជាទូទៅ ព្រះគម្ពីរត្រូវបានគេសរសេរជា ភាសា ហេព្រើរ ក្រេក និងឡាតាំង។


57

មនុស្សសមញ្ញត្រូវបានគេហាមឃាត់មិន ឱ្យមាន ឬអានព្រះគម្ពីរឡើយ។
មានតែសង្ឃប៉ុណ្ណោះ ដែលបាន អនុញ្ញាតឱ្យអាន និងបកស្រាយព្រះគម្ពីរ។
មានគ្រីស្ទានមួយចំនួនតិចណាស់ដែល បានកាន់ខ្ជាប់ នូវព្រះគម្ពីរ និងសេចក្តីពិត របស់ព្រះគម្ពីរ។
ថ្វីបើមានការបៀតបៀនក៏ដោយ គេនៅ តែបន្តការងារផ្សាយដំណឹង ហើយចែក ចាយនូវចំណែក ព្រះគម្ពីរដែលគេមាននោះ។
ពួកគេបានសាបព្រោះពូជនៃការកែទម្រង់ជា
យូរយារមុន វីគ្លីហ្វ លូធើរ និងហាសទៅ ទៀត។



58

(វីដេអូ ៨វិនាទី)លោកម៉ាធិន លូធើរ និងអ្នកដទៃខ្លះទៀត បានបកប្រែព្រះគម្ពីរ ជាភាសាសាមញ្ញរបស់មនុស្ស។ ការបៀត បៀនក៏បានមកដល់ ប៉ុន្តែវាគ្រាន់តែ បណ្តាលឱ្យការ ប្រាថ្នាចង់បាននូវព្រះ បន្ទូលរបស់ព្រះ កាន់តែរីកខ្លាំងឡើងទៅ វិញតែប៉ុណ្ណោះ។


59

ហើយនៅពេលដែលមនុស្សចាប់ផ្តើម
ស្រាវជ្រាវព្រះគម្ពីរយ៉ាងយកចិត្តទុកដាក់
សេចក្តីពិតពីដើម ដែលបានលាក់ទុក រាប់សតវត្សរ៍មកហើយនោះក៏ត្រូវបានគេ រកឃើញ។
សេចក្តីពិតនោះក៏ត្រូវបាននាំឱ្យ មាន ការចាប់អារម្មណ៍ដល់បណ្តាជន ហើយបានផ្តល់លទ្ធផល ជាការភ្ញាក់រលឹក ខាងសាសនាមួយ

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


60

នៅពេលនោះឯងហើយ ដែលការចាប់ ផ្តើមចលនាសាសនាថ្មីមួយបានមកដល់-ក្រុមនៃគ្រីស្ទានដ៏ដាច់ខាត ខ្លះជាពួក
បាបទីស្ទ ខ្លះជាពួកមេតូឌីស្ទ ខ្លះទៀតជាពួក ប្រេសប៊ីធើរៀន ហើយនិងមានពួកជំនុំផ្សេងៗជទៃទៀតជាច្រើន-បានស្រាវជ្រាវ ព្រះគម្ពីរ និងអធិស្ឋានដើម្បីសុំពន្លឺ



61

នៅពេលដែលគេបានស្រាវជ្រាវអំពីព្រះ គម្ពីរ គេបានរកឃើញនៅក្នុងបញ្ញត្តិទីបួននៃការនឹកចាំដ៏ធំអំពីថ្ងៃនៃការបង្កបង្កើត ដែល ព្រះបានសុំឱ្យរាស្ត្ររបស់ទ្រង់ "នឹកចាំ" ពួកគេបានអានសៀវភៅវិវរណៈ ហើយ បានឃើញការពិពណ៌នា អំពីរាស្ត្រចុងក្រោយបង្អស់របស់ព្រះ


62

(ព្រះគម្ពីរ វិវរណៈ ១៤:១២)

"នេះហើយជាសេចក្តីអត់ធ្មត់របស់ពួក បរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះ ហើយមានសេចក្តីជំនឿ ដល់ព្រះយេស៊ូវ"
វិវរណៈ ១៤:១២។

នៅពេលដែលគេបានអាន និងសិក្សា ខព្រះគម្ពីរដទៃទៀត ពួកគេបានដឹងយ៉ាង ច្បាស់ថា ការគោរពបញ្ញត្តិរបស់ព្រះ រួម បញ្ចូលទាំង ការគោរពថ្ងៃបរិសុទ្ធនៅក្នុង ព្រះគម្ពីរផងដែរ។



63

ពួកគេបានទទួលការចងចាំនូវការបង្ក បង្កើត ហើយបានប្រកាសសេចក្តីពិត នៃថ្ងៃបរិសុទ្ធទៅដល់ពិភពលោក



64

(វីដេអូ ១១វិនាទី)ចុះអំណោយទានខាងបទ ទំនាយវិញ តើយ៉ាងណាដែរ? តើព្រះលើកអំណោយទាននៃបទទំនាយ ជាពិសេស ឡើង នៅក្នុងចំណោមអ្នកដែលគោរព ថ្ងៃបរិសុទ្ធនៅសម័យចុងក្រោយនេះដែរ ឬទេ? តើព្រះមានអ្វីពិសេសឬទេ?

តើវាមិនសមហេតុផលទេឬអី ដែលគិត ថា ព្រះមានព្រះបន្ទូលពិសេស ដើម្បីថ្លែងទៅកាន់មនុស្សនៅជំនាន់នេះនោះ?


65

(ព្រះគម្ពីរ យ៉ូអែល ២:២៨,៣១)

សូមស្តាប់ "ក្រោយគ្រានោះមក អញ នឹងចាក់វិញ្ញាណរបស់អញ ទៅលើគ្រប់ ទាំងមនុស្ស

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


66

នោះកូនប្រុសស្រីរបស់ឯងនឹងទាយ ពួក ចាស់ៗរបស់ឯងនឹងយល់សប្តិឃើញ ហើយ
ពួកកំឡោះៗរបស់ ឯងនឹងឃើញការជាក់ ស្តែង”


67

“...មុនដែលថ្ងៃគួរស្ញែងខ្លាចរបស់ព្រះ យេហូវ៉ាបានមកដល់”
យ៉ូអែល ២:២៨,៣១។


68

សូមបញ្ជាក់ថា ព្រះបានមានព្រះបន្ទូល ថា ការនេះនឹងកើតឡើង “មុនថ្ងៃដ៏គួរ ស្ញែងខ្លាចរបស់ព្រះ
យេហូវ៉ាបានមកដល់” ឬក៏នៅមុនពេលដែល ព្រះគ្រីស្ទនឹងយាង មកជាលើកទីពីរ។
រាស្ត្ររបស់ព្រះត្រូវតែមានអំណោយទាន ខាងបទទំនាយ នៅក្នុងចំណោមពួកគេ
នៅសម័យនៃការបញ្ចប់ ប្រវត្តិសាស្ត្ររបស់ ពិភពលោកនេះ។
ទំនាក់ទំនងជាមួយព្រះវិហារនៅទីក្រុង កូរិនថូស លោកប៉ុលបានថ្លែងនូវសេចក្តីនេះ
ដែលទាក់ទងទៅនឹងអ្នកដើរតាមព្រះ:


69

(ព្រះគម្ពីរ កូរិនថូសទី១ ១:៧)
“ទាំងចាំទំរាំព្រះយេស៊ូវគ្រីស្ទ ជាព្រះ អម្ចាស់នៃយើងរាល់គ្នាលេចមកផង”
កូរិនថូសទី១ ១:៧។


70

យើងបានរកឃើញមកហើយថា រាស្ត្រ របស់ព្រះនៅសម័យចុងក្រោយ នឹងមាន លក្ខណៈជាអ្នក
“ដែលគោរពបញ្ញត្តិរបស់ ព្រះ និងមានទីបន្ទាល់អំពីព្រះយេស៊ូវ”
វិវរណៈ ១២:១៧


71

“ការអត់ធ្មត់របស់ពួកបរិសុទ្ធ


72

និងកាន់តាមបញ្ញត្តិទាំងអស់របស់ព្រះ”

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



73

ហើយមានសេចក្តីបន្ទាល់ពីព្រះយេស៊ូវ



74

ព្រះគម្ពីរ វិវរណៈ ១៩:១០)

យើងត្រូវបានគេប្រាប់ថា "ការធ្វើ បន្ទាល់ពីព្រះយេស៊ូវ គឺជាវិញ្ញាណនៃបទ ទំនាយ" វិវរណៈ ១៩:១០។

ម្យ៉ាងវិញទៀតទីបន្ទាល់អំពីព្រះយេស៊ូវ គឺការធ្វើបន្ទាល់ពីព្រះយេស៊ូវតាមរយៈ អំណោយទាន នៃបទទំនាយ។ យោង តាមព្រះគម្ពីរវិវរណៈ ពួកជំនុំដែលនៅ សល់ចុងក្រោយនេះ គឺជាប្រឡាយនៃ ការទំនាក់ទំនងរបស់ព្រះ តាមរយៈអំណោយទាននៃបទទំនាយ។

ជាអ្នកមានសេចក្តីជំនឿលើព្រះយេស៊ូវ កាន់គ្រប់បញ្ញត្តិទាំងអស់របស់ព្រះ ហើយ ត្រូវបានប្រទានពរដោយអំណោយទាន នៃបទទំនាយ។



75

មែនហើយ ព្រះនៅតែចង់ "ទាក់ទង" ជា មួយមនុស្សជំនាន់នេះ ទ្រង់នៅតែមាន អ្វីផ្សេងទៀត ដើម្បីនឹងមាន ព្រះបន្ទូលទៅ កាន់ពួកគេ។



76

ប៉ុន្តែលោកអ្នកអាចសួរថា "ចុះអំពីលទ្ធ ភាពនៃការបោកបញ្ឆោតវិញ តើយ៉ាងណា ដែរ? តើយើងអាចប្រាប់ការខុសគ្នារវាងហោរា ពិតរបស់ព្រះ និងហោរាក្លែងក្លាយបានឬ ទេ?"



77

លទ្ធភាពនៃកាបោកបញ្ឆោត បានមាន ឡើងរួចមកហើយ។

តាមរយៈប្រវត្តិសាស្ត្រមានហោរាពិត និងហោរាក្លែងក្លាយ។ យើងមិនចំបាច់ចាប់ អារម្មណ៍អំពីហោរា ក្លែងក្លាយនោះទេ ប្រសិនបើយើងដឹងនូវរបៀបដើម្បីសំគាល់ ហោរាពិតប្រាកដនោះ។



78

ព្រះគម្ពីរផ្តល់លក្ខណៈជាក់លាក់ដើម្បី សំគាល់ហោរាពិតៈ

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



79

ដំណឹងរបស់ហោរាពិតស្របទៅតាមព្រះ បន្ទូល និងច្បាប់របស់ព្រះទាំងស្រុង។



80

(ព្រះគម្ពីរ អេសាយ ៨:២០)

"ចូរទៅបើកគម្ពីរបញ្ញត្តិ និងសេចក្តី បន្ទាល់មើល បើគេនិយាយមិន ត្រូវនឹង ព្រះបន្ទូលនោះ នោះគ្មានពន្លឺរះឡើងនៅ ក្នុងខ្លួនទេ"

អេសាយ ៨:២០។



81

"បើកាលណាទំនាយរបស់ហោរានោះ បានសំរេចហើយ នោះទើបនឹងស្គាល់ហោ រានោះថា ព្រះយេហូវ៉ាបានចាត់ប្រើមកមែន"



82

(ព្រះគម្ពីរ យេរេមា ២៨:៩)

"...បើកាលណាទំនាយរបស់ហោរា នោះបានសំរេចហើយ នោះទើបនឹងស្គាល់ ហោរានោះថា ព្រះយេហូវ៉ាបានចាត់ប្រើ មកមែន"

យេរេមា ២៨:៩។



83

ហោរាពិតទស្សនទាយដើម្បីបំភ្លឺដល់ពួក ជំនុំ។

ហេតុផលមួយដែលព្រះបានប្រទាន អំណោយទានខាងវិញ្ញាណ គឺដើម្បីស្ថាបនា ពួកជំនុំរបស់ទ្រង់ឡើង។ ប្រសិនបើយើងរក ឃើញអំណោយទានពិត យើងត្រូវតែរក ឃើញពួកជំនុំពិត។ ទាំងពីរនេះភ្ជាប់គ្នា ទៅវិញទៅមក។



84

(ព្រះគម្ពីរ កូរិនថូសទី១ ១៤:៣,៤)

"ឯអ្នកដែលអធិប្បាយវិញ អ្នកនោះ និយាយនឹងមនុស្ស សំរាប់នឹងស្អាងចិត្ត កំឡាចិត្ត ហើយកំសាន្តចិត្ត...



85

តែអ្នកណាដែលអធិប្បាយនោះទើបស្អាងចិត្ត ចំពោះពួកជំនុំ"

កូរិនថូសទី១ ១៤:៣,៤។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


86

ហោរាពិតនឹងលើកដំកើងព្រះគ្រីស្ទជា ព្រះរាជបុត្រារបស់ព្រះ និងជាព្រះអង្គសង្គ្រោះរបស់មនុស្សជាតិ៖


87

(ព្រះគម្ពីរ យ៉ូហានទី១ ៤:១,២)

“ពួកស្ងួនភ្ងាអើយ កុំឱ្យជឿគ្រប់ទាំង វិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់ វិញ ដើម្បីឱ្យបានដឹងជាមកពីព្រះ ឬមិនមែន


88

ដ្បិតមានហោរាក្លែងជាច្រើនកើតមកក្នុង លោកីយ៍នេះហើយ”


89

“គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ ថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយដែលមកពីព្រះ”

យ៉ូហានទី១ ៤:១,២។


90

ហោរាប្រុស ស្រី ពិតជាអាចត្រូវបាន គេស្គាល់ដោយសារជីវិត និងការងាររបស់ ពួកគាត់។


91

(ព្រះគម្ពីរ ម៉ាថាយ ៧:១៦,១៨)

“អ្នករាល់គ្នានឹងស្គាល់គេបានដោយសារ ផលគេបង្កើត...


92

ធម្មតាដើមឈើល្អ មិនដែលបញ្ចេញ ផលអាក្រក់បានទេ ហើយដើមដែលអាក្រក់ក៏ពុំអាចនឹងបញ្ចេញផលល្អបានដែរ”

ម៉ាថាយ ៧:១៦,១៨


93

ផ្អែកទៅលើបទគម្ពីរទាំងអស់នេះ ហោ រាមិនមែនសុទ្ធតែពិតទាំងអស់នោះទេ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


94

ដំណឹងរបស់ហោរាពិត គឺជាជីវិតរបស់ គេ និងសកម្មភាពរបស់គេ ត្រូវតែគាំទ្រ និងពង្រឹងដំណឹងដែលបានទាយទុកមក នៅក្នុងព្រះគម្ពីរ ហើយនិងការបង្រៀន និងបញ្ញត្តិរបស់ព្រះ នៅក្នុងព្រះបន្ទូលដ៏ បរិសុទ្ធរបស់ទ្រង់។

ដូច្នេះវាមិនជាការអ្វីទេ ចំពោះអ្នកដែល អះអាងថាជាអ្នកនិយាយជំនួសព្រះ ឱ្យតែត្រឹមត្រូវទៅតាមការសាកល្បង!

ប្រសិនបើគេត្រឹមត្រូវមែននោះ យើង សូមអរគុណព្រះអង្គ!

ប្រសិនបើគេមិនត្រឹមត្រូវទេ សូមធ្វើតាមការប្រ កាសគ្រប់របស់ព្រះ គ្រីស្ទឱ្យ "ចូរសម្លឹងមើល" ពួកគេ


95

ខ្ញុំសូមចែកចាយរឿងមួយអំពីការដែល ព្រះបានជ្រើសរើសដើម្បី "ទាក់ទង" ជាមួយនឹងរាស្ត្ររបស់ទ្រង់។ នៅពេលមួយ ដែលពួកគេត្រូវបានប្រកាសសេចក្តីពិតឱ្យពិភពលោកដឹងអំពីសេចក្តីពិត ដែលបាន លាក់កំបាំង មកជាច្រើនសតវត្សរ៍មកហើយ នោះ។ គឺនៅក្នុងពេលនៃការភ្ញាក់រលឹកខាង សាសនាមួយ នៅដើមសតវត្សរ៍ទី១៩។

មានការចាប់អារម្មណ៍ដ៏សំខាន់មួយ នៅ ក្នុងការសិក្សាព្រះគម្ពីរនិងអធិស្ឋាន។

បទទំនាយនៅក្នុងព្រះគម្ពីរដានីយ៉ែល និងវិវរណៈ មានការចាប់អារម្មណ៍ជាពិសេស


96

សិស្សព្រះគម្ពីរដ៏ស្មោះត្រង់បានសិក្សានូវ បទទំនាយទាំងនេះ ហើយបានមកដល់ការសន្និដ្ឋានជាយថាហេតុថា ព្រះយេស៊ូវនឹង យាងមកវិញនៅសម័យរបស់ពួកគេនោះ។



97

នៅពេលដែលពួកគេបានបន្តការសិក្សា គេបានទូទាត់ថា ព្រះយេស៊ូវនឹងយាងមកវិញ នៅថ្ងៃ ទី២២ ខែតុលា ឆ្នាំ១៨៤៤។ ទោះ ជាយ៉ាងនេះក៏ដោយ ថ្ងៃទី២២ ខែតុលា បានកន្លងផុតទៅ ប៉ុន្តែការយាងមកដ៏មាន សិរីល្អរបស់ព្រះយេស៊ូវ មិនបានកើតឡើង ឡើយ។


98

វាគឺជាការខកចិត្តយ៉ាងជូរចត់មួយ។ វា បានបង្កើតឱ្យមានការចំអក ការមើលងាយ មើលថោក និងត្រូវបានគេបង្វែការល្អឱ្យ ទៅជាអាក្រក់វិញ

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



99

(វីដេអូ ៨វិនាទី) ក្រោយមក បន្ទាប់ពីការ អធិស្ឋានជាច្រើន និងការសិក្សាព្រះគម្ពីរ មក
ពួកនោះបានរកឃើញថា ថ្ងៃនោះត្រឹម ត្រូវហើយ ប៉ុន្តែព្រឹត្តិការណ៍ទេដែលខុស!

ពួកគេបានគិតថា "ទីបរិសុទ្ធ" ដែល បានពណ៌នានៅក្នុងព្រះគម្ពីរដានីយ៉ែលជំពូក ៨:១៤
គឺនៅលើផែនដី ប៉ុន្តែត្រង់ចំណុច នេះពួកគេយល់ខុស។

ជំនួសឱ្យផែនដីត្រូវបានសំអាតដោយ ភ្លើង ទីបរិសុទ្ធនៅស្ថានសួគ៌ត្រូវបានសំ អាត។ ការនោះ
បានទាក់ទងទៅនឹងភាព គ្មានទោសនៃអត្តចារិតចុងក្រោយរបស់ព្រះ
និងរដ្ឋាភិបាលរបស់ទ្រង់។


100

ចិត្តមនុស្សត្រូវបានខ្ទេចខ្ទាំ

ការខកចិត្តហាក់ដូចជាមិនបានចុះថយ ឡើយ។

ប៉ុន្តែព្រះដ៏ជាទីស្រឡាញ់ មិនដែលបោះ បង់អ្នក ស្វែងរកសេចក្ដីពិតដ៏ស្មោះស្ម័គ្រ នោះឡើយៈ

ហើយទ្រង់ក៏មិនដែលបោះបង់ចោលនូវ អ្នកជឿលើ "ការយាងមកវិញ" ទាំងនេះ
នៅពេលនៃវិបត្តិនោះដែរ។

ទ្រង់បានចង់ឱ្យពួកគេដឹងថា ទ្រង់យក ព្រះទ័យទុកដាក់ បានស្រឡាញ់ និងចង់ ជួយពួកគេ។

ដូច្នេះនៅពេលដ៏សំខាន់បំផុតនេះ ព្រះ បានជ្រើសរើសស្លាបនាអំណោយទានខាង វិញ្ញាណឡើងវិញ
សម្រាប់រាស្ត្ររបស់ទ្រង់។
វាគឺជារឿងមួយដែលធ្វើឱ្យចាប់ចិត្តយ៉ាងខ្លាំងតាំងពីដើមដំបូង!


101

ទ្រង់បានជ្រើសរើសក្មេងស្រី
អាយុ១៧ឆ្នាំដ៏ទន់ខ្សោយម្នាក់ ហើយប្រទាន ដល់នាង នូវការជាក់ស្ដែងអំពីជ័យជំនះ
នៃការស្ថាបនាឡើងវិញរបស់ព្រះ។ នាង
អែល្លិន ហាម៉ូន ត្រូវបានព្រះប្រទានការ ជាក់ស្ដែងទីមួយ ដល់នាងនៅពេលថ្មីៗ បន្ទាប់ពីការខកចិត្ត
ដ៏ធំនៅខែធ្នូ ឆ្នាំ១៨៤៤។

ព្រះបានបង្ហាញនាងឱ្យឃើញ ពួកអ្នករង់ ចាំការយាងមកវិញ កំពុងធ្វើដំណើរនៅលើ ផ្លូវឡើង
ឆ្ពោះទៅកាន់ស្ថានសួគ៌ ជាមួយ នឹងពន្លឺដ៏ត្រចះត្រចង់ ពាសពេញទាំងផ្លូវ។


102

ដំណឹងនេះគឺជាការលើកទឹកចិត្ត ចំពោះ ក្រុមអ្នកជឿលើការយាងមកវិញមួយក្រុមតូច
ដែលបែកបាក់ ខ្ចាត់ខ្ចាយនេះ ហើយដែល ក្រោយមកត្រូវបានគេទទួលស្គាល់ថា ជា ក្រុមអ្នករង់ចាំ
ការយាងមកវិញរបស់ព្រះ យេស៊ូវ និងអ្នកគោរពថ្ងៃទី៧ជាថ្ងៃបរិសុទ្ធ (សេវេនដេយអាត់វេនទីស្ទ)។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


103

ស្ត្រីក្មេងដែលក្រោយមកបានក្លាយជាអ្នក ស្រីអែល្លិន ជី វ៉ៃត៍ ដោយសារការ រៀបអាពាហ៍ពិពាហ៍ ជាមួយអ្នកគ្រូសក្រាយ ផ្លូវអាត់វេនទីស្ទឈ្មោះហ្សេម វ៉ៃត៍ នេះ បានស្មោះត្រង់ចំពោះការត្រាស់ហៅរបស់គាត់អស់រយៈពេលជាង៧០ឆ្នាំ នាងបាននិយាយ បានសរសេរ បានបង្រៀន ហើយបានឱ្យ ដំបូន្មានអំពីព្រះ។

ទោះបីជាទំហំនៃការងារ និងជំនាញ របស់គាត់ធំហួសវិស័យក៏ដោយ ប៉ុន្តែនាង បាននិយាយថា "គឺជាការណែនាំបុរស និងស្ត្រីទាំងឡាយទៅកាន់ពន្លឺដ៏ធំមួយ" ព្រះគម្ពីរ។


104

នាងបានសរសេរថា "ការយកចិត្តទុក ដាក់បន្តិចបន្តួចទៅលើព្រះគម្ពីរ ដូច្នេះព្រះ អម្ចាស់ បានផ្តល់ពន្លឺតូចមួយ ដើម្បីដឹកនាំ បុរស និងស្ត្រីទាំងឡាយទៅកាន់ពន្លឺដ៏ធំ"។
កូព័រទ័រ មីនីសទ្រី ទំព័រ ១២៥។


105

នាងបានគាំទ្រព្រះវិញ្ញាណបរិសុទ្ធ ជា តុលាការចុងក្រោយ សម្រាប់អំពាវនាវនៅ ក្នុងសំនួរនៃគោលទ្ធិទាំងអស់។
ចំពោះអ្នកដែលបានរិះគន់ព្រះបន្ទូលរបស់ព្រះ នាងបានសរសេរថាៈ


106

ចូរប្រកាន់ខ្ជាប់នូវព្រះគម្ពីររបស់អ្នក ហើយអាននូវអ្វីដែលព្រះបានមានព្រះបន្ទូល ចុះ និងបញ្ឈប់ការរិះគន់របស់អ្នក អំពីការ ពិតឬមិនពិតក្នុងព្រះគម្ពីរ ព្រមទាំងស្តាប់ បង្គាប់គ្រប់ទាំងព្រះបន្ទូលផង។


107

ធ្វើដូច្នោះ នោះគ្មានអ្នកណាម្នាក់ ក្នុង ចំណោមអ្នករាល់គ្នានឹងបាត់បង់ឡើយ"
ដំណឹងដែលបានជ្រើសរើស សៀវភៅទី១ ទំព័រ១៨


108

គ្មានអ្នកនិពន្ធស្រីណាដែលបានបោះពុម្ព សម្ភារៈសាសនាច្រើនដូចអ្នកស្រី អែល្លិន ជី. វ៉ៃត៍ ឡើយ ដូចជាសៀវភៅទស្សនាវដ្តី អត្ថបទ ត្រាក់ ខិតប័ណ្ណ និងសំបុត្រផ្ទាល់ ខ្លួន។
ដំណឹងនៃការឱ្យដំបូន្មាននិងបង្ហាញ ភ័ស្តុតាងជាថ្មីអំពីព្រះរបស់នាង ត្រូវបាន ចែកចាយជាមួយនឹងរាស្ត្ររបស់ទ្រង់ពេញមួយជីវិតរបស់នាង

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


109

សំណេររបស់នាង រាប់បញ្ចូលទាំង ដំបូន្មានលើការរស់នៅ ដែលមាន ជោគជ័យរបស់គ្រីស្ទាន ចំណីអាហារ សុខភាព ការថែរក្សាមុនឆ្លងទន្លេ គ្រឿង ញៀន អាពាហ៍ពិពាហ៍ និងគ្រួសារ ការដឹកនាំក្មេង ការអប់រំ ហើយនៅមានច្រើន លើសពីនេះទៅទៀត។

សំណេររបស់នាងជាច្រើនដែលឥឡូវ នេះមានអាយុលើសពី១០០ឆ្នាំទៅហើយ ហើយត្រូវបានផ្តល់តម្លៃដោយការរកឃើញថ្មីៗរបស់អ្នកវិទ្យាសាស្ត្រទំនើប។

នាងត្រូវបានដកស្រង់ដោយ សាស្ត្រាចារ្យ វេជ្ជបណ្ឌិត អ្នកផ្សាយ ពត៌មាន និងមនុស្សជាច្រើនទៀតថា ជា អំណាចមួយនៅក្នុងផ្នែកទាំងអស់នេះ។


110

វេជ្ជបណ្ឌិតគ្លីវ អឹម ម៉ាកសី សាស្ត្រាចារ្យ ផ្នែកខាងចំណីអាហារនៃ សាកលវិទ្យាល័យ ខោនណែល ដែលបាន ស្លាប់ទៅហើយនោះ បានថ្លែងថា:

"សំណេររបស់អ្នកស្រី អែល្លិន ជី. វៃត៍ ត្រូវបានកោតសរសើរ ពីព្រោះ វាបានផ្តល់នូវការណែនាំឆ្ពោះ ទៅកាន់ចំណី អាហារដែលផ្តល់សុខភាពល្អ នៅក្នុងខ្លួនប្រាណទាំងមូល"

អាហារធម្មជាតិនិងអាហារកសិកម្ម ខែឧសភា ឆ្នាំ១៩៥៨។


111

តាំងពីឆ្នាំ១៨៦៤មកម្ល៉េះ អ្នកស្រីអែល្លិន ជី. វៃត៍ បានសរសេរថា "ថ្នាំជក់គឺជាថ្នាំពុលមួយដ៏ធំបំផុតដែលបោកបញ្ឆោត និង បណ្តាលឱ្យមនុស្សស្លាប់យ៉ាងសាហាវបំផុត..."


112

វាមានគ្រោះថ្នាក់ជាងអ្វីៗទាំងអស់ ព្រោះវាប៉ះពាល់ដល់ប្រព័ន្ធនៃរាងកាយទាំងមូលយ៉ាងយឺតៗ ដែលគេអាចដឹង បានយ៉ាងពិបាកបំផុត"


113

ទោះជាយ៉ាងណាក៏ដោយ រហូតមកដល់ ឆ្នាំ១៩៥៧ ដែលសហគមន៍មហារីក អាមេរិកាំង និងសមាគមន៍បេះដូងសហរដ្ឋ អាមេរិក បានសន្និដ្ឋានថា វាជាកត្តាដែលបណ្តាលឱ្យមានជម្ងឺមហារីកសួត!

នៅសម័យនាង អ្នកវេជ្ជសាស្ត្រប្រ ហែលជាមានចម្ងល់ចំពោះនាងហើយ ពីព្រោះនៅសម័យនោះ គេបានគិតថា ថ្នាំជក់និងផ្សែងបារី គឺជាថ្នាំព្យាបាលជម្ងឺ សួតដ៏មានប្រសិទ្ធភាព។


114

នៅក្នុងឆ្នាំ១៩០៥ អ្នកស្រីវៃត៍ បាន សរសេរថា មាន "មេរោគ" មហារីក។

នាងបានថ្លែងថា មនុស្សកំពុងបន្តបរិភោគ សាច់ ដែលពេញទៅដោយមេរោគរបេង និងមហារីក...

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



115

ជម្ងឺរបេង មហារីក និងជម្ងឺដែល បណ្តាលឱ្យស្លាប់ផ្សេងៗទៀត ដែលត្រូវបានរាលដាលដោយការបរិភោគសាច់នេះ”
កិច្ចការខាងសុខភាព ទំព័រ៣១៣




116

ជាការពិតណាស់ សព្វថ្ងៃនេះ យើងនឹង ប្រើយ៉ាងត្រឹមត្រូវនូវពាក្យថា វីរុស។
កៅសិបបីឆ្នាំក្រោយមកទស្សនាវដ្តី ញូវ វីក បាននាំមកនូវរឿងមួយដែលមានចំណង ជើងថា” វីរុសគឺជាកត្តាដ៏សកម្មក្នុងជម្ងឺ មហារីក”



117

“លោកវេជ្ជបណ្ឌិត វ៉េនដែល ស្តេនលី វីរុសវិទូនៃសាកលវិទ្យាល័យ កាលីហ្វ័រញ៉ា និងជាអ្នកបានទទួលរង្វាន់ណូបែល”



118

បានថ្លែងដោយគ្មានករណីលើកលែងថា “គាត់ជឿថា ជម្ងឺមហារីកមនុស្សទាំងអស់សុទ្ធតែកើតមកពីវីរុស”
ញូវីក ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៥៦។



119

នៅក្នុងឆ្នាំ១៩០២ អ្នកស្រី អែល្លិន ជី វ៉ៃត៍ បានប្រកាសឱ្យដឹងថា ទីក្រុងសាន ហ្វ្រាន់ស៊ីស្កូ និងអូកឡេនដ៍ នឹងត្រូវបានមក ជួបដោយព្រះអម្ចាស់ ព្រោះទីក្រុងនេះនឹង បានដូចជាទីក្រុងសូដុំម និងកូម៉ូរា។ (អត្ថបទព្រៀងមិនទាន់បោះពុម្ព ១៩០២ ទំព័រ១១៤)




120

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩០៦ នៅម៉ោង៥និង១២នាទីព្រឹក ការរញ្ជួយផែន ដីដ៏ធំមួយនៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ បាន កើតឡើង។
បទទំនាយនេះពិតប្រាកដមែន។
ការខូចខាតបានកើតឡើងដូចដែលបាន ទាយទុកមកមែន។
នៅពេលដែលយើងពិចារណាអំពី ឧបសគ្គ និងទុក្ខកង្វល់ ដែលបានវាយសន្ធប់មកលើជីវិតរបស់អ្នកស្រី អែល្លិន ជី. វ៉ៃត៍ យើងឃើញថា ឯកសាររបស់ គាត់មានទំហំធំធេងហួសវិស័យធម្មជាតិ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


121

អ្នកខ្លះប្រហែលជាងឿងឆ្ងល់ថា តើអ្នក ស្រីអែល្លិន ជី វ៉ៃត៍ ជានរណា? ហើយ តើនាងនោះមានរូបរាងយ៉ាងណា?

ចម្លើយបាននាំយើងត្រឡប់ទៅកាន់ ថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ១៨២៧។


122

នៅថ្ងៃនោះ កូនភ្លោះមួយគូ អេលីសា បែត និងអេល្លិន បានកើតឡើង នៅក្បែរ ភូមិតូចមួយ ឈ្មោះហ្គោហា រដ្ឋម៉ែន ពីនាងយូនី និងរ៉ូប៊ើរត ហារម៉ុន។

អែល្លិន គឺជាកូនពៅនៃកូនទាំងប្រាំបី។


123

លុះបានអាយុប្រាំបួនឆ្នាំ គ្រោះថ្នាក់មួយ បានផ្លាស់ប្តូរជីវិតនាងរហូត។

នៅពេលត្រឡប់មកពីសាលាទៅផ្ទះវិញ នាងអែល្លិនបានមានគ្រោះថ្នាក់ជាទម្ងន់ ដោយត្រូវបានមិត្តរួមថ្នាក់របស់នាងចោលមួយដុំថ្ម។


124

នាងបានសន្លប់អស់បីសប្តាហ៍។ នាង មិនអាចបន្តការសិក្សារបស់នាងបានទៀត ឡើយ ហើយអាការៈបានលេចឡើងឱ្យ ឃើញថា នាងមិនអាចរស់នៅបានយូរទៀត ទេ។

នាងមិនដែលអាចសិក្សាបានលើសពី ថ្នាក់ដែលនាងបានសិក្សា នៃសាលាបឋម សិក្សារបស់រដ្ឋ នោះទៀតឡើយ។


125

ជាច្រើនឆ្នាំកន្លងមក អែល្លិន បាន ក្រឡេកមើលក្រោយដោយអារម្មណ៍ ច្របូក ច្របល់ ទៅលើជីវិតឆ្នាំទីប្រាំបួនរបស់នាង។

ជាការពិត វាជាការដែលគួរឱ្យឈឺចិត្ត ណាស់ ដោយមិនអាចចូលរៀនបាន មិន អាចរត់លេងជាមួយនឹងបងប្អូនប្រុសស្រីរបស់នាងបាន។

ប៉ុន្តែមួយជំហាននៃជីវិតរបស់នាង បង្ហាញឱ្យឃើញថា បានបញ្ចប់ ហើយ ជំហានថ្មីមួយទៀតក៏បានចាប់ផ្តើម។

អែល្លិន បានក្លាយជាសិស្សដែលគ្រេក ត្រអាលខ្លាំងនឹងការអានព្រះគម្ពីរ។ នាង បានចូលរួមការប្រជុំបោះជំរំ ការសិក្សាស្តា ជំនឿឡើងវិញ និងការប្រជុំតាមពនាស្រម (ផ្ទះតូចៗ)។


126

បន្ទាប់ពីបានចូលរួមប្រជុំបោះជំរំ មេតូឌីស្តមួយ នៅប៉ុស្តុន រដ្ឋអាម៉ែន អែល្លិន បានត្រូវជ្រមុជទឹក នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៨៤២។ នាងបានក្លាយជា សមាជិករបស់ពួកជំនុំមេតូឌីស្ត។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


127

ក្រោយមកទៀត អែល្លិន និងគ្រួសារ បានចូលរួមការប្រជុំខ្លះទៀត ដែលបានធ្វើ ឡើងនៅទីក្រុង ព័រតឡេនដ៍ រដ្ឋម៉ែន។

អ្នកអធិប្បាយនៅពេលនោះគឺ លោក វីលៀម មីល្លើរ គឺជាអតីតអនុសេនីត្រីនៃ កងទ័ពជើងទឹក ដែលបានសិក្សាព្រះគម្ពីរ យ៉ាងល្អិតល្អន់។

ពីព្រោះគាត់បានប្រកាសអំពីការយាងមក វិញឆាប់ៗរបស់ព្រះគ្រីស្ទ គាត់និងអ្នកដែល ដើរតាមគាត់ បានត្រូវគេហៅដោយចំអកថា ពួក "អាត់វេន" ឬ "មីលើរ៉ៃត៍" គ្រួសារ របស់ហាម៉ុន ក៏ត្រូវបានធ្វើឱ្យជឿទៅលើ ការពិតនៃដំណឹងរបស់លោកមីលើរ៉ៃត៍ដែរ។


128

ទោះជាយ៉ាងនេះក៏ដោយ បន្ទាប់ពីការ ខកចិត្តយ៉ាងធំនាថ្ងៃទី២២ ខែតុលា ឆ្នាំ១៨៤៤មក ពួកគេក៏ត្រូវទទួលការអាម៉ាស់ យ៉ាងខ្លាំង។

នាងអែល្លិន មានការខកចិត្តយ៉ាងខ្លាំង។ នាងយំ នាងអធិស្ឋាន នាងបានសិក្សាព្រះ បន្ទូលព្រះ ដើម្បីរកចម្លើយ ដូចជាពួកអ្នក អាត់វេនដទៃទៀតបានធ្វើដែរ។

នៅពេលនោះហើយដែល ព្រះបាន ត្រាស់ហៅនាងឱ្យធ្វើជាហោរាស្រីរបស់ទ្រង់។ ខាងរាងកាយ នាងមិនបានបង្ហាញនូវអ្វី ដែលអ្នករំពឹងថា នាងនឹងអាចក្លាយជា ហោរាស្រីនោះបានឡើយ។

នាងជាក្មេងស្រីអាយុ១៧ឆ្នាំម្នាក់ ដែល កំពុងប្រយុទ្ធជាមួយនឹងស្ថានភាពនៃជម្ងឺរបេង និងជម្ងឺបេះដូង។

ព្រះនៅតែមានព្រះបន្ទូលទៅកាន់នាង អែល្លិន ដោយការជាក់ស្តែងមួយនៅខែធ្នូ ឆ្នាំ១៨៤៤។ ដោយពាក្យនាងផ្ទាល់ នាង បានទូលទៅព្រះនូវប្រតិកម្មថា:


129

"បន្ទាប់ពីខ្ញុំបានឃើញការជាក់ស្តែង ហើយព្រះបានប្រទានមកឱ្យនូវពន្លឺនោះ ទ្រង់បានប្រាប់ឱ្យខ្ញុំចែកចាយវាទៅដល់ មនុស្ស... ប៉ុន្តែខ្ញុំបានរុញរាចំពោះការនោះ ព្រោះខ្ញុំនៅក្មេងណាស់ គេនឹងមិនទទួល ដំណឹងនេះពីខ្ញុំឡើយ"

សំបុត្ររបស់ អែល្លិន ជី. វ៉ៃត៍ ៣,១៨៤៧។


130

ទោះបីជាមានអារម្មណ៍មិនល្អមគ្រប់ គ្រាន់ និងពិការភាពខាងរាងកាយ ដើម្បី នឹងទទួលការខុសត្រូវ ចំពោះការត្រាស់ ហៅរបស់នាងក៏ដោយ ក្នុងសេចក្តីជំនឿ នាងបានទទួលបេសកកម្មសម្រាប់ព្រះ ដែលនឹងត្រូវចំណាយពេលពេញមួយជីវិត របស់នាង។


131

អែល្លិន និងប្តីរបស់គាត់ លោក ជេម វ៉ៃត៍ បានធ្វើការជាមួយគ្នាក្នុងការចែក ចាយពន្លឺដែលព្រះបានប្រទានឱ្យ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌


132

ជោគជ័យនិងភក្តីភាពរបស់ពួកគាត់ ត្រូវបានចែកចាយដោយសំណេររបស់គាត់ជា ច្រើន។

អស់មួយជីវិតរបស់នាង អែល្លិន ជី. វៃត៍ គឺជាគ្រីស្ទានយ៉ាងដាច់ខាតម្នាក់ គឺជាអ្នកបំរើរបស់ព្រះម្នាក់ ដែលមិនចេះនឿយ ហត់ ហើយនិងជាមាតាដ៏មានភក្តីភាពម្នាក់។

នាងត្រូវបានគេទទួលការស្រឡាញ់ពីប្តីរបស់ នាង គ្រួសាររបស់នាង ហើយនិងពីមនុស្សរាប់ពាន់នាក់ទៀតលើពិភពលោក។


133

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៨៨១ លោក ហ្គេម ជាប្តីរបស់នាង អែល្លិន បានស្លាប់ នៅបាថលក្រេក មីឈីហ្គេន។

នាង អែល្លិន បានឈរនៅក្បែរផ្នូរ-អង្វរសូមជំរុញការងារដែលគាត់បានធ្វើការ លះបង់ និងដែលគាត់ទាំងពីរ បានបន្តឥត ឈប់ឈរ អស់រយៈពេល៣៥ឆ្នាំមកនេះឱ្យបានសម្រេច!


134

សំណេរដ៏ល្អប្រសើរ និងមានព្រះ វិញ្ញាណសណ្ឋិតដ៏ល្អបំផុតរបស់អ្នកស្រី អែល្លិន ខ្លះបានលេចឡើង បន្ទាប់ពីពេល នោះមក។

នាងបានធ្វើការតែម្នាក់ឯងអស់រយៈ ពេល៣៤ឆ្នាំទៀត។

បេសកកម្មនៃការទស្សនទាយរបស់នាង បាននាំនាងទៅកាន់ប្រទេសជាច្រើន-ដើម្បី ដឹកនាំ បង្រៀន និងឱ្យដំបូន្មានដល់អ្នក មានជំនឿ ដូចដែលព្រះបានដឹកនាំនាង។


135

ជីវិត និងការងាររបស់អ្នកស្រី អែល្លិន ជី. វៃត៍ បិទទ្វារ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩១៥។

នាងបានស្លាប់នៅក្នុងអាយុ ៨៧ឆ្នាំ។

នាងត្រូវបានគេបញ្ចុះនៅក្បែរផ្នូររបស់ប្តី នាងនៅកន្លែងបញ្ចុះសពអូកហៀល នៅ ក្នុងបាថលក្រេក មីឈីហ្គេន។

ពីរបីសប្តាហ៍ក្រោយអនិច្ចកម្មរបស់នាង សារពត៌មានមួយបានលើកយកសេចក្តីថ្លែងមួយយ៉ាងដូច្នេះ:


136

"នាងមិនបានបង្ហាញនូវការអួតអាង ខាងវិញ្ញាណឡើយ ហើយនាងមិនបាន ស្វែងរកលាភសក្ការៈដែលអាក្រក់នោះ ឡើយ។ នាងបានរស់នៅជាជីវិតជាហោរា ស្រីម្នាក់ ដែលគួរឱ្យស្ងើចសរសើរជាទីបំផុត" សារពត៌មាន ញូយ៉ក អ៊ិនឌីផេនដេន ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩១៥។


137

មែនហើយ សំឡេងរបស់នាងនៅមាននៅ ឡើយ-ស្លាបប៉ាការបស់នាងបានសំរាកហើយ។ ប៉ុន្តែពាក្យពេចន៍ទូន្មាន ការព្រមានដាស់ តឿន ការបង្រៀន និងការលើកទឹកចិត្ត ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន របស់អ្នក នាំពាក្យដ៏ស្មោះត្រង់របស់ព្រះនេះ នឹងបន្ត ការដឹកនាំរាស្ត្ររបស់ព្រះរហូតដល់ជ័យ ជំនះចុងក្រោយ!

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌




138

(វីដេអូ ៦វិនាទី) កេរ្តិ៍ដំនែលរបស់នាង ចំពោះពិភពលោកនេះ គឺជាអំណោយទាន នៃសេចក្តីស្រលាញ់_ជាដំណឹងមកកាន់ផែន ដីឆ្លងកាត់ចក្រវាល ពីព្រះនៃសេចក្តីស្រ ឡាញ់ ដែលនៅតែចង់ "ទាក់ទង" ជា មួយនឹងកូនរបស់ទ្រង់នៅទីនេះរហូតដល់ព្រះ គ្រីស្ទយាងមក។

ពេលនោះ "ពន្លឺតូច" ក៏បានចុះថយ ទៅៗ នៅពេលដែលយើងឈរនៅក្នុងពន្លឺ សិរីល្អនៃវត្តមានរបស់ទ្រង់ម្តងទៀត ដើម្បី នឹងឃើញនិងប្រកបជាមួយនឹងទ្រង់ មុខ ទល់នឹងព្រះភ័ក្ត្រ នៅក្នុងសិរីល្អរបស់ទ្រង់ទាំង ស្រុង!

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌



139

អស់ពេលជាច្រើនឆ្នាំកន្លងមកហើយ នៅក្នុងវាលរហោស្ថានដ៏ធំល្វឹងល្វើយ នៃបឺ ខានណាឡេនដ៍ អាហ្វ្រិកខាងត្បូង មាន មនុស្សដែលរស់នៅតាមព្រៃ ដែលមាន អារ្យធម៌អន់ថយម្នាក់ឈ្មោះ ស៊ុយគូបា។

គាត់បានរស់នៅជាជីវិតដ៏ដាច់សង្វែងមួយ ដែលជាសមាជិករបស់មនុស្សដែលគ្មាន ទីលំនៅនឹងន់

នៅយប់នៃរដូវរងាមួយ គាត់បានលូន ចូលសន្សឹមៗទៅកាន់ជម្រករបស់គាត់ ហើយរៀបចំសម្រាន្ត។

ប៉ុន្តែរំពេចនោះ យប់ក៏បានក្លាយជាភ្លឺ ជាងពេលថ្ងៃទៅទៀត។

ពន្លឺបានលេចមកឯគាត់ ហើយបាន ប្រាប់ឱ្យគាត់ទៅរកមនុស្សនៃ "សៀវភៅ" គាត់ត្រូវតែស្វែងរកមនុស្សដែលថ្វាយបង្គំព្រះ។

ស៊ុយគូបាមិនបានដឹងច្បាស់ថា ការនេះមាន ន័យយ៉ាងណានោះទេ។

តើសៀវភៅអ្វីទៅ?

ប្រសិនបើគាត់បានរកសៀវភៅនោះ ឃើញ តើគាត់អាចនឹងអានវាបានយ៉ាងណា?

ភាសារបស់មនុស្សព្រៃមានសំឡេងក្រិកៗ និងសំឡេងនៅក្នុងបំពង់ក ហើយពិតជាមិន ដូចគ្នានឹងសំឡេងរបស់កុលសម្ព័ន្ធអាហ្វ្រិកដទៃទៀតឡើយ។

វាមិនដែលត្រូវបានធ្វើឱ្យទៅជាភាសា សរសេរឡើយ។

ប៉ុន្តែ "ពន្លឺដែលចាំង" ដូចដែល ស៊ុយគូបា បានហៅថា ទេវតាដែលបាន លេចមកឯគាត់នោះ បាននិយាយថា "សៀវភៅនោះនិយាយ អ្នកនឹងអាចអាន វាបាន"

ស៊ុយគូបា បានធ្វើដំណើរជាមួយនឹង គ្រួសារគាត់អស់ពេលជាច្រើនថ្ងៃ ក្នុងការ ស្វែងរកសៀវភៅនោះ។ គាត់បានទៅដល់ ខ្ទមរបស់គ្រួសារពួកបានធូ ហើយបានសួរ ថា តើពួកគេបានដឹងអំពីមនុស្ស ដែល មានសៀវភៅនោះដែរឬទេ?

មនុស្សជនជាតិភាគតិចនោះ មានការ ភ្ញាក់ផ្អើល ដោយឃើញមនុស្សព្រៃ ចេះ និយាយភាសាបានធូដូច្នេះ។

គេក៏បាននាំស៊ុយគូទៅកាន់គ្រូគង្វាល របស់គេភ្លាម។

លោកគ្រូគង្វាលនោះមានការចាប់ អារម្មណ៍យ៉ាងខ្លាំងចំពោះរឿងរបស់ ស៊ុយគូបា។

ហើយគាត់បាននិយាយថា "ដំណើរ របស់អ្នកត្រូវបានចប់ហើយ"

ស៊ុយគូបាសប្បាយចិត្តណាស់។ ប៉ុន្តែ នៅយប់នោះពន្លឺចាំងបានលេចមកឯគាត់ម្តង ទៀត។

ពន្លឺនោះនិយាយថា នោះមិនមែនជា មនុស្សដែលគាត់កំពុងស្វែងរកនោះទេ។

គាត់ត្រូវតែរក "អ្នកគោរពថ្ងៃបរិសុទ្ធ និងលោកគ្រូគង្វាលមួយផ្សេង"

លោកគ្រូគង្វាលមួយផ្សេងនឹងមានសៀវភៅ មួយ និង "សៀវភៅបួនទៀត" ផងដែរ

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌

ដែលពិតជាល្អមែនទែន"

ថ្ងៃបន្ទាប់មក ស៊ុយគួបាបានអធិស្ឋាន សុំសញ្ញាមួយ។ គាត់ត្រូវទទួលការការណែនាំចំពោះដំណើររបស់គាត់នេះ។

នៅពេលដែលគាត់អធិស្ឋាននោះ ពពក មួយដុំបានលេចមកលើមេឃ។

ស៊ុយគួបាបានជ្រកក្រោមពពកនោះ និង ធ្វើដំណើរតាមអស់រយៈពេលប្រាំពីរថ្ងៃ។ ពពកនោះបានបាត់ទៅនៅលើភូមិពីរបី។

នៅទីនោះហើយដែលស៊ុយគួបាបានសួររក លោកគ្រូគង្វាល មួយី ហើយគាត់ត្រូវបានគេនាំទៅបង្ហាញផ្ទះរបស់គាត់មួយរំពេច។

បន្ទាប់ពីស៊ុយគួបាបានប្រាប់រឿងរ៉ាវ របស់ គាត់ក្នុងការសន្ទនាជាភាសារបស់អ្នក ភូមិនោះ មកលោកគ្រូគង្វាមួយី បានយក ព្រះគម្ពីររបស់គាត់ចេញមក "នេះគឺជា សៀវភៅនោះហើយ" ស៊ុយគួបាបានឧទាន ថា

នេះហើយគឺសៀវភៅនោះ! ប៉ុន្តែ តើ ឯណាទៅសៀវភៅប្អូនទៀតដែលល្អមែនទែន នោះ?"

មែនហើយ នេះជារឿងដែលបានកើតឡើង កាលពីរាប់សិបឆ្នាំមុន អ្នកស្រី អែល្វិន ជី. វ៉ៃត៍ បានសរសេរ សៀវភៅសម្រាប់ ណែនាំក្រុមជំនុំរបស់ព្រះ ប្រាំបួនក្បាល ហៅថា ទីបន្ទាល់របស់ក្រុមជំនុំ។ ហើយ សៀវភៅទាំងនេះហើយ ដែលក្រោយមកត្រូវបានគេបញ្ចូលគ្នាទៅជាសៀវភៅប្អូន។

ការស្វែងរករបស់ស៊ុយគួបាត្រូវបាន បញ្ចប់។ គាត់បានរកឃើញមនុស្សនៃសៀវ ភៅនោះហើយ។ គាត់បានរកឃើញអ្នក គោរពថ្ងៃបរិសុទ្ធ មនុស្សដែលត្រូវបាន ប្រទានពរជាមួយនឹងអំណោយទាននៃបទទំនាយ។ គាត់និងគ្រួសារគាត់បាន ទទួលព្រះគ្រីស្ទ និងជ្រមុជទឹក។ គាត់ក៏បានក្លាយទៅជាបេសកជនរបស់ជនជាតិគាត់។

ព្រះកំពុងធ្វើការក្នុងរបៀបដ៏អស្ចារ្យសព្វ ថ្ងៃនេះដើម្បីដឹកនាំបុរស និងស្ត្រីទាំងឡាយ ទៅកាន់ពួកជំនុំពិតរបស់ទ្រង់។

ហេតុផលដែលលោកអ្នកកំពុងឮរឿង នេះ វាមិនមែនជាចៃដន្យនោះទេ។ ដូចលោកស៊ុយគួបាដូច្នោះដែរ លោកអ្នកកំពុង ត្រូវបានព្រះដឹកនាំមក។ ព្រះកំពុងដឹកនាំលោកអ្នកមកកាន់ការពិតរបស់ទ្រង់។ ព្រះ កំពុងប្រទានឱ្យអ្នកនូវសេចក្តីក្លាហាន ដើម្បីប្រឈមមុខនឹងពេលអនាគត។

ប្រហែលលោកអ្នកកំពុងបានស្វែងរក សេចក្តី ពិតជាច្រើនឆ្នាំមកហើយ។ ខ្ញុំជឿ ថាការ ស្វែងរករបស់លោកអ្នកបានបញ្ចប់ ហើយ។

លោកអ្នកកំពុងត្រូវបានដឹកនាំដោយព្រះនៃស្ថានសួគ៌ មកកាន់ទិសដៅនេះ។

# ២១. ព្រះរាជសារពីនគរស្ថានសួគ៌

លោកអ្នកអាចឧទានឡើងដូចជា ស៊ុយ គួបាដែរថា “នេះគឺជាសៀវភៅនោះ! ក្រុម ជំនុំរបស់ព្រះ!”

តើលោកអ្នកមិនចង់ចូលរួមជាមួយនឹង អ្នកដែលគោរពបញ្ញត្តិរបស់ព្រះទាំងអស់ ហើយនិងមានទីសំគាល់របស់ព្រះយេស៊ូវទេ ឬអី? តើលោកអ្នកមិនចង់ចូលរួមជាមួយនឹង មនុស្សចុងក្រោយរបស់ព្រះទេឬអី?

សូមពិចារណាលើការប្តេជ្ញាចិត្តនេះ ឱ្យ បានម៉ត់ចត់។

វាអាចជាការសម្រេចចិត្តដ៏ធំបំផុត សម្រាប់ជីវិតលោកអ្នក។

# ២២. មានជម្រើសជាច្រើន



1

តើធ្វើដូចម្តេចដើម្បីរកពួកជំនុំត្រឹមត្រូវឃើញ?


2

តើលោកអ្នកដែលឆ្ងល់ទេថា តើហេតុអ្វី បានជាមានពួកជំនុំច្រើនម៉្លេះ?
មនុស្សធម្មតាជាច្រើនត្រូវបានភាន់ច្រឡំ លើបញ្ហានេះ
ពួកជំនុំស្ទើរតែទាំងអស់បង្រៀនថា គេ ជាពួកជំនុំបរិសុទ្ធ ដែលមានសេចក្តីពិត។
តើលោកអ្នកដែលឆ្ងល់ទេថា តើពួកជំនុំ មួយណាដែលពិតជាបង្រៀន និងជឿលើ
សេចក្តីពិតរបស់ព្រះនោះ?


3

មិត្តទាំងឡាយ ព្រះគម្ពីរ មានចម្លើយ សម្រាប់យើង។ នៅក្នុងពិភពលោក នៃ ការភាន់ច្រឡំនេះ
ព្រះបន្ទូលរបស់ព្រះអាច ត្រូវបានជាទីទុកចិត្តជានិច្ច ដើម្បីនឹង
វែកញែកអំពីអ្វីដែលពិតនិងអ្វីដែលក្លែងក្លាយ!


4

ដូច្នេះចំណងជើងនៃការសិក្សារបស់ យើងនៅពេលនេះគឺ "តើហេតុអ្វីបានជា
មានពួកជំនុំច្រើនម៉្លេះ?"


5

(ព្រះគម្ពីរ អេម៉ូស ៣:៧)
"ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិន ធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់សំដែង
អោយពួកហោរាជាអ្នកបំរើទ្រង់ឃើញគំនិត លាក់បាំងរបស់ទ្រង់ផង"។
អេម៉ូស ៣:៧។



6

(វីដេអូ ៤វិនាទី) ចូរយើងទៅឯព្រះបន្ទូល របស់ព្រះ។ សូមចងចាំថា វាមិនជាការអ្វី ទេ
នូវអ្វីដែលខ្ញុំគិតនោះ។
អ្វីដែលសំខាន់នោះ គឺអ្វីដែលវាមាននៅ ក្នុងព្រះគម្ពីរ។ បើមាន ខ្ញុំជឿ។ ប្រសិន
បើគ្មាននៅក្នុងព្រះគម្ពីរទេ នោះវាមិនមែន សម្រាប់ខ្ញុំទេ!


7

ដើម្បីចាប់ផ្តើមការសិក្សារបស់យើង
សូមយើងចាប់ផ្តើមនៅក្នុងសៀវភៅចុងក្រោយបង្អស់នៃព្រះគម្ពីរ វិវរណៈ ជំពូកទីប្រាំមួយ
ដែលនិយាយអំពីបុរសជិះសេះទាំងបួន។

# ២២. មានជម្រើសជាច្រើន


8

អ្នកជិះសេះទាំងបួននេះតំណាងឱ្យពេល វេលាខុសគ្នានៅក្នុងប្រវត្តិនៃពួកជំនុំគ្រីស្ទាន។ ចេញពីកំឡុងពេលទាំងនេះមក យើង ឃើញការជឿនលឿនរបស់ពួកជំនុំផ្សេងៗ ដែលយើងមានសព្វថ្ងៃនេះ។


9

(ព្រះគម្ពីរ វិវរណៈ៦:១)

"កាលកូនចៀមបកត្រាទី១ នោះខ្ញុំឃើញ


10

រួចខ្ញុំឮតួមានជីវិត១ បន្លឺសំឡេងឡើងដូច ផ្គរលាន់ថា ចូរមកមើលចុះ" ប្រវត្តិសាស្ត្ររបស់សាសនាគ្រីស្ទឥឡូវ នេះ ត្រូវបានបង្ហាញនៅទីនេះក្នុងជំពូក ទីប្រាំមួយ។


11

(ព្រះគម្ពីរ វិវរណៈ ៦:២)

"ខ្ញុំក៏ក្រឡេកទៅឃើញសេះស១ ឯអ្នក ដែលជិះក៏កាន់ធ្នូ ហើយមានគេឱ្យមកុដដល់ អ្នកនោះ


12

រួចអ្នកនោះចេញទៅទាំងមានជ័យជំនះ ហើយឱ្យបានឈ្នះតទៅ" វិវរណៈ ៦:២។


13

ដូច្នេះក្រុមជំនុំដំបូង គឺជាក្រុមជំនុំនៃ សេចក្ដីជំនឿដ៏មានជ័យជំនះ។ គឺជាសេះ ស។ ពណ៌សតំណាងឱ្យសេចក្ដី ជំនឿដ៏ សុចរិត។


14

វាគឺជាពេលវេលាដ៏រំភើបមួយក្នុងការ រស់នៅ នៅក្នុងសតវត្សរ៍ទីមួយ បន្ទាប់ពី ការយាងទៅកាន់ស្ថានសួគ៌របស់ព្រះយេស៊ូវ វិញ។

# ២២. មានជម្រើសជាច្រើន


15

ពួកសាវកបានពោរពេញទៅដោយ សេចក្តីក្លាហាន និងសេចក្តីជំនឿយ៉ាងខ្លាំង ពីព្រោះពួកគេបានដើរ និងនិយាយជាមួយ ព្រះយេស៊ូវ។ ពួកគេបានឃើញទ្រង់រស់ពី សុគតឡើងវិញ។ ពួកគេបានឃើញទ្រង់ យាង ឡើងទៅកាន់ស្ថានសួគ៌។ ពួកគេបាន ដឹងថា ទ្រង់នឹងយាងមកវិញ។ ពួកគេជឿ លើសេចក្តីសន្យារបស់ទ្រង់ អស់ពីចិត្តរបស់ ពួកគេ។


16

ពួកគេបានចែកចាយដំណឹងល្អ ដោយ សេចក្តីក្លាហានយ៉ាងខ្លាំង និងដោយភាព រីករាយជាទីបំផុតទៅកាន់ពិភពលោកទាំង មូល។


17

(ព្រះគម្ពីរ កូល៉ុស ១:២១-២៣)

ជាការពិតប្រាកដ ដំណឹងល្អនៃសេចក្តី សង្គ្រោះ បានត្រូវផ្សព្វផ្សាយទៅកាន់គ្រប់ ទីកន្លែងដែលគេបានស្គាល់នៅលើពិភព លោក នាសម័យនោះ។ លោកប៉ុល និយាយថា

"រីឯអ្នករាល់គ្នា ដែលពីដើមត្រូវពង្រាត់ ចេញ ហើយជាខ្មាំងសត្រូវក្នុងគំនិតដោយ អំពើអាក្រក់នោះ


18

ឥឡូវនេះវិញ ទ្រង់បានផ្សះផ្សា


19

ក្នុងរូបសាច់ទ្រង់ ដោយបានទទួលសុគត ដើម្បីនឹងថ្វាយអ្នករាល់គ្នាជាដង្វាយបរិសុទ្ធ


20

ឥតសៅហ្មងហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់


21

បើតិចណាស់អ្នករាល់គ្នាបានតាំងនៅ ជាប់លាប់ ហើយមាំមួនក្នុងសេចក្តីជំនឿដែរ

២២. មានជម្រើសជាច្រើន

# ២២. មានជម្រើសជាច្រើន



22

ឥតងាកបែរចេញពីសេចក្តីសង្ឃឹមរបស់ដំណឹងល្អ ដែលអ្នករាល់គ្នាបានឮ



23

ជាដំណឹងដែលបានផ្សាយ ទៅដល់គ្រប់ ទាំងមនុស្ស ដែលកើតក្រោមមេឃផង ឯ ប៉ុលខ្ញុំជាអ្នកបំរើចំពោះដំណឹងល្អនោះដែរ”

កូល៉ុស ១:២១-២៣។



24

(ព្រះគម្ពីរ កិច្ចការ ៥:១៤)

“ហើយពួកអ្នកដែលជឿដល់ព្រះអម្ចាស់ ក៏បានចម្រើនកាន់តែច្រើនឡើង មានមនុស្ស សន្ធឹកទាំងប្រុសទាំងស្រី”

កិច្ចការ ៥:១៤។

ព្រះគម្ពីរកិច្ចការប្រាប់យើងថា មនុស្ស រាប់ពាន់នាក់បានជ្រមុជទឹករៀងរាល់ថ្ងៃ។



25

(ព្រះគម្ពីរ កិច្ចការ ២:៤៧)

“...ចំណែកព្រះអម្ចាស់ទ្រង់ក៏បន្ថែម នូវអស់អ្នកដែលកំពុងតែបានសង្គ្រោះ រាល់តែថ្ងៃទៅក្នុងពួកជំនុំថែមទៀត”

កិច្ចការ ២:៤៧

ពួកជំនុំ គឺជាព្រះកាយរបស់ព្រះគ្រីស្ទ



26

មនុស្សម្នាត្រូវបានជ្រមុជទឹកនៅក្នុងព្រះ យេស៊ូវ។ ពួកគេបានជ្រមុជទឹកទៅក្នុងរាងកាយរបស់ទ្រង់ដែលជាពួកជំនុំ។ វាជាការសំខាន់ណាស់សម្រាប់ពួកសាវកដំបូងដើម្បីនឹងស្មោះត្រង់ចំពោះព្រះយេស៊ូវ។ នៅពេលដែលពួកសាវកត្រូវបានគេហាមប្រាមមិនឱ្យ បង្រៀនអំពីព្រះនាមព្រះយេស៊ូវ ព្រះគម្ពីរនិយាយថា:



27

(ព្រះគម្ពីរ កិច្ចការ ៥:២៩)

“តែពេត្រុស និងពួកសាវកឯទៀតឆ្លើយ ឡើងថា ត្រូវតែស្តាប់បង្គាប់របស់ព្រះជាជាងមនុស្ស” កិច្ចការ ៥:២៩ ។

លោកអ្នកឃើញទេ វាជាការសំខាន់ លើសលប់ ដែលធ្វើតាមនូវអ្វីដែលព្រះបាន មានព្រះបន្ទូលជាជាងដើរតាមប្រពៃណី របស់មនុស្ស

# ២២. មានជម្រើសជាច្រើន


28

ដូច្នេះពួកគេមានជំនឿយ៉ាងបរិសុទ្ធ ពី ព្រោះពួកគេបាននៅជាមួយនឹងព្រះយេស៊ូវ។ ពួកគេជឿនូវអ្វីដែល ព្រះយេស៊ូវបាន ជឿ។

ពួកគេបង្រៀននូវអ្វីដែលព្រះយេស៊ូវបាន បង្រៀន។


29

នោះគឺជាជំនឿដូចគ្នាដែលយើងត្រូវមាន នៅពេលសព្វថ្ងៃនេះដែរ-ជាសេចក្តីជំនឿ បរិសុទ្ធ ដ៏សាមញ្ញដែល សំឡឹងមើលទៅ ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ។

សេចក្តីជំនឿដែលរង់ចាំទាំងទន្ទឹង ដើម្បីនឹងផ្សព្វផ្សាយនូវដំណឹងល្អរបស់ការ សង្គ្រោះ ទៅដល់មិត្តភក្តិ និងអ្នកជិតខាង យើងទាំងអស់-ទៅកាន់ពិភពលោកយើង នេះទាំងមូល- ដើម្បីបំពេញទៅតាមការ ត្រាស់ហៅ របស់ដំណឹងល្អដែលព្រះយេស៊ូវ បានប្រទានដល់យើង។ នោះហើយគឺជា សេចក្តីជំនឿដ៏បរិសុទ្ធ។ នោះហើយគឺជា សេចក្តីជំនឿរបស់ពួកអ្នកជឿនៃក្រុមជំនុំនៅ សតវត្សរ៍ទីមួយ។


30

ពួកជំនុំទីមួយជាពួជំនុំនៃសេចក្តីជំនឿ ដែលមានជ័យជំនះ ត្រូវបានតំណាងដោយ សេះស។ កំឡុងពេលនេះត្រូវបានចប់នៅ គ្រិស្តសករាជទី១០០។


31

តើលោកយ៉ូហានបានឃើញអ្វីនៅពេល ដែលព្រះបានបើកត្រាទីពីរនោះ?


32

(ព្រះគម្ពីរ វិវរណៈ ៦:៤)

"នោះមានសេះ១ទៀតចេញមក មាន សម្បុរក្រហម ហើយគេឱ្យអ្នកដែលជិះមាន អំណាចនឹងដកយកសេចក្តីសុខសាន្ត ពីផែន ដីចេញ


33

ឱ្យមនុស្សលោកបានសម្លាប់គ្នា គេក៏ប្រគល់ ដាវ១យ៉ាងធំដល់អ្នកនោះដែរ" វិវរណៈ ៦:៤។

ដូច្នេះ ទីនេះយើងមានតំណាងនៃសេចក្តី ជំនឿប្រឡាក់ឈាមមួយ។

# ២២. មានជម្រើសជាច្រើន



34

យើងដឹងថា បន្ទាប់ពីគ្រិស្តសករាជ ទី ១០០មក គ្រីស្ទានត្រូវបានគេចាប់ផ្តើមដឹក នឹងរទេះ ទៅកាន់ក្រុងរ៉ូម នៅទីនោះហើយ ដែលពួកគេត្រូវបានគេសម្លាប់ ហើយជា ច្រើននាក់ទៀត ត្រូវបានគេឱ្យធ្វើជាចំណីតោ

នៅក្នុងទីលាន សិល្បៈផ្សេងៗនៅជុំវិញចក្រ ភពរ៉ូម។



35

នេះគឺជាពេលដែលអាក្រក់បំផុតសម្រាប់ ពួកជំនុំគ្រីស្ទាន! ប៉ុន្តែពួកជំនុំ នៅតែរីក លូតលាស់ដដែល។

ប្រវត្តិវិទូពួកជំនុំសាសនាគ្រីស្ទម្នាក់ នាសម័យនោះបាននិយាយថា ឈាមរបស់ គ្រីស្ទានហាក់ដូចជាគ្រាប់ពូជ។

នៅពេលដែលមនុស្សស្លាប់ ហើយនិង បានលះបង់ ជីវិតរបស់គេដើម្បីថ្វាយព្រះ យេស៊ូវ វាហាក់ដូចជាគ្រាប់ពូជ ដែលគេ បានដាំដូច្នោះដែរ ដោយត្រូវបានដុះឡើង វិញជាច្រើន ដើម្បីជំនួសពូជនោះ។ ដំណឹងល្អពីសេចក្តីសង្គ្រោះត្រូវបានផ្សព្វផ្សាយពាសពេញទាំងចក្រភពរ៉ូម ហើយពាស ពេញទាំងពិភព លោកដែលគេបានស្គាល់ នៅសម័យនោះ



36

ដូច្នេះសេះក្រហម តំណាងឱ្យពួកជំនុំ ដែលមានជំនឿប្រឡាក់ឈាម។

គ្រាទីបីគឺជាពួកជំនុំគ្រីស្ទានទីពីរ ពីគ.ស១០០ ទៅគ.ស៣២៣។



37

(ព្រះគម្ពីរ វិវរណៈ ៦:៥)

ឥឡូវនេះព្រះយេស៊ូវបើកត្រាទីបី-កំឡុង ពេលទីបីនៃពួកជំនុំគ្រីស្ទាន។

"លុះបកត្រាទី៣ នោះខ្ញុំឮតួមានជីវិត ទី៣ថា ចូរមកមើលចុះ



38

ខ្ញុំក៏ក្រឡេកទៅឃើញសេះខ្មៅ១ ឯអ្នក ដែលជិះក៏កាន់ជញ្ជីង១នៅដៃ"

វិវរណៈ ៦:៥។



39

សេះខ្មៅនេះតំណាងឱ្យក្រុមជំនុំដែលមាន សេចក្តីជំនឿមិនបរិសុទ្ធ។

# ២២. មានជម្រើសជាច្រើន


40

(ព្រះគម្ពីរ កិច្ចការ ២០:២៩,៣០)
"ដ្បិតខ្ញុំដឹងថា ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ ដែល មិនចេះប្រណីដល់ហ្វូង វានឹងចូលមកក្នុង ពួកអ្នករាល់គ្នា


41

ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹង កើតមានមនុស្ស ដែលនឹងអធិប្បាយសេចក្តី ទំនាស់ខុសដែរ ដើម្បីនឹងទាញនាំពួក សិស្សឱ្យទៅតាមគេវិញ" កិច្ចការ២០:២៩,៣០

នេះគឺជាពេលវេលាដ៏គ្រៀមក្រំរបស់
ពួកជំនុំគ្រីស្ទាន។


42

វាគឺជាពេលវេលានៃសេចក្តីជំនឿដែលមិន
បរិសុទ្ធ-នៅពេលដែលពួកកាន់សាសនាដទៃ ត្រូវបានរួបរួមជាមួយនឹងពួកគ្រីស្ទាន។
លោកដានីយ៉ែលបានទស្សនទាយអំពី រឿងនេះ។


43

(ព្រះគម្ពីរ ដានីយ៉ែល ៨:១២)
"ឯពួកពលបរិវារ ក៏ត្រូវប្រគល់ទៅ ព្រមទាំងការថ្វាយ ដង្វាយដុតជានិច្ច ដោយព្រោះអំពើរំលង


44

វាបានបោះចោលសេចក្តីពិតចុះដល់ដី ក៏ធ្វើ តាមតែអំពើចិត្តហើយបានចម្រើនផង" ដានីយ៉ែល ៨:១២។


45

ការបាត់បង់សេចក្តីពិតដ៏ធំដំបូងនៅក្នុង កំឡុងពេលនោះគឺ សេចក្តីសង្គ្រោះដោយ
ជំនឿតែមួយគត់លើព្រះយេស៊ូវ។ សេចក្តី
ជំនឿតាមរយៈព្រះគ្រីស្ទ ត្រូវបានជំនួស ដោយ សេចក្តីត្រូវការរបស់ពួកជំនុំ។



46

ប្រសិនបើលោកអ្នកនៅចងចាំដូចយើង បានសិក្សាពីមុនមក ដោយយោងតាមព្រះ គម្ពីរ
សេចក្តីសង្គ្រោះ គឺជាអំណោយទាន ដែលឥតគិតថ្លៃ។
វាគឺជាអំណោយទាន ពីព្រោះយើង
ទាំងអស់គ្នាបានធ្វើបាប មិនគួរនឹងទទួល សេចក្តីសង្គ្រោះនេះឡើយ។
យើងគួរនឹងស្លាប់ ដ្បិតឈ្នួលរបស់ អំពើបាបនោះ គឺជាសេចក្តីស្លាប់ តែអំ ណោយទាននៃព្រះវិញ គឺជាជីវិតអស់ កល្បជានិច្ច។

# ២២. មានជម្រើសជាច្រើន


47

នៅពេលដែលយើងជាមនុស្សមានបាប
នៅឡើយ ព្រះគ្រីស្ទបានសុគតជំនួស យើង។
នោះគឺជាដំណឹងយ៉ាងងាយស្រួលមួយ។


48

ដើម្បីទទួលអំណោយទានដែលឥតគិត ថ្លៃ យើងគ្រាន់តែយាងព្រះយេស៊ូវមកគង់
ក្នុងចិត្តយើងប៉ុណ្ណោះ។


49

ពេលនោះទ្រង់អត់ទោសឱ្យអំពើបាប របស់យើងទាំងអស់។


50

ហើយទីពីរ ទ្រង់នឹងប្រទានអំណាចដល់ យើងឱ្យអាចឈប់ប្រព្រឹត្តអំពើបាប។ ទ្រង់
នឹងប្រទានឱ្យយើងនូវ អំណាចឱ្យដើរតាម ដានព្រះបាទរបស់ទ្រង់។


51

ប៉ុន្តែសេចក្តីដ៏សាមញ្ញនៃសេចក្តីសង្រ្គោះ នេះ ដំណឹងល្អដ៏សាមញ្ញដែលមាននៅក្នុង ព្រះយេស៊ូវ
នៅក្នុងកំឡុងពេលនៃពួកជំនុំ គ្រីស្ទាន ដែលសេចក្តីជំនឿរបស់ពួកគេត្រូវ
បានសម្របសម្រួលជាមួយនឹងជំនឿផ្សេងៗ
នេះ ត្រូវបានជំនួស ដោយការប្រព្រឹត្តិ របស់អ្នកដឹកនាំសាសនារ៉ូម៉ាំងកាលតូលិកវិញ។


52

ជំនួសឱ្យការធ្វើដំណើរឆ្ពោះទៅបល្ល័ង្ក របស់ព្រះ ទទួលព្រះគុណ និងការអត់ឱន ទោសរបស់ទ្រង់
ជំនួសឱ្យការលន់តួបាប របស់គេ ដូចដែលមានចែងនៅក្នុងព្រះ គម្ពីរនោះ គ្រីស្ទានត្រូវបានគេប្រាប់ថា
ពួក គេត្រូវតែបង់ប្រាក់ដើម្បីឱ្យអំពើបាបរបស់គេ ត្រូវបានអត់ឱនទោសឱ្យ។


53

(ព្រះគម្ពីរ យ៉ូហានទី១ ១:៩)
ប៉ុន្តែព្រះគម្ពីរនិយាយថា "តែបើយើង លន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យ ស្មោះត្រង់
ហើយសុចរិត ប្រយោជន៍នឹង អត់ទោសបាបឱ្យយើង ហើយនិងសំអាត
យើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង"
យ៉ូហានទី១ ១:៩។

# ២២. មានជម្រើសជាច្រើន




54

គ្រីស្ទានត្រូវបានគេប្រាប់ថា ពួកគេត្រូវ តែទៅឯសម្តេចសង្ឃ។ គេត្រូវតែទៅ ឯមនុស្ស។ គេមិនអាចទៅ កាន់បល្ល័ង្ក របស់ព្រះតែម្តងតទៅទៀតបានឡើយ។

សេចក្តីសង្គ្រោះបានក្លាយទៅជាស្មុគ ស្មាញ។ ហើយមនុស្សបានទទួលការសម្រប សម្រួលនេះ ពីព្រោះគេមិនមានព្រះបន្ទូល របស់ព្រះ។


55

នៅសម័យនោះ ប្រសិនបើគេមានព្រះ បន្ទូលរបស់ព្រះ ពួកគេបានប្រឆាំងនឹងច្បាប់ ជាយថាហេតុ។

ការបោះពុម្ពមិនទាន់មាននៅឡើយ ដូច្នេះវាមានការពិបាកជាខ្លាំងដើម្បីនឹងរកបទ ព្រះគម្ពីរ សូម្បីតែមួយចំណែកតូចនៃព្រះ គម្ពីរក៏ពិបាករកដែរ។

មនុស្សជាច្រើនបានទទួលយកនូវអ្វីដែល អ្នកដឹកនាំពួកជំនុំបានប្រាប់ដល់ពួកគេ ហើយសេចក្តីជំនឿរបស់ពួកគ្រីស្ទានក៏លែង បរិសុទ្ធតទៅទៀត


56

សេចក្តីពិតទីពីររបស់ព្រះគម្ពីរ ដែល ត្រូវបានសម្របសម្រួលនោះ ទាក់ទងទៅ នឹងការថ្វាយបង្គំរូបដែលធ្វើពីឈើឬថ្ម ជា ជាងថ្វាយបង្គំព្រះដែលបង្កើតយើង។ ព្រះ មានព្រះបន្ទូលនៅក្នុងបញ្ញត្តិដប់ប្រការរបស់ ទ្រង់ថា:


57

(ព្រះគម្ពីរ និក្ខមនំ ២០:៤,៥)

"កុំឱ្យធ្លាក់ធ្វើរូបណាសំរាប់ឯងឱ្យសោះ ក៏កុំឱ្យធ្វើរូបណាឱ្យដូចជាអ្វីនៅស្ថានសួគ៌ខាង លើ


58

ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែល ទាបជាងដីផង


59

ក៏កុំឱ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមនោះឡើយ ដ្បិតអញ ដែលជាយេហូវ៉ា ជាព្រះនៃឯង អញមាន សេចក្តីប្រច័ណ្ឌ


60

ក៏ទម្លាក់ការទុច្ចរិតរបស់ឪពុកទៅលើកូនចៅ រហូតដល់៣ ហើយ៤តំណផង ចំពោះ អស់អ្នកណាដែលស្អប់អញ"

និក្ខមនំ ២០:៤,៥។

# ២២. មានជម្រើសជាច្រើន


61

នេះគឺជាពេលវេលាដែលរូបបដិមាត្រូវ បានលូនចូលសន្សឹមៗទៅក្នុងពួកជំនុំ។
បញ្ញត្តិដប់ប្រការបាន បញ្ជាក់យ៉ាង ច្បាស់ថា វាខុសស្រឡះ ក្នុងការថ្វាយបង្គំអ្វី ផ្សេងទៀតនេះ ប៉ុន្តែត្រូវថ្វាយបង្គំទ្រង់តែ មួយប៉ុណ្ណោះ។


62

ការពិតទីបីរបស់ព្រះគម្ពីរ ដែលត្រូវបាន សម្របសម្រួលនៅពេលនោះ ទាក់ទងទៅ នឹងបញ្ញត្តិទីបួន និងថ្ងៃនៃការថ្វាយបង្គំ។ សូមបញ្ជាក់នូវការដែលព្រះគម្ពីរនិយាយអំពី លោកដានីយ៉ែលនៅពេលដែលគាត់បាន ឃើញ:


63

(ព្រះគម្ពីរ ដានីយ៉ែល ៧:១៥)
"ឯខ្ញុំ ដានីយ៉ែល ចិត្តខ្ញុំកើតមាន សេចក្តីតប់ប្រមល់នៅក្នុងខ្លួន ហើយការ ជាក់ស្តែងក្នុងខ្លួនខ្ញុំក៏នាំឱ្យវិតក្កព្រួយ"
ដានីយ៉ែល៧:១៥


64

លោកអ្នកបានឃើញទេ ការដែលស្តេច កុងស្តង់ទីនបានបង្ខំរាស្ត្រឱ្យអនុវត្តច្បាប់ ថ្ងៃ អាទិត្យដំបូង: ដោយបានផ្លាស់ប្តូរថ្ងៃនៃការ ថ្វាយបង្គំពីថ្ងៃបរិសុទ្ធ ជាថ្ងៃទីប្រាំពីរ ទៅថ្ងៃអាទិត្យ ជាថ្ងៃទីមួយនៃសប្តាហ៍វិញ។


65

ព្រះគម្ពីរ យ៉ូហាន ១៤:១៥)
ប៉ុន្តែចូរចងចាំថា ព្រះយេស៊ូវបានមាន ព្រះបន្ទូលថា "បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិខ្ញុំចុះ"
យ៉ូហាន ១៤:១៥។
នៅពេលដែលសេចក្តីជំនឿត្រូវបានគេ សម្របសម្រួលជាមួយពួកមិនជឿនោះ សេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូវត្រូវបានចុះថយ ហើយមនុស្សជាច្រើនបាន ដើរតាម ប្រពៃណី ជាជាងដើរតាមព្រះវិញ


66

ក្រុមជំនុំបានទទួលការសម្របសម្រួល ជំនឿ ដែលទាក់ទងទៅនឹងថ្ងៃបរិសុទ្ធ ហើយបានប៉ុនប៉ងផ្លាស់ប្តូរថ្ងៃថ្វាយបង្គំ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៥ ទស្សនា វដ្តីសន្តបុគ្គល កាទើរីន ពួកជំនុំសង់ទី ណែលកាតូលិក និយាយថា:

# ២២. មានជម្រើសជាច្រើន


67

"ការផ្លាស់ប្តូរ
ដ៏ឥតអៀនខ្មាស និងខុសប្លែក
ពីធម្មតា ដែលពួកជំនុំ
ធ្លាប់បានធ្វើដែលបានកើតឡើង កាលពី សតវត្សរ៍ទីមួយ។ ថ្ងៃបរិសុទ្ធ


68

ថ្ងៃបរិសុទ្ធ(ថ្ងៃសាបាទ) ត្រូវបានផ្លាស់ប្តូរពី
ថ្ងៃសៅរ៍ ទៅថ្ងៃអាទិត្យ...មិនមានការណែ នាំណាដែល ត្រូវបានគេកត់សំគាល់នៅក្នុង
បទគម្ពីរនោះទេ ប៉ុន្តែដោយអំណាចរបស់ ខ្លួនវិញ


69

មនុស្សដែលគិតថាព្រះគម្ពីរ គឺជា អំណាចតែមួយគត់នោះ តាមក្បួនតក្កវិជ្ជា អ្នកនោះត្រូវតែ
ក្លាយជាអ្នកសេវេនដេយ អាត់វេនទីស្ទ និងគោរពថ្ងៃសៅរ៍ជាថ្ងៃ បរិសុទ្ធវិញ"


70

ការថ្វាយបង្គំនៅថ្ងៃអាទិត្យ ជាថ្ងៃទីមួយ នៃសប្តាហ៍ មិនមាននៅក្នុងព្រះគម្ពីរទេ។
អ្នកនៅជុំវិញពិភពលោកនេះ ទទួលស្គាល់ ការនេះដូចដែលយើងបានកត់សំគាល់រួចមក ហើយ


71

ការផ្លាស់ប្តូរនេះត្រូវបាននាំចូលមកដោយ ព្រះចៅអធិរាជនៃចក្រភពរ៉ូម ព្រះនាម កុងស្តង់ទីន
នៅក្នុងគ្រិស្តសករាជ ៣២០ ហើយពួកជំនុំបានទទួលការផ្លាស់ប្តូរនេះ។


72

មិត្តអើយ ប្រសិនបើចង់ធ្វើនូវអ្វីដែល ព្រះគម្ពីរនិយាយ យើងត្រូវតែជាអ្នកសេវេន
ដេយអាត់វេនទីស្ទ! នៅក្នុងសម័យនៃការ សម្របសម្រួលជំនឿនេះ ថ្ងៃអាទិត្យដែល
គេថ្វាយបង្គំព្រះអាទិត្យ បានត្រូវគេយកមក ជំនួសថ្ងៃបរិសុទ្ធនៅក្នុងព្រះគម្ពីរហើយ។


73

ប្រវត្តិសាស្ត្ររបស់ពួកជំនុំផ្នែកខាងកើត ទំព័រ ១៨៤ និយាយថា "កាក់របស់ស្តេចកុងស្តង់ ទីន
មានម្ខាងឆ្លាក់អក្សរ ឈ្មោះព្រះគ្រីស្ទ និងម្ខាងទៀតរូបភាពព្រះអាទិត្យ..."


74

ជាសញ្ញាថា ទ្រង់មិនអាចលះបង់ នូវភក្តី ភាពរបស់ទ្រង់ចំពោះព្រះអាទិត្យបានឡើយ"
តើនោះមិនមែនជា ការដែលគួរឱ្យចាប់ អារម្មណ៍ទេឬអី?

# ២២. មានជម្រើសជាច្រើន


75

ព្រះទ្រង់បានប្រាប់យ៉ាងច្បាស់នៅក្នុង បញ្ញត្តិដប់ប្រការរបស់ទ្រង់:



76

(ព្រះគម្ពីរ និក្ខមនំ ២០:១១)

"ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាបានធ្វើផ្ទៃ មេឃ ផែនដី ហើយនិងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ



77

រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះ បានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ"

និក្ខមនំ ២០:១១។


78

ព្រះទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា ទ្រង់ ចង់ឱ្យរាស្ត្ររបស់ទ្រង់គោរពថ្ងៃទីប្រាំពីរ ជា ថ្ងៃបរិសុទ្ធ។ ត្រឡប់ទៅឯកាលដើមដំបូងវិញ ព្រះ គម្ពីរនិយាយថា



79

(ព្រះគម្ពីរ លោកុប្បត្តិ ២:៣)

"ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ



80

ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សម្រាក ពីគ្រប់ទាំងការដែលទ្រង់បានបង្កើត បានធ្វើ"

លោកុប្បត្តិ ២:៣។



81

បើព្រះជាអ្នកបង្កើត



82

ប្រទានពរនៅថ្ងៃមួយ

# ២២. មានជម្រើសជាច្រើន


83

បើទ្រង់បានញែកថ្ងៃមួយដាច់ដោយឡែក


84

ប្រសិនបើទ្រង់បានធ្វើថ្ងៃមួយឱ្យបរិសុទ្ធជាង ថ្ងៃដទៃទៀត មិត្តអើយ ពេលនោះមនុស្ស គ្មានសិទ្ធិ គ្មានអំណាចនឹងផ្លាស់ប្តូរថ្ងៃនោះទេ!

វាបានក្លាយជាបញ្ហាសំខាន់នៃការថ្វាយ

បង្គំ ជាបញ្ហាសំខាន់នៃការស្តាប់បង្គាប់ ដែលថា តើត្រូវ ដើរតាមប្រពៃណីរបស់មនុស្ស ឬក៏ត្រូវធ្វើ តាមអ្វីដែលព្រះទ្រង់បានមានព្រះបន្ទូល។


85

នេះហើយគឺជាកំឡុងពេលនៃសេចក្តី ជំនឿសម្របសម្រួល(មិនបរិសុទ្ធ)។

សេចក្តីជំនឿសម្រប សម្រួលរបស់ ពួកជំនុំ គឺចាប់ពីគ.ស៣២៣ រហូតដល់ គ.ស៥៣៦។


86

ឥឡូវនេះយើងរំកិលទៅកំឡុងពេលទីបួន នៃក្រុមជំនុំគ្រីស្ទានដែលជាសេះពណ៌ស្លាំង។


87

(ព្រះគម្ពីរ វិវរណៈ៦:៧,៨)

“លុះបកត្រាទី៤ នោះខ្ញុំឮតួមានជីវិតទី ៤ថា ចូរមកមើលចុះ


88

ខ្ញុំក៏ក្រឡេកមើលទៅឃើញសេះ១សម្បុរ ស្លាំង ឯអ្នកដែលជិះនោះមានឈ្មោះថា សេចក្តីស្លាប់ ហើយស្ថាន ឃុំព្រលឹង មនុស្សស្លាប់ក៏តាមអ្នកនោះទៅ


89

ឱ្យគេទាំង២នោះមានអំណាចលើផែនដី ១ភាគក្នុង៤ ដើម្បីនឹងសម្លាប់ដោយដាវ”

# ២២. មានជម្រើសជាច្រើន


90

អំណត់អត់ និងសេចក្តីវេទនា ហើយដោយ សត្វព្រៃនៅផែនដីផង”

វិវរណៈ ៦:៧,៨។


91

ជំនឿស្លាប់-គ្រាទីបួន។

វាគឺជាពេលនៃ ការរួបរួមរវាងសាសនា និងរដ្ឋាភិបាល។

ឥឡូវនេះចក្រភពរ៉ូម ដ៏បរិសុទ្ធពិតជា ត្រូវបានរីកចម្រើនយ៉ាងខ្លាំង ហើយវាមិន គ្រាន់តែជាសាសនារបស់រដ្ឋ ប៉ុណ្ណោះទេ ប៉ុន្តែជានយោបាយរបស់រដ្ឋថែមទៀតផង ។

ពេលនោះហើយ ដែលមានការរួបរួមគ្នា រវាងពួកជំនុំនិងនយោបាយ។


92

សូមកត់សំគាល់ នូវប្រយោគដែលបាន ថ្លែងដោយសង្ខេបនេះៈ “គ្រីស្ទសាសនា បានក្លាយទៅជាសាសនា ដែលគេបានកាន់ ជំនួសសាសនាដទៃនៅក្នុងចក្រភពរ៉ូម ទាំង មូល។

ប្រវត្តិសាស្ត្រពួកជំនុំសាសនាគ្រីស្ទ

សតវត្សរ៍ទី២ ផ្នែកទី៧


93

សាសនាគ្រីស្ទ នៅពេលដែលមាននៅ ក្នុងយុគសម័យខ្មៅងងឹត អាចត្រូវមាន ឈ្មោះថា “ជាក្រុមដែលជ្រមុជទឹកចូលជា គ្រីស្ទសាសនា ប៉ុន្តែកាន់សាសនាដទៃវិញ”

ប្រវត្តិសាស្ត្រក្រុមជំនុំសាសនាគ្រីស្ទ សតវត្សរ៍ទី២ ជំពូក២ ផ្នែកទី៧។


94

សូមចងចាំថា នៅសម័យនោះ មនុស្ស មិនបានចូលទៅឯព្រះបន្ទូលរបស់ព្រះទេ។

បើអ្នកណាមានព្រះបន្ទូលរបស់ព្រះនោះ វា គឺជាការប្រឆាំងនិងច្បាប់យ៉ាងពិតប្រាកដ ម្យ៉ាងវិញទៀត ដូចដែលយើងបាននិយាយ រួចមកហើយថា កាលណោះ ការបោះពុម្ព មិនទាន់មាននៅឡើយ។


95

មនុស្សដើរតាមប្រពៃណី។ ពួកគេដើរ តាមការបង្រៀនរបស់សាសនាដទៃ ហើយ ពិធីបុណ្យផ្សេងៗរបស់គេ ក៏បានលូនចូល សន្សឹមៗ ទៅក្នុងពួកជំនុំសាសនាគ្រីស្ទ។

នេះគឺជាការពិតនៃប្រវត្តិសាស្ត្រដែលខ្ញុំកំពុង ចែកចាយ។

# ២២. មានជម្រើសជាច្រើន



96

(វីដេអូ ៧វិនាទី) ជំនុំគ្រីស្ទសាសនាតែ មួយគត់ ដែលមាននៅសម័យនោះគឺ ពួកជំនុំរ៉ូម។

ម្តងហើយម្តងទៀត បងប្អូនអើយ យើងមិនមែនរិះគន់ ដល់បុគ្គលណាមួយ ឡើយ ប៉ុន្តែយើងនិយាយអំពី ប្រព័ន្ធរបស់ ពួកជំនុំរ៉ូម

យើងមានដូនជី សង្ឃ និងអ្នកជឿ កាតូលិកល្អៗជាច្រើននៅលើពិភពលោកនេះ ដែលស្រឡាញ់ព្រះយេស៊ូវ យ៉ាងខ្លាំង ហើយដែលកំពុងចែកចាយនូវសេចក្តីពិត។ វាជាការសំខាន់ណាស់ដែលត្រូវយល់ថា តើ យើងជាអ្វី ហើយយើងនៅទីណាសព្វថ្ងៃនេះ។


97

នេះគឺជាកាលសម័យនៃការសម្រប សម្រួល ជំនឿមួយដ៏អាក្រក់អាក្រីជាពេលវេលានៃការបៀតបៀនយ៉ាងជូរចត់ដល់ រាស្ត្ររបស់ព្រះ។



98

ហេតុដូច្នោះហើយបានជាវាត្រូវបានគេ ហៅថា "យុគសម័យខ្មៅងងឹត" គ្រីស្ទានហាសិបលាននាក់ត្រូវបានសម្លាប់ចោល ដោយសារតែសេចក្តីជំនឿរបស់គេ។


99

សូមកត់សំគាល់ជំហាននៃការ សម្របសម្រួលសេចក្តីជំនឿទាំងនេះ



100

ប្រពៃណី



101

ការធ្វើបុណ្យ

# ២២. មានជម្រើសជាច្រើន


102

ហើយការទិញច្បាប់លោះបាប ក៏ត្រូវបាន ចូលមកក្នុងពួកជំនុំ។ អ្នកអាចយកលុយ ទៅបង់សម្រាប់ទិញការលើកលែងទោស ដើម្បីឱ្យញាតិសន្តានរបស់លោកអ្នក អាចចេញពីស្ថានលាងបាប។

ឬក៏លោកអ្នកអាចបង់លុយ សម្រាប់ លោកអ្នកផ្ទាល់ ដើម្បីកុំឱ្យលោកអ្នកចូល ទៅក្នុងលាងបាប ក្នុងចំណោមអ្នកស្លាប់។ នេះគឺជាឧទាហរណ៍ម្តងទៀតអំពីពួកអ្នកមិន ជឿគ្រីស្ទសាសនា នៅក្នុងក្រុមជំនុំគ្រីស្ទាន។


103

គ្មានរឿងដូច្នេះឡើយនៅក្នុងព្រះបន្ទូល របស់ព្រះអំពីស្ថានលាងបាបនេះទេ។

រូបបដិមាបានលួនចូលទៅក្នុងពួកជំនុំ សន្សឹមៗ ព្រមទាំងថានានុក្រម និងគោលលទ្ធិរបស់ពួកជំនុំដែរ។

យើងសួរថា តើសេចក្តីពិតរបស់ព្រះត្រូវ បានបាត់បង់រហូតឬទេ?

ពិតជាមិនដូច្នោះឡើយ ព្រោះពន្លឺនៃ សេចក្តីពិតនឹងទម្លុះចូលទៅក្នុងភាពងងឹត ហើយជំហាននឹងត្រូវឈានថយក្រោយនៅ លើស្ពាន ដើម្បីរកឱ្យឃើញជាថ្មីឡើងវិញនូវ សេចក្តីពិត ដែលបានបាត់បង់នៅក្នុង

យុគសម័យដ៏ខ្មៅងងឹតនោះ។


104

នៅក្នុងពេលនៃការកែទម្រង់នោះ សេចក្តីជំនឿលើព្រះយេស៊ូវត្រូវបានគេចាប់ផ្តើមរកឃើញឡើងវិញ។


105

មនុស្សទីមួយដែលបោះជំហានចេញ ពីយុគសម័យខ្មៅងងឹតនៃទសវត្សរ៍ទី១៤០០ នោះ គឺលោកវ៉ៃលដិនសៀន។


106

ពួកគេបានរកឃើញឡើងវិញនូវព្រះ បន្ទូលរបស់ព្រះ គឺព្រះគម្ពីរ។ ព្រះគម្ពីរ សំខាន់ណាស់។ ប្រសិនបើ យើងមិនមាន ព្រះបន្ទូលរបស់ព្រះទេ ប្រសិនបើយើងគ្មាន សំបុត្រនៃសេចក្តីស្រឡាញ់របស់ទ្រង់មកកាន់ យើង ដែលយើងរកឃើញនៅក្នុងព្រះគម្ពីរ នោះទេ យើងនឹងគ្មានការណែនាំនៅក្នុង ជីវិតឡើយ។

# ២២. មានជម្រើសជាច្រើន


107

នៅអ៊ីតាលីខាងជើង យើងរកឃើញប្រវត្តិ សាស្ត្រនៃព្រះគម្ពីរ ដែលជឿទៅលើលោក វ៉ាលដិនសៀន។

អ្នកជឿលើវ៉ាលដិនសៀន នឹងសរសេរ បទព្រះគម្ពីរដោយដៃ ហើយឱ្យចំណែក នោះទៅឱ្យកូនចៅរបស់ពួកគេ។

គេបានដេរខព្រះគម្ពីរទាំងនេះ ភ្ជាប់ទៅ នឹងអាវផាយរបស់ពួកគេ កូន ចៅរបស់ ពយកគេអាចធ្វើដំណើរចុះទៅកាន់ ទីក្រុង ធំៗនៅអឺរ៉ុប។ ពួកគេនឹងចែកចាយនូវខ ព្រះគម្ពីរទាំងនេះជាមួយនឹងមិត្តភក្តិរបស់ គេ ដែលពួកគេបានរាប់អាននៅទីផ្សារ និងនៅឯសាកលវិទ្យាល័យ។


108

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ គេចាប់បានពួកគេនឹងទទួលផលវិបាកយ៉ាង ធ្ងន់ធ្ងរ គឺពួកគេនឹងត្រូវដុតនៅនឹង បង្គោលសសរ។

ដូច្នោះមនុស្សជាច្រើនត្រូវបាន បាត់បង់ ជីវិត ក្រុមវ៉ាលដិនសៀន បាន ពិចារណា ថា វាគឺជាអាទិភាពមួយ ដើម្បីឱ្យការងារ របស់ព្រះអាចមានជីវិតរស់នៅ។


109

បន្ទាប់ពវ៉ាលដិនសៀនទៅ ការកែ ទម្រង់ក៏បានមកដល់ ដោយនិស្សិតព្រះគម្ពីរ ម្នាក់នៅទីក្រុងប្រាក ឈ្មោះហ្វូន ហាស។

លោកហាស ជាមួយនឹងមិត្តរបស់គាត់ ហ្សេរ៉ូម បានរកឃើញថា វាជាការសំខាន់ លើសអ្វីៗទាំងអស់ ក្នុងការស្តាប់បង្គាប់ព្រះ ជាជាងស្តាប់បង្គាប់ពួកជំនុំឬស្តាប់បង្គាប់ មនុស្ស។


110

ពីព្រោះជំហរនៃការស្តាប់បង្គាប់របស់ ពួកគេ ដែលមានជំនឿថា យើងត្រូវតែ ស្តាប់បង្គាប់នូវអ្វីដែលព្រះ បានទាមទារឱ្យ យើងធ្វើ ប្រសើរជាងដើរតាមប្រពៃណី របស់ពួកជំនុំ ពួកគេត្រូវបានដុតសម្លាប់។

ផេះនៃសាកសពរបស់គេត្រូវបានបាច សាចចូលទៅក្នុងសមុទ្រម៉េឌីទែរ៉ាណេ។

ការកែទម្រង់បានហូរចេញពីប្រភព របស់ខ្លួន ទៅកាន់ពាសពេញ ពិភពលោក ទាំងមូល ច្រើនដូចជាផេះដែល គេបានបាចទៅក្នុងសមុទ្រដូច្នោះដែរ។


111

បន្ទាប់មកហាស និងហ្សេរ៉ូម បានត្រូវ គេដុតនៅនឹងបង្គោលសសរ ជនជាតិអាឡឺម៉ង់ ម្នាក់ ឈ្មោះ ម៉ាធិន លូធើរ បានរកឃើញសេចក្តីពិតនៃព្រះគម្ពីរ មួយ ដែលនិយាយអំពីសេចក្តីសង្គ្រោះ ដោយសារតែព្រះគុណប៉ុណ្ណោះ។

# ២២. មានជម្រើសជាច្រើន


112

មនុស្សខ្លះសួរនូវសំនួរថា "តើហេតុអ្វី បានជាលោកលូធើរ មិនបានរកឃើញឡើង
វិញនូវសេចក្តីពិតទាំងអស់ ដែលបានបាត់ បង់នៅក្នុងយុគសម័យខ្មៅងងឹត?" ហើយ
ព្រះគម្ពីរនិយាយថា


113

(ព្រះគម្ពីរ យ៉ូហាន ១៦:១២)
"ខ្ញុំនៅមានសេចក្តីច្រើនទៀត នឹងប្រាប់ ដល់អ្នករាល់គ្នា តែឥឡូវនេះ អ្នករាល់គ្នា
ពុំអាចនឹងទទួលបានទេ"
យ៉ូហាន ១៦:១២។


114

ការរកឃើញសេចក្តីពិតនៃព្រះគម្ពីរ ត្រូវ ចំណាយពេលយ៉ាងច្រើន វាមានដំណើរ ការជាដំណាក់ៗ។
វាត្រូវការពេលរាប់រយឆ្នាំ សម្រាប់យើង ទម្រាំនឹងបាត់បង់សេចក្តី ជំនឿលើព្រះយេស៊ូវ
នៅក្នុងយុគសម័យ ដ៏ខ្មៅងងឹតនោះ។
ហើយវាក៏នឹងត្រូវចំណាយពេលរាប់រយ ឆ្នាំ ដើម្បីនឹងរកឱ្យឃើញឡើងវិញនូវសេចក្តី
ពិតទាំងនេះដែរ។


115

នៅពេលដែលលោកលុធើរស្លាប់ទៅ អ្នកដែលជឿទៅលើគាត់ បានទទួលយកនូវ
អ្វីដែលគាត់បាននិយាយ ហើយក៏បាន បង្កើតជាក្រុមជំនុំលុធើររៀនឡើង។ សម្រាប់ពួកគេ
ការកែទម្រង់បានឈប់នៅ ត្រង់មរណកាលរបស់លោកលុធើរ។


116

ពីប្រទេសអាឡឺម៉ង់ទៅ យើងធ្វើដំណើរ ទៅកាន់ទីក្រុងហ្សឺណែវ ប្រទេសស្វីស ហើយរកនិស្សិត
ព្រះគម្ពីរម្នាក់ទៀតឈ្មោះ ហ្ចនកាល់វីន ដែល


117

រកឃើញនៅក្នុងការសិក្សារបស់គាត់ថា គ្រីស្ទានមិនមែនគ្រាន់តែទទួលព្រះគុណ និងការអត់ឱនទោស
ប៉ុណ្ណោះទេ ប៉ុន្តែ អាចទៅបន្តរហូតដល់បល្ល័ង្កនៃព្រះគុណ
ប៉ុន្តែវាជាការសំខាន់របស់ពួកគេក្នុងការរីកចំ រើននៅក្នុងព្រះគ្រីស្ទ។


118

ដូច្នេះលោកកាល់វីនក៏បានបង្រៀនអំពី គោលលទ្ធិនៃការរីកចំរើនខាងវិញ្ញាណ ដែល
អ្នកខ្លះបានហៅថា សន្តុបនីយកម្ម។ នៅ ពេលដែលយើងទទួលព្រះយេស៊ូវ ទ្រង់ប្រ
ទានឱ្យយើងនូវអំណាចឈ្នះលើអំពើបាប។

# ២២. មានជម្រើសជាច្រើន


119

នៅពេលដែលលោកហ្វូនកាលវិនបាន ស្លាប់ទៅ ពួកអ្នកដែលដើរតាមគាត់បាន យកនូវអ្វីដែលគាត់បាននិយាយ ហើយក៏ បានបង្កើតជាក្រុមជំនុំ ប្រេសប៊ីធើរៀន ឡើង។ លោកអ្នកឃើញទេ ដូច្នេះសេចក្តី ពិតដែលបាត់ម្តង នៅក្នុងយុគសម័យដ៏ខ្មៅ ងងឹតនោះ ត្រូវបានរកឃើញឡើងវិញដោយ គ្មានការប្រែប្រួល។


120

បន្ទាប់ពីលោកកាលវិនទៅ មានក្រុម គ្រីស្ទានមួយក្រុមនៅក្នុងផ្នែកខាងជើងនៃទ្វីប អឺរ៉ុប ដែលបានសិក្សាព្រះគម្ពីររបស់គេ ហើយបានដល់នូវសេចក្តីសន្និដ្ឋានមួយថា ជំនួសឱ្យការប្រោះទឹកលើទារក


121

ការជ្រមុជទឹកត្រូវធ្វើតាមគំរូរបស់ព្រះយេស៊ូវ ដោយធ្វើការសម្រេចចិត្តផ្ទាល់របស់បុគ្គល ម្នាក់ៗ ហើយត្រូវធ្វើដោយការជ្រមុជលិច ទៅក្នុងទឹក។ ពួកគេត្រូវបានគេហៅថា អាណាបាបទីស្ទ


122

ការជ្រមុជទឹកដោយការជ្រមុជលិចទៅ ក្នុងទឹក គឺជាការជ្រមុជលិចទាំងអស់ទៅ ក្នុងទឹក ដូចដែលព្រះយេស៊ូវបានធ្វើ គឺជា សេចក្តីពិតដ៏សំខាន់មួយដែលបានត្រូវបាត់បង់ នៅក្នុងយុគសម័យខ្មៅងងឹត ដែលជា និមិត្តរូប នៃការស្លាប់និងរស់ឡើងវិញ ជា មួយនឹងព្រះអង្គ។


123

(ព្រះគម្ពីរ រ៉ូម ៦:៣,៤) "តើអ្នករាល់គ្នា មិនដឹងទេឬអីថា យើងទាំងប៉ុន្មានដែល បានទទួល បុណ្យជ្រមុជក្នុងព្រះយេស៊ូវ គ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្តី សុគតរនៃទ្រង់ដែរ"


124

ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់


125

ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មីដូចជា ព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយ សារសិរីល្អនៃព្រះវរបិតាដែរ រ៉ូម ៦:៣,៤។


126

ហើយដើម្បីនឹងទទួលការជ្រមុជទឹកដូច ដែលព្រះយេស៊ូវបានធ្វើនោះ

# ២២. មានជម្រើសជាច្រើន


127

យើងត្រូវតែរៀនពីទ្រង់


128

លន់តួបាបរបស់យើង


129

ហើយទទួលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ របស់យើង។ ពួកអាណាបាបទីស្ទជាច្រើន ត្រូវបានបាត់បង់ជីវិតរបស់គេ ដោយគេបាន ជឿថា ពួកគេត្រូវតែដើរតាមស្នាមជានព្រះបាទរបស់ព្រះយេស៊ូវ ហើយនិងទទួល ជ្រមុជទឹកដូចដែលទ្រង់បានធ្វើ។


130

ចាប់តាំងពីការចាប់ផ្តើមដ៏បន្ទាបខ្លួននេះ មក ក្រុមជំនុំបាបទីស្ទត្រូវបានបង្កើតឡើង។


131

(ព្រះគម្ពីរ ម៉ាថាយ ២៨:១៨,១៩) "ឯ ព្រះយេស៊ូវទ្រង់យាងមកមានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកឱ្យខ្ញុំនៅ លើស្ថានសួគ៌ ហើយលើផែនដីផង


132

ដូច្នេះចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្ស នៅគ្រប់ទាំងសាសន៍


133

ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវ ព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ"

ម៉ាថាយ ២៨:១៨,១៩។

# ២២. មានជម្រើសជាច្រើន


134

ព្រះយេស៊ូវបានបញ្ជូនការត្រាស់បង្គាប់ ដល់ពួកជំនុំរបស់ទ្រង់ ឱ្យចេញទៅបង្រៀន និងធ្វើបុណ្យជ្រមុជទឹក ហើយនិងបង្កើត សាវក។
ពួកកែទម្រង់បាបទីស្ទ បានបន្តដើរតាម និងបំពេញនូវការអំពាវនាវនោះដូច ដែលយើងធ្វើសព្វថ្ងៃនេះដែរ!


135

លោកអ្នកឃើញទេ អ្នកកែទម្រង់ទាំង នេះ បានរកឃើញសេចក្ដីដែលបានបាត់បង់ នៅក្នុងយុគសម័យដ៏ខ្មៅងងឹត។ នៅពេល ដែលពួកគេរកឃើញសេចក្ដីពិត ពួកអ្នកដែលដើរតាមរបស់គេ បានចងបាច់គ្នាទៅ ជាអ្វី ដែលក្រោយមកបានក្លាយជា គណៈ (អ្នកប្រឆាំងប្រូតេស្តង់)យ៉ាងធំ ដូចជា គណៈលុធើរវៀន ប្រេសប៊ីធើរវៀន និងបាបទីស្ទ


136

ទីបំផុត នៅឯប្រទេសអង់គ្លេស បុរស ម្នាក់ឈ្មោះ ហ្វូនវេស្លី បានចាប់ផ្ដើមសិក្សា ព្រះគម្ពីរ។


137

ប្អូនប្រុសរបស់គាត់ ឆារល្ស៍បានសរសេរ បទចម្រៀងយ៉ាងពិរោះ អំពីព្រះយេស៊ូវ ហើយពួកគេបានបន្សល់ទុកនូវបទ ចម្រៀងទាំងនេះ ដើម្បីច្រៀងនៅក្នុងព្រះ វិហារ។
ពួកគេថែមទាំងបានរកឃើញថា វាមិន មែនជាការសំខាន់តែមួយគត់ ក្នុងការទទួល អំណោយទានដែលឥតគិតថ្លៃនៃសេចក្ដី សង្គ្រោះ ការស្ដាប់បង្គាប់ព្រះ ការទទួល បុណ្យជ្រមុជទឹក និងការរីកចំរើនក្នុងព្រះ គុណប៉ុណ្ណោះទេ ប៉ុន្តែគឺជាការឈរនៅលើ មូលដ្ឋាននៃព្រះបន្ទូលរបស់ព្រះឱ្យបរិសុទ្ធ វិញ។ លោកហ្វូនវេស្លី គឺជាអ្នកកែទម្រង់ដ៏ ឧត្ដមម្នាក់ ហើយនៅពេលដែលគាត់បានស្លាប់ទៅ ពួកអ្នកដែលដើរតាមគាត់ បាន យកនូវអ្វីដែលគាត់ និងអ្នកកែទម្រង់ដទៃ ទៀតបានបង្រៀន ហើយបានរៀបចំជាក្រុម ជំនុំមេតូឌីស្ទ។


138

ពេលនោះ ផ្នែកផ្សេងៗនៃពិភពលោក ដូចជាអាមេរិកខាងត្បូង អឺរ៉ុប និង អាមេរិកខាងជើង មនុស្សចាប់ផ្ដើមសិក្សា អំពីការយាងមកជាលើកទីពីររបស់ព្រះ យេស៊ូវ។


139

បុរសម្នាក់ឈ្មោះ វីលៀម មីល្ល័រ នៅ អាមេរិកខាងជើង បានសិក្សាសេចក្ដីសន្យា របស់ព្រះយេស៊ូវ នៅក្នុងព្រះគម្ពីរយ៉ូហាន ទី១៤។ គាត់ក៏បានសិក្សាអំពីបទទំនាយ របស់ដានីយ៉ែល និងវិវរណៈ ហើយគាត់ បានយល់ថា ព្រះយេស៊ូវនឹងយាងមកវិញ ឆាប់ៗនេះ។

# ២២. មានជម្រើសជាច្រើន



140

ដូច្នោះ គឺជាមូលដ្ឋាននូវអ្វីដែល



141

វ៉ាលដិនសៀន បានបង្រៀនអំពីព្រះគម្ពីរ



142

អ្វីដែលលោកហាស បានបង្រៀនអំពីការ ស្តាប់បង្គាប់



143

អ្វីដែលលោកលុធើរបានបង្រៀនអំពីព្រះគុណ



144

អ្វីដែលលោកកាលវិនបានបង្រៀន អំពី សន្ធបនីយកម្ម ឬការលូតលាស់ខាងវិញ្ញាណ



145

អ្វីដែលពួកអាណាបាបទីស្ទបានបង្រៀន អំ ពីការជ្រមុជទឹក



146

និងអ្វីដែលលោកវេស្លីបានបង្រៀនអំពីភាព បរិសុទ្ធ លោកមីល្លើរ បានបន្ថែមទៅលើ ការបង្រៀនទាំងនេះ នូវគោលទ្ធិមួយយ៉ាង សំខាន់ជាខ្លាំង: គឺការយាងមកដ៏ជិតបំផុត របស់ព្រះគ្រីស្ទ

# ២២. មានជម្រើសជាច្រើន



147

បន្ទាប់ពីពេលនៃមីល្វើរទៅ ចលនាអាត់ វេនបានបន្ត។ មិត្តរបស់គាត់បានរកឃើញ ផងដែរថា នៅពេលណាមនុស្សស្លាប់ គេ បានដេកលក់ក្នុងព្រះយេស៊ូវ រង់ចាំការរស់ ឡើងវិញ។

ដូចដែលព្រះគម្ពីរបានបង្រៀនយ៉ាង ច្បាស់ថា យើងដេកលក់រហូតដល់ពេលនៃ ការរស់ឡើងវិញ នៅពេលដែលយើងត្រូវ បានហៅចេញពីផ្នូរ។ ពេលនោះគឺជាព្រឹក ដ៏មានសិរីល្អអស្ចារ្យ ដែលនឹងរួបរួមជាមួយ នឹងអ្នកដែលជាទីស្រឡាញ់របស់យើងវិញ!



148

អ្នកអាត់វេនទីស្ពដំបូងបានរកឃើញនៅ ក្នុងព្រះគម្ពីរ:



149

១. ការស្លាប់គឺជាការដេកលក់



150

២. ព្រះយេស៊ូវនឹងយាងមកវិញឆាប់ៗ



151

៣. ទ្រង់នឹងប្រោសអ្នកស្លាប់ឱ្យរស់ឡើង វិញ នៅពេលនៃការរស់ឡើងវិញ:



152

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៦)

"ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពី ស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតានិងត្រែរបស់ ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទ នឹង រស់ឡើងវិញជាមុនបង្អស់" ថែស្សាឡូនីចទី១ ៤:១៦។

# ២២. មានជម្រើសជាច្រើន


153

(ព្រះគម្ពីរ យ៉ូហាន ១៤:១៥)

បន្ទាប់ពីសម័យវិលៀម មីល្លើរទៅ អ្នកជឿលើការយាងមកជាលើកទីពីររបស់ ព្រះគ្រីស្ទ ក៏បានរកឃើញព្រះបន្ទូលរបស់ ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរយ៉ូហាន ១៤:១៥ "បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរ កាន់តាមបញ្ញត្តិខ្ញុំចុះ"

លោកអ្នកឃើញទេ យើងទាំងអស់គ្នា ត្រូវតែមានទំនាក់ទំនងនៃសេចក្ដីស្រឡាញ់ជាមួយនឹងព្រះយេស៊ូវ។

ដោយសារយើងស្រឡាញ់ទ្រង់ យើង ចង់គោរពបញ្ញត្តិទាំងអស់របស់ទ្រង់។ មិនមែនគ្រាន់តែបញ្ញត្តិខ្លះនោះទេ ប៉ុន្តែបញ្ញត្តិ គ្រប់ទាំងអស់។


154

(ព្រះគម្ពីរ ម៉ាថាយ ១៥:៩)

សូមកត់សំគាល់នូវការដែលព្រះយេស៊ូវ បានមានព្រះបន្ទូលនៅក្នុង ព្រះគម្ពីរ ម៉ាថាយ១៥:៩ "គេថ្វាយបង្គំអញជាឥត ប្រយោជន៍ទេ ព្រោះគេបង្រៀនសេចក្ដី ដែលជាបញ្ញត្តិរបស់មនុស្សវិញ" វាពិត ណាស់សព្វថ្ងៃនេះ។ មនុស្សបង្រៀនគោល លទ្ធិ និងបញ្ញត្តិរបស់មនុស្ស។


155

ប៉ុន្តែអ្វីដែលមនុស្សនិយាយនោះ វាមិនសំខាន់អ្វីទេ។ រឿងដែលសំខាន់នោះ គឺជាអ្វីដែលព្រះមានព្រះបន្ទូលទៅវិញទេ។


156

នៅពេលដែលវាចូលដល់ការថ្វាយបង្គំ យើងត្រូវតែថ្វាយបង្គំព្រះនៅថ្ងៃបរិសុទ្ធដែលទ្រង់បានញែកចេញសម្រាប់យើង។ វាគឺ ថ្ងៃពិសេសមួយដែលទ្រង់បានប្រទានដល់ យើង។ នៅពេលដែលសេចក្ដីពិតនេះត្រូវ បានគេរកឃើញឡើងវិញនៅក្នុងព្រះគម្ពីរ មនុស្សក៏បានសិក្សាសេចក្ដីពិតទាំងនេះ ក៏ ចាប់ផ្ដើមចងក្រងគ្នាឡើង ហើយបង្កើតជាក្រុមជំនុំសេវេនដេយអាត់វេនទីស្ទ ជា យថាហេតុឡើង។
គម្ពីរអេសាយ ៥៨:១៣ និង១៤ បាន ទស្សនទាយថា នឹងមានចលនាមួយដែល ហៅថាជាក្រុមជួសជុលការបាក់បែក ដែលនឹងប្រព្រឹត្តល្មើសពីបញ្ញត្តិព្រះ។
បទព្រះគម្ពីរនេះនិយាយអំពីថ្ងៃដ៏ពិសេសនេះ:


157

(ព្រះគម្ពីរ អេសាយ ៥៨:១៣,១៤)

"បើឯងឃាត់ជើងឯង មិនឱ្យបែរចេញ ពីថ្ងៃឈប់សំរាក គឺមិនធ្វើតាមអំពើចិត្តនៅថ្ងៃបរិសុទ្ធរបស់អញ

# ២២. មានជម្រើសជាច្រើន


158

បើឯងរាប់ថ្ងៃឈប់សម្រាកទុកជាទីរីករាយចិត្ត ហើយលើកថ្ងៃបរិសុទ្ធរបស់ព្រះយេហូវ៉ា ទុកជាថ្ងៃគួរគោរព ព្រមទាំងប្រតិបត្តិផង


159

ឥតធ្វើតាមអំពើចិត្តរបស់ខ្លួន ឬស្វែងរក សេចក្ដីអំណរដល់ខ្លួនឯង ឬពោលតែពាក្យរបស់ផងខ្លួនឡើយ


160

គ្រានោះឯងនឹងបានចិត្តរីករាយក្នុងព្រះយេហូវ៉ា


161

ហើយអញនឹងបញ្ជិះឯងនៅលើទីដ៏ខ្ពស់នៃផែនដី


162

ហើយនិងចិញ្ចឹមឯងដោយមរតករបស់យ៉ាកុប ជាឰយុកោឯង ដ្បិតព្រះឱស្ឋនៃព្រះយេហូវ៉ាបានចេញវាចាហើយ”


163

ព្រះអម្ចាស់ប្រាប់យើងយ៉ាងច្បាស់ថា យើងមិនត្រូវធ្វើការងារ នៅថ្ងៃនោះឡើយ។ ឥតធ្វើតាមអំពើចិត្ត នៅថ្ងៃនោះទេ យើង មិនត្រូវស្វែងរកសេចក្ដីអំណរដល់ខ្លួនឯងនៅថ្ងៃនោះឡើយ។

# ២២. មានជម្រើសជាច្រើន



164

វាគឺជាថ្ងៃដ៏បរិសុទ្ធមួយ។ នៅពេលដែល យើងយកព្រះជាទីមួយនៅថ្ងៃបរិសុទ្ធ ពេលនោះជីវិតរបស់យើង និងពោរពេញទៅ ដោយភាពរីករាយ។

ថ្ងៃបរិសុទ្ធគឺជាថ្ងៃដ៏រំភើបបំផុត។ ព្រះ មិនបានយកចេញឆ្ងាយពីយើងទេ ទ្រង់កំពុងតែប្រទានឱ្យយើងនូវព្រះពរជាពិសេស។

វាដូចជាថ្ងៃសម្រាកមួយដែលនៅតែមាន ប្រាក់ខែដូច្នោះដែរ។

ទ្រង់មានបន្ទូលថា ទ្រង់នឹងបញ្ជិះយើង នៅលើទីដ៏ខ្ពស់បំផុតនៃផែនដីនេះ។ នេះគឺជាព្រះពរដ៏អស្ចារ្យ ដែលទ្រង់នឹងប្រទាន ដល់យើង ប្រសិនបើយើងទុកទ្រង់ជាទីមួយ និងពិសេសបំផុតនៅក្នុងជីវិតរបស់យើង-ប្រសិនបើយើងដើរតាមទ្រង់ និងរក្សាថ្ងៃបរិសុទ្ធឱ្យបានបរិសុទ្ធ ដូចដែលទ្រង់បានសុំ ឱ្យយើងធ្វើនោះ។




165

ដូច្នេះ គ្រប់ទាំងសេចក្តីពិតដែលព្រះ បានប្រទានដល់យើងនៅក្នុងព្រះគម្ពីរ សាតាំងបាននាំមកនូវការក្លែងក្លាយ-ការត្រាប់ តាមរឿងក្លែងក្លាយ។



166

ព្រះទ្រង់មានព្រះបន្ទូលថា នៅពេល ដែលយើងស្លាប់ទៅ យើងដេកលក់នៅក្នុង ផ្នូរ។ សាតាំងក្លែងបន្លំថា យើងនឹងទៅកាន់ ស្ថានសួគ៌ ឬស្ថាននរក ឬស្ថានកណ្តាល នៃសេចក្តីស្លាប់។



167

ព្រះទ្រង់មានព្រះបន្ទូលថា ការជ្រមុជ ទឹក គឺការជ្រមុជលិចទៅក្នុងទឹក។ សាតាំង និយាយថា អាចគ្រាន់ តែប្រោះទឹកបាន ហើយ។ ព្រះបានប្រទានសេចក្តីពិតដល់ យើងអំពីសុខភាព។ សាតាំងនិយាយថា ច្បាប់សុខភាព ត្រូវបានលប់ចោលហើយ។

នៅរាល់ការពិតសុទ្ធតែមានការក្លែងបន្លំទាំង អស់។ ហើយការនោះហើយ ដែលបង្កើតឱ្យមានការភាន់ច្រឡំ។




168

(ព្រះគម្ពីរ វិវរណៈ ១៨:២)

សៀវភៅវិវរណៈនិយាយអំពីការនេះ "ទេវតានោះបន្លឺឡើង ដោយសំឡេងយ៉ាង ខ្លាំងថា ក្រុងបាប៊ីឡូនដ៏ជាធំបានរលំហើយ បានរលំហើយ




169

ក៏ត្រឡប់ជាលំនៅនៃពួកអារក្ស ជាកន្លែង របស់អស់ទាំងវិញ្ញាណអាសោច៍ និងអស់ ទាំងសត្វស្លាបអាសោច៍ គួរខ្ពើម" វិវរណៈ ១៨:២។

បាប៊ីឡូននៅក្នុងបទទំនាយមានន័យថា "សាសនាច្របូកច្របល់" ហើយសូមកត់សំគាល់ការអំពាវនាវនេះ។

# ២២. មានជម្រើសជាច្រើន


170

(ព្រះគម្ពីរ វិវរណៈ ១៨:៤)

"ខ្ញុំក៏ឮសំឡេង១ទៀតពីលើមេឃ ពោលថា រាស្ត្រអញអើយ ចូរចេញពីទី ក្រុងនោះមក


171

ដើម្បីកុំឱ្យមានចំណែកក្នុងអំពើបាបវាឡើយ ក្រែងត្រូវវេទនាដូចជាវាដែរ"
វិវរណៈ១៨:៤។


172

ព្រះកំពុងត្រាស់ហៅរាស្ត្ររបស់ទ្រង់ឱ្យ ចេញពីការច្របូកច្របល់ ដើម្បីកុំឱ្យគេត្រូវ បានក្លាយជាអ្នករួមចំណែកនៃអំពើបាប របស់វា។ មិត្តអើយ ព្រះយេស៊ូវកំពុង ហៅអ្នក។ ឥឡូវនេះគឺជាពេលដែលយើង ត្រូវក្រោកឈរឡើងដើម្បីព្រះយេស៊ូវ!


173

(ព្រះគម្ពីរ កិច្ចការ ២:៤៧)

សូមកត់សំគាល់ព្រះបន្ទូលរបស់ព្រះៈ "ព្រមទាំងសរសើរដល់ព្រះ ហើយបណ្តាជនទាំងអស់គ្នាក៏រាប់អានគេ ចំណែកព្រះ អម្ចាស់ ទ្រង់ក៏បន្ថែមនូវអស់អ្នកដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃ"
កិច្ចការ ២:៤៧។


174

(ព្រះគម្ពីរ កូរិនថូសទី១ ១២:១៣)

"ដ្បិតយើងទាំងអស់គ្នា ទោះបីជា សាសន៍យូដា ឬសាសន៍ក្រេក ពាវបំរើ ឬអ្នកជាក្តី...


175

ត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ" កូរិនថូសទី១ ១២:១៣


176

(ព្រះគម្ពីរ កូរិនថូសទី១ ១:១៨)

"ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្តី ចំកួតដល់អ្នកដែលកំពុងតែវិនាស

# ២២. មានជម្រើសជាច្រើន



177

តែជាព្រះចេស្តានៃព្រះដល់យើងរាល់គ្នា ដែលកំពុងតែបានសង្គ្រោះវិញ” កូរិនថូសទី១ ១:១៨។


178

ដូចដែលយើងបានសិក្សារួចមកហើយ នៅវេលាយប់នេះ វាច្បាស់លាស់ណាស់ ដើម្បីឱ្យបានឃើញថា តាមរយៈជីវិតរបស់ ព្រះយេស៊ូវ និងការបង្រៀនរបស់ទ្រង់ បើកសំដែងឱ្យឃើញការពិត ដែលទ្រង់ចង់ ឱ្យអ្នកដើរតាមទ្រង់ដឹង និងធ្វើតាម។

យើងបានដឹងរួចមកហើយថា មាន សង្គ្រាមរវាងសេចក្ដីពិត និងក្រុមជំនុំរបស់ ព្រះគ្រីស្ទ ការបៀតបៀន ការពុករលួយ និងការក្លែងក្លាយ សេចក្ដីពិតដែលព្រះគ្រីស្ទ បានប្រទានដល់ក្រុមជំនុំរបស់ទ្រង់។

យើងបានឃើញនៅក្នុងការសិក្សាព្រះ គម្ពីរ និងប្រវត្តិសាស្ត្ររបស់យើងថា ព្រះគ្រីស្ទកំពុងដឹកនាំរាស្ត្ររបស់ទ្រង់ ត្រឡប់ ទៅរកសេចក្ដីពិត ដែលទ្រង់បានប្រទានដល់ក្រុមជំនុំដើមរបស់ទ្រង់។ ទ្រង់កំពុង ហៅមនុស្សឱ្យចេញពី សាសនាច្របូក ច្របល់ ហើយចូលទៅក្នុងសេចក្ដីពិត ដែលមាននៅក្នុងការងារបរិសុទ្ធរបស់ទ្រង់។ តើលោកអ្នកមិនចង់ឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ទេវតាឥឡូវនេះថា “...ចូរចេញ ពីវាមក រាស្ត្រអញអើយ!” តើលោកអ្នក មិនចង់ចូលរួមចំណែកក្នុងក្រុមជំនុំរបស់ព្រះ “ដែលគោរពបញ្ញត្តិរបស់ទ្រង់ទាំងអស់ ហើយនិងមានជំនឿលើព្រះយេស៊ូវ” ឥឡូវ នេះឬទេ?

យើងត្រូវបានហៅចេញពីបាប៊ីឡូន ដើម្បីនឹងធ្វើនូវអ្វីដែលត្រឹមត្រូវ តើអ្នកមិនស្រឡាញ់ព្រះយេស៊ូវរបស់អ្នកទេឬអី? ទ្រង់ នឹងយាងមកវិញឆាប់ៗនេះ ដើម្បីនឹងយកយើងទៅកាន់ដំណាក់នៅស្ថានសួគ៌ ដែល ទ្រង់កំពុងរៀបចំសម្រាប់យើងរាល់គ្នាឥឡូវ នេះ។ តើលោកអ្នកចង់ដើរតាមទ្រង់ទាំង ស្រុងឬទេ?

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ



1

តើធ្វើយ៉ាងណាដើម្បីគេចឱ្យផុតពីការវេទនាទាំងប្រាំពីរចុងក្រោយ។


2

ទីកន្លែងគឺប្រទេសអេស៊ីព្ទ.ជាតិសាសន៍ ដែលមានការជឿនលឿនជាងគេបំផុត នៅពេលដែលរឿងនោះកើតមានឡើង។ គឺនៅ ក្នុងឆ្នាំ១៤៤៥ មុនគ្រិស្តសករាជ។ អស់រយៈពេល២១៥ឆ្នាំដែលកូនចៅអ៊ីស្រាអែល បានរស់នៅទីនោះ.ពេលនោះ ជាសតវត្សរ៍ ចុងក្រោយបង្អស់ក្នុងទាសភាពដ៏ជូរចត់ របស់ពួកគេ។

ស្តេចដ៏គួរជាទីរាប់អាន ផារ៉ោន បាន ស្គាល់និងលើកដំកើងយ៉ូសែប យ៉ាងយូរហូតដល់បានស្លាប់និងសុគតរៀង១ខ្លួន។


3

អ្នកដឹកនាំថ្មី បានឃើញការជឿនលឿន យ៉ាងឆាប់រហ័សរបស់ពួកអ៊ីស្រាអែល ដែលជាការដែលគួរឱ្យព្រួយបារម្ភមួយដល់សន្តិសុខ

របស់ជាតិ ដោយភ័យខ្លាចក្រែង ពួក អ៊ីស្រាអែលអាច ចូលរួមជាមួយនឹង សត្រូវ របស់អេស៊ីព្ទនៅក្នុងពេលមានសង្គ្រាម។

ដូច្នេះហើយកូនចៅអ៊ីស្រាអែលត្រូវបាន គេដាក់ជាទាសករ ត្រូវបានគេបង្ខំឱ្យក្លាយជាទាសករនៅក្រោមការសង្កត់សង្កិនដ៏កំណាច របស់ជនជាតិអេស៊ីព្ទ។ ប៉ុន្តែព្រះគម្ពីរ និយាយថា


4

(ព្រះគម្ពីរ និក្ខមនំ ១:១២)

ប៉ុន្តែព្រះគម្ពីរនិយាយថា "ប៉ុន្តែដែល ធ្វើទុក្ខគេប៉ុនណា


5

នោះគេក៏ចំរើនជាច្រើន" និក្ខមនំ ១:១២។


6

(ព្រះគម្ពីរ និក្ខមនំ ២:២៣.២៤)

"...នោះពួកកូនចៅអ៊ីស្រាអែលគេថ្ងូរ ឡើង ដោយព្រោះការទុក្ខលំបាក

២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


7

ហើយក៏អំពាវនាវដល់ព្រះ ដោយព្រោះ ការទុក្ខលំបាករបស់ខ្លួន


8

ទ្រង់ឮដំងូររបស់គេ ហើយក៏នឹកចាំពី សេចក្ដីសញ្ញាដែលទ្រង់បានតាំងនឹងអ័ប្រាហាំ នឹងអ៊ីសាកហើយនិង យ៉ាកុប" និក្ខមនំ ២:២៣_២៤។


9

វាមានរយៈពេលជាង៤០០ឆ្នាំ តាំងពី ព្រះបានធ្វើសេចក្ដីសញ្ញាជាមួយនឹងលោក អ័ប្រាហាំ ទាក់ទងទៅនឹង កូនចៅខាង ក្រោយរបស់គាត់និងការរំដោះរបស់ពួកគេ។ ឥឡូវនេះ ទីបញ្ចប់នៃថ្ងៃនោះក៏បានមក ដល់។

ព្រះទ្រង់បានរៀបចំរួចជាស្រេច ហើយ ការរំដោះរបស់ទ្រង់ក៏បានរៀបចំរួចស្រេចដែរ!


10

ព្រះបានជួបជាមួយនឹងលោកម៉ូសេ មិនមែននៅក្នុងព្រះរាជវាំងទេ មិនមែននៅក្រោមម្លប់ពីរ៉ាមីតណាមួយ នោះទេ ប៉ុន្តែនៅខាងក្រៅ ឯទីរហោស្ថាន ម៉ាខាន ក្បែរគុម្ពោតឆេះមួយ។


11

(ព្រះគម្ពីរ និក្ខមនំ ៣:៧_៨)

"រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញបានឃើញសេចក្ដីវេទនារបស់ រាស្ត្រ អញ ដែលនៅស្រុកអេស៊ីព្ទហើយ


12

ក៏បានឮពាក្យគេអំពាវនាវដោយព្រោះពួកអ្នក ដែលសង្កត់សង្កិនដែរ ពីព្រោះអញស្គាល់ សេចក្ដីទុក្ខព្រួយរបស់គេ


13

ដូច្នេះ អញបានចុះមកដើម្បីនឹងជួយ ដោះគេឱ្យរួច..." និក្ខមនំ ៣:៧,៨។

ព្រះទ្រង់បានត្រាស់បង្គាប់ទៅកាន់លោក ម៉ូសេថា:

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


14

(ព្រះគម្ពីរ និក្ខមនំ ៣:១០)

"ដូច្នេះ ចូរមកឥឡូវ អញនឹងចាត់ឯង ឱ្យទៅឯផារ៉ោន


15

ដើម្បីឱ្យឯងបាននាំរាស្ត្រអញ គឺជាពួកកូនចៅ អ៊ីស្រាអែលចេញពីស្រុក អេស៊ីព្ទមក" និក្ខមនំ ៣:១០។


16

អស់រយៈពេលសែសិបឆ្នាំហើយ តាំងពី លោកម៉ូសេបានចេញពីស្រុកអេស៊ីព្ទមក។ សែសិបឆ្នាំតាំងពីគាត់ បាននិយាយភាសា អេស៊ីព្ទ! ជាការពិតណាស់ នៅក្នុងកំឡុងពេលទាំងអស់នោះ គាត់បានថែរក្សាចៀម នៅខាងក្រោយទីរហោស្ថានយ៉ាងឯកោ។

ការទុកចិត្តខ្លួនឯង ដោយរីករាយក្នុង ឋានៈជាព្រះអង្គម្ចាស់ក្មេងមួយអង្គ នៅក្នុងព្រះរាជវាំងនៃប្រទេសអេស៊ីព្ទនោះ បាន កន្លងផុតទៅហើយ។ ព្រះគម្ពីរនិយាយថា


17

(ព្រះគម្ពីរ កិច្ចការ ៧:២២)

"លោកបានរៀនសូត្រគ្រប់អស់ ទាំងចំណេះវិជ្ជានៃសាសន៍អេស៊ីព្ទ ហើយក៏មានពាក្យសំដីនិងការធ្វើយ៉ាងចំណាន" កិច្ចការ ៧:២២


18

ប៉ុន្តែនៅឯទីវាលរហោស្ថាន លោក ម៉ូសេ បានរៀនលើសពីការបន្ទាបខ្លួនទៅ ទៀត។ ដោយការថែរក្សា សត្វចៀម និងការ បានរៀនអំពីការអត់ធ្មត់ និងការបន្ទាបខ្លួន។ ឥឡូវនេះទ្រង់ជ្រាបថា លោកម៉ូសេ ល្មមអាចរំដោះអ៊ីស្រាអែល ហើយអនុវត្តការថែរក្សាជាឪពុកដល់រាស្ត្រ របស់ព្រះអង្គបានហើយ។

ម៉ូសេដ៏សុភាពរាបសារ បានស្តាប់ការ ណែនាំរបស់ព្រះ ហើយបានទទួលនូវអ្វីដែលព្រះបានត្រាស់បង្គាប់ ទោះបីនៅពេលនោះ គាត់បានគិតថា គាត់មិន អាចធ្វើបានក៏ដោយ។


19

ដើម្បីជួយដល់ម៉ូសេឱ្យសម្រេចបេសកកម្មដ៏ធំនេះ ព្រះបានប្រាប់ដល់អ៊ើរ៉ុន ដែលជាបងប្រុសរបស់ម៉ូសេ ដែលជាទាសករនៅស្រុកអេស៊ីព្ទ ឱ្យចេញទៅជួប នឹងម៉ូសេ។

អ៊ើរ៉ុនមិនមែនគ្រាន់តែឱ្យម៉ូសេ ប្រើ ប្រាស់ការឧបត្ថម្ភខាងសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែព្រះបានចាត់តាំងឱ្យអ៊ើរ៉ុនធ្វើជាអ្នកនាំពាក្យរបស់ម៉ូសេថែមទៀត ព្រោះថា ម៉ូសេមិនបានប្រើប្រាសភាសា អេស៊ីព្ទជាច្រើន ឆ្នាំកន្លងមកហើយ។

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


20

បងប្អូនទាំងពីរនាក់បានចូលទៅក្នុងព្រះ រាជវាំងរបស់ស្ដេចផារ៉ោន ដោយប្រកាស ថាជាអ្នកនាំពាក្យ ដែលត្រូវបានបញ្ជូនមក ដោយព្រះជាម្ចាស់។ ពួកគេបាននិយាយ ដោយនូវព្រះនាមរបស់ទ្រង់ ហើយបាន ប្រាប់អំពីអំណាចដ៏អស្ចារ្យរបស់ទ្រង់។ ស្ដេចអំនួតដ៏ក្រអឺតក្រទម អាចជ្រាបពី ស្ថានភាពដ៏ចម្លែករបស់អ្នកទាំងពីរបានយ៉ាង ច្បាស់ដោយសារតែក្រសែព្រះនេត្រមួយខ្វាប់ របស់ទ្រង់ប៉ុណ្ណោះ។

នៅចំពោះព្រះភ័ក្ត្ររបស់ស្ដេច បងប្អូន ពីរនាក់បានឈរនៅទីនោះ ម្នាក់គឺជាអ្នក គង្វាលចៀមពីស្រុកម៉ាឌាន នៅតែកាន់ដំ បងឃ្វាលចៀមរបស់គាត់ ម្នាក់ទៀតគឺជា ទាសករជនជាតិហេព្រើរនៅក្នុងស្រុកអេស៊ីព្ទ។

គេទាំងពីរនាក់ កំពុងបានប្រកាសអំពី អំណាចដ៏ឧត្ដមរបស់ព្រះ ដែលពួកគេបាន បំរើ។

នៅពេលដែលអ៊ើរ៉ុនប្រកាសថា គេបាន មកជាមួយនឹងដំណឹងពីព្រះអម្ចាស់ សូមឱ្យ ផារ៉ោនអនុញ្ញាតឱ្យរាស្ដ្ររបស់ទ្រង់ចេញទៅ ស្ដេចផារ៉ោនបានខាកស្ដោះក្នុងការខ្ពើមរអើម:


21

(ព្រះគម្ពីរ និក្ខមនំ ៥:២) "តើព្រះ យេហូវ៉ាជាអ្នកណា ដែលអញត្រូវស្ដាប់តាម ទ្រង់ និងឱ្យសាសន៍អ៊ីស្រាអែលចេញទៅ នោះ?


22

អញមិនស្គាល់ព្រះយេហូវ៉ាទេ ហើយ ក៏មិនព្រមឱ្យសាសន៍អ៊ីស្រាអែលចេញទៅ ឡើយ" និក្ខមនំ ៥:២

ជាមួយនឹងទាសកររាប់ពាន់នាក់ ដែល អាចប្រើប្រាសបានតាមចិត្ត ស្ដេចផារ៉ោន ពិតជាមិនមានបំណង ចង់ឱ្យបាត់បង់អ្នក ធ្វើការដោយមិនបាច់បង់ថ្លៃទាំងនោះឡើយ។ សំណូមពររបស់អ៊ើរ៉ុនបានទាញឱ្យមានប្រត្តិ កម្មយ៉ាងតឹងរឹងមួយ។ ស្ដេចបានបង្កើនការ ងារបន្ថែមទៀតដល់ពួកអ៊ីស្រាអែល។


23

ប៉ុន្ដែរំពេចនោះព្រះបានធ្វើឱ្យស្ដេច ផារ៉ោន ដ៏ក្រអឺតក្រទម ជ្រាបថា តើព្រះ អម្ចាស់ជានរណា និងអំពីអំណាចដ៏អស្ចារ្យ របស់ព្រះអង្គ។ ម៉ូសេនិងអ៊ើរ៉ុន បានប្រកាស ឱ្យស្ដេចផារ៉ោនជ្រាបថា ព្រះនឹងបញ្ជូន សេចក្ដីវេទនាមួយហើយមួយ ទៀតមកលើ ជនជាតិអេស៊ីព្ទ រហូតដល់ រាស្ដ្ររបស់ទ្រង់ បានត្រូវរួចចាកផុតពីការកៀបសង្កត់។

បន្ទាប់មកព្រះរាជសាររបស់ព្រះចំពោះ ស្ដេចផារ៉ោនគឺ:


24

(ព្រះគម្ពីរ និក្ខមនំ ៧:១៧) "...ស្ដេច នឹងដឹងថា អញជាព្រះយេហូវ៉ា ដោយសារ ការនេះ..." និក្ខមនំ ៧:១៧

# ២៣.ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ




25

វាមិនយូរប៉ុន្មានទេ មុននឹងសេចក្ដី វេទនាទាំងនោះចាប់ផ្ដើមធ្លាក់មក។ ការវេទនាដប់ក៏កើតឡើងយ៉ាងពិតប្រាកដ!
មុនពេលដែលសេចក្ដីវេទនានីមួយៗធ្លាក់មក ម៉ូសេនិងអ៊ើរ៉ុនបានទូលផារ៉ោនជាមុន អំពីការជំនុំជំរះដែល នឹងមកដល់ ដោយ សង្ឃឹមថា ទ្រង់នឹងដោះលែងកូនចៅ អ៊ីស្រាអែល ដើម្បីជួយសង្គ្រោះព្រះអង្គ ផ្ទាល់ និងប្រជារាស្ត្ររបស់ទ្រង់ ពីគ្រោះ មហន្តរាយ។
ប៉ុន្តែស្ដេចផារ៉ោនបានខំព្យាយាមធ្វើនូវ សកម្មភាពដូចពេលមុនៗដដែល។
ហើយយោងទៅតាមសេចក្ដីសន្យារបស់ ព្រះ វិបត្តិភ័យប្លែកៗបានធ្លាក់មកលើពួក អេស៊ីព្ទ។



26

(វីដេអូ ៩វិនាទី) ជាដំបូងទន្លេនីល ដែល ពួកអេស៊ីព្ទបានថ្វាយបង្គំ ទុកជាព្រះ របស់ពួកគេនោះ បានត្រឡប់ទៅជាឈាម នៅពេលដែលអ៊ើរ៉ុនបានវាយទឹកដោយដំបង។
ត្រីទាំងឡាយបានស្លាប់ ហើយទឹកទាំងអស់នៅក្នុងប្រទេសអេស៊ីព្ទបានក្លាយទៅជាឈាមអស់រយៈពេលប្រាំពីរថ្ងៃ។ ប៉ុន្តែស្ដេចផារ៉ោននៅតែបដិសេធមិនព្រមអនុញ្ញាតឱ្យរាស្ត្ររបស់ព្រះចេញទៅដដែល!



27

បន្ទាប់មក ការវេទនាដោយកង្កែបបាន លុកលុយពាសពេញដី។ កង្កែបរាប់លាន ក្បាលនៅក្នុងអាហារ នៅលើគ្រែ
គ្រប់ទីកន្លែងទាំងអស់! ស្ដេចដ៏ចចេសមានះ នៅតែបដិសេធ-មិនព្រមឱ្យពួកអ៊ីស្រាអែលចេញទៅដដែល។


28

ការវេទនាអំពីចៃបានមកជាបន្ទាប់ទៅ ទៀត។ ប៉ុន្តែអ្នកដឹកនាំដ៏ច្រឡោងខាមនេះនៅតែមិនព្រមអនុញ្ញាត ឱ្យប្រជារាស្ត្រ ចេញទៅទៀត។
សូមកត់សំគាល់ថា ការវេទនាបីដំបូង បានធ្លាក់មកលើទាំងពួកហេព្រើរ និង អេស៊ីព្ទ ទោះជាយ៉ាងនេះក៏ដោយ ការ វេទនាប្រាំពីរក្រោយទៀតបានធ្លាក់មកលើតែ ពួកអេស៊ីព្ទប៉ុណ្ណោះ។


29

(ព្រះគម្ពីរ និក្ខនំ ៨:២២-២៣)
"តែនៅថ្ងៃនោះអញនឹងញែកស្រុក កូសែនដែលរាស្ត្រអញនៅ មិនឱ្យមានរុយ ឡើយ


30

ដើម្បីឱ្យឯងដឹងថា អញជាព្រះយេហូវ៉ា ដ៏នៅកណ្ដាលផែនដីនេះ

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


31

អញនឹងផ្ដាច់រាស្ត្រអញ និងរាស្ត្រឯងឱ្យ ដាច់ចេញពីគ្នា ឯទីសំគាល់នេះនឹងកើត ឡើងនៅថ្ងៃស្អែក” និក្ខមនំ ៨:២២_២៣


32

បន្ទាប់មកទៀតការវេទនាអំពីរុយ ដែល បានធ្លាក់មកពាសពេញដំណាក់របស់ស្តេច ផារ៉ោន។


33

បន្ទាប់ពីរុយមក ការរាលដាលដ៏ធំមួយ បានបោសសំអាតពាសពេញទាំងផែនដី ដោយបំផ្លាញសត្វទាំងអស់ដែលនៅឯទីវាល។

ពេលនេះស្តេចផារ៉ោនបានងឿងឆ្ងល់ យ៉ាងខ្លាំង។ តើសត្វរបស់ពួកហេព្រើរត្រូវ បានបំផ្លាញដែរឬទេ? ឬមួយក៏ពួកវាត្រូវបាន ថែរក្សាដូចដែលម៉ូសេបានទស្សនទាយមែន?


34

(ព្រះគម្ពីរ និក្ខមនំ ៩:៧)

“ផារ៉ោនទ្រង់ចាត់គេទៅស៊ើបមើល ក៏ ឃើញថា គ្មានសត្វណាមួយ ក្នុងហ្វូងសត្វ របស់សាសន៍អ៊ីស្រាអែលដែលបានស្លាប់
សោះ...


35

ប៉ុន្តែផារ៉ោនមានព្រះទ័យរឹងចចេសមិន ព្រមបើកឱ្យបណ្ដាជនទៅទេ” និក្ខមនំ ៧:៩។


36

ការវេទនាទីប្រាំមួយបាននាំមកនូវ បូស នៅក្នុងចំណោមមនុស្សនិងសត្វទាំងអស់ ប៉ុន្តែស្តេចដ៏ចចេសរឹងរូស អង្គនេះនៅតែ មិនព្រមដោះលែងកូនចៅអ៊ីស្រាអែលទៀត!


37

បទទំនាយបន្ទាប់មកទៀតដែលបាន ប្រាប់ គឺការវេទនាដោយព្រិល។

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ





38

(វីដេអូ ៨វិនាទី)ទោះជាយ៉ាងនេះក៏ដោយ ព្រះទ្រង់បានសន្យាថា អស់អ្នកដែល ការពារខ្លួនគេ និងសត្វពាហណៈរបស់គេ នឹងមិនស្លាប់ឡើយ។

ដំណឹងនេះបានប្រកាសយ៉ាងលឿនទូទៅ ទាំងផែនដី ហើយពួកអេស៊ីព្ទជាច្រើនបាន ថែរក្សាហ្វូងសត្វរបស់ពួកគេ។

ព្រិលក៏បានធ្លាក់មក លាយឡំនឹងរន្ទះ និងខ្សែផ្លេកបន្ទោរ ហើយអ្នកណាដែលមិន បានរៀបចំខ្លួននោះ បានត្រូវស្លាប់ទាំងអស់!



39

(វីដេអូ ១៨វិនាទី) ពួកអេស៊ីព្ទបានឃើញ យ៉ាងច្បាស់ថា ផែនដីបាននៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់ព្រះ ដែលមានព្រះ ជន្មរស់ ហើយសុវត្ថិភាពរបស់គេមានតែ មួយគត់ គឺការស្តាប់បង្គាប់ដល់ទ្រង់។

នៅក្នុងរយៈពេលបន្តិចនោះ ស្តេច ផារ៉ោន ពិតជាបានប្រើគំនិតលេងសើច ដោយធ្វើជាស្តាប់បង្គាប់ព្រះ និងអនុញ្ញាត ឱ្យប្រជារាស្ត្រចេញទៅ ប៉ុន្តែនៅពេលដែល ការវេទនាបានស្រាកទៅ បំណងព្រះ ហឫទ័យនៃ ការស្តាប់បង្គាប់ព្រះរបស់ទ្រង់ ក៏រលាយបាត់ទៅដែរ។



40

(វីដេអូ ១៩វិនាទី) ម៉ូសេបានព្រមានដល់ ស្តេចផារ៉ោនថា ប្រសិនបើទ្រង់នៅតែ បដិសេធ និងមិនព្រមឱ្យកូនចៅ អ៊ីស្រាអែល ចេញទៅទេ ទុក្ខទោស បន្ទាប់មកទៀត ដែលនឹងកើតឡើងនោះគឺ ហ្វូងកណ្តូប។

ដោយការភ័យខ្លាចចំពោះការវេទនាធំៗ ដែលនឹងកើតមានឡើងទៀតនោះ ពួកនាហ្មឺន របស់ស្តេចផារ៉ោន បាន អង្វរករស្តេចសូម ឱ្យទ្រង់យល់ព្រម អនុញ្ញាតឱ្យពួកទាសករចេញទៅ ប៉ុន្តែ ស្តេចនៅតែបដិសេធដដែល។ ហើយ កណ្តូបក៏បានមក ដូចដែលបានទស្សន៍ទាយ មកមែន។


41

បន្ទាប់មកភាពងងឹតបីថ្ងៃយ៉ាងខ្លាំងបាន ធ្លាក់មកដល់ ប៉ុន្តែស្តេចដ៏ប្រឆាំងអង្គនេះ នៅតែបន្តការរឹងរូសជាមួយនឹងព្រះនៃស្ថាន សួគ៌ដដែល។


42

ម៉ូសេបានថ្លែងថា ការវេទនាមួយទៀត នឹងត្រូវធ្លាក់មកលើពួកអេស៊ីព្ទ-ជាការ វេទនាចុងក្រោយ ហើយដែលជាការវេទនា ធ្ងន់ជាងលើកមុនៗទាំងអស់។

ទេវតានៃការបំផ្លាញនឹងហោះពាសពេញ ដីនៅវេលាពាក់កណ្តាលអាធ្រាត្រ ហើយ នឹងសម្លាប់កូនច្បងទាំងអស់ នៅក្នុងប្រ ទេសអេស៊ីព្ទ-ទាំងកូនមនុស្ស និងកូនសត្វ។

# ២៣_ការរំលងផុតពីសេចក្ដីវេទនាដ៏ធំ



43

(វីដេអូ ១៥វិនាទី) ម្តងនេះទៀតពួក ហេព្រើរត្រូវបានរួចផុត។ ប៉ុន្តែនៅពេល នេះ ការដែលគ្រាន់តែជាជនជាតិហេព្រើរ ដែលរស់នៅស្រុកកូសែននោះ មិនទាន់គ្រប់ គ្រាន់ ដើម្បីឱ្យបានរួចផុតពីការវេទនាចុង ក្រោយបង្អស់នេះទេ។

ដើម្បីនឹងចៀសវាងការកាត់ទោសឱ្យ ស្លាប់នោះ គ្រួសារនីមួយៗត្រូវបានបង្គាប់ឱ្យ សម្លាប់កូនចៀមមួយ ហើយលាបឈាមវា ខ្លះនៅនឹងក្របទ្វារផ្ទះរបស់ពួកគេ ដែលជា សញ្ញានៃសេចក្តីជំនឿ និងការស្រឡាញ់ របស់គេ ចំពោះព្រះ។

ហើយព្រះបានសន្យាថា:

---


44

(ព្រះគម្ពីរ និក្ខមនំ ១២:១៣)

"...កាលណាអញឃើញឈាម នោះអញ នឹងរំលងផុតពីឯងរាល់គ្នាទៅ

---


45

ហើយនឹងគ្មានសេចក្តីវេទនាណាបំផ្លាញឯង រាល់គ្នា ក្នុងវេលាដែលអញវាយស្រុក អេស៊ីព្ទនោះឡើយ"

និក្ខមនំ ១២:១៣។

---


46

គឺទស្សនីយភាពដែលគួរឱ្យចាប់ អារម្មណ៍បំផុត ដែលបានពណ៌នានៅយប់ នោះ!

គ្រួសារហេព្រើររាប់ពាន់នាក់ និងពួក អេស៊ីព្ទជាច្រើន បានឈរមើលនៅមាត់ទ្វារ នៅពេលដែលឪពុកគេ កំពុងកាន់ចាន ឈាមនៅដៃម្ខាង ហើយដៃម្ខាងទៀត វលាស់ឈាមទៅលើក្របទ្វារ។

ហើយនៅពេលនោះ អ្នកឈរមើល ដែលចាប់អារម្មណ៍ជាទីបំផុតនោះ គឺពួក កូនច្បង។

---


47

(ព្រះគម្ពីរ និក្ខមនំ ១២:២៩)

"រីឯនៅកណ្តាលអធ្រាត្រក្នុងយប់នោះ ព្រះយេហូវ៉ា ទ្រង់ក៏វាយអស់ទាំងកូនច្បង នៅស្រុកអេស៊ីព្ទ

---


48

ចាប់តាំងពីបុត្រច្បងរបស់ផារ៉ោន... រហូត ដល់កូនច្បងរបស់អ្នកទោសនៅក្នុងគុក

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


49

ព្រមទាំងកូនច្បងនៃអស់ទាំងសត្វផង" និក្ខមនំ ១២:១៩។


50

ទោះជាយ៉ាងនេះក៏ដោយ ក៏គ្មានផ្ទះមួយ ណាដែលមានលាបឈាមនៅលើក្របទ្វារនោះ ត្រូវបានប៉ះពាល់ដោយការវេទនានោះឡើយ។


51

ទូទាំងព្រះរាជាណាចក្រអេស៊ីព្ទ វិបត្តិនៃ ការកាន់ទុក្ខមានការធ្ងន់ធ្ងរជាខ្លាំង។
ហើយដោយការញ័រជើង និងភ័យផង ខ្លាចផង ដែលមិនធ្លាប់មាន ស្តេចផារ៉ោន បាននឹកចាំនូវការដែលទ្រង់ បានធ្វើទុក្ខព្រះ របស់ពួកហេព្រើរ ដោយមានបន្ទូលបញ្ចើចបញ្ចើចំអកឱ្យថា


52

(ព្រះគម្ពីរ និក្ខមនំ ៥:២)
"...តើព្រះយេហូវ៉ាជាអ្នកណា ដែល អញត្រូវស្តាប់តាមទ្រង់ និងឱ្យសាសន៍អ៊ីស្រាអែលចេញទៅនោះ?
និក្ខមនំ ៥:២
ឥឡូវនេះទ្រង់បានជ្រាប ហើយដោយ ការបន្ទាបព្រះកាយ ទ្រង់និងពួកនាហ្មឺន របស់ទ្រង់ បានបញ្ជូនគេឱ្យទៅហៅ បងប្អូនហេព្រើរ ទាំងពីរនាក់នោះមក ហើយទទូចឱ្យពួកគេ នាំពួកកូនចៅអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ យ៉ាងរហ័ស ព្រោះថាបើមិនបានធ្វើ ដូច្នេះទេ នោះពួកគេនឹងត្រូវស្លាប់ទាំងអស់!



53

(វីដេអូ ១១វិនាទី) នាវេលាពាក់កណ្តាល អធ្រាត្រ រាស្ត្ររបស់ព្រះទាំងឡាយណា ដែលជ្រើសរើស យកទ្រង់ជាអ្នករំដោះពួក គេ ត្រូវបានដោះលែង។
ហើយដូចដែលព្រះបានបញ្ជាមកមែន ពួកគេបានរៀបចំសម្រាប់ពេលវេលានោះ។ ដោយមានស្បែកជើងជាប់នៅនឹងជើងរបស់ គេ អាវធំជាប់នៅលើខ្នងរបស់គេ ពួកគេ បានរៀបចំខ្លួនរួចជាស្រេច ដើម្បីការ ជន្លៀសខ្លួនដ៏ធំមួយ។ ពួកគេកំពុងនៅតាម ផ្លូវរបស់គេ ទៅដែនដីដែលបានសន្យា!

២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


54

"មែនហើយ" លោកអ្នកនិយាយថា "នោះគឺ ជារឿងដែលអស្ចារ្យមែន ប៉ុន្តែ តើវាសំខាន់សម្រាប់យើងដែលកំពុងរស់នៅក្នុង សតវត្សរ៍ទី២១នេះយ៉ាងណាទៅ? វាអាចលេចចេញជាការមិនសំខាន់ទេ ប៉ុន្តែ តើ មិនដូច្នេះទេឬអី ជាការពិត វាសំខាន់បំផុតលើសពីអ្វីៗទាំងអស់!។


55

លោកអ្នកឃើញទេ នៅក្នុងព្រះគម្ពីរ សញ្ញាថ្មី យើងរកឃើញបទទំនាយយ៉ាងគួរ ឱ្យកត់សំគាល់ដែលបានផ្ដល់ការលំអិតអំពី ព្រឹត្តិការណ៍ចុងក្រោយ ដែលនឹងកើតមាន ឡើងនៅលើផែនដីនេះ។

បទទំនាយនេះបង្ហាញឱ្យឃើញច្បាស់ ថែសម្ដងទៀត នូវការវេទនាទាំងឡាយ ដែលនឹងធ្លាក់មក ប៉ុន្តែការធ្វើនាលើកនេះ មានភាពធ្ងន់ធ្ងរជាងសម័យពួកអេស៊ីព្ទទៅ
ទៀត


56

មែនហើយ យោងទៅតាមបទទំនាយនៅក្នុង ព្រះគម្ពីរ រឿងរ៉ាវនេះនឹងត្រូវកើតឡើងម្ដង ទៀត។

មិនមែនការវេទនាដប់ទេ ប៉ុន្តែប្រាំពីរ នឹងកើតឡើងដល់កម្រិតខ្ពស់បំផុត នៅក្នុងការរំដោះរាស្ត្ររបស់ព្រះ។

មិនមែនពីប្រទេសអេស៊ីព្ទទេ ប៉ុន្តែ ចេញពីភពដែលពោរពេញទៅដោយការបះ បោរមួយ។


57

ប៉ុន្តែដូចគ្នានឹងពួកអ៊ីស្រាអែល បាន ទ្រាំទ្រនឹងពេលវេលានៃការឈឺចាប់ រងទុក្ខ វេទនាមុននឹងការរំដោះ ដ៏មានសិរីល្អ របស់ពួកគេពីស្រុកអេស៊ីព្ទ ហើយនិងបានឃើញការវេទនាធ្លាក់មកលើជនជាតិអេស៊ីព្ទ នោះ


58

រាស្ត្ររបស់ព្រះ ក៏ដូច្នេះដែរ គេនឹងបាន ឃើញការចាក់នូវសេចក្ដីវេទនាទាំងប្រាំពីរចុងក្រោយនេះមកលើមនុស្សទុច្ចរិត មុន ពេលព្រះគ្រីស្ទយាងមកវិញ។

ហោរាដានីយ៉ែលបានពិពណ៌នាអំពី ពេលវេលាដ៏លំបាកនេះ:



59

(ព្រះគម្ពីរ ដានីយ៉ែល ១២:១)

"នៅគ្រានោះ មីកែលជាមហាទេវតា
ដែលតំណាងពួកកូនចៅរបស់សាសន៍អ្នក លោកនឹងឈរឡើង



60

ក៏នឹងមានគ្រាវេទនាជាខ្លាំង ដល់ម្ល៉េះ បានជា ចាប់តាំងពីមាននគរដរាបដល់ វេលានោះឯង

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


61

នោះមិនដែលកើតមានយ៉ាងដូច្នេះឡើយហើយនៅគ្រានោះ សាសន៍អ្នកនឹងបានប្រោស
ឱ្យរួចគឺអស់អ្នកណាដែលមានកត់ទុក
ក្នុងបញ្ជី"
ដានីយ៉ែល ១២:១។


62

"ដំណឹងដ៏នៅអស់កល្ប" នឹងត្រូវបាន ប្រកាសពាសពេញពិភពលោក។
ការត្រាស់ហៅរបស់ទេវតាទី២ ឱ្យ "ចេញពីបាប៊ីឡូន" ឬក៏ប្រព័ន្ធខុសឆ្គងនៃ ការថ្វាយបង្គំ
នឹងត្រូវបានផ្តល់ឱ្យ:


63

(ព្រះគម្ពីរ វិវរណៈ ១៤:៩,១០)
"បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វានៅលើ ថ្ងាស ឬនៅដៃ


64

អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅ របស់ព្រះ..." វិវរណៈ ១៤:៩,១០។


65

នេះគឺជាការប្រកាសដ៏ធំសំបើមអស្ចារ្យ នៅក្នុងព្រះគម្ពីរ ដែលមិនធ្លាប់បានប្រកាស
ដល់មនុស្សលោកនេះសោះឡើយ។
គ្មានអ្នកណាម្នាក់បានទទួលសញ្ញារបស់ សត្វនោះ ឬ "ផឹកស្រានៃសេចក្តីឃោរឃៅ របស់ព្រះទេ
រហូតដល់បញ្ហានៃការថ្វាយ បង្គំ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅចំពោះ មនុស្សនៅលើផែនដីនេះ
និងត្រូវបានគេ ជម្រុញឱ្យជ្រើសរើស ដើម្បីទទួលបញ្ញត្តិ របស់ព្រះ ឬច្បាប់របស់មនុស្សនោះ។


66

ប៉ុន្តែ តើពេលណាទៅទើប ការនេះនឹង ត្រូវបានសម្រេច ទ្វារនៃការសាកល្បងនឹង ត្រូវបិទ
សម្រាប់មនុស្សទាំងអស់។


67

ហើយសេចក្តីប្រកាសដ៏ម៉ឹងម៉ាត់ត្រូវបាន ប្រកាសឡើង "អ្នកណាដែលអយុត្តិធម៏
ឱ្យគេនៅតែអយុត្តិធម៏ចុះ ហើយអ្នកណា ដែលស្មោកគ្រោក ឱ្យគេនៅតែស្មោក គ្រោកចុះ:

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


68

ហើយអ្នកដែលសុចរិត ឱ្យគេនៅតែសុចរិត ចុះ  ហើយអ្នកណាដែលបរិសុទ្ធ ឱ្យគេ នៅតែបរិសុទ្ធចុះ” វិវរណៈ ២២:១១។


69

ការងាររបស់ព្រះគ្រីស្ទនៅស្ថានសួគ៌ត្រូវ បានបញ្ចប់។ គ្រប់ទាំងករណីទាំងអស់ត្រូវបានធ្វើសេចក្ដីសម្រេចហើយ សម្រាប់ជីវិត អស់កល្ប ឬសេចក្ដីស្លាប់អស់កល្ប។

ទ្វារនៃសេចក្ដីមេត្តាករុណារបស់ព្រះត្រូវ បានបិទ!

ឥឡូវនេះគឺការពិសោធន៍របស់អ្នកដែល រស់នៅលើផែនដី “ពេលវេលានៃការ ពិបាក” ដែលហោរាដានីយ៉ែលបាននិយាយ។


70

ហើយមិត្តអើយសូមស្ដាប់ចុះ ព្រះមិន បានកញ្ឆក់រាស្ត្ររបស់ទ្រង់យកចេញទៅទេ រហូតទាល់តែការវេទនាត្រូវបានចប់។

ពួកគេនឹងនៅលើផែនដីនេះរហូតដល់ ទីបំផុត!

ពួកគេនឹងត្រូវបានការពារ នៅពេល ដែលមានសេចក្ដីវេទនា ដូចដែលពួកកូនចៅអ៊ីស្រាអែលដូច្នោះដែរ

ប៉ុន្តែពួកគេមិនមែនរួចខ្លួនចេញពីការ ពិបាក និងទុក្ខវេទនានោះទេ។

វាគឺជាពេលនៃការពិបាកសម្រាប់មនុស្ស គ្រប់ៗគ្នា។


71

មិត្តអើយ ហើយការពិពណ៌នាដ៏រស់ រវើកអំពីពេលវេលា នៃប្រវត្តិសាស្ត្រនៃផែន ដីនេះមិនអាចរៀបរាប់ ឱ្យដល់ទំហំនៃ សេចក្ដីពិតរបស់វាបានឡើយ នៅពេល ដែលមនុស្សអាក្រក់ផឹកពីពែងនៃសេចក្ដី ឃោរឃៅរបស់ព្រះ ជាស្រាឥតលាយជា មួយនឹងសេចក្ដីមេត្តាករុណា។

លោកយ៉ូហានបានផ្ដល់នូវការបញ្ចាំងឱ្យ មើលឃើញជាមុន អំពីពេលវេលាដ៏ពិបាក នេះដែលនឹងកើតមានឡើង នៅមុនការ យាងមកវិញរបស់ព្រះយេស៊ូវ ហើយនិងការរំដោះរាស្ត្ររបស់ទ្រង់។


72

(ព្រះគម្ពីរ វិវរណៈ: ១៥:១)

“ខ្ញុំក៏ឃើញទីសំគាល់១ទៀតដែលធំ ហើយអស្ចារ្យនៅលើមេឃ


73

គឺមានទេវតា៧ ដែលកាន់សេចក្ដីវេទនា ទាំង៧ក្រោយបង្អស់ ដ្បិតសេចក្ដីឃោរឃៅរបស់ព្រះបានសំរេច ដោយសេចក្ដីវេទនា ទាំងនោះ” វិវរណៈ: ១៥:១។ ហើយម្ដងទៀតលោកយ៉ូហានបានសរសេរថា:

# ២៣.ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


74

(ព្រះគម្ពីរ វិវរណៈ ១៦:១)
"ខ្ញុំបានឮសំឡេង១យ៉ាងខ្លាំង ចេញពី ព្រះវិហារ បន្ទីទៅកាន់ទេវទូតទាំង៧ថា


75

ចូរនាំគ្នាទៅ ហើយយកពែងទាំងប្រាំពីរ នៃព្រះពិរោធរបស់ព្រះជាម្ចាស់ចាក់ លើផែនដីទៅ"
(ព្រះគម្ពីរភាសារខ្មែរ សម្រាយ)
វិវរណៈ ១៦:១។


76

លោកអ្នកសួរថា "ប៉ុន្តែ តើអ្វីទៅដែល
ជាការវេទនាដែលនឹងត្រូវចាក់មកដោយទេវតាទាំងប្រាំពីរមកលើមនុស្សអាក្រក់នោះ?"
នោះគឺជាសំនួរដ៏ល្អ។
នៅពេលដែលយើងអានអំពីការវេទនា ទាំងនោះ លោកអ្នកនឹងកត់សំគាល់ឃើញ
អំពីការវេទនាស្រដៀងគ្នា ទៅនឹងការ វេទនា ដែលបានធ្លាក់មកលើពួកអេស៊ីព្ទ ដូច្នោះដែរ។
សូមយើងអាននូវការដែលលោក
យ៉ូហានបាននិយាយអំពីទេវតាទីមួយ


77

(ព្រះគម្ពីរ វិវរណៈ ១៦:២)
"ទេវតាទី១ ក៏ចេញទៅចាក់ពីចានខ្លួន ទៅលើផែនដី


78

នោះមនុស្សដែលមានទីសំគាល់របស់សត្វ


79

និងអស់ពួកអ្នកដែលក្រាបថ្វាយបង្គំដល់រូបវា
គេក៏កើតដំបៅកាចអាក្រក់ណាស់"
វិវរណៈ ១៦:២។


80

ប្រហែលជាការឈឺចាប់នេះ ប្រហាក់ ប្រហែលគ្នាទៅនឹងការឈឺចាប់ និងការរង ទុក្ខវេទនាទីប្រាំពីរ
របស់ជនជាតិអេស៊ីព្ទ ដោយបូស និងដំបៅដូចជាយ៉ូបបានទ្រាំទ្រ
ដូច្នោះដែរ។

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


81

តើលោកអ្នកអាចស្រមៃមើលបានទេ អំពីឥទ្ធិពលរបស់ការវេទនាទាំងនេះ ដែលនឹងអាចកើតឡើងនោះ?

សាលានឹងត្រូវបិទទ្វារ។


82

រោងចក្រទាំងឡាយត្រូវបានបិទទ្វារ។ ហាងទំនិញទាំងឡាយមិនអាចនឹងបើកទ្វារបានទេ។


83

មន្ទីរពេទ្យនានា នឹងពេញទៅដោយ មនុស្សម្នា ដែលកំពុងស្វែងរកការព្យាបាល ជាបន្ទាន់ ប៉ុន្តែវេជ្ជបណ្ឌិត និងគ្រូពេទ្យ ភាគច្រើនកំពុងរង គ្រោះ ដោយការឈឺ ចាប់ដូចគ្នាដែរ។

ហើយនៅពេលដែលមនុស្សកំពុងតែរង ទុក្ខទោស ដោយសារការឈឺចាប់របស់គេ វិបត្តិភ័យមួយទៀតក៏បានធ្លាក់មកដល់!


84

(ព្រះគម្ពីរ វិវរណៈ ១៦:៣)

"ទេវតាទី២ ក៏ចាក់ពីចានខ្លួន ទៅក្នុង សមុទ្រ រួចសមុទ្រត្រឡប់ទៅជាឈាម ដូច ជាឈាមខ្មោច ហើយគ្រប់ទាំងសត្វនៅក្នុង សមុទ្រក៏ស្លាប់អស់"

វិវរណៈ ១៦:៣)


85

ទិដ្ឋភាពដ៏អាក្រក់អស្ចារ្យ ក្លិនស្អុយដ៏ចំ ឡែក នៅពេលដែលសត្វសមុទ្រត្រូវបាន ឡើងគោកនោះ។

មនុស្សនឹងត្រូវបានជាន់គ្នាដោយសារការ ជន្លៀសខ្លួនចេញពីមាត់សមុទ្រដោយល្បឿន យ៉ាងលឿនរបស់ពួកគេ។

ប៉ុន្តែការវេទនាទីបីមានទំនាក់ទំនងយ៉ាង ជិតស្និទ្ធ ទៅនឹងការវេទនាទីពីរនេះដែរ។


86

(ព្រះគម្ពីរ វិវរណៈ:១៦:៤)

"ទេវតាទី៣ ក៏ចាក់ពីចានខ្លួនទៅក្នុងទន្លេ និងរន្ធទឹកទាំងប៉ុន្មាន នោះក៏ប្រែទៅជា ឈាមទាំងអស់ដែរ"

វិវរណៈ ១៦:៤។

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


87

សូមគិតមើល មនុស្សបែរទៅរកក្បាល ម៉ាស៊ីនទឹកដើម្បីផឹក ហើយឈាមក៏បាន ចេញមកជាជំនួសឱ្យទឹកវិញ!

នេះជាលទ្ធផលនៃការបំផ្លាញដ៏ធំធេង! តើមានអ្វីដែលអាក្រក់ជាងនេះទៅទៀតឬទេ?

ការវេទនាទាំងប្រាំពីរចុងក្រោយបង្អស់ គឺអាក្រក់ក្រៃលែង និងគួរឱ្យភ័យខ្លាចបំផុត ដែលត្រូវបានធ្វើឱ្យសុចរិត ដោយសារ សេចក្តីយុត្តិធម៌របស់ព្រះ ដូចទេវតាបាន ប្រកាសថា


88

(ព្រះគម្ពីរ វិវរណៈ ១៦:៥-៦)

"ឱព្រះដ៏គង់នៅ ហើយបានគង់នៅ តាំងតែពីដើមរៀងមកអើយ ដែលទ្រង់បាន ជំនុំជំរះកាត់ទោសដូច្នេះ នោះសុចរិតហើយ"


89

ដ្បិតគេបានកំចាយឈាមនៃពួកបរិសុទ្ធ និងពួកហោរា


90

ហើយទ្រង់បានប្រទានឈាមឱ្យគេផឹក"

វិវរណៈ ១៦:៥,៦។

នៅគ្រានោះ ពេលដែលអ្នកអាក្រក់ត្រូវ បានស្លាប់ដោយការស្រេក ហើយគ្មានអ្វី ដើម្បីផឹក គឺមានតែឈាមនោះ សេចក្តី សន្យាត្រូវបានធ្វើឡើងចំពោះអ្នកណាដែល ដើរដោយសេចក្តីសុចរិតៈ


91

(ព្រះគម្ពីរ អេសាយ ៣៣:១៦)

"...ឯអាហារនឹងបានប្រទានមកអ្នកនោះ ហើយទឹករបស់អ្នកនោះ នឹងចេះតែមាន នៅ" អេសាយ ៣៣:១៦។


92

(ព្រះគម្ពីរ វិវរណៈ១៦:៨-៩) ហើយបន្ទាប់ មកព្រះគម្ពីរនិយាយថា ទេវតាទីបួនបាន ចាក់ពីចានរបស់ទ្រង់" ទេវតាទី៤ ក៏ចាក់ ពីចានខ្លួនទៅលើព្រះអាទិត្យ រួចព្រះអាទិត្យ បានអំណាចនឹងធ្វើឱ្យមនុស្សត្រូវខ្លោចដោយសារភ្លើង"


93

មនុស្សលោកក៏ត្រូវខ្លោចទៅ ដោយ អំណាចក្តៅជាខ្លាំង តែគេមិនបានប្រែចិត្ត ដើម្បីនឹងលើកសរសើរដល់ សិរីល្អនៃព្រះទេ

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


94

គឺគេប្រមាថដល់ព្រះនាមព្រះ ដែលមាន អំណាចលើសេចក្តីវេទនាទាំងនោះវិញ” វិវរណៈ ១៦:៨_៩។

បន្ទាប់មក ទេវតាទីប្រាំបានចាក់ពីចាន របស់ទ្រង់ទៅលើទីចាត់ការរបស់សត្វនោះ:


95

(ព្រះគម្ពីរ វិវរណៈ ១៦:១០_១១) “ឯទេវតាទី៥ ក៏ចាក់ពីចានខ្លួន ទៅលើ បល្ល័ង្ករបស់សត្វនោះ រួចនគរវាត្រឡប់ទៅ ជាងងឹតសូន្យសុង


96

ហើយគេខាំអណ្តាតដោយមានសេចក្តីទុក្ខលំបាក


97

ក៏ប្រមាថដល់ព្រះនៃស្ថានសួគ៌ ដោយ ព្រោះទុក្ខលំបាក និងដំបៅរបស់គេ


98

តែមិនបានប្រែចិត្ត លះចោលពីការដែល គេប្រព្រឹត្តិឡើយ” វិវរណៈ ១៦:១០_១១។



99

ដោយសារខទាំងនេះ យើងបានឃើញ ថា ការវេទនាទាំងនេះ មិនមែនកើតមក គ្រប់ទីកន្លែងនៅលើពិភពលោកទាំងមូលទេ ឬក៏វាបណ្តាលឱ្យស្លាប់ភ្លាមៗនោះទេ ពី ព្រោះទីនេះ យើងរកឃើញថា អ្នកដែល ស្ថិតនៅក្រោមការវេទនាទីប្រាំនេះ នៅតែ ទទួលការរងទុក្ខទោសពីការឈឺចាប់ នៃការ វេទនាទីមួយដែរ។

តាមការប្រមើលមើលទៅ ការវេទនា ធ្លាក់មកជាបន្តបន្ទាប់មិនមែន ធ្លាក់មកក្នុង ពេលដំណាលគ្នានោះទេ ពីព្រោះឥទ្ធិពល របស់វាបានបន្តពីមួយទៅមួយ

សមរភូមិដ៏ធំចុងក្រោយ គឺ អើម៉ាគេដដូន នឹងកើតមានឡើងនៅគ្រា វេទនាទីប្រាំមួយនេះ:


100

(ព្រះគម្ពីរ វិវរណៈ ១៦:១២_១៤)

“ទេវតាទី៦ ក៏ចាក់ពីចានខ្លួនទៅលើ ទន្លេធំ គឺជាទន្លេអើប្រាត

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


101

រួចទឹកទន្លេនោះក៏រីងទៅ ដើម្បី ឲ្យបានរៀប ចំផ្លូវរបស់ ពួកស្តេចពីទិសខាងថ្ងៃរះ


102

រួចខ្ញុំឃើញវិញ្ញាណអសោចិ៍៣ ដូចជា កង្កែប ចេញពីមាត់នាគ


103

មាត់សត្វ និងពីមាត់ហោរាក្លែងក្លាយ


104

ដ្បិតវិញ្ញាណទាំងនោះជាវិញ្ញាណនៃពួក អារក្ស


105

ដែលចេញទៅអស់ទាំងស្តេច នៅផែនដី
ទាំងមូល ទាំងធ្វើទីសំគាល់


106

ដើម្បីនឹងប្រមូលស្តេចទាំងនោះមកក្នុងចំបាំង
នៅថ្ងៃដ៏ធំរបស់ព្រះដ៏មានព្រះចេស្តាបំផុត" វិវរណៈ ១៦:១២_១៤
ហើយគម្ពីរវិវរណៈ និយាយថា


107

(វិវរណៈ ១៦:១៦) "រួចវិញ្ញាណទាំង នោះក៏ប្រមូលគេទៅឯកន្លែង ដែលភាសា ហេព្រើរហៅថា អើម៉ាគេដូន" ពិភព លោកទាំងមូលត្រូវតែជាប់ទាក់ទងទៅនឹង ទំនាស់ចុងក្រោយនេះ។
លោកយ៉ូហានបានសរសេរថា:


108

(ព្រះគម្ពីរ វិវរណៈ ១៩:១១,១៤_១៥)
"ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះ ឃើញមានសេះស១

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


109

និងព្រះអង្គដែលគង់លើវា ទ្រង់មាន ព្រះនាមថា ស្មោះត្រង់ ហើយពិតប្រាកដ ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត...”


110

“អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ ទេសហើយស្អាតផង”


111

មានដាវយ៉ាងមុតចេញពីព្រះឱស្ឋទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍...


112

...ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំង បាយជូរជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត” វិវរណៈ ១៩:១១,១៤,១៥។


113

(ព្រះគម្ពីរ វិវរណៈ ១៦:១៧,១៨,២០_២១) “ទេវទូតទី៧យកពែងរបស់ខ្លួនចាក់ ទៅលើអាកាស ស្រាប់តែមានសំឡេងមួយ បន្លឺឡើងយ៉ាងខ្លាំងចេញពីបល្ល័ង្កក្នុងព្រះវិហារថា


114

រួចរាល់ស្រេចអស់ហើយ”


115

ពេលនោះមានផ្លេកបន្ទោរ មានឮ សំឡេង មានផ្គរលាន់និងមានរញ្ជួយផែន ដីយ៉ាងខ្លាំង...


116

កោះទាំងប៉ុន្មាននឹងរសាត់បាត់អស់ទៅ ហើយភ្នំទាំងឡាយក៏លែងមានទៀតដែរ

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


117

ពេលនោះមានព្រិលធ្លាក់មកយ៉ាង ខ្លាំង គ្រាប់ព្រិលនីមួយៗមានទំងន់ប្រ មាណ ជាងមួយចុងធ្លាក់ចុះពីលើមេឃមក លើ មនុស្សលោក


118

គេក៏នាំគ្នាជេរប្រមាថព្រះជាម្ចាស់ ព្រោះតែ គ្រោះកាចដែលកើតមានពីព្រិលនោះជាគ្រោះកាចដ៏ខ្លាំងបំផុត”

វិវរណៈ ១៦:១៧_១៨,២០_២១

(ព្រះគម្ពីរភាសាខ្មែរសម្រាយ)


119

អ្នកប្រាជ្ញនៅសម័យនោះ បានប្រើ ថាឡិន ជាខ្នាតរង្វាស់ទម្ងន់ ដែលមាន ទម្ងន់ប្រហែលជាមួយចុង ឬកន្លះហាប ស្មើនឹងសាមសិប គីឡូក្រាម គ្មានអ្នកណា ម្នាក់អាចស្រមៃអំពីការធ្វើឱ្យខ្ទេចខ្ទី ដោយសារព្យុះព្រិល ដែលនឹងកើតមាន ឡើងនោះបានឡើយ។


120

ប៉ុន្តែព្រះគម្ពីរនិយាយថា ព្រះអម្ចាស់ ផ្ទាល់ នឹងបកស្រាយទំនាស់នៅពេលដែល ទ្រង់គង់លើសេះយាងចេញទៅមុខជាមួយ នឹងកងទ័ពនៃស្ថានសួគ៌ ដើម្បីនឹងរំដោះរាស្ត្ររបស់ទ្រង់ចេញពីភពនៃការបះបោរនេះ


121

“ប៉ុន្តែ” លោកអ្នកសួរថា “តើឱ្យជឿ ជាក់លើការការពាររបស់ព្រះបានយ៉ាងណា នៅពេលដែលមានការ វេទនាទាំងនេះធ្លាក់ មកនោះ?” មានផ្លូវតែមួយគត់។


122

លោកអ្នកឃើញទេ មនុស្សដែលរំដោះ ពីការវេទនាចុងក្រោយនៅប្រទេសអេស៊ីព្ទ បានបង្ហាញសេចក្តីជំនឿ និងការស្មោះត្រង់ របស់គេចំពោះព្រះថា ជាអ្នករំដោះពួកគេ ដោយព្រោះឈាមរបស់កូនចៀមនៅលើក្របទ្វារផ្ទះរបស់ពួកគេ។

នៅពេលទេវតាដែលការបំផ្លាញបាន ហោះរំលងផ្ទះរបស់ពួកគេ នៅកណ្តាលការ វិនាសនោះ។ ពួកគេបានដើរតាមការណែនាំរបស់ព្រះ ហើយបានធ្វើការរៀបចំជាចាំបាច់។


123

ហើយម្តងទៀត រាស្ត្ររបស់ព្រះនឹងបាន រួចខ្លួន នៅពេលដែលការវេទនាបានធ្លាក់ មក ប្រសិនបើពួកគេបានទទួលឈាមរបស់ កូនចៀម នៃព្រះទុកជាយញ្ញបូជារបស់ពួក គេ ហើយអនុញ្ញាតឱ្យលោហិត របស់ទ្រង់ លាងសំអាតគេពីអំពើបាបចេញ។

# ២៣_ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


124

ដោយជីវិតរបស់យើង យើងកំពុងតែ ជ្រើសរើសនៅថ្ងៃនេះ ថាតើយើងនឹង នៅ ខាងណាមួយ-ខាងព្រះ ឬមួយក៏ខាង ទេវតាបះបោរ។

ហើយមិត្តអើយ នៅពេលដែលទេវតា បំផ្លាញចាប់ផ្ដើមធ្វើការរបស់ទ្រង់ វាយឺតពេលនឹងផ្លាស់ប្ដូរទីកន្លែងហើយ!

ទ្វារនៃការសាកល្បងនឹងត្រូវបិទជារៀង រហូតហើយ។

តើលោកអ្នកមិនដាក់ខ្លួនអ្នកនៅខាងព្រះ ក្រោមការការពាររបស់លោហិតព្រះយេស៊ូវ ឥឡូវនេះទេឬអី? ពាក្យពេចន៍ដ៏ក្រៀមក្រំ បំផុត ដែលមនុស្សនឹងបន្លឺ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរ យេរេមា ៨:២០:


125

(ព្រះគម្ពីរ យេរេមា ៨:២០)

"រដូវច្រូតកាត់បានកន្លងហើយ រដូវក្ដៅ ក៏ផុតទៅ តែយើងរាល់គ្នា មិនទាន់បានសង្គ្រោះនៅឡើយ!"


126

រឿងមួយត្រូវបានគេនិទានប្រាប់ អំពី អ្នកកាប់ឈើជាតិអូស្ត្រាលីម្នាក់ ដែលសង់ខ្ទមតូចមួយនៅក្បែរមាត់ព្រៃ។

វាមិនជាធំប៉ុន្មានទេ ប៉ុន្តែវាគឺជាផ្ទះ របស់គាត់។

ថ្ងៃមួយ នៅពេលដែលគាត់ត្រឡប់ពី ធ្វើការវិញ


127

គាត់បានស្រឡាំងកាំង និងធ្លាក់ថ្លើមក្ដុក ដោយឃើញកូនខ្ទមរបស់គាត់បានក្លាយទៅជាគំនរនៃកំទេចរងើកភ្លើង។

អ្វីដែលនៅសល់នោះគឺ កំទេចឈើ ដែលឆេះខ្មៅញ្ញង និងដែកគោលខ្លះដែលរោលខ្មៅដោយអណ្ដាតភ្លើងតែប៉ុណ្ណោះ។

គាត់បានដើរសំដៅទៅកាន់កន្លែងទ្រុង មាន់ចាស់របស់គាត់ ដែលកំពុងឈរជ្រងោនៅឡើយ។


128

អ្វីដែលគាត់បានរកឃើញនោះគឺមានតែ កំទេចផេះ និងខ្សែលួសខ្លះដែលរោលខ្មៅ អែតែប៉ុណ្ណោះ។

ទាល់គំនិត គាត់បានដើរអូសជើងកាត់ កំទេចកំទីនោះដោយអស់សង្ឃឹម។

បន្ទាប់មកទៀត គាត់បានចោលកន្ទុយ ភ្នែក ទៅកាន់បាទជើងរបស់គាត់ ភ្នែករបស់គាត់បានប្រទះឃើញនូវវត្ថុដ៏ គួរឱ្យឆ្ងល់មួយ-គឺគំនររងើកភ្លើងនៃស្លាប ជាច្រើន ដោយមិនដឹងធ្វើអ្វីគាត់បាន ទាត់គំនរនោះ។ តើលោកអ្នកគិតថា នឹងមានអ្វីកើតឡើង?

# ២៣.ការឆ្លងផុតពីសេចក្ដីវេទនាដ៏ធំ


129

កូនមាន់ដែលទើបនឹងដុះស្លាបបួន ដែលបានការពារដ៏អស្ចារ្យ ដោយស្លាបមេ ជាទីស្រឡាញ់របស់ពួកវា បានបែកខ្ញែក ឡើង។

នៅក្នុងពាក្យពេចន៍ដ៏ល្អ និងមានន័យ បំផុតរបស់បទព្រះគម្ពីរ ព្រះបានពណ៌នា ការដែលទ្រង់ចង់ធ្វើដើម្បី កូនរបស់ទ្រង់ គ្រប់ៗគ្នានៅលើផែនដីនេះ នៅពេលដែល ការវេទនាទាំងនោះធ្លាក់មកជាខ្លាំង:


130

(ព្រះគម្ពីរ ទំនុកដំកើង ៩១:១,៤)

"អ្នកណាដែលនៅជាប់ក្នុងទីកំបាំង នៃព្រះដ៏ខ្ពស់បំផុត


131

នោះនឹងបានជ្រកនៅក្រោមម្លប់នៃព្រះដ៏ មានគ្រប់ព្រះចេស្ដា...


132

ទ្រង់នឹងក្រុងឯងដោយស្លាបទ្រង់ ហើយឯងនឹងជ្រកនៅក្រោមចំអេងស្លាបរបស់ទ្រង់


133

សេចក្ដីពិតរបស់ទ្រង់ជាខែល ហើយជាអាវ ក្រោះ" ទំនុកដំកើង ៩១:១,៤។

មែនហើយ ព្រះបានប្រទានការធានារ៉ាប់រង យ៉ាងល្អប្រសើរ ដល់អ្នកណាដែលជ្រើស រើសដើរតាមទ្រង់:


134

(ព្រះគម្ពីរ ទំនុកដំកើង ៩១:៥-១១)

"ឯង នឹងមិនភ័យខ្លាចអ្វីឡើយ ទោះ ទាំងសេចក្ដីស្ញែងខ្លាចនៅពេលយប់ឬព្រួញ ដែលហើរនៅពេលថ្ងៃ


135

ឬសេចក្ដីវេទនាដែលតែងមាននៅក្នុង ទីងងឹត ឬសេចក្ដីហិនវិនាសដែលបំផ្លាញ នៅពេលថ្ងៃត្រង់ផង

# ២៣_ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


136

នឹងមានមនុស្ស១ពាន់នាក់ ដួលស្លាប់ នៅក្បែរឯង ហើយ១ម៉ឺននាក់នៅខាងដៃស្តាំ ឯងដែរ តែសេចក្តីនោះនឹងមិនមកជិតឯង ឡើយ


137

ឯងនឹងបានក្រឡេកឃើញការតបស្នង ដល់មនុស្សអាក្រក់ ដោយភ្នែកតែប៉ុណ្ណោះទេ


138

ពីព្រោះឯងបានថា ព្រះយេហូវ៉ាជាទី ពឹងជ្រកនៃឯង គឺបានយកព្រះដ៏ខ្ពស់បំផុត ជាទីលំនៅរបស់ឯង


139

យ៉ាងនោះនឹងគ្មានសេចក្តីអាក្រក់ណា កើតឡើងដល់ឯងឡើយ ក៏គ្មាន វេទនាណា មកជិតទីលំនៅរបស់ឯងដែរ


140

ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ ទ្រង់ពីដំណើរឯង...
ទំនុកដំកើង ៩១:៥_១១។



141

(វីដេអូ ១៥វិនាទី) តើមានអ្វីដែលអាចនឹង ធ្វើឱ្យមានការទុកចិត្តជាងនេះទៅទៀតដែរឬ ទេ? តើលោកអ្នកមិនចង់ជ្រកនៅក្រោម ស្លាបរបស់ព្រះដ៏សព្វចេស្តា នៅពេលដែល ការវេទនាចាប់ធ្លាក់មកទេឬអី? នៅពេល ដែលគ្មានទីកន្លែងនឹងលាក់ពួននោះ ព្រះ វរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ចង់ការពារអ្នក ហើយនឹងសង្គ្រោះអ្នកនៅក្នុង ម៉ោងនៃការពិបាកវេទនា និងហិនវិនាសនេះ។

# ២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ


142

នៅពេលដែលលោកអ្នកបង្វែរជីវិត លោកអ្នកទៅឯទ្រង់ នោះទ្រង់អាចនឹង ការពារលោកអ្នកបាន ដូចជាមេមាន់ ដែលបានប្រមូលកូនរបស់ខ្លួនឱ្យនៅក្រោម ស្លាបរបស់វាដូច្នោះដែរ។

ការសម្រេចចិត្តគឺជារបស់លោកអ្នក។ ខ្ញុំជឿជាក់ថា ព្រះចង់ធ្វើការសម្រេចចិត្ត ជូនលោកអ្នក ដើម្បីឱ្យលោក អ្នកអាចនៅ ជាមួយនឹងទ្រង់អស់កល្បរៀងរហូតទៅ ប៉ុន្តែទ្រង់មិនអាចធ្វើការនេះបានទេ។

មានតែលោកអ្នកប៉ុណ្ណោះ ដែលអាច ធ្វើការសម្រេចចិត្តនេះ។ សូមកុំរង់ចាំឡើយ។ សូមធ្វើការសម្រេចចិត្តឥឡូវនេះចុះ។

២៣.ការឆ្លងផុតពីសេចក្តីវេទនាដ៏ធំ

# ២៨. អារក្សជាប់ចំណង



1

នៅពេលដែលអារក្សមិនអាចល្បួងអ្នកណាបានទៀត


2

ក្រុមអ្នករុករក នៅលើសមុទ្រអង់តាក់ ទិក មួយក្រុមបានឈរនៅលើកោះថ្មដ៏ សោះកក្រោះមួយ។ គ្រឿងឧបភោគ បរិភោគរបស់គេបានអស់ទៅយ៉ាងឆាប់ រហ័ស។ ពួកគេបានបរិភោគម្ហូបពីរបីម៉ាត់ចុងក្រោយរបស់គេ។

ប្រេងឥន្ធនៈសម្រាប់ផ្គត់ផ្គង់របស់ពួកគេ ក៏កាន់តែនៅតិចណាស់ដែរ។

សីតុណ្ហភាពបានចុះយ៉ាងលឿន ធ្វើឱ្យ ពួកគេត្រជាក់យ៉ាងខ្លាំង។ ពួកគេបានរៀបចំខ្លួនគេសម្រាប់ភាពអាសន្នមួយ។ ពួកគេ បានដឹងថា សេចក្តីស្លាប់នឹងមកដល់ឆាប់ៗ នេះហើយ។ នៅពេលដែលពួកគេបានបោះ បង់ចោលនូវសេចក្តីសង្ឃឹមរបស់គេ


3

អ្នកផ្សងព្រេងដែលជិតស្លាប់នោះម្នាក់ បាន ឃើញកំសួលផ្សែងមួយនៅឯនាយជើងមេឃ។ ម្នាក់ក៏បាន យកវិទ្យុទាក់ទងរលកខ្លី របស់គេមកប្រើ។ ជំនួយកំពុងធ្វើដំណើរ មកហើយ។ ការរំដោះបានមកហើយ។

កំសួលផ្សែងដែលនៅឯនាយនោះ គឺជា អ្វីដែលពួកគេត្រូវការ ដើម្បីលើកទឹកចិត្តពួកគេឱ្យតស៊ូរង់ចាំ។ មិនយូរប៉ុន្មាន យល់ សប្តិអាក្រក់នៃការពិសោធន៍ដ៏គួរឱ្យរន្ធត់មួយនោះត្រូវបានបញ្ចប់។

នៅពេលឆាប់ៗខាងមុខនេះ ពួកគេត្រូវ បានជួយសង្គ្រោះយ៉ាងកក់ក្តៅបំផុតពីទូកសង្គ្រោះហើយ បន្ទាប់មក មិនយូរប៉ុន្មាន ពួកគេនឹងទៅដល់ផ្ទះវិញ ហើយទីបំផុតពួកគេក៏បានទៅដល់ផ្ទះវិញមែន មកដល់ ផ្ទះវិញហើយ។


4

សៀវភៅចុងក្រោយបង្អស់នៃព្រះគម្ពីរ វិវរណៈ បើកសំដែងឱ្យឃើញថា ជំនួយកំពុងធ្វើដំណើរមកហើយ។ ឆាប់ៗនេះ យើងនឹងត្រូវបានរំដោះដូចគ្នាដែរ។ សុបិនអាក្រក់យ៉ាងយូរនៃអំពើបាបនឹងត្រូវបានចប់។ យើងនឹងត្រូវបានរំដោះ ហើយសាតាំងនឹងត្រូវដាក់ឱ្យជាប់ឃុំឃាំង។

យើងនឹងត្រូវបានដោះលែងឱ្យមាន សេរីភាព ហើយសាតាំងនឹងត្រូវចាប់ចង។ យើងនឹងត្រូវលើកឡើងទៅស្ថានសួគ៌ ឱ្យ ជួបនឹងព្រះយេស៊ូវ ហើយសាតាំងនឹងត្រូវដាក់ច្រវាក់នៃបរិយាកាសនៅផែនដីនេះ។ យើងនឹងបានទទួលការវិនិច្ឆ័យឱ្យមានជីវិត អស់កល្បហើយសាតាំងនិងអ្នកដែលដើរ តាមវា នឹងទទួលការវិនិច្ឆ័យ ឱ្យជាប់ទោស នូវការបំផ្លាញអស់កល្ប។

# ២៤. អារក្សជាប់ចំណង



5

(វីដេអូ ១៣វិនាទី) យូរៗម្តង ចៅក្រម ឬគណៈវិនិច្ឆ័យនៅកន្លែងខ្លះលើពិភពលោក នេះ វិនិច្ឆ័យមនុស្ស ខ្លះឱ្យជាប់ទោសអស់ មួយជីវិត ដើម្បីបង្ហាញពីការអាក្រក់ ឬ កំហឹងដ៏ខ្លាំងចំពោះឧក្រិដ្ឋជននោះ។

ការវិនិច្ឆ័យអោយជាប់ទោសបីបួនជីវិត ជាបន្ត សូម្បីតែគេមានអាយុ៩៩ឆ្នាំ ឬជូន កាលគេដាក់ទោសនោះ ឱ្យ ឧក្រិដ្ឋជនដែល នៅក្នុងអាយុចូលនិវត្តរួចទៅហើយ ការកាត់ទោសបែបនេះគ្មានសង្ឃឹមថា ឧក្រិដ្ឋជននោះ នឹងនៅជាប់ ទោសគ្រប់កំណត់នោះបានឡើយ។


6

ប៉ុន្តែតាមគណៈវិនិច្ឆ័យ ការវិនិច្ឆ័យមួយ បញ្ជាក់អំពីកំហឹងរបស់សង្គម សម្រាប់តែ ឧក្រិដ្ឋជនណាដែល សាហាវឃោរឃៅខ្លាំង តែប៉ុណ្ណោះ។


7

តើលោកអ្នកបានដឹងហើយឬនៅថា នឹងមានពេលមួយមកដល់ឆាប់ៗនេះ ដែល ចៅក្រមនឹងប្រគល់ការ វិនិច្ឆ័យមួយដែល មានរយៈពេល១០០០ឆ្នាំ ហើយឧក្រិដ្ឋជន នឹងនៅជាប់រៀងរាល់ថ្ងៃ នៃការវិនិច្ឆ័យនោះ?


8

(ព្រះគម្ពីរ វិវរណៈ ២០:១-៣)

សូមស្តាប់ពាក្យទាំងនេះពីព្រះគម្ពីរ "ខ្ញុំ ក៏ឃើញទេវតា១ចុះពីស្ថានសួគ៌ មកទាំង កាន់កូនសោជង្ហុកធំ និងច្រវាក់១យ៉ាងធំនៅ ដៃ


9

ទេវតានោះក៏ចាប់នាគចងទុក១ពាន់ឆ្នាំ គឺជាពស់ពីចាស់បុរាណដែលជាអារក្សឈ្មោះថាសាតាំង


10

ក៏បោះវាចោលទៅក្នុងជង្ហុកធំ ទាំងខ្ទប់ ហើយបិទត្រាពីលើ


11

ដើម្បីកុំឱ្យវានាំអស់ទាំងសាសន៍ឱ្យវង្វេងទៀត ទាល់តែផុតពី១ពាន់ឆ្នាំនេះទៅ

# ២៤. អារក្សជាប់ចំណាង


12

ក្រោយនោះត្រូវតែស្រាយវាលែងបន្តិច” វិវរណៈ២០:១-៣។


13

ត្រង់នេះយើងរកឃើញថា ព្រះមាន
ផែនការទាក់ទងទៅនឹងឧក្រិដ្ឋកម្មដ៏ធំ នៅ លើចក្រវាលនេះ ដែលគេធ្លាប់បានស្គាល់ថា
ជាឧក្រិដ្ឋជនដែលមានការទាក់ទងយ៉ាងចំៗ ទៅនឹងអំពើបាបនិងឧក្រិដ្ឋកម្មទាំងឡាយ
ដែលបានប្រព្រឹត្តនៅលើផែនដីនេះ។

ប៉ុន្តែពេលវេលានឹងមកដល់ឆាប់ៗនេះ ដែលវានឹងត្រូវដាក់ឱ្យជាប់គុកអស់រយៈពេល ១០០០ឆ្នាំ!
មួយពាន់ឆ្នាំនៅក្នុងកន្លែង ដែលរងទុក្ខវេទនាយ៉ាងខ្ទេចខ្ទីជាទីបំផុត នៅលើលោកសន្និវាសនេះ។
ជួនកាលរយៈ ពេល នេះត្រូវបានគេយោងទៅលើរយៈ ពេលមួយសហសវត្សរ៍។



14

តើអ្វីទៅជាសហសវត្សរ៍?



15

រយៈមួយពាន់ឆ្នាំនេះត្រូវបានគេហៅថា “សហស្សវត្សរ៍” ដែលមកពីពាក្យបាលី ពីរ ម៉ាត់ថា
“សហស្ស” ដែលមានន័យថា “មួយពាន់” និង“វត្សរ៍” ដែលមានន័យ
ថា “ឆ្នាំ”។


16

បទទំនាយក៏បានប្រាប់យើងដែរថា សាតាំងត្រូវបានដាក់គុកអស់រយៈពេល



17

១០០០ឆ្នាំ ហើយថា នៅក្រោយពីពេល នោះ វានឹងត្រូវបានដោះលែងបន្តិច ដើម្បី
បញ្ជាក់ប្រាប់ពិភពលោកថា សូម្បីតែក្រោយ ពីមួយពាន់ឆ្នាំក៏ដោយ ក៏វាមិនបានផ្លាស់ប្តូរ
ដែរ គឺវានៅតែអាក្រក់ដដែល។

ដើម្បីឱ្យបានយល់អំពីបទទំនាយនេះ និងដើម្បីឱ្យឃើញយ៉ាងច្បាស់អំពីសញ្ញារបស់ វា
យើងត្រូវតែរកឱ្យឃើញនូវរបៀបដែល វាបានចាប់ផ្តើម និងបញ្ចប់ទៅវិញ ហើយ
តើមានអ្វីកើតឡើងនៅចន្លោះពេលនោះ។

# ២៤. អារក្សជាប់ចំណង



18

ខ្ញុំសូមធ្វើសេចក្តីថ្លែងការមួយឥឡូវនេះ បន្ទាប់មកខ្ញុំនឹងបន្តបង្ហាញអំពីការពិតនៃ
សេចក្តីថ្លែងការណ៍នេះ។ សហសវត្សរ៍ គឺជាការ ចងភ្ជាប់គ្នាដោយការរស់ឡើង វិញពីរៈ



19

១/ ការរស់ឡើងវិញនៅគ្រាដំបូងនៃរយៈ ពេលនោះ



20

និង២/ ការរស់ឡើងវិញនៃការផ្តន្ទា នា ពេលបំផុតកល្ប។



21

(ព្រះគម្ពីរ យ៉ូហានទី១ ៥:២៥)
ថ្ងៃមួយនៅពេលដែលព្រះយេស៊ូវកំពុង បង្រៀនពួកសាវករបស់ទ្រង់ ព្រះអង្គបាន មានព្រះបន្ទូលថា
"ប្រាកដមែន ខ្ញុំប្រាប់ អ្នករាល់គ្នាជាប្រាកដថា នឹងមានពេល វេលាមក ក៏មកដល់ហើយ



22

នៅពេលដែលមនុស្សស្លាប់នឹងឮសំឡេង
ព្រះរាជ បុត្រានៃព្រះ ហើយអ្នកណា ដែលឮនឹងបានរស់វិញ" យ៉ូហាន៥:២៥។
ទីនោះយើងមាន
យើងឃើញច្បាស់ហើយ អ្នកស្លាប់នឹង បានឮព្រះបន្ទូលរបស់ព្រះ ហើយនិងបាន រស់ឡើងវិញ។
នោះអ្នកស្លាប់ទាំងអស់នឹងត្រូវបានរស់ ឡើងវិញ។
ខ្ញុំដឹងថា នឹងធ្វើឱ្យមានការភ្ញាក់ផ្អើល ដល់លោកអ្នកខ្លះ ពីព្រោះលោកអ្នកបាន គិតថា
មានតែអ្នកសុចរិតដែល បានស្លាប់ នោះទេ ដែលបានប្រោសឱ្យរស់ឡើងវិញ។ សូមកត់
សំគាល់ព្រះគ្រីស្ទបានបញ្ជាក់ យ៉ាងល្អិតល្អន់ លើបញ្ហានេះ នៅក្នុង២៨ និង២៩នៃ ជំពូកដដែលនេះ



23

(ព្រះគម្ពីរ យ៉ូហាន ៥:២៨,២៩)
"កុំឱ្យឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមាន ពេលវេលាមក ដែលអស់ ទាំងខ្មោច
នៅក្នុងផ្នូរនឹងឮសំឡេងទ្រង់



24

ហើយនិងចេញមក គឺពួកអ្នកដែលបានប្រ ព្រឹត្តល្អ គេនឹងរស់ឡើងវិញឱ្យបានជីវិត

# ២៤. អារក្សជាប់ចំណង


25

ឯពួកអ្នកដែលបានប្រព្រឹត្តអាក្រក់វិញ គេ នឹងរស់ឡើងឱ្យជាប់មានទោស”
យ៉ូហាន ៥:២៨,២៩។



26

(វីដេអូ ៤វិនាទី) សូមកត់សំគាល់ការរស់ ឡើងវិញទាំងពីរនេះ។ ទីមួយការរស់ឡើងវិញរបស់អ្នកដែលបានធ្វើល្អ ហើយទីពីរ ការរស់ឡើងវិញរបស់អ្នករងទុក្ខវេទនា។


27

សូមស្តាប់នូវការដែលព្រះគម្ពីរបានថែង អំពីអ្នកទាំងនោះ នៅក្នុងការរស់ឡើងវិញ លើកទីមួយៈ


28

(ព្រះគម្ពីរ វិវរណៈ ២០:៥,៦) “នេះហើយជាខណរស់ឡើងវិញទី១


29

មានពរហើយ ក៏បរិសុទ្ធផង អស់អ្នក ណាដែលមានចំណែកក្នុងខណរស់ឡើងវិញ ជាន់ដំបូងនេះ សេចក្តីស្លាប់ទី២ គ្មាន អំណាចលើអ្នកទាំងនោះឡើយ


30

អ្នកទាំងនោះនឹងធ្វើជាពួកសង្ឃនៃព្រះ និង ព្រះគ្រីស្ទ ហើយនិងសោយរាជ្យជាមួយទ្រង់អស់១ពាន់ឆ្នាំ”
វិវរណៈ ២០:៥,៦។


31

រឿងនេះវាត្រូវគ្នាទៅនឹងការដែលលោក ប៉ុលបានប្រាប់ ដល់ពួកថែស្សាឡូនីច។ សូមកត់សំគាល់ការដែលគាត់បានពណ៌នា អំពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ។


32

(ព្រះគម្ពីរ ថែស្សាឡូនីចទី១ ៤:១៦,១៧)
“ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពី ស្ថានសួគ៌មកដោយ ស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា

# ២៤. អារក្សជាប់ចំណង


33

និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះ គ្រីស្ទ នឹងរស់ឡើងវិញជាមុនបង្អស់


34

រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏ នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់នៅ នាអាកាស


35

យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះ អម្ចាស់ជាដរាបតទៅ” ១១៦,១៧


36

នេះគឺជាការពណ៌នាដ៏មានសិរីល្អនៃការ រស់ឡើងវិញ។ លោកអ្នកនឹងបានកត់ សំគាល់ថា អ្នកដែលស្លាប់ ក្នុងព្រះគ្រីស្ទ
នឹងរស់ឡើងវិញជាមុនបង្អស់ហើយបន្ទាប់មកអ្នកដែលដើរតាមព្រះគ្រីស្ទដែលរស់នៅ
នឹងត្រូវលើកឡើងទៅជាមួយនឹងពួកគេ នៅក្នុងពពក ដើម្បីនឹងទៅជួបនឹងព្រះ
អម្ចាស់នៅលើអាកាស!


37

(ព្រះគម្ពីរ យ៉ូហាន ១១:២៥)
នៅថ្ងៃនោះសេចក្ដីសន្យា ដែលព្រះ យេស៊ូវបាន ធ្វើឡើង នឹងត្រូវបាន សម្រេច
“អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ ឡើងវិញដែរ” យ៉ូហាន ១១:២៥


38

មែនហើយ អ្នកសុចរិតដែលបានស្លាប់ទៅ នឹងត្រូវបានលើកពីផ្នូរឡើងវិញ។


39

(ព្រះគម្ពីរ អេសាយ ២៦:១៩)
លោកអេសាយពណ៌នាអំពីព្រឹត្តិការណ៍ ដ៏រីករាយនេះថា “ឯងរាល់គ្នាដែលអាស្រ័យ
នៅក្នុងធូលីដីអើយ ចូរក្រោកឡើង ហើយ ច្រៀងចុះ... ឯដីនឹងបញ្ចេញមនុស្សស្លាប់ មក” អេសាយ
២៦:១៩ ថ្ងៃនោះគឺជាថ្ងៃ ដែលមានសិរីល្អអស្ចារ្យ!

# ២៤. អារក្សជាប់ចំណង


40

ម្តាយនឹងទៅជួបជុំជាមួយនឹងទារករបស់ គាត់ ដែលស្លាប់ទៅហើយនោះវិញ។ ប្តី និងប្រពន្ធបានជួបជុំគ្នាឡើងវិញ។ កូនប្រុស កូនស្រី នឹងបានជួបជុំជាមួយនឹងឪពុកម្តាយ របស់គេវិញ! តើមានទស្សនីយភាពណា ដែលរំភើប ជាងនេះទៅទៀតឬទេ?


41

(ព្រះគម្ពីរ យ៉ូហាន ១៤:២,៣)

បន្ទាប់មកសេចក្តីសន្យាមួយដ៏អស្ចារ្យ ដែលព្រះគ្រីស្ទបានធ្វើជាយូរយារមកហើយ នឹងត្រូវបានសម្រេច "ខ្ញុំទៅរៀបកន្លែងឱ្យ អ្នករាល់គ្នា


42

បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះ ខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នា ទៅឯខ្ញុំ


43

ប្រយោជន៍ឱ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ "យ៉ូហាន ១៤:២,៣។

កន្លែងនេះហើយ ជាកន្លែងដែលអ្នក បានសង្គ្រោះរស់នៅក្នុង១សហសវត្សរ៍!


44

(ព្រះគម្ពីរ វិវរណៈ ២០:៦)

តើយើងនឹងកំពុងធ្វើអ្វី? លោកយ៉ូហាន ប្រាប់យើងថា "មានពរហើយ ក៏បរិសុទ្ធ ផង អស់អ្នកណាដែលមានចំណែកក្នុង ខណរស់ឡើងវិញជាន់ដំបូងនេះ សេចក្តី ស្លាប់ទី២ គ្មានអំណាចលើអ្នកទាំងនោះឡើយ


45

អ្នកទាំងនោះនឹងធ្វើជាពួកសង្ឃនៃព្រះ និងព្រះគ្រីស្ទ ហើយនិងសោយរាជ្យជាមួយនឹង ទ្រង់អស់១ពាន់ឆ្នាំ"

វិវរណៈ ២០:៦

ក្រៅពីអំណរនៃការជួបជុំជាមួយនឹង ព្រះគ្រីស្ទ និងអ្នកដើរតាមទ្រង់ដែលមិនអាច ថ្លែងបាននោះ លោកយ៉ូហានបានផ្តល់នូវ ការយល់ដឹងយ៉ាងជ្រាលជ្រៅពីការដែលពួក គេកំពុងធ្វើនៅក្នុងកំឡុងពេលនៃ សហសវត្សរ៍នោះ:

# ២៤. អារក្សជាប់ចំណង


46

(ព្រះគម្ពីរ វិវរណៈ ២០:៤)

"ខ្ញុំឃើញបល្ល័ង្កជាច្រើន និងពួកអ្នក ដែលអង្គុយលើ ហើយមានអំណាចបាន ប្រគល់ដល់អ្នកទាំងនោះ ឱ្យជំនុំជំរះ" វិវរណៈ ២០:៤។ ព្រះដ៏សព្វញ្ញូញ្ញាណ និងសព្វចេស្តានៃចក្រវាលនេះ ក៏បានបញ្ចូល មនុស្សប្រុស ស្រីទាំងឡាយទៅក្នុងកិច្ចការ ដ៏ធំធេងមួយជាមួយនឹងទេវតាដែលបាន ធ្លាក់ចុះ និងអ្នកដែលមិនបានសង្គ្រោះទាំង អស់ដែរ។


47

(ព្រះគម្ពីរ កូរិនថូសទី១ ៦:២,៣)

លោកប៉ុលបានមានប្រសាសន៍ថា "តើ មិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជំរះលោកីយ៍ ដែរទេឬអី?...


48

តើមិនដឹងទេឬអីថា យើងរាល់គ្នានឹង ជំនុំជំរះ ដល់ទាំងពួកទេវតាផង?" កូរិនថូសទី១ ៦:២,៣។


49

ពេលនោះយើងនឹងឃើញយ៉ាងច្បាស់ ទៀតថា ព្រះទ្រង់យុត្តិធម៌ និងត្រឹមត្រូវ។

រាប់ពាន់ឆ្នាំ សាតាំងបានធ្វើការចោទ ប្រកាន់ទៅលើព្រះថាមិនត្រឹមត្រូវ គ្មាន សេចក្ដីស្រឡាញ់ និងអយុត្តិធម៌។

ឆ្នាំនៃសហសវត្សរ៍ នឹងដាក់ការចោទ ប្រកាន់របស់សាតាំងនេះ ឱ្យនៅស្ងៀម និង បង្ហាញឱ្យមនុស្សនៅលើចក្រវាលទាំងមូល ឃើញថា អត្តចរិតរបស់ព្រះ គឺសុចរិត! ប៉ុន្តែតើហេតុអ្វី បានជាយើងចាំបាច់ត្រូវជំនុំជំរះដល់ទេវតាអាក្រក់ និងមនុស្សមានបាបកំណាច? តើ ពួកវាមិនត្រូវបានជំនុំជំរះទេឬអី មុនព្រះ គ្រីស្ទយាងមកវិញនោះ?


50

ពិតប្រាកដណាស់ ប៉ុន្តែលោកអ្នក ប្រហែលជាឆ្ងល់ និងមានប្រតិកម្មកើតឡើង ប្រសិនបើលោកអ្នករកមើល នៅឯនគរ ស្ថានសួគ៌ នូវអ្នកណាម្នាក់ដែលលោកអ្នក ដោយរំពឹងថា នឹងរកឃើញនៅទីនោះ_តែបែរជាគាត់ឬ នាងនោះត្រូវបានបាត់បង់ រហូតទៅវិញនោះ?

លោកអ្នកអាចសង្ស័យអំពីភាពត្រឹមត្រូវនិង ភាពយុត្តិធម៌របស់ព្រះនេះ


51

នៅក្នុងសម័យនៃសហសវត្សរ៍ បញ្ជី របស់អ្នកបាត់បង់នឹងបានបើកឡើង។ អាថ៌ កំបាំងនិងគោលបំណងដ៏ធំបំផុត ដែល លាក់កំបាំងនៅក្នុងគំនិត នីមួយៗនឹងត្រូវ បានបើកបង្ហាញ។ សេចក្ដីស្រឡាញ់ និង យុត្តិធម៌របស់ ព្រះនឹងត្រូវបានបញ្ជាក់អះអាង

# ២៤. អារក្សជាប់ចំណង


52

(ព្រះគម្ពីរ វិវរណៈ ១៦:៧)

អ្នកដែលពិនិត្យបញ្ជីនោះនឹងត្រូវបាន ឧទានឡើងនូវប្រតិកម្មតែមួយគត់ថា "មែន ហើយ ឱព្រះអម្ចាស់ជាព្រះដ៏មានព្រះចេស្ដា បំផុតអើយ សេចក្តីជំនុំជំរះរបស់ទ្រង់សុទ្ធ តែសុចរិត ហើយពិតត្រង់ទាំងអស់"

វិវរណៈ ១៦:៧


53

លោកអ្នកប្រហែលជាកំពុងតែងឿង ឆ្ងល់ថា តើមានអ្វីកើតឡើងដល់អ្នកដែល កំពុងរស់នៅ នៅពេលដែលព្រះគ្រីស្ទយាង មក ដែលមិនបានទទួលការសង្គ្រោះនោះ។ គម្ពីរវិវរណៈជំពូក១៩ ពណ៌នាអំពីការយាង មកជាលើកទីពីររបស់ព្រះគ្រីស្ទនិងការវេទនា របស់អ្នកដែលមិនបានសង្គ្រោះថាយ៉ាងដូច្នេះ


54

(ព្រះគម្ពីរ វិវរណៈ ១៩:២១)

"ហើយពួកអ្នកដែលសល់នៅ ក៏ត្រូវ ស្លាប់ដោយដាវរបស់ព្រះអង្គដែល គង់លើ សេះ ជាដាវដែល


55

ចេញពីព្រះឱស្ឋទ្រង់មក ដែលទ្រង់គង់លើ ខ្នងសេះ... វិវរណៈ ១៩:២១


56

អ្នកបាត់បង់ គ្មានផ្លូវអាចនឹងឈរនៅ ចំពោះសិរីល្អនៃការយាងមករបស់ព្រះគ្រីស្ទ ជាមួយនឹងទេវតាបរិសុទ្ធរបស់ទ្រង់ឡើយ។


57

ទេវតាមួយអង្គបានយាងទៅកាន់ផ្នូរ របស់ព្រះយេស៊ូវ ហើយទាហានរ៉ូមបាន ស្លាប់។


58

(ព្រះគម្ពីរ យេរេមា ២៥:៣៣)

ព្រះគម្ពីរនិយាយថា "នៅថ្ងៃនោះសាក សពនៃមនុស្សដែលព្រះយេហូវ៉ា បានប្រ ហារ នឹងនៅរាយពេញ ពីចុងផែនដីម្ខាង ទៅដល់ចុងផែនដីម្ខាង

# ២៤. អារក្សជាប់ចំណង


59

ឥតមានអ្នកណាសោកស្តាយគេ ឬប្រ មូលខ្មោចគេទៅកប់ឡើយ”
យេរេមា ២៥:៣៣។


60

នាការយាងមកជាលើកទីពីររបស់ព្រះ គ្រីស្ទ អ្នកបរិសុទ្ធត្រូវបានរស់ឡើងវិញ
ហើយត្រូវបានឡើងទៅជួប នឹងព្រះគ្រីស្ទ នៅលើពពក។


61

ហើយអ្នកដែលមិនត្រូវបានសង្គ្រោះនឹងត្រូវ បានសម្លាប់ដោយសារពន្លឺនៃការយាងមកនោះដោយ
“ដាវដែលចេញពីព្រះឱស្ឋទ្រង់”។ អ្នកខ្លះនឹងសួរនូវសំនួរថា “ចុះតើអ្នកដែល
មិនបានសង្គ្រោះដែលនៅក្នុងផ្នូរនោះ យ៉ាង ណាដែរ?
ចម្លើយត្រូវបានផ្តល់នូវក្នុងព្រះគម្ពីរ វិវរណៈជំពូកទី២០ខ៥


62

(ព្រះគម្ពីរ វិវរណៈ ២០:៥)
“តែមនុស្សស្លាប់ឯទៀត មិនបានរស់វិញ ទេ ទាល់តែផុតពី១ពាន់ឆ្នាំនោះទៅ...”


63

រូបភាពដែលគេកាត់ជាចំណែកតូចៗ នោះ ត្រូវបានរៀបឡើងវិញជិតរួចអស់ ហើយ
គំនិតដ៏ធំកំពុងចូល ផ្តោតអារម្មណ៍ ថា នៅពេលដែល ព្រះយេស៊ូវគ្រីស្ទនឹង
យាងត្រឡប់មកវិញនោះៈតើនឹងទៅជា
យ៉ាងណា


64

ទាំងនេះគឺជាព្រឹត្តិការណ៍ដែលនឹងកើត ឡើងនៅពេលព្រះគ្រីស្ទយ៉ាងមកវិញ។


65

១. ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ ជាមួយនឹងទេវតាបរិសុទ្ធយ៉ាងច្រើនកុះករ (ម៉ាថាយ ២៥:៣១)

# ២៤. អារក្សជាប់ចំណង


66

២. អ្នកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញ ជាមុនបង្អស់
ថែស្សាឡូនីចទី១ ៤:១៦


67

៣. អ្នកដែលកំពុងរស់នៅដែលបាន សង្គ្រោះនឹងត្រូវលើកឡើងទៅជួបព្រះយេស៊ូវ
នៅលើអាកាស(ថែស្សាឡូនីចទី១ ៤:១៧)


68

៤. អ្នកដែលបានសង្គ្រោះទៅឯដំណាក់ជា មួយនឹងព្រះយេស៊ូវ ហើយសោយរាជ្យ
ជាមួយទ្រង់អស់១០០០ឆ្នាំ
(វិវរណៈ ២០: ៤.៦)


69

៥. អ្នកមិនបានសង្គ្រោះនឹងត្រូវសម្លាប់ ដោយពន្លឺនៃការយាងមករបស់ព្រះគ្រីស្ទ (យេរេមា ២៥:៣៣)


70

៦. អ្នកអាក្រក់ដែលស្លាប់ មិនបានប្រោស អោយរស់ឡើងវិញទេ រហូតដល់ក្រោយ ១០០០ឆ្នាំ។
(វិវរណៈ ២០:៥)


71

៧. សាតាំងត្រូវចាប់ចងអស់
ពេល១០០០ឆ្នាំ ដោយច្រវាក់នៃបរិយាកាស គ្មានអ្នកណានឹងឱ្យវាល្បួង ឬបំផ្លាញទៀត ឡើយ


72

អ្នកបរិសុទ្ធនៅឯស្ថានសួគ៌ ហើយ មនុស្សអាក្រក់ទាំងអស់នឹងត្រូវស្លាប់។
គ្រប់ៗគ្នានឹងត្រូវបាត់បង់!
គ្រប់ទីកន្លែងនឹងមានការវេទនា
(យេរេមា ៤:២៣-២៦)

២៤. អារក្សជាប់ចំណង

# ២៤. អារក្សជាប់ចំណង


73

ផែនដីនេះនឹងក្លាយទៅជាគុករបស់អារក្ស។
ព្រះគម្ពីរនិយាយថា សាតាំងបានបោះទៅ ក្នុងបាត ជង្ហុកធំអស់ពេលមួយ សហស្សវត្សរ៍។
តើវាត្រូវបានដាក់ ច្រវាក់ យ៉ាងណា?
ដោយសារច្រវាក់នៃបរិយាកាស ដែល ធ្វើអោយវាគ្មានលទ្ធភាពនឹងល្បួង និង
បំផ្លាញអ្នកណាម្នាក់បានឡើយ អស់
ពេល១០០០ឆ្នាំ។


74

អស់អ្នកណាដែលបានដើរតាមសាតាំង នៅក្នុងជីវិតរបស់គេនៅលើផែនដីនេះ នឹង
ត្រូវស្លាប់នៅគ្រាយាងមកវិញរបស់ព្រះគ្រីស្ទ ឬក៏ពួកគេសល់នៅក្នុងផ្នូររហូតដល់
ពេល១០០០ឆ្នាំបានបញ្ចប់។


75

អ្នកដែលបានសង្គ្រោះទាំងអស់នៅជា មួយព្រះគ្រីស្ទមួយពាន់ឆ្នាំ។


76

អារក្សមានតែទេវតាអាក្រក់របស់វា ដើម្បីល្បួងនិងដឹកនាំទៅរកការអាក្រក់ប៉ុណ្ណោះ
ហើយពួកវានៅតែអាក្រក់ ដូចកាល
ពី៦០០០ឆ្នាំមុនដដែល។


77

ផែនដីនេះបានក្លាយជាគុក។
វាចង់បង្ហាញរបៀប ដែលវានឹងដឹកនាំ ពិភពលោក ដូច្នេះវាបានយកភាពជាម្ចាស់ ពីអ័ដាមនិងអេវ៉ា
ដោយការបោកបញ្ឆោត ប៉ុន្តែឥឡូវនេះគ្រប់ៗគ្នាអាចនឹងឃើញថា វាជាអ្នកដឹកនាំរបៀបណា!



78

(ព្រះគម្ពីរ វិវរណៈ ២០:៣)
លោកអ្នកនឹងចងចាំបានថា វិវរណៈ ២០:៣ និយាយថា:
"ក៏បោះវាចោលទៅក្នុងជង្ហុកធំ ទាំង ខ្ទប់ ហើយបិទត្រាពីលើ



79

ដើម្បីកុំឱ្យវានាំអស់ទាំងសាសន៍ឱ្យវង្វេងទៀត ទាល់តែផុតពី១ពាន់ឆ្នាំនោះទៅ:

# ២៤. អារក្សជាប់ចំណង


80

ក្រោយនោះត្រូវតែស្រាយវាលែងបន្តិច"

ពាក្យដើមនៃព្រះគម្ពីរ ហៅបាតនៃ

ជង្ហុកធំនោះថា អាប៊ូស្សូស

នេះគឺដូចជាពាក្យ ក្នុងគម្ពីរសញ្ញាចាស់ ដែលពណ៌នាអំពីពិភពលោក ក្នុងសភាព ទទេរបស់ខ្លួនមុន ពេលដែលព្រះបាន បង្កើតមកក្នុងភាពដ៏ស្រស់ប្រឹមប្រិយនេះ។


81

(ព្រះគម្ពីរ យេរេមា ៤:២៣)

វាគឺជាពាក្យដដែលនេះ ដែលប្រើក្នុង សៀវភៅយេរេមា:

"ខ្ញុំបានពិចារណារមើលផែនដី ឃើញ ថា ខូចហើយ នៅទទេ រួចមើលទៅលើ មេឃ នោះក៏ឥតមានពន្លឺដែរ"

យេរេមា ៤:២៣



82

មែនហើយ ពិភពលោកនេះ គឺជាអាប៊ូស្សូស "បាតជង្ហុក"

វានឹងក្លាយជាកន្លែងដ៏ងងឹតសូន្យសុង!

ឥឡូវនេះសូមលោកអ្នកកត់សំគាល់ថា តើ ហោរាយេរេមាបាននិយាយអំពីអ្វីទៀត អំពីផែនដីនេះនៅពេលនោះ:


83

(ព្រះគម្ពីរ យេរេមា ៤:២៤-២៥)

"ខ្ញុំក្រឡេកមើលទៅភ្នំធំ ឃើញថាញ័រ ទាំងអស់ ហើយភ្នំតូចទាំងប៉ុន្មានក៏កក្រើក រញ្ជួយ


84

ខ្ញុំក៏ពិចារណាមើលឃើញថា គ្មាន មនុស្សណាទៀតសោះ អស់ទាំងសត្វហើរ លើអាកាស បានហើរទៅបាត់ហើយ"

យេរេមា៤:២៤-២៥

លោកអ្នកនឹងកត់សំគាល់ថា គាត់បាន និយាយថា "នឹងគ្មានមនុស្សឡើយ"


85

(ព្រះគម្ពីរ យេរេមា ៤:២៦)

យេរេមាបាននិយាយម្តងទៀតថា "...រួចខ្ញុំក៏មើលទៅឃើញដីដុះដាល បាន ត្រឡប់ជាវាលស្ងាត់

# ២៤. អារក្សជាប់ចំណង


86

ហើយអស់ទាំងទីក្រុងក៏ត្រូវរលំចុះ នៅ ចំពោះព្រះយេហូវ៉ា ហើយចំពោះសេចក្តីខ្ញាល់ដ៏សហ័សរបស់ទ្រង់”

១២៦, ២៧


87

ស្តាប់ទៅវាហាក់ដូចជាកន្លែងមិនល្អយ៉ាង ពិតប្រាកដ សំរាប់នឹងសំរាកនៅអស់ពេល ១០០០ឆ្នាំ តើលោកអ្នកមិនថាដូច្នេះមែន

ទេ?

សាតាំងនិងទេវតាអាក្រក់គ្មានអ្វីនឹងធ្វើទេ ប៉ុន្តែដើរតត្រុកទៅមកគ្មានទីកំណត់ នៅលើភពដ៏ងងឹតខ្មៅចខ្មី និងឯកោនេះ ហើយនឹង ឆ្លុះបញ្ចាំងនូវលទ្ធផលនៃការប្រឆាំងបះបោររបស់វាចំពោះព្រះ!


88

ឥឡូវនេះសូមយើងរំលឹកឡើងវិញអំពីព្រឹត្តិការណ៍ ដែលនឹងកើតមានឡើងនៅក្នុង ពេលមួយសហស្សវត្សរ៍:


89

១. ផែនដីដ៏សោះកក្រោះ និងខ្មៅចខ្មី។


90

២. អ្នកដែលមិនបានសង្គ្រោះនឹងស្លាប់ទាំងអស់ស្លាប់ដោយសារពន្លឺនៃការយាងមករបស់ព្រះយេស៊ូវ។


91

៣. អ្នកដែលបានសង្គ្រោះទាំងអស់ នៅឯ ស្ថានសួគ៌សោយរាជ្យជាមួយព្រះគ្រីស្ទ។


92

៤. សាតាំងត្រូវបានចាប់ចងនៅលើពិភព ដែលងងឹតនិងខ្មៅចខ្មី ដើម្បីឆ្លុះបញ្ចាំងការប្រឆាំងបះបោររបស់វា។

# ២៤. អារក្សជាប់ចំណង


93

តើសាតាំងផ្លាស់ប្ដូរឬទេ?

ចុះតើទេវតាដែលបានដឹកនាំអោយមាន ការបះបោរនោះយ៉ាងណាដែរ?

តើពួកគេជ្រើសរើសដើរតាមសាតាំង ទៀត ឬមួយក៏ពួកគេនឹងដើរតាមព្រះគ្រីស្ទ ឥឡូវនេះ?

ហេតុផលមួយដែលព្រះដាក់អោយមាន សហស្សវត្សរ៍នៅក្នុងកាលវិភាគរបស់ទ្រង់ គឺថាទ្រង់ចង់បង្ហាញទៅកាន់

លោកសន្និវាសនេះថា ប្រសិនបើអារក្ស និងទេវតារបស់វានិងអស់អ្នកដែលជ្រើសរើសដើរតាមទ្រង់នៅលើផែនដី នេះនៅពេល ដែលពួកគេត្រូវបាន ផ្ដល់ឱកាសអោយ ម្ដងទៀតនោះ។

ពួកគេនឹងធ្វើការសំរេចចិត្តដដែល ហើយជ្រើសរើសចៅហ្វាយដដែល។


94

ពួកគេនឹងច្រានចោលផែនការនៃការ សង្គ្រោះ ទោះបីជាគេមានឱកាស មួយពាន់ដងក៏ដោយ។


95

តើព្រះគម្ពីរនិយាយយ៉ាងណាអំពីជម្រើស របស់ពួកគេ?


96

(ព្រះគម្ពីរ វិវរណៈ ២០:៧-៨)

ចម្លើយត្រូវបានផ្ដល់នៅក្នុងគម្ពីរវិវរណៈ ២០:៧,៨ "លុះផុតកំណត់ ១ពាន់ឆ្នាំនោះ ហើយទើបទ្រង់នឹងស្រាយ អារក្សសាតាំង លែងពីគុកចេញ


97

នោះវានឹងចេញទៅខំនាំអស់ទាំងសាសន៍ ដែលនៅផែនដីទាំង៤ទិសឱ្យវង្វេង...


98

ដើម្បីនឹងប្រមូលគេមកច្បាំង ចំនួនគេដូច ជាខ្សាច់នៃសមុទ្រ"

វិវរណៈ ២០:៧-៨

ប្រហែលជាអ្នកកំពុងឆ្ងល់ថា តើមនុស្ស ទាំងអស់នេះមកពីណា? តើអ្នកណានឹងនៅក្នុងសមរភូមិនោះ?

# ២៤. អារក្សជាប់ចំណង


99

(ព្រះគម្ពីរ វិវរណៈ ២០:៥)

សូមចងចាំថា យើងបានអាននៅក្នុង ជំពូកទី២០នៃព្រះគម្ពីរវិវរណៈ៖៥:

"តែមនុស្សស្លាប់ឯទៀតមិនបានរស់វិញ ទេ ទាល់តែផុតពី១ពាន់ឆ្នាំនោះទៅ"


100

មែនហើយ អ្នកសល់ពីស្លាប់ឬអ្នកមិនបាន សង្គ្រោះដែលស្លាប់ នឹងត្រូវបានលើកអោយ រស់ឡើងវិញ នៅគ្រារស់ឡើងវិញ នៃការ វេទនាចុងបំផុតនៃសហស្សវត្សរ៍។ សញ្ញាមួយដែលយើងនឹងឃើញមនុស្សអាក្រក់បាន លើកអោយមានជីវិតឡើងវិញ-ជាចំនួនដ៏ ច្រើន មនុស្សអាក្រក់ទាំងអស់តាំងពីជំនាន់ អ័ដាមរហូតដល់ព្រឹត្តិការណ៍ទី២។


101

(ព្រះគម្ពីរ វិវរណៈ ២០:៨)

យ៉ូហាននិយាយថា "ចំនួនគេដូចជា ខ្សាច់នៃសមុទ្រ" វិវរណៈ ២០:៨


102

នៅពេលជាមួយគ្នានេះទីក្រុងបរិសុទ្ធជា ទីក្រុងយេរូសាឡិមថ្មីជាមួយព្រះគ្រីស្ទនិងអ្នក ដែលបានសង្គ្រោះមកកាន់ផែនដីវិញនៅចុង សហស្សវត្សរ៍!

ទីក្រុងនេះ នឹងក្លាយជាចំណុចគោលដៅ នៃកំហឹងរបស់សាតាំងដូចព្រះគម្ពីរនិយាយថា


103

(ព្រះគម្ពីរ វិវរណៈ ២០:៧-៨)

"លុះផុតកំណត់ ១ពាន់ឆ្នាំនោះហើយ ទើបទ្រង់នឹងស្រាយអារក្សសាតាំងលែងពីគុក ចេញ


104

នោះវានឹងចេញទៅ ខំនាំអស់ទាំងសាសន៍ ដែលនៅផែនដីទាំង៤ទិសឱ្យវង្វេង...


105

ដើម្បីនឹងប្រមូលគេមកច្បាំង"

វិវរណៈ ២០: ៧-៨

# ២៤. អារក្សជាប់ចំណង


106

ឥឡូវនេះសាតាំងនិងទេវតាអាក្រក់របស់ វាចេញទៅ ដើម្បីបោកបញ្ឆោតមនុស្ស អាក្រក់ម្តងទៀត។

វាមិនបានផ្លាស់ប្តូរបន្តិចសោះឡើយ!

អ្នកមិនបានសង្គ្រោះនឹងជ្រើសរើសសាតាំង ជាអ្នកដឹកនាំរបស់ពួកគេម្តងទៀត។

អារក្សប្រមែប្រមូលពួកគេចូលក្នុង កងទ័ពដ៏ធំ ដើម្បីដណ្តើមយកទីក្រុង យេរូសាឡិមថ្មីដោយកម្លាំង។

នេះគឺជា សមរភូមិចុងក្រោយ នៅផែនដី កងទ័ពដ៏ខ្លាំងក្លាក្រោមការគ្រប់គ្រងរបស់ ទេវតាដែលបះបោរប្រឆាំង បោះជំហានទៅ មុខ!


107

សូមអានការដែលព្រះគម្ពីរនិយាយអំពីអ្វី ដែលនឹងកើតឡើង:


108

(ព្រះគម្ពីរ វិវរណៈ ២០:៩)

"នោះគេក៏ឡើងទៅ ពេញពាសលើ ផែនដី ទាំងឡោមព័ទ្ធទីដំឡើងត្រសាល របស់ពួកបរិសុទ្ធ ហើយនិងទីក្រុងស្ងួនភ្ងា ដែរ។


109

តែមានភ្លើងធ្លាក់ពីលើមេឃមកអំពីព្រះ បញ្ឆេះគេទាំងអស់ទៅ"

វិវរណៈ ២០:៩


110

សមរភូមិត្រូវបានចប់! គួរឱ្យព្រៀមក្រំ ណាស់ នៅពេលដែលវាអាចមានការខុស គ្នាយ៉ាងដូច្នេះ!

តើអារក្សនឹងទៅជាយ៉ាងណា? ព្រះ គម្ពីរប្រាប់យើងថា:


111

(ព្រះគម្ពីរ វិវរណៈ ២០:១០,១៤,១៥)

"រួចអារក្សដែលនាំគេឱ្យវង្វេង បានត្រូវ បោះទៅក្នុងបឹង ដែលឆេះជាភ្លើង និងស្ពាន់ធ័រ...


112

ចំណែកសេចក្តីស្លាប់និងស្ថានឃុំ ព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុង បឹងភ្លើងដែរ នេះជាសេចក្តីស្លាប់ទី២

# ២៤. អារក្សជាប់ចំណង



113

ហើយក៏មិនឃើញមានអ្នកណាម្នាក់ ដែលបានកត់ក្នុងបញ្ជីជីវិត ត្រូវបានបោះទៅក្នុងបឹងភ្លើងទៀតឡើយ”។
វិវរណៈ ២០:១០,១៤,១៥។
លោកពេត្រុសបានឃើញភ្លើងនេះនៅ ក្នុងការបើកសំដែងមួយ ហើយបានសរសេរ ថាៈ



114

(ព្រះគម្ពីរ ពេត្រុសទី២ ៣:១០)
“...នោះផ្ទៃមេឃនឹងបាត់ទៅ ដោយ សូរគ្រាំគ្រេង ឯធាតុសព្វសារពើនឹងរលាយ ទៅ ដោយកំដៅដ៏ក្រៃលែង



115

ហើយផែនដីនិងការសព្វសារពើ នឹងត្រូវ ឆេះអស់រលីងទៅ”
ពេត្រុទី២ ៣:១០
ពេលនោះសាតាំង ទេវតាអាក្រក់របស់ វា និងអ្នកមានបាបនឹងបាត់បង់រៀងរហូត តទៅ!



116

មិត្តអើយ! លោកអ្នកអាចមានបងប្អូន មិត្តសម្លាញ់ ឬក៏អ្នកជិតស្និទ្ធ ដែលយើង ស្រឡាញ់ពេញចិត្ត ដែលនឹងត្រូវបាត់បង់ រៀងរហូត។
ពិតប្រាកដណាស់ យើងនឹងយំ។ តើវា នឹងទៅជាយ៉ាងណា បើមិនដូច្នោះទេ តើយើងនឹងធ្វើយ៉ាងណា?



117

(ព្រះគម្ពីរ វិវរណៈ ២១:៤)
ប៉ុន្តែដំណឹងល្អនោះគឺ “ព្រះទ្រង់នឹងជូត អស់ទាំងទឹកភ្នែកពីភ្នែកគេចេញ នឹងគ្មាន សេចក្តីស្លាប់



118

ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តី មុនទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ”
វិវរណៈ ២១:៤

# ២៤. អារក្សជាប់ចំណង



119

គឺជាជីវិតអស់កល្បជំមានសិរីល្អ ដែល ព្រះបានសន្យាចំពោះអ្នកបានសង្គ្រោះ!

គំនិតរបស់មនុស្សមិនអាចពិពណ៌នា បាននូវសិរីរុងរឿង និងសម្រស់នៃស្ថានសួគ៌ ដែលព្រះកំពុងរៀបចំ សម្រាប់អ្នកដែល ស្រឡាញ់ និងចង់ដើរតាមទ្រង់នោះ បានឡើយ។

ហើយដើម្បីនឹងគិតអំពីរឿងទាំងអស់នេះ អ្នកអាក្រក់អាចមានអំណរ ក្នុងការដើរតាម ព្រះ ប៉ុន្តែតម្លៃរបស់គេនេះ វាហាក់ដូចជា ខ្ពស់ណាស់សម្រាប់ពួកគេ!

ពួកគេគ្មានបំណងជ្រើសរើសយកព្រះ គ្រីស្ទជាព្រះអង្គសង្គ្រោះរបស់គេឡើយ។

មិត្តអើយ តើថ្ងៃនោះលោកអ្នកនឹងនៅ ក្នុងក្រុមមួយណា?

នៅពេលដែលថ្ងៃនោះមកដល់ វាយឺតពេល នឹងផ្លាស់ប្តូរក្រុមហើយ?

ទោះបីជានៅដើមដំបូងនៃសហស្សវត្សរ៍ ក៏ដោយ នៅពេលព្រះយេស៊ូវយាងមកវិញ វានឹងយឺតពេលហើយ។

ប្រសិនបើលោកអ្នកនឹងស្លាប់នៅពេល នេះក៏ដោយ បើលោកអ្នកមិនបានទទួលព្រះ យេស៊ូវទេនោះ ក៏វាយឺតពេលដែរ

វិធីតែម្យ៉ាងគត់ដើម្បីឱ្យបានជាក់ច្បាស់ ពិតប្រាកដថា លោកអ្នកនៅក្នុងចំណោម ពួកបរិសុទ្ធនៅចុងសហស្សវត្សរ៍ គឺការ ប្រគល់ចិត្តនិងជីវិតរបស់លោកអ្នកទាំងស្រុងថ្វាយព្រះយេស៊ូវឥឡូវនេះ-ថ្ងៃនេះ!



120

ប្រសិនបើលោកអ្នកចង់ថ្វាយជីវិតរបស់ លោកអ្នកទៅព្រះយេស៊ូវយ៉ាងពេញលេញទាំងស្រុង ខ្ញុំសូមអញ្ជើញលោកអ្នកឡើងមក ខាងមុខ ដើម្បីអធិស្ឋានពិសេស។

ប្រសិនបើលោកអ្នកមានបញ្ហានៅក្នុង ចិត្ត សូមអញ្ជើញឡើងមកខាងមុខ ដើម្បី អធិស្ឋានឥឡូវនេះ។

ប្រសិនបើលោកអ្នកមានទម្លាប់អាក្រក់ខ្លះ ដែលលោកអ្នកត្រូវការយកជ័យជំនះលើវា សូមអញ្ជើញមកខាងមុខ ដើម្បីអធិស្ឋាន។

ប្រសិនបើលោកអ្នកកំពុងជួបប្រទះជាមួយនឹងការល្បួង សូមអញ្ជើញមកខាងលើដើម្បី អធិស្ឋាន។

ព្រះយេស៊ូវនឹងឮនូវសេចក្តីអធិស្ឋានរបស់ លោកអ្នក។ ព្រះយេស៊ូវ នឹងឆ្លើយតប ចំពោះសេចក្តីអធិស្ឋានទាំងនោះ។

ខ្ញុំនឹងរង់ចាំបន្តិច តែសូមអញ្ជើញមក ឥឡូវនេះ។

២៤. អារក្សជាប់ចំណង

# ២៥. ការល្អបំផុតដែលនឹងមកដល់!



1

ស្ថានសួគ៌គឺជាការពិត


2

មានរឿងដំណាលពីក្មេងស្រីម្នាក់ ដែលបាន រស់នៅតែក្នុងទីក្រុងពេញមួយ ជីវិតរបស់នាង។ ជាមួយនឹង ពន្លឺភ្លើង ព្រោងព្រាតពេញទីក្រុង ដែលជះពន្លឺ ពាសពេញផ្ទៃមេឃ នាងមិនដែលមានឱកាសបានឃើញផ្កាយសោះឡើយ។

នៅរដូវក្តៅមួយ នាពេលវិស្សមកាល ម្តាយរបស់នាងបាននាំនាងចេញទៅកាន់ជនបទមួយ។


3

នាពេលល្ងាច បន្ទាប់ពីព្រះអាទិត្យ អស្តង្គតទៅហ្វូងតារាបានបញ្ចេញពន្លឺព្រោង ព្រាត នៅលើវេហានារាត្រីកាល ហាក់ បីដូចជាគ្រាប់ពេជ្រ។ កុមារីតូចសំឡឹង មើលទៅលើទាំងអស្ចារ្យក្នុងចិត្ត។ នាងមានការរំភើប នឹងសម្រស់ដ៏ភ្លឺថ្លានៃហ្វូង តារា ពាសពេញផ្ទៃមេឃនេះជាខ្លាំង។

នាងភ្ញាក់ក្រញាង ហើយនិយាយថា "អូម៉ាក់ ប្រសិនបើខាងខុសនៃស្ថានសួគ៌ល្អ យ៉ាងនេះទៅហើយ ចុះទម្រាំងខាងត្រូវវិញ តើល្អយ៉ាងណាទៅ?"



4

(វីដេអូ ៥វិនាទី) ទិសដៅនៃស្ថានសួគ៌

ត្រូវបានមនុស្សប្រុសស្រីមានបំណងចាប់យកពេញទាំងសតវត្សរ៍ក្នុងលោកីយ៍

តើស្ថានសួគ៌ដូចជាអ្វីទៅ? តើវាប្រាកដជាមានពិតមែនទេ? បើមាន តើនៅឯណា ហើយមានខ្លះនៅទីនោះ?


5

មនុស្សខ្លះមិនជឿលើស្ថានសួគ៌ទេ អ្នក ខ្លះនិយាយថា មានស្ថានសួគ៌បី ឬមានស្ថាន សួគ៌ប្រាំពីរ។ អ្នកខ្លះ ទៀតនិយាយថា អ្នក នឹងទៅកាន់ស្ថានសួគ៌ នៅពេលអ្នកស្លាប់ ទៅ។


6

អ្នកខ្លះទៀតនិយាថាទេ អ្នកនឹងទៅ កាន់ស្ថានលាងបាប រួចបន្ទាប់មកប្រហែល ជាទៅស្ថានសួគ៌។


7

អ្នកខ្លះនិយាយថា ស្ថានសួគ៌មិនមែនជា កន្លែងពិតទេ តែវាគ្រាន់តែជាការស្រមើ ស្រមៃប៉ុណ្ណោះ

# ២៥. ការល្អបំផុតដែលនឹងមកដល់!



8

អ្នកខ្លះទៀតជឿថា មនុស្សរាល់គ្នានឹង បញ្ចប់នៅស្ថានសួគ៌ជាយថាហេតុ។ អ្នកខ្លះទៀតនិយាយថាមនុស្ស តិចណាស់ដែលនឹង ទៅដល់ទីនោះ។ មានការច្របូកច្របល់ជា ខ្លាំង! មានគំនិតជាច្រើន!




9

(វីដេអូ ៧វិនាទី) តើហេតុអ្វីបានជាមាន គំនិតខុសគ្នាទាំងអស់នេះ អំពីស្ថានសួគ៌? តើហេតុអ្វីបានជាមានគំនិតនិងទ្រឹស្តី ផ្សេងៗគ្នាអំពីស្ថានសួគ៌យ៉ាងដូច្នេះ នៅពេលដែលព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ ក្រឡែតនោះ?



10

តាមពិត តើអ្នកដឹងថា ព្រះគម្ពីរបញ្ជាក់ យ៉ាងល្អិតល្អន់អំពីស្ថានសួគ៌នេះឬទេ? ព្រះចង់ឱ្យយើងដឹងអំពីស្ថានសួគ៌នោះ ជាយ៉ាងណា ដើម្បីឱ្យយើងប្តេជ្ញាចិត្ត រស់នៅទីនោះ។ ស្ថានសួគ៌មិនមែនជាកន្លែងអាថ៌កំបាំង ដែលព្រះកំពុងលាក់នឹងយើងនោះទេ។



11

នៅតាមអាគារធំៗជាច្រើន មានកូនសោ ដែលចាក់ត្រូវគ្រប់ទ្វារទាំងអស់




12

ម្ចាស់នៃអាគារនោះមានកូនសោនោះ ដែលហៅថា កូនសោមេ។ កូនសោនោះចាក់ត្រូវទ្វារគ្រប់ទាំងអស់




13

ព្រះមានកូនសោមេ ដែលនឹងបើកទ្វារ អំពីអាថ៌កំបាំងនៃស្ថានសួគ៌នេះហើយកូនសោមេនោះគឺព្រះ គម្ពីរ_ជាប្រភពពតឹមានតែ មួយគត់ដែលគួរឱ្យជឿបានរបស់យើង។

សំណាងល្អណាស់ដែលយើងមិនចាំបាច់ពឹងផ្អែកលើទ្រឹស្តី ឬគំនិតរបស់មនុស្ស។

យើងមិនចាំបាច់ភាន់ច្រឡំ អំពីការពិត នៃស្ថានសួគ៌នោះឡើយ។



14

សាវកពេត្រុសសរសេរអំពីប្រភពនៃពតឹមាននេះ។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


15

(ព្រះគម្ពីរ ពេត្រុសទី២ ១:១៩)

"ហើយយើងខ្ញុំមានពាក្យទំនាយដ៏ពិត ជាង ដែលគួរឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់ តាមដូចជាតាមចង្កៀង ដែលភ្លឺក្នុងទីងងឹត


16

ទាល់តែថ្ងៃភ្លឺឡើង ហើយផ្កាយព្រឹករះឡើង ក្នុងចិត្តអ្នករាល់គ្នា" ពេត្រុសទី១ ១:៩


17

ព្រះបានបើកសំដែងនៅក្នុងព្រះបន្ទូល របស់ទ្រង់:

តើស្ថានសួគ៌នៅឯណា

តើស្ថានសួគ៌នោះយ៉ាងណាទៅ

តើរាជធានីនៃស្ថានសួគ៌នៅឯណា

តើមនុស្សនឹងធ្វើអ្វីនៅទីនោះ

តើមនុស្សនៅទីនោះយ៉ាងដូចម្តេច

តើរាជធានីនោះដូចម្តេចទៅ


18

ឥឡូវនេះ សូមយកកូនសោមេរបស់ព្រះ-ព្រះគម្ពីរ ហើយរកមើលនូវគ្រប់អនាគតពិតដែលព្រះបានរៀបចំសម្រាប់អ្នកដើរតាមទ្រង់។


19

សៀវភៅចុងក្រោយបង្អស់នៃព្រះគម្ពីរ

វិវរណៈ ព្រះអង្គបានបើកសំដែងឱ្យ លោកយ៉ូហានឃើញអំពី រូបភាពនៃអនាគតដោយព្រះអង្គផ្ទាល់។

លោកយ៉ូហានបានពណ៌នាអំពីអ្វីដែលគាត់បានឃើញ:


20

(ព្រះគម្ពីរ វិវរណៈ ២១:១,២)

"រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លង បាត់ទៅហើយ

# ២៥. ការល្អបំផុតដែលនឹងមកដល់!


21

ក៏គ្មានសមុទ្រទៀតឡើយ


22

ហើយយ៉ូហានខ្ញុំក៏ឃើញទីក្រុងបរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មក ពីព្រះ


23

គាត់តែងដូចជាប្រពន្ធថ្មោងថ្មី តែងខ្លួន ទទួលប្ដី" វិវរណៈ ២១:១,២។


24

ទស្សនីយភាពមួយចំនួន បានបង្ហាញឱ្យ ឃើញ នូវការរីករាយ និងសម្រស់ដែលកូន ក្រមុំមានក្នុងការរៀបចំ សម្រាប់ថ្ងៃ អាពាហ៍ពិពាហ៍របស់នាង!


25

ដំណាក់នៅស្ថានសួគ៌នេះ មិនមែនជា ដំណាក់ដែលមានតែលោកយ៉ូហានបានឃើញនោះទេ.ហោរារបស់ព្រះគ្រប់កាលសម័យ បានដឹងអំពីការនេះ។

សូមស្ដាប់:


26

(ព្រះគម្ពីរ កិច្ចការ ៣:២០,២១)

(វីដេអូ ៤វិនាទី)

"ហើយដែលទ្រង់បានចាត់ព្រះអង្គនោះ

ដែលបានដំរូវទុកជាមុនមកឯអ្នករាល់គ្នា គឺ ជាព្រះយេស៊ូវគ្រីស្ទ


27

ដែលស្ថានសួគ៌ត្រូវទទួល ដរាបដល់គ្រា តាំងរបស់ទាំងអស់ឡើងវិញ


28

ដែលព្រះបានមានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធរបស់ទ្រង់តាំងពីបុរាណមក" កិច្ចការ ៣:២០,២១។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


29

តើព្រះអង្គនឹងស្តារនាអ្វីឡើងវិញ?

ព្រះនឹងស្តារនាឡើងវិញ នូវអ្វីៗទាំង អស់ ដែលអ័ដាម និងអេវ៉ាបានបាត់បង់!

ផែនដីបានចេញមកពីព្រះហស្តរបស់ ព្រះដ៏បង្កបង្កើត ក្នុងភាពដ៏រុងរឿង និង គ្រប់លក្ខណ៍ ស្អាតល្អមិនអាចពិពណ៌នា បាន។


30

ព្រះអាទិករ ព្រះអង្គបានរៀបចំ និងតុបតែងផ្ទះរបស់អ័ដាម និងនាងអេវ៉ា នៅសួនច្បារអេដែន ជាស្ថានសួគ៌មួយ ដោយព្រះអង្គផ្ទាល់។

ព្រះបានប្រទានដល់គេនូវអំណាចនៅលើ ផែនដីនេះ។


31

ពួកគេមានសុខភាព សេចក្តីស្រឡាញ់ ការរីករាយ អំណរដ៏គ្រប់លក្ខណ៍ ហើយ និងបានដើរជាមួយព្រះទល់មុខនឹងព្រះភ័ក្ត្រ។ អ្វីៗទាំងអស់មានការសុខសាន្ត និងចុះស្រុះស្រួលគ្នាជាទីបំផុត។ គេមិនដែលឈឺ ឬស្លាប់ ឡើយ បើគេជ្រើសរើស ការស្តាប់បង្គាប់ នូវការណែនាំរបស់ព្រះ។


32

ហើយការណែនាំរបស់ទ្រង់នោះគឺៈ "មិនត្រូវបរិភោគផ្លែនៃដើមឈើដែលបាន ហាមឃាត់នៅក្នុងសួនច្បារ អេដែននោះ ឡើយ ពុំនោះទេ នោះអ្នកនឹងស្លាប់"


33

ប៉ុន្តែគេជ្រើសរើស បរិភោគផ្លែនោះ វិញ។ ពួកគេបានស្តាប់តាមការបោកបញ្ឆោតរបស់ទេវតាប្រឆាំង ដ៏អាក្រក់ ឈ្មោះសាតាំង ជាជាងស្តាប់ព្រះដែល ជាទីស្រឡាញ់ និងជាអ្នកថែរក្សាគេទៅវិញ។


34

ក្រោយនោះមក ជាដំបូងបង្អស់នៅក្នុង ជីវិតរបស់គេ ពួកគេមានអារម្មណ៍ថា មានទោសអៀនខ្មាស និងភ័យខ្លាច។ វាគឺជាថ្ងៃ ដ៏គួរឱ្យសោកស្តាយនិងខ្លោចផ្សាបំផុត នៃប្រវត្តិសាស្ត្ររបស់ភពផែនដីនេះ។

ដោយសារការមិនស្តាប់បង្គាប់របស់ពួក គេ នាំឱ្យពួកគេបានបាត់បង់អ្វីៗទាំងអស់ លំនៅនៅក្នុងសួនច្បាររបស់គេ អំណាច លើផែនដីរបស់គេ ហើយនិងកាប្រើប្រាស់ ដើមជីវិតរបស់ពួកគេ។ ដោយមិនអាច បរិភោគផ្លែពីដើមជីវិតបាន ពួកគេនឹងត្រូវ ស្លាប់ជាយថាហេតុ។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


35

គេគ្មានជីវិតអស់កល្បតទៅទៀតឡើយ។ ភាពរីករាយ និងសេចក្ដីស្រឡាញ់ ហើយនិងការជួបជុំជាមួយព្រះរបស់ពួកគេ ត្រូវ បានបញ្ចប់។

ពិភពដ៏គ្រប់លក្ខណ៍របស់ យើង បាន ក្លាយទៅជាវិនាសអន្តរាយដោយសារតែបណ្ដាសានៃអំពើបាប។

ផែនដីបានក្លាយទៅជាកន្លែងដែលពោរ ពេញទៅដោយទុក្ខព្រួយ និងការឈឺចាប់ដោយសារជម្ងឺនិងសេចក្ដីស្លាប់។

អ័ដាម និងអេវ៉ា លែងជាម្ចាស់តទៅទៀតហើយ ពួកគេក្លាយទៅជាទាសករទៅវិញ។



36

(ព្រះគម្ពីរ រ៉ូម ៦:១៦)

ប៉ុលបាននិយាយថា "តើអ្នករាល់គ្នាមិន ដឹងទេឬអីថា អ្នករាល់គ្នាប្រគល់ខ្លួនទៅ ធ្វើជាបាវបំរើ និងស្ដាប់តាមចៅហ្វាយណា



37

នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះឯង" រ៉ូម ៦:១៦

ប៉ុន្តែព្រះដ៏ជាទីស្រឡាញ់និងយកព្រះទ័យ ទុកដាក់ ព្រះអង្គទ្រង់បានជ្រាប។ ពស់បាន បញ្ឆោតអ័ដាម និងអេវ៉ា។ ព្រះបានស្រ ឡាញ់គេខ្លាំងណាស់ ទ្រង់មិនអាចចាកចេញពីកូនចៅដែលប្រព្រឹត្តខុសឆ្គងរបស់ទ្រង់ដោយទុកឱ្យគេគ្មានសេចក្ដីសង្ឃឹមឡើយ។


38

នៅឯក្លោងទ្វារសួនច្បារ ព្រះបានសន្យា ជាមួយ អ័ដាម និងអេវ៉ាថា ថ្ងៃណាមួយ ព្រះរាជបុត្រារបស់ទ្រង់ ពូជរបស់ស្ត្រី នឹង យាងមក ហើយសុគតជំនួសគេ ដើម្បីឱ្យគេអាចស្ដាបនាជាគ្រួសាររបស់ព្រះ និង មានជីវិត អស់កល្បឡើងវិញបាន។



39

(ព្រះគម្ពីរ លោកុប្បត្តិ ៣:១៥)

"អញនឹងធ្វើឱ្យឯងហើយនិងស្ត្រី គឺទាំង ពូជឯងនិងពូជនាង មានសេចក្ដីខ្មាំងនឹងគ្នា



40

ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹង ចឹកកែងជើងគេ" លោកុប្បត្តិ ៣:១៥។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


41

នៅពេលដែលជំនាន់មនុស្សបានកន្លង ផុតទៅ ហើយមនុស្សក៏កាន់តែចំរើនឡើង នៅលើផែនដីនេះ អំពើបាបក៏បានចំរើន ឡើងដែរ។ មនុស្សជាតិ បានភ្លេចព្រះ
និងសេចក្តីសន្យារបស់ទ្រង់ស្ទើរតែអស់រលីង។


42

(ព្រះគម្ពីរ លោកុប្បត្តិ ៦:៥)

មនុស្សបានក្លាយជាអាក្រក់ និង អសីលធម៌ ហើយ "ព្រះយេហូវ៉ាទ្រង់ ឃើញថា
ការអាក្រក់របស់មនុស្សបាន
ចម្រើនជាច្រើនឡើងនៅផែនដី


43

ហើយអស់ទាំងគំនិតក្នុងចិត្តគេ ក៏សុទ្ធតែ អាក្រក់ជានិច្ចដូច្នោះ" លោកុប្បត្តិ ៦:៥


44

វាបានក្លាយជាការចាំបាច់សំរាប់ព្រះ ដែលទ្រង់នឹងត្រូវតែបំផ្លាញមនុស្សអាក្រក់ ដោយទឹកជំនន់ដ៏ធំ ដើម្បីនឹងរក្សាជីវិតនៅ លើផែនដីនេះ! ក្រោយពីទឹកជំនន់ដ៏ធំនោះ មក មិនទាំងបានប៉ុន្មានជំនាន់ផង ពួកគេ ក៏បានក្លាយទៅជាមនុស្សពុករលួយម្តងទៀត។


45

ដើម្បីនឹងរក្សាមនុស្សនៅលើផែនដីនេះ ព្រះទ្រង់បានហៅអ័ប្រាហាំ និងគ្រួសារ របស់គាត់ឱ្យចេញពី
ការកំផិត និងការ
ពុករលួយនៃទីក្រុងអើររបស់ពួកខាល់ដេរ។ គ្រួសាររបស់គាត់គ្មានការងឿងឆ្ងល់ទេថា គេនឹងក្លាយជាមនុស្សអាក្រក់ ប្រសិនបើរស់នៅក្នុង ទីក្រុងជាមួយនឹង ពួកមនុស្សអាក្រក់ទាំងនោះ។


46

(ព្រះគម្ពីរ លោកុប្បត្តិ ១២:១,២)

ព្រះបានមានបន្ទូលទៅកាន់អ័ប្រាហាំថា "...ចូរឯងចេញពីស្រុក ពីញាតិសន្តាន និងពីផ្ទះឪពុកឯង ទៅនៅឯស្រុកដែលអញ នឹងបង្ហាញឯងចុះ


47

អញនឹងបង្កើតនគរ១យ៉ាងធំពីឯង អញ នឹងឱ្យពរដល់ឯងទាំងលើកឈ្មោះឯងជាធំផង
ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្ស
ទាំងឡាយ" លោកុប្បត្តិ១២:១,២។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


48

លោកអ័ប្រាហាំបានសុខចិត្តលះចោល ផ្ទះសំបែងដ៏មនោរម្យនៅស្រុកខាល់ដេ។ គាត់មិនបានដឹងថា គាត់បានធ្វើដំណើរទៅ ទីណាឡើយ ប៉ុន្តែគាត់ក៏ពុំបានឃើញអ្វីដែលព្រះបានរៀបទុកសំរាប់គាត់ដែរ


49

(ព្រះគម្ពីរ ហេព្រើរ ១១:៩,១០)

"ដោយសារសេចក្តីជំនឿ នោះលោក បានស្នាក់នៅក្នុងស្រុកដែល ទ្រង់សន្យាឱ្យ ដូចជានៅប្រទេសដទៃ


50

ក៏នៅតែក្នុងត្រសាលជាមួយនឹងអ៊ីសាក ហើយនិងយ៉ាកុបជាអ្នកគ្រងសេចក្តីសន្យា ដដែលទុកជាមរតកជាមួយគ្នា


51

ពីព្រោះលោករង់ចាំក្រុងមួយដែលមាន ឫសជញ្ជាំង ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់" ហេព្រើរ ១១:៩,១០។ ព្រះបានសន្យាថា នឹងប្រទានដល់លោកអ័ប្រាហាំ និងកូនចៅរបស់គាត់នូវអ្វីៗទាំងអស់ដែលអ័ដាម និង

អេវ៉ាបានបាត់បង់។


52

ហោរានៅគ្រប់កាលសម័យបានជឿ និងសំឡឹងមើលទៅរកការស្តាបនាឡើងវិញនូវអ្វីៗទាំងអស់នោះ។

ព្រះទ្រង់បានធ្វើបញ្ជីខ្លះៗ នៃសេចក្តី ជំនឿមហាសាលនេះនៅក្នុង


53

ព្រះគម្ពីរហេព្រើរជំពូក១១។ អ័ប្រាហាំ អេណុក ណូអេ អេបិល អ៊ីសាក រ៉ាហាប ដាវីឌ និងសាំយូអែល គឺជាអ្នកដែលមាន ជំនឿយ៉ាងខ្លាំង ដែលជឿលើសេចក្តី សន្យារបស់ព្រះ ដែលទ្រង់នឹង ស្តាបនាឡើងវិញនូវអ្វីៗដែលអ័ដាម និង អេវ៉ាបានបាត់បង់។ សូមកត់សំគាល់អំពីការដែលព្រះគម្ពីរនិយាយអំពីបុរសទាំងអស់នោះៈ


54

(ព្រះគម្ពីរ ហេព្រើរ ១១:១៣,១៦)

"ពួកអ្នកទាំងនោះបានស្លាប់ទៅក្នុង សេចក្តីជំនឿឥតទទួល សេចក្តីសន្យាទាំង ប៉ុន្មានទេ តែគេបានឃើញពីចម្ងាយ

ហើយក៏ទទួលគំនាប់ដែរ...

# ២៥. ការល្អបំផុតដែលនឹងមកដល់!


55

តែឥឡូវនេះ គេសង្វាតចង់បានស្រុក១ ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះគ្មានសេចក្ដីខ្មាស ដោយគេហៅទ្រង់ថា ជាព្រះ


56

នៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំ ទីក្រុងមួយឱ្យគេហើយ”
ហេព្រើរ ១១:១៣,១៦។


57

លោកអេសាយ ជាហោរាម្នាក់
ដែលជាអ្នកនាំដំណឹងពីព្រះមែសី បានផ្ដល់ ដល់យើងនូវការពណ៌នាដ៏រំភើប ស្ដីពីការស្ដាបនាឡើងវិញ ដែលព្រះទ្រង់បាន រៀបចំ សូមយើងក្រឡេកមើលទៅឯការដែលព្រះទ្រង់បានបើកសំដែងឱ្យលោកអេសាយ ឃើញ:


58

(ព្រះគម្ពីរ អេសាយ ៦៥:១៧)
ដ្បិតមើល អញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនិងផែនដីថ្មី:


59

ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំ ទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ” អេសាយ ៦៥:១៧។


60

(ព្រះគម្ពីរ អេសាយ ៦០:១៨)
ហើយម្ដងទៀត “នៅក្នុងស្រុកឯងនឹង មិនដែលឮនិយាយពីសេចក្ដីច្រឡោតទៀត ឬពីការរឹបជាន់ ឬពីការបំផ្លាញនៅព្រំដែន ឯងឡើយ


61

គឺឯងនឹងហៅកំផែងឯងថា សេចក្ដី សង្គ្រោះ ហើយទ្វារឯងថា សេចក្ដីសរសើរ ”អេសាយ ៦០:១៨។

# ២៥. ការល្អបំផុតដែលនឹងមកដល់!



62

(វីដេអូ ១៨វិនាទី) សូមគិតមើល -គ្មាន អំពើហឹង្សានៅទីនោះឡើយ! មានតែសេចក្ដី សុខសាន្តនិង ភាពស្រុះស្រួលគ្នាប៉ុណ្ណោះ! តើនោះមិនមែនជាការអស្ចារ្យ ដែលនឹងត្រូវ គិតដល់ទេឬអី? នៅទីនោះ មិនចាំបាច់ ត្រូវការគ្រឿងអាវុធ ដើម្បីទប់ទល់ និង ការពារខ្លួនឡើយ។

គ្មានអ្នករំលោភ ឬចោរឡើយ! ហើយ តើវាមិនមែនអស្ចារ្យទេឬអីដែលដើរនៅលើ ផ្លូវដែលធ្វើពីមាសទាំងនោះ ដោយគ្មាន ខ្វល់ខ្វាយអំពីការប្រយុទ្ធ ឬត្រូវចោរប្លន់ សោះនោះ? ប៉ុន្តែមិនមែនមានតែប៉ុណ្ណោះ ទេ ដែលហោរាប្រាប់យើងនោះ។ សូមស្ដាប់:


63

(ព្រះគម្ពីរ អេសាយ ១១:៦)

ឱ្យនៅគ្រានោះឆ្កែព្រៃ នឹងនៅជាមួយ នឹងកូនចៀម ឯខ្លារខិន នឹងដេកនៅជាមួយ នឹងកូនពពែ...


64

ហើយកូនក្មេងតូចៗ ជាអ្នកគង្វាលវា" អេសាយ ១១:៦។


65

ឥឡូវនេះ សូមស្ដាប់នូវអ្វីៗទៀតដែល ព្រះគម្ពីរបានប្រាប់យើងអំពីភពផែនដីនេះនៅ ពេលដែលវាត្រូវបាន ស្ដាបនាឡើងវិញនៅគ្រាចុងក្រោយ ទៅកាន់សម្រស់ដើមរបស់ខ្លួនវិញនោះ:


66

(ព្រះគម្ពីរ អេសាយ ៣៣:២៤)

"ឯពួកអ្នកដែលនៅក្នុងក្រុង គេនឹងមិន ថា ខ្ញុំឈឺទៀតឡើយ" អេសាយ ៣៣:២៤ គ្មានជម្ងឺបេះដូង គ្មានជម្ងឺមហារីក គ្មានការ រលាក-មានតែសុខភាពល្អជារៀងរហូត!

តើនេះមិនមែនជាដំណឹងដ៏ល្អទេឬអី?


67

(ព្រះគម្ពីរ អេសាយ ៣៥:៥)

"គ្រានោះភ្នែករបស់មនុស្សខ្វាក់នឹងបាន ភ្លឺឡើង" អេសាយ៣៥:៥។

គ្មានអ្វីគួរឱ្យឆ្ងល់ឡើយ ការងារដំបូង ដែលអ្នកខ្វាក់ធ្វើនោះ គឺការចង់ឃើញព្រះ ភ័ក្ត្ររបស់ព្រះយេស៊ូវ!

អូ នោះតើជាថ្ងៃដ៏រុងរឿងអស្ចារ្យ សម្រាប់អ្នកដែលធ្លាប់ខ្វាក់ភ្នែក!

# ២៥. ការល្អបំផុតដែលនឹងមកដល់!


68

(ព្រះគម្ពីរ អេសាយ ៣៥:៥,៦)

...ភ្នែករបស់មនុស្សខ្វាក់ នឹងបានភ្លឺ ឡើង ហើយត្រចៀករបស់មនុស្សថ្លង់នឹង ឮបាន"។


69

"គ្រានោះ ពួកមនុស្សខ្វិននឹងលោតដូច ជាប្រើស" អេសាយ ៣៥:៦, អេសាយ ៣៥:៥,៦។ គ្មានរទេះរុញទៀតឡើយ! គ្មាន ឈើច្រត់ទៀតឡើយ! មនុស្សគ្រប់គ្នានឹង មានរូបរាងគ្រប់លក្ខណៈទាំងអស់។


70

(ព្រះគម្ពីរ អេសាយ ៣៥:៦)

"...ហើយអណ្តាតរបស់មនុស្សគ ក៏នឹង ច្រៀងឡើង" អេសាយ ៣៥:៦។

ពួកគេមិនមែនគ្រាន់តែនិយាយប៉ុណ្ណោះ ទេ តែពួកគេថែមទាំងច្រៀងទៀតផង!

តើថ្ងៃនោះជាថ្ងៃសប្បាយយ៉ាងណាទៅ!

ប៉ុន្តែមានដំណឹងល្អជាច្រើនជាងនេះ ទៅទៀត!


71

(ព្រះគម្ពីរ អេសាយ ៣៥:១)

"ទីរហោស្ថាន ហើយទីហួតហែង នឹងមានសេចក្តីអំណរ ឯសមុទ្រខ្សាច់នឹង រីករាយ ហើយផ្កាឡើងដូចជាកុឡាប" អេសាយ៣៥:១។ តើផែនដីថ្មីនោះ ជា កន្លែងល្អយ៉ាងណាទៅ!


72

(ព្រះគម្ពីរ អេសាយ ៦៥:២១,២២)

"គ្រានោះ មនុស្សនឹងសង់ផ្ទះ ហើយ នឹងអាស្រ័យនៅផង ក៏នឹងដាំចំការទំពាំង បាយជូរ ហើយនិងបរិភោគផលដែរ


73

គេនឹងមិនសង់ រួចមានម្នាក់ទៀត អាស្រ័យនៅ ឬដាំ រួចមានម្នាក់ទៀត បរិភោគផលនោះឡើយ


74

ដ្បិតអាយុរបស់រាស្ត្រអញនឹងបានវែងដូចជា អាយុនៃដើមឈើ ហើយពួករើសតាំងរបស់ អញនឹងប្រើប្រាស់ការដែលដៃគេធ្វើជា យីនយូរទៅ" អេសាយ ៦៥:២១,២២។

# ២៥. ការល្អបំផុតដែលនឹងមកដល់!


75

វាជាការពិតប្រាកដណាស់ ដែលស្ដាប់ ទៅ ស្ថានសួគ៌ គឺជាកន្លែងដ៏ពិតប្រាកដ ដែលមានមនុស្សពិតប្រាកដ ដែលធ្វើការ ច្បាស់លាស់ តើវាអញ្ជឹងមែនឬទេ? តាមពិត យើងនឹងមានឈ្មោះផ្ទាល់របស់ យើង ហើយមនុស្សនៅទីនោះនឹងស្គាល់ យើង!


76

(ព្រះគម្ពីរ អេសាយ ៦៦:២២,២៣)

ឱ្យផ្សិតផ្ទៃមេឃថ្មី និងផែនដីថ្មី ដែល អញនឹងបង្កើតឡើងនោះ នឹងស្ថិតស្ថេរនៅចំពោះអញជាយ៉ាងណា ព្រះយេហូវ៉ាទ្រង់ មានបន្ទូលថា


77

ពូជពង្សរបស់ឯង និងឈ្មោះឯងរាល់គ្នា ក៏នឹងស្ថិតស្ថេរនៅយ៉ាងនោះដែរ” អេសាយ ៦៦:២២.


78

“គ្រានោះនឹងកើតមានដូច្នេះថា ចាប់ តាំងពីថ្ងៃចូលខែ១ ដរាបដល់ថ្ងៃចូលខែ១ ទៀត ហើយពីថ្ងៃឈប់សំរាក១ ដរាបដល់ ថ្ងៃឈប់សំរាក១ទៀត


79

នោះគ្រប់មនុស្សទាំងអស់នឹងមកក្រាបថ្វាយ បង្គំនៅចំពោះអញ នេះជាព្រះបន្ទូលនៃព្រះ យេហូវ៉ា” អេសាយ ៦៦:២៣

ផែនដីថ្មីនឹងជាកន្លែងដ៏សប្បាយរីករាយ ជាកន្លែងដែលពោរពេញទៅដោយអំណរ សម្រាប់ព្រះនិងរាស្ត្ររបស់ទ្រង់។


80

(ព្រះគម្ពីរ អេសាយ ៣៥:១០)

ឯពួកអ្នកដែលព្រះយេហូវ៉ាបានប្រោស ឱ្យរួច គេនឹងវិលមកវិញ គេនឹងមកដល់ ក្រុងស៊ីយ៉ូនដោយច្រៀង


81

ហើយនិងមានសេចក្ដីអំណរដ៏នៅអស់កល្បជានិច្ច ពាក់នៅលើក្បាលគេ គេនឹងបាន សេចក្ដីត្រេកអរ និងសេចក្ដីរីករាយ ឯអស់ ទាំងសេចក្ដីទុក្ខព្រួយ និងដំងូរទាំងប៉ុន្មាន នោះនឹងរត់បាត់ទៅ” អេសាយ ៣៥:១០។

តើស្ដាប់ទៅមិនគួរឱ្យរំភើបឬទេ?

# ២៥. ការល្អបំផុតដែលនឹងមកដល់!


82

វាជាពិធីបុណ្យដ៏រីករាយ និងអស្ចារ្យ
នៅពេលដែលអ្នកបានសង្គ្រោះចូលទៅឯ
ទីក្រុងបរិសុទ្ធរៀងរាល់ថ្ងៃបរិសុទ្ធ ដើម្បី នឹងសរសើរ ច្រៀង និងប្រកបជាមួយ នឹងព្រះ។


83

ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់កំពុង រៀបចំដំណាក់ឱ្យយើងគ្រប់ៗគ្នា។
មែនហើយ! សូមរីករាយចំពោះដំណាក់នោះ ចុះ ប៉ុន្តែលោកអេសាយបាននិយាថា យើង
ក៏នឹងសង់ផ្ទះដែរ!
មែនហើយ! ប្រហែលជាយើងនឹងមានផ្ទះនៅ ជនបទដែលយើងនឹងត្រូវសង់ដោយផ្ទាល់
ហើយរៀងរាល់ចុងសប្តាហ៍
យើងនឹងធ្វើដំណើរទៅ កាន់រាជធានីនៃ ផែនដីថ្មីនោះ ហើយប្រើដំណាក់របស់យើង
នៅក្នុងទីក្រុងនោះ



84

(វីដេអូ ៧វិនាទី) រូបភាពនៃស្ថានសួគ៌នៅ ក្នុងព្រះគម្ពីរច្បាស់លាស់ណាស់។ ព្រះនឹង បង្កើតផ្ទៃមេឃថ្មី
ស្ថានសួគ៌ថ្មី និងផែន ដីថ្មី។ ទីក្រុងបរិសុទ្ធ ទីក្រុងយេរូសាឡិមថ្មី នឹងមកពីព្រះនៅស្ថានសួគ៌។
ផែនដី ភពដែលមានការបះបោរនេះ ត្រូវរលំដោយអំពើបាប នឹងក្លាយទៅជារាជ
ធានីនៃពិភពចក្រវាលទាំងមូល។ វាអាច នឹងធ្វើឱ្យអ្នកភ្ញាក់ផ្អើល ប៉ុន្តែ ផែនដីនេះ
នឹងត្រូវក្លាយជាលំនៅស្ថានរបស់អ្នកដែលបានសង្គ្រោះ។ ព្រះយេស៊ូវបានមានបន្ទូលអំពី
រឿងនេះយ៉ាងដូច្នេះ។


85

(ព្រះគម្ពីរ ម៉ាថាយ ៥:៥)
"មានពរហើយអស់អ្នកណាដែលស្លូត ត្រង់ ដ្បិតអ្នកទាំងនោះនឹងគ្រងផែនដីជា មរតក" ម៉ាថាយ
៥:៥។
ព្រះនឹងស្តាបនាភពផែនដីនេះឡើងវិញ ទៅជាភាពល្អឥតខ្ចោះដូចដើមវិញ។
ហើយវានឹងក្លាយទៅជាផែនដីថ្មីដ៏រុងរឿង អស្ចារ្យ!


86

ប្រហែលជាលោកអ្នកនៅចាំបាននូវ សេចក្តីសន្យាដ៏អស្ចារ្យខ្លះ ដែលព្រះយេស៊ូវ
បានប្រទានដល់ពួកសាវក និងអ្នកដែលដើរ តាមទ្រង់គ្រប់វ័យទាំងអស់ មុនទ្រង់យាង
ត្រឡប់ទៅកាន់ស្ថានសួគ៌វិញ.


87

(ព្រះគម្ពីរ យ៉ូហាន ១៤:១-៣)
"កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ ខ្ញុំដែរ

# ២៥. ការល្អបំផុតដែលនឹងមកដល់!


88

នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំមានទី លំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់អ្នក រាល់គ្នាហើយ...


89

បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះ ខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នា ទៅឯខ្ញុំ


90

ប្រយោជន៍ឱ្យអ្នករាល់គ្នាបាននៅ កន្លែង ដែលខ្ញុំនៅនោះដែរ”។

យ៉ូហាន ១៤:១-៣។


91

(ព្រះគម្ពីរ ម៉ាថាយ ៦:១០)

គំរូនៃសេចក្ដីអធិស្ឋានដែលព្រះយេស៊ូវ បានបង្រៀនដល់ពួកសាវក និយាយថា

“សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យព្រះ ហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចនៅ ស្ថានសួគ៌ដែរ”

ម៉ាថាយ ៦:១០។

ត្រង់នេះយើងឃើញថា ព្រះយេស៊ូវសុំ ឱ្យយើងអធិស្ឋាន សម្រាប់ការស្ដាបនានូវ អ្វីៗទាំងអស់ឡើងវិញ។


92

ឥឡូវនេះ សូមពិចារណាឱ្យបានល្អិត ល្អន់ថែមទៀតអំពីទីក្រុងដ៏ប្រណិត ដែល លោកយ៉ូហានបាន ឃើញនៅក្នុងការជាក់ ស្ដែងនៅកោះផាត់ម៉ូស។ ហោរាហាក់ដូច ជាមានការពិបាកនឹងរកពាក្យ ដើម្បីនឹង

បញ្ជាក់ អំពីភាពដ៏អស្ចារ្យរបស់ ទីក្រុង បរិសុទ្ធនោះណាស់។

ព្រះគម្ពីរនិយាយថា:


93

(ព្រះគម្ពីរ កូរិនថូសទី១ ២:៩)

“...សេចក្ដីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែល ដល់

# ២៥. ការល្អបំផុតដែលនឹងមកដល់!


94

គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់” កូរិនថូសទី១ ២:៩។
ប៉ុន្តែសូមចាំបន្តិច។ មនុស្សជាច្រើនមិន បានអានខបន្ទាប់ ដែលនិយាយថា:


95

(ព្រះគម្ពីរ កូរិនថូសទី១ ២:១០)
ព្រះទ្រង់បានសំដែង ឱ្យយើងរាល់គ្នា ឃើញសេចក្តីទាំងនេះ ដោយសារព្រះ វិញ្ញាណទ្រង់...”


96

លោកអ្នកឃើញទេ ព្រះបានបើក សំដែងរឿងទាំងនេះ ដោយសារព្រះ
វិញ្ញាណបរិសុទ្ធទៅដល់ពួកហោរា ដែល បានសរសេរទុកសំរាប់យើងទាំងអស់គ្នា
ហើយគ្មានអ្វីដែលត្រូវថ្កល់នោះទេ ពាក់ កណ្តាលទៀតមិនទាន់ត្រូវបានប្រាប់នៅឡើយ!


97

មិត្តទាំងឡាយអើយ នោះហើយគឺជា របៀបដែលព្រះបានធ្វើដល់លោកយ៉ូហាន ហោរាអេសាយ
ហើយនិងហោរាផ្សេង១ ទៀតជាច្រើន។ វាពិតទាំងអស់-ហើយពាក់
កណ្តាលទៀតមិនទាន់ត្រូវបានប្រាប់នៅឡើយ!
នៅពេលដែលលោកយ៉ូហានបើក បង្ហាញ នូវការបកស្រាយអំពីទីក្រុងបរិសុទ្ធ នោះ
វាហាក់ដូចជារឿងយ៉ាងអស្ចារ្យដ៏លើស
លប់មួយ ដែលពិបាកនឹងជឿណាស់។
ប៉ុន្តែយើងមានព្រះបន្ទូលរបស់ ព្រះសម្រាប់បញ្ជាក់ដល់យើងអំពីការទាំងអស់
នេះ! នេះគឺ ជាអ្វីដែលលោកយ៉ូហានបាន ឃើញ



98

(វីដេអូ ១១វិនាទី) លោកយ៉ូហាននិយាយ
ថា គាត់បានឃើញផ្ទៃមេឃថ្មី ស្ថានសួគ៌ថ្មី និង ផែនដីថ្មី ហើយគ្មានសមុទ្រទៀតឡើយ។
រួចគាត់ឃើញទីក្រុងបរិសុទ្ធចុះមកពីស្ថាន សួគ៌។ រួចទ្រង់បានប្រាប់យើង អំពីទីក្រុង នោះ:


99

(ព្រះគម្ពីរ វិវរណៈ ២១:១,២,៣,១១, ១៧,២១)
“រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លង បាត់ហើយ
ក៏គ្មានសមុទ្រទៀតដែរ” វិវរណៈ ២១:១


100

“ហើយយ៉ូហានខ្ញុំក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មក ពីព្រះ
គាត់តែងដូចជាប្រពន្ធថ្មោងថ្មី តែង ខ្លួនទទួលប្តី” វិវរណៈ ២១:២

# ២៥. ការល្អបំផុតដែលនឹងមកដល់!


101

"ខ្ញុំក៏មានឮសំឡេងយ៉ាងខ្លាំង ចេញពី ស្ថានសួគ៌មកថា មើលរោងឧបោសថរបស់ព្រះបាននៅជាមួយនឹងមនុស្សហើយ


102

ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជា រាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ ក៏នឹងធ្វើជាព្រះដល់គេ" វិវរណៈ ២១:៣


103

"...ហើយពន្លឺរស្មីរបស់ទីក្រុងនោះ ក៏ ដូចជាត្បូងមានតម្លៃថ្លៃវិសេស គឺដូចជាត្បូង មណីជាតិ ហើយថ្លាដូចជាកែវចរណៃ" វិវរណៈ ២១:១១


104

"ក៏វាស់កំផែងឃើញ ១៤៤ហត្ថ
(៦៦ម៉ែត្រ)..." (ខ១៧)


105

"ទ្វារទាំង១២ ជាកែវមុក្តា១២..." (ខ២១)


106

(ព្រះគម្ពីរ វិវរណៈ ២១:១២,២១,២៣)
"...ក្រុងនោះមានកំផែងធំ ហើយខ្ពស់ ...ហើយមានឈ្មោះឆ្លាក់ទុក ដែលជាឈ្មោះរបស់ពូជអំបូរជនជាតិអ៊ីស្រាអែលទាំង១២"
(ខ១២)


107

"...ហើយផ្លូវក្រុងក៏ធ្វើពីមាសសុទ្ធថ្លា ដូចជាកែវ" (ខ២១)

# ២៥. ការល្អបំផុតដែលនឹងមកដល់!


108

"ក្រុងនោះមិនត្រូវការនឹងព្រះអាទិត្យ ឬព្រះច័ន្ទ សម្រាប់នឹងបំភ្លឺទេ ដ្បិតសិរីល្អ នៃព្រះបានបំភ្លឺហើយ ឯកូនចៀមក៏ជាចង្កៀង
នៃទីក្រុងនោះដែរ"
(ខ២៣)


109

(ព្រះគម្ពីរ វិវរណៈ ២២:១,២,៥)
"...ទន្លេទឹកជីវិតថ្លាដូចជាកែវចរណៃ ដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម"


110

"...ហើយនៅមាត់ទន្លេទាំងសងខាង នោះ មានដើមជីវិត ដែលបង្កើតផ្លែ ១២ដង គឺ១ខែម្តង១..."


111

"ក៏នឹងឥតមានយប់ទៀតឡើយ..." វិវរណៈ ២២:៥។
បល្ល័ង្ករបស់ព្រះនិងកូនចៀមនឹងនៅក្នុង រាជធានីនៃទីក្រុងយេរូសាឡិមថ្មី។


112

(ព្រះគម្ពីរ វិវរណៈ ២២:៣)
"គ្រានោះនឹងគ្មានសេចក្តីបណ្តាសារ ទៀតឡើយ ហើយបល្ល័ង្កនៃព្រះ និងកូន ចៀម
ក៏នឹងនៅក្នុងក្រុងនោះ..."
វិវរណៈ ២២:៣។
ហើយអំណោយដ៏វិសេសវិសាលមួយ នោះ ត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរ វិវរណៈ ២១:៤:


113

(ព្រះគម្ពីរ វិវរណៈ ២១:៤)
"ព្រះទ្រង់នឹងជូតអស់ទឹកភ្នែក ពីភ្នែក គេចេញ នឹងគ្មានសេចក្តីស្លាប់ ឬសេចក្តី សោកសង្រេង


114

ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀត ឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បាន កន្លងបាត់ទៅហើយ"
វិវរណៈ ២១:៤
ប្រហែលអ្នកកំពុងតែឆ្ងល់ថា តើទីក្រុង បរិសុទ្ធនោះធំប៉ុនណាទៅ

# ២៥. ការល្អបំផុតដែលនឹងមកដល់!


115

(ព្រះគម្ពីរ វិវរណៈ ២១:១៦)

លោកយ៉ូហានបានផ្តល់យ៉ាងច្បាស់ លាស់ នូវទំហំរបស់ទីក្រុងនេះ: "ទីក្រុង នោះមានរាង៤ជ្រុង បណ្តោយនិងទទឹង ស្មើគ្នា


116

ទេវតាក៏យករង្វាស់ទៅវាស់ទីក្រុង ឃើញមាន១២ពាន់ស្តាដ" វិវរណៈ២១:១៦។


117

(មួយស្តាដ មានប្រវែងប្រហែលជា ២០១ម៉ែត្រ ដូច្នេះ១២ ០០០ស្តាដ ប្រ ហែលជា ២៤០០គីឡូម៉ែត្រជុំវិញ) គេតែងវាស់ទីក្រុងបុរាណ ពីខាងក្រៅកំផែង។

ដូច្នេះទីក្រុងនោះមានមួយជ្រុង១ ប្រវែងប្រហែលជា៦០០គីឡូម៉ែត្រ។ ហើយ ប្រហែលជាលោកអ្នកឆ្ងល់ទៀតថា តើទី ក្រុងនោះធំល្មម សម្រាប់អ្នកដែលបាន សង្គ្រោះដែរឬទេ។


118

ទីក្រុងតូក្យូមានមនុស្សរស់នៅប្រហែល ជា៣៥លាននាក់ នៅក្នុងទីក្រុងនោះ។



119

ទីក្រុងញូយ៉ក ដែលធំជាងនោះ មាន មនុស្សរស់នៅជាង២០លាននាក់។


120

ទីក្រុងសេអ៊ូល និងម៉ិកស៊ិក ក៏មាន មនុស្សជិត២០លាននាក់រស់នៅក្នុងទីក្រុង នីមួយ១ដែរ។

# ២៥. ការល្អបំផុតដែលនឹងមកដល់!



121

ទោះជាយ៉ាងនេះក៏ដោយ គណិតវិទូម្នាក់ បានប៉ាន់ប្រមាណឃើញថា ទីក្រុង យេរូសាឡិមថ្មី អាចដាក់មនុស្សបាន ពីរពាន់លាននាក់!

និយាយឱ្យខ្លី គឺមានកន្លែងគ្រប់គ្រាន់ សម្រាប់ អស់អ្នកណាដែលចង់រស់នៅទីនោះ។

ប៉ុន្តែតើមានអ្វីដែលធ្វើឱ្យអ្នកមានការរវល់ នៅកន្លងដ៏អស្ចារ្យនោះ?



122

(វីដេអូ ១៥វិនាទី)គ្មានឧក្រិដ្ឋកម្ម គ្មាន ជម្ងឺតម្កាត់ គ្មានការអត់ឃ្លាន ឬការឈឺចាប់ ឡើយ គឺមានតែសេចក្ដីសុខសាន្ត និងសេចក្ដី ស្រុះស្រួលគ្នា រៀងរហូតទៅវិញ! ស្ដាប់ ទៅយើងហាក់ដូចជាមានការងារជាច្រើន នឹងធ្វើៈ សង់ផ្ទះនៅតាមជនបទរបស់ យើង ដាំសួនច្បាររបស់យើងផ្ទាល់។


123

ព្រះយេស៊ូវ ដែលជាព្រះដ៏បង្កបង្កើត ទ្រង់គង់នៅទីនោះ ដើម្បីនឹងបើកនូវអាថ៌កំបាំងអំពីការបង្កបង្កើត។

យើងនឹងតែងតែរៀនពីការថ្មីៗរហូត។ យើងនឹងអាចធ្វើដំណើរនៅពេលណាក៏បាន ដែលយើងចង់ដើរ។


124

យើងនឹងមានពេលជាមួយនឹង មិត្តភក្ដ្រ និងអ្នកដែលយើងស្រឡាញ់។

ហើយរៀងរាល់ថ្ងៃបរិសុទ្ធ យើងនឹង សរសើរដំកើងព្រះជាអម្ចាស់ ហើយនិងច្រៀងជាមួយនឹងពួកទេវតា និងព្រះយេស៊ូវ ជាពេលដ៏ពិសេសរបស់យើង ដើម្បីនឹងប្រកបជាមួយនឹងព្រះជាអម្ចាស់របស់យើង។

មែនហើយ លោកអ្នកអាចសួរថា "តើធ្វើដូច ម្ដេចដើម្បីឱ្យយើងដឹងច្បាស់ថា យើងនឹងបានទៅទីនោះ?

ចម្លើយគឺងាយទេ។ ព្រះគម្ពីរដែលជា កូនសោមេរបស់យើងនិយាយថាៈ



125

(ព្រះគម្ពីរ កាឡាទី ៣:២៩)

"ហើយបើអ្នករាល់គ្នាជារបស់ផង ព្រះគ្រីស្ទនោះក៏ជាពូជរបស់លោកអ័ប្រាហាំ ហើយក៏ជាអ្នកគ្រងមរតក តាមសេចក្ដីសន្យាផង" កាឡាទី ៣:២៩។

២៥. ការល្អបំផុតដែលនឹងមកដល់!

# ២៥. ការល្អបំផុតដែលនឹងមកដល់!


126

និយាយម្យ៉ាងទៀត ប្រសិនបើអ្នកបាន ទទួលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់អ្នកសេចក្ដីសន្យាដែលព្រះបានប្រទានឱ្យដល់ លោកអ័ប្រាហាំ ក៏ជារបស់អ្នកដែរ។ នៅ ពេលដែលយើងសិក្សាព្រះគម្ពីរ វាជាការ ដែលគួរឱ្យចាប់អារម្មណ៍ នឹងកត់សំគាល់ថា


127

ជំពូកបីដំបូង ប្រាប់យើងអំពីការដែលព្រះ បានបង្កបង្កើតពិភពលោក និងលំនៅនៃ ស្ថានសួគ៌ សំរាប់អ័ដាមនិងអេវ៉ា។ ប៉ុន្តែ អ័ដាមនិងអេវ៉ា បានបាត់បង់វាទៅអស់ រលីង។


128

ជំពូកបីចុងក្រោយនៃព្រះគម្ពីរ ផ្ដល់នូវ ផែនការជាមុនរបស់ព្រះនៃការស្ដាបនាឡើងវិញនូវអ្វីៗដែលអ័ដាម និងអេវ៉ាបានបាត់ បង់។ ថ្ងៃស្អែកដ៏ល្អប្រសើរ គឺជាយល់សប្ដិដ៏សប្បាយបំផុតរបស់យើង នឹងក្លាយជាការ ពិត!


129

ជាច្រើនឆ្នាំកន្លងមកហើយ ទូកដឹក ចៀមមួយបានបាត់បង់នៅក្នុងអ័ព្ទ នៃ សមុទ្រខាងជើង អស់រយៈពេលបីថ្ងៃ។ ចៀមដែលនៅក្នុងទូកនោះ មិនព្រមស៊ីស្មៅ ក្រៀមនៅក្នុងទូកនោះឡើយ។ វាដើរចុះដើរ ឡើងទៅខាងៗនៃកប៉ាល់ហើយចាប់ផ្ដើម ស្រែក។

វាបន្តស្រែក បៀ បៀ បៀ។ នាយ នាវិក និងសហការី មានការងឿងឆ្ងល់ជា ខ្លាំង។ គេឆ្ងល់ថា ហេតុអ្វីបានជាចៀមចេះ តែយំ ហើយមិនព្រមស៊ីស្មៅក្រៀមដូច្នេះ?

រំពេចនោះអ័ព្ទបានរសាត់បាត់ទៅ។ ទូកនោះ ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមាត់សមុទ្រ ស្កុតឡេនដ៍ឡើយ

ចៀមបានធំក្លិនស្មៅស្រស់ ដែលលាត សន្ធឹងនៅទីវាលនៃមាត់សមុទ្រស្កុតឡេនដ៍ យ៉ាងល្អត្រកាល។ ពួកវាមិនព្រមស៊ីស្មៅ ក្រៀមជាច្រើនថ្ងៃ ដែលម្ចាស់វាខំព្យាយាដាក់ ឱ្យវាស៊ីនោះទេ។



130

(វីដេអូ ៧វិនាទី) នៅពេលដែលយើង ធំក្លិនស្ថានសួគ៌ យើងក៏ត្រូវចាត់អាទិភាព របស់យើងដែរ។ នៅពេលដែលយើងធំក្លិន ជីវិតអស់កល្ប អ្វីៗដទៃទៀត ត្រូវតែ ចាត់ទុកឱ្យនៅក្នុងលំដាប់បន្ទាប់។ យើង ចង់បានដែនដីមួយទៀតនោះយ៉ាងខ្លាំង។ យើងចង់នៅឯឆ្នេរសមុទ្រដ៏នៅអស់កល្បនោះ គឺនគរស្ថានសួគ៌។

តើលោកអ្នកនឹកស្ថានសួគ៌ឬទេ? តើ លោកអ្នកចង់នៅទីនោះឬទេ?

តើចំណង់ចិត្តរបស់លោកអ្នកចង់រស់នៅ ជាមួយនឹងព្រះគ្រីស្ទនៅក្នុងសិរីល្អរៀងរហូត ដែរឬទេ?

សូមលោកអ្នកនិយាយថា "បពិត្រ ព្រះអង្គ ទូលបង្គំចង់នៅជាមួយនឹងទ្រង់។ ទូលបង្គំចង់រស់នៅជាមួយទ្រង់យ៉ាងខ្លាំងរៀងរហូត រៀងរហូត រៀងរហូតតទៅ"

# ២៥. ការល្អបំផុតដែលនឹងមកដល់!


131

(ព្រះគម្ពីរ វិវរណៈ ២២:១៧)

ព្រះទ្រង់បានប្រទានសេចក្តីអញ្ជើញនោះ ដល់អ្នក "ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មី ពោលថា អញ្ជើញមក" វិវរណៈ ២២:១៧។


132

សូមកុំបង្អង់ឡើយ!

លោកអ្នកអាចជាចំណែកនៃថ្ងៃស្អែកដ៏ អស្ចារ្យរបស់ព្រះអម្ចាស់។

សូមយាងទ្រង់ចូលក្នុងចិត្តលោកអ្នក នោះស្ថានសួគ៌នឹងក្លាយជាផ្ទះរបស់លោកអ្នក!

២៥. ការល្អបំផុតដែលនឹងមកដល់!